# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

### គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# ការវាយតម្លៃអនុកិច្ចសន្យា គ.អ.ជ.ខ
# វិធីសាស្ត្រ សេចក្តីណែនាំ
# និង
# កម្រងបាយការណ៍វាយតម្លៃទាំង២៤ខេត្ត រាជធានី

ផ្នែកតាមដានត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ

អង្គភាពគាំទ្រកម្មវិធី នៃលេខាធិការដ្ឋាន គ.ជ.អ.ប

ខែ ធ្នូ ឆ្នាំ ២០១០

# មាតិកា


មាតិកា---------------------------------------------------------------i
សេចក្តីផ្តើម----------------------------------------------------------iii


## ផ្នែកទី១


សៀវភៅណែនាំស្តីពីការវាយតម្លៃអនុកិច្ចសន្យាគណៈកម្មាធិការប្រតិបត្តិ គ.អ.ជ ------------១
សៀវភៅណែនាំការសរសេររបាយការណ៍វាយតម្លៃ ---------------------------------៥៨
របាយការណ៍វាយតម្លៃគំរូ (ដើម្បីធ្វើតេស្ត វិធីសាស្ត្រ និង ឧបករណ៍វាយតម្លៃ) -------------១០៤


## ផ្នែកទី២


ក្របខណ្ឌការងារស្តីពីការវាយតម្លៃ (ដូចគ្នាទាំងអស់គ្រប់ខេត្ត/រាជធានី) -----------------១៣៦
ខេត្តបន្ទាយមានជ័យ: អនុកិច្ចសន្យាលេខ 01/AGR/0901-00 (GOV)
ខេត្តបាត់ដំបង: អនុកិច្ចសន្យាលេខ 02/AGR/0901-001 (GOV)
ខេត្តកំពង់ចាម: អនុកិច្ចសន្យាលេខ 03/AGR/0901-00 (NRML)
ខេត្តកំពង់ឆ្នាំង: អនុកិច្ចសន្យាលេខ 04/AGR/0902-01 (GOV)
ខេត្តកំពង់ស្ពឺ: អនុកិច្ចសន្យាលេខ 05/AGR/0901-01 (GOV)
ខេត្តកំពង់ធំ: អនុកិច្ចសន្យាលេខ 06/SOC/0901-00 (GOV)
ខេត្តកំពត: អនុកិច្ចសន្យាលេខ 07/AGR/0901-00 (GOV)
ខេត្តកណ្តាល: អនុកិច្ចសន្យាលេខ 08/ AGR/0901-00 ( GOV )
ខេត្តកោះកុង: អនុកិច្ចសន្យាលេខ 09/GEN/0901-01 (GOV)
ខេត្តក្រចេះ: អនុកិច្ចសន្យាលេខ 10/GEN/0901-00 (GOV)
ខេត្តមណ្ឌលគិរី: អនុកិច្ចសន្យាលេខ 11/AGR/0901-00 ( NRML )
រាជធានីភ្នំពេញ: អនុកិច្ចសន្យាលេខ 12/GEN/0901-00 (GOV)
ខេត្តព្រះវិហារ: អនុកិច្ចសន្យាលេខ 13/EDU/0901-00 (GOV)
ខេត្តព្រៃវែង: អនុកិច្ចសន្យាលេខ 14/SOC/0902-00 (GOV)

ខេត្តពោធិ៍សាត់: អនុកិច្ចសន្យាលេខ 15/AGR/0901-00 (NRML)
ខេត្តរតនៈគិរី: អនុកិច្ចសន្យាលេខ 16/AGR/0901-00 (NRML)
ខេត្តព្រះសីហនុ: អនុកិច្ចសន្យាលេខ 17/GEN/0901-00 (GOV)
ខេត្តសៀមរាប: អនុកិច្ចសន្យាលេខ 18/AGR/0901-00 (NRML)
ខេត្តស្ទឹងត្រែង: អនុកិច្ចសន្យាលេខ 19/AGR/0901-00 (GOV)
ខេត្តស្វាយរៀង: អនុកិច្ចសន្យាលេខ 20/GEN/0901-00 (GOV)
ខេត្តតាកែវ: អនុកិច្ចសន្យាលេខ 21/AGR/0901-00 (GOV)
ខេត្តឧត្តរមានជ័យ: អនុកិច្ចសន្យាលេខ 22/AGR/0901-00 (GOV)
ខេត្តកែប: អនុកិច្ចសន្យាលេខ 23/GEN/0901-00 (GOV)
ខេត្តប៉ៃលិន: អនុកិច្ចសន្យាលេខ 24/GEN/0901-00 (GOV)

**ផ្នែកទី៣:**

ការសង្កេតរបស់ផ្នែកទៅលើរបាយការណ៍វាយតម្លៃរាជធានី ខេត្ត ----------------------៧៨៩

# អារម្ភកថា

ក្រសួង និងមន្ទីរវិស័យដែលពាក់ពន្ធ័ជាមួយនឹងគណៈកម្មាធិការជាតិ សំរាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បានទទួលមូលនិធិពី គ.ជ.អ.ប ដើម្បីអនុវត្តនូវគម្រោងដែលទាក់ទងនឹងការគាំទ្រ វិមជ្ឈការ និងវិសហមជ្ឈការ និងសេវាកម្មនានានៅថ្នាក់ក្រោមជាតិ។ មូលនិធិទាំងនោះត្រូវបានគេស្គាល់ថាជា "អនុកិច្ចសន្យា" ហើយត្រូវបានគ្រប់គ្រង និងគាំទ្រដោយគណៈកម្មាធិការ ប្រត្តិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទ ខេត្ត/រាជធានី (គ.ប្រនៃ គ.អ.ជ.ខ)។ អនុកិច្ចសន្យាត្រូវបានកែប្រែជាថ្មីរៀងរាល់ឆ្នាំដោយមានការផ្លាស់ប្តូរតិចតួចពី១ឆ្នាំទៅ១ឆ្នាំ។ ជាទូទៅការវាយតម្លៃជាផ្លូវការ នៃអនុកិច្ចសន្យាពីពេលមុនៗ មិនត្រូវបានធ្វើឡើងទេ ដោយហេតុថាមានការខ្វះខាតនូវជំនាញ និងធនធានសំរាប់ការវាយតម្លៃ។ ហេតុដូចនេះ គេមិនបានដឹងពីភាពជាប់ពាក់ពន្ធ័ និងលទ្ធផលដែលទទួលបាននៃអនុកិច្ចសន្យាទេ។

ដើម្បីដោះស្រាយបញ្ហាខ្វះចន្លោះនេះផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំវិធីសាស្ត្រ ឧបករណ៍ និងសៀវភៅណែនាំស្តីពីការវាយតម្លៃអនុកិច្ចសន្យា ហើយបានផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីនៃផ្នែកត្រួតពិនិត្យវាយតម្លៃនិងផ្សព្វផ្សាយគោលនយោបាយ មន្ត្រីត្រួតពិនិត្យវាយតម្លៃរបស់ គ.ប្រនៃ គ.អ.ជ.ខ ហើយនិងគ្រូបង្គោលត្រួតពិនិត្យវាយតម្លៃ នៅថ្នាក់ខេត្ត/រាជធានី ទាំងអស់នៅឆ្នាំ២០១០ នេះ។ ដោយផ្អែកលើវគ្គបណ្តុះបណ្តាល និងឧបករណ៍ដែលបានប្រើប្រាស់ក្នុងវគ្គបណ្តុះបណ្តាល ព្រមទាំងមូលនិធិស្ថចស្ទើងពី គ.ជ.អ.ប គណៈកម្មាធិការប្រត្តិបត្តិនៅគ្រប់ខេត្ត/រាជធានីទាំងអស់ បានរៀបចំអោយមាននូវក្រុមការងារវាយតម្លៃអនុកិច្ចសន្យា។ បន្ទាប់មកក្រុមការងារវាយតម្លៃអនុកិច្ចសន្យាបានអនុវត្តការវាយតម្លៃ អនុកិច្ចសន្យាចំនួន១ក្នុងខេត្ត/រាជធានីរបស់ខ្លួន។ ជាលទ្ធផលអនុកិច្ចសន្យា ចំនួន២៤ ត្រូវបានវាយតម្លៃជាផ្លូវការយ៉ាងត្រឹមត្រូវ នៅក្នុងឆ្នាំ២០១០ ដោយមន្ត្រីត្រួតពិនិត្យនិងវាយតម្លៃគ្រូបង្គោលត្រួតពិនិត្យ និងវាយតម្លៃ និងមន្ត្រីបង្គោលត្រួតពិនិត្យនិងវាយតម្លៃដែលមានមូលដ្ឋាននៅក្នុងខេត្ត។

នេះគឺជាការសំរេចបានដ៏គួរអោយមោទនៈមួយ នៃការកសាងសមត្ថភាព និងការអនុវត្តផ្នែកត្រួតពិនិត្យនិងវាយតម្លៃថ្នាក់ក្រោមជាតិ។ ឥឡូវនេះ គ.ជ.អ.ប មាន ក) វិធីសាស្ត្រ ឧបករណ៍ និងសៀវភៅណែនាំការវាយតម្លៃដែលបានឆ្លងកាត់ការសាកល្បងនៅក្នុងបរិបទជាក់លាក់នៃការវាយតម្លៃអនុកិច្ចសន្យា គ.ជ.អ.ខ (សៀវភៅណែនាំនេះក៏អាច

ប្រើប្រាស់បានក្នុងការវាយតម្លៃទៅលើគម្រោងខ្នាតតូចដទៃទៀត) ខ) ក្រុមការងារវាយតម្លៃដែលបានទទួលការ-បណ្តុះបណ្តាល និងមានសក្តានុពលនៅតាមខេត្ត/រាជធានីនីមួយៗ និង គ) របាយការណ៍វាយតម្លៃទាំង ២៤ ខេត្ត/រាជធានី ។

ផ្នែកត្រួតពិនិត្យវាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.បបានធ្វើការវាយតម្លៃលើរបាយការណ៍វាយតម្លៃទាំង ២៤ខេត្ត/រាជធានី ដោយផ្អែកទៅលើគុណភាពជាទូទៅនៃរបាយការណ៍ ការគោរពតាមគោលការណ៍ក្នុងសៀវភៅណែនាំ ភាពខ្លាំងរបស់របាយការណ៍ និងចំណុចដែលត្រូវកែលំអបន្ថែម។ ជារួមរបាយការណ៍ មានពតិមានដែលត្រូវការ និងការវិភាគពេញលេញ ។ របាយការណ៍ទាំងនោះបានឆ្លុះបញ្ចាំងថាក្រុមការងារវាយតម្លៃ ភាគច្រើនយល់ច្បាស់ពីជំហានសំខាន់ៗ ដែលទាក់ទងទៅនឹងការវាយតម្លៃគម្រោងខ្នាតតូច និងគោរពតាមដំណើរការ និងឧបករណ៍ដែលបានណែនាំ។ ដូច្នេះ របាយការណ៍វាយតម្លៃជាភស្តុតាងចង្អុលបង្ហាញថាក្រុមការងារវាយតម្លៃ ខេត្ត/រាជធានី បានក្រេបជញ្ជក់ និងអនុវត្តនូវជំនាញ និងចំណេះដឹង ដែលទទួលបានពីវគ្គបណ្តុះបណ្តាលវាយតម្លៃ អនុកិច្ចសន្យាប្រកបដោយប្រសិទ្ធភាព ដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងនោះ។ ចំណុចខ្លះៗនៅក្នុងរបាយការណ៍ដែល ត្រូវការកែលម្អជាបន្តរួមមាន ជំនាញ និងសមត្ថភាពក្នុងការ : វិភាគ និងទាញនូវសេចក្តីសន្និដ្ឋានដោយផ្អែកទៅលើ ក្របខ័ណ្ឌការងារត្រួតពិនិត្យ និងវាយតម្លៃនិងសំណួរវាយតម្លៃ សរសេររបាយការណ៍សង្ខេបដែលត្រូវចំណុចហើយខ្លី ដឹកនាំលើអ្វីដែលរកឃើញនៅក្នុងការពិភាក្សាក្រុម និងបច្ចេកទេសសម្រាប់ការសម្ភាសស៊ីជម្រៅ។ មានតែការបន្ត ហ្វឹកហាត់ធ្វើការវាយតម្លៃទេ ដែលអាចធ្វើអោយជំនាញនេះកើនឡើងបាន។ ដូច្នេះសូមលេខាធិការដ្ឋាន គ.ជ.អ.ប បន្តលើកទឹកចិត្តអោយមានការវាយតម្លៃអនុកិច្ចសន្យាដោយមន្ត្រីត្រួតពិនិត្យ និងវាយតម្លៃនៅថ្នាក់ក្រោមជាតិ និងមន្ត្រីបង្គោលត្រួតពិនិត្យ និងវាយតម្លៃដោយគាំទ្រជាថវិការ និងបច្ចេកទេសក៏ដូចជាផ្តល់រង្វាន់លើកទឹកចិត្តទៅក្រុម ការងារវាយតម្លៃ។

ឥឡូវនេះរបាយការណ៍ វាយតម្លៃទាំងអស់ត្រូវបានយកមកដាក់ផ្តុំគ្នា និងបង្ហាញនៅទីនេះ ដើម្បីជាការចែករំលែករៀនសូត្រ និងឯកសារយោងទៅថ្ងៃអនាគត។

# ផ្នែកទី១

# គម្រោងពង្រឹងសមត្ថភាពដល់គ្រូបង្គោលផ្នែកត្រួតពិនិត្យ និងវាយតម្លៃ នៅថ្នាក់ក្រោមជាតិ

## សៀវភៅណែនាំស្តីពីការវាយតម្លៃអនុកិច្ចសន្យារបស់គណៈកម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ

## ផ្នែកតាមដានត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប

គាំទ្របច្ចេកទេសពីគម្រោងគាំទ្រការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈ ទីមជ្ឈការ និងវិសហមជ្ឈការ

ខែ កក្កដា ឆ្នាំ ២០១០

# មាតិកា


អក្សរកាត់ ... ៤

**ផ្នែកទី I: អំពីសៀវភៅណែនាំ** ... ៥

**ផ្នែកទី II: អំពីការវាយតម្លៃអនុកិច្ចសន្យា** ... ៦

**ផ្នែកទី III: ជំហានបន្តបន្ទាប់នៃដំណើរការវាយតម្លៃអនុកិច្ចសន្យា** ... ១២

**ក. ដំណាក់កាលរៀបចំ** ... ១២

ជំហានទី១: បង្កើត/ពិនិត្យឡើងវិញនូវក្របខណ្ឌវាយតម្លៃ ... ១២

ជំហានទី២: បង្កើតក្រុមការងារវាយតម្លៃ ... ១៤

ជំហានទី៣: កំណត់សំណួរសំខាន់ៗសម្រាប់ការវាយតម្លៃ ... ១៤

ជំហានទី៤: កំណត់ប្រភពទិន្នន័យ វិធីសាស្ត្រ និងឧបករណ៍ ដើម្បីឆ្លើយនឹងសំណួរ វាយតម្លៃ ... ១៤

ជំហានទី៥: បញ្ចប់ផែនការការងារវាយតម្លៃ ... ២០

**ខ. ដំណាក់កាលប្រមូលទិន្នន័យ** ... ២១

ជំហានទី៦: ដំណើរការប្រមូលទិន្នន័យ និងចុះមូលដ្ឋាន ... ២១

**គ. រៀបចំចងក្រង វិភាគទិន្នន័យ និងសរសេររបាយការណ៍** ... ២១

ជំហានទី៧: រៀបចំចងក្រង វិភាគទិន្នន័យ ដែលប្រមូលបាន ទៅតាមសំណួរវាយតម្លៃ និងសៀវភៅកិច្ចការ របាយការណ៍វាយតម្លៃ ... ២១

ជំហានទី៨: ការធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍ ដោយវិភាគលើការវិភាគ និងធ្វើការសង្ខេប ការវាយតម្លៃលើសំណួរវាយតម្លៃអនុកិច្ចសន្យា ... ២២

ជំហានទី៩: បង្ហាញលទ្ធផលសំខាន់ៗ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ជូនដល់អ្នកពាក់ព័ន្ធនានា ដើម្បីទទួលបានយោបល់ ... ២២

ជំហានទី១០: បញ្ចប់ និងផ្សព្វផ្សាយរបាយការណ៍វាយតម្លៃ ... ២២

**ឃ.ក្រោយការវាយតម្លៃ** ... ២២

ជំហានទី១១: សកម្មភាពក្រោយការវាយតម្លៃៈ ក្រុមការងារវាយតម្លៃធ្វើការឆ្លុះបញ្ចាំងលើបទពិសោធន៍ និងការរៀនសូត្រ ... ២២

ជំហានទី១២: តាមដានការអនុវត្តអនុសាសន៍ដែលបានពីការវាយតម្លៃ ... ២៣

**ផ្នែកទី IV: ឧបករណ៍ ទម្រង់ និងគន្លឹះសម្រាប់ការវាយតម្លៃអនុកិច្ចសន្យា** ... ២៤

១ : នីតិវិធីក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យា ... ២៤

២ : ការណែនាំសម្រាប់សម្ភាសន៍ស៊ីជម្រៅសម្រាប់អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា ... ២៦

៣ : ការណែនាំការសម្ភាសន៍ស៊ីជម្រៅជាមួយក្រុមអ្នកពាក់ព័ន្ធ ... ៣១

៤ : ការណែនាំការពិភាក្សាក្រុមចំពោះអ្នកទទួលផលផ្នែកបណ្តុះបណ្តាល/អប់រំ...................................... ៣៣
៥ : ការសម្ភាសន៍ (មិនតាមកម្រងសំណួរ) អ្នកមិនបានទទួលផលក្នុងពេលចុះមូលដ្ឋាន.............................. ៣៩
៦ : គំរូករណីសិក្សា និងការណែនាំ អ្នកទទួលផលម្នាក់រៀបរាប់អំពីស្ថានភាព "មុន" និង "ក្រោយ" ការអនុវត្តគម្រោង...................................................................................................... ៤១
៧ : គំរូប្រអប់សម្រាប់ "ការដកស្រង់សំដី" នៃអ្នកទទួលផលដែលត្រូវបានសម្ភាសន៍................................. ៤៥
៨ : បញ្ជីដែលពាក់ព័ន្ធការវាយតម្លៃ និងឯកសារយោង "ត្រូវតែអាន"..................................................... ៤៦
៩ : ទស្សនាទានសំខាន់ៗក្នុងការវាយតម្លៃអនុកិច្ចសន្យា ការប្រមូល និងការវិភាគទិន្នន័យ......................... ៤៧
១០ : គន្លឹះក្នុងការសរសេររបាយការណ៍ប្រកបដោយប្រសិទ្ធភាព.............................................................. ៥៦

# អក្សរកាត់

| | |
|---|---|
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **គ.ប្រ** | គណៈកម្មាធិការប្រត្តិបត្តិ |
| **គ.អ.ជ.ខ** | គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត |
| **NCD** | ប្រពន្ធ័ទិន្នន័យគ្រប់គ្រងកិច្ចសន្យា |

# ផ្នែកទី I : អំពីសៀវភៅណែនាំ

សៀវភៅណែនាំនេះ មានគោលបំណងណែនាំអំពីការវាយតម្លៃអនុកិច្ចសន្យារវាងមន្ទីរវិស័យ និង គណៈកម្មាធិការប្រតិបត្តិនៃ គ.អ.ជ.ខ។ ជាពិសេស សៀវភៅណែនាំនេះ គឺសម្រាប់ជួយក្នុងការវាយតម្លៃ បញ្ចប់កិច្ចសន្យា ដូចមាននៅ ក្នុងជំហានទី១០ នៃវដ្តរបស់កិច្ចសន្យា នៅក្នុងសៀវភៅណែនាំស្តីពីប្រពន្ធ័កិច្ចសន្យា។ ការវាយតម្លៃអនុកិច្ចសន្យាគ្រប ដណ្តប់លើឯកសារអនុកិច្ចសន្យាដែលបានឯកភាព (ផ្នែកទី១ ផ្នែកទី២ និងផ្នែកទី៣) របាយការណ៍រីកចំរើននានា និង ឯកសារពាក់ពន្ធ័នានា រួមមានរបាយការណ៍បញ្ចប់អនុកិច្ចសន្យាផងដែរ។ សៀវភៅណែនាំនេះ ថែងអំពី **"របៀបនៃការ ធ្វើ"** និងជំហាននីមួយៗ នៃដំណើរការវាយតម្លៃបញ្ចប់នៃអនុកិច្ចសន្យា។ លើសពីនេះទៀត សៀវភៅនេះ ក៏បរិយាយអំពី វិធីសាស្រ្តសំខាន់ៗ ឧបករណ៍នានា រួមបញ្ចូលទាំងសៀវភៅកិច្ចការស្តីអំពីការសរសេររបាយការណ៍វាយតម្លៃផងដែរ។

សៀវភៅណែនាំនេះ គឺសម្រាប់អ្នកវាយតម្លៃអនុកិច្ចសន្យា ជាពិសេសសម្រាប់មន្រ្តីត្រួតពិនិត្យ និងវាយតម្លៃនៃ ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល និងភ្នាក់ងារអនុវត្តអនុកិច្ចសន្យា។ ប៉ុន្តែសៀវភៅណែនាំនេះ ក៏អាចប្រើប្រាស់ដោយ ភ្នាក់ងារដ៏ទៃទៀតផងដែរ ដូចជាអ្នកគ្រប់គ្រងគម្រោង និងមន្រ្តីត្រួតពិនិត្យ និងវាយតម្លៃ ដែលចាប់អារម្មណ៍ចង់ការធ្វើ ការវាយតម្លៃគម្រោងអភិវឌ្ឍន៏ខ្នាតតូចដោយខ្លួនឯង។

អ្នកវាយតម្លៃ គួរអនុវត្តតាមសៀវភៅណែនាំ និងប្រើប្រាស់ឧបករណ៍ និងទម្រង់គំរូ ដើម្បីធ្វើការវាយតម្លៃអនុ កិច្ចសន្យា។ នៅពេលដែលអ្នកមិនច្បាស់ ហើយមានសំណួរ ឬចម្ងល់ សូមពិភាក្សាជាមួយនឹងទីប្រឹក្សាត្រួតពិនិត្យ និងវាយតម្លៃជាមុនសិន ហើយបន្ទាប់មកអ្នកអាចពិភាក្សា ជាមួយនឹងគ្រូបង្គោលថ្នាក់រាជធានី ខេត្ត។ បើសិនជាអ្នកនៅតែមិនច្បាស់ សូមពិភាក្សាជាមួយនឹងផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប នៅភ្នំពេញ។

# ផ្នែកទី II : អំពីការវាយតម្លៃអនុកិច្ចសន្យា

## ការវាយតម្លៃអនុកិច្ចសន្យារវាងមន្ទីរវិស័យ និងគណៈកម្មាធិការប្រតិបត្តិ នៃគ.អ.ជ.ខ :

នៅក្នុងបរិបទ គ.ជ.អ.ប និងគណៈកម្មាធិការប្រតិបត្តិនៃ គ.ជ.អ.ខ នៅពេលដែលគម្រោងណាមួយរួមចំណែក ដល់ផែនការអភិវឌ្ឍន៍ និងវិនិយោគខេត្ត ក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ហើយត្រូវបានឧបត្ថម្ភគាំទ្រដោយ គ.ជ.អ.ប តាមរយៈគណៈកម្មាធិការប្រតិបត្តិនៃ គ.ជ.អ.ខ គម្រោងនោះត្រូវបានគេហៅថាជា **"អនុកិច្ចសន្យា"**។ ភ្នាក់ងារអនុវត្តគម្រោង ដែលជាមន្ទីរវិស័យ បានចុះកិច្ចសន្យាព្រមព្រៀងជាមួយនឹង គណៈកម្មាធិការប្រតិបត្តិនៃ គ.អ.ជ.ខ ដើម្បីអនុវត្តគម្រោង ( អនុកិច្ចសន្យា )។ ឯកសារអនុកិច្ចសន្យា ត្រូវបានរៀបចំដោយប្រើប្រាស់កម្មវិធីប្រព័ន្ធ ទិន្នន័យគ្រប់គ្រងកិច្ចសន្យា ហើយមាន៣ផ្នែកគឺៈ ផ្នែកទី១: បរិយាយអំពីកិច្ចសន្យាសង្ខេប ផ្នែកទី២:បរិយាយអំពី លក្ខណៈនៃអនុកិច្ចសន្យា និងផ្នែកទី៣ :អំពីការពណ៌នាពីកិច្ចសន្យា/ទម្រង់បែបបទស្នើសុំ។

នាពេលបច្ចុប្បន្ននេះ ពុំទាន់មានការវាយតម្លៃអនុកិច្ចសន្យាជាផ្លូវការនៅឡើយ។ មានមូលហេតុជាច្រើនដែលធ្វើឱ្យខកខានក្នុងការធ្វើការវាយតម្លៃអនុកិច្ចសន្យា។ ប៉ុន្តែលេខាធិការដ្ឋាន គ.ជ.អ.ប យល់ថាការវាយតម្លៃអនុកិច្ចសន្យា ពិតជាមានសារៈសំខាន់ ក្នុងការកែលំអអនុកិច្ចសន្យា និងអត្ថប្រយោជន៍ទទួលបាននាពេលអនាគតសម្រាប់ការកែលំអ អភិបាលកិច្ចមូលដ្ឋាន។ ដូច្នេះ ផ្នែកតាមដានត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំសៀវភៅណែនាំនេះឡើង ដើម្បីឱ្យគណៈកម្មាធិការប្រតិបត្តិនៃ គ.ជ.អ.ខ មានលទ្ធភាពក្នុងការវាយ តម្លៃអនុកិច្ចសន្យា។ សៀវភៅណែនាំនេះ ក៏អាចត្រូវបានប្រើប្រាស់ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទើបនឹងកកើតនា ពេលថ្មីៗកន្លងមកផងដែរ។

យើងមិនអាចវាយតម្លៃផលប៉ះពាល់របស់អនុកិច្ចសន្យាទៅលើ "ការកាត់បន្ថយភាពក្រីក្រ" ដែលជាគោលដៅ របស់អនុកិច្ចសន្យា និង "អត្ថប្រយោជន៍" ជាច្រើននៅក្នុង ចំណុច ខ នៃផ្នែកទី ៣ ទេ។ ប៉ុន្តែយើងអាចវាយតម្លៃទៅលើ "ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា" លទ្ធផលដែលទទួលបានធៀបទៅនឹងផែនការ អត្ថប្រយោជន៍ទទួលបានភ្លាមៗ ដែល បានមកពីលទ្ធផល និង"ទិសដៅបន្ទាន់"ខ្លះៗ។ សន្មតថាឯកសារផ្នែកទី៣ នៃអនុកិច្ចសន្យាពេញលេញ ហើយមានទិន្នន័យ ដែលត្រូវការដូចជារបាយការណ៍រីកចំរើននៃអនុកិច្ចសន្យា និងឯកសារពាក់ពន្ធ័ដទៃទៀតនោះ ដំណើរការវាយតម្លៃ នឹងអាចប្រព្រឹត្តទៅបាន។

ការវាយតម្លៃអនុកិច្ចសន្យា គួរត្រូវបានអនុវត្តនៅក្នុងកំឡុងខែកញ្ញា ដល់ខែតុលា ឆ្នាំ២០១០។ ជារួមចាប់ពីក្នុង កំឡុងត្រីមាសទី ២ និងទី៣ នៃឆ្នាំផែនការសកម្មភាព និងថវិកា។ ប្រភេទកិច្ចសន្យាខាងក្រោម ត្រូវបានណែនាំសម្រាប់ ការវាយតម្លៃអនុកិច្ចសន្យាឆ្នាំ ២០១០ (សូមជ្រើសរើសកិច្ចសន្យាយ៉ាងតិចមួយសម្រាប់ធ្វើការ វាយតម្លៃ)៖

- ❖ អនុកិច្ចសន្យាជាមួយនឹងមន្ទីរកសិកម្ម ឆ្នាំ២០០៨ ឬ ២០០៩ (វិស័យកសិកម្ម) ឬ
- ❖ អនុកិច្ចសន្យាជាមួយនឹងមន្ទីរកិច្ចការនារី ឆ្នាំ២០០៨ ឬ ២០០៩ (វិស័យយេនឌ័រ)

ប្រសិនបើគ្មានអនុកិច្ចសន្យាប្រភេទដូចខាងលើទេ សូមពិចារណាជ្រើសរើសអនុកិច្ចសន្យា ជាមួយនឹង មន្ទីរអប់រំ យុវជន និងកីឡា (វិស័យអប់រំ)ឆ្នាំ ២០០៨ ឬ ២០០៩ សម្រាប់ការវាយតម្លៃជំនួសវិញ ដោយពិគ្រោះ ជាមួយនឹងប្រធាន ផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងទីប្រឹក្សាត្រួតពិនិត្យ វាយតម្លៃ និងវិស័យ។ ដោយសារពេលវេលា និង ធនធានមនុស្សមានកំណត់ ប្រហែលជាមិនអាចវាយតម្លៃគ្រប់លទ្ធផល និងសកម្មភាព នៅក្នុងអនុកិច្ចសន្យាទាំងមូលបានឡើយ។ សូមជ្រើសរើសយកសកម្មភាព និងលទ្ធផលដែលសំខាន់បំផុត មកធ្វើការ វាយតម្លៃលំអិត។ ការសម្ភាសន៍ស៊ី ជម្រៅ ក្រុមពិភាក្សា និងករណីសិក្សា គួរត្រូវបានប្រើប្រាស់ ដើម្បីវាយតម្លៃ សកម្មភាព និងលទ្ធផល ដែលបានជ្រើសរើស ឱ្យបានលំអិត។ ក្រុមការងារវាយតម្លៃ គួរតែវាយតម្លៃសកម្មភាព និង លទ្ធផលដ៏ទៃទៀត ឱ្យបានលំអិតតាមដែលអាចធ្វើ បានផងដែរ។

**<u>ការវាយតម្លៃអនុកិច្ចសន្យាដោយគណៈកម្មាធិការប្រតិបត្តិនៃគ.អ.ជ.ខ ឆ្នាំ ២០១០៖</u>**

ជាផ្នែកមួយនៃគំនិតផ្តួចផ្តើមពង្រឹងសមត្ថភាពផ្នែកត្រួតពិនិត្យ និងវាយតម្លៃនៅថ្នាក់ក្រោមជាតិរបស់ផ្នែក ត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប គ្រប់មន្ត្រីត្រួតពិនិត្យ និងវាយ តម្លៃនៃផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល និងគ្រប់មន្ត្រីបង្គោលត្រួតពិនិត្យ និងវាយតម្លៃ នៃមន្ទីរវិស័យ បានទទួលការ បណ្តុះបណ្តាលជំនាញត្រួតពិនិត្យ និងវាយតម្លៃ រួមទាំងការបណ្តុះបណ្តាល ដែលទាក់ទិន នឹងទស្សនវិស័យក្នុងការវាយតម្លៃ និងវិធីសាស្ត្រនានា ជាក់លាក់ទៅលើអនុកិច្ចសន្យា។ ការសិក្សាដោយការអនុវត្ត នូវការវាយតម្លៃអនុកិច្ចសន្យា នឹងជួយ ពង្រឹងដល់ចំណេះដឹងត្រួតពិនិត្យ និងវាយតម្លៃ ដែលពួកគេទទួលបាន ពីវគ្គបណ្តុះបណ្តាល ក៏ដូចជាជំនាញបច្ចេកទេស សមត្ថភាព និងទំនុកចិត្តរបស់ពួកគេក្នុងការវាយតម្លៃគម្រោង។

**<u>អ្នកចូលរួមក្នុងការវាយតម្លៃ</u>** ៖ ការវាយតម្លៃអនុកិច្ចសន្យា តម្រូវឱ្យមានការចូលរួមយ៉ាងសកម្មពីភ្នាក់ងារសំខាន់ៗ មន្ត្រី និងអ្នកដែលទាក់ទិនទៅនឹងអនុកិច្ចសន្យាដូចជា៖

- អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា
- ភ្នាក់ងារ/មន្ទីរអនុវត្តអនុកិច្ចសន្យា
- ក្រុមការងារវាយតម្លៃ
- មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃនៃផ្នែករដ្ឋបាលនិងគ្រប់គ្រងកិច្ចសន្យា របស់គណៈកម្មាធិការប្រតិបត្តិនៃ គ.អ.ជ.ខ
- អ្នកទទួលផល (ផ្ទាល់ និងមិនផ្ទាល់) និង
- អ្នកពាក់ពន្ធ័សំខាន់ៗដទៃទៀត

## សង្វាក់លទ្ធផល និងអ្វីដែលអាចវាយតម្លៃបាន និងមិនអាចវាយតម្លៃបាន

**លទ្ធផល**

| | | | | | |
|---|---|---|---|---|---|
| អត្ថប្រយោជន៍រយៈពេលវែង/ផលប៉ះពាល់ *កាត់បន្ថយភាពក្រីក្រ* | *មិនអាចវាយតម្លៃបាន* | | | | |
| អត្ថប្រយោជន៍រយៈពេលមធ្យមៈ (វិមជ្ឈការ និងវិសហមជ្ឈការ អភិបាលកិច្ចល្អ) | *ប្រហែលមិនអាចវាយតម្លៃបាន* | | | | |
| អត្ថប្រយោជន៍បឋមៈ (បង្កើនឡើង, បន្ថយចុះ) | *បាទ/ចាស អាចវាយតម្លៃបាន ទៅលើលទ្ធផលនៅស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា ចំនុច គ ផ្នែកទី៣ (សូមមើលផ្នែក ២.២ នៃសំណួរ វាយតម្លៃលេខ៣ នៅក្នុងសៀវភៅ កិច្ចការ ការសរសេររបាយការណ៍)* | *បាទ/ចាស អាចវាយតម្លៃបានទៅលើលទ្ធផលនៅទិសដៅបន្ទាន់ នៃអនុកិច្ចសន្យា ចំនុច គ ផ្នែកទី៣ (សូមមើលផ្នែក ២.៣ នៃសំណួរ វាយតម្លៃលេខ៣ នៅក្នុងសៀវភៅ កិច្ចការ ការសរសេររបាយការណ៍)* | | | |
| លទ្ធផលៈ(សូចនាករដែលអាចរាប់បានរបស់សេវាកម្ម/ផលិតផលគម្រោង) | *(សូមមើលផ្នែក ២.១នៃសំណួរវាយតម្លៃ លេខ១ នៅក្នុង សៀវភៅកិច្ចការ ការសរសេររបាយការណ៍)* | | | | |
| សកម្មភាព | | | | | |

## បញ្ជីអ្នកដែលគួរចូលរួមនៅក្នុងការវាយតម្លៃ និងអ្នកផ្តល់ពត័មានសំខាន់ៗតាមវិធីសាស្រ្តនីមួយៗ

| ល.រ | ផ្តល់ពត័មានសំខាន់/ អ្នកចូលរួមវាយតម្លៃ | ចំនួនតិចបំផុត | ធាតុចូល/ឧបករណ៍ទាញយកទិន្នន័យ |
|---|---|---|---|
| ១ | អ្នករៀបចំ/សរសេរផ្នែកទី៣នៃអនុកិច្ចសន្យា | ១-២ | សម្ភាសន៍ស៊ីជម្រៅ |
| ២ | អ្នកគ្រប់គ្រង របស់ភ្នាក់ងារអនុវត្ត និងមន្រ្តីបង្គោល ត្រួតពិនិត្យ និងវាយតម្លៃ ដែលទទួលខុសត្រូវ | ២ | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | អ្នកទទួលផលផ្ទាល់ (ឧទាហរណ៍: អ្នកដែលទទួលវគ្គបណ្តុះបណ្តាលពីយេនឌ័រ កសិករដែលទទួលបានទិន្នផលច្រើនជាងមុន ដោយសារការប្រើប្រាស់ចំណេះដឹងកសិកម្មថ្មី/ការអនុវត្តថ្មី) | ១ | សម្ភាសន៍ស៊ីជម្រៅ |
| ៤ | អ្នកទទួលផលផ្ទាល់ (ឧទាហរណ៍: អ្នកដែលទទួលវគ្គបណ្តុះបណ្តាលពីយេនឌ័រ កសិករដែលទទួលបានទិន្នផលច្រើនជាងមុន ដោយសារការប្រើប្រាស់ចំណេះដឹងថ្មី/ការអនុវត្តថ្មី) | ៦-៨ | ការពិភាក្សាជាក្រុមក្នុងកំឡុងពេលចុះទស្សនកិច្ចនៅមូលដ្ឋាន |
| ៥ | អ្នកមិនបានទទួលការបណ្តុះបណ្តាល/ផលប្រយោជន៍ (ឧទាហរណ៍: អ្នកដែលមិនបានទទួលវគ្គបណ្តុះបណ្តាលពីយេនឌ័រ កសិករដែលមិនបានអនុវត្តបច្ចេកទេសថ្មី) | ១ | សម្ភាសន៍ស៊ីជម្រៅ /ករណីសិក្សា |
| ៦ | ភាគីពាក់ពន្ធ័ដ៏ទៃទៀតដែលសំខាន់<br>-ទីប្រឹក្សាត្រួតពិនិត្យ វាយតម្លៃ និងវិស័យ/ ប្រធានទីប្រឹក្សា ជាតំណាងអោយដៃគូរអភិវឌ្ឍន៍<br>- ប្រធានភូមិ/ក្រុមប្រឹក្សាឃុំ/ ស្មៀនឃុំ ដែលបានដឹងឮពីសកម្មភាពគម្រោង និងលទ្ធផលគម្រោង<br>- មន្រ្តីបង្គោលយេនឌ័រ និងគ្រប់គ្រងធនធានធម្មជាតិ | ២ | ការពិភាក្សាជាក្រុម/ សម្ភាសន៍ស៊ីជម្រៅ |

<u>**តួនាទីរបស់គណៈកម្មាធិការប្រតិបត្តិនៃ គ.អ.ជ.ខ**</u> **:** ផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យា មានភារកិច្ចផ្តួចផ្តើម និងគ្រប់គ្រង/ចាត់ចែងការវាយតម្លៃ ដោយមានការណែនាំពីទីប្រឹក្សាត្រួតពិនិត្យ វាយតម្លៃ និងវិស័យ និងការគាំទ្រពីគ្រូបង្គោល ថ្នាក់ក្រោមជាតិ ។

**ក្រុមការងារវាយតម្លៃ :**

- មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ របស់ផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យា ដែលជាគ្រូបង្គោលថ្នាក់ក្រោមជាតិ ជា អ្នកសម្របសម្រួល
- គ្រូបង្គោលថ្នាក់ក្រោមជាតិម្នាក់ទៀត ជាសហអ្នកសម្របសម្រួល
- មន្ត្រីបង្គោលត្រួតពិនិត្យនិងវាយតម្លៃនៃមន្ទីរវិស័យ

**តួនាទីរបស់ទីប្រឹក្សាត្រួតពិនិត្យវាយតម្លៃ និងវិស័យ** : គឺផ្តល់ការគាំទ្របច្ចេកទេសដល់ក្រុមការងារវាយតម្លៃ និងការងារ របស់ក្រុមការងារ ដូចដែលមានចែងនៅក្នុងសេចក្តីណែនាំ និងពិនិត្យឡើងវិញនូវផែនការប្រមូលទិន្នន័យពីមូលដ្ឋាន និងការរៀបចំសេចក្តីព្រាងរបាយការណ៍។

**ថវិកាសម្រាប់វាយតម្លៃ** : មិនគ្រប់ដណ្តប់លើពេលវេលា និងការខិតខំដលបានចំណាយដើម្បីធ្វើការវាយតម្លៃរបស់ក្រុមការងារវាយតម្លៃនោះទេ។ ថវិកាចំនួន ៣០០ ដុល្លា (១៥០ ដុល្លាសម្រាប់អនុកិច្ចសន្យាមួយ x អនុកិច្ចសន្យា២) ជាថវិកា ដែលបម្រុងទុកសម្រាប់ចំណាយផ្ទាល់នៅក្រោមខ្ទង់ថវិការបស់គណៈកម្មាធិការប្រតិបត្តិ នៃគ.អ.ជ.ខ។ ថ្នាក់ជាតិនឹងធ្វើ ការណែនាំអំពីខ្ទង់ថវិកាលំអិតដល់គណៈកម្មាធិការប្រតិបត្តិសម្រាប់ថវិកាការវាយតម្លៃនេះ។

សម្រាប់គណៈកម្មាធិការប្រតិបត្តិ នៃ គ.អ.ជ.ខ ធ្វើការវាយតម្លៃទៅលើអនុកិច្ចសន្យា សៀវភៅណែនាំនេះផ្តល់ជូននូវ:

- ក្របខណ្ឌវាយតម្លៃ
- សំណួរវាយតម្លៃដែលត្រូវឆ្លើយ និងប្រភពទិន្នន័យ ព្រមទាំងឧបករណ៍ផ្សេងទៀតដែលពាក់ពន្ធ័
- ឧបករណ៍ និងទម្រង់បែបបទវាយតម្លៃ
- សៀវភៅកិច្ចការសម្រាប់ធ្វើការវាយតម្លៃ និងសរសេររបាយការណ៍វាយតម្លៃ

**ផលប្រយោជន៍ខ្លះៗនៃការធ្វើការវាយតម្លៃអនុកិច្ចសន្យា:**

១) សមត្ថភាពវាយតម្លៃគម្រោងរបស់ថ្នាក់ក្រោមជាតិ: មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ របស់ផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យា និងមន្ត្រីបង្គោលត្រួតពិនិត្យ និងវាយតម្លៃរបស់មន្ទីរវិស័យ នឹងមានជំនាញបច្ចេកទេស និងទំនុកចិត្តសមស្រប សម្រាប់ការវាយតម្លៃអនុកិច្ចសន្យានៅក្នុងរាជធានី ខេត្តរបស់ខ្លួន។

២) កែលំអការរៀបចំ និងសរសេរអនុកិច្ចសន្យា និងការងារត្រួតពិនិត្យ និងវាយតម្លៃ: គណៈកម្មាធិការប្រតិបត្តិនៃ គ.អ.ជ.ខ និងមន្ទីរវិស័យដែលទទួលអនុវត្តកិច្ចសន្យា នឹងអាចកែលំអការរៀបចំគុណភាព និងភាពទាក់ទង នៃអនុកិច្ចសន្យានាពេលអនាគត ដោយបញ្ចូលនូវការរកឃើញ និងមេរៀនសំខាន់ៗបានមកពីការវាយតម្លៃ។

៣) កែលំអលទ្ធផល និងផលប្រយោជន៍ពីអនុកិច្ចសន្យា: បន្ទាប់ពីមានការកែលំអដូចចំណុចទី១ និងទី២ ខាងលើ យើងរំពឹងទុកថានឹងទទួលបានផលប្រយោជន៍ និងលទ្ធផលល្អប្រសើរជាងមុនពីអនុកិច្ចសន្យា។

# ផ្នែកទី III : ជំហានបន្តបន្ទាប់នៃដំណើរការវាយតម្លៃអនុកិច្ចសន្យា

## ក. ដំណាក់កាលរៀបចំ

### ជំហានទី ១ : បង្កើត/ពិនិត្យឡើងវិញនូវក្របខណ្ឌវាយតម្លៃ

**កំណត់សំគាល់ :** ក្របខណ្ឌវាយតម្លៃគំរូជាស្តង់ដារ ត្រូវបានផ្តល់ដើម្បីជាការណែនាំដូចខាងក្រោម :

### 1.សាវតា

រៀងរាល់ឆ្នាំ គ.ជ.អ.បបានផ្តល់ថវិកាតាមរយៈគណៈកម្មាធិការប្រត្តិបត្តិនៃ គ.អ.ជ.ខ ទៅដល់មន្ទីរវិស័យដើម្បី អនុវត្តគម្រោង និងសកម្មភាពគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ មានមូលហេតុជាច្រើនដែលធ្វើឱ្យខកខាន ក្នុងការវាយតម្លៃអនុកិច្ចសន្យាជាប្រពន្ធ័នាពេលកន្លងមក។ ការវាយតម្លៃអនុកិច្ចសន្យា ពិតជាមានសារៈសំខាន់ក្នុងការកែ លំអអនុកិច្ចសន្យា និងកែលំអការវិនិយោគ និងសេវាកម្ម តាមរយៈអនុកិច្ចសន្យាមួយដែលមានភាពល្អប្រសើរឡើង។ ហេតុនេះ គណៈកម្មាធិការប្រតិបត្តិនៃ គ.ជ.អ.ខ មានបំណងវាយតម្លៃ អនុកិច្ចសន្យាចំនួន ២ ដែលបានបញ្ចប់រួចរាល់ ដោយមានការបណ្តុះបណ្តាល និងថវិកាគាំទ្រ ពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប នៅក្នុងឆ្នាំផែនការសកម្មភាព និងថវិកា ២០១០នេះ។

### 2.គោលដៅនិងទំហំនៃការវាយតម្លៃអនុកិច្ចសន្យា

គោលដៅ គឺដើម្បីពង្រឹងនូវសមត្ថភាពវាយតម្លៃរបស់មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ នៃគណៈកម្មាធិការប្រតិបត្តិ ដោយអនុវត្តន៍ផ្ទាល់ នូវការវាយតម្លៃអនុកិច្ចសន្យាចំនួន២។ ដូច្នេះទំហំនៃការវាយតម្លៃនេះគឺនៅក្នុងដែនអនុកិច្ចសន្យា ដែលត្រូវបានជ្រើសរើសដើម្បីវាយតម្លៃ និងដំណើរការរៀនសូត្រនានា ដែលទាក់ទងនៅក្នុងដំណើរការនេះ។

### 3. គោលបំណងនៃការវាយតម្លៃ

គោលបំណង នៃការវាយតម្លៃនេះ គឺ :

១. ដើម្បីទាញយក កត់ត្រា និងវិភាគនូវអ្វីដែលអនុកិច្ចសន្យាសម្រេចបាន និងចំណុចខ្សោយរបស់អនុកិច្ចសន្យាទាក់ទិនទៅនឹងលទ្ធផល ទិសដៅបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា ហើយក៏ដើម្បីកត់ត្រានូវចំណុចរៀនសូត្រដែលបានមកពីការវាយតម្លៃ និងចំនុចដែលត្រូវកែលំអក្នុងពេលអនាគត ជាប្រពន្ធ័។

២. ដើម្បីពង្រឹងនូវចំនេះដឹង និងចំនេះធ្វើ របស់មន្ត្រីគណៈកម្មាធិការប្រត្តិបត្តិ នៃគ.អ.ជ.ខ ក្នុងការវាយតម្លៃអនុកិច្ចសន្យា នៅថ្នាក់ក្រោមជាតិ។

អ្នកវាយតម្លៃ ត្រូវស្វែងរកចម្លើយទៅនឹងសំណួរវាយតម្លៃដូចខាងក្រោម ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការវាយតម្លៃអនុកិច្ចសន្យា ៖

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អកម្រិតណា ? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចគោលបំនងបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំការអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលំអអនុកិច្ចសន្យាក្នុងពេលអនាគត ?

## 4. លទ្ធផលរំពឹងទុក

របាយការណ៍វាយតម្លៃជាមួយនឹងចម្លើយតបយ៉ាងពេញលេញទៅនឹងសំណួរវាយតម្លៃខាងលើ ដោយមានឯកសារពាក់ពន្ធ័ផ្សេងទៀតជាភាសាខ្មែរ ។

## 5. ការអនុវត្តការវាយតម្លៃ និងការរៀបចំ/គ្រប់គ្រងៈ

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃផ្នែកគ្រប់គ្រងអនុកិច្ចសន្យា នឹងត្រូវអនុវត្តការវាយតម្លៃ ដោយមានធនធាន/ធាតុចូលពីភ្នាក់ងារអនុវត្តន៍ អ្នកទទួលផល និងភាគីពាក់ពន្ធ័ ។ ដំណើរការនេះនឹងត្រូវទទួលការគាំទ្រជាបច្ចេកទេស ដោយគ្រូបង្គោលថ្នាក់ក្រោមជាតិ និងទីប្រឹក្សាត្រួតពិនិត្យ និងវាយតម្លៃថ្នាក់ក្រោមជាតិ ។

## 6. ពេលវេលា

មិនលើសពី៧ថ្ងៃ នៅក្នុងកំឡុងខែកញ្ញា និងតុលា ឆ្នាំ២០១០ ។

## 7. ថវិកា

ពេលវេលារបស់ក្រុមការងារ និងធនធាន/ធាតុចូលពីអ្នកចូលរួម ក្នុងដំណើរការវាយតម្លៃជាចំណាយមិនផ្ទាល់ ។ ថវិកាចំនួន១៥០ដុល្លាសម្រាប់ចំណាយលើការវាយតម្លៃលើអនុកិច្ចសន្យាមួយ ត្រូវបានបម្រុងទុកសម្រាប់ការចំណាយ ការងារនៅមូលដ្ឋាន និងចំណាយផ្ទាល់ដទៃទៀត ។

**ជំហានទី ២ : បង្កើតក្រុមការងារវាយតម្លៃ**

ក្រុមការងារវាយតម្លៃអនុកិច្ចសន្យា គួរតែមានសមាសភាពដូចខាងក្រោម :

- ❖ មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យា ដែលជាគ្រូបង្គោលឆ្នើម (អ្នកសម្របសម្រួល)
- ❖ គ្រូបង្គោលត្រួតពិនិត្យ និងវាយតម្លៃ ដែលមិនមែនជាមន្ត្រីផ្នែកគ្រប់គ្រងកិច្ចសន្យា (សហអ្នកសម្របសម្រួល)
- ❖ មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យា ដែលមិនមែនជាគ្រូបង្គោលឆ្នើម (សមាជិក)
- ❖ មន្ត្រីបង្គោលត្រួតពិនិត្យនិងវាយតម្លៃនៃមន្ទីរវិស័យ

**ជំហានទី ៣ : កំណត់សំណួរសំខាន់ៗសម្រាប់ការវាយតម្លៃ**

ផ្អែកលើក្របខ័ណ្ឌការងារវាយតម្លៃ (ToR) សំណួរដែលបង្កើតឡើងត្រូវទទួលបានចម្លើយដែលឆ្លើយតបទៅនឹងគោលបំណងនៅក្នុងក្របខ័ណ្ឌការងារវាយតម្លៃ។ សំណួរវាយតម្លៃ ជួយក្នុងការកំណត់វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើក្នុងការស្វែងរកចម្លើយ។ សំណួរវាយតម្លៃសំខាន់ៗសម្រាប់ការវាយតម្លៃអនុកិច្ចសន្យា ត្រូវតែបង្កើតជាមុនដើម្បីជាមគ្គុទ្ទេសក៍សម្រាប់ធ្វើការវាយតម្លៃ។

**សំណួរវាយតម្លៃ ដែលត្រូវប្រើរួមមាន :**

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចគោលបំនងបន្ទាន់របស់ខ្លួនបានកម្រិតណា? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំការអនុវត្ត និងការគ្រប់គ្រង?

៥- តើមានសេចក្តីសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលំអអនុកិច្ចសន្យាក្នុងពេលអនាគត?

**ជំហានទី ៤ : កំណត់ប្រភពទិន្នន័យ វិធីសាស្ត្រ និងឧបករណ៍ ដើម្បីឆ្លើយនឹងសំណួរវាយតម្លៃ:**

មានប្រភពទិន្នន័យសំខាន់ចំនួន ៣ សម្រាប់ការវាយតម្លៃអនុកិច្ចសន្យា :

ក- ឯកសារអនុកិច្ចសន្យា រួមមានរបាយការណ៍ និងឯកសារផ្សេងៗ

ខ- ក្រុមអ្នកពាក់ព័ន្ធ រួមមានមន្ត្រី អ្នកទទួលផល និងសហគមន៍ដែលពាក់ព័ន្ធ

គ- សញ្ញា សូចនាករ និងភាពជាក់ស្តែងនៃអនុកិច្ចសន្យា និងលទ្ធផលអនុកិច្ចសន្យា

វិធីសាស្ត្រ និងឧបករណ៍ប្រមូលទិន្នន័យ អាស្រ័យលើប្រភពទិន្នន័យដែលត្រូវការ។ ដូច្នេះឧបករណ៍ ប្រមូលទិន្នន័យត្រូវតែ តម្រូវឱ្យត្រូវនឹងប្រភពទិន្នន័យ។ ឧទាហរណ៍ ដើម្បីវាយតម្លៃលទ្ធផលនៃគម្រោងផ្លូវ **ឯកសារទិន្នន័យនៃការរីកចំរើនតែ មួយមុខមិនគ្រប់គ្រាន់ទេ** គេត្រូវតែ**ចុះសង្កេតដោយផ្ទាល់**។ សម្រាប់ការវាយតម្លៃអនុកិច្ចសន្យា វិធីសាស្ត្រ និងឧបករណ៍ ខាងក្រោម ប្រែប្រួលទៅតាមប្រភពទិន្នន័យ : ទិន្នន័យដើម (សង្កេត ការស្ទង់មតិ សំភាសន៍ ក្រុមពិភាក្សា ចុះមូលដ្ឋាន) ទិន្នន័យដែលមានស្រាប់ (ការស្រាវជ្រាវ និងវិភាគទិន្នន័យដែលមានស្រាប់)។ សូមមើលតារាងខាងក្រោម :

## សំណួរវាយតម្លៃ ឧបករណ៍វាស់វែង និងប្រភពទិន្នន័យពាក់ព័ន្ធ

| សំណួរវាយតម្លៃ | សំណួរវាយតម្លៃបន្ទាប់បន្សំ | ប្រភពទិន្នន័យសំខាន់ៗ | វិធីសាស្ត្រ និងឧបករណ៍ |
|---|---|---|---|
| ១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ? | ១.១ តើគុណភាពរបស់លទ្ធផលគ្រប់គ្រាន់ទេ ? | ក) ឯកសារអនុកិច្ចសន្យា ផ្នែកទី៣ និងរបាយការណ៍ រីកចំរើន<br>ខ) មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ ផ្នែកគ្រប់គ្រង កិច្ចសន្យា និងមន្ត្រីបង្គោលត្រួតពិនិត្យ និងវាយតម្លៃ ដែលទទួលខុសត្រូវលើអនុកិច្ចសន្យា<br>គ) តំបន់អនុវត្តគម្រោង<br>ឃ) អ្នកទទួលផល និងអ្នកផ្តល់ពត៌មានសំខាន់ៗ | ក) ស្រាវជ្រាវឯកសារ<br>ខ) សម្ភាសន៍ដោយប្រើបញ្ជីសំណួរ<br>គ) ទស្សនកិច្ច និងសង្កេតតំបន់អនុវត្តគម្រោង<br>ឃ) សម្ភាសន៍ស៊ីជម្រៅ<br>ង) សូមមើលគំរូក្នុងសៀវភៅណែនាំអំពីការសរសេររបាយការណ៍ចំនុច២.១ |
| ២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អកម្រិតណា? (ចំណុច គ ផ្នែកទី ៣) | | ក) របាយការណ៍បញ្ចប់កិច្ចសន្យា<br>ខ) ការស្ទង់មតិ និងភាពជាក់ស្តែង<br>គ) តំបន់អនុវត្តគម្រោង<br>ឃ) អ្នកទទួលផល (ផ្ទាល់ និងមិនផ្ទាល់) | ក) សិក្សាលើឯកសារ<br>ខ) ស្ថានភាពមុន និងក្រោយអនុកិច្ចសន្យា<br>គ) ទស្សនកិច្ច និងសង្កេតតំបន់អនុវត្តគម្រោង<br>ឃ) សម្ភាសន៍<br>ង) សូមមើលគំរូក្នុងសៀវភៅណែនាំអំពីការសរសេររបាយការណ៍ចំនុច២.២ |

| សំណួរវាយតម្លៃ | សំណួរវាយតម្លៃបន្ទាប់បន្សំ | ប្រភពទិន្នន័យសំខាន់ៗ | វិធីសាស្ត្រ និងឧបករណ៍ |
|---|---|---|---|
| ៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា? (ចំណុច ខ ផ្នែកទី ៣) | ៣.១ តើលទ្ធផលបានបង្កើតអត្ថប្រយោជន៍ភ្លាមៗអ្វីខ្លះ ?<br>៣.២ តើក្រុមគោលដៅទទួលបានផលប្រយោជន៍អ្វីខ្លះ ?<br>៣.៣ កម្រិតនៃការពេញចិត្តរបស់អ្នកទទួលផល? | ក) របាយការណ៍បញ្ចប់កិច្ចសន្យា<br>ខ) ការស្ទង់មតិ និងភាពជាក់ស្តែង<br>គ) តំបន់អនុវត្តគម្រោង<br>ឃ) អ្នកទទួលផល (ផ្ទាល់ និងមិនផ្ទាល់) | ក) សិក្សាលើឯកសារ<br>ខ) ទិន្នន័យ និងភាពជាក់ស្តែងនៃស្ថានភាព មុន និងក្រោយអនុកិច្ចសន្យា<br>គ) ទស្សនកិច្ច និងសង្កេតតំបន់អនុវត្តគម្រោង<br>ឃ) សម្ភាសន៍ស៊ីជម្រៅ<br>ង) សូមមើលគំរូក្នុងសៀវភៅណែនាំអំពីការសរសេររបាយការណ៍ចំនុច២.៣<br>ច) ទស្សនៈ/ភាពពេញចិត្ត តាមរយៈការសំភាសន៍ស៊ីជម្រៅ/ករណីសិក្សា |

| សំណួរវាយតម្លៃ | សំណួរវាយតម្លៃបន្ទាប់បន្សំ | ប្រភពទិន្នន័យសំខាន់ៗ | វិធីសាស្ត្រ និងឧបករណ៍ |
|---|---|---|---|
| ៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធមានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណាទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង? | ៤.១ សូមមើលធាតុ/ទិន្នន័យដែលត្រូវប្រមូលក្នុងចំនុច ២.៤ នៃសៀវភៅណែនាំអំពីការសរសេររបាយការណ៍<br>៤.២ តើក្រុមគោលដៅដែលបានកំណត់សមរម្យសម្រាប់អនុកិច្ចសន្យាដែរឬទេ ?<br>៤.៣ តើការអនុវត្តគម្រោងទាន់ពេលទេ? ឬយឺតយ៉ាវ? ផលប៉ះពាល់នៃការយឺតយ៉ាវចំពោះលទ្ធផល ?<br>៤.៤ តើសកម្មភាពអនុកិច្ចសន្យាធ្វើអោយស្ថានភាពប្រសើរឡើងទេ ? | ក) ឯកសារអនុកិច្ចសន្យា ផ្នែកទី៣ និងរបាយការណ៍រីកចំរើន<br>ខ) មន្ត្រីដែលពាក់ព័ន្ធនឹងអនុកិច្ចសន្យា<br>គ) តំបន់អនុវត្តគម្រោង<br>ឃ) អ្នកទទួលផល និងអ្នកផ្តល់ពត៌មានសំខាន់ៗ<br>ង) ការស្ទង់មតិ និងភាពជាក់ស្តែង | ក) សិក្សាលើឯកសារ<br>ខ) ទស្សនកិច្ច និងសង្កេតតំបន់អនុវត្តគម្រោង<br>គ) សង្កេត<br>ឃ) សម្ភាសន៍<br>ង) សូមមើលគំរូក្នុងសៀវភៅណែនាំអំពីការសរសេររបាយការណ៍ចំនុច២.៤<br>ច) ទិន្នន័យ និងភាពជាក់ស្តែងនៃស្ថានភាព មុន និងក្រោយអនុកិច្ចសន្យា |

| សំណួរវាយតម្លៃ | សំណួរវាយតម្លៃបន្ទាប់បន្សំ | ប្រភពទិន្នន័យសំខាន់ៗ | វិធីសាស្ត្រ និងឧបករណ៍ |
|---|---|---|---|
| ៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រ អ្វីខ្លះ សម្រាប់កែលម្អ អនុកិច្ចសន្យាក្នុងពេល អនាគត? | ៥.១ តើអនុកិច្ចសន្យាទទួលបានជោគជ័យ និងការខ្វះខាតសំខាន់ៗអ្វីខ្លះ ?<br>៥.២ តើត្រូវធ្វើអ្វីខ្លះនៅពេលក្រោយ ដើម្បី កែលំអលទ្ធផលដែលឆ្លើយតបនឹងសំណួរ វាយតម្លៃទី១ ដល់ទី៤ ? | ក) ឯកសារ កំណត់ហេតុ ការសង្កេត អត្ថបទសម្ភាសន៍ និងឯកសារការពិភាក្សាក្រុម ដែលមានជារូបភាព សំលេង ដែលពាក់ព័ន្ធនឹងការងារវាយតម្លៃ អនុកិច្ចសន្យា<br>ខ) អ្នកពាក់ព័ន្ធ និងទទួលផល (ផ្ទាល់ និងមិនផ្ទាល់)<br>គ) ពង្រាងរបាយការណ៍វាយតម្លៃ | ក) វិភាគទិន្នន័យ និងផ្ទៀងផ្ទាត់ទិន្នន័យ ដែលបានមកពីប្រភពផ្សេងៗគ្នា<br>ខ) បង្កើតពតិមានត្រឡប់ និងធាតុចូល ដែលបានពីអ្នកពាក់ព័ន្ធ និងអ្នកទទួលផល |

## ជំហានទី ៥ : បញ្ចប់ផែនការការងារវាយតម្លៃ

ផែនការការងារ សំខាន់ណាស់ក្នុងការកំណត់កាលវិភាគសម្រាប់អនុវត្តសកម្មភាព និងពេលវេលាកំណត់ ដូចដែលបានចែងនៅក្នុងក្របខ័ណ្ឌការងារវាយតម្លៃ។

សូមបែងចែកភារកិច្ចដល់សមាជិកក្រុមការងារវាយតម្លៃឱ្យបាន ច្បាស់លាស់។ ខាងក្រោមនេះ ជាតារាងពេលវេលាស្តង់ដារសម្រាប់ការវាយតម្លៃអនុកិច្ចសន្យា :

| ល.រ | ភារកិច្ច និងជំហានសំខាន់ៗក្នុងការវាយតម្លៃ | ថ្ងៃទី១ | ថ្ងៃទី២ | ថ្ងៃទី៣ | ថ្ងៃទី៤ | ថ្ងៃទី៥ | ថ្ងៃទី៦ | ថ្ងៃទី៧ |
|---|---|---|---|---|---|---|---|---|
| ១ | ក្រុមការងារវាយតម្លៃពិនិត្យ ក្របខ័ណ្ឌការងារវាយតម្លៃ និងសំណួរវាយតម្លៃឡើងវិញ | | | | | | | |
| ២ | កំណត់ទិន្នន័យដែលត្រូវការ ប្រភព និងឧបករណ៍ប្រមូលទិន្នន័យដែលពាក់ព័ន្ធ និងពេលវេលាកំណត់ដូចដែលចែងក្នុងឯកសារណែនាំ និងឯកភាពគ្នាលើផែនការការងារ | | | | | | | |
| ៣ | ប្រមូលឯកសារទាំងអស់ដែលពាក់ព័ន្ធនឹងអនុកិច្ចសន្យា និងពិនិត្យឡើងវិញ | | | | | | | |
| ការប្រមូលទិន្នន័យ និងសង្កេតតំបន់អនុវត្តគម្រោង | | | | | | | | |
| ៤ | សម្ភាសន៍អ្នករៀបចំ និងអ្នកអនុវត្តអនុកិច្ចសន្យា | | | | | | | |
| ៥ | សម្ភាសន៍អ្នកពាក់ព័ន្ធសំខាន់ដែលបានជ្រើសរើស | | | | | | | |
| ៦ | ក្រុមពិភាក្សាជាមួយអ្នកទទួលផល | | | | | | | |
| ៧ | សម្ភាសន៍ស៊ីជម្រៅ (អ្នកទទួលផល-ករណីសិក្សា) | | | | | | | |
| ៨ | សម្ភាសន៍ស៊ីជម្រៅ (អ្នកមិនបានទទួលផល-ករណីសិក្សា) | | | | | | | |
| ៩ | ពិនិត្យតំបន់អនុវត្តគម្រោង និងអ្នកទទួលផលផ្ទាល់ | | | | | | | |
| ១០ | វិភាគ និងសរសេរពង្រាងរបាយការណ៍ ដូចមាននៅក្នុងសៀវភៅសរសេររបាយការណ៍ | | | | | | | |
| ១១ | បង្ហាញលទ្ធផលដែលរកឃើញដល់អ្នកពាក់ព័ន្ធ | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ដើម្បីទទួលបានយោបល់ | | | | | | | |
| ១២ | បញ្ចប់របាយការណ៍ ដែលមានឯកសារភ្ជាប់ ទាំងអស់ និងបង្ហាញទៅដល់ គ.ប្រ នៃ គ.អ.ជ.ខ និង គ.ជ.អ.ប | | | | | | | |

## ខ. ដំណាក់កាលប្រមូលទិន្នន័យ

### ជំហានទី ៦ : ដំណើរការប្រមូលទិន្នន័យ និងចុះមូលដ្ឋាន

ក- ទិន្នន័យដែលមានស្រាប់: (ស្រាវជ្រាវ និងប្រើទិន្នន័យដែលមានស្រាប់ ដើម្បីឆ្លើយសំណួរវាយតម្លៃ)

១- ចាប់ផ្តើមដោយពិនិត្យឡើងវិញនូវឯកសារ និងរបាយការណ៍សំខាន់ៗ ដើម្បីយល់អោយបានច្បាស់អំពីអនុកិច្ចសន្យា និងដើម្បីដកស្រង់ទិន្នន័យដែលទាក់ទងនឹងសំណួរវាយតម្លៃ។ ឧ. អនុកិច្ចសន្យា ផ្នែកទី១ ទី២ និងទី៣ របាយការណ៍រីកចំរើន របាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍វគ្គបណ្តុះបណ្តាល និងហិរញ្ញវត្ថុ និងការទំនាក់ទំនងនានា។ បង្កើតបញ្ជីទិន្នន័យដែលមានសារៈសំខាន់ ក្នុងការឆ្លើយសំណួរវាយតម្លៃ ។

២- ដោយផ្អែកលើបញ្ជីទិន្នន័យដែលរកមិនបាននៅក្នុងឯកសារ កំណត់ប្រភពទិន្នន័យដែលមានសារៈសំខាន់ទាំងនោះ។

ខ-ទិន្នន័យដើមៈ( ប្រមូលទិន្នន័យដែលមិនមាននៅក្នុងឯកសារ
ប៉ុន្តែមានសារៈសំខាន់សម្រាប់ឆ្លើយសំណួរវាយតម្លៃ)

១. អ្នកផ្តល់ពតិមានសំខាន់ៗៈ (ទស្សនៈ គំនិត និងពតិមានត្រឡប់ របស់ពួកគេតាមរយៈការសំភាសន៍ និងក្រុមពិភាក្សា) ។

២. ពិនិត្យវត្តមាន /ភាពជាក់ស្តែង /សញ្ញាជារូបវ័ន្ត នៃសកម្មភាពអនុកិច្ចសន្យា លទ្ធផល និងការរីកចំរើនដែលពាក់ព័ន្ធ (តាមរយៈការពិនិត្យនៅមូលដ្ឋាន និងសង្កេតផ្ទាល់) ។

## គ. រៀបចំចងក្រង វិភាគទិន្នន័យ និងសរសេររបាយការណ៍

### ជំហានទី ៧ : រៀបចំចងក្រង និងវិភាគទិន្នន័យដែលប្រមូលបាន ទៅតាមសំណួរវាយតម្លៃ និងសៀវភៅសរសេររបាយការណ៍វាយតម្លៃ

**ជំហានទី ៨ : ទាញសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍ ដោយវិភាគលើការវិភាគ និងធ្វើការសង្ខេបការវាយតម្លៃលើ សំណួរវាយតម្លៃអនុកិច្ចសន្យា**

**ជំហានទី ៩ : បង្ហាញលទ្ធផលសំខាន់ៗ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ទៅដល់អ្នកពាក់ព័ន្ធ ដើម្បីទទួលបានយោបល់**

មុននឹងបញ្ចប់ការវាយតម្លៃ និងផ្សព្វផ្សាយរបាយការណ៍វាយតម្លៃ អ្នកវាយតម្លៃត្រូវការយោបល់ពីអ្នកពាក់ព័ន្ធ ដែលទាក់ទងនឹងលទ្ធផលសំខាន់ៗ និងសេចក្តីសន្និដ្ឋាន។ អញ្ជើញអ្នកពាក់ព័ន្ធ និងភាគីសំខាន់ៗ ដែលមានចំណាប់ អារម្មណ៍ទៅលើអត្ថប្រយោជន៍នៃអនុកិច្ចសន្យា មកចូលរួមការប្រជុំ និងបង្ហាញសេចក្តីសន្និដ្ឋានសំខាន់ៗ ដែលបានពី

ការវាយតម្លៃលទ្ធផលវាយតម្លៃដំណើរការ និងវិធីសាស្ត្រដែលបានប្រើសម្រាប់ការវាយតម្លៃ។ ប្រើស្លាយក្នុង Powerpoint និងឯកសារ ដោយសរសេរជាចំណុចៗ ស្នើសុំយោបល់ដើម្បីកែលំអ។ កត់ចំណាំចំណុចមិនស៊ីចង្វាក់គ្នា និងបំភ្លឺចំណុចទាំងនោះ។

**ជំហានទី ១០ : បញ្ចប់ និងផ្សព្វផ្សាយរបាយការណ៍វាយតម្លៃ**

អាស្រ័យលើយោបល់ត្រលប់ពីអ្នកពាក់ព័ន្ធខាងលើ ពិនិត្យឡើងវិញ និងបញ្ចប់របាយការណ៍វាយតម្លៃ ដោយភ្ជាប់ឯកសារដែលគាំទ្រដំណើរការវាយតម្លៃ ជាឯកសារភ្ជាប់។ បង្កើតរបាយការណ៍បញ្ចប់ ដែលមានបុព្វកថានិង លិខិត ប្រកាសរបាយការណ៍ពីសមាជិកអចិន្ត្រៃយ៍នៃ គ.ប្រ នៃ គ.អ.ជ.ខ។ ចែកចាយរបាយការណ៍ទៅដល់អ្នក ពាក់ព័ន្ធ។ សូមថែរក្សាឯកសារមេឱ្យបានល្អ នៅក្នុងផ្នែកគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ នៃ គ.អ.ជ.ខ និងផ្ញើឯកសារ ថតចម្លងទៅផ្នែកសម្របសម្រួលគម្រោង និងគ្រប់គ្រងកិច្ចសន្យានៅភ្នំពេញ និងផ្នែកតាមដានត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប។

**ឃ.ក្រោយការវាយតម្លៃ**

**ជំហានទី ១១ : សកម្មភាពក្រោយការវាយតម្លៃ: ក្រុមការងារវាយតម្លៃធ្វើការឆ្លុះបញ្ចាំងលើបទពិសោធន៍ និងការរៀនសូត្រ**

ក្រុមការងារវាយតម្លៃ និងអ្នកវាយតម្លៃ ជួបប្រជុំគ្នាដើម្បីធ្វើការឆ្លុះបញ្ចាំងអំពីបទពិសោធន៍របស់ពួកគេ ទាក់ទងនឹងការអនុវត្តការវាយតម្លៃ និងទាញចំណុចរៀនសូត្រ ដើម្បីជាមេរៀនសម្រាប់ការអនុវត្ត និងគ្រប់គ្រងការ វាយតម្លៃអនុកិច្ចសន្យាក្នុងពេលអនាគត។

**ជំហានទី ១២ : តាមដានការអនុវត្តអនុសាសន៍ដែលបានពីការវាយតម្លៃ**

ការវាយតម្លៃអនុកិច្ចសន្យា មានអត្ថប្រយោជន៍ នៅពេលដែលលទ្ធផល និងអនុសាសន៍ ត្រូវបាន តាមដានបន្ត និងអនុវត្ត។ ដូច្នេះ ការតាមដានបន្តនូវការវាយតម្លៃ គឺជាអនុសាសន៍សំខាន់ណាស់ ដើម្បីកែលម្អ ការរៀបចំអនុវត្ត ចងក្រងឯកសារ ត្រួតពិនិត្យ និងរបាយការណ៍អនុកិច្ចសន្យា។ ការកែលំអអនុកិច្ចសន្យា មានន័យថាកែលម្អលទ្ធផល និងអត្ថប្រយោជន៍ ដែលរួមចំណែកក្នុងការសម្រេចគោលដៅវិមជ្ឈការ និង វិសហមជ្ឈការ។

# ផ្នែកទី IV: ឧបករណ៍ ទម្រង់ និងគន្លឹះសម្រាប់ការវាយតម្លៃអនុកិច្ចសន្យា

## ១ : នីតិវិធីក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យា

១- ជួបជាមួយអ្នកអនុវត្តអនុកិច្ចសន្យា និងពន្យល់ពួកគាត់អំពីគោលបំណងនៃការវាយតម្លៃ។ សួរគាត់អំពីភាគីពាក់ព័ន្ធដែលមាន [១]។

២- ស្នើសុំឯកសារអនុកិច្ចសន្យាពីអ្នកអនុវត្តអនុកិច្ចសន្យា ដើម្បីពិនិត្យឡើងវិញនៅការិយាល័យរបស់អ្នក។ ឯកសារទាំងនោះរួមមានៈ ឯកសារអំពីអនុកិច្ចសន្យា កំណត់ហេតុប្រជុំ របាយការណ៍រីកចំរើន របាយការណ៍ត្រួតពិនិត្យ និងរបាយការណ៍បញ្ចប់កិច្ចសន្យា។ ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ មានសារៈសំខាន់ណាស់ ដែលជួយអោយអ្នកយល់ច្បាស់ពីអនុកិច្ចសន្យា។

៣- ពិនិត្យ/សិក្សាឯកសារអនុកិច្ចសន្យាៈ បំភ្លឺ ឬកំណត់គោលបំណងរបស់អនុកិច្ចសន្យាដែលត្រូវវាយតម្លៃ។ កំណត់សកម្មភាពសំខាន់ៗមួយចំនួននៃអនុកិច្ចសន្យា ដែលមានទំនាក់ទំនងនឹងលទ្ធផល រួចជ្រើសរើសសកម្មភាពសំខាន់មួយ ដើម្បីអនុវត្តការវាយតម្លៃ ក្នុងពេលចុះពិនិត្យដល់មូលដ្ឋាន និងសម្ភាសន៍ អ្នកទទួលផល។

៤- ពិនិត្យសម្ភារៈ/ឯកសារសម្រាប់វគ្គបណ្តុះបណ្តាល ដើម្បីឱ្យអ្នកអាចរៀបចំខ្លួន សម្រាប់ដឹកនាំក្រុមពិភាក្សា ជាមួយអ្នកទទួលផល និងចុះសង្កេតដល់មូលដ្ឋាន។

៥- ធ្វើការណាត់ជួបជាមួយអ្នករៀបចំ/អនុវត្តអនុកិច្ចសន្យា និងអ្នកពាក់ព័ន្ធដើម្បីធ្វើការសម្ភាសន៍ស៊ីជម្រៅ។

៦- ជ្រើសរើសអ្នកទទួលផលពីសកម្មភាពដែលបានកំណត់ និងធ្វើការណាត់ជួបជាមួយពួកគាត់ ដើម្បីធ្វើការសម្ភាសន៍ (បញ្ជីឈ្មោះអ្នកចូលរួម អាចទទួលបានពីអ្នកអនុវត្តគម្រោង ឬផ្នែកហិរញ្ញវត្ថុ)។

៧- ការពិភាក្សាក្រុមជាមួយអ្នកទទួលផល គួរតែធ្វើឡើងនៅពេលព្រឹក ចំណែកការចុះសង្កេតដល់មូលដ្ឋាន គួរតែធ្វើឡើងបន្ទាប់ពីការពិភាក្សាក្រុម។ ព្យាយាមកំណត់អ្នកចូលរួមដែលសកម្មជាងគេ នៅក្នុងការពិភាក្សាក្រុម និងធ្វើការណាត់ជាមួយគាត់ ដើម្បីមើលសកម្មភាពនៅផ្ទះ ( សង្កេតដល់មូលដ្ឋាន និងសម្ភាសន៍ ដោយគ្មានបញ្ជីសំណួរ)។

៨- រៀបចំសម្ភារៈសម្រាប់ចុះមូលដ្ឋានដើម្បីប្រមូលទិន្នន័យៈ ត្រូវប្រាកដថាអ្នកមានសម្ភារៈ ដែលអ្នកត្រូវការ ប្រើនៅពេលបំពេញការងារនៅមូលដ្ឋាន។ សម្ភារៈទាំងនោះរួមមាន ប៊ិច (យ៉ាងហោចណាស់មានពីរពណ៌ ខុសគ្នា) សៀវភៅកងសម្រាប់សរសេរ (ត្រៀម ២-៣ ក្បាល) ម៉ាស៊ីនថតសំលេង (ត្រូវប្រាកដថាវា មានថ្មគ្រប់គ្រាន់) និងម៉ាស៊ីនថតរូប (ត្រូវពិនិត្យថ្ម និងអង្គចងចាំក្នុងម៉ាស៊ីនថត)។

៩- កត់ត្រាៈ សរសេរចម្លើយនៅលើក្រដាសទំព័រមុខ (កុំសរសេរសងខាង) និងទុកចន្លោះតែមទំព័រខ្លះ។ ដូច្នេះ អ្នកអាចបន្ថែមកំណត់ចំណាំ ឬចម្លើយផ្សេងៗ ក្នុងកំឡុងពេលសន្ទនាគ្នា។ អ្នកអាចសរសេរ យោបល់ ការសង្កេត និងការវិភាគរបស់អ្នកនៅទំព័រខាងក្រោយ។

១០- ការវិភាគទិន្នន័យៈ អានទិន្នន័យទាំងអស់ដែលបានពីកំណត់ត្រាពេលអ្នកសម្ភាសន៍ ដើម្បីដឹងថាមាន ទិន្នន័យអ្វីខ្លះ ហើយសង្ខេបលទ្ធផលសំខាន់ៗដែលឆ្លើយតបនឹងសំណួរវាយតម្លៃ និងគូរបាយការណ៍។

១១- សរសេររបាយការណ៍ៈ ប្រើសៀវភៅណែនាំអំពីការសរសេររបាយការណ៍

១២- ប្រគល់របាយការណ៍វាយតម្លៃទៅផ្នែកត្រួតពិនិត្យ និងវាយតម្លៃនៃ គ.ប្រ នៃ គ.អ.ជ.ខ និងថតចំលងមួយច្បាប់ផ្ញើទៅកាន់ផ្នែក ត្រួតពិនិត្យ និងវាយតម្លៃនៃអង្គភាពគាំទ្រកម្មវិធីនៃ គ.ជ.អ.ប។

[1] **និយមន័យពាក្យភាគីពាក់ព័ន្ធៈ** ដៃគូរអភិវឌ្ឍន៍ ឬអង្គការក្រៅរដ្ឋាភិបាល ឬមន្ត្រីដែលមានផលប្រយោជន៍ នៅក្នុង អនុកិច្ចសន្យា ឬលទ្ធផល និងផលប្រយោជន៍របស់អនុកិច្ចសន្យា។ ឧទាហរណ៍ ដូចជាមន្ត្រីបង្គោលយេនឌ័រ ឬមន្ត្រី បង្គោលគ្រប់គ្រងធនធានធម្មជាតិ។ ប្រសិនបើមិនមានអង្គការក្រៅរដ្ឋាភិបាល ពាក់ពន្ធ័ជាមួយនឹងការអនុវត្ត គម្រោង ទេ គួរតែជ្រើសរើស ទីប្រឹក្សាត្រួតពិនិត្យវាយតម្លៃ និងវិស័យ ឬ ប្រធានទីប្រឹក្សា (ដើម្បីជាការឆ្លុះបញ្ចាំង ពីទស្សនៈ ពីដៃគូរអភិវឌ្ឍន៍) ប្រធានភូមិ/ស្មៀនឃុំដែលគម្រោងមានសកម្មភាព (ដើម្បីជាការឆ្លុះបញ្ចាំងពី ទស្សនៈសហគមន៍) និងមន្ត្រីបង្គោលយេនឌ័រ ឬ មន្ត្រីបង្គោលគ្រប់គ្រងធនធានធម្មជាតិ (ដើម្បីជាការឆ្លុះបញ្ចាំងពី ទស្សនៈ យេនឌ័រ និង ការគ្រប់គ្រងធនធានធម្មជាតិ) ធ្វើជាភាគីពាក់ព័ន្ធក្នុងគម្រោង។

# ២ : ការណែនាំសម្រាប់សម្ភាសន៍ស៊ីជម្រៅសម្រាប់អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា

១- កាលបរិច្ឆេទសម្ភាសន៏: ......................................................................................................

២- ឈ្មោះអ្នកចូលរួម: ..............................................................................................................

៣- លេខកិច្ចសន្យា: ..................................................................................................................

៤- ឋានះរបស់អ្នកចូលរួម: ........................................................................................................

៥- ខេត្ត: ..................................................................................................................................

៦- ឈ្មោះអនុកិច្ចសន្យា: ...........................................................................................................

៧- លេខអនុកិច្ចសន្យា: ..............................................................................................................

**ការរៀបចំ និងគ្រោងអនុកិច្ចសន្យា**

៨- តើអ្នកណាខ្លះជាអ្នកបានចូលរួមរៀបចំ និងសរសេរអនុកិច្ចសន្យានេះនៅថ្នាក់ គ.អ.ជ.ខ?

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

៩- តើអ្នកណាខ្លះជាអ្នកបានចូលរួមរៀបចំ និងសរសេរអនុកិច្ចសន្យានេះ នៅថ្នាក់មន្ទីរវិស័យដែលជាអ្នកអនុវត្ត អនុកិច្ចសន្យា?

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

*(សំណួរនេះមានគោលបំនងពិនិត្យមើលថាតើការរៀបចំនិងការសរសេរអនុកិច្ចសន្យានេះមានការចូលរួមពីភាគីផ្សេងៗកម្រិតណា)*

១០- តើអ្នកធ្វើដូចម្តេចដើម្បីកំណត់បញ្ហា ឬតម្រូវការដើម្បីសរសេរក្នុងអនុកិច្ចសន្យា ?

*[គោលបំណងសំខាន់របស់សំណួរនេះគឺដើម្បីរកអោយឃើញថាតើគាត់កំនត់បញ្ហានេះបានយ៉ាងដូចម្តេច (វិធីសាស្ត្រដែលគាត់បានប្រើ)?]*

សូមពន្យល់ :

.................................................................................................................................................

១១- ហេតុអ្វីបានជាអ្នកសម្រេចយកគោលបំណងទាំងនេះដាក់ក្នុងអនុកិច្ចសន្យា?

*[ អ្នកវាយតម្លៃត្រូវតែកំណត់គោលបំណងដាក់លាក់ពីឯកសារអនុកិច្ចសន្យា ហើយយកទៅពិភាក្សាជាមួយអ្នក រៀបចំ/ អនុវត្ត អនុកិច្ចសន្យាម្តងមួយៗ ។ ជាពិសេស សួរពួកគាត់ថាតើគោលដៅទាំងនោះសម្រេចបាន ក្នុងកម្រិតណា? មានបញ្ហាអ្វីខ្លះ? ]*

សូមពន្យល់ :

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

១២- តើគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា ផ្សារភ្ជាប់/ឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមគោលដៅ ឬអ្នកទទួលផលដែលបានកំណត់ដែរឬទេ ?

*មិនផ្សារភ្ជាប់គ្នាសោះ ...........................................................................................................ពិតជាផ្សារភ្ជាប់គ្នាល្អណាស់*

*០ ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០ ៨០ ៩០ ១០០*

សូមពន្យល់ :

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

**ភាពជាប់ពាក់ព័ន្ធ**

១៣- ហេតុអ្វីបានជាអ្នកជ្រើសរើសក្រុមគោលដៅនេះ ?

*[ អ្នកវាយតម្លៃត្រូវតែកំណត់ក្រុមគោលដៅ និងទីតាំងដែលត្រូវអន្តរាគមន៍ពីឯកសារអនុកិច្ចសន្យា ហើយយក ទៅពិភាក្សាជាមួយអ្នករៀបចំ/អនុវត្ត អនុកិច្ចសន្យា ។ វាជាការសំខាន់ណាស់ដែលត្រូវស្វែងយល់ថាតើ ក្រុមគោលដៅ និងទីតាំងដែលបានកំណត់នោះសមស្របដែរឬទេ?]*

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

## ប្រសិទ្ធផល

### *មធ្យោបាយ/ធាតុចូល*

១៤- តើថវិកាដែលទទួលបានគ្រប់គ្រាន់ អាចសម្រេចលទ្ធផលដែលបានគ្រោងទុកដែរឬទេ ?

*មិនគ្រប់គ្រាន់សោះ ........................................................................................................ ពិតជាគ្រប់គ្រាន់ណាស់*

*០ ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០ ៨០ ៩០ ១០០*

សូមពន្យល់ :

........................................................................................................................................

........................................................................................................................................

........................................................................................................................................

១៥- តើបុគ្គលិកអនុវត្តអនុកិច្ចសន្យាមានជំនាញគ្រប់គ្រាន់ អាចសម្រេចលទ្ធផលដែលបានគ្រោងទុកដែរឬទេ ?

*មិនគ្រប់គ្រាន់សោះ ........................................................................................................ ពិតជាគ្រប់គ្រាន់ណាស់*

*០ ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០ ៨០ ៩០ ១០០*

សូមពន្យល់ :

........................................................................................................................................

........................................................................................................................................

........................................................................................................................................

### *ដំណើរការគ្រប់គ្រង*

១៦- តើសកម្មភាពត្រូវបានអនុវត្តទៅតាមពេលវេលាគ្រោងទុក ឬក៏មានការយឺតយ៉ាវ ?

*មិនត្រឹមត្រូវតាមពេលវេលាសោះ ..........................................................................ពិតជាត្រឹមត្រូវតាមពេលវេលា*

*០ ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០ ៨០ ៩០ ១០០*

សូមពន្យល់ :

........................................................................................................................................

........................................................................................................................................

........................................................................................................................................

១៧- តើការប្រាស្រ័យទាក់ទង និងសម្របសម្រួល របស់ផ្នែកគ្រប់គ្រងកិច្ចសន្យានៃគ.ប្រ ជាមួយអ្នកដែលជាភ្នាក់ងារអនុវត្តគម្រោងយ៉ាងដូចម្តេចដែរ ?

សូមពន្យល់ :

............................................................................................................................................

............................................................................................................................................

............................................................................................................................................

១៨- <u>សម្រាប់តែភ្នាក់ងារអនុវត្តន៏គម្រោង</u>: តើអ្នកបានទទួលនូវការគាំទ្រ និងចម្លើយតបពី គ.ប្រ/ ផ្នែកគ្រប់គ្រង កិច្ចសន្យា ឬទីប្រឹក្សាត្រួតពិនិត្យវាយតម្លៃ និងវិស័យ ទាន់ពេលវេលាឬទេ នៅពេលដែលអ្នកត្រូវការ នៅក្នុង កំឡុងពេលអនុវត្តកិច្ចសន្យា?

សូមពន្យល់ :

............................................................................................................................................

............................................................................................................................................

............................................................................................................................................

<u>ប្រសិទ្ធភាព</u>

១៩- តើសកម្មភាពរបស់អនុកិច្ចសន្យាធ្វើអោយស្ថានភាពនៅក្នុងតំបន់គោលដៅមានភាពប្រសើរឡើងឬទេ ?

សូមពន្យល់ :

............................................................................................................................................

............................................................................................................................................

............................................................................................................................................

២០- សូមពន្យល់អំពីស្ថានភាពនៃលទ្ធផលដែលសម្រេចបាន។

*[ អ្នកវាយតម្លៃត្រូវតែយកលទ្ធផលរំពឹងទុកសំខាន់ៗមកពិភាក្សាជាមួយអ្នករៀបចំ/អនុវត្តអនុកិច្ចសន្យា។*

*អ្នកត្រូវតែសុំអោយគាត់ពន្យល់អំពីលទ្ធផលដែលមិនអាចសម្រេចបានតាមការគ្រោងទុកនៅចុងបញ្ចប់នៃអនុកិច្ចសន្យា ។]*

សូមពន្យល់ :

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

២១- តើសកម្មភាពអ្វីខ្លះដែលអនុវត្តន៍បានជោគជ័យ និងមិនសូវជោគជ័យ? ហេតុអ្វី?

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

២២- តើអ្នកមានអនុសាសន៍អ្វីដើម្បីកែលំអគុណភាពការរៀបចំនិងការអនុវត្តន៍អនុកិច្ចសន្យា?

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

២៣- **<u>ការបញ្ជ្រាបយេនឌ័រ:</u>** តើអ្នកគិតថាអនុកិច្ចសន្យានេះបានបញ្ជ្រាបយេនឌ័របានកម្រិតណាដែរ?

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

២៤- **<u>ការគ្រប់គ្រងធនធានធម្មជាតិ:</u>** តើអ្នកគិតថាអនុកិច្ចសន្យានេះបានបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិបានកម្រិតណាដែរ?

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

# ៣ : ការណែនាំការសម្ភាសន៍ស៊ីជម្រៅជាមួយក្រុមអ្នកពាក់ព័ន្ធ

**និយមន័យពាក្យភាគីពាក់ព័ន្ធ:** ដៃគូរអភិវឌ្ឍន៍ ឬអង្គការក្រៅរដ្ឋាភិបាល ឬមន្ត្រីដែលមានផលប្រយោជន៍ នៅក្នុងអនុកិច្ចសន្យា ឬ លទ្ធផល និងផលប្រយោជន៍របស់អនុកិច្ចសន្យា។ ឧទាហរណ៍ដូចជាមន្ត្រីបង្គោល យេនឌ័រ ឬមន្ត្រីបង្គោលគ្រប់គ្រងធនធានធម្មជាតិ។ ប្រសិនបើមិនមានអង្គការក្រៅរដ្ឋាភិបាល ពាក់ពន្ធ័ជាមួយនឹងការអនុវត្តគម្រោងទេ គួរតែជ្រើសរើស ទីប្រឹក្សាត្រួតពិនិត្យវាយតម្លៃ និងវិស័យ ឬ ប្រធានទីប្រឹក្សា (ដើម្បីជាការឆ្លុះបញ្ចាំងពីទស្សនៈពីដៃគូរអភិវឌ្ឍន៍) ប្រធានភូមិ/ស្មៀនឃុំដែលគម្រោងមានសកម្មភាព (ដើម្បីជាការឆ្លុះបញ្ចាំងពីទស្សនៈសហគមន៍) និងមន្ត្រីបង្គោលយេនឌ័រ ឬ មន្ត្រីបង្គោលគ្រប់គ្រងធនធានធម្មជាតិ (ដើម្បីជាការឆ្លុះបញ្ចាំងពីទស្សនៈ យេនឌ័រ និងការគ្រប់គ្រងធនធានធម្មជាតិ) ធ្វើជាភាគីពាក់ព័ន្ធក្នុងគម្រោង។

១-កាលបរិច្ឆេទសម្ភាសន៍: ..........................................................................................................
២- ឈ្មោះអ្នកឆ្លើយ:.................................................................................................................
៣- មុខតំណែងអ្នកឆ្លើយ: ..........................................................................................................
៤- លេខទូរស័ព្ទទាក់ទង: ............................................................................................................
៥- ឈ្មោះរាជធានី ខេត្ត:...........................................................................................................
៦- ឈ្មោះអនុកិច្ចសន្យា:............................................................................................................
៧- លេខអនុកិច្ចសន្យា:..............................................................................................................

**ភាពទាក់ទង :**

៨- តើគោលបំណងអនុកិច្ចសន្យាស៊ីគ្នាទៅនឹងតម្រូវការរបស់ក្រុមគោលដៅនិងអ្នកទទួលផលដែលបានកំណត់ឬទេ?

*មិនស៊ីគ្នាសោះ*..........................................................................................................*ពិតជាស៊ីគ្នា*

០ ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០ ៨០ ៩០ ១០០

សូមពន្យល់:..........................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................

៩- តើក្រុមគោលដៅដែលជ្រើសរើសនោះត្រឹមត្រូវ សក្តិសមដែរឬទេ?

*មិនសក្តិសមសោះ.............................................................................................................ពិតជាសក្តិសមណាស់*

០ ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០ ៨០ ៩០ ១០០

សូមពន្យល់:

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

**ប្រសិទ្ធផល:** *មធ្យោបាយ / ធាតុចូល*

១០- តើអ្នកគិតថាអ្នកអនុវត្តកិច្ចសន្យាមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីអនុវត្តការងារដែរឬទេ?

*មិនគ្រប់គ្រាន់សោះ...................................................................................................ពិតជាគ្រប់គ្រាន់ណាស់*

០ ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០ ៨០ ៩០ ១០០

សូមពន្យល់:...............................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១១- តើអ្នកមានអនុសាសន៍ដូចម្តេចខ្លះ ដើម្បីលើកកំពស់គុណភាពក្នុងការរៀបចំការអនុវត្តអនុកិច្ចសន្យា និងលទ្ធផល?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

# ៤: ការណែនាំការពិភាក្សាក្រុមចំពោះអ្នកទទួលផលផ្នែកបណ្តុះបណ្តាល អប់រំ

**ចំណាំ:** បន្ថែមទៅនឹងសំនួរដូចខាងក្រោម ចំនុចបន្ទាប់ទៅនេះគឺជាចំនុចដែលអ្នកគួរយកចិត្តទុកដាក់:
- ជ្រើសរើសអ្នកចូលរួម (៦-៨ នាក់) ដែលជាតំណាងក្រុមគោលដៅដែលជាអ្នកទទួលផល
- ជ្រើសរើសអ្នកសម្របសម្រួល ដើម្បីដំណើរការការពិភាក្សាក្រុម បង្ហាញសំណួរ ទាញយកចម្លើយ ទស្សនៈ និងពតិមានត្រឡប់។ អ្នកសម្របសម្រួលត្រូវតែរៀបចំមុនពេលដំណើរការពិភាក្សា។ អ្នកសម្របសម្រួលគួរតែមានជំនាញល្អខាងទំនាក់ទំនង និងសម្របសម្រួល។
-ជ្រើសរើសអ្នកកត់ត្រា ដើម្បីកត់ត្រា ថតរូបភាព និងថតសំលេង
- រៀបចំកន្លែងសមរម្យក្នុងការដំណើរការពិភាក្សាក្រុម
- សម្រាប់ការបូកសរុបចម្លើយ ការដាក់លេខកូដគួរតែបានប្រើ

១-កាលបរិច្ឆេទសម្ភាសន៍: ...........................................................................................................

២- បញ្ជីឈ្មោះអ្នកចូលរួមៈ (រួមមាន ឈ្មោះ ភេទ និងអាយុ)..............................................................

៣- ឈ្មោះរាជធានី ខេត្តៈ......................................................................................................................

៤- ឈ្មោះស្រុក ខ័ណ្ឌៈ..........................................................................................................................

៥- ឈ្មោះឃុំ សង្កាត់: ............................................................................................................................

៦- ឈ្មោះភូមិ: .......................................................................................................................................

៧- ឈ្មោះអនុកិច្ចសន្យាៈ.......................................................................................................................

៨- លេខអនុកិច្ចសន្យាៈ..........................................................................................................................

## ក- សេចក្តីផ្តើម (រយៈពេល ១៥ នាទី)

☛ អ្នកសម្របសម្រួលណែនាំក្រុម និងធ្វើការពន្យល់ដូចខាងក្រោមៈ

☛ យើងខ្ញុំទាំងអស់គ្នា គឺជាក្រុមការងារវាយតម្លៃមកពីគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ខ្ញុំឈ្មោះ...........................ហើយក្រុមការងាររបស់ខ្ញុំរួមមាន..................................................................

☛ គោលបំណង នៃការពិភាក្សានេះ គឺដើម្បីទទួលបាននូវយោបល់ ឬទស្សនៈរបស់អ្នក ដែលពាក់ព័ន្ធទៅនឹងវគ្គបណ្តុះបណ្តាល ដែលអ្នកបានចូលរួម។ យោបល់ ឬទស្សនៈរបស់អ្នកពិតជាមានសារៈសំខាន់ណាស់សម្រាប់ក្រុមដែលផ្តល់វគ្គបណ្តុះ បណ្តាល ធ្វើការកែលម្អការរៀបចំវគ្គបណ្តុះបណ្តាលឱ្យកាន់តែប្រសើរនូវវគ្គបណ្តុះបណ្តាលនាពេលអនាគត។

☛ ហេតុដូច្នេះវាពិតជាមានសារៈសំខាន់ណាស់ក្នុងការស្តាប់មតិយោបល់របស់អ្នកទាំងអស់គ្នា។

☛ គ្មានចម្លើយ ខុស ឬត្រូវទេ។

☛ សូមកុំនិយាយទាំងអស់គ្នាក្នុងពេលតែមួយ។

☛ អ្វីដែលអ្នកនិយាយនឹងត្រូវបានរក្សាការសម្ងាត់ជូន ហើយឈ្មោះរបស់អ្នកក៏មិនត្រូវបានបង្ហាញដែរ។

☛ មតិយោបល់របស់អ្នកពិតជាមានតម្លៃ ហើយយើងសូមលើកទឹកចិត្តអោយអ្នកទាំងអស់គ្នាផ្តល់ភាពស្មោះត្រង់ និងបើកចំហរ។ វាមិនជាបញ្ហាអ្វីទេនៅពេលដែលអ្នកមិនយល់ស្របជាមួយចម្លើយអ្នកដ៏ទៃ នេះគឺជាការពិភាក្សាប្រកបដោយភាពស្និទ្ធស្នាល។

☛ ថតទុកនូវការសន្ទនា ដើម្បីជួយយើងសរសេរនូវរបាយការណ៍ នៅពេលបន្ទាប់ ហើយនឹងអាចធ្វើឱ្យអ្នកសម្របសម្រួលផ្តោតទៅលើ ការសន្ទនា និងមិនត្រូវបានបង្អាក់ដោយសារការកត់ត្រា។

☛ <u>សូមអ្នកធ្វើការណែនាំខ្លួនអ្នកផ្ទាល់</u> ដោយប្រាប់នូវឈ្មោះ និងឈ្មោះភូមិដែលអ្នកស្នាក់នៅ

☛ ***<u>អ្នកសម្របសម្រួលត្រូវតែនិយាយៈ</u>*** ខ្ញុំគ្រាន់តែរំលឹកដល់អ្នកទាំងអស់គ្នាថាអ្វីដែលអ្នកនិយាយនៅទីនេះ ពេលនេះនឹងត្រូវរក្សាការសម្ងាត់ជូន។ វាពិតមានសារៈសំខាន់សម្រាប់ពួកយើងដែលអ្នកអាចនិយាយដោយសេរី និងស្មោះត្រង់។ មិនមាន ចម្លើយខុស ឬត្រូវទេ យើងគ្រាន់តែពិភាក្សាប្រកបដោយភាពស្មោះត្រង់ នូវអ្វីដែលយើងបានដឹងតែប៉ុណ្ណោះ។ យើងមិនមែន ធ្វើតេស្តសាកល្បងលើអ្នកទេ។

☛ ***<u>អ្នកសម្របសម្រួលត្រូវតែនិយាយៈ</u>*** ថ្ងៃនេះយើងនឹងជជែកគ្នាអំពីវគ្គបណ្តុះបណ្តាល ដែលអ្នកបានចូលរួមកាលពីលើកមុន

## <u>សំនួរចាប់ផ្តើម</u>

១- តើវគ្គបណ្តុះបណ្តាលធ្វើឡើងនៅទីណា?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

២- តើបណ្តុះបណ្តាលអំពីអ្វី?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

**<u>សំនួរខាងក្រោមនេះសួរដើម្បីចង់ទទួលចម្លើយតបថាតើការបណ្តុះបណ្តាលនោះ</u>**

**<u>ជាប់ទាក់ទងយ៉ាងណាទៅនឹងតម្រូវការជាក់ស្តែង</u>**

៣- នៅមុនពេលទទួលបានវគ្គបណ្តុះបណ្តាល

តើមាននរណាធ្លាប់មកពិភាក្សាជាមួយអ្នកអំពីតម្រូវការរបស់អ្នកដែរឬទេ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៤- តើវគ្គបណ្តុះបណ្តាល ឬការអប់រំឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកទេ?

សូមពន្យល់ៈ

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៥- តើវគ្គបណ្តុះបណ្តាល ឬការអប់រំឆ្លើយតប ឬស៊ីគ្នាទៅនឹងស្ថានភាពសហគមន៍ឬទេ?

សូមពន្យល់ៈ

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៦- តើហេតុអ្វីបានជាអ្នកត្រូវបានជ្រើសរើសចូលរួមវគ្គបណ្តុះបណ្តាល? ហេតុអ្វីគេមិនជ្រើសរើសអ្នកដ៏ទៃ?

សូមពន្យល់ៈ

..........................................................................................................................................

..........................................................................................................................................

**<u>សំនួរខាងក្រោមនេះសួរដើម្បីចង់ដឹងពីប្រសិទ្ធផលនៃការបណ្តុះបណ្តាល</u>**

៧- តើអ្នកចូលរួមវគ្គបណ្តុះបណ្តាលបានចូលរួមយ៉ាងសកម្មដែរឬទេ នៅក្នុងការពិភាក្សាក្នុងអំឡុងពេលបណ្តុះបណ្តាល?

*ពិតជាមិនសកម្មសោះ*.......................................................................................................................................*ពិតជាសកម្មណាស់*

០ ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០ ៨០ ៩០ ១០០

សូមពន្យល់: .

........................................................................................................................................................................

........................................................................................................................................................................

........................................................................................................................................................................

........................................................................................................................................................................

........................................................................................................................................................................

៨- តើអ្នកយល់យ៉ាងដូចម្តេចដែរអំពីការបង្រៀនរបស់គ្រូបណ្តុះបណ្តាល?

*(តើគាត់មានចំណេះដឹងគ្រប់គ្រាន់ដើម្បី បង្រៀនដែរទេ? តើអាកប្បកិរិយារបស់គាត់យ៉ាងម៉េចដែរ?)*

សូមពន្យល់:

........................................................................................................................................................................

........................................................................................................................................................................

........................................................................................................................................................................

........................................................................................................................................................................

........................................................................................................................................................................

៩- តើអ្នកបានយកចំណេះដឹងនេះ ទៅអនុវត្តដែរឬទេ? ហេតុអ្វី?

សូមពន្យល់:

........................................................................................................................................................................

........................................................................................................................................................................

........................................................................................................................................................................

........................................................................................................................................................................

........................................................................................................................................................................

១០- តើគ្រូបណ្តុះបណ្តាលដែលធ្លាប់ចុះមកតាមដាន និងជួយគាំទ្របច្ចេកទេស ដល់អ្នកដែលបានចូលរួមវគ្គបណ្តុះបណ្តាលនៅក្នុងសហគមន៍ឬទេ? តើការចុះមកមើលផ្ទាល់របស់គ្រូបណ្តុះបណ្តាល មានសារៈសំខាន់ឬទេ?

សូមពន្យល់:

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

<u>សំនួរខាងក្រោមនេះសួរដើម្បីចង់ដឹងពីប្រសិទ្ធភាពនៃការបណ្តុះបណ្តាល</u>

១១- តើវគ្គបណ្តុះបណ្តាលនេះមានសារៈសំខាន់ចំពោះអ្នកយ៉ាងដូចម្តេច? *(សូមឱ្យក្រុម ពិភាក្សាក្នុងចំណោមគ្នាគាត់ ហើយសម្រេចចិត្តផ្តល់ពិន្ទុរួមមួយដូចខាងក្រោម និងពន្យល់ហេតុផល)*

*មិនមានសារៈសំខាន់សោះ*.................................................................................................*ពិតជាមានសារៈសំខាន់ណាស់*

០ ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០ ៨០ ៩០ ១០០

សូមពន្យល់:

................................................................................................................................................

................................................................................................................................................

................................................................................................................................................

<u>សំនួរខាងក្រោមនេះសួរដើម្បីចង់ដឹងពីផលប្រយោជន៍នៃការបណ្តុះបណ្តាល</u>

១២- តើអ្នកបានសង្កេតឃើញថាមានការផ្លាស់ប្តូរដែរឬទេក្រោយពីទទួលបានវគ្គបណ្តុះបណ្តាលនេះ? នៅក្នុងចំណោមអ្នកចូលរួម? គ្រួសារ? និងសហគមន៍?

................................................................................................................................................

................................................................................................................................................

................................................................................................................................................

១៣- តើអ្នកពេញចិត្តនឹងប្រយោជន៍របស់គម្រោងនេះកម្រិតណា? *(សូមឱ្យក្រុមពិភាក្សាក្នុងចំណោមគ្នាគាត់ហើយ សម្រេចចិត្តផ្តល់ពិន្ទុរួមមួយដូចខាងក្រោម និងពន្យល់ហេតុផល)*

*អត់ពេញចិត្តសោះ*.....................................................................................................................*ពិតជាពេញចិត្តណាស់*

០ ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០ ៨០ ៩០ ១០០

សូមពន្យល់:

.............................................................................................................................................

.............................................................................................................................................

**សំនួរបញ្ចប់ (៥នាទី)**

**<u>អ្នកសម្របសម្រួលត្រូវតែនិយាយ:</u>** ឥឡូវនេះ យើងឈានជិតដល់ទីបញ្ចប់នៃការពិភាក្សាហើយ។ យើងបានជជែកគ្នាយ៉ាងច្រើន ឥឡូវយើងខ្ញុំចង់ដឹងអំពីសំនូមពររបស់អ្នកវិញ។

១៤- តើអ្នកមានសំណូមពរអ្វីខ្លះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការបណ្តុះបណ្តាល? *(សូមឱ្យក្រុមពិភាក្សាក្នុងចំណោមគ្នាគាត់លើចំនុចខាងក្រោមម្តងមួយម្តងមួយ)*

ក- សម្ភារៈនិងឯកសារសម្រាប់វគ្គបណ្តុះបណ្តាល.......................................................................................

.............................................................................................................................................

.............................................................................................................................................

ខ- ការរៀបចំ.........................................................................................................................................

.............................................................................................................................................

.............................................................................................................................................

គ- អ្នកចូលរួម.........................................................................................................................................

.............................................................................................................................................

.............................................................................................................................................

ឃ- ទីកន្លែង.........................................................................................................................................

.............................................................................................................................................

.............................................................................................................................................

ង- គ្រូផ្តល់វគ្គបណ្តុះបណ្តាល.......................................................................................................

.............................................................................................................................................

.............................................................................................................................................

## ៥: ការសម្ភាសន៍ (មិនតាមកម្រងសំណួរ)អ្នកមិនបានទទួលផលក្នុងពេលចុះមូលដ្ឋាន

១- កាលបរិច្ឆេទសម្ភាសន៍ : .......................................................................................................

២- ឈ្មោះរាជធានី ខេត្តៈ.......................................................................................................

៣- ឈ្មោះស្រុក ខណ្ឌៈ.......................................................................................................

៤- ឈ្មោះឃុំ សង្កាត់ៈ .......................................................................................................

៥- ឈ្មោះភូមិៈ.......................................................................................................

៦- ឈ្មោះអនុកិច្ចសន្យាៈ.......................................................................................................

៧- លេខអនុកិច្ចសន្យាៈ.......................................................................................................

៨- ឈ្មោះ? .......................................................................................................

៩- អាយុ? .......................................................................................................

១០- ភេទ? .......................................................................................................

១១- ស្ថានភាពគ្រួសារ? .......................................................................................................

១២- តើអ្នកស្គាល់ លោក/លោកស្រី ដែលបានទទួល ការបណ្តុះបណ្តាល/គ្រាប់ពូជ/កម្ចី/ការលើកទឹកចិត្ត ពីគម្រោងនេះទេ? បើមានសូមរៀបរាប់ៈ

.......................................................................................................

.......................................................................................................

.......................................................................................................

១៣- តើអ្នកបានដឹងអ្វីទៀតពីគម្រោងនេះទេ? បើមានសូមរៀបរាប់ៈ

.......................................................................................................

.......................................................................................................

.......................................................................................................

១៤- តើអ្នកមានចំណាប់អារម្មណ៍យ៉ាងណាចំពោះគម្រោងនេះ?

- ល្អ? ហេតុអ្វី?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

- មិនល្អ? ហេតុអ្វី?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៥- ផលប្រយោជន៏? តើផលប្រយោជន៏អ្វីខ្លះ? សូមពន្យល់អោយបានលំអិត

..........................................................................................................................................

..........................................................................................................................................

១៦- តើអ្នកចង់ចូលរួមសកម្មភាពគម្រោងនេះទេ? ហេតុអ្វី?

..........................................................................................................................................

..........................................................................................................................................

១៨-តើអ្នកមានយោបល់ ឬសំណូមពរអ្វីទៀតទេ? បើមាន ហេតុអ្វី/អ្វីខ្លះ?

..........................................................................................................................................

..........................................................................................................................................

## ៦: គំរូករណីសិក្សា និងការណែនាំ (អ្នកទទួលផលម្នាក់រៀបរាប់អំពីស្ថានភាព "មុន" និង "ក្រោយ" ការអនុវត្តគម្រោង)

" ជីវភាពរស់នៅរបស់ខ្ញុំមានភាពប្រសើរ ចាប់តាំងពីខ្ញុំបានក្លាយជាសមាជិកសហគមន៍បឹងយក្សឡោម " **លោក ចាន់ ធី** ជាអ្នកទទួលផល នៃគម្រោងកែលំអជីវភាព និងគ្រប់គ្រងធនធានធម្មជាតិ នៃ គ.ជ.អ.ប នៃស្រុកបានលុង ខេត្តរតនៈ គីរី ។ *"ឥឡូវនេះអាហារប្រចាំថ្ងៃរបស់យើងគ្រប់គ្រាន់ ហើយកូនរបស់ខ្ញុំអាចទៅរៀន"* នេះជាសំដីរបស់ **លោក ចាន់ ធី** បន្ទាប់ពីបានចូលរួមគណៈកម្មាធិការសហគមន៍បឹងយក្សឡោម នៅក្នុង



**លោក ដួង ចាន់ធី**

ស្រុកបានលុង ខេត្តរតនៈគីរី ។ សមាជិកគណៈកម្មាធិការបានទទួលកម្ចីខ្នាតតូច និងជំនាញ ដើម្បីបង្កើនប្រាក់ចំណូល នៃគម្រោងកែលំអជីវភាព និងគ្រប់គ្រងធនធានធម្មជាតិ នៃ គ.ជ.អ.ប ។ គណៈកម្មាធិការរៀបចំចាត់ចែងធនធានធម្មជាតិ និងធ្វើការអភិរក្ស និងលើកកំពស់អេកូទេសចរណ៍នៅក្នុងសហគមន៍បឹងយក្សឡោម ។មុនពេលដែលបានទទួលគម្រោងកែលំអជីវភាព និងគ្រប់គ្រងធនធានធម្មជាតិ នៃ គ.ជ.អ.ប **លោក ចាន់ ធី** មានការលំបាកក្នុងការចិញ្ចឹមកូនចំនួន៥ នាក់ និងមានការលំបាកបញ្ជូនពួកគេទៅសាលារៀន។ គាត់បានឆ្លុះបញ្ចាំងថា *"....គ្រួសាររបស់ខ្ញុំក្រណាស់ ខ្ញុំមិនអាចបញ្ជូនកូនទៅរៀនបានទេ។ ឥឡូវនេះខ្ញុំសប្បាយចិត្តណាស់ បើប្រៀបធៀបជាមួយស្ថានភាពកាលពីមុន ។"* មិនមែនតែ **លោក ចាន់ ធី** ម្នាក់ទេដែលគិតដូចនេះ សូម្បីអ្នកភូមិបឹងយក្សឡោមនេះក៏គិតដូច្នេះដែរ។

(**<u>ចំណាំ</u>** : តាមរយៈរឿង នៃគម្រោងនេះ **"ប្រយោជន៍"** អាចត្រូវកត់ត្រាទុកដោយធ្វើការប្រៀបធៀបស្ថានភាពរបស់អ្នកទទួលផល "មុន" និង "ក្រោយ" ការអនុវត្តគម្រោង។ នេះគឺជាឧទាហរណ៍នៃវិធីសាស្ត្រ តាមបែបគុណភាពនៃការ វាយតម្លៃ ដែលទិន្នន័យ និងចំនួនលេខមិនមានគ្រប់គ្រាន់ ដើម្បីកត់ត្រា នូវលទ្ធផល និងផលប៉ះពាល់គម្រោងលើក្រុម អ្នកទទួលផល) វិធីសាស្ត្រនេះត្រូវបានផ្តល់អនុសាសន៍ឱ្យអនុវត្តន៍ ក្នុងការធ្វើការវាយតម្លៃអនុកិច្ចសន្យាជាមួយនឹងវគ្គបណ្តុះបណ្តាលជាច្រើន និងជាមួយអត្ថប្រយោជន៍នៃវគ្គបណ្តុះបណ្តាល នៅពេលដែលយើងមិនមានពត៌មានគ្រប់គ្រាន់)

**សម្ភារៈ និងឧបករណ៏ ដែលត្រូវការ**

១- រៀបចំកម្រងសំណួរមុនពេលធ្វើការសម្ភាសន៏

២- កាមេរ៉ា

៣- ប្រដាប់ថតសម្លេង

៤- ប៊ិច និងក្រដាស់សម្រាប់កត់ត្រា

**ចុះទៅមូលដ្ឋាន/ចូលទៅជួបជាមួយនឹងអ្នកដែលត្រូវសម្ភាសន៏ៈ**

ក- ណែនាំខ្លួនអ្នក និងពន្យល់ពីគោលបំនង។

ខ- សុំការអនុញ្ញាតិក្នុងការប្រើប្រាស់រូបភាពរបស់គាត់ និងឈ្មោះ (អាចប្រើឈ្មោះក្លែងក្លាយប្រសិនបើគាត់មានការព្រួយបារម្ភណ៏)

គ- ធ្វើឱ្យអ្នកឆ្លើយមានអារម្មណ៏ល្អ មុនពេលដែលអ្នកចាប់សួរសំណួរដូចខាងក្រោមៈ

១- កាលបរិច្ឆេទ ..........

២- ឈ្មោះសកម្មភាព ..........

៣- ឈ្មោះខេត្ត ..........

៤- ឈ្មោះស្រុក ..........

៥- ឈ្មោះឃុំ ..........

៦- ឈ្មោះភូមិ ..........

៧- ឈ្មោះអនុកិច្ចសន្យា ..........

៨- លេខអនុកិច្ចសន្យា ..........

*(សំនួរពីលេខ ៩-១៨ សម្រាប់សម្ភាសន៏ជាមួយអ្នកទទួលផល ដែលបានចូលរួមវគ្គបណ្តុះបណ្តាល។ សំនួរខ្លះមិនអាចធ្វើទៅបានទេក្នុងការ សង្កេតនៅតំបន់អនុវត្តគម្រោង នៃសកម្មភាពខ្លះ)*

៩- ឈ្មោះអ្នកត្រូវសម្ភាសន៏ ..........

១០- អាយុ ..........

១១- ភេទ ..........

១២- ស្ថានភាពគ្រួសារ ..........

១៣- ចំនួនកូន? ប្រុស? ស្រី? ..........

១៤- កម្រិតវប្បធម៌? ............................................................................................................

១៥- មុខរបរ? ..................................................................................................................

១៦- សកម្មភាពរកប្រាក់ចំណូលសំខាន់ៗ? ...................................................................................

១៧- តើអ្នកបានចូលរួមសកម្មភាពគម្រោងនៅពេលណា?

.......................................................................................................................................

១៨- តើហេតុអ្វីបានជាអ្នកចូលរួមក្នុងសកម្មភាពគម្រោងនេះ?

.......................................................................................................................................

.......................................................................................................................................

១៩- តើសកម្មភាពនេះមានប្រយោជន៍កម្រិតណាចំពោះអ្នកទទួលផល?

.......................................................................................................................................

.......................................................................................................................................

២០- តើអ្នកទទួលផលបានទទួលនូវផលប្រយោជន៍អ្វីខ្លះពីសកម្មភាពនេះ?

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

២១- តើពួកគេពេញចិត្តនឹងសកម្មភាពនេះកម្រិតណា?

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

២២- តើអ្នកទទួលផលមានការប្តេជ្ញាចិត្តក្នុងការបន្តគម្រោងកម្រិតណា?

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

២៣- ប្រៀបធៀបអំពីស្ថានភាពរបស់អ្នកមុនការអនុវត្តគម្រោង តើឥឡូវនេះអ្នកឃើញ មានការផ្លាស់ប្តូរឬទេ? ស្ថានភាពរបស់អ្នកមានការប្រសើរឡើងឬទេ? ប្រសិនបើបានប្រសើរសូមធ្វើការពិពណ៌នា

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................................

២៤- តើសកម្មភាពដែលអ្នកកំពុងធ្វើនេះអាចនៅបន្តទៅមុខដែរឬទេ? សូមពន្យល់អោយបានលំអិត

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

២៥- តើសកម្មភាពនេះអាចយកទៅអនុវត្តនៅតំបន់ផ្សេងទៀតបានដែរឬទេ? ដោយរបៀបណា? ហេតុអ្វី?

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

២៦- តើអ្នកភូមិដទៃទៀតគិតយ៉ាងដូចម្តេចចំពោះសកម្មភាពរបស់គម្រោងនេះ? តើពួកគេមានបំណងចង់ចូលរួមឬទេ? ហេតុអ្វី? *(សម្ភាសន៍អ្នកភូមិជិតខាងពួកគេ)*

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

# ៧ : គំរូប្រអប់សម្រាប់ "ការដកស្រង់សំដី" នៃអ្នកទទួលផលដែលត្រូវបានសម្ភាសន៍

**តើអ្វី ដែលអ្នកទទួលផលត្រូវនិយាយអំពីការវិនិយោគគម្រោង និងសេវាកម្មដែលផ្តល់ឱ្យ?**

" ផ្លូវធ្វើឱ្យការធ្វើដំណើរ និងដឹកជញ្ជូនងាយស្រួលជាងមុន..... ទឹកជួយឱ្យបានសុខភាពល្អ និងសន្សំសំចៃពេលវេលា" **០៦ មេឃុំ, DWS001**

" គ្មានជំងឺច្រើនដូចពេលមុនទេ" **អ្នកប្រើប្រាស់ទឹក DWS_3**

" ខ្ញុំគិតថាផ្លូវល្អនៅតែជាអាទិភាពទី១សម្រាប់ប្រជាជននៅជនបទ ដើម្បីលើកកំពស់ជីវភាពរបស់ពួកគេ..." **មេភូមិ ស្រែង**

" ពីមុនអ្នកទៅធ្វើការនៅភ្នំពេញ ត្រូវតែស្នាក់នៅទីនោះ ប៉ុន្តែឥឡូវផ្លូវល្អ ពួកគេអាចទៅធ្វើការនៅពេលព្រឹកហើយអាចត្រលប់មក ផ្ទះវិញនៅពេលល្ងាច ហើយសុវត្ថិភាពក៏ប្រសើរជាងមុនដែរ" **-១៥ មេឃុំ គម្រោងផ្លូវ R001**

"ចាប់តាំងពីពេលប្រឡាយទឹកត្រូវបានសាងសង់ឡើង អ្នកដែលមានមានដីនៅក្បែរប្រឡាយនោះ អាចបង្កបង្កើនផល ក្នុងរដូវប្រាំង។ នៅរដូវវស្សាមានទឹកជាច្រើននៅក្នុងប្រឡាយទឹក ប្រជាពលរដ្ឋក៏អាចរកត្រីបានផងដែរ" **-១៣ ម្ចាស់ដី គម្រោងធារាសាស្ត្រ**

<u>ប្រភព:</u> ការអង្កេតតាមដានកាលពីឆ្នាំ២០០៨ លើការអង្កេតទិន្នន័យដើមនៃសេដ្ឋកិច្ចសង្គមកាលពីឆ្នាំ២០០៣ របស់ផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃអង្គភាពគាំទ្រកម្មវិធី នៃគ.ជ.អ.ប

<u>ចំណាំ</u> : នៅពេលដែលផលប្រយោជន៍ នៃអនុកិច្ចសន្យាមិនបានត្រូវបានមើលឃើញជារូបរាង (ឧទាហរណ៍ៈ លទ្ធផលនៃវគ្គបណ្តុះបណ្តាល) មតិយោបល់ និងពតិត្រលប់របស់អ្នកទទួលផលអំពី "ផលប្រយោជន៍ "។ ផលប្រយោជន៍ទាំងនេះអាចទាញយកចេញតាមរយៈការសម្ភាសន៍ស៊ីជម្រៅ និងពិភាក្សាក្រុម។ យើងត្រូវការកាមេរ៉ា និងប្រដាប់ថត សំឡេង ដើម្បីថតការសម្ភាសន៍នេះ។ អ្នកវាយតម្លៃអាចសួរសំណួរដែលបានរៀបចំជាមុន ឬក៏អាចទាញយកផ្នែក ដែលទាក់ទងពីការសម្ភាសន៍ និងពិភាក្សា ដើម្បីប្រើជាការ "ការដកស្រង់សំដី "។ ជាមួយគ្នានេះដែរ កាលបរិច្ឆេទ និងទីកន្លែង នៃការសម្ភាសន៍ ឈ្មោះ និងទំនាក់ទំនង ទៅនឹងគម្រោង គួរតែត្រូវបានកត់ត្រាទុក។

## ៨ : បញ្ជីដែលពាក់ព័ន្ធការវាយតម្លៃ និងឯកសារយោង "ត្រូវតែអាន"

| ល.រ | ចំណងជើង និងអ្នកនិពន្ធ | ប្រភព |
|---|---|---|
| ១ | សៀវភៅណែនាំប្រព័ន្ធគ្រប់គ្រងទិន្នន័យសីលា (SCD) ខែកក្កដា ២០០២ (ឥឡូវ NCD ) | គ.ជ.អ.ប/PSDD |
| ២ | សៀវភៅណែនាំ ស្តីពីការតាមដាន និងវាយតម្លៃរបស់កម្មវិធីសីលា ក្រុមការងារកម្មវិធីសីលា ឆ្នាំ២០០៣ | គ.ជ.អ.ប/PSDD |
| ៣ | Rosenboom, Jan-Willem, សៀវភៅណែនាំអំពីវគ្គបណ្តុះបណ្តាល លើការត្រួតពិនិត្យ និងវាយតម្លៃគម្រោង ឆ្នាំ១៩៩៩ | PSDD |
| ៤ | TOT វគ្គទី១: ការអភិវឌ្ឍជំនាញសំខាន់៧សម្រាប់ការគ្រប់គ្រង និងវិជ្ជាជីវៈ | គ.ជ.អ.ប/PSDD |
| ៥ | TOT វគ្គទី១: នៃវគ្គបណ្តុះបណ្តាលជំនាញគ្រូបង្គោលៈ ការគ្រោងរៀបចំកម្មវិធី បណ្តុះបណ្តាល ខែមិថុនា ឆ្នាំ២០០៩ ផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយអង្គភាពគាំទ្រកម្មវិធី គ.ជ.អ.ប | គ.ជ.អ.ប/PSDD |
| ៦ | សៀវភៅវគ្គបណ្តុះបណ្តាលជំនាញគ្រូបង្គោល ខែមិថុនា ឆ្នាំ២០១០ ផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយ គោលនយោបាយ អង្គភាពគាំទ្រកម្មវិធី គ.ជ.អ.ប។ | គ.ជ.អ.ប/PSDD |
| ៧ | TOT វគ្គទី២: ការរៀបចំគម្រោង (អនុកិច្ចសន្យា) ការត្រួតពិនិត្យ និងវាយតម្លៃ និងការសរសេររបាយការណ៍ ឆ្នាំ២០១០ របស់ផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ អង្គភាពគាំទ្រកម្មវិធី គ.ជ.អ.ប។ | គ.ជ.អ.ប/PSDD |

# ៩ : ទ្រឹស្តីសំខាន់ៗក្នុងការវាយតម្លៃអនុកិច្ចសន្យា ការប្រមូល និងការវិភាគទិន្នន័យ

## ក) តើទិន្នន័យជាអ្វី ?

ទិន្នន័យជាអ្វីដែលប្រមូលបានភ្លាមៗនៅរាយប៉ាយដែលមិនទាន់ឆ្លងកាត់ការវិភាគ/សំអាត។ ឧ. ២០ និង ១០%វាជាទិន្នន័យឆៅ និងគ្មានន័យអ្វីទេ។ ដើម្បីឱ្យទិន្នន័យមានន័យ ត្រូវយកវាមកបកស្រាយនិងវិភាគ។ ម្យ៉ាងទៀត ទិន្នន័យជាការប្រមូលការពិត ដើម្បីធ្វើសេចក្តីសន្និដ្ឋានសម្រាប់ អនុកិច្ចសន្យាមួយ។

## ខ) ការប្រមូលទិន្នន័យ សម្រាប់ការវាយតម្លៃអនុកិច្ចសន្យា

**ការប្រមូលទិន្នន័យ** ជាដំណើរការរៀបចំ និងប្រមូលទិន្នន័យទាក់ទងទៅនឹង ការវាយតម្លៃអនុកិច្ចសន្យា។

ដំណើរការប្រមូលទិន្នន័យរួមមាន សកម្មភាពមុនប្រមូល ដូចជាកំណត់ទិន្នន័យដែលត្រូវការ និងវិធីសាស្ត្រពាក់ព័ន្ធនិង ការប្រមូល និងវិភាគទិន្នន័យដែលប្រមូលបាន ។ មានវិធីសាស្ត្រ និងឧបករណ៍ ប្លែកៗជាច្រើនសម្រាប់ប្រមូល និង វិភាគទិន្នន័យ។ តម្រូវការទិន្នន័យសម្រាប់ការវាយតម្លៃអនុកិច្ចសន្យា មានទំនាក់ទំនងជិតស្និទ្ធិតាំងពីក្របខណ្ឌ័ការងារ វាយតម្លៃ និងសំណួរវាយតម្លៃ។

## គ) ប្រភេទទិន្នន័យ

- <u>ទិន្នន័យជាបរិមាណ:</u> សំដែងជាចំនួន (ចំនួនមនុស្ស ចំនួនស្ត្រី និងចំនួនបុរស) និងអត្រា (% នៃស្ត្រី)
- <u>ទិន្នន័យជាគុណភាព:</u> សំដែងជាពាក្យ ពិពណ៌នាការសង្កេត សកម្មភាព គំនិត ជំនឿ កម្រិតនៃការចូលរួម និងអារម្មណ៍

***<u>សូមចំណាំ</u>** : ជាទូទៅ ការវាយតម្លៃអាចប្រើទិន្នន័យទាំងពីរប្រភេទបញ្ចូលគ្នា ។*

## ឃ) ប្រភពទិន្នន័យសំខាន់ៗសម្រាប់វាយតម្លៃអនុកិច្ចសន្យា

- របាយការណ៍រីកចំរើន (របាយការណ៍ពិពណ៌នា និងហិរញ្ញវត្ថុ)
- ការសង្កេត នៅពេលចុះមូលដ្ឋាន
- ការពិគ្រោះយោបល់ សម្ភាសន៍ និងពិភាក្សាជាក្រុម ជាមួយអ្នកទទួលផល/សិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាល/អ្នកផ្តល់ពតិមាន និងភ្នាក់ងារអភិវឌ្ឍ។
- ឯកសារអនុកិច្ចសន្យាដែលចុះហត្ថលេខារួច (កិច្ចសន្យាជាមួយរដ្ឋាភិបាល)

- បញ្ជី និងឯកសារអនុកិច្ចសន្យា ដែលរួមទាំងឯកសារនៅក្នុងប្រព័ន្ធទិន្នន័យកិច្ចសន្យា
- ការប្រជុំ និងឯកសារស្តីពីការរំលឹកការរីកចំរើន

## ង) ជំហានវិធីសាស្រ្ត និងឧបករណ៍ក្នុងការប្រមូលទិន្នន័យ

ខាងក្រោមនេះជាជំហានសំខាន់ៗ :

#1) កំនត់ប្រភពទិន្នន័យដែលអាចរកបាន (ឯកសារ និងអ្នកផ្តល់ពត៌មាន)

#2) ជ្រើសរើសវិធីសាស្រ្តប្រមូលទិន្នន័យ ដែលសមរម្យបំផុតក្នុងការឆ្លើយសំណួរវាយតម្លៃ ។

#3) គ្រោង និង/ឬកែតម្រូវទម្រង់នៃការប្រមូលទិន្នន័យ (នៅពេលដែលគ្មានក្នុងសៀវភៅ និងគោលការណ៍ណែនាំ)

#4) បង្កើតបញ្ជីទិន្នន័យដែលត្រូវការ សម្រាប់ការវាយតម្លៃ

#5) អនុវត្តការប្រមូលទិន្នន័យ

**<u>វិធីសាស្រ្ត:</u>**

- ពិនិត្យសំភារៈ និងឯកសារដែលមាន (ប្រភពពត៌មានទីពីរ)
- ការសង្កេតផ្ទាល់ (ចុះមូលដ្ឋាន)
- សម្ភាសន៏ (បុគ្គល ក្រុម និងអ្នកផ្តល់ពត៌មានសំខាន់ៗ)
- ការពិភាក្សាក្រុម
- ការស្ទង់មតិ
- ការវាយតម្លៃរហ័ស
- ករណីសិក្សា

**<u>ឧបករណ៏:</u>**

- បញ្ជីសង្កេត
- បញ្ជីសំណួរសម្រាប់សម្ភាសន៏ សម្រាប់ការស្ទង់មតិ
- ការណែនាំអំពីការពិភាក្សាផ្តោតលើក្រុម និងការឆ្លុះបញ្ចាំងប្រចាំឆ្នាំរបស់មន្ទីរវិស័យ (ឧបករណ៏លេខ ២.២)
- ការណែនាំអំពីការសម្ភាសន៏លំអិត
- ទម្រង់ និងគំរូសម្រាប់សរសេររបាយការណ៏

- ❖ កាម៉េរ៉ា/ឧបករណ៍ថតសំលេង និងវីដេអូ

## ច) ការវិភាគទិន្នន័យ

ទិន្នន័យ អាចមានន័យបាននៅពេលវាត្រូវបានសង្ខេប វិភាគ និងបកស្រាយដោយធៀប ទៅនឹងសកម្មភាព និងលទ្ធផលអនុកិច្ចសន្យា។ ការវិភាគ គឺជាដំណើរការសង្ខេប និងរៀបចំពតិមាន និងធ្វើអោយទិន្នន័យមានន័យ។ ការ វិភាគ ចាំបាច់ណាស់សម្រាប់ជួយក្នុងការសម្រេចចិត្ត។ ដូចគ្នាដែរ ជំនាញបកស្រាយ វិភាគ និងចងក្រងទិន្នន័យក៏សំខាន់ដែរ។

ដើម្បីវិភាគទិន្នន័យជាបរិមាណ ត្រូវប្រើលេខកូដ ដាក់តាមប្រភេទ គណនាមធ្យមភាព ភាគរយ និងតារាងសង្ខេបទិន្នន័យ។ ចំពោះទិន្នន័យជាទិន្នន័យអំពីអារម្មណ៍ ឥរិយាបថ មិនអាចសង្ខេបដោយប្រើវិធីនេះទេ។ អ្នកអាចដាក់លេខកូដសម្រាប់ចម្លើយនីមួយៗ រួចរាប់ចំនួនដងនៃចម្លើយទាំងនោះ។

## ឆ) វិធីសាស្ត្រវិភាគទិន្នន័យដែលនិយមប្រើ

- ❖ ប្រមូលទិន្នន័យនៅដាក់ក្នុងប្រភេទដែលដូចគ្នា
- ❖ បង្កើតតារាង
- ❖ គណនាអត្រាដូចជាភាគរយ
- ❖ បកស្រាយទិន្នន័យសង្ខេប ដោយធៀបនឹងលទ្ធផលរំពឹងទុករបស់អនុកិច្ចសន្យា

## ជ) ឧបករណ៍វិភាគទិន្នន័យដែលនិយមប្រើ

- ❖ ម៉ាស៊ីនគិតលេខ
- ❖ កម្មវិធី SPSS ( មិនបានបញ្ចូលក្នុងមេរៀននេះទេ)
- ❖ កម្មវិធី Excel
- ❖ កម្មវិធី Access

<u>សូមសំគាល់គន្លឹះខាងក្រោម :</u>

១) សូមមើលទិន្នន័យសង្ខេបដើម្បីស្វែងរកទំនាក់ទំនងរវាងសំណួរវាយតម្លៃ។ សូមគិតមើលថាតើ អ្នកនឹងបានសេចក្តីសន្និដ្ឋានដូចម្តេច ដោយធៀបនឹងគោលបំណង និងសំនួរវាយតម្លៃ។

២) រៀបចំទុកដាក់លទ្ធផលទៅតាមសំណួរវាយតម្លៃសំខាន់ៗ ហើយស្របទៅនឹងក្របខ័ណ្ឌការងារវាយតម្លៃ និងសៀវភៅកិច្ចការសរសេររបាយការណ៍។

៣) មើលក្នុងទិន្នន័យ និងស្វែងរកភាពខុសគ្នា ប្លែកគ្នា និងផ្ទុយគ្នា។ វិនិច្ឆ័យកម្រិតសារៈសំខាន់នៃពត៌មានដែលអ្នកមាន។

៤) ឆ្លុះបញ្ចាំង និងត្រួតពិនិត្យឡើងវិញ។

៥) ប្រើក្រាហ្វិក តារាងការងារតាមរដូវកាល ផែនទី គំនូរ រូបថត មាត្រា/កម្រិត និងឧបករណ៍ជំនួយក្នុងការបង្ហាញ និងវិភាគដែលពាក់ព័ន្ធផ្សេងៗទៀត។

៦) ត្រូវចេះរិះគន់ខ្លួនឯង : តើការវិភាគនេះ មានន័យសម្រាប់អ្នក និងអនុកិច្ចសន្យាឬទេ ?

៧) លទ្ធផល និងសេចក្តីសន្និដ្ឋាន ត្រូវតែស្របគ្នា និងមិនត្រូវផ្ទុយគ្នាឡើយ។

**លំហាត់សម្រាប់អនុវត្តខ្លួនឯងដោយប្រើប្រាស់ទិន្នន័យការរំពឹងទុករបស់អ្នកចូលរួមកាលពីវគ្គបណ្តុះបណ្តាលម៉ូឌុល ១ (នៅខេត្តកែប)**

**ជំហានទី១ : ការបញ្ចូលទិន្នន័យ**

| **សំណួរទី ១** : សូមរៀបរាប់ចំណេះដឹង និងជំនាញអំពី M&E អនុកិច្ចសន្យា/គម្រោងចំនួន ៥ ដែលអ្នកត្រូវការអភិវឌ្ឍ: | **សំណួរទី ២** : តើអ្នករំពឹងថានឹងទទួលបានអ្វីខ្លះពីសិក្ខាសាលានេះ សម្រាប់យកត្រលប់ទៅវិញ ? |
|---|---|
| **បុគ្គលទី១ : (ប្រុស)**<br>✓ ការត្រួតពិនិត្យ និងវាយតម្លៃ<br>✓ ការសរសេររបាយការណ៍<br>✓ ការគ្រប់គ្រងគម្រោង<br>✓ ការរៀបចំក្របខ័ណ្ឌការងារ M&E<br>✓ ការធ្វើបទបង្ហាញ<br><br>**បុគ្គលទី២ : (ប្រុស)**<br>✓ ការត្រួតពិនិត្យ និងវាយតម្លៃ<br>✓ ការសរសេររបាយការណ៍<br>✓ ការធ្វើផែនការ<br>✓ ការគ្រប់គ្រងគម្រោង<br>✓ ការធ្វើបទបង្ហាញ<br><br>**បុគ្គលទី៣ : (ប្រុស)**<br>✓ ការត្រួតពិនិត្យ និងវាយតម្លៃ | **បុគ្គលទី១ :**<br>✓ យល់ពីតួនាទី និងការទទួលខុសត្រូវរបស់ មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ<br>✓ របៀប ត្រួតពិនិត្យ និងវាយតម្លៃ<br>✓ លើកកំពស់សមត្ថភាព<br><br>**បុគ្គលទី២ :**<br>✓ ទទួលបានចំណេះដឹងបន្ថែមលើមុខវិជ្ជាជីវៈ<br>✓ របៀប ត្រួតពិនិត្យ និងវាយតម្លៃ<br>✓ ស្គាល់កាន់តែច្បាស់ពីការ ត្រួតពិនិត្យ និងវាយតម្លៃ<br><br>**បុគ្គលទី៣ :**<br>✓ យកចំណេះដឹងទៅអនុវត្តក្នុងអង្គភាព<br>✓ ផ្សព្វផ្សាយបន្ត<br>✓ លើកកំពស់សមត្ថភាព |

| | |
|---|---|
| ✓ ការសសេរបាយការណ៍<br>✓ ជំនាញទំនាក់ទំនង<br>✓ ការធ្វើបទបង្ហាញ<br>✓ ការប្រមូល និងវិភាគពតិមាន<br><br>**បុគ្គលទី៤ :** (**ស្រី**)<br>✓ ការត្រួតពិនិត្យ និងវាយតម្លៃ<br>✓ ការធ្វើផែនការ<br>✓ ជំនាញទំនាក់ទំនង<br>✓ ជំនាញគ្រប់គ្រង<br>✓ ការធ្វើរបាយការណ៍<br><br>**បុគ្គលទី៥:** (**ស្រី**)<br>✓ ជំនាញ ត្រួតពិនិត្យ និងវាយតម្លៃ<br>✓ ការធ្វើផែនការ<br>✓ ការធ្វើរបាយការណ៍<br>✓ ជំនាញកុំព្យូទ័រ<br>✓ របៀបរបប/បែបបទទូទាត់ថវិកា | **បុគ្គលទី៤ :**<br>✓ ចំណេះដឹង និងបទពិសោធន៍ល្អៗ<br>✓ ទទួលបានចំណេះដឹងបន្ថែមលើមុខវិជ្ជាជីវៈ<br>✓ របៀបអនុវត្តការងារអោយបានល្អប្រសើរ<br><br>**បុគ្គលទី៥:**<br>✓ ចំណេះដឹង និងបទពិសោធន៍ល្អៗ<br>✓ អនុវត្តការងារបានល្អ ពេលអនាគត<br>✓ មានជំនាញច្បាស់លាស់ពេលចុះទៅសហគមន៍ |

## ជំហានទី ២ : ដាក់លេខកូដ

| **សំណួរទី ១** | កូដ | **សំណួរទី ២** | កូដ |
|---|---|---|---|
| **បុគ្គលទី១ :** (**ប្រុស**) | | **បុគ្គលទី១ :** | |
| ✓ ការត្រួតពិនិត្យ និងវាយតម្លៃ | ១ | ✓ យល់ពីតួនាទី និងការទទួលខុសត្រូវ របស់មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ | ១ |
| ✓ ការសរសេររបាយការណ៍ | ២ | | |
| ✓ ការគ្រប់គ្រងគម្រោង | ៣ | ✓ របៀបត្រួតពិនិត្យ និងវាយតម្លៃ | ២ |
| ✓ ការរៀបចំក្របខ័ណ្ឌការងារ M&E | ៤ | ✓ លើកកំពស់សមត្ថភាព | ៣ |
| ✓ ការធ្វើបទបង្ហាញ | ៥ | | |
| | | **បុគ្គលទី២ :** | |
| **បុគ្គលទី២ :** (**ប្រុស**) | ១ | ✓ ទទួលបានចំណេះដឹងបន្ថែមលើមុខវិជ្ជាជីវៈ | ៣ |
| ✓ ការត្រួតពិនិត្យ និងវាយតម្លៃ | ២ | ✓ របៀបតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | ២ |

| | | | |
|---|---|---|---|
| ✓ ការសរសេររបាយការណ៍ | ៦ | ✓ ស្គាល់កាន់តែច្បាស់ពីការត្រួតពិនិត្យ និងវាយតម្លៃ | ២ |
| ✓ ការធ្វើផែនការ | ៣ | | |
| ✓ ការគ្រប់គ្រងគម្រោង | ៥ | | |
| ✓ ការធ្វើបទបង្ហាញ | | **បុគ្គលទី៣ :** | |
| | ១ | ✓ យកចំណេះដឹងទៅអនុវត្តក្នុងអង្គភាព | ៣ |
| **បុគ្គលទី៣ : (ប្រុស)** | ២ | ✓ ផ្សព្វផ្សាយបន្ត | ៣ |
| ✓ ការត្រួតពិនិត្យ និងវាយតម្លៃ | ៧ | ✓ លើកកំពស់សមត្ថភាព | ៣ |
| ✓ ការសសេរបាយការណ៍ | | | |
| ✓ ជំនាញទំនាក់ទំនង | ៥ | | |
| ✓ ការធ្វើបទបង្ហាញ | ៨ | | |
| ✓ ការប្រមូល និងវិភាគពត៌មាន | | **បុគ្គលទី៤ :** | |
| | ១ | ✓ ចំណេះដឹង និងបទពិសោធន៍ល្អៗ | ៣ |
| **បុគ្គលទី៤ : (ស្រី)** | ៦ | ✓ ទទួលបានចំណេះដឹងបន្ថែមលើមុខវិជ្ជាជីវៈ | ៣ |
| ✓ ការត្រួតពិនិត្យ និងវាយតម្លៃ | ៧ | ✓ របៀបអនុវត្តការងារអោយបានល្អប្រសើរ | ២ |
| ✓ ការធ្វើផែនការ | ៩ | | |
| ✓ ជំនាញទំនាក់ទំនង | ២ | **បុគ្គលទី៥:** | |
| ✓ ជំនាញគ្រប់គ្រង | | ✓ ចំណេះដឹង និងបទពិសោធន៍ល្អៗ | ៣ |
| ✓ ការធ្វើរបាយការណ៍ | ១ | ✓ អនុវត្តការងារបានល្អ ពេលអនាគត | ៣ |
| | ៦ | ✓ មានជំនាញច្បាស់លាស់ពេលចុះទៅសហគមន៍ | ២ |
| **បុគ្គលទី៥: (ស្រី)** | ២ | | |
| ✓ ជំនាញ ការត្រួតពិនិត្យ និងវាយតម្លៃ | ១០ | | |
| ✓ ការធ្វើផែនការ | ១១ | | |
| ✓ ការធ្វើរបាយការណ៍ | | | |
| ✓ ជំនាញកុំព្យូទ័រ | | | |
| ✓ របៀបរបប/បែបបទទូទាត់ថវិកា | | | |

**កំណត់ចំណាំ :**

| **កូដសម្រាប់សំណួរទី ១** | **កូដសម្រាប់សំណួរទី ២** |
|---|---|
| ១= ការត្រួតពិនិត្យ និងវាយតម្លៃ<br>២= ការសរសេររបាយការណ៍<br>៣= កាគ្រប់គ្រងគម្រោង | ១= យល់ពីតួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ<br>២= របៀបត្រួតពិនិត្យ និងវាយតម្លៃ |

| | |
|---|---|
| ៤= បង្កើតក្របខ័ណ្ឌការងារ M&E<br>៥= ការធ្វើបទបង្ហាញ<br>៦= ការធ្វើផែនការ<br>៧= ជំនាញទំនាក់ទំនង<br>៨= ការប្រមូល និងវិភាគទិន្នន័យ<br>៩= ជំនាញគ្រប់គ្រង<br>១០= ជំនាញកុំព្យូទ័រ<br>១១= របៀបរបប/បែបបទទូទាត់ថវិកា | ៣. លើកកំពស់សមត្ថភាព (ទទួលចំណេះដឹង និង បទពិសោធន៍ និងអនុវត្តការងារបានល្អនាពេលអនាគត) |

**ជំហានទី ៣ : បូកសរុបចម្លើយ**

| បូកសរុបចម្លើយសម្រាប់សំណួរទី ១ | ចំនួនអ្នកឆ្លើយ | | | ភាគរយ |
|---|---|---|---|---|
| | បុរស | ស្ត្រី | សរុប | |
| ✓ ការត្រួតពិនិត្យ និងវាយតម្លៃ | ៣ | ២ | ៥ | ២០ |
| ✓ ការសរសេររបាយការណ៍ | ៣ | ២ | ៥ | ២០ |
| ✓ ការធ្វើបទបង្ហាញ | ៣ | ០ | ៣ | ១២ |
| ✓ ការធ្វើផែនការ | ១ | ២ | ៣ | ១២ |
| ✓ ជំនាញទំនាក់ទំនង | ១ | ១ | ២ | ៨ |
| ✓ ការគ្រប់គ្រងគម្រោង | ២ | ០ | ២ | ៨ |
| ✓ ផ្សេងៗ | ២ | ៣ | ៥ | ២០ |
| សរុប | ១៥ | ១០ | ២៥ | ១០០ |

| បូកសរុបចម្លើយសម្រាប់សំណួរទី ២ | ចំនួនអ្នកឆ្លើយ | | | ភាគរយ |
|---|---|---|---|---|
| | បុរស | ស្ត្រី | សរុប | |
| ✓ លើកកំពស់សមត្ថភាព | ៥ | ៤ | ៩ | ៦០ |
| ✓ របៀបត្រួតពិនិត្យ និងវាយតម្លៃ | ៣ | ២ | ៥ | ៣៣ |
| ✓ ផ្សេងៗ | ១ | ០ | ១ | ៧ |
| សរុប | ១៥ | ១០ | ២៥ | ១០០ |

## លំហាត់អំពីការសង្ខេបទិន្នន័យជាគុណភាព

**ការណែនាំ :**

ខាងក្រោមគឺជាចម្លើយ (នៃសំណួរគន្លឹះ១ អំពីបញ្ហាក្នុងសហគមន៍) ដកស្រង់ពីការសិក្សានៅមូលដ្ឋាន ដែលជាផ្នែកមួយនៃការវាយតម្លៃ។

ចូរដាក់លេខកូដ ទិន្នន័យទៅតាមន័យរបស់ឃ្លា រឺប្រភេទចម្លើយ។ បន្ទាប់មក បង្កើតតារាងរួមមួយដើម្បីបង្ហាញ លទ្ធផលរួមមាន ភាគរយ សម្រាប់ ប្រភេទចម្លើយនិមួយៗដែលលោកអ្នកបានបង្កើត។

**ចំណាំ:** ដំបូង ដាក់លេខកូដទិន្នន័យទៅតាមលេខកូដចំបងៗ ដែលលោកអ្នកកំណត់ឬរកឃើញ។ ក្នុងករណីចម្លើយមាន (ឬលើក ឡើង)តែម្តងវានឹងមិនតំណាងឱ្យប្រភេទណាមួយនោះទេ។ ដូច្នេះលោកអ្នកអាចដាក់វា បញ្ចូលក្នុងប្រភេទដែលហៅថា "ផ្សេងៗ"។

**សំណួរគន្លឹះ: តើលោកអ្នកជាសមាជិកសហគមន៍សង្កេតឃើញថាបញ្ហាចំបងៗក្នុងភូមិ មានអ្វីខ្លះ?**

**ភូមិ ក**

| | |
|---|---|
| "យើងត្រូវការការអប់រំសម្រាប់កូនចៅយើងទាំងអស់គ្នា។ តើពួកគេនឹងប្រកបការងារអ្វី បើពួកគេពុំបានទទួលការអប់រំអ្វីសោះ?"<br>" ដីធ្លីដាំដុះរបស់យើងកាន់តែអន់ថយទៅៗ។ កាលពី២០ឆ្នាំមុន ទិន្នផលស្រូវយើងផលិតបានពីរដងច្រើនជាងសព្វថ្ងៃ។"<br>" កូនស្រីខ្ញុំពីរនាក់ចង់ទៅរៀន ប៉ុន្តែសាលាដែលជិតជាងគេ មានចំងាយជាង ២០គីឡូម៉ែត្រឯណោះ និងម្យ៉ាងទៀតខ្ញុំត្រូវការឱ្យវាជួយការងារផ្ទះផង។"<br>" នៅពេលដែលអ្នកភូមិឈឺ គឺគាត់ស្លាប់។ ករណីនេះ មិនគួរឱ្យកើតមានតទៅទៀតទេ។"<br>" បើខ្ញុំសន្សំប្រាក់បានខ្លះ ម្លេះខ្ញុំអាចទិញដី និងរបស់របរបានថែមទៀត សម្រាប់គ្រួសារខ្ញុំ "<br>" អ្នកភូមិជុំវិញនេះពុំមានប្រាក់គ្រប់គ្រាន់សម្រាប់ទិញម្ហូបអាហារនិងរបស់របរទេ "<br>" យើងត្រូវការសំភារៈសំណង់ សម្រាប់ជួសជុលផ្ទះ "<br>" គ្លីនិកសុខភាពនៅឆ្ងាយពេក "<br>" ក្មេងជាច្រើនឈឺ ចាប់តាំងពីមានទឹកជំនន់ ឆ្នាំមុន យើងចង់ឱ្យកូនចៅយើងមានសុខភាពល្អ"<br>" ខ្ញុំសំណូមពរឱ្យក្រុមផ្សព្វផ្សាយ បង្ហាញយើងអំពីរបៀបដាំដំណាំផ្សេងៗទៀត ដែលមានជីវជាតិល្អសម្រាប់ម្ហូបអាហារ "<br>" ខ្ញុំចង់បញ្ជូនកូនទាំងអស់ទៅសាលា ដើម្បីគេអាចរកការងារល្អៗធ្វើនៅភ្នំពេញ "<br>" បើខ្ញុំសន្សំប្រាក់បានខ្លះ ម្លេះខ្ញុំអាចទិញដី និងរបស់របរបានថែមទៀត សម្រាប់គ្រួសារខ្ញុំ "<br>"ទំនិញឡើងថ្លៃរាល់ពេល ចំណែកប្រាក់ចំណូលយើងនៅតែដដែល។ យើងគ្មានប្រាក់ទិញប្រេងឆា និងម្ហូបផ្សេងទៀតសម្រាប់ចម្អិនទេ " | **កូដ** |

**<u>ភូមិ ខ</u>**

| | |
|---|---|
| " បើខ្ញុំសន្សំប្រាក់បានខ្លះ ម្ល៉េះខ្ញុំអាចទិញដី និងរបស់របរបានថែមទៀត សម្រាប់គ្រួសារខ្ញុំ "<br>" យើងត្រូវការទឹកថែមទៀតសម្រាប់ស្រោចស្រពផលដំណាំរបស់យើង។<br>ពីឆ្នាំមុននៅតាមប្រឡាយសឹងតែគ្មានទឹកសោះ កសិករជាច្រើន មិនអាចទទួលផលដំណាំបានល្អ "<br>" យើងគួរតែរកសាលាថ្មី។ សាលាយើងសព្វថ្ងៃនេះ មានក្មេងរៀនច្រើនពេក។ ដូច្នេះហើយក្មេងៗទាំងនោះ ត្រូវតែអង្គុយផ្ទាល់លើកំរាលឥដ្ឋដែលមិនស្អាត "<br>" បើខ្ញុំសន្សំប្រាក់បានខ្លះ ម្ល៉េះខ្ញុំអាចទិញដី និងបញ្ជូនកូនទៅ រៀននៅមហាវិទ្យាល័យ"<br>" លោកអ្នកឃើញហើយថាអ្នកភូមិឈឺ និងក្មេងៗមិនមានសុខភាពល្អ។ យើងត្រូវការបុគ្គលិកជំនាញខាង សុខភាពដ៏ល្អជាងនេះ "<br>" គិលានុបដ្ឋាកនៅគ្លីនិកមិនចេះពីជំងឺអ្វីសោះ ចំណែកការព្យាបាលរបស់គាត់ក៏មិនបានល្អ។ "<br>" យើងត្រូវការឥណទានដើម្បីចាប់ផ្តើមមុខជំនួញថ្មី។ អ្នកភូមិភាគច្រើន មានប្រាក់ចំណូលតិចតួចណាស់ រឺក៏គ្មាន ប្រាក់ចំណូលសោះតែម្តង "<br>" លុយ, លុយ, លុយ។ ពិភពលោកសព្វថ្ងៃវិលដោយសារលុយ លោកដឹងទេ។ "<br>" សំភារៈផ្នែកសុខាភិបាលត្រូវតែល្អជាងនេះ។ "<br>" អ្នកភូមិភាគច្រើននឹងប្រាប់លោកអ្នកថា បញ្ហាគឺសុខភាព ប៉ុន្តែខ្ញុំថា វាមកពីខ្វះខាតលុយ។ បើលោកមានលុយលោក នឹងមានវេជ្ជបណ្ឌិតដ៏ល្អៗសម្រាប់ថែទាំសុខភាព។ "<br>" យើងត្រូវការដាំដំណាំថែមទៀត។ ដូច្នេះយើងត្រូវការជី ពូជល្អៗ និងទឹកសម្រាប់ស្រោចស្រពគ្រប់គ្រាន់ "<br>" ខ្ញុំចង់ឱ្យកូនខ្ញុំមានការងារធ្វើគ្រប់ៗគ្នា ។ ពួកគេមិនចង់ធ្វើស្រែចំការទេ ។ ម្យ៉ាងទៀតបើគេមិនអាចរកលុយបាននៅទីនេះខ្ញុំខ្លាចក្រែងវាចាកចេញទៅទីក្រុង។"<br>" យើងទាំងអស់គ្នានៅក្នុងសហគមន៍នេះក្រណាស់។ ក្រមែន តែសប្បាយ។ "<br>" ពីអាទិត្យមុនខ្ញុំមានស្រូវលក់ ១០០គីឡូក្រាម ប៉ុន្តែលក់បានថោកពេក។ តើឱ្យខ្ញុំរស់ដូចម្តេចទៅបើលក់បានលុយតិច អញ្ចឹងចំណែករបស់របរឯទៀត ថ្លៃដូចពេជ្រ "<br>" ខ្ញុំគិតថាបញ្ហាធំជាងគេ គឺមនុស្សគ្រប់គ្នាក្នុងសហគមន៍នេះ ខ្ជិលពេក។ "<br>" យើងត្រូវការវេជ្ជបណ្ឌិតដែលមានថ្វីដៃចំណានៗថែមទៀត។ "<br>" ប្រជាជនភាគច្រើនជុំវិញនេះប្រហែលជាប្រាប់លោកថា សុខភាពគឺជាបញ្ហាចំបង ប៉ុន្តែខ្ញុំគិតថា ប្រាក់ចំណូល។ ប្រជាជនភាគច្រើនក្រណាស់។ " | **កូដ** |

## ១០ ៈ គន្លឹះក្នុងការសរសេររបាយការណ៍ប្រកបដោយប្រសិទ្ធភាព

១) ប្រើភាសាសាមញ្ញប្រចាំថ្ងៃ និងមិនបច្ចេកទេស ដើម្បីពិពណ៌នាការផ្លាស់ប្តូរ។

២) ប្រើប្រយោគខ្លី សាមញ្ញ និងល្បះកម្ម

៣) ច្បាស់លាស់ និងចំៗ (ពិពណ៌នាអោយបានតិចបំផុត)។ ធ្វើអោយរបាយការណ៍ខ្លីបំផុតតាមដែលអាចធ្វើបាន។

៤) ប្រៀបធៀបការងារជាក់ស្តែង និងសមិទ្ធិផលដែលសម្រេចបាន ជាមួយគោលដៅ និងលទ្ធផលដែលបានគ្រោងទុក។ ភ្ជាប់ទំនាក់ទំនងរវាងលទ្ធផល ជាមួយសូចនាករជោគជ័យ និងអត្ថប្រយោជន៍ដែលរំពឹងទុក។

៥) ដឹងថាអ្នករាយការណ៍អោយអ្នកណា (អ្នកគ្រប់គ្រងផ្ទាល់ ឬអ្នកផ្តល់ជំនួយ?)

៦) ប្រើក្រាហ្វិក តារាងសង្ខេប ។ល។ សម្រាប់លទ្ធផលជាបរិមាណ។

៧) ប្រើរូបថត ករណីសិក្សា ស្រង់សំដីពីការសម្ភាសន៍ និងវីដេអូសម្ភាសន៍

៨) បន្សំនៃលទ្ធផលជាបរិមាណ និងគុណភាព ធ្វើអោយរបាយការណ៍មានប្រសិទ្ធភាព

៩) បញ្ជី និងការពិពណ៌នាអំពីវគ្គបណ្តុះបណ្តាល មិនចាំបាច់ទេ។ អ្វីដែលចាំបាច់/សំខាន់ គឺតើវគ្គបណ្តុះបណ្តាល ជួយបង្កើនចំណេះដឹង និងជំនាញ ក្នុងការអនុវត្តការងារ និងផ្តល់សេវាកាន់តែប្រសើរឡើង ដូចម្តេច។

១០) របាយការណ៍អំពីការប្រជុំ និងពិគ្រោះយោបល់ ត្រូវរៀបរាប់ពីអ្វីដែលបានព្រមព្រៀង ឬការប្តេជ្ញាអ្វីខ្លះ ដែលបានធ្វើឡើង។

១១) របាយការណ៍អំពីការស្ទង់មតិ ត្រូវរៀបរាប់ពីការរកឃើញសំខាន់ៗ ការព្រមព្រៀងជុំវិញរបកគំហើញនោះ និងសកម្មភាពបន្ត។

១២) ការថ្លែងថា "ការផ្លាស់ប្តូរដែលបានកើតមានឡើង" គួរបញ្ជាក់អោយច្បាស់ពីអ្វីដែលបានផ្លាស់ប្តូរនោះ។

១៣) របាយការណ៍បែបរៀបរាប់ ត្រូវតែបន្សុំទៅនឹងរបាយការណ៍ហិរញ្ញវត្ថុ

១៤) ចូរចាប់ផ្តើមសរសេររបាយការណ៍របស់អ្នកដោយផ្តោតលើ ឬ ពីលទ្ធផលទៅអត្ថប្រយោជន៍។

### តើត្រូវកែលំអដូចម្តេច ?

- សិក្សា និងអនុវត្តអំពីវិធីវិភាគ បកស្រាយ និងប្រើព័តិមាន អោយស្របនឹងទិសដៅ អត្ថប្រយោជន៍ រំពឹងទុក និងផលប៉ះពាល់ដែលអាចកើតឡើងក្នុងបរិបទធំរបស់អនុកិច្ចសន្យា ដែលមានដូចជា គ.ជ.អ.ប និងកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ អភិបាលកិច្ចល្អ និងការកាត់បន្ថយភាពក្រីក្រ។
- សិក្សា និងអនុវត្តគន្លឹះនៃការសរសេរប្រកបដោយប្រសិទ្ធភាព
- សិក្សា និងអនុវត្តជំនាញបទបង្ហាញ

- ❖ ប្រើក្រាហ្វិក (រូបភាព តារាង អត្រា ការប្រៀបធៀប) (សូមមើលគំរូខាងក្រោម)
- ❖ សម្រាប់លទ្ធផលជាគុណភាព និងអនុកិច្ចសន្យាមិនមែនហេដ្ឋារចនាសម្ព័ន្ធ ប្រើរូបថត ករណីសិក្សា សម្រង់សំដីរបស់អ្នកទទួលផល និងវីដេអូសម្ភាសន៍ដល់អ្នកទទួលផល អ្នកចូលរួម។ល។

***ចំណាំ: ឯកសារយោងដែលគួរអាន***

ក) សៀវភៅណែនាំ ស្តីពីការត្រួតពិនិត្យ និងវាយតម្លៃរបស់កម្មវិធីសីលា (២០០៣)

ខ) សៀវភៅណែនាំសម្រាប់វគ្គបណ្តុះបណ្តាល អំពីការត្រួតពិនិត្យ និងវាយតម្លៃគម្រោង (Jan-Willem Rosenboom, 1999)

# រៀបរៀងដោយៈ

**លោក វ៉េហ្សូល ការីម**

**លោក ឃុន ស៊ីថុន**

ទីប្រឹក្សាផ្នែកត្រួតពិនិត្យ វាយតម្លៃរបស់ UNDP/PSDD

# សហការជាមួយៈ

**លោក ប្រាក់ សំអឿន**

ប្រធានផ្នែក ផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ

អង្គភាពគាំទ្រកម្មវិធី គ.ជ.អ.ប.

**លោក លី យ៉ាសាក់**

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ

**លោកស្រី លឹម រត្នពិភស្តុ**

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ

**លោកស្រី ធុយ មោលី**

ទីប្រឹក្សាផ្នែកត្រួតពិនិត្យ និងវាយតម្លៃ

**លោក ឈួន ប៊ុណ្ណា**

ទីប្រឹក្សាសម្របសម្រួលកម្មវិធីបណ្តុះបណ្តាល

**ខែកក្កដា ឆ្នាំ២០១០**

# គម្រោងពង្រឹងសមត្ថភាពគ្រូបង្គោលថ្នាក់ក្រោមជាតិ

## សៀវភៅណែនាំការសរសេររបាយការណ៍វាយតម្លៃ
## អនុកិច្ចសន្យារបស់គណៈកម្មាធិការប្រតិបត្តិ
## គ.អ.ជ.ខ

ផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ
នៃលេខាធិការដ្ឋាន គ.ជ.អ.ប

គាំទ្របច្ចេកទេសពីគម្រោងគាំទ្រការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ

ខែកក្កដា ឆ្នាំ២០១០

# ការវាយតម្លៃអនុកិច្ចសន្យា និងសៀវភៅណែនាំការសរសេររបាយការណ៍វាយតម្លៃ

## *(ការណែនាំអំពីរបៀបប្រើប្រាស់)*

## ✓ កំណត់ចំណាំ

ការសរសេររបាយការណ៍នៃការវាយតម្លៃទាមទារឱ្យមានជំនាញ និងបទពិសោធន៍។ ការវាយតម្លៃអនុកិច្ចសន្យា ឆ្នាំ២០១០គឺសម្រាប់មន្ត្រីផ្នែកត្រួតពិនិត្យ និងវាយតម្លៃថ្នាក់ក្រោមជាតិ និងជនបង្គោលផ្នែកត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីអនុវត្ត និង"រៀនសូត្រដោយអនុវត្ត"នូវការវាយតម្លៃនេះ។ហេតុដូច្នេះ សៀវភៅកិច្ចការនេះ ត្រូវបានរៀបចំឡើង ដើម្បីជួយដល់អ្នកវាយតម្លៃ ក្នុងការសរសេររបាយការណ៍វាយតម្លៃ និងជួយក្នុងការរក្សា នូវការរៀបចំរចនាសម្ព័ន្ធ ទម្រង់ និងឯកសារគាំទ្រផ្សេងៗ។

នៅពេលដែលអ្នកវាយតម្លៃបញ្ចប់កិច្ចការដូចដែលមាននៅក្នុងគោលការណ៍ណែនាំ (ផ្នែកទី១-៤) និងការណែនាំ នៅក្នុងសៀវភៅនេះ បន្ទាប់មកពួកគេនឹងបញ្ចប់របាយការណ៍វាយតម្លៃ ដើម្បីធ្វើការបង្ហាញ។ សៀវភៅកិច្ចការនេះជា មួយនឹងការណែនាំ និងកំណត់ចំណាំផ្សេងៗ នឹងត្រូវបានដកចេញ ហើយវានឹងក្លាយជារបាយការណ៍វាយតម្លៃ ដោយ មិនចាំបាច់សរសេររបាយការណ៍ថ្មីផ្សេងទៀតទេ។

## ✓ ការណែនាំដល់អ្នកវាយតម្លៃ និងអ្នកសរសេររបាយការណ៍វាយតម្លៃអនុកិច្ចសន្យា

**១**-សូមអាននូវការណែនាំ កំណត់ចំណាំ និងខ្លឹមសាររបស់សៀវភៅនេះឱ្យបានច្បាស់លាស់។ រួចហើយអានឡើងវិញ រហូតទាល់តែអ្នកច្បាស់ ហើយចាប់ផ្តើមសរសេរលើសៀវភៅនេះ *(អ្នកនឹងទទួលបានឯកសារនេះជា Soft Copy ក្នុងអំឡុងពេលបណ្តុះបណ្តាល)*

**២**-កំណត់ចំណាំ និងការណែនាំមាននៅគ្រប់ផ្នែកទាំងអស់ថាតើយកទិន្នន័យពីទីណា ហើយនិងរបៀបនៃការប្រើប្រាស់ ទិន្នន័យទាំងនោះ

**៣**-ប្រសិនបើអ្នកមិនច្បាស់អំពីផ្នែកណាមួយ នៃការវាយតម្លៃអនុកិច្ចសន្យា គោលគំនិត វាក្យស័ព្ទដែលពាក់ព័ន្ធនឹង សូមមើលឯកសារខាងក្រោមនេះ ជាមុនសិន :

ក- ផ្នែកទី១-៤ គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា ខែកក្កដា ឆ្នាំ២០១០

ខ- ផ្នែកទី៣ នៃអនុកិច្ចសន្យាដែលកំពុងធ្វើការវាយតម្លៃ

គ- សៀវភៅណែនាំវគ្គបណ្តុះបណ្តាលអំពីការត្រួតពិនិត្យនិងវាយតម្លៃ វគ្គទី១ និងវគ្គទី២ និងឯកសារភ្ជាប់ដែលមាននៅខាងក្នុងសៀវភៅណែនាំនោះ

ឃ- សៀវភៅណែនាំវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យ និងវាយតម្លៃគម្រោង ដោយ Jan-Willem Rosenboom ឆ្នាំ១៩៩៩

ង- សៀវភៅណែនាំស្តីពីការត្រួតពិនិត្យ និងវាយតម្លៃរបស់កម្មវិធីសីលា ឆ្នាំ២០០៣

ច- សៀវភៅណែនាំអំពីប្រព័ន្ធគ្រប់គ្រងទិន្នន័យ NCD ។

៤-យកចិត្តទុកដាក់លើការបញ្ចប់ការវាយតម្លៃ និងសរសេរឱ្យបានច្បាស់លាស់ ហើយសាមញ្ញ (សូមមើលឯកសារគន្លឹះ នៃការសរសេររបាយការណ៍ប្រកបដោយប្រសិទ្ធភាព) ។ សូមរៀបរាប់អំពីចំណុចខ្សោយដែលបានសង្កេតឃើញដោយ អព្យាក្រឹត ដោយប្រើភាសានៃការសរសេរប្រកបដោយការស្ថាបនា ហើយផ្តល់នូវជម្រើសដើម្បីដោះស្រាយបញ្ហាទាំងនោះនាពេលអនាគត

៥-ដកចេញ ឬលុបចោលទំព័រ កំណត់ចំណាំ និងការណែនាំ និងក្រដាស់កិច្ចការនៅពេលដែលអ្នកពង្រាងរបាយការណ៍រួចហើយ ដើម្បីធ្វើបទបង្ហាញ

៦-ស្នើសុំអ្នកចូលរួមវាយតម្លៃពិនិត្យមើលពង្រាងរបាយការណ៍វាយតម្លៃនេះឡើងវិញ

៧-ស្នើសុំសមាជិកក្រុមនៃក្រុមវាយតម្លៃផ្តល់នូវអនុសាសន៍ និងយោបល់ផ្សេងៗ

៨-បញ្ចប់របាយការណ៍ បន្ទាប់ពីបានទទួលនូវព័ត៌មានត្រលប់ពីក្រុមអ្នកពាក់ព័ន្ធ

៩-អបអរសាទរខ្លួនអ្នក និងក្រុមការងារសម្រាប់ការបញ្ចប់ការវាយតម្លៃ និងធ្វើរបាយការណ៍វាយតម្លៃ ព្រមទាំងការ អបអរនូវសមិទ្ធផលដែលអ្នកបានបង្កើតឡើង។

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | |
| ចំណងជើង : | |
| ភ្នាក់ងារអនុវត្តន៏ : | |
| រយៈពេល (ចាប់ផ្តើម និងបញ្ចាប់) | |
| រាជធានី ខេត្ត | |
| ផ្នែក /មន្ទីរជំនាញ | |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ/គ.អ.ជ.ខ | |
| ការរួមចំណែករបស់រាជធានី ខេត្ត | |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៏ | |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | |

## ក្រុមវាយតម្លៃ

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ |
|---|---|
| | |
| | |

## របាយការណ៍ស្តីពីវាយតម្លៃ រៀបចំដោយ :

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ និងតួនាទីក្នុងការវាយតម្លៃ |
|---|---|
| ១) | |
| ២) | |

រាជធានី ខេត្ត..............................

កាលបរិច្ឆេទ :...................................................

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៦៥ |
| | របាយការណ៍សង្ខេប | ៦៦ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៦៨** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៦៨ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៦៨ |
| ១.៣ | គោលបំនង និង ទំហំនៃការវាយតម្លៃ | ៦៩ |
| ១.៤ | សំណួរវាយតម្លៃ | ៦៩ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ៦៩ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ៧១ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **៧៣** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១) | ៧៣ |
| | - លទ្ធផលទី១ | ៧៣ |
| | - លទ្ធផលទី២ | ៧៥ |
| | - លទ្ធផលទី៣ | ៧៧ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម (សំណួរវាយតម្លៃទី៣) | ៧៩ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤) | ៨៣ |
| **២.៤** | **សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី៥)** | **៨៥** |

<u>**សន្លឹកកិច្ចការ**</u> *(ដកចេញនៅពេលដែលរបាយការណ៍ត្រូវបានបញ្ចប់)*

| | | |
|---|---|---|
| ទី១- | សមិទ្ធិផលសំខាន់ៗនៅកម្រិតលទ្ធផល(សម្រាប់ការវាយតម្លៃចំណុច២.១ ) | ៨៧ |
| ទី២- | ផលប្រយោជន៍រយៈពេលខ្លី លទ្ធផល និងអត្ថប្រយោជន៍ (សំណួរវាយតម្លៃលេខ៣) | ៨៩ |
| ទី៣- | ការវាយតម្លៃការរៀបចំអនុកិច្ចសន្យា ភាពជាប់ពាក់ពន្ធ័ និង ការគ្រប់គ្រង តាមរយៈ ការវាយតម្លៃទំនាក់ទំនងសមហេតុផលរវាងសកម្មភាព និងលទ្ធផល រវាងលទ្ធផល និងគោលបំនងបន្ទាន់/ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា និងរវាងគោលបំនងបន្ទាន់ និងលទ្ធផល | ៩២ |
| ទី៤- | ការឆ្លុះបញ្ចាំង ការផ្តល់ព័ត៌មានត្រឡប់ និងអនុសាសន៍ពីភ្នាក់ងារអនុវត្តកិច្ចសន្យា និងទីប្រឹក្សា ត្រួតពិនិត្យ វាយតម្លៃ និង វិស័យ/ប្រធានទីប្រឹក្សា | ៩៤ |

ទី៥- ការឆ្លុះបញ្ចាំង ការផ្តល់ព័ត៌មានត្រឡប់ និងអនុសាសន៍ពីមន្ត្រីបង្គោលយេនឌ័រ និងមន្ត្រីបង្គោលគ្រប់គ្រងធនធានធម្មជាតិ ៩៦

**ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍**

ទី១- បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ ៩៨

ទី២- ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍ /ពិភាក្សា ៩៩

ទី៣- ក្របខណ្ឌការងារវាយតម្លៃអនុកិច្ចសន្យា ១០០

ទី៤- រូបថតឯកសារ ១០២

**ប្រអប់សម្រាប់ដកស្រង់សំដី**

ទី១- តើអ្នកទទួលផលមានអ្វីខ្លះត្រូវនិយាយចំពោះការវិនិយោគនិងសេវាកម្មដែលគាត់បានទទួល? ៨២

**ករណីសិក្សា**

ទី១- " ជីវភាពរស់នៅមានភាពប្រសើរ " — **លោក ចាន់ ធី** អ្នកទទួលផល នៃសហគមន៍បឹងយក្សឡោម នៃគម្រោងកែលម្អជីវភាព និងគ្រប់គ្រងធនធានធម្មជាតិ ៨២

# អក្សរកាត់

*(**កំណត់ចំណាំ :** រៀបរាប់អក្សរកាត់ទាំងអស់ដែលអ្នកប្រើនៅក្នុងរបាយការណ៍ស្តីពីវាយតម្លៃនេះ ដូចខាងក្រោម)*

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

*(**កំណត់ចំណាំ និងការណែនាំ : មិនត្រូវសរសេរផ្នែកនេះ មុនទេ។** សូមសរសេរនៅកន្លែងនេះ នៅពេលដែលអ្នកបានបញ្ចប់ការសរសេរគ្រប់ផ្នែកទាំងអស់នៃរបាយការណ៍។ បញ្ហាលំបាកនៅទីនេះគឺការសង្ខេបរបាយការណ៍នៃការវាយតម្លៃទាំងមូល មិនឱ្យច្រើន ជាង ២ទំព័រ។)*

| គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ :<br>*(សង្ខេបឱ្យបាន៥ប្រយោគ ឬចំណុចនូវគោលបំណងនៃការវាយតម្លៃ ទំហំ និងគោលបំណងពីផ្នែកទី១.២ និង ផ្នែក១.៥ ខាងក្រោម។ ដែនកំណត់សរសេរ : ២ វាក្យខ័ណ្ឌ )* |
|---|
| ឆ្លើយទៅនឹងសំណួរទាំង៥ នៃការវាយតម្លៃ :<br>*(សូមសង្ខេបនូវលទ្ធផលរកឃើញសំខាន់ៗពីការវាយតម្លៃ (ផ្តោតលើចំណុចខ្លាំងដូចជាអត្ថប្រយោជន៍វិជ្ជមាន និងចំណុចខ្សោយនៃ អនុកិច្ចសន្យា)។ មិនត្រូវសរសេរច្រើនជាង ៥ ចំណុចក្នុង១វាក្យខណ្ឌទេ។ ចំនួន៣វាក្យខណ្ឌ = ១៥ចំណុចសំខាន់ៗ តាមរយៈ ចម្លើយសំខាន់ៗទៅនឹងសំណួរនៃការវាយតម្លៃ នៅក្នុងផ្នែកទី២.១ ផ្នែកទី២.២ ផ្នែកទី២.៣ និងផ្នែកទី ២.៤ នៅក្នុងរបាយការណ៍នេះ)។* |

| |
|---|
| សេចក្តីការសន្និដ្ឋានសំខាន់ៗ ផ្តែកទៅលើលទ្ធផលដែលបានរកឃើញ និងផ្តោតទៅលើបទពិសោធន៍ដែលទទួលបាន និងផ្នែកដែលត្រូវកែលម្អឱ្យប្រសើរឡើង (អនុសាសន៍) ដោយសង្ខេបផ្នែក ២.៥ នៃរបាយការណ៍។ ( *ដែនកំណត់សរសេរ : ៥ចំណុច*) |

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្ដីផ្ដើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

*(ការណែនាំ: ប្រើដូចខាងក្រោមនេះ)*

| |
|---|
| រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្ដល់ថវិកាតាមរយៈ គ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និងគម្រោង ដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈ ជាប្រព័ន្ធ មិនបានអនុវត្តទេកាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើន។ នៅក្នុងឆ្នាំ ២០១០ ជាមួយនឹងការគាំទ្រផ្នែកថវិកា និងបច្ចេកទេស ពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យា គ.ប្រ នៃគ.អ.ជ.ខ ក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យា ដែលបានរៀបចំរួមគ្នាជាមួយភ្នាក់ងារអនុវត្តន៍ដែលមានលេខ : *(ដាក់លេខ និងចំណងជើងនៅទីនេះ)* ដំណើរការលទ្ធផលដែលបានរកឃើញ និងការសន្និដ្ឋាន នៃការវាយតម្លៃត្រូវបានកត់ត្រា ហើយនឹងបង្ហាញតាមរយៈរបាយការណ៍ស្ដីពីការវាយតម្លៃនេះ។ |

## ១.២. គោលបំណងអនុកិច្ចសន្យា

(ការណែនាំ : សូមមើលផ្នែកទី៣នៃឯកសារអនុកិច្ចសន្យា ហើយស្រង់យកគោលបំណង នៃអនុកិច្ចសន្យាមកដាក់ខាងក្រោមនេះ)

| |
|---|
| |

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

*(ការណែនាំ: ប្រើដូចខាងក្រោមនេះ: )*

| |
|---|
| គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូល ដោយផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និងតម្លាភាព។ ដូច្នេះ ទំហំនៃការវាយតម្លៃមានដែនកំណត់តាមទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខណ្ឌការងារនៃការវាយតម្លៃ។ គោលបំណង នៃការវាយតម្លៃគឺ: ក) ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និងចំនុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំងកត់ត្រានូវ ចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត និង ខ) ដើម្បីពង្រឹងរបៀបធ្វើការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត។ |

## ១.៤. សំណួរវាយតម្លៃ

(ការណែនាំ: ប្រើដូចខាងក្រោមនេះ: )

| |
|---|
| ១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?<br>២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)<br>៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)<br>៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ?<br>៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ? |

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

*(ការណែនាំ: ប្រើដូចខាងក្រោមនេះ: )*

| |
|---|
| វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើ:<br>១) ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំនត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធដែលមាន |

នៅក្នុងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៍ ។ (*សូមមើលឯកសារភ្ជាប់ជូនទី១*)

២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗ រួមមានៈ អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផលផ្ទាល់ និងមិនផ្ទាល់ ២ ឬ៣នាក់ និងអ្នកពាក់ព័ន្ធ ២នាក់ ។ សូមពិគ្រោះជាមួយនឹងមន្រ្តីបង្គោលទៅលើបញ្ហាយេនឌ័រ និងគ្រប់គ្រងធនធានធម្មជាតិ សម្រាប់បញ្ហាពាក់ពន្ធ័វិស័យខាងលើ ។

៣) សូមប្រើប្រាស់វិធីសាស្រ្តចុះពិនិត្យតំបន់អនុវត្តន៍គម្រោង និងសង្កេតមើលសកម្មភាព ពិភាក្សាក្រុម និងករណីសិក្សា។ (*សូមមើលឯកសារភ្ជាប់ជូនទី២*)

៤) ចុះពិនិត្យតំបន់អនុវត្តន៍គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់ ។ (*សូមមើលឯកសារភ្ជាប់ជូនទី២*)

៥) វិភាគទិន្នន័យ និងបកស្រាយៈ ទិន្នន័យដែលបានប្រមូលតាមវិធីសាស្រ្តខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់

៦) ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ ដោយភ្នាក់ងារអនុវត្តន៍ និងអ្នកពាក់ព័ន្ធតាមរយៈព័ត៌មានត្រឡប់ដែលទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើង (ដាក់កាលបរិច្ឆេទនៃការធ្វើបទបង្ហាញនៅទីនេះ)

ការវាយតម្លៃត្រូវធ្វើតាម "គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា" និងវិធីសាស្រ្តដែលបានណែនាំ។ ដូច្នេះដំណើរការត្រូវបានធ្វើឡើងដោយមានទម្រង់ការណែនាំ និងតម្លាភាព រួមទាំងការចូលរួមពីអ្នកពាក់ព័ន្ធ ។

សូមសរសេរបន្ថែមនៅទីនេះ ប្រសិនបើវិធីសាស្រ្ត និងសម្ភារៈផ្សេងៗ ត្រូវបានប្រើក្រៅពីការរៀបរាប់ខាងលើ :

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

*(ការណែនាំ: រក្សាទុកចំនុចណាដែលអ្នកយល់ស្រប ហើយលុបចោលចំនុចដែលអ្នកមិនយល់ស្រប)*

១) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយ គ.ប្រ និងអ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយការប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត។

២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត : វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោង នៅពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និងបទពិសោធន៍ពីមុនមក។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណងសំខាន់ គឺដើម្បី"រៀនធ្វើដោយការអនុវត្តផ្ទាល់"។ អ្នកវាយតម្លៃ បានទទួលការគាំទ្រដោយមានគោលការណ៍ការណែនាំឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។

៣) បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យា: ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និងជោគជ័យទេ ។ មួយទៀត ទំនាក់ទំនងសង្ខេបតាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់ មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ។

៤) ដោយយើងមិនមានសូចនាករឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍" ដែលជាកម្រិតអត្ថប្រយោជន៍ទៅលើគោលនយោបាយវិម្ឋការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។

៥)ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិតទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ។ យើងអាចវាយតម្លៃតែទៅលើ*(សូមដាក់ឈ្មោះលទ្ធផលដែលបានធ្វើការវាយតម្លៃនៅទីនេះ)* ដែលជាលទ្ធផល និង*(សូមដាក់ឈ្មោះសកម្មភាពដែលបានធ្វើការវាយតម្លៃនៅទីនេះ)* ដែលជាសកម្ម

ភាពនៃអនុកិច្ចសន្យាលម្អិតតាមរយៈការសម្ភាសន៍ស៊ីជម្រៅ ក្រុមពិភាក្សា និងការចុះពិនិត្យតំបន់អនុវត្តគម្រោង។

៦) សូមរក្សាទុកចំណុចនេះប្រសិនបើវាមានសុពលភាព: ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា មិនអាចធ្វើទៅបានទេ ព្រោះចំណុច គ នៃផ្នែកទី៣ក្នុងឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ ឬមិនពេញលេញ។ ការងារនេះ នឹងកាន់តែមានសុពលភាព និងពោរពេញទៅដោយព័តិមាន បើសិនជាចំនុចដែលបានរៀបរាប់ខាងលើនេះត្រូវបានដោះស្រាយ។

**ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធនី:**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ (ដាក់លេខអនុកិច្ចសន្យានៅទីនេះ) និងដែនកំណត់ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ។

២) ការវាយតម្លៃនេះលម្អិតតែទៅលើ *(សូមដាក់ឈ្មោះលទ្ធផលដែលបានធ្វើការ វាយតម្លៃនៅទីនេះ)* ដែលជាលទ្ធផល និង *(សូមដាក់ឈ្មោះសកម្មភាពដែលបានធ្វើការវាយតម្លៃនៅទីនេះ)* ដែលជាសកម្មភាពនៃអនុកិច្ចសន្យា

៣) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃទៅលើ ភ្នាក់ងារអនុវត្តន៍ ភ្នាក់ងារដែលពាក់ព័ន្ធគម្រោង ហើយនឹងការវាយតម្លៃទៅលើគ.ប្រ នៃគ.អ.ជ.ខ និង គ.ជ.អ.ប ទេ។

ហេតុដូច្នេះ របាយការណ៍នៃការវាយតម្លៃ លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ដែលបានលើកឡើង ត្រូវពិនិត្យដោយយោលទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ។

**សូមបន្ថែមបញ្ហាប្រឈមផ្សេងៗ ដែលមិនមានក្នុងការរៀបរាប់ខាងលើ :**

# ២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១)

លទ្ធផលទី១: ការរីកចំរើនជាក់ស្តែងធៀបនឹងផែនការ (ដូចរៀបរាប់ក្នុងផ្នែកទី ៣ នៃអនុកិច្ចសន្យា : ការបរិយាយអំពីកិច្ចសន្យា)

លទ្ធផលទី១ :......................................................................................................................................

**ផ្នែក-ក :** *(ការណែនាំ : ប្រើសន្លឹកការងារទី ១ និងបំពេញសន្លឹកការងារនោះអោយបានច្រើនតាមដែលអាចធ្វើបាន មុននឹងចុះមូលដ្ឋាន ដោយប្រើឯកសារដែលមានស្រាប់ ។ បំពេញបន្ថែមចំណុចខ្វះខាត បន្ទាប់ពីការចុះមូលដ្ឋាន សម្ភាសនិងក្រុមពិភាក្សា ។ បើគ្មានព័ត៌មានអំពីសូចនាករ និងគោលដៅ ចូរកត់ត្រាទុក និងសរសេរចំណុចនេះនៅក្នុងចំណុចរៀនសូត្រ /អនុសាសន៍អំពី សារៈប្រយោជន៍នៃការបង្កើតសូចនាករ ក្នុងដំណាក់កាលរៀបចំផ្នែកទី៣ ។ សូមសរសេរកុំអោយលើសមួយទំព័រ សម្រាប់លទ្ធផល ១) ។ សូមសរសេរដែលដូចគ្នានេះ សម្រាប់លទ្ធផលទាំងអស់នៃកម្មវិធី ។*

| ល.រ<br>(១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា<br>(២) | អ្វីដែលសម្រេចបានជាក់ស្តែង<br>(៣) |
|---|---|---|
| ១.១ | | |
| | | |
| | | |
| | | |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល ធៀបនឹងគោលបំណងបន្ទាន់ (ផលប៉ះពាល់ /លទ្ធផលបឋម រយៈពេលខ្លី/មធ្យមនៃលទ្ធផល) នៃអនុកិច្ចសន្យា

*(ការណែនាំ : សង្ខេបការវាយតម្លៃកម្រិតលទ្ធផល ។ បំពេញនៅពេលដែលប្រមូលបានព័ត៌មានពីប្រភពនានា: ឯកសារ សម្ភាស ក្រុមពិភាក្សា និងចុះពិនិត្យទីតាំងអនុវត្តន៍ ។ សូមប្រើសន្លឹកការងារទី ១ ដែលភ្ជាប់ខាងក្រោយនេះ)*

| |
|---|
| |

| |
|---|
| ការណែនាំ : *មិនត្រូវអោយលើសមួយទំព័រ សម្រាប់លទ្ធផល ១ ។* បន្តធ្វើបែបនេះសម្រាប់លទ្ធផលផ្សេងទៀតនៃកម្មវិធី ។ មិនចាំបាច់ធ្វើបែបនេះទេសម្រាប់លទ្ធផលដូចជា "ការគាំទ្រប្រតិបត្តិការ" "ការត្រួតពិនិត្យ" "ការវាយតម្លៃ" ដែលមិនមែនជាលទ្ធផលកម្មវិធី ។ |

លទ្ធផលទី២: ការរីកចំរើនជាក់ស្តែងធៀបនឹងផែនការ (ដូចរៀបរាប់ក្នុងផ្នែកទី ៣ នៃអនុកិច្ចសន្យា : ការបរិយាយអំពីកិច្ចសន្យា)

លទ្ធផលទី២:......................................................................................................................................................................................................

**ផ្នែក-ក :** *(ការណែនាំ : ប្រើសន្លឹកការងារទី ១ និងបំពេញសន្លឹកការងារនោះអោយបានច្រើនតាមដែលអាចធ្វើបាន មុននឹងចុះមូលដ្ឋាន ដោយប្រើឯកសារដែលមានស្រាប់ ។ បំពេញបន្ថែមចំណុចខ្វះខាត បន្ទាប់ពីចុះមូលដ្ឋាន សម្ភាស និងក្រុមពិភាក្សា ។ បើគ្មានព័ត៌មានអំពីសូចនាករ និងគោលដៅ ចូរកត់ត្រាទុក និងសរសេរចំណុចនេះនៅក្នុងចំណុចរៀនសូត្រ/អនុសាសន៍អំពី សារៈប្រយោជន៍នៃការបង្កើតសូចនាករ ក្នុងដំណាក់កាលរៀបចំផ្នែកទី៣ ។ សូមសរសេរកុំអោយលើសមួយទំព័រ សម្រាប់លទ្ធផល ១) ។ សូមសរសេរដដែលដូចគ្នានេះ សម្រាប់លទ្ធផលទាំងអស់នៃកម្មវិធី ។*

| ល.រ<br>(១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា<br>(២) | អ្វីដែលសម្រេចបានជាក់ស្តែង<br>(៣) |
|---|---|---|
| ១.១ | | |
| | | |
| | | |
| | | |
| | | |
| | | |

**ផ្នែក-ខ** : ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល ធៀបនឹងគោលបំនងបន្ទាន់ (ផលប៉ះពាល់ /លទ្ធផលបឋម រយៈពេលខ្លី/មធ្យមនៃលទ្ធផល) នៃអនុកិច្ចសន្យា

*(ការណែនាំ : សង្ខេបការវាយតម្លៃកម្រិតលទ្ធផល ។ បំពេញនៅពេលដែលប្រមូលបានព័ត៌មានពីប្រភពនានា : ឯកសារ សម្ភាសក្រុមពិភាក្សា និងចុះពិនិត្យទីតាំងអនុវត្តន៍ ។ សូមប្រើសន្លឹកការងារទី ១ ដែលភ្ជាប់ខាងក្រោយនេះ)*

| |
|---|
| |

| |
|---|
| *ការណែនាំ : កុំអោយលើសមួយទំព័រ សម្រាប់លទ្ធផល ១ ។ បន្តធ្វើបែបនេះសម្រាប់លទ្ធផលផ្សេងទៀតនៃកម្មវិធី ។ មិនចាំបាច់ធ្វើបែបនេះទេសម្រាប់លទ្ធផលដូចជា "ការគាំទ្រប្រតិបត្តិការ" "ការត្រួតពិនិត្យ" "ការវាយតម្លៃ" ដែលមិនមែនជាលទ្ធផលកម្មវិធី ។* |

លទ្ធផលទី៣: ការរីកចំរើនជាក់ស្តែងធៀបនឹងផែនការ (ដូចរៀបរាប់ក្នុងផ្នែកទី ៣ នៃអនុកិច្ចសន្យា : ការបរិយាយអំពីកិច្ចសន្យា)

លទ្ធផលទី៣:..........................................................................................................................................................................................................

**ផ្នែក-ក :** *(ការណែនាំ : ប្រើសន្លឹកការងារទី ១ និងបំពេញសន្លឹកការងារនោះអោយបានច្រើនតាមដែលអាចធ្វើបាន មុននឹងចុះមូលដ្ឋាន ដោយប្រើឯកសារដែលមានស្រាប់ ។ បំពេញបន្ថែមចំណុចខ្វះខាត បន្ទាប់ពីចុះមូលដ្ឋាន សម្ភាសនិងក្រុមពិភាក្សា។ បើគ្មានព័ត៌មានអំពីសូចនាករ និងគោលដៅ ចូរកត់ត្រាទុក និងសរសេរចំណុចនេះនៅក្នុងចំណុចរៀនសូត្រ/អនុសាសន៍អំពី សារៈប្រយោជន៍នៃការបង្កើតសូចនាករក្នុងដំណាក់កាលរៀបចំផ្នែកទី៣។ សូមសរសេរកុំអោយលើសមួយទំព័រ សម្រាប់លទ្ធផល ១)។ សូមសរសេរដដែលដូចគ្នានេះ សម្រាប់លទ្ធផលទាំងអស់នៃកម្មវិធី ។*

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ១.១ | | |
| | | |
| | | |
| | | |
| | | |
| | | |

**ផ្នែក-ខ** : ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល ធៀបនឹងគោលបំណងបន្ទាន់ (ផលប៉ះពាល់ /លទ្ធផលបឋម រយៈពេលខ្លី/មធ្យមនៃលទ្ធផល) នៃអនុកិច្ចសន្យា

*(ការណែនាំ : សង្ខេបការវាយតម្លៃកម្រិតលទ្ធផលប៉ុណ្ណោះ ។ បំពេញនៅពេលដែលប្រមូលបានព័ត៌មានពីប្រភពនានា : ឯកសារ សម្ភាស ក្រុមពិភាក្សា និងចុះពិនិត្យទីតាំងអនុវត្តន៍ ។ សូមប្រើសន្លឹកការងារទី ១ ដែលភ្ជាប់ខាងក្រោយនេះ)*

| |
|---|
| |

| |
|---|
| *ការណែនាំ : កុំអោយលើសមួយទំព័រ សម្រាប់លទ្ធផល ១ ។ បន្តធ្វើបែបនេះសម្រាប់លទ្ធផលផ្សេងទៀតនៃកម្មវិធី ។ មិនចាំបាច់ធ្វើបែបនេះទេសម្រាប់លទ្ធផលដូចជា "ការគាំទ្រប្រតិបត្តិការ" "ការត្រួតពិនិត្យ" "ការវាយតម្លៃ" ដែលមិនមែនជាលទ្ធផលកម្មវិធី ។* |

## ២.២. ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម (សំណួរវាយតម្លៃទី ៣)

### ផ្នែក-កៈ ការសម្រេចបាននូវស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា (សំណួរវាយតម្លៃទី២)

*(សូមមើលចំណុចគ ផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា)*

| |
|---|
| កំណត់ចំណាំ : "ស្ថានភាពនៅពេលបញ្ចប់កិច្ចសន្យា" សំដៅដល់ស្ថានភាពប្រសើរឡើង ដែលជាលទ្ធផលបឋមរបស់អនុកិច្ចសន្យា នៅចុងបញ្ចប់អនុកិច្ចសន្យា។ ភាពប្រសើរឡើងដែលរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា ត្រូវបានបរិយាយនៅក្នុងចំណុច "គ" ក្នុងផ្នែកទី ៣ នៃអនុកិច្ចសន្យា។ តែនៅក្នុងភាពជាក់ស្តែង ចំណុច "គ" ក្នុងផ្នែកទី ៣ នៃ អនុកិច្ចសន្យាប្រហែលពិពណ៌នាមិនសូវច្បាស់អំពី "ស្ថានភាពនៅពេលបញ្ចប់អនុកិច្ចសន្យា" ទេ។ ក្នុងករណីនេះ ការវាយតម្លៃ **ផ្នែក-ក** ពិតជាមិនអាចធ្វើបានទេ។ សូមរំលងទៅ **ផ្នែក-ខ** ខាងក្រោម ហើយកំណត់វាជាដែនកំណត់មួយ នៅក្នុងចំណុច ១.៦ និងជាចំណុចដែលត្រូវកែលម្អក្នុងចំណុច ២.៥ នៅក្នុងរបាយការណ៍នេះ។<br><br>ការណែនាំ : សូមចាប់ផ្តើមបំពេញការងារ ត្រង់ចំណុចណាដែល "ស្ថានភាពនៅពេលបញ្ចប់អនុកិច្ចសន្យា" ត្រូវបានពិពណ៌នាច្បាស់លាស់។ សូមបរិយាយអំពីលទ្ធផល/ ស្ថានភាពប្រសើរ ពីចំណុច "គ" នៃផ្នែកទី ៣ ចូលទៅក្នុងបង្គោល ទី១ ។ សង្ខេបការវាយតម្លៃរបស់អ្នកបន្ទាប់ពីពិនិត្យឯកសារ សម្ភាស ក្រុមពិភាក្សា និងចុះពិនិត្យដល់មូលដ្ឋានរួចរាល់ ទៅក្នុងបង្គោលទី២។ ជាមួយគ្នានេះដែរ សូមដកស្រង់សំដីរបស់អ្នកផ្តល់សម្ភាសដាក់ក្នុងប្រអប់អត្ថបទ ដោយភ្ជាប់ ឬមិនបាច់ភ្ជាប់រូបថត របស់គាត់ (សូមមើលគំរូខាងក្រោម) សម្រាប់លទ្ធផលបែបគុណភាព ឬលទ្ធផល ដែលមិនអាចមើលឃើញ និងលទ្ធផលដែលមានទិន្នន័យតិចតួចពេក។ សន្លឹកកិច្ចការលេខ ២.២ នេះមិនគួរវែងជាង ៣ ទំព័រទេ។ |

| ស្ថានភាពនៅពេលបញ្ចប់កិច្ចសន្យា (១) | លទ្ធផលប្រសើរឡើងជាក់ស្តែងនៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| | |

| | |
|---|---|
| | |

**ផ្នែក-ខ: ការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា (សំណួរវាយតម្លៃទី៣)**

***(សូមមើលចំណុច-គ ផ្នែកទី៣ ការបរិយាយអំពីអនុកិច្ចសន្យា)***

| |
|---|
| ចំណាំ : គោលបំណងបន្ទាន់សំដៅទៅលើលទ្ធផល និងអត្ថប្រយោជន៏រយៈពេលខ្លី និងមធ្យម ដែលរំពឹងទុកពីការសម្រេចលទ្ធផល។ នៅក្នុងលំហាត់វាយតម្លៃនេះ វាជាការសំខាន់ណាស់ ដែលត្រូវវាយតម្លៃថា តើលទ្ធផលទាំងអស់ដែលរំពឹងទុកនៅក្រោមគោលបំនងបន្ទាន់ ត្រូវបានបង្កើតឡើងដោយអនុកិច្ចសន្យា និងទំនងជាអាចបង្កើតឡើងបានដែរឬទេ។<br>តែងតែមានគំលាតពេលវេលា រវាងពេលវេលាសម្រេចលទ្ធផលជាក់ស្តែង និងពេលវេលាដែលអត្ថប្រយោជន៏ បានមកពីលទ្ធផលនោះអាចចេញជារូបរាង។ ការប្រើសូចនាករដែលសក្តិសម មានប្រយោជន៏ខ្លាំងណាស់។ ទាំងឧបករណ៏វាយ តម្លៃបែបបរិមាណ និងគុណភាព ដូចជា ការកំណត់ និងសង្កេតភ័ស្តុតាងផ្ទាល់ ឬមិនផ្ទាល់ សម្ភាសន៏ជាមួយ អ្នកទទួលផល ពិភាក្សាក្រុមជាមួយភាគីពាក់ព័ន្ធ និងអ្នកទទួលផល ចាំបាច់ណាស់សម្រាប់ចងក្រងឯកសារអំពីលទ្ធផល និងអត្ថ ប្រយោជន៏រយៈពេលខ្លី និងមធ្យម។<br><br>ការណែនាំ: សូមប្រើសន្លឹកកិច្ចការទី២ ដើម្បីធ្វើការវាយតម្លៃ។ សូមប្រើការដកស្រង់សំដីរបស់អ្នកផ្តល់សម្ភាសដាក់ ក្នុងប្រអប់អត្ថបទ ដោយភ្ជាប់ ឬមិនបាច់ភ្ជាប់រូបថតរបស់គាត់ (សូមមើល គំរូខាងក្រោម)។ បើសិនជាអាចសូម សរសេរករណីសិក្សាខ្លីមួយដោយភ្ជាប់រូបថត (សូមមើលគំរូខាងក្រោម) សម្រាប់លទ្ធផលបែបគុណភាព ឬ លទ្ធផល ដែលមិនអាចមើលឃើញ និងលទ្ធផលដែលមានទិន្នន័យតិចតួចពេក។ ផ្នែកនេះមិនគួរវែងជាង២ទំព័រទេ។ |

| ធាតុនៃទិសដៅបន្ទាន់ (១) | ការសម្រេចបាន/លទ្ធផលជាក់ស្តែង នៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| | |

| | |
|---|---|
| | |

**ផ្នែក-គៈ សង្ខេបការវាយតម្លៃ "លទ្ធផល" និង "ផលប្រយោជន៍" ដែលអាចបំលែងជាបរិមាណ អាចវាស់វែងបាន និងអាចមើលឃើញៈ**

ការណែនាំៈ សម្រាប់ "ផលប្រយោជន៍" ដែលអាចមើលឃើញ និងអាចផ្ទៀងផ្ទាត់បានតាមរយៈឯកសារ និងការសង្កេត សូមប្រើព័ត៌មានបែបបរិមាណ។ សូមប្រើសន្លឹកកិច្ចការលេខ៣ ហើយសរសេរការវាយតម្លៃខាងក្រោមៈ

| |
|---|
| |

**សង្ខេបការវាយតម្លៃ "ផលប្រយោជន៍" ដែលមិនអាចមើលឃើញ ប៉ុន្តែជាការយល់ឃើញរបស់អ្នកទទួលផល និងអ្នក ផ្តល់ព័ត៌មានសំខាន់ៗ :**

| |
|---|
| ចំណាំ និងការណែនាំៈ សម្រាប់ "ផលប្រយោជន៍" ដែលមិនអាចមើលឃើញ និងមិនអាចផ្ទៀងផ្ទាត់បាន តាមរយៈឯកសារ និងការសង្កេត ប៉ុន្តែសង្កេតឃើញដោយអ្នកទទួលផល (ផ្ទាល់ ឬមិនផ្ទាល់) សូមប្រើវិធីសាស្ត្របែបបរិមាណ ដូចជាសម្ភាសន៍ស៊ីជម្រៅ និងករណីសិក្សា ដែលមានភ្ជាប់រូបថត និងសម្រង់សំដី។ សូមមើលគំរូនៃករណីសិក្សា និងប្រអប់ដកស្រង់សំដី និងសំណួរសម្រាប់សម្ភាសន៍នៅក្នុងសៀវភៅណែនាំ។ សូមប្រើកាមេរ៉ា និងម៉ាស៊ីនថតសំលេង បើចាំបាច់។ សូមបង្កើតប្រអប់ដកស្រង់សំដីមួយ និងយ៉ាងហោចណាស់ករណីសិក្សាមួយ ដោយផ្អែកលើសម្ភាសស៊ី ជម្រៅជាមួយអ្នកទទួលផលផ្ទាល់ និងជាមួយបុគ្គលម្នាក់ទៀតនៅក្នុងភូមិជាមួយគ្នា ដែលមិនមែនជាអ្នកទទួលផល។ |

*ចំណាំ: សូមព្យាយាមបង្កើតសម្រង់សំដីដូចខាងក្រោមដើម្បីកត់ត្រា និងគូសបញ្ជាក់ភាពប្រសើរឡើង/លទ្ធផលដែលជាការយល់ឃើញរបស់អ្នកទទួលផល ។*

## តើអ្នកទទួលផលមានអ្វីខ្លះត្រូវនិយាយចំពោះការវិនិយោគនិងសេវាកម្មដែលគាត់បានទទួល?

"ផ្លូវធ្វើអោយការធ្វើដំណើរ និងដឹកជញ្ជូន មានភាពងាយស្រួលឡើង ... ទឹកជួយអោយមានសុខភាពល្អប្រសើរ និងសន្សំសំចៃពេលវេលា"-ប្រធានភូមិ ។

"គ្មានជំងឺច្រើនដូចពីមុន"- អ្នកប្រើប្រាស់ទឹក

"ខ្ញុំនៅតែគិតថា ធ្វើអោយផ្លូវល្អប្រសើរឡើង គឺជាអាទិភាពទី១ សម្រាប់ប្រជាជនតាមជនបទ ដើម្បីពង្រឹងជីវភាពរស់នៅ របស់ពួកគេ ..."-ប្រធានភូមិស្រឿង

### បង្កើតករណីសិក្សាមួយ ហើយបញ្ចូលនៅទីនេះ ។ សូមមើលគំរូខាងក្រោម :

លោក ចន្ទី ដែលជាអ្នកទទួលផលពីគម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាព របស់ គ.ជ.អ.ប នៅបានលុង ខេត្តរតនគិរីៈ "ជីវភាពរស់នៅរបស់ខ្ញុំ មានការប្រសើរឡើង តាំងពីខ្ញុំក្លាយជាសមាជិកសហគមន៍យក្សឡោម"



លោក ដួង ចន្ទី

បន្ទាប់ពីចូលរួមគណៈកម្មាធិការសហគមន៍យក្សឡោមនៅក្នុងស្រុកបានលុង ខេត្តរតនគិរី លោក ចន្ទី បាននិយាយថាៈ "បច្ចុបន្ននេះ ម្ហូបអាហារប្រចាំថ្ងៃរបស់យើង មានគ្រប់គ្រាន់ ហើយកូនរបស់ខ្ញុំអាច ទៅសាលាបាន"។ សមាជិកគណៈកម្មាធិការ ទទួលបានកំចីខ្នាតតូច និងការបណ្តុះបណ្តាលជំនាញ បង្កើតចំណូលពីគម្រោងគ្រប់គ្រងធនធានធម្មជាតិ និង ជីវភាព របស់ គ.ជ.អ.ប ។ គណៈកម្មាធិការនេះ មានភារៈគ្រប់គ្រងធនធានធម្មជាតិ អភិរក្ស មូលដ្ឋាន និងលើកកំពស់ទេសចរណ៍បរិស្ថាននៅក្នុង សហគមន៍យក្សឡោម។ មុនពេលបាន ចូលរួមគម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរបស់ គ.ជ.អ.ប លោកចន្ទី មានការ លំបាកជាខ្លាំងក្នុងការចិញ្ចឹមកូនទាំង ៥ របស់គាត់ និងមិនអាចបញ្ជូនពួកគេទៅរៀនបានទេ។

គាត់និយាយថា "គ្រួសារ ខ្ញុំក្រណាស់ទើបខ្ញុំមិនអាចបញ្ជូនពួកគេទៅរៀនបាន។ ពេលនេះ ខ្ញុំសប្បាយចិត្តណាស់ នៅពេលប្រៀបធៀបទៅនឹងស្ថានភាពពីមុនរបស់ខ្ញុំ"។ លោកចន្ទី មិនមែនយល់ដូច្នេះតែម្នាក់ឯងទេ។ ប្រជាពលរដ្ឋនៅយក្សឡោមភាគច្រើន ក៏មានអារម្មណ៍ដូចគាត់ដែរ។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤)

ចំណាំ: ការរៀបចំ គឺសំដៅលើផ្នែកទី ៣: ការបរិយាយអំពីអនុកិច្ចសន្យា។ ការវាយតម្លៃនៅទីនេះ គឺផ្តោតលើ គុណភាព នៃខ្លឹមសារ និងការបរិយាយ ទំនាក់ទំនងតក្កភាពរវាងធាតុចូល និងលទ្ធផល រវាងលទ្ធផល និងគោលបំនង បន្ទាន់/ស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យាដែលរំពឹងទុក។ ការវាយតម្លៃនេះនឹងជួយអោយយើងយល់អំពីយុត្តិកម្ម នៃអនុកិច្ចសន្យា និងភាពពាក់ពន្ធ័ទៅនឹងនៅគោលដៅអភិវឌ្ឍថ្នាក់ខ្ពស់ និងគោលបំនង ដែលបានសរសេរនៅចំណុច ខ ផ្នែកទី៣។

ការណែនាំ : ជាដំបូង សូមប្រើសន្លឹកកិច្ចការលេខ២ និងលេខ៣ ជាមុនសិន។ បន្ទាប់មក សូមប្រើតារាងគំរូខាងក្រោម ដើម្បីវាយតម្លៃបញ្ចប់ បន្ទាប់ពីការពិនិត្យឡើងវិញនូវផ្នែកទី៣ ការពិគ្រោះយោបល់ សម្ភាស និងចុះសង្កេតដល់ មូលដ្ឋាន។ សម្រាប់បង្គោល (៣) និង (៤) សូមប្រើពិន្ទុ : ១=ខ្សោយណាស់ ២=ខ្សោយ ៣=មិនខ្លាំងមិនខ្សោយ ៤=ខ្លាំង ៥=ខ្លាំងណាស់ ហើយសូមប្រើពិន្ទុដែលបានដាក់នៅក្នុងសន្លឹកកិច្ចការទី៣។ សូមកុំសរសេរអោយលើស ពីមួយទំព័រ។

### ផ្នែក-ក: ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅនឹងតំរូវការ: មន្ទីរវិស័យ មូលដ្ឋាន គ.ជ.អ.ប និងការកាត់បន្ថយភាព ក្រីក្រ:

| ល.រ (១) | ធាតុ (២) | ទំនាក់ទំនងតក្កភាព (៣) | បរិយាយច្បាស់លាស់ (៤) | សង្ខេបការវាយតម្លៃ (៥) |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | | | |
| ២ | លទ្ធផល | | | |

| | | | | |
|---|---|---|---|---|
| ៣ | អត្ថប្រយោជន៍រយៈពេលខ្លីៈ<br>(លទ្ធផល/ផលប្រយោជន៍)<br>- គោលបំនងបន្ទាន់ *(គោលបំនងស្ថិតក្នុងចំណុច "ខ" នៃផ្នែកទី ៣)*<br>- ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា *(ចំណុច "គ" នៃផ្នែកទី ៣)* | | | |
| ៤ | លទ្ធផលអភិវឌ្ឍន៍/ផលប៉ះពាល់រយៈ ពេលវែងៈ<br>គោលដៅ និងគោលបំនងអភិវឌ្ឍន៍ *( ចំណុច "ខ" នៃផ្នែកទី ៣)* | | | |

**ផ្នែក-ខៈ សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារៈ**

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.ជ.អ.ខៈ** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យ<br>ការអនុវត្តន៍របស់ភ្នាក់ងារអនុវត្តន៍ | |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា | |
| **ពីខាងភាគីអនុវត្តន៍កិច្ចសន្យាៈ** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | |
| ៦ | ការរាយការណ៍ការរីកចំរើន និង ការកត់ត្រាឯកសារ | |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | |
| **ទាំងខាង គ.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យាៈ** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" (ចំណុច-ង ផ្នែកទី៣ )<br>និងបញ្ហាប្រឈម | |
| ៩ | ការបញ្ជ្រាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ ( ចំណុច-ឆ ផ្នែកទី៣) | |
| ១១ | ការថែរក្សា (និរន្តភាព) ( ចំណុច-ជ ផ្នែកទី៣) | |

## ២.៤. សេចក្ដីសន្និដ្ឋាន (សំណួរវាយតម្លៃទី ៥)

ចំណាំ និងការណែនាំ: នេះជាចំណុចដែលអ្នកវាយតម្លៃធ្វើការវាយតម្លៃបញ្ចប់ ទាញសេចក្ដីសន្និដ្ឋាន ដោយផ្អែកលើការពិនិត្យឯកសារឡើងវិញ ការសង្កេត និងការពិគ្រោះយោបល់ និងដោយជ្រើសរើសតែបញ្ហាយុទ្ធសាស្ត្រ និងចំណុចសំខាន់ៗ ពីការសង្ខេបការវាយតម្លៃនៃផ្នែកនីមួយៗដែលបានធ្វើឡើងនៅចំណុចមុនៗ។ ការប្រឈមនៅត្រង់នេះ គឺការឆ្លុះបញ្ចាំងពីលំហាត់ វាយតម្លៃ និងទាញសេចក្ដីសន្និដ្ឋាន និងចំណុចរៀនសូត្រ មិនអោយលើសពី២ទំព័រ (ត្រឹម ៣ ចំណុច) និងអនុសាសន៍ កែលម្អដែលអាចអនុវត្តបាន (២ចំណុច ដោយផ្ដោតលើ ការកែលម្អបន្ទាន់ និង ២ចំណុចសម្រាប់អនុសាសន៍ទាក់ទងនឹងយុទ្ធសាស្ត្រ និងរយៈពេលវែង)។ អត្ថបទព្រាង គួរតែត្រូវបានប្រើសម្រាប់ពិភាក្សាជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីទទួលយកយោបល់ពីពួកគាត់។ ការសន្និដ្ឋានក្នុងឯកសារបញ្ចប់ គួរតែបញ្ចូលយោបល់ ទាំងអស់នោះ។ សូមពិចារណាតារាងគំរូខាងក្រោម :

សេចក្ដីសន្និដ្ឋានជារួម :

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | (ផ្ដោតលើការអនុវត្ត និងលទ្ធផលបង្កើតបាន): |
| ២ | (ផ្ដោតលើផ្នែកលទ្ធផល (គោលបំនងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា និងការរួមចំណែករបស់គោលបំនងទាំងនេះក្នុងការសម្រេចគោលបំនង និងគោលដៅកម្រិតខ្ពស់) |
| ៣ | (ផ្ដោតលើឧបសគ្គ និងការប្រឈមចំបងៗ ដែលអាចចៀសវាងបាន) |

ចំណុចរៀនសូត្រ:

(ផ្តោតលើលទ្ធផលវាយតម្លៃដែលបានបង្ហាញ ដើម្បីកែលម្អការរៀបចំ គ្រប់គ្រង ការផ្តោតលើលទ្ធផល ។ល ។)

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | |
| ២ | |
| ៣ | |
| ៤ | |

អនុសាសន៍ :

(ផ្តោតលើអ្វីដែលត្រូវធ្វើ និង/ឬ ចៀសវាងនៅពេលក្រោយ ក្នុងការរៀបចំ និងអនុវត្តអនុកិច្ចសន្យា)

| ល.រ | អនុសាសន៍ |
|---|---|
| ១ | |
| ២ | |
| ៣ | |
| ៤ | |

# សន្លឹកកិច្ចការ

## សន្លឹកកិច្ចការទី១: សមិទ្ធិផលសំខាន់ៗនៅកម្រិតលទ្ធផល

*(សម្រាប់ការវាយតម្លៃចំណុច២.១)*

❖ **ចំណុច-ក :**

(<u>ការណែនាំ:</u> សូមទៅកាន់ផ្នែក **"លទ្ធផលនិងសកម្មភាព"** នៅក្នុងចំណុច-ខ ផ្នែកទី៣ **"ការពណ៌នាពីកិច្ចសន្យា /ទម្រង់បែបបទស្នើសុំ"** នៃអនុកិច្ចសន្យា។ សូមទាញយកចំនួនក្រុមគោលដៅ និងសកម្មភាព ដែលបង្ហាញជាបរិមាណ និងសូចនាករ ហើយផ្ទេរព័ត៌មានទាំងនេះទៅកាន់បង្គោលទី២ និងទី៣ នៃទម្រង់ខាងក្រោមនេះ។ សូមបំពេញបង្គោល ទី(៤) ដូចដែលអ្នកបានធ្វើការសិក្សាស្រាវជ្រាវ និង ប្រមូលព័ត៌មាន នៅក្នុងដំណើរការវាយតម្លៃ។ សូមធ្វើដដែលៗ ដើម្បីបំពេញនូវរាល់សកម្មភាពដែលមាននៅក្នុងខ្ទង់លទ្ធផល។ នៅពេលដែលអ្នកបញ្ចប់រួចរាល់សូមផ្ទេរ ព័ត៌មានទៅ កាន់បង្គោលទី(២) និង ទី(៣) នៅក្នុងទម្រង់សង្ខេបការវាយតម្លៃនៃការរីកចំរើនរបស់គម្រោងតាមលទ្ធផល នៅក្នុង ផ្នែក-<u>ក</u> ក្រោមចំណុចទី២ នៃរបាយការណ៍វាយតម្លៃ)។

*(<u>កំនត់សំគាល់:</u> អ្នកអាចទុកផ្នែក-ក ដែលបានបំពេញ រួចភ្ជាប់ជាមួយនឹងរបាយការណ៍វាយតម្លៃបញ្ចប់ ។)*

**លទ្ធផល និងសកម្មភាពដែលសម្រេចបានជាក់ស្តែងធៀបទៅនឹងការគ្រោងទុក**

| ល.រ (១) | សង្ខេបលទ្ធផល និងសកម្មភាព (២) | លទ្ធផលរំពឹងទុក/ លទ្ធផលគ្រោង (៣) | លទ្ធផលសម្រេចបាន ជាក់ស្តែង (៤) |
|---|---|---|---|
| | **លទ្ធផលទី១** | | |
| ១ | | | |
| ២ | | | |
| ៣ | | | |

| | | | |
|---|---|---|---|
| | **លទ្ធផលទី២** | | |
| ១ | | | |
| ២ | | | |
| ៣ | | | |
| | **លទ្ធផលទី៣** | | |
| ១ | | | |
| ២ | | | |
| ៣ | | | |
| ៤ | | | |
| | **លទ្ធផលទី៤** | | |
| ១ | | | |
| ២ | | | |
| ៣ | | | |
| ៤ | | | |

*ប្រភព: កំណត់ត្រាគម្រោង*

### ❖ ចំណុច-ខ : សង្ខេបសមិទ្ធិផលសំខាន់ៗ

(ការណែនាំ: ផ្អែកលើចំណុច-កខាងលើ ផ្អែកលើសម្ភាសន៍ និងការចុះមូលដ្ឋាន សូមសង្ខេបការវាយតម្លៃសមិទ្ធផលសំខាន់ៗខាងក្រោម និងចំណុចខ្វះខាតនៅកម្រិតលទ្ធផល ហើយផ្ទេរព័ត៌មានទៅក្នុងរបាយការណ៍នៃការវាយតម្លៃ (ចំណុច២.១) ។)

| ល.រ | លទ្ធផលសម្រេចបាន/ភាពខ្លាំង | ភាពខ្សោយដែលបានសង្កេតឃើញ |
|---|---|---|
| ១ | | |
| ២ | | |

### សន្លឹកកិច្ចការទី២ : ផលប្រយោជន៍រយៈពេលខ្លី លទ្ធផល និងអត្ថប្រយោជន៍ (សំណួរវាយតម្លៃលេខ៣)

កំណត់សំគាល់: គោលបំនងបន្ទាន់សំដៅទៅលើលទ្ធផល និងអត្ថប្រយោជន៍រយៈពេលខ្លី និងមធ្យម ដែលរំពឹងទុកពីការ សម្រេចលទ្ធផល។ នៅក្នុងលំហាត់វាយតម្លៃនេះ វាជាការសំខាន់ណាស់ ដែលត្រូវវាយតម្លៃថា តើលទ្ធផលទាំងអស់ ដែលរំពឹងទុកនៅក្រោមគោលបំនងបន្ទាន់ដែលត្រូវបានបង្កើតឡើងដោយអនុកិច្ចសន្យា និងទំនងជាអាចកើតមាន បាន ដែរឬទេ។ជាការពិត តែងតែមានគំលាតពេលវេលា រវាងពេលវេលានៃការសម្រេចលទ្ធផល ជាក់ស្តែង និងពេលវេលា ដែលអត្ថប្រយោជន៍បានមកពីលទ្ធផលនោះអាចចេញជារូបរាង។ ការប្រើសូចនាករ ដែលសក្តិសម មានប្រយោជន៍ខ្លាំង ណាស់។ ទាំងឧបករណ៍ វាយតម្លៃបែបបរិមាណ និងគុណភាព ដូចជា កំណត់ និងសង្កេតភ័ស្តុតាងផ្ទាល់ ឬមិនផ្ទាល់ សម្ភាសជាមួយអ្នកទទួលផល ពិភាក្សាក្រុមជាមួយភាគីពាក់ព័ន្ធ និងអ្នកទទួលផល ចាំបាច់ណាស់សម្រាប់ចងក្រង ឯកសារអំពីលទ្ធផល និងអត្ថប្រយោជន៍រយៈពេលខ្លី និងមធ្យម។

ការណែនាំ:

១)សម្រាប់ការបណ្តុះបណ្តាល និងការអប់រំដែលមាននៅក្នុងអនុកិច្ចសន្យា សូមស្វែងរកចំលើយទៅនឹងសំនួរនៅក្នុងទម្រង់គំរូទី ១ ខាងក្រោម។ ចំលើយ គួរត្រូវបានរកឃើញតាមរយៈការពិនិត្យឡើងវិញនូវកំណត់ត្រាឯកសារការ

| |
|---|
| សម្ភាសន៍ ការពិភាក្សាក្រុមជាមួយនឹងអ្នកទទួលផល និងតាមរយៈកំណត់ត្រាការចុះពិនិត្យទីតាំងគម្រោង។ សូមប្រើទម្រង់គំរូទី១ ខាងក្រោមដើម្បីធ្វើការវាយតម្លៃ។<br><br>២) ប្រើប្រាស់ទម្រង់គំរូទី២ ខាងក្រោមដើម្បីសង្ខេបសមិទ្ធផលវាយតម្លៃនៃ គោលបំណងបន្ទាន់ តាមរយៈការពិនិត្យឡើងវិញនូវកំនត់ត្រាឯកសារ ការសម្ភាសន៍ ការពិភាក្សាក្រុមជាមួយនឹងអ្នកទទួលផល និងតាមរយៈកំណត់ត្រា ការចុះពិនិត្យទីតាំងគម្រោង។ សូមផ្ទេរព័ត៌មានទាំងនេះទៅក្នុងបង្កោលទី២ ផ្នែកខ ចំណុច២.២ នៃរបាយការណ៍។<br><br>៣) សូមបំពេញបន្ថែមដោយប្រអប់ស្រង់សំដី និងករណីសិក្សា។ ប្រើប្រអប់ស្រង់សំដីពីការសម្ភាសន៍ ដោយមានដាក់ឬមិនមានដាក់រូបថត(សូមមើលគំរូខាងក្រោម)។ ប្រសិនបើអាច សូមសរសេរករណីសិក្សាខ្លីមួយ ដោយមានភ្ជាប់រូបថត(សូមមើលគំរូខាងក្រោម)ដែលប្រកបដោយព័ត៌មានជាគុណភាព និងលទ្ធផលដែលមិនអាចមើលឃើញ ហើយ និងលទ្ធផលដែលមានទិន្នន័យតិចតួចពីវា។ ចំណុចនេះមិនគួរសរសេរលើសពី២ទំព័រទេ។ |

**ទម្រង់គំរូទី១ : ផលប្រយោជន៍ពីការបណ្តុះបណ្តាល ការយល់ដឹង និងលទ្ធផលអប់រំ ទៅក្នុងកម្រិតគោលបំណងបន្ទាន់**

**សំណួរទី១: តើក្រុមគោលដៅបានទទួលផលប្រយោជន៍អ្វីខ្លះពីអនុកិច្ចសន្យា?**

| **ប្រភេទលទ្ធផល** | **ផលប្រយោជន៍/លទ្ធផលដូចដែលបានសង្កេតឃើញ ដូចដែលមានភស្តុតាងពីកំនត់ត្រា និង ដូចដែលបានបញ្ជាក់ដោយអ្នកផ្តល់ព័ត៌មានសំខាន់ៗ** |
|---|---|
| បណ្តុះបណ្តាលទៅលើ... | |
| ការយល់ដឹងទៅលើ... | |
| ពង្រឹង.................... | |

សំណួរទី២: តើក្រុមអ្នកទទួលផលពេញចិត្តនឹងផលប្រយោជន៍ដែលគេទទួលបានកម្រិតណា?

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

សំណួរទី៣:

តើវគ្គបណ្តុះបណ្តាល/ការសិក្សា/ចំនេះដឹង/ជំនាញនេះមានភាពទាក់ទងទៅនឹងស្ថានភាពរបស់អ្នកទទួលផលក្នុងកម្រិតណាដែរ? ទៅដល់សហគមន៍ទាំងមូល? ទៅភ្នាក់ងារអនុវត្តគម្រោង?

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

សំណួរទី៤: តើអ្នកមានសង្កេតឃើញមានការផ្លាស់ប្តូរអ្វីខ្លះក្រោយពីវគ្គបណ្តុះបណ្តាល/ការសិក្សា? ដល់អ្នកចូលរួម? ដល់ការអនុវត្តការងាររបស់មន្ទីរវិស័យ? ដល់គ្រួសារ? ដល់សហគមន៍ទាំងមូល?

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

**ទម្រង់គំរូទី២ : ផលប្រយោជន៍រយៈពេលខ្លី និងលទ្ធផលនៅក្នុងកម្រិតគោលបំណងបន្ទាន់:**

(សូមផ្ទេរព័តិមានពីបង្កោលទី២ ចំណុច ២.២ផ្នែក-ខ នៃរបាយការណ៍)

| ចំណុចសំខាន់ | សង្ខេបផលប្រយោជន៍ជាក់ស្តែង/លទ្ធផលដូចដែលបានធ្វើការវាយតម្លៃនៅក្នុងពេលវាយតម្លៃ |
|---|---|
| ១ | |
| ២ | |
| ៣ | |

| | |
|---|---|
| ៤ | |
| ៥ | |
| សំយោគផ្នែកទាំងអស់ខាងលើ: | |

## សន្លឹកកិច្ចការទី៣ :
## ការវាយតម្លៃការរៀបចំអនុកិច្ចសន្យា ភាពជាប់ពាក់ពន្ធ័នឹងការគ្រប់គ្រង
## តាមរយៈការវាយតម្លៃទំនាក់ទំនងសមហេតុផលរវាងសកម្មភាព និងលទ្ធផល រវាងលទ្ធផល
## និងគោលបំណងបន្ទាន់/ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា និងរវាងគោលបំណងបន្ទាន់ និងលទ្ធផល

(ការណែនាំ: សូមប្រើតារាងម៉ាទ្រិចខាងក្រោម ជាជំនួយក្នុងការសង្ខេបនូវការវាយតម្លៃភាពខ្លាំងនៃទំនាក់ទំនងសមហេតុផលរបស់លទ្ធផលទាំងអស់។ សូមពិនិត្យឡើងវិញនូវផ្នែកទី៣ នៃអនុកិច្ចសន្យា។ សម្រាប់ការវាយតម្លៃរបស់អ្នកសូមប្រើពិន្ទុដូចតទៅ : *១= ខ្សោយខ្លាំង ២= ខ្សោយ ៣=មិនខ្លាំងមិនខ្សោយ ៤=ខ្លាំង ៥=ខ្លាំងណាស់*)។ សូមប្រើប្រាស់នូវការវាយតម្លៃសង្ខេបដើម្បីសង្ខេបចំណុច ២.២ និងចំណុច ២.៣ នៃ ផ្នែក-ក នៅក្នុងរបាយការណ៍។ សូមប្រើប្រាស់ តារាងខាងក្រោមនេះភ្ជាប់ជាមួយនឹងរបាយការណ៍បញ្ចប់)។

**លទ្ធផល**

| | |
|---|---|
| អត្ថប្រយោជន៍រយៈពេលវែង/ ផលប៉ះពាល់ *កាត់បន្ថយភាពក្រីក្រ* | *មិនអាចវាយតម្លៃបានទេ* |

| | |
|---|---|
| អត្ថប្រយោជន៍រយៈពេលមធ្យមៈ (បង្កើនផលិតភាព ពង្រឹងសមត្ថភាព) | *ប្រហែលអាចវាយតម្លៃបាន ។ សញ្ញានិងភស្តុតាងខ្លះៗអាចកើតឡើង ហើយទិន្នន័យទាំងនោះ ប្រហែលជាអាចប្រមូលបាន ។* |
| ការវាយតម្លៃរបស់អ្នក ⇨ | ទំនាក់ទំនងសមហេតុផល=<br>បរិយាយច្បាស់លាស់= |

| | | |
|---|---|---|
| អត្ថប្រយោជន៍បឋមៈ (បង្កើនចំនេះដឹង, បន្ថយអំពើហឹង្សាក្នុងគ្រួសារ) | លទ្ធផលនៅស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា ចំនុច-គ ផ្នែកទី៣ | គោលបំនងបន្ទាន់នៃអនុកិច្ចសន្យា ចំនុច-គ ផ្នែកទី៣ |
| ការវាយតម្លៃរបស់អ្នក ⇨ | ទំនាក់ទំនងសមហេតុផល=<br>បរិយាយច្បាស់លាស់= | ទំនាក់ទំនងសមហេតុផល=<br>បរិយាយច្បាស់លាស់= |

| | | | | |
|---|---|---|---|---|
| លទ្ធផល *(សូចនាករដែលអាចរាប់បាននៃផលិតផល និងសេវាកម្មរបស់គម្រោង)* | លទ្ធផលទី១ | លទ្ធផលទី២ | លទ្ធផលទី៣ | លទ្ធផលទី៤ |
| ការវាយតម្លៃរបស់អ្នក ⇨ (សូមប្រើប្រាស់ចំណុចខនៃសន្លឹកកិច្ចការទី១) | ទំនាក់ទំនងសមហេតុផល=<br>បរិយាយច្បាស់លាស់= | ទំនាក់ទំនងសមហេតុផល=<br>បរិយាយច្បាស់លាស់= | ទំនាក់ទំនងសមហេតុផល=<br>បរិយាយច្បាស់លាស់= | ទំនាក់ទំនងសមហេតុផល=<br>បរិយាយច្បាស់លាស់= |

| | | | | |
|---|---|---|---|---|
| សកម្មភាព | សូមសង្ខេបទំនាក់ទំនងទៅលទ្ធផលផ្នែកខាងលើ | | | |
| ការវាយតម្លៃរបស់អ្នក ⇨ | ទំនាក់ទំនងសមហេតុផល=<br>បរិយាយច្បាស់លាស់= | ទំនាក់ទំនងសមហេតុផល=<br>បរិយាយច្បាស់លាស់= | ទំនាក់ទំនងសមហេតុផល=<br>បរិយាយច្បាស់លាស់= | ទំនាក់ទំនងសមហេតុផល=<br>បរិយាយច្បាស់លាស់= |

## សន្លឹកកិច្ចការទី៤ : ការឆ្លុះបញ្ចាំងការផ្ដល់ព័ត៌មានត្រឡប់ និងអនុសាសន៍ពីភ្នាក់ងារអនុវត្តកិច្ចសន្យា និងទីប្រឹក្សាត្រួតពិនិត្យ វាយតម្លៃ និងវិស័យ/ប្រធានទីប្រឹក្សា

(កំណត់សំគាល់ និងការណែនាំ : សន្លឹកកិច្ចការនេះត្រូវបានរៀបចំឡើង ដើម្បីឱ្យក្រុមអ្នកវាយតម្លៃមានឱកាសម្តងទៀតក្នុងការចាប់យកនូវបទពិសោធន៍ដែលទាក់ទងនឹងការវាយតម្លៃអនុកិច្ចសន្យា អនុសាសន៍ និងសំណូមពរ ដោយ ផ្តោតទៅលើបញ្ហាសំខាន់ៗ និងចំណុចរៀនសូត្រពីភ្នាក់ងារអនុវត្តន៍ និងពីដៃគូរអភិវឌ្ឍន៍របស់ គ.ជ.អ.ប ដែលជា ទីប្រឹក្សាត្រួតពិនិត្យ វាយតម្លៃនិងវិស័យ ឬប្រធានទីប្រឹក្សា) ។

សំណួរទី១: តើអ្នកអាចសង្ខេបបទពិសោធន៍ និងការសង្កេតរបស់អ្នកពីអនុកិច្ចសន្យា បានយ៉ាងណា?

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

សំណួរទី២: តើអ្នកអាចនិយាយអ្វីខ្លះពីចំណុចខ្លាំង និង ចំណុចខ្សោយសំខាន់ៗរបស់អនុកិច្ចសន្យា?

| ល.រ. | ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

សំណួរទី៣: តើត្រូវធ្វើដូចម្តេចដើម្បីបំបាត់ចំណុចខ្សោយដូចដែលអ្នកបាននិយាយខាងលើ?

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

សំណួរទី៤: តើអ្នកមានអនុសាសន៍ផ្សេងទៀតឬទេ?

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

## សន្លឹកកិច្ចការទី៥ : ការឆ្លុះបញ្ចាំង ការផ្តល់ព័ត៌មានត្រឡប់ និងអនុសាសន៍ពីមន្ត្រីបង្គោលយេនឌ័រ និងមន្ត្រីបង្គោលគ្រប់គ្រងធនធានធម្មជាតិ

(<u>កំណត់សំគាល់ និងការណែនាំ:</u> អនុកិច្ចសន្យានីមួយៗតម្រូវអោយមានការលើកកម្ពស់យេនឌ័រ និងការគ្រប់គ្រងធនធានធម្មជាតិ (សូមមើលចំណុចច និងឆ នៃផ្នែកទី៣ នៃអនុកិច្ចសន្យា)។ ការវាយតម្លៃអនុកិច្ចសន្យានឹងត្រូវពិនិត្យមើលទិដ្ឋភាពទាំង២នេះ ដើម្បីបំពេញអនុចំណុចទី៦ និងអនុចំណុចទី៧ នៅក្នុងចំណុចទី២.៤ នៃសៀវភៅណែនាំការសរសេររបាយការណ៍វាយតម្លៃ សូមប្រើប្រាស់ការណែនាំការធ្វើសម្ភាសន៍នេះ ទៅសម្ភាសន៍ ១) មន្ត្រីបង្គោល យេនឌ័រ និង ២) មន្ត្រីបង្គោលគ្រប់គ្រងធនធានធម្មជាតិ)។

កាលបរិច្ឆេទ:..........................................................ឈ្មោះអ្នកសម្ភាសន៍:.............................................

ឈ្មោះអ្នកត្រូវសម្ភាសន៍:.................................................................................................................

តួនាទី និងមន្ទីរ:..............................................................................................................................

លេខអនុកិច្ចសន្យា:............................................................ខេត្ត:.......................................................

១. តើអ្នកដឹងពីអនុកិច្ចសន្យា/គម្រោងនេះឬទេ? ដឹង ☐ មិនដឹង ☐

២. តើអ្នកអាចប្រាប់ដោយសង្ខេបបានទេពីអ្វីដែលអ្នកដឹង និងពីអ្វីដែលអ្នកមិនដឹងពីអនុកិច្ចសន្យា/គម្រោងនេះ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៣. តើអ្នកអាចសង្ខេបបទពិសោធន៍របស់អ្នក និងការសង្កេតរបស់អ្នកពីសកម្មភាពយេនឌ័រ និងគ្រប់គ្រងធនធានធម្មជាតិរបស់អនុកិច្ចសន្យា/គម្រោងនេះ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៤. តើអ្នកអាចអាចផ្តល់អនុសាសន៍ទាក់ទងនឹងថាតើត្រូវពង្រឹង រួមបញ្ចូលសកម្មភាពយេនឌ័រ/គ្រប់គ្រងធនធានធម្មជាតិ ទៅក្នុងអនុកិច្ចសន្យានេះដោយរបៀបណា?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៥. តើអ្នកមានអនុសាសន៍ផ្សេងទៀតទេ?

..........................................................................................................................................

..........................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

## ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

(កំណត់សំគាល់: ខាងក្រោមនេះ ជាឈ្មោះឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍វាយតម្លៃបញ្ចប់។ អ្នកអាចភ្ជាប់ឯកសារច្រើនជាងបញ្ជីឈ្មោះឯកសារនេះ។)

*សេចក្តីណែនាំ: សូមបំពេញឯកសារភ្ជាប់នីមួយៗអោយបានរួចរាល់ ហើយសូមទុកតែឯកសារណាដែលទាក់ទង ទៅនឹង ដំណើរការវាយតម្លៃនេះនៅក្នុងខេត្ត/រាជធានីរបស់អ្នក។ សូមដកឯកសារផ្សេងទៀតចេញ។)*

**ឯកសារដែលត្រូវភ្ជាប់ទី១ : បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបានពិនិត្យ**

(សេចក្តីណែនាំ: ខាងក្រោមនេះ ជាបញ្ជីឯកសារដែលអ្នកវាយតម្លៃត្រូវពិនិត្យ។ សូមគូស (√)នៅក្នុងប្រអប់ទី(៣) ប្រសិនបើអ្នកបានពិនិត្យឯកសារនោះនៅក្នុងកំឡុងពេលវាយតម្លៃ។ សូមបន្ថែមឈ្មោះឯកសារដែលអ្នកបានពិនិត្យ ប៉ុន្តែមិនមាននៅក្នុងបញ្ជីឈ្មោះនេះ។ សូមដកបង្គោលទី(៣) ហើយនិងឈ្មោះឯកសារដែលអ្នកមិនបានពិនិត្យ ចេញ ហើយភ្ជាប់តារាងនេះទៅក្នុងរបាយការណ៍វាយតម្លៃ)

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) | មាន (៣) |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និង ឯកសារវិសោធនកម្ម (ប្រសិនមាន) | |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ | |
| ៣ | របាយការណ៍ត្រួតពិនិត្យគម្រោង | |

| | | |
|---|---|---|
| ៤ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | |
| ៥ | លិខិតឆ្លើយឆ្លងរវាងភ្នាក់ងារអនុវត្តន៍ និងគណៈកម្មាធិការប្រត្តិបត្តិគ.អ.ជ.ខ | |
| ៦ | បញ្ជីវត្ថុបណ្តុះបណ្តាលដែលមានក្នុងអនុកិច្ចសន្យា | |
| ៧ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា | |
| ៨ | ឯកសារដ៏ទៃទៀតរួមមាន រូបថតនៃគម្រោង (អនុកិច្ចសន្យា) ដែលទុកនៅ គណៈកម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ និងនៅភ្នាក់ងារអនុវត្តន៍ ដែលមិនបានរៀបរាប់ខាងលើ | |
| ៩ | ផ្សេងទៀត | |

**ឯកសារដែលត្រូវភ្ជាប់ទី២ : ឯកសារអនុកិច្ចសន្យា លេខ (..............................) ខេត្ត/រាជធានី....................**

**បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាស/ជួបពិភាក្សា**

(<u>កំណត់សំគាល់ និងសេចក្តីណែនាំ:</u> សូមមើលឧទាហរណ៏ដូចខាងក្រោម សូមសរសេរឈ្មោះអ្នកចូលរួម ក្នុងការវាយតម្លៃ ដែលអ្នកវាយតម្លៃបានសម្ភាសន៏ ជួប និង ពិភាក្សា នៅក្នុងកំលុងពេលវាយតម្លៃ។ សូមភ្ជាប់បញ្ជីឈ្មោះដែលសរសេររួច ចុងក្រោយជាមួយរបាយការណ៏វាយតម្លៃ )

**កំនត់សំគាល់:**

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៏ប្រើសម្រាប់ប្រមូលទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | ... សីហា | លោក ក មន្ត្រីត្រួតពិនិត្យនិងវាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យា | សាលាខេត្ត | សម្ភាសន៏ស៊ីជម្រៅ |
| ២ | ... សីហា | អ្នកស្រី ខ មន្ត្រីបង្គោលត្រួតពិនិត្យ និងវាយតម្លៃ និង មន្ត្រីទទួលខុសត្រូវ | .............. | សម្ភាសន៏ស៊ីជម្រៅ |
| ៣ | ... សីហា | ក្រុមអ្នកទទួលផល (សូមសរសេរឈ្មោះខាងក្រោម) | ភូមិ ............ | សម្ភាសជាក្រុម |
| ៤ | ... | លោក គ អ្នកទទួលផលផ្ទាល់ | ភូមិ ............ | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |

| | | | | |
|---|---|---|---|---|
| | សីហា | | | |
| ៥ | ...<br>សីហា | កញ្ញា ឃ អ្នកមិនទទួលផល | ភូមិ ............ | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៦ | | មន្ត្រីបង្គោលយេនឌ័រ | | |
| ៧ | | មន្ត្រីបង្គោល គ្រប់គ្រងធនធានធម្មជាតិ | | |
| | | | | |

## ឯកសារដែលត្រូវភ្ជាប់ទី៣ : ក្របខណ្ឌការងារស្តីពីវាយតម្លៃអនុកិច្ចសន្យា

### 1.សាវតា

រៀងរាល់ឆ្នាំ គ.ជ.អ.បបានផ្តល់ថវិកាតាមរយៈគណៈកម្មាធិការប្រត្តិបត្តិនៃ គ.អ.ជ.ខ ទៅដល់មន្ទីរវិស័យ ដើម្បីអនុវត្តគម្រោង និងសកម្មភាពគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ មានមូលហេតុជាច្រើនដែល ធ្វើឱ្យខកខាន ក្នុងការវាយតម្លៃអនុកិច្ចសន្យាជាប្រពន្ធ័នាពេលកន្លងមក។ ការវាយតម្លៃអនុកិច្ចសន្យា ពិតជាមាន សារៈសំខាន់ក្នុងការកែលំអអនុកិច្ចសន្យា និងកែលម្អការវិនិយោគ និងសេវាកម្ម តាមរយៈអនុកិច្ចសន្យាមួយ ដែល មានភាពល្អប្រសើរឡើង។ ហេតុនេះ គណៈកម្មាធិការប្រតិបត្តិនៃ គ.ជ.អ.ខ មានបំណងវាយតម្លៃអនុកិច្ចសន្យាចំនួន ២ ដែលបានបញ្ចប់រួចរាល់ ដោយមានការបណ្តុះបណ្តាល និងថវិកាគាំទ្រពីផ្នែកតាមដានត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប នៅក្នុងឆ្នាំផែនការសកម្មភាព និងថវិកា ២០១០នេះ។

### 2.គោលបំណង និងទំហំនៃការវាយតម្លៃអនុកិច្ចសន្យា

គោលបំណង គឺដើម្បីពង្រឹងនូវសមត្ថភាពវាយតម្លៃរបស់មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ នៃគណៈកម្មាធិ ការប្រតិបត្តិ ដោយអនុវត្តន៍ផ្ទាល់នូវការវាយតម្លៃអនុកិច្ចសន្យាចំនួន ២។ ដូច្នេះ ទំហំនៃការវាយតម្លៃនេះគឺនៅក្នុង ដែនអនុកិច្ចសន្យា ដែលត្រូវបានជ្រើសរើសដើម្បីវាយតម្លៃ និងដំណើរការរៀនសូត្រនានា ដែលទាក់ទង នៅក្នុងដំណើរ ការនេះ។

## 3. គោលបំណងនៃការវាយតម្លៃ

គោលបំណង នៃការវាយតម្លៃនេះ គឺ :

១. ដើម្បីទាញយក កត់ត្រា និងវិភាគនូវអ្វីដែលអនុកិច្ចសន្យាសម្រេចបាន និងចំណុចខ្សោយរបស់អនុកិច្ចសន្យា ធៀបជាមួយនឹងលទ្ធផល ទិសដៅបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា ហើយក៏ដើម្បីកត់ត្រានូវ ចំណុចរៀនសូត្រដែលបានមកពីការវាយតម្លៃ និងចំនុចដែលត្រូវកែលម្អក្នុងពេលអនាគតជាប្រព័ន្ធ

២. ដើម្បីពង្រឹងនូវចំនេះដឹង និងចំនេះធ្វើ របស់មន្ត្រីគណៈកម្មាធិការប្រត្តិបត្តិ នៃគ.អ.ជ.ខ ក្នុងការវាយតម្លៃអនុកិច្ចសន្យា នៅថ្នាក់ក្រោមជាតិ ។

អ្នកវាយតម្លៃ ត្រូវស្វែងរកចម្លើយទៅនឹងសំណួរវាយតម្លៃដូចខាងក្រោម ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការវាយតម្លៃអនុកិច្ចសន្យា :

៦- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

៧- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អកម្រិតណា ? (ចំណុច គ ផ្នែកទី ៣)

៨- តើអនុកិច្ចសន្យាសម្រេចគោលបំនងបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៩- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំការអនុវត្ត និងការគ្រប់គ្រង ?

១០-តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលំអអនុកិច្ចសន្យាក្នុងពេលអនាគត ?

## 4. លទ្ធផលរំពឹងទុក

របាយការណ៍វាយតម្លៃជាមួយនឹងចម្លើយតបយ៉ាងពេញលេញទៅនឹងសំណួរវាយតម្លៃខាងលើ ដោយមាន ឯកសារពាក់ពន្ធ័ផ្សេងទៀតជាភាសាខ្មែរ ។

## 5. ការអនុវត្តការវាយតម្លៃ និងការរៀបចំ/គ្រប់គ្រង:

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃផ្នែករដ្ឋបាលគ្រប់គ្រងអនុកិច្ចសន្យា នឹងត្រូវអនុវត្តការវាយតម្លៃ ដោយមានធនធាន/ធាតុចូលពីភ្នាក់ងារអនុវត្តន៍ អ្នកទទួលផល និងភាគីពាក់ពន្ធ័។ ដំណើរការនេះ នឹងត្រូវទទួលការគាំទ្រជាបច្ចេកទេស ដោយគ្រូបង្គោលថ្នាក់ក្រោមជាតិ និងទីប្រឹក្សាត្រួតពិនិត្យ និងវាយតម្លៃថ្នាក់ក្រោមជាតិ។

## 6. ពេលវេលា

មិនលើសពី៧ថ្ងៃ នៅក្នុងកំឡុងខែកញ្ញា និងតុលា ឆ្នាំ២០១០។

## 7. ថវិកា

ពេលវេលារបស់ក្រុមការងារ និងធនធាន/ធាតុចូលពីអ្នកចូលរួម ក្នុងដំណើរការវាយតម្លៃជាចំណាយមិនផ្ទាល់។ ថវិកាចំនួន១៥0ដុល្លាសម្រាប់ចំណាយលើការវាយតម្លៃលើអនុកិច្ចសន្យាមួយត្រូវបានបម្រុងទុកសម្រាប់ ការចំណាយការងារនៅមូលដ្ឋាន និងចំណាយផ្ទាល់ដ៏ទៃទៀត ។

## ឯកសារដែលត្រូវភ្ជាប់ទី៤ : រូបថតឯកសារ

( សេចក្តីណែនាំ: អ្នកវាយតម្លៃត្រូវភ្ជាប់រូបថត២ ឬ៣សន្លឹកដែលបង្ហាញពីសកម្មភាពរបស់គម្រោង លទ្ធផល និងអ្នក ទទួលផលនៅទីនេះ)

# រៀបរៀងដោយៈ


**លោក រ៉េហ្សូល ការីម**

**លោក ឃុន ស៊ីថុន**

ទីប្រក្សាផ្នែកត្រួតពិនិត្យ វាយតម្លៃរបស់ UNDP/PSDD

**ដោយសហការជាមួយ ៖**

**លោក ប្រាក់ សំអឿន**

ប្រធានផ្នែក ផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ

អង្គភាពគាំទ្រកម្មវិធី គ.ជ.អ.ប.

**លោក លី យ៉ាសាក់**

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ

**លោកស្រី លឹម រត្នពិភស្តុ**

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ

**លោកស្រី ធុយ មោលី**

ទីប្រក្សាផ្នែកត្រួតពិនិត្យ វាយតម្លៃ

**លោក ឈួន ប៊ុណ្ណា**

ទីប្រក្សាសម្របសម្រួលកម្មវិធីបណ្តុះបណ្តាល


**ខែកក្កដា ឆ្នាំ២០១០**

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | 21/AGR/0901-00 |
| ចំណងជើង : | គាំទ្រដល់ការអភិវឌ្ឍន៍វិស័យកសិកម្មចំរុះ |
| ភ្នាក់ងារអនុវត្តន៍ : | មន្ទីរកសិកម្មខេត្តតាកែវ |
| រយៈពេល (ចាប់ផ្តើម និងបញ្ចប់) | ០១ មិនា ឆ្នាំ ២០០៩ ដល់ ៣១ ធ្នូ ២០០៩ |
| រាជធានី ខេត្ត | តាកែវ |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរកសិកម្មខេត្តតាកែវ |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ/គ.អ.ជ.ខ | ១៥.៧២០ ដុល្លា |
| ការរួមចំណែករបស់ដៃគូរអភិវឌ្ឍន៍ដទៃទៀត | ៤.៣២០ ដុល្លា |
| ការរួមចំណែករបស់សហគមន៍ | ៤.៩៦០ ដុល្លា |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៍ | ៥.៤០០ ដុល្លា |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | ៣០.៤០០ ដុល្លា |

## ក្រុមវាយតម្លៃ និងរៀបចំរបាយការណ៍:

| ឈ្មោះ | មុខតំណែង |
|---|---|
| លោក ឈួន ប៊ុណ្ណា | ទីប្រឹក្សាសម្របសម្រួលកម្មវិធីបណ្តុះបណ្តាល |
| លោកស្រី ធុយ មោលី | ទីប្រឹក្សាផ្នែកត្រួតពិនិត្យ និងវាយតម្លៃ |
| លោក លី យ៉ាសាក់ | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ |
| លោកស្រី លឹម រត្នពិភស្ត | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ |

តាកែវ

កក្កដា ២០១០

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ១០៧ |
| | របាយការណ៍សង្ខេប | ១០៨ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **១១១** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ១១១ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ១១១ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ១១១ |
| ១.៤ | សំណួរវាយតម្លៃ | ១១២ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ១១២ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ១១៣ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១១៥** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល | ១១៥ |
| | - លទ្ធផលទី១ | ១១៥ |
| | - លទ្ធផលទី២ | ១១៨ |
| | - លទ្ធផលទី៣ | ១១៩ |
| ២.២ | ការវាយតម្លៃការសម្រេចបាននូវអត្ថប្រយោជន៍ភ្លាមៗ និងលទ្ធផលនៃអនុកិច្ចសន្យា | ១២០ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង | ១២៥ |
| ២.៤ | សេចក្តីសន្និដ្ឋាន | ១២៩ |
| **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍** | | **១៣១** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ១៣១ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍/ពិភាក្សា | ១៣២ |
| ទី៣- | ក្របខណ្ឌការងារវាយតម្លៃអនុកិច្ចសន្យា | ១៣៣ |
| ទី៤- | រូបថតឯកសារ | ១៣៥ |

**ករណីសិក្សា** **១២៣**

ទី១- អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគំរោងបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ ១២៣

ទី២- អ្នកមិនទទួលផល ១២៤

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ :

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យានៃគ.ប្រខេត្តតាកែវ បានធ្វើការវាយតម្លៃអនុកិច្ចសន្យា ដែលមានចំណងជើងថា "ការគាំទ្រដល់ការអភិវឌ្ឍវិស័យកសិកម្មចំរុះ" លេខ 21/AGR/0901-00 ដែលជា អនុកិច្ចសន្យា រវាង គ.ប្រ នៃ គ.អ.ជ.ខ ខេត្តតាកែវ និងមន្ទីរកសិកម្ម។ នេះជាផ្នែកមួយនៃគម្រោងពង្រឹងសមត្ថភាព គ្រូបង្គោល ថ្នាក់ក្រោមជាតិ របស់ផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែលគាំទ្រដោយ កម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ។

គោលបំណងជាក់លាក់នៃការវាយតម្លៃនេះគឺ :

១- ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និងចំនុចខ្សោយ ធៀបទៅនឹង លទ្ធផលគោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំង កត់ត្រានូវចំណុចរៀន សូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត និង

២- ពង្រឹងរបៀប ធ្វើការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត។

ការវាយតម្លៃ អនុវត្តតាមការណែនាំ និងឧបករណ៍ស្តីពីការវាយតម្លៃអនុកិច្ចសន្យារបស់គណៈកម្មាធិការ ប្រតិបត្តិ គ.អ.ជ.ខ ដែលរៀបចំដោយផ្នែកត្រួតពិនិត្យ និងវាយតម្លៃនៃលេខាធិការដ្ឋាន គ.ជ.អ.ប។ ក្រុមការងារ វាយតម្លៃបានប្រើការពិភាក្សាក្រុម ការសម្ភាសស៊ីជម្រៅ ការចុះមូលដ្ឋាន គន្លឹះក្នុងការសង្កេតផ្ទាល់ និងរំលឹក ឯកសារអនុកិច្ចសន្យា របាយការណ៍រីកចម្រើន និងឯកសារផ្សេងៗទៀត។

ការវាយតម្លៃ ត្រូវឆ្លើយនឹងសំណួរវាយតម្លៃ (សូមមើលចំណុច ១.៣)។ ដោយសារធនធានមានកំណត់ យើងធ្វើការវាយតម្លៃស៊ីជម្រៅលើលទ្ធផលតែមួយប៉ុណ្ណោះ ចំណែកលទ្ធផលផ្សេងៗទៀតត្រូវបានវាយតម្លៃដោយ ផ្អែកលើពតិមានដែលមានស្រាប់។ ដូច្នេះ ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃស៊ីជម្រៅទៅលើអនុកិច្ចសន្យាទេ ហើយការសន្និដ្ឋានត្រូវធ្វើឡើងទៅតាមអ្វីដែលរកឃើញ។

ឆ្លើយទៅនឹងសំណួរទាំង៥ នៃការវាយតម្លៃ :

១- សកម្មភាពទាំងអស់ត្រូវបានអនុវត្ត និងលទ្ធផលសំរេចបានតាមផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១ | វគ្គបណ្តុះបណ្តាលផលិតកម្មដំណាំស្រូវ ១០វគ្គ | អ្នកចូលរួមចំនួន ៣០២នាក់ |

| | | |
|---|---|---|
| ២ | វគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ ៦វគ្គ | អ្នកចូលរួមចំនួន ១២១នាក់ |
| ៣ | ការធ្វើបង្ហាញផលិតកម្មដំណាំបន្លែ ៣០សួនបន្លែ | ការធ្វើបង្ហាញផលិតកម្មដំណាំបន្លែ ៣០សួនបន្លែ |
| ៤ | វគ្គបណ្តុះបណ្តាលការផលិតជីធម្មជាតិ ១០វគ្គ | អ្នកចូលរួមចំនួន ៣០៦នាក់ |
| ៥ | ធ្វើបង្ហាញការផលិតជីធម្មជាតិ ៧១រោង | ធ្វើបង្ហាញការផលិតជីធម្មជាតិ ៧១រោង |
| ៦ | វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក ៧វគ្គ | អ្នកចូលរួមចំនួន ១៤៨នាក់ |
| ៧ | វគ្គបណ្តុះបណ្តាលពេទ្យសត្វភូមិ ១វគ្គ | អ្នកចូលរួមចំនួន ៣០នាក់ |

២- វគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសដំណាំបន្លែ និងការបង្ហាញផលិត និងប្រើជីធម្មជាតិ មានប្រសិទ្ធភាពណាស់ ដោយសារវាចូលរួមចំណែកក្នុងការបង្កើនផលិតផលបន្លែ ការហូបបន្លែ និងចំណូលគ្រួសារ។

៣- លទ្ធផលបន្ទាន់ និងផលប្រយោជន៍ពីវគ្គបណ្តុះបណ្តាលផលិតកម្មដំណាំស្រូវ បច្ចេកទេសចិញ្ចឹមជ្រូក និងពេទ្យសត្វភូមិ ពិបាកនឹងវាយតម្លៃណាស់ ព្រោះយើងគ្មានពត៌មានមូលដ្ឋាន។

៤- ជារួម អនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យានៅកម្រិតខ្ពស់។

៥- អនុកិច្ចសន្យាពិតជាបានចូលរួមចំណែកក្នុងការសម្រេចនូវគោលបំណងបន្ទាន់ ដោយសារកសិករបានអនុវត្ត បច្ចេកទេសថ្មីដែលទទួលបានពីវគ្គបណ្តុះបណ្តាល និងការបង្ហាញ ផលិតផលកសិកម្ម និងចំណូលគ្រួសាររបស់ពួកគាត់មានការកើនឡើង ទោះជាក្នុងកម្រិត និងដែនកំណត់ក៏ដោយ។

៦- អនុកិច្ចសន្យានេះ ពិតជាមានភាពពាក់ព័ន្ធ ប្រសិទ្ធភាព និងប្រសិទ្ធផល ទាក់ទងនឹងធនធានដែលមាន ការប្រតិបត្តិ និងការគ្រប់គ្រងទូទៅ។ ប៉ុន្តែទោះជាយ៉ាងណា គុណភាពនៃការរៀបរៀងអនុកិច្ចសន្យា គួរតែត្រូវកែលំអដូចខាងក្រោមៈ

ក- បរិយាយអោយបានច្បាស់លាស់ និងអាចវាស់វែងបាន នូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា និងគោលបំណងបន្ទាន់

ខ- ការប្រើប្រាស់សូចនាករជោគជ័យធៀងនឹងទិន្នន័យមូលដ្ឋាន។

គ- ភ្ជាប់ទំនាក់ទំនងអោយបានច្បាស់រវាងលទ្ធផល និងគោលបំណងបន្ទាន់ និងគោលបំណងកម្រិតខ្ពស់។

សេចក្តីសន្និដ្ឋានៈ

១) លទ្ធផល និងអត្ថប្រយោជន៍ដែលបានពីការអនុវត្តន៍អនុកិច្ចសន្យាជាប្រយោជន៍ដល់សហគមន៍ គឺមានភស្តុតាងបង្ហាញច្បាស់លាស់ ហើយត្រូវបាន ទទួលការសារទរ ពីអ្នកទទួលផល និងមិនទទួលផល នៅក្នុងឃុំនៃគម្រោង។ ឧទាហរណ៍ ការបង្កើននូវផលិតកម្មបន្លែ និងលទ្ធផលដែលបានមកពីការប្រើប្រាស់បន្លែនៅក្នុងគ្រួសារ ការសន្សំសំចៃក្នុងគ្រួសារ និងការកើនឡើងនូវប្រាក់ចំណូល ជាលទ្ធផលសម្រេចបានពីវគ្គបណ្តុះបណ្តាល ពីបច្ចេកទេសដំណាំបន្លែនៅក្នុងអនុកិច្ចសន្យា។ លើសពីនេះទៀត ពួកគាត់បានបន្តរសកម្មភាពទាំងនេះ ទោះបីជា គម្រោងបញ្ចប់ទៅ

យូរទៅហើយក្តី ។ ជាពិសេសទៀតនោះ តំរូវការវគ្គបណ្តុះបណ្តាលស្រដៀងគ្នានេះ បានកើតឡើង បន្ទាប់ពីការអនុវត្ត សកម្មភាពគម្រោង ។

២) គួរមានការបន្តរការគាំទ្រគំរោងបែបនេះ ក៏ដូចជាការពង្រីកសកម្មភាពគំរោងបៀបនេះបន្តរទៀត ។

៣) ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីធ្វើអោយសម្រេចបាននូវអត្ថប្រយោជន៍ក្នុងកំរិតខ្ពស់ ភ្នាក់ងារអនុវត្តគម្រោង គួរមានការ ជ្រើសរើស អ្នកទទួលផលអោយបានសមស្រប ។

៤) ដើម្បីពង្រឹងនូវគុណភាព និងភាពទាក់ទងរបស់គម្រោង គួមានការបរិយាយអោយបានច្បាស់លាស់ នូវស្ថានភាពចុងបញ្ចប់ នៃកិច្ចសន្យា និងគោលបំណងបន្ទាន់របស់គម្រោង ក៏ដូចជាពង្រឹងនូវទំនាក់ទំនងតក្ក រវាងធាតុខាងលើទៅនឹងលទ្ធផល ។

៥) ផ្នែករដ្ឋបាល និងគ្រប់គ្រងអនុកិច្ចសន្យាគួរធ្វើការវាយតម្លៃគម្រោងស្រដៀងគ្នានេះអោយបាន ១ ឬ២ អនុកិច្ចសន្យា ជាប្រចាំ ។

# ១.  ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្តល់ថវិកាតាមរយៈ គ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យ ដើម្បអនុវត្តសកម្មភាព និងគម្រោង ដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈជាប្រព័ន្ធ មិនបានអនុវត្តទេកាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើន។ នៅក្នុងឆ្នាំ ២០១០ ជាមួយនឹងការគាំទ្រផ្នែក ថវិកា និងបច្ចេកទេស ពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យា គ.ប្រ នៃគ.អ.ជ.ខ ក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យា ដែលបាន រៀបចំរួមគ្នាជាមួយភ្នាក់ងារអនុវត្តនីដែលមានលេខ : 21/AGR/0901-00គាំទ្រការអភិវឌ្ឍន៏វិស័យកសិកម្មចំរុះ ដំណើរការលទ្ធផល ដែលបានរកឃើញ និងការសន្និដ្ឋាននៃការវាយតម្លៃត្រូវបានកត់ត្រា ហើយនឹងបង្ហាញ តាមរយៈរបាយការណ៍ស្តីពី ការវាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

គោលបំណងបន្ទាន់នៃអនុកិច្ចសន្យាគឺ នៅចុងឆ្នាំ ២០០៩ ទិន្នផលស្រូវ ដំណាំរួមផ្សំ និង ផលិតផលសត្វ ក្នុងគ្រួសារ និងសហគមន៏ ត្រូវបានកើនឡើង តាមរយៈ ការបណ្តុះបណ្តាល ផ្សព្វផ្សាយ និងការធ្វើបង្ហាញ នូវបច្ចេកទេសកសិកម្មសមស្រប ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូល ដោយផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និងតម្លាភាព។ ដូច្នេះ ទំហំនៃការវាយតម្លៃមានដែនកំណត់តាមទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខណ្ឌការងារនៃការវាយតម្លៃ។ គោលបំណង នៃការវាយតម្លៃគឺ: **ក**) ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និងចំនុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំង កត់ត្រានូវ ចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត និង **ខ**)

ដើម្បីពង្រឹងរបៀប ធ្វើការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត ។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើះ

១) ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំនត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធដែលមាននៅក្នុងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៍ ។ (*សូមមើលឯកសារភ្ជាប់ជូនទី១*)

២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗ រួមមានៈ អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផល ផ្ទាល់ និងមិនផ្ទាល់ ២ ឬ៣នាក់ និងអ្នកពាក់ព័ន្ធ ២នាក់ ។ សូមពិគ្រោះជាមួយនឹងមន្ត្រីបង្គោលទៅលើបញ្ហាយេនឌ័រ និងគ្រប់គ្រងធនធានធម្មជាតិ សម្រាប់បញ្ហាពាក់ពន្ធ័វិស័យខាងលើ ។

៣) សូមប្រើប្រាស់វិធីសាស្រ្តចុះពិនិត្យតំបន់អនុវត្តន៍គម្រោង និងសង្កេតមើលសកម្មភាព ពិភាក្សាក្រុម និងករណីសិក្សា។ (*សូមមើលឯកសារភ្ជាប់ជូនទី២*)

៤) ចុះពិនិត្យតំបន់អនុវត្តន៍គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់ ។ (*សូមមើលឯកសារភ្ជាប់ជូនទី២*)

៥) <u>វិភាគទិន្នន័យ និងបកស្រាយ:</u> ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់

៦) <u>ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៍</u> ដោយភ្នាក់ងារអនុវត្តន៍ និងអ្នកពាក់ព័ន្ធតាមរយៈព័តិមានត្រឡប់ដែលទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើង (ដាក់កាលបរិច្ឆេទនៃការធ្វើបទបង្ហាញ នៅទីនេះ) ការវាយតម្លៃត្រូវធ្វើតាម "គោលការណ៍ណែនាំការវាយតម្លៃ អនុកិច្ចសន្យា" និងវិធីសាស្ត្រ ដែលបានណែនាំ។ ដូច្នេះ ដំណើរការត្រូវបានធ្វើឡើងដោយមានទម្រង់ការណែនាំ និងតម្លាភាព រួមទាំងការចូលរួមពីអ្នកពាក់ព័ន្ធ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយ គ.ប្រ និងអ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយការប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត។

២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត : វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោង នៅពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និងបទពិសោធន៍ពីមុនមក។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណង សំខាន់ គឺដើម្បី "រៀនធ្វើដោយការអនុវត្តផ្ទាល់"។ អ្នកវាយតម្លៃ បានទទួលការគាំទ្រដោយមានគោលការណ៍ការ ណែនាំឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។

៣) បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យា: ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និងជោគជ័យទេ ។ មួយទៀត ទំនាក់ទំនងសង្ខេបតាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់ មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ។

៤) ដោយយើងមិនមានសូចនាករឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍"

ដែលជាកម្រិត អត្ថប្រយោជន៍ទៅលើគោលនយោបាយវិម្បការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។

៥) ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិតទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ។ យើងអាចវាយតម្លៃតែទៅលើ កសិករបានទទួលការបណ្តុះបណ្តាល ពីបច្ចេកទេស តាមរយៈការផ្សព្វផ្សាយក្សេត្រសាស្ត្រ និងការបង្ហាញ ដែលជាលទ្ធផលទី១ និងបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ ដែលជាសកម្មភាពទី២ នៃអនុកិច្ចសន្យាលំអិត តាមរយៈការសម្ភាសន៍ស៊ីជម្រៅក្រុមពិភាក្សា និងការចុះពិនិត្យតំបន់អនុវត្តគម្រោង។

៦) សូមរក្សាទុកចំណុចនេះប្រសិនបើវាមានសុពលភាព: ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា មិនអាចធ្វើទៅបានទេ ព្រោះចំណុច គ នៃផ្នែកទី៣ក្នុងឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ ឬមិនពេញលេញ។ ការងារនេះ នឹងកាន់តែមានសុពលភាព និងពោរពេញទៅដោយព័ត៌មាន បើសិនជាចំនុចដែលបានរៀបរាប់ខាងលើ នេះត្រូវបានដោះស្រាយ។

**ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធនី:**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ 21/AGR/0901-00 គាំទ្រការអភិវឌ្ឍន៍វិស័យកសិកម្មចំរុះ និងដែនកំណត់ ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ។

២) ការវាយតម្លៃនេះលម្អិតតែទៅលើ កសិករបានទទួលការបណ្តុះបណ្តាល ពីបច្ចេកទេសតាមរយៈការផ្សព្វផ្សាយ ក្សេត្រសាស្ត្រ និងការបង្ហាញ ដែលជាលទ្ធផល និងបណ្តុះបណ្តាល បច្ចេកទេសដំណាំបន្លែ ដែលជាសកម្មភាព នៃអនុកិច្ចសន្យា

៣) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃទៅលើ ភ្នាក់ងារអនុវត្តន៏ ភ្នាក់ងារដែលពាក់ព័ន្ធគម្រោង ហើយនឹង ការវាយតម្លៃទៅលើគ.ប្រ នៃគ.អ.ជ.ខ និង គ.ជ.អ.ប ទេ។

ហេតុដូច្នេះ របាយការណ៍នៃការវាយតម្លៃ លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ដែលបានលើកឡើង ត្រូវពិនិត្យដោយយោលទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ។

# ២.  លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល

### លទ្ធផលទី១ : ការផ្សព្វផ្សាយ ក្សេត្រសាស្ត្រ និងការបង្ហាញ

**ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ**

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | ▪ វគ្គបណ្តុះបណ្តាលផលិតកម្មដំណាំស្រូវ ១០វគ្គ<br>▪ វគ្គនីមួយៗមានចំនួន៥ថ្ងៃ<br>▪ អ្នកចូលរួមចំនួន ៣០០នាក់ | ▪ វគ្គបណ្តុះបណ្តាលផលិតកម្មដំណាំស្រូវ ១០វគ្គ<br>▪ វគ្គនីមួយៗមានចំនួន៥ថ្ងៃ<br>▪ អ្នកចូលរួមចំនួន ៣០២នាក់ |
| ១.២ | ▪ វគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ ៦វគ្គ<br>▪ វគ្គនីមួយៗមានចំនួន៥ថ្ងៃ<br>▪ អ្នកចូលរួមចំនួន ១២០នាក់ | ▪ វគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ ៦វគ្គ<br>▪ វគ្គនីមួយៗមានចំនួន៥ថ្ងៃ<br>▪ អ្នកចូលរួមចំនួន ១២១នាក់ |
| ១.៣ | ▪ ការធ្វើបង្ហាញផលិតកម្មដំណាំបន្លែ ៣០សួនបន្លែ | ▪ ការធ្វើបង្ហាញផលិតកម្មដំណាំបន្លែ ៣០សួនបន្លែ |
| ១.៤ | ▪ វគ្គបណ្តុះបណ្តាលការផលិតជីធម្មជាតិ ១០វគ្គ | ▪ វគ្គបណ្តុះបណ្តាលការផលិតជីធម្មជាតិ ១០វគ្គ |

| | | |
|---|---|---|
| | ▪ វគ្គនីមួយៗមានចំនួន១ថ្ងៃ<br>▪ អ្នកចូលរួមចំនួន ៣00នាក់ | ▪ វគ្គនីមួយៗមានចំនួន១ថ្ងៃ<br>▪ អ្នកចូលរួមចំនួន ៣0៦នាក់ |
| ១.៥ | ▪ ធ្វើបង្ហាញការផលិតជីធម្មជាតិ ៧១រោង | ▪ ធ្វើបង្ហាញការផលិតជីធម្មជាតិ ៧១រោង |

## ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និងសកម្មភាពនានារបស់អនុកិច្ចសន្យាដែលបានគ្រោងទុក។

អ្នកចូលរួមទាំងអស់នៅក្នុងក្រុមពិភាក្សាដែលជាសិក្ខាកាមពីវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែបានរាយការណ៍ថាពួកគេបានទទួលនូវចំណេះដឹង និងជំនាញ ដែលទាក់ទងទៅនឹងបច្ចេកទេសដាំបន្លែ។ អ្វីដែលគួរអោយចាប់អារម្មណ៍នោះគឺថា ពួកគាត់នៅចាំទ្រឹស្តីខ្លះៗពីវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែទោះបីជាវគ្គបានបញ្ចប់យូរទៅហើយក្តី (កាលពីឆ្នាំ ២00៩)។

សិក្ខាកាមភាគច្រើនចូលចិត្តវិធីសាស្រ្តបណ្តុះបណ្តាល និងអកប្បកិរិយារបស់អ្នកបណ្តុះបណ្តាល។ វិធីសាស្រ្តផ្សេងៗជាច្រើន ត្រូវបានប្រើប្រាស់នៅក្នុងវគ្គបណ្តុះបណ្តាលរួមមានបំផុស គំនិត រូបភាព ក្រុមពិភាក្សា...។ល។ អ្នកបណ្តុះបណ្តាល អាចបន្សាំខ្លួនទៅនឹងបរិបទនៅសហគមន៍បានល្អ ដើម្បីអោយមានការចូលរួមកាន់តែច្រើនពីសិក្ខាកាម។ ទោះជាយ៉ាងណាក៏ដោយ មានសិក្ខាកាមដទៃទៀត បានផ្តល់យោបល់ថា គួររួមបញ្ចូលនូវការបង្ហាញជាក់ស្តែងក្នុងកំឡុងពេលបណ្តុះបណ្តាល ដើម្បីអោយពួកគាត់អាចទទួលបាននូវជំនាញក្នុងការធ្វើជាក់ស្តែង។

សរុបសេចក្តីមក វគ្គបណ្តុះបណ្តាលនេះ មានភាពទាក់ទងទៅនឹងតំរូវការរបស់សិក្ខាកាម ហើយនិងសហគមន៍របស់គេ។ អ្វីដែលសំខាន់ទៀតនោះ អ្នកចូលរួមនៅក្នុងការពិភាក្សាក្រុម

បានគូសបញ្ជាក់ថា ចំនេះដឹង និងជំនាញដែលទទួលបាន នឹងរួមចំណែកធ្វើអោយជីវភាពរបស់គាត់កាន់តែប្រសើរ។ យើងសង្កេតឃើញថា អ្នកភូមិខ្លះបានចាប់ផ្តើមដាំបន្លែនៅក្នុងសួនបន្លែ របស់គាត់ដើម្បីធ្វើអោយចំណូលគ្រួសាររបស់ពួកគាត់កើនឡើង ហើយកាត់បន្ថយការចំណាយនៅក្នុងគ្រួសារ ក៏ដូចជាធ្វើអោយសុខភាពគ្រួសារពួកគាត់ប្រសើរឡើង។

# លទ្ធផលទី២: ជ្រើសរើសកសិករបណ្តុះបណ្តាលឱ្យក្លាយជាភ្នាក់ងារចិញ្ចឹមសត្វភូមិ

## ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ២.១ | ▪ វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក ៧វគ្គ<br>▪ វគ្គនីមួយៗមានចំនួន៣ថ្ងៃ<br>▪ អ្នកចូលរួមចំនួន ១៤0នាក់ | ▪ វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក ៧វគ្គ<br>▪ វគ្គនីមួយៗមានចំនួន៣ថ្ងៃ<br>▪ អ្នកចូលរួមចំនួន ១៤៤នាក់ |

## ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

| |
|---|
| អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និងសកម្មភាពនានាដែលបានគ្រោងទុក។ ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ មិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះបានលម្អិតទេ។ |

## លទ្ធផលទី៣:  ការបង្កើត/គាំទ្រភ្នាក់ងារចិញ្ចឹមសត្វភូមិ

### ផ្នែក-ក: ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ៣.១ | ▪ វគ្គបណ្តុះបណ្តាលពេទ្យសត្វភូមិ ១វគ្គ<br>▪ វគ្គនីមួយៗមានចំនួន៣០ថ្ងៃ<br>▪ អ្នកចូលរួមចំនួន ៣០នាក់ | ▪ វគ្គបណ្តុះបណ្តាលពេទ្យសត្វភូមិ ១វគ្គ<br>▪ វគ្គនីមួយៗមានចំនួន៣០ថ្ងៃ<br>▪ អ្នកចូលរួមចំនួន ៣០នាក់ |

### ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

| |
|---|
| អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និងសកម្មភាពនានាដែលបានគ្រោងទុក។ ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ មិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះបានលម្អិតទេ។ |

## ២.២. ការវាយតម្លៃការសម្រេចបាននូវអត្ថប្រយោជន៍ភ្លាមៗ និងលទ្ធផលនៃអនុកិច្ចសន្យា

ផ្នែកកៈ ការវាយតម្លៃការសម្រេចបានរបស់ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា | ស្ថានភាពជាក់ស្តែង |
|---|---|
| ▪ កសិករចំនួន ៣០០ នាក់ ក្នុងនោះស្រី ៩០ នាក់ មកពី ៧ឃុំ ក្នុង ៤ស្រុក គោលដៅ បានទទួល ចំណេះដឹង អំពីបច្ចេកទេសផលិតកម្មដំណាំស្រូវ | ▪ កសិករចំនួន៣០២នាក់ បានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសផលិតកម្មដំណាំស្រូវ |
| ▪ កសិករចំនួន ១២០នាក់ ក្នុងនោះស្រី ៣៦នាក់ ៥ឃុំ ក្នុង២ស្រុក គោលដៅ បានទទួល ចំណេះដឹង អំពី បច្ចេកទេសដំណាំបន្លែ តាមរយៈការបណ្តុះបណ្តាល ចំនួន៦វគ្គ និង ការ ធ្វើបង្ហាញចំនួន ៣០បង្ហាញ | ▪ កសិករចំនួន១២១នាក់ បានទទួលការបណ្តុះបណ្តាល ពីបច្ចេកទេសដំណាំបន្លែ និង បានធ្វើបង្ហាញដំណាំបន្លែចំនួន ៣០បង្ហាញ។<br>▪ អ្នកចូលរួមភាគច្រើននៅក្នុងការ ពិភាក្សាក្រុម បានរាយការណ៍ថាពួកគាត់ពេញចិត្តនឹង វគ្គបណ្តុះបណ្តាល និងការធ្វើបង្ហាញដំណាំបន្លែនេះ។ បន្ថែមពីលើនេះទៀត ពួកគាត់បញ្ជាក់ថា វគ្គបណ្តុះបណ្តាល ស្តីពីបច្ចេកទេសដំណាំបន្លែពិតជាឆ្លើយតប ទៅនឹងតំរូវការរបស់ពួកគាត់ និងសហគមន៍។ ជាងនេះទៅទៀត អ្នកចូលរួមក្រុមពិភាក្សា បានលើក ឡើងថា ពួកគាត់អាចសន្សំបាន យ៉ាងហោចណាស់ ១០០០ រៀល ក្នុងមួយពេលចំអិន ដោយការ ប្រើប្រាស់បន្លែ ដែលពួកគាត់ដាំ ដោយខ្លួនឯងផ្ទាល់ ដើម្បីចំអិនអាហារ។<br>▪ នៅក្រោយពេលបណ្តុះបណ្តាល យើងសង្កេតឃើញថា កសិករខ្លះ បន្តដាំបន្លែក្នុងគ្រួសាររបស់គាត់ ដើម្បីប្រើប្រាស់ក្នុងគ្រួសារ និងលក់អោយអ្នកភូមិ ដ៏ទៃទៀតនៅក្នុងសហគមន៍ដើម្បីយកកំរៃបន្ថែម។ |

| | |
|---|---|
| | ពួកគេមានមោទនភាពនៅពេលដែលបានឃើញបន្លែដែលគេដាំដោយផ្ទាល់ដោយមិនប្រើជីគីមី ។<br>▪ ការយល់ដឹងរបស់ពួកគាត់ទៅលើបន្លែធម្មជាតិ មានភាពប្រសើរឡើង បន្ទាប់ពីគម្រោងបានបង្ហាញ ពួកគាត់ពីចំនេះដឹង និងជំនាញ បច្ចេកទេសបន្លែនេះ។ អ្វីដែលគួរអោយចាប់អារម្មណ៏ក្រៅពីនេះទៀត អ្នកចូលរួមខ្លះនៅក្នុងការពិភាក្សាក្រុមនៅចាំទ្រឹស្តី មួយចំនួន និងអាចសូត្រឡើងវិញបាន ពីបច្ចេកទេសដាំបន្លែ ដែលគាត់បានរៀន តាំងពីវគ្គដំណាំបន្លែ នៅឆ្នាំ ២០០៩ ។ |
| ▪ កសិករចំនួន ៣០០នាក់ ក្នុងនោះស្រី ៩០នាក់ មកពី ៩ឃុំ ក្នុងស្រុកគោលដៅទាំង ៥ បានទទួលចំណេះដឹង បច្ចេកទេសការផលិត ជីធម្មជាតិ តាមរយៈការបណ្តុះបណ្តាលចំនួន ១០ វគ្គ និងការធ្វើបង្ហាញចំនួន ៧១បង្ហាញ | ▪ បានផ្តល់វគ្គបណ្តុះបណ្តាលផលិតជីធម្មជាតិចំនួន១០វគ្គ<br>▪ ការបង្ហាញជីធម្មជាតិចំនួន៧១រោងបានធ្វើរួចរាល់<br>▪ សរុប កសិករចំនួន៣០៦នាក់បានទទួលការបណ្តុះ បណ្តាល |
| ▪ កសិករចំនួន ៣០នាក់ ក្នុងនោះស្រី ៥នាក់ ៩ឃុំ ក្នុង ៤ស្រុក គោលដៅ បានទទួលការបណ្តុះ បណ្តាល អំពីវគ្គ បច្ចេកទេសភ្នាក់ងារពេទ្យ សត្វភូមិ និងមាន សមត្ថភាពគ្រប់គ្រាន់ ក្នុងការផ្តល់សេវាកម្ម ផ្នែកការពារ និង ព្យាបាល ជំងឺសត្វ និងការចិញ្ចឹមសត្វ។ ពេទ្យ សត្វភូមិ ដែលបានបណ្តុះបណ្តាល រួចចំនួន ៦០នាក់ បានទទួលការពង្រឹងសមត្ថភាព តាមរយៈប្រជុំពង្រឹង ដើម្បីផ្លាស់ប្តូរ បទពិសោធន៏ | ▪ កសិករចំនួន ៣០នាក់ បានទទួលការបណ្តុះបណ្តាល ធ្វើជាភ្នាក់ងារពេទ្យសត្វភូមិ<br>▪ ពេទ្យសត្វភូមិដែលបានបណ្តុះបណ្តាលរួចចំនួន៦០នាក់ បានចូលរួមការប្រជុំពង្រឹងសមត្ថភាព និង ផ្លាស់ប្តូរបទពិសោធន៏ ដើម្បីពង្រឹងសមត្ថភាព របស់ពួកគេ។<br>ភស្តុតាងពីរបាយការណ៏ត្រួតពិនិត្យអនុកិច្ចសន្យាបានបង្ហាញ ថាមានកសិករ ស្ម័គ្រចិត្តចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល នេះទោះបីជាគ្មានសម្ភារះបណ្តុះបណ្តាលសម្រាប់ពួកគេ ក៏ដោយ។ |

| | |
|---|---|
| ក្នុងការពារ ព្យាបាលជំងឺ និង ការចិញ្ចឹមសត្វ | |
| ▪ កសិករចំនួន ១៤០នាក់ ក្នុងនោះស្រី ៤២នាក់ មកពី ៧ឃុំ ក្នុង៣ស្រុក គោលដៅ បានទទួល ចំណេះដឹង មូលដ្ឋាន ស្តីអំពី បច្ចេកទេស ចិញ្ចឹមជ្រូក ជាលក្ខណៈ គ្រួសារ | ▪ វគ្គបច្ចេកទេសចិញ្ចឹមជ្រូកចំនួន៧វគ្គ ត្រូវបានធ្វើរួច<br>▪ កសិករចំនួន១៤៤នាក់បានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមជ្រូក |

## ផ្នែកខៈ ការវាយតម្លៃការសម្រេចបានរបស់គោលបំណងបន្ទាន់

| ល.រ | ធាតុនៃគោលបំណងបន្ទាន់ | ការសម្រេចបានជាក់ស្តែង នៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ |
|---|---|---|
| ១ | នៅចុងឆ្នាំ ២០០៩ ទិន្នផលស្រូវ ដំណាំ រួមផ្សំ និងផលិតផលសត្វ ក្នុងគ្រួសារ និងសហគមន៍ ត្រូវបានកើនឡើងតាមរយៈការបណ្តុះបណ្តាល ផ្សព្វផ្សាយ និងការធ្វើបង្ហាញ នូវ បច្ចេកទេស កសិកម្ម សមស្រប | គោលបំណងបន្ទាន់ដែលបានចែងគឺនៅក្នុងកម្រិតខ្ពស់ធ្វើអោយយើងពិបាកនៅក្នុងការវាស់វែងនៅចុងបញ្ចប់នៃកិច្ចសន្យា។ ទោះបីជាគេរំពឹងទុកថា សកម្មភាពនានា និងលទ្ធផលទាំងឡាយរបស់អនុកិច្ចសន្យា នឹងចូលរួមទៅក្នុងគោលបំណងបន្ទាន់ ប៉ុន្តែផ្អែកទៅលើការពិនិត្យឯកសារ និងវិធីសាស្ត្រវាយតម្លៃបែបគុណភាព គេមិនអាចធ្វើការវាយតម្លៃទៅលើថាតើគោល បំណងបន្ទាន់នេះបានសម្រេចក្នុងកម្រិតណាទេ។ |

## ផ្នែកគៈ ការវាយតម្លៃផលប្រយោជន៍ជារួមដែលទទួលបាន

| |
|---|
| តាមរយៈការពិភាក្សាក្រុម អ្នកចូលរួមបានបង្ហាញថា ពួកគាត់មានការពេញចិត្តចំពោះផលប្រយោជន៍ដែលអនុកិច្ចសន្យានេះសម្រេចបាន ជាពិសេស ចំនេះដឹង និងបច្ចេកទេសថ្មីទៅលើការដាំដុះបន្លែ។ ពួកគាត់បានទទួលស្គាល់ថាវាមានសារប្រយោជន៍សម្រាប់គ្រួសារគាត់ ហើយជាទូទៅ កសិករដាំបន្លែនៅពេលដែលគាត់ទំនេរពីការធ្វើស្រែ។ ជាពិសេសទៀតនោះ ពួកគាត់អាចផលិតបន្លែដើម្បីផ្គត់ផ្គង់ក្នុងគ្រួសាររបស់គាត់ ហើយពួកគាត់ខ្លះទៀតអាចរកប្រាក់ចំណូលបន្ថែមក្នុងគ្រួសារ។ |

## ករណីសិក្សាទី១: អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគំរោងបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ

**បន្ទាប់ពីចូលរួមក្នុងគម្រោងកសិកម្មរបស់គ.អ.ជ.ខ របស់ខេត្ត តាកែវ ក្នុងឆ្នាំ ២០០៩ លោក ម៉ាក បុល បាននិយាយ ÷ "ជីវភាពគ្រួសារខ្ញុំមានភាពប្រសើរឡើង តាំងពីខ្ញុំបានចូលរួមវគ្គបណ្តុះបណ្តាលដំណាំបន្លែ"**



លោក ម៉ាក បុល ជាកសិករ ៤៩ឆ្នាំ រស់នៅក្នុងភូមិអង្គប្រាង្គរ ឃុំសន្លុង ស្រុកទ្រាំង ខេត្តតាកែវ ។ គាត់បាននិយាយថាគម្រោងបណ្តុះបណ្តាលនេះ មានសារៈសំខាន់ខ្លាំងណាស់ ព្រោះគាត់បានទទួលចំណេះដឹង និងជំនាញច្រើនអំពីការដាំបន្លែ ។ គាត់បញ្ជាក់ ÷" ស្ពៃដែលខ្ញុំដាំបាន ១គុម្ព១ មានទំងន់ប្រហែល ១គ.ក ។ អ្នកជិតខាងខ្ញុំមិនចង់ជឿទេថា ខ្ញុំមិនប្រើជីគីមី" ។ ជាងនេះទៅទៀត ជីវភាពគ្រួសារគាត់ មានភាពប្រសើឡើង ដោយសារគាត់បានចំណូលបន្ថែមពីការលក់បន្លែ ។ ដូច្នេះ ចំណូលពីការលក់បន្លែ ក្លាយជាប្រភពចំណូលទី ២ របស់គ្រួសារគាត់បន្ទាប់ពីដំណាំស្រូវ ។ ការផ្លាស់ជាវិជ្ជមានមួយទៀតសម្រាប់គាត់ បន្ទាប់ពីចូលរួមសកម្មភាពគម្រោង គឺគាត់កាន់តែរវល់ជាមួយការដាំស្រូវផង និងបន្លែផង ។ ហេតុនេះហើយ បានជាគាត់អាចដាំបន្លែបានពេញមួយឆ្នាំ ។

ចុងបញ្ចប់ គាត់បានបង្ហាញការប្តេជ្ញាចិត្ត និងទឹកចិត្តក្នុងការបន្តសកម្មភាពសួនបន្លែ ទោះជាមិនបានទទួលអ្វីពីគម្រោង ក៏ដោយ ។ គាត់និយាយ ÷" គ្រាប់ពូជ ១កំប៉ុង ថ្លៃតែ ១៤០០ រៀល ប៉ុណ្ណោះ ហើយខ្ញុំអាចដាំបានជាច្រើន ។ ខ្ញុំលក់តែ ២គុម្ព រួចថ្លៃគ្រាប់ពូជទៅហើយ" ។

## ករណីសិក្សាទី២: អ្នកមិនបានទទួលផល

លោក ង៉ែន គា អាយុ ៣៤ ឆ្នាំ។ គាត់មានគ្រួសារ និងកូន ៣នាក់ ( ស្រី ១ និង ប្រុស ២)។ គាត់រស់នៅក្នុងភូមិ អង្គប្រាង្គរ ឃុំសន្លុង ស្រុកទ្រាំង ខេត្តតាកែវ។ គាត់ជាកសិករ ដែលមានចំណូលពីការដាំស្រូវ និងចិញ្ចឹមសត្វ។



ង៉ែន គា មិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលដំណាំបន្លែរបស់ គ.អ.ជ.ខ ខេត្តតាកែវ ទេ។ គាត់មិនបានត្រូវគេជ្រើសរើសអោយ ចូលរួមដោយសារ គាត់មិនបាននៅផ្ទះ នៅពេលប្រធានភូមិ ចុះមកជ្រើសរើស អ្នកចូលរួម។ គាត់និយាយ ថា វគ្គបណ្តុះបណ្តាលដំណាំបន្លែនេះ មានសារៈសំខាន់ណាស់ ព្រោះគាត់ឃើញអ្នកជិតខាងរបស់គាត់ ដែលចូលរួមវគ្គបណ្តុះបណ្តាល ទទួលបានចំណេះដឹង និងជំនាញក្នុងការដាំបន្លែ។

គាត់បានបន្ថែមទៀតថា ឥឡូវនេះអ្នកដែលបានទទួលការ បណ្តុះបណ្តាល ដាំបន្លែបានច្រើនជាងមុន សម្រាប់ហូប និងលក់ ព្រមទាំងមានចំណូល បន្ថែមពីការលក់បន្លែ។ គាត់បានលើកឡើងថា បច្ចុប្បន្ន ពួកគេអាច សន្សំបាន ១000 រៀល ក្នុងមួយថ្ងៃ ព្រោះពួកគាត់មិនចាំបាច់ ទិញបន្លែពីផ្សារ។ ម្យ៉ាងទៀត គាត់បាននិយាយថា បន្លែដែលដាំដោយ ខ្លួនឯងតាមផ្ទះ មានសារៈប្រយោជន៍ចំពោះសុខភាពគ្រួសារ ដោយសារ មិនបានប្រើជាតិគីមី។

ង៉ែន គា មានសង្ឃឹមថាអាចចូលរួមវគ្គបណ្តុះបណ្តាលអំពីសួនបន្លែរបស់គម្រោង ក្នុងពេលអនាគត និងទទួលបានផលប្រយោជន៍ ដូចអ្នកជិតខាងរបស់គាត់។ ចុងបញ្ចប់ គាត់ទទូចអោយអង្គការ
និងភ្នាក់ងារនានាជួយអភិវឌ្ឍភូមិរបស់គាត់។

## ២.៣ ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

( ពិន្ទុៈ ១= ខ្សោយណាស់ ២= ខ្សោយ ៣= មិនខ្លាំងមិនខ្សោយ ៤= ខ្សោយណាស់ ៥= ខ្លាំងណាស់ )

| ល.រ | ធាតុ | ទំនាក់ទំនងតក្កភាព | បរិយាយច្បាស់លាស់ | សង្ខេបការវាយតម្លៃ |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៤ | ៥ | សកម្មភាពដែលបានលើកឡើង ពិតជាមាន ទំនាក់ទំនងតក្ក ជាមួយនឹងលទ្ធផល ដែលបានសរសេរនៅក្នុងឯកសារអនុកិច្ចសន្យា។ ឧទាហរណ៍ លទ្ធផលទី១ ទាក់ទិននឹងកសិករទទួលបានការបណ្តុះបណ្តាល ពីបច្ចេកទេសកសិកម្ម និងការបង្ហាញ មានសកម្មភាពជាក់លាក់ដូចជា វគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវចំនួន ១០វគ្គ វគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែចំនួន ៦វគ្គ ការធ្វើសួនបន្លែបង្ហាញចំនួន ៣០ វគ្គបណ្តុះបណ្តាលពីបច្ចេកទេសផលិតជីធម្មជាតិចំនួន ១០វគ្គ និង ការធ្វើបង្ហាញជីធម្មជាតិ ចំនួន៧១រោង។ ទាំងនេះឆ្លុះបញ្ចាំងថា សកម្មភាពទាំងនេះមានទំនាក់ទំនងតក្ក ជាមួយនឹងលទ្ធផលនៅខាងលើ ហើយនិងបានសរសេរយ៉ាងច្បាស់។<br>សកម្មភាពនីមួយៗ បានសរសេរបង្ហាញច្បាស់លាស់ដោយមានចំនួន វគ្គបណ្តុះបណ្តាល និងចំនួនសិក្ខាកាម ដែលត្រូវចូលរួមក៏ដូចជាឃុំ និងស្រុកគោលដៅ ដែលគ្របដណ្តប់។ |

| | | | | |
|---|---|---|---|---|
| | | | | សកម្មភាពដីទៃទៀតនៅក្រោមលទ្ធផលបន្តរបន្ទាប់ទៀត (លទ្ធផលទី២ និងទី៣) ត្រូវបានសរសេរ ក្នុងបែបបទដូចគ្នានឹងលទ្ធផលទី១ដែរ។ សកម្មភាពនីមួយៗ មានទំនាក់ទំនងតក្ក ហើយនឹងត្រូវបានបរិយាយច្បាស់លាស់ ដូចដែលមានសរសេរនៅក្នុងអនុកិច្ចសន្យា។ |
| ២ | លទ្ធផល | ៤ | ៥ | លទ្ធផលនីមួយៗ ត្រូវបានសរសេរបរិយាយ ច្បាស់លាស់ ដោយមានសូចនាករ ជាក់លាក់ និងអាចវាស់វែងបាន។ ជាងនេះទៅទៀតនោះ លទ្ធផលនីមួយៗផ្សារភ្ជាប់គ្នាល្អ។ លទ្ធផលនីមួយៗជាការបំពេញបន្ថែមអោយគ្នាទៅវិញទៅមក ហើយរួមគ្នាបំពេញគោលបំណងបន្ទាន់។ ទោះបីជាយ៉ាងនេះក៏ដោយលទ្ធផលទាំងនេះ នៅមិនអាចធ្វើអោយគោលបំណងបន្ទាន់សម្រេចបាននៅឡើយ។ |
| ៣ | គោលបំណងបន្ទាន់ *(គោលបំណងស្ថិតក្នុងចំណុច "ខ" នៃផ្នែកទី ៣)* | ៤ | ៣ | គោលបំណងបន្ទាន់ ត្រូវបានផ្តល់អត្ថន័យយ៉ាងច្បាស់ ប៉ុន្តែគោលបំណងបន្ទាន់នេះ មានកំរិតខ្ពស់ពេក ជាហេតុធ្វើអោយអនុកិច្ចសន្យានេះពិបាកនឹងសម្រេចគោលបំណងបន្ទាន់នេះ ក្នុងកាលៈទេសៈបែបនេះ។ |
| ៤ | ស្ថានភាពចុងបញ្ចប់ អនុកិច្ចសន្យា *(ចំណុច "គ" នៃផ្នែកទី ៣)* | ៤ | ៤ | ស្ថានភាពចុងបញ្ចប់ អនុកិច្ចសន្យា ត្រូវបានបរិយាយច្បាស់ ហើយមានទំនាក់ទំនងផ្ទាល់ទៅនឹង លទ្ធផលនិងសកម្មភាពនៃអនុកិច្ចសន្យា។ ស្ថានភាពចុងបញ្ចប់នេះ បានឆ្លុះបញ្ចាំងនូវ សមិទ្ធិផលដែលសម្រេចបាន នៅក្នុងកម្រិតតលទ្ធផល។ ប៉ុន្តែវាមិនបានឆ្លុះបញ្ចាំងនូវស្ថានភាពចុងបញ្ចប់ ឬផលប៉ះពាល់ដែលអាចកើតមានឡើងនៅក្នុងកំរិត ប្រជា |

| | | | | |
|---|---|---|---|---|
| | | | | ជន និងសហគមន៍ទេ។ គ្មានភស្តុតាងច្បាស់លាស់ណាមួយដើម្បីបង្ហាញថា តើសិក្ខាកាមបានយកចំនេះដឹង និងជំនាញដែលពួកគេទទួលបាន ទៅធ្វើជាប្រយោជន៍ ក្នុងការធ្វើអោយប្រសើរឡើងនូវជីវភាពរបស់ពួកគាត់ទេ។ |
| ៥ | លទ្ធផលអភិវឌ្ឍន៍/ផលប៉ះពាល់ រយៈពេលវែងៈ គោលដៅ និងគោលបំណង អភិវឌ្ឍន៍ *( ចំណុច "ខ" នៃផ្នែកទី ៣)* | | | មិនអាចធ្វើការវាយតម្លៃបាន |

## ផ្នែក-ខៈ សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខ័ណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារៈ

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.ជ.អ.ខៈ** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | នៅមានកំរិត។ គួរតែពង្រឹងបន្ថែម ហើយមានការគាំទ្រជាបច្ចេកទេស។ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យ ការអនុវត្តន៍របស់ភ្នាក់ងារអនុវត្តន៍ | សមរម្យ។ គ្មានការប្រឈម និង ឧបសគ្គ ដែលគួរអោយកត់សំគាល់ទេ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា | ដូចតាមទំលាប់ និងនិតិវិធីដែលបានធ្វើ។ ការកត់ត្រា និងទុកដាក់ឯកសារគួរត្រូវបានកែលំអ។ |
| **ពីខាងភាគីអនុវត្តន៍កិច្ចសន្យាៈ** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | មានបុគ្គលិក ជំនាញ និងបទពិសោធន៍គ្រប់គ្រាន់។ |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | ការអនុវត្តសកម្មភាព និងលទ្ធផល ទាន់ពេលវេលា ដូចដែលបានព្រាងទុក |
| ៦ | ការរាយការណ៍ការរីកចំរើន និង ការកត់ត្រាឯកសារ | ដូចតាមទំលាប់ និងនិតិវិធីដែលបានធ្វើ។ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | លក្ខណ៍ក្នុងកិច្ចសន្យាត្រូវបានបំពេញ |
| **ទាំងខាង គ.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យាៈ** | | |

| | | |
|---|---|---|
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" (ចំណុច-ង ផ្នែកទី៣ ) និងបញ្ហាប្រឈម | ដោយសារមានការយឺតយ៉ាវក្នុងការអនុម័តកិច្ចសន្យា ដែលមិនបានព្រាងទុក សកម្មភាពមួយនៅក្នុង អនុកិច្ចសន្យា មិនអាចធ្វើទៅបានដោយសារវាជាសកម្មភាពតាមរដូវកាល។ ហានិភ័យនេះ ត្រូវបានបញ្ជាក់ យ៉ាងច្បាស់ នៅក្នុងអនុកិច្ចសន្យា ប៉ុន្តែវានៅក្រៅការគ្រប់គ្រង របស់ភ្នាក់ងារអនុវត្តគំរោង។ |
| ៩ | ការបញ្ជ្រាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | មានការលើកកំពស់យេនឌ័រ។ ការចូលរួមរបស់កសិករជាស្ត្រី នៅក្នុងវគ្គបណ្តុះបណ្តាល បច្ចេកទេស ចិញ្ចឹមជ្រូក ដំណាំស្រូវ និង ការផលិតជីធម្មជាតិ មានច្រើនលើសលុបពីផែនការ។ ការចូលរួមនេះ បូករួមទាំងស្ត្រីដែលជាមេគ្រួសារទៀតផង។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ ( ចំណុច-ឆ ផ្នែកទី៣) | ការលើកកំពស់អោយមានការដាំដុះដោយប្រើជីធម្មជាតិ និងមិនប្រើសារធាតុគីមី នៅក្នុងវគ្គបណ្តុះបណ្តាល និងការបង្ហាញ បានចូលរួមជាវិជ្ជមានទៅដល់ការយល់ដឹងពីការអភិរក្សបរិស្ថាន។ |
| ១១ | ការថែរក្សា (និរន្តភាព) ( ចំណុច-ជ ផ្នែកទី៣) | សកម្មភាព និងបច្ចេកទេសខ្លះៗដែលបានលើកឡើងដោយគម្រោង ត្រូវបានមើលឃើញថាត្រូវបានយកទៅអនុវត្តដោយកសិករ ហើយបានបន្តរហូតដល់ពេលក្រុមការងារចុះទៅធ្វើការវាយតម្លៃ។ ដូច្នេះ និរន្តភាពរបស់ផ្នែកខ្លះៗនៃគម្រោងត្រូវបានសម្រេច។ |

## ២.៤ សេចក្តីសន្និដ្ឋាន

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យានេះត្រូវបានអនុវត្តឡើងដូចការគ្រោងទុក។ ភាគីអនុវត្តអនុកិច្ចសន្យា មានសមត្ថភាព និង ធនធាន គ្រប់គ្រាន់ដើម្បីអនុវត្តអនុកិច្ចសន្យា។ សកម្មភាព និងលទ្ធផលដែលបានគ្រោងទុក ត្រូវបានបញ្ចប់ ស្របតាមផែនការការងារ។ |
| ២ | សកម្មភាពរបស់អនុកិច្ចសន្យា និងអត្ថប្រយោជន៍ដែលសហគមន៍ទទួលបានត្រូវបាន អ្នកទទួលផល និងអ្នក មិនទទួលផល សាទរ នៅក្នុងឃុំដែលគំរោងបានអនុវត្ត ហើយដែលក្រុមការងារបានទស្សនកិច្ចនៅក្នុងកំឡុង ពេលធ្វើការវាយតម្លៃ។ ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា ត្រូវបានសម្រេចទាំងស្រុងដូចការព្រាងទុក។ ភស្តុតាងអំពីលទ្ធផល និងផលប្រយោជន៍ដែលទទួលបានដូចខាងក្រោម នៅតែត្រូវបានសង្កេតឃើញ បន្ទាប់ពី ការបញ្ចប់អនុកិច្ចសន្យាជាយូរមកហើយនោះ ដូចជា:<br>ក) ការបន្តដាំដំណាំ ដោយប្រើប្រាស់ចំនេះដឹង ជំនាញ និងបច្ចេកទេសថ្មី ដែលបានទទួលពីវគ្គបណ្តុះបណ្តាល បច្ចេកទេសដំណាំបន្លែ<br>ខ) ការដាំដុះបន្លែកើនឡើងធ្វើអោយការប្រើប្រាស់បន្លែកើនឡើង ហើយការសន្សំសំចៃក្នុងគ្រួសារកើតមាន ក៏ដូចជាធ្វើអោយចំណូលក្នុងគ្រួសារកើនឡើងដោយសារការលក់បន្លែដែលលើស។<br>គ) មានតម្រូវការវគ្គបណ្តុះបណ្តាលស្រដៀងគ្នានេះ ដែលសំណូមពរដោយអ្នកភូមិជាច្រើនទៀត ដែលរស់នៅ ក្នុងស្ថានភាពស្រដៀងគ្នានេះ ប៉ុន្តែមិនទទួលបានការបណ្តុះបណ្តាលកាលពីពេលកន្លងមក។<br>ដូច្នេះអនុកិច្ចសន្យានេះបានទទួលនូវនិរន្តភាពក្នុងសកម្មភាពរបស់ខ្លួនក្នុងកំរិតខ្ពស់។ ហេតុនេះ គម្រោងបាន ចូលរួមចំណែកក្នុងកម្រិតតិចតួចទៅគោលដៅអភិវឌ្ឍន៍នៅក្នុងអនុកិច្ចសន្យា ហើយនិងគោលដៅក្នុងការ កាត់បន្ថយភាពក្រីក្រ។ |
| ៣ | ការជ្រើសរើសសិក្ខាកាម និងអ្នកទទួលផល នៅក្នុងអនុកិច្ចសន្យាដោយភាគីអនុវត្តកិច្ចសន្យាផ្ទាល់ នឹងធ្វើអោយមានការធានាថា<br>អ្នកដែលមានតម្រូវការខ្លាំងបំផុតនឹងទទួលបានផលប្រយោជន៍ពីអនុកិច្ចសន្យា។ |
| ៤ | អនុកិច្ចសន្យានេះមិនបានជួបប្រទះនូវឧបសគ្គ និងបញ្ហាប្រឈមគួរអោយកត់សំគាល់ទេ។ |

**ចំណុចរៀនសូត្រ:**

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ដូចដែលបានសង្កេតឃើញក្នុងការវាយតម្លៃនេះ ផលប៉ះពាល់របស់អនុកិច្ចសន្យា និងនិរន្តភាពរបស់លទ្ធផលនៅ ក្នុងអនុកិច្ចសន្យា អាចត្រូវបានសម្រេចបានក្នុងកំរិតខ្ពស់ ប្រសិនបើអនុកិច្ចសន្យា ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹង តម្រូវការជាអាទិភាពរបស់ក្រុមគោលដៅដែលជាអ្នកទទួលផល ។ |
| ២ | ការបរិយាយច្បាស់លាស់នូវ "គោលបំនងបន្ទាន់" ក្នុងកំរិតដែលអាចវាស់វែងបាន ជាការសំខាន់សម្រាប់ការកត់ត្រាទុក នូវលទ្ធផលរបស់អនុកិច្ចសន្យា និងផលប្រយោជន៍ដែលមាន ដើម្បីការវាយតម្លៃលទ្ធផល ។ |

**អនុសាសន៍ :**

| ល.រ | អនុសាសន៍ |
|---|---|
| ១ | គោលបំណងបន្ទាន់ នៃអនុកិច្ចសន្យា គួរត្រូវបានរៀបរៀង និងសរសេរក្នុងន័យដែលវាមានទំនាក់ទំនង ទៅនឹង លទ្ធផល ហើយបរិយាយច្បាស់អំពីអ្វីដែលជាលទ្ធផលបន្ទាន់ និងអត្ថប្រយោជន៍ ដែលរំពឹងទុក ។ |
| ២ | នៅពេលដែលការជ្រើសរើសក្រុមគោលដៅដោយភាគីអនុវត្តមិនងអាចធ្វើទៅបាន វាជាការប្រសើរបើសិន ភាគីអនុវត្តកិច្ចសន្យា ពិនិត្យមើលឡើងវិញនូវបេក្ខជនសក្តានុពលដែលអាចជ្រើសរើសអោយចូលរួម ក្នុងគម្រោង ដើម្បីជ្រើសរើសពួកគេចូលរួម ។ ការពិនិត្យឡើងវិញនេះនឹងធានាថា ក្រុមគោលដៅសមស្រប នឹងត្រូវបានជ្រើសរើសអោយចូលរួមដើម្បីធានានូវប្រសិទ្ធភាពរបស់គំរោងក្នុងកម្រិតខ្ពស់ ។ |
| ៣ | សកម្មភាពតាមដាននិងគាំទ្របន្តរ គួរត្រូវបានធ្វើឡើងទោះបីជាជីវិតរបស់គម្រោងត្រូវបានបញ្ចប់ដើម្បីធានា និរន្តភាពសកម្មភាពគម្រោង និង ផលប្រយោជន៍ទៅដល់សហគមន៍ ។ |

# ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

**ឯកសារទី១ : បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបាន ពិនិត្យ**

(សេចក្តីណែនាំ: ខាងក្រោមនេះ ជាបញ្ជីឯកសារដែលអ្នកវាយតម្លៃត្រូវពិនិត្យ។ សូមគូស (√)នៅក្នុងប្រអប់ទី(៣) ប្រសិនបើអ្នកបានពិនិត្យឯកសារនោះនៅក្នុងកំឡុងពេលវាយតម្លៃ។ សូមបន្ថែមឈ្មោះឯកសារដែលអ្នកបានពិនិត្យ ប៉ុន្តែមិនមាននៅក្នុងបញ្ជីឈ្មោះនេះ។ សូមដកបង្គោលទី(៣) ហើយនិងឈ្មោះឯកសារ ដែលអ្នកមិនបានពិនិត្យ ចេញ ហើយភ្ជាប់តារាងនេះទៅក្នុងរបាយការណ៍វាយតម្លៃ)

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) | មាន (៣) |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និង ឯកសារវិសោធនកម្ម (ប្រសិនមាន) | √ |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ | √ |
| ៣ | របាយការណ៍ត្រួតពិនិត្យគម្រោង | √ |
| ៤ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | √ |
| ៥ | លិខិតឆ្លើយឆ្លងរវាងភ្នាក់ងារអនុវត្តន៍ និងគណៈកម្មាធិការប្រត្តិបត្តិគ.អ.ជ.ខ | |
| ៦ | បញ្ជីវគ្គបណ្តុះបណ្តាលដែលមានក្នុងអនុកិច្ចសន្យា | √ |
| ៧ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា | |
| ៨ | ឯកសារដ៏ទៃទៀតរួមមាន រូបថតនៃគម្រោង (អនុកិច្ចសន្យា) ដែលទុកនៅ គណៈកម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ និងនៅភ្នាក់ងារអនុវត្តន៍ ដែលមិនបានរៀបរាប់ខាងលើ | |
| ៩ | ផ្សេងទៀត | |

**ឯកសារទី២ : ឯកសារអនុកិច្ចសន្យា លេខ** 21/AGR/0901-00 **ខេត្តតាកែវ**

**បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាសន៍/ជួបពិភាក្សា**

| ល.រ | ថ្ងៃខែ | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា | ទីកន្លែង | ឧបករណ៍ប្រើសម្រាប់ប្រមូលទិន្នន័យដែលបានប្រើ |
|---|---|---|---|---|
| ១ | ១៩ កក្កដា | លោក ចាន់ សុវណ្ណ គ្រូបណ្តុះបណ្តាល ភ្នាក់ងារអនុវត្តគម្រោង នៃមន្ទីរវិស័យ | មន្ទីរកសិកម្ម ខេត្តតាកែវ | សម្ភាសន៍ស៊ីជម្រៅ |
| ២ | ១៩ កក្កដា | លោក យក់ លស់ ប្រធានគម្រោង និងជាមន្ត្រីទទួលខុសត្រូវ | មន្ទីរកសិកម្ម ខេត្តតាកែវ | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | ២០ កក្កដា | ក្រុមអ្នកទទួលផល | ភូមិ អង្គប្រាង្គរ | សម្ភាសន៍ជាក្រុម |
| ៤ | ២០ កក្កដា | លោក ម៉ាក បុល អ្នកទទួលផលផ្ទាល់ | ភូមិ អង្គប្រាង្គរ | សម្ភាសន៍ស៊ីជម្រៅ/ករណីសិក្សា |
| ៥ | ២០ កក្កដា | លោក ង៉ែន គា អ្នកមិនទទួលផល | ភូមិ អង្គប្រាង្គរ | សម្ភាសន៍ស៊ីជម្រៅ/ករណីសិក្សា |

# ឯកសារទី៣ : ក្របខណ្ឌការងារស្តីពីវាយតម្លៃអនុកិច្ចសន្យា

## 1.សាវតា

រៀងរាល់ឆ្នាំ គ.ជ.អ.បបានផ្តល់ថវិកាតាមរយៈគណៈកម្មាធិការប្រត្តិបត្តិនៃ គ.អ.ជ.ខ ទៅដល់មន្ទីរវិស័យ ដើម្បីអនុវត្តគម្រោង និងសកម្មភាពគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ មានមូលហេតុជាច្រើនដែលធ្វើឱ្យខកខាន ក្នុងការវាយតម្លៃអនុកិច្ចសន្យាជាប្រពន្ធ័នាពេលកន្លងមក។ ការវាយតម្លៃអនុកិច្ចសន្យា ពិតជាមានសារៈសំខាន់ក្នុងការកែលំអអនុកិច្ចសន្យា និងកែលម្អការវិនិយោគ និងសេវាកម្ម តាមរយៈអនុកិច្ចសន្យាមួយ ដែលមានភាពល្អប្រសើរឡើង។ ហេតុនេះ គណៈកម្មាធិការប្រតិបត្តិនៃ គ.ជ.អ.ខ មានបំណងវាយតម្លៃអនុកិច្ចសន្យាចំនួន ២ ដែលបានបញ្ចប់រួចរាល់ ដោយមានការបណ្តុះបណ្តាល និងថវិកាគាំទ្រពីផ្នែកតាមដានត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប នៅក្នុងឆ្នាំផែនការសកម្មភាព និងថវិកា ២០១០នេះ។

## 2.គោលបំណង និងទំហំនៃការវាយតម្លៃអនុកិច្ចសន្យា

គោលបំណង គឺដើម្បីពង្រឹងនូវសមត្ថភាពវាយតម្លៃរបស់មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ នៃគណៈកម្មាធិការប្រតិបត្តិ ដោយអនុវត្តន៍ផ្ទាល់នូវការវាយតម្លៃអនុកិច្ចសន្យាចំនួន ២។ ដូច្នេះ ទំហំនៃការវាយតម្លៃនេះគឺនៅក្នុងដែនអនុកិច្ចសន្យា ដែលត្រូវបានជ្រើសរើសដើម្បីវាយតម្លៃ និងដំណើរការរៀនសូត្រនានា ដែលទាក់ទងនៅក្នុងដំណើរ ការនេះ។

## 3. គោលបំណងនៃការវាយតម្លៃ

គោលបំណង នៃការវាយតម្លៃនេះ គឺ :

១. ដើម្បីទាញយក កត់ត្រា និងវិភាគនូវអ្វីដែលអនុកិច្ចសន្យាសម្រេចបាន និងចំណុចខ្សោយរបស់អនុកិច្ចសន្យា ធៀបជាមួយនឹងលទ្ធផល ទិសដៅបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា ហើយក៏ដើម្បីកត់ត្រានូវ ចំណុច រៀនសូត្រដែលបានមកពីការវាយតម្លៃ និងចំនុចដែលត្រូវកែលម្អក្នុងពេលអនាគតជាប្រពន្ធ័
២. ដើម្បីពង្រឹងនូវចំនេះដឹង និងចំនេះធ្វើ របស់មន្ត្រីគណៈកម្មាធិការប្រត្តិបត្តិ នៃគ.អ.ជ.ខ ក្នុងការវាយតម្លៃអនុកិច្ចសន្យា នៅថ្នាក់ក្រោមជាតិ។

អ្នកវាយតម្លៃ ត្រូវស្វែងរកចម្លើយទៅនឹងសំណួរវាយតម្លៃដូចខាងក្រោម ដើម្បីឆ្លើយតបទៅនឹងគោលបំណង នៃការវាយតម្លៃអនុកិច្ចសន្យា :

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?
២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អកម្រិតណា ? (ចំណុច គ ផ្នែកទី ៣)
៣- តើអនុកិច្ចសន្យាសម្រេចគោលបំណងបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)
៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំការអនុវត្ត និងការគ្រប់គ្រង ?
៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលំអអនុកិច្ចសន្យាក្នុងពេលអនាគត ?

## 4. លទ្ធផលរំពឹងទុក

របាយការណ៍វាយតម្លៃជាមួយនឹងចម្លើយតបយ៉ាងពេញលេញទៅនឹងសំណួរវាយតម្លៃខាងលើ ដោយមាន ឯកសារពាក់ពន្ធ័ផ្សេងទៀតជាភាសាខ្មែរ ។

## 5. ការអនុវត្តការវាយតម្លៃ និងការរៀបចំ/គ្រប់គ្រងៈ

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃផ្នែករដ្ឋបាលគ្រប់គ្រងអនុកិច្ចសន្យា នឹងត្រូវអនុវត្តការវាយតម្លៃ ដោយមានធនធាន/ធាតុចូលពីភ្នាក់ងារអនុវត្តន៍ អ្នកទទួលផល និងភាគីពាក់ពន្ធ័ ។ ដំណើរការនេះ នឹងត្រូវទទួលការគាំទ្រជាបច្ចេកទេស ដោយគ្រូបង្គោលថ្នាក់ក្រោមជាតិ និងទីប្រឹក្សាត្រួតពិនិត្យ និងវាយតម្លៃថ្នាក់ក្រោមជាតិ ។

## 6. ពេលវេលា

មិនលើសពី៧ថ្ងៃ នៅក្នុងកំឡុងខែកញ្ញា និងតុលា ឆ្នាំ២០១០ ។

## 7. ថវិកា

ពេលវេលារបស់ក្រុមការងារ និងធនធាន/ធាតុចូលពីអ្នកចូលរួម ក្នុងដំណើរការវាយតម្លៃជាចំណាយមិនផ្ទាល់ ។ ថវិកាចំនួន១៥០ដុល្លាសម្រាប់ចំណាយលើការវាយតម្លៃលើអនុកិច្ចសន្យាមួយ ត្រូវបានបម្រុងទុកសម្រាប់ការចំណាយការងារនៅមូលដ្ឋាន និងចំណាយផ្ទាល់ដ៏ទៃទៀត ។

# ឯកសារទី៤ : រូបថតឯកសារក្រុមពិភាក្សាក្នុងការវាយតម្លៃ



ក្រុមពិភាក្សាវគ្គបច្ចេកទេសដំណាំបន្លែ ភូមិអង្គប្រាង្គរ ឃុំ សន្ទុង ស្រុកទ្រាំង ខេត្តតាកែវ ថ្ងៃទី ២០ កក្កដា ២០១០

# ផ្នែកទី២

# ក្របខណ្ឌការងារស្តីពីការវាយតម្លៃអនុកិច្ចសន្យា

## 1.សាវតា

រៀងរាល់ឆ្នាំ គ.ជ.អ.បបានផ្តល់ថវិកាតាមរយៈគណៈកម្មាធិការប្រត្តិបត្តិនៃ គ.អ.ជ.ខ ទៅដល់មន្ទីរវិស័យ ដើម្បីអនុវត្តគម្រោង និងសកម្មភាពគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ មានមូលហេតុជាច្រើនដែលធ្វើឱ្យខកខាន ក្នុងការវាយតម្លៃអនុកិច្ចសន្យាជាប្រព័ន្ធនាពេលកន្លងមក។ ការវាយតម្លៃអនុកិច្ចសន្យា ពិតជាមានសារៈសំខាន់ក្នុងការកែលំអអនុកិច្ចសន្យា និងកែលម្អការវិនិយោគ និងសេវាកម្ម តាមរយៈអនុកិច្ចសន្យាមួយ ដែលមានភាពល្អប្រសើរឡើង។ ហេតុនេះ គណៈកម្មាធិការប្រតិបត្តិនៃ គ.ជ.អ.ខ មានបំណងវាយតម្លៃអនុកិច្ចសន្យាចំនួន ២ ដែលបានបញ្ចប់រួចរាល់ ដោយមានការបណ្តុះបណ្តាល និងថវិកាគាំទ្រពីផ្នែកតាមដានត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប នៅក្នុងឆ្នាំផែនការសកម្មភាព និងថវិកា ២០១០នេះ។

## 2.គោលបំណង និងទំហំនៃការវាយតម្លៃអនុកិច្ចសន្យា

គោលបំណង គឺដើម្បីពង្រឹងនូវសមត្ថភាពវាយតម្លៃរបស់មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ នៃគណៈកម្មាធិការប្រតិបត្តិ ដោយអនុវត្តន៍ផ្ទាល់នូវការវាយតម្លៃអនុកិច្ចសន្យាចំនួន ២។ ដូច្នេះ ទំហំនៃការវាយតម្លៃនេះគឺនៅក្នុងដែនអនុកិច្ចសន្យា ដែលត្រូវបានជ្រើសរើសដើម្បីវាយតម្លៃ និងដំណើរការរៀនសូត្រនានា ដែលទាក់ទងនៅក្នុងដំណើរ ការនេះ។

## 3. គោលបំណងនៃការវាយតម្លៃ

គោលបំណង នៃការវាយតម្លៃនេះ គឺ :

១. ដើម្បីទាញយក កត់ត្រា និងវិភាគនូវអ្វីដែលអនុកិច្ចសន្យាសម្រេចបាន និងចំណុចខ្សោយរបស់អនុកិច្ចសន្យា ធៀបជាមួយនឹងលទ្ធផល ទិសដៅបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា ហើយក៏ដើម្បីកត់ត្រានូវ ចំណុច រៀនសូត្រដែលបានមកពីការវាយតម្លៃ និងចំនុចដែលត្រូវកែលម្អក្នុងពេលអនាគតជាប្រព័ន្ធ

២. ដើម្បីពង្រឹងនូវចំនេះដឹង និងចំនេះធ្វើ របស់មន្ត្រីគណៈកម្មាធិការប្រត្តិបត្តិ នៃគ.អ.ជ.ខ ក្នុងការវាយតម្លៃអនុកិច្ចសន្យា នៅថ្នាក់ក្រោមជាតិ។

អ្នកវាយតម្លៃ ត្រូវស្វែងរកចម្លើយទៅនឹងសំណួរវាយតម្លៃដូចខាងក្រោម ដើម្បីឆ្លើយតបទៅនឹងគោលបំណង នៃការវាយតម្លៃអនុកិច្ចសន្យា ៖

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អកម្រិតណា ? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចគោលបំណងបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំការអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលំអអនុកិច្ចសន្យាក្នុងពេលអនាគត ?

### 4. លទ្ធផលរំពឹងទុក

របាយការណ៍វាយតម្លៃជាមួយនឹងចម្លើយតបយ៉ាងពេញលេញទៅនឹងសំណួរវាយតម្លៃខាងលើ ដោយមានឯកសារពាក់ពន្ធ័ផ្សេងទៀតជាភាសាខ្មែរ ។

### 5. ការអនុវត្តការវាយតម្លៃ និងការរៀបចំ/គ្រប់គ្រងៈ

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃផ្នែករដ្ឋបាលគ្រប់គ្រងអនុកិច្ចសន្យា នឹងត្រូវអនុវត្តការវាយតម្លៃ ដោយមានធនធាន/ធាតុចូលពីភ្នាក់ងារអនុវត្តន៍ អ្នកទទួលផល និងភាគីពាក់ពន្ធ័។ ដំណើរការនេះ នឹងត្រូវទទួលការគាំទ្រជាបច្ចេកទេស ដោយគ្រូបង្គោលថ្នាក់ក្រោមជាតិ និងទីប្រឹក្សាត្រួតពិនិត្យ និងវាយតម្លៃថ្នាក់ក្រោមជាតិ ។

### 6. ពេលវេលា

មិនលើសពី៧ថ្ងៃ នៅក្នុងកំឡុងខែកញ្ញា និងតុលា ឆ្នាំ២០១០ ។

### 7. ថវិកា

ពេលវេលារបស់ក្រុមការងារ និងធនធាន/ធាតុចូលពីអ្នកចូលរួម ក្នុងដំណើរការវាយតម្លៃជាចំណាយមិនផ្ទាល់។ ថវិកាចំនួន១៥០ដុល្លាសម្រាប់ចំណាយលើការវាយតម្លៃលើអនុកិច្ចសន្យាមួយ ត្រូវបានបម្រុងទុកសម្រាប់ការចំណាយការងារនៅមូលដ្ឋាន និងចំណាយផ្ទាល់ដទៃទៀត ។

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | 01/AGR/0901-00(GOV) |
| ចំណងជើង : | កម្មវិធីកែលំអផលិតកម្មកសិកម្មគាំទ្រដោយថវិការ វិនិយោគខេត្តឆ្នាំ ២០០៩ |
| ភ្នាក់ងារអនុវត្តន៍ : | មន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ |
| រយៈពេល (ចាប់ផ្តើម និងបញ្ចប់) | ០១/០១/២០០៩ - ៣១/១២/២០០៩ |
| រាជធានី ខេត្ត | បន្ទាយមានជ័យ |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ នៃ គ.អ.ជ.ខ | ១២.៦២០,00 ដុល្លា |
| ការរួមចំណែករបស់រាជធានី ខេត្ត | 0.00 ដុល្លា |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៍ | ៣.៦00,00 ដុល្លា |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | ១៦.២២0,00 ដុល្លា |

## ក្រុមវាយតម្លៃ និង រៀបចំរបាយការណ៍

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ និងតួនាទីក្នុងការវាយតម្លៃ |
|---|---|
| ១) លោក លាង ឈន | អនុប្រធាន CAU ទទួលបន្ទុកតាមដានត្រួតពិនិត្យ និង វាយតម្លៃ |
| ២) លោក ស៊ុយ ប៊ុនថន | អនុប្រធាន CAU ទទួលបន្ទុកគ្រប់គ្រងកិច្ចសន្យា |
| ៣) លោក គាន ចំណាន | ទីប្រឹក្សាត្រួតពិនិត្យ វាយតម្លៃ និងវិស័យខេត្តនៃគម្រោង PSDD |
| ៤) លោក លាង ឆាយ | អនុប្រធានមន្ទីរទេសចរណ៍ និងជាគ្រូបង្គោល M&E ខេត្តបន្ទាយមានជ័យ |
| ៥) កញ្ញា អ៊ឹង រស្មី | អនុប្រធានមន្ទីរកិច្ចការនារី និងជាគ្រូបង្គោល M&E ខេត្តបន្ទាយមានជ័យ |

ខេត្តបន្ទាយមានជ័យ

តុលា ២០១០

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៣ |
| | របាយការណ៍សង្ខេប | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៧** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៧ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៧ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៧ |
| ១.៤ | សំណួរវាយតម្លៃ | ៨ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ៨ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ៩ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១១** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១) | ១១ |
| | - លទ្ធផលទី១ ដល់ លទ្ធផលទី១០ | ១១-១៨ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផលភ្លាមៗ និងលទ្ធផលនៃអនុកិច្ចសន្យា | ១៩ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង | ២៥ |
| **២.៤** | **សេចក្តីសន្និដ្ឋាន** | **២៧** |
| **ឯកសារដែលត្រូវភ្ជាប់ ជាមួយនឹងរបាយការណ៍** | | ៣០ |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យារបាយការណ៍ និង ឯកសារពាក់ព័ន្ធផ្សេងៗដែលបានពិនិត្យ | ៣០ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ពតិមានសំខាន់ដែលបានជួបសម្ភាសន៍/ពិភាក្សា | ៣១ |


**ករណីសិក្សា**


| | | |
|---|---|---|
| ទី១- | អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងបណ្តុបណ្តាលបច្ចេកទេសដំណាំស្រូវ | ២៣ |
| ទី២- | អ្នកមិនទទួលផល | ២៤ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

***គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ:***

មន្ត្រីត្រួតពិនិត្យ និង វាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ ខេត្តបន្ទាយមានជ័យ បានធ្វើការវាយតម្លៃអនុកិច្ចសន្យា ដែលមានចំណងជើងថា "កម្មវិធីកែលំអផលិតកម្មកសិកម្មគាំទ្រដោយថវិកាវិនិយោគខេត្ត ឆ្នាំ២០០៩" លេខ 01/AGR/0901-00 (GOV) ដែលជាអនុកិច្ចសន្យារវាង មន្ទីរកសិកម្ម និង គ.ប្រ នៃ **គ.អ.ជ.ខ** ខេត្តបន្ទាយមានជ័យ ។ នេះជាផ្នែកមួយនៃគម្រោងពង្រឹងសមត្ថភាព គ្រូបង្គោលថ្នាក់ក្រោមជាតិរបស់ផ្នែកត្រួតពិនិត្យ និងវាយតម្លៃ និង ផ្សព្វផ្សាយ គោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែលគាំទ្រ ដោយកម្មវិធីអភិវឌ្ឍន៍ តាមបែបប្រជាធិបតេយ្យតាមរយៈគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

***គោលបំណងជាក់លាក់ក្នុងការវាយតម្លៃនេះគឺ:***

១. ទាញយក កត់ត្រា និង វិភាគជាប្រពន្ធ័ទៅលើសមិទ្ធិផលនៃអនុកិច្ចសន្យា និង ចំណុចខ្សោយធៀបទៅនិងលទ្ធផល គោលបំណងបន្ទាន់ និង ស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យារួមទាំងកត់ត្រានូវចំណុចរៀនសូត្រ និង ផ្នែកដែលត្រូវធ្វើអោយប្រសើរឡើងនៅពេលអនាគត ។

២. ពង្រឹងរបៀបធ្វើការវាយតម្លៃគម្រោងរបស់ គប្រ នៃ **គ.អ.ជ.ខ** នៅក្នុងដំណើការនៃការអនុវត្ត ។ ការវាយតម្លៃអនុវត្តតាមការណែនាំ និង ឧបករណ៍ស្តីពីការវាយតម្លៃអនុកិច្ចសន្យារបស់គណៈកម្មាធិការប្រតិបត្តិ នៃ គ.អ.ជ.ខ ដែលរៀបចំដោយផ្នែកត្រួតពិនិត្យ និងវាយតម្លៃនៃលេខាធិការដ្ឋាន គ.ជ.អ.ប ។ ក្រុមការងារវាយតម្លៃបានប្រើការពិភាក្សាក្រុម ការសម្ភាសន៏ស៊ីជម្រៅ ការចុះមូលដ្ឋាន ដើម្បីធ្វើការសង្កេតដោយផ្ទាល់ និងរំលឹកឯកសារអនុកិច្ចសន្យា របាយការណ៍រីកចម្រើន និង ឯកសារផ្សេងៗទៀត ។

ការវាយតម្លៃ ត្រូវឆ្លើយនឹងសំណួរវាយតម្លៃ (សូមមើលចំណុច ១.៣)។ ដោយសារធនធានមានកំណត់ យើងធ្វើការ វាយតម្លៃស៊ីជំរៅលើលទ្ធផលមួយប៉ុណ្ណោះ ចំណែកលទ្ធផលផ្សេងៗទៀត ត្រូវបានវាយតម្លៃដោយផ្អែកលើពត៌មានដែលមានស្រាប់ ។ ដូចនេះ ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃស៊ីជម្រៅទៅលើអនុកិច្ចសន្យាទេ ហើយការសន្និដ្ឋានត្រូវធ្វើឡើងទៅតាមអ្វីដែលបានរកឃើញ ។

ឆ្លើយទៅនឹងសំណួរទាំង៥ នៃការវាយតម្លៃ :

**១. សកម្មភាពទាំងអស់ត្រូវបានអនុវត្ត និង លទ្ធផលសម្រេចបានតាមផែនការ**

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១ | ការធ្វើបង្ហាញផលិតកម្មដំណាំស្រូវ ៣ បង្ហាញ | បង្ហាញផលិតកម្មដំណាំស្រូវ ៣ បង្ហាញ |
| ២ | ការធ្វើបង្ហាញប្រពលវប្បកម្មដំណាំស្រូវ ៣ បង្ហាញ | បង្ហាញប្រពលវប្បកម្មដំណាំស្រូវ ៣ បង្ហាញ |
| ៣ | បានទទួលការ ពង្រឹង ភ្នាក់ងារពេទ្យសត្វភូមិ អ្នកចូលរួម ចំនួន ២១២ នាក់ | អ្នកចូលរួម ចំនួន ២១២ នាក់ |
| ៤ | ការចាក់វ៉ាក់សាំង គោ ក្របី សរុប ចំនួន ៩១៥៨ក្បាល ស្មើ ៩១៥៨ ក៏រិត | ការចាក់វ៉ាក់សាំង គោ ក្របី សរុប ចំនួន ៩១៥៨ ក្បាល ស្មើនឹង ៩១៥៨ ក៏រិត |
| ៥ | បណ្តុះបណ្តាលអំពីបច្ចេកទេសថែទាំនិងជួសជុសគ្រឿងយន្តកសិកម្ម ៤វគ្គ | អ្នកចូលរួមចំនួន ១២៤ នាក់ |
| ៦ | ជួសជុលម៉ូតូ ២ គ្រឿង និង កុំព្យូទ័រ ២ គ្រឿង | ជួសជុលម៉ូតូ ២ គ្រឿង និង កុំព្យូទ័រ ២ គ្រឿង |
| ៧ | ចុះតាមដានការអនុវត្តន៏គម្រោង | អនុវត្តន៏ការចុះតាមដានគម្រោងបាន ៣៥% |
| ៨ | វាយតម្លៃការអនុវត្តគម្រោង និង រៀបចំរបាយការណ៍វាយតម្លៃបញ្ចប់អនុកិច្ចសន្យា និង របាយការណ៍បិទអនុកិច្ចសន្យាជូន គ.ប្រ | មិនបានអនុវត្តន៍ |
| ៩ | បណ្តុះបណ្តាលអំពីដំណាំស្រូវ ៦ វគ្គ | -អ្នកចូលរួមចំនួន ១៩២នាក់ ក្នុងនោះស្រី100នាក់ |
| ១០ | បណ្តុះបណ្តាលអំពីការផលិត និង ប្រើប្រាស់ជីកំប៉ុស្តិ ៨ វគ្គ | -អ្នកចូលរួមចំនួន ២៥៦នាក់ |
| ១១ | បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម ៦វគ្គ | -អ្នកចូលរួមចំនួន ១៩២នាក់ |
| ១២ | បណ្តុះបណ្តាលអំពីការផលិតពូជស្រូវ ១វគ្គ | -អ្នកចូលរួមចំនួន ៣0នាក់ |
| ១៣ | បណ្តុះបណ្តាលអំពីបច្ចេកទេសដំណាំឈើហូបផ្លែ ៤វគ្គ | -អ្នកចូលរួមចំនួន ១២៨នាក់ |
| ១៤ | បណ្តុះបណ្តាលអំពីបច្ចេកទេសដំណាំបន្លែ ៤វគ្គ | -អ្នកចូលរួមចំនួន ១២៨នាក់ |
| ១៥ | បណ្តុះបណ្តាលអំពីបច្ចេកទេសដំណាំចំការ ២វគ្គ | -អ្នកចូលរួមចំនួន ៧0នាក់ |
| ១៦ | បណ្តុះបណ្តាលទីផ្សារផលិតផល ១វគ្គ | -អ្នកចូលរួមចំនួន ៣0នាក់ |
| ១៧ | បណ្តុះបណ្តាលអំពីបច្ចកទេសចិញ្ចឹមសត្វ ២៥វគ្គ | -អ្នកចូលរួមចំនួន ៥00នាក់ |
| ១៨ | បណ្តុះបណ្តាលអំពីបច្ចកទេសកែច្នៃចំណីសត្វ | អ្នកចូលរួមចំនួន ១២៨នាក់ |

**២. វគ្គបណ្តុះបណ្តាលពីបច្ចេកទេសដំណាំស្រូវៈ**

មានប្រសិទ្ធភាពណាស់ដោយសារស្របតាមស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលមានប្រភពពីកសិកម្ម រួមចំណែកក្នុងការបង្កើនទិន្នផលស្រូវ ហូបចុកគ្រប់គ្រាន់ គ្រួសារអាចបញ្ជូនកូនទៅរៀន រស់នៅសមរម្យ ។

៣. លទ្ធផលបន្ទាន់ និង ផលប្រយោជន៍ ពីវគ្គបណ្តុះបណ្តាបច្ចេកទេសកសិកម្ម ដំណាំបន្លែ ដំណាំឈើហូបផ្លែ ដំណាំចំការ បច្ចេកទេសចិញ្ចឹមសត្វ ពេទ្យសត្វភូមិ ពិបាកវាយតម្លៃព្រោះយើងគ្មានពតិមានជាមូលដ្ឋាន។

៤. ជារួមអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា នៅកំរិតខ្ពស់ ។

៥. អនុកិច្ចសន្យានេះពិតជាមានភាពពាក់ព័ន្ធ និងប្រសិទ្ធភាព ប្រសិទ្ធផល ទាក់ទងទៅនឹងធនធានដែលមាន ការប្រតិបត្តិ និង ការគ្រប់គ្រងទូទៅ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គុណភាពនៃការរៀបរៀងអនុកិច្ចសន្យា គួរតែត្រូវកែលំអរ ដូចខាងក្រោម ៈ

ក. គោលបំណងបន្ទាន់ គួរបរិយាយអោយបានច្បាស់ និង អាចវាស់វែងបាន ។

ខ. ភ្ជាប់ទំនាក់ទំនងអោយបានច្បាស់រវាងលទ្ធផល និងគោលបំណងបន្ទាន់ និង គោលបំណងកំរិតខ្ពស់ ។

គ. ភ្នាក់ងារអនុវត្តអនុកិច្ចសន្យា គួរធ្វើការតាមដានអោយបានគ្រប់សកម្មភាពដែលបានអនុវត្ត ដើម្បីជួយកែលំអរ និង ចូលរួមដោះស្រាយទាន់ពេលវេលា ។

សេចក្តីសន្និដ្ឋានសំខាន់ៗ ផ្អែកទៅលើលទ្ធផលដែលបានរកឃើញ និងផ្តោតទៅលើបទពិសោធន៍ដែលទទួលបាន និងផ្នែកដែលត្រូវកែលម្អឱ្យប្រសើរឡើង (អនុសាសន៍) ដោយសង្ខេបផ្អែក ២.៤ នៃរបាយការណ៍។

១-លទ្ធផល និង អត្ថប្រយោជន៍ ដែលទទួលបានពីការអនុវត្តអនុកិច្ចសន្យា ជាប្រយោជន៍ដល់សហគមន៍ក្នុងឃុំ ដែលអនុវត្តគម្រោង ។ ការអនុវត្តបច្ចេកទេសដំណាំស្រូវ អ្នកទទួលផលមានការកើនឡើងនូវទិន្នផលស្រូវ ហូបចុក គ្រប់គ្រាន់ សល់ពីការហូបចុក ពួកគាត់អាចលក់ដូរសម្រាប់ការផ្គត់ផ្គង់ ការរៀនសូត្ររបស់កូនពួកគាត់ ។ មិនតែ ប៉ុណ្ណោះពួកគាត់បន្តសកម្មភាពទាំងនេះ និង មួយចំនួនទៀត មានការតាំងចិត្តក្នុងការយកចំណេះដឹង និងបច្ចេកទេស ដំណាំស្រូវយកមកអនុវត្តក្បែរភូមិ ដើម្បីជាការបង្ហាញដល់សហគមន៍ពួកគាត់ផងដែរ ។

២-ដើម្បីអោយសម្រេចបាននូវអត្ថប្រយោជន៍ក្នុងកំរិខ្ពស់ ភ្នាក់ងារអនុវត្តគម្រោង គួរធ្វើការជ្រើសរើសក្រុមគោលដៅអោយ បានសមស្រប និងធ្វើការតាមដានការអនុវត្ត ដើម្បីកែលំអរ ដោះស្រាយនូវបញ្ហា ដែលបានជួបប្រទេះអោយបានទាន់ពេលវេលា។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្តល់ថវិកាវិនិយោគតាមរយៈ គ.ប្រ នៃ គ.អ.ជ.ខ ទៅឱ្យមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និងគម្រោង ដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈ ជាប្រព័ន្ធមិនបានអនុវត្តទេ កាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើន ។ នៅក្នុងឆ្នាំ២០១០នេះ ដោយមានការគាំទ្រថវិកា និងបច្ចេកទេស ពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យា គ.ប្រ នៃគ.អ.ជ.ខ ក្នុងការអនុវត្តការ វាយតម្លៃអនុកិច្ចសន្យា ដែលបានរៀបចំរួមគ្នាជាមួយភ្នាក់ងារ អនុវត្តន៍ ដែលមានលេខៈ 01/AGR/0901-00(GOV) កម្មវិធីកែលំអផលិតកម្មកសិកម្មគាំទ្រដោយថវិការ វិនិយោគខេត្តឆ្នាំ ២០០៩ ដំណើរការលទ្ធផល ដែលបានរកឃើញ និងការសន្និដ្ឋាន នៃការវាយតម្លៃ ត្រូវបានកត់ត្រា ហើយនឹងបង្ហាញតាមរយៈរបាយការណ៍ស្តីពី ការវាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

ការអនុវត្តន៍រាល់សកម្មភាពគ្រប់ផ្នែកលើការអភិវឌ្ឍន៍វិស័យកសិកម្ម ធ្វើយ៉ាងណា អោយប្រជាកសិករយល់ដឹងពីបច្ចេកទេសកសិកម្ម ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី និងការការពារមច្ឆជាតិ អោយបានល្អប្រសើរ និង ធ្វើអោយផលិតផលកសិកម្មរបស់កសិករបានទទួលបរិមាណច្រើន និង គុណភាពល្អ ធានាការហូបចុកពេញមួយឆ្នាំ និងអាចប្រកួតប្រណាំងលើទីផ្សារ។ គោលដៅនេះ និង រួមចំណែកដល់ទិសដៅរបស់កម្មវិធី គ.ជ.អ.ប "ស្ថាប័នពាក់ពន្ធ័គ្រប់ថ្នាក់ត្រូវបានពង្រឹង និង អនុវត្តប្រពន្ធ័វិមជ្ឈការ និង វិសហមជ្ឈការប្រកបដោយប្រសិទ្ធភាព " និងស្របតាមការអនុវត្តគោលនយោបាយចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូល ដោយផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និងតម្លាភាព។ ដូច្នេះ ទំហំនៃការវាយតម្លៃមានដែនកំណត់តាមទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខណ្ឌការងារនៃការវាយតម្លៃ។

| |
|---|
| គោលបំណង នៃការវាយតម្លៃគឺៈ ក) ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និងចំនុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំង កត់ត្រានូវ ចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត និង ខ) ដើម្បីពង្រឹងរបៀប ធ្វើការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត។ |

## ១.៤. សំណួរវាយតម្លៃ

| |
|---|
| ១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ? <br> ២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣) <br> ៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣) <br> ៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ? <br> ៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ? |

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

| |
|---|
| វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើៈ <br> ១) ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំនត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធដែលមាននៅក្នុងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៍។ (*សូមមើលឯកសារភ្ជាប់ជូនទី១*) <br> ២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័តិមានសំខាន់ៗរួមមានៈ អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផល ផ្ទាល់ និងមិនផ្ទាល់ ២ ឬ៣នាក់ និងអ្នកពាក់ព័ន្ធ ២នាក់។ ពិគ្រោះជាមួយនឹងមន្ត្រីបង្គោលទៅលើបញ្ហាយេនឌ័រ និងគ្រប់គ្រងធនធានធម្មជាតិ សម្រាប់បញ្ហាពាក់ពន្ធ័វិស័យខាងលើ ។ <br> ៣) ប្រើប្រាស់វិធីសាស្ត្រចុះពិនិត្យតំបន់អនុវត្តន៏គម្រោង និងសង្កេតមើលសកម្មភាព ពិភាក្សាក្រុម និងករណីសិក្សា។ (*សូមមើលឯកសារភ្ជាប់ជូនទី២*) <br> ៤) ចុះពិនិត្យតំបន់អនុវត្តន៏គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់។ (*សូមមើលឯកសារភ្ជាប់ជូនទី២*) |

៥) <u>វិភាគទិន្នន័យ និងបកស្រាយៈ</u> ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់

៦) <u>ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៍</u> ដោយភ្នាក់ងារអនុវត្តន៏ និងអ្នកពាក់ព័ន្ធតាមរយៈព័ត៌មានត្រឡប់ដែលទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើង ការវាយតម្លៃត្រូវធ្វើតាម "គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា" និងវិធីសាស្ត្រដែលបានណែនាំ។ ដូច្នេះ ដំណើរការត្រូវបានធ្វើឡើងដោយមានទម្រង់ការណែនាំ និងតម្លាភាព រួមទាំងការចូលរួមពីអ្នកពាក់ព័ន្ធ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយ គ.ប្រ និងអ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយការប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត។

២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត : វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោង នៅពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និងបទពិសោធន៏ពីមុនមក។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណង សំខាន់ គឺដើម្បី "រៀនធ្វើដោយការអនុវត្តផ្ទាល់"។ អ្នកវាយតម្លៃ បានទទួលការគាំទ្រដោយមានគោលការណ៍ការ ណែនាំឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។

៣) បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យាៈ ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និងជោគជ័យទេ ។ មួយទៀត ទំនាក់ទំនងសង្ខេបតាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ។

៤) ដោយយើងមិនមានសូចនាករបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៏" ដែលជាកម្រិត អត្ថប្រយោជន៏ទៅលើគោលនយោបាយវិម្បការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។

៥) ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃ លម្អិតទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ។ យើងអាចវាយតម្លៃតែទៅលើ កសិករបានទទួលការបណ្តុះបណ្តាលបច្ចេកទេស កសិកម្ម ផ្សព្វផ្សាយក្សេត្រសាស្ត្រ និង ការបង្ហាញ ដែលជាលទ្ធផល និង បណ្តុះបណ្តាលអំពីដំណាំស្រូវដែលជាសកម្ម ភាពនៃអនុកិច្ចសន្យាលំអិតតាមរយៈ ការសម្ភាសន៏ស៊ីជម្រៅ ក្រុមពិភាក្សា និងការចុះពិនិត្យតំបន់

អនុវត្តគម្រោង។

៦) ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់ នៃអនុកិច្ចសន្យា មិនអាចធ្វើទៅបានទេ ព្រោះចំណុច គ នៃផ្នែកទី៣ក្នុងឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ ឬមិនពេញលេញ។

ការងារនេះ នឹងកាន់តែមានសុពលភាព និងពោរពេញទៅដោយព័ត៌មាន បើសិនជាចំនុចដែលបានរៀបរាប់ខាងលើនេះត្រូវបានដោះស្រាយ។

**ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធនី:**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ: 01/AGR/0901-00(GOV) និងដែនកំណត់ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ។

២) ការវាយតម្លៃនេះលម្អិតតែទៅលើ កសិករបានទទួលការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ផ្សព្វផ្សាយក្សេត្រសាស្ត្រ និង ការបង្ហាញ ដែលជាលទ្ធផល និង បណ្តុះបណ្តាលអំពីដំណាំស្រូវ ដែលជាសកម្មភាពនៃអនុកិច្ចសន្យា

៣) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃទៅលើ ភ្នាក់ងារអនុវត្តនី ភ្នាក់ងារដែលពាក់ព័ន្ធគម្រោង ហើយនឹង ការវាយតម្លៃទៅលើគ.ប្រ នៃគ.អ.ជ.ខ និង គ.ជ.អ.ប ទេ។

ហេតុដូច្នេះ របាយការណ៍នៃការវាយតម្លៃ លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ដែលបានលើកឡើង ត្រូវពិនិត្យដោយយោលទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ។

# ២ លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល

**លទ្ធផលទី១ : ការបង្ហាញផ្នែកក្សេត្រសាស្ត្រ (ឈើហូបផ្លែ ស្រូវ បន្លែ)**

**ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀប និង ផែនការ**

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | បង្ហាញផលិតកម្មដំណាំស្រូវ ៣ បង្ហាញ - ៣ភូមិ ៣ ឃុំ ៣ស្រុក | បង្ហាញផលិតកម្មដំណាំស្រូវ ៣ បង្ហាញ - ៣ភូមិ ៣ ឃុំ ៣ស្រុក |
| ១.២ | បង្ហាញប្រពលវប្បកម្មដំណាំស្រូវ ៣ បង្ហាញ - ៣ភូមិ ៣ ឃុំ ៣ស្រុក | បង្ហាញប្រពលវប្បកម្មដំណាំស្រូវ ៣ បង្ហាញ - ៣ភូមិ ៣ ឃុំ ៣ស្រុក |

**ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល**

| |
|---|
| អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និង សកម្មភាព នានារបស់អនុកិច្ចសន្យាដែលបានគ្រោងទុក ។ ការពិនិត្យលើឯកសារ អនុកិច្ចសន្យាឡើងវិញ មិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះបានលំអិតទេ ។ |

## លទ្ធផលទី២: ការបង្កើត/ គាំទ្រភ្នាក់ងារពេទ្យសត្វភូមិ

### ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀប និង ផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ២.១ | ពង្រឹងភ្នាក់ងារពេទ្យសត្វភូមិចំនួន២១២នាក់ ក្នុងនោះ ស្រី ២នាក់ | ពង្រឹងភ្នាក់ងារពេទ្យសត្វភូមិ ចំនួន២១២នាក់ ក្នុងនោះ ស្រី ១៣នាក់ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

| |
|---|
| អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និង សកម្មភាព នានារបស់អនុកិច្ចសន្យាដែលបានគ្រោងទុក ។ ការពិនិត្យលើឯកសារ អនុកិច្ចសន្យាឡើងវិញ មិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះបានលំអិតទេ ។ |

## លទ្ធផលទី៣. ការចាក់ថ្នាំបង្កាសត្វ និង កម្មវិធីការពារប៉ារ៉ាស៊ីត ជ្រូក គោ ក្របី មាន់ ទា

### ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀប និង ផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ៣.១ | -ការចាក់វ៉ាក់សាំង គោ ក្របី សរុប ចំនួន ៩១៥៨ក្បាល ស្មើ ៩១៥៨ ក៏រិត ១៦ ឃុំក្នុង ៦ ស្រុក | -ការចាក់វ៉ាក់សាំង គោ ក្របី សរុប ចំនួន ៩១៥៨ក្បាល ស្មើ ៩១៥៨ ក៏រិត ១៦ ឃុំ ក្នុង ៦ ស្រុក |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

| |
|---|
| អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និង សកម្មភាព នានារបស់អនុកិច្ចសន្យាដែលបានគ្រោងទុក ។ការពិនិត្យលើឯកសារ អនុកិច្ចសន្យាឡើងវិញ មិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះបានលំអិតទេ ។ |

## លទ្ធផលទី ៤: សម្ភារៈកសិកម្ម

### ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀប និងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ៤.១ | បណ្តុះបណ្តាលអំពីបច្ចេកទេសថែទាំនិងជួសជុសគ្រឿងយន្តកសិកម្ម ៤វគ្គ អ្នកចូលរួមចំនួន ១២៤ នាក់ | -បណ្តុះបណ្តាលអំពីបច្ចេកទេសថែទាំនិងជួសជុសគ្រឿងយន្តកសិកម្ម ៤វគ្គ អ្នកចូលរួមចំនួន ១២៤ នាក់ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

| |
|---|
| អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និង សកម្មភាព នានារបស់អនុកិច្ចសន្យាដែលបានគ្រោងទុក ។ការពិនិត្យលើឯកសារ អនុកិច្ចសន្យាឡើងវិញ មិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះបានលំអិតទេ ។ |

## លទ្ធផលទី៨. កសិករបានទទួលការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ផ្សព្វផ្សាយក្សេត្រសាស្ត្រ និង ការបង្ហាញ

## ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀប និង ផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ៨.១ | បណ្តុះបណ្តាលអំពីដំណាំស្រូវ ៦ វគ្គ<br>-វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>-អ្នកចូលរួមចំនួន ១៩២នាក់ | បណ្តុះបណ្តាលអំពីដំណាំស្រូវ ៦ វគ្គ<br>-វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>-អ្នកចូលរួមចំនួន ១៩២នាក់ក្នុងនោះស្រី១០០នាក់ |
| ៨.២ | បណ្តុះបណ្តាលអំពីការផលិត និង ប្រើប្រាស់ជីកំប៉ុស្តិ ៨ វគ្គ<br>-អ្នកចូលរួមចំនួន ២៥៦នាក់ | បណ្តុះបណ្តាលអំពីការផលិត និង ប្រើប្រាស់ជីកំប៉ុស្តិ ៨ វគ្គ<br>-អ្នកចូលរួមចំនួន ២៥៦នាក់ ក្នុងនោះស្រី ១២១ នាក់ |
| ៨.៣ | បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី និង ថ្នាំកសិកម្ម ៦ វគ្គ<br>-អ្នកចូលរួម ចំនួន ១៩២នាក់ | បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី និង ថ្នាំកសិកម្ម ៦ វគ្គ<br>-អ្នកចូលរួមចំនួន ១៩២នាក់ក្នុងនោះស្រី ៣៨ នាក់ |
| ៨.៤ | បណ្តុះបណ្តាលអំពីការផលិតពូជស្រូវ ១វគ្គ<br>-វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>-អ្នកចូលរួមចំនួន ៣០នាក់ | បណ្តុះបណ្តាលអំពីការផលិតពូជស្រូវ ១វគ្គ<br>-វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>-អ្នកចូលរួមចំនួន ៣០នាក់ ក្នុងនោះស្រី ៦ នាក់ |
| ៨.៥ | បណ្តុះបណ្តាលអំពីបច្ចកទេសដំណាំឈើហូបផ្លែ ៤វគ្គ<br>-វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>-អ្នកចូលរួមចំនួន ១២៨នាក់ | បណ្តុះបណ្តាលអំពីបច្ចកទេសដំណាំឈើហូបផ្លែ ៤វគ្គ<br>-វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>-អ្នកចូលរួមចំនួន ១២៨នាក់ ក្នុងនោះស្រី ៤២នាក់ |

| | | |
|---|---|---|
| ៨.៦ | បណ្តុះបណ្តាលអំពីបច្ចេកទេសដំណាំបន្លែ ៤វគ្គ<br>-វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>-អ្នកចូលរួមចំនួន ១២៨នាក់ | បណ្តុះបណ្តាលអំពីបច្ចេកទេសដំណាំបន្លែ ៤វគ្គ<br>-វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>-អ្នកចូលរួមចំនួន ១២៨នាក់ ក្នុងនោះស្រី ៦៧នាក់ |
| ៨.៧ | បណ្តុះបណ្តាលអំពីបច្ចេកទេសដំណាំចំការ ២វគ្គ<br>-អ្នកចូលរួមចំនួន ៧០នាក់ | បណ្តុះបណ្តាលអំពីបច្ចេកទេសដំណាំចំការ ២វគ្គ<br>-អ្នកចូលរួមចំនួន ៧០នាក់ ក្នុងនោះស្រី ៣៨នាក់ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និង សកម្មភាពនានា របស់អនុកិច្ចសន្យាដែលបានគ្រោងទុក ។ អ្នកចូលរួមក្នុងក្រុមពិភាក្សាបានរាយការណ៍ថា ពួកគាត់ពេញចិត្តក្នុងការទទួលចំណេះដឹង និង ជំនាញបច្ចេកទេសដំណាំស្រូវ ក្រោយពេលដែលពួកគាត់ចូលរួម វគ្គបណ្តុះបណ្តាល អំពីបច្ចេកទេសដំណាំស្រូវ ។

សិក្ខាកាមភាគច្រើនចូលចិត្តវិធីសាស្រ្តបណ្តុះបណ្តាលដូចជា ការបំផុសគំនិត ការបង្ហាញរូបភាព ការលើកឧទាហរណ៍មកបញ្ជាក់ និង អកប្បកិរិយារបស់អ្នកបណ្តុះបណ្តាលមានភាពសាមញ្ញ និងលើកទឹកចិត្តអោយសិក្ខាកាមចូលរួម ក្នុងនោះដែរ សិក្ខាកាមភាគច្រើន មានភាពក្លាហានក្នុងការសួរ និង បញ្ចេញយោបល់យ៉ាងផុលផុស។ យើងឃើញថាសិក្ខាកាមមួយចំនួនបានផ្តល់យោបល់ថា គួមានការធ្វើបង្ហាញជាក់ស្តែង ដូចជាធ្វើស្រែបង្ហាញ ដើម្បីអោយពួកគាត់ទទួលបាននូវ ជំនាញក្នុងការធ្វើជាក់ស្តែងតែបើខ្វះដីស្រែពួកគាត់ធានា ថានឹងចូលរួមដោះស្រាយក្នុងការរកទីតាំង។ ចំណែកសិក្ខាកាមខ្លះទៀតក៏បានតាំងចិត្តក្នុងការពង្រីក ការអនុវត្តន៏ពីបច្ចេកទេស ដំណាំស្រូវនេះទៅលើដីស្រែរបស់គាត់ផងដែរ ។

សរុបសេចក្តីមក វគ្គបណ្តុះបណ្តាលឆ្លើតបទៅ និង តម្រូវការ និងស្ថានភាពរបស់សិក្ខាកាម និង សហគមន៏របស់ពួកគេ ។ អ្វីដែលគួរឱ្យកត់សំគាល់នោះ គឺការទទួលបាននូវចំណេះដឹង និងជំនាញ ដែលធ្វើអោយស្ថានភាព ជីវភាពកាន់តែប្រសើរ មានលទ្ធភាពបញ្ជូនកូនទៅរៀន និង មានឆន្ទះក្នុងការបន្តការអនុវត្តន៏ ទោះជាគម្រោងបានបញ្ចប់ក៏ដោយ ។

## លទ្ធផលទី. ៩ ការបណ្ដុះបណ្ដាលសម្រាប់ក្រុមរកប្រាក់ចំណូល

### ផ្នែក-ក : ការសម្រេចបានជាក់ស្ដែងធៀប និង ផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្ដែង |
|---|---|---|
| ៩.១ | បណ្ដុះបណ្ដាលទីផ្សារផលិតផល ១វគ្គ<br>-វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>-អ្នកចូលរួមចំនួន ៣០នាក់ | បណ្ដុះបណ្ដាលទីផ្សារផលិតផល ១វគ្គ<br>-វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>-អ្នកចូលរួមចំនួន ៣០នាក់ ក្នុងនោះស្រី ១២នាក់ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និង សកម្មភាព នានារបស់អនុកិច្ចសន្យាដែលបានគ្រោងទុក ។ ការពិនិត្យលើឯកសារ អនុកិច្ចសន្យាឡើងវិញ មិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះបានល់អិតទេ

## លទ្ធផលទី ១០ ការបណ្តុះបណ្តាលកសិករពីបច្ចេកទេសផ្សព្វផ្សាយសុខភាពសត្វ ផលិតកម្ម និង បង្ហាញ

### ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀប និង ផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១០.១ | បណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមសត្វ ២៥វគ្គ<br>-វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>-អ្នកចូលរួមចំនួន ៥០០នាក់ | បណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមសត្វ ២៥វគ្គ<br>-វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>-អ្នកចូលរួមចំនួន ៥០០នាក់ ក្នុងនោះស្រី ១៩៩នាក |
| ១០.២ | បណ្តុះបណ្តាលអំពីបច្ចេកទេសកែច្នៃចំណីសត្វ ៤វគ្គ<br>-វគ្គនិមួយៗមានចំនួន ៥ថ្ងៃ<br>-អ្នកចូលរួមចំនួន ១២៨នាក់ | បណ្តុះបណ្តាលអំពីបច្ចេកទេសកែច្នៃចំណីសត្វ ៤វគ្គ<br>-វគ្គនិមួយៗមានចំនួន ៥ថ្ងៃ<br>-អ្នកចូលរួមចំនួន ១២៨នាក់ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

| |
|---|
| អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និង សកម្មភាព នានារបស់អនុកិច្ចសន្យាដែលបានគ្រោងទុក ។ការពិនិត្យលើឯកសារ អនុកិច្ចសន្យាឡើងវិញ មិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះបានល់អិតទេ |

## ២.២. ការវាយតម្លៃលើការសម្រេចបាននូវអត្ថប្រយោជន៍ភ្លាមៗ និង លទ្ធផលអនុកិច្ចសន្យា

### ផ្នែក-ក: ការវាយតម្លៃការសម្រេចបាននូវស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា | ស្ថានភាពជាក់ស្តែង |
|---|---|
| កសិករគោលដៅមកពី៣ភូមិ ៣ឃុំ៣ស្រុកបានចូល រួមក្នុងការបង្ហាញផលិតកម្ម ដំណាំស្រូវ ៣បង្ហាញ | កសិករគោលដៅ ៣ភូមិ ៣ ឃុំ ៣ស្រុក បានចូលរួមការបង្ហាញផលិតកម្មដំណាំស្រូវ ៣ បង្ហាញ |
| កសិករគោលដៅ មកពី ៣ភូមិ ៣ឃុំ ៣ស្រុក បានចូលរួមក្នុងការ បង្ហាញប្រពលវប្បកម្មដំណាំស្រូវ ៣បង្ហាញ | កសិករគោលដៅ ៣ភូមិ ៣ ឃុំ ៣ស្រុក បានចូលរួមក្នុងការបង្ហាញប្រពលវប្បកម្មដំណាំស្រូវ ៣បង្ហាញ |
| កសិករគោលដៅ ចំនួន ២១២ ក្នុងនោះស្រី ២នាក់ មកពី ៧ស្រុក បានទទួលការពង្រឹងភ្នាក់ងារពេទ្យ សត្វភូមិ | កសិករគោលដៅ ចំនួន ២១២ ក្នុងនោះស្រី ២ នាក់ បានទទួលការពង្រឹងភ្នាក់ងារពេទ្យសត្វភូមិ |
| កសិករគោលដៅ មកពី ១៦ ឃុំ ក្នុង ៦ ស្រុក បានទទួល ការចាក់វ៉ាក់សាំង គោ ក្របី សរុប ចំនួន ៩១៥៨ ក្បាល ស្មើ ៩១៥៨ ក៏រិត | កសិករគោលដៅ បានទទួល ការចាក់វ៉ាក់សាំង គោ ក្របី សរុបចំនួន ៩១៥៨ក្បាល ស្មើ ៩១៥៨ ក៏រិត |
| កសិករគោលដៅ ចំនួន ១២៤ នាក់ មកពី ៤ ឃុំ ក្នុង ៤ស្រុក បានទទួល បណ្តុះបណ្តាលអំពីបច្ចេកទេសថែទាំ និងជួសជុលគ្រឿងយន្តកសិកម្ម | កសិករគោលដៅ ចំនួន ១២៤ នាក់ បានទទួលការបណ្តុះបណ្តាលអំពីបច្ចេកទេសថែទាំ និងជួសជុស គ្រឿងយន្តកសិកម្ម |
| ជួសជុល ម៉ូតូ ២ គ្រឿង និង កុំព្យូទ័រ ២ គ្រឿង | ម៉ូតូ ២ គ្រឿង និង កុំព្យូទ័រ ២ គ្រឿង ត្រូវបានជួសជុល |
| កសិករគោលដៅ ចំនួន ១៩២ នាក់ មកពី ៦ឃុំ ក្នុង ៤ស្រុក បានទទួល វគ្គបណ្តុះបណ្តាលអំពីដំណាំស្រូវ ។ | កសិករគោលដៅ ចំនួន ១៩២ នាក់ ក្នុងនោះស្រី ១០០នាក់ បានទទួលវគ្គបណ្តុះបណ្តាលអំពីដំណាំស្រូវ ។<br>-អ្នកចូលរួមភាគច្រើ មានការពេញចិត្តនឹងវគ្គបណ្តុះបណ្តាលនេះណាស់ ព្រោះវាស្របតាមស្ថានភាពរស់នៅ និងតម្រូវការរបស់គាត់ ដោយសារពួកគាត់ជាអ្នកធ្វើស្រែចំការ គាត់អាចយកចំណេះ ដឹង និងជំនាញនេះទៅអនុវត្ត ។ ជាងនេះទៅទៀត |

| | |
|---|---|
| | ទិន្នផលស្រូវ របស់ពួកគាត់មានការកើនឡើងពី ១ ហិតា ២០បាវ ទៅ ៣០បាវ គាត់អាចហូបចុកគ្រប់គ្រាន់ និងលក់ដូរ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួ សាររបស់ពួកគាត់ផងដែរ។<br>-នៅពេលក្រោយការបណ្តុះបណ្តាល យើងសង្កេតឃើញពួកគាត់ នៅចងចាំយ៉ាងច្បាស់ ពីដំណាក់កាលនិមួយៗ នៃការដាំដំណាំ ស្រូវ ពិសេសជាងនេះទៅទៀត សិក្ខាកាមខ្លះតាំងចិត្តក្នុង ការបង្ហាញនូវលទ្ធផល ដែលទទួលបានជោគជ័យដល់សហគមន៍ ពួកគាត់ និងពង្រីកបន្ថែមលើផ្ទៃដីពួកគាត់ ដែលមានតាម លទ្ធភាព ដែលអាចធ្វើទៅបាន ។ |
| កសិករគោលដៅ ចំនួន ២៥៦ នាក់ មកពី ៨ ឃុំ ក្នុង ៧ស្រុក បានទទួលវគ្គបណ្តុះបណ្តាល អំពីការ ផលិត និងប្រើប្រាស់ជីកំប៉ុស្តិ៍ | កសិករគោលដៅ ចំនួន ២៥៦ នាក់ ក្នុងនោះស្រី ១២១នាក់ បានទទួលវគ្គ បណ្តុះបណ្តាលអំពីការ ផលិត និង ប្រើប្រាស់ ជីកំប៉ុស្តិ៍ ។ |
| កសិករគោលដៅ ចំនួន ១៩២ នាក់ មកពី ៦ឃុំ ក្នុង ៦ស្រុក បានទទួលវគ្គបណ្តុះបណ្តាលបច្ចេកទេស ប្រើប្រាស់ជីគីមី និងថ្នាំ កសិកម្ម ។ | កសិករគោលដៅ ចំនួន ១៩២ នាក់ ក្នុងនោះស្រី ៣៨ នាក់ បានទទួល វគ្គបណ្តុះបណ្តាលបច្ចេកទេស ប្រើប្រាស់ជីគីមី និង ថ្នាំកសិកម្ម |
| កសិករគោលដៅ ចំនួន ៣០ នាក់ មកពី ១ឃុំ ក្នុង ១ស្រុក បានទទួលវគ្គបណ្តុះបណ្តាល អំពីការផលិត ពូជស្រូវ ។ | កសិករគោលដៅ ចំនួន ៣០ នាក ក្នុងនោះស្រី ៦ នាក់ បានទទួលវគ្គបណ្តុះបណ្តាលអំពីការផលិតពូជស្រូវ |
| កសិករគោលដៅ ចំនួន ១២៨ នាក់ មកពី ៤ឃុំ ក្នុង ៣ស្រុក បានទទួលវគ្គបណ្តុះបណ្តាលអំពីបច្ចកទេស ដំណាំឈើហូផ្លែ | កសិករគោលដៅ ចំនួន ១២៨ នាក់ក្នុងនោះស្រី ៤២នាក់ បានទទួល វគ្គបណ្តុះបណ្តាលអំពីបច្ចកទេសដំណាំឈើហូផ្លែ |
| កសិករគោលដៅ ចំនួន ១២៨ នាក់ មកពី ៤ឃុំ ក្នុង ៣ស្រុក បានទទួលវគ្គបណ្តុះបណ្តាលអំពីបច្ចេក ទេសដំណាំបន្លែ។ | កសិករគោលដៅ ចំនួន ១២៨ នាក់ក្នុងនោះ ស្រី ៦៧នាក់ បានទទួលវគ្គបណ្តុះបណ្តាលអំពី បច្ចេកទេសដំណាំបន្លែ |

| | |
|---|---|
| កសិករគោលដៅ ចំនួន ៧០នាក់ មកពី ២ ឃុំ ក្នុង ២ស្រុក បានទទួលវគ្គបណ្ដុះបណ្ដាលអំពីបច្ចេកទេស ដំណាំចំការ ។ | កសិករគោលដៅ ចំនួន ៧០នាក់ក្នុងនោះស្រី៣៨ នាក់ បានទទួលវគ្គបណ្ដុះបណ្ដាលអំពីបច្ចេកទេស ដំណាំចំការ |
| កសិករគោលដៅ ចំនួន ៣០ នាក់ក្នុងនោះស្រី ១៥នាក់ ក្នុងស្រុកម៉ាឡៃ បានទទួលវគ្គបណ្ដុះបណ្ដាល ទីផ្សារផលិតផល ។ | កសិករគោលដៅ ចំនួន ៣០ នាក់ក្នុងនោះស្រី ១២នាក់ ក្នុងស្រុកម៉ាឡៃ បានទទួលវគ្គ បណ្ដុះបណ្ដាលទីផ្សារផលិតផល |
| កសិករគោលដៅ ចំនួន៥០០នាក់ មកពី ២៥ឃុំ ក្នុង ៦ស្រុក បានទទួលវគ្គបណ្ដុះបណ្ដាលអំពីបច្ចកទេស ចិញ្ចឹមសត្វ ។ | កសិករគោលដៅ ចំនួន៥០០នាក់ ក្នុងនោះស្រី ១៩៩នាក់ បានទទួលវគ្គ បណ្ដុះបណ្ដាលអំពី បច្ចកទេសចិញ្ចឹមសត្វ |
| កសិករគោលដៅ ចំនួន ១២៨ នាក់ មកពី ៤ឃុំ ក្នុង ៤ស្រុក បានទទួលវគ្គបណ្ដុះបណ្ដាលអំពីបច្ចកទេសកែច្នៃចំណីសត្វ ។ | កសិករគោលដៅ ចំនួន ១២៨ នាក់ បានទទួលវគ្គបណ្ដុះបណ្ដាលអំពីបច្ចកទេសកែច្នៃចំណីសត្វ |

## ផ្នែក-ខ: វាយតម្លៃការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា

| ធាតុនៃគោលបំណងបន្ទាន់ | ការសម្រេចបានជាក់ស្ដែង នៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ |
|---|---|
| គាំទ្រមន្ទីរកសិកម្មក្នុងការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងធ្វើការបង្ហាញនានាដើម្បីអោយប្រជាកសិករ អាចទទួលបាននូវបច្ចេកទេស សមស្របតាមមូលដ្ឋានអោយបានឆាប់ និងមានប្រសិទ្ធភាព ជាពិសេស ការការពារស្ថេរភាពបរិស្ថានធម្មជាតិ ដែលជាទិសដៅអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជា វិប្បធម៌សន្តិភាពក្នុងតំបន់ដែលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។ | គោលបំណងបន្ទាន់ដែលបានរៀបចំនេះនៅក្នុងកំរិតខ្ពស់ពេកធ្វើអោយមានការពិបាកក្នុងការវាស់វែងនៅចុងបញ្ចាប់នៃអនុកិច្ចសន្យា។ បើយើងពិនិត្យលើឯកសារ និង វិធីសាស្ត្រវាយតម្លៃបែបគុណភាព គេមិនអាចធ្វើការវាយតម្លៃបានថាគោលបំណងបន្ទាន់នោះ សម្រេចបានកំរិតណាទេ ។ |

## ផ្នែក-គះ ការវាយតម្លៃផលប្រយោជន៍ជារួមដែលទទួលបាន

តាមរយៈការពិភាក្សាក្រុម អ្នកចូលរួមបានបង្ហាញថា ពួកគាត់ពេញចិត្តយ៉ាងខ្លាំងចំពោះវគ្គបណ្តុះបណ្តាលដំណាំស្រូវដោយពួកគាត់ទទួលបាន នូវចំណេះដឹង និងបច្ចេកទេសថ្មីពីការដាំដំណាំស្រូវ។ ជាទូទៅអ្នកដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះជាអ្នកប្រកបរបរធ្វើស្រែចំការ ដែលអាចអោយពួកគាត់យកចំណេះដឹងទាំងនេះទៅអនុវត្តន៍ ដើម្បីបង្កើនទិន្នផលស្រូវ ហូបចុកគ្រប់គ្រាន់ និងអាចលក់ដូរសម្រាប់ផ្គត់ផ្គង់ ទៅលើការរៀនសូត្ររបស់កូនចៅពួកគាត់ និងបង្កើនជីវភាពគ្រួសារ ។ ពិសេសទៅទៀត កសិករមួយចំនួនបានធ្វើការតាំងចិត្ត និងយកចំណេះដឹងរបស់គាត់ទៅអនុវត្តន៍ពង្រីកផ្ទៃដីបន្ថែម និងអនុវត្តលើដីស្រែដែលនៅជិតភូមិ ដើម្បីបង្ហាញដល់កសិករផ្សេងទៀត អំពីបច្ចេកទេសដំណាំស្រូវដែលគាត់ទទួលបានជោគជ័យ ។

## ករណីសិក្សាទី១ : អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងបណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ

| | |
|---|---|
| លោក យ៉ែម វិចិត្រ | លោក យ៉ែម វិចិត្រ ជាកសិករម្នាក់ អាយុ ៣៩ ឆ្នាំ ប្រពន្ធរបស់គាត់ឈ្មោះ ឡាន់ សុភា អាយុ ៣៨ ឆ្នាំ គាត់មានកូនចំនួន ៣ នាក់ ប្រុស ១នាក់ ស្រី ២ នាក់ គ្រួសារគាត់រស់នៅក្នុងភូមិព្រៃឬស្សី សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។ ក្រោយពីបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលបច្ចេកទេស ដំណាំស្រូវ ដែលបានរៀបចំឡើងដោយមន្ត្រីនៃមន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ រួចមកបានធ្វើអោយគាត់មានការយល់ដឹង ពីបច្ចេកទេសដំណាំស្រូវបានច្បាស់លាស់ ហើយគាត់បានយកបច្ចេកទេសនោះទៅអនុវត្ត លើដីស្រែរបស់គាត់ ១ហិតា ក្នុងចំនួនដីស្រែ ១២ហិតា ព្រោះតែគាត់ខ្វះថវិកាក្នុងការ អនុវត្តតាមបច្ចេកទេសដែលត្រូវការដោយចំណាយថវិកាច្រើន។ ក្រោយពីអនុវត្តតាម បច្ចេកទេសមកឃើញថាដីស្រែ ១ ហិតា ដែលពីមុនធ្លាប់តែបានផលជាមធ្យមត្រឹមតែ ២០បាវ តែឥឡូវ ក្នុង១ហិតា បានផលប្រមាណ ៣០បាវ ។ លោក វិចិត្រ បានមាន ប្រសាសន៍ថា ក្រោយពេល ដែលគាត់ធ្វើស្រែ តាមចច្ចេកទេសដែលគាត់បានសិក្សារួចមក គុម្ពស្រូវរបស់គាត់ល្អដូចជាគុម្ពស្លឹកគ្រៃ ហើយបានប្តេជ្ញាថានឹងអនុវត្តន៏បច្ចេកទេសនេះ នាឆ្នាំក្រោយៗទៀត ព្រមទាំងញញឹមហើយបន្តថាឆ្នាំក្រោយទៀតគាត់នឹងមានជីវភាព ធូរធា នឹងពង្រីកផ្ទៃដីបន្ថែម និងអនុវត្តលើដីស្រែដែលនៅជិតភូមិ ដើម្បីបង្ហាញដល់កសិករ ផ្សេងទៀតពី បច្ចេកទេសដំណាំស្រូវដែលគាត់ទទួលបានជោគជ័យ ។ |

## ករណីសិក្សាទី២ : អ្នកមិនបានទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងបណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ

| | |
|---|---|
| លោក **ឆាត់ វុទ្ធី** | លោក **ឆាត់ វុទ្ធី** អាយុ២៨ឆ្នាំភេទប្រុស។ គាត់មានគ្រួសារ និងកូនប្រុស១នាក់។ គាត់រស់នៅក្នុងភូមិព្រៃឫស្សី សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ គាត់ជាកសិករដែលមានចំណូលពីការដាំស្រូវ និងរត់ម៉ូតូឌុប។<br><br>**ឆាត់ វុទ្ធី** មិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលណាមួយឡើយ។ គាត់មិនបានត្រូវគេជ្រើសរើសឱ្យចូលរួមដោយសារគាត់មិនសូវបាននៅផ្ទះ នៅពេលដែលប្រធានភូមិចុះមកជ្រើសរើសអ្នកចូលរួម។ គាត់បាននិយាយថា វគ្គបណ្តុះបណ្តាលដំណាំស្រូវ នេះមានសារៈសំខាន់ណាស់ ដើម្បីចិញ្ចឹមជីវិតឱ្យមានជីវភាពធូរធារ។ គាត់បានឃើញអ្នកជិតខាងគាត់ ឈ្មោះតាផុងដែល បានចូលរួមវគ្គបណ្តុះបណ្តាលដំណាំស្រូវនេះទទួលបានចំណេះដឹង និងជំនាញបច្ចេកទេសក្នុង ការធ្វើស្រែទទួលបានផលច្រើនជាងមុន។ គាត់បានបន្តទៀតថា កាលពីមុនតាផុងគាត់មិន ទាន់បានទទួលវគ្គបណ្តុះបណ្តាល គាត់ធ្វើស្រែក្នុង៣ហិកតាបាន ចំនួន៥០បាវប៉ុណ្ណោះ។ ឥឡូវនេះ គាត់ធ្វើស្រែក្នុង៣ហិកតាបានផល រហូតដល់៦៤បាវឯណោះ។ បច្ចុប្បន្នគាត់មានជីវ ភាពធូរធារ កូនចៅបានចូលរៀនគ្រប់៧គ្នា។ គាត់បានទទួលផលចំណេញរហូតបានទិញម៉ូតូ មួយបន្ថែមទៀត។<br><br>**ឆាត់ វុទ្ធី** គាត់មានសង្ឃឹមថាអាចបានចូលរួមវគ្គបណ្តុះបណ្តាល ពីគម្រោងបច្ចេកទេសការដាំដំណាំស្រូវ ដើម្បីឱ្យបានទទួល ផលប្រយោជន៍ដូចអ្នកជិតខាងរបស់គាត់ដែរ។ ចុងបញ្ចប់គាត់ទទូចអង្គការ និងភ្នាក់ងារនានា ជួយអភិវឌ្ឍន៍ភូមិរបស់គាត់។ |

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

( ពិន្ទុ : ១=ខ្សោយណាស់ ២=ខ្សោយ ៣=មិនខ្លាំងមិនខ្សោយ ៤=ខ្លាំង ៥=ខ្លាំងណាស់ )

| ល.រ | ធាតុ | ទំនាក់ទំនងតក្កភាព | បរិយាយច្បាស់លាស់ | សង្ខេបការវាយតម្លៃ |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៤ | ៥ | សកម្មភាពដែលបានលើកឡើងមានទំនាក់ទំនងជាមួយ និង លទ្ធផលដែលបានសរសេរនៅក្នុង ឯកសារ អនុកិច្ចសន្យា ។ ហើយក្នុងសកម្មភាព និមួយៗក៏បានបង្ហាញចំនួនវគ្គ ចំនួនអ្នកចូលរួម និង សរសេរអំពីទីតាំងច្បាស់លាស់ ដូចជា ភូមិ ឃុំ ស្រុក |
| ២ | លទ្ធផល | ៤ | ៥ | ក្នុងលទ្ធផលនិមួយៗបរិយាយច្បាស់លាស់ និងផ្សាភ្ជាប់គ្នាបានល្អ ។ មិនតែប៉ុណ្ណោះមានសូចនាករ ដែលអាចវាស់វែងបាន ។ |
| ៣ | - គោលបំណងបន្ទាន់ *(គោលបំណងស្ថិតក្នុងចំណុច "ខ" នៃផ្នែកទី ៣)* | ៤ | ៤ | គោលបំណងបន្ទាន់បរិយាយបានច្បាស់លាស់ ប៉ុន្តែមានទំហំធំ ដូច ជារួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ វាអាចភន្តច្រឡំ និង គោលដៅអភិវឌ្ឍន៍ ជាហេតុធ្វើអោយគោលបំណងបន្ទាន់នេះពិបាកនឹងសម្រេចបាន ។ |
| ៤ | ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា *(ចំណុច "គ" នៃផ្នែកទី ៣)* | | | ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យាសមហេតុផលនិងច្បាស់លាស់ត្រង់ប្រជាកសិករអាចយកចំណេះដឹងដែលបានទទួលការបណ្តុះបណ្តាលទៅអនុវត្ត តែត្រង់អនុវត្តបានក៏រិតណាណនោះ យើងមិនអាចវាយតម្លៃបានទេ គឺវាអាស្រ័យលើសមត្ថភាព និង លទ្ធភាពរបស់ប្រជាកសិករខ្លួនឯងជាអ្នកសម្រេច ។ |

| | | | | |
|---|---|---|---|---|
| ៥ | លទ្ធផលអភិវឌ្ឍន៏/ផលប៉ះពាល់រយៈពេលវែងៈ គោលដៅ និង គោលបំណងអភិវឌ្ឍន៏ ( *ចំណុច "ខ" នៃផ្នែកទី ៣*) | ៥ | ៥ | មិនអាចធ្វើការវាយតម្លៃបានទេ |

## ផ្នែក-ខៈ សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខ័ណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៏ និងការកត់ត្រាឯកសារៈ

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.អ.ជ.ខៈ** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | គួរតែមានកិច្ចសហការណ៏ពីជំនាញពាក់ពន្ធ័ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យការអនុវត្តន៏របស់ភ្នាក់ងារអនុវត្តន៏ | ការអនុវត្តន៏នៅមានក៏រិត ។ ការគាំទ្រផ្នែកហិរញ្ញវត្ថុមានបញ្ហាប្រឈមមួយចំនួន គួរមានការកែលំអរ ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា | ការកត់ត្រា និង ទុកដាក់ឯកសារ គួរពង្រឹងបន្ថែម |
| **ពីខាងភាគីអនុវត្តន៏កិច្ចសន្យាៈ** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | បុគ្គលិក ជំនាញ មានបទពិសោធន៏គ្រប់គ្រាន់ក្នុងការអនុវត្តន៏ការងារ ។ |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | ការអនុវត្តសកម្មភាព និង លទ្ធផលទាន់ពេលវេលាដូចដែលបានគ្រោងទុក ។ |
| ៦ | ការរាយការណ៏ការរីកចំរើន និង ការកត់ត្រាឯកសារ | ការអនុវត្តតាមទំលាប់ និង នីតិវិធីដែលបានប្រើ ។ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | បានអនុវត្តន៏ទៅតាមលក្ខណ័ក្នុងកិច្ចសន្យា ។ |
| **ទាំងខាង គ.អ.ជ.ខ និងភាគីអនុវត្តកិច្ចសន្យាៈ** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត"( ចំណុច-ង ផ្នែកទី៣ ) និងបញ្ហាប្រឈម | មានសកម្មភាព ២ នៅក្នុងអនុកិច្ចសន្យាមិនបានអនុវត្ត ដោយសារ ធ្វើពុំទាន់ ទាក់ទងនិងការគ្រប់គ្រងរបស់ភ្នាក់ងារអនុវត្តគម្រោង និង សកម្មភាពមួយចំនួន |

| | | |
|---|---|---|
| | | តូចខ្លះទៀត មិនអាចធ្វើទៅបានដោយសារវាជាសកម្មភាពតាមរដូវកាល ។ ហានិភ័យដែលទាក់ទង និងកត្តាធម្មជាតិនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងអនុកិច្ចសន្យា មិនបានបញ្ជាក់ពីការគ្រប់គ្រងរបស់ភ្នាក់ងារ អនុវត្តគម្រោងទេ ។ |
| ៩ | ការបញ្ជ្រាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | មានការលើកកម្ពស់ការងារយេនឌ័រ ។ ដោយជំរុញការចូលរួមរបស់ស្ត្រីក្នុងក ារអនុវត្តសកម្មភាពតាមរយៈការជ្រើសតាំង និង ការកំណត់សមាសភាពស្រី ៥០% ជាមូលដ្ឋានបង្អែក ដល់ការគ្រប់គ្រងនៅក្នុង របាយការណ៏បញ្ចប់អនុកិច្ចសន្យាក៏បានរំលេចពីការងារដែលទាក់ទងនិង បញ្ហាយេនឌ័រផងដែរ ។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ ( ចំណុច-ឆ ផ្នែកទី៣) | ជំរុញ និង លើកកម្ពស់ដល់ការដាំដុះ និង ប្រើប្រាស់ជីធម្មជាតិ និង បង្កើននូវប្រភពធនធានធម្មជាតិ (បន្លែសត្វពាហណៈជាប្រភពចំណី និង ជាកំលាំងអូសទាញ ) ដែលកន្លងមកមូលដ្ឋានមានការជួបប្រទះរឿងរាល់ឆ្នាំ (ស្រូវ-បន្លែ-ត្រី) មានការថយចុះនិងវិចរិលជាបន្តបន្ទាប់ ។ |
| ១១ | ការថែរក្សា (និរន្តភាព) (ចំណុច-ជ ផ្នែកទី៣) | កសិករបានបន្តការអនុវត្តសកម្មភាព និង បច្ចេកទេសខ្លះៗដែលគម្រោងលើកឡើង រហូតដល់ក្រុមការងារចុះទៅធ្វើ ការវាយតម្លៃ ។<br>ដូច្នេះវាជាផ្នែកខ្លះៗដែលគម្រោងយើងត្រូវបានសម្រេច។ |

## ២.៤. សេចក្តីសន្និដ្ឋាន

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យានេះត្រូវបានអនុវត្តឡើងដូចដែលបានគ្រោងទុក ។ ភាគីអនុវត្តអនុកិច្ចសន្យា មានសមត្ថភាព និងធនធាន គ្រប់គ្រាន់ដើម្បីអនុវត្តអនុកិច្ចសន្យា ។ សកម្មភាព និង លទ្ធផលភាគច្រើន ដែលបានគ្រោង |

| | |
|---|---|
| | ទុកត្រូវបានបញ្ចប់ស្របតាមផែនការការងារ លើកលែងមួយផ្នែកតូចអនុវត្តមិនទាន់ ។ |
| ២ | សកម្មភាពរបស់អនុកិច្ចសន្យា និង អត្ថប្រយោជន៍ដែលសហគមន៍ទទួលបានយ៉ាងពេញចិត្ត ចំពោះអ្នកទទួលផល និង អ្នកមិនទទួលផលផងដែរ នៅក្នុងឃុំដែលអនុវត្តសកម្មភាពបណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវដែលក្រុមការងារចុះធ្វើការវាយតម្លៃ ដោយចុះទៅសម្ភាសន៍ និងពិនិត្យនូវស្ថានភាពជាក់ស្តែងនៅតាមមូលដ្ឋាន ។ ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាត្រូវបានសម្រេចដូចដែលបានព្រាងទុក ។ ភស្តុតាងអំពីលទ្ធផល និង ផលប្រយោជន៍ដែលទទួលបាននេះ យើងបានសង្កេតឃើញក្រោយពីអនុកិច្ចសន្យាត្រូវបានបញ្ចប់ដូចជា :<br>- កសិករដែលទទួលពី វគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវបានយកចំណេះដឹង និង ជំនាញនេះដើម្បីបន្តការអនុវត្ត និងមួយចំនួនទៀតមានការតាំងចិត្ត ក្នុងការធ្វើស្រែបង្ហាញពីភាពជោគជ័យដល់អ្នកដែលមិនបានចូលរួមក្នុងវគ្គនេះ ។<br>- ទិន្នផលស្រូវមានការកើនឡើង ការហូបចុកគ្រប់គ្រាន់ និង កើនប្រាក់ចំណូលសម្រាប់គ្រួសារ ពួកគាត់អាចបញ្ជូនកូនទៅរៀន ។<br>- វគ្គបណ្តុះបណ្តាលនេះជាតម្រូវការ និង សំណូមពររបស់អ្នកភូមិជាច្រើនទៀត ដែលមានស្ថានភាពស្រដៀងគ្នា គឺប្រកបរបរធ្វើស្រែចំការ ហើយពួកគាត់មិនបានចូលរួមក្នុងវគ្គនេះផងដែរ ។<br>ដូច្នេះ អនុកច្ចសន្យានេះ ទទួលនិរន្តភាពក្នុងសកម្មភាពរបស់ខ្លួន កំរិតខ្ពស់ ។<br>វាជាផ្នែកតូចមួយក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍ នៅក្នុងអនុកិច្ចសន្យា ។ |
| ៣ | ការតាមដានត្រួតពិនិត្យ សកម្មភាព នៅក្នុងអនុកិច្ចសន្យាដោយភាគីអនុវត្តអនុកិច្ចសន្យាផ្ទាល់ នឹងធ្វើអោយធានាថា រាល់បញ្ហារបស់អ្នកពាក់ពន្ធ័ ដែលកើតមានឡើងត្រូវបានដោះស្រាយទាន់ពេល ។ |

**ចំណុចរៀនសូត្រ:**

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ការបរិយាយពី គោលបំណងបទ្ទាន់ មានលក្ខណៈច្បាស់លាស់មានសារៈសំខាន់សម្រាប់ការកត់ត្រាទុកនូវលទ្ធផលអនុកិច្ចសន្យា និងផលប្រយោជន៍ដែលមាន ដើម្បីការវាយតម្លៃលទ្ធផល ។ |
| ២ | និរន្តភាពរបស់លទ្ធផលនៅក្នុងអនុកិច្ចសន្យា មិនអាចសម្រេចបានក្នុងកំរិតខ្ពស់ទេ ប្រសិនបើមិនបានតាមដាន និងគាំទ្របន្តនៅពេលគំរោងត្រូវបានបញ្ចប់ ។ |

**អនុសាសន៍ :**

| ល.រ | អនុសាសន៍ |
|---|---|
| ១ | គោលបំណងបន្ទាន់នៃអនុកិច្ចសន្យា គួរត្រូវបានរៀបរៀង និង សរសេរក្នុងន័យទំនាក់ទំនងទៅនិង លទ្ធផល ហើយបរិយាយច្បាស់អំពីអ្វីដែលជាលទ្ធផលបន្ទាន់ និង អត្ថប្រយោជន៍ដែលរំពឹងទុក ។ |
| ២ | ការតាមដាន និងត្រួតពិនិត្យសំខាន់ណាស់ គួរអនុវត្តជាប្រចាំ ដើម្បីធានាថា រាល់បញ្ហារបស់អ្នកពាក់ពន្ធ័ ដែលកើតមានឡើងត្រូវបានដោះស្រាយទាន់ពេល និង មានទំនុកចិត្តពីសហគមន៍ ។ |
| ៣ | ការជ្រើសរើសក្រុមគោលដៅ ដើម្បីអោយមានប្រសិទ្ធភាព គួរជ្រើសរើសអ្នកដែលមានតម្រូវការ និងមានស្ថាន ភាពសមស្រប និង សកម្មភាពរបស់អនុកិច្ចសន្យា ។ |
| ៤ | ការគាំទ្របន្ថែមដល់ក្រុមគោដៅ គួរតែបន្តធ្វើទោះគម្រោងបានបញ្ចាប់ហើយក្តី ដើម្បីនិរន្តរភាពបច្ចេកទេស ជំនាញ និងទំនើបកម្ម ។ |

## ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

**ឯកសារទី១ : បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបាន ពិនិត្យ**

(សេចក្តីណែនាំ: ខាងក្រោមនេះ ជាបញ្ជីឯកសារដែលអ្នកវាយតម្លៃត្រូវពិនិត្យ។ សូមគូស (√) នៅក្នុងប្រអប់ទី(៣) ប្រសិនបើអ្នកបានពិនិត្យឯកសារនោះនៅក្នុងកំឡុងពេលវាយតម្លៃ។ សូមបន្ថែមឈ្មោះឯកសារដែលអ្នកបានពិនិត្យ ប៉ុន្តែមិនមាននៅក្នុងបញ្ជីឈ្មោះនេះ។ សូមដកបង្គោលទី(៣) ហើយនិងឈ្មោះឯកសារដែលអ្នកមិនបានពិនិត្យ ចេញ ហើយភ្ជាប់តារាងនេះទៅក្នុងរបាយការណ៍វាយតម្លៃ)

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) | មាន (៣) |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និង ឯកសារវិសោធនកម្ម (ប្រសិនមាន) | √ |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ | |
| ៣ | របាយការណ៍ត្រួតពិនិត្យគម្រោង | |
| ៤ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | √ |
| ៥ | លិខិតឆ្លើយឆ្លងរវាងភ្នាក់ងារអនុវត្តន៍ និងគណៈកម្មាធិការប្រត្តិបត្តិគ.អ.ជ.ខ | |
| ៦ | បញ្ជីវត្ថុបណ្តុះបណ្តាលដែលមានក្នុងអនុកិច្ចសន្យា | √ |
| ៧ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា | √ |
| ៨ | ឯកសារដ៏ទៃទៀតរួមមាន រូបថតនៃគម្រោង (អនុកិច្ចសន្យា) ដែលទុកនៅគណៈកម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ និងនៅភ្នាក់ងារអនុវត្តន៍ ដែលមិនបានរៀបរាប់ខាងលើ | |
| ៩ | ផ្សេងទៀត | |

## ឯកសារដែលត្រូវភ្ជាប់ទី២ : ឯកសារអនុកិច្ចសន្យា លេខ 01/AGR/0901-00(GOV)ខេត្ត បន្ទាយមានជ័យ

### បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាសន៍/ជួបពិភាក្សា

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៍ប្រើសម្រាប់ប្រមូលទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | ១៤ កញ្ញា | លោក យស វណ្ណី មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ មន្ទីរកសិកម្មខេត្ត | មន្ទីរកសិកម្ម | សម្ភាសន៍ស៊ីជម្រៅ |
| ២ | ១៤ កញ្ញា | អ្នកស្រី សៀវ សិនេហ៍ នាយិកា ទីប្រឹក្សា នៃ PSDD | PSDD | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | ១៥ កញ្ញា | ក្រុមអ្នកទទួលផល (សូមសរសេរឈ្មោះខាងក្រោម) | ភូមិ ព្រះពន្លា | សម្ភាសជាក្រុម |
| ៤ | ១៥ កញ្ញា | លោក យ៉ែម វិចិត្រអ្នកទទួលផលផ្ទាល់ | ភូមិ ព្រះពន្លា | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៥ | ១៥ កញ្ញា | លោក ឆាត់ វុទ្ធី អ្នកមិនទទួលផល | ភូមិ ព្រះពន្លា | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៦ | | មន្ត្រីបង្គោលយេនឌ័រ | | |
| ៧ | | មន្ត្រីបង្គោល គ្រប់គ្រងធនធានធម្មជាតិ | | |
| | | | | |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | **02/AGR/0901-001** |
| ចំណងជើង : | កម្មវិធីអភិវឌ្ឍន៍កសិកម្មចំរុះ |
| ភ្នាក់ងារអនុវត្តន៏ : | មន្ទីរកសិកម្មខេត្ត |
| រយៈពេល (ចាប់ផ្តើម និងបញ្ចប់) | 01/01/2009 ដល់ 31/12/2009 |
| រាជធានី ខេត្ត | បាត់ដំបង |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរកសិកម្មខេត្ត |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ នៃ គ.អ.ជ.ខ | 13,000US$ |
| ការរួមចំណែករបស់រាជធានី ខេត្ត | 0 |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៏ | 13,560US$ |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | 26,560US$ |

## ក្រុមវាយតម្លៃ

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ |
|---|---|
| លោក អ៊ុំ កុសល | ប្រធានមន្ទីរផែនការខេត្តបាត់ដំបង និងជាគ្រូបង្គោល |
| លោក ជិម រឿងវិទ្យ៍ | អនុប្រធានមន្ទីរផែនការខេត្តបាត់ដំបងនិងជាគ្រូបង្គោល |
| លោកស្រី ឈុន ធារិន | ប្រធានការិយាល័យមន្ទីរកិច្ចការនារីខេត្តនិងជាគ្រូបង្គោល |
| ៤-លោក រិទ្ធី សុពិសិទ្ធី | មន្រ្តីតាមដាន-វាយតំលៃ គ.ប្រ-គ.អ.ជ.ខ |

## របាយការណ៏ស្តីពីវាយតម្លៃ រៀបចំដោយ :

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ និងតួនាទីក្នុងការវាយតម្លៃ |
|---|---|
| ១-លោក អ៊ុំ កុសល | ប្រធានមន្ទីរផែនការខេត្តបាត់ដំបង និងជាគ្រូបង្គោល |
| ២-លោក ជិម រឿងវិទ្យ៍ | អនុប្រធានមន្ទីរផែនការខេត្តបាត់ដំបងនិងជាគ្រូបង្គោល |
| ៣-លោកស្រី ឈុន ធារិន | ប្រធានការិយាល័យមន្ទីរកិច្ចការនារីខេត្តនិងជាគ្រូបង្គោល |
| ៤-លោក រិទ្ធី សុពិសិទ្ធី | មន្រ្តីតាមដាន-វាយតំលៃ គ.ប្រ-គ.អ.ជ.ខ |

ខេត្តបាត់ដំបង

តុលា ឆ្នាំ២០១០

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៣ |
| | របាយការណ៍សង្ខេប | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៧** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៧ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៧ |
| ១.៣ | គោលបំនង និង ទំហំនៃការវាយតម្លៃ | ៧ |
| ១.៤ | សំណួរវាយតម្លៃ | ៨ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ៨ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ៩ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១០** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១) | ១០ |
| | - លទ្ធផលទី១ | ១០ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម (សំណួរវាយតម្លៃទី៣) | ១២ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤) | ១៨ |
| **២.៤** | **សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី៥)** | **២២** |
| | **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍** | **២៥** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ២៥ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍ /ពិភាក្សា | ២៦ |


**ករណីសិក្សា**


| | | |
|---|---|---|
| ទី១- | " ជីវភាពគ្រួសាររបស់ខ្ញុំមានការប្រែប្រួលប្រសើរជាងមុន " **លោក ហូ ភឿន** អ្នកទទួលផល | ១៦ |
| ទី២- | " ទិន្នផលឪឡឹកបានកើនឡើង" **លោក ម៉ា សំអឿន** អ្នកក្រៅគម្រោង។ | ១៧ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **ប.វ.ស** | ប្រពលវប្បកម្មដំណាំស្រូវ |
| **CIP** | កម្មវិធីវិនិយោគឃុំ/សង្កាត់ |
| **CDP** | ផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ |

# របាយការណ៍សង្ខេប

## គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ:

ការវាយតំលៃនេះមានគោលបំណង ពិនិត្យមើលពីលទ្ធផលសំរេចបានជាក់ស្តែង ដោយប្រៀបធៀបទៅនឹងផែនការ ដែលបានគ្រោងរបស់អនុកិច្ចសន្យា ដោយធ្វើការឆ្លុះបញ្ចាំងពីប្រសិទ្ធិភាពនៃលទ្ធផលអនុកិច្ចសន្យា (Outcome) ប្រៀបធៀបជាមួយទិសដៅបន្ទាន់របស់អនុកិច្ចសន្យា តាមរយៈការពិនិត្យដែលមានស្រាប់ ដូចជាឯកសារអនុកិច្ចសន្យា របាយការណ៍ប្រចាំខែ កំនត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធដែលមាននៅក្នុងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៏ និងធ្វើការសំភាសន៏ជាលក្ខណៈបុគ្គល និងជាក្រុមជាមួយ អ្នករៀបចំនិងអនុវត្តអនុកិច្ច សន្យា អ្នកពាក់ព័ន្ធ អ្នកក្រៅគំរោង ព្រមទាំងចុះពិនិត្យ ដល់តំបន់អនុវត្តអនុកិច្ចសន្យាផងដែរ ។

## សង្ខេបនូវលទ្ធផលរកឃើញសំខាន់ៗពីការវាយតម្លៃ

### លទ្ធផលសំរេចបាន

- ❖ ផ្តល់វគ្គបណ្តុះបណ្តាលកសិករគំរូធ្វើបង្ហាញពីការធ្វើផលិតកម្មស្រូវតាមរបៀប ប.វ.ស ដោយប្រើជីកំប៉ុស្តិ៍ មានចំនួន២៤វគ្គ ហើយវគ្គនិមួយៗមានចំនួន ២ថ្ងៃ (លើផែនការ៣ថ្ងៃ)និងអ្នកចូលរួមចំនួន ២៤នាក់ ។
- ❖ ធ្វើបង្ហាញផលិតកម្មស្រូវតាមរបៀប ប.វ.ស ចំនួន ២៤កន្លែង ចំនួន ២លើក មានអ្នកចូលរួមចំនួន ៥០៦នាក់ (ផែនការ៤៨០នក់) ។
- ❖ វគ្គបណ្តុះបណ្តាលពីបច្ចេកទេសនៃការប្រើប្រាស់ជីកំប៉ុស្តិ៍ មាន៥វគ្គ ហើយវគ្គនិមួយៗមានចំនួន ២ថ្ងៃ មានអ្នកចូលរួមចំនួន ២១៩នាក់ (ផែនការ១០០នាក់) ។
- ❖ វគ្គបណ្តុះបណ្តាលពីសុវត្ថិភាពនៃការប្រើប្រាស់ថ្នាំពុលគីមីកសិកម្ម ៥វគ្គ វគ្គនិមួយៗមានចំនួន ២ថ្ងៃ មានអ្នកចូលរួមចំនួន ២០៩នាក់ (ផែនការ១០០នាក់) ។

**ចំណុចខ្លាំង:** សកម្មភាពនៃអនុកិច្ចសន្យាដែលបានគ្រោងទុក ត្រូវបានអនុវត្តចប់សព្វគ្រប់និងមានប្រជាជនចូលរួមច្រើនលើសពីចំនួនដែលបានគ្រោងទុក ។ បច្ចេកទេសកសិកម្មដែលអនុកិច្ចសន្យាបានផ្តល់ជូនកសិករក្រោយពេលអនុវត្តជាក់ស្តែង ដូចជាការស្ទូងស្រូវតាមរបៀប ប.វ.ស ជាលទ្ធផលស្រូវ បែកគុម្ពល្អ

អាចផ្តល់ផលបានពី ២.៥តោន ទៅ ៤តោនក្នុង១ហិកតា ដីស្រែធូរមានជីជាតិ ។ ជាងនេះទៀត ទិន្នផលឪឡឹកកសិករដែលប្រើប្រាស់ជីធម្មជាតិអាចរកចំណូលបានពី២០០០ ទៅ ២៥០០ ដុល្លារ ក្នុងមួយរដូវ ។

**ចំណុចខ្សោយ:** បច្ចេកទេសដំណាំស្រូវមួយដើម ប.វ.ស កសិករភាគច្រើនមិនទាន់ទទួលយកបាននៅឡើយទេ ដោយសារការចំណាយខ្ពស់ ខ្វះប្រភពទឹកនិងប្រព័ន្ធធារាសាស្ត្រ និងខ្វះវត្ថុធាតុដើមសំរាប់ធ្វើជីកំប៉ុស្តិ៍ ។

## សេចក្តីសន្និដ្ឋានសំខាន់ៗ:

ការអនុវត្តអនុកិច្ចសន្យាបានប្រព្រឹត្តទៅមានលក្ខណៈល្អប្រសើរ ដោយមានការគាំទ្រថវិកា និងបច្ចេកទេសដល់កសិករគោលដៅ ដែលធ្វើឱ្យកសិករក្រុមទទួលផលបានចំណេះដឹងបច្ចេកទេសក្នុងការថែរក្សាគុណភាពដីដាំដុះរបស់គាត់ជាក់ស្តែង យើងសង្កេតឃើញមានការចូលរួមយ៉ាងច្រើនពីកសិករ ក្នុងវគ្គបណ្តុះបណ្តាលនិមួយៗ។ ជាការពិត ប្រសិនបើកសិករ យកបច្ចេកទេសថ្មីនេះទៅអនុវត្តជាប្រចាំនោះ វាពិតជាអាចជួយឱ្យដីស្រែមានគុណភាពប្រសើរ ជាងមុន ដែលអាចធានាដល់ការប្រើប្រាស់ដីប្រកបដោយនិរន្តរភាព។ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយបច្ចេកទេស ដែលបានផ្តល់ជូនកសិករ តម្រូវឱ្យមានការចំណាយខ្ពស់ ប្រភពទឹកគ្រប់គ្រាន់ ព្រមទាំងចំណាយពេលវេលាច្រើនដែល ធ្វើឱ្យកសិករដែលមានផ្ទៃដីបង្កបង្កើនផលច្រើន មិនទាន់អាចទទួលយកទៅអនុវត្តទាំងស្រុងនៅឡើយទេ ។

## អនុសាសន៍

១. ការជ្រើសរើសក្រុមគោលដៅ គួរជ្រើសរើសតែគ្រួសារណាដែលមានលក្ខណៈវិនិច្ឆ័យសមស្របទៅនិងគោលបំណងគំរោង ឬលទ្ធផល សកម្មភាពរបស់គំរោង ។

២. ការចុះតាមដានត្រួតពិនិត្យ ត្រូវធ្វើជាប្រចាំដើម្បីប្រសិទ្ធិភាពនៃការអនុវត្តន៍គំរោង ។

៣. ការប្រើប្រាស់តារាងតក្កភាព ផែនការសកម្មភាព និងវាស់កំណត់ត្រាភាពរីកចំរើន រួមទាំងបញ្ហាប្រឈមនានា គឺជាមធ្យោបាយល្អបំផុត សំរាប់ឆ្លុះបញ្ចាំងលើប្រសិទ្ធិភាពនិងភាពសក្តិសិទ្ធនៃការអនុវត្តន៍គំរោង ។

៤. ក្រុមគោលដៅគួរមានការចុះធ្វើទស្សនៈកិច្ចសិក្សា នៅតំបន់ដ៏ទៃដើម្បីរៀនសូត្រពីបទពិសោធន៍និងបច្ចេកទេសផ្សេងៗ។

៥. គួរមានវិធីសាស្ត្រ និងការលើកទឹកចិត្តដល់ប្រជាកសិករក្នុងការអនុវត្តបច្ចេកទេសថ្មីនេះ ក្រោយពីគាត់បានទទួលការបណ្តុះបណ្តាល ដូចជាការបង្កើតកម្មវិធីប្រលងប្រណាំងកសិករគំរូជាដើម ។

៦. ការបណ្តុះបណ្តាលបច្ចេកទេសនេះ គួរតែចាប់ផ្តើមអនុវត្តពីភូមិ ឬឃុំណាដែលមានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ ដែលធ្វើអោយកសិករអាចមានលទ្ធភាពអនុវត្តបាននូវបច្ចេកទេសពេញលេញ ហើយគួរជ្រើសរើសតែគ្រួសារកសិករណាដែលមានដីតិចតួចមកចូលរួម សកម្មភាព ប.វ.ស ព្រោះគាត់មានពេលវេលាគ្រប់គ្រាន់ក្នុងការដកស្ទូងនិងថែទាំ ។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្ដីផ្ដើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្ដល់ថវិកាតាមរយៈ គ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យ ដើម្បអនុវត្តសកម្មភាព និងគម្រោង ដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈជាប្រព័ន្ធ មិនបានអនុវត្តទេកាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើន។ ប៉ុន្តែការវាយតំលៃនេះ គឺជាការសាកល្បងអនុវត្ត វាយតំលៃរបស់ក្រុមគ្រូបង្គោលប្រចាំខេត្តបាត់ដំបង ក្រោយពីទទួលបានការបណ្ដុះបណ្ដាលនៅខេត្តកំពង់ចាមកន្លងមក ដោយមានការថវិកានិងបច្ចេកទេសពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃ លេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យា គ.ប្រ នៃ គ.អ.ជ.ខ។ ការអនុវត្តការវាយតម្លៃ អនុកិច្ចសន្យា បានរៀបចំរួមគ្នាជាមួយភ្នាក់ងារអនុវត្តន៍គឺមន្ទីរកសិកម្មខេត្ត ដែលបានអនុវត្តអនុកិច្ចសន្យា ស្តីពី **កម្មវិធីអភិវឌ្ឍន៍កសិកម្មចំរុះ** លេខអនុកិច្ចសន្យា : **02/AGR/0901-001**។ លទ្ធផល ដែលបានរកឃើញ និងការសន្និដ្ឋាន នៃការវាយតម្លៃត្រូវបានកត់ត្រា ហើយនឹងបង្ហាញតាមរយៈរបាយការណ៍ វាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

បានធ្វើអោយប្រសើរឡើងនូវផលិតផលកសិកម្មរបស់គ្រួសារកសិករចំនួន ១,៣៥៩គ្រួសារ នៅក្នុងស្រុកគោលដៅចំនួន៣ ១៤ឃុំ និង៣៣ភូមិ ក្នុងខេត្តបាត់ដំបង តាមរយៈការផ្ដល់បច្ចេកទេសកសិកម្ម ទុនដែលពិបាករក និង សេវាកម្មបណ្ដុះបណ្ដាល ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

១- ដើម្បីពិនិត្យមើលពីលទ្ធផលសំរេចបានជាក់ស្តែង ដោយប្រៀបធៀបទៅនឹងផែនការដែលបានគ្រោងរបស់អនុកិច្ចសន្យា ។

២- ឆ្លុះបញ្ចាំងពីប្រសិទ្ធិភាពនៃលទ្ធផលអនុកិច្ចសន្យា (Outcome) ប្រៀបធៀបជាមួយទិសដៅបន្ទាន់របស់អនុកិច្ចសន្យា ។

៣- ឆ្លុះបញ្ចាំងពីបទពិសោធន៍ (ភាពខ្លាំង ភាពខ្សោយ និង ឧបសគ្គ) នៃការអនុវត្តអនុកិច្ចសន្យា ដើម្បីបង្កើនចំណេះដឹងលើការវាយតំលៃអនុកិច្ចសន្យារបស់ក្រុមគ្រូបង្គោលប្រចាំខេត្ត ។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ? តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើៈ

១) ការពិនិត្យដែលមានស្រាប់ៈ ឯកសារអនុកិច្ចសន្យា របាយការណ៍ប្រចាំខែ កំនត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែល ពាក់ព័ន្ធដែលមាន នៅក្នុងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៏។ *(សូមមើលឯកសារភ្ជាប់ជូនទី១)*

២) ធ្វើការសំភាសន៏ជាលក្ខណៈបុគ្គល និងជាក្រុមជាមួយ : អ្នករៀបចំនិងអនុវត្តអនុកិច្ចសន្យាចំនួន ១នាក់ និងអ្នកទទួលផលផ្ទាល់ចំនួន ៤៤នាក់ មិនផ្ទាល់ ៣នាក់ និងអ្នកពាក់ព័ន្ធចំនួន ២នាក់។

៣) ចុះពិនិត្យដល់តំបន់អនុវត្តអនុកិច្ចសន្យា *(សូមមើលឯកសារភ្ជាប់ជូនទី២)*

៤) សំភាសន៏ក្រុមគោលដៅមួយគ្រួសារដើម្បីធ្វើជាករណីសិក្សា ។

៥) <u>វិភាគទិន្នន័យ និងបកស្រាយៈ</u> ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់ ។

៦) <u>ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៏</u> ដោយភ្នាក់ងារអនុវត្តន៏ និងអ្នកពាក់ព័ន្ធតាមរយៈព័ត៌មានត្រឡប់ដែលទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើង (ដាក់កាលបរិច្ឆេទនៃការធ្វើបទបង្ហាញនៅទីនេះ) ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះ គឺជាការវាយតំលៃផ្ទៃក្នុងដោយមានការចូលរួម ដែលធ្វើឡើងដោយក្រុមគ្រូបង្គោលប្រចាំខេត្ត សហការជាមួយផ្នែកតាមដានវាយតំលៃនៃគ.ប្រ-គ.អ.ជ.ខ។ ទោះជាយ៉ាងណាក៏ដោយក្រុមវាយតំលៃយើងបានប្រឹង ប្រែង និងយកចិត្តទុកដាក់ ដើម្បីធានាឱ្យដំណើរការវាយតម្លៃមានសុក្រិត្យ និងតម្លាភាព ។

២) ដោយសារចំណេះដឹងលើបច្ចេកទេសរបស់ក្រុមគ្រូបង្គោលនៅមានកម្រិត និងជាការសាកល្បងនៃការវាយតំលៃនោះ ក្រុមវាយតំលៃយើងបានជ្រើសរើសតែលទ្ធផលមួយនៃអនុកិច្ចរបស់មន្ទីរកសិកម្មឆ្នាំ២០០៩ មកធ្វើការវាយតំលៃប៉ុណ្ណោះ (លទ្ធផលទី១:កម្មវិធីបង្កើនគុណភាពដី) ។

៣) បញ្ហាប្រឈម ដោយសារតែក្រុមវាយតំលៃមានការងារស្មុលរវៀង១ខ្លួន ធ្វើអោយក្រុមវាយតំលៃពិបាកនៅក្នុងការជួបជុំគ្នា ឯកសារនិងឧបករណ៍សំរាប់ការវាយតំលៃច្រើនពិបាកយល់នៅពេលចាប់ផ្តើមដំបូង ។

# ២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល

**លទ្ធផលទី១:** កម្មវិធីបង្កើនគុណភាពដី

**ផ្នែក_ក : លទ្ធផលសម្រេចបានជាក់ស្តែង ធៀបនឹងផែនការ:**

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | ▪ វគ្គបណ្តុះបណ្តាលកសិករគំរូធ្វើបង្ហាញពីការធ្វើផលិកម្មស្រូវតាមរបៀប ប.វ.ស ដោយប្រើជីកំប៉ុស្តិ៍ ២៤វគ្គ<br>▪ វគ្គនិមួយៗមានចំនួន ៣ថ្ងៃ<br>▪ អ្នកចូលរួមចំនួន ២៤នាក់<br>▪ ធ្វើបង្ហាញផលិតកម្មស្រូវតាមរបៀប ប.វ.ស ចំនួន ២៤កន្លែង ចំនួន ២លើក មានអ្នកចូលរួមចំនួន ៤៨០នាក់ | ▪ វគ្គបណ្តុះបណ្តាលកសិករគំរូធ្វើបង្ហាញពីការធ្វើផលិកម្មស្រូវតាមរបៀប ប.វ.ស ដោយប្រើជីកំប៉ុស្តិ៍ ២៤វគ្គ<br>▪ វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>▪ អ្នកចូលរួមចំនួន ២៤នាក់<br>▪ ធ្វើបង្ហាញផលិតកម្មស្រូវតាមរបៀប ប.វ.ស ចំនួន ២៤កន្លែង ចំនួន ២លើក មានអ្នកចូលរួមចំនួន ៥០៦នាក់ |
| ១.២ | ▪ វគ្គបណ្តុះបណ្តាលពីបច្ចេកទេសនៃការប្រើប្រាស់ជីកំប៉ុស្តិ៍ ៥វគ្គ<br>▪ វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>▪ មានអ្នកចូលរួមចំនួន ១០០នាក់ | ▪ វគ្គបណ្តុះបណ្តាលពីបច្ចេកទេសនៃការប្រើប្រាស់ជីកំប៉ុស្តិ៍ ៥វគ្គ<br>▪ វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>▪ មានអ្នកចូលរួមចំនួន ២១៩នាក់ |
| ១.៣ | ▪ វគ្គបណ្តុះបណ្តាលពីសុវត្ថិភាពនៃការប្រើប្រាស់ថ្នាំពុលកសិកម្ម ៥វគ្គ<br>▪ វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>▪ មានអ្នកចូលរួមចំនួន ១០០នាក់ | ▪ វគ្គបណ្តុះបណ្តាលពីសុវត្ថិភាពនៃការប្រើប្រាស់ថ្នាំពុលកសិកម្ម ៥វគ្គ<br>▪ វគ្គនិមួយៗមានចំនួន ២ថ្ងៃ<br>▪ មានអ្នកចូលរួមចំនួន ២០៩នាក់ |

## ផ្នែក_ខ : ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល ធៀបនឹងគោលបំនងបន្ទាន់

ការអនុវត្តអនុកិច្ចសន្យាបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ដោយមានការគាំទ្រចូលរួមទាំងថវិកា និងបច្ចេកទេស ដែលធ្វើឱ្យកសិករក្រុមគោលដៅ ទទួលបានការបណ្តុះបណ្តាលនេះ ពិសេសជាងនេះទៀតសកម្មភាពនេះពិតជាឆ្លើយតបទៅនឹងគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា។ ជាក់ស្តែងយើងសង្កេតឃើញមានការចូលរួម យ៉ាងច្រើនពីកសិករ ក្នុងវគ្គបណ្តុះបណ្តាល នីមួយៗ។ នេះសបញ្ជាក់ឱ្យឃើញថាប្រជាកសិករពិតជាមានការចាប់អារម្មណ៍ និងចូលរួមយ៉ាងសកម្ម លើវគ្គបណ្តុះបណ្តាលទាំងនេះដោយហេតុថាការទទួលបាននូវចំណេះដឹង និងបច្ចេកទេសនានាក្នុងវគ្គពិតជាឆ្លើយតបទៅនិងតម្រូវការប្រចាំថ្ងៃក្នុងការប្រកបរបរកសិកម្ម។ ជាការពិតប្រសិនបើកសិករយកបច្ចេកទេសថ្មីនេះទៅអនុវត្តជាប្រចាំនោះ វាពិតជា អាចជួយឱ្យដីស្រែមានគុណភាពប្រសើរជាងមុន ដែលអាចធានាដល់ការប្រើប្រាស់ដី ប្រកបដោយនិរន្តរភាព។ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយ សម្រាប់ប្រជាកសិករដែលមានដីស្រែច្រើន ហិកតា បច្ចេកទេសនេះនៅមិនទាន់ជាតម្រូវការចាំបាច់របស់ពួកគេនៅឡើយទេ ប្រសិនបើគេគិតទៅលើថ្លៃដើមនៃផលិតកម្ម បើកសិករប្រើប្រាស់បច្ចេកទេស ប.វ.ស ទៅលើដីស្រែ ៣ហិកតា នោះកសិករនឹងមិនអាចធានាបានទៅលើថ្លៃឈ្នួលសម្រាប់ដកស្ទូង ដែលមានតម្លៃលើសការស្ទូងធម្មតា ៣ដង ម្យ៉ាងទៀតការធ្វើបែបនេះកសិករត្រូវចំណាយពេលវេលាច្រើន ថ្ងៃរហូតដល់ស្ទូងរួច។ ក្រៅពីនេះកសិករនៅប្រឈមនឹងបញ្ហា សំខាន់មួយទៀតគឺបញ្ហាទឹក ជាក់ស្តែងប្រព័ន្ធធារាសាស្រ្តស្ទើរគ្រប់តំបន់នៃខេត្តបាត់ដំបងបច្ចុប្បន្ន មិនមានលទ្ធភាពអាច ស្រោចស្រពគ្រប់គ្រាន់ទាំងរដូវប្រាំង និងវស្សាបានទេ ដែលជាឧបសគ្គដ៏ចំបងដល់ការគ្រប់គ្រងទឹកក្នុង ការបញ្ចេញបញ្ចូលទឹកតាមតម្រូវការ។ កត្តានេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការ ប្រើប្រាស់បច្ចេកទេស ប.វ.ស នេះ។ ជាងនេះទៀតការប្រើប្រាស់ជីកំប៉ុស្តិ៍ពិតជាជួយកែប្រែគុណភាពដី ស្រែរបស់ពួកគាត់ ប៉ុន្តែការប្រើប្រាស់ជីប្រភេទនេះតែមួយមុខនោះមិនមែន ជាមធ្យោបាយល្អក្នុងការលើកស្ទួយជីវភាពរបស់កសិករនោះទេ ពីព្រោះទិន្នផលទាបបើធៀបនឹងការចំណាយខ្ពស់ របស់គាត់។ ដូចនេះការបណ្តុះបណ្តាលពីបច្ចេកទេសក្នុងការប្រើប្រាស់ ជីគីមីជាមួយជីធម្មជាតិគឺជាមធ្យោបាយប្រសើរបំផុត។ បច្ចេកទេសនេះប្រហែលជាអាចជួយឱ្យទិន្នផលស្រូវរបស់ គាត់កើនឡើងព្រមទាំងអាចថែរក្សាគុណភាពដីបានថែម ទៀតផង ប្រសិនបើគាត់ប្រើប្រាស់ទៅតាមបច្ចេកទេស។ ជាក់ស្តែងបើយើងពិនិត្យមើលកសិកម្មនៅបណ្តាលប្រទេសជឿនលឿនដ៏ទៃទៀត ដូចជា ប្រទេសជប៉ុន វៀតណាម និងថៃជាដើម ជាឧទាហរណ៍មួយក្នុងការពិចារណា។ ដូច្នេះលទ្ធផលនេះអាចឆ្លើយតបទៅនឹងផលប្រយោជន៍រយៈពេលវែងនៅពេលខាងមុខ តែភ្លាមៗនេះវាមិនមែនជាតម្រូវការចាំបាច់របស់ កសិករនោះទេ។

## ២.២.ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផលនិងអត្ថប្រយោជន៍បឋម

### ផ្នែក_ក: ការសម្រេចបាននូវស្ថានភាពរំពឹងទុកនៅពេលបញ្ចប់កិច្ចសន្យា

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់កិច្ចសន្យា | ស្ថានភាពជាក់ស្តែង |
|---|---|
| ▪ កសិករចំនួន ២៤នាក់ មកពី ២៤ឃុំ ក្នុង ៣ស្រុកគោលដៅបានទទួលចំណេះដឹងអំពីបច្ចេកទេសផលិត កម្មដំណាំស្រូវជាមួយជីកំប៉ុស្តិ៍ និងធ្វើបង្ហាញ ចំនួន ៤៨បង្ហាញ ដែលមានកសិករចូលរួមចំនួន ៤៨០នាក់ | ▪ កសិករចំនួន ២៤នាក់ ស្រី២នាក់ បានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសផលិតកម្មដំណាំស្រូវជាមួយជីកំប៉ុស្តិ៍ និងបានធ្វើបង្ហាញពីដំណាំស្រូវចំនួន ២៤បង្ហាញ ២លើក ដែលមានកសិករចូលរួមចំនួន ៥០៦នាក់ ក្នុងនោះស្ត្រី ១៨៦នាក់<br>▪ អ្នកចូលរួមភាគច្រើនក្នុងការពិភាក្សាបានរាយការណ៍ថាពួកគាត់ពេញចិត្តនឹងវគ្គបណ្តុះបណ្តាល និងការធ្វើបង្ហាញនេះ។ ពិសេសគាត់ថែមទាំងបញ្ជាក់ទៀតថាការបណ្តុះបណ្តាលនេះបានធ្វើឱ្យគាត់ចេះធ្វើស្រែមួយបែបទៀតដែលចំណាយពូជតិច ហើយទទួលផលច្រើន។ ប៉ុន្តែបច្ចេកទេសនេះមិនទាន់ត្រូវបានយកមកអនុវត្តឱ្យបាន ១០០ភាគរយនៅឡើយទេ នេះជាការបញ្ជាក់ពីអ្នកក្រុមពិភាក្សា ពីព្រោះបច្ចេកទេសនេះត្រូវប្រឈមមុខយ៉ាងខ្លាំង ចំពោះបញ្ហាបញ្ចេញបញ្ចូលទឹក មួយវិញទៀតត្រូវចំណាយថវិកាច្រើន និងពេលវេលាយូរក្នុងការដកស្ទូង បើសិនគាត់មានដីស្រែលើសពី ៤រ៉ៃឡើងទៅ។ កត្តានេះបានជំរុញឱ្យកសិករមិនអាចយកបច្ចេកទេសថ្មីនេះ ទៅអនុវត្តឱ្យបានពេញលេញទេ។ ទោះជាយ៉ាងណាក្តីប្រជាកសិករមួយចំនួនដែលមានដីស្រែក្បែរភូមិ ពួកគាត់បានបន្តការអនុវត្ត ប.វ.ស នេះក្នុងផ្ទៃដីពី១ រ៉ៃទៅ ៤រ៉ៃ ព្រោះគាត់អាចឆ្លៀតពេលនិងប្រមូលកម្លាំងស្ទូងទាន់ពេលងាយស្រួលដាក់ជីកំប៉ុស្តិនិងថែទាំទឹក ។ |

| | |
|---|---|
| ▪ កសិករចំនួន ១00នាក់ ៥ឃុំ ក្នុងស្រុកគោលដៅ ចំនួន ៣ស្រុក បានទទួលចំណេះដឹងអំពីបច្ចេកទេស នៃការប្រើប្រាស់ជីកំប៉ុស្តិ៍ ចំនួន ៥វគ្គ | ▪ កសិករចំនួន ២១៩នាក់ ស្ត្រី ១៣៦នាក់ បានទទួលចំណេះដឹងអំពីបច្ចេកទេស នៃការប្រើប្រាស់ជីកំប៉ុស្តិ៍ ចំនួន ៥វគ្គ<br>▪ តាមរយៈក្រុមពិភាក្សាបានឱ្យដឹងថា គាត់ពេញចិត្តនឹងវគ្គបណ្តុះបណ្តាលនេះណាស់ ព្រោះវាបានជួយឱ្យគាត់ចេះផលិតជីកំប៉ុស្តិ៍ដែលមានគុណភាព ដែលធ្វើឱ្យដំណាំរបស់គាត់លូតលាស់បានល្អ។ ជាងនេះទៀត អ្នកចូលរួមបញ្ជាក់ថា គាត់អាចរកចំណូលបានពី ២000 ទៅ ២៥00ដុល្លាអាមេរិក ក្នុងមួយហិកតា ពីដំណាំឪឡឹកប្រើជីធម្មជាតិនេះ។<br>▪ ក្រោយពីការបណ្តុះបណ្តាល យើងសង្កេតឃើញកសិករជាង ៨0%ដែលបានរៀនវគ្គនេះបានធ្វើជីធម្មជាតិនេះនៅតាមផ្ទះរៀងៗខ្លួន ហើយគាត់បានប្រើជីនេះទៅលើដំណាំក្រូច ឪឡឹក ពិសេសស្រូវ ដែលធ្វើដំណាំរបស់គាត់លូតលាស់បានល្អហើយធន់នឹងជម្ងឺថែមទៀត។ តាមរយៈការរៀនតគ្នា បច្ចុប្បន្នអ្នកភូមិជាង ៦0% មានរង ជីកំប៉ុស្តិ៍គ្រប់ៗ គ្នា។<br>▪ ការយល់ដឹងរបស់ពួកគាត់មានការប្រសើរឡើងបន្ទាប់ពីការបណ្តុះបណ្តានេះ ពួកគាត់មានចំណេះដឹង និង ជំនាញក្នុងការធ្វើជីធម្មជាតិប្រកបដោយគុណភាពខ្ពស់ |
| ▪ កសិករចំនួន ១00នាក់ ៥ឃុំ ក្នុងស្រុកគោលដៅ ចំនួន ៣ស្រុក បានទទួលចំណេះដឹងអំពីសុវត្ថិភាព ក្នុង នៃការប្រើប្រាស់ថ្នាំពុលគីមីកសិកម្មចំនួន ៥វគ្គ | ▪ កសិករចំនួន ២១៤នាក់ ស្ត្រី ១0៨នាក់ បានទទួលចំណេះដឹងអំពីសុវត្ថភាពនៃការប្រើប្រាស់ថ្នាំពុលគីមីកសិកម្មចំនួន ៥វគ្គ<br>▪ តាមរយៈក្រុមពិភាក្សា អ្នកចូលរួមភាគច្រើនពេញចិត្តនឹងវគ្គណ្តុះបណ្តាលនេះ។ សហគមន៍របស់ពួកគាត់កំពុងជួបនឹងបញ្ហា ក្នុងការប្រើប្រាស់ថ្នាំពុលនេះ ជាក់ស្តែងសុខភាពរបស់អ្នកភូមិមិនសូវជាល្អប៉ុន្មានទេ |

| | |
|---|---|
| | ដោយសារគាត់ប្រើប្រាស់ថ្នាំនេះដោយមិនបានការពារខ្លួនឱ្យបានល្អ។<br>▪ ក្រោយពីការបណ្តុះបណ្តាល យើងសង្កេតឃើញមានកសិករមួយចំនួនចាប់ផ្តើមចេះការពារខ្លួន ដូចជាពាក់អាវ និងពាក់ម៉ាស់នៅពេលបាញ់ថ្នាំ បើតាមការអះអាងរបស់អ្នកចូលរួម។ គាត់បានបន្ត ពន្យល់ទៀតថា ភាគច្រើនពួកគាត់មិនសូវពាក់អាវការពារ ឬម៉ាស់ទេ ព្រោះគាត់ពិបាកដកដង្ហើមណាស់ ហើយមិនទំលាប់ទៀត បើទោះបីគាត់ដឹងថាវាមានគ្រោះថ្នាក់យ៉ាងណាក៏ដោយ។ |
| ▪ កសិករចំនួន ១០០នាក់ ៥ឃុំ ក្នុងស្រុកគោលដៅចំនួន ៣ស្រុក បានទទួលចំណេះដឹងអំពីការប្រើប្រាស់ ថ្នាំពុលធម្មជាតិកសិកម្មចំនួន ៥វគ្គ | ▪ បានបណ្តុះបណ្តាលពីការប្រើប្រាស់ថ្នាំពុលធម្មជាតិចំនួន ៥វគ្គ<br>▪ សរុបកសិករចំនួន ២០៩នាក់ ស្ត្រី ៩២នាក់ បានទទួលការបណ្តុះបណ្តាលនេះ |
| ▪ កសិករចំនួន ៦០នាក់ ៣ឃុំ ក្នុងស្រុកគោលដៅចំនួន ២ស្រុក បានទទួលចំណេះដឹងអំពីបច្ចេកទេសបណ្តុះផ្សិតចំបើងចំនួន ៥វគ្គ | ▪ បានផ្តល់វគ្គបណ្តុះបណ្តាលពីបច្ចេកទេសបណ្តុះផ្សិតចំនួន ៣វគ្គ<br>▪ សរុបកសិករចំនួន ១៣២ ស្ត្រី៩៥នាក់ បានទទួលការបណ្តុះបណ្តាល |

## ផ្នែក ៦ ខ:ការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា

| ធាតុនៃទិសដៅបន្ទាន់ (១) | ការសម្រេចបាន/លទ្ធផលជាក់ស្តែង នៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| ធ្វើឱ្យប្រសើឡើងនូវជីវភាពកសិករដែលស្ថិតនៅតំបន់គោលដៅដោយផ្តោតលើការពង្រីកផលិតកម្មកសិកម្ម និងកសិផលផ្សេងៗទៀតតម្រូវតាមទីផ្សាររបស់គ្រួសារកសិករតាមរយ:ការអនុវត្តបច្ចេកទេសថ្មីដោយរក្សារបាននិរន្តភាព។ | - គាត់ចេះធ្វើជីកំប៉ុស្តិ៍ដែលមានគុណភាព<br>- ផលដំណាំលូតលាស់ល្អនិងទទួលផលបានច្រើន<br>- ជីវភាពគ្រួសារនិមួយៗប្រសើរជាងមុន<br>- ចេះពីរបៀបប្រើប្រាស់ថ្នាំពុលគីមីប្រកបដោយសុវត្ថិភាព |

## ផ្នែក_គៈ សង្ខេបការវាយតម្លៃ "លទ្ធផល" និង "ផលប្រយោជន៍" ដែលអាចបំលែងជាបរិមាណអាចវាស់វែងបាន និងអាចមើលឃើញៈ

បច្ចេកទេសដំណាំស្រូវមួយដើម ប.រ.ស កសិករភាគច្រើនមិនទាន់ទទួលយកបាននៅឡើយទេ ។ គាត់បានពន្យល់ថា ជាការពិតបច្ចេកទេសនេះធ្វើឱ្យគាត់ ចំនេញពូជ និងទិន្នផលច្រើន ប៉ុន្តែការអនុវត្តបច្ចេកទេសប្រឈមមុខនឹងការ លំបាកជាច្រើនរួមមាន ការបញ្ចេញបញ្ចូលទឹក បើកសិករមានដីច្រើនជាង ៤រ៉ៃ គាត់ត្រូវចំណាយថវិកា និងពេលវេលាយ៉ាងច្រើនសម្រាប់ការដកស្ទូង។ ដែលនេះជាការប្រឈមយ៉ាងខ្លាំងចំពោះជីវភាពរបស់គាត់។ ម្យ៉ាងវិញទៀត ការប្រើប្រាស់ជីធម្មជាតិសុទ្ធ ជាការប្រឈមមួយទៀត ព្រោះកសិករបច្ចុប្បន្នភាគច្រើនប្រើប្រាស់ គោយន្ត ជំនួស សត្វគោ ដូចនេះគាត់មានការលំបាកក្នុងការធ្វើជីធម្មជាតិនេះ។ ប៉ុន្តែបច្ចេកទេសទាំងអស់នេះ នៅតែមានសារសំខាន់ សម្រាប់គ្រួសារកសិករដែលមានលទ្ធភាពអាចធ្វើបាន ជាក់ស្តែងដំណាំស្រូវតាមរបៀប ប.រ.ស ជាលទ្ធផលស្រូវ បែកគុម្ពល្អ ដែលអាចហុចផលបានពី ២.៥តោន ទៅ ៤តោនក្នុង១ហិកតា ដីស្រែធូរមានជីជាតិ។ ជាងនេះទៀត ទិន្នផលឱឡឹក កសិករដែលប្រើប្រាស់ជីធម្មជាតិអាចរកចំណូលបានពី២០០០ ទៅ ២៥០០ ដុល្លារ ក្នុងមួយរដូវ។

**សង្ខេបការវាយតម្លៃ "ផលប្រយោជន៏" ដែលមិនអាចមើលឃើញ ប៉ុន្តែជាការយល់ឃើញរបស់អ្នក ទទួលផល និងអ្នកផ្តល់ព័ត៌មានសំខាន់ៗ:**

ក្រោយពីកម្មវិធីឬអនុកិច្ចសន្យាបានផ្តល់នូវចំណេះដឹងច្បាស់លាស់តាមរយៈការបណ្តុះបណ្តាល និងការធ្វើបង្ហាញនានាបានធ្វើអោយប្រជាកសិករ ដែលជាក្រុមគោលដៅបានយល់ច្បាស់អំពីរបៀបធ្វើ និងការប្រើប្រាស់ជីកំប៉ុស្តិ៍ លើដំណាំផ្សេងៗ ការប្រើប្រាស់ថ្នាំគីមីត្រឹមត្រូវតាមបច្ចេកទេស។ ចំណេះដឹងទាំងនេះដែលកសិករយក ទៅអនុវត្តជា ប្រចាំពិតជាបានជួយអោយការថែរក្សា និងជួយបង្កើននូវគុណភាពដីសំរាប់ដំណាំផ្សេងៗបានយូរអង្វែង។

## ករណីសិក្សាទី១ : គ្រួសារ លោក ហូ ភឿន

អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងបណ្តុះបណ្តាលបច្ចេកទេសធ្វើជីកំប៉ុស្តិ៍

លោក ហូ ភឿន បាននិយាយថា : ជីវភាពគ្រួសារខ្ញុំ មានការប្រែប្រួលច្រើនឡើង តាំងពីខ្ញុំបានចូលរួមវគ្គបណ្តុះបណ្តាលធ្វើជីកំប៉ុស្តិ៍ ក្នុងគម្រោងរបស់មន្ទីរកសិកម្ម ខេត្តបាត់ដំបង កាលពីឆ្នាំ ២០០៩។



លោក ហូ ភឿន ជាកសិករធ្វើស្រែ និងចំការ អាយុ ៥0ឆ្នាំ។ គាត់មានគ្រួសារ និងកូន ៣នាក់ ប្រុស ១នាក់ និងស្រី ២នាក់ រស់នៅភូមិព្រៃកប្បួង ឃុំព្រៃកប្បួង ស្រុក ឯកភ្នំ ខេត្តបាត់ដំបង។ គាត់ត្រូវបានមេភូមិព្រៃកប្បួង ណែនាំ ឱ្យចូលរួមក្នុងវគ្គបណ្តុះ បណ្តាលនិងធ្វើបង្ហាញពីការកែប្រែគុណភាពដីនេះ។ ក្រោយពីបានឆ្លងកាត់ការបណ្តុះ បណ្តាលមក គាត់បានសំដែងការពេញចិត្តចំពោះ គម្រោងនេះណាស់។ គាត់បានបន្ថែម ថាគាត់បានទទួលចំណេះដឹង និងជំនាញ យ៉ាងច្រើន។ គាត់មានការផ្លាស់ប្តូរគំនិតដែលគាត់មិនបាននឹកគិតថាកាកសំណល់ ជុំវិញ ផ្ទះគាត់សុទ្ធតែផ្តល់ប្រយោជន៏ឱ្យគាត់សូម្បីតែអាចម៏គោនិងសំរាម។ គាត់បានបញ្ជាក់ថា បច្ចុប្បន្នគាត់ប្រើជីកំប៉ុស្តិ៍ដែលគាត់ផលិតបាននេះ លើចំការ ឪឡឹក ២ហិកតា។ គាត់អាចរកចំណូលបាន ២៥០0ដុល្លារ ក្នុងមួយរដូវ ដែលចំនួលនេះ កើនជាងមុនសំរាប់ការដាំក្នុងផ្ទៃដីដូចគ្នា។ ចំពោះដំណាំស្រូវក៏ កើនទិន្នផល ដូចគ្នាដែរ ប៉ុន្តែគាត់មិនបានកត់ត្រា។

ដោយឃើញពីផលប្រយោជន៏របស់ជីកំប៉ុស្តិ៍ ចុងបញ្ចប់គាត់បានប្តេជ្ញាចិត្តថានឹងបន្តធ្វើជីកំប៉ុស្តិ៍នេះជារៀងរហូត លុះត្រាតែគាត់ឈប់ធ្វើរបរកសិកម្ម ព្រោះគាត់ នឹងមិនត្រូវការចំណាយថវិកាសំរាប់ការដាក់ជីដូចមុនទៀតទេ ណាមួយគាត់ សង្កេតឃើញថាគាត់ចំណាយពេលតិច ក្នុងការរៀបចំរងលើកក្រោយ ដោយសារ ដីធូរ ក្រោយការប្រើជីកំប៉ុស្តិ៍ ។

**ករណីសិក្សាទី ២: អ្នកមិនបានទទួលផល**



លោក ម៉ា សំអឿន អាយុ ២៩ឆ្នាំ មានគ្រួសារ និងកូនស្រី ១នាក់។ គាត់រស់នៅក្នុងភូមិព្រៃកហ្លួង ឃុំព្រៃកហ្លួង ស្រុកឯកភ្នំ ខេត្តបាត់ដំបង។ គាត់ជាកសិករដែលមានចំណូលចំបងពីការធ្វើស្រែ និងដាំឪឡឹក។ លោក ម៉ា សំអឿន មិនបានចូលរួម ក្នុងវគ្គបណ្តុះបណ្តាលពីបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ របស់មន្ទីរកសិកម្ម ក្រោមការឧបត្ថម្ភថវិការបស់ គ.អ.ជ.ខ ទេ ពីព្រោះពេលប្រធានភូមិមកជ្រើស រើសគាត់មិននៅផ្ទះជាប់រវល់ចុះទៅស្រែនៅជិតព្រៃរនាម ជាប់បឹងទន្លេសាប។ ចំពោះគាត់ការ ថ្វីត្បិតតែមិនចូលរួមវគ្គ តែគាត់គិតថាវគ្គបណ្តុះបណ្តាលនេះមាន សារៈសំខាន់ណាស់ ពីព្រោះបន្ទាប់ពីគាត់បានទទួលការបង្ហាញពីអ្នកជិតខាងដែល បានចូលរួមវគ្គនោះ គាត់បានធ្វើជីកំប៉ុស្តិ៍ហើយអនុវត្តសាកល្បងលើ ដំណាំឪឡឹក របស់គាត់។ គាត់ទទួលបានផលច្រើនណាស់ដោយបញ្ជាក់ថា " ឪឡឹកក្នុង ១រ៉ៃ លក់បាន ១លានរៀល ឯណោះ"។ គាត់ចាប់អារម្មណ៍ថា ការប្រើជីកំប៉ុស្តិ៍ជួយឱ្យ គាត់កាត់បន្ថយការចំណាយលើការដាក់ជី ដែលជានិច្ចកាលគាត់ត្រូវទិញជីគីមី មកប្រើ។ ទោះជាការលូតលាស់ឃឺតបន្តិចតែដំណាំពុំសូវមានជំងឺ មិនចំណាយ ថវិកាច្រើនក្នុងការទិញថ្នាំសំលាប់សត្វល្អិត វាក៏ធ្វើឱ្យដីធូរពេលដាំលើកក្រោយ។

លោក ម៉ា សំអឿន មានសង្ឃឹមថានឹងបានទទួលការបង្ហាត់បង្ហាញដោយផ្ទាល់ពីអ្នកបច្ចេកទេសកសិកម្មនៅពេលក្រោយទៀត ឬក៏អាចចូលរួមវគ្គផ្សេងៗ ទៀតប្រសិនបើមាន ដែលនេះជាឱកាសសំរាប់គាត់ក្នុងការ ទទួលទុនចំណេះដឹង សំរាប់កែប្រែជីវភាពគ្រួសារតាមរយៈ ការរៀនសូត្រពីបច្ចេកទេស និងបទ ពិសោធន៍ថ្មីៗក្នុងរបរកសិកម្ម។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

**ផ្នែក_ក: ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅនឹងតំរូវការ:** មន្ទីរវិស័យ មូលដ្ឋាន គ.ជ.អ.ប និងការកាត់បន្ថយភាព ក្រីក្រៈ

| ល.រ | ធាតុ | ទំនាក់ទំនងតក្កភាព | បរិយាយច្បាស់លាស់ | សង្ខេបការវាយតម្លៃ |
|---|---|---|---|---|
| ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់ | | | | |
| ១ | សកម្មភាព | ៤ | ៤ | សកម្មភាពដែលបានលើកឡើងពិតជាមានទំនាក់ទំនងតក្កភាពល្អ ជាមួយនឹងលទ្ធផលដែលបានដែលបានសរសេរនៅក្នុងឯកសារអនុកិច្ចសន្យា។ ម្យ៉ាងទៀតការជ្រើសរើសអ្នកទទួលផល ធ្វើឡើងដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន ផ្អែកទៅលើអាទិភាពគ្រួសារក្រីក្រ ហើយជាអ្នកប្រកបរបរកសិកម្មជាចំបង ដែលពួកគាត់អាចបង្កើនទិន្នផលកសិកម្មបានក្រោយពីបណ្តុះបណ្តាលរួច។ ជាក់ស្តែងលទ្ធផលទី១ ទាក់ទង នឹងការកែលម្អគុណភាពដី។ នៅក្នុងលទ្ធផលនេះមាន សកម្មភាពជាក់លាក់ដូចជាវគ្គបណ្តុះបណ្តាលពី បច្ចេកទេសដំណាំស្រូវតាមរបៀប ប.វ.ស ដោយប្រើជីកំប៉ុស្តិ៍ និងការធ្វើបង្ហាញចំនួន ២៤បង្ហាញ ២លើក វគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសនៃការប្រើប្រាស់ជីកំប៉ុស្តិ៍ ចំនួន ៥វគ្គ វគ្គបណ្តុះបណ្តាលអំពីសុវត្ថិភាពនៃការ ប្រើប្រាស់ថ្នាំពុលកសិកម្មចំនួន ៥វគ្គ វគ្គបណ្តុះ បណ្តាលអំពីការប្រើប្រាស់ថ្នាំពុល ធម្មជាតិចំនួន ៥វគ្គ និងវគ្គបណ្តុះបណ្តាលអំពីបច្ចេក ទេសបណ្តុះផ្សិតចំបើងចំនួន ៥វគ្គ។ ទាំងអស់នេះបានឆ្លុះបញ្ចាំងថាសកម្មភាព |

| | | | | |
|---|---|---|---|---|
| | | | | ទាំងនេះមានទំនាក់ទំនងតក្ក ជាមួយនឹងលទ្ធផល នៅខាងលើ ហើយនិងបានសរសេរយ៉ាងច្បាស់ ។ សកម្មភាពនីមួយៗ បានសរសេរបង្ហាញច្បាស់លាស់ ដោយមានចំនួនវគ្គបណ្តុះបណ្តាល និងចំនួនសិក្ខាកាម ដែលត្រូវចូលរួមក៏ដូចជាឃុំ និងស្រុកគោលដៅដែលបានកំណត់ ។ សកម្មភាពផ្សេងទៀតនៅក្រោមលទ្ធផលបន្តបន្ទាប់ (លទ្ធផលទី២ និងទី៣) ត្រូវបានសរសេរ ក្នុងបែបបទដូចគ្នានឹងលទ្ធផលទី១ដែរ ។ សកម្មភាពនិមួយៗ មានទំនាក់ទំនងតក្ក ហើយនឹងត្រូវបាន បរិយាយច្បាស់លាស់ ដូចដែលមានសរសេរនៅក្នុងអនុកិច្ចសន្យា ។ |
| ២ | លទ្ធផល | ៤ | ៤ | លទ្ធផលនិមួយៗ<br>ត្រូវបានបរិយាយច្បាស់លាស់ដោយ មានសូចនាករជាក់លាក់ និងអាចវាស់វែងបាន ។ ពិសេសទៅទៀត លទ្ធផលនិមួយៗ ផ្សារភ្ជាប់គ្នា និងបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ព្រមទាំងរួមគ្នាបំពេញគោលបំណងបន្ទាន់ ។ កត្តានេះបានធ្វើឱ្យគោលបំណងបន្ទាន់សម្រេចបានដោយជោគជ័យ ។ |
| ៣ | អត្ថប្រយោជន៍រយៈពេលខ្លីៈ (លទ្ធផល/ផលប្រយោជន៍)<br>- គោលបំនងបន្ទាន់ (គោលបំនងស្ថិតក្នុងចំណុច "ខ" នៃផ្នែកទី ៣)<br>- ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា (ចំណុច "គ" នៃផ្នែកទី ៣) | ៣ | ៣ | គោលបំណងបន្ទាន់មានភាពច្បាស់លាស់ស៊ីគ្នានឹង សកម្មភាព ដែលធ្វើឱ្យអនុកិច្ចសន្យានេះងាយនឹង សម្រេចបាននូវគោលបំណងបន្ទាន់ ។<br>ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា ត្រូវបានបរិយាយ យ៉ាងច្បាស់ និងមានទំនាក់ទំនងដោយផ្ទាល់ទៅនឹង លទ្ធផល និងសកម្មភាពនៃអនុកិច្ចសន្យា ។ ស្ថានភាពចុងបញ្ចប់នេះ បានឆ្លុះបញ្ចាំងនូវសមិទ្ធិផល ដែលសម្រេចបាននៅក្នុងកម្រិតលទ្ធផល ។ ប៉ុន្តែវា មិបានរំលេចឱ្យឃើញពីស្ថានភាពចុងបញ្ចប់ ឬផល |

| | | |
|---|---|---|
| | | ប៉ះពាល់តិចតួចបំផុតដែលអាចកើតឡើងនៅក្នុងក៏រិតប្រជាជន និងសហគមន៍ ។ គ្មានភស្តុតាងច្បាស់លាស់ណាមួយដើម្បីបង្ហាញថា តើសិក្ខាកាមបានយកចំណេះដឹង និងជំនាញដែលពួកគេទទួលបានទៅធ្វើជាប្រយោជន៍ ក្នុងការធ្វើឱ្យប្រសើរឡើងនូវជីវភាពរបស់ពួកគាត់ទេ ។ |
| ៤ | លទ្ធផលអភិវឌ្ឍន៍/ផលប៉ះពាល់ រយៈពេលវែង: គោលដៅ និងគោលបំនងអភិវឌ្ឍន៍ (ចំណុច "ខ" នៃផ្នែកទី ៣) | មិនអាចធ្វើការវាស់វែងបាន |

## ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារ:

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.ជ.អ.ខ:** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | ដោយមានកិច្ចសហការល្អ ជាមួយភ្នាក់ងារអនុវត្តកិច្ចសន្យា ត្រូវបានរៀបចំបានល្អ ទាន់ពេលវេលា មានភាពស៊ីសង្វាក់គ្នា ហើយការរៀបចំលទ្ធផល សកម្មភាពឆ្លើយតបទៅតាមចំនួនថវិកាដែលបានវិភាជន៍ ។ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យការអនុវត្តន៍របស់ភ្នាក់ងារអនុវត្តន៍ | មិនមានការប្រឈម និងឧបសគ្គគួរឱ្យកត់សំគាល់ទេ ដោយមន្ត្រីគ.ប្រ បានធ្វើការចុះតាមដាន ត្រួតពិនិត្យជាប្រចាំសហការណ៍ជាមួយមន្ត្រីបង្គោលនិងដោយមានការគាំទ្រពីទីប្រឹក្សាត្រួតពីនិត្យវាយតម្លៃ ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា | រាល់ការចុះត្រួតពិនិត្យ ឯកសារទាក់ទងនិងអនុកិច្ចសន្យានានា ត្រូវបានយកមកផ្ទៀងផ្ទាត់ជាមួយនិង លទ្ធផល |

| | | |
|---|---|---|
| | | អនុវត្តជាក់ស្តែង ហើយភាពរីកចំរើនរបស់ការអនុវត្តន៍គំរោងត្រូវបានកត់ត្រា និងរក្សាទុកបានល្អសំរាប់ជា ឯកសារយោងនៅពេលវាយតម្លៃបញ្ចប់អនុកិច្ចសន្យា ។ |
| **ពីខាងភាគីអនុវត្តន៍កិច្ចសន្យាៈ** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | ការគ្រប់គ្រងល្អធ្វើឱ្យគម្រោងដំណើរការបានល្អ ដោយមន្ត្រីបង្គោលនិងមន្ត្រីអនុវត្តមានបទពិសោធន៍ ច្រើនឆ្នាំជាមួយ គំរោងវិនិយោគខេត្ត និងដោយមានការគាំទ្របច្ចេកពី មន្ត្រីគ.ប្រផងដែរ ។ ម្យ៉ាងទៀតគ្រូបង្រៀនមានជំនាញច្បាស់លាស់និងវិធីសាស្ត្រល្អក្នុងការផ្ទេរចំណេះដឹង ដោយមានឧបករណ៍បង្រៀនគ្រប់គ្រាន់ មានឯកសាររូបភាពដែលធ្វើឱ្យអ្នកចូលរួមងាយយល់និងអាចអនុវត្តបានឆាប់ ។ |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | អនុវត្តទាន់ពេលវេលា និងទទួលបានលទ្ធផលល្អ ដោយមន្ត្រីអនុវត្តសុទ្ធតែមានជំនាញនិងបច្ចេកទេសពេញលេញក្នុងការផ្ទេរចំណេះដឹង ហើយការដាក់ផែនការ សកម្មភាព អនុវត្តត្រូវនិងស្ថានភាព ភូមិសាស្ត្រ និងពេលវេលានៃការធ្វើ ស្រែចំការរបស់កសិករ ដែលជាលក្ខណៈបង្ករអំណោយផលដល់ការអនុវត្តសកម្មភាព ។ |
| ៦ | ការរាយការណ៍ការរីកចំរើន និង ការកត់ត្រាឯកសារ | ផ្តល់មក គ.ប្រ ទាន់ពេលវេលា |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | បានបំពេញតាមលក្ខខ័ណ្ឌក្នុងកិច្ចសន្យា |
| **ទាំងខាង គ.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យាៈ** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" ( ចំណុច-ង ផ្នែកទី៣ ) និងបញ្ហាប្រឈម | ដំណើរការទៅបានល្អដោយមានការចូលរួមសហការពីអាជ្ញាធរមូលដ្ឋាន |
| ៩ | ការបញ្ជ្រាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | នៅក្នុងគម្រោងនេះមានការចូលរួមពីបុរសនិងស្ត្រី ហើយរាល់សកម្មភាពនៃការអនុវត្តន៍គំរោងដូចជា ការបង្ហាញ និងវគ្គបណ្តុះបណ្តាលមន្ត្រីបង្គោលតែងបញ្ជ្រាបពីការយល់ដឹងលើទស្សនៈយេនឌ័រជាប្រចាំ ។ |

| | | |
|---|---|---|
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ ( ចំណុច-ឆ ផ្នែកទី៣) | ពិតជាបានជួយដល់ការកាត់បន្ថយការបំពុលបរិស្ថាន ដោយប្រជាកសិករងាកមកប្រើប្រាស់ជីកំប៉ុស្តិ៍ ថ្នាំពុលធម្មជាតិជាងប្រើ ជីគីមីនិងថ្នាំពុលគីមី ជាពិសេសពួកគាត់បានយល់ដឹងបន្ថែមលើសុវត្ថិភាពនៃការប្រើប្រាស់ថ្នាំពុលគីមីហើយកាត់បន្ថយនៃការប្រើប្រាស់នេះ ។ រាល់សកម្មភាពទាំងអស់ មិនមានផលប៉ះពាល់អវិជ្ជមានដល់ការគ្រប់គ្រងធនធានធម្មជាតិទេ តែបានធ្វើឱ្យប្រសើរឡើងនូវគុណភាពដីធ្លីវិញ។ |
| ១១ | ការថែរក្សា (និរន្តភាព) ( ចំណុច-ជ ផ្នែកទី៣) | ទោះជាយ៉ាងណាក៏គេសង្កេតឃើញសកម្មភាព នៃផ្នែកខ្លះក្នុងគម្រោងត្រូវបានយកមកអនុវត្តដោយកសិករដូចដែលក្រុមការងារ ចុះទៅធ្វើការវាយតម្លៃបានឃើញស្រាប់។ ដូច្នេះវាមាននិរន្តរភាពផ្នែកខ្លះៗនៃ គម្រោង។ |

## ២.៤. សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី ៥)

និយាយរួមការអនុវត្តអនុកិច្ចសន្យានេះបានបញ្ចប់ទៅប្រកបដោយជោគជ័យដែលមានការចូលរួមយ៉ាងច្រើន ពីកសិករ ដោយក្រុមគោលដៅភាគច្រើនជាគ្រួសារកសិករក្រីក្រ និងមានចំណូលពឹងផ្អែកលើរបរកសិកម្មជាចំបង។ ការបង្ករបង្កើនផលនៅមានក៏រិតទាបដោយមូលហេតុពុំមានបច្ចេកទេសនិងចំណេះដឹងលើការកែប្រែគុណភាពដី និងវិធី សាស្ត្របង្ករបង្កើនផល។ ការចូលរួមក្នុងគំរោងគឺជាតម្រូវការអាទិភាពរបស់ ពួកគាត់ដើម្បីបង្កើនជីវភាព រស់នៅតាម រយៈរបរកសិកម្មនេះ ។ ក្រោយការបណ្តុះបណ្តាលពួកគាត់បានយកចំណេះដឹង និងបទពិសោធន៍ ដែលបានចែករំលែក ក្នុងវគ្គយកមកអនុវត្តភាគច្រើនលើការប្រើប្រាស់ជីកំប៉ុស្តិ៍ និងចញ្ចឹមត្រី ហើយមួយចំនួនទៀត នៅបន្តការអនុវត្តន៍ ប.វ.ស។ ប៉ុន្តែបច្ចេកទេសដែលបានផ្តល់ជូននេះ នៅមិនទាន់ត្រូវបានទទួលយក ទៅអនុវត្តជាប្រចាំឱ្យ បានទូលំទូលាយ នៅឡើយទេ។ ជាការកត់សំគាល់ មានកសិករតិចតួចដែលព្រមទទួលយក បច្ចេកទេសថ្មីនេះ (ប.វ.សនិងជីកំប៉ុស្តិ៍) ទៅប្រើខណៈការចំណាយខ្ពស់លើការដកស្ទូងនិងថែទាំ ធ្វើឱ្យកសិករ មានការរារែកបើទោះជាទិន្នផលស្រូវកើនឡើងក៏ដោយ។

អ្នកបន្តអនុវត្តភាគច្រើនជាអ្នកដែលមានដីស្រែតិចតួចប៉ុណ្ណោះ។ ដោយឡែកកសិករមួយចំនួន ទៀតទទួលស្គាល់និងអនុវត្តការប្រើប្រាស់ជីកំប៉ុស្តិ៍ ខណៈទិន្នផលដំណាំឪឡឹកកើនឡើងហើយការចំណាយលើការដាក់ជីនិងថែទាំតិចតួច។

ផ្អែកទៅលើលទ្ធផលនៃការវាយតម្លៃ បានបង្ហាញថាភាពជោគជ័យនៃគំរោងភាគច្រើនបានសំរេចដល់គោលបំនងបន្ទាន់នៃគំរោង ហើយសកម្មភាពមួយចំនួនក៏អាចឈានដល់និរន្តរភាពនិងផលប៉ះពាល់ជាវិជ្ជមានដែរដូចជាការ ប្រើប្រាស់ជីកំប៉ុស្តិ៍ និងការប្រើប្រាស់ថ្នាំពុលធម្មជាតិជាដើម ។ ផលប្រយោជន៍នៃការប្រើប្រាស់ជីកំប៉ុស្តិ៍បានសាយ ភាយដល់ប្រជាកសិករដែលមិនមែនក្រុមគោលដៅហើយចំនួននៃអ្នកធ្វើជីកំប៉ុស្តិ៍កើនឡើងជាលំដាប់ ។ សរុបមក គំរោងនេះ គួរបន្តប្រសិនបើមានថវិកាសំរាប់វិនិយោគលើវិស័យនេះ ហើយអនុសាសន៍មួយចំនួនខាងក្រោមគួរត្រូវ បានពិចារណា ដើម្បីកែលំអការអនុវត្តគំរោងឱ្យមានប្រសិទ្ធិភាពនិងនិរន្តរភាព ។

## សេចក្ដីសន្និដ្ឋានជារួមៈ

**ចំណុចរៀនសូត្រៈ**

កែប្រែទំលាប់ចាស់ជាការលំបាក បើទោះជាការបណ្តុះបណ្តាលបច្ចេកទេស មានភាពងាយស្រួល និងអនុវត្តក៏ដោយ ។ កសិករនៅមិនទាន់អាចមានលទ្ធភាពយកចំណេះដឹងទៅអនុវត្តឱ្យបានពេញលេញទេ ដោយមូលហេតុឧបសគ្គមួយចំនួនធ្វើឱ្យមានការរារាំងដល់ការអនុវត្ត ដូចជាការអនុវត្ត ដំណាំស្រូវ ប.វ.ស ជាដើម។ ទោះជាយ៉ាងណាក្តី ការងាកមកប្រើជីកំប៉ុស្តិ៍របស់កសិករគឺជាសញ្ញាវិជ្ជមានមួយដែលការកែប្រែគុណភាពដីនិងការកាត់បន្ថយ ការបំពុលបរិស្ថាន និងការចំណាយថវិកាលើការថែទាំ ត្រូវបានកាត់បន្ថយ ។ ការកត់សំគាល់មួយទៀតដែលគំរោងគួរពិចារណា សំរាប់ការអនុវត្តបន្ត គឺ **ការជ្រើសរើសក្រុមគោលដៅឱ្យត្រូវនិងគោលបំណងនិងលទ្ធផល សកម្មភាព ដូចជាជ្រើសរើសអ្នកដែលមានដីស្រែតិចមកចូលរួមសកម្មភាព ប.វ.ស និងជី កំប៉ុស្តិ៍ ដើម្បីឱ្យគាត់មានឱកាសបង្កើនទិន្នផលតាមរយៈការបណ្តុះបណ្តាល ខណៈពួកគាត់អាចមានពេលវេលាគ្រប់គ្រាន់ ក្នុងការដកស្ទូងនិងថែទាំបញ្ចេញបញ្ចូលទឹក ដាក់ជីកំប៉ុស្តិ៍ជាដើម ។**

**អនុសាសន៍ ៖**

១. ការជ្រើសរើសក្រុមគោលដៅ គួរជ្រើសរើសតែគ្រួសារណាដែលមានលក្ខណៈវិនិច្ឆ័យសមស្របទៅនិងគោលបំណងគំរោង ឬលទ្ធផល សកម្មភាពរបស់គំរោង ហើយដែលតាមរយៈការចូលរួមរបស់គាត់ អាចសំរេចបានដល់គោលបំនងបន្ទាន់ និងឈានទៅរកសំរេចបានដល់ផលប៉ះពាល់ជាវិជ្ជមាន ។

២. ការចុះតាមដានត្រួតពិនិត្យ ត្រូវធ្វើជាប្រចាំដើម្បីប្រសិទ្ធិភាពនៃការអនុវត្តន៏គំរោង ហើយវាជាឱកាសមួយសំរាប់ផ្ទៀងផ្ទាត់លទ្ធផលជាក់ស្តែងទៅនិងលទ្ធផលរំពឹងទុក ហើយក៏ជាពេលដែលត្រូវដោះស្រាយរាល់បញ្ហា ប្រឈមដែលកើតមានឡើងក្នុងកំឡុងពេលអនុវត្ត សំរាប់កែលំអលើរាល់សកម្មភាពដែលត្រូវអនុវត្តបន្ត ។

៣. ការប្រើប្រាស់តារាងតក្កភាព ផែនការសកម្មភាព និងវាល់កំណត់ត្រាភាពរីកចំរើន រួមទាំងបញ្ហាប្រឈមនានា គឺជាមធ្យោបាយល្អបំផុត សំរាប់ឆ្លុះបញ្ចាំងលើប្រសិទ្ធិភាពនិងភាពសក្តិសិទ្ធ នៃការអនុវត្តន៏គំរោង ។

៤. ក្រុមគោលដៅគួរមានការចុះធ្វើទស្សនៈកិច្ចសិក្សា នៅតំបន់ដ៏ទៃដើម្បីរៀនសូត្រពីបទពិសោធន៍និងបច្ចេកទេសផ្សេងៗ យកមកធ្វើការប្រៀបធៀបនិងស្វែងយល់ពីចំណុចដែលធ្វើឱ្យប្រសើរឡើងដល់ការបង្កើនទិន្នផលកសិកម្ម ។

៥. គួរមានវិធីសាស្ត្រ និងការលើកទឹកចិត្តដល់ប្រជាកសិករក្នុងការអនុវត្តបច្ចេកទេសថ្មីនេះ ក្រោយពីគាត់បានទទួលការបណ្តុះបណ្តាល ដូចជាការបង្កើតកម្មវិធីប្រលងប្រណាំងកសិករគំរូជាដើម ។

៦. ការបណ្តុះបណ្តាលបច្ចេកទេសនេះ គួរតែចាប់ផ្តើមអនុវត្តពីភូមិ ឬឃុំណាដែលមានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ ដែលធ្វើអោយកសិករអាចមានលទ្ធភាពអនុវត្តបាននូវបច្ចេកទេសពេញលេញ ហើយគួរជ្រើសរើសតែគ្រួសារកសិករណាដែលមានជីវិតចតួចមកចូលរួម សកម្មភាព ប.វ.ស ព្រោះគាត់មានពេលវេលាគ្រប់គ្រាន់ក្នុងការដកស្ទូងនិងថែទាំ ។

## ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

**ឯកសារដែលត្រូវភ្ជាប់ទី១ : បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបានពិនិត្យ**

| ល.រ | ឈ្មោះឯកសារ/របាយការណ៍ | មាន |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និង ឯកសារវិសោធនកម្ម (ប្រសិនមាន) | √ |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ | √ |
| ៣ | របាយការណ៍ត្រួតពិនិត្យគម្រោង | √ |
| ៤ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | √ |
| ៥ | លិខិតឆ្លើយឆ្លងរវាងភ្នាក់ងារអនុវត្តន៍ និងគណៈកម្មាធិការប្រត្តិបត្តិគ.អ.ជ.ខ | |
| ៦ | បញ្ជីវត្ថុបណ្តុះបណ្តាលដែលមានក្នុងអនុកិច្ចសន្យា | √ |
| ៧ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា | √ |
| ៨ | ឯកសារដ៏ទៃទៀតរួមមាន រូបថតនៃគម្រោង (អនុកិច្ចសន្យា) ដែលទុកនៅគណៈកម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ និងនៅភ្នាក់ងារអនុវត្តន៍ ដែលមិនបានរៀបរាប់ខាងលើ | √ |
| ៩ | ផ្សេងទៀត | √ |

## ឯកសារដែលត្រូវភ្ជាប់ទី២ : ឯកសារអនុកិច្ចសន្យា លេខ 02/AGR/0901-001ខេត្តបាត់ដំបង

## បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាស/ជួបពិភាក្សា

| ល.រ | ថ្ងៃខែ | ឈ្មោះ និង តួនាទី<br>នៅក្នុងបរិបទអនុកិច្ចសន្យា | ទីកន្លែង | ឧបករណ៍ប្រើសម្រាប់ប្រមូល<br>ទិន្នន័យដែលបានប្រើ |
|---|---|---|---|---|
| ១ | ២៦<br>សីហា | លោក មន្ត្រីត្រួតពិនិត្យនិងវាយតម្លៃ ផ្នែកគ្រប់គ្រងកិច្ចសន្យា | សាលាខេត្ត | សម្ភាសន៍ស៊ីជម្រៅ |
| ២ | ២៧<br>កញ្ញា | លោក សេង រដ្ឋណាក់ មន្ត្រីបង្គោល ត្រួតពិនិត្យ និងវាយតម្លៃ និង មន្ត្រីទទួលខុសត្រូវ | មន្ទីរកសិកម្ម<br>ខេត្តបាត់ដំបង | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | ២៨<br>និង<br>២៩<br>កញ្ញា | ក្រុមអ្នកទទួលផល | ភូមិ តាកាយ<br>ភូមិ ថ្មី<br>ភូមិ ព្រែកហ្លួង | សម្ភាសជាក្រុម |
| ៤ | ២៩<br>កញ្ញា | លោក ហូ ភឿន អ្នកទទួលផលផ្ទាល់ | ភូមិ ព្រែកហ្លួង | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៥ | ២៩<br>កញ្ញា | លោក ម៉ា សំអឿន អ្នកមិនទទួលផល | ភូមិ ព្រែកហ្លួង | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |

# របាយការណ៍ស្តីពីការវាយតម្លៃ

| លេខអនុកិច្ចសន្យា : | 03/AGR/0901-00 (NRML) |
|---|---|
| ចំណងជើង : | គាំទ្រគម្រោងផ្សព្វផ្សាយបច្ចេកទេសកសិកម្មសមស្រប |
| ភ្នាក់ងារអនុវត្តន៍ : | មន្ទីរកសិកម្មខេត្តកំពង់ចាម |
| រយៈពេល (ចាប់ផ្តើម និងបញ្ចប់) | 01/01/2009 ដល់ 31/12/2009 |
| រាជធានី ខេត្ត | ខេត្តកំពង់ចាម |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរកសិកម្មខេត្តកំពង់ចាម |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ នៃ គ.អ.ជ.ខ | US$ 19,300.00 |
| ការរួមចំណែករបស់រាជធានី ខេត្ត | US$ 0.00 |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៍ | US$ 0.00 |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | US$ 19,300.00 |

## ក្រុមវាយតម្លៃ និងរៀបចំរបាយការណ៍:

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ និងតួនាទីក្នុងការវាយតម្លៃ |
|---|---|
| លោក **ប្រាក់ និត្យ** | គ្រូបង្គោលត្រួតពិនិត្យ និងវាយតម្លៃ គ.ប្រ |
| លោក **ចិន សារ៉ាត** | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ គ.ប្រ |
| លោក **ជី ខេង** | គ្រូបង្គោលត្រួតពិនិត្យ និងវាយតម្លៃ មន្ទីរកិច្ចការនារី |
| លោក **សឿន រិទ្ធី** | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ គ.ប្រ |

**ខេត្តកំពង់ចាម**

កាលបរិច្ឆេទ : ០៥ តុលា ២០១០

# មាតិកា


| | | |
|---|---|---|
| **អក្សរកាត់** | | ៣ |
| | **របាយការណ៍សង្ខេប** | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៨** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៨ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៨ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៨ |
| ១.៤ | សំណួរវាយតម្លៃ | ៩ |
| ១.៥ | វិធីសាស្រ្ត សម្ភារៈ និងដំណើរការវាយតម្លៃ | ៩ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ១០ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១២** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល( សំណួរវាយតម្លៃទី ១) | ១២ |
| | - លទ្ធផលទី១ | ១២ |
| | - លទ្ធផលទី២ | ១៤ |
| | - លទ្ធផលទី៣ | ១៥ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម ( សំណួរវាយតម្លៃទី៣) | ១៦ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង ( សំណួរវាយតម្លៃទី ៤) | ២១ |
| **២.៤** | **សេចក្តីសន្និដ្ឋាន ( សំណួរវាយតម្លៃទី៥)** | **២៥** |
| **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍** | | **២៧** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ២៧ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍/ពិភាក្សា | ២៨ |
| **ករណីសិក្សា** | | **១៩** |
| ករណីសិក្សាទី១: | អ្នកទទួលផលពីអនុកិច្ចសន្យាមន្ទីរកសិកម្ម លើគម្រោងប្រពលវប្បកម្មដំណាំបន្លែ | ១៩ |
| ករណីសិក្សាទី២: | អ្នកមិនទទួលផលពីអនុកិច្ចសន្យាមន្ទីរកសិកម្ម លើគម្រោងប្រពលវប្បកម្មដំណាំបន្លែ | ២0 |

# អក្សរកាត់

| | | |
|---|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | **:** | គណៈកម្មាធិការប្រតិបត្តិ នៃ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត |
| **កិច្ចសន្យា GOV** | **:** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យដែលមានប្រភពថវិកាពី **យូ.អិន.ឌី.ភី/ភី.អេស.ឌី.ឌី** |
| **គ.ជ.អ.ប** | **:** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ ក្រោមជាតិ |

# របាយការណ៍សង្ខេប

**គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ :**

តាមរយៈគម្រោងពង្រឹងសមត្ថភាពគ្រូបង្គោលថ្នាក់ក្រោមជាតិ របស់ផ្នែកត្រួតពិនិត្យវាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការបានធ្វើការបណ្តុះបណ្តាលដល់គ្រូបង្គោលថ្នាក់ក្រោមជាតិ និងមន្ត្រីត្រួតពិនិត្យ និង វាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យា នៃ គ.ប្រ ស្តីពីការវាយតម្លៃលើគម្រោងអនុកិច្ចសន្យា។

ក្រោយពីបានឆ្លងកាត់វគ្គបណ្តុះបណ្តាលរួចហើយ អនុកិច្ចសន្យា ដែលមានចំណងជើងថា **"គាំទ្រគម្រោងផ្សព្វផ្សាយបច្ចេកទេសកសិកម្មសមស្រប " លេខ 03/AGR/0901-00 (NRML)** ដែលជាអនុកិច្ចសន្យារវាង គ.ប្រនៃ គ.អ.ជ.ខ ខេត្តកំពង់ចាម និងមន្ទីរកសិកម្មខេត្ត ត្រូវបានក្រុមការងារវាយតម្លៃកំណត់យកមកសិក្សា និងធ្វើការវាយតម្លៃដោយមានគោលបំណងជាក់លាក់ដូចខាងក្រោម:

១- ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផល នៃអនុកិច្ចសន្យា និងចំណុចខ្សោយធៀបទៅនឹងលទ្ធផលគោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់ នៃការអនុវត្តន៏កិច្ចសន្យា រួមទាំងកត់ត្រានូវចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត ។

២- ពង្រឹងរបៀបធ្វើការវាយតម្លៃគម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្តន៏ ។

ក្រុមការងារវាយតម្លៃបានប្រើប្រាស់និតិវិធីនៃការវាយតម្លៃតាមការណែនាំ និងឧបករណ៏ស្តីពីការវាយតម្លៃអនុកិច្ចសន្យា របស់គណៈកម្មាធិការប្រតិបត្តិ គ.អ.ជ.ខ ដែលរៀបចំដោយផ្នែកត្រួតពិនិត្យ និងវាយតម្លៃ នៃលេខាធិការដ្ឋាន គ.ជ.អ.ប ។ ឧបករណ៏ដែលត្រូវបានយកមកប្រើប្រាស់នៅពេលនេះមាន : ការពិភាក្សាក្រុម ការសម្ភាសន៏ស៊ីជម្រៅ ការចុះមូលដ្ឋាន ការសង្កេតផ្ទាល់ និងពិនិត្យពិភាក្សាលើឯកសារអនុកិច្ចសន្យា របាយការណ៏រីកចម្រើន ព្រមទាំងឯកសារផ្សេងៗទៀត ដែលមាន ស្រាប់ ។ ជាងនេះទៅទៀត ការវាយតម្លៃត្រូវបានឆ្លើយទៅនឹងសំណួរវាយតម្លៃដែលបានរៀបចំក្នុងចំណុច ១.៤ នៃទិដ្ឋភាពរួម នៃការវាយតម្លៃ ។

ដោយសារតែធនធាន និងពេលវេលាមានកំណត់ ក្រុមការងារបានធ្វើការវាយតម្លៃស៊ីជម្រៅលើលទ្ធផលតែមួយប៉ុណ្ណោះ គឺ **ការបង្ហាញផ្នែកក្សេត្រសាស្ត្រលើដំណាំបន្លែ** ។ ចំណែកលទ្ធផលផ្សេងៗទៀតត្រូវបានវាយតម្លៃដោយផ្អែកលើពតិមានដែលមាន ស្រាប់ដូចជា របាយការណ៏វគ្គបណ្តុះបណ្តាល របាយការណ៏រីកចំរើន របាយការណ៏បញ្ចប់អនុកិច្ចសន្យា ។ ដូច្នេះ ការវាយតម្លៃ នេះមិនមែនជាការវាយតម្លៃស៊ីជម្រៅទៅលើអនុកិច្ចសន្យាទេ ហើយការសន្និដ្ឋានត្រូវធ្វើឡើងទៅតាមអ្វីដែលរកឃើញ ។

**ឆ្លើយទៅនឹងសំណួរទាំង៥ នៃការវាយតម្លៃ :**

១-សកម្មភាពទាំងអស់ត្រូវបានអនុវត្ត និងលទ្ធផលសំរេចបានតាមផែនការ

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសំរេចបានជាក់ស្តែង |
|---|---|---|
| ១ | សាលារៀន **អាយ.ភី.អ៊ឹម** ដំណាំបន្លែចំនួន ៤សាលា (៤ភូមិ) | **អនុវត្តបាន ១០០% :** កសិករបានចូលរួមមាន ចំនួន ១២0នាក់ ស្រី៣៧នាក់ ប្រុស៨៣នាក់ ក្នុងនោះជ្រើសរើស កសិករបាន ចំនួន៤៨នាក់ សម្រាប់ធ្វើការបណ្តុះបណ្តាល ។ |
| ២ | សាលារៀនប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៏ធម្មជាតិចំនួន ៨សាលា (៨ភូមិ) | **អនុវត្តបាន១00%** **:** កសិករបានចូលរួមមានចំនួន ២៨0នាក់ ស្រី ១00នាក់ ប្រុស ១៨0នាក់ ក្នុងនោះជ្រើសរើស កសិករបានចំនួន ៩៦នាក់ សម្រាប់ធ្វើការបណ្តុះបណ្តាល ។ |
| ៣ | កម្មវិធីបង្កើនគុណភាពដីសាលារៀនដីកំប៉ុស្តចំនួន៤ សាលា | **អនុវត្តបាន ១០០% : កសិករ**បានចូលរួមមានចំនួន ៦0នាក់ ស្រី ១៨នាក់ ប្រុស៤២នាក់ ក្នុងនោះជ្រើសរើសកសិករបាន ចំនួន ៦0 នាក់ សំរាប់ធ្វើការបណ្តុះបណ្តាល |
| ៤ | ការបញ្ច្រាបយេនឌ័រក្នុងវិស័យកសិកម្មចំនួន១០ លើក | **អនុវត្តបាន ១០០%:** បានបង្រៀនមេរៀនបញ្ជ្រាប យេនឌ័រ ដល់មន្ត្រីខេត្ត-ស្រុក ចំនួន ៦ លើក ស្មើនឹង ៧៥%។ អ្នកចូលរួមសរុប ១៤៩ នាក់ ក្នុងនោះស្រី ២២នាក់ ។ |
| ៥ | បង្ហាញការចិញ្ចឹមជ្រូកចំនួន ៣ បង្ហាញ | **អនុវត្តបាន ១00%** **:** កសិករបានចូលរួមមានចំនួន ៣៦នាក់ ស្រី ៣0នាក់ ប្រុស ៦នាក់ ក្នុងនោះជ្រើសរើសកសិករបានចំនួន ៩៦នាក់ សំរាប់ធ្វើការបណ្តុះបណ្តាល ។ |
| ៦ | បង្ហាញបច្ចេកទេសធ្វើឡជីវឧស្ម័ចំនួន ១៤បង្ហាញ | **អនុវត្តបាន ១00% :** ដោយជ្រើសរើសកសិករបាន ចំនួន ១៤ គ្រួសារ ក្នុងចំណោមកសិករចូលរួមសរុប ៣៥0 នាក់ ក្នុងនោះស្រី ២៤៤ នាក់ ។ |

២-សាលារៀន **អាយ.ភី.អ៊ឹម** ដំណាំបន្លែ បានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការបង្កើនផលិតផលបន្លែ ដែលជាហេតុធ្វើឱ្យស្ថានភាពជីវភាពសេដ្ឋកិច្ចគ្រួសារក្នុងសហគមន៍ទាំងមូលមានភាពប្រសើរឡើង តាមរយៈការបង្កើនមុខរបរ និងប្រាក់ចំណូល

៣-គោលបំណងបន្ទាន់ និងផលប្រយោជន៏ពិតជាមានទំនាក់ទំនងបែបតក្ក ជាមួយលទ្ធផល និងសកម្មភាព ក៏ប៉ុន្តែវិសាលភាពនៃ គោលបំណងនោះវាធំធេង ដែលយើងពុំអាចមានលទ្ធភាពក្នុងការវាយតម្លៃបានឡើយ ព្រោះគ្មានទិន្នន័យមូលដ្ឋាន

គ្រប់គ្រាន់ ។
៤-ជារួមអនុកិច្ចសន្យាបានសម្រេចនូវស្ថានភាពចុងក្រោយ មានទំនាក់ទំនងទៅនឹងលទ្ធផល និងសកម្មភាព ។ វាបានឆ្លុះបញ្ចាំងនូវសមិទ្ធផលដូចជា ការផ្តល់នូវចំណេះដឹង សេវា និងការអនុវត្តន៏ជាក់ស្តែងនៅមូលដ្ឋាន ប៉ុន្តែវាមិនបានឆ្លុះបញ្ចាំងនូវស្ថានភាពចុងបញ្ចប់ឬផលប៉ះពាល់ដែលអាចកើតមានឡើងក្នុងកម្រិតប្រជាជន និងសហគមន៏ទេព្រោះវាគ្មានភស្តុតាង ច្បាស់លាស់ណាមួយ ដើម្បីបង្ហាញថាតើក្រុមគោលដៅបានយកចំណេះដឹង និងជំនាញ ដែលពួកគេទទួលបានទៅធ្វើជាប្រយោជន៏ក្នុងការធ្វើឱ្យប្រសើរ ឡើងនូវជីវភាពរស់នៅរបស់ពួកគាត់បន្តទៀត ឬយ៉ាងណា ។
៥-អនុកិច្ចសន្យាពិតជាបានចូលរួមចំណែក ក្នុងការសម្រេចនូវគោលបំណងបន្ទាន់ ដោយសារកសិករបានអនុវត្តបច្ចេកទេសថ្មីដែលទទួលបានពីវគ្គបណ្តុះបណ្តាល, ការបង្ហាញផលិតផលកសិកម្ម និងចំណូលគ្រួសាររបស់ពួកគាត់ មានការកើនឡើង ទោះជាក្នុងកម្រិត និងដែនកំណត់ក៏ដោយ ។
៦-អនុកិច្ចសន្យានេះ ពិតជាមានភាពពាក់ព័ន្ធ ប្រសិទ្ធិភាព និងប្រសិទ្ធិផល ទាក់ទងនឹងធនធាន ដែលបានប្រតិបត្តិ និងគ្រប់គ្រងទូទៅ ។ ប៉ុន្តែទោះជាយ៉ាងណា គុណភាពនៃការរៀបចំអនុកិច្ចសន្យាគួរតែត្រូវកែលំអដូចខាងក្រោម :

ក-បរិយាយឱ្យបានច្បាស់លាស់ និងអាចវាស់វែងបាននូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា និងគោលបំណងបន្ទាន់

ខ- ការប្រើប្រាស់សូចនាករជោគជ័យធៀបនឹងទិន្នន័យមូលដ្ឋាន។

**សេចក្តីសន្និដ្ឋាន :**

១) លទ្ធផល និងអត្ថប្រយោជន៏ ដែលបានពីការអនុវត្តន៏អនុកិច្ចសន្យាជាប្រយោជន៏សម្រាប់សហគមន៏ មានភស្តុតាងជាច្រើនបានបង្ហាញអោយឃើញនៅពេលក្រុមការងារចុះដល់មូលដ្ឋាន ហើយក៏ត្រូវបានទទួលការសារទរពីអ្នកទទួលផល និងមិនទទួលផលនៅក្នុងឃុំដែលបានទទួលគម្រោងផងដែរ។ ឧទាហរណ៏ការបង្កើននូវផលិតកម្មបន្លែ និងលទ្ធផលដែលបានមកពីការប្រើប្រាស់បន្លែនៅក្នុងគ្រួសារ ការសន្សំសំចៃ និងការកើនឡើងនូវប្រាក់ចំណូលក្នុងគ្រួសារ ជាលទ្ធផលសម្រេចបានពីវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ នៅក្នុងអនុកិច្ចសន្យា។ អ្វីដែលគួរកត់សំគាល់ គឺពួកគាត់នៅតែបន្តសកម្មភាពទាំងនោះជាប់រហូតមក ទោះបីជាគម្រោងបញ្ចប់ទៅជាង១ឆ្នាំហើយក្តី។ ម្យ៉ាងវិញទៀត តម្រូវការវគ្គបណ្តុះបណ្តាល ស្រដៀងគ្នានេះបាន កើតឡើងបន្ទាប់ពីការអនុវត្តន៏សកម្មភាពគម្រោង ។
២) គួរមានការបន្តការគាំទ្រ ក៏ដូចជាការពង្រីកសកម្មភាពគម្រោងរបៀបនេះបន្តទៀត។
៣) ទោះបីសកម្មភាពមានការឆ្លើយតបបានល្អយ៉ាងណាក៏ដោយ ប៉ុន្តែដើម្បីធ្វើអោយសម្រេចបាននូវអត្ថប្រយោជន៏ ក្នុងកំរិតខ្ពស់ ភ្នាក់ងារអនុវត្តន៏គម្រោងគួរធ្វើការជ្រើសរើសអ្នកទទួលផលអោយបានសមស្រប ។
៤) ដើម្បីពង្រឹងនូវគុណភាព និងភាពទាក់ទងរបស់គម្រោង គួរមានការបរិយាយអោយបានច្បាស់លាស់ នូវស្ថានភាពចុងបញ្ចប់ នៃកិច្ចសន្យា និងគោលបំណងបន្ទាន់របស់គម្រោង ក៏ដូចជាពង្រឹងនូវទំនាក់ទំនងតក្ក រវាងធាតុខាងលើទៅនឹងលទ្ធផល ។
៥) ផ្នែករដ្ឋបាល និងគ្រប់គ្រងអនុកិច្ចសន្យា គួរធ្វើការវាយតម្លៃគម្រោងស្រដៀងគ្នានេះអោយបាន ១ ឬ ២ អនុកិច្ចសន្យាជាប្រចាំ ។

៦) ការគ្រោងកាលវិភាគនៃការអនុវត្តន៍អនុកិច្ចសន្យាគួរត្រូវបានគិតគូឱ្យបានល្អិតល្អន់ និងជាក់លាក់ ចៀសវាងគម្លាតខ្លាំងពេករវាងផែនការ និងការអនុវត្តន៍ជាក់ស្តែង ។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំគ.ជ.អ.ប បានផ្តល់ថវិកាតាមរយៈគ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យដើម្បីអនុវត្តសកម្មភាព និងគម្រោងដែលគាំទ្រ ដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈ ជាប្រព័ន្ធមិនបានអនុវត្តទេកាលពីពេល កន្លងមក ដោយមកពីហេតុផលជាច្រើន។ នៅក្នុងឆ្នាំ ២០១០ ជាមួយនឹងការគាំទ្រផ្នែកថវិកា និងបច្ចេកទេស ពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យា គ.ប្រ នៃ គ.អ.ជ.ខ ក្នុងការអនុវត្តន៍ការវាយតម្លៃអនុកិច្ចសន្យា ដែលបានរៀបចំរួមគ្នាជាមួយភ្នាក់ងារអនុវត្តន៍ ដែលមានលេខ: 03/AGR/0901-00(NRML) ***គាំទ្រគម្រោងផ្សព្វផ្សាយបច្ចេកទេសកសិកម្មសមស្រប*** ដំណើរការលទ្ធផលដែលបានរកឃើញ និងការសន្និដ្ឋាន នៃការវាយតម្លៃត្រូវបានកត់ត្រា ហើយនឹងបង្ហាញតាមរយៈរបាយការណ៍ស្តីពីការវាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

គោលបំណងបន្ទាន់ របស់អនុកិច្ចសន្យានេះគឺ ផ្សព្វផ្សាយ និងបញ្ជ្រាបបច្ចេកទេសកសិកម្មសមស្រប ដោយជំរុញ និងលើកទឹកចិត្តកសិករ ឱ្យទទួលបានចំណេះដឹង និងបទពិសោធន៍ជាក់ស្តែងនានា អំពីការធ្វើកសិកម្មសមស្រប ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណងគឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូលដោយផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និងតម្លាភាព។ ដូច្នេះ ទំហំនៃការវាយតម្លៃមានដែនកំណត់ តាមទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខ័ណ្ឌការងារនៃការវាយតម្លៃ។ គោលបំណងនៃការវាយតម្លៃគឺ :

**ក)** ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និងចំណុចខ្សោយធៀបទៅនឹងលទ្ធផលគោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំងកត់ត្រានូវចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត ។

**ខ)** ដើម្បីពង្រឹងរបៀបធ្វើការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្តន៍។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និង ការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើ :

១) ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំណត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធដែលមាននៅក្នុងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃគ.ប្រ និងភ្នាក់ងារអនុវត្តន៍ ។

២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់៧រូបមាន : អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផលផ្ទាល់ និង មិនផ្ទាល់២នាក់ និងអ្នកពាក់ព័ន្ធ ២នាក់ ។ ការពិគ្រោះយោបល់នេះបានផ្តោតជាមួយនឹងមន្ត្រីបង្គោលទៅលើបញ្ហាយេនឌ័រ និងគ្រប់គ្រង ធនធានធម្មជាតិ សម្រាប់បញ្ហាពាក់ពន្ធ័វិស័យខាងលើ ។

៣) វិធីសាស្ត្រចុះពិនិត្យតំបន់អនុវត្តន៍គម្រោង និងសង្កេតមើលសកម្មភាព ពិភាក្សាក្រុម និងករណីសិក្សា។

៤) ចុះពិនិត្យតំបន់អនុវត្តន៍គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់ ។

៥) វិភាគទិន្នន័យនិងបកស្រាយ: ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់ ។

៦) ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ ដោយភ្នាក់ងារអនុវត្តន៍និងអ្នកពាក់ព័ន្ធតាមរយៈព័តិមាន ត្រឡប់ដែល ទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើង នាថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ ២០១០ ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យ មកពីខាងក្រៅទេ ។ ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងដោយ គ.ប្រ និងអ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយ ការប្រឹងប្រែងត្រូវធ្វើឡើងដើម្បី ធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត។

២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិតៈ វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោងនៅពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និងបទពិសោធន៍ពីមុនមក។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណងសំខាន់គឺដើម្បី **"រៀនធ្វើ ដោយការអនុវត្តផ្ទាល់"។** អ្នកវាយតម្លៃបានទទួលការគាំទ្រដោយមានគោលការណ៍ការណែនាំ ឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ ។

៣) បញ្ហាប្រឈមក្នុងផ្នែកទី៣នៃអនុកិច្ចសន្យា : ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និងជោគជ័យទេ ។ ម្យ៉ាងទៀត ទំនាក់ទំនងសង្ខេបតាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់ មិនត្រូវបានបង្ហាញឱ្យបានច្បាស់ លាស់ ហើយទំនាក់ទំនងទាំងនោះមិនសូវស៊ីសង្វាក់គ្នាទេ ។

៤) ដោយយើងមិនមានសូចនាករបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ **"គោលដៅអភិវឌ្ឍន៍"** ដែលជាកម្រិតអត្ថប្រយោជន៍ទៅលើគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត **"គោលបំណង"** ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ ។

៥)ដោយសាពេលវេលាធនធាន និងថវិកាមានកំណត់យើងមិនអាចធ្វើការវាយតម្លៃលម្អិតទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ ។ យើងអាចវាយតម្លៃតែទៅលើសកម្មភាពវគ្គបំពាក់បំប៉នសាលារៀនអាយ.ភី.អឹម ដំណាំបន្លែ ដែលជាលទ្ធផល ទី១ គឺការបង្ហាញផ្នែកក្សេត្រសាស្ត្រលើដំណាំបន្លែនៃអនុកិច្ចសន្យារបស់មន្ទីរកសិកម្ម ។ ការវាយតម្លៃត្រូវបានរៀបចំការងារ លំអិត តាមរយៈការសម្ភាសន៍ស៊ីជម្រៅ ក្រុមពិភាក្សា និងការចុះពិនិត្យតំបន់អនុវត្តគម្រោងដោយផ្ទាល់ ។

៦)ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា មិនអាចធ្វើទៅបានទេ ព្រោះចំណុច **គ** នៃផ្នែកទី៣ក្នុងឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ឬមិនពេញលេញ ។ ការងារនេះនឹងកាន់តែមានសុពលភាព និងពោពេញទៅដោយព័ត៌មានបើសិនជាចំណុចដែលបានរៀបរាប់ខាងលើនេះត្រូវបានដោះស្រាយ ។

**<u>ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និងបដិសេធន៍:</u>**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ 03/AGR/0901-00 (NRML) គាំទ្រគម្រោងផ្សព្វផ្សាយបច្ចេកទេស កសិកម្មសមស្រប និងដែនកំណត់ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌនៃការវាយតម្លៃនេះ ។

២) ការវាយតម្លៃនេះលម្អិតតែទៅលើការបង្ហាញផ្នែកក្សេត្រសាស្ត្រ (បន្លែ,ដំណាំ) ដែលជាលទ្ធផល និងវត្ថុបំពាក់បំប៉នសាលារៀន **អាយ.ភី.អឹម** ដំណាំបន្លែ ដែលជាសកម្មភាពនៃអនុកិច្ចសន្យា ។

៣) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃទៅលើភ្នាក់ងារអនុវត្តន៍ ភ្នាក់ងារដែលពាក់ព័ន្ធគម្រោង និងការវាយតម្លៃទៅលើ គ.ប្រ នៃគ.អ.ជ.ខ និង គ.ជ.អ.ប ទេ ។

ហេតុដូច្នេះ របាយការណ៍នៃការវាយតម្លៃលទ្ធផល ដែលបានរកឃើញ និងអនុសាសន៍ដែលបានលើកឡើង ត្រូវពិនិត្យ ដោយប្រយោលទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ ។

# ២_លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១)

លទ្ធផលទី១: ការរីកចំរើនជាក់ស្តែងធៀបនឹងផែនការ (ដូចរៀបរាប់ក្នុងផ្នែកទី ៣ នៃអនុកិច្ចសន្យា : ការបរិយាយអំពីកិច្ចសន្យា)

*លទ្ធផលទី១ :ការបង្ហាញផ្នែកក្សេត្រសាស្ត្រ (ឈើហូបផ្លែ ស្រូវ បន្លែ ដំណាំ)*

**ផ្នែក-ក ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ**

| ល.រ<br>(១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា<br>(២) | អ្វីដែលសម្រេចបានជាក់ស្តែង<br>(៣) |
|---|---|---|
| ១.១ | - ប្រជុំជ្រើសរើសកសិករសាលារៀន **អាយ.ភី.អឹម** បន្លែ មានចំនួន ៤ប្រជុំ<br>- កសិករត្រូវជ្រើសរើស ចូលរួមចំនួន ៤៨នាក់ | - បានរៀបចំប្រជុំបានចំនួន ៤លើក<br>- កសិករចូលរួមចំនួន ៤៨នាក់ ស្រី ១១ នាក់ |
| ១.២ | - វគ្គបំពាក់បំប៉នសាលារៀន **អាយ.ភី.អឹម** ដំណាំបន្លែ ៤0វគ្គ | - វគ្គបំពាក់បំប៉នសាលារៀន **អាយ.ភី.អឹម** ដំណាំបន្លែ ដំណើរការបាន ៤0វគ្គ |
| ១.៣ | - រៀបចំទិវាបិទសាលារៀន អាភីអ៊ឹម ដំណាំបន្លែ ៤ទិវា | - បានរៀបចំទិវាបិទសាលារៀន **អាយ.ភី.អ៊ឹម** ដំណាំបន្លែ ៤ទិវា |
| ១.៤ | - ប្រជុំជ្រើសរើសកសិករសាលារៀនប្រពលវប្បកម្មដំណាំស្រូវ តាមគោលការណ៍ធម្មជាតិ (**ប.វ.ស**) ចំនួន ៨សាលា<br>- កសិករត្រូវជ្រើសរើសចូលរួមចំនួន ៩៦នាក់ | - បានប្រជុំជ្រើសរើសកសិករ ចំនួន ៨លើក<br>- កសិករត្រូវជ្រើសរើសចូលរួមចំនួន ៩៦នាក់ ស្រី ៣៥ នាក់ |
| ១.៥ | - វគ្គបំពាក់បំប៉នកសិករ សាលារៀន (**ប.វ.ស**) សរុបចំនួន ១២៨វគ្គ | - វគ្គបំពាក់បំប៉នកសិករ សាលារៀន (**ប.វ.ស**) សរុបចំនួន ១២៨វគ្គ |

| | | |
|---|---|---|
| ១.៦ | - ទិវាបិទវគ្គសាលារៀន (ប.រ.ស) ចំនួន ៥ទិវា | - ទិវាបិទវគ្គសាលារៀន (ប.រ.ស) ចំនួន ៥ទិវា |

## ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និងសកម្មភាពនានា តាមផែនការដែលបានគ្រោងទុក។ អ្នកចូលរួមទាំងអស់នៅក្នុងក្រុមពិភាក្សាដែលជាសិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែនោះបានរាយការណ៍ថា ពួកគេរីករាយសប្បាយចិត្តក្រៃលែងដោយបានទទួលនូវចំណេះដឹង និងជំនាញ ដែលទាក់ទងទៅនឹងបច្ចេកទេសដាំបន្លែ ដែលកាលពីមុនពួកគាត់ប្រកបរបរដំណាំបន្លែនេះតែតាមទំលាប់ត។គ្នា ដោយមិនសូវយកចិត្តទុកដាក់ក្នុងការជ្រើសរើសពូជល្អ។ ហើយជាងនេះ ភាគច្រើនបានប្រើប្រាស់ថ្នាំពុល និងជីគីមីតាមការដឹងត។គ្នាធ្វើអោយមានការប៉ះពាល់ ដល់សុខភាពមនុស្ស សត្វ និងធ្វើអោយដីកាន់តែចុះអន់ថយគុណភាពជាលំដាប់។ អ្វីដែលគួរអោយចាប់អារម្មណ៍នោះគឺថា ពួកគាត់នៅចាំទ្រឹស្តីបានច្រើនពីវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ ទោះបីជាវគ្គបានបញ្ចប់តាំងពីដើមឆ្នាំ២០០៩ក៏ដោយ។ សិក្ខាកាមភាគច្រើនចូលចិត្តវិធីសាស្ត្របណ្តុះបណ្តាល និងអកប្បកិរិយារបស់អ្នកបណ្តុះបណ្តាល។ វិធីសាស្ត្រផ្សេង។ ជាច្រើនត្រូវបានប្រើប្រាស់នៅក្នុងវគ្គបណ្តុះបណ្តាល រួមមានបំផុសគំនិត រូបភាព និងការអនុវត្តន៍ជាក់ស្តែង ដោយផ្សារភ្ជាប់ទៅនឹងទ្រឹស្តី។ អ្នកបណ្តុះបណ្តាលអាចបន្សាំខ្លួនទៅនឹងបរិបទនៅសហគមន៍បានល្អ ដែលជាហេតុធ្វើឱ្យសិក្ខាកាម ចូលរួមយ៉ាងសកម្មក្នុងវគ្គបណ្តុះបណ្តាលនេះ ។ សរុបសេចក្តីមកវគ្គបណ្តុះបណ្តាលនេះ មានភាពទាក់ទងទៅនឹងតម្រូវការរបស់សិក្ខាកាម និងសហគមន៍របស់គាត់។ អ្វីដែលសំខាន់ទៀតនោះ អ្នកចូលរួមនៅក្នុងការពិភាក្សាក្រុម បានគូសបញ្ជាក់ថា តាមរយៈចំណេះដឹងចំណេះធ្វើ និងបទពិសោធន៍ដែលកសិករទទួលមកនោះបានលើកទឹកចិត្តកសិករឱ្យយកទៅអនុវត្តតាម និងកែប្រែទំលាប់មួយចំនួន ដែលមិន មែនជាវិធីសាស្ត្រសមស្របនៅក្នុងការដាំដុះដំណាំរបស់ពួកគាត់ និងរួមចំណែកធ្វើអោយជីវភាពរបស់គាត់កាន់តែប្រសើរ ។ ជាងនេះទៅទៀត បានធ្វើឱ្យមានការចាប់អារម្មណ៍កាន់ តែខ្លាំងឡើងពី កសិករក្រៅគម្រោងក្នុងការទទួលយកបច្ចេកវិទ្យាទៅអនុវត្តតាមផងដែរ។ ក៏ប៉ុន្តែ តាមរយៈការជ្រើសរើសកសិករជាក្រុមគោលដៅ បានពិនិត្យឃើញថា កសិករ ភាគច្រើនមានកំរិតជីវភាពមធ្យមនៅក្នុងភូមិ ហើយប្រកបមុខរបរជាអ្នកដាំដំណាំបន្លែជាយូរមកហើយដែរ មានន័យថា មិនទាន់បានផ្តោតទៅលើតែកសិករក្រីក្រមិនទាន់មានមុខរបរ នៅឡើយទេ ។

## *លទ្ធផលទី២:កម្មវិធីបង្កើនគុណភាពដី*

## ផ្នែក-ក ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ២.១ | ប្រជុំជ្រើសរើសកសិករ ធ្វើរោងសន្សំជីធម្មជាតិ ៤ប្រជុំ | - មានការប្រជុំចំនួន ៤លើក ជ្រើសរើសបានកសិករចំនួន ៦0នាក់ ស្រី ២0នាក់ ក្នុងចំណោមកសិករ ១៤0នាក់ស្រី ៦២នាក់ ដោយជ្រើសរើសចេញពី ភូមិត្រពាំងត្នោត ឃុំស្រមរ ស្រុកជើងព្រៃ ភូមិតាំងរលៀង ឃុំមេព្រីង ស្រុកបាធាយ និងភូមិដូងភូមិទន្លេស ឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ។ |
| ២.២ | បង្រៀនកសិករ និងរៀបចំធ្វើរោងជីកំប៉ុស្ត ចំនួន ១៦វគ្គ | - កសិករចំនួន ៦0នាក់ ស្រី ២0នាក់ បានទទួលការបណ្តុះបណ្តាលក្នុងវគ្គទាំង ១៦ |

## ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

| |
|---|
| ផ្នែកលើរបាយការណ៍រីកចំរើន បានពិនិត្យឃើញថា សកម្មភាពដែលបានគ្រោងក្នុងលទ្ធផលទី ២ នេះ បានអនុវត្តចប់សព្វគ្រប់ និងជោគជ័យ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏នៅមានភាពយឺតយ៉ាវ នៃការអនុវត្តន៍ផងដែរ ដោយគ្រោងក្នុងកាលវិភាគអនុវត្តស្ថិតក្នុងខែ មីនា និង មេសា តែការអនុវត្តន៍ជាក់ស្តែង គឺពន្យារហួតដល់ខែ មិថុនា ទៅវិញ ។ **ដោយសារតែការពិនិត្យឯកសារតែលើរបាយការណ៍ប៉ុណ្ណោះ ដូច្នេះក្រុមការងារមិនអាចវាយតម្លៃគុណភាព នៃលទ្ធផលនេះបានលម្អិតទេ ។** |

*លទ្ធផលទី៣: ការបង្ហាញការចិញ្ចឹមសត្វ ( ជ្រូក មាន់ ចំណីសត្វ)*

## ផ្នែក-ក ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ

| ល.រ<br>(១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា<br>(២) | អ្វីដែលសម្រេចបានជាក់ស្តែង<br>(៣) |
|---|---|---|
| ៣.១ | ប្រជុំជ្រើសរើសកសិករ ដើម្បីបង្ហាញការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ ចំនួន ៣ប្រជុំ | - បានប្រជុំ ចំនួន ៣ លើក=១00% |
| ៣.២ | វគ្គបំពាក់បំប៉នកសិករ អំពីសាលារៀនចិញ្ចឹមជ្រូក និងការធ្វើបង្ហាញ ចំនួន ៣0វគ្គ | - វគ្គបំប៉នកសិករចិញ្ចឹមជ្រូក ចំនួន ៣0 វគ្គ =១00% |
| ៣.៣ | រៀបចំទិវាបិទសាលារៀនចិញ្ចឹមជ្រូកជាលកណៈគ្រួសារ ៣ប្រជុំ | - រៀបចំទិវាបិទសាលារៀនចិញ្ចឹមជ្រូកចំនួ ៣ប្រជុំ=១00% |
| ៣.៤ | ប្រជុំផ្សព្វផ្សាយ និងជ្រើសរើសកសិករធ្វើឡជីវឧស្ម័ន ១៤ប្រជុំ | - ប្រជុំផ្សព្វផ្សាយ និងជ្រើសរើសកសិករធ្វើឡជីវឧស្ម័នចំនួន ១៤ ប្រជុំ=១00% |
| ៣.៥ | គាំទ្របច្ចេកទេសធ្វើឡជីវឧស្ម័ន ៤២លើក | - គាំទ្របច្ចេកទេសធ្វើឡជីវឧស្ម័ន ៤២ លើក=១00% |

## ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

**ក្រុមការងារមិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនៃអនុកិច្ចសន្យានេះបានលម្អិតទេ។** ក្រុមការងារបានពិនិត្យលើរបាយការណ៍រីកចំរើនបានឱ្យឃើញថា ការគ្រោងកាលវិភាគអនុវត្ត របស់កិច្ចសន្យាគឺចាប់ពីខែមិថុនា រហូតដល់ខែ វិច្ឆិកា ក៏ប៉ុន្តែការអនុវត្តន៏វិញ បានចាប់ផ្តើមពីខែ កក្កដា នឹងបញ្ចប់ ខែវិច្ឆិកា ។

## ២.២. ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម

### ផ្នែក-កៈ <u>ការសម្រេចបាននូវស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា</u>

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា (១) | ស្ថានភាពជាក់ស្តែងនៅពេលបញ្ចប់អនុកិច្ចសន្យា (២) |
|---|---|
| - កសិករចំនួន ៤៨នាក់, ស្រី ១១នាក់ មកពី ២ ឃុំ ក្នុងស្រុកគោលដៅ ២ បានទទួលការបណ្តុះបណ្តាលសាលារៀន **អាយ.ភី.អឹម** ដំណាំបន្លែ ។ | - សាលារៀន **អាយ.ភី.អឹម** ដំណាំបន្លែចំនួន ៤សាលា ត្រូវបានបណ្តុះបណ្តាលដល់កសិករ។ កសិករចំនួន ៤៨នាក់ ក្នុងនោះមានស្រី ១១នាក់ មកពី២ឃុំ ក្នុងស្រុកគោលដៅ២។<br>- អ្នកចូលរួមភាគច្រើន នៅក្នុងការពិភាក្សាក្រុម បានរាយការណ៍ថា ពួកគាត់ពេញចិត្តនឹងវគ្គបណ្តុះបណ្តាល និងការធ្វើបង្ហាញ ដំណាំបន្លែ (សណ្តែកកួរ) នេះណាស់ ។ ពួកគាត់បញ្ជាក់បន្ថែម ពីលើនេះទៀតថា វគ្គបណ្តុះបណ្តាលដំណាំបន្លែនេះពិតជាឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគាត់ និងសហគមន៍ ដោយសារតែពីមុនពួកគាត់បានប្រកបរបរ នេះជាយូរមកហើយ តែពួកគាត់នៅខ្វះខាតបច្ចេកទេស ដាំដុះតែប៉ុណ្ណោះ ។<br>- ចំណុចគួរឱ្យកត់សំគាល់គឺ កសិករដែលបានបណ្តុះបណ្តាលទាំងនោះបានចែករំលែកចំណេះដឹងដែលបានទទួលទាំងនោះទៅដល់កសិករផ្សេងៗទៀតនៅក្បែរផ្ទះ និងក្នុងភូមិរបស់គាត់ ដែលស្ថិតនៅក្រៅគម្រោងហើយ។<br>- មានការចាប់អារម្មណ៍កាន់តែខ្លាំងឡើង ពីកសិករក្រៅគម្រោងក្នុងការទទួលយកបច្ចេកវិទ្យាដែលបានផ្សព្វផ្សាយដល់កសិករក្នុងគម្រោង និងយកទៅអនុវត្តតាមផងដែរ។<br>- នៅក្រោយពេលបណ្តុះបណ្តាល យើងសង្កេតឃើញថា កសិករភាគច្រើនបានបង្កើនការដាំបន្លែក្នុងគ្រួសាររបស់គាត់កាន់តែកើនឡើង មានអ្នកខ្លះបានកាប់ដើមស្វាយចន្ទី |

| | |
|---|---|
| | ចោល ដើម្បីងាកមកដាំដំណាំបន្លែវិញ ។<br>- បានជួយកសិករឱ្យចេះប្រើប្រាស់ ជីគីមីគួបផ្សំជាមួយជីធម្មជាតិ និងថ្នាំសំលាប់សត្វល្អិតឱ្យសមស្របតាមបទដ្ឋានបច្ចេកទេសសំដៅការកាត់បន្ថយឥទ្ធិពលជាអវិជ្ជមានដល់បរិស្ថានធម្មជាតិ មនុស្ស និងសត្វផងដែរ ។<br>- ផ្អែកលើបទពិសោធន៍ជាច្រើនឆ្នាំ ចំពោះគ្រូបង្រៀន របស់មន្ទីរបានយកចិត្តទុកដាក់ខ្ពស់លើការបង្រៀនបច្ចេកទេសដាំដំណាំ និងការអនុវត្តន៍ជាក់ស្តែង ដែលធ្វើឱ្យកសិករងាយយល់ និងទទួលបានចំណេះដឹងទាំងនោះ ។ មិនតែប៉ុណ្ណោះ ក្រោយពីវគ្គត្រូវបានបញ្ចប់មួយរយៈ គ្រូនៅតែបន្តចុះតាមដានសកម្មភាពក្រុមគោលដៅផងដែរ ជាហេតុធ្វើឱ្យពួកគាត់មានឱកាសសាកសួរបន្ថែមនូវចម្ងល់នានាដើម្បីកែលំអរចំណុចខ្វះខាត និងសមត្ថភាពឱ្យកាន់តែប្រសើរឡើង ក្នុងការថែរក្សាផលដំណាំបន្លែរបស់ពួកគាត់ |
| - កសិករចំនួន ៩៦នាក់ បានទទួលការបណ្តុះបណ្តាលសាលារៀនប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិចំនួន ៨សាលា (៨ភូមិ) ។ | - សាលារៀនប្រពលវប្បកម្មដំណាំស្រូវ តាមគោលការណ៍ធម្មជាតិចំនួន ៨សាលា (៨ភូមិ) |
| - កសិករចំនួន ៦០នាក់ស្រី ១៨នាក់ ប្រុស ៤២ នាក់ បាន ធ្វើការបណ្តុះបណ្តាលសាលារៀនជីកំប៉ុស្តចំនួន ៤សាលា | - កម្មវិធីបង្កើនគុណភាពដី សាលារៀនជីកំប៉ុស្តចំនួន ៤សាលា ត្រូវបានធ្វើការបណ្តុះបណ្តាល ។ |
| - ការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មចំនួន ១០លើក | - ការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មចំនួន ៦លើក |
| - កសិករចំនួន ៣៦នាក់ ស្រី ៣០នាក់ ប្រុស ៦នាក់ បានបណ្តុះបណ្តាលការចិញ្ចឹមជ្រូកចំនួន ៣បង្ហាញ ។ | - បង្ហាញការចិញ្ចឹមជ្រូកចំនួន ៣បង្ហាញ |
| - កសិករចំនួន ១៤គ្រួសារ បានទទួលបច្ចេកទេសធ្វើឡជីវឧស្ម័ន ។ | - បង្ហាញបច្ចេកទេសធ្វើឡជីវឧស្ម័នចំនួន ១៤បង្ហាញ |

## ផ្នែក-ខ: ការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា

| ធាតុនៃគោលបំណងបន្ទាន់ (១) | ការសម្រេចបានជាក់ស្តែង នៅពេលបញ្ចប់ អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| ផ្សព្វផ្សាយ និងបញ្ជ្រាបបច្ចេកទេសកសិកម្មសមស្រប ដោយជំរុញនិងលើកទឹកចិត្តកសិករឱ្យទទួលបានចំណេះដឹង និងបទពិសោធន៍ជាក់ស្តែងនានា អំពីការធ្វើកសិកម្ម សមស្រប ។ | គោលបំណងបន្ទាន់បានចែងនេះមានកម្រិតខ្ពស់ ដែលធ្វើឱ្យពិបាកវាស់វែងនៅចុងបញ្ចប់នៃអនុកិច្ចសន្យា ។ ទោះបីគេរំពឹងទុកថា លទ្ធផល និងសកម្មភាព និងចូលរួមទៅក្នុងគោលបំណងបន្ទាន់ ប៉ុន្តែ ដោយការ ពិនិត្យលើឯកសារ និងវិធីសាស្ត្រវាយតម្លៃតាមបែប គុណភាព គេមិនអាចធ្វើការវាយតម្លៃថា តើគោលបំណងបន្ទាន់នេះ សម្រេចបានកម្រិតណានោះឡើយ ។ |

## ផ្នែក-គ: ការវាយតម្លៃផលប្រយោជន៍ដែលទទួលបាន :

តាមរយ:ការពិភាក្សាក្រុម អ្នកចូលរួមបានបង្ហាញថា ពួកគាត់មានការពេញចិត្តចំពោះផលប្រយោជន៍ដែលអនុកិច្ចសន្យានេះ សម្រេចបាន ជាពិសេសចំណេះដឹង និងបច្ចេកទេសថ្មីទៅលើការដាំដុះបន្លែ។ ពួកគាត់បានទទួលស្គាល់ថា វាមានសារប្រយោជន៍ សម្រាប់គ្រួសារគាត់ដែលចេះប្រើប្រាស់ជីគីមីគួបផ្សំជាមួយជីធម្មជាតិ និងថ្នាំសំលាប់សត្វល្អិតអោយសមស្របតាមបទដ្ឋាន បច្ចេកទេសសំដៅការកាត់បន្ថយឥទ្ធិពលជាអវិជ្ជមានដល់បរិស្ថានធម្មជាតិ មនុស្ស និងសត្វផងដែរ។ ដូច្នេះការអនុវត្តន៍តាម បច្ចេកទេសថ្មីនឹងបន្តជាប្រចាំនៃវដ្តដំណាំ ហើយបង្កើតបានជាទំលាប់មួយ ជំនួសអោយទំលាប់ចាស់ សម្រាប់ផ្ទេរអោយកូនចៅ និងសាច់ញាតិនៅជំនាន់ក្រោយ។ថែមទៀត។ ជាពិសេសទៀតនោះ ពួកគាត់អាចផលិតបន្លែដើម្បីផ្គត់ផ្គង់ក្នុងគ្រួសាររបស់គាត់ នឹងអាចបង្កើនប្រាក់ចំណូលបន្ថែមក្នុងគ្រួសារកាន់តែប្រសើរ។

# ករណីសិក្សា

## ករណីសិក្សាទី១: អ្នកទទួលផលពីអនុកិច្ចសន្យាមន្ទីរកសិកម្ម លើគម្រោង ប្រពលវប្បកម្មដំណាំបន្លែ

បន្ទាប់ពីចូលរួមក្នុងគម្រោងអភិវឌ្ឍន៍កសិកម្មរបស់ គ.អ.ជ.ខ របស់ខេត្តកំពង់ចាមក្នុងឆ្នាំ ២០០៩។ លោក ភន់ ផុន បាននិយាយថា: "ជីវភាពរបស់គ្រួសារខ្ញុំមានភាពប្រសើរឡើងជាងមុន ឆ្ងាយណាស់ ចាប់តាំងពីខ្ញុំបានចូលរួមវគ្គបណ្តុះបណ្តាល ដំណាំបន្លែ" ។

លោក ភន់ ផុន ជាកសិករ អាយុ ៤៦ឆ្នាំ រស់នៅភូមិគៀនរូង សង្កាត់វិហារលួង ខេត្ត កំពង់ចាម ។ គាត់បាននិយាយថា ការបណ្តុះបណ្តាលនេះពិតជាមានសារៈសំខាន់ដល់គ្រួសារគាត់ខ្លាំងណាស់ ពីព្រោះគាត់ បានទទួលចំណេះដឹង និងជំនាញថ្មីៗជាច្រើន អំពីការដាំបន្លែ ដែលពីមុនមកធ្លាប់តែដាំតាមទំលាប់តគ្នា ។ លោកបញ្ជាក់: "សណ្តែកដែលខ្ញុំបានដាំនោះ ឥឡូវបានឡើងទ្រើង និងមាន ក្តិបស្នេកស្កុះ នឹងអាចបេះយកទៅលក់ក្នុង ពេលឆាប់ៗ" ។ ខ្ញុំ បានអនុវត្តទៅតាមបច្ចេកទេសគ្រូបង្រៀន ដោយប្រើតែ ជីធម្មជាតិព្រោះយល់ថា ការប្រើជីគីមីច្រើនពេក នាំឱ្យសណ្តែក របស់ខ្ញុំមានអាយុកាលផ្តល់ផលរយៈពេលខ្លី (ឆាប់ងាប់ដើម) និងបានទិន្នផលតិច ។


លោក ភន់ ផុន និង ភរិយា

មិនត្រឹមតែសណ្តែកទេ! ននោងក៏ខ្ញុំដាំដែរ"។ គួកត់សំគាល់ថា ជីវភាពរបស់ គ្រួសារគាត់មានភាពប្រសើរឡើង ដោយបានចំណូលបន្ថែមពីការលក់បន្លែ ដែលចំណូលពីការលក់បន្លែ នោះបានច្រើនជាងស្រូវទៀត ពីព្រោះផលស្រូវដែលគាត់ដាំ គឺទុកសម្រាប់តែហូបប៉ុណ្ណោះ ពុំបានលក់ដូរ អ្វីឡើយ ។ បំលាស់ប្តូរជាវិជ្ជមានមួយទៀត គឺបានធ្វើអោយ សមាជិកក្នុង គ្រួសារគាត់ដែលធ្លាប់តែទំនេរ នៅចន្លោះរដូវធ្វើស្រែ បែរជាមានការងារប្រកបមុខរបរយ៉ាងមមាញឹកទៅវិញ ។ គាត់បន្តពោលទាំងទឹក មុខញញឹមថា : "ទោះបីជារវល់យ៉ាងណាក៏ដោយ ក៏ខ្ញុំឆ្លៀតឈ្វេងចូលមើលចំការ សណ្តែករបស់ខ្ញុំស្ទើរតែ គ្រប់រង នៅពេលណាខ្ញុំត្រឡប់ពីស្រែវិញ" ។ ចុងបញ្ចប់ គាត់បានបង្ហាញការប្តេជ្ញាចិត្តខ្ពស់ថា នឹងបន្ត សកម្មភាពសួនបន្លែនេះជារៀងរហូត ទោះបីជាគម្រោងបានបញ្ចប់យ៉ាងណាក៏ដោយ។ គាត់និយាយថា : "បើយើងប្រើពូជ ២គីឡូក្រាមគ្រាប់ យើងអាចបានផលបន្ថែមកវិញ ប្រហែលជាង ៤តោន និងអាចរក ចំណូលសល់បាន ១.០០០ដុល្លារ ក្នុងមួយរដូវ (ពេលសណ្តែកមានតម្លៃ ចាប់ពី ១.៥០០រៀលទៅ ២.០០០រៀល)" ។ តែអកុសលឆ្នាំនេះ ថ្លៃសណ្តែកកួរបានតែ ៧០០ ទៅ ១០០០រៀលប៉ុណ្ណោះ ធ្វើឱ្យប្រាក់ចំណូលរបស់ខ្ញុំមានការថយចុះទៅវិញ។

**ករណីសិក្សាទី២: អ្នកមិនទទួលផល ពីកិច្ចសន្យារបស់មន្ទីរកសិកម្មលើគម្រោងប្រពលវប្បកម្មដំណាំបន្លែ**

លោក កាន់ សំណាង អាយុ ៤០ឆ្នាំ ប្រពន្ធឈ្មោះ ឈិត សុខខេង មានកូន ០៤នាក់ (ស្រី ០៣នាក់)។ គាត់រស់នៅភូមិគៀនរូង សង្កាត់វិហារលួង ខេត្តកំពង់ចាម មានមុខរបរធ្វើស្រែចំការ និងរកប្រាក់ចំណូលរួមផ្សំ តាមរយៈការរត់រទេះសេះ ។ គ្រួសារលោក កាន់ សំណាង មិនបានចូលរួម វគ្គបណ្តុះបណ្តាលដំណាំបន្លែ ពីគម្រោងរបស់ គ.អ.ជ.ខ ខេត្តកំពង់ចាម ឡើយ ដោយគាត់ជាប់រវល់ធ្វើស្រែចំការ ម្យ៉ាងទៀតពុំមានដី ដាំបន្លែផង ដែលជាហេតុមិនស្របទៅតាមគោលការណ៍នៃការ ជ្រើសរើស របស់គម្រោងឡើយ។ គាត់និយាយថា: "វគ្គ បណ្តុះបណ្តាល ដំណាំបន្លែនេះ ពិតជាមានសារៈសំខាន់ណាស់ ពីព្រោះ អ្នកជិតខាងរបស់គាត់ ដែលបានចូលរួមវគ្គ បណ្តុះបណ្តាល ទទួលបានចំណេះដឹង និងបច្ចេកទេសក្នុងការ ដាំបន្លែ" ។ លោកបានបញ្ជាក់ថា: "ក្រោយពីការផ្តល់ ចំណេះដឹង ក្នុង ការដាំបន្លែ អ្នកទាំងនោះ បានបង្កើនដីដាំបន្លែ ផលបន្លែ របស់ពួកគេបានកើន ហើយប្រាក់ចំណូលក៏ទទួលបាន ច្រើនជាងមុនដែរ"។ លោកបានបន្តថា : "ជួនកាលខ្ញុំបាន ទៅទិញ បន្លែ ពីពួកគេយកមកហូប ដោយយល់ថាបន្លែ ដែលពួកគេបានដាំនោះ ប្រើតែជីធម្មជាតិគ្មានជាតិពុល ហើយពេលខ្លះ ពួកគេមិនយកកម្រៃពីខ្ញុំទៀតផង ដោយចែកឱ្យមកខ្ញុំយកទៅបរិភោគតែម្តង នេះមកពីពួកគេ សប្បាយចិត្តនឹងបានផលច្រើន..." ។ ជាមួយ គ្នានោះដែរ លោក កាន់ សំណាង មានបំណងចង់ចេះបច្ចេកទេស ដាំបន្លែដែរ ទោះបីជាគាត់ពុំមានដី គ្រប់គ្រាន់សម្រាប់ដាំបន្លែក៏ដោយ ។ លោកបានបញ្ជាក់ថា : "ពេលទំនេរ ខ្ញុំបាន ទៅដេីរលេង ជាមួយអ្នក ដែលបានរៀនសូត្រពីបច្ចេកទេសដាំបន្លែ និងបានសួរនាំអំពី បច្ចេកទេសដាំដុះ ដើម្បីទុក អនុវត្តនៅពេលណា ដែលខ្ញុំមានឱកាសបានដាំបន្លែ" ។ លោកក៏បានធ្វើចំណាប់អារម្មណ៍ផងដែរក្នុងន័យវិជ្ជមាន ចំពោះការផ្តល់ នូវចំណេះដឹងនិងបច្ចេកទេសដាំបន្លែ តាមរយៈ អាយ.ភី.អឹម ដោយលោកបានសង្កត់ធ្ងន់ថា: "ការផ្តល់ នូវចំណេះដឹងសម្រាប់ការដាំបន្លែ ដោយបានប្រើនូវបច្ចេកទេស ត្រឹមត្រូវ មិនប្រើជីគីមីបែបនេះ ពិតជា ធ្វើឱ្យដំណាំទទួលបានផលច្រើន មិនប៉ះពាល់ដល់សុខភាព និងងាយស្រួលរកទីផ្សារទៀតផង "។ ជាចុងក្រោយ លោកបានសំណូមពរឱ្យកម្មវិធី ក៏ដូចជាអង្គការដទៃទៀត បង្កើតឱ្យមានវគ្គរបៀបនេះបន្ថែមទៀត ដើម្បីផ្តល់នូវបច្ចេកទេស ទាំងថ្មី ទាំងចាស់ ទៅដល់គ្រួសារផ្សេងៗទៀត និងដើម្បីជួយអភិវឌ្ឍន៍ដល់ភូមិរបស់ គាត់បន្តទៀត ផងដែរ។



លោក កាន់ សំណាង និង ភរិយា

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

**ផ្នែក-ក: ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅនឹងតំរូវការៈ មន្ទីរវិស័យ មូលដ្ឋាន គ.ជ.អ.ប និងការ កាត់បន្ថយភាពក្រីក្រៈ**

**ពិន្ទុ: ១=ខ្សោយណាស់ , ២=ខ្សោយ , ៣=មធ្យម , ៤=ខ្លាំង , ៥=ខ្លាំងណាស់**

| ល.រ (១) | ធាតុ (២) | ទំនាក់ទំនងតក្កភាព (៣) | បរិយាយច្បាស់លាស់ (៤) | សង្ខេបការវាយតម្លៃ (៥) |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៤ | ៤ | – សកម្មភាពដែលបានលើកឡើងក្នុងអនុកិច្ចសន្យានេះ ពិតជាមានទំនាក់ទំនងតក្ក ជាមួយនឹងលទ្ធផល ។ ជាក់ស្តែងដូចជាលទ្ធផលទី១ (ការបង្ហាញផ្នែកក្សេត្រសាស្ត្រ) កសិករទទួលបានការបណ្តុះបណ្តាល ពីបច្ចេកទេសកសិកម្ម និងការបង្ហាញមានសកម្មភាពជាក់លាក់ ដូចជា វគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ **អាយ.ភី.អឹម** ចំនួន ៤០វគ្គ ស្មើនឹង ៤សាលា ។ វគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវចំនួន ១២៨វគ្គ ស្មើនឹង ៨សាលា ។<br>– សកម្មភាពនីមួយៗ បានសរសេរបង្ហាញច្បាស់លាស់ ដោយមានចំនួនវគ្គបណ្តុះបណ្តាល និងចំនួនកសិករគោលដៅដែលត្រូវចូលរួមពីឃុំ និងស្រុកគ្របដណ្តប់ ។ ចំពោះសកម្មភាពផ្សេងទៀត |

| | | | | |
|---|---|---|---|---|
| | | | | ដែលស្ថិតនៅក្រោមលទ្ធផលបន្តរបន្ទាប់ **(លទ្ធផលទី២និងទី៣) ត្រូវបានសរសេរក្នុងបែបបទដូចគ្នានឹងលទ្ធផលទី១ដែរ ។** |
| ២ | លទ្ធផល | ៥ | ៥ | - លទ្ធផលនីមួយៗ ត្រូវបានសរសេរ បរិយាយច្បាស់លាស់ និងផ្សារភ្ជាប់គ្នាល្អ ដោយបានបំពេញបន្ថែមឱ្យគ្នា ទៅវិញទៅមក ហើយរួមគ្នាឆ្លើយតបទៅនិងគោលបំណងបន្ទាន់ ។ ទោះបីជាយ៉ាងនេះក៏ដោយ លទ្ធផលទាំងនោះនៅមិនអាចធ្វើឱ្យគោលបំណងបន្ទាន់សម្រេចបាននៅឡើយ ។ |
| ៣ | - គោលបំណងបន្ទាន់ | ៤ | ៤ | - ទោះបីគេ រំពឹងទុកថាលទ្ធផល និងសកម្មភាព បានចូលរួមទៅក្នុងគោលបំណងបន្ទាន់ ប៉ុន្តែដោយការពិនិត្យលើឯកសារ និងវិធីសាស្ត្រវាយតម្លៃ តាមបែបគុណភាព គេមិនអាចធ្វើការវាយតម្លៃ ថាតើគោលបំណងបន្ទាន់នេះសម្រេចបានកម្រិតណា នោះឡើយ ។<br>- ពោលគឺវាមានកម្រិតខ្ពស់ពេក ដែលយើងនឹងពិបាកធ្វើការវាស់វែងបាន ។ |
| ៤ | លទ្ធផលអភិវឌ្ឍន៍/ផលប៉ះពាល់រយៈពេលវែងៈ | ៤ | ៤ | - ស្ថានភាពនៅចុងបញ្ចប់ នៃអនុកិច្ចសន្យាមានទំនាក់ទំនងច្បាស់លាស់ ទៅនឹងលទ្ធផល និងសកម្មភាព នៃអនុកិច្ចសន្យា។ ព្រោះថា ស្ថានភាពនោះវាបានឆ្លុះបញ្ចាំង នូវសមិទ្ធផលដែល |

| | | | | |
|---|---|---|---|---|
| ៦ | | | | សម្រេចបាន នៅក្នុងលទ្ធផល ហើយ ស្ថិតនៅក្នុងកម្រឹតតែកសិករគោលដៅ និងសហគមន៍ប៉ុណ្ណោះ ។ប្រការសំខាន់មួយទៀតគឺពុំទាន់មាន ទិន្នន័យណាដែលជាភស្តុតាងអាចបញ្ជាក់ថា ក្រោយពីកសិករទទួលបាន ចំណេះដឹងទាំងអស់នោះ យកទៅអនុវត្ត ធ្វើឱ្យជីវភាពរបស់ពួកគាត់ ប្រសើរឡើងកម្រិតណានោះឡើយ ។ |

## ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខ័ណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារៈ

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.អ.ជ.ខ :** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | នៅមានកម្រិតនៅឡើយ ពោលគឺ ត្រូវការជួយពង្រឹងសមត្ថភាព និងបច្ចេកទេសបន្ថែម ។ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យ ការអនុវត្តន៍ របស់ភ្នាក់ងារអនុវត្តន៍ | ពុំមានការប្រឈម និងឧបសគ្គ ដែលបណ្តាលឱ្យរាំងស្ទះដល់កិច្ចដំណើរការរបស់គម្រោងទេ។ ចំពោះពេលវេលាដែលអនុវត្តគម្រោងមានភាពយឺតយ៉ាវបន្តិចបន្តួច ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា | បានរៀបចំទុកដាក់ទៅតាមប្រភេទឯកសារ និងការកត់ត្រា អនុកិច្ចសន្យាបានត្រឹមត្រូវទៅតាមនីតិវិធី ។ |
| **<u>ពីខាងភាគីអនុវត្តន៍កិច្ចសន្យាៈ</u>** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | មន្ត្រីជំនាញ មានបទពិសោធន៍ និងបច្ចេកទេស គ្រប់គ្រាន់ ។ |
| ៥ | ការអនុវត្តន៍សកម្មភាពទាន់ពេលវេលា និងលទ្ធផល | ការអនុវត្តន៍សកម្មភាព និងលទ្ធផលមិនទាន់ពេលវេលាតាមការគ្រោងទុក ។ |
| ៦ | ការរាយការណ៍ការរីកចំរើន និង ការកត់ត្រាឯកសារ | ត្រឹមត្រូវទៅតាមនីតិវិធី ។ |

| | | |
|---|---|---|
| ៧ | ការគោរពតាមលក្ខខ័ណ្ឌកិច្ចសន្យា | ត្រូវបានគោរពតាមលក្ខខ័ណ្ឌ នៃកិច្ចសន្យា |
| **ទាំងខាង គ.អ.ជ.ខ និងភាគីអនុវត្តកិច្ចសន្យាៈ** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" (ចំណុច-ង ផ្នែកទី៣ ) និងបញ្ហាប្រឈម | ដោយសារមានការយឺតយ៉ាវក្នុងការអនុម័តកិច្ចសន្យា និងថវិកាផ្តល់ឱ្យមានភាពរអាក់រអួលមិនទាន់ពេលវេលាបានជះឥទ្ធិពលដល់ការចាប់ផ្តើមដំណើរការគម្រោង ធ្វើឱ្យមានភាពយឺតយ៉ាវពីដើមឆ្នាំ ។ |
| ៩ | ការបញ្ជ្រាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | ការបញ្ជ្រាបយេនឌ័រ ត្រូវបានលើកកម្ពស់ ។ ជាក់ស្តែងកសិករជាស្ត្រីក្នុងគម្រោងមានប្រមាណជា៣៥% ដែលក្នុងនោះកសិករស្រីជាមេគ្រួសារ ឬមេម៉ាយមានជីវភាពក្រីក្រត្រូវបានផ្តល់អាទិភាពមុនគេ ។ ដោយឡែក ផ្នែកចិញ្ចឹមសត្វ ពិនិត្យឃើញថា មានស្ត្រីស្ទើរតែ១00% បានចូលរួម ។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ ( ចំណុច-ឆ ផ្នែកទី៣) | មានការគ្រប់គ្រងធនធានធម្មជាតិ ដោយសារបានបណ្តុះបណ្តាល អំពីបច្ចេកទេសប្រើប្រាស់ជីធម្មជាតិ ថ្នាំសម្លាប់សត្វល្អិត និងការប្រើប្រាស់ឡជីវឧស្ម័ន សំដៅកាត់បន្ថយការជះឥទ្ធិពលអវិជ្ជមាន ដល់បរិស្ថានធម្មជាតិ មនុស្ស និងសត្វផងដែរ ។ |
| ១១ | ការថែរក្សា (និរន្តភាព) | តាមសកម្មភាពអនុវត្តអនុកិច្ចសន្យា និងបច្ចេកទេសមួយចំនួន ដែលបានផ្តល់តាមរយៈគម្រោង ឃើញថាកសិករភាគច្រើនបានបន្តអនុវត្តគម្រោង បន្ទាប់ពីការបណ្តុះបណ្តាល រហូតមកដល់ពេលក្រុមការងារចុះទៅវាយតម្លៃ ។ ដូច្នេះ គម្រោងត្រូវបានបន្តនិរន្តរភាព និងបានថែរក្សា ។ ជាងនេះទៅទៀត បានធ្វើឱ្យមានការចាប់អារម្មណ៍កាន់តែខ្លាំងឡើង ពីកសិករក្រៅគម្រោងក្នុងការទទួលយកបច្ចេកវិទ្យា ដែលបានផ្សព្វផ្សាយដល់កសិករក្នុងគម្រោង និងយកទៅអនុវត្តតាមផងដែរ ។ |

## ២.៤. សេចក្តីសន្និដ្ឋាន

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | សកម្មភាព និងលទ្ធផលដែលបានគ្រោងទុក ត្រូវបានបញ្ចប់ ស្របតាមផែនការការងារ ។ ភាគីអនុវត្តអនុកិច្ចសន្យា មានសមត្ថភាព បទពិសោធន៍ធ្វើការងារនេះយូរឆ្នាំ និងធនធានគ្រប់គ្រាន់ ដើម្បីអនុវត្តអនុកិច្ចសន្យា ។ |
| ២ | លទ្ធផល និងអត្ថប្រយោជន៍ ដែលបានមកពីការអនុវត្តអនុកិច្ចសន្យា ជាប្រយោជន៍ ដល់សហគមន៍ វាបានឆ្លុះបញ្ចាំងនូវសមិទ្ធផល ដូចជាការផ្តល់នូវចំណេះដឹងផ្សារភ្ជាប់នឹងការអនុវត្តន៍ជាក់ស្តែងនៅមូលដ្ឋាន ដែលនាំឱ្យស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា ត្រូវបានសម្រេចទាំងស្រុងដូចការព្រាងទុក ។ ភស្តុតាងអំពីលទ្ធផល និងផលប្រយោជន៍ ដែលទទួលបានដូចខាងក្រោម នៅតែត្រូវបានសង្កេតឃើញ បន្ទាប់ពីការបញ្ចប់អនុកិច្ចសន្យា ជាយូរមកហើយនោះ ដូចជា:<br>ក) ចំណុចមួយដ៏សំខាន់ ក្នុងការទាក់ទាញការចាប់អារម្មណ៍របស់កសិករ ផ្តោតមកលើបច្ចេកវិជ្ជាកសិកម្ម ដែលបានផ្សព្វផ្សាយ និងបានធ្វើឱ្យប្រសើរឡើង ដល់ការដាំដុះដំណាំរបស់កសិករកាន់តែមានប្រសិទ្ធិភាព និងនិរន្តរភាព ។<br>ខ) ការដាំដុះបន្លែកើនឡើង ហើយការសន្សំសំចៃក្នុងគ្រួសារកើតមាន ក៏ដូចជាធ្វើឱ្យចំណូលក្នុងគ្រួសារកើន ឡើងដោយសារការលក់បន្លែ ។<br>គ) ជាងនេះទៅទៀត បានធ្វើឱ្យមានការចាប់អារម្មណ៍កាន់តែខ្លាំងឡើង ពីកសិករក្រៅគម្រោងក្នុងការទទួលយកបច្ចេកវិទ្យា ដែលបានផ្សព្វផ្សាយដល់កសិករក្នុងគម្រោង និងយកទៅអនុវត្តតាមផងដែរ ។<br>ដូច្នេះ អនុកិច្ចសន្យានេះ បានទទួលនូវនិរន្តភាពក្នុងសកម្មភាពរបស់ខ្លួនក្នុងកម្រិតខ្ពស់ ។ ទោះបីជាយ៉ាងណា ក៏គម្រោងនៅបានចូលរួមចំណែកក្នុងកម្រិតតិចតួច ក្នុងការរួមចំណែកសម្រេចគោលដៅ និងទិសដៅ របស់ គ.ជ.អ.ប " ដោយធានាឱ្យផលិតករយល់ដឹង និងទទួលយកបច្ចេកទេសកសិកម្ម សមស្របធ្វើឱ្យមានសុវត្ថិភាព ផលិតកម្មសត្វ និងដំណាំកសិកម្មគ្រប់ប្រភេទ ឆ្ពោះទៅកំណើនស្បៀងអាហារ ការលើកស្ទួយជីវភាព និងការកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋនៅក្នុងខេត្តកំពង់ចាម ។ |
| ៣ | អនុកិច្ចសន្យានេះមិនបានជួបប្រទះនូវឧបសគ្គ និងបញ្ហាប្រឈមគួរអោយកត់សំគាល់ទេ ។ |

**ចំណុចរៀនសូត្រ:**

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ដូចដែលបានសង្កេតឃើញក្នុងការវាយតម្លៃនេះ ផលប៉ះពាល់របស់អនុកិច្ចសន្យា និងនិរន្តភាព របស់លទ្ធផលនៅក្នុងអនុកិច្ចសន្យាត្រូវបានសម្រេចបានក្នុងកម្រិតខ្ពស់ ដោយអនុកិច្ចសន្យាបានរៀបចំឡើង ឆ្លើយតបទៅនឹងតម្រូវការ ជាអាទិភាពរបស់ក្រុមគោលដៅ និងសហគមន៍ ។ |
| ២ | ការចែករំលែកបទពិសោធន៍ និងចំណេះធ្វើពីគ្រួសារមួយទៅគ្រួសារផ្សេងទៀត បានក្លាយជាទំលាប់ដ៏ល្អមួយ និងបានលើកកម្ពស់ទឹកចិត្តឱ្យពួកគេ យកទៅអនុវត្តតាម និងកែប្រែទំលាប់មួយចំនួន ដែលមិនមែនជាវិធីសាស្ត្រសមស្រប នៅក្នុងការដាំដុះដំណាំ ។ |
| ៣ | ក្នុងគោលបំណងបន្ទាន់នៃអនុកិ្ចសន្យាបានបរិយាយច្បាស់លាស់ ឆ្លើយតបនឹងតម្រូវការជាក់ស្តែង ជាអាទិភាព របស់ក្រុមគោលដៅ និងសហគមន៍ ដែលអាចវាយតម្លៃបានសម្រាប់ទុកជាបទពិសោធន៍ ។ |
| ៤ | ឆន្ទះនៃការអនុវត្តន៍ការងាររបស់មន្ត្រីភ្នាក់ងារអនុវត្តន៍គម្រោង មានកម្រិតខ្ពស់ ទោះបីជាពួកគាត់មិនបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ក៏ដោយ ។ |

**អនុសាសន៍ :**

| ល.រ | អនុសាសន៍ |
|---|---|
| ១ | គួរជ្រើសរើសកសិករគោលដៅ ដោយកំណត់ឱ្យបានត្រឹមត្រូវ ហ្មត់ចត់ទៅតាមនិតិវិធី និងលក្ខណៈវិនិច្ឆ័យ ព្រមទាំងមានការផ្តល់សម្ភារៈសិក្សា និងឯកសារនានាឱ្យបានគ្រប់គ្រាន់ ។ |
| ២ | សកម្មភាពតាមដាន និងគាំទ្របន្ត គួរត្រូវបានធ្វើឡើង ទោះបីជាជីវិតរបស់គម្រោង ត្រូវបានបញ្ចប់ក៏ដោយ ដើម្បីធានានិរន្តភាពសកម្មភាពគម្រោង និងផលប្រយោជន៍ទៅដល់សហគមន៍។ |
| ៣ | សកម្មភាព គួរត្រូវអនុវត្តតាមផែនការដែលបានគ្រោងទុក ដើម្បីធានាឱ្យអនុកិច្ចសន្យាទទួលបានជោគជ័យ |
| ៤ | ការអនុវត្តគម្រោងគួរផ្តល់ការពង្រឹងសមត្ថភាពដល់មន្ត្រីជំនាញដើម្បីឱ្យការអនុវត្តន៍កាន់តែប្រសើរឡើង |
| ៥ | ការរៀបចំអនុកិច្ចសន្យា គួរត្រូវបានអនុម័ត យ៉ាងយូរក្នុងអំឡុងខែកុម្ភៈ |

## ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

**ឯកសារដែលត្រូវភ្ជាប់ទី១ :** បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបានពិនិត្យ

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) | មាន (៣) |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) | ✓ |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ | ✓ |
| ៣ | របាយការណ៍ត្រួតពិនិត្យគម្រោង | |
| ៤ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | ✓ |
| ៥ | លិខិតឆ្លើយឆ្លងរវាងភ្នាក់ងារអនុវត្តនិ៍ និងគណៈកម្មាធិការប្រត្តិបត្តិគ.អ.ជ.ខ | ✓ |
| ៦ | បញ្ជីវត្ថុបណ្ដុះបណ្ដាលដែលមានក្នុងអនុកិច្ចសន្យា | ✓ |
| ៧ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា | ✓ |
| ៨ | ឯកសារដ៏ទៃទៀតរួមមាន រូបថតនៃគម្រោង (អនុកិច្ចសន្យា) ដែលទុកនៅគណៈកម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ និងនៅភ្នាក់ងារអនុវត្តនិ៍ ដែលមិនបានរៀបរាប់ខាងលើ | ✓ |
| ៩ | ផ្សេងទៀត | |

**ឯកសារដែលត្រូវភ្ជាប់ទី២:** បញ្ជីឈ្មោះអ្នកផ្តល់ព័តិមានសំខាន់ៗ ដែលបានជួបសម្ភាសន៍/ជួបពិភាក្សា

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៍ប្រើសម្រាប់ប្រមូល ទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | ២១ កញ្ញា | លោក **ចេង សំណាង** នាយកទីប្រឹក្សា **ភី.អេស.ឌី.ឌី** ប្រចាំខេត្ត កំពង់ចាម | គ.ប្រ | សម្ភាសន៍ស៊ីជម្រៅ |
| ២ | ២១ កញ្ញា | លោក **អៀម ពិសិដ្ឋ** ទីប្រឹក្សា តាមដានត្រួតពិនិត្យវាយតម្លៃ និងវិស័យ | គ.ប្រ | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | ២១ កញ្ញា | លោក **ហេង ប៊ិនយិ** ប្រធានមន្ទីរកសិកម្ម ខេត្តកំពង់ចាម | មន្ទីរកសិកម្ម ខេត្ត | សម្ភាសន៍ស៊ីជម្រៅ |
| ៤ | ២១ កញ្ញា | លោក **ម៉ៅ វណ្ណថន** មន្ត្រីបង្គោល M&E មន្ទីរកសិកម្ម ខេត្តកំពង់ចាម | មន្ទីរកសិកម្ម ខេត្ត | សម្ភាសន៍ស៊ីជម្រៅ |
| ៥ | ២៧ កញ្ញា | ១-**គីម ស៊ីនុន** កសិករ | ភូមិ គៀនរូង | សម្ភាសន៍ជាក្រុម |
| | | ២-**ព្រីក សេម** កសិករ | ភូមិ គៀនរូង | សម្ភាសន៍ជាក្រុម |
| | | ៣-**សំ អូន** កសិករ | ភូមិ គៀនរូង | សម្ភាសន៍ជាក្រុម |
| | | ៤-**វង់ ប៊ុនធឿន** កសិករ | ភូមិ គៀនរូង | សម្ភាសន៍ជាក្រុម |
| | | ៥-**ទឹម តយ** កសិករ | ភូមិ គៀនរូង | សម្ភាសន៍ជាក្រុម |
| | | ៦-**ផុន ផេង** កសិករ | ភូមិ គៀនរូង | សម្ភាសន៍ជាក្រុម |
| | | ៧-**ចាន់ លឹមហ៊ាង** កសិករ | ភូមិ គៀនរូង | សម្ភាសន៍ជាក្រុម |
| | | ៨-**សុខ លាត** កសិករ | ភូមិ គៀនរូង | សម្ភាសន៍ជាក្រុម |
| | | ៩-**ភន់ ផុន** កសិករ | ភូមិ គៀនរូង | សម្ភាសន៍ជាក្រុម |
| | | ១០-**ស៊ឹម ស៊ីណាត** កសិករ | ភូមិ គៀនរូង | សម្ភាសន៍ជាក្រុម |
| | | ១១-**សុខ ណៃស្រ៊ាង** កសិករ | ភូមិ គៀនរូង | |
| | | ១២-**វន់ ស្រីពៅ** កសិករ | ភូមិ គៀនរូង | |
| | | ១៣-**អេង ឃីម** កសិករ | ភូមិ គៀនរូង | |
| | | ១៤-**ឃុត ស៊ីលាន** កសិករ | ភូមិ គៀនរូង | |

| | | | | |
|---|---|---|---|---|
| | | | ភូមិ គៀនរូង | |
| ៦ | ២៧ កញ្ញា | លោក **ភន់ ផុន** អកទទួលផលផ្ទាល់ | ភូមិ គៀនរូង | សម្ភាសន៍ស៊ីជម្រៅ/ករណីសិក្សា |
| ៧ | ២៧ កញ្ញា | លោក **កាន់ សំណាង** អ្នកមិនទទួលផល | ភូមិ គៀនរូង | សម្ភាសន៍ស៊ីជម្រៅ/ករណីសិក្សា |

# របាយការណ៍វាយតម្លៃអនុកិច្ចសន្យា

| | |
|---|---|
| លេខអនុកិច្ចសន្យា : | 04/AGR/0902-01(GOV) |
| ចំណងជើង : | គាំទ្រដល់វិស័យជលផល |
| ភ្នាក់ងារអនុវត្តន៍ : | ខ័ណ្ឌជលផលខេត្តកំពង់ឆ្នាំង<br>ក្នុងសង្កាត់ផ្សារឆ្នាំង/ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង |
| រយៈពេល (ចាប់ផ្តើម និងបញ្ចាប់) | ០១/០១/២០០៩ ដល់ ៣១/១២/២០០៩ |
| រាជធានី ខេត្ត | កំពង់ឆ្នាំង |
| ផ្នែក /មន្ទីរជំនាញ | ខណ្ឌជលផលខេត្តកំពង់ឆ្នាំង |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ នៃ គ.អ.ជ.ខ | ៧,៣០០ ដុល្លា |
| ការរួមចំណែករបស់រាជធានី ខេត្ត | ០ ដុល្លា |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៍ | ០ ដុល្លា |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | ៧,៣០០ ដុល្លា |

## ក្រុមវាយតម្លៃ និងរៀបចំរបាយការណ៍

| ឈ្មោះ | មុខតំណែង និងមុខងារ |
|---|---|
| លោក ឌឹម ឌុន | អនុប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា និងជាអ្នកសម្របសម្រួល |
| លោក នង គីមឡេង | មន្ត្រីផ្នែកគ្រប់គ្រងកិច្ចសន្យា និងជាអ្នកសម្របសម្រួល |
| កញ្ញា ជួន វឌ្ឍនារី | អនុប្រធានការិយាល័យមន្ទីរកិច្ចការនារីនិងជាអ្នកសម្របសម្រួល |
| លោក លី ហុងស្រេង | នាយរងផ្នែករដ្ឋបាលជលផលកំពង់ប្រាសាទ និងជាអ្នកសម្របសម្រួល |
| លោក ឆាយ តឿ | ទីប្រឹក្សាត្រួតពិនិត្យ និងវាយតម្លៃ និងជាទីប្រឹក្សាបច្ចេកទេស |

ខេត្ត កំពង់ឆ្នាំង

កាលបរិច្ឆេទ : វិច្ឆិកា ២០១០

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៣ |
| | របាយការណ៍សង្ខេប | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៨** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងខណ្ឌរដ្ឋបាលជលផល | ៨ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៨ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៨ |
| ១.៤ | សំណួរវាយតម្លៃ | ៩ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ៩ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ១០ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១១** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល | ១១ |
| | - លទ្ធផលទី១ | ១១ |
| | - លទ្ធផលទី២ | ១២ |
| | - លទ្ធផលទី៣ | ១៣ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម | ១៥ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង | ២៣ |
| ២.៤ | សេចក្តីសន្និដ្ឋាន | ២៩ |
| ២.៥ | អនុសាសន៍ | ៣០ |
| **ឯកសារភ្ជាប់ជាមួយនឹងរបាយការណ៍** | | **៣២** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ៣២ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍/ពិភាក្សា | ៣៣ |
| **ករណីសិក្សា** | | |
| ករណីសិក្សាទី១ : អ្នកទទួលផលពីអនុកិច្ចសន្យា | | ១៩ |
| ករណីសិក្សាទី២ : អ្នកមិនបានទទួលផល | | ២១ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| 01/AGR/0902-01 | អនុកិច្ចសន្យាគាំទ្រវិស័យជលផល |

# របាយការណ៍សង្ខេប

**គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើៈ**

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងមន្ត្រីបង្គោលតាមដានត្រួតពិនិត្យវាយតម្លៃខេត្តកំពង់ឆ្នាំង បានធ្វើការវាយតម្លៃអនុកិច្ចសន្យា ដែលមានចំណងជើងថា “គាំទ្រដល់វិស័យជលផល ” លេខ 01/AGR/0902-01 ដែលជាអនុកិច្ចសន្យារវាង ខ័ណ្ឌរដ្ឋបាលជលផល និង គ.ប្រ នៃ គ.អ.ជ.ខ ខេត្តកំពង់ឆ្នាំង ។ នេះជាផ្នែកមួយនៃគម្រោងពង្រឹងសមត្ថភាព គ្រូបង្គោលថ្នាក់ក្រោមជាតិរបស់ផ្នែកត្រួតពិនិត្យ និងវាយតម្លៃ និង ផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ តាមរយៈគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

**គោលបំណងជាក់លាក់ក្នុងការវាយតម្លៃៈ**

១. ទាញយក កត់ត្រា និង វិភាគជាប្រព័ន្ធទៅលើសមិទ្ធិផលនៃអនុកិច្ចសន្យា និងចំណុចខ្វះខាតធៀបទៅនិង លទ្ធផលគោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំងកត់ត្រានូវចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើអោយប្រសើរឡើងនៅពេលអនាគត ។

២. ពង្រឹងរបៀបធ្វើការវាយតម្លៃគម្រោងរបស់ គប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើការនៃការអនុវត្ត។ ការវាយតម្លៃអនុវត្តតាមការណែនាំ និងឧបករណ៍ស្តីពីការវាយតម្លៃអនុកិច្ចសន្យារបស់គ.ប្រ នៃ គ.អ.ជ.ខ ដែលរៀបចំដោយផ្នែកត្រួតពិនិត្យ និងវាយតម្លៃនៃលេខាធិការដ្ឋាន គ.ជ.អ.ប ។ ក្រុមការងារវាយតម្លៃបានប្រើការពិភាក្សាក្រុម ការសម្ភាសន៍ស៊ីជម្រៅ ការចុះមូលដ្ឋាន ដើម្បីធ្វើការសង្កេតដោយផ្ទាល់ និងពិនិត្យឯកសារអនុកិច្ចសន្យា របាយការណ៏រីកចម្រើន និង ឯកសារពាក់ពន្ធ័ផ្សេងៗទៀត ។

ការវាយតម្លៃ ត្រូវបានឆ្លើយនឹងសំណួរវាយតម្លៃ (សូមមើលចំណុច ១.៣) ។ ដោយសារធនធាន និងពេលវេលាមានកំណត់ ក្រុមការងារបានធ្វើការវាយតម្លៃស៊ីជំរៅទៅលើលទ្ធផលមួយប៉ុណ្ណោះ ក្នុងចំណោមលទ្ធផលដទៃទៀត ចំណែកឯ លទ្ធផលផ្សេងៗទៀត ត្រូវបានវាយតម្លៃដោយផ្អែក លើពត៌មានដែលមានស្រាប់ ។

ដូចនេះការវាយតម្លៃនេះមិនមែនជាការវាយតម្លៃស៊ីជម្រៅទៅលើអនុកិច្ចសន្យាទាំងមូលនោះទេ។តែទោះជាយ៉ាងណា ការសន្និដ្ឋាននៅទីបញ្ចប់ត្រូវបានធ្វើឡើង ទៅតាមអ្វីដែលបានរកឃើញ តាមរយៈការពិភាក្សាក្រុម និងសំភាសន៍ជាមួយអ្នកទទួលផល ក៏ដូចជាអ្នកពាក់ពន្ធ័ ជាពិសេសគឺឯកសារពាក់ពន្ធ័ដែលមាននៅក្នុងដៃ។

ឆ្លើយទៅនឹងសំណួរទាំង៥ នៃការវាយតម្លៃ :

១. សកម្មភាពទាំងអស់ត្រូវបានអនុវត្ត និង លទ្ធផលសម្រេចបានតាមផែនការ

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១ | អប់រំផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ ព្រៃលិចទឹក: | -វគ្គផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ព្រៃលិចទឹក ២លើក ក្នុង១លើក មានរយៈ ពេល ១ ថ្ងៃ<br>-មានសិក្ខាកាម ១០០នាក់ក្នុង នោះស្រី ១៧ នាក់ លើឃុំចំនួន ២ ឃុំ ។ |
| ២ | ធ្វើផ្លាកសញ្ញាសំគាល់តំបន់ព្រៃលិចទឹក: | ធ្វើផ្លាកសញ្ញាសំគាល់តំបន់ព្រៃលិចទឹកចំនួន៧ផ្ទាំង |
| ៣ | ការអប់រំអំពីច្បាប់/បទដ្ឋានជលផលៈ | - អប់រំផ្សព្វផ្សាយច្បាប់ស្តីពីជលផល បានចំនួន ១៣ លើកស្ថិតនៅក្នុងឃុំគោលដៅ ៥ឃុំ ។<br>-សិក្ខាកាមចូលរួមចំនួន៦៤២នាក់( ស្រី១៨៧នាក់) |
| ៤ | បណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រី : | - បណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រី ចំនួន ៤ វគ្គ ក្នុង១វគ្គមានរយៈ ពេល ២ ថ្ងៃ ។<br>- អ្នកចូលរួម ចំនួន ១៩៦ នាក់ស្រី ១១៣ នាក់ |
| ៥ | ទស្សនកិច្ចសិក្សាក្រៅខេត្ត : | - ទស្សនកិច្ចសិក្សាក្រៅខេត្ត ១ លើករយៈពេល ៣ ថ្ងៃ មានមន្ត្រី ២ រូបចូលរួម។ |
| ៦ | បណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីអណ្តែង ក្នុងស្បោងប្លាស្ទិច និងការបង្ហាញ | - បណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីអណ្តែង ក្នុងស្បោងប្លាស្ទិចនិងការបង្ហាញ ១ វគ្គ រយៈពេល ៣ថ្ងៃ ។<br>-អ្នកចូលរួមវគ្គបណ្តុះបណ្តាល២៥នាក់ស្រី១៣នាក់ |
| ៧ | ទស្សនកិច្ចសិក្សា ក្នុងខេត្ត : | - ទស្សនកិច្ចសិក្សាក្នុងខេត្ត ចំនួន ១ លើក រយៈពេល ១ ថ្ងៃ ។<br>-អ្នកចូលរួមទស្សនកិច្ចសិក្សា២៥ នាក់ ស្រី ៥នាក់ |

២. វគ្គបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមត្រីអណ្តែងក្នុងថង់ផ្លាស់ស្ទិច និងការបង្ហាញ: មានប្រសិទ្ធភាពណាស់ ដោយសារស្រប តាមស្ថានភាព និងតម្រូវការរស់នៅរបស់ប្រជាពលរដ្ឋ ដែលមានបំណងបង្កើតមុខរបរបន្ថែម ក៏ដូចជាកាត់បន្ថយនូវការចំណាយក្នុងគ្រួសារ។ ដូច្នេះការចិញ្ចឹមត្រី រួមចំណែកក្នុងការទ្រទ្រង់ជីវភាព ហូបចុក ហើយសល់ពីតម្រូវការពួកគាត់អាចលក់បន្តដល់អ្នកភូមិដើម្បីផ្គត់ផ្គង់ជីវភាព។ គួរតែបន្តការពង្រីកសកម្មភាព និងផ្តល់លទ្ធភាពដល់ក្រុមគោលដៅផ្សេងៗបន្ថែមទៀត។

៣. ទិសដៅបន្ទាន់និងផលប្រយោជន៍ពីវគ្គបណ្តុះបណ្តាបច្ចេកទេសចិញ្ចឹមត្រីអណ្តែងក្នុងថង់ផ្លាស់ស្ទិចនិងការបង្ហាញ គឺពិតជាដោះស្រាយបាននូវតម្រូវការអាទិភាព ព្រោះតំបន់នេះពីមុនពុំមានការចិញ្ចឹមត្រីទេ ដូច្នេះប្រជាជនក្នុងភូមិពឹងផ្អែកលើកការទិញត្រីពីផ្សា និងឈ្មួញដើលក់តាមម៉ូតូ។ បច្ចុប្បន្នក្រោយពីការដាក់ គម្រោងសកម្មភាព គឺគម្រោងកំពុងតែមាននិរន្តរភាពល្អ និងទទួលការគាំទ្រចូលរួមពីអ្នកទទួលផល ក៏ដូចជាអ្នកភូមិដែលរស់នៅក្នុងភូមិ។

៤. ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា: ជារួមស្ថានភាពចុងបញ្ចប់នៃការអនុវត្តគម្រោង នៅមានកំរិតខ្ពស់បង្គួរ ដោយវិសាលភាពគម្រោងអនុវត្ត ចំពោះក្រុមគោលដៅ ហើយពួកគេនៅតែបន្តអនុវត្ត និងកំពុងមានការចាប់អារម្មណ៍ពីអ្នកភូមិដទៃផ្សេងទៀតជាពិសេស មានអ្នកភូមិ៤គ្រួសារផ្សេងទៀតបានធ្វើការចិញ្ចឹមត្រីតាមដែរ។

៥. អនុកិច្ចសន្យានេះពិតជាបានចូលរួមចំណែកសម្រេចនូវគោលបំណងបន្ទាន់: ដោយសារកសិករដែលទទួលផលពីវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីអណ្តែងក្នុងស្បោងប្លាស្ទិច និងធ្វើបង្ហាញ បានយកចំណេះដឹងនិងជំនាញនេះដើម្បីបន្តការអនុវត្ត និងមួយចំនួនទៀតមានការតាំងចិត្ត ក្នុងការធ្វើបង្ហាញពីភាពជោគជយ័ ដល់អ្នកដែលមិនបានចូលរួមក្នុងវគ្គនេះ។ ម្យ៉ាងទៀតផលប្រយោជន៍ ពីគម្រោងនេះគាត់ទទួលបានទទួល ត្រីហូប កាត់បន្ថយការចំណាយនៅក្នុងគ្រួសារមួយកំរិត ធំលើការចំណាយទិញត្រីសម្រាប់ធ្វើម្ហូប បង្កើនប្រាក់ចំណូលក្នុងគ្រួសារបានមួយកំរិត ។

៦. អនុកិច្ចសន្យានេះពិតជាមានការភាពពាក់ព័ន្ធ និងប្រសិទ្ធភាព ប្រសិទ្ធផល: ទាក់ទងទៅនឹងធនធានដែលមានការប្រតិបត្តិការ និងការគ្រប់គ្រងទូទៅ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គុណភាពនៃការរៀបរៀង អនុកិច្ចសន្យាគួរតែត្រូវកែលំអរ ដូចខាងក្រោម :

ក. គោលបំណងបន្ទាន់ គួរបរិយាយអោយបានច្បាស់ និងអាចវាស់វែងបាន ។

ខ. ភ្ជាប់ទំនាក់ទំនងអោយបានច្បាស់រវាងលទ្ធផល និងគោលបំណងបន្ទាន់ និងគោលបំណងកំរិតខ្ពស់ ។

គ. នៅក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យាគួររៀបចំឱ្យមានក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ ។

## សេចក្តីសន្និដ្ឋានសំខាន់ៗ

១-លទ្ធផល និងអត្ថប្រយោជន៏ ដែលទទួលបានពីការអនុវត្តអនុកិច្ចសន្យា ជាប្រយោជន៏ដល់សហគមន៍ ក្នុងឃុំដែលអនុវត្តគម្រោង ព្រោះអត្ថប្រយោជន៏ដែលសហគមន៏ទទួលបាន មានការពេញចិត្ត ចំពោះអ្នកទទួលផល និងអ្នកមិនទទួលផលផងដែរ។ ផលប្រយោជន៏ ពីគម្រោងវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីក្នុងស្បោងផ្លាស់ស្ទិច និងធ្វើបង្ហាញនេះ គាត់ទទួលបានត្រីហូប កាត់បន្ថយការចំណាយនៅក្នុងគ្រួសារមួយគីរិតធំលើការចំណាយ ទិញត្រីសម្រាប់ធ្វើម្ហូបទន្ទឹមនឹងនោះបានបង្កើនប្រាក់ចំណូលក្នុងគ្រួសារបានមួយគីរិតតាមរយៈនៃការលក់ផលត្រី

ម្យ៉ាងទៀត គាត់អាចយកទឹកកាកសំណល់ដែលត្រូវស្តារពីស្រះត្រីចិញ្ចឹមមកធ្វើជាជី សម្រាប់ស្រោចដំណាំហូបផ្លែក៏ដូចជាដំណាំ បន្លែបានទៀតផង ដោយវាមានការលូតលាស់លឿននិងល្អ ដែលជាអាហារ គ្មានជាតិគីមីសម្រាប់សំរាប់គ្រួសារគាត់។ មិនតែប៉ុណ្ណោះកសិករដែលទទួលផលពី វគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីអណ្តែងក្នុងស្បោងប្លាស្ទិច និងធ្វើ បង្ហាញបានយកចំណេះដឹង និងជំនាញនេះ ដើម្បីបន្តការអនុវត្តទន្ទឹមនឹងនោះមានកសិកមួយចំនួនទៀត មានការតាំង ចិត្ត ក្នុងការធ្វើបង្ហាញពីភាពជោគជយ័ ដល់អ្នកដែលមិនបានចូលរួមក្នុងវគ្គនេះផងដែរ។

២- គោលបំណងបន្ទាន់នៃអនុកិច្ចសន្យា គួរត្រូវបានរៀបរៀង និងសរសេរក្នុងន័យទំនាក់ទំនងទៅនិង លទ្ធផលហើយ បរិយាយអោយច្បាស់ អំពីអ្វីដែលជាលទ្ធផលបន្ទាន់ និងអត្ថប្រយោជន៏ដែលរំពឹងទុក និងបញ្ជាក់ពីសូចនាករសម្រាប់វាស់វែងឱ្យបានច្បាស់លាស់ ពិសេសនៅក្នុងផ្នែកទី ៣នៃអនុកិច្ចសន្យា។

៣-គួរបន្តការគាំទ្រ និងពង្រីកបន្ថែមគម្រោងវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីអណ្តែងក្នុងស្បោងប្លាស្ទិច និងធ្វើបង្ហាញ ដល់កសិករបន្ថែមទៀត ។

៣-ដើម្បីពង្រឹងគុណភាពនៃការអនុវត្តគម្រោង ការជ្រើសរើសក្រុមគោលដៅ ដើម្បីអោយមានប្រសិទ្ធភាពគួរជ្រើសរើសអ្នកដែលមានតម្រូវការ និងមានស្ថានភាពសមស្រប និងសកម្មភាពរបស់អនុកិច្ចសន្យា ។

៤- នៅក្នុងផ្នែកទី៣នៃអនុកិច្ចសន្យាគួរបង្កើតក្របខ័ណ្ឌ ការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីងាយស្រួល ក្នុងដំណើរការវាយតម្លៃផលប្រយោជន៏ និងប្រសិទ្ធិភាពអនុកិច្ចសន្យា ។

# ១. និដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងខណ្ឌរដ្ឋបាលជលផល

រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្តល់ថវិកាតាមរយៈ គ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យ/ខណ្ឌ ដើម្បីអនុវត្តសកម្មភាព និងគម្រោងដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។ការវាយតម្លៃអនុកិច្ចសន្យាមានលក្ខណៈជាប្រព័ន្ធ មិនបានអនុវត្តទេ កាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើន។ នៅក្នុងឆ្នាំ ២០១០ ជាមួយនឹងការគាំទ្រ ផ្នែកថវិកា និងបច្ចេកទេសពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យា គ.ប្រ នៃគ.អ.ជ.ខ ក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យា បានធ្វើការរៀបចំរួមគ្នាជាមួយភ្នាក់ងារអនុវត្តន៍ដែលមានលេខៈ*(04/AGR/0902-01(GOV)* ។

ដំណើរការលទ្ធផលដែលបានរកឃើញ និងការសន្និដ្ឋាន នៃការវាយតម្លៃត្រូវបានកត់ត្រា ហើយនឹងបង្ហាញតាមរយៈ របាយការណ៍ ស្តីពីការវាយតម្លៃនេះដល់អ្នកពាក់ព័ន្ធ និងភ្នាក់ងារអនុវត្ត ដើម្បីជាមូលដ្ឋានក្នុងការកែលំអរ ការរៀបចំ និងអនុវត្តអនុកិច្ចសន្យា។

## ១.២. គោលបំណងអនុកិច្ចសន្យា

គោលបំណងបន្ទាន់នៃអនុកិច្ចសន្យា គឺស្របទៅតាមគោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរួមចំណែក កាត់ បន្ថយភាពក្រីក្រតាមរយៈអភិបាលកិច្ចល្អនៅមូលដ្ឋាន ។ គោលបំណងរបស់ខ័ណ្ឌរដ្ឋបាល គឺបន្តការអប់រំ ប្រជាពលរដ្ឋ ឱ្យមានការយល់ដឹងអំពីច្បាប់ និងការអភិរក្ស និងស្គាល់នូវចំណុចវិជ្ជមាន-អវិជ្ជមាន ដើម្បីធានានូវ និរន្តរភាពនៃ ប្រភពធនធានជលផល។ អនុវត្តយុទ្ធសាស្រ្តបង្កើនផលស្តុកត្រីក្នុងធម្មជាតិអោយសំបូរឡើងវិញ ដោយបង្កើន ប្រសិទ្ធិភាពការងារ គ្រប់គ្រងថែរក្សា អភិរក្សធនធានជលផលប្រកបដោយនិរន្តរភាព និងអភិវឌ្ឍន៍ ធនធានជលផល តាមរយៈការបង្កើនការយល់ដឹង និងមានចំណេះ ដឹងបច្ចេកទេស ក្នុងការអភិវឌ្ឍន៏ លើផ្នែក វារីវប្បកម្ម ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូល ដោយផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និងតម្លាភាព។ ដូច្នេះទំហំនៃការវាយតម្លៃ មានដែន

កំណត់តាមទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខណ្ឌការងារនៃការវាយតម្លៃ។ គោលបំណង នៃការវាយតម្លៃគឺ: ក) ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និងចំនុចខ្វះខាត ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំង កត់ត្រានូវ ចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត និង ខ) ដើម្បីពង្រឹងរបៀប ធ្វើការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្តអនុកិច្ចសន្យា។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? ( ចំណុច គ ផ្នែកទី៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? ( ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណាទាក់ទងនឹងការរៀបចំ អនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

**វិធីសាស្ត្រ និងឧបករណ៍ដែលបានប្រើៈ**

១) ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំណត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្ដុះបណ្ដាល និងរាល់ឯកសារដែលពាក់ព័ន្ធដែលមាននៅក្នុងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៍។

២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗ រួមមានៈ អ្នកគ្រប់គ្រង អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា ចំនួន៣ នាក់ អ្នកទទួលផលផ្ទាល់ ចំនួន ៨ នាក់ អ្នកទទួលផលមិនផ្ទាល់ ២នាក់ និងអ្នកពាក់ព័ន្ធ ២នាក់។ ការពិគ្រោះបានផ្តោតទៅលើបញ្ហាយេនឌ័រ និងគ្រប់គ្រងធនធានធម្មជាតិ សម្រាប់បញ្ហាពាក់ពន្ធ័វិស័យខាងលើ ។

៣) ប្រើប្រាស់វិធីសាស្ត្រចុះពិនិត្យតំបន់អនុវត្តន៏គម្រោង និងសង្កេតមើលសកម្មភាព ពិភាក្សាក្រុម និងករណីសិក្សា។

៤) ចុះពិនិត្យតំបន់អនុវត្តន៏គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់។

៥) វិភាគទិន្នន័យ និងបកស្រាយៈ ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀង

ផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់ ដែលមានក្នុងបញ្ជីសំណួរ ។

៦) ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៍: ដោយភ្នាក់ងារអនុវត្តន៍ និងអ្នកពាក់ព័ន្ធតាមរយៈព័ត៌មានត្រឡប់ដែលទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើង ។ ការវាយតម្លៃនេះ ត្រូវបានធ្វើតាម "គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា" និងវិធីសាស្ត្រដែលបានណែនាំដោយ គ.ជ.អ.ប ។ ដូច្នេះដំណើរការ ត្រូវបានធ្វើឡើងដោយមានទម្រង់ការណែនាំ និងតម្លាភាព រួមទាំងការចូលរួមពីអ្នកពាក់ព័ន្ធ ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយ គ.ប្រ និងអ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា ។ ទោះជាយ៉ាងណាក៏ដោយការប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត ។

២) បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យា: ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និងជោគជ័យទេ ។ មួយទៀត ទំនាក់ទំនងសង្ខេបតាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់ មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ ។

៣) ដោយយើងមិនមានសូចនាករវាស់ យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍" ដែលជាកម្រិត អត្ថប្រយោជន៍ទៅលើគោលនយោបាយវិស្សកម្ម និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ ។

៤) ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃ លម្អិតទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ ។ យើងអាចវាយតម្លៃតែទៅលើ ( ការបណ្តុះបណ្តាលកសិករពីបច្ចេកទេស ផ្សព្វផ្សាយអំពីត្រី និងការបង្ហាញ) ដែលជាលទ្ធផល និង ( បណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីអណ្តែង ក្នុងស្បោងប្លាស្ទិច និងការបង្ហាញ ) ដែលជាសកម្មភាពនៃអនុកិច្ចសន្យាលំអិត តាមរយៈការសម្ភាសន៍ស៊ីជម្រៅ ក្រុមពិភាក្សា និងការចុះពិនិត្យតំបន់អនុវត្តគម្រោង ។

# ២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១)

**លទ្ធផលទី១ : គណៈកម្មាធិការសហគមន៍នេសាទ**

**ផ្នែក-ក : ការសម្រេចជាក់ស្តែងធៀបនឹងផែនការ**

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | អប់រំផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ ព្រៃលិចទឹក:<br>-វគ្គផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ ព្រៃលិចទឹក ២លើក ក្នុង១លើក មានរយៈ ពេល ១ ថ្ងៃ<br>-មានសិក្ខាកាម ១០០នាក់ក្នុង នោះស្រី ១៧ នាក់ លើឃុំចំនួន ២ ឃុំ | អប់រំផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ ព្រៃលិចទឹក:<br>- វគ្គផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ ព្រៃលិចទឹក ២លើក ក្នុង១លើក រយៈពេល ១ ថ្ងៃ<br>- មានសិក្ខាកាម ១០០នាក់ ក្នុងនោះស្រី ១៧ នាក់ លើឃុំចំនួន ២ ឃុំ<br>- សម្រេចបាន១០០% នៃផែនការគ្រោងទុកក្នុងអនុកិច្ចសន្យា។ |
| ១.២ | ធ្វើផ្លាកសញ្ញាសំគាល់តំបន់ព្រៃលិចទឹក:<br>- ធ្វើផ្លាកសញ្ញាសំគាល់តំបន់ព្រៃលិចទឹក ចំនួន៧ ផ្ទាំង | ធ្វើផ្លាកសញ្ញាសំគាល់តំបន់ព្រៃលិចទឹក:<br>- បានធ្វើផ្លាកសញ្ញាសំគាល់តំបន់ព្រៃលិចទឹក ចំនួន៧ ផ្ទាំង<br>- សម្រេចបាន១០០% នៃផែនការគ្រោងទុកក្នុងអនុកិច្ចសន្យា។ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃអំពីការសម្រេចបាននូវលទ្ធផល ធៀបនឹងគោលបំណងបន្ទាន់ (ផលប៉ះពាល់ /លទ្ធផលបឋម រយៈពេលខ្លី/មធ្យមនៃលទ្ធផល) នៃអនុកិច្ចសន្យា

តាមរយៈនៃការសិក្សាលើរបាយការណ៍បញ្ចប់អនុកិច្ចសន្យា របាយការណ៍រីកចំរើន ការចុះសម្ភាសន៍ជាមួយ អ្នកគ្រប់គ្រង អ្នករៀបចំ និងអ្នកអនុវត្តអនុកិច្ចសន្យា បានបង្ហាញថា: ការអនុវត្តលទ្ធផលសកម្មភាព នៅក្នុងអនុកិច្ចសន្យាសម្រេចបានគ្រប់លទ្ធផល ធៀបនិងផែនការគ្រោងទុក និងសម្រេចបានតាមគោលបំណងបន្ទាន់ របស់អនុកិច្ចសន្យា ។ សកម្មភាព និងលទ្ធផលបានឆ្លើយតបទៅនិង តម្រូវការជាអាទិភាពរបស់មូលដ្ឋាន ក៏ដូចជាគោលដៅយុទ្ធសាស្ត្ររបស់ខណ្ឌ។

**លទ្ធផលទី២: ការអប់រំអំពីច្បាប់/បទដ្ឋានជលផល**

**ផ្នែក-ក : ការសម្រេចជាក់ស្តែងធៀបនឹងផែនការ**

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | ការអប់រំអំពីច្បាប់/បទដ្ឋានជលផល:<br>- អប់រំផ្សព្វផ្សាយអំពីច្បាប់ជលផល : ១៣ វគ្គ ក្នុង ១វគ្គ មានរយៈពេល ១ថ្ងៃ<br>- ដែលមានសិក្ខាកាម ចំនួន ៦៤២ នាក់ ស្រី ១៨៧ នាក់ | ការអប់រំអំពីច្បាប់/បទដ្ឋានជលផល<br>- អប់រំផ្សព្វផ្សាយច្បាប់ស្តីពីជលផលបានចំនួន ១៣ លើក<br>- ស្ថិតនៅក្នុងឃុំគោលដៅ៥ឃុំ ជលសារ, ព្រៃគ្រី, កោះថ្កូវ ,ពាមឆ្កោក ក្នុងស្រុកជលគីរី និងឃុំអំពិលទឹក ក្នុងស្រុកកំពង់ត្រឡាច ។<br>- សិក្ខាកាមចូលរួម ចំនួន ៦៤២ នាក់ (ស្រី១៨៧នាក់) ។<br>- សម្រេចបាន 98.77% នៃផែនការគ្រោងទុកក្នុងអនុកិច្ចសន្យា |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃអំពីការសម្រេចបាននូវលទ្ធផល ធៀបនឹងគោលបំណងបន្ទាន់ (ផលប៉ះពាល់ /លទ្ធផលបឋម រយៈពេលខ្លី/មធ្យមនៃលទ្ធផល) នៃអនុកិច្ចសន្យា

ការសិក្សាលើរបាយការណ៍បញ្ចប់អនុកិច្ចសន្យា របាយការណ៍រីកចំរើន ការចុះសម្ភាសន៍ជាមួយអ្នកគ្រប់គ្រង អ្នករៀបចំ និងអ្នកអនុវត្តអនុកិច្ចសន្យា បានបង្ហាញថាៈ ការអនុវត្តលទ្ធផលសកម្មភាព នៅក្នុងអនុកិច្ចសន្យា លទ្ធផលនេះសម្រេចបាន ៩៨.៧៧% ធៀបនិងផែនការគ្រោងទុក និងសម្រេចបានតាមគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា ។ ខ្លឹមសារវគ្គបណ្តុះបណ្តាលបានឆ្លើយតបទៅនិង តម្រូវការរបស់មូលដ្ឋាន ដែលគាត់ចង់ដឹងអំពីច្បាប់ជលផល ។

## លទ្ធផលទី៣: ការបណ្តុះបណ្តាលកសិករពីបច្ចេកទេស ផ្សព្វផ្សាយអំពីត្រី និងការបង្ហាញ

## ផ្នែក-ក : ការសម្រេចជាក់ស្តែងធៀបនឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | បណ្តុះបណ្តាលអំពិបច្ចេកទេសចិញ្ចឹមត្រី :<br>- បណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រី ចំនួន ៤ វគ្គ ក្នុង១វគ្គមានរយៈ ពេល ២ ថ្ងៃ | បណ្តុះបណ្តាលអំពិបច្ចេកទេសចិញ្ចឹមត្រី :<br>- បណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រី ចំនួន ៤ វគ្គ-១វគ្គមានរយៈពេល២ថ្ងៃ<br>- អ្នកចូលរួម ចំនួន ១៩៦ នាក់ស្រី ១១៣ នាក់<br>- សម្រេចបាន 100 %នៃផែនការគ្រោងទុកក្នុងអនុកិច្ចសន្យា។ |
| ១.២ | ទស្សនកិច្ចសិក្សាក្រៅខេត្ត:<br>- ទស្សនកិច្ចសិក្សាក្រៅខេត្ត ១ លើក | ទស្សនកិច្ចសិក្សាក្រៅខេត្ត :<br>- ទស្សនកិច្ចសិក្សាក្រៅខេត្ត ១ លើក<br>- រយៈពេលទស្សនកិច្ចសិក្សា ៣ ថ្ងៃ<br>- មានមន្ត្រី ២ រូប ចូលរួមក្នុងការធ្វើទស្សនកិច្ចសិក្សា<br>- សម្រេចបាន 100 %នៃផែនការគ្រោងទុកក្នុងអនុកិច្ចសន្យា |
| ១.៣ | បណ្តុះបណ្តាលអំពិបច្ចេកទេសចិញ្ចឹមត្រីអណ្តែង ក្នុងស្បោងប្លាស្ទិច និងការបង្ហាញ<br>- បណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីអណ្តែង ក្នុងស្បោងប្លាស្ទិចនិងការបង្ហាញ ១ វគ្គ រយៈពេល ៣ថ្ងៃ<br>- អ្នកចូលរួមវគ្គបណ្តុះបណ្តាល ២៥ នាក់ | បណ្តុះបណ្តាលអំពិបច្ចេកទេសចិញ្ចឹមត្រីអណ្តែង ក្នុងស្បោងប្លាស្ទិច និងការបង្ហាញ :<br>- បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមត្រីអណ្តែង ក្នុងស្បោងប្លាស្ទិចនិងការបង្ហាញ ១ វគ្គ<br>- រយៈពេលបណ្តុះបណ្តាល រយៈពេល ៣ថ្ងៃ<br>- អ្នកចូលរួមវគ្គបណ្តុះបណ្តាល ២៥ នាក់ ស្រី ១៣ នាក់<br>- សម្រេចបាន 100 %នៃផែនការគ្រោងទុកក្នុងអនុកិច្ចសន្យា។ |

| | | |
|---|---|---|
| ១.៤ | ទស្សនកិច្ចសិក្សា ក្នុងខេត្ត :<br>- ទស្សនកិច្ចសិក្សាក្នុងខេត្ត ចំនួន ១ លើក រយៈពេល ១ ថ្ងៃ<br>- អ្នកចូលរួមទស្សនកិច្ចសិក្សា ២៥ នាក់ | ទស្សនកិច្ចសិក្សា ក្នុងខេត្ត :<br>- ទស្សនកិច្ចសិក្សាក្នុងខេត្ត ចំនួន ១ លើក<br>- រយៈពេលទស្សនកិច្ចសិក្សា ១ ថ្ងៃ<br>- អ្នកចូលរួមទស្សនកិច្ចសិក្សា ២៥ នាក់ ស្រី ៥ នាក់<br>- សម្រេចបាន 100 %នៃផែនការគ្រោងទុកក្នុងអនុកិច្ចសន្យា។ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃអំពីការសម្រេចបាននូវលទ្ធផល ធៀបនឹងគោលបំណងបន្ទាន់ (ផលប៉ះពាល់ /លទ្ធផលបឋម រយៈពេលខ្លី/មធ្យមនៃលទ្ធផល) នៃអនុកិច្ចសន្យា

- តាមរយៈនៃការសិក្សាលើរបាយការណ៍បញ្ចប់អនុកិច្ចសន្យា របាយការណ៍រីកចំរើន ការចុះសម្ភាសន៏ជាមួយ អ្នកគ្រប់គ្រង អ្នករៀបចំ និងអ្នកអនុវត្តអនុកិច្ចសន្យា អ្នកពាក់ព័ន្ធ អ្នកទទួលផល និងអ្នកមិនទទួលផលបានបង្ហាញថា : ការអនុវត្តលទ្ធផល សកម្មភាព នៅក្នុងអនុកិច្ចសន្យាសម្រេចបានលទ្ធផលល្អ ធៀបនិងផែនការគ្រោងទុក និងសម្រេចបានតាម គោលបំណងបន្ទាន់របស់អនុកិច្ចសន្យា ។ សកម្មភាព និងលទ្ធផលបានឆ្លើយតបទៅនិង តម្រូវការជាអាទិភាពរបស់មូលដ្ឋាន ដែលតម្រូវការ ចង់ទទួលបានចំណេះដឹង ជំនាញ បច្ចេកទេស ពីការចិញ្ចឹមត្រីអណ្តែង ក្នុងស្បោងប្លាស្ទិចនៅតាមគ្រួសារ ដើម្បីបង្កើនចំណូល និងដោះស្រាយជីវភាពគ្រួសារ ។ ដូច្នេះការអនុវត្តសកម្មភាព-លទ្ធផលនេះបានឆ្លើយតប ទៅ និងតម្រូវការរបស់មូលដ្ឋាន និងសម្រេចបានគោលបំណងបន្ទាន់នៃកិច្ចសន្យា។

- នៅក្នុងក្រុមពិភាក្សាស៊ីជំរៅ ជាមួយអ្នកទទួលផល ដែលជាសិក្ខាកាមពីវគ្គបណ្តុះបណ្តាល បានរាយការណ៍ថា ពួកគាត់បានទទួលនូវចំណេះដឹង និងជំនាញ ដែលទាក់ទងទៅនិងបច្ចេកទេសចិញ្ចឹមត្រីអណ្តែងក្នុងថង់ផ្លាស់ស្ទិច ជាពិសេសបន្ទាប់ពីការសិក្សារៀនសូត្រចប់សព្វគ្រប់ពួកគាត់អាចអនុវត្តជាក់ស្តែងដោយខ្លួនឯងបាន ។

- សិក្ខាកាមទាំងអស់មានការពេញចិត្តចំពោះវិធីសាស្រ្ត សំរបសំរួលវគ្គបណ្តុះបណ្តាល និង ឥរិយាបថ ព្រមទាំងចំណះដឹង និងជំនាញ របស់អ្នកសំរបសំរួល ។ អ្នកសំរបសំរួលមានទេពកោសល្យក្នុងការធ្វើបង្ហាញការចិញ្ចឹមជាក់ស្តែង ដែលធ្វើឱ្យពួកគាត់អាចទទួលបាននូវជំនាញច្បាស់លាស់ក្នុងការចិញ្ចឹមត្រី ។

- មានសិក្ខកាមបានផ្តល់យោបល់ ជួយផ្តល់សំភារៈសម្រាប់ធ្វើបង្ហាញការចិញ្ចឹមត្រីដល់កសិករគំរូបន្ថែមទៀត ។

សរុបសេចក្តីមក វគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីអណ្តែង ក្នុងស្បោងប្លាស្ទិចនិងការបង្ហាញ នេះគឺបានធ្វើឱ្យជីវភាពរបស់គាត់កាន់តែប្រសើរឡើង ដោយទទួលបានចំណូលបន្ថែម និង កាត់បន្ថយចំណាយលើការទិញត្រីសម្រាប់ដោះស្រាយជីវភាពគ្រួសារ ។

## ២.២. ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម

### ផ្នែក-ក: ការសម្រេចបាននូវស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា | ស្ថានភាពជាក់ស្តែងនៅពេលបញ្ចប់អនុកិច្ចសន្យា |
|---|---|
| — កសិករ១០០នាក់ ( ស្រី ៣៤ នាក់) ទទួលបានការអប់រំ ច្បាប់ អំពីអត្ថប្រយោជន៍ព្រៃលិចទឹក | -កសិករ១០០នាក់ ( ស្រី ៣៤ នាក់) ទទួលបានការអប់រំច្បាប់ អំពីអត្ថប្រយោជន៍ព្រៃលិចទឹកដែលផ្សព្វផ្សាយបានចំនួន២លើក រយៈ ពេល ២ថ្ងៃ ស្ថិតនៅក្នុង ឃុំពាម ឆ្មោក និងកោះថ្កូវ ។<br>-កសិករមានការយល់ដឹងពីអត្ថប្រយោជន៍របស់ព្រៃលិចទឹក<br>-យល់ពីច្បាប់ការពារ និង អភិរក្សព្រៃលិចទឹក |
| — ផ្លាកសញ្ញាសំគាល់តំបន់ព្រៃលិចទឹកចំនួន៧ផ្ទាំងសំរាប់ធ្វើការ ផ្សព្វផ្សាយអំពីការការពារ និងអភិរក្សធនធាន ជលផលទៅតាមតំបន់គោលដៅ ។ | -ផ្លាកសញ្ញាសំគាល់តំបន់ព្រៃលិចទឹកចំនួន៧ផ្ទាំងសំរាប់ ធ្វើការ ផ្សព្វផ្សាយអំពីការការពារ និងអភិរក្សធនធាន ជលផលទៅ តាម តំបន់គោលដៅត្រូវបានតម្លើងរួច។<br>-ប្រជាពលរដ្ឋយល់ពីតំបន់ហាមឃាត់។ |
| — ប្រជុំផ្សព្វផ្សាយនិងជ្រើសរើសគណៈកម្មការសហគមន៍ដើម្បីបង្កើតជម្រកត្រី បានចំនួន ២ កន្លែង ។ | -ផ្សព្វផ្សាយនិងជ្រើសរើសគណៈកម្មការសហគមន៍ដើម្បីបង្កើត ជម្រកត្រី បានចំនួន ២ កន្លែងស្ថិតនៅក្នុងឃុំធ្លកវៀន និង ឃុំក្បាលទឹក។<br>- មានសមាជិកចូលរួមចំនួន ២០០នាក់ (ស្រី៥២នាក់)។ |
| — អប់រំផ្សព្វផ្សាយច្បាប់ស្តីពីជលផលបានចំនួន ១៣ លើក | - អប់រំផ្សព្វផ្សាយច្បាប់ស្តីពីជលផលបានចំនួន ១៣លើក ស្ថិតនៅក្នុងឃុំ ជលសារ, ព្រៃគ្រី, កោះថ្កូវ ពាមឆ្មោក ក្នុងស្រុក ជលគីរី និងឃុំអំពិលទឹក ក្នុងស្រុកកំពង់ត្រឡាច<br>- អ្នកចូលរួមចំនួន៦៤២នាក់ (ស្រី១៨៧នាក់) ។<br>- កសិករទទួលបានចំណេះដឹងពីច្បាប់ជលផល។ |
| — បណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រី បានចំនួន ៤ វគ្គ (ក្នុង១វគ្គ២ថ្ងៃ ) | -បណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រី បានចំនួន ៤ វគ្គ (ក្នុង១វគ្គ២ថ្ងៃ)ស្ថិតនៅក្នុងឃុំឆ្នុកទ្រូ និងឃុំត្រពាំងចាន់ ក្នុងស្រុកបរិបូរណ៍ ។<br>-កសិករចូលរួមចំនួន ១៩៦ នាក់ (ស្រី១១៣នាក់ )។<br>- កសិករទទួលបានចំណេះដឹងពីបច្ចេកទេសចិញ្ចឹមត្រី |

| | |
|---|---|
| — មន្ត្រីពីររូបទៅទស្សនកិច្ចសិក្សាស្វែងយល់ និងដកស្រង់នូវបទពិសោធន៍ ការអនុវត្តអនុកិច្ចសន្យា ចំនួន ៣ថ្ងៃ | -មន្ត្រីពីររូបបានទៅទស្សនកិច្ចសិក្សាស្វែងយល់ និងដកស្រង់នូវបទពិសោធន៍ ការអនុវត្តអនុកិច្ចសន្យា ចំនួន ៣ថ្ងៃនៅខេត្តសៀមរាប ដែលរៀបចំដោយ គ.ប្រ ខេត្តកំពង់ឆ្នាំង ។<br>-មន្ត្រីមានសមត្ថភាពក្នុងការអនុវត្តអនុកិច្ចសន្យា។ |
| — បណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីអណ្តែងក្នុងស្បោងប្លាស្ទិច និងធ្វើបង្ហាញ ដល់ប្រជាកសិករ បានចំនួន ១វគ្គ (១វគ្គ៣ថ្ងៃ) ស្ថិតនៅក្នុងឃុំ ប្រស្និប ក្នុងស្រុករលាប្អៀរ ដែលមាន សមាជិកចូលរួម ចំនួន ២៥ នាក់ ។ | -បណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីអណ្តែងក្នុងស្បោងប្លាស្ទិច និងធ្វើបង្ហាញ ដល់ប្រជាកសិករ បានចំនួន ១វគ្គ (១វគ្គ៣ថ្ងៃ) ស្ថិតនៅក្នុងឃុំ ប្រស្និប ក្នុងស្រុករលាប្អៀរ។<br>- កសិករ ចូលរួម ចំនួន ២៥ នាក់ (ស្រី១៣នាក់)<br>- កសិករដែលបានចូលរួមវគ្គបណ្តុះបណ្តាលបានយកចំណេះដឹងជំនាញ បច្ចេកទេស អនុវត្តបាន ៥គ្រួសារតាមការរយៈការធ្វើបង្ហាញ ដែលមាននិរន្តរភាពរហូតដល់បច្ចុប្បន្ន។ ទន្ទឹមនឹងនោះ មានកសិក ៤រូប ផ្សេងទៀតបានធ្វើការចិញ្ចឹម តាមបន្ទាប់ពីឃើញពីភាព ជោគជ័យរបស់កសិករគំរូនៅក្នុងការចិញ្ចឹមត្រីក្នុងស្បោងផ្លាស្ទិក។<br>-តាមរយៈនៃការសម្ភាសន៍ក្រុមអ្នកទទួលផលបានបង្ហាញថា : អ្នកទទួលផលទាំងអស់មានការពេញចិត្ត ខ្លាំងណាស់ចំពោះវគ្គបណ្តុះបណ្តាល ព្រោះវាបានផ្តល់នូវចំណេះបច្ចេកទេសចិញ្ចឹមត្រីអណ្តែងនៅក្នុងថង់ប្លាស្ទិចបានផ្តល់ផលប្រយោជន៍ក្នុងគ្រួសារ ដូចជាបានទទួលត្រីហូបដែលមានជាតិប្រូតេអ៊ិន(ជីវសាស្ត្រ) កាត់បន្ថយការចំណាយលើការទិញត្រី បង្កើនប្រាក់ចំណូលក្នុងគ្រួសារ ចំណេញពេលវេលាក្នុង ស្វែងរកទិញត្រី ។<br>-បានផ្តល់អត្ថប្រយោជន៍មួយទៀត គឺយើងអាចយកទឹកចិញ្ចឹមមកធ្វើជាជី សម្រាប់ស្រោចដំណាំបន្លែ ក៏ជាដំណាំហូបផ្លែ ។ |
| — ដឹកនាំ សហគមន៍ទៅធ្វើទស្សនកិច្ចសិក្សាស្វែងយល់ពីការអនុវត្តជាក់ស្តែង របស់កសិករ ពីសកម្មភាពចិញ្ចឹមត្រីអណ្តែងរបស់ប្រជាពលរដ្ឋនៅ ស្រុកកំពង់ត្រឡាច ចំនួន១ថ្ងៃ ។ | -ដើម្បីបង្កើនសមត្ថភាពនិងការយល់ដឹងរបស់សិក្ខាកាមឱ្យកាន់តែទូលំទូលាយ ក្រុមការងារបានដឹកនាំសហគមន៍ទៅធ្វើទស្សនកិច្ចសិក្សាស្វែងយល់ពីការអនុវត្តជាក់ស្តែងរបស់កសិករពីសកម្មភាពចិញ្ចឹមត្រីអណ្តែងរបស់ប្រជាពលរដ្ឋនៅស្រុកកំពង់ត្រឡាច |

| | |
|---|---|
| | ចំនួន១ថ្ងៃ ។<br>- កសិករទទួលបានជំនាញបន្ថែមពីលើទ្រឹស្តី ដើម្បីអនុវត្តបន្ត |
| — មន្ត្រីតាមដានត្រួតពិនិត្យវាយតម្លៃរបស់ខណ្ឌរដ្ឋបាលជលផលចុះតាមដានពិនិត្យមើលការអនុវត្តសកម្មភាពរបស់ភ្នាក់ងារអនុវត្ត | -មន្ត្រីតាមដានត្រួតពិនិត្យវាយតម្លៃរបស់ខណ្ឌរដ្ឋបាលជលផលបានចុះតាមដានពិនិត្យមើលការអនុវត្តសកម្មភាពរបស់ភ្នាក់ងារអនុវត្តបានចំនួន ៨ លើក ដែលស្ថិតនៅតាម ឃុំគោលដៅ ។<br>-គម្រោងសកម្មភាពបានអនុវត្តសម្រេចបានតាមកម្មវិធីគ្រោង |

**ផ្នែក-ខ: ការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា**

| ធាតុនៃគោលបំណងបន្ទាន់ | ការសម្រេចបានជាក់ស្តែង នៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ |
|---|---|
| ទិសដៅបន្ទាន់របស់របស់អនុកិច្ចសន្យាខណ្ឌរដ្ឋបាលជលផលគឺបន្តការអប់រំប្រជាពលរដ្ឋ ឱ្យមានការយល់ដឹងអំពីច្បាប់ និងការអភិរក្ស និងស្គាល់នូវចំណុចវិជ្ជមាន-អវិជ្ជមានដើម្បីធានានូវនិរន្តរភាពនៃប្រភពធនធានជលផល ។ | គោលបំនងបន្ទាន់ដែលមានចែងក្នុងអនុកិច្ចសន្យា ស្ថិតក្នុងកំរិតខ្ពស់ ដែលយើងពិបាកក្នុងការវាស់វែង នៅចុងបញ្ចប់នៃអនុកិច្ចសន្យា ។បើយើងពិនិត្យលើឯកសារនិងវិធីសាស្រ្តវាយតម្លៃបែបគុណភាព គេមិនអាចធ្វើការវាយតម្លៃបានថាគោលបំណងបន្ទាន់នោះសម្រេចបានកំរិតណាទេ ។ តែទោះជាយ៉ាងនេះក្តី ការអនុវត្តសកម្មភាពក្នុងអនុកិច្ចសន្យាដូចជា សារៈសំខាន់បន្តរួមចំណែកលើកស្ទួយវិស័យជលផល អោយក្លាយ ជាឋាមពល មួយទាក់ទាញ ស្មារតីប្រជាពលរដ្ឋក្នុងការថែរក្សាការពារ និងអភិវឌ្ឍន៍ធនធានជលផលឱ្យកាន់តែរីកចំរើនឡើងនាពេលអនាគត ។-តាមរយះការធ្វើ អង្កេត និងចុះសម្ភាសន៏ជាមួយអ្នកអនុវត្តគម្រោង អ្នកពាក់ព័ន្ធ និងអ្នកទទួលផលបានបង្ហាញឱ្យឃើញថា គម្រោងនេះមានផលប្រយោជន៏យ៉ាងខ្លាំងចំពោះ អ្នកទទួលផល ព្រោះបានអនុវត្តគម្រោងចំពោះទិសដៅ ឬគោលបំណងរបស់ប្រជាពលរដ្ឋ ដែលចង់បាន។ |

## ផ្នែក-គៈ សង្ខេបការវាយតម្លៃ "លទ្ធផល" និង "ផលប្រយោជន៏"

តាមរយៈការពិភាក្សាក្រុមអ្នកចូលរួមបានបង្ហាញថាពួកគាត់ពេញចិត្តយ៉ាងខ្លាំងចំពោះបណ្តុះបណ្តាលអំពី បច្ចេក-ទេស ចិញ្ចឹមត្រីអណ្តែងក្នុងស្បោងប្លាស្ទិច និងធ្វើបង្ហាញ ពួកគាត់ទទួលបាន នូវចំណេះដឹង និងបច្ចេកទេសថ្មីពីការចិញ្ចឹមត្រី ក្នុងថង់ផ្លាស្ទិច។ ជាទូទៅអ្នកដែលចូលរួមក្នុងវគ្គ បណ្តុះបណ្តាលនេះជាអ្នកប្រកបរបរធ្វើស្រែចំការ ដែលអាចឱ្យពួក គាត់យកចំណេះដឹងទាំងនេះទៅអនុវត្តន៏ ដើម្បី ជាការរួមចំណែកដោះស្រាយការហូបចុកគ្រប់គ្រាន់ និងអាចលក់ដូរ សម្រាប់ផ្គត់ផ្គង់ ទៅលើការរៀនសូត្ររបស់កូនចៅពួកគាត់ និងបង្កើនជីវភាពគ្រួសារ ។

ម្យ៉ាងទៀតគម្រោងនេះធ្វើប្រជាពលរដ្ឋទទួលបានទាំងបច្ចេកទេសចិញ្ចឹមត្រី ហើយមិនតែប៉ុណ្ណោះប្រជាពលរដ្ឋអាចគំនិតកែឆ្នៃគម្រោងនេះឱ្យកាន់តែប្រសើរបន្ថែមទៀត ដូចជាការរៀបចំតដ្ឋធ្វើជាអាងសម្រាប់ចិញ្ចឹមត្រីឱ្យបានរយៈពេលវែង ។ ពិសេសទៅទៀត កសិករមួយចំនួនបានធ្វើការតាំងចិត្ត និងយកចំណេះដឹងរបស់គាត់ទៅអនុវត្តន៏ពង្រីក ការចិញ្ចឹមត្រីបន្ថែម ដោយបង្វែរពីការចិញ្ចឹមត្រីពីថង់ផ្លាស្ទិចទៅជាការចិញ្ចឹមត្រីតាមស្រះ និងធ្វើបង្ហាញដល់កសិករផ្សេងទៀត អំពីបច្ចេកទេសចិញ្ចឹមត្រីដែលគាត់ទទួលបានជោគជ័យ ។

**សង្ខេបការវាយតម្លៃ "ផលប្រយោជន៏" ដែលមិនអាចមើលឃើញ ប៉ុន្តែជាការយល់ឃើញរបស់អ្នកទទួលផល និងអ្នក ផ្តល់ព័ត៌មានសំខាន់ៗ :**

តាមរយៈការពិភាក្សាក្រុម ( សំភាសន៏ស៊ីជំរៅ ) ក្រុមអ្នកទទួលផល ដែលចូលរួមសំភាសន៏បានបង្ហាញថាអារម្មណ៏ពី

អត្ថប្រយោជន៏ដោយពោលថា :

- គាត់ចិញ្ចឹមត្រី បានទទួលត្រីហូបដែលមានជាតិប្រូតេអ៊ិន(ជីវសាស្ត្រ) ក្រុមគ្រួសារពុំមានជំងឺ
- កាត់បន្ថយការចំណាយនៅក្នុងគ្រួសារ មួយក៏រិតធំ លើការចំណាយទិញត្រី សម្រាប់ធ្វើម្ហូប
- បង្កើនប្រាក់ចំណូលក្នុងគ្រួសារ ដោយគាត់ចិញ្ចឹមត្រីបានលក់ក្នុងមួយខែពី ២-៣ គីឡូក្រាម
- ចំណេញពេលវេលា ពុំចំណាយពេលឆ្ងាយពីផ្ទះក្នុងស្វែងរកទិញត្រី និង ទៅរកនេសាទត្រី។
- គាត់អាចយកទឹកកាកសំណល់ដែលត្រូវស្តារពីស្រះត្រីចិញ្ចឹម មកធ្វើជាជី សម្រាប់ស្រោចដំណាំបន្លែ និងឈើហូបផ្លែ ។

## ករណីសិក្សាទី១ : អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងវគ្គបណ្តុះបណ្តាលអំពី បច្ចេកទេសចិញ្ចឹមត្រីអណ្តែងក្នុង ស្បោងប្លាស្ទិច និងធ្វើបង្ហាញ

លោក **ហ៊ុន សៅ** ដែលជាអ្នកទទួលផលពីគម្រោង វគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីអណ្តែង ក្នុងស្បោងប្លាស្ទិច របស់ ខ័ណ្ឌរដ្ឋជលផលខេត្តកំពង់ឆ្នាំង ។








នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០ក្រុមការងារវាយតម្លៃអនុកិច្ចសន្យារបស់ គណៈកម្មាធិការប្រតិបត្តិខេត្តកំពង់ឆ្នាំង បានចុះជួបសម្ភាសន៍ជាមួយ លោក **ហ៊ុន សៅ** រស់នៅ ភូមិ ត្រពាំងអំពិល ឃុំប្រស្និប ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

លោក **ហ៊ុន សៅ** ជាកសិករមួយរូបក្នុងចំណោមកសិកទាំង២៥រូប ដែលបានចូលរួមវគ្គបណ្តុះបណ្តាលអំពី បច្ចេកទេសចិញ្ចឹមត្រីអណ្តែងក្នុងស្បោងប្លាស្ទិច។ គាត់មានអាយុ ៥១ ឆ្នាំ មានកូនចំនួន ៧ នាក់ ស្រី ៥នាក់ ដែល កូនគាត់មួយនាក់ទើបតែមានគ្រួសារ។ លោកបានមានប្រសាសន៍ថា គម្រោងបណ្តុះបណ្តាល អំពីបច្ចេកទេសចិញ្ចឹម ត្រីអណ្តែងក្នុងស្បោងប្លាស្ទិចនេះមានសារៈសំខាន់ខ្លាំងណាស់ ព្រោះគាត់បានទទួល ចំណេះដឹងជំនាញជាច្រើន ពី ររៀបចិញ្ចឹមត្រីអណ្តែងក្នុងស្បោងប្លាស្ទិច ហើយអាចមានលទ្ធភាព កែឆ្នៃកន្លែងចិញ្ចឹមត្រីពីការដាក់ស្បោងទៅជា ការរៀបឥដ្ឋ ដើម្បីឱ្យមានរយៈពេលវែងក្នុងចិញ្ចឹម ។ គាត់បានបញ្ជាក់ថា កូនត្រីអណ្តែងអាចទាញ យកផលបានក្នុង កំឡុងពី ២ខែ ទៅ៣ខែ ហើយអាចចាប់ធ្វើម្ហូបពី ១ គ.ក ទៅ ១.៥ គ.ក ក្នុងម្តង១។ ក្នុងមួយខែយើងអាច ចាប់ត្រីបាន ១ដង ទៅ២ដង ។ លើសពីនេះទៅទៀត គាត់អាចលក់បានក្នុងតម្លៃ ៦,000រៀល ក្នុងមួយ គីឡូក្រាម។ បន្ថែមពីលើនេះទៀត គាត់អាចយកទឹកដែលចិញ្ចឹមត្រីទៅស្រោចដំណាំផ្សេង១ ឬស្រូវ បានយ៉ាងល្អ ព្រោះទឹកមានជីជាតិល្អ។ ជាងនេះទៅទៀតគ្រួសាររបស់គាត់មានភាពជីវភាពប្រសើរឡើង ដោយសារគាត់មាន ប្រភពចំណូលមួយយ៉ាងល្អដែលមិនចាំបាច់ស្វះស្វែងរកម្ហូប នៅពេលដែលគាត់មានការរវល់ខ្លាំង វីក៏ត្រូវការចាំបាច់ មិនតែប៉ុណ្ណោះ បានកាត់បន្ថយការដើលេងរបស់កូន១ ដោយពួកគេត្រូវរកចំណីដែលមានស្រាប់នៅក្នុងភូមិសម្រាប់ ឱ្យត្រីស៊ី។ មកទល់បច្ចុប្បន្ន ការចិញ្ចឹមត្រីរបស់គាត់នៅតែបន្ត នឹងទៅថ្ងៃអនាគតគាត់នឹងពង្រីកការចិញ្ចឹមត្រីនៅផ្ទះ របស់គាត់មួយទៀតដែលគាត់នឹងធ្វើការសាងសង់នាពេលខាងមុខ។ ទន្ទឹមនឹងនោះ គាត់ក៏បានបង្ហាញពីឆន្ទះ ក្នុងការចែករំលែកបទពិសោធន៍ដល់អ្នកភូមិទាំងឡាយណាដែលចង់ដឹង នឹងស្វែងយល់ពីការចិញ្ចឹមត្រីនេះផងដែរ ។

ចុងបញ្ចប់នៃការជួបសម្ភាសន៍គាត់ក៏បង្ហាញនូវការប្តេជ្ញាចិត្ត និងទឹកចិត្តក្នុងថែរក្សា និងបន្តការចិញ្ចឹមត្រីនេះ បានល្អទោះជាមានការរវល់យ៉ាងណាក៏ដោយ ព្រោះការចិញ្ចឹមត្រីមានផលប្រយោជន៍ យ៉ាងច្រើនដល់គ្រួសារគាត់គឺ:

- គាត់ចិញ្ចឹមត្រី បានទទួលត្រីហូបដែលមានជាតិប្រូតេអ៊ិន(ជីវសាស្ត្រ) ក្រុមគ្រួសារពុំមានជំងឺ
- កាត់បន្ថយការចំណាយនៅក្នុងគ្រួសារ មួយក៏វិតធំ លើការចំណាយទិញត្រី សម្រាប់ធ្វើម្ហូប

- បង្កើនប្រាក់ចំណូលក្នុងគ្រួសារ ដោយគាត់ចិញ្ចឹមត្រីបានលក់ក្នុងមួយខែពី ២-៣ គីឡូក្រាម
- ចំណេញពេលវេលា ពុំចំណាយពេលឆ្ងាយពីផ្ទះក្នុងស្វែងរកទិញត្រី និង ទៅរកនេសាទត្រី ។
- គាត់អាចយកទឹកកាកសំណល់ដែលស្អារពីស្រះត្រីចិញ្ចឹម មកធ្វើជាជី សម្រាប់ស្រោចដំណាំបន្លែ ។
- ធ្វើឱ្យជីវភាពសមរម្យ មានសុខភាពល្អ មិនមានជំងឺ ។

**ករណីសិក្សាទី២ :**

**អ្នកមិនបានទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងបណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីអណ្តែងក្នុងស្បោងប្លាស្ទិច**





លោក **សន ខេង** អាយុ៥៤ ឆ្នាំ ភេទប្រុស ជាប្រជាជនរស់នៅ ភូមិត្រពាំងអំពិល ឃុំប្រស្និប ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ គាត់មានគ្រួសារ និងមានកូនចំនួន៣ នាក់ ( ស្រី ២នាក់ )។ គាត់ជាកសិករ ដែលមានចំណូលពីការធ្វើស្រែ និងឡើងត្នោត។ លោក **សន ខេង** មិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលចិញ្ចឹម ត្រីអណ្តែងក្នុងស្បោងប្លាស្ទិចនៅក្នុងភូមិត្រពាំងអំពិលទេ។ គាត់មិនបានត្រូវគេជ្រើសរើសឱ្យចូលរួមដោយសារគាត់រវល់ នឹងមុខរបររបស់គាត់ ដូច្នេះនៅពេលដែលប្រធានភូមិចុះមកជ្រើសរើសអ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលគាត់មិនបាននូវផ្ទះ។ គាត់បានបន្តទៀតថា វគ្គបណ្តុះបណ្តាលចិញ្ចឹមត្រីអណ្តែងក្នុងស្បោងប្លាស្ទិចនេះមានសារៈសំខាន់ ដើម្បីឱ្យជីវភាពសមរម្យ ព្រោះបានត្រីហូប ពុំឱ្យពិបាកទិញត្រីផង និងអាចលក់បានប្រាក់ខ្លះៗទៀតផង។ គាត់បានឃើញអ្នកជិតខាងគាត់ ឈ្មោះ **សៅ** ដែលបានចូលរួមវគ្គបណ្តុះបណ្តាលចិញ្ចឹមត្រីអណ្តែងក្នុងស្បោងប្លាស្ទិចនេះ ទទួលបានចំណេះដឹង និងជំនាញបច្ចេកទេស ក្នុងការចិញ្ចឹមត្រីអណ្តែងទទួលបានផលច្រើន។ គាត់បានបន្តទៀតថា កាលពីមុន បង សៅ

គាត់មិនទាន់បាន ទទួលវគ្គបណ្តុះបណ្តាលនេះ គាត់ពិបាកក្នុងការស្វែងរកម្ហូបពីព្រោះកូនរបស់ច្រើន ពេលធ្វើម្ហូបត្រូវការធ្វើឱ្យច្រើនបាន ហូបគ្រប់។ ឥឡូវនេះគ្រួសាររបស់គាត់ មានការហូបចុកគ្រប់គ្រាន់ ដោយមានត្រីសម្រាប់ធ្វើម្ហូប និងមានបន្លែដែលមិន ជាតិពុលសម្រាប់ហូប។ បច្ចុប្បន្នគាត់មានជីវភាព មានការហូបចុកគ្រប់គ្រាន់ កូនចៅបានចូលរៀនគ្រប់ៗគ្នា និងមាន សុខភាពល្អពុំមានជំងឺ។

លោក **សន ខេង** គាត់មានសង្ឃឹមថាអាចបានចូលរួមវគ្គបណ្តុះបណ្តាល ចិញ្ចឹមត្រីអណ្តែង ក្នុងស្បោងប្លាស្ទិច ដើម្បីឱ្យបានទទួលផលប្រយោជន៍ដូចអ្នកជិតខាងរបស់គាត់ដែរ ហើយគាត់និយាយថា បើគាត់ត្រូវបានគេជ្រើសរើសឱ្យចិញ្ចឹមត្រីគាត់និងចូលរួម ។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

( ពិន្ទុ : ១=ខ្សោយណាស់ ២=ខ្សោយ ៣=មិនខ្លាំងមិនខ្សោយ ៤=ខ្លាំង ៥=ខ្លាំងណាស់ )

**ផ្នែក-ក: ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅនឹងតំរូវការ:**

| ល.រ (១) | ធាតុ (២) | ទំនាក់ទំនងតក្កភាព (៣) | បរិយាយច្បាស់លាស់ (៤) | សង្ខេបការវាយតម្លៃ (៥) |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៥ | ៥ | សកម្មភាពដែលបានលើកឡើងមានទំនាក់ទំនងជាមួយ និងលទ្ធផលដោយសកម្មភាពនីមួយៗមានការឆ្លើយតបគ្នាទៅវិញទៅមក និងធ្វើលទ្ធផលនីមួយៗ សម្រេចបានបានល្អនៅពេលដែលសកម្មភាពបានអនុវត្តចប់ ។ ហើយក្នុងសកម្មភាពនិមួយៗក៏បានបង្ហាញចំនួនវគ្គ ចំនួនអ្នកចូលរួម ចំនួនថ្ងៃ រយះពេលនិង មានលម្អិត សម្ភារ:ប្រើប្រាស់ច្បាស់លាស់ ។ ដូចជាវគ្គបណ្តុះបណ្តាលចិញ្ចឹមត្រីអណ្តែង ក្នុងស្បោងប្លាស្ទិច ១ វគ្គមានអ្នកចូលរួម ២៥ នាក់ គឺបានជ្រើសរើស កសិករគោលដៅ៥នាក់ដើម្បីធ្វើបង្ហាញ គំរូឱ្យអ្នកចូលរួមឃើញពីប្រសិទ្ធភាព គម្រោង ។ គ្រប់សកម្មភាពនិមួយៗ មានសរសេរច្បាស់លាស់ពីចំនួនវគ្គពី ចំនួនអ្នកចូលរួមនិងការគ្រោងមានខ្ទង់ |

| | | | | |
|---|---|---|---|---|
| | | | | ចំណាយត្រឹមត្រូវដែលធានាដល់ការអនុវត្ត ។ |
| ២ | លទ្ធផល | ៥ | ៥ | ក្នុងលទ្ធផលនិមួយៗមានទំនាក់ទំនងគ្នាពីលទ្ធផលមួយទៅមួយ ដោយបង្ហាញពី បង្កើតសហគមន៍មួយត្រូវមាន ដំណើរ ការនៃការរៀបចំ និងមានលទ្ធផល ពង្រីក សមត្ថភាព ចំណេះដឹង ជំនាញ និងមានការផ្សព្វផ្សាយច្បាប់លើអនុវត្តគម្រោង ។ លទ្ធផលនិមួយៗមានភាពទំនាក់ទំនងគ្នាល្អដើម្បីសម្រេចទិសដៅបន្ទាន់ ។តែទោះជាយ៉ាងនេះក្តីលទ្ធផលនៅក្នុងអនុកិច្ចសន្យាមិនអាចសម្រេចទិសដៅបន្ទាន់ល្អនៅឡើយទេ។ ការសិក្សាក៏បានវិភាគទៅលើគុណភាពទូទៅរបស់សេវាកម្មដែលបានផ្តល់ ខ្លឹមសារសេវាកម្ម សមត្ថភាពជំនាញ ភ្នាក់ងារផ្តល់សេវាកម្ម និង ការត្រៀម រៀបចំ ចាត់ចែង ពេលវេលា ទីកន្លែង និងការអញ្ជើញអ្នកចូលរួម ។ ចំលើយ តបពីក្រុមអ្នកទទួលផល បានបង្ហាញជាទូទៅពួកគេភាគច្រើនជាផ្តល់ចំលើយ វិជ្ជមានលើទិដ្ឋភាពខាងលើនេះ គឺរីតពេញចិត្តយ៉ាងខ្លាំង ចំពោះលទ្ធផល |
| ៣ | អត្ថប្រយោជន៍រយៈពេលខ្លី: | ៤ | ៤ | គោលបំណងបន្ទាន់បរិយាយបានច្បាស់ |

| | | | | |
|---|---|---|---|---|
| | (លទ្ធផល/ផលប្រយោជន៍)<br>- គោលបំណងបន្ទាន់<br>*(គោលបំណងស្ថិតក្នុងចំណុច "ខ" នៃផ្នែកទី ៣)* | | | លាស់ ពីការជួយដល់ប្រជាពលរដ្ឋអំពីយល់ដឹងពីច្បាប់ និងអនុវត្តច្បាប់ការអភិរក្សប្រភពធនធានជលផលឱ្យមាននិរន្តរភាព ។<br>តែទិសដៅបន្ទាន់នេះ មានវិសាលភាពធំ តែការអនុវត្តសកម្ម ភាពស្ថិតក្នុងតំបន់គោលដៅតិចតួច ។<br>អ្នកទទួលផលយល់ឃើញថា សេវាកម្មដែលបានផ្តល់វាជាតំរូវការចាំបាច់របស់ពួកគាត់ ។ |
| ៤ | -ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា<br>*(ចំណុច "គ" នៃផ្នែកទី ៣)* | ៥ | ៥ | ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា លទ្ធផល សកម្មភាពបានសម្រេចតាមការគ្រោងទុករបស់អនុកិច្ចសន្យាបានល្អ ដោយគម្រោងមាននិរន្តរភាពបានយូររហូតដល់បច្ចុប្បន្ន ប្រជាពលរដ្ឋមានការចូលរួមនិងមានការគាំទ្រពីអាជ្ញាធរគ្រប់ថ្នាក់ ។ គម្រោងបាននិងកំពុងរីកសាយភាយ និងមានការពេញចិត្តខ្លាំងពអ្នកទទួលផល ។ |
| ៥ | លទ្ធផលអភិវឌ្ឍន៍/ផលប៉ះពាល់រយៈ ពេលវែងៈ<br>គោលដៅ<br>និងគោលបំណងអភិវឌ្ឍន៍ *(ចំណុច "ខ" នៃផ្នែកទី ៣)* | | | មិនអាចធ្វើការវាយតម្លៃបាន |

## ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខ័ណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារ:

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.ជ.អ.ខ:** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | -ការរៀបចំអនុកិច្ចសន្យាមានក៏រិតជាបង្គួរ ដោយមានបទពិសោធន៏ រៀបចំគម្រោងជាមួយអង្គការផ្សេងៗ តែទោះជាយ៉ាងណាក៏ដោយ តម្រូវឱ្យមានការគាំទ្របន្ថែមពីគ.ប្រ និងទីប្រឹក្សា លើការរៀបចំអនុកិច្ចសន្យាតាមប្រព័ន្ធ NCD ។<br>-ចំណេះដឹង និងបទពិសោធន៏លើការចូលរួម លើដំណើរការការអនុវត្តន៏ប្រព័ន្ធផែនការនៃកម្មវិធី រហូតដល់ដំណាក់កាលរៀបចំជាគំរោងនានាក្នុងអនុកិច្ចសន្យាគំរោងត្រូវបានរៀបចំឡើង ដោយផ្អែកលើតំរូវការមូលដ្ឋាន និងគោលនយោបាយវិស័យជលផលរបស់រដ្ឋាភិបាល។ ការចាត់ចែងរៀបចំសរសេរឯកសារអនុកិច្ចសន្យា អាចគ្រប់គ្រងបានជាពីសេសផ្នែកទី I និងII ។ រីឯការប្រើប្រាស់ប្រព័ន្ធទិន្នន័យកិច្ចសន្យាអាចបញ្ចូលទិន្នន័យអនុកិច្ចសន្យាទៅក្នុងប្រព័ន្ធ ដែលជាការជួយសំរួលពីផ្នែកគ្រប់គ្រងកិច្ចសន្យាដើម្បីរៀបចំកិច្ចសន្យា ។<br>-លើការចាត់ចែងរៀបចំសរសេរឯកសារអនុកិច្ចសន្យា នៅមាន ការខ្វះខាត លើការចូលរួមពីអ្នកពាក់ព័ន្ធ មានចន្លោះប្រហោង ព័តិមាន មិនបានបំពេញពិសេសសូចនាករសម្រាប់វាស់វែង ។ |
| ២ | ការគាំទ្រ និងការត្រួតពិនិត្យការអនុវត្តន៏របស់ភ្នាក់ងារអនុវត្តន៏ | -មានការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យការអនុវត្តន៏ គម្រោងដល់មូលដ្ឋាន ។<br>-ការងារតាមដានត្រួតពិនិត្យគឺជាកិច្ចការចាំបាច់ ដើម្បីផ្តល់ឱ្យនូវគណនេយ្យភាព តំល្លាភាព ការមើលឃើញភាពខ្វះខាត និងការ ធ្វើការកែលំអការអនុវត្តន៏ឱ្យមានប្រសិទ្ធិភាព និងភាពសក្តិសិទ្ធ ប្រកបដោយនិរន្តរភាព។ |

| | | |
|---|---|---|
| | | –ខណ្ឌរដ្ឋបាលជលផលបានតែងតាំង ជនបង្គោលតាមដាន ត្រួតពិនិត្យនិងវាយតំលៃ ពួកគេទាំងនោះ បានចូលរួមវគ្គតំរង់ទិស និងកិច្ចប្រជុំពង្រឹងការអនុវត្តន៏ ដែលរៀបចំដោយគ.ប្រ ដើម្បីផ្តល់ការគាំទ្រការអនុវត្តសកម្មភាពរបស់អនុកិច្ច សន្យា។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារអនុកិច្ចសន្យា | -ឧបករណ៏តាមដានត្រួតពិនិត្យ វាយតំលៃដែលបានណែនាំឱ្យប្រើ ពុំទាន់បានប្រើឱ្យចំទិសដៅ ឬពុំបានប្រើ ដូចនេះខណ្ឌពុំមានព័តិមាន ទុកដាក់គ្រប់គ្រាន់ ពុំមានប្រព័ន្ធកត់ត្រាជាឯកសារសំរាប់ការ សរសេរ របាយការណ៏តាមដាន និងវាយតំលៃ។<br>- មានការរៀបចំប្រជុំត្រឹមត្រូវដើម្បីពិនិត្យការរីកចំរើន ការអនុវត្តន៏ និងផ្តល់ចំលើយតបឬអនុសាសន៏ ពីការរកឃើញពីការត្រួតពិនិត្យ។ |
| **ពីខាងភាគីអនុវត្តន៏កិច្ចសន្យា:** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | -ជំនាញគ្រប់គ្រងគម្រោង មន្ត្រីទាំងអស់សុទ្ធតែបានចប់សញ្ញាប័ត្របរិញ្ញាបត្រ និងអនុបណ្ឌិត និងមានបទពិសោធន៏យ៉ាងច្រើនក្នុងគ្រប់គ្រងទូទៅ និងបច្ចេកទេស គឺមានសមត្ថភាព គ្រប់គ្រាន់ ។<br>-មន្ត្រីមានជំនាញ និងមានឆន្ទៈក្នុងការគ្រប់គ្រង និងអនុវត្តគម្រោង |
| ៥ | ការអនុវត្តសកម្មភាព | ការអនុវត្តន៏ទៅតាមអ្វីបានគ្រោងទុកក្នុងអនុកិច្ចសន្យា ដោយមានត្រួតពិនិត្យលើសកម្មភាពដែលបានអនុវត្តនៅមូលដ្ឋាន ហើយមន្ត្រីទំាងអស់សុទ្ធតែមានជំនាញ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោង ។ ការគាំទ្រផ្នែកហិរញ្ញវត្ថុមានបញ្ហា ប្រឈមមួយចំនួន ដោយមានសំនុំឯកសារច្រើនមន្ទីរ មិនធ្លាប់បាន |

| | | |
|---|---|---|
| | | ជួយប្រទះដូចនេះមានបញ្ហាខ្លះក្នុងរៀបចំឯកសារ ទូទាត់ ។ |
| ៦ | របាយការណ៍ | -របាយការណ៍ការរីកចំរើន នៅមាន កម្រិតដោយមានខែត្រីមាស ខ្លះមានការយឺតយ៉ាវ និងព័ត៌មាន ពុំសូវច្បាស់ ( ខ្វះទិន្នន័យដែលចង់បាន ) ។<br>- ការបូកសរុបរបាយការណ៍មានការយឺតយ៉ាវខ្លះៗ ដោយសារ មន្ត្រីតាមដានត្រួតពិនិត្យ និង វាយតម្លៃ ត្រូវបំពេញ ការងារ ស្ទួល ក៏ដូចជាការសហាកការណ៍ជាមួយអង្គការក្រៅរដ្ឋាភិបាល មានការមមាញឹកច្រើន ។ -ការប្រើប្រាស់ប្រពន្ធ័ទិន្នន័យកិច្ចសន្យា (NCD) នៅមិនទាន់ដំណើការបានទាន់ពេល និងល្អនៅឡើយ ដោយមូលហេតុ ឧបករណ៏ ប្រើប្រាស់មានសភាពចាស់ ទ្រុឌទ្រោម (កុំព្យូទ័រខូច) |
| ៧ | លក្ខខណ្ឌកិច្ចសន្យា | បានអនុវត្តន៏ទៅតាមលក្ខណ្ឌ័ក្នុងកិច្ចសន្យា។ មិនមានបញ្ហាអ្វីដែល ធ្វើឱ្យរាំងស្ទះដល់ការអនុវត្តអនុកិច្ចសន្យាឡើយ |
| **ទាំងខាង គ.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យា:** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" (ចំណុច-ង ផ្នែកទី៣ ) និងបញ្ហាប្រឈម | អនុវត្តន៏គម្រោងបានតាមការគ្រោងទុក។ |
| ៩ | ការបញ្ជ្រាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | គម្រោងអនុវត្តមានចូលរួមពីស្ត្រីយ៉ាងច្រើន តាមរយៈការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ដែលចំនួនអ្នកទទួលផល ២,៥០០ នាក់ ក្នុងនោះមានស្រីរហូតដល់ ១,២០០ នាក់ ។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ ( ចំណុច-ឆ ផ្នែកទី៣) | គម្រោងនេះមានលក្ខណៈជាការគ្រប់គ្រងធនធានធម្មជាតិ គឺគ្រប់សកម្មភាពសុទ្ធតែការពារធនធានធម្មជាតិជាពិសេស ធនធានជលផល ។ |
| ១១ | ការថែរក្សា (និរន្តភាព) ( ចំណុច-ជ ផ្នែកទី៣) | គម្រោងទាំងអស់ភាគច្រើនមាននិរន្តភាពបានយូរ ។ |

## ២.៤. សេចក្តីសន្និដ្ឋាន

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យានេះត្រូវបានអនុវត្តសម្រេចបានតាមផែនការការងារដែលបានគ្រោង ។ អ្នកអនុវត្តអនុកិច្ចសន្យាមានសមត្ថភាព ជំនាញ និងធនធានគ្រប់គ្រាន់ដើម្បីអនុវត្តអនុកិច្ចសន្យា ។ សកម្មភាព និង លទ្ធផលភាគច្រើនដែលបានគ្រោងទុកត្រូវបានបញ្ចប់ស្របតាមផែនការការងារ ។សកម្មភាពមួយចំនួនតូចអនុវត្តមានការយឺតយ៉ាវមិនស្របតាមផែនការការងារក្នុងអនុកិច្ចសន្យា ដោយពេលដែលអនុវត្តសកម្មភាព ត្រូវជាន់ជាមួយគម្រោងកម្មវិធីផ្សេង ។ |
| ២ | សកម្មភាពរបស់អនុកិច្ចសន្យា និង អត្ថប្រយោជន៍ដែលសហគមន៍ទទួលបានយ៉ាងពេញចិត្ត ចំពោះអ្នកទទួលផល និងអ្នកមិនទទួលផលផងដែរ នៅក្នុងឃុំដែលអនុវត្តសកម្មភាពបណ្តុះបណ្តាលបច្ចេកទេស ចិញ្ចឹមត្រីក្នុងថង់ផ្លាស្ទិចនិងការបង្ហាញ ដែលក្រុមការងារចុះធ្វើការវាយតម្លៃ ដោយចុះទៅសម្ភាសន៍ និងពិនិត្យនូវស្ថានភាពជាក់ស្តែងនៅតាមមូលដ្ឋាន បានបង្ហាញឱ្យឃើញភស្តុតាងអំពីលទ្ធផល និងផលប្រយោជន៍ដែលទទួលបានយើងបានសង្កេតឃើញក្រោយពីអនុកិច្ចសន្យាត្រូវបានបញ្ចប់ ដូចជា :<br>- កសិករដែលទទួលផលពី វគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីអណ្តែងក្នុងស្បោងប្លាស្ទិច និងធ្វើបង្ហាញ បានយកចំណេះដឹង និងជំនាញនេះ ដើម្បីបន្តការអនុវត្ត និងមានការសាយភាយដល់កសិក៤រូប ផ្សេងទៀតផងដែរ ហើយពួកគាត់ក៏មានការតាំងចិត្តក្នុងការធ្វើបង្ហាញពីភាពជោគជយ័ដល់អ្នកដែលមិនបានចូលរួមក្នុងវគ្គនេះ ។<br>- ផលប្រយោជន៍ពីគម្រោងនេះគាត់ ទទួលបានទទួលត្រីហូប កាត់បន្ថយការចំណាយនៅក្នុងគ្រួសារមួយកំរិតធំលើការចំណាយទិញត្រីសម្រាប់ធ្វើម្ហូប បង្កើនប្រាក់ចំណូលក្នុងគ្រួសារបានមួយកំរិត និងធ្វើឱ្យជីវភាពធូធារ មានសុខភាពល ម្យ៉ាងទៀតគាត់អាចយកទឹកកាកសំណល់ដែលត្រូវស្តារពីស្រះត្រីចិញ្ចឹមមកធ្វើជាជី សម្រាប់ស្រោចដំណាំបន្លែ និងឈើហូបផ្លែផងដែរ ។<br>-វគ្គបណ្តុះបណ្តាលនេះពិតជាឆ្លើយតបតាមតម្រូវការ និងសំណូមពររបស់អ្នកភូមិជាច្រើនទៀតដែលមានស្ថានភាពស្រដៀងគ្នាគឺប្រកបរបរចំបងធ្វើស្រែចំការហើយមានតំរូវការចិញ្ចឹមត្រីបន្ថែមទៀតស្របនិងស្ថានភាពសហគមន៍របស់គាត់ ។<br>ដូច្នេះ អនុកិច្ចសន្យានេះ ទទួលនិរន្តភាពក្នុងសកម្មភាពរបស់ខ្លួន កំរិតខ្ពស់ ហើយវាជាការចូលរួមចំណែកក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍ នៅក្នុងអនុកិច្ចសន្យា ។ |
| ៣ | ការអនុវត្តអនុកិច្ចសន្យានេះទទួលបានជោគជ័យមិនមានជួបប្រទះនូវឧបសគ្គនិងបញ្ហាប្រឈមគួរឱ្យកត់សំគាល់ |

<u>ចំណុចរៀនសូត្រៈ</u>

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ការបរិយាយពី គោលបំណងបន្ទាន់ មានលក្ខណៈច្បាស់លាស់មានសារៈសំខាន់សម្រាប់ការកត់ត្រាទុកនូវលទ្ធផលអនុកិច្ចសន្យា និងផលប្រយោជន៏ដែលមាន ដើម្បីការវាយតម្លៃលទ្ធផល ។ |
| ២ | ការអនុវត្តអនុកិច្ចសន្យាបានទទួលជោគជ័យ គឺដោយសារមានការចូលរួមគាំទ្រថវិកា និង បច្ចេកទេសពីកម្មវិធី គ.ជ.អ.ប ជាពិសេសការសហការរវាងថ្នាក់ដឹកនាំមន្ត្រីគ្រប់ជាន់ថ្នាក់នៅក្នុងខណ្ឌរដ្ឋបាលជលផល និងក្រុមប្រឹក្សា ឃុំ ក៏ដូចជាជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារ មេភូមិ ប្រជាពលរដ្ឋដែលបានចូលរួមកសាងផែនការ សំរាប់អភិវឌ្ឍន៏ និងរួមចំណែកអភិវឌ្ឍន៏មូលដ្ឋាន។ |
| ៣ | ធនធានមនុស្សសម្រាប់អនុវត្តអនុកិច្ចសន្យា មានចំណេះដឹងស្រាប់ អំពីនិតិវិធី គោលការណ៍ និងបទដ្ឋាននានា ហើយពួកគេក៏ងាយនឹងយល់ដឹងលើការបង្កើតបន្ថែមថ្មីដោយកម្មវិធីថ្មីផងដែរ ។ |
| ៤ | ខណ្ឌរដ្ឋបាលជលផលបានអនុកិច្ចសន្យាជាមួយគ.អ.ជ.ខ/គ.ប្រក្នុងឆ្នាំកន្លងមក ទទួលបាននូវបទពិសោធន៏ពេញលេញក្នុងការគ្រោងអនុកិច្ចសន្យា គ្រប់គ្រងថវិកា ការធ្វើផែនការ និងការអនុវត្តន៏ ។ ទាំងនេះបានបង្ហាញពីតំលៃនៃការផ្លាស់ប្តូរប្រកបដោយគុណភាព សមត្ថភាពអនុវត្តរបស់មន្ត្រី និងការលើកទឹកចិត្តជំរុញឱ្យ មានការទទួលខុសត្រូវ ធានាបាននូវតម្លាភាព គណនេយ្យភាព និងការពង្រឹងប្រសិទ្ធិភាពការងារ។ កម្មវិធីមានគោលការណ៏ណែនាំហិរញ្ញវត្ថុ និងរដ្ឋបាលច្បាស់លាស់សម្រាប់ការអនុវត្តសកម្មភាព ។ |
| ៥ | គោលការណ៏ ណែនាំហិរញ្ញវត្ថុ និងរដ្ឋបាលច្បាស់លាស់នៅក្នុងកម្មវិធីមួយ គឺជាឧបករណ៏គ្រប់គ្រង ដ៏មានសារៈសំខាន់ណាស់ ដើម្បីឱ្យការអនុវត្តកម្មវិធីដើរទៅតាមដំត្រឹមត្រូវ ដែលធ្វើឱ្យការអនុវត្តសកម្មភាពនៅក្នុងអនុកិច្ចសន្យា មានលក្ខណៈជាបទដ្ឋាន ។ |

## ២.៥ អនុសាសន៍

| ល.រ | អនុសាសន៍ |
|---|---|
| ១ | នូវក្នុងផ្នែកទី៣ សូមបរិយាយអោយបានច្បាស់ ទាក់ទងទៅលទ្ធផលបន្ទាន់ និងអត្ថប្រយោជន៍ដែលរំពឹងទុក និងបញ្ជាក់ពី សូចនាករសម្រាប់វាស់វែងឱ្យបានច្បាស់លាស់ ។ |
| ២ | ការរៀបចំអនុកិច្ចសន្យាគួររៀបចំឱ្យមានទំនាក់ទំនងលទ្ធផលឱ្យបានល្អបន្ថែមទៀត ពិសេសនៅក្នុងផ្នែកទី៣នៃអនុកិច្ចសន្យា ។ |
| ៣ | នៅក្នុងផ្នែកទី៣នៃអនុកិច្ចសន្យាគួរបង្កើតក្របខ័ណ្ឌ ការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីងាយស្រួល ក្នុងដំណើរការវាយតម្លៃផលប្រយោជន៍ និង ប្រសិទ្ធិភាពអនុកិច្ចសន្យា ។ |
| ៤ | ការជ្រើសរើសក្រុមគោលដៅ ដើម្បីអោយមានប្រសិទ្ធភាព គួរជ្រើសរើសអ្នកដែលមានតម្រូវការ និងមានស្ថាន ភាពសមស្រប និង សកម្មភាពរបស់អនុកិច្ចសន្យា ។ ដំណើរការជ្រើសរើសក្រុមគោលដៅគួរតែបង្កើតលក្ខណៈវិនិច្ឆ័យឱ្យបានសមស្រប និងមានមូលដ្ឋានបង្អែកត្រឹមត្រូវ ។ |
| ៥ | មន្ត្រីត្រួតពិនិត្យ ត្រូវប្រើប្រាស់ទម្រង់ទី៨ដែល គ.ប្របានផ្តល់អោយ ដើម្បីធ្វើការតាមដានការអនុវត្តគម្រោងក៏ដូចជាការផ្តល់យោបល់ត្រឡប់ ។ ប្រការនេះ គឺតំរូវឱ្យមានការគិតឡើងវិញដោយការរៀបចំការប្រជុំជនបង្គោលត្រួតពិនិត្យ វាយតំលៃដើម្បីតំរង់ទិស និងកែលំអរការងារត្រួតពិនិត្យ ជាមួយមន្ត្រីអនុវត្ត។ |

## ឯកសារភ្ជាប់ជាមួយនឹងរបាយការណ៍

### ឯកសារទី១ : បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបាន ពិនិត្យ

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) | មាន (៣) |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និង ឯកសារវិសោធនកម្ម (ប្រសិនមាន) | √ |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ | √ |
| ៣ | របាយការណ៍ត្រួតពិនិត្យគម្រោង | |
| ៤ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | √ |
| ៥ | លិខិតឆ្លើយឆ្លងរវាងភ្នាក់ងារអនុវត្តន៍ និងគណ:កម្មាធិការប្រត្តិបត្តិគ.អ.ជ.ខ | |
| ៦ | បញ្ជីវត្ថុបណ្តុះបណ្តាលដែលមានក្នុងអនុកិច្ចសន្យា | √ |
| ៧ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា | |
| ៨ | ឯកសារដ៏ទៃទៀតរួមមាន រូបថតនៃគម្រោង (អនុកិច្ចសន្យា) ដែលទុកនៅ គណ:កម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ និងនៅភ្នាក់ងារអនុវត្តន៍ ដែលមិនបានរៀបរាប់ខាងលើ | √ |
| ៩ | ផ្សេងទៀត | |

# ឯកសារភ្ជាប់ទី២ : ឯកសារអនុកិច្ចសន្យា លេខ (04/AGR02/0901-01) ខេត្តកំពង់ឆ្នាំង

## បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាស/ជួបពិភាក្សា

| ល.រ | ថ្ងៃខែ | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា | ទីកន្លែង | ឧបករណ៍ប្រើសម្រាប់ប្រមូលទិន្នន័យដែលបានប្រើ |
|---|---|---|---|---|
| ១ | ២៥ តុលា (ពេលព្រឹក) | សំភាសន៍អ្នកគ្រប់គ្រងរៀបចំអនុកិច្ចសន្យា<br>១-លោក កែវ ថាយ នាយខ័ណ្ឌរដ្ឋបាលជលផល<br>២-លោក សេង ប៊ុនឈឿន, នាយរងខ័ណ្ឌរដ្ឋបាលជលផល<br>៤- លោក អ៊ុយ សោភា មន្ត្រីរៀបចំអនុកិច្ចសន្យា | ខណ្ឌរដ្ឋបាលជលផល | សម្ភាសន៍ស៊ីជម្រៅ |
| ២ | ២៥ តុលា (ពេលល្ងាច | សំភាសន៍អ្នកពាក់ព័ន្ធ<br>១-លោក ឆាយ តឿ ទីប្រឹក្សាត្រួតពិនិត្យ និងវាយតម្លៃ | គ.ប្រ | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | ២៦ តុលា (ពេលព្រឹក) | សំភាសន៍ស៊ីជំរៅក្រុមអ្នកទទួលផល៨នាក់ | ភូមិត្រពាំងអំពិល | សម្ភាសន៍ជាក្រុម |
| ៤ | ២៦ តុលា ពេលល្ងាច | សម្ភាសស៊ីជម្រៅ/ករណីសិក្សា អ្នកទទួលផល<br>លោក ហ៊ុន សៅ | ភូមិត្រពាំងអំពិល | សម្ភាសស៊ីជម្រៅ /ករណីសិក្សា |
| ៥ | ២៦ តុលា ពេលល្ងាច) | សម្ភាសស៊ីជម្រៅ/ករណីសិក្សា អ្នកមិនទទួលផល<br>លោក សន ខេង | ភូមិត្រពាំងអំពិល ឃុំប្រស្និប ស្រុករលាប្អៀរ | សម្ភាសស៊ីជម្រៅ /ករណីសិក្សា |
| ៦ | ២៦ តុលា ពេលល្ងាច) | សំភាសន៍អ្នកពាក់ព័ន្ធ<br>១-លោក មេភូមិត្រពាំងអំពិល | ភូមិត្រពាំងអំពិល ឃុំប្រស្និប ស្រុករលាប្អៀរ | សម្ភាសន៍ស៊ីជម្រៅ |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | **05/AGR/0901-01 (GOV)** |
| ចំណងជើង: | គាំទ្រប្រព័ន្ធកសិកម្មសមស្របនិងលើកកំពស់ជីវភាពរស់នៅ |
| ភ្នាក់ងារអនុវត្តន៍ : | មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ - ការិយាល័យក្សេត្រសាស្ត្រ |
| រយៈពេល (ចាប់ផ្តើម និងបញ្ចាប់) | ចាប់ផ្តើម: 01/01/2009 និង បញ្ចប់: 31/12/2009 |
| រាជធានី ខេត្ត | កំពង់ស្ពឺ |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ/ គ.អ.ជ.ខ | 20,400 ដុល្លារសហរដ្ឋអាមេរិច |
| ការរួមចំណែករបស់រាជធានី ខេត្ត | គ្មាន |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៍ | គ្មាន |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | 20,400 ដុល្លារសហរដ្ឋអាមេរិច |

## ក្រុមវាយតម្លៃ

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ |
|---|---|
| ១-លោក ហ៊ុន ប៊ុនរ៉ា | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ គ.ប្រ ( គ្រូបង្គោល ) |
| ២-លោក អ៊ុំ ដេត | អនុប្រធានមន្ទីរផែនការ (គ្រូបង្គោល ) |
| ៣-លោក ជឿង ជឿន | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ គ.ប្រ |
| ៤-លោក ណុប ព្រីន | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ គ.ប្រ |
| ៥-លោក ខាត់ ភាព | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ គ.ប្រ |
| ៦-លោក ហ៊ីង សុគន្ធី | ទីប្រឹក្សាត្រួតពិនិត្យ និងវាយតម្លៃ |

## របាយការណ៍ស្តីពីការវាយតម្លៃ រៀបចំដោយ

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ និងតួនាទីក្នុងការវាយតម្លៃ |
|---|---|
| ១) លោក ហ៊ុន ប៊ុនរ៉ា | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ គ.ប្រ ( គ្រូបង្គោល ) |
| ២) លោក ខាត់ ភាព | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ គ.ប្រ |

# ខេត្តកំពង់ស្ពឺ

កាលបរិច្ឆេទ: កញ្ញា ២០១០

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៣ |
| | របាយការណ៍សង្ខេប | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៨** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៨ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៨ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៨ |
| ១.៤ | សំណួរវាយតម្លៃ | ៩ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ៩ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ១០ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១២** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១) | ១២ |
| | - លទ្ធផលទី១ | ១២ |
| | - លទ្ធផលទី២ | ១៥ |
| | - លទ្ធផលទី៣ | ១៦ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម (សំណួរវាយតម្លៃទី២-ទី៣) | ១៧ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤) | ២២ |
| **៣** | **សេចក្តីសន្និដ្ឋាន** (សំណួរវាយតម្លៃទី៥) | **២៧** |
| | - ចំណុចរៀនសូត្រ | ២៨ |
| | - អនុសាសន៍ | ២៩ |
| **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍** | | **៣១** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ៣១ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍/ពិភាក្សា | ៣២ |


**ករណីសិក្សា**


| | |
|---|---|
| - ករណីសិក្សាទី១: អ្នកទទួលផល | ២០ |
| - ករណីសិក្សាទី២: អ្នកមិនទទួលផល | ២១ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

**គោលបំណង និងវិធីសាស្ត្រនៃការវាយតម្លៃដែលបានប្រើៈ**

នាពេលបច្ចុប្បន្ននេះ ពុំទាន់មានការវាយតម្លៃអនុកិច្ចសន្យាជាផ្លូវការនៅឡើយទេ សម្រាប់ គ.អ.ជ.ខ ចំពោះ មន្ទីរវិស័យ និងគម្រោងស្រុកទាំងអស់។

អនុកិច្ចសន្យានេះ ជាតំណាងឱ្យអនុកិច្ចសន្យាសម្រាប់ឆ្នាំ២០០៩ទាំងអស់ដែលត្រូវបានយកមកសិក្សា សម្រាប់ ការវាយតម្លៃនៅចុងឆ្នាំ២០១០នេះ។ នៅឆ្នាំ២០០៩ មន្ទីរកសិកម្មបានទទួលថវិកាចំនួន ២០.៤០០,០០ ដុល្លារ អាមេរិកដែលមាន៦លទ្ធផល និងមានសកម្មភាពរងចំនួន១៧ ក្នុងនោះលទ្ធសំខាន់មាន៣ទេ ដែល៣ទៀត ត្រូវបាន ប្រើប្រាស់សម្រាប់ការតាមដាន ត្រួតពិនត្យ ការវាយតម្លៃ និងប្រតិបត្តិការទូទៅសម្រាប់ គម្រោងទាំងមូលដែលមាន ថវិកាស្មើនឹង១២ភាគរយជាង នៃថវិកាទាំងមូល។

ការវាយតម្លៃអនុកិច្ចសន្យា ពិតជាមានសារៈសំខាន់ក្នុងការកែលម្អអនុកិច្ចសន្យា និងអត្ថប្រយោជន៏ទទួលបាននាពេលអនាគត សម្រាប់ការកែលម្អការអនុវត្តគម្រោងនៅមូលដ្ឋាន។ ដូចនេះគោលបំណងនៃការវាយតម្លៃលើកនេះគឺៈ

*១- ដើម្បីផ្តល់ព័ត៌មានដល់គណៈកម្មាធិការប្រតិបត្តិ មន្ទីរវិស័យ និងគម្រោងស្រុក ដើម្បីពង្រីកលើគុណភាពនៃការធ្វើសេចក្តីសម្រេចចិត្ត ក្នុងការជ្រើសរើសគម្រោងឱ្យបានត្រឹមត្រូវ និងការអនុវត្តតាមរយៈការផ្តល់ជូនព័ត៌មាន និងអនុសាសន៏ផ្សេងៗដែលមានសារសំខាន់ ចំពោះមន្ទីរវិស័យ ក្នុងការចែកចាយផលប្រយោជន៏ និងការអភិវឌ្ឍនៃគម្រោង នៃកម្មវិធី គ.ជ.អ.ប ដែលប្រើប្រាស់វិធីសាស្ត្រវាយតម្លៃ មួយដែលមាន ការបណ្តុះបណ្តាលត្រឹមត្រូវពីថ្នាក់ជាតិក្នុងការ ធ្វើឱ្យប្រសើរឡើង ដល់សមត្ថភាព និងចំណេះដឹង ចំពោះមន្ត្រីតាមដានត្រួតពិនិត្យដែលបានទទួលគម្រោងក្នុងឆ្នាំ ២០០៩ និងសម្រាប់ជាឯកសារ ដ៏មានសារសំខាន់សម្រាប់ ការអនុវត្តគម្រោងនៅឆ្នាំក្រោយៗ និង*

*២- ពង្រឹងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃតាមរយៈការប្រើប្រាស់វិធីសាស្ត្រ ដែលត្រូវធ្វើការប្រមូលទិន្នន័យមួយ ដែលបានមកពីសម្ភាសជាមួយអ្នកពាក់ព័ន្ធពីថ្នាក់ខេត្ត រហូតដល់អ្នកទទួលផល និងអ្នកមិនទទួលផលទៀត ហើយ ច្របាច់បញ្ចូលក្នុងរបាយការណ៏មួយដែលសមស្រប និងមានប្រសិទ្ធភាព សម្រាប់ការឆ្លុះបញ្ចាំងឡើងវិញនិងជាចំណេះ ដឹងមួយដែលបានមកពីការចុះអនុវត្តជាក់ស្តែងនៅទីតាំងគម្រោង។*

ទោះបីជាគោលបំណងខាងលើបានគ្រប់ដណ្តប់សម្រាប់ការវាយតម្លៃលើកនេះក៏ដោយ តែយើងមិនអាចវាយតម្លៃផលប៉ះពាល់របស់អនុកិច្ចសន្យាទៅលើ **"ការកាត់បន្ថយភាពក្រីក្រ"** ដែលជាគោលដៅរបស់អនុកិច្ចសន្យា និង **"អត្ថប្រយោជន៏" "ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា"** លទ្ធផលដែលទទួលបានធៀបទៅនឹងផែនការ អត្ថប្រយោជន៏

ទទួលបានភ្លាមៗ ដែលបានមកពីលទ្ធផល និង"**ទិសដៅបន្ទាន់**"ខ្លះៗ ទាំងអស់នោះបានទេ ប៉ុន្តែគេអាចធ្វើការប្រៀបធៀប និងធ្វើការប៉ាន់ប្រមាណ លើចំណេះដឹង និងចម្លើយដែលបានឆ្លើយក្នុងកិច្ចសម្ភាស និងការពិនិត្យមើលជាក់ស្តែង ក្នុងកម្រិតមួយចំណែក ហើយធ្វើការប្រៀបធៀបទៅនឹងការអនុវត្តទាំងមូលតែម្តង។

**ឆ្លើយទៅនឹងសំណួរទាំង៥ នៃការវាយតម្លៃៈ**

១- សកម្មភាពទាំងអស់ត្រូវបានអនុវត្ត និងលទ្ធផលសម្រេចបានតាមផែនការ លើកលែងសកម្មភាពចំនួន២ក្នុងលទ្ធផលទី១ការបង្ហាញផ្នែកក្សេត្រសាស្ត្រ (ឈើហូបផ្លែ ស្រូវ បន្លែ ដំណាំ)គឺ ទិវាស្រែបង្ហាញ និងទិវាបង្ហាញអំពីបន្លែ ដែលការអាក់ខាន នោះបណ្តាលមកពី ការប្រមូលផលមុនគម្រោង និងខកខានមិនបានអនុវត្ត និងទិវាបន្លែបង្ហាញអាក់ខាន ដោយសាររដូវវស្សារអូសបន្លាយ។

| ល.រ | **សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣ៈ ការបរិយាយអំពីអនុកិច្ចសន្យា** | **អ្វីដែលសម្រេចបានជាក់ស្តែង** |
|---|---|---|
| ១ | បណ្តុះបណ្តាល អំពីបច្ចេកទេស ជីកំប៉ុស្តិ៍-ស្រូវ ១៩ វគ្គ | កសិករចូលរួម ៥៩៦នាក់/ស្រី ៣៧០ នាក់ |
| ២ | ការធ្វើបង្ហាញកំប៉ុស្តិ៍-ស្រូវ និងតាមដាន ចំនួន ៣៣ បង្ហាញ | ការបង្ហាញកំប៉ុស្តិ៍-ស្រូវបានចំនួន ៣៣ កន្លែង |
| ៣ | បណ្តុះបណ្តាលអំពីបច្ចេកទេសកំប៉ុស្តិ៍-បន្លែ ១០ វគ្គ | កសិករចូលរួម ៣១៥នាក់/ស្រី ២០៩ នាក់ |
| ៤ | ការធ្វើបង្ហាញដំណាំបន្លែ និងតាមដាន ២០បង្ហាញ | ការបង្ហាញកំប៉ុស្តិ៍-បន្លែបានចំនួន ២០កន្លែង |
| ៥ | វគ្គបណ្តុះបណ្តាលវិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម ៦ វគ្គ ដើម្បីជ្រើសរើសកសិករឱ្យក្លាយជាអ្នកផ្សព្វផ្សាយ អ្នកស្ម័គ្រចិត្តកសិកម្មភូមិ ពេទ្យសត្វភូមិ និងជនបង្គោលកសិកម្ម | សិក្ខាកាមចូលរួម ចំនួន ១៦៨ នាក់ /ស្រី ០៣ នាក់ |
| ៦ | វគ្គផ្សព្វផ្សាយពីសុវត្ថិភាពនៃការដឹកជញ្ជូន ការស្តុក និងការប្រើប្រាស់ថ្នាំពុលកសិកម្ម ១៤ វគ្គ | អាជីវករ និងកសិករ ចំនួន១៤វគ្គកសិករ ចំនួន ៧០០ នាក់/ស្រី ៣៤៦ នាក់ |

២- មានចំនុចខ្វះខាតមួយនៅក្នុងអនុកិច្ចសន្យានេះដែរ ដែលអ្នករៀបចំគម្រោង ឬអ្នករៀបចំអនុកិច្ចសន្យា មិនបានសរសេររៀបរាប់អំពីស្ថានភាពចុងបញ្ចប់នៅក្នុងចំណុចគ ផ្នែកទី៣នៃអនុកិច្ចសន្យាឆ្នាំ២០០៩។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ យើងអាចទាញការសន្និដ្ឋានមួយបានកម្រិតដែរតាមរយៈការសម្ភាស និងការអង្កេត ទូទៅថា អនុកិច្ចសន្យានេះអាចសម្រេចបាននូវគោលបំណងរបស់ខ្លួន បើមិនទាំងអស់ តែបាន

មួយចំនួនធំ ឬស្ថានភាពចុងបញ្ចប់តាមរយៈចម្លើយរបស់អ្នកផ្ដល់សម្ភាសន៍ និងការសន្និដ្ឋានរួមមានកម្រិតខ្ពស់។

៣- លទ្ធផលបន្ទាន់ និងផលប្រយោជន៍ពីវគ្គបណ្ដុះបណ្ដាលវិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម ដើម្បីជ្រើសរើសកសិករ ឱ្យក្លាយជាអ្នកផ្សព្វផ្សាយអ្នកស្ម័គ្រចិត្តកសិកម្មភូមិពេទ្យសត្វភូមិ និងជនបង្គោលកសិកម្ម និងវគ្គផ្សព្វផ្សាយ ពីសុវត្ថិភាពនៃការដឹកជញ្ជូន ស្ដុក ប្រើប្រាស់ថ្នាំពុលកសិកម្ម ពិបាកនឹងវាយតម្លៃណាស់ ព្រោះយើងគ្មានព័ត៌មានពីមូលដ្ឋាន និងឯកសារជាក់លាក់សម្រាប់ការវាស់ស្ទង់ឡើយ។ នៅមានសកម្មភាពពីរទៀតដែលយើង មិនបានអនុវត្តដែរគឺ ទិវាស្រែបង្ហាញនិងទិវាបន្លែបង្ហាញ ជាហេតុធ្វើឱ្យមានការប៉ះពាល់មួយផ្នែកធំនៃលទ្ធផល បន្ទាន់។

៤- មានភាពពាក់ព័ន្ធច្រើននៃការប្រើប្រាស់ធនធានបានល្អត្រឹមត្រូវឈានទៅសម្រេចគោលដៅ។ មានការប្រើប្រាស់មនុស្ស ប្រើប្រាស់ថវិកា ប្រើប្រាស់សម្ភារៈ ដែលជាប្រសិទ្ធភាពនៃការអនុវត្តការងារ។ ក្នុងនោះដែរ យើងមានការកំណត់បាននូវគោលដៅត្រឹមត្រូវ ដែលអាចសម្រេចបាន ដែលនោះអាចរាប់បានថាជាប្រសិទ្ធផល។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ គុណភាពនៃការរៀបរៀងអនុកិច្ចសន្យា គួរតែត្រូវការកែលម្អដូចខាងក្រោមៈ

- ការសរសេរស្ថានភាពចុងបញ្ចប់ ដែលស្ថិតនៅក្នុងចំណុចគ នៃផ្នែកទី៣ ដោយមានការ បរិយាយឱ្យបានច្បាស់ និងអាចវាស់វែងបាន។
- ការសរសេរគោលដៅបន្ទាន់យ៉ាងណាឱ្យស្របទៅនឹងទំនាក់ទំនងរវាងទុន/ធាតុចូលនិងលទ្ធផល និង រវាង លទ្ធផល និងអត្ថប្រយោជន៍របស់គម្រោង/អនុកិច្ចសន្យា ឬចំណេះដឹងលើតារាងគំរូកត្តភាព ព្រោះវាជា ឧបករណ៍រៀបចំ និងវិភាគអនុកិច្ចសន្យា ដែលតម្រូវឱ្យវិភាគអំពីៈ តម្រូវការភាគីពាក់ព័ន្ធ លទ្ធភាព គម្រោង ទំនាក់ទំនងតក្ករវាងធាតុមួយចំនួន (ទុន/ធាតុចូល សកម្មភាព លទ្ធផល ទិសដៅ និងគោល បំណង) និងការសន្មត។
- ការប្រើប្រាស់សូចនាករដែលបានមកពីទិន្នន័យមូលដ្ឋាន។
- ភ្ជាប់ទំនាក់ទំនងឱ្យបានច្បាស់រវាងលទ្ធផល និងគោលបំណងបន្ទាប់ និងគោលបំណងកម្រិតខ្ពស់។

**សេចក្ដីសន្និដ្ឋានៈ**

១- អនុកិច្ចសន្យានេះត្រូវបានអនុវត្តឡើងដូចការគ្រោងទុក។ ភាគីអនុវត្តអនុកិច្ចសន្យា មានសមត្ថភាព និង ធនធានគ្រាប់គ្រាន់ដើម្បីអនុវត្តអនុកិច្ចសន្យា។ មានសកម្មភាពពីរ ធ្វើឱ្យប៉ះពាល់ដល់លទ្ធផល ទី១ទាំង មូលដែរ ដែលយើងបានរកឃើញនៅក្នុងការវាយតម្លៃនេះ ទោះបីសកម្មភាពជាច្រើនសម្រេចបាននៅក្នុង លទ្ធផលតាមការគ្រោងទុកក៏ដោយ ព្រោះវាមិនបានបង្ហាញដោយផ្ទាល់ថា ទិន្នផលពិតជាមានការកើន ឡើងបើយើងប្រៀបធៀប ទៅនឹងឆ្នាំទៅ ឬពីអ្នកដែលមិនបាន

អនុវត្តតាមបច្ចេកទេសថ្មីនេះ។ ហើយ ម្យ៉ាងទៀត យើងអាចសន្និដ្ឋានបានថា ការតាមដានត្រួតពិនិត្យ និងការផ្តល់ព័ត៌មានទៅសហគមន៍ មានការយឺតយ៉ាវ ឬខ្វះការទំនាក់ទំនង។

២- លទ្ធផលសកម្មភាពនៃការអនុវត្តគម្រោងក្នុងឆ្នាំ២០០៩ ពិតជាមានការគាំទ្រលើប្រព័ន្ធកសិកម្មសមស្រប និងលើកកម្ពស់ជីវភាពរស់នៅ តាមរយៈការបង្ហាញផ្ទៃកក្សេត្រសាស្ត្រមានៈ ការបណ្តុះបណ្តាលអំពី បច្ចេកទេស ជីកំប៉ុស្តិ៍-ស្រូវ និងការបណ្តុះបណ្តាលអំពីបច្ចេកទេសកំប៉ុស្តិ៍-បន្លែ។

៣- ប្រជាពលរដ្ឋដែលជាអ្នកទទួលផល បានទទួលនូវចំណេះដឹងថ្មី លើការធ្វើកសិកម្ម ដែលក្នុងនោះគម្រោង បានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅមូលដ្ឋាន តែឆន្ទៈនៃការកែប្រែទម្លាប់ចាស់នៃការធ្វើ កសិកម្មតាមបែបបូរាណ មកការធ្វើកសិកម្មបែបទំនើបបាន នៅមិនទាន់ឃើញមានហើយភស្តុតាង និងទិន្នន័យក៏មិនគ្រប់គ្រាន់ដែលបញ្ជាក់ថាគាត់បានផ្លាស់ប្តូរដែរ។

៤- អនុកិច្ចសន្យានេះបានទទួលនូវនិរន្តរភាពក្នុងសកម្មភាពរបស់ខ្លួនក្នុងកម្រិតខ្ពស់ តែគម្រោងបានចូលរួមចំណែកក្នុងកម្រិតតិចតួចទៅគោលដៅអភិវឌ្ឍន៍នៅក្នុងអនុកិច្ចសន្យា ហើយនិងគោលដៅក្នុងការកាត់បន្ថយភាពក្រីក្រ។

**<u>អនុសាសន៍</u> :**

៥- គួរមានការបន្តការគាំទ្រគម្រោងបែបនេះក៏ដូចជាការពង្រីកសកម្មភាពគម្រោងបន្តទៀត មិនចំពោះតែមន្ទីរកសិកម្មដែលជាម្ចាស់ នៃគម្រោងដែលត្រូវធ្វើការវាយតម្លៃនោះទេ តែសម្រាប់អ្នកអនុវត្តន៍គម្រោងទាំងអស់។

៦- គួរមានការជ្រើសរើសអ្នកទទួលផលឱ្យបានសមស្រប ដោយមានការចូលរួមផ្ទាល់ពីមន្ទីរសាមីជាភ្នាក់ងារ អនុវត្តន៍គម្រោង ដើម្បីធ្វើឱ្យសម្រេចបាននូវអត្ថប្រយោជន៍ក្នុងកម្រិតខ្ពស់។

៧- គួរបរិយាយឱ្យបានច្បាស់លាស់នូវស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា និងគោលបំណងបន្ទាន់របស់គម្រោង និងទំនាក់ទំនងតក្កទៅនឹងលទ្ធផលនីមួយៗ។

៨- ផ្នែករដ្ឋបាល និងគ្រប់គ្រងអនុកិច្ចសន្យាគួរធ្វើការវាយតម្លៃគម្រោងស្រដៀងគ្នានេះឱ្យបាន១ ឬ២អនុកិច្ចសន្យាជាប្រចាំ។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្តល់ថវិកាតាមរយៈ គ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និងគម្រោង ដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈជាប្រព័ន្ធ មិន បានអនុវត្តទេកាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើន។ នៅក្នុងឆ្នាំ ២០១០ ជាមួយនឹងការគាំទ្រផ្នែក ថវិកា និងបច្ចេកទេស ពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យា គ.ប្រ នៃគ.អ.ជ.ខ ក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យា ដែលបាន រៀបចំរួមគ្នាជាមួយភ្នាក់ងារអនុវត្តន៍ដែលមានលេខ : ***05/AGR/0901-01 (GOV)*** ចំណងជើងកិច្ចសន្យាៈ គាំទ្រប្រព័ន្ធកសិកម្មសមស្រប និងលើកកំពស់ជីវភាពរស់នៅភ្នាក់ងារអនុវត្តន៍ៈ មន្ទីរកសិកម្ម ដំណើរការលទ្ធផល ដែល បានរកឃើញនិងការសន្និដ្ឋាន នៃការវាយតម្លៃត្រូវបានកត់ត្រា ហើយនឹងបង្ហាញតាមរយៈរបាយការណ៍ស្តីពី ការវាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

កិច្ចសន្យានេះឆ្លើយតប និងធ្វើឱ្យសម្រេចនូវទិសដៅ របស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជា ធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលប្រើប្រាស់ការការអនុវត្តតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ គឺរដ្ឋាភិបាល ផ្នែកឯកជន និង NGOs បានផ្តល់សេវាកម្ម និងកសាងហេដ្ឋារចនាសម្ព័ន្ធស្របទៅនិងផែនការ និងការអនុវត្តការ គ្រប់គ្រងបានល្អ គឺជុំរុញឱ្យមានការកើនឡើង ជាអតិបរមានូវស្បៀងអាហារ របស់ប្រជាកសិករជនបទ តាមរយៈ ការបង្កើនផលិតភាពកសិកម្ម និងប្រាក់ចំណូលក្នុងគ្រួសារ។

ដូចនេះ គោលបំណងបន្ទាន់របស់មន្ទីរកសិកម្មខេត្តឬកិច្ចសន្យានេះគឺពង្រឹងសេវាផ្សព្វផ្សាយ អំពីបច្ចេកទេស កសិកម្ម និងបង្កើនប្រាក់ចំណូល ជូនដល់ប្រជាកសិករតាមរយៈការបង្កើនទិន្នផល ស្រូវ/ដំណាំរួមផ្សំ និងការចិញ្ចឹម សត្វ ព្រមទាំងធ្វើបង្ហាញបច្ចេកទេសកសិកម្មសមស្រប នៅក្នុងភូមិ ឃុំគោលដៅ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណង នៃការវាយតម្លៃគឺៈ ក) ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និងចំនុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា

រួមទាំង កត់ត្រានូវ ចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត និង ខ) ដើម្បីពង្រឹងរបៀប ធ្វើការវាយតម្លៃគម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត។ ដូច្នេះ ទំហំនៃការវាយតម្លៃ មានដែនកំណត់តាមទំហំនៃ អនុកិច្ចសន្យានិងរាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខណ្ឌការងារនៃការវាយតម្លៃ។ ដូចនេះគោលបំណងនេះ គឺដើម្បីវាយតម្លៃ អនុកិច្ចសន្យាទាំងមូលដោយផ្នែករដ្ឋបាល និងគ្រប់គ្រង កិច្ចសន្យារបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និងតម្លាភាព។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើៈ

១) ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំណត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធដែលមាននៅក្នុងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៍។

២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗ រួមមានៈ អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផល ផ្ទាល់ និងមិនផ្ទាល់ ២ ឬ៣នាក់ និងអ្នកពាក់ព័ន្ធ ២នាក់។ សូមពិគ្រោះជាមួយ នឹងមន្ត្រីបង្គោលទៅលើបញ្ហាយេនឌ័រ និងគ្រប់គ្រងធនធានធម្មជាតិ សម្រាប់បញ្ហាពាក់ពន្ធ័វិស័យខាងលើ។

៣) ប្រើប្រាស់វិធីសាស្ត្រចុះពិនិត្យតំបន់អនុវត្តន៍គម្រោង និងសង្កេតមើលសកម្មភាព ពិភាក្សាក្រុម និងករណីសិក្សា ដែលយើងមានប្រភពទិន្នន័យសំខាន់ចំនួន ៣ សម្រាប់ការវាយតម្លៃអនុកិច្ចសន្យាៈ ទី១-ឯកសារអនុកិច្ចសន្យា រួមមានរបាយការណ៍ និងឯកសារផ្សេងៗ។ ទី២-ការទទួលទិន្នន័យពីក្រុមអ្នកពាក់ព័ន្ធ រួមមានៈ អ្នកទទួលផលផ្ទាល់អ្នកទទួលផលមិនផ្ទាល់ ដៃគូរអភិវឌ្ឍន៍ ឬអង្គការក្រៅរដ្ឋាភិបាល មន្ត្រីដែលមាន ផលប្រយោជន៍នៅក្នុងអនុកិច្ចសន្យា ឬលទ្ធផល មន្ត្រីបង្គោលយេនឌ័រ ឬមន្ត្រី បង្គោលគ្រប់គ្រងធនធានធម្មជាតិ ទីប្រឹក្សា

ត្រួតពិនិត្យ វាយតម្លៃ និងវិស័យ ឬ ប្រធានទីប្រឹក្សា ប្រធានភូមិ/ស្មៀនឃុំដែលគម្រោងមានសកម្មភាព និងសហគមន៍ដែលពាក់ព័ន្ធ។ ទី៣- សញ្ញាសូចនាករ និងភាពជាក់ស្តែងនៃអនុកិច្ចសន្យា និងលទ្ធផលអនុកិច្ចសន្យា។

៤) ចុះពិនិត្យតំបន់អនុវត្តន៍គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់។

៥) វិភាគទិន្នន័យ និងបកស្រាយៈ ទិន្នន័យដែលបានប្រមូលតាមវិធីសាស្រ្តខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់។

៦) ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ ដោយភ្នាក់ងារអនុវត្តន៍ និងអ្នកពាក់ព័ន្ធតាមរយៈព័តិមានត្រឡប់ដែលទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើង។ ការវាយតម្លៃត្រូវធ្វើតាម "គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា" និងវិធីសាស្រ្តដែលបានណែនាំ។ ដូច្នេះ ដំណើរការត្រូវបានធ្វើឡើងដោយមានទម្រង់ការណែនាំ និងតម្លាភាព រួមទាំងការចូលរួមពីអ្នកពាក់ព័ន្ធ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយ គ.ប្រ និងអ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា។

២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិតៈ វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោង នៅពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និងបទពិសោធន៍ពីមុនមក។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណង សំខាន់ គឺដើម្បី "រៀនធ្វើដោយការអនុវត្តផ្ទាល់"។ អ្នកវាយតម្លៃ បានទទួលការគាំទ្រដោយមានគោលការណ៍ការ ណែនាំឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។

៣) បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យាៈ ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និងជោគជ័យទេ ។ មួយទៀត ទំនាក់ទំនងសង្ខេបតាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ។

៤) ដោយយើងមិនមានសូចនាករឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍" ដែលជាកម្រិត អត្ថប្រយោជន៍ទៅលើគោលនយោបាយវិម្ឋការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។

៥) ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិតទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ។ យើងអាចវាយតម្លៃតែទៅលើ **ការបង្ហាញផ្នែកក្សេត្រសាស្រ្ត (ឈើហូបផ្លែ ស្រូវ បន្លែ ដំណាំ)** ដែលជាលទ្ធផល និង **សក ក.១.២ បណ្តុះបណ្តាល អំពីបច្ចេកទេស ជីកំប៉ុស្តិ៍-ស្រូវ** *និង* **ការធ្វើ បង្ហាញកំប៉ុស្តិ៍-ស្រូវ និងតាមដាន ចំនួន៣៣បង្ហាញ** ដែលជាសកម្ម ភាពនៃអនុកិច្ចសន្យាលំអិតតាមរយៈ ការសម្ភាស ស៊ីជម្រៅ ក្រុមពិភាក្សា និងការចុះពិនិត្យតំបន់អនុវត្តគម្រោង។

**<u>ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធន៍:</u>**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ 05/AGR/0901-01 (GOV) គាំទ្រប្រព័ន្ធកសិកម្ម សមស្រប និងលើកកំពស់ជីវភាពរស់នៅភ្នាក់ងារអនុវត្តន៏: មន្ទីរកសិកម្មនិងដែនកំណត់ ដូចដែលបានកំណត់ នៅក្នុង ក្របខ័ណ្ឌនៃការវាយតម្លៃនេះ។

២) ការវាយតម្លៃនេះលម្អិតតែទៅលើ **ការបង្ហាញផ្នែកក្សេត្រសាស្ត្រ** (**ឈើហូបផ្លែ ស្រូវ បន្លែ ដំណាំ**) ដែលជាលទ្ធផល និង **សក ក.១.២ បណ្តុះបណ្តាល អំពីបច្ចេកទេស ជីកំប៉ុស្តិ៍-ស្រូវ** *និង* **ការធ្វើបង្ហាញកំប៉ុស្តិ៍-ស្រូវ និងតាមដានចំនួន៣៣បង្ហាញ** ដែលជាសកម្មភាពនៃអនុកិច្ចសន្យា។

៣) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃទៅលើ ភ្នាក់ងារអនុវត្តន៏ ភ្នាក់ងារដែលពាក់ព័ន្ធគម្រោង ហើយនឹង ការវាយតម្លៃទៅលើគ.ប្រ នៃគ.អ.ជ.ខ និង គ.ជ.អ.ប ទេ។

ហេតុដូច្នេះ របាយការណ៍នៃការវាយតម្លៃ លទ្ធផលដែលបានរកឃើញ និងអនុសាសន៏ដែលបានលើកឡើង ត្រូវ ពិនិត្យដោយយោលទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ។

# ២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទីមួយ)

**លទ្ធផលទី១ : ការបង្ហាញផ្នែកក្សេត្រសាស្ត្រ (ឈើហូបផ្លែ ស្រូវ បន្លែ ដំណាំ)**

**ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ**

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | ▪ វគ្គបណ្តុះបណ្តាល អំពីបច្ចេកទេស ជីកំប៉ុស្តិ៍-ស្រូវ ១៩ វគ្គ<br>▪ វគ្គនីមួយៗ ស្មើនឹងសាលាមួយហើយមានរយៈពេល១ថ្ងៃ<br>▪ អ្នកចូលរួមសរុបចំនួន៥៧០នាក់ | ▪ វគ្គបណ្តុះបណ្តាល អំពីបច្ចេកទេស ជីកំប៉ុស្តិ៍-ស្រូវ ១៩ វគ្គ<br>▪ វគ្គនីមួយៗ ស្មើនឹងសាលាមួយហើយមានរយៈពេល១ថ្ងៃ<br>▪ អ្នកចូលរួមសរុបចំនួន ៥៩៦នាក់/ស្រី ៣៧០ នាក់ |
| ១.២ | ▪ ការធ្វើបង្ហាញកំប៉ុស្តិ៍-ស្រូវ និងតាមដាន ចំនួន៣៨បង្ហាញ ដែលការបង្ហាញកំប៉ុស្តិ៍មានចំនួន១៩លើក និងការបង្ហាញស្រូវ មានចំនួន ១៩លើក។<br>▪ កសិករបង្ហាញមានចំនួន៣៨នាក់ ស្មើ៣៨កន្លែង | ▪ ការធ្វើបង្ហាញកំប៉ុស្តិ៍-ស្រូវ និងតាមដាន ចំនួន៣៨បង្ហាញ<br>▪ កសិករបង្ហាញមានចំនួន៣៨នាក់ ស្មើ៣៨កន្លែង |
| ១.៣ | ▪ ទិវាស្រែបង្ហាញ | ▪ ខកខានមិនបានអនុវត្ត ទិវាស្រែបង្ហាញ ដោយសារអ្នកធ្វើបង្ហាញប្រមូលផលមុនគម្រោង |

| | | |
|---|---|---|
| ១.៤ | ■ បណ្តុះបណ្តាលអំពីបច្ចេកទេសកំប៉ុស្តិ៍-បន្លែ ១០វគ្គ<br>■ វគ្គនីមួយៗ ស្មើនឹងសាលាមួយហើយមានរយៈពេល១ថ្ងៃ<br>■ អ្នកចូលរួមចំនួន ៣០០នាក់ | ■ បណ្តុះបណ្តាលអំពីបច្ចេកទេសកំប៉ុស្តិ៍-បន្លែ<br>■ វគ្គនីមួយៗ ស្មើនឹងសាលាមួយហើយមានរយៈពេល១ថ្ងៃ<br>■ អ្នកចូលរួមចំនួន ៣១៥នាក់/ស្រី ២០៩ នាក់ |
| ១.៥ | ■ ការធ្វើបង្ហាញដំណាំបន្លែ និងតាមដាន ២០បង្ហាញ<br>■ កសិករបង្ហាញមានចំនួន២០នាក់ ស្មើ២០ កន្លែង | ■ ការធ្វើបង្ហាញដំណាំបន្លែ និងតាមដាន ២០បង្ហាញ<br>■ កសិករបង្ហាញមានចំនួន២០នាក់ ស្មើ២០ កន្លែង |
| ១.៦ | ■ ទិវាបង្ហាញអំពីបន្លែ | ■ ខកខានមិនបានអនុវត្ត ទិវាបន្លែបង្ហាញ ដោយសាររដូវវស្សារអូសបន្លាយ |

## ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល ធៀបនឹងគោលបំណងបន្ទាន់

នៅក្នុងលទ្ធផលសកម្មភាពនៃការអនុវត្តគម្រោងក្នុងឆ្នាំ២០០៩យើងឃើញថាៈ ការគាំទ្រប្រព័ន្ធកសិកម្មសមស្រប និងលើកកម្ពស់ជីវភាពរស់នៅ តាមរយៈការបង្ហាញផ្នែកក្សេត្រសាស្ត្រមានៈ ការបណ្តុះបណ្តាលអំពីបច្ចេកទេស ជីកំប៉ុស្តិ៍-ស្រូវ និងការបណ្តុះបណ្តាលអំពីបច្ចេកទេសកំប៉ុស្តិ៍-បន្លែ ប្រជាពលរដ្ឋដែលជាអ្នកទទួលផលបានទទួលនូវ ចំណេះដឹងថ្មីលើការធ្វើកសិកម្ម ដែលក្នុងនោះគម្រោងបានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅមូលដ្ឋាន និងឃើញមានការកែប្រែទម្លាប់ចាស់នៃការធ្វើកសិកម្មតាមបែបបូរាណ មកកាធ្វើកសិកម្មបែបទំនើបមួយចំនួនធំដែរ ព្រោះដោយមានការចូលរួមយ៉ាងសកម្មពីអ្នកទទួលផល និងសហគមន៍។ ពួកគាត់នៅបានចាំទ្រឹស្តីជាច្រើនដែល គ្រូបណ្តុះបណ្តាលបាន បង្ហាត់បង្ហាញនៅក្នុងអំឡុងពេលរៀន និងក្រោយពេលរៀន។

សិក្ខាកាមភាគច្រើនចូលចិត្តវិធីសាស្ត្របណ្តុះបណ្តាល និងទង្វើ និងអកប្បកិរិយារបស់អ្នកបណ្តុះបណ្តាល។ វិធីសាស្ត្រផ្សេងៗជាច្រើន ត្រូវបានប្រើប្រាស់នៅក្នុងវគ្គបណ្តុះបណ្តាលរួមមានការបំផុសគំនិត ការពិភាក្សាក្រុម លំហាត់ជាក់ស្តែង និងការល្បែងដែលធ្វើឱ្យសិក្ខាកាមកាន់តែទទួលយល់បាន ...។ល។ អ្នកបណ្តុះបណ្តាល អាចបន្សាំខ្លួនទៅនឹងបរិបទនៅសហគមន៍បានល្អ ដើម្បីឱ្យមានការចូលរួមកាន់តែច្រើនពីសិក្ខាកាម។ តែទោះជាយ៉ាងណាក៏ដោយ សិក្ខាកាមបានត្អូញត្អែពីរយៈពេលនៃការបណ្តុះបណ្តាល ដែលមិនអាចធ្វើឱ្យពួកគាត់អាចយល់ឱ្យអស់ពីដំណើរវិវឌ្ឍន៍ពិតប្រាកដពីដើមដល់ចប់នៃអាយុជីវិត និងទំនាក់ទំនងរបស់ ជីកំប៉ុស្តិ៍ និងដំណាំស្រូវ ឬការតាមដានផលដំណាំគាត់បន្តទៀតឱ្យច្បាស់លាស់ជាងនេះ។

ដូចនេះសរុបមកវិញ វគ្គបណ្តុះបណ្តាលនេះ ពិតជាមានសារសំខាន់ណាស់ចំពោះតម្រូវការជាក់ស្តែងនៅមូលដ្ឋាន ដែលភាគច្រើនពួកគាត់ពឹងផ្អែកទាំងស្រុងលើការប្រកបរបរស្រែចំការ និងការដាំដំណាំរួមផ្សំ។ លើសពីនេះនោះ អ្នកចូលរួមបានបញ្ចេញពីចំណេះដឹង ជំនាញ និងចំណេះធ្វើដែលគ្រូបណ្តុះបណ្តាលបានបង្ហាត់បង្ហាញ បូករួមនឹងចំណេះដឹងផ្សេងៗ
ជុំវិញជីវភាពរស់នៅប្រចាំថ្ងៃ។ យើងឃើញមានភាពប្រែប្រួលមួយចំនួនធំលើការបង្កើតរោងជីកំប៉ុស្តិ៍បន្ថែម បើទោះបីមិនទាន់ត្រឹមត្រូវតាមបច្ចេកទេស តែកសិករជាច្រើនចេះប្រមូលវត្ថុ ធាតុដើមផ្សេងៗ ដែលអាចបង្កើតកំប៉ុស្តិ៍បាន មកដាក់ក្នុងរោង ឬកន្លែងមួយបានល្អដែរ។ ឯការងារស្រែចំការវិញ ពួកកាត់ចេះផ្លាស់ប្តូរជាបន្តើរៗពីការធ្វើស្រែបូរាណមកការងារ បច្ចេកទេសសមស្របវិញទោះបីមិនទាន់បានតាមគោលបំណងដែលយើងចង់បាន តែមានចំណុចវិជ្ជមានច្រើនគួរសម ដែលនេះអាចជាការរួមចំណែកមួយធំសម្រាប់ការងាររីកចម្រើន នៅក្នុងសហគមន៍របស់គាត់ ហើយក៏បានរួមចំណែកក្នុងការកាត់បន្ថយចំណាយនៅក្នុងគ្រួសារ ក៏ដូចជាធ្វើឱ្យមានសុខភាពគ្រួសារពួកគាត់កាន់តែប្រសើរដែរមួយចំណែកដែរ។

## លទ្ធផលទី២: ជ្រើសរើសកសិករឱ្យក្លាយជាអ្នកផ្សព្វផ្សាយ អ្នកស្ម័គ្រចិត្តកសិកម្មភូមិ ពេទ្យសត្វភូមិ និងជនបង្គោលកសិកម្ម

### ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | ■ ជ្រើសរើសកសិករ ២១០ នាក់ | ■ បានជ្រើសរើសកសិករចំនួន២១០នាក់ |
| ១.២ | ■ វគ្គបណ្តុះបណ្តាលវិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម ៦ វគ្គ<br>■ អ្នកចូលរួមចំនួន ២១០នាក់<br>■ វគ្គនីមួយៗមានចំនួន៥ថ្ងៃ | ■ វគ្គបណ្តុះបណ្តាលវិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម ៦ វគ្គ នៅមន្ទីរកសិកម្មខេត្ត<br>■ អ្នកចូលរួមចំនួន ១៦៨ នាក់ /ស្រី ០៣ នាក់<br>■ វគ្គនីមួយៗមានចំនួន៥ថ្ងៃ |

### ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល ធៀបនឹងគោលបំណងបន្ទាន់

| |
|---|
| អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និងសកម្មភាពតាមការគ្រោងទុក។ ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ មិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះបានលម្អិតទេ។ តែទោះជាយ៉ាងណា ក៏យើងឃើញមានការដកថវិកាមួយចំនួននៅក្នុង លទ្ធផលនៃការចុះតាមដាន សក ក.២.១ចុះតាមដានការ អនុវត្តគម្រោង និងសក ក.២.២ប្រជុំប្រចាំ ត្រីមាស តាមដានការអនុវត្តគម្រោង និងយេនឌ័រ។ ថវិកាដែលបានដក ចេញពីសកម្មភាពទាំង អស់នេះត្រូវបានបន្ថែមទៅលើ សកម្មភាព ខ.១.១ ជ្រើសរើសកសិករ និងសកម្មភាព ខ.១.២ វគ្គបណ្តុះបណ្តាល វិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម នៃលទ្ធផល ខ.១ នៃជ្រើសរើសកសិករ ឱ្យក្លាយជាអ្នកផ្សព្វផ្សាយ អ្នកស្ម័គ្រ ចិត្តកសិកម្មភូមិ និងជនបង្គោលកសិកម្ម។ |

## លទ្ធផលទី៣: កសិករបានទទួលការបណ្តុះបណ្តាលពី បច្ចេកទេសផ្សព្វផ្សាយក្សេត្រសាស្រ្ត និងការបង្ហាញ

## ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | ■ ជ្រើសរើសកសិករ និងអាជីវករ ៧00 នាក់ | ■ ជ្រើសរើសកសិករ និងអាជីវករ ៧00 នាក់ |
| ១.២ | ■ វគ្គផ្សព្វផ្សាយពីសុវត្ថិភាពនៃការដឹកជញ្ជូន ស្តុក ប្រើប្រាស់ថ្នាំពុលកសិកម្ម ១៤ វគ្គ ស្មើ១៤ កន្លែង<br>■ អ្នកចូលរួមចំនួន ៧00នាក់<br>■ វគ្គនីមួយៗមានចំនួន១ថ្ងៃ | ■ វគ្គផ្សព្វផ្សាយពីសុវត្ថិភាពនៃការដឹកជញ្ជូន ស្តុក ប្រើប្រាស់ថ្នាំពុលកសិកម្ម ១៤ វគ្គ ស្មើ១៤ កន្លែង<br>■ អ្នកចូលរួមចំនួន ៧00 នាក់/ស្រី ៣៤៦ នាក់<br>■ វគ្គនីមួយៗមានចំនួន១ថ្ងៃ |

## ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល ធៀបនឹងគោលបំណងបន្ទាន់

| |
|---|
| អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និងសកម្មភាពតាមការគ្រោងទុក។ ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ មិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះបានលម្អិតទេ។ |

## ២.២. ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម

## ផ្នែក-កៈ ការសម្រេចបាននូវស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា (សំណួរវាយតម្លៃទី២)

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា | ស្ថានភាពជាក់ស្តែងនៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ |
|---|---|
| - កសិករចូលរួមសរុបចំនួន៥៧០នាក់/ស្រី២០០ នាក់ មកពីឃុំចំនួន៩ ក្នុងស្រុកចំនួន៣ ស្មើនឹង១៩កន្លែង សម្រាប់ ការបណ្តុះបណ្តាលជីកំប៉ុស្ត-ស្រូវ គោលដៅទទួលបាន ចំណេះដឹងអំពីបច្ចេកទេសផលិតកម្មដំណាំស្រូវ។ | -កសិករចូលរួមសរុបចំនួន ៥៩៦នាក់/ស្រី ៣៧០ នាក់។ ប្រជាពលរដ្ឋដែលជាអ្នកទទួលផលបានទទួលនូវ ចំណេះដឹងថ្មីលើការធ្វើកសិកម្ម ដែលក្នុងនោះគម្រោងបានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅមូលដ្ឋាន និងពិតជាមានការកែប្រែទម្លាប់ចាស់ នៃការធ្វើកសិកម្មតាមបែបបូរាណ មកការធ្វើកសិកម្មបែបទំនើប ដោយមានការចូលរួមយ៉ាងសកម្មពីអ្នកទទួលផល និងសហគមន៍ ហើយកសិករ បានស្គាល់ពីផលប្រយោជន៍ពីរ<br>ទី១- ការធ្វើជីកំប៉ុស្តិ៍ ដោយប្រើប្រាស់វត្ថុធាតុដើមដែលមានស្រាប់នៅជុំវិញ។<br>ទី២-បច្ចេកទេសផលិតស្រូវ ដែលទទួលបានទិន្នផលខ្ពស់តាមរយៈ ការប្រើពូជថ្មី សំណាបមានអាយុកាលខ្លី ការកាត់បន្ថយការប្រើជីគីមី និងថ្នាំពុលកសិកម្ម ...។ |
| -ការធ្វើបង្ហាញកំប៉ុស្តិ៍-ស្រូវ ៣៨បង្ហាញ ក្នុង នោះការធ្វើបង្ហាញស្រូវ មានចំនួន ១៩បង្ហាញ និងការធ្វើបង្ហាញជីកំប៉ុស្តិ៍ ចំនួន១៩ដែល ជ្រើសរើស សម្រាប់ការធ្វើបង្ហាញចំពោះ កសិករ ចំនួន៥៧០នាក់ /ស្រី២០០នាក់ មកពី ឃុំចំនួន៩ ក្នុងស្រុកចំនួន៣ លើការធ្វើរោងជី កំប៉ុស្តិ៍ រួមនឹងបច្ចេកទេស និងការធ្វើស្រែ បង្ហាញក្នុងស្រែជាក់ស្តែង | -កសិករចូលរួមសរុបចំនួន ៥៩៦នាក់/ស្រី ៣៧០ នាក់។ បានទទួលចំណេះ ដឹងពិតប្រាកដ និងបានឃើញជាក់ស្តែងពីការធ្វើបង្ហាញ កំប៉ុស្តិ៍-ស្រូវ ចំនួន៣៣បង្ហាញ ពីកសិករបង្ហាញចំនួន៣៣នាក់ ស្មើ៣៨កន្លែង។ |

| | |
|---|---|
| -កសិករចូលរួម៣00នាក់/ស្រី១៥0នាក់ មកពីឃុំ ចំនួន៨ ក្នុងស្រុកចំនួន៣ ស្មើនឹង ១0កន្លែង សម្រាប់ការបណ្តុះបណ្តាល ជីកំប៉ុស្ត-បន្លែ គោលដៅទទួលបាន ចំណេះដឹង អំពីបច្ចេកទេសដាំដុះដូចជាៈ ការរៀបចំដី ការថែទាំ និងការប្រមូលផលជីកំប៉ុស្តិ៍ តាមរយៈការផ្តល់វគ្គចំនួន១0 | -កសិករចូលរួមចំនួន ៣១៥នាក់/ស្រី២០៩នាក់។ កសិករស្គាល់ពីផលប្រយោជន៏នៃការធ្វើជីកំប៉ុស្តិ៍ និងចេះបច្ចេកទេសដាំបន្លែដែលទទួលបានទិន្នផលខ្ពស់ មានតម្លៃនៅលើទីផ្សារ និងតាមពេលវេលារដូវកាល តាមរយៈការប្រើជីកំប៉ុស្តិ៍ ការកាត់បន្ថយ ការប្រើជីគីមី និងថ្នាំពុលកសិកម្ម ដោយផ្តោតលើបច្ចេកទេស នៃការធ្វើជីកំប៉ុស្តគោក បច្ចេកទេសនៃការធ្វើជីកំប៉ុស្តទឹក បច្ចេកទេសនៃការដាំដុះដំណាំបន្លែ ការរៀបចំដី ការជ្រើសរើសពូជ ការបណ្តុះកូន ការថែទាំនិងបច្ចេកទេស ផ្សំថ្នាំពុលកំចាត់សត្វល្អិតពីធម្មជាតិ។ |
| -ការធ្វើបង្ហាញកំប៉ុស្តិ៍-បន្លែ ចំនួន ២0 បង្ហាញ ក្នុងនោះការធ្វើបង្ហាញបន្លែ មានចំនួន១0 បង្ហាញ និងការធ្វើបង្ហាញ ជីកំប៉ុស្តិ៍ចំនួន១0 ដែលជ្រើសរើស សម្រាប់ការធ្វើបង្ហាញ ចំពោះកសិករ ចំនួន៣00 នាក់/ស្រី១៥0 នាក់មកពីឃុំ ចំនួន៨ ក្នុងស្រុកចំនួន៣ លើ ការ ធ្វើរោងជីកំប៉ុស្តិ៍ រួមនឹងបច្ចេកទេស និង ការធ្វើបន្លែបង្ហាញ ក្នុងសួនជាក់ស្តែង តាម លក្ខណៈបច្ចេកទេស សមស្រប និងទទួលបាន ទិន្នផលខ្ពស់។ | -កសិករចូលសរុបចំនួន ៣១៥នាក់/ស្រី២០៩នាក់ និងបានទទួល ចំណេះដឹងពិតប្រាកដ ដោយបានឃើញជាក់ស្តែងពីការធ្វើបង្ហាញ កំប៉ុស្តិ៍-បន្លែ ចំនួន២0បង្ហាញ ពីកសិករបង្ហាញចំនួន២0នាក់ ស្មើ២0កន្លែង។ |
| -កសិករចំនួន ២១០នាក់/ស្រី១០០ នាក់បាន ទទួលវគ្គបណ្តុះបណ្តាល វិធីសាស្រ្ត ផ្សព្វផ្សាយ កសិកម្ម ចំនួន៦វគ្គ នៅមន្ទីរកសិកម្មខេត្ត ដោយវគ្គនីមួយៗ មានចំនួន៥ថ្ងៃ។ | - បណ្តុះបណ្តាលពេទ្យសត្វភូមិ ចំនួន 0៦ វគ្គ សិក្ខាកាមចូលរួមចំនួន ១៦៨នាក់/ស្រី0៣នាក់ឱ្យក្លាយជាអ្នកផ្សព្វផ្សាយអ្នកស្ម័គ្រចិត្ត កសិកម្ម ភូមិ និងជនបង្គោលកសិកម្ម និងជាអ្នកដើតួយ៉ាងសំខាន់ ក្នុងការផ្សព្វផ្សាយបច្ចេកទេសដល់កសិករ ហើយនាំយក បញ្ហាប្រឈម នៅមូលដ្ឋានជូនមន្ទីរ។ |
| -កសិករចំនួន ៧00នាក់ បានទទួលវគ្គ ផ្សព្វផ្សាយ ពីសុវត្ថិភាពនៃការដឹកជញ្ជូន ស្តុក លើចំណេះដឹងនៃការប្រើប្រាស់ថ្នាំពុល | -វគ្គផ្សព្វផ្សាយពីសុវត្ថិភាពនៃការដឹកជញ្ជូនស្តុកប្រើប្រាស់ ថ្នាំពុលកសិកម្ម ដល់អាជីវករនិងកសិករ ចំនួន១៤វគ្គ កសិករចំនួន៧00 នាក់/ស្រី ៣៤៦ នាក់។ |

| | |
|---|---|
| កសិកម្ម ១៤ វគ្គ ស្មើ១៤ កន្លែង។ | |

**ផ្នែក-ខ: ការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា (សំណួរវាយតម្លៃទី៣)**

| ធាតុនៃគោលបំណងបន្ទាន់ | ការសម្រេចបានជាក់ស្តែង នៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ |
|---|---|
| ការពង្រឹងសេវាផ្សព្វផ្សាយ អំពីបច្ចេកទេសកសិកម្ម និង បង្កើន ប្រាក់ចំណូលជូនដល់ប្រជាកសិករតាម រយៈការបង្កើន ទិន្នផល ស្រូវ/ដំណាំរួមផ្សំ និងការចិញ្ចឹមសត្វ ព្រមទាំង ធ្វើបង្ហាញ បច្ចេកទេសកសិកម្មសមស្រប នៅក្នុងភូមិ ឃុំគោលដៅ។ | គោលបំណងបន្ទាន់ដែលបានចែងគឺនៅក្នុង កម្រិតខ្ពស់ធ្វើឱ្យយើងពិបាកនៅក្នុងនៅក្នុងកា រ វាស់វែងនៅចុងបញ្ចប់នៃកិច្ចសន្យា។ ទោះបីគេ រំពឹងទុកថា សកម្មភាពនានា និងលទ្ធផលទាំង ឡាយរបស់អនុកិច្ចសន្យា នឹងចូលរួមទៅក្នុង គោលបំណងបន្ទាន់ក៏ដោយ ប៉ុន្តែផ្អែកទៅលើ ការពិនិត្យឯកសារ និងវិធីសាស្ត្រវាយតម្លៃបែប គុណភាព គេមិនអាចធ្វើការវាយតម្លៃទៅលើ ថាតើគោល បំណងបន្ទាន់នេះបានសម្រេចក្នុង កម្រិតណាទេ។ |

**ផ្នែក-គ: ការវាយតម្លៃ "លទ្ធផល" និង "ផលប្រយោជន៍" រួមដែលទទួលបាន**

តាមការពិភាក្សាក្រុម អ្នកចូលរួមបានបង្ហាញថា ពួកគាត់មានការចូលរួមពេញចិត្តចំពោះផលប្រយោជន៍ដែលអនុកិច្ចសន្យានេះសម្រេចបាន ពិសេស ចំណេះដឹង និងបច្ចេកទេសថ្មីទៅលើការដាំដុះស្រូវ និងការផលិតជីកំប៉ុស្តិ៍។ ទិន្នផលដែលទទួលបាន មានការកើនឡើងក្នុងស្រែដែលធ្លាប់បាន ទិន្នផលទាបកាលពីពេលមុន តាមរយៈការស្ទូងស្រូវ និងដើមសំណាបខ្ចី ពីបច្ចេកទេសថ្មី ហើយដីស្រែ ដែលធ្លាប់តែរឹងកាលពីពេលមុនហាក់ដូចជាបានធូរបន្តិចតាមរយៈការប្រើប្រាស់គោលការណ៍នៃ ជីកំប៉ុស្តិ៍តាម ធម្មជាតិ។ គួរស្រូវហាក់ដូចជាវែងជាងមុន ហើយទិន្នផលអាចសរុបថាបានកើនជាងមុនដែរ។

យើងឃើញថា នៅក្នុងចំណោមមនុស្សដែលបានផ្តល់បទសម្ភាស សុទ្ធតែឆ្លើយថាពេញចិត្ត១០០% ព្រោះគាត់យល់ថា ទោះបីអ្នកមិនបានចូលរៀនក៏អាចទទួលចំណេះបានដែរ ព្រោះពួកគាត់អាចទទួលបានផ្សេងពីវគ្គតាមរយៈការធ្វើបង្ហាញពីអ្នកធ្វើបង្ហាញដោយផ្ទាល់នៅនឹងស្រែតែម្តង។ ដូចនេះចម្លើយពីអ្នកត្រូវសម្ភាសទាំងអស់គឺមានភាពវិជ្ជមានច្រើន ដែលបង្ហាញថាគាត់ពិតជាមានការ ពេញចិត្តបំផុត។

## ករណីសិក្សាទី១៖ អ្នកទទួលផលក្នុងគម្រោង បណ្តុះបណ្តាល អំពីបច្ចេកទេស ជីកំប៉ុស្តិ៍-ស្រូវ

## " ជីវភាពរស់នៅមានភាពប្រសើរ "




លោក ប៉ែន ហ៊ិន កសិករបង្ហាញ និងក្រុមគ្រួសារ ថតក្នុងពេលធ្វើបទសម្ភាស

លោក ប៉ែន ហ៊ិន កសិករអាយុ ៤៨ឆ្នាំ រស់នៅភូមិស្ពួល ឃុំ អមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ មានកូនពីរនាក់ ក្នុងបន្ទុក ជាអ្នក ដែល បានទទួលវគ្គ បណ្តុះបណ្តាល អំពីបច្ចេកទេស ជីកំប៉ុស្តិ៍-ស្រូវ គម្រោងគាំទ្រប្រព័ន្ធកសិកម្មសមស្របនិងលើកកំពស់ជីវភាពរស់នៅរបស់ មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ ដែលទទួល បានថវិកាពី គ.ជ.អ.ខ ក្នុងឆ្នាំ២០០៩ បានមានប្រសាសន៍ថា៖ វគ្គបណ្តុះបណ្តាលនេះ មានសារប្រយោជន៍បំផុត ចំពោះការងារស្រែចំការ និងពិតជាពាក់ព័ន្ធទៅនឹងការកាត់បន្ថយការចំនាយនៅក្នុងគ្រួសាររបស់គាត់។ គាត់បានបញ្ជាក់ថា៖ "ពីមុនខ្ញុំបានចំណាយពូជច្រើនក្នុងការសាបព្រោះ តែឥឡូវខ្ញុំអាចសន្សំ និងកាត់បន្ថយពូជបានច្រើនសម្រាប់ហូប និងលក់វិញ"។ គាត់បានបន្ថែមទៀតថា៖ "ពីមុនគាត់បានប្រើប្រាស់សំនាបរហូតដល់ទៅ១ស្លឹក តែឥឡូវគាត់ប្រើតែពាផ្លូន គឺគ្រប់គ្រាន់ហើយ"។ លើសពីនេះទៀត សម្រាប់កំលាំងពលកម្ម ក៏បានថយចុះមួយចំណែកដែរព្រោះគាត់ មិនធ្វើការធ្ងន់ៗដូចមុន ដែលត្រូវរែក និងរាយកណ្តប់ពេលមានការស្ទូងមកដល់។

លោក ប៉ែន ហ៊ិន បាន សម្តែងអារម្មណ៍មិនទាន់អស់ចិត្ត ហើយបានជម្រាបជូនបន្តទៀតថា មិនថា មិនគ្រាន់តែអ្នកដែលទទួលបានវគ្គបណ្តុះបណ្តាលទេ តែគ្រួសារផ្សេងៗទៀតដែលរស់នៅក្បែរនោះ ក៏មានការផ្លាស់ប្តូរច្រើន លើរបៀប និងទម្លាប់ធ្វើស្រែ ហើយចេះចាប់ពង្រីកយកការធ្វើជីកំប៉ុស្តិ៍ ដែលគាត់អះអាងថា ការធ្វើកំប៉ុស្តិ៍មកដាក់ក្នុងស្រែ ធ្វើឱ្យស្រូវរបស់គាត់មានរសជាតិឆ្ងាញ់ និងបាយទន់ មិនតែប៉ុណ្ណោះ ដីស្រែដែលធ្លាប់រឹងក៏ប្រែជាទន់មកវិញដែរ។

ចុងបញ្ចប់គាត់បានបង្ហាញការតាំងចិត្ត និងមានជំនឿលើកសិកម្មបែបទំនើប ហើយនិងជួយជម្រាបដល់អ្នកជិតខាងរបស់គាត់ឱ្យផ្លាស់ប្តូរផ្នត់គំនិតចាស់ខ្លះ មកចាប់ផ្តើមទទួលយកបច្ចេកទេស និងចំណេះដឹងថ្មីៗ លើមុខរបរកសិកម្ម នេះ ព្រោះគាត់មានទស្សនៈរួមថា ដីមិនរីកទៅណាទេ តែមនុស្សចេះតែរីកពីមួយថ្ងៃទៅមួយថ្ងៃ ហើយដីធ្វើកសិកម្ម កាន់តែរួមតូច ដូចនេះការចាប់យកបច្ចេកទេសថ្មី ពិតជាការសមស្របណាស់ សម្រាប់ធ្វើឱ្យទិន្នផលស្រូវមានការ កើនឡើង។

## ករណីសិក្សាទី២: អ្នកមិនទទួលផលក្នុងគម្រោង បណ្តុះបណ្តាល អំពីបច្ចេកទេស ជីកំប៉ុស្តិ៍-ស្រូវ



បងស្រី នៅ ហឿន

បងស្រី នៅ ហឿន អាយុ៣៧ឆ្នាំ ជានារីកំព្រា និងរស់នៅ ជាមួយបងប្អូនបង្កើត និងសាច់ថ្លៃចំនួន៦នាក់។ គាត់រស់នៅក្នុង កម្រិតជីវភាពគ្រួសារខ្សត់ខ្សោយ ដូចបណ្តាគ្រួសារដទៃទៀត ក្នុងភូមិស្ទួល ឃុំ អមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ និងមានការងារស្រែចំការ ការចញ្ចឹមសត្វ និងការដាំដំណាំរួមផ្សំបន្តិចបន្តួចជាមុខរបរចិញ្ចឹមជីវិត។

ដោយសារគាត់ជាប់រវល់នឹងការងារស្រែចំការ ដែលតម្រូវឱ្យគាត់ទៅឆ្ងាយ និងមិនសូវចាប់អារម្មណ៍ផងនោះ នៅ ហឿន មិនបានចូលរួមក្នុង វគ្គបណ្តុះបណ្តាល អំពីបច្ចេកទេស ជីកំប៉ុស្តិ៍-ស្រូវ របស់មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ ដែល ទទួល បាន ថវិកាពី គ.ជ.អ.ខ ក្នុងឆ្នាំ២០០៩ទេ។

តែទោះបីជាគាត់មិនបានចូលរួមវគ្គ តែគាត់ពិតជាមានការស្ងើចសរសើរចំពោះវិធីសាស្ត្រ និងបច្ចេកទេសនៃការធ្វើជីកំប៉ុស្តិ៍ និងរបៀបក្នុងការធ្វើកសិកម្មដំណាំស្រូវថ្មីនេះណាស់។ គាត់បាននិយាយថា "ដំបូងខ្ញុំមិនចាប់អារម្មណ៍ទេ ហើយក៏មិនជឿជាក់ដែរ តែខ្ញុំបានឃើញជាក់ស្តែងពី គុម្ព និងដើមស្រូវធំៗដែលដុះក្នុងស្រែលោក ពូ លោក ប៉ែន ហ៊ាន ដែលនៅក្បែរខ្ញុំស្រែខ្ញុំ។ ហើយខ្ញុំរឹតតែជឿថែមទៀតនៅពេលគាត់ប្រមូលផលស្រូវ ខ្ញុំឃើញថាមានការកើនឡើងលើទិន្នផល និងបាយមានរស់ជាតិឆ្ងាញ់ និងទន់ជាងមុន"។ ថែមលើសពីនេះទៀត គាត់បានកត់សម្គាល់ឃើញថាមានកសិករក្នុងភូមិកាន់តែច្រើនទៅៗ បានអនុវត្តតាមបច្ចេកទេសថ្មីនេះ តែសម្រាប់ខ្ញុំមិនបានបានអនុវត្ត១០០% នៅឡើយ ទេ ព្រោះស្រែរបស់ខ្ញុំភាគច្រើន ជាស្រែទំពាំងពិបាកក្នុងការបញ្ចេញបញ្ចូលទឹក តែខ្ញុំក៏បានបន្ធូរដៃ ក្នុងការចាប់ដុំធំ មកបី ឬបួនដើមវិញដែរ។ ហើយគាត់បានបន្ថែមថា គាត់នឹងចាប់ផ្តើមរៀបចំរោងជីកំប៉ុស្តិ៍មួយនៅឆ្នាំក្រោយ និងសាក ល្បងស្ទូងស្រូវ១ដើម ដោយជ្រើសរើសសំណាបខ្ចី ដូចគេខ្លះដែរ បើគាត់អាចគ្រប់គ្រងទឹកក្នុងស្រែបាន។

គាត់បានបញ្ជាក់ថែមទៀតថា ជីកំប៉ុស្តិ៍ពិតជាមានសារសំខាន់បំផុត ព្រោះវាបានកាត់បន្ថយការចំណាយក្នុងគ្រួសារ ក្នុងការទិញជី គីមី និងបានធ្វើឱ្យដីមានសភាពទន់វិញដែរ ហើយទិន្នផលស្រូវ ពិតជាមានការកើនឡើងពិតប្រាកដមែន។

នៅ ហឿន មានរំពឹងថានឹងបានចូលរួម ក្នុងវគ្គបណ្តុះបណ្តាល អំពីបច្ចេកទេស ជីកំប៉ុស្តិ៍-ស្រូវ និងវគ្គដទៃផ្សេងៗទៀត នៅពេលអនាគតខាងមុខ ហើយនឹងមិនធ្វើឱ្យខកខានទៀតឡើយ។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤)

(ពិន្ទុ: ១=ខ្សោយណាស់ ២=ខ្សោយ ៣=មិនខ្លាំង មិនខ្សោយ ៤= ខ្លាំង ៥=ខ្លាំងណាស់)

**ផ្នែក-ក: ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅនឹងតំរូវការ: មន្ទីរវិស័យ មូលដ្ឋាន គ.ជ.អ.ប និងការកាត់បន្ថយភាពក្រីក្រ:**

| ល.រ (១) | ធាតុ (២) | ទំនាក់ទំនងតក្កភាព (៣) | បរិយាយច្បាស់លាស់ (៤) | សង្ខេបការវាយតម្លៃ (៥) |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៤ | ៤ | សកម្មភាពដែលបានកើតឡើង ពិតជាមានទំនាក់ទំនងតក្កភាព ជាមួយនឹងលទ្ធផលដែលបានសរសេរនៅក្នុងឯកសារអនុកិច្ចសន្យា បើទោះបីមានចំណុចខ្វះខាតខ្លះក្តី ។ ឧទាហរណ៍លទ្ធផលទី១ទាក់ទិននឹង ការបង្ហាញផ្នែកក្សេត្រសាស្ត្រ (ឈើហូបផ្លែ ស្រូវ បន្លែ ដំណាំ) ទទួលបានការបណ្តុះបណ្តាលដូចជា វគ្គបណ្តុះបណ្តាលអំពីបច្ចេកទេស ជីកំប៉ុស្តិ៍-ស្រូវ ១៩វគ្គ ការធ្វើបង្ហាញកំប៉ុស្តិ៍-ស្រូវ និងតាមដាន ចំនួន៣៨ បង្ហាញ ទិវាស្រែបង្ហាញ (អត់បានធ្វើ) បណ្តុះ បណ្តាលអំពីបច្ចេកទេសកំប៉ុស្តិ៍-បន្លែ ការធ្វើ បង្ហាញដំណាំបន្លែ និងតាមដាន២០ បង្ហាញ ទិវាបង្ហាញអំពីបន្លែ (ទោះបីអត់បានធ្វើ) ។ ទាំងនេះឆ្លុះបញ្ចាំងថា សកម្មភាព ទាំងនេះ មានទំនាក់ទំនងតក្កជាមួយនឹងលទ្ធផលខាងលើ ហើយនឹង |

| | | | | |
|---|---|---|---|---|
| | | | | សរសេរបាន ច្បាស់លាស់តែ ដកមួយពិន្ទុ សម្រាប់ការមិន បានបញ្ជាក់ ឈ្មោះទីតាំង និងចំនួនអ្នកបង្ហាញក្នុង សកម្មភាពអ្នកបង្ហាញស្រូវ និងជីកំប៉ុស្តិ៍នៅក្នុងអនុកិច្ចសន្យាដោយដាក់បញ្ជាក់ឱ្យច្បាស់ លាស់ថា រោងជីកំប៉ុស្តិ៍មានអ្នកបង្ហាញប៉ុន្មាន និងការបង្ហាញស្រូវមានអ្នកបង្ហាញប៉ុន្មាន អ្នក។ ហើយសកម្មភាពផ្សេងៗទៀតនៅក្នុង លទ្ធផលពីរដំទៃទៀតក៏ដូចគ្នាដែរ។ ដូចនេះ ការដកពិន្ទុ១ គឺជាការត្រឹមត្រូវ។ |
| ២ | លទ្ធផល | ៤ | ៤ | លទ្ធផលនីមួយៗ ត្រូវបានសរសេរបរិយាយច្បាស់លាស់ ដោយមានសូចករជាក់លាក់ និងអាចវាស់វែងបាន។ ជាងនេះទៅទៀត លទ្ធផលនីមួយៗផ្សារភ្ជាប់គ្នាល្អ។ លទ្ធផលនីមួយៗជាការបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ហើយរួមគ្នាបំពេញគោលបំណងបន្ទាន់។ ទោះបីជាយ៉ាងណាក៏ដោយលទ្ធផលទាំងនេះ នៅមិនទាន់អាចធ្វើឱ្យគោលបំណង បន្ទាន់សម្រេចបាន នៅឡើយទេ។ |
| ៣ | អត្ថប្រយោជន៍រយៈពេលខ្លីៈ (លទ្ធផល/ផលប្រយោជន៍)<br>- គោលបំណងបន្ទាន់<br>- ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា | ៤ | ៣ | -គោលបំណងបន្ទាន់ ត្រូវបានផ្តល់អត្ថន័យយ៉ាងច្បាស់លាស់ ប៉ុន្តែគោលបំណងបន្ទាន់នេះ មានកម្រិតខ្ពស់ពេកជាហេតុធ្វើឱ្យអនុកិច្ចសន្យានេះពិបាក នឹងសម្រេចគោលបំណងបន្ទាន់នេះណាស់ ក្នុងកាលៈទេសៈនេះ |

| | | | | |
|---|---|---|---|---|
| | | | | -ស្ថានភាពចុងក្រោយក្នុងអនុកិចសន្យានេះ មិនបានសេរសេរទៀត ដែលជាហេតុធ្វើឱ្យ បាត់បង់នូវព័តិមានស្តីពីទំនាក់ទំនងផ្ទាល់ ទៅនឹងលទ្ធផល និងសកម្មភាពនៃអនុកិច្ច សន្យា។ ដូចនេះយើងក៏ពិបាកធ្វើការឆ្លុះ បញ្ចាំងនូវសមិទ្ធផលដែលសម្រេចបាននៅ ក្នុងកម្រិតលទ្ធផល ហើយក៏មិនអាចឆ្លុះ បញ្ចាំងនូវស្ថានភាពបញ្ចប់ ឬផលប៉ះពាល់ ដែល អាចកើតមានឡើងនៅ ក្នុងកម្រិត ប្រជាជន និងសហគមន៏បានដែរ។ គ្មានភស្តុ តាងច្បាស់លាស់ណាមួយដើម្បី បង្ហាញថា សិក្ខាកាមបានយកចំណេះដឹង និង ជំនាញ ដែលពួកគេទទួលបាន ទៅធ្វើជា ប្រយោជន៏ ក្នុងការធ្វើឱ្យប្រសើរ ឡើងនូវ ជីវភាពរបស់ ពួកគាត់ទេឱ្យគ្រប់គ្រាន់។ |
| ៤ | លទ្ធផលអភិវឌ្ឍន៏/ផលប៉ះពាល់ រយៈពេលវែងៈ<br>-គោលដៅ<br>-គោលបំណងអភិវឌ្ឍន៏ | | | មិនអាចធ្វើការវាយតម្លៃបាន |

**ផ្នែក-ខៈ សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខ័ណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើ របាយការណ៏ និងការកត់ត្រាឯកសារៈ**

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.ជ.អ.ខៈ** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | អ្នកតាមដាន ត្រួតពិនត្យ និងវាយតម្លៃរបស់មន្ទីរ វិស័យមិនទាន់ចេះប្រើប្រាស់ ប្រព័ន្ធទិន្នន័យNCD នៅឡើយទេ។ ដូចនេះវាធ្វើឱ្យមានការលំបាកមួយ |

| | | |
|---|---|---|
| | | កម្រិតទៀតដល់មន្ទីរ គ.ប្រ ហើយក៏ធ្វើ សមត្ថភាពនៃការសរសេរអនុកិច្ចសន្យានេះ នៅមានកម្រិត។ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យការអនុវត្តន៍របស់ភ្នាក់ងារអនុវត្តន៍ | នៅពេលមានសកម្មភាពណាមួយមិនអាច អនុវត្តបានយើងឃើញមានការធ្វើវិសោធនកម្មមួយ ទៀតដែលនេះអាចរាប់ថាជាដំណោះ ស្រាយដ៏ល្អមួយពេលយើងមានបញ្ហាថែដន្យ កើតឡើងដោយមិនចាំបាច់រងចាំ ឬជំនះធ្វើ ដោយ មិនសូវបានផលនោះ ទេ ឬធ្វើឱ្យស្ទះពេលវេលានោះឡើយ។ តែវិសោធនកម្មបានធ្វើឱ្យខាតបង់រយៈពេលអនុវត្តគម្រោងខ្លះ ព្រោះជាប់រវល់ធ្វើវិសោធនកម្ម ហើយអាចបង្ហាញពីការគ្រោងមិនបានច្បាស់លាស់ ពីដើមឆ្នាំដែលធ្វើឱ្យថវិកាទាំងនោះត្រូវរត់ចេញពីលទ្ធផលមួយទៅលទ្ធមួយទៀត។ ការធ្វើវិសោធនកម្ម មិនគួរឱ្យកើតឡើយញឹកញាប់ពេកទេ ព្រោះវាអាចធ្វើឱ្យថវិកាមួយចំនួនទៅផ្តុំតែលើទីតាំងនិងលទ្ធផលតែមួយ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា | ខ្វះការងារតាមដានឱ្យបានច្បាស់លាស់ ដែលមានទិន្នន័យមួយច្បាស់លាស់ សម្រាប់ធ្វើការផ្ទះបញ្ជាំងទៅនឹងគោលដៅបន្ទាន់នៅឡើយទេ។ ខ្វះតារាងស្តង់ដាណាមួយច្បាស់លាស់សម្រាប់ការងារវាយតម្លៃ។ ក្នុងអនុកិច្ចសន្យានេះ មិនមានផែនការការងារឱ្យ បានច្បាស់លាស់ ដែលមិនបានបញ្ចូលតារាង Logframe ដែលក្នុងនោះមានដាក់ក្រុមការងារ ដែលជាអ្នកទទួលខុសត្រូវដែរលើការបញ្ច្រាប យេនឌ័រ និងការគ្រប់គ្រងធនធានធម្មជាតិ។ ដូចនេះការកត់ត្រា និងទុកដាក់ឯកសារគួរត្រូវបានកែលម្អ។ |

| | | |
|---|---|---|
| **ពីខាងភាគីអនុវត្តន៍កិច្ចសន្យា:** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | មានបុគ្គលិក ជំនាញ និងបទពិសោធន៍គ្រប់គ្រាន់ ។ |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | ការអនុវត្តសកម្មភាព និងលទ្ធផលទាន់ពេល វេលា ដូចដែលបានព្រាងទុក ។ |
| ៦ | ការរាយការណ៍ការរីកចំរើន និង ការកត់ត្រាឯកសារ | ដូចតាមទម្លាប់ និងនិតិវិធីដែលបានធ្វើ ។ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | លក្ខខណ្ឌក្នុងកិច្ចសន្យាត្រូវបានបំពេញ |
| **ទាំងខាង គ.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យា:** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" (ចំណុច-ង ផ្នែកទី៣ ) និងបញ្ហាប្រឈម | យើងឃើញមានសកម្មភាព ខកខានមិនបានអនុវត្ត ដូចជាទិវាស្រូវបង្ហាញ និងទិវាបន្លែបង្ហាញ ដោយសាររដូវវស្សារអូសបន្លាយ និងដោយសារអ្នកធ្វើបង្ហាញប្រមូលផលមុនគម្រោង ដែលនេះបញ្ជាក់ឱ្យឃើញថា ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" និងបញ្ហាប្រឈម នៅមានកម្រិតមួយទុនខ្សោយនៅឡើយ ។ |
| ៩ | ការបញ្ជ្រាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | អ្នកចូលរួមភាគច្រើនជាស្ត្រី ហើយគម្រោងពិតជាបានចូលរួមបន្ធូរបន្ថយការងាររបស់ស្ត្រីមួយចំណែកលើការប្រើប្រាស់កំលាំងពលកម្ម ដូចជាការដកស្ទូង ហើយស្ត្រីភាគច្រើនក៏ទទួលបានចំណូល និងចំណេះដឹងលើការងារដាំដុះគ្រាន់បើដែរ ។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ ( ចំណុច-ឆ ផ្នែកទី៣) | ការអនុវត្តអនុកិច្ចសន្យានេះ ពិតជាសមស្របទៅនិងគោលនយោបាយផ្តល់មូលនិធិលើ គម្រោងដែលចង់ឱ្យអ្នកទទួលផលស្គាល់ និងចេះស្រលាញ់ ព្រមទាំងការការពារបរិស្ថាន និងការប្រើប្រាស់ធនធានដែលមានស្រាប់ក្នុងសហគមន៍របស់ ខ្លួនតាមរយៈសម្រាប់ការកាត់បន្ថយការរុនរានព្រៃនិងការសម្លាប់សត្វ ឱ្យងាកមកការធ្វើកសិកម្ម ដើម្បីបង្កើនចំនូលវិញ ។ |

| | | |
|---|---|---|
| ១១ | ការថែរក្សា (និរន្តភាព) ( ចំណុច-ជ ផ្នែកទី៣) | សកម្មភាព និងបច្ចេកទេសមួយចំនួនពិតជាអនុវត្តបន្តដែលជាកត្តាមួយ សម្រាប់ការចូលរួមកាត់បន្ថយ ភាពក្រីក្រនៅតាមទីជនបទដែលឆ្លើយតបទៅ នឹងគោលដៅរបស់រាជរដ្ឋាភិបាលប្រាកដមែនដែលជំរុញឱ្យមានការកើនឡើងជាអតិបរមានូវស្បៀងអាហាររបស់ប្រជាកសិករតាមជនបទតាមរយៈការបង្កើនផលិតភាពកសិកម្ម និងប្រាក់ចំណូលក្នុងគ្រួសាររហូតដល់ពេលដែលក្រុមការងារចុះទៅធ្វើការវាយតម្លៃ។ ដូចន្នេះនិរន្តភាពរបស់ ផ្នែកខ្លះនៃគម្រោងត្រូវបានសម្រេច។ |

## ២.៤. សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី ៥)

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យានេះត្រូវបានអនុវត្តឡើងដូចការគ្រោងទុក។ ភាគីអនុវត្តអនុកិច្ចសន្យា មានសមត្ថភាព និងធនធានគ្រាប់គ្រាន់ដើម្បីអនុវត្តអនុកិច្ចសន្យា។<br>មានសកម្មភាពពីរធ្វើឱ្យប៉ះពាល់ដល់លទ្ធផលទាំងមូលនៃការវាយ តម្លៃដែរ តែការសន្និដ្ឋានជារួមសកម្មភាព និងលទ្ធផលដែលបានគ្រោងទុក ត្រូវបានបញ្ចប់ស្របតាមផែនការ ការងារ។ |
| ២ | មានចំណុចជាច្រើនដែលអ្នករៀបចំបានរំលង ដែលជាហេតុធ្វើឱ្យសូចនាករជាច្រើនបានបាត់បង់ ដែលនោះជាខ្នាតវាស់វែងមួយសម្រាប់ការងារត្រួតពិនិត្យ និងវាយតម្លៃ។ ផ្នែកសំខាន់មួយដែល ដែលមានប្រយោជន៏សម្រាប់ការវាយតម្លៃនេះដែរ គឺស្ថានភាពចុងក្រោយនៃអនុកិច្ចសន្យា តែផ្នែកនេះ មិនត្រូវបានគេសរសេរឡើយដែលជាហេតុធ្វើឱ្យមានចំណុចខ្វះខាតក្នុងការបំពេញទម្រង់របាយការណ៏វាយតម្លៃនេះដែរ។ កិច្ចសន្យានេះ ទោះបីលទ្ធផល និងសកម្មភាពជាច្រើនបាននិយាយចំទៅតម្រូវការនៅក្នុងសហគមន៏ ប៉ុន្តែវាមិនទាន់ឆ្លើយ តបទាំងស្រុងទេ ពីព្រោះទីនោះមិនទាន់ជាតំបន់ដែលមានប្រភពទឹកគ្រប់គ្រាន់ ដែលនោះជាការខ្វះខាតលើការ សន្និដ្ឋានលើទីតាំង និងស្ថានភាពលំបាកផ្សេងៗ ការរៀបចំពេលវេលាសម្រាប់ការបណ្តុះបណ្តាលហាក់ដូច ជាខ្លីពេក ដែលវាមិនអាចបំពេញ និងធ្វើឱ្យកសិករអាចយល់អស់បានពេល ដែលពួកគេជួបបញ្ហាផ្ទាល់នោះ។ |

| | |
|---|---|
| | ទោះបីមិនបានសរសេរស្ថានភាពចុងក្រោយក៏ដោយ តែការវិភាជន៍បានពីថ្នាក់ខេត្តឆ្នាំ២០០៩នេះដែរ មានចំនួន តិច ដូចនេះមន្ទីរកសិកម្ម ក៏រៀបចំឱ្យសមស្របនៅនឹងតម្រូវការជាអាទិភាពជាងគេនៅក្នុងតំបន់ និងកម្រិត មូលដ្ឋានណាដែលឆ្ងាយជាងគេ និងមិនទាន់មានកសិកម្មបែបទំនើបខ្លះ ចូលទៅដល់ ហើយក៏នៅមានភស្តុតាង លទ្ធផល និងផលប្រយោជន៍ដែលទទួលបានមានដូចខាងក្រោម នៅតែបានសង្កេតឃើញ បន្ទាប់ពីបញ្ចប់អនុកិច្ច សន្យាជាយូរមកហើយនោះ ដូចជា:<br>ក) ការបន្តធ្វើរោងជីកំប៉ុស្តិ៍ ដោយប្រើប្រាស់ចំណេះដឹង ជំនាញ និងបច្ចេកទេសថ្មី ដែលទទួលបានពីវគ្គបណ្តុះបណ្តាល ។<br>ខ) ការបន្តធ្វើស្រែតាមបច្ចេកទេសថ្មី ដូចជាការជ្រើសរើសពូជ ការសាប ការស្ទូងស្រូវមួយដើម និងការប្រើប្រាស់ជីកំប៉ុស្តិ៍ ដែលនេះនៅមានការរីកសាយដល់កសិករដ៏ទៃទៀត ហាក់ដូចជានៅមានការគាំទ្រច្រើន ដែលនោះជាការសន្សំសំចៃមួយក្នុងគ្រួសារ និងជួយឱ្យគ្រួសារទាំងនោះទទួលបានទិន្នផលបន្ថែមមួយចំនួនទៀត សម្រាប់ការកែលម្អកម្រិតជីវភាពរបស់ពួកគាត់មួយចំណែកធំ ។<br>គ) មានតម្រូវការវគ្គបណ្តុះបណ្តាលបែបហ្នឹង ឬស្រដៀងគ្នានេះ ដែលសំណូមពរដោយអ្នកភូមិ និងអាជ្ញាធរ ជាច្រើន ដែលរស់នៅក្នុងស្ថានភាពស្រដៀងគ្នានេះ ដែលមិនទាន់បានទទួលវគ្គបណ្តុះបណ្តាលកន្លងមក ។<br>ដូច្នេះអនុកិច្ចសន្យានេះ បានទទួលនូវនិរន្តភាពក្នុងសកម្មភាពរបស់ខ្លួនក្នុងកម្រិតខ្ពស់ តែគម្រោងបានចូលរួមចំណែកក្នុងកម្រិតតិចតួចទៅគោលដៅអភិវឌ្ឍន៍នៅក្នុងអនុកិច្ចសន្យា ហើយនិងគោលដៅក្នុងការកាត់បន្ថយភាពក្រីក្រ ។ |
| ៣ | ការជ្រើសរើសសិក្ខាកាម និងអ្នកទទួលផលនៅក្នុងកិច្ចសន្យា ដោយភាគីអនុវត្តកិច្ចសន្យាផ្ទាល់ និងធ្វើឱ្យមានការធានាថា អ្នកដែលចូលរួមនោះពិតជាអ្នកដែលមានតម្រូវការខ្លាំង ដែលសមនឹងទទួលបានផលប្រយោជន៍ពីអនុកិច្ចសន្យា ហើយឱ្យសហគមន៍ចងក្រងគ្នាជាក្រុម និងធ្វើការពង្រីកចំណេះដឹងរបស់ពួកគេឱ្យបានទូលំទូលាយ ដោយគ្រោងសម្ភារៈឱ្យគ្រប់គ្រាន់សម្រាប់ការផ្តល់ក្នុងការធ្វើបង្ហាញ ។ |

**<u>ចំណុចរៀនសូត្រ:</u>**

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ការបាត់បង់ និងអាក់ខានមិនបានសរសេរស្ថានភាពចុងក្រោយ ឬការបរិយាយមិនបានច្បាស់លាស់នៅក្នុងអន កិច្ចសន្យា ពិតជាការបាត់នូវសូចនាករសំខាន់ សម្រាប់ការវាស់វែងនៅក្នុងការវាយតម្លៃ លើផ្នែកគុណភាព ។ |
| ២ | ដើម្បីឱ្យលទ្ធផលមួយមាននិរន្តភាពលើការបន្តអនុវត្តទៅបាន លុះត្រាតែ ការជ្រើសរើសយកលទ្ធផល |

| | |
|---|---|
| | មួយនោះ ទាមទារឱ្យ អ្នកអនុវត្តគម្រោងត្រូវដឹងពីស្ថានភាពពិតប្រាដក និងទីតាំងភូមិសសាស្ត្រនៅក្នុង តំបន់នោះ ឱ្យបាន ច្បាស់លាស់សិន ព្រោះវាជាហេតុផលមួយសំខាន់ តើថាអ្នកទទួលផលទាំងនោះ ពិតជាមានតម្រូវការលើ លទ្ធផលនោះដែរ ឬទេ ថាតើនោះ ជាតំបន់ដែលមិនមានទឹកគ្រាប់គ្រាន់ ឬតំបន់សំបូរសត្វបំផ្លាញដូចនោះការ ធ្វើកសិកម្មបែបថ្មីអាចនឹងមិនធានាលើនិរន្តភាពនៃការអនុវត្តបានដែរ។ ដូចនេះផលប៉ះពាល់របស់អនុកិច្ចសន្យា និងនិរន្តភាពរបស់លទ្ធផលនៅក្នុងអនុកិច្ចសន្យាអាចត្រូវបាន សម្រេចបាន ក្នុងកម្រិតខ្ពស់ប្រសិនបើអនុកិច្ចសន្យា ត្រូវបានរៀបចំឡើងដើម្បី ឆ្លើយតបទៅនឹងតម្រូវការ ជាអាទិភាពរបស់ក្រុមគោលដៅជាអ្នកទទួលផល។ |
| ៣ | គម្រោងកសិកម្មភាគច្រើន ជាគម្រោងដែលត្រូវធ្វើតាមរដូវកាល និងមានរយៈពេលពិសោធន៍មួយ ច្បាស់លាស់ ដោយមានការពន្យល់ និងអនុវត្តជាក់ស្តែងនៅក្នុងស្រែ ឬនៅក្នុងសួន ឬកសិដ្ឋានផ្ទាល់ ដូចនេះ ចំនួនថវិកា និង ពេលវេលាប្រាដកជាអាចធ្វើឱ្យការអនុវត្ត គម្រោង និងផលដែលបានពីគម្រោង មានការ ថយចុះមួយកម្រិតធំ បើថវិកា និងពេលវេលានោះមិនគ្រាប់គ្រាន់។ |
| ៤ | ការបរិយាយច្បាស់លាស់នូវ គោលបំណងបន្ទាន់ ក្នុងកម្រិតដែលអាចវាស់វែងបានជាការសំខាន់ណាស់ សម្រាប់ ការកត់ត្រាទុក នូវលទ្ធផលរបស់អនុកិច្ចសន្យា និងផលប្រយោជន៏ដែលមាន ដើម្បីការ វាយតម្លៃលទ្ធផល។ |

**<u>អនុសាសន៍</u> :**

| ល.រ | អនុសាសន៍ |
|---|---|
| ១ | គួររក្សាប្រព័ន្ធទិន្នន័យគ្រប់គ្រងកិច្ចសន្យា និងសរសេររបាយការណ៍ជាប្រចាំ ដាក់ជូនទៅថ្នាក់ខេត្ត ហើយគ.ប្រ ត្រូវផ្តល់មធ្យោបាយដែលទាក់ទងនឹងប្រព័ន្ធនេះមានកុំព្យូទ័រការលើកទឹកចិត្តផ្សេងៗដែលអាចធ្វើបាន និងផ្តល់ វគ្គបណ្តុះបណ្តាលលើ ការប្រើប្រាស់ប្រព័ន្ធព័តិមានវិទ្យា NCD។ |
| ២ | គួរធានាថា NCDបានដំឡើង និងថែរក្សាយ៉ាងត្រឹមត្រូវ និងធ្វើដំណើរដើម្បីទៅ ជួយដល់ខេត្ត តាមការចាំបាច់ ហើយការកត់ត្រានៃរាល់ទិន្នន័យទាំងអស់គួរមានការណែនាំពីគម្រោង ឬពីអ្នកគាំទ្រទាំង អស់ដែលធ្វើឱ្យ ព័តិមាននោះអាចទទួលយកបាន និងផ្លូវការ។ បង្កើតតារាងសម្រាប់ការតាមដានណា ដែលមាន ប្រយោជន៍។ ធ្វើយ៉ាងណាឱ្យគាត់យល់ អំពីសារៈសំខាន់នៃការចងក្រងឯកសារអំពីការរីកចម្រើន និង របាយការណ៍លទ្ធផល និងយល់អំពីសារៈសំខាន់នៃការប្រមូលទិន្នន័យ និងវិធីសាស្ត្រប្រមូល ទិន្នន័យ សម្រាប់ តាមដានត្រួតពិនិត្យ និងវាយតម្លៃអនុកិច្ចសន្យា។ |
| ៣ | គួរពិនិត្យឡើងវិញរបៀបសរសេររបាយការណ៍រីកចម្រើន ស្តីពីការអនុវត្តន៍កិច្ចសន្យាដែលខេត្ត និងថ្នាក់ជាតិ |

| | |
|---|---|
| | ផ្ញើមក និងត្រូវធានាថា ទិន្នន័យ និងពត៌មាន ត្រូវបានបញ្ចូលយ៉ាងត្រឹមត្រូវក្នុង NCD ហើយគ.ប្រ គួរជុំរុញការយល់ដឹងបន្ថែមលើតួនាទី និងភារកិច្ច និងយល់ច្បាស់អំពីគោលការណ៍ វិធីសាស្ត្រ ឧបករណ៍តាមដានត្រួតពិនិត្យ និងវាយតម្លៃសំខាន់ៗ (ដូចជា ក្របខ័ណ្ឌ និងសូចនាករតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ) និងតម្រូវការសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ អនុកិច្ចសន្យា/គម្រោង។ |
| ៤ | មន្ត្រីគ.ប្រ គួរពិនិត្យឡើងវិញលើប្រព័ន្ធគ្រប់គ្រងកិច្ចសន្យា រួមមានទម្រង់បែបបទ គោលការណ៍ ណែនាំ និងនីតិវិធី នានាត្រូវបានធ្វើឡើង និងផ្តល់អនុសាសន៍ ដើម្បីធ្វើឱ្យប្រសើរឡើងដល់ ការអនុវត្តន៍ប្រព័ន្ធ និងនីតិវិធីទាំង នោះ។ |
| ៥ | មន្ទីរគួរសរសេរគោលដៅបន្ទាន់យ៉ាងណាឱ្យស្របទៅនឹងទំនាក់ទំនងរវាងទុន/ធាតុចូលនិងលទ្ធផល និងរវាងលទ្ធផល និងអត្ថប្រយោជន៍របស់គម្រោង/អនុកិច្ចសន្យា ឬចំណេះដឹងលើតារាងគំរូកត្តភាព ព្រោះវាជាឧបករណ៍ រៀបចំ និងវិភាគអនុកិច្ចសន្យា ដែលតម្រូវឱ្យវិភាគអំពីៈ តម្រូវការភាគីពាក់ព័ន្ធ លទ្ធភាពគម្រោង ទំនាក់ទំនង តក្ករវាងធាតុ មួយចំនួន (ទុន/ធាតុចូល សកម្មភាព លទ្ធផល ទិសដៅ និងគោល បំណង) និងការសន្មត។ |
| ៦ | គួរជ្រើសរើសតំបន់ឱ្យតិចតែគ្រោងថវិកាឱ្យត្រឹមត្រូវតាមនិងផ្តល់បច្ចេកទេសឱ្យសមស្របនោះគម្រោងពិតជាបានរួមចំណែកធ្វើឱ្យអ្នកចូលរួមយល់ និងជឿជាក់ជាងនេះ ដោយបូករួមនឹងសម្ភារបង្ហាញបានគ្រប់គ្នា។ |

## ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

### ឯកសារភ្ជាប់ទី១ : បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបានពិនិត្យ

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) | មាន (៣) |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និង ឯកសារវិសោធនកម្ម (ប្រសិនមាន) | √ |
| ២ | របាយការណ៍ត្រួតពិនិត្យគម្រោង | √ |
| ៣ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | √ |
| ៤ | ផ្សេងទៀត | √ |

**ឯកសារភ្ជាប់ទី២ : ឯកសារអនុកិច្ចសន្យា លេខ (05/AGR/0901-01 (GOV)) ខេត្ត កំពង់ស្ពឺ**

**បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាស/ជួបពិភាក្សា**

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៍ប្រើសម្រាប់ប្រមូលទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | *ថ្ងៃទី២៨ខែកញ្ញា ឆ្នាំ២០១០(ព្រឹក)* | **លោក ជិន អឿង**<br>អនុការិយាល័យផែនការ | មន្ទីរកសិកម្ម | សម្ភាសស៊ីជម្រៅ |
| ២ | *ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០(ព្រឹក)* | **លោក ទៀង ហ៊ីល្លីណា**<br>ប្រធានការិយាល័យក្សេត្រសាស្ត្រ | មន្ទីរកសិកម្ម | សម្ភាសស៊ីជម្រៅ |
| ៣ | *ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០(រសៀល)* | **លោក ហ៊ីង សុគន្ធី**<br>ទីប្រឹក្សាត្រួតពិនិត្យ និងវាយតម្លៃ | គ.ប្រ | សម្ភាសស៊ីជម្រៅ |
| ៤ | *ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០(ព្រឹក)* | **ក្រុមពិភាក្សាជាមួយអ្នកទទួលផល**<br>ចំនួន៨នាក់ | ភូមិស្នួល<br>ឃុំអមលាំង<br>ស្រុកថ្ពង | សម្ភាសស៊ីជម្រៅ |
| ៥ | *ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០(ព្រឹក)* | **លោក ប៉ែន ណន**<br>អ្នកទទួលផលផ្ទាល់<br>និងជាអ្នកបង្ហាញស្រូវ-ជីកំប៉ុស្តិ៍ | ភូមិស្នួល<br>ឃុំអមលាំង<br>ស្រុកថ្ពង | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៦ | *ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០(រសៀល)* | **កញ្ញា នៅ ហឿន**<br>អ្នកមិនទទួលផល | ភូមិស្នួល<br>ឃុំអមលាំង<br>ស្រុកថ្ពង | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៧ | *ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០(រសៀល)* | **លោក ឈួយ ហ៊ីម**<br>មេភូមិស្នួល | ភូមិស្នួល<br>ឃុំអមលាំង<br>ស្រុកថ្ពង | សម្ភាសស៊ីជម្រៅ |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | **06/SOC/0901-00** |
| ចំណងជើង : | បង្កើនការបណ្តុះបណ្តាលរដ្ឋបាល និងវិជ្ជាជីវៈ |
| ភ្នាក់ងារអនុវត្តន៍ : | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ធំ |
| រយៈពេល (ចាប់ផ្តើម និងបញ្ចប់) | ០១ ខែមករា ឆ្នាំ២០០៩ ដល់ ៣១ ខែធ្នូ ឆ្នាំ២០០៩ |
| រាជធានី ខេត្ត | កំពង់ធំ |
| ផ្នែក ,មន្ទីរជំនាញ | មន្ទីរការងារខេត្តកំពង់ធំ |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ/គ.អ.ជ.ខ | ៦,000.00 ដុល្លារ |
| ការរួចចំណែករបស់ដៃគូរអភិវឌ្ឍន៍ដទៃទៀត | 0.00 ដុល្លារ |
| ការរួមចំណែករបស់រាជធានី ខេត្ត | 0.00 ដុល្លារ |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៍ | ១,000.00 ដុល្លារ |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | ៧,000.00 ដុល្លារ |

## ក្រុមវាយតម្លៃ និងរៀបចំរបាយការណ៍:

| **ឈ្មោះ** | **មុខតំណែង និងភ្នាក់ងារ** |
|---|---|
| លន់ គីមអាន | គ្រូបង្គោលឆ្នើមមន្ត្រីCAU |
| ហែម សុគាន់ | គ្រូបង្គោលឆ្នើមមន្ត្រី CAU |
| វ៉ាត រតនះ | គ្រូបង្គោលមន្ទីរការងារ |
| ស៊ុន ហេង | មន្ត្រីផ្នែកគ្រប់គ្រងកិច្ចសន្យា |
| ទេព សុខបូរ៉ាន់ | គ្រូបង្គោលមន្ទីរកិច្ចការនារីខេត្ត |

**កំពង់ធំ**

**តុលា ២០១០**

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៣ |
| | របាយការណ៍សង្ខេប | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៥** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យាវវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៥ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៥ |
| ១.៣ | គោលបំនង និង ទំហំនៃការវាយតម្លៃ | ៥ |
| ១.៤ | សំណួរវាយតម្លៃ | ៥ |
| ១.៥ | វិធីសាស្រ្ត សម្ភារៈ និងដំណើរការវាយតម្លៃ | ៦ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ៦ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **៨** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១) | ៨ |
| | - លទ្ធផលទី១ | ៨ |
| | - លទ្ធផលទី២ | ៩ |
| | - លទ្ធផលទី៣ | ១០ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម (សំណួរវាយតម្លៃទី៣) | ១១ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤) | ១៧ |
| **២.៤** | **សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី៥)** | **១៩** |
| **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍** | | |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ២១ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍ /ពិភាក្សា | ២២ |
| **ករណីសិក្សា** | | **១៣** |
| ទី១- | អ្នកទទួលផលពីជី EM | ១៣ |
| ទី២- | អ្នកមិនទទួលផលពីជី EM | ១៤ |
| ទី៣- | អ្នកទទួលផលពីការបណ្តុះផ្សិតអំបោះ | ១៥ |
| ទី៤- | អ្នកមិនទទួលផលពីការបណ្តុះផ្សិតអំបោះ | ១៦ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

## របាយការណ៍សង្ខេប

គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ :

មន្ត្រីត្រួតពិនិត្យនិងវាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យានៃគ.ប្រខេត្តកំពង់ធំបានធ្វើការវាយតម្លៃអនុកិច្ចសន្យាដែលមានចំណងជើងថា "បង្កើនការបណ្តុះបណ្តាលរដ្ឋបាលនិងវិជ្ជាជីវៈ" លេខ ០៦/SOC/០៩០២-០០ ដែលជាអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ ខេត្តកំពង់ធំ និងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ធំ ។ នេះជាផ្នែកមួយនៃគម្រោងពង្រឹងសមត្ថភាព គ្រូបង្គោលថ្នាក់ក្រោមជាតិរបស់ផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែលគាំទ្រ ដោយកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ ។

គោលបំណងជាក់លាក់នៃការវាយតម្លៃនេះគឺ :

- ☞ កត់ត្រានិងវិភាគសមិទ្ធផលនៃអនុកិច្ចសន្យា និងចំនុចខ្សោយធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យារួមទាំងកត់ត្រានូវចំណុចរៀនសូត្រនិង លើកជាគំនិតដើម្បីកែលំអ
- ☞ ពង្រឹងរបៀប ធ្វើការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត ។

ការវាយតម្លៃនេះអនុវត្តតាមការណែនាំស្តីពីការវាយតម្លៃអនុកិច្ចសន្យារបស់គណៈកម្មាធិការប្រតិបតិគ.អ.ជ.ខ ដែលរៀបចំដោយផ្នែកត្រួតពិនិត្យនិងវាយតម្លៃនៃលេខាធិការដ្ឋានគ.ជ.អ.ប ។វិធីសាស្ត្រវាយតម្លៃដែលក្រុមការងារបានប្រើរួមមានៈ ការពិភាក្សាក្រុម ការសម្ភាសស៊ីជម្រៅ ការចុះមូលដ្ឋាន ការសង្កេតផ្ទាល់និង ការផ្ទៀងផ្ទាត់ឯកសារអនុកិច្ចសន្យា របាយការណ៍ រីកចម្រើន និងឯកសារពាក់ពន្ធ័ផ្សេងៗទៀត ។

**លទ្ធផល/ការរកឃើញ**

- ☞ មន្ទីរការងារមានធនធាននិងការតាំងចិត្តគ្រប់គ្រាន់ក្នុងការអនុវត្តអនុកិច្ចសន្យាទៅតាមលក្ខខណ្ឌនៃកិច្ចសន្យា
- ☞ សកម្មភាព និងលទ្ធផលរបស់អនុកិច្ចសន្យាត្រូវបានផ្តល់ដល់ក្រុមគោលដៅតាមការគ្រោង ទាន់ពេលវេលា និងមានគុណភាព ( កាត់ដេរ បណ្តុះផ្សិត និង ការផលិតនិងប្រើប្រាស់ជី IM )
- ☞ សិក្ខាកាមភាគច្រើនបានបញ្ចប់វគ្គបណ្តុះបណ្តាលរបស់ខ្លួនប្រកបដោយជោគជ័យនិងទទួលបានចំណើងបច្ចេកទេសជំនាញដើម្បី ប្រកបរបរចិញ្ចឹមជីវិត ។

រាល់សកម្មភាពនិងលទ្ធផលគ្រោងទុករបស់អនុកិច្ចសន្យាត្រូវបានអនុវត្តតែទោះបីយ៉ាងណាក៏ដោយការសំរេចគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា " ធ្វើអោយប្រជាពលរដ្ឋមានមុខជំនាញច្បាស់លាស់សំរាប់ប្រកបមុខរបរចិញ្ចឹមជីវិត និងផ្សព្វផ្សាយ ជំនាញបន្តដល់សហគមន៏ " និងអត្ថប្រយោជន៏ដែលទទួលបានពីការអនុវត្តអនុកិច្ចនៅមានកំរិតនៅឡើយ ។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប បានផ្តល់ថវិកាតាមរយៈ គ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និងគម្រោងដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈជាប្រព័ន្ធមិនបានអនុវត្តទេកាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើន។ នៅក្នុងឆ្នាំ ២០១០ ជាមួយនឹងការគាំទ្រផ្នែកថវិកា និងបច្ចេកទេសពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យាគ.ប្រនៃគ.អ.ជ.ខការវាយតម្លៃអនុកិច្ចសន្យា 06/SOC/0902-00 "បង្កើនការបណ្តុះបណ្តាលរដ្ឋបាល និងវិជ្ជាជីវៈ" របស់មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានរៀបចំឡើងដោយក្រុមវាយតំម្លៃរបស់ គ.ប្រ នៃ គ.អ.ជ.ខ។ ខាងក្រោមនេះគឺជា របាយការណ៍សង្ខេបពី ដំណើរការ លទ្ធផលដែលបានរកឃើញ និងការសន្និដ្ឋាននៃការវាយតម្លៃ ។

## ១.២. គោលបំណងអនុកិច្ចសន្យា

**គោលបំណងអនុកិច្ចសន្យាគឺ:** ធ្វើអោយប្រជាពលរដ្ឋមានមុខជំនាញច្បាស់លាស់សំរាប់ប្រកបមុខរបរចិញ្ចឹមជីវិត និងផ្សព្វផ្សាយ ជំនាញបន្តដល់សហគមន៏ ដើម្បី បង្កើនប្រាក់ចំណូលក្នុងគ្រួសារ ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

- កត់ត្រា និងវិភាគសមិទ្ធផលនៃអនុកិច្ចសន្យា និងចំនុចខ្សោយធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យារួមទាំងកត់ត្រានូវចំណុចរៀនសូត្រនិងលើកជាសំនើរគំនិតដើម្បីកែលំអការអនុវត្ត អនុកិច្ចសន្យា និង
- ដើម្បីពង្រឹងរបៀប ធ្វើការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត ។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

វិធីសាស្ត្រ និងឧបករណ៍ដែលប្រើៈ

- ☞ ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ និងរបាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍វគ្គបណ្តុះបណ្តាលនិងរាល់ឯកសារដែលពាក់ព័ន្ធដែលមាននៅក្នុងផ្នែករដ្ឋបាលនិងគ្រប់គ្រង កិច្ចសន្យានៃ គ.ប្រនិងភ្នាក់ងារអនុវត្តន៍។
- ☞ ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗរួមមានៈ អ្នករៀបចំនិងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផលផ្ទាល់ និងមិនផ្ទាល់ និងអ្នកពាក់ព័ន្ធ។
- ☞ ចុះពិនិត្យតំបន់អនុវត្តន៍គម្រោងនិងសង្កេតមើលសកម្មភាពពិភាក្សាក្រុមនិងករណីសិក្សា។
- ☞ ចុះពិនិត្យតំបន់អនុវត្តន៍គម្រោងហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់។
- ☞ <u>វិភាគទិន្នន័យ និងបកស្រាយៈ</u> ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ ត្រូវបានធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់
- ☞ <u>ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញនិងអនុសាសន៍</u>ដោយភ្នាក់ងារអនុវត្តន៍និងអ្នកពាក់ព័ន្ធតាមរយៈព័ត៌មានត្រឡប់ ដែលទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើងនៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១០។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើង ដោយ គ.ប្រ និងអ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយ ក្រុមវាយតម្លៃ បានយកចិត្តទុកដាក់ជាខ្ពស់ដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត។

២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត : វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោង នៅពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញនិងបទពិសោធន៍ពីមុនមក ។ទោះបីជាយ៉ាងណាក៏ដោយគោលបំណងសំខាន់ គឺដើម្បី "រៀនធ្វើដោយការអនុវត្តផ្ទាល់"។ អ្នកវាយតម្លៃបានទទួលការគាំទ្រ ដោយមានគោលការណ៍ការណែនាំ ឧបករណ៍ និងវគ្គបណ្តុះបណ្តាល ដែលពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។

៣) បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យាៈ ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់" លើការរីកចម្រើន និងជោគជ័យទេ ។ មួយទៀតទំនាក់ទំនងសង្ខេបតាមបែបតក្កភាព រវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ។

៤) ដោយយើងមិនមានសូចនាករបឋមយើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍" ដែលជាកម្រិតអត្ថប្រយោជន៍ទៅលើគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។

៥) ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃ លទ្ធផលនិងផលប្រយោជន៏ដែលទទួលបានក្រោយវគ្គបណ្តុះបណ្តាលអោយបានលម្អិតតាមរយៈការចុះជួបផ្ទាល់អ្នកទទួលផលផ្ទាល់អោយបានច្រើន។ យើងអាចវាយតម្លៃតែទៅលើលទ្ធផលសំរេចបាននិងផលប្រយោជន៏ដែលទទួលបានពីការអនុវត្តអនុកិច្ចសន្យាតាមរយៈការសម្ភាសន៏ ស៊ីជម្រៅអ្នកទទួលផល ២-៣ នាក់ ក្រុមពិភាក្សា និងការចុះពិនិត្យតំបន់អនុវត្តគម្រោង (២-៣កន្លែង) តែប៉ុណ្ណេះ។

៦) ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាមិនអាចធ្វើទៅបានទេ ព្រោះចំណុច គ នៃផ្នែកទី៣ ក្នុងឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ ឬមិនពេញលេញ។ ការងារនេះនឹងកាន់តែមានសុពលភាព និងពោរពេញទៅដោយព័តិមានបើសិនជាចំនុចដែលបានរៀបរាប់ខាងលើនេះត្រូវបាន ដោះស្រាយ។

# ២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី១)

**លទ្ធផលទី១:កសិករបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ការបណ្តុះផ្សិត**

**ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ**

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១ | -វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈការបណ្តុះផ្សិត អំបោះ និងផ្សិតចំបើងមួយវគ្គ | -វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ការបណ្តុះផ្សិត អំបោះ និងផ្សិត ចំបើងមួយវគ្គ |
| | -មួយវគ្គ ៣០ ថ្ងៃ | -មួយវគ្គ ៣០ ថ្ងៃ |
| | -អ្នកចូលរួម ៣០ នាក់ | -អ្នកចូលរួម ៣០ នាក់/ស្រី៨នាក់ |
| | | -អ្នកក្រីក្រ២០នាក់/សិស្សបោះបង់សាលា៨នាក់ /មេម៉ាយ កំព្រា២នាក់ |

**ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល**

ការអនុវត្តអនុកិច្ចសន្យានេះ សម្រេចបាននូវលទ្ធផល និងសកម្មភាពនានារបស់ដែលមានគ្រោងក្នុងកិច្ចសន្យា។ អ្នកចូលរួមទាំងអស់នៅក្នុងក្រុមពិភាក្សាបានបញ្ជាក់ថាពួកគេ បានទទួលនូវចំណេះដឹង និងជំនាញបណ្តុះបណ្តាល ហើយបានរៀនធ្វើផ្ទាល់ប្រកបដោយជោគជ័យ ជាក់ស្តែងនៅពេលនេះគាត់នៅចាំនៅឡើយ ។ សិក្ខាកាម ភាគច្រើន ចូលចិត្ត វិធីសាស្ត្របង្រៀន ការយកចិត្តទុកដាក់ និងលើកទឹកចិត្តរបស់គ្រូបណ្តុះបណ្តាល។ វិធីសាស្ត្រផ្សេងៗ ជាច្រើន ត្រូវបានប្រើប្រាស់នៅក្នុងវគ្គបណ្តុះ បណ្តាលរួមមានបំផុសគំនិត រូបភាព ការធ្វើបង្ហាញផ្ទាល់... ។ល ។អ្នកបណ្តុះបណ្តាលមានជំនាញសំរបសំរួល និងមានទំនាក់ ទំនងល្អជាមួយសិក្ខាកាមជំរុញអោយមានការចែករំលែកចំណេះដឹងកាន់តែប្រសើរឡើង។ វគ្គបណ្តុះបណ្តាលនេះឆ្លើយតបទៅ នឹងតំរូវការជាអទិភាពរបស់សហគមន៍-ឃុំ-សង្កាត់ ដែលបានស្នើឡើងនៅក្នុង សិក្ខាសាលាសមាហរណកម្ម ផែនការថ្នាក់ស្រុក។ ការបង្កើតឱកាសការងារ និងចំនូលបន្ថែមក្នុងគ្រួសារពិតជាអាចចូលរួមចំណែកក្នុងការធ្វើអោយប្រសើរឡើង ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋក្រីក្រ ស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

## លទ្ធផលទី២:. កសិករបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈជាជាងកាត់ដេរ

## ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយ អំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ២ | វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជាជាងកាត់ដេរ ២វគ្គ | វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជាជាងកាត់ដេរ ២វគ្គ |
| | -រយៈពេល ៤ខែ | -រយៈពេល ៤ខែ |
| | -អ្នកចូលរួម ៤០ នាក់ | -អ្នកចូលរួម ៤០ នាក់ ក្នុងនោះស្រី៣៧ នាក់ |
| | | -អ្នកក្រីក្រ២៣នាក់ កំព្រា៥នាក់ សិស្សបោះបង់សាលា ១២នាក់ ។ |

## ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

ជារួមការបណ្តុះបណ្តាលវិជ្ជាជីវៈជាជាងកាត់ដេរត្រូវបានអនុវត្តប្រកបដោយជោគជ័យ ។ អ្នកទទួលផលក្នុងក្រុមពិភាក្សាបានបង្ហាញពីការពេញចិត្តរបស់គេចំពោះគ្រូ និងរាល់ការរៀបចំរបស់មជ្ឈមណ្ឌលក្នុងរយះពេលបណ្តុះបណ្តាល និងក្រោយពេលបណ្តុះបណ្តាល ។ ខាងក្រោមនេះគឺជាចំនុចខ្លាំងរបស់គំរោងៈ

- ☞ អាត្រាបញ្ចប់វគ្គបណ្តុះបណ្តាលមានកំរិតខ្ពស់
- ☞ អាត្រារកបានការងារធ្វើបន្ទាប់ពីបញ្ចប់វគ្គមានកំរិតខ្ពស់ ។គ្រប់អ្នកចូលរួមពិភាក្សាទាំងអស់សុទ្ធតែមានការងារធ្វើដោយប្រើប្រាស់ជំនាញដែលបានរៀនដោយទទួលប្រាក់ចំនូល ចន្លោះពី ៤០-៦០ ដុល្លារ ហើយបានអោយតំលៃខ្ពស់ចំពោះ ផលប្រយោជន៏នៃវគ្គនេះចំពោះខ្លួនគេផ្ទាល់ និងសហគមន៏ ។
- ☞ ក្មេងស្រីជាច្រើនត្រូវបានជ្រើសរើស ដើម្បីចូលរួមវគ្គបណ្តុះបណ្តាល ។ ក្មេងស្រីទាំងនេះ ជាពិសេសក្មេងស្រីក្នុងគ្រួសារ ក្រីក្រត្រូវបានផ្តល់ឳកាសក្នុងការទទួលបានការងារសមរម្យ ដើម្បីជៀសវាងការងារ ដែលអាចមានគ្រោះថ្នាក់មួយចំនួនដូចជាៈអ្នកឡង់សេស្រាបៀរ អ្នកទទួលភ្ញៀវក្នុងហាងខារ៉ាអូខេ និងក្នុងរង្គសាល ។
- ☞ តាមរយៈការផ្តល់ឳកាសការងារដល់យុវវ័យគម្រោងបានចូលរួមចំណែកក្នុងការសំរាលបន្ទុកក្នុងគ្រួសារពីសមាជិកដែលអាចផ្គត់ផ្គង់គ្រួសារគេតាមរយៈបៀវត្សរបស់គេ ។
- ☞ យុវវ័យដែលទទួលបានការបណ្តុះបណ្តាលមានការអោយតំលៃលើខ្លួនឯងនិងមានមោទនភាពជាងមុន ដោយសារគេមានចំណេះដឹងជំនាញអាចរកចំនូលដោយខ្លួនឯងបាន ។

**លទ្ធផលទី៣: វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីវិធីផលិត និងប្រើប្រាស់ជី ធម្មជាតិ**

**ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ**

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយ អំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ៣ | -វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីវិធីផលិត និងប្រើប្រាស់ ជី ធម្មជាតិ EM ១ វគ្គ | -វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីវិធីផលិត និងប្រើប្រាស់ជី ធម្មជាតិ EM ១ វគ្គ |
| | -រយៈពេល ១ខែ | -រយៈពេល ១ខែ |
| | -អ្នកចូលរួម ១៥១ នាក់ | -អ្នកចូលរួម ១៥១ នាក់ ក្នុងនោះស្រី៤៥ នាក់ |
| | | -អ្នកក្រីក្រ១០៥នាក់ កំព្រា១១នាក់ មេម៉ាយ២២នាក់ ជនពិការចំនួន៣នាក់ ។សិស្សបោះបង់សាលាចំនួន ២២នាក់ |

**ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល ធៀបនឹងគោលបំនងបន្ទាន់ (ផលប៉ះពាល់/លទ្ធផលបឋម រយៈពេលខ្លី/មធ្យមនៃលទ្ធផល) នៃអនុកិច្ចសន្យា**

ការបើកវគ្គបណ្តុះបណ្តាលស្តីពីវិធីផលិត និងប្រើប្រាស់ ជី ធម្មជាតិ EM ដំណើរប្រកបដោយជោគជ័យតាមការគ្រោងទុក។ គុណភាពនៃការបណ្តុះបណ្តាល អាចទទួលយកបាន គ្រូមានបទពិសោធន៍ និង ជំនាញច្បាស់លាស់ក្នុងការផ្ទេរចំណេះដឹង ហើយមានការយកចិត្តទុកដាក់ក្នុងរយះពេលបណ្តុះបណ្តាល ។អ្នកចូលរួមបណ្តុះបណ្តាល ក្រោយពីបញ្ចប់វគ្គ មានចំណេះដឹងគ្រប់គ្រាន់ក្នុងការផលិតនិងប្រើប្រាស់ជី EM ។ ទោះបីជាគ្មានទិន្នន័យច្បាស់លាស់ក៏ដោយ ការយកចំណេះដឹង ដែលទទួលបានពី វគ្គនេះមកប្រើប្រាស់ដើម្បីជាប្រយោជន៍ ក្នុងគ្រួសារក៏ដូចជាការងារកសិកម្មនៅមានកំរិតទាបនៅឡើយ ដោយគោលបំណង របស់អ្នកចូលរួមវគ្គភាគច្រើនគឺត្រឹមតែដើម្បីទទួលបានចំណេះដឹង ដើម្បីប្រើប្រាស់ក្នុងពេលវេលាដែលចាំបាច់ ។

## ២.២. ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម (សំណួរវាយតម្លៃទី ៣)

### ផ្នែកកៈ ការវាយតម្លៃការសម្រេចបានរបស់ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា

| ស្ថានភាពនៅពេលបញ្ចប់កិច្ចសន្យា | លទ្ធផលប្រសើរឡើងជាក់ស្តែងនៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| ☞វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ការបណ្តុះផ្សិតអំបោះ និងផ្សិត ចំបើង មួយវគ្គ រយៈពេល ៣០ថ្ងៃ ដែលមានអ្នកទទួលផល សរុបចំនួន ៣០ នាក់ | ☞វគ្គបណ្តុះបណ្តាលត្រូវបានរៀបចំនិងបញ្ចប់ដោយជោគជ័យ ដោយមានសិស្សសរុប ៣០ នាក់ ស្រី ៨នាក់ ទោះបីជាមានសិស្ស៨នាក់ បានបោះបង់វគ្គក៏ដោយ ។ ជារួមសិស្ស ដែលទទួលបានការបណ្តុះបណ្តាលមានជំនាញគ្រប់គ្រាន់ ក្នុងការបណ្តុះផ្សិតអំបោះ និងផ្សិតចំបើង តែការប្រើប្រាស់ជំនាញនេះដើម្បីរកចំនូលបន្ថែមក្នុងគ្រួសារនៅមានកំរិត នៅឡើយ ។ |
| ☞វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ជាជាងកាត់ដេរ ២វគ្គ រយៈពេល ៤ ខែ ដែលមានអ្នកទទួលផលសរុបចំនួន ៤០ នាក់ | ☞វគ្គបណ្តុះបណ្តាលត្រូវបានរៀបចំនិងបញ្ចប់ដោយជោគជ័យ ដោយមានសិស្សសរុប ៤០ នាក់ ស្រី ៣៧នាក់ ទោះបីជាមានសិស្ស១២នាក់ បានបោះបង់វគ្គក៏ដោយ ។ ជារួមសិស្សដែលទទួលជំនាញកាត់ដេរតែពុំទាន់គ្រប់គ្រាន់ដើម្បីបង្កើតរបរនៅឡើយដោយការបណ្តុះបណ្តាលមាន រយៈពេលខ្លី ។ |
| ☞វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីវិធីផលិត និងប្រើប្រាស់ជីធម្មជាតិ EM ១ វគ្គ រយៈពេល១ខែ អ្នកចូលរួម ១៥១ នាក់ ។ | ☞វគ្គបណ្តុះបណ្តាលត្រូវបានរៀបចំនិងបញ្ចប់ដោយជោគជ័យ អ្នកចូលរួមវគ្គភាគច្រើនបានប្រើប្រាសជំនាញដែលបាន រៀនតាមរយៈការបង្កើតកន្លែងដោយខ្លួនឯង និង ធ្វើការអោយហាងអ្នកដទៃដើម្បីរកចំនូល ដោយមានសិស្សសរុប ១៥១ នាក់ ស្រី ៤៥នាក់ ទោះបីជា មានសិស្ស២២នាក់ បានបោះបង់វគ្គក៏ដោយ ។ការប្រើប្រាស់ ជំនាញដែលទទួលបាននៅមានកំរិតទាបនៅឡើយ ។ |

## ផ្នែក-ខ: ការសម្រេចបានទូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា

| ធាតុនៃទិសដៅបន្ទាន់ (១) | ការសម្រេចបាន/លទ្ធផលជាក់ស្តែង នៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| ធ្វើអោយប្រជាពលរដ្ឋមានមុខជំនាញច្បាស់លាស់សំរាប់ប្រកបមុខរបរចិញ្ចឹមជីវិតនិងផ្សព្វផ្សាយជំនាញបន្តដល់សហគមន៍ដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសារ។ | ពេលចប់វគ្គបណ្តុះបណ្តាលជាកសិករភាគច្រើនបានយកចំណេះដឹងទៅធ្វើតាមផ្ទះដើម្បីបង្ហាញស្នាដៃនិងផលិតបានជោគជ័យរកចំណូលបានសមស្រប។ ជាការជាក់ស្តែងសិក្ខាកាមដែលជាអ្នកមានគ្រួសារនិងកំពុងមានតួនាទីជាមេគ្រួសារ ចាប់ផ្តើមយកអាជីពជាអ្នកបណ្តុះផ្សិត ដាំដំណាំរួមផ្សំ និងចិញ្ចឹមសត្វ បង្កើតជីអ៊ីអឹមប្រើប្រាស់ ។សិក្ខាកាមជាសិស្សសាលាហើយនៅលីវនិងខ្លះជាមន្ត្រីស៊ីវិលដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងជីអ៊ីអឹមភាគច្រើនពុំបានយកទៅអនុវត្តន៍ទេដោយសារ ការខ្វះធនធានក្នុងគ្រួសារ និងមានជីវភាពខ្វះខាតពួកគេគ្រាន់តែធ្វើខ្លួនឯងនៅតាមផ្ទះនិងខ្លះទៀតត្រូវបោះបង់ចោល ។នេះស្តែងអោយឃើញថាសិក្ខាកាមទាំងនោះពួកគេរៀនដើម្បីចង់ទុកអនុវត្តន៍ ថ្ងៃក្រោយឬយកទៅ បង្រៀនកូនក្មួយ គេប៉ុណ្ណោះ ។ |

## ផ្នែក-គ: សង្ខេបការវាយតម្លៃ "លទ្ធផល" និង "ផលប្រយោជន៍" ដែលអាចបំលែងជាបរិមាណអាចវាស់វែងបាន និងអាចមើលឃើញ:

អ្នកចូលរួមក្នុងក្រុមពិភាក្សា និងអ្នកទទួលផលចុះជួបផ្ទាល់ បានបង្ហាញថាពួកគាត់មានការពេញចិត្តចំពោះការអនុវត្តអនុកិច្ចសន្យានេះ ព្រោះថា គាត់បានទទួលនូវចំណេះដឹងជំនាញដែលអាចយកទៅប្រើប្រាស់ជាប្រយោជន៍នៅក្នុងគ្រួសារ និង បង្កើនប្រាក់ចំណូលជាពិសេសជំនាញកាត់ដេរទោះបីជារយៈពេលនៃវគ្គខ្លីបន្តិចក៏ដោយ។ យុវវ័យដែលបានចូលរួមវគ្គជំនាញ កាត់ដេរបានអះអាងថាបើគ្មានអនុកិច្ចសន្យានេះ ម្លេះពួកគេពិតជាគ្មានលទ្ធភាពក្នុងការទទួលបានជំនាញនេះទេ ព្រោះគ្រួសារ ពុំមានលទ្ធភាពបង់ប្រាក់ឈ្នួលបង្រៀននៅកន្លែងឯកជន។

# ករណីសិក្សា

## ករណីសិក្សាទី១: អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគំរោងបណ្តុះបណ្តាល ( លោក ញឹម វិចិត្រ)

ក្រោយពីបានចូលរៀនវគ្គបណ្តុះបណ្តាលពីវិធីផលិតនិងការប្រើប្រាស់ជីសរីរាង្គនោះមក និងដោយសារបាន យកចិត្តទុកដាក់អាន សៀវភៅមេរៀន មើលហើយមើលទៀតជាច្រើនលើកជាច្រើនសាររហូតធ្វើអោយ ខ្ញុំកាន់តែយល់ច្បាស់ពីបច្ចេកទេសចំណេះ ជំនាញធ្វើនិងប្រើប្រាស់ បានជោគជ័យដល់សព្វថ្ងៃ។ នេះជាសំដីរបស់ប្អូនប្រុស ញឹម វិចិត្រ ហៅហុក អាយុ២៨ឆ្នាំ មានកូនស្រី មួយនាក់ហើយសព្វថ្ងៃកំពុងប្រកបមុខរបរកសិកម្មដាំដុះដំណាំនិងចិញ្ចឹមសត្វ។ គាត់បានកៀងគរបងប្អូនមកពីភ្នំពេញ អោយមកនៅជាមួយក្នុងកសិដ្ឋានរបស់គាត់ដែលមានទីកដីធំទូលាយរបស់ឪពុកម្តាយរបស់គាត់ ដែលឪពុកលោក បានចាប់យកកាន់កាប់គាស់កាយរុករាន ហែកដីធ្វើស្រែចំការតាំងពឆ្នាំ១៩៧២ នៅក្នុងភូមិអូរក្រូច ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ចំងាយពី ទីរួមខេត្តកំពង់ធំប្រមាណ ៤៩គ.ម។

លោក ញឹម វិចិត្រ ជាអ្នកប្រើប្រាស់ជីក្នុងការដាំដុះ និងចិញ្ចឹមសត្វមកដល់សព្វថ្ងៃ។ គួបផ្សំដោយឪពុកម្តាយ របស់លោកមានដីធំទូលាយស្រាប់ផង និងដោយមានការជួយគាំទ្រ ពីបងប្អូននៅភ្នំពេញ ពីក្រុមហ៊ុនCP និងក្រុមហ៊ុនពណ៌បៃតងផងនោះប្អូន ប្រុស វិចិត្រ បានសំរេចចិត្តបង្កើត តម្លើងរោងកិនចំណីសត្វបានមួយ ដោយចាប់ផ្តើមពង្រីកមុខរបរលើការបណ្តុះកូនឈើហូបផ្លែ និង ដំណាំផ្សេង ការចិញ្ចឹមជ្រូក មាន់ ទា ។ តាមការបានសំភាសន៍ជាមួយលោកផ្ទាល់ទើបបានដឹងថា នៅក្នុងគ្រួសាររបស់ប្អូនប្រុស គ្មានពេលទំនេទេ គឺសមាជិកទាំង៩នាក់រវល់ទាំងអស់គ្នារាល់ៗថ្ងៃតាមមុខរបរផ្សេងៗគ្នាអ្នកខ្លះ មើលរោងម៉ាស៊ីនកិនចំណី សត្វ អ្នកខ្លះថែទាំជ្រូក អ្នកខ្លះមើលមាន់ តាំងពីកន្លែងភ្ញាស់រហូតដល់កន្លែងកូនមាន់ តូច ធំ និង ប្រមូលពងយកទៅលក់។ កំរៃ ដែលបានពីការលក់សត្វ លក់ដំណាំដាំដុះ រួមផ្សំផ្សេងៗគឺយកប្រាក់នោះទៅបង្វិលទិញឈើ ទិញដែក និងទិញសំភារៈផ្សេងៗ យកមកពង្រីកទ្រុងជ្រូក ទ្រុងមាន់ ប្រក់ស្បៃពណ៌បៃតង កែច្នៃទ្រុងមាន់មេពូជចិញ្ចឹមមិនលែងក្រៅទ្រុង ។ ជាពិសេសរៀបចំកែ ច្នៃទ្រុងជ្រូក អោយមានអនាម័យល្អស្អាតនិងទ្រុងសត្វផ្សេងៗ ត្រូវកែច្នៃអោយមានអនាម័យទាំងអស់ដើម្បីមានជា ទីកន្លែងពេញចិត្ត ស្រឡាញ់ ចង់តែរស់នៅជាមួយមុខរបរនេះរហូតជានិច្ចជាកាល។ ការដែលចិញ្ចឹមបានល្អ និងដំណាំដាំដុះទទួលផលបានល្អប្រសើរ ទាំងអស់នេះដោយសារ ចេះប្រើប្រាស់ជី បានត្រឹមត្រូវ ដោយសារប្អូនបានចូលរួមវគ្គរៀបចំឡើងដោយមន្ទីរការងារខេត្ត។

ប្អូន ញឹម វិចិត្រ បានបញ្ជាក់ថា ប្អូនធ្លាប់មានជំងឺគ្រុនពោះវៀន ហើយក្រោយមកបានប្រើទឹក EM ជាថ្នាំព្យាបាល ហើយដូចបានធូរស្រាលច្រើនរហូតមក។ អ្នកស្រុក ភូមិអូរក្រូចទាំងមូលតែងភ្ញាក់ផ្អើលចង់រៀនចង់ធ្វើតាមប្អូន ហើយបច្ចុប្បន្ននេះប្អូនបានជួយបណ្តុះបណ្តាលនូវចំណេះដឹង នោះដល់អ្នកភូមិផងរបងជាមួយគ្នា ដែលពួកគាត់មានចំណង់ចំណូលចិត្តចង់ចេះចង់ដឹងធ្វើមែន ។

## ករណីសិក្សាទី២: អ្នកមិនទទួលផលជី EM

កញ្ញាស្រី គួន ចាន់សី អាយុ ២៩ឆ្នាំ គាត់មានគ្រួសារ និង មានកូន ៤នាក់ មានកូនប្រុស ២ ស្រី ២ រស់នៅក្នុងភូមិអូរក្រូច ប្តីមាន មុខរបបជាពិសេសចូលព្រៃរកអនុផលព្រៃឈើ បន្ទាប់ពីធ្វើស្រែរួច តែគាត់ធ្វើនំ អាកោ នំ ក្រូច លក់ នៅមុខផ្ទះដែលជាប់ និងថ្នល់ជាតិ កំពង់ធំ-ព្រះវិហារ។ លោកមេភូមិបានប្រាប់ខ្ញុំថា គេមករកចុះឈ្មោះខ្ញុំអោយទៅរៀនធ្វើជី EM បណ្តុះផ្សិតដែរ តែពេលនោះខ្ញុំរវល់ទៅរកគ្រាក់ជាមួយប្តីខ្ញុំព្រោះទៅរកគ្រាក់បើដើររក ៥ -៦ យប់ទើបមកផ្ទះវិញ។ ដូចនេះគ្រួសារនេះមិនបានទៅចូលរៀនវគ្គ EM និង ផ្សិត និងគេដែលមានទីតាំងនៅខេត្តកំពង់ធំនោះទេ។ កញ្ញាស្រី គួន ចាន់សី ដែលពេលនេះប្តីគាត់រវល់ទៅរកគ្រាក់ គាត់នៅផ្ទះជាមួយ កូន៤នាក់ និងម្តាយក្មេកបានមានសម្តីថាគាត់ បានឃើញគ្រួសារប្អូន ញឹម វិចិត្រ ធ្វើដំណាំ និងចិញ្ចឹមសត្វ ដោយប្រើប្រាស់ជី EM ពួកគេចិញ្ចឹមសត្វដាំដំណាំ បានលក់ដោតជ័យណាស់ គួរតែរៀនសូត្រពីពួកគាត់។ កញ្ញាស្រី គួន ចាន់សី បានប្រាប់ថាគាត់ឧស្សាហ៍ទៅសាកសួរ និងសុំទិញចំណីសត្វពីប្អូន ញឹម វិចិត្រ ដែរ។ កញ្ញាស្រី ក៏បានបញ្ជាក់ផងដែរថា មុខរបរ របស់ ប្អូន ញឹម វិចិត្រ ចិញ្ចឹមមនុស្សមួយគ្រួសារធំអោយមានការងារធ្វើ ដោយ មិនបាច់ទៅដើរស៊ីឈ្នួលគេ ឬ ដើរចំណាកស្រុកឡើយ ។ទីបញ្ចប់ កញ្ញាស្រី សី បានសំណូមពរសុំអោយលោក មេភូមិជួយកុំខាន អោយសោះ បើពេលណាអង្គការមានការបើកគ្គបណ្តុះបណាលលើជំនាញ ចំណេះ និង វិជ្ជាជីវៈណាមួយក៏ដោយ គាត់សុំទៅរៀន នឹងគេផង នៅខេត្តក៏ទៅដែរ ។

**ករណីសិក្សាទី ៣: អ្នកទទួលផលពីការបណ្តុះផ្សិត ភូមិកំពង់ធំ កំពង់រទេះ ក្រុងស្ទឹងសែន**

អ្នកស្រី ហែម តាំងសួន អាយុ ៣៥ឆ្នាំ មានកូន៤នាក់ប្រុស ២ ស្រី ២ រស់នៅក្នុងភូមិកំពង់ធំ សង្កាត់កំពង់រទេះជាភូមិជាប់ជាយក្រុងស្ទឹងសែន។ អ្នកស្រីរៀនសូត្រមានចំណេះដឹងត្រឹមថ្នាក់ទី៧ សម័យរដ្ឋកម្ពុជាស្មើនឹងថ្នាក់ទី ១០ សម័យឆ្នាំ ២000។ ស្វាមីរបស់អ្នកស្រីប្រកបមុខរបរជាជាងសំណង់ ហើយជួយបិតស្រា និងចិញ្ចឹមជ្រូកលក់ ។

អ្នកស្រីបានចូលរៀនវគ្គបណ្តុះបណ្តាលពីការបណ្តុះផ្សិត នៅក្នុងមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ នៃមន្ទីរការងារខេត្ត អ្នកស្រីទទួលបានចំណេះដឹងមធ្យមពីការបណ្តុះផ្សិតអំបោះ ហើយក៏ចាប់ផ្តើមយកជំនាញបណ្តុះផ្សិតអំបោះនេះ ធ្វើជាអាជីពប្រចាំគ្រួសារបានចំណាយពេលវេលាយ៉ាងច្រើន និងថវិកាមួយចំនួនសមស្រប រៀបចំរោងបណ្តុះផ្សិត ចង្ក្រានចំហុយ អាចម៍រណា។ អ្នកស្រីបានត្អូញត្អែរថា ឆ្នាំដំបូងធ្វើពុំបានជោគជ័យទេ ផ្សិតចេះតែខូច កើតជំងឺតែរហូតអ្នកស្រីចង់និយាយថាអ្វីដែលអ្នកស្រីចង់ បានផលប្រយោជន៍ពីការបណ្តុះផ្សិតនោះ ទៅជាមិនបានតាមសេចក្តីប្រាថ្នាឡើយ តែអ្នកស្រី មិនអស់ចិត្តហើយការមិនបោះបង់ ចោលដែរ នៅតែខំតស៊ូធ្វើបន្តទៀតតាមលទ្ធភាព។ ម្យ៉ាងទៀតប្តីរបស់អ្នកស្រី តែងចិញ្ចឹមចិត្តគាំទ្រការបណ្តុះផ្សិតនេះជានិច្ច ដោយចូលរួមធ្វើសព្វកិច្ចការទាំងអស់ជាមួយអ្នកស្រី ក្នុងជំហរជឿជាក់ថា និងធ្វើបានជោគជ័យមិនខាន ។

ឥឡូវនេះឆ្នាំ ទី២ ហើយការបណ្តុះផ្សិតរបស់អ្នកស្រីទទួលបានប្រាក់ចំនេញជាច្រើនពីការផលិតផ្សិត និង យកទៅលក់នៅទីផ្សារចំងាយ១គម។ ផ្សិតអំបោះលក់បាន ពី ៤000 ទៅ ៥000រៀល ក្នុងមួយ គ.ក្រ តែបើបោះដុំ ១ គ.ក្រ បាន តែ ៣៥00 រៀល ហើយលក់ដាច់ជាងគេនៅរដូវបុណ្យភ្ជុំបិណ្ឌ និង រដូវបុណ្យការចាប់ពីខែ ១២ ដល់ ខែ ៥ ។ **លោកស្រីមានមោទនៈភាពណាស់ ព្រោះពេលកន្លងមកមាន សិក្ខាកាមជាអ្នកសិក្សាស្រាវជ្រាវ ក្នុងអង្គការផ្សេងៗ តែងបានចុះ មកធ្វើសំភាសន៍ជាមួយគ្រួសារ គាត់ពី ការបណ្តុះផ្សិតនេះ ដូចពេលនេះ បានជួបសំណេះសំណាលជាមួយពួកយើងនេះដែរ។** គ្រួសាររបស់អ្នកស្រីក៏ចាប់ផ្តើម មានទំនាក់ទំនង នឹងសង្គមខាងក្រៅ ដោយមានការចាប់អារម្មណ៍ពីអ្នកខាងក្រៅនេះហើយពូតផ្តុំបានជាផល ផ្តល់កំលាំងចិត្តដល់ គ្រួសាររបស់អ្នកស្រី អោយតាំងចិត្តខិតខំបន្តមុខរបរ បណ្តុះផ្សិតនេះជាអាជីពក្នុងគ្រួសារទៅ ។

## ករណីសិក្សា ទី ៤ : អ្នកមិនបានទទួលផលពីការបណ្តុះផ្សិតអំបោះ

អ្នកស្រី អ៊ីម ចាន់ថន អាយុ៣៥ឆ្នាំ ធ្វើប៉ូលិសទាំងប្តីទាំងប្រពន្ធ ។ គាត់មានកូន២នាក់ (ប្រុស ១ ស្រី ១)ក្រៅពីការងារស្នូលនៅការិយាល័យប៉ូលីសប្អូនប្រុស ប្អូនស្រីប្តីប្រពន្ធទាំងពីរនាក់នេះតែងប្រឹងប្រែងបង្កបង្កើនផលដំណាំបន្លែបង្កា និងធ្វើដំណាំ រួមផ្សំនៅក្នុងផ្ទះរបស់ខ្លួន ដោះដូរលក់ចាយវាយផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ។

អ្នកទាំងពីរមិនបានទៅចូលរៀនវគ្គបណ្តុះបណ្តាលផ្សិត នឹងគេទេ ដោយរវល់ទៅធ្វើការបាត់ពីផ្ទះជាប់ការងារជាប៉ូលីសនៅក្នុងខេត្ត។ នៅពេលមើលឃើញគ្រួសារអ្នកស្រី ហែម កាំងសួន ដែលមានផ្ទះស្ថិតនៅមិនឆ្ងាយប៉ុន្មានពីផ្ទះខ្លួន ហើយដែលកំពុងរស់នៅក្នុងរបត់ផ្លូវមួយ ចាប់យករបរបណ្តុះផ្សិតអំបោះលក់ ធ្វើជាមុខរបបអាជីព ទទួលបានជោគជ័យ ហើយជាមុខរបរ ធ្វើក្នុងផ្ទះ។ អ្នកស្រីចង់បានដូចគាត់ ចង់ធ្វើតាមគ្រួសារដូចលោកស្រី ហែម កាំងសួន ណាស់ តែស្តាយ គ្មានលទ្ធភាព និងមិនដឹងទៅទាក់ទង ជាមួយអ្នកណា។ អ្នកស្រីតែងទៅពិភាក្សានិយាយការងារលេងជាមួយអ្នកស្រី ហែម កាំងសួន ដែលកំពុងធ្វើការបណ្តុះផ្សិត និងកំពុងលក់ផ្សិតចេញ បានរាល់ថ្ងៃ។ អ្នកស្រីបានសំណូមពរថាបើកាលណាមានការបើកវគ្គបណ្តុះបណ្តាលពីជំនាញវិជ្ជាជីវៈ ណាមួយ ក៏ដោយ អោយតែជាជំនាញ ចំណេះដឹងផ្នែកបច្ចេកទេសកសិកម្ម អ្នកស្រីចូលចិត្តណាស់ ហើយបើមានបើកវគ្គបណ្តុះផ្សិតម្តងទៀត គាត់នឹងសុំចូលរៀន ប្តីគាត់ក៏បាន ខ្លួនគាត់ក៏បាន ។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤)

ផ្នែក-ក: ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅនឹងតំរូវការ: មន្ទីរវិស័យ មូលដ្ឋាន គ.ជ.អ.ប និងការកាត់បន្ថយភាព ក្រីក្រ:

| ល.រ (១) | ធាតុ (២) | ទំនាក់ទំនង តក្កភាព (៣) | បរិយាយ ច្បាស់លាស់ (៤) | សង្ខេបការវាយតម្លៃ (៥) |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៤ | ៤ | សកម្មភាពដែលបានលើកឡើង ពិតជាមាន ទំនាក់ទំនងតក្ក ជាមួយនឹងលទ្ធផលដែលបាន សរសេរនៅក្នុងឯកសារអនុកិច្ចសន្យា ព្រោះថា សកម្មភាពសំខាន់ទាំង៣ ពិតចូលរួមចំណែកក្នុងការសំរេចបាននូវលទ្ធផល ។ហើយសកម្មភាពទាំងអស់សុទ្ធតែបានកំណត់ ចំនួនវគ្គ និងអ្នកចូលរួម។ |
| ២ | លទ្ធផល | ៤ | ៤ | លទ្ធផលបានសរសេរបរិយាយច្បាស់លាស់ ដោយមានសូចនាករជាក់លាក់និងអាចវាស់វែងបាន ។លទ្ធផលទាំងនេះនៅមិនអាចធ្វើអោយគោលបំណងបន្ទាន់សម្រេចបាននៅឡើយ ព្រោះទំហំនៃការអនុវត្តនៅមានកំរិតនៅឡើយ ដោយអាស្រ័យទៅនឹងថវិកាដែលមាន។ |
| ៣ | អត្ថប្រយោជន៏រយះពេលខ្លីះ (លទ្ធផល/ផលប្រយោជន៏) - គោលបំនងបន្ទាន់ -ស្ថានភាពចុងបញ្ចប់ អនុកិច្ចសន្យា | ៤ | ៣ | គោលបំណងបន្ទាន់មានភាពពាក់ពន្ធ័នឹង លទ្ធផល និង មានអត្ថន័យច្បាស់លាស់អាចទទួល យកបាន ប៉ុន្តែគោលបំណងបន្ទាន់នេះ មានកំរិតខ្ពស់ និងទូលាយនៅឡើយ។ គួរតែ សរសេរដោយផ្តោតលើគោលការណ៏ SMART |
| ៤ | លទ្ធផលអភិវឌ្ឍន៏/ផលប៉ះពាល់រយះពេលវែងៈគោលដៅ និងគោលបំនងអភិវឌ្ឍន៏ | | | មិនអាចធ្វើការវាយតម្លៃបាន |

## ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារ:

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.ជ.អ.ខ:** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | នៅមានកំរិត ទាមទារការយកចិត្តដាក់បន្ថែម ជាពិសេសនៅផ្នែក យុត្តិកម្មអនុកិច្ចសន្យា។ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យការអនុវត្តន៏របស់ភ្នាក់ងារអនុវត្តន៏ | មានការគាំទ្រ និងសហការណ៏ល្អ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារអនុកិច្ចសន្យា | ល្អបង្គួរទាមទារការពង្រឹងបន្ថែម |
| **ពីខាងភាគីអនុវត្តន៏កិច្ចសន្យា:** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | ជាទូទៅមន្ទីរមានធនធាននិងការតាំងចិត្តគ្រប់គ្រាន់ក្នុងការអនុវត្ត |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និងលទ្ធផល | ការអនុវត្តសកមភាពនិងលទ្ធផល ទាន់ពេលវេលា ដូចដែលបានព្រាងទុក |
| ៦ | ការរាយការណ៏ការរីកចំរើន និងការកត់ត្រាឯកសារ | ជាប្រចាំនិងទាន់ពេលវេលាតាមការកំណត់របស់ គ. ប្រ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | លក្ខខណ្ឌ័ក្នុងកិច្ចសន្យាត្រូវបានបំពេញ |
| **ទាំងខាង គ.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យា:** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" និងបញ្ហាប្រឈម | ការទំលាក់ថវិកាយឺតជាងការគ្រោងទុកនាំអោយមានការយឺតយ៉ាវបន្តិចក្នុងការអនុវត្ត តែពុំមានផលប៉ះពាល់ខ្លាំងព្រោះសកម្មភាពទាំងអស់របស់អនុកិច្ចសន្យាពុំមែនជាសកម្មភាពប្រកាន់រដូវកាល។ |

| | | |
|---|---|---|
| ៩ | ការបញ្ជ្រាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | មានការលើកកំពស់យេនឌ័រ ជាពិសេសផ្ដល់ឱកាស អោយស្រីក្នុងការទទួលបាន ចំណេះដឹងជំនាញ ។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ | ពុំមានភាពពាក់ពន្ធ័ដោយផ្ទាល់ ។ |
| ១១ | ការថែរក្សា (និរន្តភាព) | និរន្តភាពរបស់គម្រោងផ្សិតអាស្រ័យលើការតាំងចិត្ត របស់អ្នកទទួលផល និងទីផ្សារ ។អ្នកចូលរួមបណ្ដុះបណ្ដាល ភាគតិចប៉ុណ្ណោះដែលបានប្រើចំណេះដឹងដែលបានទទួល ពីវគ្គផ្សិត និង EM ទោះបីជាមន្ទីរនៅតែបន្តគាំទ្រ លើផ្នែកស្មារតី និងបច្ចេកទេស និង ឥណទាន ក៏ដោយ ។ |

## ២.៤. សេចក្ដីសន្និដ្ឋាន

### សេចក្ដីសន្និដ្ឋានជារួម :

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | រាល់សកម្មភាព និងលទ្ធផលគ្រោងទុករបស់អនុកិច្ចសន្យាត្រូវបានអនុវត្តតែទោះបីយ៉ាងណាក៏ដោយការសំរេច គោលបំណងបន្ទាន់របស់អនុកិច្ចសន្យាៈ "ធ្វើអោយប្រជាពលរដ្ឋមានមុខជំនាញច្បាស់លាស់សំរាប់ប្រកបមុខរបរ ចិញ្ចឹម ជីវិតនិង ផ្សព្វផ្សាយ ជំនាញបន្តដល់សហគមន៍" និងអត្ថប្រយោជន៍ដែលទទួលបានពីការ អនុវត្ត អនុកិច្ចសន្យា នៅមានកំរិត នៅឡើយ ។ |

### ចំណុចរៀនសូត្រ

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ការទទួលបានការងារនិងការបង្កើតមុខរបរបន្ទាប់ពីទទួលបានបណ្ដុះបណ្ដាលអាស្រ័យជាចំបងលើការតាំងចិត្តរបស់ ដូច្នោះការជ្រើសរើសអ្នកទទួលផល និងការទទួលបានពត៌មានពីឱកាសការងារ បានត្រឹមត្រូវគឺជាកត្តាសំខាន់ ។ |

### អនុសាសន៍

| ល.រ | អនុសាសន៍ |
|---|---|
| ១ | ការជ្រើសរើសអ្នកទទួលផលអោយបានត្រឹមត្រូវដោយមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់បើអាចធ្វើទៅបានគ្រួសារ ងាយទទួលរងគ្រោះគួរតែត្រូវបានពិចារណាក្នុងការជ្រើសរើស (គួរជៀសវាងជ្រើសរើសសិស្សដែលកំពុងសិក្សា) |

| | |
|---|---|
| ២ | គួរធ្វើ TNA ដើម្បីកំណត់តម្រូវការវគ្គអោយបានច្បាស់លាស់ជាមុន |
| ៣ | ចំពោះគម្រោងកាត់ដេររយៈពេលបណ្តុះបណ្តាលគួរតែល្មមគ្រប់គ្រាន់នឹងអាចធ្វើអោយសិក្ខាកាមមានជំនាញគ្រប់គ្រាន់អាចបើកមុខរបរក្នុងលក្ខណះប្រកួតប្រជែងបាន។ |

# ឯកសារភ្ជាប់ទី១:

## បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ

| ល.រ | ឈ្មោះឯកសារ/របាយការណ៍ | ទំព័រ |
|---|---|---|
| ១ | កិច្ចសន្យាសង្ខេប | ៣ ទំព័រ |
| ២ | តារាងកាលវិភាគអនុវត្តន៍របស់កិច្ចសន្យា | ២ ទំព័រ |
| ៣ | ថវិការលំអិត និងកាលវិភាគទូរទាត់ | ២ ទំព័រ |
| ៤ | ផ្នែកទី ២ ល័ក្ខខ័ណ្ឌនៃកិច្ចសន្យា | ៥ ទំព័រ |
| ៥ | ផ្នែកទី ៣ ការពិពណ៌នាកិច្ចសន្យា | ៤ ទំព័រ |
| ៦ | របាយការណ៍ស្តីពីការតាមដាន និងវាយតម្លៃអនុកិច្ចសន្យា | ២៣ ទំព័រ |
| ៧ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | ៥ ទំព័រ |

# ឯកសារដែលត្រូវភ្ជាប់ទី៧:

បញ្ជីឈ្មោះអ្នកផ្ដល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាសន៍/ជួបពិភាក្សា

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៍ប្រើសម្រាប់ប្រមូលទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | កញ្ញា | លោក ខុង សោភ័ណ ទីប្រឹក្សា M&E | គ/ប្រ | សម្ភាសន៏ស៊ីជម្រៅ |
| ២ | កញ្ញា | លោក អៀង សុភាព ប្រធានមន្ទីរការងារខេត្ត | មន្ទីរការងារ | សម្ភាសន៏ស៊ីជម្រៅ |
| ៣ | កញ្ញា | ក្រុមអ្នកទទួលផល (ពីការបណ្ដុះផ្សិត) | មណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត | សម្ភាសជាក្រុម |
| ៤ | កញ្ញា | អ្នកទទួលផល (លោក ញឹម វិចិត្រ) | ភូមិ អូរគ្រួច ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៥ | កញ្ញា | អ្នកស្រី គួន ចាន់សី អ្នកមិនទទួលផល | ភូមិ អូរគ្រួច ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៦ | កញ្ញា | អ្នកទទួលផល (អ្នកស្រី ហែម កាំងសួន) | ភូមិ កំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៧ | កញ្ញា | អ្នកស្រី អ៊ីម ចាន់ថន អ្នកមិនទទួលផល | ភូមិ កំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៨ | កញ្ញា | កញ្ញា លី សុជាតា អ្នកទទួលផល | ភូមិ ត្រពាំងឫស្សី ឃុំត្រពាំងឫស្សីស្រុកកំពង់ស្វាយ | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៩ | កញ្ញា | កញ្ញា ឆេង សាវ៉ាត អ្នកមិនទទួលផល | ភូមិ ត្រពាំងឫស្សី ឃុំត្រពាំងឫស្សីស្រុកកំពង់ស្វាយ | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |

គជអប
NCDD

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | **07/AGR/0901-00 (GOV)** |
| ចំណងជើង : | កម្មវិធីអភិវឌ្ឍន៏កសិកម្មចំរុះ |
| ភ្នាក់ងារអនុវត្តន៏ : | មន្ទីរកសិកម្មខេត្តកំពត |
| រយៈពេល ( ចាប់ផ្តើម និងបញ្ចប់) | 01/01/2009 – 31/12/2009 |
| រាជធានី ខេត្ត | កំពត |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរកសិកម្មខេត្តកំពត |
| ចំនួនថវិកាស្នើសុំពី  គ.អ.ជ.ខ | US$ 18,620.00 |
| សរុបថវិកាចូលរួមរបស់ភ្នាក់ងារអនុវត្តន៏ | US$ 1200.00 |
| សរុបថវិកាចូលរួមដោយសហគមន៏ | US$ 6600.00 |
| សរុបថវិកាពីប្រភពឬអ្នកផ្តល់ជំនួយដទៃទៀត | US$ 0.00 |
| **សរុបរួមថវិកាក្នុងកិច្ចសន្យា ( ១+២+៣+៤)** | US$ 26,420.00 |

## ក្រុមវាយតម្លៃ   និងរៀបចំរបាយការណ៏

| ឈ្មោះ | មុខតំណែងដើម | តួនាទីក្នុងក្រុមវាយតម្លៃ |
|---|---|---|
| លោក  អ៊ុំ យូឡាយ | អនុប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា និង រដ្ឋបាលនៃគ.ប្រ | សំភាសន៏ |
| លោក  ឡេន ឌឿន | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ  នៃគ.ប្រ | កត់ត្រា |
| លោក  ខឹម ប៉ុណ្ណា | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ  មន្ទីរកសិកម្ម | អង្កេតការណ៏ |
| លោក  ហ៊ី វិចិត្រ | ទីប្រឹក្សាត្រួតពិនិត្យ និងវាយតម្លៃ នៃគ.ប្រ | ទីប្រឹក្សាគាំទ្រគម្រោង |

## ខេត្តកំពត

## ថ្ងៃទី ១៨-២១ ខែ តុលា  ឆ្នាំ ២០១០

# មាតិកា


| | | |
|---|---|---|
| | **អក្សរកាត់** | ៣ |
| | **របាយការណ៍សង្ខេប** | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | ៧ |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៧ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៧ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៧ |
| ១.៤ | សំណួរវាយតម្លៃ | ៨ |
| ១.៥ | វិធីសាស្រ្ត សម្ភារៈ និងដំណើរការវាយតម្លៃ | ៨ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ៨ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១០** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១) | ១០ |
| | - លទ្ធផលទី១ | ១០ |
| | - លទ្ធផលទី២ | ១២ |
| | - លទ្ធផលទី៣ | ១៣ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម (សំណួរវាយតម្លៃទី៣) | ១៤ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤) | ១៩ |
| **២.៤** | **សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី៥)** | **២២** |
| **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍** | | **២៤** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ២៤ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍/ពិភាក្សា | ២៥ |
| **ករណីសិក្សា** | | **១៧** |
| ករណីសិក្សាទី១: | | ១៧ |
| ករណីសិក្សាទី២: | | ១៨ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាងគ.អ.ជ.ខ និងមន្ទីរវិស័យ( ថវិកា PSDD) |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

**គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ :**

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃផ្នែកគ្រប់គ្រង់កិច្ចសន្យានៃគ.ប្រ សហការណ៍ជាមួយមន្ត្រីត្រួតពិនិត្យ និងវាយតម្លៃមន្ទីរ កសិកម្មខេត្ត និងទីប្រឹក្សាត្រួតពិនិត្យវាយតម្លៃ បានធ្វើការវាយតម្លៃអនុកិច្ចសន្យា ដែលមានចំណងជើងថា កម្មវិធីអភិវឌ្ឍន៍កសិកម្មចំរុះ លេខអនុកិច្ចសន្យា 07/AGR/0901-00 (GOV) ដែលជាអនុកិច្ចសន្យារវាងគ.អ.ជ.ខ ខេត្តកំពត និងមន្ទីរកសិកម្មខេត្ត។ ដំណើរ ការនេះជាផ្នែកមួយនៃគម្រោងពង្រឹងសមត្ថភាពគ្រូបង្គោលនៅថ្នាក់ក្រោមជាតិរបស់ផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយ គោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែលគាំទ្រដោយគម្រោងគាំទ្រកម្មវិធី អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យតាម រយៈវិមជ្ឈការ និងវិសហមជ្ឈការ។

- **ការវាយតម្លៃនេះក្នុងគោលបំណង** កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធិផលនៃអនុកិច្ចសន្យា និងចំនុចខ្លាំង ចំនុចខ្សោយធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា ព្រមទាំងកត់ត្រានូវចំណុចរៀនសូត្រ និង បទពិសោធន៍ និងផ្នែកនានា ដែលត្រូវធ្វើឱ្យប្រសើរឡើងនាពេលអនាគត ហើយក៏ពង្រឹងរបៀបធ្វើការវាយតម្លៃ គម្រោងរបស់គ.ប្រ នៃគ.អ.ជ.ខ។ ដំណើរការវាយតម្លៃបានអនុវត្តតាមការណែនាំ និងឧបករណ៍ស្តីពីការវាយតម្លៃអនុវត្តកិច្ចសន្យារបស់គ.ប្រនៃគ.អ.ជ.ខ ដែលរៀបចំដោយផ្នែកត្រួតពិនិត្យនិងវាយតម្លៃ នៃលេខាធិការដ្ឋានគ.ជ.អ.ប។ ក្រោយពីទទួលការណែនាំមន្ត្រីត្រួតពិនិត្យ និងវាយតម្លៃនៃគ.ប្រ បានសម្របសម្រួលឱ្យមានការបង្កើតក្រុមការងារវាយធ្វើការប្រជុំពិនិត្យឯកសារពាក់ព័ន្ធ ជ្រើសរើសគម្រោងដែលត្រូវធ្វើការវាយតម្លៃ និងជ្រើសរើសក្រុមគោលដៅត្រូវសម្ភាសន៍។ ដោយសារថវិកា និងពេលពេលវេលាមានកំណត់ក្រុមការងារវាយតម្លៃ ធ្វើការវាយតម្លៃស៊ីជម្រៅតែលើគម្រោងចិញ្ចឹមមាន់ និងគម្រោងជីកំប៉ុស្តិ៍ ហើយក្រុមការងារបានប្រមូលទិន្នន័យ តាមរយៈ ការពិភាក្សាក្រុម ការសម្ភាសន៍ស៊ីជម្រៅ ការសង្កេតផ្ទាល់ និងគម្រោងផ្សេងៗទៀតត្រូវបានវាយតម្លៃដោយផ្អែកលើឯកសារដែលមានស្រាប់ដូចជាឯកសារអនុកិច្ចសន្យា របាយការណ៍រីកចំរើនប្រចាំឆ្នាំ របាយការណ៍បញ្ចប់អនុកិច្ចសន្យា របាយការណ៍វគ្គបណ្តុះបណ្តាល និងឯកសារផ្សេងទៀត។ ដូច្នេះការវាយតម្លៃនេះមិនមែនជាការវាយតម្លៃស៊ីជម្រៅទៅលើអនុកិច្ចសន្យាទាំងមូលនោះទេ ហើយការសន្និដ្ឋានត្រូវធ្វើឡើងទៅតាមអ្វីដែលរកឃើញ។

**ឆ្លើយទៅនឹងសំណួរទាំង៥នៃការវាយតម្លៃ :**

១-សកម្មភាពបានអនុវត្ត និងលទ្ធផលសម្រេចបាន

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣:ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសំរេចបានជាក់ស្តែង |
|---|---|---|
| **លទ្ធផលទី១: កសិករបានទទួលការបណ្តុះបណ្តាលពី បច្ចេកទេសផ្សព្វផ្សាយក្សេត្រសាស្ត្រ និងការបង្ហាញ** | | |
| ១ | បណ្តុះបណ្តាលស្តីពីការប្រើប្រាស់ថ្នាំពុលធម្មជាតិលើដំណាំ (៤វគ្គ=១២០នាក់) | កសិករចូលរួមចំនួន១២០នាក់/ស្ត្រី ២៨នាក់ |
| ២ | បណ្តុះបណ្តាលស្តីពីការធ្វើជីកំប៉ុស្ត (១០វគ្គ=២៥០នាក់) | កសិករចូលរួមចំនួន២៥០នាក់/ស្ត្រី៨៧នាក់ |
| ៣ | បណ្តុះបណ្តាលបច្ចេកទេសដាំដំណាំបន្លែ (២ថ្ងៃក្នុង១វគ្គ ៤វគ្គ= ១២០នាក់) | កសិករចូលរួមចំនួន១២០នាក់/ស្ត្រី៣៨នាក់ |
| **លទ្ធផលទី២:** ការបណ្តុះបណ្តាលកសិករពីបច្ចេកទេស ផ្សព្វផ្សាយអំពីការចិញ្ចឹមត្រី និងការបង្ហាញ | | |
| ១ | បណ្តុះបណ្តាលស្តីពីការចិញ្ចឹមត្រី (៤វគ្គ=១២០នាក់) ៣ថ្ងៃ/វគ្គ | កសិករចូលរួម១២០នាក់/ស្ត្រី ២៨នាក់ |
| **លទ្ធផលទី៣:ការបណ្តុះបណ្តាលកសិករពីបច្ចេកទេស ផ្សព្វផ្សាយសុខភាពសត្វ ផលិតកម្ម និងការបង្ហាញ** | | |
| ១ | បណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់ (៦វគ្គ=១៥០នាក់) ៣ថ្ងៃ/វគ្គ | អ្នកចូលរួមចំនួន ១៥០នាក់/ស្ត្រី ៩៥នាក់ |

២- វគ្គបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមមាន់ និងការធ្វើបង្ហាញ មានប្រសិទ្ធភាព ព្រោះក្រោយពីកសិករមានការយល់ដឹង ពីបច្ចេកទេសនេះពួកគាត់បានអនុវត្ត ហើយទទួលបានលទ្ធផល ប្រសើរដោយជួយសំរាលនូវបន្ទុកចំណាយក្នុងគ្រួសារ។ ចំពោះ វគ្គបណ្តុះបណ្តាលបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ និងការបង្ហាញ វាមានក៏ប្រសិទ្ធភាពដែរដោយសារ កសិករភាគច្រើនមានយល់ដឹងពីសារ សំខាន់ នឹងឱ្យតំលៃលើ ជីកំប៉ុស្តិ៍ ហើយនៅតាមផ្ទះគាត់ច្រើនមាន រោងកំប៉ុស្តិ៍ កសិករប្រើពាក្យថា" ភូមិស្អាត ស្រែល្អ" ។

៣- លទ្ធផលបន្ទាន់ និងផលប្រយោជន៏ នៃវគ្គចិញ្ចឹមមាន់ និងកំប៉ុស្តិ៍នេះ កសិករមានការយល់ដឹង បានអនុវត្ត និងផ្លាស់ ប្តូរឥរិយាបទ មួយខុសពីមុន។ ដូចក្នុងករណីការចិញ្ចឹមាន់ កសិករមានទ្រុង ធ្វើអនាម័យទ្រុងមាន់ មានមាន់សម្រាប់ធ្វើម្ហូប និងមានចំណូលពីការលក់មាន់  ចំពោះគម្រោងជីកំប៉ុស្តិ៍ កសិករភាគច្រើនដែលបាន ចូលរួមវគ្គបណ្តុះបណ្តាល បានប្រើប្រាស់ជីកំប៉ុស្តិ៍ សម្រាប់ស្រែ និងដំណាំបានតិចតួច។ ដោយឡែកគម្រោងផ្សេងទៀតដែលមាននៅក្នុងអនុកិច្ចសន្យា ពិនិត្យជារួមដោយផ្អែក លើលទ្ធផលនៃរបាយការណ៏ប្រចាំឆ្នាំ របាយការណ៏

វគ្គបណ្តុះបណ្តាល និងការចុះត្រួតពិនិត្យនៅមូលដ្ឋានអាចវាយតម្លៃថាការ រៀបចំអនុកិច្ចសន្យា និងការអនុវត្តមានប្រសិទ្ធភាព។

៤- ជារួមអនុកិច្ចសន្យាសំរេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាបានដែលបានរំពឹងទុក។

៥- អនុកិច្ចសន្យានេះពិតជាមានការពាក់ព័ន្ធ ប្រសិទ្ធភាព និងប្រសិទ្ធផល សមស្របតាមធនធាន ដែលបានវិភាជន៍សម្រាប់ ប្រតិបត្តិការ ការគ្រប់គ្រងទូទៅ និងអនុវត្តសកម្មភាព ដែលបានគ្រោង នៅក្នុង អនុកិច្ចសន្យា។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏នៅមាន ចំណុចដែលគួរកែលម្អ ខ្លះៗចំពោះគុណភាព នៃការ រៀបចំអនុកិច្ចសន្យាដូចខាងក្រោម:

- ធ្វើការបរិយាយអំពីគោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់របស់អនុកិច្ចសន្យា នៅក្នុងផ្នែកទី**III** ឱ្យបានច្បាស់ លាស់ និង អាចវាស់វែងបានដើម្បីសម្រួលដល់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។
- កំណត់សូចនាករជោគជ័យ/អាចសម្រេចបានធៀបនឹងទិន្នន័យមូលដ្ឋានឬរៀបចំឱ្យមានក្របខ័ណ្ឌការងារត្រួតពិនិត្យ និង វាយតម្លៃ។

ភ្ជាប់ទំនាក់ទំនងឱ្យបានជាក់លាក់រវាងលទ្ធផលជាមួយគោលបំណងបន្ទាន់ និងគោលបំណងកម្រិតខ្ពស់។

**សេចក្តីសន្និដ្ឋាន :**

១- លទ្ធផល និងអត្ថប្រយោជន៍ដែលបានពីការអនុវត្តអនុកិច្ចសន្យា ពិតជាបានឆ្លើយតបនូវតំរូវការរបស់សហគមន៍ដោយមាន ភស្តុតាងបង្ហាញច្បាស់លាស់ហើយត្រូវបានទទួលការសារទរពីអ្នកទទួលផលនៅក្នុងភូមិ ឃុំគោលដៅនៃគម្រោង។ ឧទាហរណ៏ គម្រោងចិញ្ចឹមមាន់ កសិករទទួលបានបច្ចេកទេសការចិញ្ចឹមមាន់បានសម្រាប់ម្ហូប និងបានចំណូល ពីការលក់មាន់។ ចំពោះគម្រោង ជីកំប៉ុស្តិ៍ កសិករភាគច្រើនដែលបានចូលរួម វគ្គបណ្តុះបណ្តាលបានប្រើប្រាស់កាកសំណល់ធ្វើជីកំប៉ុស្តិ៍សម្រាប់ស្រែ ដើម្បីកែប្រែ គុណភាពដី កាត់បន្ថយការចំណាយទិញ ជីគីមី និងទិន្នផលស្រូវ កើនជាងមុន។

២- ពាក់ព័ន្ធលើដំណើរការជ្រើសរើសកសិករចូលរួមសកម្មភាពគម្រោងឃើញថា មិនបានល្អត្រឹមត្រូវ និងចំគោលដៅគំរោង ព្រោះមន្ត្រីគម្រោងបានប្រគល់ការ ងារនេះឱ្យទៅមេភូមិជាអ្នកចាត់ចែងក្នុងការជ្រើសរើស។

៣- គួរមានគាំទ្រគម្រោងបែបនេះ ក៏ដូចជាការពង្រីកសកម្មភាពគម្រោងរបៀបនេះបន្តទៀត តែគួរត្រូវពង្រឹងបន្ថែមលើដំណើរ ការជ្រើសរើសក្រុមគោលដៅ វិសាស្ត្របង្រៀន និងការចុះតាមដានដើម្បីការទ្រកសិករទទួលផលក្នុងការអនុវត្តបច្ចេកទេសថ្មី។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្តល់ថវិកាតាមរយៈ គ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និងគម្រោងដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ នៅក្នុងឆ្នាំ២០១០ នេះដោយមានការគាំទ្រទាំងថវិកា និងបច្ចេកទេសពីផ្នែកត្រួតពិនិត្យវាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប ផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់គ.ប្រនៃគ.អ.ជ.ខ បានអនុវត្តការវាយតម្លៃអនុកិច្ចសន្យា ដែលបានរៀបចំរួមគ្នាជាមួយមន្ទីរកសិកម្មខេត្តដែលជាភ្នាក់ងារអនុវត្តន៍អនុកិច្ចសន្យាលេខៈ 07/AGR/0901-00 (GOV) ស្តីពីកម្មវិធីអភិវឌ្ឍន៍កសិកម្មចំរុះ។ លទ្ធផលដែលបានរកឃើញ និងការសន្និដ្ឋាននៃការវាយតម្លៃត្រូវបានកត់ត្រា ហើយនឹងបង្ហាញតាមរយៈរបាយការណ៍ស្តីពីការវាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

កិច្ចសន្យានេះត្រូវបានរៀបចំដើម្បីគាំទ្រដល់មន្ទីរកសិកម្មខេត្តក្នុងការអនុវត្តរាល់សកម្មភាពអភិវឌ្ឍន៍វិស័យកសិកម្ម ធ្វើយ៉ាងណាឱ្យប្រជាកសិករយល់ដឹងពីបច្ចេកទេសកសិកម្ម លើដំណាំស្រូវ ការចិញ្ចឹមមាន់ ត្រីការធ្វើជីកំប៉ុស្តិ ក្នុងន័យថាជំរុញឱ្យផលិតផលកសិកម្មរបស់កសិករបានទទួលនូវបរិមាណច្រើន និងគុណភាពល្អ ធានាការហូបចុកពេញមួយឆ្នាំ និងអាចប្រកួតប្រជែងលើទីផ្សារ។ គោលដៅនេះនឹងរួមចំណែកដល់ទិសដៅ របស់កម្មវិធីជាតិគឺស្ថាប័នពាក់ព័ន្ធគ្រប់ថ្នាក់ត្រូវបានពង្រឹង ការអនុវត្តប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការប្រកបដោយប្រសិទ្ធិភាព។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

**គោលបំណង** គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូលដោយមន្ត្រីផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់គ.ប្រនៃគ.អ.ជ.ខ សហការជាមួយមន្ត្រីបង្គោលតាមដានត្រួតពិនិត្យរបស់មន្ទីរកសិកម្ម ដើម្បីឱ្យមានការវាយតម្លៃតាមបែបចូលរួម និងធានាឱ្យមានតម្លាភាព។ ដូច្នេះទំហំនៃការវាយតម្លៃមានដែនកំណត់តាមទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាដែលពាក់ព័ន្ធដូច មានចែងក្នុងក្របខណ្ឌការងារនៃការវាយតម្លៃ។គោលបំណងនៃការវាយតម្លៃគឺៈ **ក**)កត់ត្រា និងវិភាគ ជាប្រព័ន្ធទៅលើសមិទ្ធិផលនៃអនុកិច្ចសន្យា និងចំណុចខ្លាំងខ្សោយធៀបទៅ នឹងលទ្ធផលគោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យារួមទាំងកត់ត្រានូវចំណុចរៀនសូត្រ និងមេរៀនដែលត្រូវធ្វើឱ្យប្រសើរ ឡើងនៅពេលអនាគត និង**ខ**)ដើម្បីពង្រឹងរបៀបធ្វើការវាយតម្លៃគម្រោងរបស់គ.ប្រ

នៃគ.អ.ជ.ខនៅក្នុង ដំណើរការនៃការអនុវត្តគម្រោងផ្សេងៗទៀត។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រសម្ភារៈ និងដំណើរការវាយតម្លៃ

**វិធីសាស្ត្រ និងឧបករណ៍ដែលបានប្រើៈ**

១) ការពិនិត្យឯកសារអនុកិច្ចសន្យា របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍បញ្ចប់កិច្ចសន្យារបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គ បណ្តុះបណ្តាលឡើងវិញ និងការចុះប្រមូលពិតមានទិន្នន័យពីអ្នកទទួលផលដល់មូលដ្ឋាន និង ទីតាំងគម្រោង។

២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗ រួមមានៈ អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា ទីប្រឹក្សា និងអ្នកទទួលផលផ្ទាល់ ចំនួន ៤0នាក់(៥ភូមិ)។

៣) ចុះពិនិត្យតំបន់អនុវត្តន៏គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់។

៤) <u>វិភាគទិន្នន័យ និងបកស្រាយៈ</u> ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ ត្រូវបានធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់។

៥) បានរៀបចំការប្រជុំនៅថ្ងៃទី ខែ ឆ្នាំ២០១០ ដើម្បីបង្ហាញនិងផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងផ្តល់អនុសាសន៏។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះត្រូវបានធ្វើឡើង ដោយក្រុមវាយតម្លៃដែលបានចាត់តាំងដោយគ.ប្រ និងមានការចូលរួម ពីអ្នកអនុវត្តផ្ទាល់ និងមានកិច្ចសហការណ៍ផ្តល់យោបល់ពីទីប្រឹក្សា ត្រួតពិនិត្យវាយតម្លៃ។ ទោះជាយ៉ាងណាក៏ដោយ

ការប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពរលូន លទ្ធផលអាចទទួលយកបាន។

២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិតៈ វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោង នៅពេលដែលអ្នកវាយតម្លៃមិនទាន់មានជំនាញច្បាស់លាស់ និងបទពិសោធន៏ពីមុនមក។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណងសំខាន់ គឺដើម្បីរៀនធ្វើដោយការអនុវត្តផ្ទាល់។ អ្នកវាយតម្លៃបានទទួលការគាំទ្រដោយមានគោលការណ៏ ការណែនាំឧបករណ៏ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។

៣) ដោយយើងមិនមានសូចនាករបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៏" ដែលជាកម្រិតអត្ថប្រយោជន៏ទៅលើគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និង កម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។

៤) ដោយពេលវេលាធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិតទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ។ យើងបានជ្រើសរើសតែលទ្ធផលចំនួន២ សម្រាប់ការចុះវាយតម្លៃនៅមូលដ្ឋានមកធ្វើការវាយតម្លៃតាមរយៈការសម្ភាសន៏ស៊ីជម្រៅក្រុមពិភាក្សា និងការចុះពិនិត្យផ្ទាល់តំបន់អនុវត្តគម្រោងៈ(លទ្ធផលទី១)កសិករបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសផ្សព្វផ្សាយក្សេត្រសាស្ត្រនិងការបង្ហាញៈសកម្មភាពបណ្តុះបណ្តាលស្តីពីការធ្វើជីកំប៉ុស្តិ៍(១០វគ្គ=២៥០នាក់)។(លទ្ធផលទី២)ការបណ្តុះបណ្តាលកសិករពីបច្ចេកទេសផ្សព្វផ្សាយសុខភាពសត្វផលិតកម្ម និងការបង្ហាញៈសកម្មភាពបណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់ (៦វគ្គ=១៥០នាក់) ៣ថ្ងៃ /វគ្គ។

**<u>ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធន៏ៈ</u>**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះអនុកិច្ចសន្យាលេខៈ 07/AGR/0901-00(GOV) និងដែនកំណត់ ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ។

២) ការវាយតម្លៃនេះលម្អិតតែទៅលើកសិករបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមមាន់ និងបណ្តុះបណ្តាលស្តីពីការធ្វើជីកំប៉ុស្តិ៍ ដែលជាសកម្មភាពនៃអនុកិច្ចសន្យា ។

៣) ការវាយតម្លៃនេះផ្តោតទៅលើភ្នាក់ងារអនុវត្ត និងអ្នកទទួលផលហើយមិនមែនជាការវាយតម្លៃទៅលើគ.ប្រ នៃ គ.អ.ជ.ខ និងគ.ជ.អ.ប ទេ។

ហេតុដូច្នេះរបាយការណ៏នៃការវាយតម្លៃលទ្ធផលដែលបានរកឃើញ និងអនុសាសន៏ដែលបានលើកឡើងត្រូវពិនិត្យដោយយោលទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ។

# ២.លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃៈ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១)

**លទ្ធផលទី១ : កសិករបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសផ្សព្វផ្សាយក្សេត្រសាស្ត្រ និងការបង្ហាញ**

**ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ**

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ១.១ | បណ្តុះបណ្តាលស្តីពីការប្រើប្រាស់ថ្នាំពុលធម្មជាតិលើដំណាំ (៤វគ្គ=១២០នាក់) | ៤វគ្គ មានកសិករចំនួន១២០នាក់/ស្ត្រី២៨នាក់ (៣ស្រុក ៤ឃុំ ៤ភូមិ) |
| ១.២ | បណ្តុះបណ្តាលស្តីពីការធ្វើជីកំប៉ុស្ត (១០វគ្គ=២៥០នាក់) | ១០វគ្គមានកសិករចំនួន២៥០នាក់/ស្ត្រី៤៧នាក់ (៣ស្រុក ១០ឃុំ ១០ភូមិ) |
| ១.៣ | បណ្តុះបណ្តាលបច្ចេកទេសដាំដំណាំបន្លែ (២ថ្ងៃក្នុង១វគ្គ ៤វគ្គ=១២០នាក់) | ៤វគ្គមានកសិករចំនួន១២០នាក់/ស្ត្រី៣៨នាក់ (៤ស្រុក ៤ឃុំ ៤ភូមិ) |

**ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល**

អនុកិច្ចសន្យានេះសម្រេចបាន១០០%ធៀបនឹងលទ្ធផល និងកម្មភាពក្នុងអនុកិច្ចសន្យាដែលបានគ្រោងទុក។ អ្នកចូលរួមទាំងអស់នៅក្នុងក្រុមពិភាក្សាដែលជាសិក្ខាកាមពីវគ្គបណ្តុះបណ្តាលបេច្ចេកទេសកំប៉ុស្តិ៍បានឱ្យដឹងថាពួកគេបានទទួលនូវចំណេះដឹង និងអនុវត្តជំនាញដែលទាក់ទងទៅនឹងបច្ចេកទេសធ្វើជីកំប៉ុស្តិ៍។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺពួកគាត់បានឱ្យតំលៃលើគុណភាពជីកំប៉ុស្តិ៍ ដោយគាត់ប្រើពាក្យថា"ភូមិស្អាត ស្រែល្អ" និងនៅផ្ទះភាគច្រើនមានរោងកំប៉ុស្តិ៍ ហើយទិន្នផលស្រូវកើនជាងមុន និងទទួលបានប្រាក់ចំណូលពីការលក់ស្រូវ។ សិក្ខាកាមភាគច្រើនពេញចិត្តនឹងការបង្រៀន ព្រោះគ្រូមានការយល់ដឹងច្រើនលើបច្ចេកទេសនេះ " អាចឆ្លើយនូវសំណួររបស់កសិករ " ការពន្យល់ ច្បាស់ល្អ អាកប្បកិរិយាសមរម្យ ពេលរៀនមានសំណួរបំផុសគំនិត ក្រុមពិភាក្សាប្រើរូបភាព...។ ទោះជាយ៉ាង នេះក៏ដោយ ក៏មានសិក្ខាកាមមួយចំនួនទៀតបានផ្តល់យោបល់ថា គួរតែបញ្ជូលនូវការអនុវត្តជាក់ស្តែងក្នុងកំឡុង ពេលបណ្តុះបណ្តាល ឧទាហរណ៍ បើនិយាយពីការធ្វើជីកំប៉ុស្តិ៍ សុំឱ្យមានវត្ថុធាតុទាំងនោះ សំរាប់ការអនុវត្តន៍ជាក់ស្តែង និងអាចឱ្យសិក្ខាកាមរកម្នាក់មួយមុខរួចធ្វើនៅពេលនោះតែម្តង។ ដោយឡែកឯកសារ មេរៀន

គួរបង្ហាញតាមរយៈ ការប្រើប្រាស់ផ្ទាំងរូបភាព ប្រសើរជាងសរសេរអក្សរច្រើន។

សរុបសេចក្តីមកការបើកវគ្គបណ្តុះបណ្តាលគឺមានភាពទាក់ទិនទៅនឹងតម្រូវការរបស់សិក្ខាកាម និងសហគមន៍ ព្រោះនៅក្នុងសហគមន៍ទាំងអស់សុទ្ធតែជាគ្រួសារដែលមានមុខរបរសំខាន់ធ្វើស្រែ ដាំបន្លែ។ ដូច្នេះវារួមចំណែកក្នុង ការកាត់បន្ថយការចំណាយបានមួយកំរិតនៅក្នុងមូលដ្ឋាន និងសហគមន៍ជាពិសេសទៀតនោះ អាចកែលំអរគុណភាព ដី និងធ្វើឱ្យប្រសើរឡើងនូវបរិស្ថាន។ ជារួមយើងឃើញថាអ្នកភូមិក៏ដូចជាក្នុងសហគមន៍ មានការយកចិត្តទុកដាក់ យ៉ាងខ្លាំងក្នុងការទទួលយកចំណេះដឹងទៅអនុវត្ត ដែលធ្វើឱ្យជីវភាពរបស់គាត់បានប្រសើរឡើងតាមរយៈការប្រើប្រាស់ ជីកំប៉ុស្តិ៍សម្រាប់ដាក់ស្រែដាំដំណាំ ធ្វើឱ្យមានការមានទិន្នផល កើនជាងមុនកាត់បន្ថយចំណាយ ផ្សេងៗ និងធ្វើឱ្យសុខភាព គ្រួសារពួកគាត់បានប្រសើរជាងមុន។

## លទ្ធផលទី២ : ការបណ្តុះបណ្តាលកសិករពីបច្ចេកទេស ផ្សព្វផ្សាយអំពីត្រី និងការបង្ហាញ

### ផ្នែក-ក :  ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ ។

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| **២.១** | បណ្តុះបណ្តាលស្តីពីការចិញ្ចឹមត្រី(៤វគ្គ=១២០នាក់) ៣ថ្ងៃ/វគ្គ | ៤វគ្គ មានកសិករ ចំនួន១២០នាក់/ស្ត្រី២៨នាក់ (២ស្រុក ៤ឃុំ ៤ភូមិ) |

### ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល

| |
|---|
| តាមការពិនិត្យលើរបាយការណ៍បញ្ចប់កិច្ចសន្យារបាយការណ៍ប្រចាំឆ្នាំអនុកិច្ចសន្យានេះ សម្រេចបាននូវលទ្ធផល និងសកម្មភាព១០០%ធៀបនឹងផែនការដែលបានគ្រោងទុក។ ការពិនិត្យឯកសារអនុកិច្ចសន្យា និងរបាយការណ៍រីកចំរើនប្រចាំឆ្នាំ យើងមិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះបានលំអិតទេ។ |

## លទ្ធផលទី៣ : ការបណ្តុះបណ្តាលកសិករពីបច្ចេកទេស ផ្សព្វផ្សាយសុខភាពសត្វ ផលិតកម្ម និងការបង្ហាញ

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ៣.១ | បណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់ (៦វគ្គ=១៥០នាក់)៣ថ្ងៃ/វគ្គ | ៦វគ្គ មានកសិករចំនួន១៥០នាក់/ស្ត្រី៩២នាក់(៤ស្រុក ៦ឃុំ ៦ភូមិ) |

## ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល

អនុកិច្ចសន្យានេះសម្រេចបាន១០០%ធៀបនឹងលទ្ធផល និងសកម្មភាពក្នុងអនុកិច្ចសន្យាដែលបានគ្រោងទុក អ្នកចូលរួមទាំងអស់នៅក្នុងក្រុមពិភាក្សាដែលជាសិក្ខាកាម ពីវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ បានឱ្យដឹងថាពួកគាត់បានទទួលនូវចំណេះដឹងថ្មី និងជំនាញដែលទាក់ទងទៅ នឹងបច្ចេកទេសចិញ្ចឹមមាន់។ សិក្ខាកាមភាគច្រើនពេញចិត្តនឹងវគ្គនេះ ហើយការបង្រៀនមានលក្ខណៈប្រសើរ គ្រូមានការយល់ដឹងច្រើនលើបច្ចេកទេសនេះ មានវិធីសាស្រ្តបង្រៀន ដោយមិនធ្វើឱ្យសិក្ខាធុញថប់ទេ ហើយការពន្យល់ច្បាស់ល្អ អាកប្បកិរិយាសមរម្យ ពេលរៀនមានសំណួរបំផុសគំនិត ក្រុមពិភាក្សា ប្រើរូបភាពច្រើន និងក្រោយពីបញ្ចប់វគ្គគ្រូបានចុះតាមដាន និងគាំទ្រលើដំណើរអនុវត្តរបស់កសិករ។ សរុបសេចក្តីមកការបើកវគ្គបណ្តុះបណ្តាលគឺមានការឆ្លើយតបនឹងតម្រូវការរបស់សិក្ខាកាម និងសហគមន៍ ព្រោះនៅក្នុងសហគមន៍ទាំងអស់សុទ្ធតែគ្រួសារប្រកបមុខរបរចិញ្ចឹមសត្វ បន្ថែមលើការធ្វើស្រែ ដាំបន្លែ។ ដូច្នេះគម្រោងនេះធ្វើឱ្យគ្រួសារគាត់ទទួលបាននូវផលប្រយោជន៍ដូចជា ការកាត់បន្ថយទិញម្ហូប មានប្រាក់ចំណូលបន្ថែមពីការលក់មាន់ សម្រាប់ដោះស្រាយបន្ទាន់ក្នុងគ្រួសារករណីខ្វះលុយកូនរៀន បុណ្យ-ការ ទិញ ថ្នាំពេទ្យ ...(គិតជាមធ្យម ៥០ម៉ឺន ទៅ៨០ម៉ឺន ក្នុងមួយឆ្នាំ)។ ហើយគម្រោងនេះធ្វើឱ្យកសិករមានជំនឿលើបច្ចេកទេសថ្មីដែលទទួលបានពីវគ្គធ្វើឱ្យគាត់មានការផ្លាស់ប្តូរឥរិយាបទ ដោយមានការយល់ដឹងថាគាត់មិនបរិភោគមាន់ងារដោយសារជម្ងឺទៀតទេ(ងាប់កប់ ឬដុតចោល)ជឿលើការប្រើប្រាស់វ៉ាក់សាំង មានទ្រុងមាន់ត្រឹមត្រូវ ផ្តល់ចំណីដែលខុសពីការចិញ្ចឹមតាមយថាហេតុ។ បើប្រៀបធៀបជារួមយើងវិភាគឃើញថាអ្នកភូមិ ក៏ដូចជាក្នុងសហគមន៍មានការយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការអនុវត្តន៏នូវបច្ចេកទេសថ្មីស្តីពីការចិញ្ចឹមមាន់ ធ្វើឱ្យផលិតកម្មមាន់ពួកគាត់កើនឡើង មិនងាប់ដូចមុនដែលធ្វើឱ្យជីវភាពរបស់ គាត់បានប្រសើរឡើងតាមរយៈការកើន ឡើងនៃប្រាក់ចំណូល និងធ្វើឱ្យ សុខភាពគ្រួសារពួកគាត់បានប្រសើរជាងមុន។

## ២.២ ការវាយតម្លៃលើការសំរេចបាននូវអត្ថប្រយោជន៍ភ្លាមៗ និងលទ្ធផលនៃអនុកិច្ចសន្យា

### ផ្នែកកៈ ការវាយតម្លៃការសំរេចបាននូវស្ថានភាពរំពឹងទុក នូវពេលបញ្ចប់អនុកិច្ចសន្យា

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា (១) | ស្ថានភាពជាក់ស្តែងនៅពេលបញ្ចប់អនុកិច្ចសន្យា (២) |
| --- | --- |
| បណ្តុះបណ្តាលស្តីពីការប្រើប្រាស់ថ្នាំពុលធម្មជាតិលើដំណាំ (៤វគ្គ=១២០នាក់) | -៤វគ្គ មានកសិករចំនួន១២០នាក់/ស្ត្រី២៨នាក់(៣ស្រុក ៤ឃុំ ៤ភូមិ) គ្រួសារបង្ហាញ ១២០គ្រួសារ ។ |
| បណ្តុះបណ្តាលស្តីពីការធ្វើជីកំប៉ុស្ត (១០វគ្គ=២៥០នាក់) | - ១០វគ្គមានកសិករចំនួន២៥០នាក់/ ស្ត្រី៤៧នាក់ (៣ស្រុក ១០ ឃុំ ១០ភូមិ) គ្រួសារបង្ហាញ ២៥០ គ្រួសារ ។<br>- វគ្គនេះបានផ្តល់សំភារៈដូចជា សៀវភៅបច្ចេកទេស រោងកំប៉ុស្តិ៍ ចំនួន ២៥០រោង ។<br>-អ្នកចូលរួមភាគច្រើននៅក្នុងការពិភាក្សាក្រុម បានរាយការណ៍ថា ពួកគាត់ពេញចិត្ត នឹងវគ្គបណ្តុះបណ្តាល និងការធ្វើបង្ហាញ ជីកំប៉ុស្តិ៍នេះ។ បន្ថែមពីលើនេះទៀត ពួកគាត់បញ្ជាក់ថា វគ្គនេះ ពិតជាឆ្លើយតប ទៅនឹងតម្រូវការរបស់ពួកគាត់ ក៏ដូចជាក្នុង សហគមន៍ដែរ។ ជាងនេះទៀតអ្នកចូលរួមក្រុមពិភាក្សាបាន លើកឡើងថា កាលដែលមិនទាន់ចូលរៀនវគ្គបណ្តុះបណ្តាល គាត់បាន ទិញ ជីគីមីដាក់ស្រែ៣បាវ/១ហិចតា (តម្លៃក្នុង ១បាវ ៩៥០០០រៀល តែគិតជារួមអស់ ២៨៥.០០០រៀល ។<br>- ក្រោយវគ្គបណ្តុះបណ្តាលពួកគាត់បាន ធ្វើការសន្សំជីកំប៉ុស្តិ៍ និងបានទិញជីគីមីដាក់ស្រែ (១បាវ/១ហិចតា) បន្ថែមដោយសារជីកំប៉ុស្តិ៍មិនគ្រប់។ ការយល់ដឹងរបស់ពួកគាត់ទៅលើការសន្សំ ជីកំប៉ុស្ត៍នេះមានភាពប្រសើរឡើង បន្ទាប់ពីគម្រោង បានផ្តល់វគ្គ បណ្តុះបណ្តាល នូវជំនាញ ចំណេះដឹង និង បច្ចេកទេសទាំងនេះ។ អ្វីដែលគួរចាប់អារម្មណ៏នោះពួកគាត់នូវតែអនុវត្តបន្តធ្វើ |

| | |
|---|---|
| | ជាប្រចាំ គ្រប់ផ្ទះភាគច្រើន មានរោងកំប៉ុស្តិ៍ ហើយមាន បរិស្ថានស្អាត ល្អស្រស់ ស្អាតភូមិ ។ |
| បណ្តុះបណ្តាលបច្ចេកទេសដាំដំណាំបន្លែ(២ថ្ងៃ ក្នុង១វគ្គ ៤វគ្គ=១២០នាក់) | ៤វគ្គ មានកសិករចំនួន១២០នាក់/ស្ត្រី៣៨នាក់(៤ស្រុក ៤ឃុំ ៤ភូមិ) គ្រួសារបង្ហាញ១២០ គ្រួសារ ។ |
| បណ្តុះបណ្តាលស្តីពីការចិញ្ចឹមត្រី (៤វគ្គ = ១២០នាក់) ៣ថ្ងៃ/វគ្គ | ៤វគ្គ មានកសិករចំនួន១២០នាក់/ស្ត្រី២៨នាក់(២ស្រុក ៤ឃុំ ៤ភូមិ) |
| • បណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់ (៦វគ្គ=១៥០នាក់)៣ថ្ងៃ/វគ្គ | - ៦វគ្គ មានកសិករចំនួន១៥០នាក់/ស្ត្រី៩២នាក់(៤ស្រុក ៦ឃុំ ៦ភូមិ) គ្រួសារបង្ហាញ ១៥០គ្រួសារ ។<br>-វគ្គនេះបានផ្តល់សម្រាប់អ្នកចូលរួមមាន សៀវភៅមេរៀន (បច្ចេកទេស) ពូជមាន់ ៧៥០ក្បាល និងសំភារៈទ្រុងមាន់១៥០ រោង ។<br>-អ្នកចូលរួមវគ្គភាគច្រើន នៅក្នុងការពិភាក្សាក្រុម បានឱ្យដឹង ថាពួកគាត់ពេញចិត្ត និងវគ្គបណ្តុះបណ្តាល និងការធ្វើបង្ហាញ នេះ ។<br>-វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមមាន់ ពិតជាឆ្លើយតប ទៅនឹងតម្រូវការ របស់ពួកគាត់ក៏ដូចជា ក្នុងសហគមន៍ដែរ ។ ជាងនេះទៀត អ្នកចូលរួម ក្រុមពិភាក្សា បានលើកឡើងថា កាល មិនទាន់ចូលរៀន វគ្គបណ្តុះបណ្តាល គាត់ចិញ្ចឹមតាមយថាហេតុ មិនមានទ្រុង មិនប្រើវ៉ាក់សាំង មាន់ងាប់យកធ្វើជាម្ហូប ការចិញ្ចឹមមាន់មិនបានផល(កូនដប់ក្បាល់នៅ ២-៣ក្បាលប៉ុណ្ណោះ ឬងាប់ដាច់ពូជក៏មាន) ។<br>ក្រោយវគ្គបណ្តុះបណ្តាលពួកគាត់បាន អនុវត្តបច្ចេកទេសថ្មីធ្វើឱ្យពួកគាត់ ចិញ្ចឹមមាន់បានប្រសើរដោយ ទទួលបានផលពីមាន់សម្រាប់ការកាត់បន្ថយទិញម្ហូប មានប្រាក់ចំណូលបន្ថែម ពីការលក់មាន់សម្រាប់ដោះស្រាយបន្ទាន់ក្នុងគ្រួសារករណីខ្វះលុយកូនរៀន បុណ្យ ការ ទិញ |

| | |
|---|---|
| | ថ្នាំពេទ្យ... (គិតជាមធ្យម៥០ម៉ឺន ទៅ៨០ម៉ឺនរៀល ក្នុងមួយឆ្នាំ)។ ការយល់ដឹងរបស់ពួកគាត់ ទៅលើការចិញ្ចឹមមាន់ ធ្វើឱ្យគាត់មាន ការផ្លាស់ប្តូរ ឥរិយាបទ ដោយមាន ការ យល់ដឹង ថាគាត់ មិនបរិភោគមាន់ងាប់ ដោយ សារជម្ងឺទៀតទេ (ងាប់ កប់ ឬ ដុតចោល) ជឿលើវ៉ាក់សាំង មានទ្រុងមាន់ត្រឹមត្រូវ ផ្តល់ចំណី ដែលខុសពីការ ចិញ្ចឹម តាមយថាហេតុ។ បើប្រៀបធៀប ជារួមយើងវិភាគ ឃើញថា អ្នកភូមិក៏ដូចជាក្នុង សហគមន៏ មានការ យកចិត្តទុកដាក់យ៉ាងខ្លាំង នូវការ ទទួលយកចំណេះដឹង ដែលធ្វើឱ្យជីវភាពរបស់គាត់បាន ប្រសើរឡើង តាមរយៈ ការកាត់បន្ថយចំណាយផ្សេងៗ និងធ្វើឱ្យសុខភាពគ្រួសារ ពួកគាត់បានប្រសើរជាងមុន។ |

## ផ្នែក-ខ: ការវាយតម្លៃការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា

| ល.រ | គោលបំណងបន្ទាន់ | ការសម្រេចបានជាក់ស្តែង នៅពេលបញ្ចប់អនុកិច្ចសន្យា / ក្នុងពេលវាយតម្លៃ |
|---|---|---|
| ១ | មិនមានសរសេរពីគោលបំណងន្ទាន់ទេ នៅក្នុងអនុកិច្ចសន្យា | មិនបានធ្វើការវាយតម្លៃលើគោលបំណងបន្ទាន់ទេ ព្រោះមិនមានក្នុងអនុកិច្ចសន្យា។ |

## ផ្នែក-គ: ការវាយតម្លៃផលប្រយោជន៏ជារួមដែលទទួលបាន:

តាមរយៈការពិភាក្សាក្រុមអ្នកចូលរួមអ្នកទទួលផលផ្ទាល់បានបង្ហាញថា ពួកគាត់មានការពេញចិត្តចំពោះផលប្រយោជន៏ដែលអនុកិច្ចសន្យានេះសម្រេចបានជាពិសេស គឺចំណេះដឹង និងបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ ចិញ្ចឹមសត្វ។ ពួកគាត់ បានទទួលស្គាល់ថា វាមានសារៈប្រយោជន៏ណាស់សំរាប់គ្រួសារគាត់ជាកសិករ ព្រោះគម្រោងទាំងនេះបានជួយច្រើនសម្រាប់ពួកគាត់ ក្នុងការបង្កើនទិន្នផល បង្កើនប្រាក់ចំណូល និងសុខភាពគ្រួសារប្រសើរឡើង ហើយក៏បានកែលំអរគុណ ភាពដី និងបរិស្ថាន ផងដែរ។

# ករណីសិក្សា

## ករណីសិក្សាទី ១ : អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងបណ្ដុះបណ្ដាលបច្ចេកទេសពីការធ្វើជីកំប៉ុស្ដិ៍:

បងស្រី ង៉ែត ចាន់ធឿន ដែលជាអ្នកទទួលផលពីគម្រោងបណ្ដុះបណ្ដាលពីការធ្វើជីកំប៉ុស គាំទ្រដោយគំរោងអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការរបស់ គ.ជ.អ.ប នៅភូមិតូច ឃុំក្រាំងស្នាយ ស្រុកឈូក ខេត្តកំពត ក្នុងឆ្នាំ២០០៩ "ជីវភាពរស់នៅរបស់ខ្ញុំ មានការប្រសើរឡើងតាំងពីខ្ញុំបានទទួល ការបណ្ដុះបណ្ដាល និងអនុវត្តអំពីបច្ចេកទេសធ្វើជីកំប៉ុស្ដិ៍ ។





រោងជីកំប៉ុស្ដិ៍បងស្រី ង៉ែត ធឿន

**បងស្រី ង៉ែត ចាន់ធឿន** ជាកសិករម្នាក់មានអាយុ ៣៧ឆ្នាំ មានគ្រួសារ និងកូនប្រុស៣នាក់ ស្រី២នាក់រស់ **នៅភូមិតូច ឃុំក្រាំងស្នាយ ស្រុកឈូក ខេត្តកំពត** ។ គាត់បាននិយាយថាគម្រោងបណ្ដុះបណ្ដាលពីបច្ចេកទេសធ្វើជីកំប៉ុស្ដិ៍នេះ មានសារៈសំខាន់ណាស់ ព្រោះគាត់បានទទួលចំណេះដឹងជំនាញសម្រាប់គាត់ ក៏ដូចជាកសិកររស់នៅ ក្នុងភូមិដែលបានចូលរួមវគ្គបណ្ដុះបណ្ដាលនេះដែរ ។ គាត់បញ្ជាក់ថាៈ ឥឡូវខ្ញុំមិនចំណាយប្រាក់កាសច្រើនដូចពេលមុនក្នុងការទិញជីគីមីទៀតទេ អ្នកជិតខាងហាក់ដូចជាមិនទាន់ជឿថាស្រូវរបស់គាត់ល្អ ដោយសារប្រើជីកំប៉ុស្ដិ៍ទេ ហើយទទួលបានផលច្រើនជាងពេលមុន (សម្រាប់ស្រែ២ ស្លឹកកើន៣០ថាំង ទៅ៥០ថាំង) ជាងនេះទៅទៀតគាត់បានសង្កេតឃើញថាដីស្រែរបស់គាត់ដីធូរស្រួលស្ទូងមានដុះស្មៅក្នុងស្រែ អង្ករល្អ "ភ្លឺដូចឆ្អឹង" បាយឆ្ងាញ់មានសុខភាពល្អជាងមុន ហើយជីវភាពក៏ប្រសើរឡើងគ្រាន់បើ ព្រោះហូបគ្រប់គ្រាន់បាន ១តោនដែរសម្រាប់ឆ្នាំនេះ ។ ជាការផ្លាស់ប្ដូរមួយទៀតសម្រាប់គ្រួសារគាត់បន្ទាប់ពីចូលរួម សកម្មភាពគម្រោងគឺភូមិស្អាត មិនមានសំរាម ឬលាមកសត្វនៅពាសវាលពាសកាល ព្រោះឥឡូវគាត់មានរោងជីកំប៉ុស្ដិ៍ ។ ជាចុងបញ្ចប់គាត់បង្ហាញពីការប្ដេជ្ញាចិត្តក្នុងការបន្តសកម្មភាព បច្ចេកទេស ធ្វើជីធម្មជាតិបន្តទៀត ទោះបីគម្រោងត្រូវបញ្ចប់ក៏ដោយ តែទោះជាណាង ណាក៏ការសន្សំជីមិនបានគ្រប់តាមតំរូវការនៃទំហំស្រែឡើយ ជាហេតុធ្វើឱ្យ គាត់ចំណាយថវិកា បន្ថែមទិញជីគីមីដើម្បីបង្គ្រប់ (មុនទិញ៣បាវ/ឆ្នាំ តែ ឥឡូវទិញ១បាវ/ឆ្នាំ) ។

## ករណីសិក្សាទី ២: អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ :

កញ្ញា សាន ស្រីពៅ ដែលជាអ្នកទទួលផលពីគម្រោង **បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់** គាំទ្រដោយគំរោងអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការរបស់ គ.ជ.អ.ប នៅភូមិត្រពាំងចក ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត ក្នុងឆ្នាំ ២០០៩ "ជីវភាពរស់នៅរបស់ខ្ញុំ មានភាពប្រសើរឡើងតាំងពីខ្ញុំបានទទួលការបណ្តុះបណ្តាល និងអនុវត្តអំពីបច្ចេកទេសចិញ្ចឹមមាន់ " ។





ការចិញ្ចឹមមាន់របស់ស្រីពៅ

កញ្ញា សាន ស្រីពៅ អាយុ ៣១ឆ្នាំ គាត់រស់នៅជាមួយបងស្រីម្នាក់ ជាស្រីមេម៉ាយ **នៅភូមិត្រពាំងចក ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត**។ គាត់ជាកសិករ ដែលមានចំណូលពីដំណាំស្រូវ ចិញ្ចឹមសត្វ និងលក់ចាប់ហួយបន្តិចបន្តួចនៅផ្ទះ។ កញ្ញា សាន ស្រីពៅ បានចូលរួមវគ្គបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមមាន់នៅខែកក្កដា ឆ្នាំ២០០៩ របស់មន្ទីរកសិកម្ម។ គាត់បានត្រូវគេជ្រើសរើស អោយចូលរួមដោយប្រធានភូមិសួរពីការពេញចិត្ត និងប្តេជ្ញាចិត្តក្នុងការចិញ្ចឹមមាន់។ គាត់និយាយថាវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់នេះមានសារៈសំខាន់ណាស់ព្រោះនៅក្នុងភូមិគ្រួសារភាគច្រើនចិញ្ចឹមមាន់ តែមុននោះការចិញ្ចឹម បានត្រឹមតែចិញ្ចឹមបានតិចតួច មិនដែលបានលក់ ឆ្នាំខ្លះងាប់ដាច់ពូជ ព្រោះចិញ្ចឹមតាមយថាហេតុ មិនដឹងពីផលប្រយោជន៍នៃការធ្វើទ្រុង ការឱ្យចំណី វ៉ាក់សាំង និងការថែទាំ ... តែក្រោយពីបានទទួលវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ ការចិញ្ចឹមបានអនុវត្តតាមបច្ចេកទេស ធ្វើឱ្យការចិញ្ចឹមបានល្អជាងមុន មាន់មិនសូវងាប់ ព្រោះបានធ្វើទ្រុង ធ្វើវ៉ាក់សាំង ការថែទាំ និងផ្តល់ចំណីបានគ្រប់គ្រាន់ ហើយលទ្ធផលក៏ប្រសើជាងពេលមុនៗដែរ ឥឡូវនេះបានផលប្រយោជន៍ពីមាន់ច្រើនគួរសមដូចជា ធ្វើម្ហូប លក់បានចំណូលពី៥០ម៉ឺន ទៅ៦០ម៉ឺនក្នុងមួយឆ្នាំ។ គាត់បានបន្ថែមទៀតថាកសិករនៅជិតខាងដែលមិនបានចូលរៀន បានសរសើរពីការចិញ្ចឹមមាន់របស់គាត់ហើយពេលខ្លះ អ្នកជិតខាងបានពឹងពាក់ឱ្យជួយ ចាក់វ៉ាក់សាំង ដល់មាន់របស់គេទៀត។





កញ្ញា សាន ស្រីពៅ មានសង្ឃឹមថាអ្នកជិតខាងរបស់គាត់នឹងបានចូលរួម វគ្គបណ្តុះបណ្តាល អំពីបច្ចេកទេសចិញ្ចឹមមាន់ដែរ ព្រោះវគ្គនេះធ្វើឱ្យកសិករយល់ដឹងពីបច្ចេកទេសចិញ្ចឹម និងជួយគ្រួសារក្នុងការរកប្រាក់ចំណូលបន្ថែម ពីការងារចិញ្ចឹមមាន់។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

ផ្នែក-កៈ ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅនឹងតំរូវការៈ មន្ទីរវិស័យ មូលដ្ឋាន ត.ជ.អ.ប និងការកាត់បន្ថយភាព ក្រីក្រៈ

ពិន្ទុ : ១=ខ្សោយណាស់ ២=ខ្សោយ ៣=មិនខ្លាំងមិនខ្សោយ ៤=ខ្លាំង ៥=ខ្លាំងណាស់

| ល.រ (១) | ធាតុ (២) | ទំនាក់ទំនងតក្កភាព (៣) | បរិយាយច្បាស់លាស់ (៤) | សង្ខេបការវាយតម្លៃ (៥) |
|---|---|---|---|---|
| ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់ | | | | |
| ១ | សកម្មភាព | ៤ | ៤ | សកម្មភាពដែលបានលើកឡើងពតិជាមានទំនាក់ទំនងតក្កជាមួយនឹងលទ្ធផលដែលបានសរសេរក្នុងអនុកិច្ចសន្យា។ ជាក់ស្តែងក្នុងលទ្ធផលទី១: កសិករទទួលការបណ្តុះបណ្តាលពីបច្ចេកទេសផ្សព្វផ្សាយក្សេត្រសាស្រ្ត និងការបង្ហាញមានសកម្មភាពជាក់លាក់ដូចជា: បណ្តុះបណ្តាលស្តីពីការប្រើប្រាស់ថ្នាំពុលធម្មជាតិលើ ដំណាំ (៤វគ្គ=១២០នាក់) បណ្តុះបណ្តាលស្តីពីការធ្វើជីកំប៉ុស្តិ៍ (១០វគ្គ=២៥០នាក់) បណ្តុះបណ្តាលបច្ចេកទេសដាំដំណាំបន្លែ(២ថ្ងៃក្នុង១វគ្គ៤វគ្គ=១២០នាក់)។ ទាំងនេះឆ្លុះបញ្ចាំងឱ្យឃើញថាសកម្មភាពមានទំនាក់ទំនងតក្កជាមួយនឹងលទ្ធផល ខាងលើហើយសកម្មភាពនីមួយៗបានបញ្ជាក់ពី ចំនួនវគ្គបណ្តុះបណ្តាល ចំនួនសិក្ខាកាមចូលរួមជាការងាយស្រួលក្នុងការចុះត្រួត ពិនិត្យសកម្មភាពគម្រោង ប៉ុន្តែរាល់សកម្មភាពដែលបានមិនបានបង្ហាញពីតំបន់គោលដៅប្រភេទអ្នកទទួលផល។ សកម្មភាពដទៃទៀតនៅក្នុងលទ្ធផលទី២ និងទី៣ត្រូវបានសរសេរក្នុងបែបបទដូចគ្នា នឹងលទ្ធផលទី១ ដែរ |

| | | | | |
|---|---|---|---|---|
| | | | | ហើយសកម្មភាពនីមួយៗមានទំនាក់ទំនងតក្ក និងបាន បរិយាយដូចដែលបានសរសេរក្នុងអនុកិច្ចសន្យា។ |
| ២ | លទ្ធផល | ៤ | ៣ | លទ្ធផលនីមួយៗត្រូវបានសរសេរបរិយាយមានលក្ខណៈ ទូលំទូលាយ ដោយមិនមានសូចនាករជាក់លាក់ដែល អាចវាស់វែងបាន។ តែលទ្ធផលនីមួយៗជាការបំពេញ ឱ្យគ្នាទៅវិញទៅមក ហើយនឹងរួមគ្នាបំពេញឱ្យឆ្លើយ នឹងគោលបំណងដែលបានសរសេរនៅ ផ្នែកទី៣ចំនុច ក។ |
| ៣ | - គោលបំណងបន្ទាន់ *(គោលបំណងស្ថិតក្នុងចំណុច "ខ" នៃផ្នែកទី ៣)* | ៤ | ១ | មិនមានការសរសេរពីគោលបំណងបន្ទាន់នៅ ផ្នែកទី៣ ចំនុចខ ទេ។ |
| ៤ | ស្ថានភាពចុងបញ្ចប់ អនុកិច្ចសន្យា *(ចំណុច "គ" នៃផ្នែកទី ៣)* | ៤ | ៤ | នៅចុងបញ្ចប់នៃអនុកិច្ចសន្យានេះ ត្រូវបានបរិយាយ ច្បាស់ ហើយមានទំនាក់ទំនងផ្ទាល់ទៅនឹងលទ្ធផល សកម្មភាពរបស់អនុកិច្ចសន្យា។ ស្ថានភាពចុងបញ្ចប់ នេះ បានឆ្លុះបញ្ចាំងនូវសមិទ្ធិផល ដែលសម្រេចបាន នៅក្នុង ក៏រិតលទ្ធផល។ |
| ៥ | លទ្ធផលអភិវឌ្ឍន៏/ផលប៉ះពាល់រយៈពេលវែងៈ គោលដៅ និងគោលបំណងអភិឌ្ឍន៏ **(ចំណុច ខ នៃផ្នែកទី៣)** | | | មិនអាចធ្វើការវាយតម្លៃបាន |

**ផ្នែក-ខៈ សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខ័ណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារៈ**

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ..អ.ជ.ខៈ** | | |

| | | |
|---|---|---|
| ១ | ជំនាញរៀបចំកិច្ចសន្យា | នៅមានកំរិត គួរតែពង្រឹងបន្ថែម ហើយមានការគាំទ្រជាបច្ចេកទេស។ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យ ការអនុវត្តន៍របស់ភ្នាក់ងារ អនុវត្តន៏ | គាំទ្របានទាន់ពេលវេលា។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា | មានសមត្ថភាពគ្រប់គ្រងក្នុងការត្រួតពិនិត្យ និងកត់ត្រាឯកសារអនុកិច្ចសន្យា។ |
| **ពីខាងភាគីអនុវត្តន៍កិច្ចសន្យាៈ** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | មានបុគ្គលិកជំនាញ និងបទពិសោធន៏សមល្មម។ |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | ការអនុវត្តសកម្មភាពនិង លទ្ធផលទាន់ពេលវេលា ដូចដែលបាន គ្រោងទុកក្នុងកិច្ចសន្យា ទោះបីជាមានការយឺតយ៉ាវខ្លះក្នុងការទូទាត់ថវិកា។ |
| ៦ | ការរាយការណ៏ការរីកចំរើន និងការកត់ត្រាឯកសារ | ពេលខ្លះការផ្ញើរបាយការណ៏រីកចំរើនមកគ.ប្រមិនសូវទៀងទាត់ ពេលវេលា ពេលខ្លះទាល់តែមានរំលឹកពីគ.ប្រ។ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | លក្ខខណ្ឌក្នុងកិច្ចសន្យា ត្រូវបានគោរព។ |
| **ទាំងខាង គ.អ.ជ.ខ និងភាគីអនុវត្តកិច្ចសន្យាៈ** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" (ចំណុច-ង ផ្នែកទី៣) និងបញ្ហាប្រឈម | អនុកិច្ចសន្យាបានអនុវត្តទៅដោយរលូន មិនមានប្រឈមជាមួយ កត្តាហានិភ័យណាមួយឡើយ។ |
| ៩ | ការបញ្រ្ជាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | មានការលើកកំពស់យេនឌ័រ។ ការចូលរួមរបស់កសិករជាស្ត្រីមាននៅគ្រប់សកម្មភាពបណ្តុះបណ្តាលពិសេសលើ វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់មានស្ត្រី៦១% តែបើគិតជាមួយវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី បន្លែ ការផ្សំថ្នាំពុលធម្មជាតិ និងការផលិតជីកំប៉ុស្តិ៍ សរុបជាមធ្យម ៣១%ជាស្ត្រី។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ ( ចំណុច-ឆ ផ្នែកទី៣) | ការលើកកំពស់ឱ្យមានការដាំដុះ ដោយប្រើជីធម្មជាតិ និងមិនប្រើសារធាតុគីមីនូវក្នុងវគ្គបណ្តុះបណ្តាល និងការបង្ហាញបានចូលរួមជាវិជ្ជមាន ទៅ |

| | | |
|---|---|---|
| | | ដល់ការយល់ដឹងពីការអភិរក្សធនធានធម្មជាតិ និងបរិស្ថាន។ |
| ១១ | ការថែរក្សា (និរន្តភាព) (ចំណុច ជ ផ្នែកទី៣) | គម្រោងនេះមាននិរន្តរភាពបានល្អប្រសើ ដោយសារវាស្របទៅ នឹងតំរូវការរបស់កសិករ ថែមទាំងមានការអនុវត្តរបស់កាត់ទទួលនូវលទ្ធផល ប្រសើរធ្វើឱ្យកសិករនៅតែបន្តការអនុវត្ត។ |

## ២.៤. សេចក្តីសន្និដ្ឋាន

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យាត្រូវបានអនុវត្តតាមដូចការគ្រោងទុក។ភាគីអនុវត្តកិច្ចសន្យាមានសមត្ថភាពនិងធនធានគ្រប់គ្រាន់ដើម្បីអនុវត្តអនុកិច្ចសន្យា។ សកម្មភាព និងលទ្ធផលបានគ្រោងទុកត្រូវបានបញ្ចប់ស្របតាមផែនការការងារ។ |
| ២ | លទ្ធផលរបស់អនុកិច្ចសន្យា និងអត្ថប្រយោជន៍ដែលសហគមន៍ទទួលបាន ត្រូវបានអ្នកទទួលផលសាទរនៅក្នុងឃុំដែលគម្រោងបានអនុវត្ត។ ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា ត្រូវបានសម្រេចដូចការគ្រោងទុក។ ភស្តុតាងអំពីលទ្ធផល និងផលប្រយោជន៍ដែលទទួលបានហើយនៅតែត្រូវបានអនុវត្តបន្ត ក្រោយពីការបញ្ចប់អនុកិច្ចសន្យាដូចជា:<br>ក) ផ្ទះភាគច្រើនមានរោងកំប៉ុស្តិ៍ និងកំពុងបន្តការសន្សំជីកំប៉ុស្តិ៍ តាមបច្ចេកដែលទទួលបានពីវគ្គបណ្តុះបណ្តាល របស់កម្មវិធី សម្រាប់ការធ្វើស្រែ និងដំណាំផ្សេងៗ។ ចំពោះគម្រោងចិញ្ចឹមមាន់ក៏មិនខុសពីកំប៉ុស្តិ៍ដែរព្រោះថា ភាគច្រើនផ្ទះកសិករទទួលផលពីគម្រោងភាគច្រើនបានចិញ្ចឹមមាន់ ដោយមានទ្រុងត្រឹមត្រូវ និងការថែទាំតាមបច្ចេក ទេស ហើយចំនួនមាន់ក៏មានការកើនឡើងដែរ ដែលអាចជួយសំរួលដល់ជីវភាព បាន មួយក៏រិត តាមរយៈប្រាក់ ចំណូលពីការចិញ្ចឹមមាន់។<br>ខ) មានតម្រូវការវគ្គបណ្តុះបណ្តាលដូចគ្នានេះ សំណូមពរដោយអ្នកភូមិជិតខាងជាច្រើនទៀត ដោយពួកគាត់មើលឃើញពីអត្ថប្រយោជន៍នៃគម្រោងធ្វើជីកំប៉ុស្តិ៍ និងមាន់។ ដូច្នេះអនុកិច្ចសន្យាបានទទួលនូវនិរន្តរភាព និងសកម្មភាពរបស់គម្រោងក៏រឹតខ្ពស់។ ហេតុនេះគម្រោងបានចូលរួមចំណែកក្នុងក៏រឹតតិចតួចទៅគោលដៅ អភិវឌ្ឍន៍នៅក្នុងអនុកិច្ចសន្យា ហើយនឹងគោលដៅក្នុងការកាត់បន្ថយភាពក្រីក្រ បានមួយកម្រឹតតាមការសំភាសន៍កសិករគម្រោងកំប៉ុស្តិ៍ ចំនួន២៤នាក់ និងគម្រោងចិញ្ចឹមមាន់ចំនួន ១៦នាក់។ |
| ៣ | ការជ្រើសរើសសិក្ខាកាម និងអ្នកទទួលផលនៅក្នុងអនុកិច្ចសន្យា បើតាមការសំភាសន៍ជាមួយភ្នាក់ងារអនុវត្តអនុកិច្ចសន្យាបានបញ្ជាក់ថា ដំណើរការជ្រើសរើសកសិករចូលរួមវគ្គ តាមរយៈអាជ្ញាធរដែនដី ដោយមានការចូលរួមពីមេឃុំ ភូមិ ភ្នាក់ងារអនុវត្តគម្រោង។ តែបើតាមការសំភាសន៍កសិករចូលរួមវគ្គកំប៉ុស្តិ៍ និងវគ្គចិញ្ចឹម |

| | |
|---|---|
| | មាន់បានបញ្ជាក់ថា មេភូមិបានសួររកអ្នកស្មគ្រចិត្ត ហើយយកចិត្តទុកដាក់លើការងារកសិកម្ម និងចិញ្ចឹមសត្វ ដោយមេភូមិបញ្ជាក់ថាពេលរៀនចប់ត្រូវតែអនុវត្តដើម្បីធ្វើឱ្យមានការធានាថា អ្នកដែលមានតម្រូវការខ្លាំងបំផុត នឹងទទួលបានផលប្រយោជន៍ពីគម្រោង ។ |
| ៤ | អនុកិច្ចសន្យានេះមិនបានជួបប្រទះនូវឧបសគ្គ និងបញ្ហាប្រឈមដែលគួរឱ្យកត់សំគាល់ទេ។ |

**ចំណុចរៀនសូត្រៈ**

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ដូចដែលបានសង្កេតឃើញក្នុងការចុះវាយតម្លៃនេះ ផលប៉ះពាល់របស់អនុកិច្ចសន្យា និងនិរន្តរភាពរបស់លទ្ធផលនៅក្នុងអនុកិច្ចសន្យា ត្រូវបានរៀបចំឡើង និងបានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងជាអាទិភាពរបស់ក្រុមគោលដៅដែលជាអ្នកទទួលផល។ |
| ២ | មិនមានការបរិយាយច្បាស់លាស់នូវគោលបំណងបន្ទាន់ ក្នុងក៏រឹតដែលអាចវាស់វែងបាន ជាការសំខាន់សំរាប់ការកត់ត្រាទុក នូវលទ្ធផលរបស់អនុកិច្ចសន្យា និងផលប្រយោជន៍ដែលមានសំរាប់ធ្វើការវាយតម្លៃលទ្ធផល។ |
| ៣ | ការវាស់វែងទៅលើគុណភាពនៃវគ្គបណ្តុះបណ្តាលអាចវាស់វែងបាន បើភ្នាក់ងារអនុវត្តគម្រោងមានការវាយតម្លៃមុន និងក្រោយវគ្គបណ្តុះបណ្តាលហើយរក្សាទុកឯកសារសំអាង។ |

**អនុសាសន៍ :**

| ល.រ | អនុសាសន៍ |
|---|---|
| ១ | រាល់ វគ្គបណ្តុះបណ្តាលត្រូវមានឯកសារសំអាងពីការវាយតម្លៃវគ្គមុន និងក្រោយវគ្គបណ្តុះបណ្តាល |
| ២ | ភ្នាក់ងារអនុវត្តគម្រោងគប្បីពិភាក្សា និងរដ្ឋអំណាចមូលដ្ឋានធ្វើយ៉ាងណាឱ្យកសិករដែលមក ចូលរួមក្នុង វគ្គបណ្តុះបណ្តាលឱ្យបានពេញលេញតាមកាលវិភាគដែលបានគ្រោងទុក។ |
| ៣ | ភ្នាក់ងារអនុវត្តគម្រោងគប្បីធ្វើរបាយការណ៍រីកចំរើនផ្ញើរមកគណៈកម្មាធិការប្រតិបត្តិឱ្យទាន់ពេលវេលា។ |
| ៤ | ភ្នាក់ងារអនុវត្តគម្រោងគប្បីរៀបចំលក្ខណៈវិនិច្ឆ័យច្បាស់លាស់និងសហការជាមួយឃុំ ភូមិក្នុងការជ្រើសរើសកសិករចូលរួមវគ្គ។ |
| ៥ | ភ្នាក់ងារអនុវត្តការរៀបចំផែនការសកម្មភាពប្រចាំខែគប្បីឱ្យមានជាក់លាក់ខ្ពស់។ |

## ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

**ឯកសារដែលត្រូវភ្ជាប់ទី១ :** បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបានពិនិត្យ

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) | មាន (៣) |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និងឯកសារវិសោធនកម្ម (ប្រសិនមាន) | √ |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ | √ |
| ៣ | របាយការណ៍ត្រួតពិនិត្យគម្រោង | √ |
| ៤ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | √ |
| ៥ | លិខិតឆ្លើយឆ្លងរវាងភ្នាក់ងារអនុវត្តន៍ និងគណៈកម្មាធិការប្រត្តិបត្តិគ.អ.ជ.ខ | |
| ៦ | បញ្ជីវត្ថុបណ្ដុះបណ្ដាលដែលមានក្នុងអនុកិច្ចសន្យា | √ |
| ៧ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា | √ |
| ៨ | ឯកសារដ៏ទៃទៀតរួមមាន រូបថតនៃគម្រោង (អនុកិច្ចសន្យា) ដែលទុកនៅគណៈកម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ  និងនៅភ្នាក់ងារអនុវត្តន៍ ដែលមិនបានរៀបរាប់ខាងលើ | |
| ៩ | ផ្សេងទៀត | |

**ឯកសារទី២ :** បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាសន៍ / ជួបពិភាក្សា

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៍ប្រើសម្រាប់ប្រមូលទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | ១៤/១០ | លោក ខឹម ប៉ុណ្ណាប្រធានការិ.ផ្សព្វផ្សាយ | មន្ទីរកសិកម្ម | សម្ភាសន៍ស៊ីជម្រៅ |
| ២ | ១៤/១០ | អ្នកស្រី អ៊ូច ចន្ទ័បុប្ផា ការិ.ផែនការគណនេយ្យ | មន្ទីរកសិកម្ម | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | ១៤/១០ | លោក ហ៊ី វិចិត្រ | ទីប្រឹក្សា | សម្ភាសន៍ស៊ីជម្រៅ |
| ៤ | ១៨/១០ | ក្រុមអ្នកទទួលផល ៨នាក់ វគ្គកំប៉ុស្តិ៍ | ភូមិព្រៃឈើនៀង ស្រុកឈូក | សម្ភាសន៍ជាក្រុម |
| ៥ | ១៩/១០ | ក្រុមអ្នកទទួលផល ៨នាក់ វគ្គកំប៉ុស្តិ៍ | ភូមិតូច ស្រុកឈូក | សម្ភាសន៍ជាក្រុម/ករណីសិក្សា |
| ៦ | ២០/១០ | ក្រុមអ្នកទទួលផល ៨នាក់ វគ្គកំប៉ុស្តិ៍ | ភូមិអង្គឃ្លៃ ស្រុកឈូក | សម្ភាសន៍ជាក្រុម |
| ៧ | ២១/១០ | ក្រុមអ្នកទទួលផល ៨នាក់ វគ្គមាន់ | ភូមិត្រពាំងចក ស្រុកអង្គរជ័យ | សម្ភាសន៍ជាក្រុម/ករណីសិក្សា |
| ៨ | ២១/១០ | ក្រុមអ្នកទទួលផល ៨នាក់ វគ្គមាន់ | ភូមិចាក់ជ្រុំ ស្រុកអង្គរជ័យ | សម្ភាសន៍ជាក្រុម |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | 08/ AGR/0901-00( GOV ) |
| ចំណងជើង : | ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម |
| ភ្នាក់ងារអនុវត្តន៍ : | មន្ទីរកសិកម្មខេត្តកណ្តាល |
| រយៈពេល (ចាប់ផ្តើម និងបញ្ចប់) | 01/01/2009 ដល់ 31/12/2009 |
| រាជធានី ខេត្ត | កណ្តាល |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរកសិកម្មខេត្តកណ្តាល |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ/គ.អ.ជ.ខ | ៣២.១០០ដុល្លា |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៍ | ២.៥០០ដុល្លា |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | ៣៤.៦០០ដុល្លា |

## ក្រុមវាយតម្លៃ

| ឈ្មោះ | មុខតំណែង និងមុខងារ | |
|---|---|---|
| លោក រុយ ឈុនលី | សមាជិកអចិន្ត្រៃយ៍ គ.ប្រ នៃ គ.អ.ជ.ខ ខេត្តកណ្តាល | ជាប្រធាន |
| លោក ហ៊ីង ធឿន | អនុប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា និងជាគ្រូបង្គោល | សមាជិក |
| លោកស្រី ឡេង រីម | អនុប្រធានមន្ទីរកិច្ចការនារី និងជាគ្រូបង្គោល | សមាជិក |
| លោក បូ សារឿន | មន្ត្រីផ្នែករដ្ឋបាលមូលដ្ឋាន និងជាគ្រូបង្គោល | សមាជិក |
| លោក សុខ ស្រ៊ុន | មន្ត្រីផ្នែកពិនិត្យបញ្ជាក់មន្ទីរកសិកម្ម | សមាជិក |
| លោក ប៉ាន់ ខេមរិទ្ធ | មន្ត្រីតាមដានត្រួតពិនិត្យមន្ទីរកសិកម្ម | សមាជិក |
| លោក ទុញ បូរ៉ា | មន្ត្រីតាមដានត្រួតពិនិត្យ វាយតម្លៃ គ.ប្រ | សមាជិក |
| លោក ស៊ុយ សុខណា | មន្ត្រីតាមដានត្រួតពិនិត្យ វាយតម្លៃ គ.ប្រ | សមាជិក |
| លោកស្រី ជាសុខា | មន្ត្រីតាមដានត្រួតពិនិត្យ វាយតម្លៃ គ.ប្រ | សមាជិក |

## របាយការណ៍ស្តីពីការវាយតម្លៃ រៀបចំដោយ :

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ និងតួនាទីក្នុងការវាយតម្លៃ |
|---|---|
| លោក ហ៊ុង ជឿន | អនុប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា និងជាគ្រូបង្គោល |
| លោកស្រី ឡេង រីម | អនុប្រធានមន្ទីរកិច្ចការនារី និងជាគ្រូបង្គោល |
| លោក បូ សារឿន | មន្ត្រីផ្នែករដ្ឋបាលមូលដ្ឋាន និងជាគ្រូបង្គោល |
| លោកស្រី ជាសុខា | មន្ត្រីតាមដានត្រួតពិនិត្យ វាយតម្លៃ គ.ប្រ |

## ខេត្ត កណ្តាល

កាលបរិច្ឆេទ : ១២ ខែ វិច្ឆិកា ២០១០

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ១ |
| | របាយការណ៍សង្ខេប | ២ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | ៥ |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៥ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៥ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៥ |
| ១.៤ | សំណួរវាយតម្លៃ | ៦ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ៦ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ៧ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **៩** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១) | ៩ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម (សំណួរវាយតម្លៃទី៣) | ១៣ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤) | ១៨ |
| **២.៤** | **សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី៥)** | **១៩** |
| **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍** | | **២១** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ២១ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍/ពិភាក្សា | ២២ |
| **ករណីសិក្សា** | | |
| ទី១- | " ជីវភាពរស់នៅមានភាពប្រសើរ " — **លោក សៀក-រ៉ុង** អ្នកទទួលផល នៃសហគមន៍ (ពាមសាលា) នៃគម្រោងកែលម្អជីវភាព និងគ្រប់គ្រងធនធានធម្មជាតិ | ១៦ |
| ទី២- | អ្នកមិនបានទទួលផល | ១៧ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ :

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ ខេត្តកណ្តាល និងគ្រូបង្គោល បានធ្វើការវាយតម្លៃអនុកិច្ចសន្យាដែលមានចំណងជើងថា " ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម " លេខ 08/AGR/0901-00 ដែលជាអនុកិច្ចសន្យា រវាង គ.ប្រ នៃ គ.អ.ជ.ខ ខេត្តកណ្តាល និងមន្ទីរកសិកម្ម ។ នេះជាផ្នែកមួយក្នុងការពង្រឹងសមត្ថភាពដល់គ្រូបង្គោល ថ្នាក់ក្រោមជាតិ និងមន្ត្រីរបស់MEរបស់គ.ប្រ ដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ តាមរយៈវិមជ្ឈការនិងវិសហមជ្ឈការ ។

គោលបំណងជាក់លាក់នៃការវាយតម្លៃនេះគឺ :

១- ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និងចំណុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំង កត់ត្រានូវចំណុច រៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត ។

២- ពង្រឹងរបៀប ធ្វើការវាយតម្លៃគម្រោងរបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត ។ ការវាយតម្លៃ អនុវត្តតាមការណែនាំ និងឧបករណ៍ស្តីពីការវាយតម្លៃអនុកិច្ចសន្យារបស់គណៈកម្មាធិការ ប្រតិបត្តិ គ.អ.ជ.ខដែលរៀបចំដោយផ្នែកត្រួតពិនិត្យនិងវាយតម្លៃនៃផ្នែកគ្រប់គ្រងកិច្ចសន្យាគ.អ.ជ.ខនិងគ្រូបង្គោលថ្នាក់ក្រោមជាតិ ។ក្រុមការងារ វាយតម្លៃបានប្រើការពិភាក្សាក្រុមការសម្ភាសស៊ីជម្រៅ ការចុះមូលដ្ឋាន គន្លឹះក្នុងការសង្កេតផ្ទាល់និងរំលឹក ឯកសារអនុកិច្ចសន្យា របាយការណ៍រីកចម្រើននិងឯកសារផ្សេងៗទៀត ។ ដែលពាក់ពន្ធ័ការវាយតម្លៃ បានឆ្លើយតបនឹងសំណួរវាយតម្លៃស៊ីជម្រៅលើ លទ្ធផលតែមួយប៉ុណ្ណោះ ។ ដូច្នេះការវាយតម្លៃនេះមិនមែនជាការវាយតម្លៃស៊ីជម្រៅ ទៅលើអនុកិច្ចសន្យា របស់មន្ទីរកសិកម្ម ទាំងស្រុងទេ គឺវាយតម្លៃលើលទ្ធផលស្តីពីការបង្ហាលផ្នែក ក្សេតសាស្ត្រ ដែលឯកស្រង់នូវសកម្មភាព អំពីបច្ចេកទេស ដាំបន្លែ និងបង្ហាញ ។

ឆ្លើយទៅនឹងសំណួរទាំង៥ នៃការវាយតម្លៃ :

១- សកម្មភាពទាំងអស់ត្រូវបានអនុវត្ត និងលទ្ធផលសំរេចបានតាមផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១ | វគ្គបច្ចេកទេសជីកំប៉ុស្តិ៍ ៤វគ្គ / ៤0រណ្តៅ | ១០0នាក់/ស្រី ៥0នាក់ |
| ២ | វគ្គបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំកំចាត់សត្វល្អិត ៦វគ្គ | ១៨0នាក់/ស្រី ៨0នាក់ |
| ៣ | វគ្គបច្ចេកទេសដាំបន្លែ និងបង្ហាញ ៤វគ្គ ៤ បង្ហាញ | ១០0នាក់/ស្រី ៥0នាក់ |
| ៤ | វគ្គបច្ចេកទេសកែប្រែគុណភាពដី និងធ្វើបង្ហាញ ៤វគ្គ បង្ហាញ និង៤ បង្ហាញ | ១០0នាក់/ ស្រី៤៥នាក់ |

២- វគ្គបណ្តុះបណ្តាលអំពីបច្ចេទេសដំណាំបន្លែ និងការបង្ហាញផលិត និងប្រើជីធម្មជាតិ មានប្រសិទ្ធិភាពណាស់ដោយសារវាចូលរួមចំណែកក្នុងការបង្កើនផលិតផលបន្លែ ការហូបបន្លែ និងបង្កើនចំណូលក្នុងគ្រួសារ ។

៣- ជារួម អនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាទទួលបាននៅកម្រិតខ្ពស់ ។

៤- អនុកិច្ចសន្យាពិតជាបានចូលរួមចំណែកក្នុងការសម្រេចនូវគោលបំណងបន្ទាន់ ដោយសារកសិករបានអនុវត្តបច្ចេកទេសថ្មីដែលទទួលបានពីវគ្គបណ្តុះបណ្តាល និងបង្ហាញ ផលិតផលកសិកម្ម និងចំណូលគ្រួសាររបស់ពួក គាត់មានការកើនឡើង ទោះជាក្នុងកម្រិត និងដែនកំណត់ក៏ដោយ ។

៦- អនុកិច្ចសន្យានេះ ពិតជាមានភាពពាក់ព័ន្ធ ប្រសិទ្ធផល ទាក់ទងនឹងធនធានដែលមាន ការប្រតិបត្តិ និងការគ្រប់គ្រងទូទៅ ។ ប៉ុន្តែទោះជាយ៉ាងណា គុណភាពនៃការរៀបរៀងអនុកិច្ចសន្យា គួរតែត្រូវកែលំអដូចខាងក្រោម:

ក- បរិយាយអោយបានច្បាស់លាស់ និងអាចវាស់វែងបាន នូវសមត្ថភាពចុងបញ្ចប់នៃអនុកិច្ចសន្យា និងគោលបំណងបន្ទាន់

ខ- ការប្រើប្រាស់សូចនាករជោគជ័យធៀបនឹងទិន្នន័យមូលដ្ឋាន ។

គ- ភ្ជាប់ទំនាក់ទំនងអោយបានច្បាស់លាស់រវាងលទ្ធផល គោលបំណងបន្ទាន់ និងគោលបំណង កម្រិតខ្ពស់ ។

**សេចក្តីសន្និដ្ឋាន:**

១) លទ្ធផល និងអត្ថប្រយោជន៏ដែលបានពីការអនុវត្តន៏អនុកិច្ចសន្យាជាប្រយោជន៏ដល់សហគមន៏ គឺមាន

ភស្តុតាង បង្ហាញ ច្បាស់លាស់ ហើយត្រូវបាន ទទួលការសារទរ ពីអ្នកទទួលផលដោយផ្ទាល់ និងអ្នក មិនទទួលផល នៅក្នុងឃុំនៃគម្រោង ។ ឧទាហរណ៍ការ បង្កើននូវផលិតផលដាំបន្លែ និងលទ្ធផលដែលបានមក ពីការប្រើប្រាស់បន្លែ នៅក្នុងគ្រួសារ ការសន្សំសំចៃក្នុងគ្រួសារ និងការ កើនឡើងនូវប្រាក់ចំណូល ជាលទ្ធផលសម្រេចបាន ពីវគ្គ បណ្តុះបណ្តាល ពីបច្ចេកទេសដំណាំបន្លែ នៅក្នុងអនុកិច្ចសន្យា ។

ជាពិសេសទៀតនោះតំរូវការវគ្គបណ្តុះបណ្តាលស្រដៀងគ្នានេះបានកើតឡើង បន្ទាប់ពីការអនុវត្តសកម្មភាពគម្រោងចប់ ។

២) គួរមានការបន្តការគាំទ្រគំរោងបែបនេះ ក៏ដូចជាការពង្រីកសកម្មភាពគំរោងបៀបនេះបន្តទៀត ។

៣) ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីធ្វើអោយសម្រេចបាននូវអត្ថប្រយោជន៍ក្នុងកំរិតខ្ពស់ ភ្នាក់ងារអនុវត្តគម្រោងគួរមានការបណ្តុះបណ្តាលបំប៉នបន្ថែមដល់កសិករដែលឋិតក្នុងគម្រោងនិងបើកវគ្គបណ្តុះបណ្តាលកសិករថ្មី ស្តីអំពីបច្ចេកទេសដាំដំណាំបន្លែដើម្បីឱ្យកសិករបានកែប្រែទម្លាប់ចាស់មកប្រើបច្ចេកទេសសមស្របនាពេលបច្ចុប្បន្ន ។

៤) ដើម្បីពង្រឹងនូវគុណភាព និងភាពទាក់ទងរបស់គម្រោង ផ្នែករដ្ឋបាល និងគ្រប់គ្រងអនុកិច្ចសន្យាបានធ្វើការវាយតម្លៃគម្រោងស្រដៀងគ្នានេះ មានចំនួន ២គម្រោងនៃអនុកិច្ចសន្យារបស់មន្ទីរ ។
មានឥណទានគោ របស់មន្ទីរកសិកម្ម និងម៉ាស៊ីនប៉ូបទឹកចលត័ របស់មន្ទីរធនធានទឹកលើលទ្ធផល និងសកម្មភាពដែលបាន អនុវត្តន៍ក្នុងឆ្នាំ ២០០៩ ។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំគ.ជ.អ.ប ផ្តល់ថវិកាតាមរយៈ គ.ប្រ នៃគ.អ.ជ.ខ ខេត្តកណ្តាលទៅមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និងគម្រោងដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។ ការវាយតម្លៃអនុកិច្ចសន្យា ដែលមានលក្ខណៈជាប្រព័ន្ធមិនបានអនុវត្តទេ ដោយមកពីហេតុផលជាច្រើនកាលពីពេលកន្លងមក ដោយមាននៅក្នុងឆ្នាំ ២០១០ ជាមួយនឹងការគាំទ្រផ្នែក ថវិកា និងបច្ចេកទេស ពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋានគ.ជ.អ.បនិងផ្នែករដ្ឋបាលនិងគ្រប់គ្រងកិច្ចសន្យាគ.ប្រនៃគ.អ.ជ.ខ ក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យាដែលបានរៀបចំរួមគ្នាជាមួយភ្នាក់ងារអនុវត្តនីគម្រោងរបស់មន្ទីរកសិកម្ម ដែលមានលេខអនុកិច្ចសន្យា 08/AGR/0901-00បានរកឃើញនិងបានធ្វើការសន្និដ្ឋានការវាយតម្លៃត្រូវបានកត់ត្រា ហើយនឹងបង្ហាញតាមរយៈរបាយការណ៍ស្តីពី ការវាយតម្លៃសកម្មភាព និងលទ្ធផល នៃនុកិច្ចសន្យានេះ ។

## ១.២. គោលបំណងអនុកិច្ចសន្យា

នៅចុងឆ្នាំ ២០០៩ ទិន្នផលដំណាំបន្លែ និងដំណាំរួមផ្សំផ្សេងទៀត និង ប្រាក់ចំណូលក្នុងគ្រួសារសហគមន៍ត្រូវបានកើនឡើង តាមរយៈការបណ្តុះបណ្តាល ផ្សព្វផ្សាយ និងការធ្វើបង្ហាញ នូវបច្ចេកទេសកសិកម្មសមស្របនេះជាពិសេសគឺលើសកម្មភាពវគ្គបណ្តុះបណ្តាលបច្ចេកទេស ដំណាំបន្លែ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

ការវាយតម្លៃលទ្ធផលនៃសកម្មភាព វគ្គបណ្តុះបណ្តាលបច្ចេកទេស ដំណាំបន្លែនៃនុកិច្ចសន្យានេះ ផ្នែករដ្ឋបាលគ្រប់គ្រងកិច្ចសន្យារបស់គ.ប្រនៃគ.អ.ជ.ខ និងគ្រូបង្គោលបានអនុវត្តនី ក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេសនិងតម្លាភាព។ដូច្នេះ ទំហំនៃការវាយតម្លៃមានដែនកំណត់តាមទំហំនៃលទ្ធផល និងសកម្មភាពនៃអនុកិច្ចសន្យានិងរាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខណ្ឌការងារនៃការវាយតម្លៃ។ គោលបំណង នៃការវាយតម្លៃគឺៈ **ក)** ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធិផលនៃអនុកិច្ចសន្យា និងចំនុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យារួមទាំងកត់ត្រានូវចំណុចរៀនសូត្រនិងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត និង **ខ)** ដើម្បីពង្រឹងរបៀប ធ្វើការវាយតម្លៃ គម្រោង របស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើ៖

១) បានពិនិត្យឯកសារអនុកិច្ចសន្យារបាយការណ៍ប្រចាំខែកំនត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់ កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធដែលមាន នៅក្នុងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៍ ។

២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗរួមមាន៖អ្នករៀបចំនិងអនុវត្តអនុកិច្ចសន្យានិងអ្នកទទួលផលផ្ទាល់ និងមិនផ្ទាល់ចំនួន៨នាក់និងអ្នកពាក់ព័ន្ធ៣នាក់ ។ សូមពិគ្រោះជាមួយនឹងមន្ត្រីបង្គោលទៅលើបញ្ហាយេនឌ័រ និងគ្រប់គ្រង ធនធានធម្មជាតសម្រាប់បញ្ហាពាក់ពន្ធ័វិស័យខាងលើ ។

៣) ប្រើប្រាស់វិធីសាស្ត្រចុះពិនិត្យតំបន់អនុវត្តន៍គម្រោងនិងសង្កេតមើលសកម្មភាពពិភាក្សាក្រុម និង អ្នកទទួលផលផ្ទាល់សមាសកសិករចំនួនពីរនាក់សំរាប់ករណីសិក្សានៅក្នុងភូមិព្រៃកខ្មែរ ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ។

៤) ចុះពិនិត្យតំបន់អនុវត្តន៍គម្រោងភូមិព្រៃកខ្មែរ ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់

៥) ធ្វើការវិភាគទិន្នន័យ និងបកស្រាយ៖ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើនឹងត្រូវធ្វើការវិភាគនិងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់ ។

៦) បានផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញនិងអនុសាសន៍ដោយភ្នាក់ងារអនុវត្តន៍ និងអ្នកពាក់ព័ន្ធតាមរយៈព័ត៌មាន ត្រឡប់ដែលទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើង នៅថ្ងៃទី២៩. ខែកញ្ញា ឆ្នាំ២០១០ ការវាយ តម្លៃត្រូវធ្វើតាម "គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា" និងវិធីសាស្ត្រដែលបានធ្វើ ។

| |
|---|
| ការបណ្តុះបណ្តាល និងណែនាំពីថ្នាក់ជាតិ។ ដូច្នេះ ដំណើរការត្រូវបានធ្វើឡើងដោយមានទម្រង់ការណែនាំ និង តម្លាភាព រួមទាំងការចូល រួមពីអ្នកពាក់ព័ន្ធ។ |

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

| |
|---|
| ១) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើង ដោយ គ.ប្រ គ្រូបង្គោលដែលទទួលបានការបណ្តុះបណ្តាលពីថ្នាក់ជាតិ និងអ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា។ទោះជាយ៉ាងណាក៏ដោយការ ប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានា ឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត។<br>២) ថ្វីត្បិតតែចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត : វាជាបញ្ហាប្រឈមតិចតួចក្នុងការវាយ តម្លៃគម្រោងនៅពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញនិងបទពិសោធន៍ពីមុនមក។ ទោះបីជាយ៉ាងណាក៏ ដោយគោលបំណងសំខាន់ គឺដើម្បី"រៀនធ្វើដោយការអនុវត្តផ្ទាល់។ អ្នកវាយតម្លៃ បានទទួលការគាំទ្រដោយ មានគោលការណ៍ការណែនាំឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដើម្បីដោះ ស្រាយបញ្ហាទាំងអស់នេះ។<br>៣) បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យា: ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និងជោគជ័យទេ ។ មួយទៀត ទំនាក់ទំនង សង្ខេបតាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់ មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ។<br>៤) ដោយយើងមិនមានសូចនាករឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍" ដែលជា កម្រិត អត្ថប្រយោជន៍ ទៅលើគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។<br>៥) ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការ វាយតម្លៃ លម្អិតទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ។យើងអាចវាយតម្លៃតែទៅលើកសិករពីចច្ចេកទេស តាមរយៈការបង្ហាញផ្នែក ក្សេតសាស្ត្រ (ជីកំប៉ុស៍ ជីគីមី និងថ្នាំគីមី ដំណាំបន្លែ និងកែប្រែគុណភាពដី) ដែលជាលទ្ធផល ទីមួយនៃអនុកិច្ចសន្យា លំអិតតាមរយៈការសម្ភាសន៍ស៊ីជម្រៅ ក្រុមពិភាក្សា និងការចុះពិនិត្យតំបន់អនុវត្តគម្រោង។<br>៦) ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់នៃអនុ កិច្ចសន្យា មិនអាចធ្វើទៅបានទេ ព្រោះចំណុច គ នៃផ្នែកទី៣ក្នុងឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ ឬមិន ពេញលេញ។ |

ការងារនេះ នឹងកាន់តែមានសុពលភាព និងពោរពេញទៅដោយព័តិមាន បើសិនជាចំនុចដែលបានរៀបរាប់ខាងលើនេះត្រូវបានដោះស្រាយ ។

**<u>ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធនឹ:</u>**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ 08/AGR/0901-00 និងដែនកំណត់ ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ ។

២) ការវាយតម្លៃនេះលម្អិតតែទៅលើ *កសិករដែលទទួលបានការបណ្តុះបណ្តាលពីបច្ចេកទេសតាមរយៈការបង្ហាញផ្នែកក្សេតសាស្ត្រដែលជាលទ្ធផល និងបណ្តុះបណ្តាលបច្ចេលទេសដំណាំបន្លែ និងធ្វើបង្ហាញដែលជាសកម្មភាព នៃះអនុកិច្ចសន្យានេះ ។*

៣) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃទៅលើ ភ្នាក់ងារអនុវត្តនឹ ភ្នាក់ងារដែលពាក់ព័ន្ធគម្រោង ហើយនឹង ការវាយតម្លៃទៅលើគ.ប្រ នៃគ.អ.ជ.ខ និង គ.ជ.អ.ប ទេ។ ហេតុដូច្នេះ របាយការណ៍នៃការវាយតម្លៃលទ្ធផលដែលបានរកឃើញ និងអនុសាសន៍ដែលបានលើកឡើង ត្រូវពិនិត្យដោយយោលទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ ។

# ២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១)

លទ្ធផលទី១ :ការបង្ហាញផ្នែកក្សេត្រសាស្ត្រ ជីកំប៉ុស្តិ៍ ជីគីមី និងថ្នាំគីមី ដំណាំបន្លែនិងកែប្រែគុណភាពដី

**ផ្នែក-ក :**

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ១.១ | វគ្គបច្ចេលទេសជីកំប៉ុស្តិ៍ ៤វគ្គ (៤0រណ្តៅ) | ១00នាក់ ស្រី ៥0នាក់ |
| ១.២ | វគ្គបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំកំចាត់សត្វល្អិត ៦វគ្គ | ១៨0នាក់/ស្រី ៨0នាក់ |
| ១.៣ | វគ្គបច្ចេកទេសដាំបន្លែ និងបង្ហាញ ៤វគ្គ ៤ បង្ហាញ | ១00នាក់/ស្រី ៥0នាក់ |
| ១.៤ | វគ្គបច្ចេកទេសកែប្រែគុណភាពដី និងធ្វើបង្ហាញ ៤វគ្គ បង្ហាញ និង៤ បង្ហាញ | ១00នាក់/ ស្រី៤៥នាក់ |

**ផ្នែក-ខ** : ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល ធៀបនឹងគោលបំណងបន្ទាន់ (ផលប៉ះពាល់ /លទ្ធផលបឋម រយៈពេលខ្លី/មធ្យមនៃលទ្ធផល) នៃអនុកិច្ចសន្យា

| |
|---|
| អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និង សកម្មភាពនានារបស់ អនុកិច្ចសន្យាដែលបានគ្រោងទុក ។ អ្នកចូលរួមទាំងអស់នៅក្នុងក្រុមពិភាក្សា ដែលជាសិក្ខាកាមពីវគ្គហ្វឹកហ្វឺន បច្ចេកទេសដំណាំបន្លែ បានរាយការណ៍ថាពួកគាត់បានទទួលនូវចំណេះដឹង និងជំនាញ ដែលទាក់ទងនឹងបច្ចេកទេសដាំបន្លែ ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺថា ពួកគាត់ |

នៅចាំទ្រីស្តី ខ្លះៗពីវគ្គហ្វឹកហ្វឺនបច្ចេកទេសដំណាំបន្លែ ទោះបីជាវគ្គនេះបានបញ្ចប់ទៅហើយក្តី ( ពីឆ្នាំ២០០៩) ។

សិក្ខាកាមភាគច្រើនចូលចិត្តវិធីសាស្ត្របណ្តុះបណ្តាលនិងអកប្បកិរិយារបស់អ្នកសម្របសម្រួល ។ វិធីសាស្ត្រផ្សេងៗជាច្រើន ត្រូវបានប្រើប្រាស់នៅក្នុងវគ្គហ្វឹកហ្វឺន រួមមានការបំផុសគំនិត ប្រើផ្ទាំងរូបភាព ក្រុមពិភាក្សាការអនុវត្តជាក់ស្តែង...។ ល ។ អ្នកសម្របសម្រួល អាចបន្សាំខ្លួនទៅនឹងបរិបទនៅសហគមន៍បានល្អ ជាពិសេសក្នុងពេលអនុវត្តជាក់ស្តែងជាមួយសិក្ខាកាម ធ្វើឱ្យចូលរួមកាន់តែមានការផុលផុល ។ ប៉ុន្តែគួរឱ្យស្តាយពេលអនុវត្តជាក់ស្តែងក៏នៅមានសិក្ខាកាមខ្លះអវត្តមាន ។

សរុបសេចក្តីមក វគ្គហ្វឹកហ្វឺននេះមានភាពទាក់ទងទៅនឹងតម្រូវការរបស់សិក្ខាកាម ហើយនិងសហគមន៍របស់ពួកគាត់ ។ អ្វីដែលសំខាន់ទៀតនោះ អ្នកចូលរួមនៅក្នុងការពិភាក្សាក្រុម បានគូសបញ្ជាក់ថាចំណេះដឹង និងជំនាញដែលទទួលបាន នឹងរួមចំណែកធ្វើឱ្យជីវភាពរបស់គាត់កាន់តែប្រសើរឡើង ។យើងសង្កេតឃើញថា អ្នកភូមិខ្លះបានចាប់ផ្តើមដាំបន្លែនៅក្នុងចំការ ហើយចំការខ្លះមានបន្លែល្អមអាចប្រមូលផល និង ចំការខ្លះកំពង់ប្រមូលផល ដែលធ្វើឱ្យគ្រួសារគាត់មានប្រាក់ចំណូលកើនឡើង ហើយកាត់បន្ថយការចំណាយនៅក្នុងគ្រួសារ ក៏ដូចជាធ្វើឱ្យគ្រួសារគាត់មានសុខភាពល្អប្រសើរឡើងថែមទៀត ។

## លទ្ធផលទី២: ការបង្ហាញ ផ្នែកនីតិកម្ម -កសិកម្ម

**ផ្នែក-ក :**

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ១.១ | ពង្រឹងសគមហនីពូជស្រូវតណេទានដោយសិក្ខាសាលា ១៤ លើក | ៥០០នាក់ ស្រី ២៥០នាក់ |

## លទ្ធផលទី៣:

**ផ្នែក-ក :**

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ១.១ | -វគ្គបណ្តុះបណ្តាលបច្ចេកទេសផលិតកម្មដំណាំស្រូវ ចំនួន៦វគ្គរយៈពេល១៥សប្តាហ៍ (១ សប្តាហ៍ រៀន១ថ្ងៃ) | ១៨០នាក់ ស្រី៧៦នាក់ |
| ១.២ | បច្ចេកទេសបណ្តុះ ផ្សិតដល់ បណ្តុះបណ្តាល និងធ្វើបង្ហាញ ចំនួន៨វគ្គ /៨ បង្ហាញ | ២០០នាក់ ស្រី ៨០នាក់ |

**លទ្ធផលទី៤ : ការបង្ហាញ និងចិញ្ចឹមសត្វ ( ជ្រូក មាន់ ចំណីសត្វ )**

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ១.១ | ពង្រឹងសហគមន៍ ចិញ្ចឹមគោ តាំងពី ឆ្នាំ២០០៤ និងរៀបចំ សហគមន៍ចំនួន ៨លើក | ៦០នាក់ |
| ១.២ | ពង្រឹងសហគមន៍ភ្នាក់ងារសុខភាពសត្វភូមិ ដោយប្រជុំ ៣ដង និងបំប៉ន ៤លើក | ៧២ នាក់ ស្រី៣នាក់ |

**លទ្ធផលទី៥ : ជ្រើសរើសកសិករ បណ្តុះបណ្តាល អោយក្លាយជាភ្នាក់ងារចិញ្ចឹមសត្វភូមិ**

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ១.១ | បណ្តុះបណ្តាលពីផលិតកម្ម និងបសុព្យាបាលភាពភ្នាក់ងារសុខភាពសត្វភូមិ ៣វគ្គរយះពេល៣០ថ្ងៃ | ៧២នាក់ ស្រី ៧នាក់ |
| ១.២ | បណ្តុះបណ្តាលការចិញ្ចឹមសត្វ ៨វគ្គ រយះពេល ៣ថ្ងៃ | ២៤០នាក់ ស្រី ៨០នាក់ |
| ១.៣ | ពង្រឹងភ្នាក់ងារពេទ្យសត្វភូមិ តាមរយះសិក្ខាសាលារួម នៅថ្នាក់ខេត្ត | ១២០នាក់ ស្រី ២០នាក់ |

## ២.២. ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម

### ផ្នែក-កៈ ការសម្រេចបាននូវស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា (សំណួរវាយតម្លៃទី២)

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា (១) | ស្ថានភាពជាក់ស្តែងនៅពេលបញ្ចប់ អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| កសិករសរុបចំនួន ១០០នាក់ ក្នុងនោះស្រី៥០នាក់មកពីឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ឃុំបឹងធំ ស្រុកអង្គស្នួល ទទួលបាននូវបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ ។ ពិសេសគឺកសិករចំនួន ៤០នាក់ ទទួលបានរណ្តៅជីម្នាក់មួយរណ្តៅ ។ | -ស្រុកកណ្តាលស្ទឹង : មាន២វគ្គ កសិករចូលរួម ៥១នាក់ ស្រី៣៤នាក់ អនុវត្តធ្វើរណ្តៅជី ២០កន្លែង និងទិវាបង្ហាញពីលទ្ធផលដែលសម្រេចបាន មានកសិករចូលរួម១០០នាក់ ក្នុងនោះ ស្រី៤២នាក់ ។<br>-ស្រុកអង្គស្នួលមាន២វគ្គកសិករចូលរួម៥០នាក់ ក្នុងនោះស្រី២៣នាក់អនុវត្តធ្វើរណ្តៅជី ២០កន្លែង និងទិវាបង្ហាញពីលទ្ធផល ដែលសម្រេចបានមានកសិករចូលរួម ១០០នាក់ ក្នុងនោះ ស្រី ១៩នាក់ ។ |
| កសិករចូលរួមសរុបចំនួន១៨០នាក់ ក្នុងនោះស្រី ៨០នាក់ ដែលមកពី ៦ឃុំ និង៦ស្រុកគោលដៅ ទទួលបាននូវការ បណ្តុះបណ្តាល អំពីបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំ គីមីកំចាត់សត្វល្អិតចំនួន៨វគ្គ ក្នុងមួយវគ្គរយៈពេល៣ថ្ងៃ | កសិករនៅក្នុងឃុំនៃស្រុកគោលដៅមានអ្នកចូលរួម ១៨២នាក់ ក្នុងនោះស្រី៥៨នាក់ ទទួលបាននូវការបណ្តុះបណ្តាល បច្ចេក-ទេស ប្រើប្រាស់ជីគីមី និងថ្នាំគីមី កំចាត់សត្វល្អិត។ |
| កសិករចូលរួមសរុបចំនួន ១០០នាក់ ក្នុងនោះស្រី ៥០នាក់ មកពី៤ឃុំ និង៣ស្រុកគោលដៅទទួលបាននូវបច្ចេកទេសដំណាំបន្លែចំនួន ៤វគ្គក្នុងមួយវគ្គ មានរយៈ-ពេល ៣ថ្ងៃ ព្រមទាំងមានការធ្វើបង្ហាញដល់កសិករក្នុងមួយវគ្គរយៈពេល៨ថ្ងៃ ។ | -ស្រុកកៀនស្វាយមាន ១វគ្គ កសិករចូលរួម ២៩នាក់ ក្នុងនោះស្រី ១១នាក់ និងទិវាធ្វើបង្ហាញពីលទ្ធផល កសិករចូលរួមចំនួន ៥០នាក់ ស្រី២០នាក់ ។<br>-ស្រុកមុខកំពូលមាន១វគ្គ កសិករចូលរួម២៥នាក់ ស្រី ០៩នាក់ និងទិវាធ្វើបង្ហាញពីលទ្ធផល កសិករចូលរួម ៥០នាក់ ស្រី ២០នាក់ ។ |

| | |
|---|---|
| | -ស្រុកស្អាងមាន២វគ្គ កសិករចូលរួម ៥២នាក់ ស្រី ១៦នាក់ និងទិវាធ្វើបង្ហាញពីលទ្ធផល កសិករចូលរួម ១០០នាក់ ស្រី ៣៩នាក់ ។ |
| កសិករទទួលបាននូវការបណ្តុះបណ្តាល និងឱ្យគាត់អនុវត្ត ធ្វើបង្ហាញចំនួន៤គ្រួសារមាន៤កន្លែង ។ កសិករចូលរួម ចំនួន ១០០នាក់ ស្រី៤៥នាក់ មកពី២ឃុំ ក្នុងស្រុក អង្គស្នួល ទទួលបាននូវបច្ចេកទេសកែប្រែគុណភាពដី ចំនួន៤វគ្គ ក្នុង១វគ្គរយៈពេល ៣ថ្ងៃ និងធ្វើបង្ហាញដល់ កសិករ ១វគ្គរយៈពេល៣ថ្ងៃ ។ | -ឃុំឆក់ឈើនាងមាន២វគ្គ កសិករចូលរួមចំនួន៥២នាក់ ស្រី២៥នាក់ និងធ្វើបង្ហាញពីលទ្ធផលកសិករចូលរួម១០០នាក់ ស្រី២៤នាក់ ។<br><br>-ឃុំដំណាក់អំពិលមាន២វគ្គ កសិករចូលរួម ៥៣នាក់ ស្រី៣៤នាក់ និងធ្វើបង្ហាញពីលទ្ធផលមានកសិករចូលរួម ១០០នាក់ ស្រី៥៧នាក់ |
| កសិករទទួលបាននូវការបណ្តុះបណ្តាល និងឱ្យគាត់អនុវត្តធ្វើបង្ហាញ ៨គ្រួសារ មាន៨កន្លែង ។ កសិករចូលរួម២០០នាក់ស្រី៨០នាក់មកពី៨ឃុំ និង៣ស្រុកគោលដៅទទួលបាននូវបច្ចេកទេសបណ្តុះផ្សិតចំនួន៨វគ្គ ក្នុង១វគ្គមានរយៈពេល៣ថ្ងៃ ។ | -ស្រុកកោះធំមាន៣វគ្គ ក្នុង១វគ្គរយៈពេល៦ថ្ងៃ កសិករចូលរួម ៧៥នាក់ ស្រី១២នាក់ និងទិវាធ្វើបង្ហាញពីលទ្ធផលមានកសិករ ចូលរួម ៧៥នាក់ ស្រី១២នាក់ ។<br><br>- ស្រុកស្អាង មាន៣វគ្គ ១វគ្គរយៈពល៦ថ្ងៃ កសិករចូលរួម៧៥នាក់ ស្រី១៦នាក់ និងធ្វើទិវាបង្ហាញពីលទ្ធផលមានកសិករចូលរួម ៧៥នាក់<br><br>-ស្រុកអង្គស្នួលមាន២វគ្គ ក្នុង១វគ្គរយៈពេល៦ថ្ងៃ កសិករចូលរួមចំនួន ៥០នាក់ ស្រី១នាក់ និងធ្វើទិវាបង្ហាញពីលទ្ធផលមានកសិករចូលរួម ៥០នាក់ ស្រី១នាក់។ |
| ពេទ្យសត្វភូមិ ៧២នាក់ស្រី០៣នាក់ ដែលបានបណ្តុះបណ្តាលរួចធ្វើការបណ្តុះបណ្តាលបំប៉នបន្ថែម អំពីបច្ចេកទេសចិញ្ចឹមសត្វនិងការប្រើប្រាស់ថ្នាំព្យាបាល ដោយប្រជុំ ៣ខែម្តង និងបំប៉ន៤វគ្គមានរយៈពេល២ថ្ងៃ | ប្រជុំពង្រឹងសហគមន៍ភ្នាក់ងារសុខភាពសត្វភូមិ ៣ខែម្តង និងបំប៉ន ៨លើក មានសិក្ខាកាមចូលរួម ២៩៧នាក់ ស្រី១៤នាក់ ។ |
| កសិករ៧២នាក់ ស្រី០៧នាក់ នៅស្រុកគោលដៅ (លើកដែកល្វាឯមនិងកោះធំ) ទទួលបាននូវការបណ្តុះបណ្តាល | ស្រុកគោលដៅដែលបានចុះកិច្ចសន្យា ត្រូវបានអនុវត្តនូវវគ្គបណ្តុះបណ្តាល និងហ្វឹកហ្វឺនពេទ្យសត្វភូមិថ្មី មាន |

| | |
|---|---|
| ពីផលិតកម្ម និងបសុព្យាបាលឱ្យក្លាយជាភ្នាក់ងារសុខភាពសត្វភូមិថ្មីមានចំនួន៣វគ្គ ក្នុងមួយវគ្គរយៈពេល ៣០ថ្ងៃ ។ | សិក្ខាកាមចូលរួម៧៤នាក់ ស្រី០៧នាក់ ។ |
| កសិករចំនួន ៤០នាក់ ស្រី៨០នាក់នៅ ៨ឃុំ និង៤ស្រុកគោលដៅមាន ៨វគ្គរយៈពេល៣ថ្ងៃទទួលបាននូវការបណ្តុះបណ្តាល បច្ចេកទេសចិញ្ចឹមសត្វ ។ | កសិករចំនួន ២៤០នាក់ ស្រី៦៨នាក់នៅក្នុងឃុំ ស្រុកគោលដៅ ទទួលបាននូវការបណ្តុះបណ្តាល បច្ចេកទេសចិញ្ចឹមសត្វ ។ |

## ផ្នែក-ខ: ការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា

| ធាតុនៃគោលបំណងបន្ទាន់ (១) | ការសម្រេចបានជាក់ស្តែង នៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| នៅចុងឆ្នាំ២០០៩ ភ្នាក់ងារសុខភាពសត្វភូមិត្រូវបានពង្រឹង និងបណ្តុះបណ្តាលពីបច្ចេកទេសផលិតកម្ម និងបសុព្យាបាល ដើម្បីមានលទ្ធភាពអនុវត្តក្នុងការងារកាន់តែល្អប្រសើរ។ ពិសេសទៅទៀតនោះប្រជាកសិករដែលទទួលការបណ្តុះបណ្តាលអំពីបច្ចេកទេសនិងចំណេះដឹងថ្មីៗដើម្បីបង្កើនទិន្នផល និងផលិតផលកសិកម្ម ដូចជាទិន្នផលស្រូវ ការដាំដំណាំបន្លែ ការចិញ្ចឹមសត្វ ដើម្បីបង្កើនប្រាក់ចំណូលប្រចាំគ្រួសារ ។ | គោលបំណងបន្ទាន់ដែលចែងក្នុងអនុកិច្ចសន្យាមាន ការរំពឹងទុកថា សកម្មភាព និង លទ្ធផលទាំងអស់ ត្រូវបានអនុវត្ត។ ក្រោយពេលពិនិត្យលើឯកសារ និងវិធីសាស្ត្រ វាយតម្លៃបែបគុណភាព យើងអាចវាយតម្លៃ បានថាការអនុវត្តនេះសម្រេចបាន ទៅតាមលទ្ធផលនិងសកម្មភាពដែលបានចែងនោះ ។ |

# ករណីសិក្សា

## ករណីសិក្សាទី ១

លោក សៀក រ៉ុង មានជីវភាពល្អប្រសើរចាប់តាំងពីគាត់បានក្លាយខ្លួនជាសមាជិកសហគមន៍ (ពាមសាលា) គាត់ជាអ្នកទទួលផលនៃគំរោងកែលំអរជីវភាព និងគ្រប់គ្រងធនធានធម្មជាតិ នៃគ.អ.ជ.ប នៃស្រុកស្អាង ឃុំស្អាងភ្នំ ខេត្តកណ្តាល ។



លោក សៀក-រ៉ុង ប្រពន្ធរឿង-សារឹម

ក្រោយពីបានចូលរួមគណៈកម្មាធិការសហគម៍ (ពាមសាលា) នៅក្នុងស្រុកស្អាង ខេត្តកណ្តាល លោកសៀក រ៉ុងបាននិយាយថាៈ "បច្ចុប្បន្ននេះ អាហារ ប្រចាំថ្ងៃរបស់យើងមានគ្រប់គ្រាន់ ហើយកូនរបស់គាត់ អាចទៅសាលាបាន។ នេះជាសំដី លោកពូ សៀក រ៉ុង ដែលគាត់ទទួលជំនាញពីរមន្ទីរកសិកម្មពីការបណ្តុះបណ្តាល ស្តីពីដំណាំបន្លែនៃគំរោង កែលំអជីវភាព និង គ្រប់គ្រងធនធានធម្មជាតិនៃគ.ជ.អ.ប លោក សៀក រ៉ុង និងប្រពន្ធរបស់គាត់ ឈ្មោះ រឿង សារឹម គាត់បានរៀបការ តាំងពី ឆ្នាំ១៩៨៤ គាត់មានកូន នៅក្នុងបន្ទុកចំនួន ៦នាក់ មាន ប្រុស ៣នាក់ ស្រី៣ នាក់ គាត់មានការលំបាកណាស់ ក្នុងការចិញ្ចឹមកូន ។ តែមកដល់ពេលនេះគាត់បានការកូនចំនួន ៣ នាក់ហើយ គាត់ទទួលបានចៅ ៦ នាក់នៅសល់ កូន៣នាក់ក្នុងបន្ទុករបស់គាត់ឃើញថាជីវភាពរបស់គាត់ មានភាព ធូរធារច្រើន ។

## ករណីសិក្សាទី២ : អ្នកមិនបានទទួលផល

លោក ស៊ឹ គុណ អាយុ ៤៥ឆ្នាំ ។ គាត់មានប្រពន្ធ និង មានកូន៥នាក់ ( ស្រី ៣នាក់ និង ប្រុស២នាក់ ) គាត់រស់នៅក្នុងភូមិ ពាមសាលា ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ។គាត់ជាកសិករដែលមានចំណូលពីការ ធ្វើស្រែ ចិញ្ចឹមសត្វ និង ដាំបន្លែ ។

លោក ស៊ឹ គុណ មិនត្រូវបានចូលរួមក្នុងវគ្គហ្វឹកហ្វឺនបច្ចេកទេសដំណាំបន្លែ របស់គ.អ.ជ.ខ ខេត្តកណ្តាលទេ គាត់មិន ត្រូវបានជ្រើសរើសឱ្យចូលរួម ដោយសារគាត់មិននៅផ្ទះ រវល់នាំកូនទៅព្យាបាលជម្ងឺនៅមន្ទីរពេទ្យ នៅពេល ប្រធានភូមិ ចុះមកជ្រើសរើសអ្នកចូលរួម។ គាត់និយាយថា វគ្គហ្វឹកហ្វឺនបច្ចេកទេសដំណាំបន្លែនេះ មានសារៈសំខាន់ ណាស់ព្រោះគាត់ឃើញ អ្នកជិតខាងរបស់គាត់ ដែលបានចូលរួមវគបណ្តុះបណ្តាល ទទួល បានចំណេះដឹង និង ជំនាញក្នុងការដាំបន្លែ និងទទួលបានទិន្នផលខ្ពស់ ។ គាត់បានបន្ថែមទៀតថា ឥឡូវនេះ អ្នកដែល បានទទួល ការបណ្តុះបណ្តាលដាំបន្លែបានច្រើនជាងមុន សម្រាប់ហូប និងលក់ ព្រមទាំងមាន ចំណូលបន្ថែម ពីការលក់បន្លែ ។ គាត់បានលើកឡើងថា បច្ចុប្បន្ន ពួកគេអាចសន្សំប្រាក់បាន ២.000រៀល ក្នុងមួយថ្ងៃ ព្រោះ ពួកគាត់មិនចាំបាច់ទិញ បន្លែពីផ្សារ ។ ម្យ៉ាងទៀត គាត់បាននិយាយថា បន្លែដែលដាំ ដោយខ្លួនឯងតាមផ្ទះ មានសារៈ ប្រយោជន៍ ចំពោះសុខភាពគ្រួសារ ដោយសារមិនបានប្រើជាតិគីមី ។ សព្វថ្ងៃគាត់បានទទួលនូវការយល់ដឹងខ្លះៗ ពីអ្នកដែលបាន ចូលរួមវគ្គ ហើយគាត់បានអនុវត្តតាមអ្នកជិតខាង ក្នុងការដាំបន្លែនេះ និងទទួលបាន ទិន្នផល គ្រាន់បើដែរ ប៉ុន្តែ គាត់ត្រូវការការបណ្តុះបណ្តាលក្នុងវគ្គបច្ចេកទេស។ លោក ស៊ឹ គុណ មានសង្ឃឹមថា នឹងអាចបាន ចូលរួមវគ្គ ហ្វឹកហ្វឺនអំពីបច្ចេកទេសដាំបន្លែរបស់គម្រោង ក្នុងពេលអនាគត និងទទួលបាននូវផលប្រយោជន៍ ដូចអ្នកជិតខាង របស់គាត់ ។ នៅចុងបញ្ចប់ គាត់ទទួចឱ្យអង្គការ និងភ្នាក់ងារនានាជួយអភិវឌ្ឍន៍ភូមិរបស់គាត់ ។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤)

**សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខ័ណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើ របាយការណ៍ និងការកត់ត្រាឯកសារះ**

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.ជ.អ.ខះ** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | គួរតែពង្រឹងបន្ថែម ហើយមានគាំទ្រ ទៅលើបច្ចេកទេស និងជំនាញច្បាស់លាស់ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យការអនុវត្តន៏របស់ភ្នាក់ងារអនុវត្តន៏ | មិនមានការប្រឈម ឬឧបសគ្គអ្វីគួរអោយកត់សំគាល់ ទេ ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា | ធ្វើទៅតាមការគ្រោងរបស់អនុកិច្ចសន្យា ការកត់ត្រា និងរក្សាទុកឯកសារ គួរតែមានការកែលំអរ ។ |
| **ពីខាងភាគីអនុវត្តន៍កិច្ចសន្យាះ** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | បុគ្គលិកជំនាញ មានបទពីសោធន៏គ្រប់គ្រាន់ ក្នុងការបំពេញការងារ ។ |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | គ្រប់សកម្មភាព និងលទ្ធផល ទាន់ពេលវេលាដូចការគ្រោងទុកទៅតាមអនុកិច្ចសន្យា ។ |
| ៦ | ការរាយការណ៍ការរីកចំរើន និង ការកត់ត្រាឯកសារ | ដូចតាមទំលាប់ និងអនុកិច្ចសន្យាដែលបានធ្វើ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | តាមលក្ខណ័ក្នុងកិច្ចសន្យា ត្រូវបានបំពេញ |

## ២.៤. សេចក្តីសន្និដ្ឋាន

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | គួរត្រូវមានសកម្មភាពតាមដានវាយតម្លៃ និងធ្វើការគាំទ្របន្ត នៅពេលគម្រោងត្រូវបានបញ្ចប់ ដើម្បីបន្តនិរន្តរភាព គម្រោងធានាបាននូវផលប្រយោជន៍របស់សហគមន៍ ។ |
| ២ | ការជ្រើសរើសសកម្មភាពនៃអនុកិច្ចសន្យាស្របទៅតាមតំរូវការជាក់ស្តែងក្នុងមូលដ្ឋាន ក៏ដូចជាសក្តានុភាពនៃលក្ខណៈភូមិសាស្រ្ត ហើយភ្នាក់ងារអនុវត្តធ្វើការជ្រើសរើសសិក្ខាកាម ជាអ្នកទទួលផល គឺចំគោលដៅរបស់ប្រជាជន ។ |
| ៣ | បន្ទាប់ពីអនុកិច្ចសន្យាត្រូវបានបញ្ចប់ ការដាំដំណាំបន្លែក៏ត្រូវបានបន្តនិរន្តរភាព ដោយត្រូវបានប្រើប្រាស់ចំណេះដឹង ជំនាញ បច្ចេកទេសដែលទទួលបានពីវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ រួមទាំងបទពិសោធន៍ ក៏ដូចជាលក្ខណៈភូមិសាស្រ្តផងដែរ ។ |
| ៤ | ទទួលបានចំណេះដឹងបច្ចេកទេស ធ្វើឱ្យដំណាំបន្លែមានការកើនឡើង ឆ្លើយតមតាមតំរូវការទីផ្សារ ប្រាក់ចំណូល កើនឡើង ធ្វើឱ្យមានជីវភាពធូធាររួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ |
| ៥ | ត្រូវបានកាត់បន្ថយជាបណ្តើរៗនូវការប្រើប្រាស់ជីគីមី និងថ្នាំកំចាត់សត្វល្អិតបំផ្លាញដំណាំ ប្តូរមកប្រើប្រាស់ជីធម្មជាតិវិញ ។ |
| ៦ | ប្រជាជនមានការគាំទ្រដោយក្តីរីករាយនូវគំរោងនេះដែលធ្វើឱ្យគាត់កែប្រែជីវភាពជាបណ្តើរ ។ |
| ៧ | ការអនុវត្តសកម្មភាពដំណាំបន្លែដំណើរការរលូនមិនមានជួបប្រទះបញ្ហាប្រឈមឬក៏ឧបសគ្គគួរគត់សំគាល់ទេ |

ចំណុចរៀនសូត្រៈ

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | សកម្មភាពនីមួយៗក្នុងអនុកិច្ចសន្យា បានធ្វើការជ្រើសរើសផ្អែកតាមលក្ខខ័ណ្ឌនៃការណែនាំ ហើយឆ្លងតាមការ ប្រជុំ អនុម័ត ពី គ.អ.ជ.ខ ដែលធ្វើឱ្យសកម្មភាពទាំងអស់សមស្របតាមគោលដៅ របស់អ្នកទទួលផល។ |
| ២ | .ភ្នាកងារអនុវត្តត្រូវបានចាត់តាំងមន្រ្តីបង្គោលសំរាប់អនុវត្តអនុកិច្ចសន្យា ។ |
| ៣ | ក្នុងដំណើរការអនុវត្តសកម្មភាពគឺត្រូវបានធ្វើការតាមដានត្រួតពិនិត្យ ជាប្រចាំ ផ្អែកតាមប្រតិទិនការងារប្រចាំខែ |

**អនុសាសន៍ :**

| ល.រ | អនុសាសន៍ |
|---|---|
| ១ | គួរត្រូវបានធ្វើការលើកវគ្គបច្ចេកទេសដំណាំបន្លែនេះបន្តទៀតក្នុងការឆ្លើយតបតាមតំរូវការចាំបាច់របស់ ។ |
| ២ | គួរត្រូវមានសកម្មភាពតាមដានវាយតម្លៃ និងធ្វើការគាំទ្របន្ត នៅពេលគម្រោងត្រូវបានបញ្ចប់ ដើម្បីបន្តនិរន្តរភាព គម្រោងធានាបាននូវផលប្រយោជន៍របស់សហគមន៍ ។ |

## ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

**ឯកសារដែលត្រូវភ្ជាប់ទី១ : បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបានពិនិត្យ**

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) |
|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និង ឯកសារវិសោធនកម្ម |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ |
| ៣ | របាយការណ៍ត្រួតពិនិត្យគម្រោង |
| ៤ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា |
| ៥ | លិខិតឆ្លើយឆ្លងរវាងភ្នាក់ងារអនុវត្តន៍ និងគណៈកម្មាធិការប្រត្តិបត្តិគ.អ.ជ.ខ |
| ៦ | បញ្ជីវគ្គបណ្តុះបណ្តាលដែលមានក្នុងអនុកិច្ចសន្យា |
| ៧ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា |

## ឯកសារដែលត្រូវភ្ជាប់ទី២ :

## បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាស/ជួបពិភាក្សា

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៍ប្រើសម្រាប់ប្រមូលទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | កញ្ញា | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ<br>លោក សំ-សុវណ្ណ គ្រូបណ្តុះបណ្តាល | មន្ទីរកសិកម្ម<br>ខេត្តកណ្តាល | សម្ភាសន៍ស៊ីជម្រៅ |
| ២ | កញ្ញា | មន្ត្រីទទួលខុសត្រូវ<br>- លោក ប៊ុន ទូនស៊ីបូណា | មន្ទីរកសិកម្ម<br>ខេត្តកណ្តាល | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | កញ្ញា | ក្រុមអ្នកទទួលផល | ភូមិ ព្រែកខ្មែរ | សម្ភាសន៍ជាក្រុម |
| ៤ | កញ្ញា | អ្នកទទួលផលផ្ទាល់<br>- លោក ទៀង-រ៉ុង | ភូមិព្រែកខ្មែរ | សម្ភាសន៍ស៊ីជម្រៅ/ករណីសិក្សា |
| ៥ | កញ្ញា | អ្នកមិនបានទទួលផល<br>- លោក សំ-គុណ | ភូមិព្រែកខ្មែរ | សម្ភាសស៊ីន៏ជម្រៅ/ករណីសិក្សា |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | 09/GEN/0901-01(GOV) |
| ចំណងជើង : | គាំទ្រការបញ្ជ្រាបយេនឌ័រ |
| ភ្នាក់ងារអនុវត្តន៏ : | មន្ទីរកិច្ចការនារី |
| រយៈពេល (ចាប់ផ្តើម និងបញ្ចប់) | ០១ មករា ឆ្នាំ ២០០៩ ដល់ ៣១ ធ្នូ ២០០៩ |
| រាជធានី ខេត្ត | កោះកុង |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរកិច្ចការនារី |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ/គ.អ.ជ.ខ | ៦៩២៥ ដុល្លា |
| ការរួមចំណែករបស់ដៃគូរអភិវឌ្ឍន៏ដ៏ទៃទៀត | ៥០០ ដុល្លា |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | ៧៤២៥ ដុល្លា |

## ក្រុមវាយតម្លៃ:

| ឈ្មោះ | មុខតំណែង |
|---|---|
| លោកស្រី សរ ស៊ីមអ៊ីម | ប្រធានមន្ទីរកិច្ចការនារីខេត្ត |
| លោកស្រី ចេង វន្នី | ក្រុមប្រឹក្សាស្រុកមណ្ឌលសីមា ជាលេខា |
| លោក ស្រី យិន សារ៉ាត | មន្ត្រីអនុវត្តន៏គំរោងមន្ទីរកិច្ចការនារី ជាសមាជិក |
| កញ្ញា យ៉ាន់ សុផាន់ | មន្ត្រី មន្ទីរអប់រំ ជាសមាជិក |
| លោក ង៉ិន ប៊ុនធឿន | មន្ត្រី ME គ.ប្រ ជាសមាជិក |
| លោក ធីវ គានថាវ | មន្ត្រី ME គ.ប្រ ជាសមាជិក |
| លោក ឈាង សេងយន់ | មន្ត្រីបង្គោលមន្ទីរ កសិកម្ម ជាសមាជិក |
| លោក គង់ ប៊ុណ្ណា | ទីប្រឹក្សា PMESA និងជាអ្នកជួយសម្របសម្រួល |

# របាយការណ៍ ស្តីពីការវាយតម្លៃ រៀបចំដោយៈ

| ឈ្មោះ | មុខតំណែង |
| --- | --- |
| លោកស្រី ចេង វន្ទី | អ្នករៀបចំនិងសរសេររបាយការណ៍ |
| លោក ងិន ប៊ុនធឿន | អ្នករៀបចំនិងសរសេររបាយការណ៍ |
| កញ្ញា យ៉ាន់ សុផាន់ | រួមសហការ |
| លោក ធីវ គានថាវ | រួមសហការ |
| លោក គង់ ប៊ុណ្ណា | ផ្តល់ប្រឹក្សា និង ជួយសម្របសម្រួល |

## ខេត្តៈកោះកុង

ខែតុលា ឆ្នាំ ២០១០

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៤ |
| | របាយការណ៍សង្ខេប | ៥ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៨** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៨ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៨ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៨ |
| ១.៤ | សំណួរវាយតម្លៃ | ៩ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ៩ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ១០ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១២** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល(សំណួរវាយតម្លៃទី១) | ១២ |
| | - លទ្ធផលទី២ | ១២ |
| | - លទ្ធផលទី៥ | ១៤ |
| ២.២ | ការវាយតម្លៃការសម្រេចបាននូវអត្ថប្រយោជន៍ភ្លាមៗ | ១៥ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង | ២១ |
| ២.៤ | សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី៥) | ២៤ |
| **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍** | | ២៦ |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ២៦ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍/ពិភាក្សា | ២៧ |
| **ករណីសិក្សា** | | |
| ទី១- | អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគំរោងបណ្តុះបណ្តាលជំនាញកែឆ្នៃចំណីអាហា និងវត្ថុផ្សព្វផ្សាយ យេនឌ័រ | ១៨ |
| ទី២- | អ្នកមិនទទួលផលពីអនុកិច្ចសន្យា | ២០ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

## គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ :

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ ខេត្តកោះកុង បានធ្វើការវាយតម្លៃ អនុកិច្ចសន្យា ដែលមានចំណងជើងថា "ការគាំទ្រដល់ការបញ្ជ្រាបយេនឌ័រ" លេខ 09/GEN/0901-01(GOV) ដែលជាអនុកិច្ចសន្យាធ្វើឡើងរវាង គ.ប្រ នៃ គ.អ.ជ.ខ ខេត្តកោះកុង និងមន្ទីរកិច្ចការនារី ។ នេះជាផ្នែកមួយ នៃគម្រោងពង្រឹង សមត្ថភាពគ្រូបង្គោលថ្នាក់ក្រោមជាតិ របស់ផ្នែកត្រួតពិនិត្យវាយតម្លៃ និងផ្សព្វផ្សាយ គោលនយោបាយ នៃលេខាធិ ការដ្ឋាន គ.ជ.អ.ប ដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ តាមរយៈវិមជ្ឈការនិងវិសហមជ្ឈការ ។

## គោលបំណងជាក់លាក់នៃការវាយតម្លៃនេះគឺ :

- ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និង ចំណុចខ្សោយ ធៀប ទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំងកត់ត្រា នូវចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត ។
- ពង្រឹងរបៀបធ្វើការវាយតម្លៃគម្រោងរបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងដំណើរការអនុវត្ត ។

ការវាយតម្លៃ អនុវត្តតាមការណែនាំ និងឧបករណ៍ ស្តីពីការវាយតម្លៃអនុកិច្ចសន្យារបស់គណៈកម្មាធិការ ប្រតិបត្តិនៃ គ.អ.ជ.ខ ដែលរៀបចំដោយផ្នែកត្រួតពិនិត្យ និងវាយតម្លៃនៃលេខាធិការដ្ឋាន គ.ជ.អ.ប ។ ក្រុមការងារ វាយតម្លៃបានប្រើការពិភាក្សាក្រុម ការសម្ភាសស៊ីជម្រៅ ការចុះមូលដ្ឋាន គន្លឹះក្នុងការសង្កេតផ្ទាល់ និងរំលឹកឯកសារ អនុកិច្ចសន្យា របាយការណ៍រីកចម្រើន និងឯកសារផ្សេងៗ ទៀត ។

អាស្រ័យដោយធនធាន/ពេលវេលា និងសមត្ថភាពការងារវាយតម្លៃរបស់ក្រុមការងារមានកំណត់/ក៏រិត ក្រុម ការងារសម្រេចធ្វើការសិក្សាវាយតម្លៃដោយស៊ីជម្រៅទៅលើតែលទ្ធផលចំនួន២ប៉ុណ្ណោះ ចំណែកឯលទ្ធផលដ៏ទៃផ្សេង ទៀតត្រូវបានសិក្សាវាយតម្លៃ ដោយផ្អែកលើព័តិមានដែលមានស្រាប់ ។ដូច្នេះការវាយតម្លៃនេះមិនមែនជាការវាយ តម្លៃស៊ីជម្រៅទៅលើអនុកិច្ចសន្យាទាំងមូលនោះទេ ចំណែកឯការសន្និដ្ឋានវិញទៀតសោតក៏ត្រូវបានធ្វើឡើងទៅតាម តែអ្វី ដែលបានរកឃើញប៉ុណ្ណោះ ។

**ឆ្លើយទៅនឹងសំណួរទាំង៥ នៃការវាយតម្លៃ :**

១-សកម្មភាពទាំងអស់ត្រូវបានអនុវត្ត និងលទ្ធផលសម្រេចបានតាមផែនការ

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១ | វគ្គបណ្តុះបណ្តាលជំនាញកែឆ្នៃចំណីអាហារដល់ប្រជាពលរដ្ឋនៅឃុំប៉ាកខ្លង ចំនួន១៥នាក់រយៈពេល៧ថ្ងៃ | អ្នកចូលរួមចំនួន ១៥នាក់ |
| ២ | វគ្គផ្សព្វផ្សាយការបញ្ជ្រាបយេនឌ័រដល់ប្រជាពលរដ្ឋនៅភូមិប៉ាកខ្លងចំនួន៣០ នាក់ រយៈពេល១ ថ្ងៃ | អ្នកចូលរួមចំនួន ៣០នាក់ |
| ៣ | ការប្រជុំពង្រឹងការបញ្ជ្រាបយេនឌ័រដល់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ នៅឃុំប៉ាកខ្លងចំនួន២០នាក់រយៈពេល១ថ្ងៃ | សមាជិកគណៈកម្មាធិការ គ.ក.ន.ក ចំនួន ២០ នាក់ ត្រូវបានចូលរួម |

២-វគ្គផ្សព្វផ្សាយស្តីពីយេនឌ័រ ដល់ប្រជាពលរដ្ឋនៅឃុំប៉ាកខ្លង និងការប្រជុំពង្រឹងការបញ្ជ្រាបយេនឌ័រ ដល់សមាជិកគណៈកម្មាធិការទទួលបន្ទុកនារីនិងកុមារនៅឃុំប៉ាកខ្លង មានប្រសិទ្ធភាពខ្ពស់ណាស់ពីព្រោះបុរសស្រ្តី មួយចំនួននៅក្នុងឃុំ ចាប់ផ្តើមផ្លាស់ប្តូរទម្លាប់ និង ការប្រព្រឹត្តរបស់ពួកគាត់ ដូចជាអំពើហឹង្សា ក្នុងគ្រួសារ ត្រូវបានកាត់បន្ថយ ដោយសារ ពួកគាត់ចេះមានការអៀនខ្មាស់ យល់ដឹងអំពីច្បាប់ សិទ្ធនិងតួនាទីមនុស្សម្នាក់ៗមិនថាបុរស ឬ ស្រ្តី។ ជនប្រព្រឹត្តខុស ត្រូវបានកោះហៅ មកទទួលការណែនាំ ឬ ទទួលខុសត្រូវនៅចំពោះ ច្បាប់ជាធរមាន។ នៅពេលមាន បញ្ហាទាក់ទង ទៅនិងបញ្ហាស្រ្តីនិងកុមារ ពួកគាត់ដឹងពីមធ្យោបាយ ទីកន្លែង ឬ អ្នកដែលអាចជួយដោះស្រាយបាន។ ស្ថានភាពស្រ្តី មានភាពរីកចំរើនជាងមុន ព្រោះពួកគាត់ចូលចិត្ត ចូលរួមស្តាប់ការប្រជុំ ការផ្សព្វផ្សាយ វេទិកាផ្សេងៗ ពិសេសទាំង បុរសនិងស្រ្តី ពួកគាត់មានចំណាប់អារម្មណ៏ច្រើន ក្នុងការចូលរួមក្នុងកិច្ចដំណើរការ កសាងកម្មវិធីវិនិយោគឃុំសង្កាត់ ដើម្បី មានឱកាសលើកឡើងពីបញ្ហា/តម្រូវការនានា របស់ពួកគាត់ដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍមូលដ្ឋានរបស់ ខ្លួន ដែលខុសពីមុន ពួកគាត់មិនខ្វល់ពីការចង់ដឹង ចង់ឮ ចង់ចេះ អ្វីក្រៅតែពី ប្រឹងព្យាយាមប្រឈមនិងបញ្ហានានា ដែលគួរឱ្យកើតមាន។ ស្រ្តីមានផ្ទៃពោះបានទៅពិនិត្យផ្ទៃពោះ និងសម្រាលកូននៅមណ្ឌលសុខភាពបានចំនួនច្រើន ជាងមុន។ ចំនួនសិស្សស្រីដែលបោះបង់ចោលការសិក្សាបានថយចុះជាងឆ្នាំមុនៗ។

៣-លទ្ធផលបន្ទាន់ និងផលប្រយោជន៏ពីវគ្គបណ្តុះបណ្តាល ជំនាញកែឆ្នៃចំណីអាហារ ពិបាកធ្វើការវាយតម្លៃ ពីព្រោះ អាចមិនសូវទទួលបានប្រសិទ្ធភាព ដោយសារមានតែស្រ្តី៥នាក់ ក្នុងចំណោមស្រ្តីក្រីក្រទាំង១៥នាក់ ដែលបានយក ចំណេះដឹងនេះទៅប្រកបរបររកស៊ី ប៉ុន្តែមិនយូរប៉ុន្មានក៏បានបោះបង់ចោលរបរនោះទៅវិញ ដោយសារទំនិញ /

គ្រឿង ផ្សំ ឬ វត្ថុធាតុដើមចេះតែឡើង (នៅពេលធ្វើរួចលក់តម្លើងថ្លៃបន្តិចតាមតម្លៃទីផ្សារលក់មិនដាច់ បើលក់ដូចតម្លៃមុន ធ្វើឱ្យខាតដើម)។

៤-អនុកិច្ចសន្យាពិតជាបានចូលរួមចំណែកក្នុងការសម្រេចនូវគោលបំណងបន្ទាន់ ដោយសារអ្នកទទួលផលបានយកនូវចំណេះដឹង ដែលគេបានទទួលទៅប្រែក្លាយស្ថានភាពនិងជីវភាពរស់នៅ របស់ពួកគាត់ឱ្យមានភាពល្អប្រសើរឡើង បើទោះ ជាក្នុងកម្រិត និងដែនកំណត់នេះក៏ដោយ។

៥-អនុកិច្ចសន្យានេះពិតជាមានភាពពាក់ព័ន្ធ ប្រសិទ្ធភាព និងប្រសិទ្ធផល ទាក់ទងនឹងធនធានដែលមានការប្រតិបត្តិ និង ការគ្រប់គ្រងទូទៅ។ ប៉ុន្តែគុណភាពនៃការរៀបរៀងអនុកិច្ចសន្យាគួរតែត្រូវកែលំអដូចខាងក្រោម:

ក-បរិយាយអោយបានច្បាស់លាស់ និងអាចវាស់វែងបាន នូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា និង គោលបំណងបន្ទាន់។

ខ- ការប្រើប្រាស់សូចនាករជោគជ័យធៀបនឹងទិន្នន័យមូលដ្ឋាន។

គ- ភ្ជាប់ទំនាក់ទំនងអោយបានច្បាស់រវាងលទ្ធផល និងគោលបំណងបន្ទាន់ និងគោលបំណងកម្រិតខ្ពស់។

**សេចក្តីសន្និដ្ឋាន:**

១- លទ្ធផលនិងអត្ថប្រយោជន៍នានា ដែលបានកើតចេញពីការអនុវត្តន៍អនុកិច្ចសន្យា គឺពិតជាបានផ្តល់ផលប្រយោជន៍ដល់សហគមន៍ ។ មានការអះអាងនិងបង្ហាញច្បាស់ ពីក្រុមអ្នកទទួលផលដោយផ្ទាល់ និងមិនផ្ទាល់នៅក្នុងឃុំនៃគម្រោង ។ ឧទាហរណ៍ស្ត្រីមេផ្ទះ ដែលធ្លាប់តែរស់នៅដោយសារប្តី បានប្រែក្លាយទៅជាអ្នក ដែលមានលទ្ធភាពអាចរកប្រាក់ចំណូលបាន ជាមួយនិងលទ្ធភាពដែលអាចឆ្លៀតយកពេលវេលាខ្លះ ស្ម័គ្រចិត្តចូលរួមធ្វើជាអ្នកទ្រទ្រង់ សុខភាពភូមិទៀតផង។បញ្ហារបស់នារីនិងកុមារត្រូវបានលើកកម្ពស់ និងយកចិត្តទុកដាក់ខ្ពស់ពីអាជ្ញាធរនិងស្ថាប័ន ពាក់ព័ន្ធ ពិសេសគឺគណៈកម្មាធិការ គ.ក.ន.ក។ អំពើហឹង្សាក្នុងគ្រួសារ ត្រូវបានកាត់បន្ថយ,ការជួញដូរនិងការ រំលោភ/បំពានទៅលើស្ត្រីនិងកុមារត្រូវបានទប់ស្កាត់...។

២- គួរបន្តការគាំទ្រ ឬ ពង្រីកសកម្មភាពគម្រោងបែបនេះជាបន្តទៀត។

៣- គួរមានការ ជ្រើសរើស អ្នកទទួលផលអោយបានសមស្រប។

៤- ដើម្បីពង្រឹងនូវគុណភាពនិងភាពទាក់ទងរបស់គម្រោងគួរមានការបរិយាយអោយបានច្បាស់លាស់ នូវស្ថានភាពចុងបញ្ចប់ នៃកិច្ចសន្យា និងគោលបំណងបន្ទាន់ របស់គម្រោងក៏ដូចជាពង្រឹងនូវទំនាក់ទំនងតក្ករវាងធាតុខាងលើទៅនឹងលទ្ធផល។

៥- ផ្នែករដ្ឋបាលនិងគ្រប់គ្រងអនុកិច្ចសន្យា គួរធ្វើការវាយតម្លៃគម្រោងស្រដៀងគ្នានេះអោយបាន១ឬ២អនុកិច្ចសន្យាជាប្រចាំ។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្តល់ថវិកាតាមរយៈ គ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និងគម្រោង ដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការវាយតម្លៃអនុកិច្ចសន្យា ដែលមានលក្ខណៈជាប្រព័ន្ធ មិនបានអនុវត្តទេ កាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើន។ នៅក្នុងឆ្នាំ ២០១០ ជាមួយនឹង ការគាំទ្រផ្នែក ថវិកា និងបច្ចេកទេស ពីផ្នែកត្រួតពិនិត្យវាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែករដ្ឋបាលនិងគ្រប់គ្រងកិច្ចសន្យា គ.ប្រ នៃ គ.អ.ជ.ខ ក្នុងការអនុវត្ត ការវាយតម្លៃអនុកិច្ចសន្យា ដែលបាន រៀបចំរួមគ្នាជាមួយភ្នាក់ងារអនុវត្តន៍ដែលមានលេខៈ 09/GEN/0901-01(GOV) គាំទ្រការបញ្រ្ជាបយេនឌ័រ ដំណើរ ការលទ្ធផលដែលបានរកឃើញ និងការសន្និដ្ឋាន នៃការវាយតម្លៃ ត្រូវបានកត់ត្រាហើយនឹងបង្ហាញ តាមរយៈរបាយ ការណ៍ ស្តីពីការវាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

គោលបំណងបន្ទាន់នៃអនុកិច្ចសន្យាគឺនៅចុងឆ្នាំ ២០០៩ ស្ថានភាពស្ត្រីនិងកុមារនៅក្នុង ឃុំប៉ាកខ្លងនឹង មានភាពល្អប្រសើរជាងមុន ដោយសារ យ៉ាងហោចណាស់ក៏មានស្ត្រីក្រីក្រម្នាក់ បានក្លាយជាអ្នក មានលទ្ធភាព ក្នុងការជួយរកប្រាក់ ចំណូលចិញ្ចឹមគ្រួសារ,អំពើហឹង្សាក្នុងគ្រួសារត្រូវបានកាត់បន្ថយ,បញ្ហាស្ត្រីនិងកុមារ ត្រូវបាន គណៈកម្មាធិការ ទទួល បន្ទុកកិច្ចការនារីនិងកុមារឃុំ ជួយដោះស្រាយ។ គម្រោងអទិភាពមួយចំនួន របស់ស្ត្រីនិងកុមារ ដែលបានលើកឡើង ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគឃុំ ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃ ទៅលើសកម្មភាពចំនួន២ នៃលទ្ធផលទី២ និងសកម្មភាពចំនួន១នៃលទ្ធផលទី៥ នៃ អនុកិច្ចសន្យាទាំងមូល ដោយផ្នែករដ្ឋបាលនិងគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងលក្ខណៈមួយ ប្រកប ដោយបច្ចេកទេសនិងតម្លាភាព។ ដូច្នេះទំហំនៃការវាយតម្លៃមានដែនកំណត់ តាមទំហំនៃអនុកិច្ចសន្យា និង រាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខណ្ឌការងារនៃការវាយតម្លៃ ។ គោលបំណងនៃការវាយតម្លៃគឺ:

ក-ទាញយកកត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និងចំណុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំងកត់ត្រានូវចំណុចរៀនសូត្រ

និងផ្នែកដែល ត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត និង ខ) ដើម្បីពង្រឹងរបៀប ធ្វើការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត ។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចទូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើៈ

១- ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញរបាយការណ៍ប្រចាំខែកំណត់ហេតុប្រជុំ របាយការណ៍បញ្ចប់ កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលមានការពាក់ព័ន្ធនៅក្នុងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៍ ។

២- ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗ រួមមានៈ អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផល ផ្ទាល់ និងមិនផ្ទាល់ ២ ឬ ៣នាក់ និងអ្នកពាក់ព័ន្ធ ២នាក់

៣- វិភាគទិន្នន័យ និងបកស្រាយទិន្នន័យ ដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់

៤- ផ្ទៀងផ្ទាត់លទ្ធផល ដែលបានរកឃើញនិងអនុសាសន៍ដោយភ្នាក់ងារអនុវត្តន៍ និងអ្នកពាក់ព័ន្ធតាមរយៈព័ត៌មាន ត្រឡប់ ដែលទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើង ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១- ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើង ដោយ គ.ប្រ និងអ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយ ការ ប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត។

២- ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោង។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណងសំខាន់ គឺដើម្បី "រៀនធ្វើដោយការអនុវត្តផ្ទាល់"។ អ្នកវាយតម្លៃ បានទទួលការគាំទ្រ ដោយមានគោលការណ៍ការណែនាំ ឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធ ដើម្បី ដោះ ស្រាយបញ្ហាទាំងអស់នេះ។

៣- បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យា ការវិភាគតារាងតក្កភាពមិនមាន "សូចនាករ" និង"មធ្យោបាយ ផ្ទៀងផ្ទាត់"លើការរីកចម្រើននិងជោគជ័យទេ។ មួយទៀតទំនាក់ទំនងសង្ខេបតាមបែប តក្កភាពរវាង សកម្មភាព (ធាតុចូល)និងលទ្ធផលនិងរវាងលទ្ធផលទៅនឹងគោលបំណងបន្ទាន់ មិនត្រូវបាន បង្ហាញ ឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ។

៤- ដោយយើងមិនមានសូចនាករបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ"គោលដៅអភិវឌ្ឍន៍" ដែលជា កម្រិតអត្ថប្រយោជន៍ទៅលើគោល នយោបាយ វិម្មការនិងវិសហមជ្ឈការ និងការកាត់បន្ថយ ភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធ នោះទេ។

៥- ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិតទៅលើលទ្ធ ផលនិងសកម្មភាពទាំងអស់បានទេ ។ យើងអាចវាយតម្លៃតែទៅលើប្រជាពលរដ្ឋ នៅឃុំប៉ាកខ្លង បានចូលរួមការ ផ្សព្វផ្សាយពីគោលគំនិតនៃការបញ្ច្រាបយេនឌ័រ និងសមាជិកនៃគណកម្មាធិការ ទទួលបន្ទុក កិច្ចការនារី និងកុមារ ឃុំ ដែលបានទទួលចំណេះដឹងស្តីពីការបញ្ច្រាបយេនឌ័រ ដែលជាសកម្មភាពទី១ និងសកម្មភាពទី២នៃលទ្ធផល ទី២ស្ត្រីនិងយុវវ័យបានទទួលការបណ្តុះបណ្តាលពីការកែឆ្នៃចំណីអាហារក្រៀម ដែលជាសកម្មភាពទី១ នៃលទ្ធផលទី៥នៃអនុកិច្ចសន្យា លំអិតតាមរយៈការសម្ភាសន៍ស៊ីជម្រៅ ក្រុមពិភាក្សា នៅតំបន់អនុវត្តគម្រោង។

៦- សូមរក្សាទុកចំណុចនេះប្រសិនបើវាមានសុពលភាព ការវាយតម្លៃទៅលើ ស្ថានភាពចុងបញ្ចប់ នៃ អនុកិច្ចសន្យា មិនអាចធ្វើទៅបានទេ ព្រោះចំណុច គ នៃផ្នែកទី៣ក្នុងឯកសារ អនុកិច្ចសន្យា មិនច្បាស់លាស់ ឬ មិនពេញលេញ។ ការងារនេះនឹងកាន់តែមានសុពលភាពនិងពោរពេញទៅដោយព័ត៌មាន បើសិនជាចំនុច ដែលបានរៀប រាប់ខាងលើនេះត្រូវបានដោះស្រាយ។

**ចំណុចដែលត្រូវរាប់បញ្ចូលដកចេញ និង ដិសេធន៍:**

១- ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ 09/GEN/0901-01(GOV） គាំទ្រការបញ្ច្រាបយេនឌ័រ និងដែនកំណត់ ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ។

២- ការវាយតម្លៃនេះលម្អិតតែទៅលើប្រជាពលរដ្ឋ និងគណៈកម្មាធិការ គ.ក.ន.ក ពីការយល់ដឹង តាមរយៈ ការប្រជុំ ផ្សព្វផ្សាយ និងការរៀបរាប់បង្ហាញ ដែលជាលទ្ធផល និងបណ្តុះបណ្តាល ជំនាញកែឆ្នៃចំណី អាហារក្រៀម ដែលជាសកម្មភាព នៃអនុកិច្ចសន្យា

៣- ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃទៅលើ ភ្នាក់ងារអនុវត្តន៏ ភ្នាក់ងារដែលពាក់ព័ន្ធគម្រោង ហើយនឹង ការវាយតម្លៃទៅលើគ.ប្រ នៃគ.អ.ជ.ខ និង គ.ជ.អ.ប ទេ។

ហេតុដូច្នេះ របាយការណ៏នៃការវាយតម្លៃ លទ្ធផលដែលបានរកឃើញ និងអនុសាសន៏ដែលបានលើកឡើង ត្រូវពិនិត្យដោយយោលទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ។

# ២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល

លទ្ធផលទី២ : ការផ្សព្វផ្សាយពីយេនឌ័រ និងការប្រជុំបញ្ច្រាបយេនឌ័រជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ

ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | -វគ្គ ផ្សព្វផ្សាយពីយេនឌ័រ១វគ្គ<br>-មានអ្នកចូលរួម៣០នាក់<br>-រយៈពេលចំនួន១ថ្ងៃ | -វគ្គ ផ្សព្វផ្សាយពីយេនឌ័រ១វគ្គ<br>-មានអ្នកចូលរួម៣០នាក់<br>-រយៈពេលចំនួន១ថ្ងៃ |
| ១.២ | -ប្រជុំពង្រឹងការបញ្ច្រាបយេនឌ័រ១វគ្គ<br>-មានរយៈពេលចំនួន១ថ្ងៃ<br>-អ្នកចូលរួមចំនួន ២០នាក់ | -ប្រជុំពង្រឹងការបញ្ច្រាបយេនឌ័រ១វគ្គ<br>-មានរយៈពេលចំនួន១ថ្ងៃ<br>-អ្នកចូលរួមចំនួន ២០នាក់ |

## ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និងសកម្មភាពនានារបស់អនុកិច្ចសន្យាដែលបានគ្រោងទុក ។អ្នកចូលរួមទាំងអស់នៅក្នុងក្រុមពិភាក្សា ដែលជាសិក្ខាកាមពីវគ្គផ្សព្វផ្សាយ យេនឌ័រ បានរាយការណ៏ថាពួកគេបានទទួលនូវចំណេះដឹងដែលទាក់ទងទៅនឹងភាពស្មើគ្នារវាងបុរសនិងស្ត្រីក្នុង ការទទួលបាននូវសិទ្ធក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ សិទ្ធក្នុងការបង្កើន ចំណេះដឹង សិទ្ធិក្នុងការការពារដោយអំណាចច្បាប់.. ។ល ។ អ្វីដែលគួរអោយចាប់អារម្មណ៏នោះ គឺពួកគាត់នៅចាំ បានថា នៅពេលដែលបញ្ហាអ្វីមួយកើតឡើង គាត់ដឹងថានឹង ត្រូវទៅ ទំនាក់ទំនងនៅកន្លែងណា អ្នកណា ដើម្បីជួយដោះស្រាយ, យកចំណេះដឹងនានាទៅប្រតិបត្តិនៅក្នុងសង្គមគ្រួសារ បញ្ចៀសបានបញ្ហា ។ គណៈកម្មាធិការ គ.ក.ន.ក មាន សមត្ថភាព និងជំនឿជាក់ចំពោះការងារសមល្មម អាចបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនបានល្អជាងមុន ធ្វើឱ្យបញ្ហាស្ត្រី និងកុមារត្រូវបានកាត់បន្ថយ ដូចជាចំនួនស្ត្រីដែល ស្លាប់ក្រោយពេល សំរាលកូន, អត្រាស្លាប់របស់ទារកក្រោយពេលសំរាល, ចំនួនស្ត្រីមានផ្ទៃពោះបានទៅទទួលសេវាពីស្ថាប័នសាធារណៈ មានចំនួនច្រើនជាងមុន.. ។ល ។ សរុបសេចក្តីមក វគ្គបណ្តុះបណ្តាលនេះ មានភាពទាក់ទងទៅនឹងតម្រូវការរបស់សិក្ខាកាម  ហើយនិងសហគមន៏របស់គេ ។  អ្វីដែលសំខាន់ទៀតនោះ អ្នកចូលរួមនៅក្នុងការពិភាក្សាក្រុមបានគូសបញ្ជាក់ថា  ចំណេះដឹង       និងជំនាញដែលទទួលបាន  នឹងរួមចំណែកធ្វើអោយជីវភាពរបស់គាត់កាន់តែប្រសើរ ។ យើងសង្កេតឃើញថាអ្នកភូមិខ្លះ បានចាប់ផ្តើមកែទម្លាប់ពីការ គេចវេសពីការចូលរួមប្រជុំផ្សេងៗមកជាចូលចិត្ត  ព្រោះពួកគាតបានយល់ ឃើញថា ពួកគាត់និងទទួលបានផលប្រយោជន៏ច្រើនប្រការ ។

## លទ្ធផលទី៥ : វគ្គកែឆ្នៃចំណីអាហារក្រៀម

ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
| --- | --- | --- |
| ១.១ | -វគ្គ កែឆ្នៃចំណីអាហារ១វគ្គ<br>- មានរយៈពេលចំនួន៧ថ្ងៃ<br>-អ្នកចូលរួមមានចំនួន១៥នាក់ | -វគ្គ កែឆ្នៃចំណីអាហារ១វគ្គ<br>-មានរយៈពេលចំនួន៧ថ្ងៃ<br>-អ្នកចូលរួមមានចំនួន១៥នាក់ |

ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

| |
| --- |
| ចំពោះក្រុមស្ត្រីដែលបាន ទទួលចំណេះដឹងពីការកែឆ្នៃចំណីអាហារក្រៀមវិញ ថ្វីត្បិតតែបច្ចុប្បន្ន ពួកគាត់មិនអាចប្រកបមុខរបរនោះបានមែន ប៉ុន្តែពួកគាត់ នៅតែអាចធ្វើសម្រាប់ក្រុមគ្រួសារ និងអាចធ្វើលក់នៅថ្ងៃណាមួយក្នុងករណីពេលវេលាមានអំណោយផល ។ |

## ២.២. ការវាយតម្លៃការសម្រេចបាននូវអត្ថប្រយោជន៍ភ្លាមៗ និងលទ្ធផលនៃអនុកិច្ចសន្យា

ផ្នែកកៈ ការវាយតម្លៃការសម្រេចបានរបស់ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា | ស្ថានភាពជាក់ស្តែង |
| --- | --- |
| - ប្រជាពលរដ្ឋចំនួន៣០នាក់ក្នុងភូមិប៉ាក់ខ្លង ឃុំប៉ាក់ខ្លង នឹងបានទទួលចំណេះដឹង ពីយេនឌ័រ តាមរយៈការអប់រំផ្សព្វផ្សាយ រយៈពេល១ថ្ងៃ។<br>- ប្រជាពលរដ្ឋទាំងនោះ នឹងផ្លាស់ប្តូរឥរិយាបទ និងការ ប្រព្រឹត្តរបស់ពួកគាត់បានល្អប្រសើរជាងមុន។ | - ប្រជាពលរដ្ឋចំនួន៣៨នាក់ក្នុងភូមិប៉ាកខ្លង ឃុំប៉ាក់ខ្លង បានចូលរួម ក្នុង ការអប់រំផ្សព្វផ្សាយពីយេនឌ័រ រយៈពេល ១ថ្ងៃ។<br>-ប្រជាពលរដ្ឋទាំងនោះបានផ្លាស់ប្តូរឥរិយាបទ និងការប្រព្រឹត្តរបស់ពួកគាត់បានល្អប្រសើរជាងមុន ដូចជាអំពើហឹង្សាក្នុងគួសារ ត្រូវបានកាត់ បន្ថយ ផ្ទត់គំនិត និងការប្រព្រឹត្តរបស់ឪពុកម្តាយ និងសហគមន៍មកលើ ស្ត្រី និងកុមារ បានកែប្រែពីអវិជ្ជមាន មកជា វិជ្ជមាន ដូចជាបានអនុញ្ញាតឱ្យស្ត្រី និងកូនស្រីបានចូលរួម ស្តាប់ការផ្សព្វផ្សាយពីសុខភាពបន្តពូជ បានចូលរួម ក្នុងវគ្គបណ្តុះបណ្តាលនៅឆ្ងាយពីផ្ទះ រយៈពេលច្រើនថ្ងៃ (៦ខែ) ដូចជាវគ្គកាត់ដេរ សំអាងការ..។ល។ |
| - សមាជិកគណកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំប៉ាក់ខ្លង ចំនួន២០រូប នឹងបានចូលរួមក្នុងកិចប្រជុំបញ្ជ្រាបយេនឌ័ររេរៀបចំដោយ មន្ទីរកិច្ចការនារីខេត្ត រយៈពេល១ថ្ងៃ។<br>- បញ្ហាស្ត្រី, យុវវ័យ និងកុមារនៅភូមិប៉ាកខ្លង ឃុំប៉ាកខ្លង នឹងត្រូវបានកាត់បន្ថយដោយសារមានការគាំទ្រ និងជំរុញពីគណៈកម្មាធិការ គ.ក.ន.ក ឃុំ។ | -ការយល់ដឹងរបស់ពួកគាត់ទៅលើបញ្ហា និង តម្រូវការរបស់យេនឌ័រ មានភាពប្រសើរជាងមុន ហើយពួកគាត់បានបង្កើនការយកចិត្តទុកដាក់ ទៅលើ តម្រូវការ របស់នារី និងកុមារ បានច្រើន ។<br>-បន្ទាប់ពីការផ្សព្វផ្សាយ និងបានធ្វើបង្ហាញដល់ពួកគាត់ពីដំណើរ ការ នៃការរៀបចំការប្រជុំការរៀបចំរបៀបវារៈប្រជុំ ជនបង្គោល មាន សមត្ថភាពក្នុងការរៀបចំកិច្ចប្រជុំ និងអាចប្រើប្រាស់ ថវិកាសម្រាប់ ដំណើរការប្រជុំទ្បេងទាត់ ។ |
| - ស្ត្រីក្រីក្រគ្មានការងារធ្វើនៅភូមិប៉ាកខ្លង ឃុំប៉ាកខ្លង ស្ត្រីក្រីក្រចំនួន១៥នាក់ នឹងបានចូលរួម ក្នុងវគ្គបណ្តុះបណ្តាលកែច្នៃចំណីអាហារក្រៀមរយៈពេល៧ ថ្ងៃ។ | -ស្ត្រីក្រីក្រចំនួន ១៥ នាក់ នៅភូមិប៉ាកខ្លង ឃុំប៉ាកខ្លង បានចូលរួមក្នុង វគ្គបណ្តុះបណ្តាលកែឆ្នៃចំណីអាហារក្រៀម រយៈពេល៧ថ្ងៃ។ |

ផ្នែកខ: ការវាយតម្លៃការសម្រេចបានរបស់គោលបំណងបន្ទាន់

| ល.រ | ធាតុនៃគោលបំណងបន្ទាន់ | ការសម្រេចបានជាក់ស្តែង នៅពេលបញ្ចប់ អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ |
|---|---|---|
| ១ | នៅចុងឆ្នាំ២០០៩ជំរុញការបញ្រ្ជាបយេនឌ័រ តាមរយៈការផ្សព្វផ្សាយ ការបណ្តុះបណ្តាល ជំនាញ និងការពង្រឹង សមត្ថភាពដល់មន្ត្រី នៅសហគមន៏ ដើម្បីបង្កើនកិច្ចសហការក្នុងការកែប្រែនិងលើកកំពស់ស្ថានភាព រស់នៅរបស់ស្ត្រី និងកុមារឱ្យមានភាពកាន់តែប្រសើរ ឡើង។ | -គោលបំណងបន្ទាន់ ដែលបានចែងគឺនៅក្នុងកម្រិតខ្ពស់ធ្វើអោយយើង ពិបាកក្នុងការវាស់វែង នៅចុងបញ្ចប់ នៃកិច្ចសន្យា។<br>-ទោះបីជាគេរំពឹងទុកថា សកម្មភាពនានា និងលទ្ធផលទាំងឡាយរបស់ អនុកិច្ចសន្យា នឹងចូលរួម ទៅក្នុងគោលបំណងបន្ទាន់ ប៉ុន្តែផ្អែកទៅលើ ការពិនិត្យ ឯកសារ និងវិធីសាស្រ្ត វាយតម្លៃបែបគុណភាព គេមិនអាច ធ្វើការវាយតម្លៃ ទៅលើ ថាតើគោល បំណងបន្ទាន់នេះបានសម្រេចក្នុង កម្រិតណាទេ។ |

ផ្នែកគ: ការវាយតម្លៃផលប្រយោជន៏ជារួមដែលទទួលបាន

តាមរយៈការពិភាក្សាក្រុមអ្នកចូលរួមបានបង្ហាញថា ពួកគាត់មានការពេញចិត្តចំពោះផលប្រយោជន៏ ដែលអនុកិច្ចសន្យានេះសម្រេចបាន ជាពិសេសចំណេះដឹង និងជំនាញកែឆ្នៃចំណីអាហារក្រៀម។ ពួកគាត់បានទទួលស្គាល់ថាវាមាន សារប្រយោជន៏សម្រាប់ពួកគាត់និងក្រុមគ្រួសារគាត់ណាស់ បើទោះបីជាពេលនេះតម្លៃទំនិញ ឬ វត្ថុធាតុដើម /គ្រឿងផ្សំ សម្រាប់យកមកប្រើប្រាស់លើមុខរបរនេះ ក្នុងបច្ចុប្បន្នមិនទាន់អាចទៅរួចយ៉ាងណាក៏ដោយ ក៏គាត់នៅមាន ចំណេះដឹង សម្រាប់ធ្វើហូបចុកនៅក្នុងគ្រួសាររបស់គាត់បានដែរ ប៉ុន្តែនៅពេលមានឧកាស គាត់នឹងយកចំណេះដឹងនេះ ទៅប្រើប្រាស់ ដើម្បីរកប្រាក់ចំណូលបាន។ ចំពោះវគ្គផ្សព្វផ្សាយពីយេនឌ័រ និងការបញ្ជ្រាបយេនឌ័រក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិង កុមារឃុំ បានធ្វើឱ្យសហគមន៏ មានការផ្លាស់ប្តូរគោលគំនិត កែប្រែទម្លាប់ ឬ ជំនឿបែបមិនសមស្រប ជំនួសវិញនូវ ទស្សនៈលក្ខណៈស្បង់ ពោលគឺ ស្ត្រីហ៊ាននិយាយ /ពិគ្រោះ អំពីបញ្ហាផ្លូវភេទ,ស្ត្រីមានផ្ទៃពោះទៅទទួលសេវា ពីមណ្ឌលសុខភាព ការសម្រាលកូនដោយឆ្មបបុរាណដែលគ្មានជំនាញច្បាស់លាស់ត្រូវបានកាត់បន្ថយ។ ចំនួនសិស្សស្រី បោះបង់ចោលការសិក្សានៅកំរិតបឋម, និងមធ្យមសិក្សាត្រូវបានថយចុះ។ អំពើហឹង្សាក្នុងគ្រួសារត្រូវបានកាត់បន្ថយ ស្ត្រីនិងយុវវ័យ មានចិត្តចង់ ចូលរួមក្នុងការងារសង្គម។ គណៈកម្មាធិការ គ.ក.ន.ក មានសុឆន្ទៈ ក្នុងការបើកទ្វារចំហរ នូវ ទស្សនៈចូលរួម ជាមួយនឹង

សំណូមឱ្យបានបញ្ចូលបញ្ហាយុវវ័យទៅក្នុងរបៀបវារៈនៃអង្គប្រជុំ និង អនុញ្ញាត ឱ្យតំណាង ក្រុមយុវវ័យ ត្រូវបាន ចូលរួម ក្នុងការប្រជុំប្រចាំខែរបស់គណៈកម្មាធិការ គ.ក.ន.ក ដើម្បីឱ្យពួកគេ មានឱកាស លើកឡើង ពីបញ្ហា ដែលគេជួបប្រទះ ហើយពិភាក្សានិងដោះស្រាយរួមគ្នា។

**ករណីសិក្សាទី១:** អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងកែឆ្នៃចំណីអាហារគ្រៀម និងវគ្គផ្សព្វផ្សាយពីគោលគំនិតនៃការបញ្ជ្រាបយេនឌ័រ នៅឃុំប៉ាកខ្លង

បន្ទាប់ពីចូលរួមក្នុងគម្រោងផ្សព្វផ្សាយ ពីគោលគំនិតនៃការ បញ្ជ្រាបយេនឌ័រ និងវគ្គបណ្តុះបណ្តាលជំនាញកែឆ្នៃចំណីអាហារគ្រៀម របស់មន្ទីរ កិច្ចការនារី និង គ.អ.ជ.ខ របស់ខេត្តកោះកុង ក្នុងឆ្នាំ ២០០៩ អ្នកស្រី សុខ អូន បាននិយាយ÷ "ជីវភាពគ្រួសាររបស់ខ្ញុំមាន ភាពល្អប្រសើរ ឡើងតាំងពីខ្ញុំបាន ចូលរួមស្តាប់ការប្រជុំផ្សព្វផ្សាយស្តីពីគោលគំនិតនៃការបញ្ជ្រាបយេនឌ័រ និង វគ្គបណ្តុះបណ្តាលជំនាញកែឆ្នៃចំណីអាហារគ្រៀម "



អ្នកស្រី សុខ អូន

អ្នកស្រី សុខ អូន អាយុ ៣៥ឆ្នាំ រស់នៅក្នុងភូមិ១ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ជាមេផ្ទះ ប្តីជាកម្មករសំណង់ មានកូន៣នាក់ ( ស្រី២នាក់) ។ គាត់បាននិយាយថាគម្រោងបណ្តុះបណ្តាលនេះ និងគម្រោងផ្សព្វផ្សាយនេះ មានសារៈសំខាន់ខ្លាំងណាស់ ព្រោះគាត់ទទួលបានទាំងចំណេះដឹងនិងជំនាញ។ គាត់បញ្ជាក់ថា ÷ " សព្វថ្ងៃ នេះជីវភាពគ្រួសាររបស់ខ្ញុំបានរីកចំរើនជាងមុនច្រើន ទាំងនេះអាស្រ័យដោយសារខ្ញុំ បានយកជំនាញ និងចំណេះដឹង ដែល បានទទួលទាំងប៉ុន្មានមកអនុវត្ត "។ គាត់បានបន្តទៀតថា "ដោយសារខ្ញុំជាកូនកំព្រា, ខ្ញុំមិនបានរៀនសូត្រអ្វីជ្រៅ ជ្រះទេ ប្តីខ្ញុំជាកម្មករសំណង់ ដោយសារភាពក្រីក្រខ្ញុំបានទុកកូនម្នាក់ឱ្យនៅជាមួយម្តាយនៅឯស្រុក បន្ទាប់មកកូន ស្រីម្នាក់ទៀតក៏ត្រូវបានឈប់រៀនទៀត។ នៅពេលដែលខ្ញុំបានចូលរួម ស្តាប់ការផ្សព្វផ្សាយពីគោលគំនិតនៃការ បញ្ជ្រាបយេនឌ័រ ខ្ញុំមានការរំភើបក្នុងចិត្ត ហើយចាប់ផ្តើមមានសង្ឃឹមឡើងវិញថា ទោះបីជាខ្ញុំមានចំណេះដឹងតិចតួច ក៏មានឱកាសចូលរួមក្នុងការងារអភិវឌ្ឍន៏សហគមន៏ និងសង្គមជាតិបានដែរ ខ្ញុំចាប់ផ្តើមផ្លាស់ប្តូរការគិត ដោយ ព្យាយាមចូលរួមគ្រប់ការផ្សព្វផ្សាយ ឬ ការប្រជុំផ្សេងៗ ព្រោះចង់ដឹងតើគេនិយាយពីអ្វី ហើយយកព័តមាននេះទៅ ប្រាប់បន្តដល់ប្តីនិងកូន។ ខ្ញុំបានអនុញ្ញាតឱ្យកូនស្រីរបស់ខ្ញុំចូលរួមក្នុងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ (ស្នាក់នៅកន្លែងរៀន) រយៈពេល៦ខែ ដែលពីមុនមក ខ្ញុំតែងព្រួយបារម្ភ មិនឱ្យកូនស្រីដើរទៅណាឆ្ងាយពីខ្លួន។ ជាងនេះទៅទៀត ខ្ញុំបានស្ម័គ្រ ចិត្តធ្វើជាអ្នកទ្រទ្រង់សុខភាពភូមិ ដោបានជួយអប់រំផ្សព្វផ្សាយពីសុខភាពដល់ប្រជាពលរដ្ឋក្នុងភូមិ ជួយជំរុញស្ត្រីមាន ផ្ទៃពោះឱ្យទៅប្រើប្រាស់សេវាកម្មនៅមណ្ឌលសុខភាព និង បញ្ជូនកូនទៅចាក់ថ្នាំបង្ការ.... ។ល។

ចំពោះគម្រោងកែឆ្នៃចំណីអាហារគ្រៀមវិញ ទោះបីជានៅពេលនេះខ្ញុំផ្អាកការធ្វើនំចំណីលក់ ដោយសារ

ទំនិញ ឡើងថ្លៃ លក់មិនចំណេញ ប៉ុន្តែខ្ញុំមានជីវភាពធូរធារនៅថ្ងៃនេះក៏ចាប់ផ្តើមពីគម្រោងនេះដែរ ព្រោះក្រោយពេល លក់ នំចំណីមិនដាច់ ខ្ញុំបានសម្រេចចិត្តផ្លាស់ប្តូរមុខរបរធ្វើនំបញ្ចុករែកលក់វិញ ដូច្នេះខ្ញុំអាចជួយរកប្រាក់ចំណូលចិញ្ចឹមកូន និងឧបត្ថមការរៀនសូត្ររបស់កូនទីបីរបស់ខ្ញុំរហូតរៀងមក ដែលកាលពីដើមខ្ញុំធ្លាប់រស់នៅបានដោយសារការចិញ្ចឹម របស់ប្តីតែម្នាក់ឯង។

ជីវភាពគ្រួសារ លោកស្រី សុខ អូន មានភាពប្រសើរឡើង ដោយសារគាត់បានចំណូលបន្ថែមពី ការលក់នំបញ្ចុកផង ហើយនិងពីកូនស្រីដែលបានក្លាយជាបុគ្គលិកនៅហាងកែសម្ផស្សផង។ ការផ្លាស់ប្តូរជាវិជ្ជមានមួយទៀត សម្រាប់គាត់ បន្ទាប់ពីចូលរួមសកម្មភាពគម្រោង គឺគាត់ត្រូវបានទទួលការរាប់អានកាន់តែច្រើនពីអ្នកភូមិដោយ សារគាត់ ជាអ្នកជួយរួមចំណែកធ្វើឱ្យប្រជាពលរដ្ឋ ទទួលបាននូវសុខភាពល្អប្រសើរផងដែរ។

ចុងបញ្ចប់ គាត់បានបង្ហាញការប្តេជ្ញាចិត្ត និងទឹកចិត្តក្នុងការបន្តសកម្មភាពជួយខ្លួនឯង ជួយក្រុមគ្រួសារ និងជួយ រួមចំណែកការងារអភិវឌ្ឍន៍សហគមន៍របស់គាត់អោយកាន់តែប្រសើរឡើងជាលំដាប់។

**ករណីសិក្សាទី២:** អ្នកមិនទទួលផល

លោក ខាន់ សុជា អាយុ ៤៥ ឆ្នាំ មានទីលំនៅភូមិប៉ាក់ខ្លង ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង។ ប្រពន្ធឈ្មោះ អ៊ីង សាវ៉ន មានកូន ៥ នាក់ ( ស្រី ១ )។ គាត់ គឺជាអ្នកនេសាទ។ លោក ខាន់ សុជា មិនត្រូវបានជ្រើស រើសឱ្យចូលរួមក្នុងកម្មវិធី ប្រជុំផ្សព្វផ្សាយស្តីពីយេនឌ័រ និង វគ្គបណ្តុះ បណ្តាលកែ ច្នៃចំណីអាហារក្រៀមទេ មូលហេតុ ពេលមានការចុះមក ជ្រើសរើសប្រជាពលរដ្ឋឱ្យចូលរួម គាត់មិននៅផ្ទះ ។ ក្នុងកិច្ចផ្តល់សម្ភាសន៍ជាមួយក្រុមការងាររបស់យើងគាត់បានផ្តល់ចំណាប់អារម្មណ៍ថា **"ខ្ញុំចង់ចូលរួមវគ្គទាំងអស់នោះណាស់ ប៉ុន្តែពេលប្រធានភូមិចុះមក ជ្រើសរើសអ្នកចូលរួម ខ្ញុំមិននៅផ្ទះ**។ គាត់បានបន្តទៀតថា **"សកម្មភាព ទាំង ២ ខាងលើនេះ មានសារសំខាន់ខ្លាំណាស់ ព្រោះខ្ញុំយល់ថា ឥឡូវនេះ គេយកចិត្តដាក់ចំពោះការងារយេនឌ័រ ហើយប្រជាពលរដ្ឋនៅ ក្នុងភូមិ ឬ សហគមន៍នានា ក៏ពួកគេនិយមលើកយករឿង យេនឌ័រនេះ មកជជែកដេញដោលគ្នាដែរ**។ លោក ខាន់ សុជា បានបង្ហាញការត្អូញត្អែថា រូបគាត់មានការយល់ដឹងតិចតួចណាស់អំពីបញ្ហាយេនឌ័រ ហើយប្រភពព័តិមាន ដែលគាត់ ទទួលបានបន្តិចបន្តួចនោះ ភាគច្រើនស្តាប់ឮគេជជែកគ្នានៅតាមរោងកាហ្វេ ឬ ការជួបជុំគ្នាណាមួយ និងតាមរយៈ វិទ្យុ ទូរស្សន៍ ព្រឹត្តប័ត្រខ្លះៗប៉ុណ្ណោះ និងចំពោះវគ្គបណ្តុះបណ្តាល កែច្នៃចំណីអាហារ លោក ខាន់ សុជា បានផ្តល់ចំណាប់ អារម្មណ៍ថា**"វគ្គនេះក៏ពិតជាល្អណាស់ដែរ ព្រោះខ្ញុំមានជំនឿថា បងប្អូនស្ត្រីដែលធ្លាប់បានឆ្លងកាត់វគ្គនេះ ពួកគាត់អាច យកចំណេះដឹងនេះទៅប្រើប្រាស់បង្កើតជាមុខរបរបន្ទាប់បន្សំបាន និងយ៉ាងហោចណាស់ក៏អាចចែករំលែកចំណេះទាំង នេះទៅកូន ចៅ ឬ អ្នកភូមិដ៏ទៃៗទៀតបានដែរ"** ។


លោក ខាន់ សុជា

ជាចុងក្រោយ លោក ខាន់ សុជា បានសំណូមពរឱ្យមានវគ្គកែច្នៃស្រដៀងៗគ្នានេះជាបន្តទៀត ពោលគឺវគ្គទាំងឡាយណា ដែលមានសភាពស្របទៅនិងស្ថានភាពភូមិសាស្ត្រ ទីកន្លែង ពេលវេលា ធនធាន ចៀសវាងប្រជាពលរដ្ឋបានឆ្លងកាត់វគ្គនិងមានជំនាញរួចហើយ ប៉ុន្តែមិនអាចយកចំណេះដឹងទាំងនោះទៅប្រើប្រាស់បាន។

## ២.៣ ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

(ពិន្ទុ: ១= ខ្សោយណាស់ ២= ខ្សោយ ៣= មិនខ្លាំងមិនខ្សោយ ៤= ខ្លាំង ៥= ខ្លាំងណាស់ )

| ល.រ | ធាតុ | ទំនាក់ទំនង | បរិយាយច្បាស់លាស់ | សង្ខេបការវាយតម្លៃ |
|---|---|---|---|---|
| ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់ | | | | |
| ១ | សកម្មភាព | ៤ | ៥ | - សកម្មភាពដែលបានលើកឡើង ពិតជាមានទំនាក់ទំនងតក្កជាមួយនឹងលទ្ធផល ដែលបានសរសេរនៅក្នុងឯកសារអនុកិច្ចសន្យា។ ឧទាហរណ៍លទ្ធផលទី២ទាក់ទងនឹងប្រជាពលរដ្ឋនៅ ឃុំប៉ាកខ្លង ទទួលបានវគ្គផ្សព្វផ្សាយពីគោល គំនិតនៃការ បញ្ច្រាបយេនឌ័រចំនួន១វគ្គ។<br>- សមាជិកគណ:កម្មាធិការ គ.ក.ន.ក ចំនួន២០រូប បានទទួលការប្រជុំពង្រឹងការបញ្ច្រាបយេនឌ័រចំនួន១វគ្គ។<br>- វគ្គបណ្តុះបណ្តាលជំនាញកែឆ្នៃចំណីអាហារក្រៀម ចំនួន១វគ្គ ទាំងអស់នេះអាចឆ្លុះបញ្ចាំងបានថា សកម្មភាពទាំងនេះ មានទំនាក់ទំនងតក្កជាមួយនឹងលទ្ធផលនៅខាងលើហើយ និងបានសរសេរយ៉ាងច្បាស់ ។ សកម្មភាព នីមួយៗបាន សរសេរបង្ហាញ ច្បាស់លាស់ ដោយមានចំនួនវគ្គបណ្តុះ បណ្តាល និងចំនួនសិក្ខាកាម ដែលត្រូវចូលរួមក៏ដូចជាឃុំ និងស្រុក គោលដៅ ដែលគ្របដណ្តប់។ |
| ២ | លទ្ធផល | ៤ | ៥ | - លទ្ធផលនីមួយៗ ត្រូវបានសរសេរបរិយាយ ច្បាស់លាស់ ទោះបីជាមានចំណុច ខ្វះខាតខ្លះក្នុងការសរសេរសូចនា ករមិនសូវជាក់លាក់ និងអាចពិបាកវាស់វែងបានខ្លះ ក៏ដោយ។ ជាងនេះទៅទៀតនោះ លទ្ធផលនីមួយៗ ក៏បានផ្សារភ្ជាប់គ្នាល្អដែរ ។ លទ្ធផលនីមួយៗជាការបំពេញបន្ថែមអោយគ្នាទៅវិញទៅមក ហើយរួមគ្នាបំពេញគោលបំណងបន្ទាន់ ។ទោះបីជាយ៉ាងនេះក៏ដោយលទ្ធផលទាំងនេះនៅមិនអាចធ្វើអោយគោលបំណង បន្ទាន់សម្រេចបាននៅឡើយ។ |

| | | | | |
|---|---|---|---|---|
| ៣ | គោលបំណងបន្ទាន់ (គោលបំណងស្ថិតក្នុងចំណុច "ខ" នៃផ្នែកទី ៣) | ៤ | ៣ | - គោលបំណងបន្ទាន់ ត្រូវបានផ្តល់អត្ថន័យយ៉ាងច្បាស់ ប៉ុន្តែ គោលបំណងបន្ទាន់នេះ មានកំរិតខ្ពស់ពេកជាហេតុធ្វើអោយអនុកិច្ចសន្យានេះពិបាកនឹងសម្រេច គោលបំណបំណងបន្ទាន់នេះ ក្នុងកាលៈទេសៈបែបនេះ។ |
| ៤ | ស្ថានភាពចុងបញ្ចប់ អនុកិច្ចសន្យា (ចំណុច "គ" នៃផ្នែកទី ៣) | ៤ | ៤ | - ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យាត្រូវបានបរិយាយច្បាស់ ហើយមានទំនាក់ទំនងផ្ទាល់ទៅនឹងលទ្ធផល និងសកម្ម ភាពនៃអនុកិច្ចសន្យា។ ស្ថានភាពចុងបញ្ចប់នេះបានឆ្លុះ បញ្ចាំងនូវសមិទ្ធិផល ដែលសម្រេចបាននៅក្នុងកម្រិត លទ្ធផល ។ ប៉ុន្តែវាមិនបាន ឆ្លុះ បញ្ចាំងនូវស្ថានភាពចុង បញ្ចប់ ឬ ផលប៉ះពាល់ ដែលអាចកើតមានឡើងនៅក្នុង កំរិតប្រជាជន និងសហគមន៏ទេ។ គ្មានភស្តុតាងច្បាស់លាស់ណាមួយ ដើម្បីបង្ហាញថា តើអ្នកចូលរួមបានយកចំណេះដឹង និងជំនាញដែលពួកគេទទួលបានទៅធ្វើជាប្រយោជន៏ ក្នុងការធ្វើអោយប្រសើរឡើងនូវជីវភាពរបស់ពួកគាត់ទេ។ |
| ៥ | លទ្ធផលអភិវឌ្ឍន៏/ផលប៉ះពាល់ រយៈពេលវែងៈ គោលដៅ និងគោលបំណង អភិវឌ្ឍន៏ (ចំណុច "ខ" នៃផ្នែកទី ៣) | | | - មិនអាចធ្វើការវាយតម្លៃបាន |

ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខ័ណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារ:

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| ពីខាង គ.ជ.អ.ខ: | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | នៅមានកំរិត គួរតែពង្រឹងបន្ថែម និងមានការគាំទ្រ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យការអនុវត្តន៏របស់ភ្នាក់ងារអនុវត្តន៏ | សមរម្យ ។ គ្មានការប្រឈម និងឧបសគ្គដែលគួរឱ្យកត់សម្គាល់ទេ ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា | ដូចតាមទំលាប់ និងនិតិវិធីដែលបានធ្វើ ។ ការកត់ត្រា និងទុកដាក់ឯកសារគួរត្រូវបានកែលំអ ។ |
| ពីខាងភាគីអនុវត្តន៏កិច្ចសន្យា: | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | មានបុគ្គលិក ជំនាញ និងបទពិសោធន៏គ្រប់គ្រាន់ ។ |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | ការអនុវត្តសកម្មភាព និងលទ្ធផលទាន់ពេលវេលាដូចដែលបានព្រាងទុក |
| ៦ | ការរាយការណ៍ការរីកចំរើន និង ការកត់ត្រាឯកសារ | ដូចតាមទំលាប់ និងនិតិវិធីដែលបានធ្វើ ។ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | លក្ខណ័ក្នុងកិច្ចសន្យាត្រូវបានបំពេញ |
| ទាំងខាង គ.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យា: | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" និងបញ្ហាប្រឈម | ដោយសារមានការយឺតយ៉ាវក្នុងការអនុម័តកិច្ចសន្យា សកម្មភាពមួយនៅក្នុងអនុកិច្ចសន្យាមិនអាចធ្វើ ទៅបាន ដោយសារវាជាសកម្មភាព តាមរដូវកាល ។ ហានិភ័យនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងអនុកិច្ចសន្យា ប៉ុន្តែវានៅក្រៅការគ្រប់ គ្រងរបស់ភ្នាក់ងារ អនុវត្តគម្រោង ។ |
| ៩ | ការបញ្ជ្រាបយេនឌ័រ | មានការលើកកំពស់យេនឌ័រ ។ ការចូលរួមរបស់ប្រជាពលរដ្ឋជាស្ត្រីនៅក្នុងវគ្គបណ្តុះបណ្តាល កែឆ្នៃចំណីអាហារគ្រៀម ការផ្សព្វផ្សាយយេនឌ័រ មានគ្រប់ផែនការ |
| ១០ | ការថែរក្សា | សកម្មភាព ដែលបានលើកឡើងដោយគម្រោងត្រូវបានមើលឃើញថាត្រូវបានយកទៅអនុវត្តដោយប្រជាពលរដ្ឋ និងមន្ត្រីដែលជាយន្តការគាំទ្រ ហើយបានបន្តរហូតដល់ពេល ក្រុមការងារចុះទៅធ្វើការវាយតម្លៃ ។ ដូច្នេះនិរន្តភាពរបស់ផ្នែកខ្លះៗនៃគម្រោងត្រូវបានសម្រេច ។ |

## ២.៤ សេចក្តីសន្និដ្ឋាន

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យានេះត្រូវបានអនុវត្តឡើងដូចការគ្រោងទុក។ ភាគីអនុវត្តអនុកិច្ចសន្យា មានសមត្ថភាព និងធនធាន គ្រប់គ្រាន់ដើម្បីអនុវត្តអនុកិច្ចសន្យា។ សកម្មភាព និងលទ្ធផលដែលបានគ្រោងទុកត្រូវបានបញ្ចប់ ស្របតាមផែនការការងារ។ |
| ២ | សកម្មភាពរបស់អនុកិច្ចសន្យា និងអត្ថប្រយោជន៍ដែលសហគមន៍ទទួលបាន ត្រូវបានអ្នកទទួលផលផ្ទាល់និង មិនផ្ទាល់គាំទ្រនិងបង្ហាញការពេញចិត្តផងដែរ ។ ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាត្រូវបានសម្រេចទាំង ស្រុងដូចការព្រោងទុក។ ភស្តុតាងអំពីលទ្ធផល និងផលប្រយោជន៍ នៃគម្រោងដូចជា:<br>**ក-** សមត្ថភាព ក្នុងការធ្វើអន្តរាគមន៍ និងការដោះស្រាយបញ្ហាយេនឌ័រនៅក្នុងតំបន់ ដែលកើតចេញពីប្រជុំ និងពីការផ្សព្វផ្សាយនានាបាននិងកំពុងបន្ត ប្រើប្រាស់ជាឧករណ៍ដ៏មានប្រសិទ្ធភាពបំផុត។<br>**ខ-** មានតម្រូវការវគ្គបណ្តុះបណ្តាលស្រដៀងគ្នានេះ ដែលសំណូមពរដោយអ្នកភូមិជាច្រើន។ អនុកិច្ចសន្យា នេះមាននិរន្តភាពក្នុងកំរិតខ្ពស់។ លទ្ធផលនៃគម្រោងនៅតែបានចូលបន្តចូលសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ |
| ៣ | ការជ្រើសរើសសិក្ខាកាម និងអ្នកទទួលផល នៅក្នុងអនុកិច្ចសន្យាដោយភាគីអនុវត្តកិច្ចសន្យាផ្ទាល់នឹងធ្វើអោយមានការធានាថា អ្នកដែលមានតម្រូវការខ្លាំងបំផុតនឹងទទួលបានផលប្រយោជន៍ពីអនុកិច្ចសន្យា។ |
| ៤ | អនុកិច្ចសន្យានេះមិនបានជួបប្រទះនូវឧបសគ្គ និងបញ្ហាប្រឈមគួរឱ្យកត់សម្គាល់ទេ។ |

<u>ចំណុចរៀនសូត្រ:</u>

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ដូចដែលបានសង្កេតឃើញក្នុងការវាយតម្លៃនេះ ផលប៉ះពាល់របស់អនុកិច្ចសន្យា និងនិរន្តភាពរបស់លទ្ធផលនៅក្នុងអនុកិច្ចសន្យា អាចត្រូវបានសម្រេចបានក្នុងកំរិតខ្ពស់ ប្រសិនបើអនុកិច្ចសន្យា ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹង តម្រូវការជាអាទិភាពរបស់ក្រុមគោលដៅដែលជាអ្នកទទួលផល។ |

| | |
|---|---|
| ២ | ការបរិយាយច្បាស់លាស់នូវ "គោលបំណងបន្ទាន់" ក្នុងករិតដែលអាចវាស់វែងបាន ជាការសំខាន់សម្រាប់ការកត់ត្រាទុក នូវលទ្ធផលរបស់អនុកិច្ចសន្យា និងផលប្រយោជន៍ដែលមាន ដើម្បីការវាយតម្លៃលទ្ធផល។ |

អនុសាសន៍ :

| ល.រ | អនុសាសន៍ |
|---|---|
| ១ | គោលបំណងបន្ទាន់ នៃអនុកិច្ចសន្យា គួរត្រូវបានរៀបរៀង និងសរសេរក្នុងន័យដែលវាមានទំនាក់ទំនង ទៅនឹងលទ្ធផល ហើយបរិយាយច្បាស់អំពីអ្វីដែលជាលទ្ធផលបន្ទាន់ និងអត្ថប្រយោជន៍ ដែលរំពឹងទុក។ |
| ២ | ដើម្បីឱ្យការប្រើប្រាស់លទ្ធផលគម្រោងទទួលបានប្រសិទ្ធភាពខ្ពស់ ឆ្លើយតបនឹងគោលបំណងបន្ទាន់, ឃុំ សង្កាត់ ដែលជាអ្នកលើកគម្រោង ឬ សាមីមន្ទីរ ដែលទទួលគាំទ្រគម្រោង គួរប្រមើលមើល ប៉ាន់ប្រមាណ អំពីសក្តានុពលនៃលទ្ធផលគម្រោង និង តម្រូវការ ,លទ្ធភាព ,ធនធាននៃសហគមន៍ជាមុនសិន។ឧទា. គម្រោងកែឆ្នៃចំណីអាហារជាគម្រោងមួយ ដែលជួយរួមចំណែកក្នុងការបង្កើន ផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ប៉ុន្តែដោយសារនៅក្នុងសហ គមន៍មិនមានធនធានគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ឱ្យការកែឆ្នៃ ធ្វើឱ្យដំណើរការកែច្នៃនោះត្រូវអាក់ខានជាបណ្តោះ អាសន្ន ពោលគឺសិក្ខាកាមដែលបានឆ្លងកាត់វគ្គរួចហើយ ប៉ុន្តែពុំទាន់មានឱកាសក្នុងការយកចំណេះដឹងរបស់ខ្លួន ទៅប្រើប្រាស់បាន |
| ៣ | សកម្មភាពត្រួតពិនិត្យ គួរតែត្រូវបានធ្វើឡើងជាប្រចាំ បើទោះបីសកម្មភាពគម្រោងត្រូវបានបញ្ចប់សព្វគ្រប់ទៅហើយក្តី (មាននិរន្តភាពនៃលទ្ធផលគម្រោង និង ផ្តល់ផលប្រយោជន៍ដល់សហគមន៍យូរអង្វែង)។ |

# ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

| ល.រ | ឈ្មោះឯកសារ | ឯកសារលំអិត |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និង ឯកសារវិសោធនកម្ម | sub-contract |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ | monthly report |
| ៣ | របាយការណ៍ត្រួតពិនិត្យគម្រោង | |
| ៤ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | end of report |
| ៥ | លិខិតឆ្លើយឆ្លងរវាងភ្នាក់ងារអនុវត្តន៍ និងគណៈកម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ | |
| ៦ | បញ្ជីវគ្គបណ្តុះបណ្តាលដែលមានក្នុងអនុកិច្ចសន្យា | Training inventory |
| ៧ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា | financial report |
| ៨ | បញ្ជីសំណួរសម្រាប់ ជាឧបករណ៍ក្នុងការងារវាយតម្លៃ | Questionnaires |
| ៩ | រូបថត | Images |
| ១០ | រូបថតសកម្មភាពទូទៅ | In general pictures |

**ឯកសារទី២ : ឯកសារអនុកិច្ចសន្យា លេខ 09/GEN/0901-01(GOV) ខេត្តកោះកុង**

បញ្ជីឈ្មោះអ្នកផ្តល់ព័តិមានសំខាន់ៗ ដែលបានជួបសម្ភាសន៍/ជួបពិភាក្សា

| ល.រ | ថ្ងៃ - ខែ | ឈ្មោះ | តួនាទី | ទីកន្លែង | ឧបករណ៍សម្រាប់ប្រមូលទិន្នន័យ |
|---|---|---|---|---|---|
| ១ | ២៨ កញ្ញា | សមាជិ គ.ក.ន.ក ឃុំ | | ឃុំប៉ាក់ខ្លង | សម្ភាសន៍ជាក្រុម |
| ២ | ២៨ កញ្ញា | គង់ វិស្នា | មន្ត្រីបង្គោល គ.ក.ន.កឃុំ | ឃុំប៉ាក់ខ្លង | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | ២៨ កញ្ញា | ក្រុមអ្នកទទួលផលផ្ទាល់ | | ឃុំប៉ាក់ខ្លង | សម្ភាសន៍ជាក្រុម |
| ៤ | ២៨ កញ្ញា | ក្រុមអ្នកទទួលផលមិនផ្ទាល់ | | ឃុំប៉ាក់ខ្លង | សម្ភាសន៍ជាក្រុម |
| ៥ | ២៨ កញ្ញា | លោក ស្រី សុខ អូន | ប្រជាពលរដ្ឋ | ឃុំប៉ាក់ខ្លង | សម្ភាសន៍ស៊ីជម្រៅ/ករណីសិក្សា |
| ៦ | ២៨ កញ្ញា | លោក ខាន់ សុជា | ប្រជាពលរដ្ឋ | ឃុំប៉ាក់ខ្លង | សម្ភាសន៍ស៊ីជម្រៅ/ករណីសិក្សា |
| ៧ | ២៩ កញ្ញា | លោកស្រី សរ ស៊ីមអ៊ីម | ប្រធានមន្ទីរការនារី | មន្ទីរកិច្ចការនារី | សម្ភាសន៍ស៊ីជម្រៅ |
| ៨ | ៣០ កញ្ញា | កញ្ញា សាន់ សានីរ | ប្រធានទីប្រឹក្សាគម្រោង PSDD | អាគារ គ.ប្រ | សម្ភាសន៍ស៊ីជម្រៅ |
| ៩ | ៣០ កញ្ញា | រិទ្ធ សោភ័ត្រ | អភិបាលរងស្រុក | សាលាស្រុកមណ្ឌលសីមា | សម្ភាសន៍ស៊ីជម្រៅ |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | 10/GEN/0901-00 |
| ចំណងជើង : | ការបញ្ជ្រាបគោលគំនិតយេនឌ័រសំខាន់ៗ និង ការពង្រឹងបណ្តាញ អ្នកទទួលបន្ទុកស្ត្រី និងកុមារភូមិ-ឃុំតាមរយៈការអនុវត្ត គោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ។ |
| ភ្នាក់ងារអនុវត្តន៏ : | មន្ទីរកិច្ចការនារីខេត្ត |
| រយៈពេល (ចាប់ផ្តើម និងបញ្ចប់) | 01/01/2009 ដល់ 31/12/2009 |
| រាជធានី ខេត្ត | ខេត្តក្រចេះ |
| មន្ទីរជំនាញ | មន្ទីរកិច្ចការនារីខេត្ត |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬ គ.ប្រ/គ.អ.ជ.ខ | US$ : 7,075.00 |
| ការរួមចំណែករបស់រាជធានី ខេត្ត | គ្មាន |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៏ | គ្មាន |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | US$ : 7,075.00 |

## ក្រុមវាយតម្លៃ និងរៀបចំរបាយការណ៍

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ |
|---|---|
| លោក គឹម ផល្លា | អនុប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល និងជាគ្រូបង្គោល M&E គ.ប្រ |
| លោក ប៉ែន រដ្ឋា | មន្ត្រីបង្គោលគម្រោង NRML និងជាគ្រូបង្គោល M&E |
| លោក ហោ ឡារ៉ូ | មន្ត្រី M&E គ.ប្រ |
| លោក ទៀង ប៊ុនថេត | មន្ត្រី M&E គ.ប្រ |

## ក្រចេះ

កញ្ញា ២០១០

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៣ |
| | របាយការណ៍សង្ខេប | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៧** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ | ៧ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៧ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៧ |
| ១.៤ | សំណួរវាយតម្លៃ | ៨ |
| ១.៥ | វិធីសាស្ត្រ សម្ភារ និងដំណើរការវាយតម្លៃ | ៨ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ៩ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១១** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល ( សំណួរវាយតម្លៃទី ១) | ១១ |
| | - លទ្ធផលទី១ | ១១ |
| ២.២ | ការវាយតម្លៃសម្រេចលើអត្ថប្រយោជន៍ភ្លាមៗ ការសម្រេចបាននូវលទ្ធផល អនុកិច្ចសន្យា ( សំណួរវាយតម្លៃទី៣ ) | ១២ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង ( សំណួរវាយតម្លៃទី ៤ ) | ១៦ |
| **២.៤** | **សេចក្តីសន្និដ្ឋាន ( សំណួរវាយតម្លៃទី៥ )** | **១៩** |
| | | |
| **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍** | | **២១** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ២១ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍ /ពិភាក្សា | ២២ |
| | | |
| **ករណីសិក្សា** | | |
| ទី១- | លោក **ហ៊ៅ ជឿន** អាយុ ៦២ ឆ្នាំ អ្នកទទួលផលពីគម្រោង | ១៤ |
| ទី២- | លោក **ចិន សម្ផស្ស** អាយុ ៣៨ ឆ្នាំ អ្នកមិនបានទទួលផលផ្ទាល់ពីគម្រោង | ១៥ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

**គោលបំណង និងវិធីសាស្រ្ត នៃការវាយតម្លៃដែលបានប្រើ :**

មន្រ្តីត្រួតពិនិត្យ និងវាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យា នៃ គ.ប្រ ខេត្តក្រចេះ បានធ្វើការវាយតម្លៃអនុកិច្ចសន្យា ឆ្នាំ២០០៩ ដែលមានចំណងជើង ( **ការបញ្ជ្រាបគោលគំនិតយេនឌ័រសំខាន់៧ និង ការពង្រឹងបណ្តាញអ្នកទទួលបន្ទុកស្រ្តី និង កុមារភូមិ-ឃុំ តាមរយៈការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ**) និងលេខអនុកិច្ចសន្យា 10/GEN/0901-00 ដែលជាអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខក្រចេះ និងមន្ទីរកិច្ចការនារីខេត្ត។ នេះជាផ្នែកមួយនៃគម្រោងពង្រឹងសមត្ថភាពគ្រូបង្គោលថ្នាក់ក្រោមជាតិរបស់ផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍន៏តាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និង វិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ។

**គោលបំណងជាក់លាក់នៃការវាយតម្លៃនេះគឺ :**

១- ទាញយក កត់ត្រា និងវិភាគតាមលក្ខណៈជាប្រព័ន្ធទៅលើលទ្ធផល និងសមិទ្ធផលនៃអនុកិច្ចសន្យា ស្វែងរកចំណុចខ្សោយ និងចំនុចខ្លាំង ធៀបទៅនឹងលទ្ធលផល គោលបំណងបន្ទាន់ និងស្ថានភាពបញ្ចប់នៃអនុកិច្ចសន្យា ព្រមទាំងកត់ត្រា នូវចំណុច រៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត ។

២- ពង្រឹងរបៀបធ្វើការវាយតម្លៃគម្រោងរបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្តការវាយតម្លៃ អនុវត្តតាមការណែនាំ និងឧបករណ៏ ស្តីពីការវាយតម្លៃអនុកិច្ចសន្យារបស់ គ.ប្រ នៃ គ.អ.ជ.ខ ដែលរៀបចំដោយផ្នែកត្រួតពិនិត្យ វាយតម្លៃ នៃលេខាធិការដ្ឋាន គ.ជ.អ.ប ។ ក្រុមការងារវាយតម្លៃ បានពិនិត្យអនុកិច្ចសន្យា របាយការណ៏រីកចម្រើន និងឯកសារផ្សេងទៀត រួមទាំងការចុះមូលដ្ឋាន ដោយប្រើវិធីសាស្រ្តដូចជា : ការសម្ភាសន៏ស៊ីជម្រៅ ការពិភាក្សាក្រុម និង ការសង្កេតផ្ទាល់ ។ ដោយសារធនធាន និងពេលវេលាមានកំណត់ យើងធ្វើការវាយតម្លៃស៊ីជម្រៅទៅលើតែលទ្ធផល **ពង្រឹងសមត្ថភាពមន្រ្តីបណ្តាញយេនឌ័រ** ប៉ុណ្ណោះ ដោយមិនបានធ្វើការវាយតម្លៃស៊ីជម្រៅលើអនុកិច្ចសន្យាទាំងស្រុងនោះទេ ហើយការសន្និដ្ឋាននេះត្រូវធ្វើឡើងតាមអ្វីដែលបានរកឃើញជាក់ស្តែង

**ឆ្លើយទៅនឹងសំណួរទាំង៥ នៃការវាយតម្លៃ :**

១- សកម្មភាព និងលទ្ធផលដែលបានអនុវត្ត ធៀបនឹងផែនការ :

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣:ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១ | **លទខ.១(២១១០១០០១) ពង្រឹងសមត្ថភាពដល់មន្រ្តីមន្ទីរកិច្ចការនារី**<br>សកខ.១.២ : វគ្គបណ្តុះបណ្តាលស្តីពីជំនាញសំខាន់៧ និង គោលគំនិត | អនុវត្ត០៦វគ្គ រយៈពេល ១២ថ្ងៃ<br>អ្នកចូលរួម១៤០នាក់ ៥៨នាក់ |

| | | |
|---|---|---|
| | យេនឌ័រដល់ថ្នាក់ដឹកនាំភូមិ-ឃុំ អ្នកទទួលបន្ទុកកិច្ចការនារីឃុំ និងមន្ត្រីកិច្ចការនារីស្រុក ចំនួន ៦វគ្គ ក្នុង១វគ្គ រយៈពេល ២ថ្ងៃ មានអ្នកចូលរួម ២២នាក់ /ស្រី៨នាក់ នៅសង្កាត់អូរឬស្សី ក្រុងក្រចេះ | សម្រេចបាន១០០% ក្នុងនោះមាន ១វគ្គ រយៈពេល ២ថ្ងៃអ្នកចូលរួម២២នាក់/៩នាក់ នៅសង្កាត់អូរឬស្សីក្រុងក្រចេះ សម្រេចបាន១០០% ។ |

២-វគ្គបណ្តុះបណ្តាលស្តីពីជំនាញសំខាន់ៗ និងគោលគំនិតយេនឌ័រ ដើម្បីពង្រឹងសមត្ថភាព ដល់មន្ត្រីមន្ទីរកិច្ចការនារី និងថ្នាក់ដឹកនាំភូមិ-ឃុំ និងអ្នកទទួលបន្ទុកស្ត្រី និងកុមារភូមិ បានធ្វើឱ្យស្ថានភាពក្នុងមូលដ្ឋានទាំងមូល មានការ ផ្លាស់ប្តូរដោយបានកាត់បន្ថយនូវអំពើហិង្សាក្នុងគ្រួសារ និងការជួញដូរស្ត្រីភេទ និងកុមារ ព្រមទាំងបណ្តាញទំនាក់ ទំនងយែនឌ័រ និងកែលំអពីតួនាទី ការទទួលខុសត្រូវ និងភាពជាអ្នកដឹកនាំ ត្រូវបានពង្រឹង និងផ្សព្វផ្សាយបន្ត ដោយ ថ្នាក់ដឹកនាំភូមិ-ឃុំ និងអ្នកទទួលបន្ទុកស្ត្រី ។

៣- គោលបំណងបន្ទាន់បានបរិយាយច្បាស់លាស់ ហើយមានទំនាក់ទំនងជាមួយលទ្ធផល និង សកម្មភាព ក៏ប៉ុន្តែ វាមានកម្រិតខ្ពស់ពេក ដែលយើងពិបាកធ្វើការវាស់វែង។

៤- ស្ថានភាពនៅចុងបញ្ចប់នៃអនុកិច្ចសន្យាមានទំនាក់ទំនងទៅនឹងលទ្ធផល និងសកម្មភាព ។ ហើយវាបានឆ្លុះបញ្ចាំងនូវសមិទ្ធិផល ដូចជារួមចំណែកកែលំអគោលនយោបាយ និងបទបញ្ញត្តិនានា សំរាប់វិមជ្ឈការ និងវិសហមជ្ឈ តាមរយៈការលើកកំពស់ការយល់ដឹងពីយេនឌ័រ ការចូលរួមរបស់ស្ត្រីក្នុងដំណើការអភិវឌ្ឍន៍ ការធ្វើការសម្រេចចិត្ត និងតួនាទីរបស់ស្ត្រីនៅក្នុងសង្គម។

៥- ជាក់ស្តែងមន្ទីរកិច្ចការនារីនៅតែជំរុញលើកទឹកចិត្តដល់ក្រុមស្ត្រីក្នុងការបញ្ចេញមតិយោលបល់ និង គាំទ្រដល់ក្រុមការងារចុះធ្វើការវាយតម្លៃ រហូតដល់ចុងបញ្ចប់នៃអនុកិច្ចសន្យាទទួលបានជោគជ័យ។

**សេចក្តីសន្និដ្ឋាន ៖**

១-លទ្ធផល និងអត្ថប្រយោជន៏ដែលបានមកពីការអនុវត្តអនុកិច្ចសន្យា ជាប្រយោជន៏ដល់សហគមន៏។ វាបានឆ្លុះបញ្ចាំងនូវសមិទ្ធផលដូចជាការផ្តល់នូវចំណេះដឹង និងបទពិសោធន៏ល្អអំពីគោលគំនិតយេនឌ័រ ដល់ក្រុមប្រក្សាឃុំ មេភូមិ និងជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារ និងការផ្សព្វផ្សាយបន្តនៅមូលដ្ឋានដែលនាំមកនូវ ការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ ការជួញដូរ ការចាប់រំលោភ ដែលអាចរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រមួយកម្រិត

២- ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីធ្វើឱ្យសម្រេចនូវអត្ថប្រយោជន៏កម្រិតខ្ពស់ ភ្នាក់ងារអនុវត្តគម្រោងគួរតែមានការជ្រើសរើសអ្នកទទួលផល ឬក្រុមគោលដៅឱ្យបានសមស្រប មានចំណេះដឹងជាមូលដ្ឋាន មានឆន្ទៈទទួល

ខុសត្រូវ និងសកម្មក្នុងការងារ ។

៣- គួរមានការបន្តគាំទ្រគម្រោងបែបនេះឱ្យបានទូលំទូលាយ និងគ្រប់តំបន់គោលដៅដែលដាច់ស្រយាលដោយប្រើប្រាស់វិធីសាស្ត្រដូចជា : ក្រុមគោលដៅធ្វើការចុះផ្សព្វផ្សាយបន្តដល់តំបន់គោលដៅដាច់ស្រយាល តាមរយៈការលើកទឹកចិត្ត ជាសោហ៊ុយ ឬសម្ភារៈផ្សេងៗដែលជាតម្រូវការចាំបាច់ជាក់ស្តែង ។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្តល់ថវិកាតាមរយៈគ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និងគម្រោងដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈជាប្រព័ន្ធ មិនបានអនុវត្តទេ កាលពីពេលកន្លងមកដោយមកពីហេតុផលជាច្រើន។ នៅក្នុង ឆ្នាំ២០១០ ជាមួយនឹងការគាំទ្រ ផ្នែកថវិកានិងបច្ចេកទេស ពីផ្នែកត្រួតពិនិត្យវាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល គ.ប្រនៃ គ.អ.ជ.ខ ក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យាដែលបានរៀបចំរួមគ្នាជាមួយភ្នាក់ងារអនុវត្តន៍ ដែលមានលេខអនុកិច្ចសន្យា 10/GEN/0901-00 និងឈ្មោះអនុកិច្ច សន្យា គាំទ្រដល់មន្ទីរកិច្ចការនារីដើម្បីកាត់បន្ថយភាពក្រីក្រ ដំណើរការលទ្ធផលដែលបានរកឃើញ និងការសន្និដ្ឋាន នៃការវាយតម្លៃត្រូវបានកត់ត្រា ហើយនឹងបង្ហាញតាមរយៈរបាយការណ៍ស្តីពីការវាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

គោលបំណងនៃកិច្ចសន្យានេះ គឺផ្តល់ការគាំទ្រដល់មន្ទីរកិច្ចការនារីខេត្ត ក្នុងការអនុវត្តន៍សកម្មភាពនានា និងការគ្រប់គ្រងកម្មវិធីបញ្ជ្រាបយេនឌ័រ ដែលស្របពេលជាមួយគ្នានេះ ក៏នឹងមានការរៀបចំវេទិកាបណ្តាញជនបង្គោល គាំទ្រកិច្ចការនារីតាមភូមិ ឃុំ ស្រុក និងបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ និងជនបង្គោល យេនឌ័រឃុំ មន្ទីរពាក់ពន្ធ័ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិអំពីតួនាទីយេនឌ័រ យុទ្ធសាស្ត្របញ្ជ្រាប យេនឌ័រ ដើម្បីឱ្យពួកគេអាចតាមដានបន្ថែមទៀត ទៅលើការអនុវត្តផែនការ របស់បណ្តាមន្ទីរជំនាញ អង្គភាព ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ ជាពិសេសការអនុវត្តការងារអភិវឌ្ឍន៍នៅមូលដ្ឋាន ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាលេខ 10/GEN/0901-00 ដោយផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលរបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និងតម្លាភាព។ ដូច្នេះទំហំនៃការវាយតម្លៃមានដែនកំណត់ តាមទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខណ្ឌ

ការងារ នៃការវាយតម្លៃ។ គោលបំណង នៃការវាយតម្លៃគឺៈ ក) ទាញយក កត់ត្រា និងវិភាគ ជាប្រព័ន្ធទៅលើសមិទ្ធផល នៃអនុកិច្ចសន្យា និង ចំណុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការ អនុវត្តកិច្ចសន្យា រួមទាំង កត់ត្រានូវ ចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត និង ខ) ដើម្បីពង្រឹងរបៀបធ្វើ ការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើៈ

១) ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំណត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់កិច្ច សន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធដែលមាន នៅក្នុង ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល នៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៍ ។

២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗ រួមមានៈ អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផល ផ្ទាល់ និងជាប្រយោល់ ២ នាក់ និងអ្នកពាក់ព័ន្ធ ២នាក់ ។

៣) វិធីសាស្ត្រចុះពិនិត្យតំបន់អនុវត្តន៍គម្រោង និងសង្កេតមើលសកម្មភាព ពិភាក្សាក្រុម និង ករណីសិក្សា ។

៤) ចុះពិនិត្យតំបន់អនុវត្តន៍គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់។

៥) វិភាគទិន្នន័យ និងបកស្រាយៈ ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់ ។

៦) ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ ដោយភ្នាក់ងារអនុវត្តន៍និងអ្នកពាក់ព័ន្ធ តាមរយៈ

ព័ត៌មាន ត្រឡប់ដែលទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើងនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០ ការវាយតម្លៃ ត្រូវធ្វើតាម "គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា" និងវិធីសាស្ត្រដែលបាន ណែនាំ។ ដូច្នេះដំណើរការត្រូវ បានធ្វើឡើងដោយមានទម្រង់នៃការណែនាំ និងតម្លាភាព រួមទាំងការចូលរួម ពីអ្នកពាក់ព័ន្ធផងដែរ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយ គ.ប្រ និង អ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា ។ ទោះជាយ៉ាងណាក៏ដោយក៏ការប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត ។

២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត : វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោងនៅពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និងបទពិសោធន៍ពីមុនមក។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណង សំខាន់ គឺដើម្បី "រៀនធ្វើដោយការអនុវត្តផ្ទាល់"។ អ្នកវាយតម្លៃ បានទទួលការគាំទ្រ ដោយមាន គោលការណ៍ការ ណែនាំឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។

៣) បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យា: ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិន មាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និងជោគជ័យទេ។ មួយទៀតទំនាក់ទំនង សង្ខេប តាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់ មិនត្រូវ បានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ។

៤) ដោយយើងមិនមានសូចនាកបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍" ដែលជាកម្រិត អត្ថប្រយោជន៍ទៅលើគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។

៥) ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិតទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ។ យើងអាចវាយតម្លៃតែទៅលើការ **ពង្រឹងសមត្ថភាពមន្ត្រីបណ្តាញយេនឌ័រ** ដែលជា លទ្ធផល និង **វគ្គបណ្តុះបណ្តាលស្តីពីជំនាញសំខាន់ៗ និងគោលគំនិតយេនឌ័រដល់ថ្នាក់ដឹកនាំភូមិ-ឃុំ អ្នកទទួល បន្ទុកកិច្ចការនារីឃុំ និងមន្ត្រីកិច្ចការនារីស្រុក** ដែលជាសកម្មភាព

នៃអនុកិច្ចសន្យាលម្អិតតាមរយៈការសម្ភាសន៍ស៊ី ជម្រៅ ក្រុមពិភាក្សា និងការចុះពិនិត្យតំបន់ អនុវត្ត គម្រោង។

៦) ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាមិនអាចធ្វើទៅបានទេព្រោះចំណុច គ នៃផ្នែកទី៣ ក្នុង ឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ ឬមិនពេញលេញ។ ការងារនេះនឹងកាន់តែមានសុពលភាព និងពោរពេញទៅ ដោយព័ត៌មាន បើសិនជាចំណុចដែលបានរៀបរាប់ខាងលើ នេះត្រូវបានដោះស្រាយ។

**<u>ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធន៏:</u>**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះកិច្ចសន្យាលេខ (10/GEN/0901-00) និងដែនកំណត់ ដូចដែលបាន កំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ។

២) ការវាយតម្លៃនេះលម្អិតតែទៅលើលទ្ធផល **ពង្រឹងសមត្ថភាពមន្ត្រីបណ្តាញយេនឌ័រ** និងសកម្មភាព **វគ្គបណ្តុះបណ្តាលស្តីពីជំនាញសំខាន់ៗ និងគោលគំនិតយេនឌ័រ** ដែលជាសកម្មភាពនៃអនុកិច្ចសន្យា ។

៣) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃទៅលើ ភ្នាក់ងារអនុវត្តន៏ ភ្នាក់ងារដែលពាក់ព័ន្ធគម្រោង ហើយនឹង ការវាយតម្លៃទៅលើ គ.ប្រ នៃ គ.អ.ជ.ខ និង គ.ជ.អ.ប ទេ ។

ហេតុដូច្នេះរបាយការណ៏នៃការវាយតម្លៃ លទ្ធផលដែលបានរកឃើញ និងអនុសាសន៏ដែលបានលើកឡើង ត្រូវពិនិត្យដោយយោងទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ។

# ២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល

**លទ្ធផលទី១ : ពង្រឹងសមត្ថភាពមន្ត្រីមន្ទីរកិច្ចការនារី**

***ផ្នែក-ក :ការសម្រេចជាក់ស្តែងធៀបនឹងផែនការ***

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១ | **លទខ.១(២១១០១០០១) ពង្រឹងសមត្ថភាពដល់មន្ត្រីមន្ទីរកិច្ចការនារី**<br>សកខ.១.២ : វគ្គបណ្តុះបណ្តាលស្តីពីជំនាញសំខាន់ៗ និង គោលគំនិត យេនឌ័រដល់ថ្នាក់ដឹកនាំភូមិ-ឃុំ អ្នកទទួលបន្ទុកកិច្ចការនារីឃុំ និងមន្ត្រី កិច្ចការនារីស្រុក ចំនួន ៦វគ្គ ក្នុង១វគ្គ រយៈពេល២ថ្ងៃ។ ក្នុងនោះមាន ១វគ្គ រយៈពេល ២ថ្ងៃ អ្នកចូលរួម ២២នាក់ /៩នាក់ នៅសង្កាត់អូរឬស្សី ក្រុងក្រចេះ ។ | អនុវត្ត០៦វគ្គ រយៈពេល ១២ថ្ងៃ អ្នកចូលរួម១៤០នាក់ ៥៨នាក់ សម្រេចបាន១០០%<br>ក្នុងនោះមាន ១វគ្គ រយៈពេល ២ថ្ងៃអ្នកចូលរួម២២នាក់/៩នាក់ នៅសង្កាត់អូរឬស្សីក្រុងក្រចេះ សម្រេចបាន១០០% ។ |

**ផ្នែក**-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និងសកម្មភាពរបស់អនុកិច្ចសន្យាដែលបានគ្រោងទុក អ្នកចូលរួមទាំងអស់នៅក្នុងវគ្គបណ្តុះបណ្តាលនេះបានបញ្ជាក់ថាគេបានទទួលនូវចំណេះ ដឹង និងជំនាញដែលទាក់ទងទៅនឹងការ**ពង្រឹងសមត្ថភាពមដល់ន្ត្រីបណ្តាញយេនឌ័រថ្នាក់ដឹកនាំភូមិ-ឃុំ** ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺ ពួកគាត់នៅមានការចងចាំផ្នែកទ្រឹស្តី ស្តីពីការបញ្ចូលគោលគំនិតយេនឌ័រ។ ម្យ៉ាងទៀតទោះបីជាវគ្គនេះបានបញ្ចប់យូរទៅហើយក្តី ក៏វិធីសាស្ត្រដែលមន្ទីរជំនាញបានយកទៅបណ្តុះបណ្តាលនោះ បានធ្វើឱ្យសិក្ខាកាមភាគច្រើនចូលចិត្ត និងមានការចាប់អារម្មណ៍ខ្ពស់ហើយវិធីសាស្ត្រដែលយកមកប្រើរួមមានការបំផុសគំនិតតាមរយៈរូបភាព និងពិភាក្សាក្រុម... ។ ល ។ ថ្នាក់ដឹកនាំ ភូមិ-ឃុំ អ្នកទទួលបន្ទុកកិច្ចការនារីឃុំ និង មន្ត្រីកិច្ចការនារីស្រុកបាទទួលចំណេះដឹង ស្តីពីជំនាញសំខាន់ៗ និងគោលគំនិតយេនឌ័រ ដែលជាវគ្គពង្រឹងសមត្ថភាព ដើម្បីយកទៅ ផ្សព្វផ្សាយបន្តដែលជាហេតុធ្វើឱ្យស្ថានភាពក្នុងមូលដ្ឋានទាំងមូលមានការផ្លាស់ប្តូរ និងកាត់បន្ថយ អំពើហឹង្សាក្នុងគ្រួសារ ការជួញដូរស្ត្រីភេទ ...។ ល។

ទន្ទឹមនឹងលទ្ធផលខាងលើនេះ ក៏នៅមានបញ្ហាមួយចំនួនដែរ ដោយក្រុមគោលដៅមិនយកចំណេះដឹងទៅផ្សព្វផ្សាយបន្ត និងអនុវត្តឱ្យបានទូលំទូលាយ ដល់សហគមន៍ ។

## ២.២. ការវាយតម្លៃសម្រេចលើអត្ថប្រយោជន៍ភ្លាមៗ ការសម្រេចបាននូវលទ្ធផល អនុកិច្ចសន្យា

## ផ្នែក-កៈ ការសម្រេចបាននូវស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា

| ស្ថានភាពនៅពេលបញ្ចប់កិច្ចសន្យា (១) | លទ្ធផលប្រសើរឡើងជាក់ស្តែងនៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| **វគ្គបណ្តុះបណ្តាលស្តីពីជំនាញសំខាន់ៗ និងគោលគំនិតយេន ឌ័រ ដល់ថ្នាក់ដឹកនាំភូមិ-ឃុំ អ្នកទទួល បន្ទុកកិច្ចការនារីឃុំ និងមន្ត្រីកិច្ចការនារីស្រុក** ចំនួន១វគ្គ មានសិក្ខាកាមចូលរួម ចំនួន២២ នាក់/ស្រ្តី០៩នាក់ (នៅក្នុងសង្កាត់អូរឬស្សី) | ក្រុមគោលដៅចូលរួមមានចំនួន២២នាក់/ស្រី០៩ នាក់ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីជំនាញសំខាន់ៗ និងគោលគំនិតយេនឌ័រ ជាក្រុមគោលដៅ ដែលមន្ទីរបាន ជ្រើសរើសតាមរយៈ ការស្ម័គ្រចិត្ត និងផ្អែកលើ ចំណេះ ដឹងជាមូលដ្ឋានរបស់ពួកគាត់ ។ វគ្គបានឆ្លើយ តបទៅ នឹងតម្រូវការស្របពេលដែល ស្ថានភាពក្នុងសហគមន៍ កំពុងជួបប្រទះ ដូចជា អំពើហឹង្សា ក្នុងគ្រួសារ ការជួញ ដូរផ្លូវភេទ ការចាប់រំលោភផ្លូវភេទកុមារមិនទាន់ គ្រប់អាយុ...។ល។ ដោយសារឆន្ទៈ និងភាពសកម្ម ចូលរួម ថែមទាំងមាន សំណួរផុលផុស និងមានការ ផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមករបស់សិក្ខាកាមរួមទាំងអ្នកសម្របសម្រួលមានទេព្យកោសល្យ និងភាពប៉ិនប្រសព្វ មិនតែប៉ុណ្ណោះក្រោយពីវគ្គត្រូវ បានបញ្ចប់មួយរយៈ គ្រូបានចុះតាមដានសកម្មភាព ក្រុមគោលដៅផងនោះ វារឹតតែមានសារៈសំខាន់ ណាស់សម្រាប់ពួកគាត់មានឱកាសសាកសួរបន្ថែម នូវចម្ងល់នានា ដែលធ្វើឱ្យពួកគាត់មានចំណេះដឹង និង សមត្ថភាពកាន់តែប្រសើរឡើងក្នុងការផ្សព្វផ្សាយបន្ត ប្រកដោយប្រសិទ្ធភាព និងធ្វើឱ្យស្ថានភាពក្នុងមូល ដ្ឋានទាំងមូល មានការផ្លាស់ប្តូរ និងកាត់បន្ថយបាននូវ អំពើហឹង្សាក្នុងគ្រួសារ និងសកម្មភាពនានាមួយចំនួន ទៀត។ |

## ផ្នែក-ខ: ការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា

| ធាតុនៃទិសដៅបន្ទាន់ (១) | ការសម្រេចបាន/លទ្ធផលជាក់ស្តែង នៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| ដោយផ្អែកទៅសភាពការណ៍នៃបញ្ហារបស់សហគមន៍ និងតំរូវការនៅមូលដ្ឋានដែលកំពុងកើតមាន ហើយត្រូវការជាចាំបាច់ដើម្បីកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារការ រកស៊ីជួញដូរស្ត្រី និងកុមារ តាមរយៈការលើកកំពស់ស្ត្រីឱ្យ មានការចូលរួមយ៉ាងសកម្មក្នុងការសំរេចចិត្ត តាមរយៈការ បណ្តុះបណ្តាល ផ្សព្វផ្សាយបន្ត និងជាពិសេស សំរាប់ការ កែលំអពីតួនាទី ការទទួលខុសត្រូវ និង ភាពជាអ្នកដឹកនាំ ដើម្បីអភិវឌ្ឍន៍នៅមូលដ្ឋាន ។ | គោលបំណងបន្ទាន់បានចែងនេះមានកម្រិតខ្ពស់ ដែលធ្វើឱ្យ ពិបាកវាស់វែងនៅចុងបញ្ចប់នៃអនុកិច្ចសន្យា។ ទោះបីគេរំពឹងទុកថាលទ្ធផល និងសកម្មភាព និងចូលរួមទៅក្នុងគោលបំណងបន្ទាន់ ប៉ុន្តែដោយការពិនិត្យលើឯកសារ និង វិធីសាស្រ្ត វាយតម្លៃតាមបែបគុណភាព គេមិនអាចធ្វើការវាយតម្លៃថា តើគោលបំណងបន្ទាន់នេះសម្រេចបានកម្រិតណានោះឡើយ ។ |

## ផ្នែក-គ: ការវាយតម្លៃអត្ថប្រយោជន៍ជារួមដែលទទួលបាន

| |
|---|
| តាមរយៈការពិភាក្សាជាមួយក្រុមអ្នកទទួលផលបានបង្ហាញថា ពួកគាត់មានការពេញចិត្តចំពោះផលប្រយោជន៍ដែលអនុកិច្ចសន្យានេះ សម្រេចបានជាពិសេសចំណេះដឹង ស្តីពីវគ្គជំនាញសំខាន់ៗ និងគោលគំនិតយេនឌ័រ។ ពួកគាត់បានទទួលស្គាល់ថា វាមានសារៈប្រយោជន៍សម្រាប់គ្រួសារ និងសហគមន៍ទាំងមូល ព្រោះវាជាតំរូវការរបស់សហគមន៍ និងមូលដ្ឋាន។ ទោះជាលទ្ធផល ខាងលើនេះមានលក្ខណៈល្អ ប្រសើរក៏ដោយ ក៏ប្រជាពលរដ្ឋក្នុងសហគមន៍ ប្រមាណតែ៦០%ប៉ុណ្ណោះ ដែលបានទទួលផលពីគម្រោងនេះ ។ ទន្ទឹមនេះដែរប្រជាពលរដ្ឋមួយចំនួនទៀតមិនបាន ទទួលផលពីគម្រោងនេះ ដោយសារពួកគាត់ រស់នៅតំបន់ឆ្ងាយដាច់ប្រយាល ភូមិសាស្រ្តមានការលំបាកក្នុងការធ្វើ ដំណើរ និងការទំនាក់ទំនង ។ |

## ករណីសិក្សា

### ករណីសិក្សាទី១ (អ្នកទទួលផលផ្ទាល់)



**លោក ហ៉ៅ ជឿន**

បន្ទាប់ពីចូលរួមក្នុងគម្រោងបញ្ហាយេនឌ័រ ដែលអនុវត្តដោយមន្ទីរកិច្ចការនារីខេត្តរួចមក លោក **ហ៉ៅ ជឿន** អាយុ ៦២ឆ្នាំ ជាក្រុមប្រឹក្សាសង្កាត់អូឫស្សី រស់នៅក្នុងភូមិអូរឫស្សី១ សង្កាត់អូឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ បាននិយាយថា ÷ ខ្ញុំ និងគ្រួសារខ្ញុំមានការយល់ដឹងច្រើន ពីបញ្ហាយេនឌ័រ។ លោក **ហ៉ៅ ជឿន** បានរៀបរាប់បន្តទៀតថាៈគម្រោងបណ្តុះបណ្តាលនេះមានសារៈសំខាន់ខ្លាំងណាស់ ព្រោះគាត់បានទទួលចំណេះដឹង និងយល់បានកាន់តែច្បាស់ពីបញ្ហាយេនឌ័រ និងអំពើហឹង្សាក្នុងគ្រួសារ ដើម្បីធ្វើការផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ឱ្យបានយល់គ្រប់ៗគ្នា។ គាត់ក៏បានបញ្ជាក់ទៀតថាៈ កាលពីដំបូងនៅ ក្នុងសហគមន៍មានកើតឡើងនូវ អំពើហឹង្សាច្រើន ជាពិសេសចំពោះយុវវ័យ ប្រុសៗ ដែលចូលចិត្តបង្ករជំលោះ វាយតប់គ្នាជារឿយៗ។ ភាគច្រើនបុរសៗតែងតែគិតថា ស្ត្រីគួរតែនៅផ្ទះដាំបាយ មើលកូន គឺគ្រប់គ្រាន់ហើយ មិនគួរទៅជ្រៀតជ្រែក ក្នុងការងារសង្គមនោះទេ។ បន្ទាប់ពីបានទទួលការផ្សព្វផ្សាយពីច្បាប់ និង គោលគំនិតយេនឌ័របន្តដល់សហគន៏ក៏ដូចជាក្នុងភូមិរបស់ខ្ញុំ និងភូមិផ្សេងៗទៀត ឃើញថា មានការប្រែប្រួលយ៉ាងច្រើន ដូចជាៈ អំពើហឹង្សាក្នុងគ្រួសារត្រូវបានកាត់បន្ថយយ៉ាងច្រើន ជាពិសេស ស្ត្រីមានការយល់ដឹងពីតួនាទីរបស់ខ្លួន និងចូលរួមក្នុងការអភិវឌ្ឍសហគមន៍ យ៉ាងផុសផុល ។ ជាចុងបញ្ចប់ គាត់បានបង្ហាញការប្តេជ្ញាចិត្ត និងទឹកចិត្តក្នុងការបន្តសកម្មភាពផ្សព្វផ្សាយបញ្ហាយេនឌ័រ និងអំពើហឹង្សាដល់សហគន៏របស់គាត់ ទោះជាមិនបានទទួលអ្វីពីគម្រោងក៏ដោយ ។ គាត់និយាយថាៈ គម្រោងនេះ ពិតជាមានប្រយោជន៏ខ្លាំងណាស់។ វាអាចកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ កាត់បន្ថយ ការធ្វើចំណាកស្រុករបស់ អ្នកភូមិ និងជួយអោយស្ត្រីមានឱកាសច្រើនក្នុងការ អភិវឌ្ឍន៏សហគមន៏ និងប្រទេសជាតិទាំងមូល ឱ្យមានការរីក ចំរើនទៀតផង។

## ករណីសិក្សាទី២ :( អ្នកទទួលផលមិនផ្ទាល់ )



**លោក ជិន សម្ផស្ស**

លោក **ចិន សម្ផស្ស** អាយុ ៣៨ ឆ្នាំ រស់នៅភូមិ អូរឫស្សី២ សង្កាត់ អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ។ គាត់មានគ្រួសារ និងកូន៥នាក់ ( ស្រី ៣នាក់ និងប្រុស ២នាក់) ។ គាត់គឺជាសមាជិកក្រុមប្រឹក្សាសង្កាត់អូរឫស្សី ដែលទើបតែជ្រើសរើសចូលថ្មី ។

លោក **ចិន សម្ផស្ស** មិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលពីច្បាប់ ជំនាញសំខាន់៧ និងគោលគំនិតយ៉េនឌ័រ របស់ គ.អ.ជ.ខ ខេត្តក្រចេះ ដែលអនុវត្តដោយមន្ទីរកិច្ចការនារីខេត្តទេ។ គាត់មិនត្រូវបានជ្រើសរើសឱ្យចូលរួមដោយសារ គាត់នៅពេលនោះ គាត់មិនទាន់ក្លាយជាសមាជិកក្រុមប្រឹក្សាសង្កាត់នៅឡើយ ហើយវគ្គនោះ តម្រូវឱ្យតែអ្នកដែលជាសមាជិកក្រុម ប្រឹក្សាសង្កាត់ប៉ុណ្ណោះ ព្រោះពួកគាត់មានលទ្ធភាពច្រើនក្នុងការផ្សព្វផ្សាយបន្តដល់សហគមន៍។ គាត់និយាយថា វគ្គបណ្តុះបណ្តាល ពីច្បាប់ ជំនាញសំខាន់៧ និងគោលគំនិតយេនឌ័រ មានសារៈសំខាន់ណាស់ ព្រោះវាធ្វើឱ្យប្រជាពលរដ្ឋបានយល់ ដឹងពីច្បាប់ និងបញ្ហាយេនឌ័រក្នុងគ្រួសារ បញ្ហាអេដស៍ ចេះយោគយល់គ្នា និងអប់រំខ្លួនឯងផង។ គាត់បានបន្ថែមទៀតថា ឥឡូវនេះសហគមន៍ ក្រោយពីបានទទួលការផ្សព្វផ្សាយពីវគ្គនេះ តាមរយៈសមាជិកក្រុមប្រឹក្សាសង្កាត់ អំពើហឹង្សាក្នុងគ្រួសារត្រូវបានកាត់បន្ថយ ការឈ្លោះវាយតប់គ្នានៅក្នុងសហគន៍ពុំសូវកើតមាន ព្រោះប្រជាជនបានយល់ដឹងពីច្បាប់ និងបញ្ហាយេនឌ័រ ស្ត្រីមានការយល់ដឹងពីតួនាទីរបស់ខ្លួនក្នុងការចូលរួមអភិវឌ្ឍន៍សហគមន៍។

ចុងបញ្ចប់គាត់បន្ថែមទៀតថា អំពើហឹង្សាកើតមានច្រើនក្នុងពេលបច្ចុប្បន្ន ជាពិសេសអំពើហឹង្សាក្នុងគ្រួសារ។ គាត់បានទទូចឱ្យមន្ទីរវិស័យ អង្គការ និងភ្នាក់ងារពាក់ពន្ធ័ ជួយលើកកម្ពស់ ការបញ្ជ្រាបយេនឌ័រឱ្យបានច្រើនបន្តទៀត និងសូមឱ្យជួយគាំទ្រគម្រោងបណ្តុះបណ្តាលអំពី ច្បាប់អំពើហឹង្សា និង បញ្ហាយេនឌ័រដល់សហគន៍ឱ្យបានជាប់ ជាប្រចាំ។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

**ផ្នែក-កៈ ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅតាមតម្រូវការៈ មន្ទីរវិស័យ មូលដ្ឋាន គ.ជ.អ.ប និងការកាត់បន្ថយភាពក្រីក្រៈ**

*សំគាល់:ពិន្ទុ ១= ខ្សោយណាស់២= ខ្សោយ ៣=មធ្យម ៤=ខ្លាំង ៥=ខ្លាំងណាស់)*

| ល.រ (១) | ធាតុ (២) | ទំនាក់ទំនងតក្កភាព (៣) | បរិយាយច្បាស់លាស់ (៤) | សង្ខេបការវាយតម្លៃ (៥) |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៤ | ៤ | ការសរសេរអនុក្កិសន្យា និងការអនុវត្តសកម្មភាពនេះមានភាពស៊ីជម្រៅ និងមានទំនាក់ទំនងទៅនឹងតក្កភាព ថែមទាំងបានឆ្លើយតបជាមួយក្រុមគោលដៅ។ ឧទាហរណ៏:វគ្គបណ្តុះបណ្តាលស្តីពីជំនាញសំខាន់ៗ និងគោលគំនិតយេនឌ័រដល់ ថ្នាក់ដឹកនាំភូមិ-ឃុំ អ្នកទទួលបន្ទុកកិច្ចការនារី ឃុំ និងមន្ត្រីកិច្ចការនារីស្រុក ចំនួន ១វគ្គមានអ្នក ចូលរួម ២២នាក់/ស្ត្រី០៩នាក់ |
| ២ | លទ្ធផល | ៤ | ៤ | ដោយសារលទ្ធផលនៃការជ្រើសរើស ថ្នាក់ដឹកនាំ ភូមិ-ឃុំ អ្នកទទួលបន្ទុកកិច្ចការ នារីឃុំ សម្រាប់ បណ្តុះបណ្តាលឱ្យក្លាយជាភ្នាក់ងារផ្សព្វផ្សាយបន្ត នៅមូលដ្ឋាន ហើយសកម្មភាពបណ្តុះបណ្តាល នេះវាបានឆ្លើយតប ទៅនឹងតម្រូវការ ដោយ គាត់ទទួលបានចំណេះដឹងទាំងនេះ យកទៅផ្សព្វ ផ្សាយបន្តឱ្យទាន់ពេល និងតំរូវការនៅមូលដ្ឋាន របស់គាត់ ។ |
| ៣ | - គោលបំណងបន្ទាន់ *(គោលបំណងស្ថិតក្នុងចំណុច "ខ" នៃផ្នែកទី ៣)* | ៤ | ៤ | គោលបំណងបន្ទាន់បានបរិយាយច្បាស់លាស់ ហើយមានទំនាក់ទំនងជាមួយលទ្ធផល និង សកម្មភាព ក៏ប៉ុន្តែវាមានកម្រិតខ្ពស់ពេក ដែល |

| | | | | |
|---|---|---|---|---|
| | | | | យើងនឹងពិបាកធ្វើការវាស់វែងបាន ។ |
| ៤ | ស្ថានភាពចុងបញ្ចប់នៃអនុកិច្ច សន្យា (ចំណុច គ នៃផ្នែកទី៣) | ៤ | ៤ | ស្ថានភាពនៅចុងបញ្ចប់នៃអនុកិច្ចសន្យាមានទំនាក់ទំនង ទៅនឹងលទ្ធផល និងសកម្មភាព។ ហើយវាបានឆ្លុះបញ្ចាំង នូវសមិទ្ធផលដូចជាការផ្តល់នូវចំណេះដឹងសេវា និងការអនុវត្តជាក់ស្តែង នៅមូលដ្ឋាន ដែលនឹងនាំមកនូវការបញ្ចូល គោលគំនិតយេនឌ័រ ដល់ថ្នាក់ដឹកនាំដើម្បីផ្សព្វផ្សាយបន្តទៅមូលដ្ឋាន ប៉ុន្តែវាមិនបាន ឆ្លុះបញ្ចាំង នូវស្ថានភាពចុងបញ្ចប់ ឬផលប៉ះពាល់ដែលអាច កើតមានឡើង ក្នុងកម្រិត ប្រជាជន និងសហគមន៍ ទេ ព្រោះវាគ្មានភស្តុតាង ច្បាស់លាស់ណាមួយ ដើម្បីបង្ហាញថាតើក្រុមគោលដៅបានយក ចំណេះដឹង និងជំនាញ ដែលពួកគេទទួលបាន ទៅធ្វើជាប្រយោជន៍ក្នុងការធ្វើឱ្យប្រសើរឡើង នូវជីវភាពរស់នៅ ឬការកាត់បន្ថយនូវអំពើហឹង្សា និងកាត់បន្ថយសកម្មភាពផ្សេងៗទៀត ដែលកើត ឡើងនៅមូលដ្ឋាន របស់ពួកគាត់បន្តទៀត ឬ យ៉ាងណា ។ |

**ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារ:**

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.ជ.អ.ខ :** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | ជំនាញការរៀបចំកិច្ចសន្យានៅមានកម្រិតនៅឡើយ ដែលត្រូវ ការជួយពង្រឹងសមត្ថភាពបន្ថែម ។ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យ ការ | ការគាំទ្រមានភាពរលូនគ្មានការប្រឈម និងឧបសគ្គ |

| | | |
|---|---|---|
| | អនុវត្តន៍ របស់ភ្នាក់ងារអនុវត្តន៍ | ដែលនាំឱ្យរាំងស្ទះដល់កិច្ចដំណើរការរបស់គម្រោងនោះឡើយ ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារអនុកិច្ចសន្យា | មានការរៀបចំទុកដាក់ឯកសារ និងការកត់ត្រាឯកសារដែលទាក់ទង និងអនុកិច្ចសន្យាបានល្អ ។ |
| **ពីខាងភាគីអនុវត្តន៍កិច្ចសន្យា :** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | មន្ត្រីមានជំនាញ និងបទពិសោធន៍គ្រប់គ្រាន់ |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | ការអនុវត្តសកម្មភាព និង លទ្ធផលមិនទាន់ពេលវេលាតាមការគ្រោងទុក ។ |
| ៦ | ការរាយការណ៍ពីការរីកចម្រើន និងការកត់ត្រាឯកសារ | មានរបាយការណ៍ការរីកចម្រើន ប៉ុន្តែមិនឃើញមានការកត់ត្រាឯកសារផ្សេងៗដូចជាកំណត់ហេតុប្រជុំនិងឯកសារចុះតាមដានការអនុវត្តគម្រោង ។ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | ត្រូវបានបំពេញ តាមលក្ខខណ្ឌកិច្ចសន្យា |
| **ទាំងខាង គ.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យា :** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្ទុត់" (ចំណុច-ង ផ្នែកទី៣) និងបញ្ហាប្រឈម | មានការរៀបចំផែនការគ្រប់គ្រង និងបានកំណត់ "ហានិភ័យនិងកត្តាសន្ទុត" និងបញ្ហាប្រឈម ។ |
| ៩ | ការបញ្ជ្រាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | មានការបញ្ជ្រាបយេនឌ័រទៅក្នុងគម្រោង |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ ( ចំណុច-ឆ ផ្នែកទី៣) | គម្រោងមានបញ្ចូលការគ្រប់គ្រងធនធានធម្មជាតិ |
| ១១ | ការថែរក្សា (និរន្តភាព) ( ចំណុច-ជ ផ្នែកទី៣) | សកម្មភាព និងបច្ចេកទេសខ្លះៗ ដែលបានកើតឡើងដោយគម្រោងបានមើលឃើញថាបានយកទៅអនុវត្តដោយសិក្ខាកាម ហើយបានបន្តរហូតដល់ពេលក្រុមការងារចុះទៅវាយតម្លៃ ។ ដូច្នេះនិរន្តរភាពគម្រោងត្រូវបានសម្រេច ។ |

## ២.៤. សេចក្តីសន្និដ្ឋាន

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យាត្រូវបានអនុវត្តដូចការគ្រោងទុក ។ភាគីអនុវត្តអនុកិច្ចសន្យាជាមន្ត្រីមានសមត្ថភាព បទពិសោធន៍ និងធនធានគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោងដែលបានចុះកិច្ចសន្យាជាមួយ គ.ប្រ នៃ គ អ ជ ខ ។ សកម្មភាព និងលទ្ធផល ដែលបានគ្រោងទុកបានអនុវត្តរួចរាល់ ទោះបីមានការយឺតយ៉ាវបន្តិចបន្តួចក្តី ។ |
| ២ | លទ្ធផល និងអត្ថប្រយោជន៍ដែល បានមកពីការអនុវត្តអនុកិច្ចសន្យា ជាប្រយោជន៍ដល់សហគមន៍ វាបានឆ្លុះបញ្ចាំងនូវសមិទ្ធផល ដូចជាការផ្តល់នូវចំណេះដឹងផ្សាភ្ជាប់នឹងការរស់នៅជាក់ស្តែងនៅមូលដ្ឋាន ដែលនាំមកនូវ ការកាត់បន្ថយអំពើហឹង្សា និងសកម្មភាពនានាទៀតដែលមានក្នុងមូលដ្ឋាន និងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជន តាមរយៈវគ្គបណ្តុះបណ្តាលនេះ ។ សកម្មភាពអនុកិច្ចសន្យាបានអនុវត្តដោយជោគជ័យ មានការពេញចិត្ត និងចូលរួមយ៉ាងសកម្មពីភ្នាក់ងារ និង សហគមន៍តំបន់គោលដៅ នូវសមិទ្ធផលដែលបានផ្តល់ឱ្យពួកគាត់ ។ ជាក់ស្តែងក្រុមគោលដៅ និង សហគមន៍នៅតែអនុវត្តបន្តរហូតដល់ក្រុមការងារចុះធ្វើការវាយតម្លៃ ដែលធ្វើឱ្យស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាទទួលបានជោគជ័យ ។ |
| ៣ | (ផ្តោតលើឧបសគ្គ និងការប្រឈមចំបងៗ ដែលអាចជៀសវាងបាន) ក្នុងអំឡុងពេលអនុវត្តអនុកិច្ចសន្យាមានជួបឧបសគ្គ និងការប្រឈមខ្លះៗ ដូចជា : កត្តាធនធានមនុស្ស ធម្មជាតិ (ទឹកជំនន់ ) ភូមិសាស្ត្រតំបន់ដាច់ស្រយាល ទោះបីបានជួបនូវបញ្ហាប្រឈម ដូចបានរៀបរាប់ខាងលើ ក៏គម្រោងនៅតែអនុវត្តបានជោគជ័យ តាមការគ្រោងទុក ។ |

ចំណុចរៀនសូត្រ:

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ផលប៉ះពាល់នៃការអនុវត្តអនុកិច្ចសន្យា និងលទ្ធផលដែលសម្រេចបាន នៅតែមាននិរន្តភាព ក្នុងកម្រិតខ្ពស់ ពីព្រោះអនុកិច្ចសន្យាបានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ជាអាទិភាពរបស់ក្រុមគោលដៅ និង សហគមន៍ ។ |
| ២ | ក្នុងគោលបំណងបន្ទាន់នៃអនុកិ្ចសន្យាបានបរិយាយច្បាស់លាស់ឆ្លើយតប នឹងតម្រូវការជាក់ស្តែងជាអាទិភាពរបស់ក្រុមគោលដៅ និងសហគមន៍ ដែលអាចវាយតម្លៃបានសម្រាប់ទុកជាបទពិសោធន៍ ។ |

<u>អនុសាសន៍</u> :

| ល.រ | អនុសាសន៍ |
|---|---|
| ១ | ការរៀបរៀងអនុកិច្ចសន្យាមានលក្ខណៈទូលំទូលាយពេកដោយក្តោបតែទៅលើការកាត់បន្ថយភាពក្រីក្រមិនបានលំអិតច្បាស់លាស់លើចំណុចតម្រូវការបន្ទាន់សកម្មភាពរបស់លទ្ធផលនិងអត្ថប្រយោជន៍ដែលបានគ្រោងទុក ។ |
| ២ | ត្រូវពង្រឹងការទំនាក់ទំនងល្អជាប្រចាំ រវាងភ្នាក់ងារអនុវត្ត និង គ.ប្រ នៃ គ អ ជ ខ ដើម្បីធ្វើឱ្យការអនុវត្តគម្រោង ទទួលបានជោគជ័យប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ |
| ៣ | សកម្មភាពត្រូវអនុវត្តតាមផែនការដែលបានគ្រោងទុកដើម្បីឱ្យអនុកិច្ចសន្យាទទួលបានជោគជ័យ |
| ៤ | ភ្នាក់ងារអនុវត្តអនុកិច្ចសន្យាត្រូវធានាលើការរៀបចំ និងទុកដាក់ឯកសារឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ ។ |
| ៥ | ត្រូវមានការលើកទឹកចិត្តដល់ភ្នាក់ងារអនុវត្តគម្រោង និងបង្កើនការចុះតាមដានដល់ក្រុមគោលដៅ ដើម្បីធ្វើឱ្យគម្រោងមាននិរន្តភាព ។ |

## ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

**ឯកសារដែលត្រូវភ្ជាប់ទី១ :**

**បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យារបាយការណ៍និងឯកសារទាក់ទងផ្សេងៗដែលបានពិនិត្យ**

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) | មាន (៣) |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និងឯកសារវិសោធនកម្ម (ប្រសិនមាន) | ✓ |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ | |
| ៣ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | ✓ |
| ៤ | លិខិតឆ្លើយឆ្លងរវាងភ្នាក់ងារអនុវត្តន៍ និងគណៈកម្មាធិការប្រត្តិបត្តិគ.អ.ជ.ខ | |
| ៥ | បញ្ជីវត្ថុបណ្តុះបណ្តាលដែលមានក្នុងអនុកិច្ចសន្យា | ✓ |
| ៦ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា | ✓ |
| ៧ | ឯកសារដ៏ទៃទៀតរួមមាន រូបថតនៃគម្រោង (អនុកិច្ចសន្យា) ដែលទុកនៅ គណៈកម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ និងនៅភ្នាក់ងារអនុវត្តន៍ ដែលមិនបានរៀបរាប់ខាងលើ | |
| ៨ | ផ្សេងទៀត | |

## ឯកសារដែលត្រូវភ្ជាប់ទី២ : ឯកសារអនុកិច្ចសន្យា លេខ (10/GEN/0109-00) ខេត្តក្រចេះ

## បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាសន៍/ជួបពិភាក្សា

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៍ប្រើសម្រាប់ប្រមូល ទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | ២៩/៩/០១០ ព្រឹក | លោកស្រី ខាត់ សុខឃៀន អនុប្រធាន មន្ទីរកិច្ចការនារីខេត្ត | មន្ទីរកិច្ចការនារីខេត្ត | សម្ភាសន៍ស៊ីជម្រៅ |
| ២ | ២៩/៩/០១០ ព្រឹក | លោក ជៅ ចន្ទ្រ ទីប្រឹក្សាតាមដាន និង វាយតម្លៃមន្ទីរវិស័យ PSDD | គ.ប្រ | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | ២៩/៩/០១០ ព្រឹក | **ក្រុមអ្នកទទួលផល** | សង្កាត់អូរឫស្សី | សម្ភាសន៍ជាក្រុម |
| ៤ | ២៩/៩/០១០ ល្ងាច | លោក លោក ហ៊ៅ ជឿន អ្នកទទួលផលផ្ទាល់ | ភូមិអូរឫស្សីទី១ | សម្ភាសន៍ស៊ីជម្រៅ/ករណីសិក្សា |
| ៥ | ២៩/៩/០១០ ល្ងាច | លោក ជិន សម្ផស្ស អ្នកមិនទទួលផល | ភូមិអូរឫស្សីទី២ | សម្ភាសន៍ស៊ីជម្រៅ/ករណីសិក្សា |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | 11/AGR/0901-00 ( NRML ) |
| ចំណងជើង : | កែលំអការគ្រប់គ្រងធនធានធម្មជាតិ និងការចិញ្ចឹមជីវិតតាមរយៈការកែលំអផលិតផលកសិកម្ម |
| ភ្នាក់ងារអនុវត្តន៍ : | មន្ទីរកសិកម្ម |
| រយៈពេល (ចាប់ផ្តើម និងបញ្ចប់) | ០១ មករា ឆ្នាំ២០០៩ ដល់ ៣១ ធ្នូ ឆ្នាំ២០០៩ |
| រាជធានី ខេត្ត | មណ្ឌលគិរី |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរកសិកម្ម |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ/គ.អ.ជ.ខ | USD 10,500.00 |
| ការរួមចំណែករបស់រាជធានី ខេត្ត | 00 |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៍ | USD 1,050.00 |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | USD 11,550.00 |

## ក្រុមវាយតម្លៃ

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ |
|---|---|
| លោក ម៉ែន ផល្លីន | គ្រូបង្គោលប្រចាំខេត្តមណ្ឌលគិរី |
| លោក ខឿន ញឹម | គ្រូបង្គោលប្រចាំខេត្តមណ្ឌលគិរី |
| លោក ខៀវ សុខលីម | មន្ត្រីតាមដានត្រួតពិនិត្យ និងវាយតម្លៃ គ.ប្រ នៃ គ.អ.ជ.ខ |
| លោក អ៊ឹម នឿន | មន្ត្រីតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់មន្ទីរកសិកម្ម |

## របាយការណ៍ស្តីពីវាយតម្លៃ រៀបចំដោយ:

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ និងតួនាទីក្នុងការវាយតម្លៃ |
|---|---|
| លោក ម៉ែន ផល្លីន | គ្រូបង្គោលតាមដាន និងវាយតម្លៃប្រចាំខេត្ត |
| លោក ខឿន ញឹម | គ្រូបង្គោលតាមដាន និងវាយតម្លៃប្រចាំខេត្ត |
| លោក ខៀវ សុខលីម | មន្ត្រីតាមដានត្រួតពិនិត្យ និងវាយតម្លៃ គ.ប្រ |
| | |

ខេត្ត មណ្ឌលគិរី

កាលបរិច្ឆេទ : តុលា ២០១០

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៤ |
| | របាយការណ៍សង្ខេប | ៥ |
| **១** | **ទិដ្ឋភាពរួម នៃការវាយតម្លៃ** | **៨** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៨ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៨ |
| ១.៣ | គោលបំនង និង ទំហំនៃការវាយតម្លៃ | ៨ |
| ១.៤ | សំណួរវាយតម្លៃ | ៩ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ៩ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ១០ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១២** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១) | ១២ |
| | - លទ្ធផលទី១ | ១២ |
| | - លទ្ធផលទី២ | ១៤ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម (សំណួរវាយតម្លៃទី៣) | ១៥ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤) | ២០ |
| **២.៤** | **សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី៥)** | **២៣** |
| | | |
| **ករណីសិក្សា** | | **១៨** |
| ទី១- | " ជីវភាពរស់នៅមានភាពប្រសើរ " អ្នកទទួលផល នៃសហគមន៍បឹងយក្សឡោម នៃគម្រោងកែលម្អជីវភាព និងគ្រប់គ្រងធនធានធម្មជាតិ | ១៨ |
| ទី២- | អ្នកមិនបានទទួលផល | ១៩ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **NRML** | គម្រោងគ្រប់គ្រងធនធានធម្មជាតិ និងលើកស្ទួយជីវភាពរស់នៅ |

# របាយការណ៍សង្ខេប

អនុកិច្ចសន្យាត្រូវបានរៀបចំឡើងគាំទ្រដល់ភូមិគោលដៅក្នុងស្រុកកោះញែក ដើម្បីអនុវត្តសកម្មភាពមួយចំនួនក្នុងការកែលំអការគ្រប់គ្រងធនធានធម្មជាតិ និងការចិញ្ចឹមជីវិត តាមរយៈការកែលំអ ផលិតផលកសិកម្ម ឱ្យទទួល បានជោគជ័យ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ស្របតាមយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ក្នុងការអនុវត្តសកម្មភាពការងាររយៈពេលមួយឆ្នាំទៅតាមអនុកិច្ចសន្យាដែលបានគ្រោងទុក គម្រោងដែលមន្ទីរកសិកម្មបានអនុវត្ត គឺពិតជាលទ្ធផលមួយដែលប្រជាពលរដ្ឋក្នុងសហគមន៍ទាំងមូលពេញចិត្តនឹងទទួលយកនូវបច្ចេកទេសថ្មីៗ ដើម្បីកែលំអជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ ។ ទន្ទឹមនឹងនោះដែរ លទ្ធផលរបស់គម្រោងមាន ភាពទាក់ទងគ្នាពីសកម្មភាពមួយទៅសកម្មភាពមួយទៀត ដើម្បីធ្វើឱ្យសម្រេចបាននូវលទ្ធផលជាវិជ្ជមាន ។

គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើៈ

ក្រុមការងារវាយតម្លៃ នៃ គ.ប្រ ខេត្តមណ្ឌលគិរី បានធ្វើការវាយតម្លៃអនុកិច្ចសន្យាដែលមានចំណងជើងថាៈ កែលំអការគ្រប់គ្រងធនធានធម្មជាតិ និងការចិញ្ចឹមជីវិត តាមរយៈការកែលំអផលិតផលកសិកម្ម លេខកិច្ចសន្យា 11/AGR/0901-00 (NRML) ដែលជាអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរកសិកម្មខេត្ត ។ នេះជាផ្នែក មួយនៃគម្រោងពង្រឹងសមត្ថភាពគ្រូបង្គោលថ្នាក់ក្រោមជាតិរបស់ផ្នែកត្រួតពិនិត្យ វាយតម្លៃ និង ផ្សព្វផ្សាយ គោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍន៍ តាមបែបប្រជាធិបតេយ្យ តាមរយៈវិមជ្ឈ ការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ។

គោលបំណងជាក់លាក់ នៃការវាយតម្លៃនេះគឺៈ

- ទាញយកការកត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផល នៃអនុកិច្ចសន្យា និងចំណុចខ្សោយ ដើម្បីធ្វើការប្រៀបធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់ នៃអនុកិច្ចសន្យា រួមទាំង កត់ត្រានូវ ចំណុចរៀនសូត្រ និងផ្នែកមួយចំនួនដែលត្រូវធ្វើឱ្យប្រសើរឡើងនាពេលអនាគត និង
- ពង្រឹងពីរបៀបធ្វើការវាយតម្លៃគម្រោងរបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្តន៍ ។

ការវាយតម្លៃបានអនុវត្តតាមការណែនាំ និងប្រើប្រាស់ឧបករណ៍ ស្តីពីការវាយតម្លៃអនុកិច្ចសន្យារបស់គណៈកម្មាធិការប្រតិបត្តិ នៃ គ.អ.ជ.ខ ដែលរៀបចំដោយផ្នែកត្រួតពិនិត្យ និងវាយតម្លៃ នៃលេខាធិការដ្ឋាន គ.ជ.អ.ប ។ ក្រុមការងារវាយតម្លៃបានប្រើការពិភាក្សាក្រុម ការសម្ភាសន៍ស៊ីជម្រៅ ការសម្ភាសន៍អ្នករៀបចំ និងអ្នកអនុវត្ត ការសម្ភាសន៍អ្នកពាក់ព័ន្ធ ការសម្ភាសន៍អ្នកទទួលផលផ្ទាល់ ការសម្ភាសន៍អ្នកមិនបានទទួលផល ការចុះមូលដ្ឋាន គន្លឹះក្នុងការសង្កេត និងពិនិត្យឡើងវិញលើរបាយការណ៍រីកចំរើន ឯកសារផ្សេងៗ និងពិនិត្យអនុកិច្ចសន្យា ។

ការវាយតម្លៃត្រូវឆ្លើយទៅនឹងសំណួរដែលត្រូវសម្ភាសន៍ ប៉ុន្តែដោយធនធាន មានកំរិតយើងបានធ្វើការវាយតម្លៃ ស៊ីជម្រៅតែលើលទ្ធផលមួយប៉ុណ្ណោះ ចំណែកឯលទ្ធផលផ្សេងៗទៀត យើងវាយតម្លៃដោយផ្អែកលើព័ត៌មាន ដែលមានស្រាប់។ ដូច្នេះការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃស៊ីជម្រៅ លើអនុកិច្ចសន្យាទាំងមូលទេ ចំពោះការ សន្និដ្ឋានត្រូវបានធ្វើឡើងទៅតាមអ្វីដែលបានរកឃើញ ។

ឆ្លើយទៅនឹងសំណួរទាំង ៥ នៃការវាយតម្លៃ :

១-សកម្មភាពទាំងអស់ត្រូវបានអនុវត្ត និងលទ្ធផលសំរេចបានតាមផែនការ

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣: បរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ០១ | ប្រជុំអ្នកភូមិដើម្បីជ្រើសរើសកសិករស្ម័គ្រចិត្តចិញ្ចឹមជ្រូកបង្ហាញ | ០១ដង អ្នកចូលរួម ៣០នាក់ |
| ០២ | បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូកបង្ហាញ | ០១វគ្គ អ្នកចូលរួម ២០គ្រួសារ |
| ០៣ | ផ្តល់ពូជជ្រូកដល់កសិករសម្រាប់ចិញ្ចឹមជ្រូកបង្ហាញ | ០២កន្លែង ជ្រូកចំនួន ០៨ក្បាល |
| ០៤ | សាងសង់ទ្រុងជ្រូកសម្រាប់ឱ្យកសិករចិញ្ចឹមជ្រូកបង្ហាញ | ចំនួន ០២ទ្រុង |
| ០៥ | ផ្តល់ចំណី វ៉ាក់សាំងការពារ និងថ្នាំព្យាបាលឱ្យកសិករចិញ្ចឹមជ្រូកបង្ហាញ | ០២គ្រួសារ ជ្រូកចំនួន ០៨ក្បាល |
| ០៦ | ទិវាបង្ហាញស្តីពីបច្ចេកទេសចិញ្ចឹមជ្រូកបង្ហាញ | មិនបានអនុវត្ត |
| ០៧ | ពង្រឹងសមត្ថភាពភ្នាក់ងារពេទ្យសត្វភូមិដែលមានស្រាប់ | ចំនួន ៩៨នាក់ |

១- វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមជ្រូក ការផ្តល់ពូជជ្រូកសាច់ និងផ្តល់ថ្នាំវ៉ាក់សាំងការពារជំងឺជ្រូក ពិតជាមានសារ ប្រយោជន៍ និងប្រសិទ្ធភាពខ្លាំងណាស់ ព្រោះវាបានរួមចំណែកក្នុងការផ្គត់ផ្គង់ ជីវភាពគ្រួសារ និងបង្កើនប្រាក់ចំណូល ។

២- លទ្ធផលជាបន្ទាន់ និងផលប្រយោជន៍ពីទិវាបង្ហាញពីបច្ចេកទេសចិញ្ចឹមជ្រូក និងការពង្រឹងសមត្ថភាពដល់ភ្នាក់ងារពេទ្យ សត្វភូមិ មិនអាចវាយតម្លៃបានទេ ព្រោះរយៈពេលយូរពេកហើយយើងគ្មានទិន្នន័យ និងព័ត៌មានមូលដ្ឋានពិតបាកជ ។

៣- ជារួមអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់ នៃអនុកិច្ចសន្យានៅកំរិតខ្ពស់ ។

៤- អនុកិច្ចសន្យាពិតជាបានរួមចំណែកក្នុងការសម្រេចនូវគោលបំណងជាបន្ទាន់ ដោយសារកសិករបានអនុវត្ត នូវបច្ចេកទេសថ្មីៗ ដែលទទួលបានពីវគ្គបណ្តុះបណ្តាលបច្ចេកទេស ចិញ្ចឹមជ្រូក ការផ្តល់ពូជជ្រូក និងការផ្តល់វ៉ាក់សាំងការពារ និងព្យា- បាលជម្ងឺផ្សេងៗបានទាន់ពេលវេលា ។ ទន្ទឹមនឹងនោះដែរ ក៏ធ្វើឱ្យប្រជាកសិករមានការកើនឡើងនូវការចញ្ចឹមជ្រូកជា លក្ខណៈគ្រួសារ និងចំណូលគ្រួសាររបស់ពួកគាត់មានការកើនឡើងទោះជាក្នុងកំរិត និងដែនកំណត់ណាមួយក៏ដោយ ។

៥- អនុកិច្ចសន្យានេះពិតជាមានភាពពាក់ព័ន្ធ ប្រសិទ្ធភាព និងប្រសិទ្ធផល ទាក់ទងនឹងធនធានដែលមាន ការប្រតិបត្តិ

និងការគ្រប់គ្រងទូទៅ ។ ប៉ុន្តែទោះជាយ៉ាងណា គុណភាព នៃការរៀបរៀងអនុកិច្ចសន្យា គួរតែត្រូវបានកែលំអដូចខាង ក្រោម:

-ក្នុងសកម្មភាពនិមួយៗ ត្រូវបញ្ជាក់អំពីចំនួនអ្នកចូលរួម និងចំនួនវគ្គដែលត្រូវបណ្តុះបណ្តាល ដល់ប្រជាកសិករទាំងនោះ

-បរិយាយឱ្យបានច្បាស់លាស់ និងអាចវាស់វែងបាននូវស្ថានភាពចុងបញ្ចប់អនុកិចសន្យា និងគោលបំណងបន្ទាន់

-គួរប្រើប្រាស់សូចនាករជោគជ័យធៀបទៅនឹងទិន្នន័យមូលដ្ឋានដែលមានស្រាប់ដើម្បីរកឱ្យឃើញពីការរីកចំរើន

-ភ្ជាប់ទំនាក់ទំនងឱ្យបានច្បាស់លាស់រវាងលទ្ធផល និងគោលបំណងបន្ទាន់ និងគោលបំណងកម្រិតខ្ពស់ ។

**សេចក្តីសន្និដ្ឋានសំខាន់ៗ:**

១- លទ្ធផល និងអត្ថប្រយោជន៍ដែលបានកើតឡើងពីការអនុវត្តន៍អនុកិច្ចសន្យា វាជាប្រយោជន៍មួយយ៉ាងសំខាន់ដល់សហគមន៍មូលដ្ឋាន ព្រោះវាមានភស្តុតាងបង្ហាញយ៉ាងច្បាស់លាស់ ដូចជា បច្ចេកទេសចិញ្ចឹមជ្រូក ការថែរក្សា ការផ្តល់ចំណី និងការប្រើប្រាស់វ៉ាក់សាំងការពារ និងព្យាបាលជម្ងឺផ្សេងៗ លទ្ធផលទាំងនេះ ត្រូវបានទទួលការអបអរសាទរពីអ្នកទទួលផលផ្ទាល់ និងអ្នកទទួលផលប្រយោលពីគម្រោងនៅក្នុងឃុំ ។ ឧទាហរណ៍: ការបង្កើននូវការចិញ្ចឹមជ្រូកជាលក្ខណ:គ្រួសារនៅក្នុងភូមិ ឃុំ និងការមានការងារធ្វើនៅក្នុងគ្រួសារ នឹងទទួលបានកំនើនឡើងនូវប្រាក់ចំណូលដែលជា លទ្ធផលសម្រេចបានពីវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក ដែលបានលើកក្នុងអនុកិច្ចសន្យា ។ លើសពីនេះទៅ ទៀត ពួកគាត់បានបន្តនូវសកម្មភាពទាំងនេះជាលក្ខណ:គ្រួសារនៅក្នុងភូមិ បើទោះបីជាគម្រោងបានបញ្ចប់ទៅហើយយូរក៏ដោយ ។ ជាពិសេសជាងនេះទៀត ការចិញ្ចឹមជ្រូកតាមលក្ខណ:បច្ចេកទេសធ្វើឱ្យចំណេញពេលវេលា ជ្រូកឆាប់ធំ ធាត់ល្អ ចំណូលគ្រួសារមានការកើនឡើងទ្វេរដង ។

២- គួរមានការការគាំទ្រគម្រោងបែបនេះ ក៏ដូចជាការពង្រីកទីតាំងសកម្មភាពអនុវត្តគម្រោងឱ្យបានច្រើន និងជាបន្តបន្ទាប់

៣- ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីធ្វើឱ្យសម្រេចបាននូវអត្ថប្រយោជន៍ក្នុងកំរិតមួយខ្ពស់ ភ្នាក់ងារអនុវត្តគម្រោងគួរមាន ការចុះជួយណែនាំបន្ថែមទៀតឱ្យបានញឹកញាប់ នូវអ្វីដែលជាបញ្ហាបន្ទាន់របស់ប្រជាកសិករ ។

៤- ដើម្បីពង្រឹងនូវគុណភាព និងភាពទាក់ទាញរបស់គម្រោង គួរមានការបរិយាយឱ្យបានច្បាស់លាស់នូវរាល់សកម្មភាពនីមួយៗ និងស្ថានភាពចុងបញ្ចប់ នៃអនុកិច្ចសន្យា និងគោលបំណងបន្ទាន់របស់គម្រោង ក៏ដូចជាការពង្រឹងនូវភាពទំនាក់ទំនងតក្កភាពរវាងធាតុខាងលើទៅនឹងលទ្ធផលសម្រេចបាន ។

# ១.ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្ដីផ្ដើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្ដល់ថវិកាតាមរយៈ គ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និងគម្រោង ដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈជាប្រព័ន្ធ មិន បានអនុវត្តទេកាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើន។ នៅក្នុងឆ្នាំ ២០១០ ជាមួយនឹងការគាំទ្រផ្នែក ថវិកា និងបច្ចេកទេស ពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យា គ.ប្រ នៃគ.អ.ជ.ខ ក្នុងការអនុវត្តន៏ការវាយតម្លៃអនុកិច្ចសន្យា ដែលបាន រៀបចំរួមគ្នាជាមួយភ្នាក់ងារអនុវត្តន៏ដែលមានលេខៈ 11/AGR/090-00(NRML) ដំណើរការលទ្ធផល ដែលបាន រកឃើញ និងការសន្និដ្ឋាន នៃការវាយតម្លៃត្រូវបានកត់ត្រា ហើយនឹងបង្ហាញតាមរយៈរបាយការណ៍ស្ដីពីការវាយ តម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

គោលបំណងបន្ទាន់ នៃអនុកិច្ចសន្យា គឺនៅចុងឆ្នាំ២០០៩ កសិករនឹងទទួលបានទិន្នផលស្រូវខ្ពស់ និងការចិញ្ចឹមសត្វបានលទ្ធផល ល្អប្រសើរ ដើម្បីកែលំអជីវភាពរស់នៅ និងការចិញ្ចឹមជីវិតរបស់ពួកគាត់ ព្រោះចំណេះដឹង និងបច្ចេកទេសកសិកម្មរបស់គាត់ មានភាពល្អប្រសើរជាងមុន ដោយសារគាត់ទទួលបាននូវសេវា អប់រំបច្ចេកទេសកសិកម្មដូចជា វគ្គបណ្ដុះបណ្ដាលបច្ចេកទេសធ្វើ ស្រែប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ វគ្គបណ្ដុះបណ្ដាល បច្ចេកទេសចិញ្ចឹមសត្វ និងការចិញ្ចឹមជ្រូកបង្ហាញ ។ មួយវិញទៀត ភ្នាក់ងារពេទ្យភូមិ នឹងត្រូវទទួលបាននូវការពង្រឹងបន្ថែមលើចំណេះដឹង ជំនាញកាន់តែរឹងមាំ និងមានលទ្ធភាព គ្រប់គ្រាន់ក្នុងការជួយដល់សកម្មភាពចិញ្ចឹមសត្វរបស់ប្រជាកសិករនៅថ្នាក់មូលដ្ឋាន ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូល ដោយផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលរបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និងតម្លាភាព។ ដូច្នេះទំហំ នៃការវាយតម្លៃមានដែនកំណត់តាមទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខណ្ឌការងារនៃការវាយតម្លៃ។ គោលបំណង នៃការវាយតម្លៃគឺៈ **ក)** ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផល នៃអនុកិច្ចសន្យា និងចំនុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់ នៃការអនុវត្តន៏កិច្ចសន្យា រួម

ទាំងកត់ត្រានូវចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត និង ខ) ដើម្បីពង្រឹងរបៀប ធ្វើការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្តន៍។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផល នៃអនុកិច្ចសន្យាសម្រេចបានកម្រិតតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់ នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើៈ

១) ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំនត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធដែលមាននៅក្នុងផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលនៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៍។

២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗ រួមមានៈ អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផល ផ្ទាល់ និងមិនផ្ទាល់ចំនួន ០៦នាក់ និងអ្នកពាក់ព័ន្ធ ០១នាក់ និងពិគ្រោះជាមួយនឹងមន្ត្រីទទួលបន្ទុកកសិកម្មស្រុក សម្រាប់បញ្ហាពាក់ព័ន្ធវិស័យខាងលើ ។

៣) បានប្រើប្រាស់វិធីសាស្ត្រចុះពិនិត្យតំបន់អនុវត្តន៍គម្រោង និងសង្កេតមើលសកម្មភាពពិភាក្សាក្រុម និងករណីសិក្សា។

៤) ចុះពិនិត្យតំបន់អនុវត្តន៍គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់ ។

៥) <u>វិភាគទិន្នន័យ និងបកស្រាយៈ</u> ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់

៦) <u>ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៍</u> ដោយភ្នាក់ងារអនុវត្តន៍ និងអ្នកពាក់ព័ន្ធតាមរយៈព័ត៌មានត្រឡប់ដែលទទួលបានពីការបង្ហាញ ដោយសង្ខេបដែលបានធ្វើឡើង ការវាយតម្លៃត្រូវធ្វើតាម "គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា" និងវិធីសាស្ត្រដែលបានណែនាំ។ ដូច្នេះដំណើរការត្រូវបានធ្វើឡើងដោយមានទម្រង់ការណែនាំ និងតម្លាភាព រួមទាំងការចូលរួមពីអ្នកពាក់ព័ន្ធ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយ គ.ប្រ និងអ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយ ការប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត។

២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត : វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោង នៅពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និងបទពិសោធន៍ពីមុនមក។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណង សំខាន់ គឺដើម្បី"រៀនធ្វើដោយការអនុវត្តផ្ទាល់"។ អ្នកវាយតម្លៃ បានទទួលការគាំទ្រដោយមានគោលការណ៍ការ ណែនាំឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។

៣) បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យា: ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និងជោគជ័យទេ ។ មួយទៀត ទំនាក់ទំនងសង្ខេបតាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់ មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ។

៤) ដោយយើងមិនមានសូចនាករបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍" ដែលជាកម្រិតអត្ថប្រយោជន៍ទៅលើគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។

៥) ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិតទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ។ យើងអាចវាយតម្លៃតែទៅលើ ការបង្ហាញការចិញ្ចឹមសត្វ (ជ្រូក មាន់ ចំណីសត្វ ) ដែលជាលទ្ធផល និងប្រជុំអ្នកភូមិដើម្បីជ្រើសរើសកសិករចិញ្ចឹមជ្រូកបង្ហាញ វគ្គបណ្តុះបណ្តាល បច្ចេកទេសចិញ្ចឹមជ្រូក ការផ្តល់ពូជជ្រូកសាច់ដល់កសិករចិញ្ចឹមជ្រូកបង្ហាញ សាងសង់ទ្រុងជ្រូកឱ្យកសិករចិញ្ចឹមជ្រូកបង្ហាញ ការផ្តល់ ចំណី វ៉ាក់សាំងការពារ និងថ្នាំព្យាបាលឱ្យកសិករចិញ្ចឹមជ្រូកបង្ហាញ ទិវាបង្ហាញស្តីពីបច្ចេកទេសចិញ្ចឹមជ្រូកបង្ហាញ ដែលជាសកម្មភាពនៃអនុកិច្ចសន្យាលម្អិត តាមរយៈការសម្ភាសន៍ស៊ីជម្រៅ ក្រុមពិភាក្សា និងការចុះពិនិត្យតំបន់ អនុវត្តគម្រោង។

៦) សូមរក្សាទុកចំណុចនេះប្រសិនបើវាមានសុពលភាព: ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា មិនអាចធ្វើទៅបានទេ ព្រោះចំណុច គ នៃផ្នែកទី៣ ក្នុងឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ ឬមិនពេញលេញ។ ការងារនេះ នឹងកាន់តែមានសុពលភាព និងពោរពេញទៅដោយព័ត៌មាន បើសិនជាចំនុចដែលបាន រៀបរាប់ខាងលើ នេះត្រូវបានដោះស្រាយ។

| |
|---|
| **ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និងបដិសេធៈ**<br>១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ 11/AGR /0901-00 (NRML) ការកែលំអការគ្រប់គ្រងធនធានធម្មជាតិ និងការចិញ្ចឹមជីវិតតាមរយៈការកែលំអផលិតផលកសិកម្ម និងដែនកំណត់ ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ។<br>២) ការវាយតម្លៃនេះលម្អិតតែទៅលើ ការបង្ហាញការចិញ្ចឹមសត្វ (ជ្រូក មាន់ ចំណីសត្វ) ការបង្កើត/គាំទ្រដល់ភ្នាក់ងារពេទ្យសត្វ ដែលជាលទ្ធផល និងសកម្មភាពដូចជា ការប្រជុំជ្រើសរើសកសិករស័គ្រចិត្តចិញ្ចឹមជ្រូកបង្ហាញ វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក ការផ្តល់ពូជជ្រូកសាច់ ការសាងសង់ទ្រុងសម្រាប់ដាក់ជ្រូក ការផ្តល់ចំណីវ៉ាក់សាំងការងារ ថ្នាំព្យាបាល ទិវាស្តីពីការចិញ្ចឹមជ្រូកបង្ហាញ និងការចុះពង្រឹងសមត្ថភាព ដល់ភ្នាក់ងារពេទ្យសត្វ ភូមិដែលជាសកម្មភាពនៃអនុកិច្ចសន្យា ។<br>៣) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃទៅលើភ្នាក់ងារអនុវត្តន៍ ភ្នាក់ងារដែលពាក់ព័ន្ធគម្រោង ហើយនឹងការវាយតម្លៃទៅលើគ.ប្រ នៃគ.អ.ជ.ខ និង គ.ជ.អ.ប ទេ។<br>ហេតុដូច្នេះ របាយការណ៍នៃការវាយតម្លៃ លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ដែលបានលើកឡើង ត្រូវពិនិត្យដោយយោលទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ។ |
| **សូមបន្ថែមបញ្ហាប្រឈមផ្សេងៗ ដែលមិនមានក្នុងការរៀបរាប់ខាងលើ :**<br>- គម្រោងដែលបានផ្តល់ឱ្យមានចំនួនតិចពេក ហើយប្រជាកសិករនៅទីនោះសុទ្ធតែជាអ្នកដែលធ្វើស្រែ ដូច្នេះពួកគាត់ ត្រូវការវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូកច្រើននាក់ ពីព្រោះក្រៅពីធ្វើស្រែពួកគាត់តែងតែចិញ្ចឹមជ្រូក បន្ទាប់បន្សំសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ ។ |

# ២-លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល

**លទ្ធផលទី១ : ការបង្ហាញការចិញ្ចឹមសត្វ (ជ្រូក មាន់ ចំណីសត្វ)**

**ផ្នែក-ក :ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ**

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១ | -ប្រជុំអ្នកភូមិដើម្បីជ្រើសរើសកសិករស្ម័គ្រចិត្តចិញ្ចឹមជ្រូកបង្ហាញ ០១ដង<br>-អ្នកចូលរួមចំនួន: ៣0នាក់ | -ប្រជុំអ្នកភូមិដើម្បីជ្រើសរើសកសិករស្ម័គ្រចិត្តចិញ្ចឹមជ្រូកបង្ហាញ ០១ដង<br>-អ្នកចូលរួមចំនួន: ៣0នាក់ |
| ២ | -បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូកបង្ហាញ ០១វគ្គ<br>-អ្នកចូលរួមចំនួន: ២0គ្រួសារ | -បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូកបង្ហាញ ០១វគ្គ<br>-អ្នកចូលរួមចំនួន: ២0គ្រួសារ |
| ៣ | -ផ្តល់ពូជជ្រូកសាច់ដល់កសិករសម្រាប់ចិញ្ចឹមជ្រូកបង្ហាញ 0២គ្រួសារ<br>-ចំនួនជ្រូក: 0៨ក្បាល | -ផ្តល់ពូជជ្រូកសាច់ដល់កសិករសម្រាប់ចិញ្ចឹមជ្រូកបង្ហាញ 0២គ្រួសារ<br>-ចំនួនជ្រូក: 0៨ក្បាល |
| ៤ | -សាងសង់ទ្រុងសម្រាប់ដាក់ជ្រូកឱ្យកសិករចិញ្ចឹមជ្រូកបង្ហាញ 0២ទ្រុង | -សាងសង់ទ្រុងសម្រាប់ដាក់ជ្រូកឱ្យកសិករចិញ្ចឹមជ្រូកបង្ហាញ 0២ទ្រុង |
| ៥ | -ផ្តល់ចំណី វ៉ាក់សាំងការពារ និងថ្នាំព្យាបាលឱ្យកសិករចិញ្ចឹមជ្រូកបង្ហាញ 0២ គ្រួសារ | -ផ្តល់ចំណី វ៉ាក់សាំងការពារ និងថ្នាំព្យាបាលឱ្យកសិករចិញ្ចឹមជ្រូកបង្ហាញ 0២គ្រួសារ |
| ៦ | -ធ្វើទិវាបង្ហាញស្តីពីបច្ចេកទេសចិញ្ចឹមជ្រូកបង្ហាញ ០១ថ្ងៃ<br>-អ្នកចូលរួមចំនួន: ៤៥នាក់ | -មិនបានអនុវត្តតាមគម្រោងដែលបានគ្រោងទុកក្នុងអនុកិច្ចសន្យា |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល នៃអនុកិច្ចសន្យា

- អនុកិច្ចសន្យានេះមិនបានសម្រេចលទ្ធផល និងសកម្មភាពនានា មួយរយភាគរយទៅទៅតាមអនុកិច្ចសន្យាដែលបានគ្រោងទុកនោះទេ ។ ដោយសារសកម្មភាពមួយក្នុងចំណោមសកម្មភាពទាំងអស់ ដើម្បីសម្រេចលទ្ធផល មិនត្រូវបានអនុវត្តគឺការធ្វើទិវាបង្ហាញស្តីពីបច្ចេកទេសចិញ្ចឹមជ្រូកបង្ហាញដល់ប្រជាពលរដ្ឋក្នុងភូមិ ។
- អ្នកចូលរួមទាំងអស់នៅក្នុងក្រុមពិភាក្សា ដែលជាសិក្ខាកាមមកពីវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូកបានបញ្ជាក់ថា ពួកគេទាំងអស់គ្នាទទួលបាននូវចំណេះដឹង ជំនាញ និងបច្ចេកទេសថ្មីៗ ដែលទាក់ទងទៅនឹងការចិញ្ចឹមជ្រូកតាមលក្ខណៈបច្ចេកទេសកសិកម្ម ។ អ្វីដែលធ្វើឱ្យពួកគាត់មានការចាប់អារម្មណ៍ខ្លាំងនោះគឺ ពួកគាត់បានអនុវត្តការចិញ្ចឹមជ្រូក តាមបច្ចេកទេសទាំងនោះ ធ្វើឱ្យពួកគាត់ចំណេញពេលវេលា ជ្រូកឆាប់ធំធាត់ល្អ រកចំណូលបានច្រើន បង្កើនការចិញ្ចឹមជ្រូក ជាពិសេសគាត់បានយកបច្ចេកទេសនោះមកអនុវត្ត ជាប្រចាំរហូតមកដល់សព្វថ្ងៃ ទោះបីជាការងារទាំងនោះបានបញ្ចប់ទៅយូរឆ្នាំហើយក៏ដោយ ។
- ក្រុមពិភាក្សាភាគច្រើនគាត់បានចូលចិត្តវិធីសាស្រ្តបណ្តុះបណ្តាល និងអាកប្បកិរិយារបស់អ្នកបណ្តុះបណ្តាល ។ វិធីសាស្រ្តផ្សេងៗជាច្រើន ត្រូវបានអ្នកបណ្តុះបណ្តាលយកមកប្រើប្រាស់រួមមាន ការប្រើសំនួរបំផុស ការពិភាក្សាក្រុម ការបង្ហាញរូបភាព ..... ។ មួយវិញទៀតអ្នកបណ្តុះបណ្តាលជាមនុស្សដែលប្រជាពលរដ្ឋស្គាល់ច្បាស់ ដូច្នេះធ្វើឱ្យពួកគាត់ទាំងអស់គ្នាមានភាពស្និទ្ធស្នាល ហើយមានការចូលរួមយ៉ាងផុសផុលច្រើនក្នុងកំឡុងនៃវគ្គបណ្តុះបណ្តាល ។
- ការផ្តល់ពូជជ្រូកសាច់ឱ្យកសិករពីរគ្រួសារធ្វើការចិញ្ចឹមជ្រូកបង្ហាញដល់ប្រជាពលរដ្ឋដទៃទៀត គឺមានលក្ខណៈត្រឹមត្រូវ ល្អប្រសើរ តម្លាភាព ដោយប្រជាពលរដ្ឋដែលបានចូលរួមក្នុងវគ្គទាំងមូល ត្រូវបានជ្រើសរើសចេញពីការបោះឆ្នោត ដើម្បីចិញ្ចឹមជ្រូកបង្ហាញ ហើយអ្នកដែលឈរឈ្មោះ គឺជាអ្នកដែលធ្លាប់ចិញ្ចឹមជ្រូកតាមបែបធម្មជាតិនាពេលកន្លងមក ។

សរុបសេចក្តីមក វគ្គបណ្តុះបណ្តាលនេះមានភាពទាក់ទងទៅនឹងតម្រូវការរបស់សិក្ខាកាម និងសហគមន៍របស់គាត់ ។ អ្វីដែលសំខាន់ទៀតនោះ មុននឹងបើកវគ្គបណ្តុះបណ្តាលមន្ទីរបានចុះមកពិភាក្សាជាមុន ហើយក្នុងពេលបណ្តុះបណ្តាលអ្នកចូលរួមនៅក្នុងក្រុមពិភាក្សាបានបញ្ជាក់ថា ចំណេះដឹង ជំនាញ និងបច្ចេកទេសដែលទទួលបាន នឹងរួមចំណែកធ្វើឱ្យជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់កាន់តែប្រសើរមួយកំរិតថែមទៀត ។ ជារួមយើងសង្កេតឃើញថា ប្រជាពលរដ្ឋដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល មានការពេញចិត្តជាខ្លាំងដោយពួកគាត់បានបង្កើនចំនួននៃការចិញ្ចឹមជ្រូក ដែលធ្វើឱ្យចំណូលគ្រួសាររបស់ពួកគេមានការកើនឡើង ។

## លទ្ធផលទី២: ការបង្កើត /គាំទ្រភ្នាក់ងារពេទ្យសត្វភូមិ

### ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀននឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ០១ | -ចុះតាមដាន និងពង្រឹងសមត្ថភាពដល់ភ្នាក់ងារពេទ្យសត្វភូមិ<br>-អ្នកចូលរួមចំនួនៈ ៩៨នាក់ | -បើកវគ្គបំពាក់បំប៉ នសមត្ថភាពដល់ភ្នាក់ងារពេទ្យសត្វភូមិ ០១វគ្គ<br>-មានរយៈពេល ចំនួន ០៥ថ្ងៃ<br>-អ្នកចូលរួមចំនួនៈ ៣៨នាក់ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល នៃអនុកិច្ចសន្យា

| |
|---|
| លទ្ធផលទីពីរក្នុងអនុកិច្ចសន្យានេះ គឺសម្រេចនូវលទ្ធផល និងសកម្មភាពទាំងអស់ដែលបានគ្រោងទុក ។ ព្រោះក្រុមការងារអនុវត្តគម្រោងបានចុះពិនិត្យ តាមដាន និងពង្រឹង សមត្ថភាពបន្ថែមដល់ភ្នាក់ងារពេទ្យសត្វភូមិដែលបានជ្រើសរើសនាពេលកន្លងមក សម្រាប់អនុវត្តការងារពេទ្យសត្វភូមិបន្តទៀត ។ ការពិនិត្យឯកសារអនុកិច្ចសន្យា យើងមិនអាច វាយតម្លៃគុណភាព នៃលទ្ធផលនេះឱ្យបានលំអិត និងស៊ីជម្រៅទេ ។ |

## ២.២. ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម

### ផ្នែក-ក: ការសម្រេចបាននូវស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់កិច្ចសន្យា | ស្ថានភាពជាក់ស្តែងនៅពេលបញ្ចប់ |
|---|---|
| -ប្រជាពលរដ្ឋពីរគ្រួសារ ដែលមកពី ០២ភូមិ ០១ឃុំ ០១ស្រុក ត្រូវបានជ្រើសរើសជាកសិករចិញ្ចឹមជ្រូកបង្ហាញ រួមមានជ្រូកចំនួន ០៤ក្បាល ទ្រុងជ្រូក ០១ ផ្តល់ចំណី វ៉ាក់សាំងការពារ និងថ្នាំព្យាបាលសម្រាប់មួយគ្រួសារ | -ប្រជាពលរដ្ឋពីរគ្រួសារ ដែលមកពី ០២ភូមិ ០១ឃុំ ០១ស្រុក ត្រូវបានជ្រើសរើសជាកសិករចិញ្ចឹមជ្រូកបង្ហាញ រួមមានជ្រូកចំនួន ០៤ក្បាល សង់ទ្រុងជ្រូក ០១ ផ្តល់ចំណី ៩០គីឡូក្រាម ក្នុងមួយគ្រួសារ៧ និងបានចុះចាក់វ៉ាក់សាំងការពារជម្ងឺប៉េស្ត អុតក្តាម និងចាក់ថ្នាំទំលាក់ប៉ារ៉ាស៊ិត ។ |
| **-កសិករចំនួន ២០គ្រួសារ** ដែលមកពី ០២ភូមិ ០១ឃុំ ០១ស្រុក គោលដៅ បានទទួលចំណេះដឹងជំនាញ និង បច្ចេកទេស តាមរយៈវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេស ចិញ្ចឹមជ្រូក ចំនួន ០១វគ្គ | **កសិករចំនួន ៣៤នាក់** ក្នុងនោះស្រី **២១នាក់** ដែលមកពី ០២ភូមិ ០១ឃុំ ០១ស្រុក គោលដៅ បានទទួលចំណេះដឹងជំនាញ និងបច្ចេកទេស តាមរយៈវគ្គបណ្តុះបណ្តាស្តីពីបច្ចេកទេសចិញ្ចឹមជ្រូក ចំនួន ០១វគ្គ<br>*អ្នកចូលរួមភាគច្រើន នៅក្នុងការពិភាក្សាជាក្រុម បានរាយការណ៍ថា ពួកគាត់ពេញចិត្តនឹងវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមជ្រូកនេះណាស់ ។ បន្ថែមលើនេះទៅទៀត ពួកគាត់បានបញ្ជាក់យ៉ាងច្បាស់ថា វគ្គនេះពិតជាបានឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍គាត់ ។ មួយវិញទៀត អ្នកចូលរួមក្រុមពិភាក្សាបានលើកឡើងថា ពួកគាត់បានបង្កើនចំនួន នៃការចិញ្ចឹមជ្រូក ដោយសារការចិញ្ចឹមជ្រូកតាមលក្ខណៈបច្ចេកទេសកសិកម្ម ប្រើរយៈពេលខ្លី ជ្រូកឆាប់ធំធាត់ មិនសូវមានជម្ងឺ និងងាយស្រួលលក់ ។<br>*នៅក្រោយពេលវគ្គបណ្តុះបណ្តាលយើងសង្កេតឃើញថាកសិករដែលទទួលការចិញ្ចឹមជ្រូកបង្ហាញ បានរៀបចំការចិញ្ចឹមជ្រូកមានលក្ខណៈជាទ្រង់ទ្រាយធំ ដោយគាត់យល់ឃើញថា កន្លងមកគាត់ចិញ្ចឹមជ្រូកតាមបែបធម្មជាតិមិន |

| | |
|---|---|
| | សូវទទួលបានផលល្អ តែក្រោយពីទទួលបាននូវបច្ចេកទេសកសិកម្ម ធ្វើឱ្យកាត់ពេញចិត្តក្នុងការពង្រីកបន្ថែមនូវមុខរបរនេះ ។ ការយល់ដឹងរបស់ពួកគាត់ទៅលើបច្ចេកទេសចិញ្ចឹមជ្រូក មានភាពប្រសើរឡើង បន្ទាប់ពីគម្រោងបានបង្ហាញ និងផ្តល់ចំណេះដឹង ជំនាញ និងបច្ចេកទេស ។ អ្វីដែលប្រសើរជាងនេះទៀត ពួកគាត់គិតថា ការចិញ្ចឹមជ្រូកតាមលក្ខណះបច្ចេកទេស វាមានភាពងាយស្រួល និងទទួលបានទិន្នផលខ្ពស់ ហើយចំណេញពេលវេលាច្រើន ។ |

## ផ្នែក-ខ: ការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា

| ល.រ | ធាតុនៃគោលបំណងបន្ទាន់ | ការសម្រេចបានជាក់ស្តែង នៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ |
|---|---|---|
| ០១ | នៅក្នុងឆ្នាំ២០០៩ កសិករនឹងទទួលបានទិន្នផល ស្រូវ និងការចិញ្ចឹមសត្វល្អប្រសើរ ដើម្បីកែលំអ ជីវភាពរស់នៅក្នុងគ្រួសារ និងសហគមន៍ តាម រយៈសេវាអប់រំបច្ចេកទេសកសិកម្ម វគ្គបណ្តុះ បណ្តាលបច្ចេកទេសធ្វើស្រែប្រពលវប្បកម្ម និង បច្ចេកទេសស្តីពីការចិញ្ចឹមជ្រូក ជាពិសេសការ ពង្រឹងសមត្ថភាពដល់ភ្នាក់ងារពេទ្យសត្វភូមិ ។ | គោលបំណងបន្ទាន់ដែលបានចែងនៅក្នុងអនុកិច្ចសន្យា គឺមានកម្រិតខ្ពស់ ដែលធ្វើឱ្យយើងពិបាក ក្នុងការវាស់វែងនៅចុងបញ្ចប់នៃអនុកិច្ចសន្យា។ ទោះបីជាគេរំពឹងថាសកម្ម ភាព និងលទ្ធផលទាំងអស់របស់អនុកិច្ចសន្យានឹងចូលរួម ទៅក្នុងគោលបំណងបន្ទាន់ ។ ប៉ុន្តែផ្អែកលើការ ពិនិត្យ ឯកសារ និងវិធីសាស្ត្រវាយតម្លៃបែបគុណភាព យើងមិន អាចវាយតម្លៃបានថា តើគោលបំណង បន្ទាន់នេះ សម្រេចបានលទ្ធផលកម្រិតណានោះទេ |

## ផ្នែក-គ: សង្ខេបការវាយតម្លៃផលប្រយោជន៍ជារួមដែលទទួលបាន និងអាចមើលឃើញ:

| |
|---|
| តាមរយៈការពិភាក្សាក្រុម អ្នកចូលរួមបានបង្ហាញថា ពួកគាត់មានការពេញចិត្តជាខ្លាំងចំពោះផលប្រយោជន៍ដែល ទទួលបានពីអនុកិច្ចសន្យានេះសម្រេចបាន ជាពិសេសចំណេះដឹង ជំនាញ និងបច្ចេកទេសថ្មីៗស្តីពីការចិញ្ចឹមសត្វជ្រូក។ ហើយពួកគាត់ទទួលស្គាល់ថា គម្រោងនេះពិតជាមានសារៈប្រយោជន៍សម្រាប់គ្រួសារគាត់ និងសហគមន៍ ហើយជា ទូទៅពួកគាត់អាចបង្កើនចំនួន នៃការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ និងអ្នកខ្លះ ទៀត អាចរកចំណូលបានច្រើន ជីវភាពធូរធា ។ ជាពិសេសជាងនេះទៅទៀត |

គ្រួសារដែលទទួលបានការចិញ្ចឹម ជ្រូកបង្ហាញពីរគ្រួសារនាឆ្នាំកន្លងមក ពួកគាត់បាននឹងកំពុងបន្តការចិញ្ចឹមជ្រូក តាមលក្ខណៈបច្ចេកទេសកាន់តែច្រើន ឡើងបន្ថែមទៀត ហើយអ្នកដទៃ ក៏វិលមករកការចិញ្ចឹមជ្រូក តាមលក្ខណៈបច្ចេកទេសវិញដែរ ។

# ករណីសិក្សា

## ករណីសិក្សាទី១: អ្នកទទួលផលផ្ទាល់ពីអនុកិច្ចសន្យាក្នុងគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក

**បន្ទាប់ពីបានចូលរួមក្នុងគម្រោងកសិកម្មរបស់ គ.អ.ជ.ខ ខេត្តមណ្ឌលគិរី ក្នុងឆ្នាំ២០០៩ អ្នកស្រី សាន ផល្លា បាននិយាយថា: ប្រាក់ចំណូលខ្ញុំមានការកើនឡើង ចាប់តាំងពីខ្ញុំបានចូលរួមវគ្គបណ្តុះបណ្តាល និងការចិញ្ចឹមជ្រូកបង្ហាញ**



អ្នកស្រី សាន ផល្លា កសិករចិញ្ចឹមជ្រូកបង្ហាញ

អ្នកស្រី **សាន ផល្លា** ជាប្រជាកសិករម្នាក់ អាយុ ៣២ឆ្នាំ រស់នៅភូមិអូរយ៉េះ ឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី ។ គាត់បាននិយាយថា គម្រោងបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមជ្រូកបង្ហាញរបស់មន្ទីរកសិកម្មនេះ ពិតជាមានសារៈប្រយោជន៍ខ្លាំងណាស់ ព្រោះគាត់ទទួលបានចំណេះដឹង និងបច្ចេកទេសច្រើនអំពីការចិញ្ចឹមជ្រូក ដែលពីមុនគាត់ចិញ្ចឹមតាមបែបធម្មជាតិសុទ្ធសាធ ។ គាត់បានបញ្ជាក់ថា ជ្រូករបស់ខ្ញុំឆាប់ ធំធាត់ ស្អាត ឆាប់បានលក់ ហើយលក់បានថ្លៃជាងមុនទៅទៀត ។ អ្នកជិតខាង មានការចាប់អារម្មណ៍ការចិញ្ចឹមជ្រូករបស់ខ្ញុំណាស់ ។ ជាងនេះទៅទៀត ជីវភាពគ្រួសារគាត់ មានភាពប្រសើរឡើង តាមរយៈប្រាក់ចំណូលពីការចិញ្ចឹមជ្រូក ។ ដូច្នេះប្រភពចំណូលពីការចិញ្ចឹមជ្រូក ជាចំណូលទីពីរបន្ទាប់របរម៉ាស៊ីនកិនស្រូវ ។ ការផ្លាស់ប្តូរជាវិជ្ជមានមួយទៀតរបស់គាត់ បន្ទាប់ពីចូលរួមពីគម្រោង គឺគាត់កាន់ តែរវល់ជាមួយនឹងការចិញ្ចឹមជ្រូក ព្រោះត្រូវផ្តល់ចំណីជ្រូកជាទៀងទាត់ សំអាតទ្រុង តាមដាន និងចាក់វ៉ាក់សាំងការពារ ទៅតាមបច្ចេកទេស ។

ជាចុងក្រោយ គាត់បានបង្ហាញពីការប្តេជ្ញាខ្ពស់ ចង់ឱ្យគម្រោងចិញ្ចឹមជ្រូករបស់គាត់មានការរីកចំរើនទៅមុខ ព្រោះជាមុខរបរមួយងាយស្រួល ។

## ករណីសិក្សាទី២: អ្នកមិនបានទទួលផល



មីង រិទ្ធ ទាង អាយុ ៥៦ឆ្នាំ មានគ្រួសារ កូន ៧នាក់ រស់នៅភូមិអូរយ៉េះ ឃុំស្រែសង្គម ស្រុកកោះញែក ។ គាត់ជាកសិករដែលមានចំណូលពីការធ្វើស្រែ និងការចិញ្ចឹមសត្វ បន្ទាប់បន្សំតិចតួច ។ មីង ទាង មិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម ជ្រូករបស់ គ.អ.ជ.ខ ខេត្តមណ្ឌលគិរីទេ ។ គាត់បាននិយាយថាការបណ្តុះបណ្តាលអំពី បច្ចេកទេសចិញ្ចឹមជ្រូក គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះគាត់បានទៅមើល ឃើញការចិញ្ចឹមរបស់អ្នកជិតខាងដែលបានចូលរួមទទួលបានចំណេះដឹង ជំនាញ និង បច្ចេកទេសចិញ្ចឹម ។ គាត់បានបន្ថែមទៀតថា ជ្រូកដែលខ្ញុំចិញ្ចឹមជាជ្រូកកណ្តុរ ចិញ្ចឹមតាមបែបធម្មជាតិ ដោយ ប្រលែងចោលក្នុងបរិវេណផ្ទះ មិនមានទ្រុង មិនបានផ្តល់ចំណីទៀងទាត់ មិនបានថែទាំ និងចាក់ថ្នាំការពារឡើង ដែល ផ្ទុយស្រឡះពីការចិញ្ចឹមរបស់អ្នកជិតខាង ដែលទទួលបានការបណ្តុះបណ្តាល ។ ម្យ៉ាងវិញទៀតពូជដែលគេជ្រើសរើស ជាពូជជ្រូកសាច់យ៉ក់ស៊ី យកមកពីស្រុកក្រោម ឆាប់ធំធាត់ ឆាប់បានលក់ ស្អាត មានទំងន់ធ្ងន់ ធំ ជាពិសេសលក់បាន ថ្លៃជាងជ្រូកកណ្តុរ ។ គាត់បានបន្តទៀតថា ពេលយើងមានជ្រូក គឺយើងមានលុយ នៅពេលយើងត្រូវការលុយ យើង អាចលក់ជ្រូក ដើម្បីដោះស្រាយជីវភាព ប៉ុន្តែគាត់មិនមានលទ្ធភាពទិញជ្រូកល្អមកចិញ្ចឹមទេ ដោយសារតែជីវភាពក្រ លំបាកពេក ។ មីង ទាង សង្ឃឹមថានឹងបានចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូករបស់គម្រោងក្នុងពេល អនាគត និងទទួលបានផលប្រយោជន៍ ដូចអ្នកជិតខាងរបស់គាត់ដែរ។ ជាចុងក្រោយគាត់សំណូមពរឱ្យអង្គការ និងភ្នាក់ងារនានាជួយអភិវឌ្ឍន៍ភូមិរបស់គាត់បន្តទៀតផង ។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

### ផ្នែក-ក: ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅនឹងតំរូវការៈ មន្ទីរវិស័យ គ.ជ.អ.ប និងការកាត់បន្ថយភាពក្រីក្រៈ

( ពិន្ទុ ១ =ខ្សោយណាស់   ពិន្ទុ ២ =ខ្សោយ   ពិន្ទុ ៣ = មធ្យម   ពិន្ទុ ៤ = ខ្លាំង   ពិន្ទុ ១ = ខ្លាំងណាស់ )

| ល.រ | ធាតុ | ទំនាក់ទំនងតក្កភាព | បរិយាយច្បាស់លាស់ | សង្ខេបការវាយតម្លៃ |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៤ | ៤ | សកម្មភាពដែលបានលើកឡើង ពិតជាមានភាពទំនាក់ទំនងតក្កជាមួយលទ្ធផល ដែលបានសរសេររៀបរាប់នៅក្នុងអនុកិច្ចសន្យា។ ជាក់ស្តែងលទ្ធផលទទី១ ទាក់ទិននឹងកសិករទទួលបានវគ្គបណ្តុះបណ្តាល ស្តីពីបច្ចេកទេសចិញ្ចឹមជ្រូកចំនួន ០១វគ្គ ការសង់ទ្រុងដាក់ជ្រូក ០២ទ្រុង ការផ្តល់ចំណី វ៉ាក់សាំងការពារ និងថ្នាំព្យាបាលជម្ងឺ ។ បញ្ហានេះឆ្លុះបញ្ចាំងឱ្យឃើញថា សកម្មភាពពិតជាមានទំនាក់ទំនងតក្កជាមួយនឹងលទ្ធផលនៅខាងលើ ដែលបានសរសេរយ៉ាងច្បាស់ ។ សកម្មនីមួយៗ បានសរសេរបង្ហាញច្បាស់លាស់ ដោយមានចំនួនវគ្គបណ្តុះបណ្តាល ចំនួនថ្ងៃ ចំនួនប្រជាកសិករដែលត្រូវចូលរួម ក៏ដូចជាភូមិ ឃុំ ស្រុក គោលដៅ ដែលគម្រោងបានអនុវត្តក្នុងឆ្នាំ ២០០៩ ។ សកម្មភាពដទៃទៀត ក្រោមលទ្ធផលបន្តបន្ទាប់ទៀត (លទ្ធផលទី២) ត្រូវបានសរសេរ ក្នុងបែបបទដូចគ្នានិងលទ្ធផលទី១ដែរ។ សកម្មភាពនីមួយៗមានទំនាក់ទំនងតក្ក ហើយនឹងត្រូវបាន បរិយាយច្បាស់លាស់ ដូចដែលបានសរសេរនៅក្នុងអនុកិច្ចសន្យា។ |
| ២ | លទ្ធផល | ៤ | ៤ | លទ្ធផលនីមួយៗ ត្រូវបានសរសេរបរិយាយច្បាស់លាស់ ដោយមាន សូចនាករ ជាក់លាក់ និងអាចវាស់វែងបាន ។ ជា ពិសេសទៀតនោះ លទ្ធផលនីមួយៗ បានផ្សាភាប់គ្នាល្អ |

| | | | | |
|---|---|---|---|---|
| ៣ | | | | លទ្ធផលនីមួយៗ ជាការបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ហើយរួមគ្នាបំពេញគោលបំណងបន្ទាន់ ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏លទ្ធផលទាំងនោះនៅមិនអាចធ្វើឱ្យគោលបំណងបន្ទាន់ សម្រេចបានមួយរយភាគរយទេ ។ |
| ៣ | - គោលបំណងបន្ទាន់ *(គោលបំនងស្ថិតក្នុងចំណុច"ខ"នៃផ្នែកទី៣)* | ៤ | ៤ | គោលបំណងបន្ទាន់ ត្រូវបានផ្តល់នូវផលប្រយោជន៍យ៉ាងជាក់ច្បាស់ ប៉ុន្តែគោលបំណងបន្ទាន់នេះ មានកម្រិតខ្ពស់ពេក ជាហេតុធ្វើឱ្យសកម្មភាពក្នុងអនុកិច្ចសន្យាពិបាកនឹងសម្រេចគោលបំណងបន្ទាន់ខ្លាំងណាស់ ដោយសារប្រជាកសិករពួកគាត់ពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ ។ |
| ៤ | *ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា ចំណុច គ ផ្នែកទី៣* | ៤ | ៣ | ស្ថានភាពចុងបញ្ចប់ នៃអនុកិច្ចសន្យា ត្រូវបានបរិយាយច្បាស់លាស់ ហើយមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងលទ្ធផល និងសកម្មភាពរបស់អនុកិច្ចសន្យា ។ ស្ថានភាពចុងបញ្ចប់នេះត្រូវបានឆ្លុះបញ្ចាំងនូវសមិទ្ធិផលដែលសម្រេចបាននៅក្នុងក៏រិតលទ្ធផល ។ ប៉ុន្តែវាមិនបានឆ្លុះបញ្ចាំងនូវស្ថាន ភាពចុងបញ្ចប់ ឬផលប៉ះពាល់ដែលអាចកើតមានឡើង ដល់ប្រជាកសិករ និងសហគមន៍ទេ ។ គ្មានភស្តុតាងណាមួយ ជាក់ច្បាស់ដើម្បីបង្ហាញថា តើកសិករទាំងនោះបានយក ចំណេះដឹង ជំនាញ និងបច្ចេកទេស ពិតប្រាកដ ដែលពួកគេ ទទួលបាន ទៅធ្វើជាប្រយោជន៍ ក្នុងការធ្វើឱ្យប្រសើរឡើង ក្នុងជីវភាពរស់ប្រចាំថ្ងៃរបស់ពួកគេឡើយ។ |
| ៥ | *លទ្ធអភិវឌ្ឍន៍/ផលប៉ះពាល់រយៈពេលវែង គោលដៅនិងគោលបំណងអភិវឌ្ឍន៍ (ចំណុច ខផ្នែកទី៣ )* | | | នៅក្នុងចំណុចនេះ យើងមិនអាចធ្វើការវាយតម្លៃបានឡើយ ។ |

**ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារ:**

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.ជ.អ.ខ:** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | នៅមានកំរិត គួរតែពង្រឹងសមត្ថភាពបន្ថែមទៀត ហើយត្រូវមានការគាំទ្របច្ចេកទេស ។ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យការអនុវត្តន៍របស់ភ្នាក់ងារអនុវត្តន៍ | គ្មានបញ្ហាប្រឈម និងឧបសគ្គធំៗ ដែលគួរឱ្យកត់សំគាល់ទេ ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា | មានការរៀបចំទុកដាក់ឯកសារ និងការកត់ត្រាឯកសារដែលទាក់ទងនិងអនុកិច្ចសន្យាបានល្អ ។ |
| **ពីខាងភាគីអនុវត្តន៍កិច្ចសន្យា:** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | មានមន្ត្រីជំនាញ និងបទពិសោធន៏គ្រប់គ្រាន់ ។ |
| ៥ | ការអនុវត្តន៍សកម្មភាពទាន់ពេលវេលា និងលទ្ធផល | ការអនុវត្តន៍សកម្មភាព និងលទ្ធផល មិនបានទាន់ពេលវេលាដូចដែលបានគ្រោងទុកទេ ដោយការចុះហត្ថលេខាលើអនុកិច្ចសន្យាមានការយឺតយ៉ាវ ។ |
| ៦ | ការរាយការណ៏ការរីកចំរើន និងការកត់ត្រាឯកសារ | អនុវត្តទៅតាមការណែនាំរបស់ គ.ប្រ នៃ គ.អ.ជ.ខ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | ត្រូវបានគោរពតាមមួយរយភាគរយ |
| **ទាំងខាង គ.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យា:** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" ( ចំណុច-ង ផ្នែកទី៣ ) និងបញ្ហាប្រឈម | ដោយសារមានការយឺតយ៉ាវក្នុងការអនុម័តអនុកិច្ចសន្យា ដែលបានព្រាងទុក ដូច្នេះសកម្មភាពមួយមិនអាចធ្វើទៅបាន ដោយសារគ្មានពេលវេលាគ្រប់គ្រាន់សម្រាប់ចុះទៅអនុវត្ត ។ ម្យ៉ាងទៀតហានិភ័យនេះត្រូវបានភ្នាក់ងារអនុវត្តបញ្ជាក់ថា ដោយសារការដកថវិកាមិនទាន់ ពីព្រោះការអនុវត្តគម្រោងមិនបានពីដើមឆ្នាំ ។ |
| ៩ | ការបញ្ជ្រាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | មានការលើកកំពស់យេនឌ័រ ដោយការចូលរួមរបស់កសិករភាគច្រើនជាស្ត្រី នៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមជ្រូក ។ ជាពិសេសជាងនេះទៀត |

| | | |
|---|---|---|
| | | ការចូលរួមសុទ្ធជាស្ត្រីដែលជាមេផ្ទះ ហើយជាអ្នកផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ ។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ ( ចំណុច-ឆ ផ្នែកទី៣) | គម្រោងនេះជាគម្រោងដែលផ្តល់បច្ចេកទេសចិញ្ចឹមជ្រូក ដូច្នេះ វាមិនអាចប៉ះពាល់និងធ្វើឱ្យខូចខាតធនធានធម្មជាតិឡើយ ប៉ុន្តែវាអាចឱ្យប្រជាពលរដ្ឋបានយល់កាន់តែច្បាស់ ពីអត្ថប្រយោជន៍ដែលទទួលបានពីធនធានធម្មជាតិ ។ |
| ១១ | ការថែរក្សា (និរន្តភាព) ( ចំណុច-ជ ផ្នែកទី៣) | ជាមួយគ្នានេះដែរត្រូវតែពង្រឹងអំពីតួនាទី និងសមត្ថភាពរបស់ពួកគាត់ជាប្រចាំ ដើម្បីឱ្យពួកគេជួយជាទីប្រឹក្សាផង និងអ្នកអនុវត្តផង ធ្វើបែបនេះនឹងធានាបាននូវចីរភាព និងនិរន្តភាពកសិកម្ម ។ |

## ២.៤. សេចក្តីសន្និដ្ឋាន

<u>សេចក្តីសន្និដ្ឋានជារួម:</u>

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យានេះត្រូវបានអនុវត្តដូចការគ្រោងទុក ។ ភ្នាក់ងារអនុវត្តអនុកិច្ចសន្យាមានសមត្ថភាព បទពិសោធន៍ និងធនធានគ្រប់គ្រាន់ដើម្បីធ្វើឱ្យសម្រេចបាននូវលទ្ធផលដូចបានរៀបរាប់ក្នុងអនុកិច្ចសន្យា។ លទ្ធផល និងសកម្មភាពដែលបានគ្រោងទុកត្រូវបានអនុវត្តស្ទើរមួយរយភាគរយ លើកលែងតែសកម្មភាពមួយចុងក្រោយ គឺទិវាបង្ហាញអំពីបច្ចេកទេសចិញ្ចឹមជ្រូក ដែលមិនអាចអនុវត្តទាន់ពេលវេលា ។ ទោះជាយ៉ាងនេះក្តី យើងគិតថា សកម្មភាពខាងលើនេះមិនជះឥទ្ធិពលខ្លាំងចំពោះការសម្រេចបានលទ្ធផលនោះទេ ។ |
| ២ | សកម្មភាពរបស់អនុកិច្ចសន្យា និងអត្ថប្រយោជន៍ដែលប្រជាកសិករ និងសហគមន៍ទទួលបាន ទាំងអ្នកទទួលផល និងអ្នកមិនទទួលផល ត្រូវបានអបអរសាទរចំពោះគម្រោងដែលបានអនុវត្តនៅក្នុងឃុំ ។ ស្ថានភាពចុងបញ្ចប់ នៃអនុកិច្ចសន្យាត្រូវបានសម្រេចទាំងស្រុងដូចការគ្រោងទុក ។ ភស្តុតាងអំពីលទ្ធផល និងផលប្រយោជន៍ដែល ទទួលបាន ត្រូវបានសង្កេតឃើញបន្ទាប់ពីការបញ្ចប់អនុកិច្ចសន្យា នាឆ្នាំកន្លងមក រួមមាន:<br>-កសិករបន្តការចិញ្ចឹមជ្រូកតាមលក្ខណៈបច្ចេកទេសថ្មីៗ<br>ដែលទទួលបានពីវគ្គបណ្តុះបណ្តាលបច្ចេកទេសក្នុងការ ចិញ្ចឹមជ្រូកសាច់ ។<br>-ការចិញ្ចឹមជ្រូកក្នុងភូមិគោលដៅមានការកើនឡើង ដោយសារការចិញ្ចឹមរបៀបនេះទទួលបានលទ្ធផលខ្ពស់ និងចំណេញពេលវេលាគឺជ្រូកឆាប់ធំធាត់ល្អ ។ |

| | |
|---|---|
| | -ប្រជាកសិករដែលរស់នៅក្នុងឃុំជាមួយគ្នា សំណូមពរឱ្យមានវត្តស្ដីពីបច្ចេកទេសចិញ្ចឹមជ្រូក ព្រោះថាស្ថានភាពរស់នៅរបស់ពួកគេ គឺដូចគ្នានឹងភូមិដែលបានអនុវត្តគម្រោងនេះ ។<br>ដូច្នេះអនុកិច្ចសន្យានេះ បានទទួលនូវនិរន្តរភាពក្នុងសកម្មភាពរបស់ខ្លួនក៏រិតខ្ពស់ ។ ហេតុនេះ គម្រោងបានរួមចំណែកក្នុងកម្រិតតិចតួចនៅឡើយ បើគិតទៅតាមគោលដៅអភិវឌ្ឍនៅក្នុងអនុកិច្ចសន្យា ហើយនិងគោលដៅក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។ |
| ៣ | ការជ្រើសរើសសិក្ខាកាម គឺធ្វើឡើងដោយភ្នាក់ងារអនុវត្តអនុកិច្ចសន្យា និងមានការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន មន្ត្រីកសិកម្មស្រុក និងប្រជាពលរដ្ឋក្នុងភូមិគោលដៅ ។ ប៉ុន្តែការជ្រើសរើស កសិករចិញ្ចឹមជ្រូកបង្ហាញ ធ្វើឡើងដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ មានន័យថាជ្រើសរើសកសិករណាដែលមានឆន្ទៈមោះមុតមានពេល វេលាគ្រប់គ្រាន់ ធ្វើស្រែនៅជិតផ្ទះ និងធ្លាប់ចិញ្ចឹមជ្រូកតាមបែបធម្មជាតិនាពេលកន្លងមក ។ |

<u>ចំណុចរៀនសូត្រ:</u>

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ដូចដែលបានសង្កេតឃើញក្នុងការវាយតម្លៃនេះស្រាប់ ផលប៉ះពាល់របស់អនុកិច្ចសន្យា និងនិរន្តរភាពរបស់លទ្ធផលនៅក្នុងអនុកិច្ចសន្យា អាចត្រូវបានសម្រេចក្នុងកម្រិតខ្ពស់ ប្រសិនបើអនុកិច្ចសន្យានេះត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាអាទិភាពរបស់ក្រុមគោលដៅដែលជាអ្នកទទួលផល ។ |
| ២ | ការបរិយាយច្បាស់លាស់នូវគោលបំណងបន្ទាន់ ក្នុងកំរិតដែលអាចវាស់វែងបានជាកត្តាសំខាន់សម្រាប់ការកត់ត្រាទុកនូវរាល់លទ្ធផលរបស់អនុកិច្ចសន្យា និងផលប្រយោជន៍ដែលមាន ។ |
| ៣ | ប្រជាកសិករបានពង្រីកចំនួននូវការចិញ្ចឹម ព្រោះថាការចិញ្ចឹមជ្រូកតាមលក្ខណៈបច្ចេកទេសកសិកម្មទទួលបានលទ្ធផលខ្ពស់ អាចរកចំណូលបានច្រើនជាង ការចិញ្ចឹមធម្មតា ។ |
| ៤ | ប្រជាកសិករបានយកចំណេះដឹង ជំនាញ និងបច្ចេកទេសទៅអនុវត្តផ្ទាល់ក្នុងក្រុមគ្រួសារ និងសហគមន៍ ។ |

<u>អនុសាសន៍</u> :

| ល.រ | អនុសាសន៍ |
|---|---|
| ១ | ទំលាក់ថវិកាឱ្យបានដើមឆ្នាំ និងអនុម័តលើអនុកិច្ចសន្យាឱ្យបានទាន់ពេលវេលា ។ |
| ២ | សរសេរអំពីស្ថានភាពចុងបញ្ចប់របស់អនុកិច្ចសន្យាឱ្យបានច្បាស់លាស់ និងបញ្ជាក់អំពីសូចនាករត្រូវវាស់វែង ។ |
| ៣ | ត្រូវតែបង្កើនទំនាក់ទំនងល្អបន្ថែមទៀត រវាងភ្នាក់ងារអនុវត្តអនុកិច្ចសន្យា និងគ.ប្រ នៃគ.អ.ជ.ខ ដើម្បីធានា |

| | |
|---|---|
| | ដល់ប្រសិទ្ធភាព និងប្រសិទ្ធរបស់គម្រោង ។ |
| ៤ | សកម្មភាពត្រូវអនុវត្តតាមផែនការដែលបានគ្រោងទុក និងទាន់ពេលវេលា ដើម្បីឱ្យអនុកិច្ចសន្យាទទួលបានជោគជ័យ ។ |
| ៥ | ភ្នាក់ងារអនុវត្តគម្រោងត្រូវចុះតាមដានត្រួតពិនិត្យ គាំទ្រ និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋ(អ្នកទទួលផល) ដែលជួបបញ្ហា ដែលត្រូវការជំនួយបច្ចេកទេស គំនិតយោបល់ ការប្រឹក្សា ឱ្យបានញឹកញាប់ ទៀងទាត់ និងទាន់ពេលវេលា ហើយក៏គួរធ្វើឡើងបើទោះបីជីវិតរបស់គម្រោងបានបញ្ចប់ហើយក៏ដោយ ដើម្បីធានាដល់និរន្តរភាព សកម្មភាពគម្រោង និងផលប្រយោជន៍សហគមន៍ ។ |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | **12/GEN/0901-00 (GOV)** |
| ចំណងជើង: | បណ្តុះបណ្តាលជំនាញសំអាងការអ៊ុតសក់ដល់សហគមន៍ក្រីក្រ |
| ភ្នាក់ងារអនុវត្តន៍ : | មន្ទីកិច្ចការនារីរាជធានីភ្នំពេញ |
| រយៈពេល (ចាប់ផ្តើម និងបញ្ចាប់) | ចាប់ផ្តើម: 01/01/2009 និង បញ្ចាប់: 31/12/2009 |
| រាជធានី ខេត្ត | រាជធានីភ្នំពេញ |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរកិច្ចការនារី |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ/គ.អ.រ | 10,800.00 ដុល្លារសហរដ្ឋអាមេរិក |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៍ | 3000.00 ដុល្លាសហរដ្ឋអាមេរិក |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | 13,800.00 ដុល្លាសហរដ្ឋអាមេរិក |

## ក្រុមវាយតម្លៃ

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ |
|---|---|
| លោកស្រី មុំ សណ្តាប់ | ប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល |
| លោកស្រី ឈាង តុលា | អនុប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល |
| លោក អួង ផាន់ណា | មន្ត្រីត្រួតពិនិត្យ និងវាយតំលៃគ.ប្រ |
| លោក ទូច សីហា | មន្ត្រីត្រួតពិនិត្យ និងវាយតំលៃគ.ប្រ |
| លោក ឌី ផលា | ទីប្រឹក្សាត្រួតពិនិត្យ វាយតំលៃ និងវិស័យ |

## របាយការណ៍ស្តីពីវាយតម្លៃ រៀបចំដោយ :

| ឈ្មោះ | មុខតំណែង និងតួនាទីក្នុងការវាយតម្លៃ |
|---|---|
| លោក អួង ផាន់ណា | មន្ត្រីត្រួតពិនិត្យ និងវាយតំលៃគ.ប្រ |
| លោក ទូច សីហា | មន្ត្រីត្រួតពិនិត្យ និងវាយតំលៃគ.ប្រ |

## រាជធានីភ្នំពេញ

ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៣ |
| | របាយការណ៍សង្ខេប | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៩** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.រ និងមន្ទីរវិស័យ | ៩ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៩ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៩ |
| ១.៤ | សំណួរវាយតម្លៃ | ១០ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ១០ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ១១ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១៣** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល | ១៣ |
| | - លទ្ធផលទី១ | ១៣ |
| | - លទ្ធផលទី២ | ១៤ |
| | - លទ្ធផលទី៣ | ១៦ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម | ១៧ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង | ២២ |
| ២.៤ | សេចក្តីសន្និដ្ឋាន | ២៦ |
| | - ចំណុចរៀនសូត្រ | ២៧ |
| | - អនុសាសន៍ | ២៨ |
| **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍** | | **៣០** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ៣០ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍/ពិភាក្សា | ៣១ |
| **ករណីសិក្សា** | | **២០** |
| | - ករណីសិក្សាទី១ | ២០ |
| | - ករណីសិក្សាទី២ | ២១ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.រ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍រាជធានីភ្នំពេញ |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.រ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

**គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ :**

មន្ត្រីត្រួតពិនិត្យ និងវាយតំលៃផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលរបស់គ.ប្រវាជធានីភ្នំពេញ បានធ្វើការវាយតំលៃអនុកិច្ចសន្យា ដែលមានចំណងជើងថា: " **បណ្តុះបណ្តាលជំនាញសំអាងការ និងអ៊ុតសក់ដល់សហគមន៍ក្រីក្រ** " អនុកិច្ចសន្យាលេខ: **12/GEN/ 0901-00(GOV)** ដែលជាអនុកិច្ចសន្យារវាងគ.ប្រ នៃគ.អ.រ និងមន្ទីរកិច្ចការនារី ។ នេះជាផ្នែកមួយនៃគម្រោង ពង្រឹងសមត្ថភាពគ្រូបង្គោលថ្នាក់ ក្រោមជាតិរបស់ផ្នែកត្រួតពិនិត្យ វាយតំលៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋានគ.ជ.អ.ប ដែលគាំទ្រដោយ កម្មវិធីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ តាម រយៈវិមជ្ឈការ និងវិសហមជ្ឈការ ។

គោលបំណងជាក់លាក់នៃការវាយតំលៃគឺ:

១- កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា មន្ទីរវិស័យ និងគម្រោងពង្រឹងតួនាទីថ្នាក់ខណ្ឌ ជាមួយគ.ប្រ និងរកឃើញនូវចំនុចខ្សោយធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាព ចុងបញ្ចប់ នៃអនុកិច្ចសន្យារួមទាំង កត់ត្រានូវចំនុចរៀនសូត្រ និងផ្នែកនៃអនុកិច្ចសន្យាដែលត្រូវ ធ្វើឱ្យប្រសើរឡើង នាពេលអនាគត ។

២- ពង្រឹងការងារតាមដានត្រួពិនិត្យ និងវាយតំលៃគម្រោងរបស់គ.ប្រ នៃគ.អ.រ នៅក្នុងការដំណើរការអនុវត្តអនុកិច្ចសន្យា និងឆ្លុះបញ្ចាំងឱ្យឃើញពីចំនុចវិជ្ជមាន និងអវិជ្ជមាន ដែលទទួលបានពីការវាយតំលៃតាមរយៈ ការប្រមូលទិន្នន័យ និងការចុះសំភាសន៍ផ្ទាល់ ជាមួយក្រុមគោលដៅពាក់ព័ន្ធ។

ទោះបីជាគោលបំណងខាងលើបានគ្រប់ដណ្តប់សម្រាប់ការវាយតម្លៃលើកនេះក៏ដោយតែយើងមិនអាចវាយតម្លៃផលប៉ះពាល់របស់អនុកិច្ចសន្យាទៅលើ **"ការកាត់បន្ថយភាពក្រីក្រ"** ដែលជាគោលដៅរបស់អនុកិច្ចសន្យា និង **"អត្ថប្រយោជន៏"** **"ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា "** លទ្ធផលដែលទទួលបានធៀបទៅនឹងផែនការអត្ថប្រយោជន៏ ទទួលបានភ្លាមៗ ដែលបានមកពីលទ្ធផល និង**"ទិសដៅបន្ទាន់"** ខ្លះៗ ទាំងអស់នោះបានទេ ប៉ុន្តែគេអាចធ្វើការប្រៀប ធៀប និងធ្វើការប៉ាន់ប្រមាណលើចំណេះដឹង និងចម្លើយដែលបានឆ្លើយក្នុងកិច្ចសម្ភាសន៏ និងការពិនិត្យមើលជាក់ស្តែង ក្នុងកម្រិតមួយចំណែក ហើយធ្វើការប្រៀបធៀបទៅនឹងការអនុវត្តទាំងមូលតែម្តង។

ឆ្លើយទៅនឹងសំណួរទាំង៥ នៃការវាយតំលៃ:

១- សកម្មភាពទាំងអស់ត្រូវបានអនុវត្ត និងលទ្ធផលសំរេចតាមផែនការគ្រោងទុក

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១ | បណ្តុះបណ្តាល ក្រុមការងារមន្ទីរ-ខណ្ឌស្តីពីសីលធម៌សង្គម បំណិនជីវិត និង អភិវឌ្ឍន៍គ្រួសារខ្មែរ ១វគ្គ ដល់ជនបង្គោលមន្ទីរជំនាញចំនួន២៩នាក់ | បានបណ្តុះបណ្តាលចំនួន១វគ្គ ដែលមានសិក្ខាកាមចូលរួម សរុបចំនួន៣០នាក់ ក្នុងនោះស្ត្រីចំនួន ២៧នាក់ |
| ២ | បណ្តុះបណ្តាល ប្រជុំ និងសិក្ខាសាលាក្រៅក្រុង ១៥នាក់-ថ្ងៃ | បាន១លើក មន្ត្រីចូលរួមចំនួន ១៥នាក់-ថ្ងៃ |
| ៣ | បណ្តុះបណ្តាលពីការរៀបរៀបវេទិការពង្រឹងការងារដល់គ្រូបង្គោលមន្ទីរ/ជុំវិញក្រុង ១វគ្គ ដល់ជនបង្គោលមន្ទីរជំនាញចំនួន៣០នាក់ | បានបណ្តុះបណ្តាលចំនួន១វគ្គ ដែលមានសិក្ខាកាមចូលរួម សរុបចំនួន ៣០នាក់ ក្នុងនោះស្ត្រីចំនួន ២៧នាក់ |
| ៤ | ផ្សព្វផ្សាយសីលធម៌សង្គម បំណិនជីវិត និង អភិវឌ្ឍន៍គ្រួសារ ដល់មន្ត្រីទទួល បន្ទុកស្រីនិងកុមារ ៨វគ្គ អ្នកចូលរួមចំនួន ៣៦០នាក់ | ផ្សព្វផ្សាយបានចំនួន៨វគ្គដែលមានសិក្ខាកាមចូលរួម សរុបចំនួន៣៦០នាក់ ក្នុងនោះស្ត្រីចំនួន ៣១០នាក់ |
| ៥ | ផលិតអាវយឺតចំនួន១២០០អាវ | អាវយឺតចំនួន១២០០អាវ ត្រូវបាន ផលិតសំរេចបាន១០០% តាមការផែនការគ្រោងទុក |
| 6 | ផលិតផ្ទាំងរូបភាពចំនួន៤៧៥០ផ្ទាំង | ផ្ទាំងរូបភាពចំនួន៤៧៥០ផ្ទាំង ត្រូវបានផលិតសំរេចបាន ១០០%តាមការផែនការគ្រោងទុក |
| 7 | បណ្តុះបណ្តាលជំនាញសំខាន់ៗដល់ក្រុមប្រឹក្សា,មន្ត្រីទទួលបន្ទុកកិច្ចការនារីនិងកុមារ,មេភូមិ និងជំនួយការភូមិ ចំនួន៧វគ្គ អ្នកចូលរួមចំនួន២៨០នាក់ | ផ្សព្វផ្សាយបានចំនួន៧វគ្គដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៣១០នាក់ ក្នុងនោះស្ត្រីចំនួន ២៧០នាក់ |

| | | |
|---|---|---|
| 8 | ផ្សព្វផ្សាយពីសីលធម៌សង្គម បំណិនជីវិត និងអភិវឌ្ឍន៍គ្រួសារ ដល់សហគមន៍ ៧វគ្គ អ្នកចូលរួមចំនួន ៣១៥នាក់ | បានផ្សព្វផ្សាយដល់សិក្ខាកាមចំនួន ៣៣០នាក់ ស្ត្រីចំនួន ២៨៣នាក់ |
| ៩ | បណ្តុះបណ្តាលជំនាញសំអាងការ និង អ៊ុតសក់ដល់សហគមន៍ ៣វគ្គ អ្នកចូលរួមចំនួន៦០នាក់ | សិក្ខាកាមជាស្ត្រីចំនួន៦០នាក់ |
| ១០ | សំភារៈសំរាប់សំអាងការនៅសហគមន៍ ចំនួន៥គ្រឿង | បានទិញ៥គ្រឿង ៈកង្ហាហត្ថារី២ បំពង់ចំហុយសក់១ បំពង់អប់សក់១ និងកៅអីកក់សក់១ |
| ១១ | ផ្សព្វផ្សាយពី ការជួញដូរស្ត្រី និងកុមារដល់ប្រជាជន ចំនួន៧វគ្គ អ្នកចូលរួមចំនួន ៣១៥នាក់ | បានផ្សព្វផ្សាយដល់សិក្ខាកាម ចំនួន៣៣៤នាក់ ស្ត្រីចំនួន១៩៨នាក់ |
| ១២ | ផ្សព្វផ្សាយពីការពង្រឹងមេភូមិ និងជំនួយការភូមិពីយេនឌ័រក្នុងការ ចូលរួមអភិវឌ្ឍន៍ ៧វគ្គ អ្នកចូលរួមចំនួន៣១៥នាក់ | បានផ្សព្វផ្សាយដល់សិក្ខាកាម ចំនួន៣៣៨នាក់ ស្ត្រីចំនួន២៥២នាក់ |
| ១៣ | ផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារដល់ប្រជាជន ៧វគ្គ អ្នកចូលរួមចំនួន ៣១៥នាក់ | បានផ្សព្វផ្សាយដល់សិក្ខាកាម ចំនួន៣៣៤នាក់ ស្ត្រីចំនួន២០០នាក់ |

២-ការបណ្តុះបណ្តាលជំនាញសំអាងការ និងអ៊ុតសក់ មានសារៈប្រយោជន៍ណាស់ ដោយផ្តល់ជំនាញវិជ្ជាជីវៈពិតប្រាកដដល់ស្ត្រីក្រីក្រដែលរស់នៅក្នុងសហគមន៍ ដែលធ្វើឲ្យពួកគេអាចរកការងារធ្វើបាន មានមុខរបរច្បាស់លាស់ អាចរកប្រាក់ចំណូលបានដោយខ្លួនឯង និងអាចផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារបន្ថែមទៀត ។

៣-លទ្ធផលបន្ទាន់ និងផលប្រយោជន៍ពីវគ្គបណ្តុះបណ្តាលសីលធម៌សង្គម បំណិនជីវិត និងអភិវឌ្ឍន៍គ្រួសារខ្មែរ ប្រជុំ និងសិក្ខាសាលាក្រៅក្រុង ការរៀបចំវេទិកាពង្រឹងការងារដល់គ្រូបង្គោលមន្ទីរផ្សព្វផ្សាយសីសធម៌សង្គម បំណិនជីវិតនិងអភិវឌ្ឍន៍គ្រួសារដល់មន្ត្រីទទួលបន្ទុកស្រីនិងកុមារ ផលិតអាវយឺត ផលិតផ្ទាំងរូបភាពបណ្តុះបណ្តាលជំនាញ សំខាន់ៗដល់ក្រុមប្រឹក្សា,មន្ត្រីទទួលបន្ទុកកិច្ចការនារី និងកុមារ មេភូមិ និងជំនួយការភូមិ ផ្សព្វផ្សាយ

ពីសីលធម៌ សង្គម បំណិនជីវិត និងអភិវឌ្ឍន៍គ្រួសារដល់សហគមន៍ សំភារៈសំរាប់សំអាងការ នៅសហគមន៍ ផ្សព្វផ្សាយពីការ ជួញដូរស្ត្រី និងកុមារដល់ប្រជាជន ផ្សព្វផ្សាយពីការពង្រឹងមេភូមិ និងជំនួយការភូមិ ពីយេនឌ័រ ក្នុងការចូលរួមអភិវឌ្ឍន៍ ផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារដល់ប្រជាជន ពិបាកធ្វើការ វាយតំលៃណាស់ព្រោះយើងគ្មាន ឯកសារ និងពតិមានជាមូលដ្ឋានសំរាប់យកមកធ្វើការវាយតំលៃ ។

៤-ជារួមអនុកិច្ចសន្យាសំរេចបាននូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាទទួលបានលទ្ធផលល្អប្រសើរតាមផែនគ្រោងទុក គឺ១០០% ។

៥- អនុកិច្ចសន្យាពិតជាបានរួមចំណែកក្នុងការសំរេចនូវគោលបំណងបន្ទាន់ដោយសារស្ត្រីដែលជាសិក្ខាកាម បានទទួល ចំណេះដឹង ជំនាញផ្នែកសំអាងការ និងអ៊ុតសក់ ហើយពួកគេបានយកជំនាញទាំងនេះ ទៅអនុវត្តជាក់ស្តែងដោយ បានបើកហាងអ៊ុតសក់បំរើសេវាកម្មសំអាងការ តាមក្រុមហ៊ុនសំអាងការ និងអ្នកខ្លះក្លាយជាគ្រូបណ្តុះបណ្តាល ប្រចាំមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សហគមន៍សាមគ្គី ដើម្បីរកចំណូលក្នុងគ្រួសាររបស់ពួគេ។ ចំណែកខ្លះទៀតទោះបីជាមិនបានបើកហាងក៏ដោយ ក៏ពួកគេបាននិងកំពុងយកជំនាញនេះ ទៅប្រើប្រាស់ជាមួយបងប្អូន និង ក្រុមគ្រួសារ ដើម្បីកាត់បន្ថយការចំណាយនៅក្នុងក្រុមគ្រួសារ។

៦- អនុកិច្ចសន្យានេះពិតជាមានភាពពាក់ព័ន្ធ ប្រសិទ្ធិភាព និងប្រសិទ្ធិផល ដែលទាក់ទងទៅនឹងធនធានដែលបានធ្វើប្រតិបត្តិការ និងការគ្រប់គ្រងទូទៅ ។ ប៉ុន្តែទោះជាយ៉ាងណា គុណភាពនៃការរៀបចំអនុកិច្ចសន្យា គួរតែត្រូវកែលំអរដូចខាងក្រោមៈ

ក- បរិយាយឱ្យបានច្បាស់លាស់ និងអាចវាស់វែងបាន នូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា និងគោលបំណងបន្ទាន់ ។ ជាពិសេសគួរមានតារាងផែនការតក្កភាព និងតារាងគ្រប់គ្រងគំរោងតាមលទ្ធផល។

ខ- ការប្រើប្រាស់សូចនាករជោគជ័យធៀបទិន្នន័យជាមូលដ្ឋាន ។

គ- ភ្ជាប់ទំនាក់ទំនងឱ្យបានច្បាស់លាស់រវាងលទ្ធផល គោលបំណងបន្ទាន់ គោលបំណងកំរិតខ្ពស់ ។

**សេចក្តីការសន្និដ្ឋានៈ**

១- លទ្ធផល និងអត្ថប្រយោជន៏ដែលបានពីការអនុវត្តន៍អនុកិច្ចសន្យាជាប្រយោជន៏ដល់សហគមន៍ គឺមានភស្តុតាងបង្ហាញច្បាស់លាស់ ហើយត្រូវបានទទួលសាទរពីអ្នកទទួលផល និងអ្នកមិនទទួលផលនៅក្នុងសង្កាត់ខណ្ឌរបស់គំរោង។ ដូចជាមានជំនាញច្បាស់លាស់លើផ្នែកសំអាងការ និងអ៊ុតសក់ ដែលអាចរកប្រាក់ចំណូល សំរាប់ក្រុមគ្រួសារ និងខ្លួនឯង ។ លើសពីនេះទៀតយកចំណេះទាំងនេះ ទៅបណ្តុះបណ្តាលបន្តទៅអ្នកជំនាន់ ក្រោយទៀត ។

២- គួរមានការគាំទ្រគំរោងនេះ ដោយពង្រីកសកម្មភាពគំរោងនេះបន្តទៅទៀត ។

៣- ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីធ្វើឱ្យសំរេចបានអត្ថប្រយោជន៍ក្នុងកំរិតខ្ពស់ ភ្នាក់ងារអនុវត្តគំរោងគួរជ្រើសរើសអ្នកទទួលផលឱ្យបានសមស្រប ។

៤- ដើម្បីពង្រឹងនូវគុណភាព និងភាពទាក់ទងរបស់គម្រោង គួរមានការបរិយាយឱ្យបានច្បាស់លាស់ នូវស្ថានភាព ចុងបញ្ចប់ នៃអនុកិច្ចសន្យា និងគោលបំណងបន្ទាន់របស់គម្រោង ក៏ដូចជាពង្រឹងនូវ ទំនាក់ទំនងតក្កភាពធាតុ ខាងលើទៅនឹងលទ្ធផល ។

៥- ផ្នែករដ្ឋបាលនិងការគ្រប់គ្រងអនុកិច្ចសន្យាគួរធ្វើការវាយតំលៃគំរោងស្រដៀងគ្នានេះឱ្យបាន១ ឬ២ អនុកិច្ចសន្យាជា ប្រចាំ ។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.រ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្តល់ថវិកាតាមរយៈ គ.ប្រ នៃគ.អ.រ ទៅមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និងគម្រោងដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈជាប្រព័ន្ធ មិនបានអនុវត្តទេកាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើន។ នៅក្នុងឆ្នាំ ២០១០ ជាមួយនឹងការគាំទ្រផ្នែកថវិកា និងបច្ចេកទេស ពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យា គ.ប្រ នៃគ.អ.រ ក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យា ដែលបានរៀបចំរួមគ្នាជាមួយភ្នាក់ងារអនុវត្តន៍ដែលមានអនុកិច្ចសន្យាលេខៈ **12/GEN/0901-00 ( GOV )** និងចំណង ជើង " **បណ្តុះបណ្តាលជំនាញសំអាងការ និងអ៊ុតសក់ដល់សហគមន៍ក្រីក្រ**" ដំណើរការលទ្ធផល ដែលបានរកឃើញ និងការសន្និដ្ឋាន នៃការវាយតម្លៃត្រូវបានកត់ត្រា ហើយនឹងបង្ហាញតាមរយៈរបាយការណ៍ស្តីពី ការវាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

គោលបំណង អនុកិច្ចសន្យា គឺបង្កើនការចូលរួមរបស់ស្ត្រី និងធ្វើឱ្យមានតុល្យភាព បុរសស្ត្រីក្នុងសកម្មភាព អភិវឌ្ឍន៍ សង្គម និងសេដ្ឋកិច្ចដោយបង្កើនការយល់ដឹងឱ្យបានទូលំទូលាយពីតួនាទី និង ការទទួលខុសត្រូវ របស់ស្ត្រីតាមរយៈ ការបង្កើត និងពង្រឹងបណ្តាញការងារយេនឌ័រ និងកុមារពីថ្នាក់ក្រុងរហូតសង្កាត់ សំដៅរួមចំណែកការបញ្រ្ជាប យេនឌ័រ និងជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ តាមគោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូល ដោយផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ នៃ គ.អ.រ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និងតម្លាភាព។ ដូច្នេះ ទំហំនៃការវាយតម្លៃមានដែនកំណត់តាមទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខណ្ឌការងារនៃការវាយតម្លៃ។ គោលបំណង នៃការវាយតម្លៃគឺៈ ក) ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និងចំនុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំងកត់ត្រានូវចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត និង ខ) ដើម្បីពង្រឹងរបៀបធ្វើការវាយ

តម្លៃ គម្រោងរបស់ គ.ប្រ នៃគ.អ.រ នៅក្នុងដំណើរការនៃការអនុវត្ត ។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា?

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ?

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សំភារៈ និងដំណើរការវាយតម្លៃ

**វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើៈ**

១) ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆ្នាំ និងកំណត់ហេតុប្រជុំ របាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍បញ្ចប់អនុកិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍ វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធ ដែលមាននៅក្នុងផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលនៃគ.ប្រ និង ភ្នាក់ងារ អនុវត្តន៍ ។

២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗ រួមមានៈ អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និង អ្នកទទួលផល ផ្ទាល់០១នាក់ និងមិនផ្ទាល់ ០១នាក់ មេភូមិ០១នាក់ មន្ត្រីបង្គោលឃេនឌ័រ០១នាក់ និង ចៅសង្កាត់០១នាក់ ។

៣) ចុះពិនិត្យតំបន់អនុវត្តន៍គម្រោង និងសង្កេតមើលសកម្មភាព ពិភាក្សាក្រុម និង ករណីសិក្សា។

៤) ចុះពិនិត្យតំបន់អនុវត្តន៍គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់ ។

៥) <u>វិភាគទិន្នន័យ និងបកស្រាយៈ</u> ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់ ។

៦) <u>ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៍</u> ដោយភ្នាក់ងារអនុវត្តន៍ និងអ្នកពាក់ព័ន្ធតាមរយៈ ព័ត៌មានត្រឡប់ដែលទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើងកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០។ ការវាយតម្លៃត្រូវធ្វើតាម "គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា" និងវិធីសាស្ត្រដែលបានណែនាំ។ ដូច្នេះ ដំណើរការត្រូវបានធ្វើឡើងដោយមានទម្រង់ការណែនាំ និងតម្លាភាព រួមទាំងការចូលរួមពីអ្នកពាក់ព័ន្ធ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយ គ.ប្រ និងអ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយការប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត។

២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត : វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោង នៅពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និង បទពិសោធន៍ពីមុនមក។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណង សំខាន់ គឺដើម្បី"រៀនធ្វើដោយការអនុវត្តផ្ទាល់" ។ អ្នកវាយតម្លៃ បានទទួលការគាំទ្រ ដោយមានគោលការណ៍ការ ណែនាំឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធ ដើម្បីដោះស្រាយ បញ្ហាទាំងអស់នេះ។

៣) បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យាៈ ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និងជោគជ័យទេ ។ មួយទៀត ទំនាក់ទំនងសង្ខេបតាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់ មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ។

៤) ដោយយើងមិនមានសូចនាករបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍" ដែលជាកម្រិត អត្ថប្រយោជន៍ទៅលើគោលនយោបាយវិម្ឋការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។

៥)ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិត ទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ។ យើងអាចវាយតម្លៃតែទៅលើសកម្មភាព **បណ្តុះបណ្តាលស្តីពីការកសាងទំនុកចិត្តដល់ ក្រុមស្ត្រី និងគណៈកម្មាធិការធនធានធម្មជាតិ** ដែលជាលទ្ធផលទី២ និងសកម្មភាព ***បណ្តុះបណ្តាលជំនាញ សំអាងការ និងអ៊ុតសក់ដល់សហគមន៍*** ដែលជាសកម្មភាពទី៦ នៃអនុកិច្ចសន្យា លំអិតតាមរយៈ ការសម្ភាសន៍ ស៊ីជម្រៅ ក្រុមពិភាក្សា និងការចុះពិនិត្យតំបន់អនុវត្តគម្រោង។

៦)ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា មិនអាចធ្វើទៅបានទេ ព្រោះចំណុច **គ** នៃផ្នែក ទី៣ ក្នុងឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ ឬមិនពេញលេញ។ ការងារនេះ នឹងកាន់តែមានសុពលភាព និង ពោរពេញ ទៅដោយព័ត៌មាន បើសិនជាចំនុចដែលបានរៀបរាប់ខាងលើ នេះត្រូវបានដោះស្រាយ។

**<u>ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធន៍:</u>**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ អនុកិច្ចសន្យាលេខ:**12/GEN/0901-00(GOV)**

គាំទ្រដល់មន្ទីរកិច្ចការនារីរាជធានីភ្នំពេញ ដើម្បីលើកកំពស់សមភាពយេនឌ័រ និងដែនកំណត់ ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ។

២) ការវាយតម្លៃនេះលម្អិតតែទៅលើ **ការបណ្តុះបណ្តាល ស្តីពីការកសាងទំនុកចិត្ត ដល់ក្រុមស្ត្រី និងគណៈ កម្មាធិការធនធានធម្មជាតិ** ដែលជាលទ្ធផលទី២ និង *វគ្គបណ្តុះបណ្តាលជំនាញសំអាងការ និងអ៊ុតសក់ ដល់សហគមន៍* ដែលជាសកម្មភាពទី៦ នៃអនុកិច្ចសន្យា ។

៣) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃទៅលើ ភ្នាក់ងារអនុវត្តន៍ ភ្នាក់ងារដែលពាក់ព័ន្ធគម្រោង ហើយនឹង ការវាយតម្លៃទៅលើគ.ប្រ នៃគ.អ.រ និង គ.ជ.អ.ប ទេ ។

ហេតុដូច្នេះ របាយការណ៍នៃការវាយតម្លៃ លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ដែលបានលើកឡើង ត្រូវពិនិត្យដោយយោលទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ។

# ២_លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល

**លទ្ធផលទី១ :ពង្រឹងសមត្ថភាពដល់មន្ត្រីកិច្ចការនារី**

**ផ្នែក-ក : ការសំរេចជាក់ស្តែងធៀបនឹងផែនការ**

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | បណ្តុះបណ្តាលក្រុមការងារមន្ទីរ-ខណ្ឌ ស្តីពីសីលធម៌សង្គម បំណិនជីវិតនិង អភិវឌ្ឍន៍គ្រួសារខ្មែរ ១វគ្គ អ្នកចូលរួម២៥នាក់ | បានចំនួន១វគ្គ សិក្ខាកាមចំនួន៣០នាក់ ស្ត្រី២៧នាក់ ដែលមានរយៈពេល០១ថ្ងៃ |
| ១.២ | បណ្តុះបណ្តាល ប្រជុំ និងសិក្ខាសាលា ក្រៅក្រុង ១៥នាក់-ថ្ងៃ | បានចំនួន១លើក សិក្ខាកាមចូលរួមចំនួន៤នាក់ រយៈពេល០៣ថ្ងៃ ស្មើនឹង១២នាក់-ថ្ងៃ |
| ១.៣ | បណ្តុះបណ្តាលពីការរៀបចំ វេទិការពង្រឹង ការងារដល់គ្រូបង្គោល មន្ទីរ/ជុំវិញក្រុង១វគ្គ អ្នកចូលរួម៣០នាក់ ។ | បានចំនួន១វគ្គ សិក្ខាកាមចំនួន៣០នាក់ ស្ត្រី២៧នាក់ ដែលមានរយៈពេល០១ថ្ងៃ |

**ផ្នែក-ខ : ការវិភាគ និងវាយតំលៃជារួមអំពីលទ្ធផល**

| |
|---|
| អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និងសកម្មភាពតាមការគ្រោងទុក ។ ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ មិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះបានលម្អិតទេ ។ |

**លទ្ធផលទី២: បណ្តុះបណ្តាលស្តីពីការកសាងទំនុកចិត្ត ដល់ក្រុមស្ត្រី និង គណៈ កម្មាធិការ ធនធានធម្មជាតិ**

**ផ្នែក-ក : ការសំរេចលទ្ធផលជាក់ស្តែងធៀបនឹងផែនការ**

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ២.១ | ផ្សព្វផ្សាយសីលធម៌សង្គម បំណិនជីវិត និង អភិវឌ្ឍន៍គ្រួសារដល់មន្ត្រីទទួលបន្ទុកស្រីនិងកុមារ ចំនួន៨វគ្គ អ្នកចូលរួមចំនួន៣៦០នាក់ | ផ្សព្វផ្សាយបានចំនួន៨វគ្គ សិក្ខាកាមចូលរួម សរុបចំនួន៣៦០នាក់ ក្នុងនោះស្ត្រីចំនួន៣១០នាក់ |
| ២.២ | ផលិតអាវយឺតចំនួន១២០០អាវ | ផលិតអាវយឺតចំនួន១២០០អាវ សំរេចបាន១០០% តាមការផែនការគ្រោងទុក |
| ២.៣ | ផលិតផ្ទាំងរូបភាពចំនួន៤៧៥០ផ្ទាំង | ផលិតផ្ទាំងរូបភាពចំនួន៤៧៥០ផ្ទាំង សំរេចបាន១០០% តាមការផែនការគ្រោងទុក |
| ២.៤ | បណ្តុះបណ្តាលជំនាញសំខាន់ៗដល់ក្រុម ប្រឹក្សា,មន្ត្រីទទួលបន្ទុកកិច្ចការនារីនិងកុមារ,មេភូមិ និងជំនួយការភូមិ ចំនួន៧វគ្គ អ្នកចូលរួម ២៨០នាក់ | ផ្សព្វផ្សាយបានចំនួន៧វគ្គ សិក្ខាកាមចូលរួម សរុបចំនួន៣១០នាក់ ក្នុងនោះស្ត្រីចំនួន២៧០នាក់ |
| ២.៥ | ផ្សព្វផ្សាយពីសីលធម៌សង្គម បំណិនជីវិត និងអភិវឌ្ឍន៍គ្រួសារដល់សហគមន៍ ចំនួន៧ វគ្គ អ្នកចូលរួមចំនួន៣១៥នាក់ ។ | បណ្តុះបណ្តាលបានចំនួន៧វគ្គ សិក្ខាកាមចូលរួមសរុបចំនួន៣៣៤នាក់ ដែលវគ្គនីមួយៗមានរយៈពេល០១ថ្ងៃ |
| ២.៦ | បណ្តុះបណ្តាលជំនាញសំអាងការ និង អ៊ុតសក់ដល់សហគមន៍ ដល់សហគមន៍ ចំនួន ៣វគ្គ អ្នកចូលរួមចំនួន៦០នាក់ | បណ្តុះបណ្តាលបានចំនួន៣វគ្គ សិក្ខាកាមចូលរួមសរុបចំនួន៦០នាក់ ដែលវគ្គនីមួយៗមានរយៈពេល ៣ខែ សំរេចបាន១០០% តាមផែនការដែលបានគ្រោងទុក ។ |

| | | |
|---|---|---|
| ២.៧ | សំភារៈសំរាប់សំអាងការនៅសហគមន៍ ៥គ្រឿង | ទិញសំភារៈសំអាងការសំរាប់បង្រៀនដល់សិស្សរៀនសំអាងការអ៊ុតសក់នៅសហគមន៍សាមគ្គីចំនួន៥គ្រឿង ( កង្ចា២ បំពង់ចំហុយសក់១ បំពង់អប់សក់១ កៅអីកក់សក់១ ) |

## ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

អនុកិច្ចសន្យារបស់មន្ទីរកិច្ចការនារី ដែលបានអនុវត្តនៅក្នុងឆ្នាំ២០០៩ សំរេចបានលទ្ធផល និងសកម្មភាពនានារបស់អនុកិច្ចសន្យាដូចដែលបានគ្រោងទុក ។ យោងតាមការពិភាក្សាក្រុម របស់អ្នកទទួលផលពីគម្រោង បានឆ្លុះបញ្ចាំងឱ្យឃើញថា: ការបណ្តុះបណ្តាលសំអាងការ និងអ៊ុតសក់ ធ្វើឱ្យពួកគាត់មានចំណេះដឹង ជំនាញច្បាស់លាស់ អាចប្រកបមុខរបរដោយខ្លួនឯង ដោយមិនពឹងផ្អែកលើឪពុកម្តាយ ឬប្តីឡើយ មិនតែប៉ុណ្ណោះពួកគាត់មានមុខរបរពិតប្រាកដ អាចរកថវិកាចិញ្ចឹមជីវិតដោយខ្លួន និងផ្គត់ផ្គង់គ្រួសារទាំងមូល ។

សិក្ខាកាមទាំងអស់មានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះមេរៀន ការបង្រៀន និងការអនុវត្តផ្ទាល់ របស់គ្រូបណ្តុះបណ្តាល ដែលផ្តល់ជំនាញ និងចំណេះដឹងដល់ពួកគាត់ ។ ទន្ទឹមនឹងនេះដែរ សិក្ខាកាមមួយចំនួនបានសំណូមពរ សូមការបណ្តុះបណ្តាល លើកក្រោយទៀត សូមឱ្យមានឧបករណ៍ សំភារៈសំរាប់សិក្ខាកាម និងសំរាប់គ្រូបង្រៀនឱ្យមានគ្រប់គ្រាន់ ដើម្បីឱ្យសិក្ខាកាមងាយឆាប់យល់នូវមេរៀននីមួយៗ។ ទន្ទឹមនឹងនេះដែរ សិក្ខាកាមបានសំណូមពរដល់ស្ថាប័នពាក់ព័ន្ធ មេត្តាផ្តល់កន្លែងស្នាក់នៅក្នុងរយៈពេលសិក្សាសំរាប់សិក្ខាកាមដែលមាន ទីលំនៅឆ្ងាយពីមជ្ឈមណ្ឌលបណ្តុះបណ្តាល ដែលមានទីតាំងស្ថិតនៅសង្កាត់ត្រពាំងក្រសាំង ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលគ្មានលទ្ធភាពចំណាយលើមធ្យោបាយទៅ និងមក ក្នុងកំឡុង ពេលសិក្សាប្រចាំថ្ងៃ ។

ដូច្នេះសរុបសេចក្តីមកគម្រោងបណ្តុះបណ្តាលជំនាញសំអាងការ និងអ៊ុតសក់ មានសារៈប្រយោជន៍ណាស់សំរាប់ផ្តល់ជំនាញ ចំណេះដឹង មានមុខរបរពិតប្រាកដ និងសិក្ខាកាមខ្លះទៀតក្លាយជាគ្រូបណ្តុះបណ្តាល នៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈសហគមន៍សាមគ្គី ស្ថិតនៅសង្កាត់ត្រពាំងក្រសាំង ខណ្ឌដង្កោ រាជធានីភ្នំពេញទៀតផង ។ លើសពីនេះទៀតក្នុងការ ជួយលើកកំពស់ជីវភាពរស់នៅរបស់ស្ត្រី ក្រុមគ្រួសារ និងសហគមន៍ ឱ្យកាន់តែប្រសើរឡើង ដែលស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលតំណាក់កាលទី២ ក្នុងការកាត់ បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

## លទ្ធផលទី៣: បណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រ

### ផ្នែក-ក : ការសំរេចបានលទ្ធផលជាក់ស្តែងធៀបនឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ៣.១ | ផ្សព្វផ្សាយពី ការជួញដូរស្ត្រី និងកុមារដល់ប្រជាជន ចំនួន៧វគ្គ អ្នកចូលរួមចំនួន ៣១៥នាក់ | ផ្សព្វផ្សាយបានចំនួន៧វគ្គ សិក្ខាកាមចូលរួមសរុបចំនួន៣៣៨នាក់ ក្នុងនោះស្ត្រីមានចំនួន១៩០នាក់ ដែលវគ្គនីមួយៗ មានរយៈពេល០១ថ្ងៃ ។ |
| ៣.២ | ផ្សព្វផ្សាយពីការពង្រឹងមេភូមិ និងជំនួយការភូមិពីយេនឌ័រក្នុងការ ចូលរួមអភិវឌ្ឍន៍ ៧វគ្គ អ្នកចូលរួមចំនួន៣១៥នាក់ | ផ្សព្វផ្សាយបានចំនួន៧វគ្គ សិក្ខាកាមចូលរួមសរុបចំនួន៣៣៨នាក់ ក្នុងនោះស្ត្រីមានចំនួន ២៥២នាក់ ដែលវគ្គនីមួយៗ មានរយៈពេល០១ថ្ងៃ ។ |
| ៣.៣ | ផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារដល់ប្រជាជន ៧វគ្គ អ្នកចូលរួមចំនួន ៣១៥នាក់ | ផ្សព្វផ្សាយបានចំនួន៧វគ្គ សិក្ខាកាមចូលរួមសរុបចំនួន៣៣៨នាក់ ក្នុងនោះស្ត្រីមានចំនួន ២០០នាក់ ដែលវគ្គនីមួយៗ មានរយៈពេល០១ថ្ងៃ ។ |

### ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

| |
|---|
| អនុកិច្ចសន្យានេះសំរេចបានលទ្ធផល និងសកម្មភាពផ្សេងៗដូចដែលបានគ្រោងទុក ។ ដោយគ្រាន់តែពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ យើងមិនអាចវាយតំលៃគុណភាព នៃលទ្ធផល បានលំអិតឡើយ ។ |

## ២.២. ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម

### ផ្នែក-ក: ការសម្រេចបាននូវស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា | ស្ថានភាពជាក់ស្តែងនៅពេលបញ្ចប់អនុកិច្ចសន្យា/ ក្នុង ពេលវាយតម្លៃ |
|---|---|
| បណ្តុះបណ្តាលក្រុមការងារមន្ទីរ-ខណ្ឌ ស្តីពី សីលធម៌សង្គម បំណិនជីវិត និង អភិវឌ្ឍន៍គ្រួសារខ្មែរ ចំនួន១វគ្គ | មន្ត្រីមន្ទីរកិច្ចការនារី និងការិយាល័យកិច្ចនារី ប្រចាំខណ្ឌទាំង៨ បានទទួលការបណ្តុះបណ្តាល ស្តីពីសីលធម៌សង្គម បំណិនជីវិត និងអភិ វឌ្ឍន៍គ្រួសារខ្មែរ ចំនួន០១វគ្គ សិក្ខាកាមចំនួន៣០នាក់ ស្ត្រី២៧នាក់ ដែលមានរយៈពេល០១ថ្ងៃ។ |
| បណ្តុះបណ្តាល ប្រជុំ និងសិក្ខាសាលា ក្រៅក្រុង ១៥នាក់-ថ្ងៃ | ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីមន្ទីរចំនួន៤នាក់ បានចូលរួម សិក្ខាសាលា នៅខេត្តបាត់ដំបងចំនួន១លើកសិក្ខាកាមចូលរួមចំនួន៤នាក់ រយៈពេល ០៣ថ្ងៃ ស្មើនឹង១២នាក់-ថ្ងៃ ។ |
| បណ្តុះបណ្តាលពីការរៀបចំ វេទិការពង្រឹង ការងារដល់គ្រូបង្គោលមន្ទីរ/ជុំវិញក្រុង ១វគ្គ | មន្ត្រីមន្ទីរជំនាញជុំវិញសាលារាជធានីភ្នំពេញ ទទួលបានការបណ្តុះបណ្តាលស្តីពីការរៀបចំវេទិការពង្រឹងការងារដល់គ្រូបង្គោលមន្ទីរ ជំនាញបានចំនួន១វគ្គ សិក្ខាកាមចំនួន៣០នាក់ ស្ត្រី២៧នាក់ ដែលមានរយៈពេល០១ថ្ងៃ។ |
| ផ្សព្វផ្សាយសីសធម៌សង្គម បំណិនជីវិត និង អភិវឌ្ឍន៍គ្រួសារដល់មន្ត្រីទទួល បន្ទុកស្រី និងកុមារ ចំនួន៨វគ្គ | ផ្សព្វផ្សាយស្តីពី ផ្សព្វផ្សាយសីសធម៌សង្គម បំណិនជីវិត និងអភិវឌ្ឍន៍គួសារដល់ចៅសង្កាត់ ចៅសង្កាត់រង មន្ត្រីទទួល បន្ទុកស្រី និង កុមារ មេភូមិ នគរបាល និងប្រជាជន បានចំនួន៨វគ្គ សិក្ខាកាម ចូលរួម សរុបចំនួន៣៦០នាក់ ក្នុងនោះស្ត្រីចំនួន ២៥៩នាក់ ។ |
| ផលិតអាវយឺតចំនួន១២០០អាវ | ផលិតបានអាវយឺតចំនួន១២០០អាវ ស្តីពីសីលធម៌សង្គម បំណិនជីវិត និងអភិវឌ្ឍន៍គ្រួសារខ្មែរ |
| ផលិតផ្ទាំងរូបភាព ចំនួន៤៧៥០ផ្ទាំង | បានផលិតផ្ទាំងរូបភាពចំនួន៤៧៥០ផ្ទាំង ស្តីពីការផ្តល់ឱកាស និង |

| | |
|---|---|
| | លើកទឹកចិត្តធ្វើឱ្យស្ត្រីមានភាពក្លាហាន ផ្សព្វផ្សាយដល់ខណ្ឌ សង្កាត់ ភូមិ និងសហគមន៍។ |
| បណ្តុះបណ្តាលជំនាញសំខាន់ៗ ចំនួន៧វគ្គ ដល់ក្រុមប្រឹក្សា ,មន្ត្រីទទួលបន្ទុកកិច្ចការនារី និងកុមារ,មេភូមិ និងជំនួយការភូមិ | បានផ្សព្វផ្សាយ ចំនួន៧វគ្គ ដល់ក្រុមប្រឹក្សា មន្ត្រីទទួលបន្ទុកកិច្ចការ នារីនិងកុមារ, មេភូមិ និងជំនួយការភូមិ សិក្ខាកាមចូលរួម សរុប ចំនួន៣១០នាក់ ក្នុងនោះស្ត្រីចំនួន ២៧០នាក់ ដើម្បីស្វែងយល់ និង ធ្វើបច្ចុប្បន្នភាពបញ្ហាយេនឌ័រ មុននឹងដំណើរការរៀបចំកម្មវិធីវិនិ យោគសង្កាត់ និងពង្រឹងកិច្ចសហការនៅមូលដ្ឋាន ។ |
| ផ្សព្វផ្សាយពីសីលធម៌សង្គម បំណិនជីវិត និងអភិវឌ្ឍន៍គ្រួសារដល់សហគមន៍ ចំនួន៧លើក អ្នកចូលរួមចំនួន៣១៥នាក់។ | បានផ្សព្វផ្សាយពីសីលធម៌សង្គម បំណិនជីវិត និងអភិវឌ្ឍន៍គ្រួសារដល់ប្រជាពលរដ្ឋនៅតាមភូមិបានចំនួន៧វគ្គ សិក្ខាកាមចូលរួមសរុប ចំនួន៣៣៤នាក់ ដែលវគ្គនីមួយៗ មាន រយៈពេល ០១ថ្ងៃ |
| បណ្តុះបណ្តាលជំនាញសំអាងការ និង អ៊ុតសក់ដល់សហគមន៍ ៣វគ្គ ចំនួន៦០នាក់ | បានបណ្តុះបណ្តាលជំនាញសំអាងការ និងអ៊ុតសក់ ដល់ស្ត្រីក្រីក្រក្នុងសហគមន៍បានចំនួន៣វគ្គ សិក្ខាកាមចូលរួមសរុបចំនួន ៦០នាក់ដែល វគ្គនីមួយៗមានរយៈពេល៣ខែ ។ |
| សំភារៈសំរាប់សំអាងការនៅសហគមន៍ ៥គ្រឿង | ទិញសំភារៈសំអាងការសំរាប់បង្រៀនដល់សិស្សរៀនសំអាងការ អ៊ុតសក់នៅសហគមន៍សាមគ្គីបានចំនួន៥គ្រឿង ក្នុងនោះមានៈ កង្ហា ចំនួន២ បំពង់ចំហុយសក់១ បំពង់អប់សក់១ និងកៅអីកក់សក់១ ។ |
| ផ្សព្វផ្សាយពី ការជួញដូរស្ត្រី និងកុមារ ដល់ប្រជាជន ចំនួន៧វគ្គ ដល់ប្រជាជនចំនួន ៣១៥ នាក់ | បានផ្សព្វផ្សាយការជួញដូរស្ត្រី និងកុមារ ដល់ប្រជាជនចំនួន៧វគ្គ ប្រជាជនចូលរួមសរុបចំនួន៣៣៤នាក់ ក្នុងនោះស្ត្រីមាន ចំនួន ១៩៨នាក់ ដែលវគ្គនីមួយៗមានរយៈពេល០១ថ្ងៃ ។ |
| ផ្សព្វផ្សាយពីការពង្រឹងមេភូមិ និងជំនួយការភូមិ ពីយេនឌ័រក្នុងការចូលរួមអភិវឌ្ឍន៍ | បានផ្សព្វផ្សាយពីការពង្រឹងមេភូមិ និងជំនួយការភូមិ ស្តីពីយេនឌ័រក្នុង ការចូលរួមអភិវឌ្ឍន៍បានចំនួន៧វគ្គ សិក្ខាកាមចូលរួមសរុបចំនួន ៣៣៨នាក់ ក្នុងនោះស្ត្រីមាន ចំនួន២៥២នាក់ ដែលវគ្គ |

| | |
|---|---|
| ចំនួន៧វគ្គ ចំនួន៣១៥នាក់ | នីមួយៗ មានរយៈពេល ០១ថ្ងៃ ។ |
| ផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ដល់ប្រជាជន ចំនួន៧វគ្គ | បានផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ដល់ប្រជាជន ចំនួន៧វគ្គ សិក្ខាកាមចូលរួមសរុបចំនួន៣៣៤នាក់ ក្នុងនោះ ស្ត្រីមាន ចំនួន២០០នាក់ ដែលវគ្គនីមួយៗ មាន រយៈពេល០១ថ្ងៃ |

## ផ្នែក-ខ: ការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា

| ធាតុនៃគោលបំណងបន្ទាន់ | ការសម្រេចបានជាក់ស្តែង នៅពេលបញ្ចប់ អនុកិច្ចសន្យា /ក្នុងពេលវាយតម្លៃ |
|---|---|
| នៅបំណាច់ឆ្នាំ២០០៩ ស្ត្រីដែលជា សិក្ខាកាម មកពីសហគមន៍ក្រីក្រ នៅតាមខណ្ឌទាំង៨ ក្នុង រាជធានីភ្នំពេញ នឹងទទួលជំនាញ មានមុខរបរថ្មី មានប្រាក់ចំណូលកើន ឡើងតាមរយៈជំនាញដែល ទទួលពីការបណ្តុះបណ្តាល សំអាងការ និងអ៊ុតសក់ | គោលបំណងបន្ទាន់ ដែលបានចែង នៅក្នុងក៏រិតខ្ពស់ធ្វើឱ្យ យើងពិបាកនៅក្នុងការវាស់វែង នៅចុងបញ្ចប់នៃអនុកិច្ច សន្យា។ ទោះបីជាគេរំពឹងថា សកម្មភាពនានានិងលទ្ធផល ទាំងឡាយរបស់អនុកិច្ចសន្យានឹងចូលរួមទៅក្នុងគោលបំណង បន្ទាន់ ប៉ុន្តែផ្អែកទៅលើការពិនិត្យឯកសារ និងវិធីសាស្ត្រ វាយតំលៃបែបគុណភាព គេមិនអាចវាយតំលៃទៅលើគោល បំណងបន្ទាន់នេះបានសំរេចក្នុងក៏រិតណាទេ |

## ផ្នែក-គ: ការវាយតំលៃផលប្រយោជន៍ជារួមដែលទទួលបាន

| |
|---|
| តាមរយៈការពិភាក្សាក្រុម យើងសង្កេតឃើញថាៈ សិក្ខាកាមមានការពេញចិត្តចំពោះផលប្រយោជន៍ នៃអនុកិច្ចសន្យា ដែលសំរេចបាន នូវចំណេះដឹង និងជំនាញ សំអាងការ និងអ៊ុតសក់ ។ ពួកគាត់បានទទួលស្គាល់ថាៈ វាមានប្រយោជន៍ណាស់ សំរាប់ខ្លួនគេផ្ទាល់ ដែលអាចរកប្រាក់ចំណូលមកផ្គត់ផ្គង់គ្រួសាររបស់ពួកគេ កាន់តែប្រសើរឡើង ។ |

# ករណីសិក្សា

## ករណីសិក្សាទី១:  អ្នកទទួលផលបុគ្គលពីគម្រោងការ  និងអ៊ុតសក់

**ប្អូនស្រី  លុយ  តុលា** មានបងប្អូនចំនួន ៤នាក់ ប្រុស ១នាក់ ស្រី ៣នាក់ នាងជាកូនទី២ ដែលមានម្តាយឈ្មោះហ៊ូ សុម៉ាលី អាយុ៤៤ឆ្នាំ មុខរបរលក់ចាប់ហួយតិចតួច និងឪពុកឈ្មោះលុយ ចាន់សុខន (ស្លាប់ ) រស់នៅភូមិលូ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ គឺជាអ្នកទទួលផលពីគម្រោងបណ្តុះបណ្តាលជំនាញសំអាងការ និងអ៊ុតសក់ នៃគម្រោងកិច្ចសន្យា របស់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍រាជធានីភ្នំពេញ។

" *ក្រោយពីបានចូលរួមក្នុងគម្រោងខាងលើនេះ ធ្វើឱ្យ ជីវភាពរស់នៅរបស់នាងខ្ញុំបានធូរធារច្រើន* " នេះជាសំដីរបស់ប្អូនស្រី លុយ តុលា ។






ប្អូនស្រី លុយ តុលា

ក្នុងពេលផ្តល់បទសំភាសន៍

មុន **តុលា** ចូលរួមក្នុងគម្រោងវគ្គបណ្តុះបណ្តាលជំនាញសំអាងការ និងអ៊ុតសក់ **តុលា** គ្មានមុខរបរ គ្មានជំនាញច្បាស់លាស់ គ្មាន លុយចាយ សុំតែលុយម្តាយចាយ ។ នាងមានការពេញចិត្តមុខរបរ នេះតាំងពីតូច និងសប្បាយរីករាយជាអនេក ក្នុងការចូលរួមក្នុង គម្រោងនេះ ហើយចាប់តាំងពី **តុលា** បានចូលរួមក្នុងគម្រោងបណ្តុះ បណ្តាល ស្តីពីសំអាងការនិងអ៊ុតសក់ នៅក្នុងឆ្នាំ២០០៩ ទទួលបាន វិញ្ញាបនប័ត្រ និងសំភារៈមួយចំនួន ដែលធ្វើឱ្យ **តុលា** មានចំណេះដឹង ជំនាញច្បាស់លាស់ ។ កាលពីមុន **តុលា**គ្មានមុខរបរ តែបន្ទាប់ពីបាន បញ្ចប់វគ្គបណ្តុះបណ្តាលរួចមក **តុលា** ខិតខំយកចំណេះដឹង ដែលទទួលបានមក ប្រកបមុខរបរពិតប្រាកដ មានប្រាក់ចំណូល ធ្វើឱ្យជីវភាព រស់នៅក្នុងគ្រួសារធូរធាជាងមុន ហើយអាចបើកហាងអ៊ុតសក់ មួយដោយខ្លួនឯង ដែលមានឈ្មោះថា:" **តុលាស្រីស្រស់អ៊ុតសក់ទាន់សម័យ** " **តុលា** អាចរកប្រាក់ចំណូលបានចាយខ្លួនឯងដោយមិនចាំបាច់ពឹងផ្អែកលើម្តាយទៀតឡើយ ។ មិនតែប៉ុណ្ណោះ នាងខ្ញុំបានផ្គត់ផ្គង់ដល់ប្អូនៗក្នុងការសិក្សាបានមួយចំនួន ទៀតផង ហើយសល់ខ្លះទៀតសំរាប់សន្សំទុក ដើម្បីទិញសំភារៈអ៊ុតសក់បន្ថែមទៀត។ **តុលា** គិតថា មុខរបរនេះងាយ ស្រួលស្អាតខ្លួន និងអាចបើកហាងបានគ្រប់កន្លែង ។ ថ្ងៃអនាគត បើសិនជាមានថវិកាច្រើន នាងខ្ញុំនឹងពង្រីកហាង ឱ្យបានធំ និងបំរើអតិថិជនឱ្យបានកាន់តែច្រើន ដើម្បីរកប្រាក់ចំណូលបានកាន់តែច្រើនថែមទៀតមកចិញ្ចឹមគ្រួសារ ទាំងមូល ។

## ករណីសិក្សាទី២: អ្នកមិនទទួលផលជាបុគ្គលពីគម្រោងសំអាងការ និងអ៊ុតសក់



ប្អូនស្រី ហ៊ូ ស្រស់
ក្នុងពេលផ្តល់បទសំភាសន៍

**ប្អូនស្រី ហ៊ូ ស្រស់** អាយុ១៩ឆ្នាំ រស់នៅភូមិលូ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ ប្អូន**ស្រីមានបងប្អូន**ទាំងអស់ចំនួន៥នាក់ ស្រី៤នាក់ ប្រុស១នាក់ នាងជាកូនទី៥ ។ ប្អូនស្រី មិនមែនជាអ្នកទទួលផលពីគម្រោងទេ ប៉ុន្តែបានដឹងពីគម្រោងបណ្តុះបណ្តាលជំនាញសំអាងការ និងអ៊ុតសក់របស់មន្ទីរកិច្ចការនារី តាមរយៈ**ប្អូនស្រី លុយ តុលា** បានចូលរៀនកាលពី ឆ្នាំ២០០៩។ ពេលឃើញគេរៀនចេះជំនាញអ៊ុតសក់ ហើយបើកហាងនិងរកប្រាក់ចំណូលបានថែមទៀត នាងមានចំណាប់អារម្មណ៍ជាខ្លាំង ចំពោះមុខជំនាញអ៊ុតសក់នេះ ហើយចង់រៀនជំនាញវិជ្ជាជីវៈនេះដូច**ប្អូនស្រី លុយ តុលា** ដែរ។ លើសពីនេះទៀត **ប្អូនស្រី ហ៊ូ ស្រស់** គិតថាវា មានសារៈប្រយោជន៍ណាស់ ធ្វើឱ្យយើងចេះដឹង មានជំនាញ ច្បាស់លាស់ និងអាចប្រកបមុខរបរ ខ្លួនឯងបាន ដោយមិនពឹងផ្អែក លើឪពុកម្តាយឡើយមិនតែប៉ុណ្ណោះមុខរបរនេះ កាលណាយើងចេះប្រាកដ ជំនាញនេះ អាចផ្តល់សេវាដល់យុវវ័យបច្ចុប្បន្ន ក្នុងការលើកសម្ផស្សស៊ីវិល័យក្នុងសង្គម ។ យើងអាចរកលុយ បានច្រើនមកចិញ្ចឹម បងប្អូន និងក្រុមគ្រួសារទាំងអស់ របស់យើងទៀតផង ។ ចុងក្រោយប្អូនស្រីសង្ឃឹមថា នឹងអាចចូលរួមវគ្គបណ្តុះ បណ្តាលអ៊ុតសក់ របស់គម្រោងក្នុងពេលអនាគត និងទទួលបានជំនាញ ចំណេះដឹង ដើម្បីឱ្យអាចបើកហាងអ៊ុតសក់ និងសំអាងការដូចអ្នកជិតខាងដែរ ។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤)

### ផ្នែក-ក: ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅនឹងតំរូវការៈ មន្ទីវិស័យ មូលដ្ឋាន គ.ជ.អ.ប និងការកាត់បន្ថយភាព ក្រីក្រៈ

ពិន្ទុ : ១=ខ្សោយណាស់ ២=ខ្សោយ ៣=មិនខ្លាំងមិនខ្សោយ ៤=ខ្លាំង ៥=ខ្លាំងណាស់

| ល.រ | ធាតុ | ទំនាក់ទំនងតក្ក ភាព | បរិយាយច្បាស់លាស់ | សង្ខេបការវាយតម្លៃ |
|---|---|---|---|---|
| ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់ | | | | |
| ១ | សកម្មភាព | ៤ | ៤ | សកម្មភាពដែលបានលើកឡើងនៅក្នុងអនុកិច្ចសន្យាពិតជាមានទំនាក់ទំនងតក្កភាពជាមួយលទ្ធផលដែលបានសរសេរនៅក្នុងឯកសារអនុកិច្ចសន្យា។ ឧទាហរណ៍ លទ្ធផលទី១ ពង្រឹងសមត្ថភាពដល់មន្ត្រីមន្ទីរកិច្ចការនារី មានសកម្មភាពជាក់លាក់ដូចជា : បណ្តុះបណ្តាលក្រុមការងារមន្ទីរខណ្ឌ ស្តីពីសីលធមិសង្គម បំណិនជីវិត និងអភិវឌ្ឍន៍គ្រួសារខ្មែរ ចំនួន០១វគ្គ បណ្តុះបណ្តាល ប្រជុំ និងសិក្ខាសាលាក្រៅក្រុងចំនួន១៥នាក់-ថ្ងៃ បណ្តុះបណ្តាលស្តីពីការរៀបចំវេទិការ ពង្រឹងការងារដល់គ្រូបង្គោលមន្ទីរជុំវិញសាលារាជធានី ចំនួន០១វគ្គ ។ ទាំងនេះបានឆ្លុះបញ្ចាំងឱ្យឃើញថា សកម្មភាពទាំងអស់មានទំនាក់ទំនងតក្កភាពជាមួយនឹងលទ្ធផលខាងលើ ហើយបានសរសេរបញ្ជាក់យ៉ាងច្បាស់លាស់ ។ សកម្មភាពនីមួយៗបានសរសេរបង្ហាញយ៉ាងច្បាស់ |

| | | | | |
|---|---|---|---|---|
| | | | | ដោយមានចំនួនវគ្គបណ្តុះបណ្តាល និងចំនួនសិក្ខាកាម ដែលត្រូវចូលរួម ក៏ដូចជា សង្កាត់ និងខណ្ឌគោលដៅ ដែលត្រូវចុះអនុវត្តអនុកិច្ចសន្យា ។ ចំពោះសកម្មភាពដទៃទៀត នៅក្រោមលទ្ធផលបន្តបន្ទាប់មកទៀត (លទ្ធផលទី២ និងលទ្ធផលទី៣) ត្រូវបានសរសេរក្នុងទំរង់បែបបទដូចគ្នានឹងលទ្ធផលទី១ដែរ ។ សកម្មភាពនីមួយៗមានទំនាក់ទំនងតក្កភាព ហើយនឹងត្រូវបានបរិយាយជាក់លាក់ ដូចដែលមានសរសេរនៅក្នុងអនុកិច្ចសន្យា ។ |
| ២ | លទ្ធផល | ៤ | ៤ | លទ្ធផលនីមួយៗត្រូវបានសរសេរច្បាស់លាស់ដោយមាន សូចនាករជាក់លាក់ ដែលអាចវាស់វែងបាន ។ លើសពីនេះទៅទៀត លទ្ធផលនីមួយៗផ្សារភ្ជាប់គ្នាយ៉ាងល្អ និងបំពេញ បន្ថែមឱ្យគ្នាទៅវិញទៅមក ហើយឆ្លើយតបទៅនឹងគោលបំណងបន្ទាន់ ក្នុងអនុកិច្ចសន្យា ។ ទោះបីជាយ៉ាងនេះ ក៏ដោយលទ្ធផលទាំងនេះ នៅមិនទាន់អាចធ្វើឱ្យគោលបំណងបន្ទាន់សំរេចបាននៅឡើយ ។ |
| ៣ | អត្ថប្រយោជន៍រយៈពេលខ្លី:(លទ្ធផល/ផលប្រយោជន៍)<br>- គោលបំណងបន្ទាន់<br>- ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា | ៤ | ៣ | -គោលបំណងបន្ទាន់ ត្រូវបានផ្តល់អត្ថន័យយ៉ាងច្បាស់ ប៉ុន្តែ គោលបំណងបន្ទាន់នេះ មានកំរិតខ្ពស់ពេក ជាហេតុធ្វើឱ្យ អនុកិច្ចសន្យានេះពិបាកនឹងសំរេចគោលបំណង បន្ទាន់នេះ ក្នុងកាលៈទេសៈបែបនេះ ។<br>-ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា ត្រូវបានបរិយាយច្បាស់ ហើយមានទំនាក់ទំនងផ្ទាល់ទៅនឹងលទ្ធផល និងសកម្មភាពនៃអនុកិច្ចសន្យា។<br>ស្ថានភាពចុងបញ្ចប់នេះបានឆ្លុះបញ្ចាំងនូវសមិទ្ធិផល |

| | | | | |
|---|---|---|---|---|
| | | | | ដែលសំរេចបាននៅក្នុងក៏រិត លទ្ធផល។ ប៉ុន្តែវាមិនបាន ឆ្លុះបញ្ចាំងនូវស្ថានភាពចុងបញ្ចប់ ឬផលប៉ះពាល់ ដែលកើតមានឡើងនៅក្នុងក៏រិតប្រជាជននិងសហគមន៍ទេ។ គ្មានភស្តុតាងច្បាស់លាស់ណាមួយ ដើម្បីបង្ហាញឱ្យឃើញថាតើសិក្ខាកាមបានយកចំណេះដឹងនិងជំនាញ ដែលពួកគេទទួលបានទៅធ្វើជា ប្រយោជន៍ក្នុងការធ្វើឱ្យប្រសើរឡើង នូវជីវភាព របស់ពួកគេទេ ។ |
| ៤ | លទ្ធផលអភិវឌ្ឍន៍/ផលប៉ះ ពាល់រយៈពេលវែង: គោលដៅ និង គោលបំណងអភិវឌ្ឍន៍ | | | មិនអាចធ្វើការវាយតំលៃបាន។ |

## ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខ័ណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារ:

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.អ.រ :** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | សមត្ថភាព ក្នុងការរៀបចំកិច្ចសន្យានៅមានចំនុចខ្វះខាតច្រើន ជាពិសេសផ្នែកទី៣ និងគំរោងថវិកា។ ដូច្នេះគួរពង្រឹងសមត្ថភាពបន្ថែម ហើយមានការគាំទ្រផ្នែកបច្ចេកទេស។ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យការអនុវត្តន៍របស់ភ្នាក់ងារអនុវត្តន៍ | សមរម្យ គ្មានការប្រឈម គ្មានឧបសគ្គ ដែលធ្វើឱ្យរាំងស្ទះដល់ការអនុវត្តកិច្ចសន្យាទេ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា | ធ្វើតាមទំលាប់ តាមនិតិវិធីដែលបានធ្វើ ។ ការកត់ត្រា និងទុកដាក់ឯកសារគួរត្រូវបានកែលំអ។ |

| | | |
|---|---|---|
| **ពីខាងភាគីអនុវត្តន៍កិច្ចសន្យាៈ** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | មន្ត្រីមានជំនាញច្បាស់លាស់ និងបទពិសោធន៍ គ្រប់គ្រាន់ក្នុងការអនុវត្តការងារ ។ |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | ការអនុវត្តសកម្មភាព និងលទ្ធផល ទាន់ពេល វេលាទៅតាមផែនការដែល បានគ្រោងទុក ។ |
| ៦ | ការរាយការណ៍ការរីកចំរើន និង ការកត់ត្រាឯកសារ | ធ្វើទៅតាមទំរង់បែបបទដែលបានណែនាំ និង និតិវិធីដែលបានធ្វើ ។ ឯកសារខ្លះបញ្ជូនមកគណៈកម្មាធិការប្រតិបត្តិ មិនបានថតចំលងទុកនៅសាម៉ីមន្ទីររបស់ខ្លួន ។ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | បានគោរព និងអនុវត្ត តាមលក្ខខណ្ឌកិច្ចសន្យា |
| **ទាំងខាង គ.អ.រ និងភាគីអនុវត្តកិច្ចសន្យាៈ** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" និងបញ្ហាប្រឈម | មិនមានបញ្ហាប្រឈមអ្វីឡើយ ដោយសារការអនុម័តកិច្ចសន្យានិង ការទំលាក់ថវិកាពីថ្នាក់ជាតិ បានទាន់ពេល ធ្វើឱ្យការអនុវត្តគម្រោង បានតាមផែនការគ្រោងទុក ។ ប៉ុន្តែការទំលាក់ថវិកាពីថ្នាក់ជាតិ ជាទូទៅមិនបាននៅដើមត្រីមាសទី១នោះទេ ។ |
| ៩ | ការបញ្ជ្រាបយេនឌ័រ | ស្ត្រី និងអ្នកដែលធ្វើការជាមួយស្ត្រីជាក្រុមគោលដៅទី១ ដែលត្រូវផ្តល់ឱកាសក្នុងការពង្រឹងសមត្ថភាព និងលើកទឹកចិត្ត ។ ការចូលរួមរបស់សិក្ខាកាម ភាគច្រើនជាស្ត្រីនៅក្នុងវគ្គផ្សព្វផ្សាយ ឬវគ្គបណ្តុះបណ្តាលពីយេនឌ័រ ជាពិសេស វគ្គបណ្តុះបណ្តាលសំអាងការ និងអ៊ុតសក់ សុទ្ធតែជាស្ត្រីដែលនៅរស់នៅ ក្នុងសហគមន៍អ្នកក្រីក្រ ។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ | គំរោងនេះមិនបានប៉ះពាល់ជាវិជ្ជមានដល់បរិស្ថានឡើយ ព្រោះទិសដៅនៃការអនុវត្តគំរោងនេះ គឺផ្តោតទៅលើ |

| | | |
|---|---|---|
| | | ការចូលរួមពីស្ត្រីការអភិវឌ្ឍន៍ និងជំរុញឱ្យមានការគាំទ្រ ពីស្ថាប័ននានា ក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ។ លើសពីនេះទៀតគំរោងនេះ ជួយពង្រឹងដល់ការគ្រប់គ្រង និងថែរក្សាបរិស្ថាន និងការគ្រប់គ្រងធម្មជាតិ នឹងត្រូវបានដាក់បញ្ចូលផងដែរទៅក្នុងកម្មវិធីសិក្សា នៃវគ្គបណ្តុះបណ្តាលនានាដែលបានរៀបចំឡើង នៅក្នុងផែនការសកម្មភាពជាក់ស្តែង របស់កិច្ចសន្យានេះដូចជា: ស្ត្រីបានចូលរួមការផ្សព្វផ្សាយការថែទាំនិងការដាំកូនឈើ ។ |
| ១១ | ការថែរក្សា | សកម្មភាពដែលបានលើកឡើងក្នុងគម្រោងនេះត្រូវបានយកទៅអនុវត្តជាក់ស្តែងដោយសិក្ខាកាមមកពីសហគមន៍ក្រីក្រ ហើយបានបន្តរហូតដល់ពេលក្រុមការងារចុះវាយតំលៃ ឃើញជាក់ស្តែង ។ ដូចនេះ និរន្តភាពផ្នែកខ្លះ នៃគម្រោង ត្រូវបានសំរេច ។ |

## ២.៤. សេចក្តីសន្និដ្ឋាន

<u>សេចក្តីសន្និដ្ឋានជារួម</u> :

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យានេះត្រូវបានអនុវត្តសំរេចបានដូចការគ្រោងទុក ។ ភាគីអនុវត្តកិច្ចសន្យាមានសមត្ថភាព និងធនធានគ្រប់គ្រាន់ ដើម្បីអនុវត្តអនុកិច្ចសន្យានេះ ។ ចំពោះលទ្ធផល និងសកម្មភាពដែលបានគ្រោងទុក ត្រូវបានបញ្ចប់ស្របតាមផែនការការងារ ១០០% ។ |
| ២ | សកម្មភាពរបស់អនុកិច្ចសន្យា និងអត្ថប្រយោជន៍ដែលសហគមន៍ទទួលបាន អ្នកទទួលផល និងអ្នកមិនទទួលផលពេញចិត្ត គំរោងដែលបានអនុវត្ត ។ ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា ត្រូវបានសំរេចទាំងស្រុង ដូចការព្រាងទុក ។ ភស្តុតាងអំពីផលប្រយោជន៍ ដែលទទួលបានដូចខាងក្រោមនៅតែឃើញបន្ទាប់ពីបានបញ្ចប់អនុកិច្ច |

| | |
|---|---|
| | សន្យាជាយូរមកហើយ ដូចជា:<br>- ស្ត្រីដែលជាសិក្ខាកាមមកពីសហគមន៍ក្រីក្រ នៅក្នុងខណ្ឌទាំង៨ ក្នុងរាជធានីភ្នំពេញ បានប្រើប្រាស់ចំណេះដឹង ជំនាញ ដែលទទួលបានពីវគ្គបណ្តុះបណ្តាលជំនាញសំអាងការ និងអ៊ុតសក់ ទៅប្រកបរបរចិញ្ចឹមជីវិត<br>- ដោយសារមានជំនាញច្បាស់លាស់ និងភាពវៃឆ្លាត សិក្ខាកាមមួយចំនួន បានទៅប្រកបមុខរបរជីវិតដោយបើកហាងអ៊ុតសក់ រកប្រាក់ចំណូលសំរាប់ជីវភាពប្រចាំថ្ងៃ និងអាចសន្សំបានទុកខ្លះទៀតផង។<br>- អ្នកខ្លះទៀតដែលមិនបានទទួលការបណ្តុះបណ្តាល ចង់ចូលរួមរៀនដូចគេ ដោយសំណូមពរសូមឱ្យមានវគ្គនេះ ទៀត។ |
| ៣ | អនុកិច្ចសន្យានេះមិនបានជួបប្រទះឧបសគ្គ និងបញ្ហាប្រឈមគួរឱ្យកត់សំគាល់ទេ ។ |

<u>**ចំណុចរៀនសូត្រ:**</u>

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ការរៀបចំឱ្យមានវគ្គបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពពីថ្នាក់ជាតិបានជួយបង្កើនសមត្ថភាពដល់មន្ត្រីត្រួតពិនិត្យវាយតំលៃរបស់គ.ប្រ និងមន្ត្រីមន្ទីកាន់តែមានទំនុកចិត្តការងារ និងបង្កើនប្រសិទ្ធភាពការងារ។ |
| ២ | ការរៀបចំឱ្យមានមន្ត្រីទទួលបន្ទុកកិច្ចការនារី និងកុមារថ្នាក់សង្កាត់ និងមានជនបង្គោលនៅតាមមន្ទីរជំនាញក្នុងការងារយេនឌ័របានជួយបង្កើនការទំនាក់ទំនងការងារ ផ្សព្វផ្សាយព័ត៌មាន<br>និងបទពិសោធន៍ទាក់ទងនឹងការ គាំទ្រដល់ស្ត្រី និងកុមារ ។ |
| ៣ | ការរៀបចំឱ្យមានផែនការសកម្មភាពការងារ និងរបាយការណ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆ្នាំ របស់ផ្នែក នៃ គ.ប្រ មន្ទីរវិស័យអោយបានទៀងទាត់ ទៅតាមការកំណត់របស់ថ្នាក់ជាតិ ក៏ដូចជាគ.ប្រ បានជួយតំរង់ទិសការអនុវត្តន៍គំរោងសំរេចបានទៅតាមផែនការដែលបានលើកឡើង និងជួយសំរួលដល់ប្រធានគំរោង មន្ត្រីបង្គោលផែនការ និងមន្ត្រីត្រួតពិនិត្យ វាយតំលៃរបស់មន្ទីរជំនាញ និងមន្ត្រីត្រួតពិនិត្យ និងវាយតំលៃ របស់គ.ប្រ សំរាប់ រៀបចំកាលវិភាគចុះតាមដាន ត្រួតពិនិត្យសកម្មភាព និងលទ្ធផលការងាររបស់មន្ទីរនៅតាមមូលដ្ឋាន ធ្វើអោយ ការគាំទ្រ និងការផ្តល់យោបល់ត្រលប់បានទាន់ពេលវេលា ហើយទទួលបានលទ្ធផលល្អប្រសើរពីគំរោង។ |

| | |
|---|---|
| ៤ | ការប្រជុំប្រចាំខែរបស់គ.ប្រ ការប្រជុំប្រចាំខែរបស់ផ្នែកនៃគ.ប្រ និងការប្រជុំប្រចាំខែរបស់មន្ទីរ ដើម្បីរកចំណុចខ្លាំង និងចំណុចខ្វះខាត ដែលកើតមានឡើងជាយថាហេតុ ដើម្បីរកដំណោះស្រាយអោយបានសមស្រប និងផ្តល់យោបល់ត្រលប់បានទាន់ពេលវេលា។<br>ការទទួលយកមកវិញបាននូវព័ត៌មានត្រឡប់ដើម្បីធ្វើការកែលំអ ការងារអោយទទួលបានប្រសិទ្ធភាពខ្ពស់ គឺជាមធ្យោបាយមួយយ៉ាងល្អ និងគឺជាការឆ្លើយតបទៅ នឹងតំរូវការ របស់ដៃគូក្នុងក្រុមការងារ ក្នុងការពង្រឹង សមត្ថភាពផ្ទាល់ខ្លួនផង និងពង្រឹងសមត្ថភាពដល់ដៃគូដែល ចូលរួមធ្វើ អោយភាគីពាក់ព័ន្ធ មានជំនឿជឿជាក់លើយន្តការដឹកនាំរបស់កម្មវិធី ។ |
| ៥ | សមភាពនៃការចូលរួមរបស់យេនឌ័រ គឺជាកត្តាសំខាន់ក្នុងការអនុវត្តន៍អភិបាលកិច្ចមូលដ្ឋាន សំដៅអោយមានសមធម៌ ក្នុងការទទួលផលពីការប្រើប្រាស់ធនធាន និងសេវាកម្មសង្គម ដោយឈរលើគោលការណ៍ច្បាប់ និងការអភិវឌ្ឍន៍នោះ ចាំបាច់ត្រូវជំរុញអោយមានការចូលរួមរបស់ស្ត្រី លើគ្រប់សកម្មភាព និងការធ្វើសេចក្តីសំរេចចិត្ត ។ ប៉ុន្តែទោះបីជាមានការជំរុញការលើកទឹកចិត្ត ដើម្បីបញ្ជ្រាបយេនឌ័រ ក្នុងការអភិវឌ្ឍន៍ក៏ដោយ ក៏ស្ត្រីនៅ តែពុំទាន់មានភាពក្លាហាននៅឡើយ ដោយស្ត្រីពុំសូវមានពេលវេលា គ្រប់គ្រាន់ក្នុងការចូលរួមសកម្មភាពការងារ ហើយក៏មិនទាន់ហ៊ានបញ្ចេញនូវមតិយោបល់ច្រើននៅឡើយ ។ |
| ៦ | មន្ទីរវិស័យ ខណ្ឌ សង្កាត់ បានយល់ច្បាស់ពីតួនាទីភារកិច្ចរបស់ខ្លួន ក្នុងការគាំទ្រសម្របសម្រួលដល់អនុវត្តន៍គំរោងអោយមានភាពរលូន តម្លាភាព និងការទទួលខុសត្រូវ ក្នុងការចូលរួមអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនពិសេស លើការស្តារគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងហេដ្ឋារចនាសម្ព័ន្ធអរូបវន្តអោយបានចំគោលដៅដែលជាតំរូវ ការជាក់ស្តែង របស់ប្រជាសពលរដ្ឋ ។ |

**<u>អនុសាសន៏</u> :**

| ល.រ | អនុសាសន៏ |
|---|---|
| ១ | ទិសដៅបន្ទាន់ នៃអនុកិច្ចសន្យាគួរត្រូវបានរៀបរៀង និងសរសេរឱ្យវាមានទំនាក់ទំនងទៅនឹងធាតុចូល និងលទ្ធផល ហើយបរិយាយច្បាស់លាស់អំពីលទ្ធផលបន្ទាន់ និងអត្ថប្រយោជន៍ដែលរំពឹងទុក ។ |
| ២ | ជួយផ្គត់ផ្គង់សំភារៈដល់គ្រូឧទ្ទេស និងសិក្ខាកាមឱ្យបានគ្រប់គ្រាន់ក្នុងពេលបង្រៀន និងការអនុវត្តជាក់ស្តែង ។ |

| | |
|---|---|
| ៣ | នៅពេលដែលការជ្រើសរើសក្រុមគោលដៅ ឬសិក្ខាកាមមករៀនគួរពិនិត្យបន្ថែមពីសក្តានុពល និងឱកាសដែលសិក្ខាកាមពេលបញ្ចប់វគ្គបណ្តុះបណ្តាល ឬវគ្គផ្សព្វផ្សាយអាចយកជំនាញទាំងនេះអាចយកទៅអនុវត្ត និងផ្សព្វផ្សាយបន្តជាពិសេសទីប្រជុំជនដែលមានសេវាច្រើន ។ ការពិនិត្យឡើងវិញនេះ នឹងធានាថាក្រុមគោលដៅសមស្រប នឹងត្រូវបានជ្រើសរើសឱ្យចូលរួម ដើម្បីធានានូវប្រសិទ្ធិភាពរបស់គម្រោង ។ |
| ៤ | មន្ទីរគួរបង្កើនសកម្មភាពតាមដាន ត្រួពិនិត្យ និងគាំទ្របន្តដល់សិក្ខាកាមដែលបានបញ្ចប់វគ្គ ដើម្បីរកឱ្យឃើញនូវផលប៉ះពាល់ពីគម្រោង ទោះបីជាគម្រោងត្រូវបានបញ្ចប់រួចហើយក៏ដោយ គឺដើម្បីធានានិរន្តភាពសកម្មភាព គម្រោង និងផលប្រយោជន៍ទៅដល់សហគមន៍ ។ |
| ៥ | បង្កើនការគាំទ្រ និងការលើកទឹកចិត្តសំរាប់ផ្តល់សេវានៅតាមមូលដ្ឋានដល់មន្ត្រីទទួលបន្ទុកកិច្ចការនារី ដើម្បីបង្កើនកិច្ចសហការ និងការសង្គ្រោះដល់ជនរងគ្រោះជានារី និងកុមារបានទាន់ពេលវេលា ។ |
| ៦ | មន្ទីរគួរសិក្សាឱ្យបានស៊ីជំរៅអំពីផលប្រយោជន៍ និងតក្កភាពនៃគម្រោងដើម្បីឱ្យគុណភាព អនុកិច្ចសន្យាប្រសើរ ឡើង។ |
| ៧ | មន្ទីរដែលជាអ្នកអនុវត្តគំរោង ត្រូវរក្សាប្រព័ន្ធទិន្នន័យដែលទាក់ទងនឹងអនុកិច្ចសន្យា និងបញ្ជូនទិន្នន័យទាំងនោះមកគ.ប្រ នៃគ.អ.រ ជាប្រចាំ ដើម្បីមានព័ត៌មានគ្រប់គ្រាន់ ក្នុងការបូកសរុបតាមដាន វិភាគ និងដាក់ជូន គ.ប្រ និងផ្ញើជូនថ្នាក់ជាតិ ។ |

## ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

**ឯកសារដែលត្រូវភ្ជាប់ទី១ ៖ បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបានពិនិត្យ**

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) | មាន (៣) |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) លេខ 12/GEN/0901-00 | √ |
| ២ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា លេខ 12/GEN/0901-00 | √ |
| ៣ | របាយការណ៍ប្រចាំឆ្នាំ២០០៩ របស់គណៈកម្មាធិការអភិវឌ្ឍន៍រាជធានីភ្នំពេញ | √ |
| ៤ | របាយការណ៍បញ្ចប់កិច្ចសន្យារវាងគ.ជ.អ.ប និងគ.អ.រ ឆ្នាំ២០០៩ | √ |

## ឯកសារដែលត្រូវភ្ជាប់ទី២ : ឯកសារអនុកិច្ចសន្យា លេខ 12/GEN/0901-00 រាជធានីភ្នំពេញ

## បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាសន៍/ជួបពិភាក្សា

| ល.រ | ថ្ងៃខែ | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា | ទីកន្លែង សំភាសន៍ | ឧបករណ៍ប្រើសម្រាប់ប្រមូលទិន្នន័យដែលបានប្រើ |
|---|---|---|---|---|
| ១ | ១៨ តុលា | លោក ឱ ផលា ទីប្រឹក្សាត្រួតពិនិត្យ និងវាយតំលៃ របស់គ.ប្រ | សាលារាជធានី | សម្ភាសន៍ស៊ីជម្រៅ |
| ២ | ១៩ តុលា | ក្រុមអ្នកទទួលផល | មន្ទីរកិច្ចការនារី | សម្ភាសន៍ជាក្រុម |
| ៣ | ២០ តុលា | លោកស្រី ទេស ច័ន្ទសារឿន ផ្នែកគ្រប់គ្រងកិច្ចសន្យា | មន្ទីរកិច្ចការនារី | សម្ភាសន៍ស៊ីជម្រៅ |
| ៤ | ២០ តុលា | អ្នកស្រី សោម ម៉ានី មន្ត្រីបង្គោលត្រួតពិនិត្យ និងវាយតម្លៃ និង មន្ត្រីទទួលខុសត្រូវ | មន្ទីរកិច្ចការនារី | សម្ភាសន៍ស៊ីជម្រៅ |
| ៥ | ២០ តុលា | លោកស្រី ឈៀង ស៊ុន ឡាយ គ្រូបង្គោលយេនឌ័រមន្ទីរកិច្ចការនារី | មន្ទីរកិច្ចការនារី | សំភាសន៍ស៊ីជំរៅ |
| ៦ | ២១ តុលា | លោករស់ វណ្ណា ចៅសង្កាត់ត្រពាំងក្រសាំង | សង្កាត់ត្រពាំងក្រសាំង ខណ្ឌដង្កោ | សម្ភាសន៍ស៊ីជម្រៅ |
| ៧ | ២២ តុលា | លោកសាកឹម យឿន មេភូមិសាមគ្គីទី១ | សង្កាត់ត្រពាំងក្រសាំង ខណ្ឌដង្កោ | សម្ភាសន៍ស៊ីជម្រៅ |
| ៨ | ២៥ តុលា | កញ្ញា លុយ តុលា អ្នកទទួលផលផ្ទាល់ | ភូមិ លូ រាជធានីភ្នំពេញ | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៩ | ២៥ តុលា | កញ្ញា ហ៊ូ ស្រស់ អ្នកមិនទទួលផល | ភូមិ លូ រាជធានី ភ្នំពេញ | សម្ភាសន៍ស៊ីជម្រៅ/ករណីសិក្សា |

| | | | | |
|---|---|---|---|---|
| ១០ | ២៥ តុលា | លោកស្រីឈៀង ស៊ុនឡាយ មន្ត្រីបង្គោលយេនឌ័រ | មន្ទីរកិច្ចការនារី | សម្ភាសន៍ស៊ីជម្រៅ |
| ១១ | ២៦ តុលា | - បង្ហាញលទ្ធផលដែលរកឃើញដល់អ្នកពាក់ព័ន្ធ ដើម្បីទទួលបានយោបល់<br>-បញ្ចប់របាយការណ៍ ដែលមានឯកសារភ្ជាប់ទាំងអស់ និងបង្ហាញដល់គ.ប្រ នៃ គ.អ.រ និង គ.ជ.អ.ប | សាលារាជធានីភ្នំពេញ | |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | 13/EDU/0901-00(GOV) |
| ចំណងជើង : | លើកកំពស់អក្ខរកម្មនៅជនបទ |
| ភ្នាក់ងារអនុវត្តន៏ : | មន្ទីរអប់រំយុវជន និងកីឡាខេត្តព្រះវិហារ |
| រយៈពេល (ចាប់ផ្តើម និងបញ្ចប់) | 01/01/2009 -31/12/2009 |
| រាជធានី ខេត្ត | ខេត្តព្រះវិហារ |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរអប់រំយុវជន និងកីឡាខេត្តព្រះវិហារ |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ/ គ.អ.ជ.ខ | ៧,000ដុល្លា |
| ការរួមចំណែករបស់រាជធានី ខេត្ត | 0.00 ដុល្លា |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៏ | 0.00 ដុល្លា |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | ៧,000ដុល្លា |

## ក្រុមវាយតម្លៃ

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ |
|---|---|
| លោក វិញ សត្ថា | អនុប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា |
| លោក និល ហេងគី | មន្ត្រីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ |
| លោកនូ តារាមុន្នី | មន្ត្រីគ្រប់គ្រងកិច្ចសន្យា |
| លោក ព្រាប យឹមតែម | មន្ត្រីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ មន្ទីរអប់រំ |
| លោក មាស សំអុន | ទីប្រឹក្សាផ្នែកតាមដានត្រួតពិនិត្យ និងវាយតម្លៃ |

## របាយការណ៏ស្តីពីវាយតម្លៃ រៀបចំដោយ :

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ និងតួនាទីក្នុងការវាយតម្លៃ |
|---|---|
| លោក វិញ សត្ថា | អនុប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យាគ.ប្រ |
| លោក និល ហេងគី | មន្ត្រីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគ.ប្រ |

ខេត្តព្រះវិហារ

កាលបរិច្ឆេទ :២/១១/២០១០

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៣ |
| | របាយការណ៍សង្ខេប | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៧** |
| ១.១ | សេចក្ដីផ្ដើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៧ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៧ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៧ |
| ១.៤ | សំណួរវាយតម្លៃ | ៨ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ៨ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ៨ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១១** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១) | ១១ |
| | - លទ្ធផលទី១ | ១១ |
| | - លទ្ធផលទី២ | ១៣ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម | ១៤ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤) | ១៨ |
| **២.៤** | **សេចក្ដីសន្និដ្ឋាន (សំណួរវាយតម្លៃទី៥)** | **២១** |

<u>**ឯកសារដែលត្រូវភ្ជាប់ជាមួយរបាយការណ៍**</u> **២៤**

ឯកសារទី១: បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបាន ពិនិត្យ ២៤

ឯកសារទី២: បញ្ជីឈ្មោះអ្នកផ្ដល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាសន៍/ជួបពិភាក្សា ២៥

**ករណីសិក្សា** **១៦**

ករណីសិក្សាទី១: អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងដំណើរការបើកថ្នាក់អក្ខរកម្ម ១៦

ករណីសិក្សាទី២: អ្នកមិនបានទទួលផល ១៧

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

***គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ :***

ក្រុមការងារវាយតម្លៃចំនួន០៤រូបដែលត្រូវបានតែងតាំងដោយសមាជិកអចិន្ត្រៃយ៍គ.ប្រនៃគ.អ.ជ.ខខេត្តព្រះវិហារ បានធ្វើការវាយតម្លៃអនុកិច្ចសន្យាដែលមានចំណងជើងថា "លើកកំពស់អក្ខរកម្មនៅជនបទ" លេខ:13/EDU/0901-00(GOV) ដែលជាអនុកិច្ចសន្យារវាង គ.ប្រនៃគ.ជ.អ.ខខេត្តព្រះវិហារ ជាមួយមន្ទីរអប់រំយុវជន និងកីឡាខេត្ត។ នេះគឺជាផ្នែកមួយនៃគម្រោងពង្រឹងសមត្ថភាព គ្រូបង្គោលថ្នាក់ក្រោមជាតិរបស់ផ្នែកតាមដានត្រួតពិនិត្យ និង វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋានគ.ជ.អ.ប ដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ដែលហៅកាត់ថា" គ.ជ.អ.ប" ។

***គោលបំណងជាក់លាក់នៃការវាយតម្លៃនេះគឺ:***

*១-ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធិផលនៃអនុកិច្ចសន្យា និងចំណុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណង និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តអនុកិច្ចសន្យា រួមទាំងកត់ត្រានូវចំណុចរៀនសូត្រ និងផ្នែកដែលត្រូវ ធ្វើឱ្យប្រសើរឡើងនៅពេលអនាគត។*

*២-ពង្រឹងរបៀបធ្វើការវាយតម្លៃគម្រោងរបស់ គ.ប្រនៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្តគម្រោង។ ការវាយ តម្លៃអនុវត្តទៅតាមការណែនាំ និងឧបករណ៍ស្តីពីការវាយតម្លៃអនុកិច្ចសន្យា របស់គណៈកម្មាធិការប្រតិបត្តិនៃ គ.អ.ជ.ខ ដែលរៀបចំដោយផ្នែកតាមដាន ត្រួតពិនិត្យនិងវាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប។ ក្រុមការងារវាយតម្លៃបានប្រើការពិភាក្សាជាក្រុម ការសំភាសន៍ស៊ីជម្រៅ ការចុះទៅមូលដ្ឋានផ្ទាល់ គន្លឹះក្នុងការសង្កេតផ្ទាល់និងរំលឹកឯកសារអនុកិច្ចសន្យារបាយការណ៍រីកចំរើន និងឯកសារផ្សេងៗទៀត។ ការវាយតម្លៃ ត្រូវបានឆ្លើយតបទៅនឹងសំណួរវាយតម្លៃ(សូមមើលនៅចំណុច១.៣)។ ដោយសារធនធានមានកំណត់យើងបានធ្វើការ វាយតម្លៃស៊ីជម្រៅលើលទ្ធផលតែពីរប៉ុណ្ណោះចំណែកលទ្ធផលផ្សេង ទៀតត្រូវផ្អែកទៅលើ ពត៌មានដែលមានស្រាប់។ ដូចនេះ ការវាយតម្លៃមិនមែនជាការវាយតម្លៃស៊ីជម្រៅ ទៅលើអនុកិច្ចសន្យាទេ ហើយការសន្និដ្ឋានត្រូវធ្វើឡើងតាម អ្វីដែលបានរកឃើញ។*

***ឆ្លើយទៅនឹងសំណួរទាំង៥ នៃការវាយតម្លៃ :***

១-សកម្មភាពទាំងអស់ត្រូវបានអនុវត្តនិងសម្រេចបានលទ្ធផលដូចខាងក្រោម:

| ***ល.រ*** | ***សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា*** | ***អ្វីដែលសម្រេចបានជាក់ស្តែង*** |
|---|---|---|
| **<u>លទ្ធផលទី១</u>** | | |
| ១.១ | រៀបចំដំណើរការបើកថ្នាក់អក្ខរកម្ម(០៨ប្រជុំ) | រៀបចំដំណើរការបើកថ្នាក់អក្ខរកម្ម (០៨ប្រជុំ) |
| ១.២ | គាំទ្រថ្នាក់អក្ខរកម្មចំនួន០៨ថ្នាក់ | គាំទ្រថ្នាក់អក្ខរកម្មចំនួន០៨ថ្នាក់រយ:ពេល០៨ខែ។ |

| | | |
|---|---|---|
| | រយៈពេល០៨ខែ មានសិស្ស២០០នាក់ (ស្ត្រី១០០នាក់) | ដោយឡែក០១ថ្នាក់នៅឃុំឈានមុខគាំទ្របានតែ០២ខែ ។ ចំនួន០៧ថ្នាក់បាន ដំណើរការបញ្ចប់មានសិស្សសរុបចំនួន ១៦៣នាក់,ស្ត្រី១២៨នាក់ |
| **លទ្ធផលទី២** | | |
| ១.១ | បណ្តុះបណ្តាលគ្រូអក្ខរកម្មចំនួន ០៨នាក់ | បណ្តុះបណ្តាលគ្រូអក្ខរកម្មបានតែចំនួន ០៧នាក់ ។ |
| ២-ការរៀបចំដំណើរការបើកថ្នាក់អក្ខរកម្ម ជាចំណុចមួយមានប្រសិទ្ធភាពក្នុងការចាប់ផ្តើមដំបូង ក្នុងការពិភាក្សាជាមួយសហគមន៍ អាជ្ញាធរ និងមាតាបិតាសិស្ស ក្នុងការកៀគរប្រមូលកុមារឱ្យចូលរៀន ។<br>៣-ជារួម អនុកិច្ចសន្យាសម្រេចបាននូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យានៅកំរិតខ្ពស់ ។<br>៤-អនុកិច្ចសន្យា ពិតជាបានចូលរួមចំណែកក្នុងការសម្រេចបាននូវគោលបំណង ដោយសារសិស្សថ្នាក់អករកម្ម ទាំងនោះ បានអនុវត្តនូវចំណេះដឹងដែលពួកគាត់ទទួលបានពីថ្នាក់អក្ខរកម្មយកទៅប្រកបរបរ និងរកប្រាក់ចំណូលពីប្រភពផ្សេងៗ ដើម្បីកែលំអជីវភាពរស់នៅប្រចាំថ្ងៃរបស់គ្រួសារកាន់តែប្រសើរឡើង ។ | | |

**សេចក្តីសន្និដ្ឋានៈ**

១-មានសមត្ថភាពសមល្មមសំរាប់អនុវត្តអនុកិច្ចសន្យា និងមានធនធានគ្រប់គ្រាន់ ដើម្បីអនុវត្តអនុកិច្ចសន្យាដែលធ្វើឱ្យសកម្មភាព និងលទ្ធផលដែលបានគ្រោងទុកត្រូវបានបញ្ចប់ដោយសមស្របទៅតាមផែនការ ។

២-មានអត្ថប្រយោជន៏ដល់សហគមន៏រួមទាំងអ្នកទទួលផលផ្ទាល់ អ្នកទទួលផលប្រយោល និងអ្នកមិនបានទទួលផលដោយ មានការអបអរសាទរ និងពេញចិត្តជាខ្លាំង ដែលគម្រោងបើកថ្នាក់អក្ខរកម្មនេះបានអនុវត្តនៅក្នុងភូមិ-ឃុំ របស់ពួកគាត់ ។

៣-ការជ្រើសរើសប្រជាពលរដ្ឋជាអនក្ខរជន ឱ្យមកចូលរៀនអក្ខរកម្មជាពិសេសអនក្ខរជនជាស្ត្រី ពិតជាតម្រូវការដ៏ជាក់លាក់មួយ ដែលទទួលបានអត្ថប្រយោជន៏ពីអនុកិច្ចសន្យានេះ ។ ការផ្តល់ថ្នាក់អក្ខរកម្មចំនួន៨ថ្នាក់នេះបានចូលរួម ចំណែកយ៉ាងខ្លាំងក្នុងការលើកកំពស់សមភាពយេនឌ័រ ការផ្តល់អំណាច នឹងចំណេះដឹងដល់ស្ត្រី ដើម្បីបានចូលរួម ចំណែកក្នុងការងារសង្គមនៅមូលដ្ឋានយ៉ាងពិតប្រាកដ ។ ម្យ៉ាងទៀត ការអនុវត្តន៏អនុកិច្ចសន្យានេះ មិនមានចំណុចណា ដែលអាចសន្និដ្ឋានបានថា មានផលប៉ះពាល់ជាអវិជ្ជមានដល់ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានឡើយ ។

៤-អនុកិច្ចសន្យានេះ មានការប្រឈមមួយចំនួន ដោយសារមន្ត្រីអប់រំខេត្ត មន្ត្រីការិយាល័យអប់រំក្រៅប្រព័ន្ធស្រុក និងអាជ្ញាធរមូលដ្ឋាន មិនសូវបានចុះធ្វើការតាមដានត្រួតពិនិត្យឱ្យបានដិតដល់ ក្នុងពេលថ្នាក់អក្ខរកម្មកំពុងដំណើរការដែលជាហេតុធ្វើឱ្យបាត់បង់ការចូលរួម និងការជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋដែលជាអនក្ខរជន ។

៥-មន្ត្រីថ្នាក់ខេត្ត-ស្រុក អាជ្ញាធរភូមិ-ឃុំ មន្ទីរ និងការិយាល័យអប់រំយុវជននិងកីឡា និងគណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ខេត្ត-ស្រុក និងឃុំ ព្រមទាំងអ្នកពាក់ព័ន្ធនានា គួរតែបង្កើនការយកចិត្តទុកដាក់

បន្ថែមទៀត ក្នុងការតាមដាន ការលើកទឹកចិត្ត និងការដាស់តឿនដល់ក្រុមគោលដៅ សំដៅជួយជំរុញ និងពង្រឹង ដំណើរការនៃការ បើកថ្នាក់អក្ខរកម្មនៅមូលដ្ឋាន ហើយគួរតែចុះធ្វើការតាមដាន និងត្រួតពិនិត្យ នូវដំណើរការនេះ ឱ្យបានជាប់ជាប្រចាំ ។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប បានផ្តល់ថវិកាតាមរយៈ គ.ប្រ នៃ គ.អ.ជ.ខ ទៅមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និងគម្រោង ដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈជាប្រព័ន្ធមិនបានអនុវត្តទេ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដោយមកពីហេតុផលជាច្រើន។ នៅក្នុងឆ្នាំ២០១០ ដោយមានការគាំទ្រផ្នែកថវិកា និងបច្ចេកទេស ពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យា គ.ប្រ នៃគ.អ.ជ.ខ ក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យា ដែលបានរៀបចំរួមគ្នាជាមួយភ្នាក់ងារអនុវត្តន៍ ដែលមានលេខៈ***13/EDU/0901-00(GOV)***។ ដំណើរការលទ្ធផល ដែលបានរកឃើញ និងការសន្និដ្ឋាននៃការវាយតម្លៃ ត្រូវបានកត់ត្រា និងបង្ហាញតាមរយៈរបាយការណ៍ស្តីពីការវាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

គោលបំណងបន្ទាន់របស់អនុកិច្ចសន្យាឆ្នាំ២០០៩នេះសំដៅចូលរួមសំរេចឱ្យបាននូវគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយអ្នកមិនចេះអក្សរ និងភាពក្រីក្រនៅជនបទ និងអនុវត្តនូវគោលនយោបាយកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការនៅមូលដ្ឋាន តាមរយៈការបើកថ្នាក់អក្ខរកម្ម និងជំរុញឱ្យអត្រាកុមារចូលសាលារៀន កើនឡើងកាន់តែខ្ពស់ថែមទៀត ដែលរំពឹងថាលទ្ធផលខាងក្រោមនេះ នឹងជួយបង្កើនការផ្តល់សេវាអប់រំក្រៅប្រព័ន្ធ ដើម្បីសំរេចគោលដៅជាយុទ្ធសាស្រ្តរបស់ក្រសួងអប់រំតាមរយៈការកាត់បន្ថយជាអតិបរិមានូវអនក្ខរជននៅតាមភូមិ-ឃុំ នៅក្នុងខេត្តទាំងមូលដែលរួមមាន០៣ចំណុចធំៗ ដូចខាងក្រោមៈ

១- យុទ្ធនាការផ្សព្វផ្សាយ អំពីសារៈសំខាន់នៃកម្មវិធីអក្ខរកម្មក្នុងតំបន់គោលដៅទាំង៨

២- បណ្តុះបណ្តាលគ្រូអក្ខរកម្មចំនួន៨នាក់

៣- គាំទ្រថ្នាក់អក្ខរកម្មចំនួន៨ថ្នាក់ រយៈពេល៨ខែ ដែលមានសិស្ស២០០នាក់ (ស្រ្តី ១០០នាក់)

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូល ដោយផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ នៃ គ.អ.ជ.ខនៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេសនិងតម្លាភាព។

ដូច្នេះទំហំនៃការវាយតម្លៃមានដែនកំណត់តាម ទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខ័ណ្ឌការងារនៃការវាយតម្លៃ។ គោលបំណង នៃការវាយតម្លៃគឺៈ ក) ទាញយកកត់ត្រា និងវិភាគតាមលក្ខណៈជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និងចំនុច ខ្សោយធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តអនុកិច្ចសន្យា រួមទាំងកត់ត្រា នូវមេរៀនបទពិសោធន៍ និងផ្នែកដែល

ត្រូវធ្វើឱ្យប្រសើរឡើងនាពេលអនាគត និង ខ) ដើម្បីពង្រឹងរបៀបធ្វើការ វាយតម្លៃគម្រោងរបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត ។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

**វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើៈ**

១) ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំណត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់អនុកិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារពាក់ព័ន្ធដែលមាននៅក្នុង ផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យា នៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៍ ។

២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗ រួមមានៈ អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផលផ្ទាល់ និងមិនផ្ទាល់ចំនួន២ ឬ៣នាក់ និងអ្នកពាក់ព័ន្ធចំនួន២នាក់ ។ សូមពិគ្រោះជាមួយនឹងមន្ត្រីបង្គោលទៅលើបញ្ហាយេនឌ័រ និងគ្រប់គ្រងធនធានធម្មជាតិ សម្រាប់បញ្ហាពាក់ពន្ធ័វិស័យខាងលើ ។

៣) ប្រើប្រាស់វិធីសាស្ត្រចុះពិនិត្យ តំបន់អនុវត្តន៏គម្រោង និងសង្កេតមើលសកម្មភាព ពិភាក្សាក្រុម និងករណីសិក្សា។

៤) ចុះពិនិត្យតំបន់អនុវត្តន៏គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់ ។

៥) <u>វិភាគទិន្នន័យ និងបកស្រាយៈ</u> ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់ ។

៦) <u>ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៍</u> ដោយភ្នាក់ងារអនុវត្តន៏ និងអ្នកពាក់ព័ន្ធតាមរយៈ ព័ត៌មានត្រឡប់ដែលទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើង(ដាក់កាលបរិច្ឆេទនៃការធ្វើបទបង្ហាញនៅទីនេះ) ។ ការវាយតម្លៃត្រូវធ្វើតាម "គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា" និងវិធីសាស្ត្រដែលបានណែនាំ។ ដូច្នេះដំណើរការត្រូវបានធ្វើឡើងដោយមានទម្រង់ការណែនាំ និងតម្លាភាព រួមទាំងការចូលរួមពីអ្នកពាក់ព័ន្ធ ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ។ ការវាយតម្លៃនេះ ត្រូវបានធ្វើឡើង

ដោយ គ.ប្រ និងអ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយការប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត។

២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិតៈ វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោង នៅពេលដែលអ្នកវាយតម្លៃមានជំនាញ និងបទពិសោធន៍តិចតួច។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណងសំខាន់គឺដើម្បី"រៀនធ្វើដោយការអនុវត្តផ្ទាល់"។ អ្នកវាយតម្លៃ បានទទួលការគាំទ្រដោយមានគោលការណ៍ការណែនាំឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។

៣) បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យាៈ ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និងជោគជ័យទេ ។ មួយទៀត ទំនាក់ទំនងសង្ខេបតាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះ មិនសូវស៊ីសង្វាក់គ្នាឡើយ។

៤) ដោយយើងមិនមានសូចនាករ យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍" ដែលជាកម្រិតអត្ថប្រយោជន៍ទៅលើគោលនយោបាយវិម្ជការ និងវិសហមជ្ឈការ ការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។

៥)ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិតទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ។ យើងអាចវាយតម្លៃតែទៅលើសិស្សថ្នាក់អក្ខរកម្មមួយចំនួន ដែលបានទទួលការបណ្តុះបណ្តាលចំណេះដឹងតាមរយៈការបើកថ្នាក់អក្ខរកម្ម និងការបង្ហាញ ដែលជាលទ្ធផលទី១ នៃសកម្មភាពទី១ និងសកម្មភាពទី២ នៃអនុកិច្ចសន្យាលំអិតតាមរយៈការសម្ភាសន៍ស៊ីជម្រៅ ក្រុមពិភាក្សា និងការចុះពិនិត្យតំបន់អនុវត្តគម្រោង។

៦) សូមរក្សាទុកចំណុចនេះ ប្រសិនបើវាមានសុពលភាពៈ ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាមិនអាចធ្វើទៅបានទេ ព្រោះចំណុច គ នៃផ្នែកទី៣ក្នុងឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ ឬមិនពេញលេញ។ ការងារនេះ នឹងកាន់តែមានសុពលភាព និងពោរពេញទៅដោយព័ត៌មាន បើសិនជាចំណុចដែលបានរៀបរាប់ខាងលើនេះ ត្រូវបានដោះស្រាយ។

**<u>ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធន៍ៈ</u>**

១) ការវាយតម្លៃនេះ ត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ 13/EDU/0901-00(GOV) លើកកំពស់អក្ខរកម្ម និងដែនកំណត់ ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌនៃការវាយតម្លៃនេះ។

២) ការវាយតម្លៃនេះ លម្អិតតែទៅលើ **ថ្នាក់អប់រំក្រៅប្រព័ន្ធ** ដែលជាលទ្ធផល **រៀបចំដំណើរការថ្នាក់អក្ខរកម្ម និងការគាំទ្រថ្នាក់អក្ខរកម្មចំនួន០៨ថ្នាក់រយៈពេល០៨ខែ** ដែលជាសកម្មភាពនៃអនុកិច្ចសន្យា។

៣) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃទៅលើភ្នាក់ងារអនុវត្តន៍ ភ្នាក់ងារដែលពាក់ព័ន្ធគម្រោង ហើយនឹងការវាយតម្លៃទៅលើ គ.ប្រ នៃគ.អ.ជ.ខ និង គ.ជ.អ.ប ទេ។ ហេតុដូច្នេះ របាយការណ៍នៃការវាយតម្លៃលទ្ធផល

ដែលបានរកឃើញ និងអនុសាសន៍ដែលបានលើកឡើងត្រូវពិនិត្យដោយយោលទៅលើបរិបទខាងលើនិងអនុវត្តតាមលំដាប់លំដោយ ។

# ១. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល

**លទ្ធផលទី១ :** *ថ្នាក់អប់រំក្រៅប្រព័ន្ធ*

**ផ្នែក-ក :** *ការសម្រេចបានជាក់ស្តែងធៀបទៅនិងផែនការ*

| *ល.រ* | *សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា* | *អ្វីដែលសម្រេចបានជាក់ស្តែង* |
|---|---|---|
| ១.១ | រៀបចំដំណើរការបើកថ្នាក់អក្ខរកម្ម( ០៨ប្រជុំ)<br>▪ ស្រុកនែប០១ថ្នាក់, ស្រុកជ័យសែន០១ថ្នាក់<br>▪ ស្រុករវៀង០២ថ្នាក់, ស្រុកត្បែងមានជ័យ០១ថ្នាក់<br>▪ ស្រុកគូលែន០១ថ្នាក់ ,ស្រុកសង្គមថ្មី០១ថ្នាក់, ស្រុកជាំក្សាន្ត០១ថ្នាក់ ។ | រៀបចំដំណើរការបើកថ្នាក់អក្ខរកម្ម( ០៨ប្រជុំ)<br>▪ ស្រុកនែប០១ថ្នាក់, ស្រុកជ័យសែន ០១ថ្នាក់<br>▪ ស្រុករវៀង០២ថ្នាក់, ស្រុកត្បែងមានជ័យ០១ថ្នាក់<br>▪ ស្រុកគូលែន០១ថ្នាក់, ស្រុកសង្គមថ្មី០១ថ្នាក់, ស្រុកជាំក្សាន្ត០១ថ្នាក់ ។ |
| ១.២ | គាំទ្រថ្នាក់អក្ខរកម្មចំនួន០៨ថ្នាក់ រយៈពេល០៨ខែ( ០៨ថ្នាក់)<br>▪ ឧបត្ថម្ភប្រាក់ខែសម្រាប់គ្រូអក្ខរកម្ម០៨នាក់/០៨ខែ | គាំទ្រថ្នាក់អក្ខរកម្មចំនួន០៨ថ្នាក់ រយៈពេល០៨ខែ( ០៨ថ្នាក់)<br>▪ ឧបត្ថម្ភប្រាក់ខែសម្រាប់គ្រូអក្ខរកម្ម០៨នាក់/០៨ខែ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផលនិងសកម្មភាពនានារបស់អនុកិច្ចសន្យាដែលបានគ្រោងទុក ។ អ្នកចូលរួមទាំងអស់នៅក្នុងក្រុមពិភាក្សាដែលជាសិស្សថ្នាក់អក្ខរកម្មដែលទទួលបានការបណ្តុះបណ្តាល និងការបង្រៀនពីថ្នាក់អក្ខរកម្មនោះ បានឱ្យដឹងថាពួកគេទាំងអស់គ្នាទទួលបាននូវចំណេះដឹង និងជំនាញថ្មីៗ ពីការចូលរួមរៀន នៅក្នុងថ្នាក់អក្ខរកម្ម ដូចជា: ធ្វើឱ្យពួកគាត់បានស្គាល់ព្យញ្ជនៈ ស្គាល់ស្រះ ចេះប្រកប ចេះសរសេរ ចេះអាន ចេះបូកលេខ ចេះចែក គុណ និងដកលេខ។ ពួកគាត់បានយល់ពីការអប់រំមនុស្សចាស់ មនុស្សធំ និងកុមារ ការរស់នៅស្អាត ការហូបចុកស្អាត ចេះគោរពគ្នាទៅវិញទៅមក ចេះស្រលាញ់ និងចេះអធ្យាស្រ័យគ្នា។ ជាពិសេសពួកគាត់នៅចងចាំបាននូវទ្រឹស្តី និងអត្ថន័យខ្លឹមសារ នៅក្នុងមេរៀននីមួយៗ ទោះបីជាវាបានបញ្ចប់ក្នុងរយៈពេលយូរទៅហើយក៏ដោយ( កាលពីឆ្នាំ២០០៩) ។ សិស្សថ្នាក់អក្ខរកម្មភាគច្រើន ពេញចិត្តនឹងវិធីសាស្ត្រ

និងអាក្បកិរិយា របស់អ្នកគ្រូបណ្តុះបណ្តាល។ វិធីសាស្ត្រផ្សេងៗជាច្រើនត្រូវបានយកមកប្រើប្រាស់នៅក្នុងថ្នាក់អក្ខរកម្ម រួមមានៈ ការសួរ សំណួរបំផុសគំនិត ការសួរតាមរយៈរូបភាព និងការពិភាក្សា ជាក្រុម...។ល។ លោកគ្រូ-អ្នកគ្រូ ដែលជាអ្នកបណ្តុះបណ្តាល អាចបន្សាំខ្លួនបានយ៉ាងល្អប្រសើរនៅក្នុងសហគមន៍ ដែលជាហេតុធ្វើឱ្យសិស្សមានការចូលរួមច្រើន។ ជាងនេះទៅទៀត មានសិស្សជាច្រើន បានសំណូមពរសុំឱ្យមានការបើកថ្នាក់អក្ខរកម្មបន្តទៅទៀតនៅក្នុងភូមិ-ឃុំរបស់ពួកគាត់ និងសុំរក្សាទុកលោកគ្រូ-អ្នកគ្រូដែលធ្លាប់បានបណ្តុះបណ្តាលកាលពី ឆ្នាំ២០០៩ ឱ្យនៅដដែល។ ទាំងនេះព្រោះថា លោកគ្រូ-អ្នកគ្រូទាំងនោះ មានវិធីសាស្ត្រល្អៗ ព្រមទាំងតរិយាបទ និងទេពកោសល្យយ៉ាងប្រពៃ ដែលអាចធ្វើឱ្យពួកគាត់ឆាប់ចាប់បាន និងងាយយល់នូវខ្លឹមសារមេរៀន។ ម្យ៉ាងវិញទៀត ពួកគាត់បានសំណូមពរសុំឱ្យខាងអប់រំ ផ្តល់ជាធ័ត្របួអាវភ្លៀងព្រមទាំងពិលបំភ្លឺផ្លូវ ដើម្បីឱ្យពួកគាត់មានលទ្ធភាពបានមកចូលរួម រៀនសូត្រឱ្យបានទៀងទាត់ដោយហេតុការបើកថ្នាក់បង្រៀនបានធ្វើឡើងនៅពេលយប់ និងក្នុងរដូវភ្លៀងធ្លាក់ និងផ្លូវទៅកាន់ថ្នាក់រៀន មានការលំបាកដោយកន្លែងផងដែរ។ សរុបសេចក្តីមក ការបើកថ្នាក់អក្ខរកម្មនេះ មានភាពទាក់ទងទៅនឹងតំរូវការជាក់ស្តែងយ៉ាងពិតប្រាកដរបស់សិស្ស និងសហគមន៍របស់ពួកគាត់។ សំខាន់ជាងនេះទៅទៀតអ្នកចូលរួម នៅក្នុងការពិភាក្សាក្រុម បានគូសបញ្ជាក់ថា ចំណេះដឹង និងជំនាញនានា ដែលពួកគាត់ទទួលបាន និងរួមចំណែកដល់ការកែលម្អជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់កាន់តែល្អ ប្រសើរ។ យើងសង្កេតឃើញថា អ្នកដែលធ្លាប់បានចូលរៀនថ្នាក់អក្ខរកម្មមួយចំនួន បានចាប់ផ្តើមសំអាតបរិវេនផ្ទះ ធ្វើការចិញ្ចឹមមាន់ ជ្រូក និងដាំដំណាំបន្លែបង្ការផ្សេងៗរបស់គាត់ ដើម្បីធ្វើឱ្យចំណូលគ្រួសាររបស់គាត់បានកើនឡើង និងកាត់បន្ថយការចំណាយនៅក្នុងគ្រួសារ ក៏ដូចជាធ្វើឱ្យសុខភាពគ្រួសាររបស់ពួកគាត់បានប្រសើរឡើង។ ហើយចំណែកឯអាត្រា នៃអ្នកមិនចេះអក្សរក៏ត្រូវបានថយចុះក្នុងភូមិរបស់គាត់ផងដែរ។

## *លទ្ធផលទី២: ការបណ្តុះបណ្តាលដល់គ្រូក្រៅប្រព័ន្ធ*

**ផ្នែក-ក :** *ការសម្រេចបានជាក់ស្តែងធៀបទៅនិងផែនការ*

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | បណ្តុះបណ្តាលគ្រូអក្ខរកម្មចំនួន០៨នាក់ | បណ្តុះបណ្តាលគ្រូអក្ខរកម្មចំនួន០៧នាក់ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

ក្នុងឱកាសប្រារព្ធពិធីបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសបង្រៀន និងចិត្តគរុកោសល្យដល់គ្រូអក្ខរកម្មនៅថ្នាក់ខេត្ត មានការចូលរួមជាគណៈអធិបតីភាពដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមស៊ុយ សេរិទ្ធ អភិបាលរងខេត្ត។ ឆ្លៀតក្នុងពេលដ៏មានតម្លៃនោះ ឯកឧត្តមបានមានមតិនិងអនុសាសន៍ជាច្រើនដែលជាមូលដ្ឋានគ្រឹះ សម្រាប់លោកគ្រូ-អ្នកគ្រូយកទៅពិចារណា និងអនុវត្តន៍តាម ក្នុងការផ្ទេរចំណេះដឹងទៅឱ្យសិស្សនៅថ្នាក់មូលដ្ឋាន។ ការបើកវគ្គបណ្តុះបណ្តាលនេះមានរយៈពេល០៨ថ្ងៃ ចាប់ផ្តើមពីថ្ងៃទី១២-១៩ ខែមីនាឆ្នាំ២០០៩ នៅសាលប្រជុំរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដោយមានសិក្ខាកាមមកពីគ្រប់ស្រុកសរុបចំនួន០៧នាក់ ដែលក្នុងនោះមានស្ត្រីចំនួន០៤នាក់។ អវត្តមានអ្នកគ្រូ០១នាក់ ដែលជាគ្រូប្រចាំ នៅក្នុងស្រុកសង្គមថ្មី។ មូលហេតុដែលមិនបានមកចូលរួមនេះគឺគាត់រស់នៅទីកន្លែងឆ្ងាយហើយស្ថានភាពផ្លូវការមានការលំបាកខ្លាំង ក៏ប៉ុន្តែគាត់ធ្លាប់ទទួលបានការបណ្តុះបណ្តាលបច្ចេកទេសបង្រៀនដូចគ្នានេះ ម្តងរួចមកហើយកាលពីឆ្នាំទៅ( ឆ្នាំ២០០៨) ។

## ២.២. ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម

### ផ្នែក-ក: ការសម្រេចបាននូវស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា | ស្ថានភាពជាក់ស្តែង |
|---|---|
| ▪ ថ្នាក់អក្ខរកម្មចំនួន០៨ថ្នាក់ ត្រូវបានដំណើរការទៅតាមផែនការដែលបានគ្រោងទុក | ▪ ថ្នាក់អក្ខរកម្មចំនួន០៨ថ្នាក់ ត្រូវបានដំណើរការទៅតាមភូមិគោលដៅទាំង០៨ |
| ▪ ប្រជាពលរដ្ឋជាអនក្ខរជនចំនួន២០០នាក់(ស្ត្រី១០០នាក់) នឹងបានឆ្លងផុត ពីគ្រោះមិនចេះអក្សរ។ | ▪ ប្រជាពលរដ្ឋជាអនក្ខរជនចំនួន១៥៩នាក់ ក្នុងនោះស្ត្រីចំនួន១២៧នាក់បានចូលរួមប្រឡងបញ្ចប់វគ្គ។ លទ្ធផលជាក់ស្តែងមានសិស្ស១៣១នាក់ក្នុងនោះ ស្ត្រី១០៥នាក់បានប្រលងជាប់ប័ណ្ណអនក្ខរកម្ម។<br>▪ អ្នកចូលរួមភាគច្រើន នៅក្នុងការពិភាក្សាក្រុម បានរាយការណ៍ថា ពួកគាត់ពេញចិត្ត នឹងបទពិសោធន៍ និងការបង្ហាត់បង្ហាញរបស់អ្នកគ្រូបង្រៀន។ ពិសេសពួកគាត់បានបញ្ជាក់ថា ការបើកថ្នាក់អក្ខរកម្មនេះ ពិតជាឆ្លើយតបទៅនិងតំរូវការរស់នៅបច្ចុប្បន្នរបស់ពួកគេ និងសហគមន៍។ លើសពីនេះទៅទៀត ពួកគាត់ចេះរៀបចំពេលវេលា ពីភាពទំនេរឥតប្រយោជន៍មកធ្វើការនៅផ្ទះ ដូចជា: ចិញ្ចឹមសត្វ ដាំដំណាំបន្លែ ដើម្បីធ្វើយ៉ាងណារក្សាសុខភាព តាមរបៀបរស់នៅស្អាត ហូបស្អាត ដែលនាំឱ្យគ្រួសារពួកគាត់កាន់ តែមានជីវភាពធូរធារ ប្រសើរឡើងមួយកំរិតថែមទៀត។<br>▪ នៅក្រោយពេលទទួលបានការបណ្តុះបណ្តាលពីថ្នាក់អក្ខរកម្ម គាត់បានបញ្ជាក់ថា គាត់អាចធ្វើការគិតលេខក្នុងការលក់ដូរបានរហ័សជាងមុន។ តួយ៉ាងពីមុនលក់ត្រី១គីឡូ ៦០០០រៀល ដល់ត្រី១.៥គីឡូ គាត់ថា១៥០០០រៀល តែក្រោយទទួលបានការចូលរៀនថ្នាក់អក្ខរកម្មទើបគាត់ចេះគិតថា ១គីឡូ៦០០០រៀល ដល់១.៥គីឡូ ស្មើ៩០០០រៀល។ គាត់មានមោទនភាពណាស់ នៅពេលគាត់ចេះអក្សរ និងចេះគិតលេខ។<br>▪ មន្ត្រីការិយាល័យអប់រំក្រៅប្រព័ន្ធ កាន់តែទទួលបាននូវបទពិសោធន៍ក្នុងការរៀបចំបើកថ្នាក់អក្ខរកម្ម និងជួយគៀវគរអ្នកមិនចេះអក្សរឱ្យមកចូលរួមរៀន ដើម្បីអាចបានឆ្លងផុតពីគ្រោះមិនចេះអក្សរ។ |

## ផ្នែក-ខ: ការសម្រេចបាននូវគោលបំណងបន្ទាន់

| ធាតុនៃគោលបំណងបន្ទាន់ | ការសម្រេចបានជាក់ស្តែង នៅពេលបញ្ចប់ អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ |
|---|---|
| ▪ គោលបំណងបន្ទាន់របស់អនុកិច្ចសន្យានេះ គឺសំដៅចូលរួមសំរេចឱ្យបាននូវគោលនយោបាយ របស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយអ្នកមិនចេះអក្សរ និងភាពក្រីក្រនៅជនបទ និង អនុវត្តន៏នូវគោលនយោបាយកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការនៅមូលដ្ឋាន។ គោលបំណងនេះ ជំរុញ និងបង្កើន ការចេះអាន និងចេះសរសេរ នៅតាមតំបន់ជនបទ ឱ្យបានច្រើនថែមទៀត ដើម្បីចូលរួមកាត់បន្ថយអ្នកមិនចេះអក្សរ និងជំរុញឱ្យអត្រាកុមារចូលសាលារៀនកើនឡើងកាន់តែខ្ពស់ថែមទៀត។ | ▪ គោលបំណងបន្ទាន់ដែលបានចែង គឺនៅក្នុងកម្រិតខ្ពស់ធ្វើអោយយើងពិបាកនៅក្នុងការវាស់វែងនៅចុងបញ្ចប់នៃអនុកិច្ចសន្យា។ ទោះបីជាគេរំពឹងទុកថា សកម្មភាពនានា និងលទ្ធផលទាំងឡាយរបស់អនុកិច្ចសន្យា និងចូលរួមទៅក្នុងគោលបំណងបន្ទាន់ ប៉ុន្តែផ្អែកទៅលើការពិនិត្យឯកសារ និងវិធីសាស្ត្រវាយតម្លៃបែបគុណភាព គេមិនអាចធ្វើការវាយតម្លៃថា តើគោលបំណងបន្ទាន់នេះបានសម្រេចក្នុងកម្រិតណាទេ។ |

## ផ្នែក-គ: សង្ខេបការវាយតម្លៃ ផលប្រយោជន៏ជារួមដែលទទួលបាន

តាមរយៈការពិភាក្សាជាក្រុម អ្នកចូលរួមបានបង្ហាញថា ពួកគាត់មានការពេញចិត្តជាខ្លាំង ចំពោះផលប្រយោជន៏ដែល អនុកិច្ចសន្យានេះសម្រេចបាន ជាពិសេសការបើកថ្នាក់អក្ខរកម្មដែលបានផ្តល់ នូវចំណេះដឹង និងជំនាញនានាទៅលើការ រស់នៅស្អាត ហូបស្អាត និងចំណេះដឹងបន្ថែមសំរាប់ការប្រកបមុខរបរ ដើម្បីបង្កើនជីវភាពរស់នៅប្រចាំថ្ងៃនៅក្នុង គ្រួសារ ហើយនិងក្នុងសហគមន៏ទាំងមូលរបស់ពួកគាត់។ ពួកគាត់បានទទួលស្គាល់ថា ការបើកថ្នាក់អក្ខរកម្ម គឺពិតជា មានសារៈប្រយោជន៏ ដែលអាចជួយដល់អ្នកមិនចេះអក្សរក្នុងគ្រួសារ និងអ្នកមិនចេះអក្សរ នៅក្នុងងសហគមន៏ដែល ពួកគាត់កំពុងរស់នៅ។ ជាពិសេសជាងនេះទៅទៀត ពួកគាត់អាចរំលឹកឡើងវិញអំពីការរៀនអានអក្សរដែលពួកគេ បានបោះបង់ចោលកាលពី២០ឆ្នាំមុន។ ក្រោយមកបន្ទាប់ពីបានរៀនសូត្រពួកគាត់ តែងតែព្យាយាមអានឯកសារនានា ដែលគាត់មាន។ ពិសេសឯកសារទាក់ទងនឹងផ្នែកកសិកម្ម ដែលភ្នាក់ងារអង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានចែកជូន ពួកគាត់នៅពេលប្រជុំភូមិ ដែលឯកសារទាំងនោះមាននិយាយអំពី វិធីចិញ្ចឹមមាន់ ចិញ្ចឹមត្រី ចិញ្ចឹមជ្រូក និង របៀបដាំបន្លែបង្ការផ្សេង១ជាដើម ដែលធ្វើឱ្យពួកគាត់បានយល់ដឹង និងអាចនាំយកនូវចំណេះដឹងមួយចំនួនតាមរយៈ ការអាននេះទៅអនុវត្តបានជោគជ័យ ទទួលបានប្រាក់ចំណូលបន្ថែមក្នុងគ្រួសារសំរាប់ការដោះស្រាយជីវភាពរស់នៅ ប្រចាំថ្ងៃរបស់ពួកគាត់បានមួយកំរិតថែមទៀត។

## ករណីសិក្សា១: អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងដំណើរការបើកថ្នាក់អក្ខរកម្ម

លោកស្រី **ហែន សឿន** ដែលជាអ្នកទទួលផលពីគម្រោងថ្នាក់អប់រំក្រៅប្រព័ន្ធ គ.ជ.អ.ប នៅភូមិគូលែនខាងជើង ឃុំគូលែនខាងជើង ស្រុកគូលែន ខេត្តព្រះវិហារ បាននិយាយថា "ជីវភាពរស់នៅរបស់ខ្ញុំ មានការប្រសើរឡើងតាំងពីខ្ញុំបានចូលរួមរៀននៅក្នុងថ្នាក់អក្ខរកម្មជាមួយប្រជាពលរដ្ឋដ៏ទៃទៀតក្នុងភូមិ " ។



លោកស្រី ហែន សឿន មានអាយុ៣៨ឆ្នាំ រស់នៅភូមិ-ឃុំគូលែនជើង ស្រុកគូលែន ខេត្តព្រះវិហារ ។ គាត់មានកូន០៣នាក់( ប្រុស០២នាក់,ស្រី០១នាក់) ។ គាត់បានរៀនចប់ថ្នាក់ទី២កាលពីគាត់មានអាយុ១២ឆ្នាំ គាត់ប្រកបមុខរបរ ធ្វើស្រែចំការ រីឯការរកប្រាក់ចំណូលវិញមានកំរិតទាបនៅឡើយ ។ គាត់បាននិយាយថា "មូលហេតុដែលគាត់មករៀនព្រោះមិនទាន់ចេះអក្សរ ចេះលេខច្បាស់ ធ្វើអោយការគិតរបស់គាត់មានការលំបាកក្នុងពេលយករបស់ទៅលក់ដូរម្តងៗ ។ គាត់បានបញ្ជាក់ថា គាត់អាចធ្វើការគិតលេខក្នុងការលក់ដូរបានឆាប់រហ័ស ហើយប្រសើរជាងមុន ។ គាត់មាន មោទនភាពណាស់នៅពេលគាត់ចេះអក្សរ និងចេះគិតលេខ ។ គាត់មានការពេញចិត្ត និងសកម្មភាពនេះណាស់ដោយគាត់មានប្រសាសន៏ថា " បើមានបើកបង្រៀនលើក ក្រោយគាត់ និងប្តេជ្ញចិត្តចូលរៀនបន្តទៀត" គាត់បានបន្ថែមទៀតថា "បន្ទាប់ពីបាន រៀនថ្នាក់អក្ខរកម្មធ្វើអោយគាត់មានចំណេះដឹងកាន់តែប្រសើរឡើង និងចេះរកស៊ី លក់ដូរដែលជួយសម្រួលដល់ជីវភាពគាត់បានល្អជាងមុន ព្រមទាំងបានយកចំណេះដឹង នេះទៅជួយបង្រៀនដល់កូនៗរបស់គាត់ និងអ្នកជិតខាងបន្ត ។ គាត់ថាការបើកថ្នាក់ អក្ខរកម្មនេះគឺពិតជាមានសារៈសំខាន់ណាស់ ក្នុងការផ្តល់នូវចំណេះដឹងនានា សម្រាប់ អ្នកមិនទាន់ចេះអក្សរក្នុងភូមិរបស់គាត់ ក៏ដូចជាសង្គមជាតិទាំងមូល ក្នុងគោលដៅ កាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជាទាំងមូល ។

## ផ្នែក-ង: ករណីសិក្សា២: អ្នកមិនបានទទួលផល



លោកស្រី កា ពៅ អាយុ ៥៥ឆ្នាំ ។គ្រួសារគាត់មានកូន០៧នាក់ ។គាត់រស់នៅក្នុងភូមិគូលែនជើង ឃុំគូលែនជើង ស្រុកគូលែន ខេត្តព្រះវិហារ ។គាត់ជាកសិករដែលរកប្រាក់ចំណូលបានមកពីការធ្វើស្រែ ។គាត់បានស្គាល់ជិតខាងមួយចំនួនដែលបានទៅចូលរួមរៀនថ្នាក់អក្ខរកម្មដូចជាលោកស្រី ហែន សឿន, ហើយអ្នកជិតខាងដែល មិនបានទៅចូលរៀនមាន លោកស្រី ចែម វ៉ូន និងលោកស្រីហែន ម៉ៃ អ្នកពីនាក់នេះ មិនបានចូលរៀនថ្នាក់អក្ខរកម្មដូចគាត់ដែរ ។

គាត់បាននិយាយថា: មូលហេតុដែលមិនបានទៅចូលរួមរៀនថ្នាក់អក្ខរកម្មមកពីផ្ទះនៅឆ្ងាយពីសាលា ណាមួយប្តីខឹងបន្ទោស ដោយប្តីគាត់និយាយថា "ខ្លួនចាស់ ហើយតើទៅរៀនធ្វើអ្វី? គាត់មានការលំបាកណាស់ពេលធ្វើការងារបំរើកូន ពេលយក ត្រីទៅលក់ដូរម្តងៗ តែងតែអោយកូនជួយគិត បើមិនអញ្ចឹងគិតខុស មកផ្ទះវិញ ប្តីបន្ទោស ។ តួយ៉ាងពីមុនលក់ត្រី ១គីឡូស្មើ ៦000រៀល ដល់ត្រី១,៥គីឡូ គាត់ថា ១៩000រៀល ខំតែប្រកែកយកឈ្នះនិងគេ។ គាត់បាននិយាយថា មូលហេតុនេះមក ពីមិនចេះបូកលេខ គុណចែក ទើបវាមានការលំបាកដូច្នោះ។ គាត់ចាប់អារម្មណ៍ថា ថ្នាក់អក្ខរកម្មជាកម្មវិធីមួយល្អ សំរាប់អ្នកដែលមិនចេះអក្សរជាឳកាសល្អសម្រាប់ឱ្យ យើងចង់ចេះដឹងពីការសរសេរ ការអាន ការបូក ដក គុណ ចែក លេខ ជាដើម ព្រោះថាកាលណាបើយើងចេះអក្សរ ចេះបូក គុណ ចែកលេខ វាងាយស្រួលសម្រាប់ ប្រើប្រាស់ពេលប្រកបរបបរកស៊ី ដើម្បីបង្កើនជីវភាពនៅក្នុងគ្រួសារ។ គាត់បានមាន ប្រសាសន៍បន្ថែមថា " អ្នកបានរៀន និងអ្នកមមិនបានរៀន ខុសគ្នា អ្នកចេះអក្សរ និងអ្នកមិនចេះអក្សរខុសគ្នា អ្នកចេះ គឺ គេចេះគិតគូរ លក់ដូរ បានឆាប់រហ័ស.........ចំណែកខ្ញុំមិនចេះអក្សរ គឺចេះតែចង្រ្កាន ជើងឆ្នាំង (គាត់និយាយបណ្តើរ សើចបណ្តើរ) ។

គាត់បានសំណូមពរថា បើមានការបើកថ្នាក់អក្ខរកម្មលើកក្រោយសូមអោយបើកនៅជិតផ្ទះរបស់គាត់ ដើម្បីឱ្យគាត់និងអ្នករស់នៅជិតខាងគាត់ បានទៅរៀនផង។ គាត់និយាយថា "ជីវភាពខ្ញុំមានការលំបាកហើយខ្ញុំក៏ចង់បានជីវភាពធូរធារប្រសើរ ឡើងដូចគេដូចឯងដែរ" ។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤)

(១=ខ្សោយណាស់ ២=ខ្សោយ ៣=មិនខ្លាំងមិនខ្សោយ ៤=ខ្លាំង ៥=ខ្លាំងណាស់)

**ផ្នែក-ក: ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅនឹងតំរូវការៈ មន្ទីរវិស័យ មូលដ្ឋាន គ.ជ.អ.ប និងការកាត់បន្ថយភាពក្រីក្រៈ**

| ល.រ | ធាតុ | ទំនាក់ទំនងតក្កភាព | បរិយាយច្បាស់លាស់ | សង្ខេបការវាយតម្លៃ |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៤ | ៤ | សកម្មភាពដែលបានលើកឡើងពិតជាមានទំនាក់ទំនងតក្កភាពជាមួយនឹងលទ្ធផលដែលបានសរសេរនៅក្នុង ឯកសារអនុកិច្ចសន្យា។ ឧទាហរណ៍លទ្ធផលទី១ ទាក់ ទិននឹងដំណើរការរៀបចំបើកថ្នាក់អក្ខរកម្ម និងការគាំ ទ្រថ្នាក់អក្ខរកម្មចំនួន០៨ថ្នាក់រយៈពេល០៨ខែ។ នេះ បញ្ជាក់ថា សកម្មភាពទាំងនេះ ពិតជាមានទំនាក់ទំនង តក្កភាពជាមួយលទ្ធផលនៅខាងលើដែលបានសរសេរ យ៉ាងច្បាស់លាស់។ សកម្មភាពនីមួយៗ បានបង្ហាញយ៉ាងច្បាស់លាស់គឺការបើកថ្នាក់ចំនួន០៨ថ្នាក់និងការ គាំទ្រថ្នាក់អក្ខរកម្មចំនួន០៨ថ្នាក់ រយៈពេល០៨ខែ។ សកម្មភាពដ៏ទៃទៀត ដែលនៅក្រោមលទ្ធផលបន្ត បន្ទាប់ទៀត(លទ្ធផលទី៥) ត្រូវបានសរសេរនៅក្នុង បែបបទដូចគ្នាទៅនឹងលទ្ធផលទី១ដែរ។ ហេតុដូចនេះ សកម្មភាពនីមួយៗមានទំនាក់ទំនងតក្កភាពហើយ ត្រូវបានបរិយាយយ៉ាងច្បាស់លាស់ ដូចដែលមាន សរសេរនៅក្នុងអនុកិច្ចសន្យា។ |
| ២ | លទ្ធផល | ៤ | ៤ | លទ្ធផលនីមួយៗ ត្រូវបានសរសេរច្បាស់លាស់ដោយមានសូចនាករជាក់លាក់ និងអាចវាស់វែងបាន។ ជាងនេះទៅទៀតនោះលទ្ធផលនីមួយៗបានផ្សារភ្ជាប់គ្នាល្អ។លទ្ធផលនីមួយៗជាការបំពេញបន្ថែមឱ្យគ្នាទៅវិញ ទៅមកហើយបានរួមគ្នាបំពេញគោលដៅ |

| | | | | |
|---|---|---|---|---|
| | | | | និងគោល បំណងដូចគ្នា។ ទោះបីជាយ៉ាងនេះក៏ដោយ លទ្ធផល ទាំងនេះនៅមិនទាន់ធ្វើឱ្យគោលបំណងបន្ទាន់សម្រេច បាននៅឡើយ។ |
| ៣ | -គោលបំណងបន្ទាន់ *(គោលបំណងស្ថិតក្នុងចំណុច "ខ" នៃផ្នែកទី ៣)* | ៤ | ៣ | គោលបំណងបន្ទាន់ ត្រូវបានផ្តល់អត្ថន័យច្បាស់លាស់ ប៉ុន្តែគោលបំណងនេះ មានទំហំធំពេកជាហេតុធ្វើឱ្យអនុកិច្ចសន្យានេះ ពិបាកនិងសម្រេចគោលបំណងក្នុងកាលៈទេសៈបែបនេះ។ |
| ៤ | -ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា (ចំណុច "គ" នៃផ្នែកទី៣) | ៤ | ៤ | ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាបាននិយាយច្បាស់ ហើយមានទំនាក់ទំនងផ្ទាល់ ទៅនឹងលទ្ធផល និងសកម្មភាពនៃអនុកិច្ចសន្យា។ ស្ថានភាពចុង បញ្ចប់នេះ បានឆ្លុះបញ្ចាំងនូវសមិទ្ធផល ដែលសម្រេចបាននៅក្នុងកំរិតលទ្ធផលដែលសិស្សថ្នាក់អក្ខរកម្មមួយចំនួនធំ ដែល បានយកនូវអ្វីដែលពួកគាត់ទទួលបានទៅអនុវត្តក្នុងការប្រកបរបរ ចិញ្ចឹមជីវិត និងជាប្រយោជន៍ក្នុងការធ្វើឱ្យ ជីវភាពពួកគាត់កាន់តែប្រសើរឡើង។ |
| ៥ | លទ្ធផលអភិវឌ្ឍន៍/ផលប៉ះពាល់រយៈ ពេលវែងៈ គោលដៅ និងគោលបំណងអភិវឌ្ឍន៍ *(ចំណុច "ខ" នៃផ្នែកទី ៣)* | | | មិនអាចធ្វើការវាយតម្លៃបានទេ។ |

## ផ្នែក-ខៈ សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខ័ណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារៈ

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.ជ.អ.ខៈ** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | នៅមានកំរិត។ គួរមានការពង្រឹងបន្ថែមទៀតដល់មន្ត្រីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យការអនុវត្តន៍របស់ភ្នាក់ងារអនុវត្តន៍ | បានល្អ ។គ្មានការប្រឈមនិងឧបសគ្គដែលគួរឱ្យកត់សំគាល់ទេ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា | ដូចតាមទំលាប់ និងនិតិវិធីដែលបានធ្វើពីមុនៗ ការតក់ត្រានិងទុកដាក់ឯកសារគួរត្រូវបានកែលំអ។ |

| | | |
|---|---|---|
| **ពីខាងភាគីអនុវត្តន៍កិច្ចសន្យា:** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | នៅមានកំរិត។ គួរតែពង្រឹងបន្ថែមនិងគាំទ្របច្ចេកទេស |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | បានអនុវត្តទាន់ពេលដូចដែលបានកំណត់ក្នុងអនុកិច្ចសន្យា |
| ៦ | ការរាយការណ៍ការរីកចំរើន និង ការកត់ត្រាឯកសារ | នៅមានកំរិត។ អ្នកអនុវត្តផ្សេង អ្នករាយការណ៍ និងកត់ត្រាផ្សេង។ មិនមានការផ្តល់ពត៌មានត្រឡប់ឱ្យគ្នាទៅវិញទៅមក។ |
| ៧ | ការគោរពតាមលក្ខខ័ណ្ឌកិច្ចសន្យា | លក្ខខ័ណ្ឌកិច្ចសន្យាក្នុងកិច្ចសន្យាត្រូវបានបំពេញ។ |
| **ទាំងខាង ត.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យា:** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" (ចំណុច-ង ផ្នែកទី៣) និងបញ្ហាប្រឈម | មានការយឺតយ៉ាវក្នុងការអនុម័តកិច្ចសន្យា។ ការទំលាក់ថវិកាមានការយឺតយ៉ាវ។ សកម្មភាពទាំងនេះត្រូវអនុវត្តទៅតាមរដូវកាល។ |
| ៩ | ការបញ្ជ្រាបយេនឌ័រ (ចំណុច-ច ផ្នែកទី៣) | មានការលើកកំពស់យេឌ័រ។ ការចូលរួមរបស់សិស្សជាស្ត្រីក្នុងថ្នាក់រៀន និងមានសិស្សស្រីចំនួនជាច្រើន ចូលរួមក្នុងដំណើរការ នៃយុទ្ធនាការផ្សព្វផ្សាយ ដែលស្ត្រីភាគច្រើនជាមេគ្រួសារ។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ (ចំណុច-ឆ ផ្នែកទី៣) | មានការបញ្ជ្រាបពីការគ្រងគ្រងធនធានធម្មជាតិពី៣0%ទៅ៤0% ព្រោះថាអត្ថបទអប់រំនេះវាជាអត្ថបទពហុវិស័យ។ |
| ១១ | ការថែរក្សា (និរន្តភាព) (ចំណុច-ជ ផ្នែកទី៣) | សកម្មភាព និងបច្ចេកទេសខ្លះៗ ដែលបានលើកឡើងដោយគម្រោងត្រូវបានមើលឃើញថា ការជ្រើសរើសគ្រូ និងសិស្សសម្រាប់កម្មវិធីអក្ខរកម្ម មន្ទីរអប់រំបានសហការជាមួយក្រុមប្រឹក្សាឃុំ ក្នុងឃុំគោលដៅនីមួយៗតាមរយៈការិយាល័យអប់រំស្រុក និងអាជ្ញាធិរមូលដ្ឋាន ដោយផ្អែកតាមលក្ខខ័ណ្ឌជ្រើសរើស របស់ក្រសួងអប់រំ។ |

## ២.៤. សេចក្តីសន្និដ្ឋាន

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យានេះ ត្រូវបានបង្កើតឡើងដូចការគ្រោងទុក។ ភាគីអនុវត្តអនុកិច្ចសន្យាមានសមត្ថភាពល្មម និងមានធនធានគ្រប់គ្រាន់ដើម្បីអនុវត្តន៍អនុកិច្ចសន្យា។ សកម្មភាពនិងលទ្ធផលដែលបានគ្រោងទុកត្រូវបានបញ្ចប់ ស្របតាមផែនការការងារ។ |
| ២ | សកម្មភាពរបស់អនុកិច្ចសន្យា និងអត្ថប្រយោជន៍ ដែលសហគមន៍ទទួលបាន ត្រូវបានក្រុមពិភាក្សារួមទាំងអ្នកទទួលផលផ្ទាល់ និងអ្នកទទួលផលប្រយោល មានការអបអរសាទរ ពេញចិត្តជាខ្លាំងដោយគម្រោងបើកថ្នាក់អក្ខរកម្មនេះ ត្រូវបានអនុវត្តនៅក្នុងភូមិ-ឃុំរបស់ពួកគាត់។ រីឯស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាត្រូវបានសម្រេចស្ទើរតែទាំងស្រុងដូចការព្រាងទុក។ ភស្តុតាងអំពីលទ្ធផល និងផលប្រយោជន៍ ដែលទទួលបាន នៅតែអាចសង្កេតឃើញ បន្ទាប់ពីអនុកិច្ចសន្យាត្រូវបានបញ្ចប់ជាយូរមកហើយ។ ភស្តុតាង និងផលប្រយោជន៍ ទាំនោះមានដូចជាៈ<br>ក)-គ្រូអក្ខរកម្មតាមភូមិកាន់តែមានមានបទពិសោធន៍ក្នុងការបង្រៀន និងបទពិសោធន៍ក្នុងការប្រមូលសិស្ស ឱ្យចូលរៀនបានចប់ចុងចប់ដើមតាមផែនការដែលបានគ្រោងទុក។<br>ខ)-ប្រជាពលរដ្ឋជាអនក្ខរជនចំនួន១៣១នាក់/ស្រ្តីចំនួន១០៥នាក់ (សិស្សចូលរួមប្រឡងសរុបចំនួន១៦៣នាក់/ស្រី១២៨នាក់) បានឆ្លងផុតពីគ្រោះមិនចេះអក្សរ។<br>គ)-មន្រ្តីការិយាល័យអប់រំក្រៅប្រព័ន្ធកាន់តែទទួលបាននូវបទពិសោធន៍ ក្នុងការរៀបចំបើកថ្នាក់អក្ខរកម្ម និងជួយគៀងគរអ្នកមិនចេះអក្សរ ឱ្យមកចូលរួមរៀន។<br>ឃ)-អ្នកភូមិជាច្រើនដែលរស់នៅក្នុងភាពជាអនក្ខរជន បានសំណូមពរសូមឱ្យមានការគាំទ្រ ដល់ការបើកថ្នាក់ អក្ខរកម្មជាបន្តទៅទៀត ដើម្បីចូលរួមចំណែកគោលដៅអភិវឌ្ឍន៍សហសវត្ស និងការកាត់បន្ថយភាពក្រីក្រ។ |
| ៣ | ការជ្រើសរើសប្រជាពលរដ្ឋជាអនក្ខរជននៅក្នុងកិច្ចសន្យា ដោយភាគីអនុវត្តកិច្ចការផ្ទាល់និងធ្វើឱ្យមានការធានាថា ក្រុមអ្នកទទួលផលដែលមានតម្រូវការខ្លាំងបំផុតនឹងទទួលបានអត្ថប្រយោជន៍ពីអនុកិច្ចសន្យា។ |
| ៤ | អនុកិច្ចសន្យានេះ មានបញ្ហាប្រឈមខ្លះៗ ដោយសារអ្នកអនុវត្តន៍មិនសូវបានចុះធ្វើការតាមដានត្រួតពិនិត្យក្នុងពេលថ្នាក់អក្ខរកម្មកំពុងដំណើរការបង្រៀន។ មានថ្នាក់អក្ខរកម្មចំនួន០១ថ្នាក់ គឺស្ថិតនៅ ក្នុងឃុំឈានមុខ ស្រុកត្បែងមានជ័យ ដែលមន្រ្តីអប់រំខេត្តបានធ្វើការសហការជាមួយមន្រ្តីការិយាល័យអប់រំក្រៅប្រព័ន្ធស្រុក និងអាជ្ញាធិរមូលដ្ឋានបានចុះបើកថ្នាក់អក្ខរកម្ម ប៉ុន្តែដំណើរការបានតែចំនួន០២ខែក៏ត្រូវផ្អាកទៅវិញ។ មូលហេតុគ្មានសិស្សចូលរៀន ដែលធ្វើឱ្យការប្រឡងបញ្ចប់ត្រូវបានអាក់ខានផងដែរ។ |

**<u>ចំណុចរៀនសូត្រ:</u>**

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ផ្អែកតាមលទ្ធផលនៃការអនុវត្តន៍អនុកិច្ចសន្យានេះឃើញថា ការទម្លាក់ថវិកាពីថ្នាក់ជាតិមានការយឺតយ៉ាវ រួមទាំងមានការយឺតយ៉ាវក្នុងការអនុម័តថវិកា ដែលជាហេតុធ្វើឱ្យការរៀបចំអនុកិច្ចសន្យាការចុះហត្ថលេខា និងការអនុវត្តកិច្ចសន្យាមានការយឺតយ៉ាវដែរ។ |
| ២ | មន្ត្រីនៃភាគីទាំងពីរ (ភាគី គ.អ.ជ.ខ និងភាគីអនុវត្តន៍) នៅមិនទាន់មានសមត្ថភាព និងពេលវេលាព្រមទាំងជំនាញពេញលេញក្នុងការគ្រប់គ្រងនិងអនុវត្តន៍អនុកិច្ចសន្យានៅឡើយ ។ជាពិសេសសមត្ថភាពក្នុងការតាមដាន ការរីកចំរើនការ ទូទាត់និងការដោះស្រយាបញ្ហាប្រឈមនានា ដែលបានជួបប្រទះក្នុងកំឡុងពេលកំពុងអនុវត្ត អនុកិច្ចសន្យា។ |
| ៣ | កិច្ចសហការរបស់ភ្នាក់ងារអនុវត្តន៍អនុកិច្ចសន្យា ជាមួយមន្ត្រីការិយាល័យអប់រំក្រៅប្រព័ន្ធស្រុក និងអាជ្ញាធរ មូលដ្ឋាន និងអ្នកពាក់ព័ន្ធសំខាន់ៗដទៃទៀតនៅមានកំរិតដែលជាហេតុធ្វើឱ្យអនក្ខរជន មួយចំនួនមិនបានយល់ ច្បាស់លាស់អំពីអត្ថប្រយោជន៏ដ៏ជាក់លាក់ក្នុងដំណើរការផ្សព្វផ្សាយជ្រើសរើស សិស្សអក្ខរកម្ម។ |
| ៤ | ការចូលរួមពីមន្ត្រីថ្នាក់ខេត្ត-ស្រុក អាជ្ញាធរភូមិ-ឃុំ មន្ទីរ និងការិយាល័យអប់រំយុវជននិងកីឡានៅថ្នាក់ស្រុក និងគណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ខេត្ត-ស្រុក និងឃុំព្រមទាំងអ្នកពាក់ព័ន្ធនានា ក្នុងកំឡុងពេលនៃការអនុវត្តន៍អនុកិច្ចសន្យានៅមានកំរិតដែលជាហេតុធ្វើឱ្យមិនសូវមានប្រសិទ្ធិភាពក្នុងការពិភាក្សាការសំរេច ចិត្តក្នុងការដោះស្រាយបញ្ហាប្រឈមនានាដែលបានជួបប្រទះ។ |

**<u>អនុសាសន៏</u> :**

| ល.រ | អនុសាសន៏ |
|---|---|
| ១ | ថ្នាក់ជាតិគួរផ្តល់ថវិកាឱ្យបានទាន់ពេលវេលា។ ថ្នាក់ខេត្តគួរបន្ថែមចំនួនថវិកាដល់មន្ទីរអប់រំយុវជននិងកីឡាសំរាប់សកម្មភាពនៃការបើកថ្នាក់អក្ខរកម្ម និងអនុម័តថវិកានេះឱ្យបានទាន់ពេលវេលា។ |
| ២ | ទាំងភាគីអនុវត្តន៍ និងភាគី គ.អ.ជ.ខ មិនទាន់មានជំនាញ និងបច្ចេកទេសគ្រប់គ្រាន់ក្នុងការគ្រប់គ្រងគម្រោង និងការអនុវត្តន៍អនុកិច្ចសន្យា ការតាមដានការរីកចំរើន និងការដោះស្រាយបញ្ហានានា ដែលបានជួបប្រទះក្នុង កំឡុងពេលកំពុងអនុវត្តអនុកិច្ចសន្យា។ |
| ៣ | ក្នុងដំណើរការផ្សព្វផ្សាយ ដើម្បីជ្រើសរើសសិស្សអក្ខរកម្មភ្នាក់ងារអនុវត្តន៍អនុកិច្ចសន្យាគួរតែបង្កើនកិច្ចសហការ បន្ថែមទៀតជាមួយមន្ត្រីការិយាល័យអប់រំក្រៅប្រព័ន្ធស្រុក និងអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធសំខាន់ៗ ដទៃទៀតធ្វើយ៉ាងណាឱ្យពួកគាត់ បានយល់ពីអត្ថប្រយោជន៏ដ៏ជាក់លាក់ ដែលពួកគាត់ |

| | |
|---|---|
| | នឹងទទួលបានបន្ទាប់ការសិក្សាអក្ខរកម្ម។ ការផ្តល់ព័ត៌មានច្បាស់លាស់ដល់ពួកគាត់នៅពេលផ្សព្វផ្សាយអាចជាធនធានដ៏មានសារ សំខាន់មួយ ជួយដល់ពួកគាត់ក្នុងការធ្វើការសំរេចចិត្តបានត្រឹមត្រូវនិងមានប្រសិទ្ធិភាព។ កាលណាការធ្វើ សេចក្តីសំរេចចិត្តបានត្រឹមត្រូវការបោះបង់ចោលការរៀនសូត្រចំពោះសិស្សមួយចំនួន គឺពិតជានឹងមិនកើតមាន ដូចជាថ្នាក់អក្ខរកម្មមួយដែលស្ថិតនៅក្នុងឃុំឈានមុខ ស្រុកត្បែងមានជ័យ ដែលបានបើកឱ្យដំណើរការ ទៅហើយត្រូវបិទទៅវិញ ពាក់កណ្តាលទីដោយសារតែអវត្តមានរបស់សិស្សនោះឡើយ។ |
| ៤ | មន្ត្រីថ្នាក់ខេត្ត-ស្រុក អាជ្ញាធរភូមិ-ឃុំ មន្ទីរ និងការិយាល័យអប់រំយុវជននិងកីឡា និងគណៈកម្មាធិការអប់រំ សំរាប់ទាំងអស់គ្នាថ្នាក់ខេត្ត-ស្រុក និងឃុំ ព្រមទាំងអ្នកពាក់ព័ន្ធនានា គួរតែបង្កើនការចូលរួមបន្ថែមទៀត ដើម្បីជួយពង្រឹងដំណើរការនៃការបើកថ្នាក់អក្ខរកម្មនេះឱ្យបាន កាន់តែប្រសើរ និងមានប្រសិទ្ធិភាពសំរាប់ជា ផលប្រយោជន៍របស់សហគមន៍និងប្រជាពលរដ្ឋ ទូទាំងខេត្ត ស្របតាមគោលនយោបាយនៃគោលដៅអភិវឌ្ឍន៍សហសវត្ស និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាលកម្ពុជា។ |

## ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

## ឯកសារទី១ : បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបាន ពិនិត្យ

| ល.រ | ឈ្មោះឯកសារ/របាយការណ៍ | មាន |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និង ឯកសារវិសោធនកម្ម (ប្រសិនមាន) | √ |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ | √ |
| ៣ | របាយការណ៍ត្រួតពិនិត្យគម្រោង | |
| ៤ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | √ |
| ៩ | ផ្សេងទៀត | |

**ឯកសារទី២ : ឯកសារអនុកិច្ចសន្យា លេខ (13/EDU/0901-00(GOV)) ខេត្តព្រះវិហារ**

**បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាសន៍/ជួបពិភាក្សា**

| ល.រ | ថ្ងៃខែ | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា | ទីកន្លែង | ឧបករណ៍ប្រើសម្រាប់ប្រមូលទិន្នន័យដែលបានប្រើ |
|---|---|---|---|---|
| ១ | ១៩ តុលា | លោក ម៉ែន ឃន<br>ប្រធានការិ.អប់រំក្រៅប្រព័ន្ធ<br>ភ្នាក់ងារអនុវត្តគម្រោងនៃមន្ទីរវិស័យ | មន្ទីរអប់រំខេត្ត | សម្ភាសន៍ស៊ីជម្រៅ |
| ២ | ១៩ តុលា | លោក មាស សំអុន ទីប្រឹក្សាផ្នែករដ្ឋបាលមូលដ្ឋាន និងតាមដាន វាយតម្លៃ | គ.ប្រនៃគ.ជ.អ.ខ | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | ២០ តុលា | ក្រុមអ្នកទទួលផល | ភូមិគូលែនខាងជើងជើង ស្រុកគូលែន | សម្ភាសជាក្រុម |
| ៤ | ២០ តុលា | លោកស្រី ហែន សឿន<br>អ្នកទទួលផលផ្ទាល់ | ភូមិគូលែនខាងជើង ស្រុកគូលែន | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៥ | ២០ តុលា | លោកស្រី កា ពៅ អ្នកមិនទទួលផល | ភូមិគូលែនខាងជើង ស្រុកគូលែន | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |

**<u>សំគាល់:</u>** ចំពោះការសំភាសន៍ជាមួយទីប្រឹក្សា (PSDD) ក្រុមការងារវាយតំលៃបានគ្រោងថា នឹងធ្វើការសំភាសន៍ជាមួយប្រធានទីប្រឹក្សា ក៏ប៉ុន្តែដោយសារលោកប្រធានទីប្រឹក្សាជាប់រវល់ ក្រុមការងារបានធ្វើការសំភាសន៍ជាមួយលោក មាស សំអុន ទីប្រឹក្សាផ្នែករដ្ឋបាលមូលដ្ឋាន និងត្រួតពិនិត្យ តាមដាន និងវាយតម្លៃវិញ។

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | 14/SOC/0902-00 (GOV) |
| ចំណងជើង : | គម្រោងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ភ្នាក់ងារអនុវត្តន៏ : | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រៃវែង |
| រយៈពេល (ចាប់ផ្តើម និងបញ្ចប់) | ០១ ខែមករា ដល់ ៣១ ខែធ្នូ ឆ្នាំ២០០៩ |
| រាជធានី ខេត្ត | ខេត្តព្រៃវែង |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រៃវែង |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬ គ.ប្រ/គ.អ.ជ.ខ | ១៣.០០០,០០ ដុល្លារ |
| ការរួមចំណែករបស់រាជធានី ខេត្ត | ០,០០ ដុល្លារ |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៏ | ០,០០ ដុល្លារ |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | ១៣.០០០,០០ ដុល្លារ |

## ក្រុមវាយតម្លៃ និងរៀបចំរបាយការណ៍

| ឈ្មោះ | មុខតំណែង |
|---|---|
| លោក សូ ចិត្ត | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ ផ្នែកគ្រប់គ្រងកិច្ចសន្យា |
| លោក មាន សាម៉ន | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ ផ្នែកគ្រប់គ្រងកិច្ចសន្យា |
| លោក ស៊ិន ស៊ីម | មន្ត្រីបង្គោលមន្ទីរអភិវឌ្ឍន៏ជនបទ |
| លោក សៀវ លាងហេង | មន្ត្រីបង្គោលមន្ទីរបរិស្ថាន |

**ខេត្តព្រៃវែង**

**ខែតុលា ឆ្នាំ២០១០**

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៣ |
| | របាយការណ៍សង្ខេប | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៨** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ/គ.អ.ជ.ខ និងមន្ទីរវិស័យ | ៨ |
| ១.២ | គោលបំណងនៃអនុកិច្ចសន្យា | ៨ |
| ១.៣ | គោលបំណង និងទំហំនៃការវាយតម្លៃ | ៨ |
| ១.៤ | សំណួរវាយតម្លៃ | ៩ |
| ១.៥ | វិធីសាស្ត្រ សម្ភារ និងដំណើរការវាយតម្លៃ | ៩ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ១០ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១២** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល | ១២ |
| | - លទ្ធផលទី១ | ១២ |
| | - លទ្ធផលទី២ | ១៣ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍ភ្លាមៗ និងលទ្ធផលនៃអនុកិច្ចសន្យា | ១៤ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង | ១៨ |
| **២.៤** | **សេចក្តីសន្និដ្ឋាន** | **២២** |
| **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍** | | **២៤** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ២៤ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍/ពិភាក្សា | ២៥ |
| **ករណីសិក្សា** | | |
| ទី១- | អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងបណ្តុះបណ្តាលជំនាញជួសជុលម៉ូតូ | ១៦ |
| ទី២- | អ្នកមិនទទួលផលពីអនុកិច្ចសន្យានៃគម្រោងបណ្តុះបណ្តាលជំនាញជួសជុលម៉ូតូ | ១៧ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ** | គណៈកម្មាធិការប្រតិបត្តិ |
| **គ.អ.ជ.ខ** | គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ/គ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

**គោលបំណង និងវិធីសាស្ត្រនៃការវាយតម្លៃ :-**

ក្រុមត្រួតពិនិត្យវាយតម្លៃ ( មន្ត្រីផ្នែកគ្រប់គ្រងកិច្ចសន្យា និងមន្ត្រីបង្គោលមន្ទីរ) បានរួមគ្នាវាយតម្លៃអនុកិច្ចសន្យាមួយ ដែលមានចំណងជើងថា "**គម្រោងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ : លេខ 14/SOC/0902-00**" ដែលជាអនុកិច្ចសន្យា រវាង គ.អ.ជ.ខ ខេត្តព្រៃវែង ជាមួយនឹងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ នេះជាផ្នែកមួយនៃគម្រោងពង្រឹង សមត្ថភាពគ្រូបង្គោលថ្នាក់ក្រោមជាតិរបស់ផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយ គោលនយោបាយនៃលេខាធិការ- ដ្ឋាន គ.ជ.អ.ប ដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍតាមបែប ប្រជាធិប - តេយ្យ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ ។

គោលបំណងនៃការវាយតម្លៃនេះ គឺដើម្បីទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និង ចំណុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា ព្រមទាំងកត់ត្រានូវ ចំណុចរៀនសូត្រ និងផ្នែកនានា ដែលត្រូវធ្វើឱ្យប្រសើរឡើងនាពេលអនាគត។ ទិសដៅមួយទៀត គឺដើម្បីពង្រឹងរបៀប របបនៃការវាយតម្លៃការអនុវត្តអនុកិច្ចសន្យារបស់ គ.ប្រ/គ.អ.ជ.ខ ជាមួយនឹងភ្នាក់ងារអនុវត្តន៍ ។

**វិធីសាស្ត្រ និងឧបករណ៍ដែលបានប្រើប្រាស់:**

<u>១)</u> ពិនិត្យឡើងវិញនូវឯកសារអនុកិច្ចសន្យា របាយការណ៍រីកចម្រើនសកម្មភាព និងហិរញ្ញវត្ថុប្រចាំខែ កំណត់ហេតុប្រជុំ របាយការណ៍វគ្គបណ្តុះបណ្តាល របាយការណ៍បញ្ចប់អនុកិច្ចសន្យា និងឯកសារពាក់ព័ន្ធនានា ដែលមាននៅក្នុងផ្នែក រដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ/គ.អ.ជ.ខ និងភ្នាក់ងារអនុវត្តន៍ ។

<u>២)</u> ធ្វើការសម្ភាសន៍ជាមួយអ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យាលេខ 14/SOC/0902-00 ( ប្រធានមន្ទីរ ជនបង្គោល និងគ្រូបណ្តុះបណ្តាលជំនាញ) និងពិគ្រោះជាមួយមន្ត្រីបង្គោលលើបញ្ហាយេនឌ័រ និងគ្រប់គ្រងធនធានធម្មជាតិសម្រាប់ បញ្ហាពាក់ព័ន្ធនឹងវិស័យខាងលើ ។ ពិគ្រោះយោបល់ជាមួយទីប្រឹក្សាផ្នែកត្រួតពិនិត្យ វាយតម្លៃ និងវិស័យនៃគម្រោង ភីអេសឌីឌី លើការអនុវត្តអនុកិច្ចសន្យាទាំងមូល ។

<u>៣)</u> ចុះពិនិត្យទីតាំងអនុវត្តគម្រោង និងសង្កេតមើលសកម្មភាព និងភស្តុតាងគម្រោងដោយផ្ទាល់, ពិភាក្សាជាមួយនឹង អ្នកទទួលផលផ្ទាល់ចំនួន ៧ នាក់, រៀបចំករណីសិក្សា របស់អ្នកទទួលផលម្នាក់នៅទីតាំងគម្រោង, ព្រមទាំងសម្ភាសន៍ និងរៀបចំករណីសិក្សារបស់អ្នកទទួលផលមិនផ្ទាល់ ១ នាក់ ដែលរស់នៅក្នុង

ភូមិជាមួយអ្នកទទួលផលផ្ទាល់។

៤) វិភាគទិន្នន័យ និងបកស្រាយទិន្នន័យ ដែលប្រមូលបានតាមវិធីសាស្ត្រខាងលើ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយតបនឹងសំណួរវាយតម្លៃជាក់លាក់។ ធ្វើការផ្ទៀងផ្ទាត់ពង្រាងលទ្ធផលនៃការវាយតម្លៃជាមួយនឹងអនុសាសន៍ ពីភ្នាក់ងារអនុវត្តន៍ និងអ្នកពាក់ព័ន្ធ តាមរយៈព័ត៌មានត្រឡប់ទទួលបាន ពីកិច្ចប្រជុំបង្ហាញលទ្ធផលនៃការវាយតម្លៃ។

**ឆ្លើយទៅនឹងសំណួរទាំង៥នៃការវាយតម្លៃ :**

១- សកម្មភាពទាំងអស់ត្រូវបានអនុវត្ត

| ល-រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង | % សម្រេចបាន |
|---|---|---|---|
| ១ | វគ្គបណ្តុះបណ្តាលជំនាញជួសជុលម៉ូតូ ១ វគ្គ/២០ នាក់/៤ ខែ | ១ វគ្គ អ្នកចូលរួម ១៨នាក់ (ស្ត្រី0នាក់) រយៈពេល ៤ ខែ | ៩៥.៧៤% ☆ |
| ២ | វគ្គបណ្តុះបណ្តាលអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ១៩ វគ្គ | ១៩ វគ្គ អ្នកចូលរួម ៣២៩ នាក់ (ស្ត្រី ៨៣ នាក់) | ១00% |
| ៣ | វគ្គផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ១៣ វគ្គ | ១៣ វគ្គ អ្នកចូលរួម ៥៨៣ នាក់ (ស្រី ១៥១ នាក់) | ១00% |

☆ **សម្គាល់ :** ការបណ្តុះបណ្តាលនៅខែទី១ និងទី២ មានសិក្ខាកាម ២0 នាក់តាមការគ្រោង តែដល់ខែទី៣ ឈប់ម្នាក់ និងខែទី៤ ឈប់ម្នាក់ទៀត

២- វគ្គបណ្តុះបណ្តាលជំនាញជួសជុលម៉ូតូនេះមានប្រសិទ្ធភាពខ្ពស់ ដោយសារវគ្គនេះបានផ្តល់ចំណេះដឹង ជំនាញច្បាស់លាស់ ដែលអ្នកទទួលផលបានយកជំនាញនេះទៅប្រកបរបរជួសជុលម៉ូតូ សម្រាប់ដោះស្រាយជីវភាព និងបានបង្កើនប្រាក់ចំណូលក្នុងគ្រួសារជាប្រចាំ។

៣- វគ្គបណ្តុះបណ្តាល និងវគ្គផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពៈ លទ្ធផលនេះប្រជាពលរដ្ឋបានទទួលចំណេះដឹង ដែលអាចទប់ស្កាត់ ឬគេចផុតពីការឆបោកដោយឈ្មួញទុច្ចរិតបាន។ ឧទាហរណ៍ ពេលមានក្រុមហ៊ុនចូលមកឃោសនាដល់ប្រជាពលរដ្ឋក្នុងភូមិថា ធានានឹងរកការងារឱ្យធ្វើនៅក្រៅប្រទេស ពេលនោះមេឃុំ ឬអ្នកភូមិបានទូរស័ព្ទសួរមកមន្ទីរការងារថា តើក្រុមហ៊ុននោះមានអាជ្ញាប័ណ្ណស្របច្បាប់ទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈពិតមែនដែរឬទេ?

៤- ជារួម អនុកិច្ចសន្យានេះសម្រេចបាននូវស្ថានភាពចុងបញ្ចប់ក្នុងកម្រិតមួយខ្ពស់ ហើយវាពិតជាបានរួមចំណែក ក្នុងការសម្រេចបាននូវគោលបំណងបន្ទាន់ ដោយសារអ្នកទទួលផលទាំងនោះបានយកចំណេះដឹងស្តីពីជំនាញ ជួសជុលម៉ូតូទៅប្រកបរបររកស៊ីប្រចាំថ្ងៃរបស់ខ្លួន ដែលតាមរយៈមុខរបរនេះពិតជាបានបង្កើនប្រាក់ចំណូល គ្រួសាររបស់ពួកគាត់មួយកម្រិត។

៥- អនុកិច្ចសន្យានេះពិតជាមានការពាក់ព័ន្ធ ប្រសិទ្ធភាព និងប្រសិទ្ធផល សមស្របតាមធនធាន ដែលបានវិភាជន៍ សម្រាប់ប្រតិបត្តិការ និងការគ្រប់គ្រងទូទៅ។ ក៏ប៉ុន្តែទោះជាយ៉ាងណាដោយ ក៏នៅមានចំណុចដែលគួរកែលម្អ ខ្លះៗចំពោះគុណភាពនៃការរៀបចំអនុកិច្ចសន្យា ដូចខាងក្រោមៈ

- ធ្វើការបរិយាយអំពីគោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់របស់អនុកិច្ចសន្យានៅក្នុងផ្នែកទី **III** ឱ្យ បានច្បាស់លាស់ និងអាចវាស់វែងបាន ដើម្បីសម្រួលដល់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។
- កំណត់សូចនាករជោគជ័យ/អាចសម្រេចបាន ធៀបនឹងទិន្នន័យមូលដ្ឋាន ឬរៀបចំឱ្យមានក្របខ័ណ្ឌការងារ ត្រួតពិនិត្យ និងវាយតម្លៃ។
- ភ្ជាប់ទំនាក់ទំនងឱ្យបានជាក់លាក់រវាងលទ្ធផលជាមួយគោលបំណងបន្ទាន់ និងគោលបំណងកម្រិតខ្ពស់។

**សេចក្តីសន្និដ្ឋាន ៈ**

១. លទ្ធផល និងអត្ថប្រយោជន៍ ដែលទទួលបានពីការអនុវត្តអនុកិច្ចសន្យានោះ ជាប្រយោជន៍រួមដល់សហគមន៍ គ្រួសារ និងបុគ្គល ដែលរស់នៅក្នុងតំបន់គោលដៅគម្រោង។ ឧទាហរណ៍ៈ អ្នកទទួលផល ដែលបានទទួលការ បណ្តុះបណ្តាលជំនាញស្តីពីជួសជុលម៉ូតូនោះ ពីមុនមកមិនមានមុខរបរច្បាស់លាស់ទេ ហើយពួកគេតែងតែធ្វើ ចំណាកស្រុកទៅរកការងារធ្វើ ដោយគ្មានគោលដៅច្បាស់លាស់ទេ។ តែពេលនេះ ពួកគាត់បានយកចំណេះដឹង និងជំនាញជួសជុលម៉ូតូនោះទៅប្រកបរបររកស៊ី។ ពួកគាត់ពេញចិត្តនឹងរបរជួសជុលម៉ូតូនោះណាស់ ពីព្រោះវា បានផ្តល់ប្រាក់ចំណូលបន្ថែម និងធ្វើឱ្យជីវភាពគ្រួសាររបស់ពួកគាត់បានល្អប្រសើជាងមុន។ រីឯអ្នក ដែលមិន ទទួលផលផ្ទាល់ពីគម្រោងនោះ ក៏បានអបអរសាទរចំពោះអ្នកទទួលផលផ្ទាល់ពីគម្រោងបណ្តុះបណ្តាលជំនាញ ជួសជុលម៉ូតូ ហើយពួកគាត់បានសំណូមពរឱ្យមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈផ្តល់ការបណ្តុះបណ្តាល ជំនាញនេះ ឬជំនាញផ្សេងៗទៀតដល់កសិករក្រីក្រនៅមូលដ្ឋានជាបន្តទៅទៀត។

២. គួរបន្តការគាំទ្រគម្រោងបែបនេះ ក៏ដូចជាការពង្រីកសកម្មភាពគម្រោងរបៀបនេះបន្តទៅទៀត។

៣. ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីធ្វើឱ្យសម្រេចបាននូវអត្ថប្រយោជន៍ក្នុងកម្រិតខ្ពស់ ភ្នាក់ងារអនុវត្ត

គម្រោងគួរបន្តការជ្រើសរើសអ្នកទទួលផលឱ្យបានសមស្របតាមលក្ខណៈវិនិច្ឆ័យ/គោលការណ៍ ឬលើកកម្ពស់ដល់ គ្រួសារស្ត្រីមេម៉ាយ ឬស្ត្រីជាមេគ្រួសារទីទាល់ក្រ ហើយមានកូនតូចៗ។

៤. ដើម្បីពង្រឹងគុណភាព និងភាពទាក់ទងរបស់គម្រោង គួរមានការបរិយាយនៅផ្នែកទី **III** ឱ្យបានច្បាស់លាស់ និងអាចវាស់វែងបានពីស្ថានភាពចុងបញ្ចប់ និងគោលបំណងបន្ទាន់របស់កិច្ចសន្យា ក៏ដូចជាពង្រឹងទំនាក់ទំនង តក្កភាពនៃធាតុនានាទៅនឹងលទ្ធផល និងអត្ថប្រយោជន៍របស់គម្រោង។

៥. ការវាយតម្លៃអនុកិច្ចសន្យាដោយផ្នែកគ្រប់គ្រងកិច្ចសន្យា គ.ប្រ/គ.អ.ជ.ខ គួរធ្វើឱ្យបានយ៉ាងហោចណាស់ ១ ឬ ២ អនុកិច្ចសន្យាជារៀងរាល់ឆ្នាំ ក្នុងគោលបំណងកែលម្អ និងតម្រង់ទិសការអនុវត្តអនុកិច្ចសន្យាឱ្យកាន់ តែមានប្រសិទ្ធភាពខ្ពស់។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ/គ.អ.ជ.ខ និងមន្ទីរវិស័យ

ជារៀងរាល់ឆ្នាំ គ.ជ.អ.ប បានវិភាជន៍ថវិកាតាមរយៈ គ.ប្រ/គ.អ.ជ.ខ ទៅឱ្យមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និងគម្រោង ដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ រយៈកាលកន្លងមក ការវាយតម្លៃអនុកិច្ចសន្យា ដែលមានលក្ខណៈជាប្រព័ន្ធបែបនេះ មិនត្រូវបានអនុវត្តទេ ដោយសារហេតុផលរាំងស្ទះជាច្រើន។ នៅក្នុងឆ្នាំ២០១០ ជាមួយនឹងការគាំទ្រថវិកា និងបច្ចេកទេសពីផ្នែកតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃ លេខាធិការដ្ឋាន គ.ជ.អ.ប, ផ្នែកគ្រប់គ្រងកិច្ចសន្យា គ.ប្រ/គ.អ.ជ.ខ រួមសហការជាមួយជនបង្គោលត្រួតពិនិត្យ និង វាយតម្លៃរបស់មន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ទីរបរិស្ថាន បានធ្វើការវាយតម្លៃអនុកិច្ចសន្យាលេខ: **14/SOC/0902-00** ដែលមានចំណងជើងថា "**គម្រោងកម្មវិធីបណ្តុះបណ្តាលមុខវិជ្ជាជីវៈ**"។ ក្នុងការវាយតម្លៃអនុកិច្ចសន្យានេះ ក្រុម វាយតម្លៃបានប្រើប្រាស់វិធីសាស្ត្រ និងឧបករណ៍មួយចំនួន ដូចមានបរិយាយក្នុងរបាយការណ៍សង្ខេប។ ចំពោះលទ្ធផល ដែលបានរកឃើញ និងសេចក្តីសន្និដ្ឋាននៃការវាយតម្លៃនេះ ត្រូវបានកត់ត្រា និងលើកមកបង្ហាញនៅក្នុងរបាយការណ៍ វាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

មន្ទីរមានគោលបំណងផ្តោតទៅលើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជូនដល់ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទ ដើម្បី ឱ្យពួកគាត់មានជំនាញពិតប្រាកដ ក្នុងការយកទៅប្រកបមុខរបរ និងការបង្កើនជីវភាពគ្រួសារ ឱ្យកាន់តែប្រសើរឡើង សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រក្នុងគ្រួសារ និងសង្គមជាតិទាំងមូល។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូល ដោយផ្នែកគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ/គ.អ.ជ.ខ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និងតម្លាភាព។ ដូច្នេះ ទំហំនៃការវាយតម្លៃមានដែនកំណត់ច្បាស់លាស់តាមទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាពាក់ព័ន្ធ ដូចមានចែងនៅក្នុងក្របខណ្ឌការងារនៃការវាយតម្លៃនេះ។ គោលបំណង នៃការវាយតម្លៃគឺ: ក) ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និង

ចំណុចខ្សោយ ធៀបនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តអនុកិច្ចសន្យា រួមទាំងកត់ត្រានូវចំណុច រៀនសូត្រ និងផ្នែកនានា ដែលត្រូវកែលម្អនៅពេលអនាគត, និង ខ) ដើម្បីពង្រឹងរបៀបរបបវាយតម្លៃការអនុវត្ត គម្រោង ឬអនុកិច្ចសន្យារបស់ គ.ប្រ/គ.អ.ជ.ខ ជាមួយភ្នាក់ងារអនុវត្តន៍។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាបានល្អកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និង ការគ្រប់គ្រង?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យានៅពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារ និងដំណើរការវាយតម្លៃ

**វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើប្រាស់ :**

១) ពិនិត្យឡើងវិញនូវឯកសារអនុកិច្ចសន្យា របាយការណ៍ប្រចាំខែ កំណត់ហេតុប្រជុំ របាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍វគ្គបណ្តុះបណ្តាល និងឯកសារពាក់ព័ន្ធនានា ដែលមាននៅក្នុងផ្នែកគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ/គ.អ.ជ.ខ និងភ្នាក់ងារអនុវត្តន៍។

២) ពិគ្រោះជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗដូចជាៈ អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផលផ្ទាល់ និង មិនផ្ទាល់ ២ ឬ ៣ នាក់ និងអ្នកពាក់ព័ន្ធ ២ នាក់។ ពិគ្រោះជាមួយមន្ត្រីបង្គោលទៅលើបញ្ហាយេនឌ័រ និងគ្រប់គ្រង ធនធានធម្មជាតិ សម្រាប់បញ្ហាពាក់ពន្ធ័នឹងវិស័យខាងលើ។

៣) ប្រើប្រាស់វិធីសាស្ត្រចុះពិនិត្យផ្ទាល់ដល់តំបន់អនុវត្តន៏គម្រោង សង្កេតមើលសកម្មភាព ពិភាក្សាក្រុម និងរៀបចំ ករណីសិក្សា។

៤) ចុះពិនិត្យផ្ទាល់ដល់តំបន់អនុវត្តន៏គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់។

៥) <u>វិភាគ និងបកស្រាយទិន្នន័យៈ</u> រាល់ទិន្នន័យ ដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងត្រូវវិភាគ និង

ផ្ទៀងផ្ទាត់ ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់។

៦) ផ្ទៀងផ្ទាត់លទ្ធផល ដែលបានរកឃើញ និងអនុសាសន៍នានា ពីភ្នាក់ងារអនុវត្តន៍ និងអ្នកពាក់ព័ន្ធនានា តាមរយៈព័តិមានត្រឡប់ ដែលទទួលបានពីកិច្ចប្រជុំបង្ហាញលទ្ធផលនៃការវាយតម្លៃ នាថ្ងៃទី០១ ខែតុលា ឆ្នាំ២០១០។

ការវាយតម្លៃនេះត្រូវបានអនុវត្តតាម "**គោលការណ៍ណែនាំស្តីពីការវាយតម្លៃអនុកិច្ចសន្យា**"។ ដូច្នេះដំណើរការនៃការ វាយតម្លៃអនុកិច្ចសន្យានេះត្រូវបានធ្វើឡើងស្របតាមគោលការណ៍ណែនាំ ធានាបាននូវតម្លាភាព និងមានការចូលរួម ពីភាគីពាក់ព័ន្ធ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃអនុកិច្ចសន្យានេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ គឺជាការវាយតម្លៃដោយ គ.ប្រ និងអ្នកពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យានេះ។ ទោះជាយ៉ាងនេះក្តី ក៏ការវាយតម្លៃនេះត្រូវធ្វើឡើង ដោយឆន្ទៈ និងធានាបាននូវលទ្ធផលជាក់ស្តែង មិនលំអៀង។

២) ចំណេះដឹងអំពីបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត ដែលជាបញ្ហាប្រឈមមួយ ក្នុងការវាយតម្លៃគម្រោង ពីព្រោះអ្នកវាយតម្លៃមិនមានជំនាញ និងបទពិសោធន៍វាយតម្លៃពីមុនមកសោះ។ ក៏ប៉ុន្តែការវាយតម្លៃនេះមានចរិត "ធ្វើបណ្តើរ រៀនបណ្តើរ"។ ដូច្នេះហើយមុនពេលវាយតម្លៃអនុកិច្ចសន្យានេះ ក្រុមអ្នកវាយតម្លៃបានទទួលការគាំទ្រ បច្ចេកទេសពីថ្នាក់ជាតិលើគោលការណ៍ណែនាំ និងឧបករណ៍ប្រើប្រាស់ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ។

៣) បញ្ហាប្រឈមក្នុងផ្នែកទី ៣ នៃអនុកិច្ចសន្យា: ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល/សកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់" លើការរីកចម្រើន និងជោគជ័យទេ។ ម្យ៉ាងទៀត ទំនាក់ទំនងសង្ខេបតាម បែបតក្កភាពរវាង ធាតុចូល សកម្មភាព និងលទ្ធផល និងរវាងលទ្ធផលទៅនឹងគោលបំណងបន្ទាន់ ឬសារៈប្រយោជន៍ មិនមានបង្ហាញច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះក៏មិនសូវស៊ីសង្វាក់គ្នាដែរ។

៤) ដោយសារតែគ្មានសូចនាករបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍" ដែលជាកម្រិតអត្ថប្រយោជន៍ដ៏សំខាន់នៃគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ ព្រមទាំងកម្រិត "គោលបំណង" ដែលជាផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។

៥) ដោយសារពេលវេលា និងធនធានមានកម្រិត យើងមិនមានលទ្ធភាពវាយតម្លៃលម្អិតលើលទ្ធផល និងសកម្មភាព ទាំងអស់បានទេ។ ដូច្នេះ យើងសម្រេចវាយតម្លៃតែលើលទ្ធផល និងផលប៉ះពាល់នៃការ

បណ្តុះបណ្តាលជំនាញជួសជុល ម៉ូតូ ដែលជាលទ្ធផលមួយនៅក្នុងអនុកិច្ចសន្យា តាមរយៈការសម្ភាសន៍ស៊ីជម្រៅ ក្រុមពិភាក្សា និងការចុះពិនិត្យតំបន់ អនុវត្តគម្រោង។ រីឯការបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពមិនត្រូវបានវាយតម្លៃ តាមបែបស៊ីជម្រៅទេ គឺគ្រាន់តែសម្ភាសន៍យកព័ត៌មានខ្លះៗពីភ្នាក់ងារអនុវត្តន៍តែប៉ុណ្ណោះ។

**<u>ចំណុច ដែលត្រូវបញ្ចូល ដកចេញ ឬបដិសេធ :</u>**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ **14/SOC/0902-00** គឺ **គម្រោងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ** និងដែនកំណត់ ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌនៃការវាយតម្លៃនេះ។

២) ការវាយតម្លៃនេះលម្អិតតែទៅលើការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញជួសជុលម៉ូតូ ដែលជាលទ្ធផល និងសកម្មភាព នៃអនុកិច្ចសន្យា។ រីឯលទ្ធផលនៃការបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពនោះមិន ត្រូវបានវាយតម្លៃទេ ពីព្រោះក្រុមអ្នកវាយតម្លៃមិនមានជំនាញគ្រប់គ្រាន់ សម្រាប់បំពេញការងារនេះទេ។

៣) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃ ដើម្បីស្វែងរកកំហុសរបស់ភ្នាក់ងារអនុវត្តន៍ អ្នកពាក់ព័ន្ធគម្រោង និង គ.ប្រ/គ.អ.ជ.ខ និង គ.ជ.អ.ប ទេ គឺធ្វើឡើង ដើម្បីស្វែងរកប្រសិទ្ធភាពនៃការវិនិយោគ។

ហេតុដូច្នេះ របាយការណ៍នៃការវាយតម្លៃ និងលទ្ធផល ដែលបានរកឃើញ និងអនុសាសន៍នានា ដែលបានលើកឡើង ត្រូវពិនិត្យពិគ្រោះដោយផ្អែកទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ។

# ២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល

លទ្ធផលទី១ :ការបណ្តុះបណ្តាលពីជំនាញជួសជុលម៉ូតូ :

**ផ្នែក-ក :** ការសម្រេចបានជាក់ស្តែង ធៀបនឹងផែនការ :

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី ៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១ | - វគ្គបណ្តុះបណ្តាលពីជំនាញជួសជុលម៉ូតូ ១ វគ្គ<br>- វគ្គនេះមានរយៈពេល ៤ ខែ<br>- អ្នកចូលរួមចំនួន ២០ នាក់ | - វគ្គបណ្តុះបណ្តាលពីជំនាញជួសជុលម៉ូតូ ១ វគ្គ<br>- វគ្គនេះមានរយៈពេល ៤ ខែ<br>- អ្នកចូលរួមចំនួន ១៨ នាក់ (ការបណ្តុះបណ្តាលនៅខែទី១ និងទី២ មានសិក្ខាកាម ២០ នាក់ តាមការគ្រោង តែដល់ខែទី៣ ឈប់ម្នាក់ និងខែទី៤ ឈប់ម្នាក់ទៀត) |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល :

| |
|---|
| អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និងសកម្មភាពតាមការគ្រោងទុក។ អ្នកទទួលផលពីការបណ្តុះបណ្តាលជំនាញជួសជុលម៉ូតូ ដែលបានចូលរួមក្នុងក្រុមពិភាក្សានោះបានបញ្ជាក់ថា រយៈពេល ៤ ខែ ដែលពួកគាត់បានរៀនសូត្រកាលពីឆ្នាំ២០០៩កន្លងទៅ គឺពិតជាចំណេះដឹង និងជំនាញមួយ ដែលពួកគាត់អាចយកទៅប្រកបមុខរបរជួសជុលម៉ូតូនៅមូលដ្ឋានបាន។ ពួកគាត់បានលើកសរសើរដល់មន្ទីរការងារ និងគ្រូបណ្តុះបណ្តាលថា ការគ្រប់គ្រង និងការបង្ហាត់បង្រៀនសិក្ខាកាមបានល្អ។ គ្រូបានបង្រៀនទ្រឹស្តីមុនបន្ទាប់មកសិក្ខាកាមអនុវត្តផ្ទាល់ជា ក្រុមតូចៗ ហើយបន្ទាប់មកអនុវត្តម្នាក់ម្តងៗ ។ ដូច្នេះសិក្ខាកាមម្នាក់ៗ សុទ្ធតែបានទទួលទ្រឹស្តី និងអនុវត្តផ្ទាល់គ្រប់គ្នា។ |

| |
|---|
| រួមសេចក្តីមក វគ្គបណ្តុះបណ្តាលនេះជាតម្រូវការសំខាន់របស់សិក្ខាកាម គ្រួសារ និងសហគមន៍របស់គាត់ ។ បច្ចុប្បន្ន ពួកគាត់បានចំណូលមួយចំណែកពីមុខរបរជួសជុលម៉ូតូនេះ ។ |

លទ្ធផលទី២: វគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព :

**ផ្នែក-ក :** ការសម្រេចបានជាក់ស្តែង ធៀបនឹងផែនការ :

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១ | - វគ្គបណ្តុះបណ្តាលអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ១៩ វគ្គ<br>- វគ្គនេះមានរយៈពេល ១ថ្ងៃ ក្នុង ១វគ្គ<br>- អ្នកចូលរួម ៣២៩ នាក់ ( ស្ត្រី ៨៣នាក់) | - វគ្គបណ្តុះបណ្តាលអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ១៩ វគ្គ<br>- វគ្គនេះមានរយៈពេល ១ ថ្ងៃ/១ វគ្គ<br>- អ្នកចូលរួម ៣២៩ នាក់ ( ស្ត្រី ៨៣នាក់) |
| ២ | - វគ្គផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ១៣វគ្គ<br>- វគ្គនេះមានរយៈពេល ១ថ្ងៃ ក្នុង ១វគ្គ<br>- អ្នកចូលរួម ៥៨៣ នាក់ ( ស្ត្រី ១៥១ នាក់) | - វគ្គផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ១៣វគ្គ<br>- វគ្គនេះមានរយៈពេល ១ថ្ងៃ/១ វគ្គ<br>- អ្នកចូលរួម ៥៨៣ នាក់ ( ស្ត្រី ១៥១ នាក់) |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល :

| |
|---|
| អនុកិច្ចសន្យានេះសម្រេចបានទូវលទ្ធផល និងសកម្មភាពនានា ដែលបានគ្រោងទុក តែមិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះបានលម្អិតទេ ។ |

## ២.២. ការវាយតម្លៃលើការសម្រេចបាននូវអត្ថប្រយោជន៍ភ្លាមៗ និងលទ្ធផលនៃអនុកិច្ចសន្យា :

### ផ្នែក កៈ ការវាយតម្លៃការសម្រេចបាននូវស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា :

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា | ស្ថានភាពជាក់ស្តែង |
|---|---|
| សិក្ខាកាមចំនួន ២០ នាក់ទទួលបានចំណេះដឹង និងជំនាញជួស ជុលម៉ូតូ។ ក្រោយពេល បញ្ចប់វគ្គបណ្តុះបណ្តាល ពួកគាត់នឹង ទទួលបានកញ្ចប់សម្ភារ សម្រាប់យកទៅបង្កើតមុខរបរចិញ្ចឹម ជីវិត។ | សិក្ខាកាមចំនួន១៨ នាក់បានទទួលចំណេះដឹង និង កញ្ចប់សម្ភារៈ ពីវគ្គបណ្តុះបណ្តាលជំនាញជួសជុលម៉ូតូ និង បានបង្កើតមុខរបរ ជួសជុលម៉ូតូ ដើម្បីបង្កើនចិរិកាចិញ្ចឹមជីវភាពគ្រួសារ។ |
| ក្រុមប្រឹក្សាឃុំ ជនបង្គោលនារី និងកុមារឃុំ មេភូមិ អនុប្រធាន ភូមិ ជំនួយការភូមិ មេប៉ុស្តិ៍ គ្រូបង្រៀន និង ព្រះសង្ឃចំនួន ១,២៩៧ នាក់ នឹងទទួលបានចំណេះដឹង ស្តីពីការធ្វើចំណាកស្រុក ដោយសុវត្ថិភាព តាមរយៈការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុក ដោយសុវត្ថិភាព | ក្រុមប្រឹក្សាឃុំ ជនបង្គោលនារី និងកុមារឃុំ មេភូមិ អនុប្រធាន ភូមិ ជំនួយការភូមិ មេប៉ុស្តិ៍ គ្រូបង្រៀន និងព្រះសង្ឃចំនួន ៩១២ នាក់ ទទួលបានចំណេះដឹង ស្តីពីការធ្វើចំណាកស្រុក ដោយសុវត្ថិភាព តាមរយៈការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុក ដោយសុវត្ថិភាព។ |

### ផ្នែក-ខៈ ការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា :

| ធាតុនៃគោលបំណងបន្ទាន់ | ការសម្រេចបានជាក់ស្តែងនៅពេល បញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ |
|---|---|
| ក្នុងចំណុច ខ របស់ផ្នែកទី III នៃអនុកិច្ចសន្យា មិនមាន បរិយាយពីអត្ថប្រយោជន៍រយៈពេលខ្លី និងមធ្យម ដែលជាគោលបំណងបន្ទាន់ របស់អនុកិច្ចសន្យាទេ | អ្នកចូលរួមទាំងអស់ ក្នុងការពិភាក្សាក្រុម បាន រាយការណ៍ថា វគ្គបណ្តុះបណ្តាលជំនាញជួសជុលម៉ូតូ ពិតជា ឆ្លើយតបទៅនឹង តម្រូវការរបស់ពួកគាត់ណាស់ ព្រោះវាបង្កើនបានប្រាក់ចំណូល ប្រចាំថ្ងៃ ដែលគាត់អាច រកបានជាមធ្យម ៥,០០០រៀល ក្នុង ១ ថ្ងៃ និងវាជា |

| | |
|---|---|
| | ការងារធ្វើនៅរោងមុខផ្ទះមិនពិបាកដើររកការងារធ្វើដូចកាល ពីមុនទៀតទេ។ |

☆ ៩១២ នាក់ ជាចំនួនសម្រេចបានតាមការគ្រោងលម្អិតថវិកាសកម្មភាពនៃអនុកិច្ចសន្យា ។

រីឯ ១.២៩៧ នាក់ ជាចំនួនគ្រោងលើសក្នុងកម្រិតលទ្ធផល ដោយមិនបានកែសម្រួលតាមការលម្អិតថវិកាសកម្មភាព

## ផ្នែក-គៈ ការវាយតម្លៃផលប្រយោជន៍ជារួមដែលទទួលបាន :

| |
|---|
| តាមរយៈការពិភាក្សាក្រុម អ្នកចូលរួមបានបង្ហាញថា ពួកគាត់ពេញចិត្តចំពោះផលប្រយោជន៍ ដែលអនុកិច្ចសន្យានេះសម្រេចបាន គឺជំនាញជួសជុលម៉ូតូ។ ពួកគាត់បានទទួលស្គាល់ថា វាមានសារៈប្រយោជន៍សម្រាប់គ្រួសារគាត់ ហើយជា ទូទៅ វាបានផ្តល់ជំនាញច្បាស់លាស់ ដែលជាមុខរបរសម្រាប់ដោះស្រាយជីវភាព និងរួមចំណែកបង្កើនប្រាក់ចំណូល ក្នុងគ្រួសារជាប្រចាំ។ |

## ករណីសិក្សាទី១: អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងបណ្តុះបណ្តាលជំនាញជួសជុលម៉ូតូ



លោក **សេង វណ្ណា**

**បន្ទាប់ពីបានទទួលចំណេះដឹង ជំនាញជួសជុលម៉ូតូ ពីគម្រោងកម្មវិធីបណ្តុះបណ្តាល វិជ្ជាជីវៈរបស់មន្ទីរការងារបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រៃវែងក្នុងឆ្នាំ២០០៩ លោក សេង វណ្ណា បាននិយាយថាៈ “ជីវភាពគ្រួសារខ្ញុំមានភាពប្រសើរឡើងតាំងពីខ្ញុំបានបើកសេវាកម្មជួសជុលម៉ូតូ ”**

លោក **សេង វណ្ណា** មានអាយុ ២២ឆ្នាំ ជាកូនកំព្រាម្តាយ ហើយឪពុកមានប្រពន្ធថ្មី (ទី២) ទៀត គាត់រស់នៅជាមួយម្តាយមីងតាំងពីតូច ដែលជាប្រជាពលរដ្ឋ រស់នៅក្នុងភូមិថ្កូវ ឃុំដំរីពួន ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។ គាត់បាននិយាយថាៈ គម្រោងវគ្គណ្តុះបណ្តាលនេះ មានសារៈសំខាន់ណាស់សម្រាប់គាត់ ព្រោះគាត់បានទទួលចំណេះដឹង និងជំនាញជួសជុលម៉ូតូ និងបានទទួលកញ្ចប់សម្ភារសម្រាប់ដំណើរការជួសជុលម៉ូតូ ហើយបច្ចុប្បន្ននេះគាត់បាន យកជំនាញនេះ ទៅប្រកបជាមុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់គាត់ និងបង្កើនប្រាក់ចំណូល បានមួយកម្រិតទៀតផង។ ពីមុនគាត់មានការលំបាកខ្លាំងណាស់ និងគ្មានលំនឹងក្នុងចិត្ត ក្រៅពីជួយធ្វើស្រែ ពូ-មីង គាត់គ្មានមុខរបរអ្វីបន្ថែមទៀតទេ។ គាត់បានបន្ថែមទៀតថា “តាំងពីខ្ញុំបានប្រកបរបរជួសជុលម៉ូតូមក ខ្ញុំមានការពេញចិត្តខ្លាំងណាស់ព្រោះ វាអាចរកចំណូលបានជាមធ្យម ៥000 រៀល ក្នុង ១ថ្ងៃ” នេះជាប្រភពចំណូលទី ២ របស់គាត់បន្ទាប់ពីធ្វើស្រែវស្សា។

លោកបានបញ្ជាក់ទៀតថា “អ្នកភូមិ ក៏ដូចជាអ្នកធ្លាប់បានមកជួសជុលម៉ូតូកន្លែងខ្ញុំ ពួកគេពេញចិត្តនឹងសកម្មភាពរបស់ខ្ញុំណាស់ ហើយខ្ញុំក៏មានគម្រោងនឹងទិញគ្រឿង បន្លាស់ឱ្យបានគ្រប់មុខបន្ថែមទៀត ដើម្បីបំពេញសេចក្តីត្រូវការរបស់អ្នកមកជួសជុលម៉ូតូនៅទីនេះ។ ចំណែកអ្នកនៅភូមិជិតខាង ពួកគាត់ក៏សប្បាយចិត្តដែរចំពោះ មុខរបររបស់ខ្ញុំ ព្រោះពេលម៉ូតូរបស់ពួកគាត់ខូច យកមកដល់កន្លែងខ្ញុំនោះ ខ្ញុំជួស ជុលបានទាន់ចិត្ត និងតាមតម្រូវការរបស់គាត់ភ្លាម។ ម្យ៉ាងទៀតពេល ពួកគាត់មក ជួសជុល ម៉ូតូ/កង់បន្តិចបន្តួច ខ្ញុំមិនយកប្រាក់ពីពួកគាត់ទេ។”

## ករណីសិក្សាទី២: អ្នកមិនទទួលផលពីអនុកិច្ចសន្យា



លោក **ប៉េ ជីវ៉ា**

លោក ប៉េ ជីវ៉ា មានអាយុ ២៣ ឆ្នាំ ជាកូនកំព្រាម្តាយ ហើយឪពុកមានប្រពន្ធថ្មីទៀត គាត់រស់នៅជាមួយបងស្រី ដែលជាប្រជាពលរដ្ឋរស់នៅក្នុងភូមិថ្កូវ ឃុំដីរីពួន ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។

លោក **ប៉េ ជីវ៉ា** មិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ជំនាញជួសជុលម៉ូតូ ពីគម្រោងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលអនុវត្តដោយមន្ទីរការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រៃវែងនៅក្នុងឆ្នាំ២០០៩ទេ។ គាត់មិនត្រូវ បានគេជ្រើសរើសឱ្យចូលរួមគម្រោងទេ ដោយសារក្នុងភូមិនេះ គេជ្រើស រើសយកតែម្នាក់។ ម្យ៉ាងទៀតគាត់មិនបានដឹងព័ត៌មាននៅពេលដែលគេ មកជ្រើសរើសទេ។ គាត់និយាយទៀតថា វគ្គបណ្តុះបណ្តាលជំនាញជួស ជុលម៉ូតូ នេះមានសារៈសំខាន់ណាស់ ព្រោះគាត់សង្កេតឃើញថា បន្ទាប់ពី *វណ្ណា* រៀនជំនាញ ជួសជុលម៉ូតូចប់ គាត់មានចំណេះដឹង និង ជំនាញ ច្បាស់លាស់។ មិនតែប៉ុណ្ណោះគាត់បានបើកអាជីវកម្មជួសជុលម៉ូតូ បានតាមតម្រូវការ អតិថិជន ដែលមកជួសជុលម៉ូតូនៅតូបរបស់គាត់។ លោក *ប៉េ ជីវ៉ា* បាន បន្តទៀតថា *វណ្ណា* អាចរកចំណូល ពីការជួសជុលម៉ូតូ បានជាមធ្យមប្រមាណ ២០,០០០ រៀល ក្នុង ១ថ្ងៃ។ ដោយសង្កេត ឃើញបែបនេះ *ជីវ៉ា* មានការសោកស្តាយព្រោះ មិនបានរៀន ជំនាញនេះដូច លោក *សេង វណ្ណា* ហើយគាត់ចង់ចេះជំនាញ នេះណាស់។ ដោយឡែកអ្នកជិតខាង និងអតិថិជន ដែលមក ជួសជុលម៉ូតូ នៅតូប *វណ្ណា* ក៏ពេញចិត្តជំនាញជួសជុលម៉ូតូ ដែលជាមុខរបររបស់ *វណ្ណា* ណាស់ដែរ ព្រោះទីតាំងជួសជុលម៉ូតូ នៅជិត ជាងមុនប្រមាណ ៧ គីឡូម៉ែត្រ។ ម្យ៉ាងទៀតថ្វីត្បិតតែ *វណ្ណា* ជាជាងថ្មីពិតមែន តែគាត់អាច ជួសជុលម៉ូតូបានដូចជាងជើងចាស់ ដែលពួកគាត់ធ្លាប់ បានទៅជួសជុល កាលពីលើកមុនដែរ។ នៅពេលខ្លះពួកគាត់មកជួសជុល ម៉ូតូ/ កង់ បន្តិចបន្តួចនោះ *វណ្ណា* មិនយកប្រាក់ពីពួកគាត់ទេ។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

**ផ្នែក-ក: ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅនឹងតម្រូវការ មន្ទីរវិស័យ មូលដ្ឋាន គ.ជ.អ.ខ និងការកាត់បន្ថយភាព ក្រីក្រ:** (ពិន្ទុ : ១= ខ្សោយណាស់, ២= ខ្សោយ, ៣= មិនខ្លាំងមិនខ្សោយ, ៤= ខ្លាំង, ៥= ខ្លាំងណាស់)

| ល.រ | ធាតុ | ទំនាក់ទំនង តក្កភាព | បរិយាយ ច្បាស់លាស់ | សង្ខេបការវាយតម្លៃ |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតម្រូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៤ | ៤ | សកម្មភាព ដែលបានលើកឡើងពិតជាមានទំនាក់ទំនងតក្កជាមួយនឹងលទ្ធផល ដែលបានសរសេរក្នុងឯកសារអនុកិច្ចសន្យា។ ឧទាហរណ៍ **លទ្ធផលទី១** ទាក់ទងនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈ មានសកម្មភាពជាក់លាក់អំពីជំនាញជួសជុលម៉ូតូដល់ប្រជាពលរដ្ឋចំនួន ១ វគ្គ ដែល មានសិក្ខាកាមសរុប២០ នាក់ រយៈពេល ៤ខែ។ **លទ្ធផលទី២** ទាក់ទងទៅនឹងការបណ្តុះបណ្តាលអំពីសិទ្ធិកុមារ និងស្ត្រី មានសកម្មភាពជាក់លាក់ស្តីពីការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ នារី និងកុមារឃុំ មេភូមិ អនុប្រធានភូមិ ជំនួយការ ភូមិ មេប៉ុស្តិ៍ ព្រះសង្ឃ និងគ្រូ បង្រៀន ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព |
| ២ | លទ្ធផល | ៤ | ៣ | លទ្ធផលនីមួយៗត្រូវបានសរសេរច្បាស់លាស់ ដោយមាន សូចនាករជាក់លាក់ និងអាចវាស់វែងបាន។ លទ្ធផល នីមួយៗ អាចបំពេញឱ្យគ្នាទៅវិញទៅមក គឺប្រជាពលរដ្ឋ ធ្វើចំណាកស្រុកព្រោះតែខ្វះការងារ ឬខ្វះមុខរបរ ហើយ កិច្ចសន្យានេះក៏បានផ្តល់ជំនាញ សម្រាប់បង្កើតមុខរបរ ផងដែរ។ ក៏ប៉ុន្តែលទ្ធផល ទាំងអស់នេះនៅមិនទាន់ធ្វើឱ្យ គោលបំណងបន្ទាន់ សម្រេចបាន |

| | | | | |
|---|---|---|---|---|
| | | | | នៅឡើយទេ ព្រោះថា គោលបំណង ដែលសរសេរនៅផ្នែក **ខ** នៃអនុកិច្ចសន្យា ជាគោលដៅរបស់ **គ.ជ.អ.ប**។ |
| ៣ | គោលបំណងបន្ទាន់ (គោលបំណងស្ថិតក្នុងចំណុច **ខ** នៃផ្នែកទី**៣**) | ៣ | ៣ | គោលបំណងបន្ទាន់មិនបានសរសេរ ក្នុងកម្រិតលទ្ធផលដែលសម្រេចបាននៃអនុកិច្ចសន្យា ដែលជាអត្ថប្រយោ-ជន៍រយៈពេលខ្លីទេ តែវាជាគោលដៅកាត់បន្ថយភាពក្រីក្ររបស់ **គ.ជ.អ.ប** ។ |
| ៤ | ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា *(ចំណុច "គ" នៃផ្នែកទី ៣)* | ៣ | ៣ | ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា ត្រូវបានបរិយាយច្បាស់លាស់ ដោយមានទំនាក់ទំនងផ្ទាល់ ទៅនឹងលទ្ធផល និងសកម្មភាពអនុកិច្ចសន្យា។ ស្ថានភាពចុងបញ្ចប់នេះ បានឆ្លុះបញ្ចាំងនូវសមិទ្ធផល ដែលសម្រេចបាននៅក្នុង កម្រិតលទ្ធផល។ ប៉ុន្តែវាមិនបានឆ្លុះបញ្ចាំងនូវស្ថានភាព ចុងបញ្ចប់ និងផលប៉ះពាល់ដែលអាចកើតមានឡើងក្នុង កម្រិតប្រជាពលរដ្ឋ និងសហគមន៍ទេ។ គ្មានភស្តុតាង ច្បាស់លាស់ណាមួយបង្ហាញថា សិក្ខាកាមទាំងនោះបាន យកចំណេះដឹង និងជំនាញ ដែលពួកគេបានទទួល ទៅធ្វើ ធ្វើជាសារៈប្រយោជន៍ ក្នុងការធ្វើឱ្យប្រសើរឡើងនូវ ជីវភាពរបស់ពួកគាត់ទេ។ |
| ៥ | លទ្ធផលអភិវឌ្ឍន៍/ផលប៉ះពាល់រយៈពេលវែងៈ គោលដៅ និងគោលបំណងអភិវឌ្ឍន៍ *(ចំណុច "ខ" នៃផ្នែកទី ៣)* | | | មិនអាចវាស់វែងបាន |

**ផ្នែក-ខៈ សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខណ្ឌនៃអនុកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើ របាយការណ៍ និងការកត់ត្រាឯកសារ :**

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ភាគី គ.អ.ជ.ខៈ** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | នៅមានកម្រិត ។ គួរពង្រឹងបន្ថែម លើបច្ចេកទេស ។ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យការអនុវត្តរបស់ភ្នាក់ងារអនុវត្តន៏ | សមរម្យល្អ ។ គ្មានការប្រឈម និងឧបសគ្គគួរឱ្យកត់សំគាល់ទេ ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារអនុ-កិច្ចសន្យា | ដូចតាមទម្លាប់ និងនីតិវិធីដែលបានធ្វើ ។ ការកត់ត្រា និងទុកដាក់ ឯកសារគួរត្រូវបានកែលម្អ ។ |
| **ភាគីភ្នាក់ងារអនុវត្តន៏អនុកិច្ចសន្យាៈ** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | មានបុគ្គលិកជំនាញ និងបទពិសោធន៏គ្រប់គ្រាន់ ។ |
| ៥ | ការអនុវត្តសកម្មភាព និងលទ្ធផលទាន់ពេលវេលា | ការអនុវត្តសកម្មភាព និងលទ្ធផល បានទាន់ពេលវេលាតាមការគ្រោងទុក ។ |
| ៦ | ការរាយការណ៍ស្តីពីការរីកចម្រើន និងការកត់ត្រាឯកសារ | ដូចតាមទម្លាប់ និងនីតិវិធីដែលបានធ្វើ ។ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | លក្ខខ័ណក្នុងកិច្ចសន្យាត្រូវបានបំពេញ ។ |
| **ភាគីរួមគ្នារវាង គ.អ.ជ.ខ និងភ្នាក់ងារអនុវត្តអនុកិច្ចសន្យាៈ** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" (ចំណុច-**ង** ផ្នែកទី**៣**) និងបញ្ហាប្រឈម | សិក្ខាកាម ២ នាក់បានបោះបង់ការសិក្សាជំនាញជួសជុលម៉ូតូ ក្នុង នោះមានៈ ម្នាក់បានបោះបង់ការសិក្សា បន្ទាប់ពីរៀនបាន ២ ខែ ដោយសារធុរៈក្នុងគ្រួសារ និងម្នាក់ទៀតបានបោះបង់ការសិក្សា មុនពេលបញ្ចប់វគ្គ ១ ខែ ដោយសារជម្ងឺ ។ |
| ៩ | ការបញ្ជ្រាបយេនឌ័រ (ចំណុច-**ច** ផ្នែកទី **៣**) | កិច្ចសន្យានេះបានផ្តល់លទ្ធផលជាវិជ្ជមាន ដល់ស្ត្រី២៦% តាមរយៈ ការលើកទឹកចិត្តឱ្យចូលរួមវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយ ស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដើម្បីបង្កើននូវចំណេះដឹង ក្នុងការធ្វើសេចក្តីសម្រេចចិត្ត មុននឹងទៅរកការងារធ្វើឆ្ងាយពី លំនៅដ្ឋាន។ ទោះបីជាភាគរយ |

| | | |
|---|---|---|
| | | ស្ត្រីតិចក៏ដោយ តែសមាសភាព ដែលបានមកចូលរួមវគ្គនេះ គឺជាតំណាងមកពីគ្រប់សមាសភាព ពាក់ព័ន្ធ ដែលមាននៅថ្នាក់មូលដ្ឋាន ភូមិ ឃុំ ដែលជារចនាសម្ព័ន្ធ ការពារផលប្រយោជន៍ដល់ស្ត្រី និងកុមារ។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ (ចំណុច- **ឆ** ផ្នែកទី**៣**) | អ្នកបណ្តុះបណ្តាលបានយកចិត្តទុកដាក់ខ្ពស់ដល់ការប៉ះពាល់នានា ទៅលើធនធានធម្មជាតិ និងបរិស្ថាន ពិសេសការគិតគូរពីសុខភាព របស់សិក្ខាកាម ដោយបានណែនាំអំពីការទុកដាក់កាកសំណល់ឱ្យ មានសណ្តាប់ធ្នាប់ និងការប្រុងប្រយ័ត្នលើសកម្មភាពនានា ដូចជា ការទុកដាក់ប្រេងសាំង ប្រេងម៉ាស៊ីន ដែលផ្លាស់ចេញពីម៉ូតូ ថ្មស្អុយសល់ពីការផ្សារជាដើម។ ការធ្វើបែបនេះ ក្នុងន័យបញ្ជៀស ឱ្យផុតពីគ្រោះថ្នាក់ ជាយថាហេតុ ឬការប៉ះពាល់ទៅលើសុខភាព របស់សិក្ខាកាម ដែលជាបរិស្ថានមនុស្ស។ |
| ១១ | ការថែរក្សា និរន្តភាព ( ចំណុច-**ជ** ផ្នែកទី **៣**) | ក្រោយពេលបញ្ចប់វគ្គ សិក្ខាកាមទាំងអស់នឹងបានទទួលកញ្ចប់សម្ភារ សម្រាប់ចាប់ផ្តើមមុខរបរដោយខ្លួនឯង។ មិនតែប៉ុណ្ណោះ ពួកគាត់នឹងទទួលបាននូវការគាំទ្របច្ចេកទេសបន្ថែម ពេលគាត់អនុវត្តសកម្មភាពជួសជុលម៉ូតូ ដោយមានការចុះពិនិត្យសាកសួរផ្ទាល់ពីជនបង្គោល និងគ្រូបង្ហាត់ ឬក៏អាចទំនាក់ទំនងតាមរយៈទូរស័ព្ទមកសុំការប្រឹក្សាយោបល់ពីគ្រូបង្ហាត់ នៅពេលដែលពួកគាត់មានចម្ងល់ ឬបញ្ហានានាពាក់ព័ន្ធទៅនឹងការជួសជុលម៉ូតូ។ |

## ២.៤. សេចក្តីសន្និដ្ឋាន ៖

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យានេះត្រូវបានអនុវត្តស្របតាមការគ្រោងទុក។ ភ្នាក់ងារអនុវត្តអនុកិច្ចសន្យាមានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ ដើម្បីអនុវត្តអនុកិច្ចសន្យានេះ។ ដូច្នេះហើយសកម្មភាព និងលទ្ធផល ដែលបានគ្រោងទុកត្រូវបានបញ្ចប់ស្របតាមផែនការការងារ និងពេលវេលា ដែលបានកំណត់។ |
| ២ | សកម្មភាពរបស់អនុកិច្ចសន្យា និងអត្ថប្រយោជន៍ ដែលអ្នកទទួលផលទទួលបាន ត្រូវបានអ្នកទទួលផល និងអ្នក មិនទទួលផលសាទរក្នុងភូមិ ឃុំ ដែលគម្រោងបានអនុវត្ត ហើយដែលក្រុមការងារបានទស្សនកិច្ចនៅក្នុងកំឡុង ពេលធ្វើការវាយតម្លៃ។ ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាសម្រេចបាន ៩៨.៥៨ %។ ភស្តុតាងអំពីលទ្ធផល និងផលប្រយោជន៍ ដែលទទួលបាន នៅតែត្រូវបានសង្កេតឃើញ បន្ទាប់ពីបញ្ចប់អនុកិច្ចសន្យាអស់រយៈពេល ១ ឆ្នាំ ទៅហើយ គឺអ្នកទទួលផលបានសង់រោង ឬ តូបតូចៗ សម្រាប់ជួសជុលម៉ូតូ។ ដូចនេះអនុកិច្ចសន្យានេះបាន ទទួលនូវនិរន្តរភាព ក្នុងសកម្មភាពរបស់ខ្លួនក្នុងកម្រិតខ្ពស់។ ម្យ៉ាងទៀត គម្រោងនេះបានចូលរួមចំណែកកាត់ បន្ថយភាពក្រីក្រក្នុងកម្រិតតិចតួច ទៅនឹងគោលដៅក្នុងការកាត់បន្ថយភាពក្រីក្រ។ **អ្នកទទួលផល៨៧%** បានយកចំណេះដឹង និងជំនាញជួសជុលម៉ូតូទៅធ្វើអាជីវកម្ម។ |
| ៣ | ការជ្រើសរើសសិក្ខាកាម ដែលជាអ្នកទទួលផលនៅក្នុងអនុកិច្ចសន្យាដោយភាគីអនុវត្តគម្រោងផ្ទាល់ នឹងធ្វើឱ្យ មានការធានាថាអ្នកដែលមានតម្រូវការខ្លាំងបំផុតនឹងទទួលបានផលប្រយោជន៍ពីអនុកិច្ចសន្យា។ |
| ៤ | មិនមានឧបសគ្គ និងបញ្ហាចម្បង ដែលអាចចៀសវាងបាន គួរឱ្យកត់សំគាល់ទេ។ |

<u>ចំណុចរៀនសូត្រ៖</u>

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | អត្ថប្រយោជន៍របស់អនុកិច្ចសន្យា និងនិរន្តរភាពរបស់លទ្ធផល នៅក្នុងអនុកិច្ចសន្យា ត្រូវបានសម្រេចជោគជ័យ ប្រសិនបើអនុកិច្ចសន្យាត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ក្រុមគោលដៅ ដែលជាអ្នកទទួលផល។ |
| ២ | ការបរិយាយច្បាស់លាស់នូវ "គោលបំណងបន្ទាន់" (ចំនុច ខ ផ្នែកទី៣) ក្នុងកម្រិត ដែលអាចវាស់វែងបានជា ប្រការសំខាន់បំផុត សម្រាប់ការកត់ត្រាទុកនូវលទ្ធផលរបស់អនុកិច្ចសន្យា និងផលប្រយោជន៍ដែលមានដើម្បី ជួយសម្រួលដល់ការវាយតម្លៃលទ្ធផល និងគោលបំណងបន្ទាន់នៃអនុកិច្ចសន្យា។ |

| | |
|---|---|
| ៣ | ការបរិយាយច្បាស់លាសនូវ "ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា" (ចំនុច **គ** ផ្នែកទី**៣**) ជាការសំខាន់សម្រាប់ ធ្វើការឆ្លុះបញ្ចាំងនូវសមិទ្ធផល ដែលសម្រេចបាននៅក្នុងកម្រិតអត្ថប្រយោជន៍របស់លទ្ធផល ដែលអាចកើតមានឡើង។ |

អនុសាសន៍ :

| ល.រ | អនុសាសន៍ |
|---|---|
| ១ | នៅពេលជ្រើសរើសក្រុមគោលដៅ គួរបន្តការជ្រើសរើសអ្នកទទួលផលឱ្យបានសមស្របតាមលក្ខណៈវិនិច្ឆ័យ/គោលការណ៍ ឬលើកកម្ពស់ដល់ គ្រួសារស្ត្រីមេម៉ាយ ឬស្ត្រីជាមេគ្រួសារទីទាល់ក្រ ហើយមានកូនតូចៗ។ |
| ២ | គួរបរិយាយឱ្យច្បាស់លាស់នូវ "គោលបំណងបន្ទាន់" ក្នុងកម្រិតមួយអាចវាស់វែងបាន ជាការសំខាន់សម្រាប់ការកត់ត្រាទុកនូវលទ្ធផលរបស់អនុកិច្ចសន្យា និងផលប្រយោជន៍ ដែលមាន ដើម្បីជាការវាយតម្លៃលទ្ធផល។ |
| ៣ | គួរបរិយាយឱ្យច្បាស់លាស់នូវស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា សម្រាប់ធ្វើការឆ្លុះបញ្ចាំងនូវសមិទ្ធផល ដែលសម្រេចបាននៅក្នុងកម្រិតលទ្ធផល និងស្ថានភាពចុងបញ្ចប់ ឬផលប៉ះពាល់ដែលអាចកើតមានឡើង។ |

**ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍៖**

**ឯកសារដែលត្រូវភ្ជាប់ទី១ ៖ បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបានពិនិត្យ**

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) | មាន (៣) |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និង ឯកសារវិសោធនកម្ម (ប្រសិនមាន) | √ |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ | √ |
| ៣ | របាយការណ៍ត្រួតពិនិត្យគម្រោង | √ |
| ៤ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | √ |
| ៥ | លិខិតឆ្លើយឆ្លងរវាងភ្នាក់ងារអនុវត្តន៍ និងគណៈកម្មាធិការប្រត្តិបត្តិគ.អ.ជ.ខ | √ |
| ៦ | បញ្ជីវគ្គបណ្តុះបណ្តាលដែលមានក្នុងអនុកិច្ចសន្យា | √ |
| ៧ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា | √ |
| ៨ | ឯកសារដ៏ទៃទៀតរួមមាន ៖ រូបភាពនៃគម្រោង (អនុកិច្ចសន្យា) ដែលទុកនៅ គ.ប្រ/គ.អ.ជ.ខ និងនៅមន្ទីររបស់ភ្នាក់ងារអនុវត្តន៍ ដែលមិនបានរៀបរាប់ខាងលើ | √ |
| ៩ | ផ្សេងទៀត | |

## ឯកសារដែលត្រូវភ្ជាប់ទី២: បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាសន៍/ជួបពិភាក្សា

| ល.រ | ថ្ងៃខែ | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា | ទីកន្លែង | ឧបករណ៍ប្រើសម្រាប់ប្រមូល ទិន្នន័យដែលបានប្រើ |
|---|---|---|---|---|
| ១ | ២២ កញ្ញា | លោក ហ៊ន់ ហ៊ាន ទីប្រឹក្សាត្រួតពិនិត្យ វាយតម្លៃ និងវិស័យ ប្រចាំខេត្តព្រៃវែង | ការិយាល័យ គ.ប្រ | សម្ភាសន៍ស៊ីជម្រៅ |
| ២ | ២២ កញ្ញា | លោក ហែម ហឿន ប្រធានមន្ទីរ/ប្រធានគម្រោង/មន្ត្រីអនុម័ត | មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | សម្ភាសន៍ស៊ីជម្រៅ (ភ្នាក់ងារអនុវត្ត) |
| ៣ | ២២ កញ្ញា | លោក តឹក ចាន់ថា មន្ត្រីបង្គោល | មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | សម្ភាសន៍ស៊ីជម្រៅ (ភ្នាក់ងារអនុវត្ត) |
| ៤ | ២២ កញ្ញា | លោក យ៉ន ថេត គ្រូបណ្តុះបណ្តាល ជំនាញជួសជុលម៉ូតូ | មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | សម្ភាសន៍ស៊ីជម្រៅ (ភ្នាក់ងារអនុវត្ត) |
| ៥ | ២៣ កញ្ញា | ក្រុមអ្នកទទួលផល | វត្តស្វាយបូព្រឹក ឃុំជាខ្លាង | សម្ភាសន៍ជាក្រុម |
| ៦ | ២៣ កញ្ញា | លោក សេង វណ្ណា អ្នកទទួលផលផ្ទាល់ | ភូមិ ថ្កូវ ឃុំដីរីពួន ស្រុកស្វាយអន្ទរ | សម្ភាសន៍ស៊ីជម្រៅ /ករណីសិក្សា |
| ៧ | ២៣ កញ្ញា | លោក ប៉េ ជីវ៉ា អ្នកមិនទទួលផល | ភូមិ ថ្កូវ ឃុំដីរីពួន ស្រុកស្វាយអន្ទរ | សម្ភាសន៍ស៊ីជម្រៅ/ ករណីសិក្សា |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | 15/AGR/0901-00 (NRML) |
| ចំណងជើង : | **ពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ និងសុវត្ថិភាពស្បៀង និងបង្កើនប្រាក់ចំណូល** |
| ភ្នាក់ងារអនុវត្តន៍ : | មន្ទីរកសិកម្មខេត្តពោធិ៍សាត់ |
| រយៈពេល (ចាប់ផ្តើម និងបញ្ចប់) | **01 / 03 / 2009 ដល់ 31/ 12 /2009** |
| រាជធានី ខេត្ត | ពោធិ៍សាត់ |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរកសិកម្មខេត្តពោធិ៍សាត់ |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ/គ.អ.ជ.ខ | **$ 17,100.00** |
| ការរួមចំណែករបស់រាជធានី ខេត្ត | **$ 00** |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៍ | **$ 300.00** |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | **$ 17,400.00** |

## ក្រុមវាយតម្លៃ និងរៀបចំរបាយការណ៍

| ឈ្មោះ | មុខតំណែងដើម | តួនាទីក្នុងក្រុមវាយតម្លៃ |
|---|---|---|
| លោក **ជួប គឹមឡេង** | អនុប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា | ប្រធានក្រុម |
| លោក **ហ៊ើរ ចាន់ដារ៉ា** | មន្ត្រីត្រួតពិនិត្យវាយតម្លៃ មន្ទីរកសិកម្ម | សមាជិក |
| លោក **ឈុន ធារ៉ា** | មន្ត្រីត្រួតពិនិត្យវាយតម្លៃ មន្ទីរផែនការ | សមាជិក |
| លោក **ខិម យ៉ារិន** | ទីប្រឹក្សាត្រួតពិនិត្យវាយតម្លៃ និងវិស័យ | ទីប្រឹក្សាគាំទ្រ |

## ខេត្តពោធិ៍សាត់

**កាលបរិច្ឆេទ : ២៥ តុលា ២០១០**

# មាតិកា


| | | |
|---|---|---|
| | **អក្សរកាត់** | ៣ |
| | **របាយការណ៍សង្ខេប** | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៨** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៨ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៨ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៨ |
| ១.៤ | សំណួរវាយតម្លៃ | ៩ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ៩ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ១០ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១១** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១) | ១១ |
| | - លទ្ធផលទី១: | ១១ |
| | - លទ្ធផលទី២: | ១៣ |
| | - លទ្ធផលទី៣: | ១៤ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម (សំណួរវាយតម្លៃទី៣) | ១៥ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤) | ២១ |
| ២.៤ | សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី៥) | ២៦ |
| | **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍** | **២៨** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ២៨ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍/ពិភាក្សា | ២៩ |
| | **ករណីសិក្សា** | **១៩** |
| ទី១- | " ជីវភាពរស់នៅមានភាពប្រសើរ " លោក ឃុន សោមអ្នកទទួលផល | ១៩ |
| ទី២- | អ្នកមិនទទួលផល | ២០ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

**គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ :**

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ សហការណ៏ជាមួយទីប្រឹក្សាត្រួតពិនិត្យវាយតម្លៃ និង វិស័យ ខេត្តពោធិ៍សាត់ បានធ្វើការវាយតម្លៃអនុកិច្ចសន្យា ដែលមានចំណងជើងថា "**ពង្រឹងការគ្រប់គ្រង ធនធានធម្មជាតិ និងសុវត្ថិ ភាពស្បៀង និងបង្កើនប្រាក់ចំណូល**" លេខ: 15/AGR/0901-00 (NRML) ដែលជាអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ ខេត្តពោធិ៍សាត់ និងមន្ទីរកសិកម្ម។ នេះជាផ្នែកមួយ នៃគំរោង ពង្រឹងសមត្ថភាពគ្រូបង្គោល នៅថ្នាក់ក្រោមជាតិ របស់ផ្នែកត្រួតពិនិត្យវាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ លេខាធិការដ្ឋាន គ.ជ.អ.ប ដែលគាំទ្រដោយកម្មវិធី អភិវឌ្ឍន៏ តាមបែបប្រជាធិបតេយ្យតាមរយៈ វិមជ្ឈការ និង វិសហមជ្ឈការ ។

**គោលបំណង នៃការវាយតម្លៃគឺ:**

១) ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធិផលនៃអនុកិច្ចសន្យា និងចំនុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំង កត់ត្រានូវ ចំណុចរៀនសូត្រ ដែលបានមក ពីការវាយតម្លៃ និងចំនុចដែលត្រូវកែលម្អក្នុងពេលអនាគតជាប្រពន្ធ័ដើម្បីពង្រឹងនូវចំនេះ ដឹង និងចំនេះធ្វើ របស់មន្ត្រី គណៈកម្មាធិការប្រត្តិបត្តិ នៃគ.អ.ជ.ខ ក្នុងការវាយតម្លៃ អនុកិច្ចសន្យា នៅថ្នាក់ក្រោមជាតិ។

២) ដើម្បីពង្រឹងរបៀបធ្វើការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត។ ដំណើរការនៃការវាយតម្លៃផ្អែកទៅលើការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំណត់ ហេតុប្រជុំ របាយការណ៏បញ្ចាប់កិច្ចសន្យា របាយការណ៏ហិរញ្ញវត្ថុ របាយការណ៏វគ្គបណ្តុះបណ្តាល និងរាល់ឯកសារ ដែលពាក់ព័ន្ធ ដែលមាននៅក្នុងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃគ.ប្រ ភ្នាក់ងារអនុវត្តន៏។ ក្រុមការងារវាយតម្លៃ បានរៀបចំការសម្ភាសន៏ស៊ីជំរៅ ពិភាក្សាជាក្រុម ការចុះដល់មូលដ្ឋាន និងរំលឹកឯកសា អនុកិច្ចសន្យា ឡើងវិញ។

ដំណើរការនៃការវាយតម្លៃបានដំណើរការទៅតាមជំហានដែលនឹងសង្ខេបដូចតទៅ: ដើម្បីដំណើរការវាយតម្លៃ នេះ ក្រុមការងារត្រូវបានបង្កើតឡើងដោយមានការតែងតាំងពី គ.ប្របន្ទាប់មកក្រុមការងារនេះបានរៀបចំការប្រជុំ ដើម្បីពិភាក្សាជ្រើសរើសទីតាំងដែលត្រូវសម្ភាសន៏ ចំនួនកសិករ កំណត់គម្រោងសកម្មភាព ប្រធានបទនៃការ វាយតម្លៃ ក្នុងនោះដែរក្រុមបាកំណត់វិធីសាស្ត្រក្នុងការវាយតម្លៃដូចជា : ពិភាក្សាជាក្រុម សម្ភាសន៏ស៊ីជម្រៅ

នៅមូលដ្ឋាន ករណី សិក្សា និងពិនិត្យឯកសារដែលមានស្រាប់រួមមានរបាយការណ៍ប្រចាំខែ កំណត់ហេតុប្រជុំ របាយការណ៍ បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធដែលមាននៅក្នុងផ្នែករដ្ឋបាល និង គ្រប់គ្រងកិច្ចសន្យានៃគ.ប្រ។ ក្រោយពីការសម្ភាសន៍ ប្រមូលព័ត៌មាននៅមូលដ្ឋានរួចហើយ ដើម្បីវិភាគទិន្នន័យដែល ប្រមូលទាំងនេះ និងផ្តល់អនុសាសន៍សម្រាប់ការអនុវត្តគម្រោងបន្តហើយបានរៀបចំចងក្រងជាសេចក្តីព្រាងដោយ វាយតម្លៃ។ ក្រុមការងារបានរៀបចំការប្រជុំដើម្បីវិភាគលើទិន្នន័យដែលប្រមូលបានទាំងនេះ និងផ្តល់អនុសាសន៍ដល់ ការអនុវត្តគម្រោង និងចងក្រងជាសេចក្តីព្រាងរបាយការណ៍។ បន្ទាប់មកក្រុមការងារបានរៀបចំការប្រជុំម្តងទៀតជា មួយភ្នាក់ងារអនុវត្ត និងអ្នកពាក់ព័ន្ធដើម្បីបង្ហាញពីលទ្ធផលនៃការវាយតម្លៃ។

លទ្ធផលសង្ខេបមានដូចខាងក្រោមៈ

**១-សកម្មភាពទាំងអស់ត្រូវអនុវត្ត និងលទ្ធផលសំរេច តាមផែនការ**

| ល.រ | **សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣:ការបរិយាយអំពីអនុកិច្ចសន្យា** | **អ្វីដែលសំរេចបានជាក់ស្តែង** |
|---|---|---|
| ១ | បណ្តុះបណ្តាល និងបង្ហាញពីការផលិតពូជស្រូវ (២៦វគ្គ/ បង្ហាញ៥២កន្លែង) | កសិករចូលរួមចំនួន៥២០នាក់ ក្នុងនោះស្រី ៣៥៥នាក់ |
| ២ | បណ្តុះបណ្តាល និងបង្ហាញប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិប.វ.ស (១៦វគ្គ/កសិករ៣២០នាក់/ស្រី១៨៥នាក់/បង្ហាញ១៦កន្លែង) | កសិករចូលរួមចំនួន៣២០នាក់ ក្នុងនោះស្រី ២៣២ នាក់ |
| ៣ | បណ្តុះបណ្តាល និងបង្ហាញការប្រើប្រាស់ថ្នាំពុលធម្មជាតិលើដំណាំបន្លែ (១០វគ្គ/កសិករ២០០នាក់ស្រី១២៤នាក់/បង្ហាញ១០កន្លែង) | កសិករចូលរួមចំនួន២០០នាក់ក្នុងនោះស្រី ១៤៥នាក់ |
| ៤ | បណ្តុះបណ្តាល និងបង្ហាញ សុវត្ថិភាពការប្រើប្រាស់ថ្នាំពុល កសិកម្មលើដំណាំស្រូវ (៨វគ្គ/កសិករ១៦០នាក់/ស្រី៨៥នាក់/បង្ហាញ៨កន្លែង) | កសិករចូលរួម១៦០នាក់ ក្នុងនោះស្រី៨៥នាក់ |
| ៥ | ការបណ្តុះបណ្តាល និងធ្វើជីកំប៉ុស្តិ៍(៨វគ្គ/កសិករ២៤០នាក់/បង្ហាញ៨កន្លែង) | កសិករចូលរួម២៤០នាក់ក្នុងនោះស្រី ១៤៦ នាក់ |
| ៦ | ពង្រឹងភ្នាក់ងារសុខភាពសត្វភូមិឱ្យទៅជាភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ | អ្នកចូលរួមចំនួន ១១៥ នាក់ ក្នុងនោះស្រី ២ នាក់ |

| |
|---|
| ២- វគ្គបណ្ដុះបណ្ដាលពីបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ និងការបង្ហាញដោយប្រើប្រាស់ជីធម្មជាតិ និងកាត់បន្ថយការប្រើប្រាស់ ជីគីមីព្រោះវត្ថុធាតុដើមនៃការធ្វើជីកំប៉ុស្តិ៍ កសិករអាចរកនៅក្នុងមូលដ្ឋានរបស់គាត់បានដូចជា : លាមកសត្វគ្រាប់មុខ ស្លឹកឈើ កាកសំណល់ផ្ទះបាយ ចំបើង។ល។ វាអាចកាត់បន្ថយការចំណាយក្នុងការទិញជីគីមីបានមួយក៏រិតធំហើយម្យ៉ាងទៀតវាអាច ប្រើជាមួយដំណាំស្រូវ បន្លែផ្សេងៗ គឺវារក្សានូវគុណភាពដី និងរក្សាគុណភាពក្លិននៃគ្រាប់អង្ករ និងកាត់បន្ថយជំងឺផ្សេងៗ ដែលបង្កឡើងដោយសារជីគីមី ។<br>៣- លទ្ធផលបន្ទាន់ និងផលប្រយោជន៍នៃវគ្គបណ្ដុះបណ្ដាលផលិតពូជស្រូវ. និងបង្ហាញប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ ធម្មជាតិប.វ.ស. ថ្នាំពុលធម្មជាតិលើដំណាំបន្លែ ថ្នាំពុលកសិកម្មលើដំណាស្រូវ ពង្រឹងភ្នាក់ងារសុខភាព សត្វភូមិឱ្យទៅជាភ្នាក់ងារ ផ្សព្វផ្សាយកសិកម្មភូមិ ពិបាក និងវាយតម្លៃណាស់ ព្រោះយើងគ្មានពតិមានមូលដ្ឋាន ។<br>៤- ជារួមអនុកិច្ចសន្យាសំរេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាសំរេចបាន ១០០% ។<br>៥-អនុកិច្ចសន្យាពិតជាបានចូលរួមចំណែកក្នុងការសំរេចនូវគោលបំណងបន្ទាន់ ដោយសារកសិករបានអនុវត្តបច្ចេកទេសថ្មី ដែល ទទួលបានពីវគ្គបណ្ដុះបណ្ដាល និងការបង្ហាញ ផលិតផលកសិកម្ម និង ពីបច្ចេកទេសផលិតពូជស្រូវទិន្នផលខ្ពស់ ធ្វើជីកំប៉ុស្តិ៍ ការដាំបន្លែ ប្រព័ន្ធប្រពលវប្បកម្ម តាមគោលការណ៍ធម្មជាតិ និងការចិញ្ចឹមសត្វ ដោយមានការបង្ហាញដល់កសិករ ពីការប្រើប្រាស់ ថ្នាំធម្មជាតិ និង ថ្នាំគីមីប្រកបដោយសុវត្ថិភាព គឺជាការរួមចំណែកមួយយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងជួយលើកស្ទួយ ជីវភាពរបស់ ប្រជាជន និងពង្រឹង/ពង្រីក ធនធានមនុស្ស ដូចជាការការពារតាមរយៈការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ក៏ដូចជាប្រកបរបរកសិកម្មដើម្បីឱ្យមាននិរន្តរភាព និង បានកើនឡើងជាលំដាប់ ។ |
| **សេចក្តីសន្និដ្ឋាន :**<br>១ លទ្ធផល និងអត្ថប្រយោជន៍ដែលបានពីការអនុវត្តកិច្ចសន្យា ជាប្រយោជន៍ដល់សហគមន៍ និងមានភ័ស្តុតាងបង្ហាញច្បាស់លាស់ ហើយត្រូវបានទទួលការសារទរ ពីអ្នកទទួលផល និងមិនទទួលផល នៅក្នុងឃុំ នៃគំរោង ។ ឧទាហរណ៍ ការបង្ហាញធ្វើជីកំប៉ុស្តិ៍ និងលទ្ធផល បានពីការប្រើប្រាស់ជីលើដំណាំស្រូវ និងបន្លែផ្សេងៗ គឺវាអាចជួយក្នុងការសន្សំសំចៃក្នុងគ្រួសារ ក្នុងការទិញជីគីមី និងការកើនឡើងនូវប្រាក់ចំណូល ជាលទ្ធផលសម្រេចបានពីវគ្គបណ្ដុះបណ្ដាលពីបច្ចេកទេសធ្វើជីកំប៉ុស្តិ៍នៅក្នុងអនុកិច្ចសន្យា។ លើសពីនេះទៀត ពួកគាត់បានបន្តសកម្មភាពទាំងនេះ ទោះបីជាគម្រោងត្រូវបញ្ចប់យូរទៅហើយក៏ដោយ ។ ជាពិសេសទៀត នោះ តម្រូវការវគ្គបណ្ដុះបណ្ដាលស្រដៀងគ្នានេះបន្តទៀតបន្ទាប់ពីការអនុវត្តសកម្មភាពគម្រោង ។<br>២ គួរមានការគាំទ្រគម្រោងបែបនេះ ក៏ដូចជាការពង្រឹងសកម្មភាពគម្រោងរបៀបនេះបន្តទៀត ។ |

៣ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីធ្វើឱ្យសម្រេចបាននូវអត្ថប្រយោជន៍ក្នុងកំរិតខ្ពស់ ភ្នាក់ងារអនុវត្តគម្រោងគួរជ្រើសរើស អ្នកទទួលផលឱ្យបានសមស្រប ។

៤ ដើម្បីពង្រឹងនូវគុណភាព និងភាពទាក់ទងរបស់គម្រោង គួរមានការបរិយាយឱ្យបានច្បាស់លាស់ នូវស្ថានភាពចុងបញ្ចប់ នៃកិច្ចសន្យា និងគោលបំណងបន្ទាន់របស់គម្រោង ។

៥ ផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យាគួរធ្វើការវាយតម្លៃអនុកិច្ចសន្យាឱ្យបាន ១ ឬ២ អនុកិច្ចសន្យាក្នុង ១ ឆ្នាំ ។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្ដីផ្ដើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្ដល់ថវិកាតាមរយៈ គ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និងគម្រោង ដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ នៅក្នុងឆ្នាំ ២០១០នេះ ដោយមានការគាំទ្រ ទាំងថវិកា និងបច្ចេកទេស ពីផ្នែកត្រួតពិនិត្យវាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប ផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ នៃគ.អ.ជ.ខ បានអនុវត្តការវាយតម្លៃអនុកិច្ចសន្យា ដែលបានរៀបចំរួមគ្នាជាមួយមន្ទីរកសិកម្មខេត្តដែលជាភ្នាក់ងារអនុវត្តអនុកិច្ចសន្យាលេខ : **15 / AGR / 0901-00** ស្ដីពីការ **ពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ និងសុវត្ថិភាពស្បៀង និងបង្កើនប្រាក់ចំណូល។** ដំណើរការ លទ្ធផលដែលបានរកឃើញ និងការសន្និដ្ឋាន នៃការវាយតម្លៃត្រូវបានកត់ត្រា ហើយនឹងបង្ហាញតាមរយៈរបាយការណ៍ស្ដីពីការវាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

កិច្ចសន្យានេះត្រូវបានរៀបចំ ដើម្បីគាំទ្រដល់មន្ទីរកសិកម្មខេត្ត ក្នុងការអនុវត្តរាល់សកម្មភាពគ្រប់ផ្នែកលើការអភិវឌ្ឍវិស័យកសិកម្ម។ ធ្វើយ៉ាងណាឱ្យប្រជាកសិករយល់ដឹងពីបច្ចេកទេសកសិកម្ម ការដាំដុះ ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រីក្នុងស្រែ ការធ្វើជីកំប៉ុស្ដិ៍ ពង្រឹងភ្នាក់ងារពេទ្យសត្វភូមិ និងការការពារមច្ឆាជាតិឱ្យបានល្អប្រសើរ និងធ្វើឱ្យផលិតផលកសិកម្មរបស់កសិករបានទទួលនូវបរិមាណច្រើន និងគុណភាព ល្អធានាការហូបចុកពេញមួយឆ្នាំ និងអាចប្រកួតប្រណាំងលើទីផ្សារ។ គោលដៅនេះនឹងរួមចំណែកដល់ទិសដៅរបស់កម្មវិធីជាតិគឺស្ថាប័នពាក់ព័ន្ធគ្រប់ថ្នាក់ ត្រូវបានពង្រឹង និង អនុវត្ត ប្រព័ន្ធវិមជ្ឈការ និង វិសហមជ្ឈការ ប្រកបដោយប្រសិទ្ធភាព។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

**គោលបំណង** គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូល ដោយផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និងតម្លាភាព។ ដូច្នេះ ទំហំនៃការវាយតម្លៃមានដែនកំណត់តាមទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខ័ណ្ឌការងារនៃការវាយតម្លៃ។ គោលបំណង នៃការវាយតម្លៃគឺ: **ក)** ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធិផលនៃអនុកិច្ចសន្យា និងចំនុចខ្លាំងខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំងកត់ត្រានូវ ចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត និង **ខ)** ដើម្បីពង្រឹង

របៀបធ្វើការវាយតម្លៃគម្រោងរបស់គ.ប្រនៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្តគម្រោងផ្សេងៗ ទៀត។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

**វិធីសាស្ត្រ និងឧបករណ៍ដែលបានប្រើៈ**

១) ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំនត់ហេតុប្រជុំ និងរបាយការណ៍បញ្ចាប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និង ការចុះប្រមូលពិតមានទិន្នន័យពីអ្នកទទួលផលដល់មូលដ្ឋាន និងទីតាំងគម្រោង។

២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័តិមានសំខាន់ៗ រួមមានៈ អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផលផ្ទាល់ ១នាក់ និងមិនផ្ទាល់ ១នាក់ និងអ្នកពាក់ព័ន្ធ ៨នាក់។ ហើយបានពិគ្រោះជាមួយនឹងអនុប្រធានមន្ទីរកសិកម្មទទួលបន្ទុកកិច្ចសន្យា ប្រធានការិយាល័យផ្សព្វផ្សាយកសិកម្ម និងទីប្រឹក្សាត្រួតពិនិត្យវាយតម្លៃទៅលើបញ្ហាយេនឌ័រ និងគ្រប់គ្រងធនធានធម្មជាតិ សម្រាប់បញ្ហាពាក់ពន្ធ័វិស័យកសិកម្ម ។

៣) ចុះពិនិត្យតំបន់អនុវត្តន៏គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភ័ស្តុតាងគម្រោងដោយផ្ទាល់។

៤) <u>វិភាគទិន្នន័យ និងបកស្រាយៈ</u> ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើត្រូវបានធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់។

៥) បានរៀបចំការប្រជុំនៅថ្ងៃទី ២៩ ខែ តុលា ឆ្នាំ២០១០ដើម្បីបង្ហាញនិងផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងផ្តល់អនុសាសន៏។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះត្រូវបានធ្វើឡើង ដោយក្រុមវាយតម្លៃដែលបានចាត់តាំងដោយ គ.ប្រ និងមានការចូលរួមពីអ្នកអនុវត្តផ្ទាល់ អ្នកពាក់ព័ន្ធផ្ទាល់ និង មិនផ្ទាល់ក្នុងអនុកិច្ចសន្យា និងមានកិច្ចសហការណ៍ ផ្តល់យោបល់ពីទីប្រឹក្សាត្រួតពិនិត្យវាយតម្លៃ ។ទោះជាយ៉ាងណាក៏ដោយការប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃ មានភាពរលូន លទ្ធផលអាចទទួលយកបាន ។

២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត : វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោង នៅពេលដែលអ្នកវាយតម្លៃនៅមានជំនាញខ្វះខាត និងបទពិសោធន៍ពីមុនមក។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណង សំខាន់ គឺដើម្បីរៀនធ្វើដោយការអនុវត្តផ្ទាល់។ អ្នកវាយតម្លៃ បានទទួលការគាំទ្រ ដោយមានគោលការណ៍ណែនាំ ឧបករណ៍ និងវគ្គបណ្តុះបណ្តាល ដែលពាក់ព័ន្ធដើម្បីដោះស្រាយ បញ្ហាទាំងអស់នេះ។

៣) ដោយយើងមិនមានសូចនាករបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍" ដែលជាកម្រិតអត្ថប្រយោជន៍ទៅលើគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និង កម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។

៤)ដោយពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិតទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ។ យើងបានជ្រើសរើសតែលទ្ធផលមួយជាសំណាក សម្រាប់ការចុះវាយតម្លៃ នៅមូលដ្ឋាន គឺកសិករទទួលបានការបណ្តុះបណ្តាលពី **កម្មវិធីបង្កើនគុណភាពដី** និង*សកម្មភាពៈ* **ការបណ្តុះបណ្តាលនិងធ្វើដី កំប៉ុស្តិ៍(៨វគ្គ/កសិករ២៤០នាក់/បង្ហាញ ៨ កន្លែង)** មកធ្វើការវាយតម្លៃ តាមរយៈការសម្ភាសន៍ស៊ីជម្រៅក្រុម ពិភាក្សា និងការចុះពិនិត្យផ្ទាល់ដល់តំបន់អនុវត្តគម្រោង ។

**<u>ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធន៍:</u>**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះអនុកិច្ចសន្យាលេខ: **15 / AGR / 0901-00** និងដែនកំណត់ ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ។

២) ការវាយតម្លៃនេះលម្អិតតែទៅលើ *លទ្ធផលទី៣:* **កម្មវិធីបង្កើនគុណភាពដី** និង *សកម្មភាព:***ការបណ្តុះបណ្តាលនិងធ្វើដីកំប៉ុស្តិ៍(៨វគ្គ/កសិករ២៤០នាក់/បង្ហាញ ៨កន្លែង)** ដែលជាសកម្មភាពនៃអនុកិច្ចសន្យា ។

៣) ការវាយតម្លៃនេះផ្តោតទៅលើភ្នាក់ងារអនុវត្ត និងអ្នកទទួលផលហើយមិនមែនជាការវាយតម្លៃទៅលើ គ.ប្រ នៃគ.អ.ជ.ខ និង គ.ជ.អ.ប ទេ។

ហេតុដូច្នេះ របាយការណ៍នៃការវាយតម្លៃ លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ដែលបានលើកឡើង ត្រូវ ពិនិត្យដោយយោលទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ។

# ២: លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរនៃការវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១)

**លទ្ធផលទី១ : ការបង្ហាញផ្នែកក្សេត្រសាស្ត្រ (ឈើហូបផ្លែ ស្រូវ បន្លែ ដំណាំ)**

**ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ**

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង(៣) |
|---|---|---|
| ១.១ | • បណ្តុះបណ្តាលនិងបង្ហាញពីការផលិតពូជស្រូវ (២៦វគ្គ/បង្ហាញ៥២កន្លែង) | • បណ្តុះបណ្តាល និងបង្ហាញពីការផលិតពូជស្រូវ ៥២ កន្លែង ២៦វគ្គ ដល់ កសិករ ចំនួន ៥២០នាក់ ក្នុងនោះស្រី ៣៩៥នាក់ |
| ១.២ | • បណ្តុះបណ្តាល និងបង្ហាញប្រព័ន្ធប្រពលវប្បកម្ម ស្រូវតាមគោលការណ៍ធម្មជាតិ ប.វ.ស (១៦វគ្គ/កសិករ៣២០នាក់/ស្រី១៨៥នាក់/ បង្ហាញ១៦កន្លែង) | • បណ្តុះបណ្តាលនិងបង្ហាញអំពីប្រព័ន្ធប្រពលវប្បកម្ម ស្រូវតាមគោលការណ៍ធម្មជាតិ ១៦កន្លែង ដល់កសិករចំនួន ៣២០នាក់ ក្នុងនោះស្រី ២៣២ នាក់ |
| ១.៣ | • បណ្តុះបណ្តាល និងបង្ហាញការប្រើប្រាស់ ថ្នាំពុល ធម្មជាតិលើដំណាំបន្លែ (១០វគ្គ/កសិករ២០០នាក់ ស្រី១២៤នាក់/បង្ហាញ១០កន្លែង) | • បណ្តុះបណ្តាលនិងបង្ហាញការប្រើប្រាស់ថ្នាំពុលធម្មជាតិ លើដំណាំបន្លែ ១០កន្លែងដល់កសិករ ចំនួន២០០នាក់ ក្នុងនោះស្រី ១៤៥នាក់ |
| ១.៤ | • បណ្តុះបណ្តាល និងបង្ហាញ សុវត្ថិភាពការប្រើ ប្រាស់ថ្នាំពុលកសិកម្ម លើដំ ណាំ ស្រូវ (៨វគ្គ/ កសិករ១៦០នាក់/ស្រី៨៥នាក់ / បង្ហាញ៨កន្លែង | • បណ្តុះបណ្តាល និង បង្ហាញ៨កន្លែង អំពីសុវត្ថិភាពការ ប្រើ ប្រាស់ថ្នាំពុលកសិកម្ម លើ ដំណាំស្រូវ ដល់កសិករ ១៦០នាក់ក្នុងនោះស្រី៨៥នាក់ ។ |

## ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល

អនុកិច្ចសន្យានេះសម្រេចបាន ១០០%ធៀបនឹងលទ្ធផល និងកម្មភាពក្នុងអនុកិច្ចសន្យាដែលបានគ្រោងទុក។ តាមការវិភាគនូវលទ្ធផលខាងលើនេះកសិករបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលបច្ចេកទេសផ្នែកក្សេត្រសាស្ត្រ រួមមានការផលិតពូជស្រូវ ប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ ការប្រើប្រាស់ថ្នាំពុលធម្មជាតិលើដំណាំ បន្លែ និងសុវត្ថិភាពការប្រើប្រាស់ថ្នាំពុលធម្មជាតិកសិកម្មលើដំណាំស្រូវ ហើយពួកគាត់បានយកចំណេះដឹង និងជំនាញដែលបានរៀននេះ យកទៅអនុវត្តសម្រាប់កែលម្អជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ ។ អ្វីដែលគួរកត់សំគាល់គឺ ទោះបីជាវគ្គបណ្តុះបណ្តាលត្រូវបានបញ្ចប់ ប៉ុន្តែការអនុវត្តរបស់ពួកគាត់នៅតែបន្ត។ សកម្មភាពនេះបានឆ្លុះបញ្ចាំងអំពីវិធីសាស្ត្រ គុណភាព និងអកប្បកិរិយារបស់គ្រូបណ្តុះបណ្តាលដែលអាចធ្វើឱ្យកសិករ មានការចាប់អារម្មណ៍ងាយយល់ អំពីអត្ថប្រយោជន៍នៃប្រធានបទដែលបានបង្រៀន ដែលក្នុងនោះមានការបំផុសគំនិត ប្រើផ្ទាំងរូបភាព ក្រុមពិភាក្សា ការអនុវត្តផ្ទាល់តែម្តង ...។ ល។ គ្រូបណ្តុះបណ្តាលអាចបន្សាំខ្លួនទៅនឹងស្ថានភាព នៅក្នុងសហគមន៏បានល្អ ដើម្បីឱ្យមានការចូលរួមរបស់សិក្ខាកាមបានច្រើន និងស្និទ្ធស្នាល ។

- សរុបសេចក្តីមកការបើកវគ្គបណ្តុះបណ្តាលគឺមានភាពទាក់ទិនទៅនឹងតម្រូវការរបស់សិក្ខាកាម និងសហគមន៏ ។ អ្វីដែលល្អប្រសើរជាងនេះទៀត គឺអ្នកចូលរួមក្នុងការក្រេបយកចំណេះដឹង និងជំនាញដែលបានទទួលនោះវារួម ចំណែកក្នុងការកាត់បន្ថយភាពក្រីក្របានយ៉ាងច្រើននៅក្នុងមូលដ្ឋាន និងសហគមន៏ ដូចជាការកាត់បន្ថយការប្រើ ប្រាស់ពូជស្រូវប្រើប្រាស់ជីគីមីនិងកាត់បន្ថយការប្រើប្រាស់ថ្នាំពុលកសិកម្ម។ ជារួមយើងវិភាគ ឃើញថាអ្នកភូមិ ក៏ដូចជាក្នុងសហគមន៏ មានការយកចិត្តទុកដាក់យ៉ាងខ្លាំងនូវការទទួលយក ចំណេះដឹងដែលធ្វើឱ្យជីវភាពរបស់គាត់ បានប្រសើរឡើងតាមរយៈការកាត់បន្ថយចំណាយផ្សេងៗ និងធ្វើឱ្យសុខភាពគ្រួសារពួកគាត់បានប្រសើរជាងមុន ។

## លទ្ធផលទី២ : កម្មវិធីបង្កើនគុណភាពដី

### ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ ។

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ២.១ | • ការបណ្តុះបណ្តាលនិងធ្វើជីកំប៉ុស្តិ៍( ៨វគ្គ/កសិករ២៤០នាក់/ បង្ហាញ ៨កន្លែង) | • ការបណ្តុះបណ្តាល ៨វគ្គ និង បង្ហាញ៨កន្លែង ពីការធ្វើជីកំប៉ុស្តិ៍ កសិករចូលរួម ២៤០នាក់ ក្នុងនោះ ស្រី ១៤៦នាក់ ។ |

### ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល

| |
|---|
| តាមការពិនិត្យលើរបាយការណ៍បញ្ចប់កិច្ចសន្យារបាយការណ៍ប្រចាំឆ្នាំអនុកិច្ចសន្យានេះ សម្រេច បាននូវលទ្ធផល និង សកម្មភាព១០០%ធៀបនឹងផែនការដែលបានគ្រោងទុក ។ អ្នកចូលរួមទាំងអស់នៅក្នុងក្រុមពិភាក្សា ដែលជាសិក្ខាកាមបានចូលរួមពីការបណ្តុះបណ្តាលបច្ចេកធ្វើជីកំប៉ុស្តិ៍ មានការសាទរ ដោយសារជាតម្រូវការរបស់ពួកគាត់ក្នុងការធ្វើស្រែចំការ ជាពិសេសទៅទៀតគឺវត្ថុធាតុដើមអាចប្រមូលបាន នៅក្នុងមូលដ្ឋាន យកទៅប្រើ លើដំណាំស្រូវ ដំណាំផ្សេងៗមានទិន្នផលល្អប្រសើជាងមុន ទាំងគុណភាព និងបរិមាណ ហើយក៏បានរួមចំណែកសន្សំថវិកាបានមួយចំនួនពីការទិញជីគីមីមកប្រើប្រាស់ក្នុងមួយឆ្នាំៗ ។ |

**លទ្ធផលទី៣ : ការបណ្តុះបណ្តាលកសិករពីបច្ចេកទេស ផ្សព្វផ្សាយសុខភាពសត្វ ផលិតកម្ម និងការបង្ហាញផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ ។**

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ៣.១ | • ពង្រឹងភ្នាក់ងារសុខភាពសត្វភូមិឱ្យទៅជាភ្នាក់ងារផ្សព្វ ផ្សាយកសិកម្មភូមិ ៤វគ្គ =១១០នាក់ ស្រី ២នាក់ | • ពង្រឹងភ្នាក់ងារសុខភាពសត្វភូមិឱ្យក្លាយទៅជាភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ៤វគ្គ<br>• អ្នកចូលរួមចំនួន ១១៥ នាក់ ក្នុងនោះស្រី ១ នាក់<br>• វគ្គនិមួយៗមានចំនួន ៤ថ្ងៃ |

**ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល**

ក្នុងការអនុវត្តកិច្ចសន្យាសម្រេចបាននូវលទ្ធផល និងសកម្មភាព១០០%ធៀបនឹងផែនការ ដែលបានគ្រោងទុក។ តាមការពិនិត្យឯកសារ ការអនុវត្តកិច្ចសន្យាឡើងវិញ គឺមិនអាចវាយតម្លៃគុណភាព លទ្ធផលនេះ បានលម្អិតទាំងស្រុងនោះទេដោយសារពុំមានឯកសារតម្កល់ពីការវាយតម្លៃមុន និងក្រោយវគ្គបណ្តុះបណ្តាល។

## ២.២:ការវាយតម្លៃ និងលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៏បឋម

### ផ្នែក កៈ ការវាយតម្លៃការសម្រេចបាននូវស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា :

| **ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា (១)** | **ស្ថានភាពជាក់ស្តែងនៅពេលបញ្ចប់** អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| • បណ្តុះបណ្តាលនិងបង្ហាញផលិតពូជស្រូវ ដល់កសិករ ចំនួន២៦កន្លែងចំនួនមនុស្ស៥២០នាក់ ស្រី២៨៣នាក់ | · កសិករចំនួន ៥២០នាក់ ក្នុងនោះស្រី ៣១៥នាក់ នៅក្នុង **ឃុំ១៥ នៃស្រុក៥ បានទទួលការ** បណ្តុះបណ្តាល ៣វគ្គនិង កសិករ ចំនួន៥២នាក់ បានរៀបចំការបង្ហាញ ពីការផលិតពូជ ស្រូវដោយ មានការរៀបចំទ្រុងសន្សំជីកំប៉ុស្តិ ដែលបានទទួល ការឧបត្ថម្ភ ថវិកាចំនួន៥ដុល្លារ ស្រូវពូជចំនួន ៥គ.ក្រ និង ចប កាប់១ផ្លែ ក្នុង១គ្រួសារ។ |
| • បណ្តុះបណ្តាល និងបង្ហាញប្រព័ន្ធប្រពលវប្បកម្មស្រូវ តាម គោលការណ៍ធម្មជាតិ កសិករ ចំនួន៣២០នាក់ ស្រី ១៨៥នាក់. ១៦កន្លែង | កសិករចំនួន ៣២០នាក់ស្រី ១៨៥នាក់នៅក្នុង **១២ឃុំ** ៦ស្រុក បានទទួលការបណ្តុះបណ្តាល៣វគ្គ និងកសិករ ចំនួន ៥២នាក់បាន រៀបចំការបង្ហាញ ពីប្រព័ន្ធប្រពលវប្បកម្មស្រូវ ដោយមានការរៀបចំទ្រុង ជីកំប៉ុស្តិ៍ ដែលបានទទួលការឧបត្ថម្ភ ថវិកាចំនួន ៥ដុល្លារ ស្រូវពូជ ចំនួន ៥គ.ក្រ និង ចប កាប់១ផ្លែ ក្នុង១គ្រួសារ។ |
| • បណ្តុះបណ្តាលនិងបង្ហាញការប្រើប្រាស់ថ្នាំពុលធម្មជាតិ លើដំណាំបន្លែ ១០កន្លែងដល់កសិករ ចំនួន២០០នាក់ ក្នុងនោះស្រី ១៤៥នាក់ : | បានចុះធ្វើការបណ្តុះបណ្តាល៣វគ្គ កសិករ ទាំង១០កន្លែង/២០ បង្ហាញ (១កន្លែង២បង្ហាញ) សរុបកសិករចូលរួម ចំនួន ២០០នាក់ ស្រី ១៦០នាក់ ៤ស្រុក ៧ឃុំ ១០កន្លែង ស្តីពីថ្នាំពុល ការពារដំណាំផ្សំពីរុក្ខជាតិ ព្រមទាំងបានបែងចែកពាងត្រាំថ្នាំ ចំនួន $4,00/គ្រួសារ និងថវិកាទិញវត្ថុធាតុផ្សំ ពីរុក្ខជាតិចំនួន $4,00/គ្រួសារ សំរាប់គ្រួសារសរុប ២០គ្រួសារ និងបាន បែងចែកចប កាប់ជូនកសិករចំនួន ១ផ្លែ/គ្រួសារ សរុបចំនួន ២០ផ្លែ។ |
| • បណ្តុះបណ្តាល និងបង្ហាញ៨កន្លែង អំពីសុវត្ថិភាព ការ ប្រើប្រាស់ថ្នាំពុលកសិកម្មលើដំណាំស្រូវ | បានចុះធ្វើការបណ្តុះបណ្តាល៣គ្គ កសិករទាំង៨កន្លែង/៨បង្ហាញ (១កន្លែង១បង្ហាញ) សរុប កសិករចូលរួម |

| | |
|---|---|
| ដល់កសិករ១៦០នាក់ ក្នុងនោះស្រី ៨៥នាក់ : | ចំនួន ១៦០នាក់ ស្រី ៨៥នាក់ ៥ស្រុក ៧ឃុំ ៨កន្លែង ស្ដីពីសុវត្ថិភាព ការប្រើ ប្រាស់ថ្នាំពុលកសិកម្មលើដំណាំស្រូវ ។ |
| • កសិករចំនួន២៤០នាក់ក្នុងនោះស្រី ១៣០នាក់ មកពី៨ឃុំ ក្នុងស្រុកគោលដៅទាំង៤ បានទទួលចំណេះដឹង ពីបច្ចេកទេស ធ្វើជីកំប៉ុស្តិ៍តាមរយៈការបណ្តុះបណ្តាលចំនួន៨វគ្គ និង ការធ្វើបង្ហាញចំនួន៨កន្លែង | · បានចុះធ្វើការបណ្តុះបណ្តាលកសិករទាំង៨កន្លែង/៨បង្ហាញ (១កន្លែង១បង្ហាញ) សរុប កសិករចូលរួម ចំនួន ២៤០នាក់ ស្រី ១៤៦នាក់ ៤ស្រុក ៤ឃុំ ៨កន្លែង ស្ដីពីការធ្វើជីកំប៉ុស្តិ៍ ព្រមទាំងបានបែងចែក (សៀវភៅបច្ចេកទេស ពូជស្រូវចំនួន ១០គីឡូរកាម ចប រនាស់ ធុងទឹក និងជីអ៊ុយរ៉េ) ទ្រុងជីកំប៉ុស្តិ៍ ចំនួន $10,00 /គ្រួសារ ។<br>· អ្នកចូលរួមភាគច្រើននៅក្នុងការពិភាក្សាក្រុម បានរាយការណ៍ថា ពួកគាត់ពេញចិត្តនឹងវគ្គ បណ្តុះបណ្តាល និងការធ្វើ បង្ហាញជីកំប៉ុស្តនេះ ។ បន្ថែមពីលើនេះទៀត ពួកគាត់បញ្ជាក់ថា វគ្គបណ្តុះបណ្តាលស្ដីពីបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ ពិតជាឆ្លើយតប ទៅនឹងតម្រូវការរបស់ពួកគាត់ក៏ដូចជាក្នុងសហគមន៍ដែរ។ ជាងនេះទៀតអ្នកចូលរួមក្រុមពិភាក្សាបានលើកឡើងថា កាលដែលមិនទាន់ចូលរៀនវគ្គបណ្តុះបណ្តាល គាត់បានទិញ ជីគីមី ដាក់ស្រែ៣ការ៉ុង/១ហិចតា មានតម្លៃក្នុង ១ការ៉ុង ៩៥០០០រៀល តែគិតជារួមអស់ ២៨៥០០០ រៀល ។<br>· ក្រោយវគ្គបណ្តុះបណ្តាលពួកគាត់បានធ្វើការសន្សំជីកំប៉ុស្តិ៍និងគាត់បានទិញជីគីមីដាក់ស្រែ១ការ៉ុង/ ១ហិចតា ទេសំរាប់ទ្រាប់បាត គឺមានន័យថាគាត់ចំណេញ ២ការ៉ុង ដែលមានតម្លៃ ១៩០០០០រៀល។ ហើយមិនត្រឹមតែប៉ុណ្ណេះគាត់បានយកជីនេះ ជីកំប៉ុស្តិ៍ មកដាំបន្លែផ្សេងៗទៀតបាន ដោយស្រួលដោយ មិនបាច់ប្រើជីគីមី |

| | |
|---|---|
| | • ការយល់ដឹងរបស់ពួកគាត់ទៅលើការសន្ទុំដីកំប៉ុស្តិ៍នេះមានភាពប្រសើរឡើង បន្ទាប់ពីគម្រោង បានផ្តល់វគ្គបណ្តុះ បណ្តាល នូវជំនាញ ចំនេះដឹង និងបច្ចេកទេសទាំងនេះ។ អ្វីដែលគួរចាប់អារម្មណ៍នោះពួកគាត់បាននូវតែអនុវត្តធ្វើជាប្រចាំ ។ |
| • ពង្រឹងភ្នាក់ងារសុខភាពសត្វភូមិឱ្យទៅជាភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ ៨វគ្គ =១១០នាក់ ស្រី ២នាក់ | • បានពង្រឹងភ្នាក់ងារសុខភាពសត្វភូមិឱ្យក្លាយទៅជាភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ ៨វគ្គ ១៤ឃុំ ៣ស្រុក<br>• អ្នកចូលរួមចំនួន ១១៥ នាក់ ក្នុងនោះស្រី ២ នាក់ វគ្គនីមួយៗមានចំនួន ៤ថ្ងៃ ។ |

**ផ្នែក-ខ: ការវាយតម្លៃការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា**

| ល.រ | គោលបំណងបន្ទាន់ | ការសម្រេចបានជាក់ស្តែង នៅពេលបញ្ចប់អនុកិច្ចសន្យា /ក្នុងពេលវាយតម្លៃ |
|---|---|---|
| ១ | គាំទ្រមន្ទីរកសិកម្មខេត្តក្នុងការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងធ្វើការបង្ហាញនានា ដើម្បីឱ្យប្រជាកសិករអាចទទួលបាននូវ បច្ចេកទេសសមស្រប តបតាមមូលដ្ឋានឱ្យបានឆាប់ និងមានប្រសិទ្ធភាពខ្ពស់ ។ | គោលបំណងបន្ទាន់ដែលបានចែងគឺនៅក្នុងកំរិតខ្ពស់ធ្វើឱ្យយើងពិបាកក្នុងការវាស់វែងនៅពេលបញ្ចប់កិច្ចសន្យា។ ទោះបីជារំពឹងទុកថាសកម្មភាពនានានិងលទ្ធផលទាំងឡាយរបស់អនុកិច្ចសន្យា និងចូលរួមក្នុងគោលបំណងបន្ទាន់ ប៉ុន្តែផ្អែកទៅលើការពិនិត្យឯកសារ និង វិធី-សាស្ត្រ វាយតម្លៃបែបគុណភាព គេមិនអាចវាយតម្លៃទៅលើ គោលបំណងបន្ទាន់នេះបានសម្រេចក្នុងកម្រិតណាទេ ។ |

| |
|---|
| តាមរយៈការពិភាក្សាក្រុមអ្នកចូលរួមបានបង្ហាញថា ពួកគាត់មានការពេញចិត្តចំពោះផលប្រយោជន៍ដែលអនុកិច្ចសន្យា នេះសម្រេចបាន ជាពិសេស គឺចំណេះដឹង និង បច្ចេកទេសធ្វើជីកំប៉ុស្តិ៍ ។ ពួកគាត់បានទទួលស្គាល់ថាវាមានសារៈ ប្រយោជន៍ណាស់សំរាប់គ្រួសារគាត់ជាកសិករ ដែលឆ្នាំកន្លងមករាល់រដូវធ្វើស្រែម្តងៗពួកគាត់ត្រូវការចំណាយ ថវិកា យ៉ាងច្រើនដើម្បីទិញជីគីមីមកដាក់លើដំណាំស្រូវក៏ដូចជាដំណាំបន្លែបង្កាតាមច្បារដំណាំរបស់គាត់ ។ ក្រោយ ពីទទួលបានបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ គាត់បានរៀបចំធ្វើជាទ្រុងសំរាប់ប្រមូល លាមកគោ ក្របី សំរាម កាក |

សំណល់ផ្ទះ បាយ និង ស្លឹករុក្ខជាតិផ្សេងៗ មកដាក់តាមស្រទាប់របស់វា រយៈពេល ១០ថ្ងៃ ទើបច្របល់បញ្ចូលគ្នាម្តង ក្នុង១ឆ្នាំខ្ញុំ ប្រមូលបានជីកំប៉ុស្តិ៍ ៣ទ្រុង ដែលធ្វើឱ្យដំណាំស្រូវរបស់គ្រួសារខ្ញុំកើនទិន្នផល ២ដងច្រើនជាងឆ្នាំមុនៗ ។

# ករណីសិក្សា

## ករណីសិក្សាទី ១ : អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងបណ្តុះបណ្តាលបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ :

**លោក ឃុន សោមដែលជាអ្នកទទួលផលពីគម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាព របស់ គ.ជ.អ.ប នៅភូមិជើងភ្លើងឃុំស្នាមព្រះស្រុកបាកាន ខេត្តពោធិ៍សាត់ក្នុងឆ្នាំ ២០០៩ "ជីវភាពរស់នៅរបស់ខ្ញុំ មានការប្រសើរឡើងតាំងពីខ្ញុំបានទទួលការបណ្តុះបណ្តាលអំពីបច្ចេកទេសធ្វើជីកំប៉ុស្តិ៍"។**



លោក ឃុន សោម

លោក ឃុន សោម ជាកសិករម្នាក់មានអាយុ ៥៣ឆ្នាំមានគ្រួសារ និងកូនប្រុស៣នាក់ ស្រី២នាក់រស់នៅ ភូមិជើងភ្លើង ឃុំស្នាមព្រះ ស្រុក បាកាន ខេត្តពោធិ៍សាត់ ។ គាត់បាននិយាយថាគម្រោង បណ្តុះបណ្តាលពី បច្ចេកទេសធ្វើ ជីកំប៉ុស្តិ៍នេះ មានសារៈសំខាន់ណាស់ព្រោះគាត់បានទទួលចំណេះដឹង ជំនាញសម្រាប់គាត់ក៏ដូចប្រជាពលរដ្ឋរស់នៅភូមិមួយចំនួន ដែលបានចូលរួមវគ្គបណ្តុះបណ្តាលនេះ។ គាត់បញ្ជាក់ថា : ឥឡូវ ខ្ញុំមិនចំណាយប្រាក់កាសច្រើនដូចពេលមុនទៀតទេ អ្នកជិតខាងខ្ញុំ មិនចង់ជឿទេថាការ ធ្វើជីធម្មជាតិបែបនេះ វាទទួលបានផលល្អប្រសើរសោះ។ ជាងនេះទៅទៀត ធ្វើអោយ គ្រួសារគាត់កាន់តែមានជីវភាពប្រសើរឡើង ដោយសារគាត់ប្រើជីធម្មជាតិ ទៅលើ ដំណាំស្រូវ បន្លែ ហើយនេះក៏ជាចំណូលរបស់គ្រួសារគាត់។

ជាការផ្លាស់ប្តូរមួយទៀតសម្រាប់គ្រួសារគាត់បន្ទាប់ពីចូលរួមសកម្មភាពគម្រោង គឺគាត់ កាន់តែរវល់ជាមួយការដាំស្រូវផងធ្វើបន្លែផង។ ហេតុនេះហើយបានជាធ្វើស្រែ ដាំបន្លែ បានពេញ១ឆ្នាំ ជាចុងបញ្ចប់គាត់បង្ហាញពីការប្តេជ្ញាចិត្តក្នុងការបន្តសកម្មភាព បច្ចេកទេស ធ្វើជីធម្មជាតិបន្តទៀត ទោះបីមិនបានទទួលការឧបត្ថម្ភថវិកាធ្វើទ្រុងជី និងសំភារៈផ្សេងៗពី គម្រោងក៏ដោយ។ គាត់និយាយថាគ្រាន់តែ កាកសំណល់នៅជុំវិញផ្ទះគាត់មិនខ្វះឡើយ គឺដើររកតែមួយភ្លែត គឺបានភ្លាម ម្យ៉ាងអាចឱ្យគាត់សល់ថវិកា ផ្គត់ផ្គង់គ្រួសារបានមួយកំរិត ដោយមិនចំណាយថវិកាទៅលើ ការទិញជីគីមី។

## ករណីសិក្សាទី ២: អ្នកមិនបានទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងបណ្តុះបណ្តាលបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ :

លោកស្រី ឈុន ឃៀ ដែលជាអ្នកមិនទទួលផលពីគម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាព របស់ គ.ជ.អ.ប នៅភូមិជើងភ្លើង ឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់ មិនបានទទួលការបណ្តុះបណ្តាលអំពីបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ ។



លោកស្រី ឈុន ឃៀ

លោកស្រី ឈុន ឃៀ អាយុ ៤៤ឆ្នាំគាត់មានគ្រួសារ និងកូនស្រី២នាក់ ប្រុស ៣នាក់ គាត់រស់នៅភូមិជើងភ្លើង ឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ គាត់ជាកសិករដែលមានចំណូលពីការដាំស្រូវ និងចិញ្ចឹមសត្វ ។ លោកស្រី ឈុន ឃៀ មិនបានចូលរួមវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសធ្វើជីកំប៉ុស្តិ៍របស់មន្ទីរកសិកម្មឡើយ ។ គាត់មិនបានត្រូវគេជ្រើសរើស អោយចូលរួមដោយគាត់ជាប់រវល់ការងារច្រើននៅពេលប្រធានភូមិចុះមកជ្រើសរើស ។ គាត់និយាយថា វគ្គបណ្តុះបណ្តាលបច្ចេកទេសធ្វើជីកំប៉ុស្តិ៍នេះ មានសារៈសំខាន់ណាស់ព្រោះគាត់ឃើញអ្នកភូមិជិតខាងរបស់គាត់ដែលបានចូលរួមវគ្គបណ្តុះបណ្តាលទទួលបានចំណេះ និងជំនាញក្នុងការធ្វើជីធម្មជាតិ ។ គាត់បានបន្ថែមទៀតថា ឥឡូវនេះអ្នកដែលទទួលបានការបណ្តុះបណ្តាលបាននាំគ្នាដាំដំណាំបន្លែជាច្រើនមុខសម្រាប់ហូប និងលក់ព្រមទាំងមានចំណូលបន្ថែមពីការលក់បន្លែ ។ គាត់បានលើកឡើងថា : បច្ចុប្បន្នពួកគេអាចសន្សំបាន ១០០០រៀល ក្នុងមួយថ្ងៃ ព្រោះគាត់មិនចាំបាច់ទិញបន្លែពីផ្សារ ។ គាត់បន្ថែមទៀតថា បន្លែដែលដាំដោយខ្លួន ឯងនៅតាមផ្ទះមានសារៈប្រយោជន៍ចំពោះសុខភាពគ្រួសារ ដោយសារមិនប្រើជីគីមី ។

លោកស្រី ឈុន ឃៀមានសង្ឃឹមថានឹងបានចូលរួមវគ្គបណ្តុះបណ្តាល អំពីបច្ចេកទេសធ្វើជីកំប៉ុស្តិ៍របស់គម្រោងក្នុងពេលអនាគតនិងទទួលបានផលប្រយោជន៍ដូចអ្នកជិត ខាងរបស់គាត់ ។

ជាចុងបញ្ចប់គាត់ទទូចអោយអង្គការ និងភ្នាក់ងារនានាជួយអភិវឌ្ឍន៍ភូមិរបស់គាត់បន្ថែមទៀតផងហើយដើម្បីបានចូលរួមជាមួយកម្មវិធីនេះដែរ ។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

**ផ្នែក-ក: ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅនឹងតំរូវការ : មន្ទីរវិស័យ មូលដ្ឋាន គ.ជ.អ.ប និងការកាត់បន្ថយភាព ក្រីក្រ :**

**ពិន្ទុ : ១=ខ្សោយណាស់ ២=ខ្សោយ ៣=មិនខ្លាំងមិនខ្សោយ ៤=ខ្លាំង ៥=ខ្លាំងណាស់**

| ល.រ (១) | ធាតុ (២) | ទំនាក់ទំនងតក្កភាព (៣) | បរិយាយច្បាស់លាស់ (៤) | សង្ខេបការវាយតម្លៃ (៥) |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៤ | ៤ | សកម្មភាពដែលបានលើកឡើងពិតជាមានទំនាក់ទំនងតក្កជាមួយនឹងលទ្ធផល ដែលបានសរសេរក្នុងអនុកិច្ចសន្យា ។ ជាក់ស្តែងក្នុងលទ្ធផលទី ១ ការបង្ហាញផ្នែកក្សេត្រសាស្ត្រ (ឈើហូបផ្លែ ស្រូវ បន្លែ ដំណាំ) មានសកម្មភាពជាក់លាក់ដូចជា : បណ្តុះបណ្តាល និងបង្ហាញពីការផលិតពូជស្រូវ (២៦វគ្គ/បង្ហាញ ៥២កន្លែង) កសិករចំនួន ៥២០នាក់ ក្នុងនោះស្រី ៣១៥នាក់ បណ្តុះបណ្តាល និងបង្ហាញ ប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ ធម្មជាតិ ប.វ.ស (១៦វគ្គ/កសិករ៣២០នាក់/ស្រី ១៨៥នាក់/បង្ហាញ ១៦កន្លែង) បណ្តុះបណ្តាល និង បង្ហាញការប្រើប្រាស់ ថ្នាំពុលធម្មជាតិលើដំណាំបន្លែ (១០វគ្គ/កសិករ ២០០នាក់ស្រី១២៤នាក់/បង្ហាញ១០ កន្លែង) បណ្តុះ បណ្តាល និងបង្ហាញ សុវត្ថិភាពការប្រើប្រាស់ថ្នាំ ពុល កសិកម្មលើដំណាស្រូវ (៨វគ្គ/កសិករ ១៦០នាក់ /ស្រី៨៥នាក់/បង្ហាញ៨កន្លែង) និងធ្វើជីកំប៉ុស្តិ(៨វគ្គ/កសិករ២៤០នាក់/បង្ហាញ |

| | | | | |
|---|---|---|---|---|
| | | | | ៨កន្លែង) ។ ទាំងអស់នេះឆ្លុះបញ្ចាំងឱ្យឃើញថាសកម្មភាពទាំងនេះមានទំនាក់ទំនងតក្ក ជាមួយនឹងលទ្ធផលខាងលើ ហើយសរសេរបញ្ជាក់យ៉ាងច្បាស់នូវសកម្មភាពនីមួយៗ នូវចំនួនវគ្គបណ្តុះបណ្តាល ចំនួនសិក្ខាកាមចូលរួម និងទីតាំងគោលដៅសំរាប់អនុវត្តជាការងាយស្រួល ក្នុងការចុះត្រួតពិនិត្យសកម្មភាពគម្រោង ។ សកម្មភាពដទៃទៀតនៅក្នុង (លទ្ធផលទី២ ៣ ៤ និង ទី៥) ត្រូវបានសរសេរក្នុងបែបបទដូចគ្នានឹងលទ្ធ-ផលទី១ដែរ។ សកម្មភាពនីមួយៗមានទំនាក់ទំនងតក្ក ហើយនិងត្រូវបានបរិយាយច្បាស់លាស់ដូចដែលបានសរសេរ ក្នុងអនុកិច្ចសន្យា ។ |
| ២ | លទ្ធផល | ៤ | ៤ | លទ្ធផលនីមួយៗត្រូវបានសរសេរបរិយាយច្បាស់លាស់ ដោយមានសូចនាករ ជាក់លាក់ ដែលអាចវាស់វែង បាន ។ ជាងនេះទៅទៀតលទ្ធផលនីមួយៗជាការ បំពេញឱ្យគ្នាទៅវិញទៅមក ហើយនឹងរួមគ្នាបំពេញ ឱ្យគោលបំណងបន្ទាន់ ។ ទោះបីជាយ៉ាងនេះក៏ដោយ លទ្ធផលទាំងអស់នេះមិនអាចធ្វើឱ្យគោលបំណង បន្ទាន សម្រេចបានទាំងស្រុងនៅឡើយទេ ។ |
| ៣ | - គោលបំណងបន្ទាន់ *(គោលបំណងស្ថិតក្នុងចំណុច "ខ" នៃផ្នែកទី ៣)* | | | គាំទ្រមន្ទីរកសិកម្មខេត្តក្នុងការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និង ធ្វើការបង្ហាញនានាដើម្បីឱ្យប្រជាកសិករអាចទទួលបាន នូវបច្ចេកទេស សមស្របតាមមូលដ្ឋាន ឱ្យបានឆាប់ និងមានប្រសិទ្ធិភាពខ្ពស់ និងដោយឆ្លង តាមដំណាក់កាលៗ ។ |
| ៤ | ស្ថានភាពចុងបញ្ចប់ | ៤ | ៤ | នៅចុងបញ្ចប់នៃកិច្ចសន្យានេះ លទ្ធផលរំពឹង |

| | | | | |
|---|---|---|---|---|
| | អនុកិច្ចសន្យា ( *ចំណុច "គ" នៃផ្នែកទី ៣)* | | | ទុករួមមាន ១) បណ្តុះបណ្តាល និងបង្ហាញផលិតពូជស្រូវ ដល់កសិករ ចំនួន២៦កន្លែង ( ចំនួនមនុស្ស ៥២០នាក់ ស្រី២៨៣នាក់ ) ។<br>២) បណ្តុះបណ្តាលនិងបង្ហាញប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ (បវស) ដល់កសិករ ចំនួន ១៦ កន្លែង (ចំនួនមនុស្ស ៣២០នាក់ ស្រី ១៨៥នាក់) ។<br>៣) បណ្តុះបណ្តាល និងបង្ហាញការប្រើប្រាស់ថ្នាំពុលធម្មជាតិលើដំណាំបន្លែ ដល់កសិករចំនួន ១០ កន្លែង (ចំនួនមនុស្ស ២០០នាក់ ស្រី ១២៤នាក់) ។<br>៤) បណ្តុះបណ្តាល និងបង្ហាញ សុវត្ថិភាពការប្រើប្រាស់ ថ្នាំពុលកសិកម្ម លើដំណាស្រូវ ដល់កសិករចំនួន ៨ កន្លែង (ចំនួនមនុស្ស ១៦០នាក់ ស្រី ៨៥ នាក់) ។<br>៥) ការបណ្តុះបណ្តាល និងធ្វើជីកំប៉ុស្តិចំនួន ០៨កន្លែង (ចំនួនមនុស្ស ២៤០នាក់ ស្រី ៩៥នាក់)<br>៦) ពង្រឹងភ្នាក់ងារសុខភាពសត្វភូមិ ចំនួន ១១៥នាក់ ស្រី ៥នាក់ ចំណេះដឹងទាំងអស់នេះពួកគាត់អាចយកទៅប្រើប្រាស់ក្នុងការប្រកបមុខរបរកសិកម្មដែលជាមុខរបរ ស្នូលរបស់ពួកគាត់បានមួយកម្រិតដែរ ។ |
| ៥ | លទ្ធផលអភិវឌ្ឍន៍/ផលប៉ះពាល់រយៈពេលវែងៈ គោលដៅ និងគោលបំណងអភិឌ្ឍន៍ (ចំណុច ខ នៃផ្នែកទី៣ ) | | | មិនអាចធ្វើការវាយតម្លៃបាន |

## ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខ័ណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារៈ

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ..អ.ជ.ខ :** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | អាចរៀបចំកិច្ចសន្យាបានដោយខ្លួនឯងលើកលែងតែភាសាអង់គ្លេសក្នុង NCD |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យ ការអនុវត្តន៍របស់ភ្នាក់ងារអនុវត្តន៍ | គាំទ្របានទាន់ពេលវេលា ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា | មានសមត្ថភាពគ្រប់គ្រងក្នុងការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា ។ |
| **ពីខាងភាគីអនុវត្តន៍កិច្ចសន្យាៈ** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | មានបុគ្គលិកជំនាញ និង បទពិសោធន៍គ្រប់គ្រាន់ ។ |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និងលទ្ធផល | ការអនុវត្តសកម្មភាពនិង លទ្ធផលទាន់ពេលវេលា ដូចដែលបាន គ្រោងទុកក្នុងកិច្ចសន្យា ទោះបីជាមានការយឺតយ៉ាវខ្លះក្នុងការទូរទាត់ថវិកា។ |
| ៦ | ការរាយការណ៍ការរីកចំរើន និងការកត់ត្រាឯកសារ | ការធ្វើរបាយការណ៍រីកចំរើនមកគ.ប្រមិនសូវទៀងទាត់ ពេលវេលា ពេល ខ្លះទាល់តែមានរំលឹកពីគ.ប្រ ។ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | លក្ខខ័ណ្ឌក្នុងកិច្ចសន្យា ត្រូវបានគោរព ។ |
| **ទាំងខាង គ.អ.ជ.ខ និងភាគីអនុវត្តកិច្ចសន្យាៈ** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្ទត" (ចំណុច-ង ផ្នែកទី៣) និងបញ្ហាប្រឈម | មានការគ្រប់គ្រងហានិភ័យ និង កត្តាសន្ទតបានល្អដូចជា : ការផ្តល់ថវិកាបានទាន់ពេលវេលាពី គ.ប្រ នៃ គ.អ.ជ.ខ ដើម្បីបំពេញនូវទឹកប្រាក់វិញដែលទាមទាសំរាប់ ការគាំទ្រ ដល់ការអនុវត្តន៍គំរោង។ មានការចូលរួម និងគាំទ្រយ៉ាងសកម្មពីសហគមន៍ទាំងប្រុសទាំងស្រី |

| | | |
|---|---|---|
| | | ដែលជាអ្នកទទួលផលផ្ទាល់ក្នុងឃុំ គោលដៅ។ ស្ថាប័ន រដ្ឋាភិបាល អាជ្ញាធរ សង្គមស៊ីវិលគ្រប់ថ្នាក់មានការតាំងចិត្តឬ សន្យា ក្នុងការគាំទ្រដល់មន្ទីរក្នុងការ អនុវត្តន៍កិច្ចសន្យានេះ។ មានកិច្ចសហការណ៍ល្អជាមួយមន្ទីរ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលពាក់ព័ន្ធនឹងបញ្ហាការគ្រប់គ្រង ធនធានធម្មជាតិនិងបរិស្ថាន។ |
| ៩ | ការបញ្ជ្រាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | តាមការសង្កេត និងពិនិត្យលើឯកសារសំអាងបញ្ជាក់ឱ្យឃើញថា ស្ត្រីលើស ៤៥ភាគរយ បានទទួលផលផ្ទាល់ពីគំរោងនេះ ក្នុងចំណោម អ្នកទទួលផល ទាំងអស់ក្នុងនោះ ស្ត្រីបានចូលរួម ក្នុងវគ្គបណ្តុះបណ្តាល ប្រជុំ និងសកម្ម-ភាពផ្សេងៗទៀត។ នេះគឺជាការ ផ្តល់នូវឱកាស និងតួនាទីយ៉ាងធំធេងដល់ ស្ត្រីគ្រប់ការិត ដើម្បីចូលរួមនិង/ឬ អនុវត្តនូវសកម្មភាពទាំងឡាយ ដែល ទាក់ទងនឹងការគ្រប់គ្រងធនធាន ធម្មជាតិ និងបរិស្ថានក្នុងឃុំរបស់ខ្លួន។ ដើម្បីអនុវត្តន៍ឱ្យមាន ប្រសិទ្ធភាព កិច្ចសន្យានេះបានកំណត់ឱ្យមានការ ចូលរួមយ៉ាងពេញលេញ ពីស្ត្រីលើសកម្មភាពមួយចំនួនដូចជា: ការបណ្តុះ-បណ្តាល បច្ចេកទេស ការធ្វើបង្ហាញ និង ការផ្សព្វផ្សាយផ្សេងៗ ។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ (ចំណុច-ឆ ផ្នែកទី៣) | គំរោងនេះបានគាំទ្រយ៉ាងសកម្មក្នុងការអនុវត្តន៍យុទ្ធសាស្ត្រការគ្រប់គ្រង ធនធានធម្មជាតិ និងបរិស្ថាននៅថ្នាក់ឃុំដូចជា :<br>- ការបណ្តុះបណ្តាល បច្ចេកទេសផលិតជីធម្មជាតិ ។<br>- ការបណ្តុះបណ្តាល បច្ចេកទេសប្រើថ្នាំពុលធម្មជាតិដែលមិនគម្រាម កំហែងដល់សុខភាពមនុស្ស ។ |
| ១១ | ការថែរក្សា (និរន្តរភាព) ( ចំណុច-ជ ផ្នែកទី៣) | គម្រោងនេះមាននិរន្តរភាពបានល្អប្រសើ ដោយសារកសិករបានយក ចំណេះដឹងទៅអនុវត្ត ដូចជាការធ្វើជីកំប៉ុស្តិ ប្រពលវប្បកម្មដំណាំស្រូវ និងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ។ |

## ២.៤. សេចក្តីសន្និដ្ឋាន

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យាត្រូវបានអនុវត្តឡើង និងទទួលបានលទ្ធផលដូចការគ្រោងទុកក្នុងអនុកិច្ចសន្យា ។ ភាគីអនុវត្តកិច្ចសន្យាមានសមត្ថភាពនិង ធនធានគ្រប់គ្រាន់ដើម្បីអនុវត្តអនុកិច្ចសន្យា ។ សកម្មភាព និងលទ្ធផល ដែលបានគ្រោងទុក ត្រូវបានបញ្ចប់ស្របតាមផែនការការងាររបស់មន្ទីរដែលបានរៀបចំឡើង ។ |
| ២ | ផ្តោតលើផ្នែកលទ្ធផល (គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា និងការរួមចំណែករបស់គោលបំណងទាំងនេះក្នុងការសម្រេចគោលបំណង និងគោលដៅកម្រិតខ្ពស់) សកម្មភាពរបស់អនុកិច្ចសន្យា និងអត្ថប្រយោជន៍ដែលសហគមន៍ទទួលបាន ទាំងអ្នកទទួលផល និងអ្នកមិនបានទទួលផល មានការត្រេកអរនៅក្នុងឃុំដែលគម្រោងបានអនុវត្ត ។ ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា ត្រូវបានសម្រេចទាំងស្រុងដូចការគ្រោងទុក ។ ភស្តុតាងជាក់ស្តែងអំពីលទ្ធផល និងផលប្រយោជន៍ដូចខាង ក្រោមថ្វីត្បិតតែគម្រោងត្រូវបានបញ្ចប់យូរហើយក៏ដោយដូចជា :<br>ក) ពួកគាត់នៅតែបន្តធ្វើជីកំប៉ុស្តិ៍ ដោយប្រើបច្ចេកដែលទទួលបានពីវគ្គបណ្តុះបណ្តាលរបស់កម្មវិធី ។<br>ខ) ការប្រើជីកំប៉ុស្តិ៍ ទៅលើដំណាំស្រូវ និង បន្លែមានការកើនឡើង ហើយការសន្សំសំចៃ ក្នុងគ្រួសារកើតមាន ក៏ដូចជាធ្វើឱ្យចំណូលក្នុងគ្រួសារកើនឡើង ដោយសាគាត់ចំណាយថវិកាទៅលើការទិញជីគីមីមានកំរិតទាប ។<br>គ) មានតម្រូវការវគ្គបណ្តុះបណ្តាលស្រដៀងគ្នានេះ ដែលសំណូមពរដោយអ្នកភូមិជិតខាងជាច្រើនទៀតដោយពួកគាត់មើលឃើញពីអត្ថប្រយោជន៍ នៃវគ្គបណ្តុះបណ្តាលបច្ចេកទេស ធ្វើជីកំប៉ុស្តិ៍នេះ។ ដូច្នេះអនុកិច្ចសន្យាបានទទួលនូវនិរន្តរភាព និងសកម្មភាពរបស់គម្រោងកំរិតខ្ពស់ ។ ហេតុនេះ គម្រោងបានចូលរួមចំណែក ក្នុងកំរិតតិចតួចទៅគោលដៅអភិវឌ្ឍន៍នៅក្នុងអនុកិច្ចសន្យា ហើយនិងគោលដៅក្នុងការកាត់បន្ថយភាពក្រីក្រ បានមួយកម្រិត តាមការសំភាសមនុស្ស ៨នាក់ អ្នកដែលនៅអនុវត្តបន្តស្មើ ៧៥ % ។ |
| ៣ | ការជ្រើសរើសសិក្ខាកាម និងអ្នកទទួលផល នៅក្នុងអនុកិច្ចសន្យា ដោយមានកិច្ចសហការល្អរវាងរដ្ឋអំណាច និង ភ្នាក់ងារអនុវត្តគម្រោងធ្វើឱ្យមានការធានាថា អ្នកដែលមានតម្រូវការខ្លាំងបំផុតនឹងទទួលបានផលប្រយោជន៍ពីគម្រោង ។ |
| ៤ | អនុកិច្ចសន្យានេះមិនបានជួបប្រទះនូវឧបសគ្គ និងបញ្ហាប្រឈមដែលគួរឱ្យកត់សំគាល់ទេ ។ |

**ចំណុចរៀនសូត្រ:**

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ដូចដែលបានសង្កេតឃើញក្នុងការចុះវាយតម្លៃនេះ ផលប៉ះពាល់របស់អនុកិច្ចសន្យា និង និរន្តរភាព របស់លទ្ធផលនៅក្នុងអនុកិច្ចសន្យា ត្រូវបានសម្រេចក្នុងកំរិតខ្ពស់ ដោយ អនុកិច្ចសន្យានេះ ត្រូវបាន រៀបចំឡើង និងបានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ជាអាទិភាពរបស់ក្រុម គោលដៅដែលជា អ្នកទទួលផល ។ |
| ២ | មានការបរិយាយច្បាស់លាស់នូវ គោលបំណងបន្ទាន់ ក្នុងកំរិតដែលអាចវាស់វែងបាន ជាការសំខាន់ សំរាប់ការកត់ត្រាទុក នូវលទ្ធផលរបស់អនុកិច្ចសន្យា និងផលប្រយោជន៏ដែលមាន សំរាប់ធ្វើការ វាយតម្លៃ លទ្ធផល ។ |
| ៣ | ការវាស់វែងទៅលើគុណភាពនៃវគ្គបណ្តុះបណ្តាលអាចវាស់វែងបាន បើភ្នាក់ងារអនុវត្តគម្រោង មានការវាយតម្លៃមុន និងក្រោយវគ្គបណ្តុះបណ្តាលហើយរក្សាទុកឯកសារសំអាង ។ |

**អនុសាសន៏ :**

| ល.រ | អនុសាសន៏ |
|---|---|
| ១ | រាល់វគ្គបណ្តុះបណ្តាលត្រូវមានឯកសារសំអាងពីការវាយតម្លៃវគ្គមុន និង ក្រោយវគ្គបណ្តុះបណ្តាល |
| ២ | ភ្នាក់ងារអនុវត្តគម្រោងគប្បីពិភាក្សា និងរដ្ឋអំណាចមូលដ្ឋានធ្វើយ៉ាងណាឱ្យកសិករដែលមកចូលរួមក្នុង វគ្គ បណ្តុះបណ្តាលឱ្យបានពេញលេញតាមកាលវិភាគដែលបានគ្រោងទុក ។ |
| ៣ | ភ្នាក់ងារអនុវត្តគម្រោងគប្បីធ្វើរបាយការណ៏រីកចំរើនផ្ញើមកគណៈកម្មាធិការប្រតិបត្តិឱ្យទាន់ពេលវេលា ។ |
| ៤ | ភ្នាក់ងារអនុវត្តការរៀបចំផែនការសកម្មភាពប្រចាំខែគប្បីឱ្យបានជាក់លាក់ ។ |

## ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍:

**ឯកសារដែលត្រូវភ្ជាប់ទី១ : បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបានពិនិត្យ**

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) |
|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និង ឯកសារវិសោធនកម្ម (ប្រសិនមាន) |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា/មន្ទីរវិស័យ |
| ៣ | របាយការណ៍ត្រួតពិនិត្យគម្រោង |
| ៤ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា |
| ៥ | លិខិតឆ្លើយឆ្លងរវាងភ្នាក់ងារអនុវត្តន៏ និងគណៈកម្មាធិការប្រត្តិបត្តិគ.អ.ជ.ខ |
| ៦ | បញ្ជីវត្ថុបណ្ដុះបណ្ដាលដែលមានក្នុងអនុកិច្ចសន្យា |
| ៧ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា |
| ៨ | ឯកសារដ៏ទៃទៀតរួមមាន រូបថតនៃគម្រោង (អនុកិច្ចសន្យា) ដែលទុកនៅគណៈកម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ និងនៅភ្នាក់ងារអនុវត្តន៏ ដែលមិនបានរៀបរាប់ខាងលើ |

## ឯកសារទី២ : បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាសន៍ / ជួបពិភាក្សា

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៍ប្រើសម្រាប់ប្រមូលទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | 0១ តុលា | លោក ឡាយ វិសិដ្ឋ អនុប្រធានមន្ទីរ | មន្ទីរកសិកម្ម | សម្ភាសន៍ស៊ីជម្រៅ |
| ២ | 0១ តុលា | លោក ហៃ ធូ រ៉ា អនុប្រធានការិយាល័យផ្សព្វផ្សាយ | មន្ទីរកសិកម្ម | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | ២១ កញ្ញា | ក្រុមអ្នកទទួលផល ៩នាក់ | ភូមិ ជើងភ្លើង | សម្ភាសន៍ជាក្រុម |
| ៤ | ២១ កញ្ញា | លោក ឃុន សោមអ្នកទទួលផលផ្ទាល់ | ភូមិ ជើងភ្លើង | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៥ | ២១ កញ្ញា | លោកស្រី ឃុន ឃៀ អ្នកមិនទទួលផល | ភូមិ ជើងភ្លើង | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | 16/AGR/0901-00 (NRML) |
| ចំណងជើង : | គម្រោងអភិវឌ្ឍន៍ប្រពន្ធ័កសិកម្មចំរុះ |
| ភ្នាក់ងារអនុវត្តន៍ : | មន្ទីរកសិកម្មខេត្ត |
| រយះពេល ( ចាប់ផ្តើម និងបញ្ចាប់) | 01/01/2009 ដល់ 31/12/2009 |
| រាជធានី ខេត្ត | រតនគិរី |
| ផ្នែក ,មន្ទីរជំនាញ | មន្ទីរកសិកម្មខេត្ត |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ នៃ គ.អ.ជ.ខ | 12,000.00 ដុល្លារ |
| តម្លៃសរុប ( ដុល្លារសហរដ្ឋអាមេរិក) | 12,000.00 ដុល្លារ |

## ក្រុមវាយតម្លៃនិងរៀបចំរបាយការណ៍:

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ |
|---|---|
| លោក កែវ ពៅ | ប្រធានផ្នែក CAU គ.ប្រ |
| កញ្ញា ទូច លក្ខិណា | ទីប្រឹក្សា M&E \PSDD |
| លោក មូរ រដ្ឋធានី | គ្រូបង្គោល M&E គ.ប្រ |
| លោក សៅ ពុទ្ធី | គ្រូបង្គោល M&E គ.ប្រ |
| លោក ប៉ែន សូរិយា | មន្ត្រី M&E គ.ប្រ |

## ខេត្តរតនគិរី

កាលបរិច្ឆេទ: ២០ / ១០ /២០១០

# មាតិកា


**អក្សរកាត់ ---------------------------------------------------------- ១**

**របាយការណ៍សង្ខេប ---------------------------------------------------- ២**

**១. ទិដ្ឋភាពរួមនៃការវាយតម្លៃ ------------------------------------------ ៥**

១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ-------- ៥

១.២. គោលបំណងអនុកិច្ចសន្យា---------------------------------------------- ៥

១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ-------------------------------------- ៦

១.៤. សំណួរវាយតម្លៃ---------------------------------------------------- ៦

១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ ------------------------------ ៦

១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ ---------------------------- ៨

**២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ --------------------------- ១០**

២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល --------------------១០

២.២. ការវាយតម្លៃសម្រេចលើអត្ថប្រយោជន៍ភ្លាមៗ ការសម្រេចបាននូវលទ្ធផល អនុកិច្ចសន្យា -- ១៣

ករណីសិក្សាទី១ (អ្នកទទួលផលផ្ទាល់) ----------------------------------------១៥

ករណីសិក្សាទី២ (អ្នកមិនទទួលផលផ្ទាល់) ------------------------------------ ១៦

២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង---------------------- ១៧

២.៤. សេចក្តីសន្និដ្ឋាន -------------------------------------------------២០

**ឯកសារដែលត្រូវភ្ជាប់ទី១ : ----------------------------------------------២៤**

បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យារបាយការណ៍និងឯកសារទាក់ទងផ្សេងៗ ដែលបានពិនិត្យ -------២៤

បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាសន៍/ជួបពិភាក្សា ------------------២៥

# អក្សរកាត់

**គ.ប្រ នៃ គ.អ.ជ.ខ :** គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត

**គ.ជ.អ.ប :** គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# របាយការណ៍សង្ខេប


គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ : មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យា នៃគ.ប្រខេត្តរតនគិរី រួមទាំងក្រុមការងារដែលជាមន្ត្រីបង្គោល M&Eមន្ទីរវិស័យបានធ្វើការវាយតម្លៃអនុកិច្ចសន្យាឆ្នាំ២០០៩ ដែលមានចំណងជើង (គាំទ្រដល់មន្ទីរកសិកម្ម ដើម្បីកាត់បន្ថយភាពក្រីក្រ) និងលេខអនុកិច្ចសន្យា 16/AGR/0901-00(NRML) ដែលជាអនុកិច្ចសន្យារវាងគ.ប្រនៃគ.អ.ជ.ខ និងមន្ទីរកសិកម្មខេត្ត ។ នេះជាផ្នែកមួយនៃគម្រោងពង្រឹងសមត្ថភាព គ្រូបង្គោលថ្នាក់ ក្រោមជាតិរបស់ផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.បដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

<u>គោលបំណងជាក់លាក់នៃការវាយតម្លៃនេះគឺ :</u>

១- ទាញយកការកត់ត្រា និងវិភាគតាមលក្ខណៈជាប្រព័ន្ធ ទៅលើលទ្ធផល និងសមិទ្ធផលនៃអនុកិច្ចសន្យាចំណុចខ្សោយ ធៀបទៅនឹងលទ្ធលផល គោលបំណងបន្ទាន់ និងស្ថានភាពបញ្ចប់នៃអនុកិច្ចសន្យា ព្រមទាំងកត់ត្រា នូវចំណុច រៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត ។

២-ពង្រឹងរបៀបធ្វើការវាយតម្លៃគម្រោងរបស់គ.ប្រនៃគ.អ.ជ.ខនៅក្នុងដំណើរការនៃការអនុវត្ត ការវាយតម្លៃ អនុវត្តតាមការណែនាំ និងឧបករណ៍ ស្តីពីការវាយតម្លៃអនុកិច្ចសន្យារបស់គ.ប្រ នៃ គ.អ.ជ.ខ ដែលរៀបចំដោយផ្នែក ត្រួតពិនិត្យ វាយតម្លៃនៃលេខាធិការដ្ឋាន គ.ជ.អ.ប ។ ក្រុមការងារវាយតម្លៃបានពិនិត្យអនុកិច្ចសន្យា របាយការណ៍រីកចម្រើន និងឯកសារផ្សេងទៀត រួមទាំងការចុះមូលដ្ឋានដោយប្រើវិធីសាស្ត្រដូចជាៈការសម្ភាសន៍ស៊ីជម្រៅ ការពិភាក្សាក្រុម ការសង្កេតផ្ទាល់ ។ ដោយសារធន ធាន និងពេលវេលាមានកំណត់ យើងធ្វើការវាយតម្លៃស៊ីជម្រៅ ទៅលើតែលទ្ធផលចំនួន១ និងសកម្មភាពចំនួន១ក្នុងអនុកិច្ចសន្យាតែប៉ុណ្ណោះ ហើយការសន្និដ្ឋាននេះ ត្រូវធ្វើឡើងតាមអ្វីដែលបាន រកឃើញជាក់ស្តែង ។


ឆ្លើយទៅនឹងសំណួរទាំង៥ នៃការវាយតម្លៃ :

១- សកម្មភាព និងលទ្ធផលដែលបានអនុវត្ត ធៀបនឹងផែនការ :

១.១ វគ្គបណ្តុះបណ្តាល ស្តីពីផលិតកម្មដំណាំស្រូវ អនុវត្តបាន ០១វគ្គ សំរេចបានលទ្ធផល ១០០%

- អ្នកចូលរួមសរុប ក្នុង១ឃុំ ៣០នាក់ ដែលមាន ២ ភូមិ ទំពូនរឿងធំ និងភូមិបង្កិត នៅស្រុកតាវែង

២-វគ្គបានធ្វើឱ្យស្ថានភាពប្រជាកសិករក្រុមគោលដៅរបស់គំរោងក្នុងមូលដ្ឋានមានការកែប្រែទិន្នផល ស្រូវពីទិន្នផលស្រូវតិចទៅច្រើន ។

៣- គោលបំណងបន្ទាន់បានបរិយាយច្បាស់លាស់ ហើយមានទំនាក់ទំនងជាមួយលទ្ធផល និង សកម្មភាព ក៏ប៉ុន្តែ វាមានកម្រិតខ្ពស់ពេក ដែលយើងនឹងពិបាកធ្វើការវាស់វែងបាន ។

៤-ស្ថានភាពនៅចុងបញ្ចប់នៃអនុកិច្ចសន្យា មិនបានរៀបរាប់ពីអ្វីដែលបានគ្រោង និងសម្រេចបាននោះទេ ប៉ុន្តែភ្នាក់ងារអនុវត្តបានរៀបរាប់ច្រើនពីវិធីសាស្ត្រគ្រប់គ្រងកិច្ចសន្យា និងទីតាំងវិធីក្នុងការតាមដានគំរោង ដូចនេះក្រុមការងារមានការលំបាកក្នុងការឆ្លុះបញ្ចាំង និងវាស់វែង នូវសមិទ្ធផលរបស់គម្រោងទៅនឹងស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា ប៉ុន្តែដោយគោលបំណងបន្ទាន់របស់គំរោងបានបង្កើតឡើងដូចនេះ ក្រុមការងារបានធ្វើការឆ្លុះបញ្ចាំងលទ្ធផលធៀបនិងគោលបំណងបន្ទាន់វិញ ។

៥- ជាក់ស្តែងក្រុមគោលដៅ និងសហគមន៍ នៅតែអនុវត្តសកម្មភាពបន្តរហូតដល់ក្រុមការងារចុះធ្វើការវាយតម្លៃ ដែលអាចធ្វើឱ្យគោលបំណងបន្ទាន់របស់អនុកិច្ចសន្យាទទួលបានជោគជ័យមួយកម្រិតដែរ ។

**អនុសាសន៍ដែលទាញចេញពីការវាយតម្លៃអនុកិច្ចសន្យាៈ**

១- លទ្ធផល និងអត្ថប្រយោជន៍ដែលបានមកពីការអនុវត្តអនុកិច្ចសន្យា ជាប្រយោជន៍ដល់សហគមន៍ វាបានឆ្លុះបញ្ចាំងនូវសមិទ្ធផល ដូចជាការផ្តល់នូវចំណេះដឹងផ្សាភ្ជាប់នឹងការអនុវត្តជាក់ស្តែង នៅមូលដ្ឋានដែលនាំមកនូវកំណើនផលិតកម្មដំណាំស្រូវ កំណើននូវទិន្នផលស្រូវបានមួយកំរិត និងជាប្រយោជន៍ក្នុងការធ្វើឱ្យ ប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជន តាមរយៈវគ្គផលិតកម្មដំណាំស្រូវ ។

២- ការអនុវត្តសកម្មភាពដំណាំស្រូវបានឆ្លើយតប និងតំរូវការជាក់ស្តែងរបស់សហគមន៍គោលដៅដែលបានស្នើឡើងតាមរយៈការធ្វើសមាហរណកម្មនៅថ្នាក់ស្រុក ដោយសហគមន៍គោលដៅបានយកចំណេះដឹង និងជំនាញដែលពួកគេទទួលបានទៅធ្វើជាប្រយោជន៍ ក្នុងការធ្វើឱ្យប្រសើរឡើងនូវជីវភាព រស់នៅរបស់ពួកគាត់ ក្នុងន័យរួមចំណែកកាត់បន្ថយភាពក្រីក្រ។ យ៉ាងហោចណាស់ក៏មានកសិករចំនួន

៤គ្រួសារក្នុង ចំណោមកសិករ ៣០គ្រួសារបានអនុវត្តនូវបច្ចេកទេសថ្មីក្នុងការដាំដុះស្រូវ តាមបែបប្រពលវប្បកម្ម និងទទួលបាន ទិន្នផលស្រូវកើនឡើង ។

៣- ការសិក្សាពីលទ្ធភាព និងធនធានរបស់កសិករនៅសហគមន៍អោយបានច្បាស់លាស់ (មានៈសំភារៈកសិកម្ម កំលាំងអូសទាញ រនាស់ នង្គ័ល និងដីស្រែ សំរាប់បង្កបង្កើនផល និងប្រពន្ធ័បង្ហូរទឹក គ្រប់គ្រាន់តែឬទេ... ដើម្បីអោយការអនុវត្តគម្រោងអាចឆ្លើយតប ជៀសវាងអនុវត្តដោយគ្រាន់តែស្គាល់ និងដឹងដែលវាអាចប៉ះពាល់ដល់ការចំណាយថវិការបស់គម្រោង ហើយភ្នាក់ងារអនុវត្តអាចត្រៀមអ្វីជាយុទ្ធសាស្រ្តដែលយើងត្រូវអនុវត្តមុនគេដើម្បីជួយដល់កសិករទាំងនោះ ។

៤- ការផ្ទេរចំណេះដឹងថ្មីដល់សហគមន៍ជនជាតិដើមភាគតិចត្រូវធ្វើឡើងដោយប្រុងប្រយត្ន័បំផុត និងត្រូវធ្វើការតាមដាន និងបង្ហាញពីរបៀបធ្វើអោយបានជិតដល់ ដូចជាការធ្វើបង្ហាញ ពីការសាប ស្ទូងស្រូវ... ដោយសាយតែពួកគេធ្លាប់តែធ្វើចំការពរនេចរដូចនេះចំណេះដឹងពិតជាខុសផ្លែកពីគ្នា ហើយការ តាមដានត្រូវធ្វើឡើងគ្រប់តំណាក់កាលសំខាន់ៗនៃវត្តរបស់សកម្មភាព ។

៥- ការលើកស្ទួយស្ថានភាពយេនឌ័រនៅក្នុងការងារកសិកម្មតំរូវអោយមានការរៀបចំយុទ្ធសាស្រ្តក្នុងការអនុវត្តអោយបានជាក់លាក់សិក្សាអោយបានច្បាស់លាស់ ដើម្បីអាចជួយដល់ស្រ្តីក្រីក្រ មានកូនច្រើននៅក្នុងបន្ទុក ហើយខ្វះកំលាងពលកម្ម ដូចនេះគម្រោងត្រូវមានយុទ្ធសាស្រ្តធ្វើដូចម្តេចដើម្បីពួកគេអាចទទួលផលប្រយោជ ន៍ពីគម្រោង ហ៊ើយអាចឈានទៅរកការកាត់បន្ថយភាពក្រីក្រពិតៗ ។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## *១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ*

រៀងរាល់ឆ្នាំ គ.ជ.អ.ប បានផ្តល់ថវិកាដល់គ.ប្រ នៃគ.អ.ជ.ខ ដើម្បីធ្វើការវិភាជន៍ជូនមន្ទីរវិស័យ ក្នុងគោលបំណងគាំទ្រនូវតំរូវការរបស់មូលដ្ឋាន ដើម្បីពង្រឹងដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅ ថ្នាក់ក្រោមជាតិ។ ដោយឡែកការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈជាប្រព័ន្ធមិនបានអនុវត្តទេ បន្ទាប់ពីគម្រោង ទទួលបានថវិកាតិចតួចមកដោយគ្រាន់តែសិក្សាយកពត៌មានខ្លះតែប៉ុណ្ណោះ ដើម្បីយកមកចងក្រង ជាមេរៀនបទពិសោធន៍ ប៉ុន្តែនៅឆ្នាំ ២០១០នេះដោយមានការការគាំទ្រ ផ្នែកថវិកា និងបច្ចេកទេស ពីផ្នែកត្រួត ពិនិត្យ វាយតម្លៃនិងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែករដ្ឋបាល និងគ្រប់គ្រង កិច្ចសន្យាគ.ប្រនៃគ.អ.ជ.ខក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យា ដែលបានរៀបចំ រួមគ្នា ជាមួយភ្នាក់ងារអនុវត្តន៏ដែលមានលេខអនុកិច្ចសន្យា 16/AGR/0901-00 (NRML) និងឈ្មោះ អនុកិច្ចសន្យា គាំទ្រដល់ មន្ទីរកសិកម្ម ដើម្បីកាត់បន្ថយភាពក្រីក្រ ដំណើរការលទ្ធផលដែលបានរកឃើញ និងការសន្និដ្ឋាននៃការវាយតម្លៃត្រូវបានកត់ត្រា ហើយនឹងបង្ហាញតាមរយៈរបាយការណ៍ស្តីពីការវាយ តម្លៃនេះ។

## *១.២. គោលបំណងអនុកិច្ចសន្យា*

គោលបំណងនៃកិច្ចសន្យានេះ នឹងរួមជាវិភាគទានដល់កម្មវិធីគ.អ.ជ.បដែលមានគោលបំណងកាត់បន្ថយភាពក្រីក្រ តាមរយៈអភិបាលកិច្ចល្អ។ ភារៈកិច្ចដើម្បីលើកតម្កើងបច្ចេកវិជ្ជាដល់កសិករតាមរយៈការផ្សព្វផ្សាយ បច្ចេកទេសអំពីផលិតកម្មដំណាំស្រូវ ធ្វើឱ្យកសិករមានកំណើនខ្លះនៃការផលិតស្រូវ។ តួនាទីរបស់មន្ទីរកសិកម្មខេត្ត ជាពិសេស ការិយាល័យក្សេត្រសាស្ត្រ គឺត្រូវផ្តល់ការផ្សាព្វផ្សាយប្រកបដោយប្រសិទ្ធភាពតាមរយៈការវិនិយោគសម្រាប់ការអភិវឌ្ឍមូលដ្ឋាន ដែលក្រោមការរំពឹងទុកថា ចំនួន និង គុណភាពផលិតផលស្រូវ មានភាពទទួលយកបាន និង សមស្រប។ កម្មវិធីនឹងចូលរួមចំណែកក្នុងការរក្សាស្ថេរភាពស្បៀង ដែលជាបញ្ហាមួយយ៉ាងសំខាន់ និងជាចម្បងក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនតាមភូមិ ឃុំនានា និងតាមទីជនបទដាច់ស្រយាល ។

### ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូលដោយផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និងតម្លាភាព។ ដូច្នេះទំហំនៃការវាយតម្លៃ មានដែនកំណត់ តាមទំហំនៃអនុកិច្ចសន្យា និង រាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខ័ណ្ឌការងារ នៃការវាយតម្លៃ ។ គោលបំណង នៃការវាយតម្លៃ គឺៈ ក) ទាញយកការកត់ត្រានិងវិភាគជាប្រព័ន្ធទៅលើ សមិទ្ធផលនៃអនុកិច្ចសន្យា និង ចំណុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុង បញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំង កត់ត្រានូវ ចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើង នៅពេលអនាគត និង ខ) ដើម្បីពង្រឹងរបៀបធ្វើ ការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត ។

### ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា?

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ?

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹង ការរៀបចំអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

### ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើៈ

១) ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំណត់ហេតុប្រជុំ និងរបាយការណ៍ បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធ

ដែលមាន នៅក្នុង ផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៍ ។
២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗ រួមមាន : អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផលផ្ទាល់ និងមិនផ្ទាល់ ២ នាក់ និងអ្នកពាក់ព័ន្ធ ៣នាក់ ។
៣) វិធីសាស្ត្រចុះពិនិត្យតំបន់អនុវត្តន៍គម្រោង និងសង្កេតមើលសកម្មភាពពិភាក្សាក្រុម និងករណីសិក្សា ។
៤) ចុះពិនិត្យតំបន់អនុវត្តន៍គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភ័ស្តុតាងគម្រោងដោយផ្ទាល់ ។
៥) <u>វិភាគទិន្នន័យ និងបកស្រាយៈ</u> ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់ ។
៦) <u>ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៍</u> ដោយភ្នាក់ងារអនុវត្តន៍ និងអ្នកពាក់ព័ន្ធតាមរយៈព័ត៌មានត្រឡប់ដែលទទួលបានពីការបង្ហាញដោយសង្ខេប ដែលបានធ្វើឡើងនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ ការវាយតម្លៃ ត្រូវធ្វើតាម"គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា" និងវិធីសាស្ត្រដែលបានណែនាំ។ ដូច្នេះដំណើរការត្រូវ បានធ្វើឡើងដោយមានទម្រង់ការណែនាំ និងតម្លាភាព រួមទាំងការចូលរួមពីអ្នកពាក់ព័ន្ធ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយ គ.ប្រ និង អ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយការប្រឹងប្រែង ត្រូវធ្វើឡើង ដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត ។

២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត : វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោងនៅ ពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និងបទពិសោធន៍ពីមុនមក។ ទោះបីជាយ៉ាងណាក៏ដោយគោលបំណង សំខាន់ គឺដើម្បី "រៀនធ្វើដោយការអនុវត្តផ្ទាល់"។ អ្នកវាយតម្លៃ បានទទួលការគាំទ្រដោយមានគោលការណ៍ការ ណែនាំឧបករណ៍និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។

៣) បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យាៈ ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្ម-ភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និងជោគជ័យទេ។ មួយទៀតទំនាក់ទំនងសង្ខេប តាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាង លទ្ធផល ទៅនឹងគោលបំណងបន្ទាន់ មិនត្រូវ បានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនង ទាំងនោះវាមិនសូវស៊ីគ្នាទេ។

៤) ដោយយើងមិនមានសូចនាករបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍" ដែលជាកម្រិត អត្ថប្រយោជន៍ទៅលើគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ ។

៥) ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិត ទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ។ យើងអាចវាយតម្លៃតែទៅលើ (កសិករដែលទទួលបានការបណ្តុះបណ្តាល) ដែលជាសកម្មភាពនៃអនុកិច្ចសន្យាលម្អិត តាមរយៈការ សម្ភាសន៍ស៊ីជម្រៅដល់ក្រុមពិភាក្សានិង
ការចុះពិនិត្យជាក់ស្តែងតំបន់អនុវត្តគម្រោង ។

៦) ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាមិនអាចធ្វើទៅបានទេព្រោះចំណុច គូនៃផ្នែកទី៣ ក្នុងឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ ឬមិនពេញលេញ។ ការងារនេះនឹងកាន់តែមានសុពលភាព និងពោរពេញទៅដោយព័ត៌មាន បើសិនជាចំណុចដែលបានរៀបរាប់ខាងលើ នេះត្រូវបានដោះស្រាយ ។

<u>ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធនី:</u>

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ (16/AGR/0901-00)( MRML) និង ដែនកំណត់ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ ។

២) ការវាយតម្លៃនេះលម្អិតតែទៅលើលទ្ធផលជ្រើសរើសកសិករសំរាប់ការបណ្តុះបណ្តាលពីផលិតកម្មដំណាំស្រូវដែលជាសកម្មភាពនៃអនុកិច្ចសន្យា ។

៣) ការវាយតម្លៃនេះផ្តោតទៅលើការអនុវត្តគម្រោងរបស់ភ្នាក់ងារអនុវត្តន៍ និងអ្នកទទួលផលពីគម្រោង ដោយឡែកមិនមានការវាយតម្លៃទៅលើគ.ប្រ នៃគ.អ.ជ.ខ និង គ.ជ.អ.ប ទេ ។

ហេតុដូច្នេះរបាយការណ៍នៃការវាយតម្លៃ លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ដែលបានលើកឡើងត្រូវពិនិត្យ ដោយយោងទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ។

# ២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## *២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល*

លទ្ធផលទី១ :ជ្រើសរើសកសិករដើម្បីធ្វើការបណ្តុះបណ្តាលអំពីផលិតកម្មដំណាំស្រូវ

ផ្នែក-ក :ការសម្រេចជាក់ស្តែងធៀបនឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | វគ្គបណ្តុះបណ្តាលស្តីពីការផលិតកម្មដំណាំស្រូវ<br>- ១វគ្គ<br>- ១ថ្ងៃ<br>- អ្នកចូលរួម៣០ នាក់ | អនុវត្ត ០១វគ្គ ១០០% |

**ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល**

អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និងសកម្មភាពរបស់អនុកិច្ចសន្យាដែលបានគ្រោងទុក អ្នកចូលរួម ទាំងអស់នៅក្នុងក្រុមពិភាក្សា ដែលជាសិក្ខាកាមនៃវគ្គផលិតកម្មដំណាំស្រូវបានបញ្ជាក់ថា គេបានទទួល នូវចំណេះដឹង និងជំនាញដែលទាក់ទងទៅនឹងបច្ចេកទេសក្នុងការផលិតស្រូវ ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ នោះ គឺថាពួកគាត់នៅមានការចងចាំផ្នែក ទ្រឹស្តីពីវគ្គបណ្តុះបណ្តាលបច្ចេកទេស ផលិតស្រូវទោះបីជាវគ្គ បានបញ្ចប់យូរទៅហើយក្តី (ឆ្នាំ២០០៩) វិធីសាស្ត្រដែលមន្ទីរជំនាញ បានយកទៅបណ្តុះបណ្តាល ធ្វើឱ្យសិក្ខា-កាមភាគច្រើនចូលចិត្ត និងមានការចាប់អារម្មណ៍ ហើយវិធីសាស្ត្រ ដែលយកមកប្រើរួមមាន ការបំផុស គំនិតតាមរយៈបង្ហាញផ្ទាំងរូបភាព និងពិភាក្សាក្រុមជាដើម ។ល។ ក្រុមគោលដៅទទួលបានចំណេះដឹង និងមានការបង្ហាញពីរបៀបបច្ចេកទេសធ្វើស្រែ ឱ្យត្រូវទៅស្ថានភាព ក្នុងមូលដ្ឋាន ទាំងមូលមានការផ្លាស់ប្តូរ និងមានការហូបចុកបានគ្រប់គ្រាន់មួយចំនួនតូច ដូច្នេះការ កើនឡើង នៃការធ្វើស្រែរបស់ប្រជាជនមានជីវភាពធូរធារជាងមុន ដោយសារការផ្លាស់ផ្តូរ

ពីការចំការទៅធ្វើស្រែ ។ ទន្ទឹមនឹងលទ្ធផលខាងលើនេះក៏នៅ មានបញ្ហាមួយចំនួនដោយក្រុមគោលដៅមិនយក ចំណេះដឹង ទៅផ្សព្វផ្សាយបន្ត និងមិនអនុវត្តបានទូលំ ទូលាយនៅក្នុងសហគមន៍ដោយសារតាំងពីបុរាណមក ពួកគាត់ទំលាប់ការដាំស្រូវចំការ ម្យ៉ាងវិញទៀត ដោយយោងលើលក្ខណៈភូមិសាស្ត្រមិនអំណោយផល ព្រោះតំបន់ខ្លះនៅលើភ្នំ ផ្ទៃដីស្រែមានតិចតួច ហើយ ពួកគាត់ពុំមានសំភារៈគ្រប់គ្រាន់ក្នុងការធ្វើស្រែ ។

## *២.២. ការវាយតម្លៃសម្រេចលើអត្ថប្រយោជន៍ភ្លាមៗ ការសម្រេចបាននូវលទ្ធផល អនុកិច្ចសន្យា*

**ផ្នែក -ក: ការសម្រេចបាននូវស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា**

| ស្ថានភាពនៅពេលបញ្ចប់កិច្ចសន្យា (១) | លទ្ធផលប្រសើរឡើងជាក់ស្តែងនៅពេល បញ្ចប់ អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| វគ្គបណ្តុះបណ្តាលផលិតកម្មដំណាំស្រូវនេះ មាន ក្រុមគោលដៅចូលរួមចំនួន ៣០នាក់ ស្រី១៣ នាក់មាន២ឃុំ ក្នុង១ភូមិ មាន១៥នាក់នៅក្នុងស្រុកតាវែង ។ | ក្រុមគោលដៅចូលរួមមានចំនួន ៣០នាក់ ស្រី០៦នាក់ បានទទួលវគ្គបណ្តុះបណ្តាល ស្តីពី ផលិតកម្មដំណាំស្រូវ ដែលជាតំរូវការរបស់ក្រុមកសិករគោលដៅ មន្ទីរបាន ជ្រើសរើសតាមការស្ម័គ្រចិត្ត និង ផ្អែកលើលក្ខណៈ វិនិច្ឆ័យសមស្របដែរត្រូវជ្រើសរើស។ វគ្គបានឆ្លើយតប នៅនឹងតម្រូវការស្របពេល ដែលស្ថានភាពសហគមន៍ មូលដ្ឋានកំពុងជួបប្រទះ នូវបញ្ហាខ្វះខាត់ស្បៀងហើយ ទាមតាឱ្យមានការបណ្តុះបណ្តាលនូវបច្ចេកទេស ផលិត កម្មដំណាំស្រូវបន្ថែម ក្នុងការបង្កើនទិន្នផលស្រូវ។ កសិករដែលទទួលបានចំណេះដឹងពី វគ្គបណ្តុះបណ្តាល ផលិតកម្មដំណាំស្រូវ បានយកទៅអនុវត្តលើដីស្រែរបស់ ខ្លួនទិន្នផលស្រូវមានការកើនឡើងជាង កាលពីឆ្នាំមុន បន្តិចគឺអាចកាត់បន្ថយការខ្វះខាតស្បៀងបានមួយចំនួន |

**ផ្នែក -ខ: ការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា**

| ធាតុនៃទិសដៅបន្ទាន់ (១) | ការសម្រេចបាន/លទ្ធផលជាក់ស្តែង នៅពេលបញ្ចប់ អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| ដោយផ្អែកទៅសភាពការណ៍នៃបញ្ហា របស់ប្រជា | ស្របតាមតម្រូវការជាក់ស្តែង របស់កសិករមូលដ្ឋាន |

| | |
|---|---|
| កសិករ ដែលកំពុងកើតមាន ហើយត្រូវការជាចាំបាច់នូវ ការដោះស្រាយផ្នែកផលិត ដោយផ្តោតសំខាន់ ការបង្កើនផលិកម្មដំណាំស្រូវ ប្រកបដោយប្រសិទ្ធភាព ក្នុងគោលបំណងចង់ឱ្យកសិករមានស្បៀងហូបគ្រប់គ្រាន់ បង្កើនប្រាក់ចំណូលគ្រួសារ និងអាចបន្សាំខ្លួនជាមួយការប្រែប្រួលស្ថានភាពរស់នៅក៏ដូចជា ការប្រែប្រួលបរិស្ថានតាមរយៈ ការអនុវត្តសកម្មភាពទាំងនេះជាប្រពន្ធ័។ | មន្ទីរកសិកម្មខេត្តបានរៀបចំនូវផែនការ សកម្មភាពមួយចំនួន<br>ដើម្បីដោះស្រាយបញ្ហារបស់ពួកគាត់ស្រប តាមស្ថានភាពតំបន់។ បើទោះបីការរៀបចំផែនការ សកម្មភាពបានល្អទំនងនឹងដោះស្រាយបញ្ហាខ្វះខាត ស្បៀងរបស់ កសិករបានមួយកំរិត ប៉ុន្តែបើក្រឡេកមើលទៅលើការអនុវត្តកិច្ចសន្យាជាក់ស្តែង ពិសេសការចូលរួមរបស់កសិករ និងវិធីសាស្ត្រវាយតម្លៃបែបគុណភាពយើងមិនអាចវាយតម្លៃឃើញថា តើគោល បំណងបន្ទាន់ អាចដោះស្រាយបានកម្រិតណានោះ ឡើយ។ |

**ផ្នែក-ឥ: ការវាយតម្លៃអត្ថប្រយោជន៍ជារួមដែលទទួលបាន**

| |
|---|
| តាមរយៈការពិភាក្សាក្រុមប្រឹក្សាឃុំបានបង្ហាញថា កសិករមានការពេញចិត្តចំពោះផលប្រយោជន៍ ដែលអនុកិច្ចសន្យានេះជាពិសេសចំណេះដឹង និងបច្ចេកទេសនៃការធ្វើស្រូវ។ ពួកគាត់បានទទួលស្គាល់ថាវាមានសារៈប្រយោជន៍ សម្រាប់គ្រួសារ ក៏ដូចជាសហគមន៍ទាំងមូលព្រោះជាធម្មតាប្រជាកសិករនៅតំបន់នេះភាគច្រើនធ្វើស្រែចំការទៅតាមបែបបុរាណ និងតាមទំនៀមទំលាប់ប្រពៃណីរបស់ពួកគាត់មិនដែលទទួលបាននូវការបណ្តុះបណ្តាល់ពីជំនាញបច្ចេកទេសផលិកម្មដំណាំស្រូវនេះទេ។ ទោះជាលទ្ធផលខាងលើនេះមានលក្ខណៈល្អប្រសើរក៏ដោយ ប៉ុន្តែទំហំនៃការផ្សព្វផ្សាយពីផលិតកម្មដំណាំស្រូវដល់ប្រជាកសិករនៅមិនទាន់បានទូលំទូលាយនៅឡើយ ហើយចំណេះដឹងរបស់ប្រជាកសិករដែលបានចូលរួម នៅមានកំរិត ការយកទៅអនុវត្តផ្ទាល់របស់ពួកគាត់ក៏នៅមិនទាន់បានល្អប្រសើរនោះការផ្សព្វផ្សាយបន្តនៅមិនទាន់បានអនុវត្តជាហេតុ ធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនទៀត ដែលមិនបានទទួលផលពីគម្រោងនេះ មិនទាន់មានជំនឿលើបច្ចេកទេសការផ្សព្វផ្សាយផលិកម្មដំណាំស្រូវនេះឡើយ ។ |

*ករណីសិក្សាទី១   (អ្នកទទួលផលផ្ទាល់)*



លោកជួល ខ្ទេង

លោក ជួល ខ្ទេង បាននិយាយថា: បន្ទាប់ពីបានទទួលការបណ្តុះបណ្តាលពីផលិតកម្មដំណាំស្រូវ គម្រោងកម្មវិធីរបស់មន្ទីរកសិកម្មខេត្តរតនគិរីនៅក្នុង ឆ្នាំ២០០៩ បច្ចុប្បន្ននេះជីវភាពគ្រួសារខ្ញុំ មានភាពល្អប្រសើរឡើង។ លោក ជួល ខ្ទេង ភេទប្រុស អាយុ៤៥ឆ្នាំ ជនជាតិគ្រឹង សញ្ជាតិខ្មែរ ជាអ្នកទទួលផលផ្ទាល់ពីគម្រោងកម្មវិធីរបស់ គ.ជ.អ.ប ដែលបានអនុវត្តនៅភូមិបង្កិត ឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនគិរី ។ លោកមានប្រពន្ធ និងមានកូន៥នាក់ ស្រី៣នាក់ គាត់បាននិយាយទៀតថា: ពីមុនគាត់មានជីវភាពលំបាករស់នៅពឹងតែមុខរបរចញ្ចឹមសត្វបន្តិចបន្តួច និងការកាប់ព្រៃដាំស្រូវចំការតែប៉ុណ្ណោះ ប៉ុន្តែការកាប់ព្រៃដាំស្រូវនេះ មិនអាចធ្វើឱ្យគាត់មានស្រូវហូបគ្រប់គ្រាន់ទេ គឺមានការខ្វះខាតស្រូវអង្ករហូបសឹងតែរៀងរាល់ឆ្នាំ។

ក្រោយពីបានចូលរួមវគ្គបណ្តុះបណ្តាលពីផលិតកម្មដំណាំ ស្រូវរួចមក គាត់យកចំណេះដឹង និងបច្ចេកទេស ពីការដាំដំណាំស្រូវនោះ យកទៅអនុវត្តក្នុងការបង្ក បង្កើនផលរបស់គាត់ធ្វើឱ្យគាត់មាន ស្រូវហូបគ្រប់គ្រាន់បានមួយកំរិត ដោយគាត់មិនចាំបាច់ទៅកាប់ ព្រៃធ្វើចំការទៀតទេ។ ម្យ៉ាងទៀតស្រូវរបស់គាត់អាចផ្គត់ផ្គង់ជីវភាពក្នុងគ្រួសាររបស់គាត់បានធូរធារ ច្រើនជាងមុន ពេលនេះខ្ញុំមានការសប្បាយចិត្ត នៅពេលដែរប្រៀបធៀប ទៅនឹងស្ថានភាពពីមុន របស់ខ្ញុំ ហើយលោក ជួល ខ្ទេង មិនមែនយល់ដូច្នេះតែម្នាក់ឯងទេ។ ប្រជាពលរដ្ឋនៅក្នុងភូមិបង្កិត ភាគច្រើនក៏មានអារម្មណ៏ដូចគាត់អញ្ចឹងដែរ ។

*ករណីសិក្សាទី២ (អ្នកមិនទទួលផលផ្ទាល់)*



អ្នកមីង ឈឹម យឿម

អ្នកមីង ឈឹម យឿម អាយុ៤២ឆ្នាំ ភេទស្រី ជនជាតិគ្រឹង សញ្ជាតិខ្មែរ ជាស្ត្រីមេម៉ាយ កូន៤នាក់ ស្រី២នាក់។ គាត់រស់នៅភូមិបង្កិត ឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនគីរី។ គាត់មិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលពីផលិតកម្មដំណាំស្រូវ របស់កម្មវិធីគ.ជ.អ.ប ដែលអនុវត្តដោយមន្ទីរកសិកម្មខេត្តរតនគីរី នៅក្នុងឆ្នាំ ២០០៩ទេ។ មូលហេតុដែលគាត់មិនត្រូវបាន គេជ្រើសរើសឱ្យចូលរួមគម្រោង ដោយសារក្នុងភូមិនេះ គេជ្រើសរើសតែអ្នកដែលមានកំលាំងពលកម្ម និងមានផ្ទៃ ដីស្រែសមស្រប ។ ម្យ៉ាងទៀតគាត់មិនបានដឹងពតិមាន នៅពេលដែលគេមក ជ្រើសរើស។ គាត់និយាយទៀតថា វគ្គបណ្តុះបណ្តាលដំណាំស្រូវ នេះមានសារៈ-សំខាន់ណាស់ ព្រោះគាត់សង្កេតឃើញថា បន្ទាប់ពី លោក ជួង ខ្មែង បានចូល រៀនចប់ គាត់មានចំណេះដឹងនិងបច្ចេកទេសពីដំណាំស្រូវ រួចគាត់យកទៅ អនុវត្ត ជាក់ស្តែងឃើញថា ទទួលបានលទ្ធផលល្អ ដោយគាត់មានស្រូវហូបគ្រប់គ្រាន់។ ដោយសង្កេតឃើញបែបនេះ អ្នកមីង ឈឹម យឿម មានការសោកស្តាយ ព្រោះ មិនបានចូលរៀនជំនាញនេះដូច លោក ជួង ខ្មែង ហើយគាត់ចង់ចេះជំនាញនេះ ណាស់ ។ ទៅពេលខាងមុខអ្នកមីង ឈឹម យឿម ព្យាយាមនិងសន្យាចូលរួមនៅក្នុងគម្រោង នេះជាក់ជាមិនខាន ដោយគាត់មើលឃើញថា លោក ជួង ខ្មែង មាន ជីវភាពធូរធារ មានស្រូវហូបគ្រប់គ្រាន់ជាងពេលមិនទាន់បានចូលក្នុងគម្រោង ។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

### ផ្នែក-ក: ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅនិងតម្រូវការមន្ទីរវិស័យ មូលដ្ឋាន គ.ជ.អ.ប និងការកាត់បន្ថយភាពក្រីក្រ:

សំគាល់:ពិន្ទុ ១= ខ្សោយណាស់២= ខ្សោយ ៣=មធ្យម ៤=ខ្លាំង ៥=ខ្លាំងណាស់)

| ល.រ (១) | ធាតុ (២) | ទំនាក់ទំនងតក្កភាព (៣) | បរិយាយច្បាស់លាស់( ៤) | សង្ខេបការវាយតម្លៃ (៥) |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៤ | ៤ | សកម្មភាពដែលបានលើកឡើងពិតជាមានទំនាក់ទំនងតក្កជាមួយនឹងលទ្ធផលដែលបានសរសេរ ក្នុងឯកសារអនុកិច្ចសន្យា។ ឧទាហរណ៍ **លទ្ធផលទី១** ទាក់ទងនឹងការបណ្តុះបណ្តាល ពីផលិតកម្ម ដំណាំស្រូវ មានសកម្មភាពជាក់លាក់ អំពីបណ្តុះបណ្តាលឈើហូបផ្លែស្មើ៦០នាក់ស្ត្រី០៤នាក់ មានសកម្មភាពជាក់លាក់អំពីបណ្តុះបណ្តាលការធ្វើជីកំប៉ុស្តដែលមានសិក្ខាកាមសរុប ៣០នាក់ ស្ត្រី៥នាក់ រយះពេល ២ថ្ងៃ ។ **លទ្ធផលទី២**ការបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិអ្នកចូលរួម១៣នាក់ ស្ត្រី០៤នាក់ និងការចាក់វ៉ាក់សាំង សារទឹកគោក្របីមានចំនួន១០៩៦ក្បាល់ |
| ២ | លទ្ធផល | ៤ | ៣ | លទ្ធផលនីមួយៗត្រូវបានសរសេរច្បាស់លាស់ដោយមានសូចនាករជាក់លាក់ និងអាចវាស់វែងបាន ។លទ្ធផលនីមួយៗ |

| | | | | |
|---|---|---|---|---|
| | | | | អាចបំពេញឱ្យគ្នា ទៅវិញទៅមក គឺប្រជាពលរដ្ឋធ្វើការដាំស្រូវចំការច្រើន ធ្វើឱ្យបាត់បង់ព្រៃឈើច្រើនកិច្ចសន្យានេះក៏បានផ្តល់ជំនាញសម្រាប់ការបង្កបង្កើនផលស្រូវផងដែរ ។ ក៏ប៉ុន្តែលទ្ធផលទាំងអស់នេះនៅមិនទាន់ធ្វើឱ្យគោលបំណងបន្ទាន់មិនទាន់សម្រេចបាននៅឡើយទេព្រោះថាគោលបំណងដែលសរសេរនៅផ្នែក**ខ** នៃអនុកិច្ចសន្យា ជាគោលដៅរបស់ **គ.ជ.អ.ប** ។ |
| ៣ | - គោលបំណងបន្ទាន់ (គោលបំណងស្ថិតក្នុងចំណុច "ខ" នៃផ្នែកទី៣) | ៤ | ២ | គោលបំណងបន្ទាន់មិនបានសរសេរក្នុងកម្រិតលទ្ធផលដែលសម្រេចបាននៃអនុកិច្ចសន្យា ដែលជាអត្ថប្រយោជន៍រយៈពេលខ្លីទេ តែវាជាគោលដៅកាត់បន្ថយភាព ក្រីក្ររបស់ **គ.ជ.អ.ប** ។ |
| ៤ | ស្ថានភាពចុងបញ្ចប់នៃអនុកិច្ច សន្យា (ចំណុច គ នៃផ្នែកទី៣) | ១ | ១ | ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាមិនបានបរិយាយច្បាស់លាស់នោះទេ នូវអ្វីដែលគម្រោងចង់សំរេចបានក្រោយពីការអនុវត្តកិច្ចសន្យា ។<br>ប៉ុន្តែមានការរៀបរាប់ពីលក្ខណៈនៃការគ្រប់គ្រងគម្រោង និងវិធីសាស្ត្រចុះតាមដានគម្រោង |

**ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារ:**

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.ជ.អ.ខ :** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | ជំនាញការរៀបចំនៅមានកម្រិតនៅឡើយត្រូវការជួយពង្រឹងសមត្ថភាពបន្ថែម ។ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យការអនុវត្តន៍ របស់ភ្នាក់ងារអនុវត្តន៍ | ការគាំទ្រមានភាពរលូន គ្មានការប្រឈម និងឧបសគ្គ ដែលនាំឱ្យរាំងស្ទះដល់កិច្ចដំណើរការរបស់គម្រោង នោះឡើយ ។ |
| ៣ | ការត្រួតពិនិត្យ និង កត់ត្រាឯកសារអនុកិច្ចសន្យា | តាមធម្មតា ឬតាមទម្លាប់  នីតិវិធីដែលបានធ្វើការកត់ត្រានិងទុកដាក់ឯកសារគួរត្រូវបានកែលម្អ |
| **ពីខាងភាគីអនុវត្តន៍កិច្ចសន្យា :** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | មន្ត្រីមានជំនាញ និងបទពិសោធន៍គ្រប់គ្រាន់ |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និងលទ្ធផល | ការអនុវត្តសកម្មភាព និង លទ្ធផលមិនទាន់ពេលវេលាតាមការគ្រោងទុក ។ |
| ៦ | ការរាយការណ៍ការរីកចម្រើន និងការកត់ត្រា ឯកសារ | មានរបាយការណ៍ការរីកចម្រើនប៉ុន្តែមិនឃើញមានការកត់ត្រាឯកសារផ្សេងៗដូចជាកំណត់ហេតុប្រជុំនិង ឯកសារចុះតាមដានការអនុវត្តគម្រោង |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | ត្រូវបានបំពេញ តាមលក្ខខណ្ឌកិច្ចសន្យា |
| **ទាំងខាង គ.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យា :** | | |

| | | |
|---|---|---|
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្ទត់" (ចំណុច-ង ផ្នែកទី៣ ) និងបញ្ហាប្រឈម | មានការរៀបចំផែនការគ្រប់គ្រងនិងបានកំណត់ "ហានិភ័យនិងកត្តាសន្ទត" និងបញ្ហាប្រឈម ។ |
| ៩ | ការបញ្ជ្រាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | មានការបញ្ជ្រាបយេនឌ័រទៅក្នុងគម្រោងបាន៣០% |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ ( ចំណុច-ឆ ផ្នែកទី៣) | គំរោងមានបញ្ចូលការគ្រប់គ្រងធនធានធម្មជាតិ ដូចជាការកាត់បន្ថយការរុករានដីព្រៃដាំស្រូវចំការ |
| ១១ | ការថែរក្សា (និរន្តភាព) ( ចំណុច-ជ ផ្នែកទី៣) | ក្រោយពេលបញ្ចប់វគ្គ សិក្ខាកាមទាំងអស់នឹងបាន ទទួលចំណេះដឹងសម្រាប់ចាប់ផ្តើមមុខរបរដោយ ខ្លួនឯង។ មិនតែប៉ុណ្ណោះពួកគាត់នឹងទទួលបាននូវ ការគាំទ្របច្ចេកទេសបន្ថែមពេលគាត់ អនុវត្តសក ម្មភាពធ្វើស្រែដោយមានការចុះពិនិត្យសាកសួរ ផ្ទាល់ពីជនបង្គោល និងគ្រូបង្ហាត់ នៅពេលដែលពួក គាត់មានចម្ងល់ឬបញ្ហានានាពាក់ព័ន្ធទៅនឹងការ ធ្វើស្រែ ។ |

## ២.៤. សេចក្តីសន្និដ្ឋាន

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យាត្រូវបានអនុវត្តដូចការគ្រោងទុក។ ភាគីអនុវត្តអនុកិច្ចសន្យាមានមន្ត្រីមានសមត្ថភាព បទពិសោធន៍ និងធនធានគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោងដែលបានចុះកិច្ចសន្យា ជាមួយ គ.ប្រ នៃ គ អ ជ ខនៅក្នុងឆ្នាំ២០០៩ ។ |

| | |
|---|---|
| ២ | លទ្ធផល និងអត្ថប្រយោជន៍ ដែលបានមកពីការអនុវត្តអនុកិច្ចសន្យាជាប្រយោជន៍ដល់សហគមន៍ វាបានឆ្លុះបញ្ចាំងនូវសមិទ្ធិផល ដូចជាការផ្តល់នូវចំណេះដឹងផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែងនៅមូលដ្ឋានផលិតកម្មដំណាំស្រូវ ។សកម្មភាពអនុកិច្ចសន្យាបានអនុវត្តដោយជោគជ័យ និងមានការពេញចិត្តក្នុងការចូលរួមពីសហគមន៍តំបន់គោលដៅនូវសមិទ្ធផលដែលបានផ្តល់ឱ្យពួកគាត់ ។ |
| ៣ | ក្នុងអំឡុងពេលអនុវត្តអនុកិច្ចសន្យាមានជួប ឧបសគ្គ និងការប្រឈមខ្លះៗ ដូចជា : កត្តាធនធានមនុស្ស ធម្មជាតិ (គ្រោះទឹកជំនន់ និងព្យុះកេត សាណា) ទោះបីជាជួបប្រទះនូវបញ្ហា ប្រឈមដូចបានរៀបរាប់ខាងលើ ក៏គម្រោងនៅតែអនុវត្តបានជោគជ័យតាមការគ្រោងទុក ផលប៉ះពាល់នៃគម្រោងគឺមានទំហំតូច ។ |

<u>ចំណុចរៀនសូត្រ</u> :

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ផលប៉ះពាល់នៃការអនុវត្តអនុកិច្ចសន្យា និងលទ្ធផលដែលសម្រេចបាន នៅតែមាននិរន្តភាព ក្នុងកម្រិត ខ្ពស់ ព្រោះអនុកិច្ចសន្យាបានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ជាអាទិភាពរបស់ក្រុមគោលដៅ និងសហគមន៍ ។ |
| ២ | ការបរិយាយច្បាស់លាស់នូវ "គោលបំណងបន្ទាន់" (ចំនុច ខ ផ្នែកទី៣ ) ក្នុងកម្រិត ដែលអាចវាស់វែងបាន ជា ប្រការសំខាន់បំផុត សម្រាប់ការកត់ត្រាទុកនូវលទ្ធផលរបស់អនុកិច្ចសន្យានិងផលប្រយោជន៍ដែលមាន ដើម្បី ជួយសម្រួលដល់ការវាយតម្លៃលទ្ធផល និងគោលបំណងបន្ទាន់នៃអនុកិច្ចសន្យា។ |
| ៣ | ការបរិយាយច្បាស់លាសនូវ "ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា "(ចំនុច គ ផ្នែកទី៣) ជាការសំខាន់សម្រាប់ធ្វើការឆ្លុះបញ្ចាំងនូវសមិទ្ធផល ដែលសម្រេចបាននៅក្នុងកម្រិតអត្ថប្រយោជន៍របស់លទ្ធផល ដែលអាចកើតមានឡើង។ |

អនុសាសន៍ៈ

| ល.រ | អនុសាសន៍ |
|---|---|
| ១ | ការរៀបរៀងអនុកិច្ចសន្យាមានលក្ខណៈទូលំទូលាយពេក ដោយក្តោបតែទៅលើការកាត់បន្ថយភាពក្រីក្រ មិនបានលំអិតច្បាស់លាស់លើចំណុចតម្រូវការបន្ទាន់សកម្មភាពរបស់លទ្ធផល និងអត្ថ-ប្រយោជន៍ ដែលបានគ្រោងទុក។ |
| ២ | ត្រូវតែពង្រឹងការទំនាក់ទំនងល្អជាប្រចាំ រវាងភ្នាក់ងារអនុវត្ត និង គ.ប្រ/គ អ ជ ខ ដើម្បីធ្វើឱ្យការអនុវត្តគម្រោងបានទទួលជោគជ័យប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ |
| ៣ | សកម្មភាពត្រូវអនុវត្តតាមផែនការដែលបានគ្រោងទុក ដើម្បីឱ្យអនុកិច្ចសន្យាទទួលបានជោគជ័យ |
| ៤ | ភ្នាក់ងារអនុវត្តអនុកិច្ចសន្យាត្រូវធានាលើការរៀបចំ និងទុកដាក់ឯកសារឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ ។ |
| ៥ | ភ្នាក់ងារអនុវត្តគម្រោងត្រូវលើកទឹកចិត្ត និងពង្រឹងការអនុវត្ត និងការចុះតាមដានដល់ក្រុមគោលដៅ ជាប្រចាំដើម្បីធ្វើឱ្យគម្រោងមាននិរន្តរភាព ។ |

## ឯកសារដែលត្រូវភ្ជាប់ទី១ ៖

*បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យារបាយការណ៍និងឯកសារទាក់ទងផ្សេងៗ ដែលបានពិនិត្យ*

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) |
|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និងឯកសារវិសោធនកម្ម |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ |
| ៣ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា |
| ៤ | លិខិតឆ្លើយឆ្លងរវាងភ្នាក់ងារអនុវត្តន៍ និងគណៈកម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ |
| ៥ | បញ្ជីវគ្គបណ្តុះបណ្តាលដែលមានក្នុងអនុកិច្ចសន្យា |
| ៦ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា |
| ៧ | ឯកសារដ៏ទៃទៀតរួមមាន រូបថតនៃគម្រោង (អនុកិច្ចសន្យា) ដែលទុកនៅគណៈ-កម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ និងនៅភ្នាក់ងារអនុវត្តន៍ ដែលមិនបានរៀបរាប់ខាងលើ |

## ឯកសារដែលត្រូវភ្ជាប់ទី២៖

*បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាសន៍/ជួបពិភាក្សា*

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៍ប្រើសម្រាប់ប្រមូលទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | | លោក សយ សូណា<br>ប្រធានមន្ទីរកសិកម្មខេត្ត | មន្ទីរកសិកម្មខេត្ត | សម្ភាសន៍ស៊ីជម្រៅ |
| ២ | | លោក ឡាច ប៊ុនធឿត<br>ប្រធានទីប្រឹក្សា PSDD | គ.ប្រ | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | | <u>ក្រុមអ្នកទទួលផល</u><br>១- លោក វ៉ាត់ ងៀវ<br>២- លោក វ៉ាក់ ពីវ<br>៣- លោក បោះ អែម<br>៤- លោក តុ ពីវ<br>៥- លោក ក្រោះ បាន | សាលាឃុំ<br>តាវែងលើ | សម្ភាសន៍ជាក្រុម |
| ៤ | | លោក ជួល ខ្វេង<br>អ្នកទទួលផលផ្ទាល់ | ភូមិ បង្កិត | សម្ភាសន៍ស៊ីជម្រៅ/ករណីសិក្សា |
| ៥ | | លោកស្រី ឈិម យឿម<br>អ្នកមិនទទួលផល | ភូមិ បង្កិត | សម្ភាសន៍ស៊ីជម្រៅ/ករណីសិក្សា |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | **17/GEN/0901-00** |
| ចំណងជើង : | គាំទ្រដល់យុទ្ធសាស្ត្របញ្រ្ជាបយេនឌ័រ |
| ភ្នាក់ងារអនុវត្តន៍ : | មន្ទីរកិច្ចការនារីខេត្តសៀមរាប |
| រយៈពេល (ចាប់ផ្តើម និងបញ្ចប់) | ៣០ មិនា ២០០៩ ដល់ ១៨ ធ្នូ ២០០៩ |
| រាជធានី ខេត្ត | សៀមរាប |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរកិច្ចការនារីខេត្តសៀមរាប |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ នៃ គ.អ.ជ.ខ | ១១,000.00 ដុល្លាអាមេរិក |
| ការរួមចំណែករបស់រាជធានី ខេត្ត | 0.00 ដុល្លាអាមេរិក |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៍ | 0.00 ដុល្លាអាមេរិក |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | ១១,000.00 ដុល្លាអាមេរិក |

## ក្រុមវាយតម្លៃ និង រៀបចំរបាយការណ៍

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ |
|---|---|
| លោក **និម សុគិន** | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ គ.ប្រ |
| លោក **ឡុង វ៉ាន់សាក់** | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ គ.ប្រ |
| លោក **សេង វិសាល** | មន្ត្រីគ្រប់គ្រងកិច្ចសន្យា គ.ប្រ |
| កញ្ញា **លុយ រតនា** | មន្ត្រីមន្ទីរកិច្ចការនារី |

**សៀមរាប**

កញ្ញា ២០១០

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៣ |
| | របាយការណ៍សង្ខេប | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៨** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៨ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៨ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៨ |
| ១.៤ | សំណួរវាយតម្លៃ | ៩ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ៩ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ១០ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១៣** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល | ១៣ |
| | - លទ្ធផលទី១ | ១៣ |
| | - លទ្ធផលទី២ | ១៤ |
| | - លទ្ធផលទី៣ | ១៦ |
| | - លទ្ធផលទី៤ | ១៧ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផលកម្រិតអត្ថប្រយោជន៍ភ្លាមៗ | ១៩ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង | ២៣ |
| ២.៤ | សេចក្តីសន្និដ្ឋាន | ២៩ |

| | | |
|---|---|---|
| **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍** | | **៣២** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ៣២ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍/ពិភាក្សា | ៣៣ |

| | |
|---|---|
| **ករណីសិក្សា** | **២២** |
| ករណីសិក្សាទី១: អ្នកទទួលផលពីគម្រោងបណ្តុះបណ្តាលជំនាញកាត់ដេរដល់ក្រុមស្ត្រី | ២២ |
| ករណីសិក្សាទី២: អ្នកមិនបានទទួលផលពីគម្រោងបណ្តុះបណ្តាលជំនាញកាត់ដេរដល់ក្រុមស្ត្រី | ២៣ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

**គោលបំណង និងវិធីសាស្ត្រនៃការវាយតម្លៃដែលបានប្រើ:**

មន្ត្រីត្រួតពិនិត្យនិងវាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យា នៃ គ.ប្រ ខេត្តសៀមរាប បានធ្វើការ វាយតម្លៃ អនុកិច្ចសន្យាដែលមានចំណងជើងថា ការគាំទ្រដល់យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ លេខ 17/GEN/0901-00 ដែលជាអនុកិច្ចសន្យា រវាង គ.ប្រ នៃ គ.អ.ជ.ខ ខេត្តសៀមរាប និងមន្ទីរកិច្ចការនារី។ នេះជាផ្នែកមួយនៃគម្រោងពង្រឹងសមត្ថភាព គ្រូបង្គោលថ្នាក់ក្រោមជាតិរបស់ផ្នែកត្រួតពិនិត្យវាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ។

គោលបំណងជាក់លាក់នៃការវាយតម្លៃនេះគឺៈ

១-ទាញយក កត់ត្រា និងវិភាគេជាប្រព័ន្ធទៅលើលទ្ធផលនៃអនុកិច្ចសន្យា និងចំនុចខ្សោយធៀបទៅនិងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់ នៃការអនុវត្តអនុកិច្ចសន្យា រួមទាំងកត់ត្រានូវចំនុចរៀនសូត្រ និងផ្នែកដែលធ្វើអោយប្រសើរឡើងនៅពេលអនាគត និង

២-ពង្រឹងរបៀបធ្វើការវាយតម្លៃគម្រោងរបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងដំណើរការ នៃការអនុវត្ត ។ ការវាយតម្លៃ អនុវត្តតាមការណែនាំ និង ឧបករណ៍ ស្តីពីការវាយតម្លៃអនុកិច្ចសន្យារបស់គណៈកម្មាធិការប្រតិបត្តិ គ.អ.ជ.ខ ដែលរៀបចំដោយផ្នែកត្រួតពិនិត្យ និងវាយតម្លៃ នៃលេខាធិការដ្ឋាន គ.ជ.អ.ប ។ ក្រុមការងារវាយតម្លៃបានប្រើការពិភាគ្សាក្រុម ការសំភាសន៍ស៊ីជំរៅ ការចុះមូលដ្ឋានគន្លឹះ នៃការសង្កេតផ្ទាល់ និងរំលឹកឯកសារអនុកិច្ចសន្យា របាយការណ៍រីកចំរើន និងឯកសារផ្សេងៗទៀត ។ ការវាយតម្លៃ ត្រូវឆ្លើយនឹងសំណួរវាយតម្លៃ (សូមមើលចំណុច ១.៣ ) ។ ដោយសារធនធានមានកំណត់ យើងធ្វើការវាយតម្លៃស៊ីជម្រៅតែទៅលើលទ្ធផលមួយប៉ុណ្ណោះ ចំណែកឯផលផ្សេងទៀតត្រូវបានវាយតម្លៃ ដោយផ្អែកលើព័ត៌មានដែលមានស្រាប់ ។ ដូច្នេះ ការវាយតម្លៃមិនមែនវាយតម្លៃ ស៊ីជំរៅទៅលើអនុកិច្ចសន្យាទេ ហើយការសន្និដ្ឋានត្រូវធ្វើតាមអ្វីដែលយើងបានរកឃើញ ។

**ឆ្លើយតបទៅនិងសំនួរទាំង៥ នៃការវាយតម្លៃៈ**

**១-សកម្មភាពទាំអស់ត្រូវបានអនុវត្ត និងលទ្ធផលសំរេចបានតាមផែនការ**

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី៣ៈ ការបរិយាយពិអនុកិច្ចសន្យា | អ្វីដែលសំរេចបានជាក់ស្តែង |
|---|---|---|
| ១ | ប្រជុំបណ្តាញការងារយេនឌ័រនៅថ្នាក់ខេត្ត ដែលមានអង្គការមិនមែនរដ្ឋាភិបាល និង | ប្រជុំប្រចាំឆមាស ២លើក មានចំនួន ២ថ្ងៃ អ្នកចូលរួមចំនួន ៩៧នាក់ ស្រី ៨៥នាក់ |

| | | |
|---|---|---|
| | ជនបង្គោលមន្ទីរ និងស្រុកចូលរួម | |
| ២ | ពង្រឹងសមត្ថភាពមន្ត្រីមន្ទីរកិច្ចការនារីខេត្ត ស្រុក ប្រចាំត្រីមាស ចំនួន៣លើក | ប្រជុំប្រចាំត្រីមាស ៣លើក មានចំនួន ៣ថ្ងៃ អ្នកចូលរួមចំនួន ៨០នាក់ ស្រី៧៧នាក់ |
| ៣ | មន្ត្រីកិច្ចការនារីខេត្តចូលរួមប្រជុំសិក្ខាសាលា វគ្គបណ្តុះបណ្តាល និង ទស្សនកិច្ចសិក្សា នៅក្រៅខេត្ត | ប្រជុំនៅខេត្តកំពង់ចាម ១លើក ចំនួន៣ថ្ងៃ មានចំនួន ០៤នាក់ ស្រី ០៤នាក់ |
| ៤ | ប្រជុំរៀបចំកសាងផែនការ ៣ឆ្នាំរំកិលរបស់ មន្ទីរ២០០៩-២០១៣ នៅថ្នាក់ខេត្ត ១លើក | ប្រជុំចំនួន ១លើក រយៈពេល ២ថ្ងៃ អ្នកចូលរួមចំនួន២៣នក់ ស្រី២២នាក់ |
| ៥ | ចុះជួយគាំទ្រជនបង្គោលទទួលបន្ទុកកិច្ចការ នារី និងកុមារឃុំ សមាជិកក្រុមប្រឹក្សាឃុំ CIP ជំហាន១ដល់ ជំហាន៤ នៅ១២ស្រុក | ចុះជួយគាំទ្រ ២លើក ចំនួន ១០ថ្ងៃ មានចំនួន ០៥នាក់ ស្រី ០៥នាក់ |
| ៦ | មន្ត្រីកិច្ចការនារីចុះគាំទ្រជនបង្គោល ទទួល បន្ទុកកិច្ចការនារី និងកុមារក្នុងសិក្ខាសាលា សមាហរណកម្មផែនការថ្នាក់ស្រុកទាំង១២ | មន្ត្រីកិច្ចការនារីចំនួន ០៣នាក់ចូលរួម |
| ៧ | សិក្ខាសាលាស្តីពីគោលគំនិតយេនឌ័រដល់ ស្ត្រីថ្នាក់ដឹកនាំជាអភិបាលរងស្រុក និងកិច្ច ការនារីស្រុកទាំង១២ | អ្នកចូលរួមសរុបចំនួន ៥៦នាក់ ស្រី ៥៥នាក់ |
| ៨ | ផ្សព្វផ្សាយច្បាប់ស្តីពី ការបង្រ្កាបអំពើចាប់ ពង្រត់ និងការលក់ដូមនុស្សធ្វើអជីវកម្ម លើ មនុស្ស ១លើក | អ្នកចូលរួមចំនួន ៣៩៦នាក់ ស្រី ២៩៩នាក់ |
| ៩ | អប់រំផ្សព្វផ្សាយពីសិទ្ធកុមារ ២លើក | អ្នកចូលរួមសរុប ៤៥៧នាក់ ស្រី ២៨៦នាក់ |
| ១០ | ផ្សព្វផ្សាយច្បាប់ទប់ស្កាត់អំពើហឹង្សាក្នុង គ្រួសារ និងកិច្ចការពារជនរគ្រោះ ១លើក | អ្នកចូលរួមសរុប ៦២២នាក់ ស្រី ៤០០នាក់ |
| ១១ | ផ្តល់ការចិញ្ចឹមជ្រូកពូជដល់ក្រុមស្ត្រី ១វគ្គ | អ្នកចូលរួមស្ត្រី ០៥នាក់ ម្នាក់ៗទទួលបាន កូនជ្រូកមេពូជ ០១ក្បាល |
| ១២ | ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈកាត់ដេរ ដល់ស្ត្រី ១វគ | អ្នកចូលរួមស្រី ១២នាក់ ម្នាក់ៗទទួលបាន មាស៊ីនដេរ ១គ្រឿង និងសំភារៈ១កំប្លេ |

២-គម្រោងផ្តល់ជ្រូកមេពូជដល់ក្រុមស្ត្រី និងវគ្គបណ្តុះបណាលជំនាញកាត់ដេរ និងឆ្នៃម៉ូត សម្លៀកបំពាក់ ស្ត្រីដល់សហគមន៍មានអត្ថប្រយោជន៍ដោយវាបានចូលរួមចំណែកក្នុងការបង្កើនប្រាក់ចំណូលគ្រួសារបានមួយកម្រិត ។

៣-លទ្ធផលបន្ទាន់ និងអត្ថប្រយោជន៍នៃគម្រោងទាំងពីរខាងលើគឺ:-ក)ការចិញ្ចឹមជ្រូកមេពូជដល់ក្រុម ស្ត្រីក្រីក្រ និងងាយរងគ្រោះ មានបំណងជួយក្រុមស្ត្រីតាមរយៈការចែករំលែក និង ជួយគ្នាមានលក្ខណៈជាប្រព័ន្ធ។ បានផ្ទេរ និងពង្រីកក្រុមដើម្បីផ្តល់កូនជ្រូក ចែកបន្តគ្នាចិញ្ចឹម និងលក់បង្កើនប្រាក់ចំណូល គ្រួសារ។ **ខ)**ដូចគ្នាដែរ ការផ្តល់វគ្គ បណ្តុះបណ្តាល ជំនាញវិជ្ជា ជីវៈកាត់ដេរនិងឆ្នៃម៉ូត គឺបានផ្តល់ចំណេះដឹងវិជ្ជាជីវៈដល់ពួកគាត់ និងដើម្បីផ្តល់សេចក្តីទុកចិត្ត សម្រាប់ស្វែងរកអាជីព និងប្រាក់ចំណូលគ្រួសារ ជៀសវាងការធ្វើចំណាកស្រុកឆ្ងាយនិង ប្រកបមុខរបរដែលសង្គមខ្មែរគិតពុំងរិះគន់ ។

៤-អនុកិច្ចសន្យាពិតជាបានចូលរួមចំណែកក្នុងការសម្រេចនូវគោលបំណងបន្ទាន់ដោយសារក្រុមគោលដៅនៃអ្នកទទួលផលបានយកចំណេះដឹង ដែលទទួលបានពីវគ្គបណ្តុះបណ្តាលទៅប្រើប្រាស់ក្នុងការស្វែងរកប្រាក់ចំណូលគ្រួសារ ទោះជាក្នុងកម្រិតណាក៏ដោយ ។

៥- អនុកិច្ចសន្យានេះពិតជាមានភាពពាក់ព័ន្ធ ប្រសិទ្ធភាព និងប្រសិទ្ធផលទាក់ទងនឹងធនធានដែលមាន ការប្រតិបត្តិការ និងការគ្រប់គ្រងទូទៅ ។ តែទោះជាយ៉ាងណាគុណភាពនៃការរៀបចំអនុកិច្ចសន្យាគួរតែត្រូវកែលម្អខ្លះឱ្យរឹតតែប្រសើរដូចជា:-

ក)ត្រូវបរិយាយឱ្យបានច្បាស់លាស់ និងអាចវាស់វែងបាននូវស្ថានភាពបញ្ចប់អនុកិច្ចសន្យា និងគោលបំណងបន្ទាន់ ។

ខ)ការប្រើប្រាស់សូចនាករជោគជ័យធៀបនឹងទិន្នន័យមូលដ្ឋាន ។

គ)ភ្ជាប់ទំនាក់ទំនងឱ្យបានច្បាស់រវាងលទ្ធផល និងគោលបំណងបន្ទាន់ និងជាមួយគោលដៅក្នុងតារាងតក្កភាពនៃឋានានុក្រមផែនការ ។

**សេចក្តីសន្និដ្ឋានសំខាន់ៗ:** លទ្ធផលនិងអត្ថប្រយោជន៍ដែលបានពីការអនុវត្តអនុកិច្ចសន្យាក្នុងសហគមន៍ ពិតជាមានភស្តុតាងបង្ហាញយ៉ាងច្បាស់លាស់ ហើយត្រូវបានទទួលសាទរពីសំណាក់អ្នកទទួលផលផ្ទាល់ ក៏ដូចជាអ្នកទទួលផលដោយប្រយោលក្នុងឃុំគោលដៅ ។ជាក់ស្តែងការផ្តល់វគ្គបណ្តុះបណ្តាលជំនាញកាត់ដេរឆ្នៃម៉ូត និងការផ្តល់គម្រោងចិញ្ចឹមជ្រូកមេពូជ

ដល់ក្រុមស្ត្រីក្រីក្រ និងងាយរងគ្រោះ ក្នុងគោលបំណងលើកស្ទួយ និងគាំទ្រការបង្កើនសមត្ថភាពស្ត្រី ដើម្បីស្វែងរកប្រាក់ចំណូលគ្រួសារបន្ថែមលើមុខរបរកសិកម្ម ផលិតកម្មដំណាំស្រូវ។ ជាពិសេសជាងនេះទៀត គម្រោងបានចូលរួមចំណែកយ៉ាងធំមួយផ្នែកទៀតក្នុងការពង្រឹង និងផ្តល់ទំនុកចិត្តឱ្យពួកគាត់មានលំនឹងផ្នែកផ្លូវចិត្ត ប្រកបដោយសមភាព សមធម៌ យេនឌ័រ ជៀសវាងការធ្វើចំណាកស្រុកមិនស្របច្បាប់និងប្រកបមុខរបរដទៃទៀតដែលសង្គមខ្មែរកំពុងរិះគន់ផងដែរ។ ឧទាហរណ៍ជាក់ស្តែង គម្រោងផ្តល់វគ្គបណ្តុះបណ្តាលកាត់ដេរដល់ស្ត្រីក្រីក្រ និងងាយរងគ្រោះត្រូវបានបញ្ចប់ហើយក្តី តែពួកគាត់មានសមត្ថភាពជំនាញ អាចចេញទៅប្រកបមុខរបរជាមួយសេវាឯកជន ក្នុងការរកប្រាកចំណូលបានមួយកម្រិត ។ ពួកគាត់ក៏បានបង្កើនសមត្ថភាពជំនាញនេះមួយកម្រិតទៀតតាមរយៈការអនុវត្តជាក់សែងផងដែរ។ ចំពោះគម្រោងផ្តល់ជ្រូកមេពូជទៀតសោត ឃើញថាបានផ្តល់ឱកាសល្អមួយដែលបង្ហាញឱ្យពីការចេះសន្សំសំចៃរាល់កាកសំណល់ផ្ទះបាយ និងធនធានដែលមានក្នុងសហគមន៍ដុចជាៈ-ត្រកួន ព្រលិត ស្មៅផ្ទី និងរុក្ខជាតិដទៃទៀតដែលជ្រូកអាចស៊ីបាន និងបង្កើនការធំធាត់ ។

ទោះជាគម្រោងដែលផ្តល់នេះ ប្រព្រឹត្តិទៅទទួលបានលទ្ធផលគួរជាទីមោទនពិតមែន តែភ្នាក់ងារសាម៉ីមន្ទីរ ត្រូវសរសេរ និងបរិយាយឱ្យបានច្បាស់ អំពីគោលបំណងបន្ទាន់ ឬទិសដៅ ពិសេសគប្បីពិចារណាឱ្យបានល្អិតល្អន់ផងដែរ ចំពោះការធានាឱ្យមាននិរន្តភាពដូចជាៈ-បន្តការគាំទ្រ និងពង្រីកគោលដៅតាមលទ្ធភាព ធនធានរបស់ខ្លួន ធានាធ្វើយ៉ាងណាការជ្រើសរើសអ្នកទទួលផលត្រូវតែពិចារណាបានល្អិតល្អន់ទៅលើគ្រួសារក្រីក្រ និងងាយរងគ្រោះដោយសហការជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន ដោយផ្តោតលើតារាងអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងភូមិជាអាទិភាព ។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

ជារៀងរាល់ឆ្នាំគ.ជ.អ.ប បានផ្តល់ថវិកាតាមរយៈគ.ប្រ នៃគ.អ.ជ.ខទៅមន្ទីរ-វិស័យដើម្បីអនុវត្តសកម្មភាពនិងគម្រោងដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។ ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈជាប្រព័ន្ធមិនបានអនុវត្តទេកាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើនដូចជា ពុំមានទីប្រឹក្សាគម្រោង ឬ អ្នកឯកទេស/ជំនាញពិតប្រាកដដើម្បីវាយតម្លៃពីប្រសិទ្ធិភាព-ផលប៉ះពាល់រយៈពេលយូរអង្វែង ឬចីរភាពគម្រោងឡើយ បើគិតចាប់តាំងពីអតីតកម្មវិធីសិលាកន្លងមក ។ ខ្ទង់ថវិកាសម្រាប់ការវាយតម្លៃមានកំរិត ។

នៅក្នុងឆ្នាំ ២០១០ ជាមួយនឹងការគាំទ្រផ្នែកថវិកា និងបច្ចេកទេសពីផ្នែកត្រួតពិនិត្យវាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋានគ.ជ.អ.ប និងផ្នែករដ្ឋបាលនិងគ្រប់គ្រងកិច្ចសន្យា គ.ប្រ នៃគ.អ.ជ.ខ ក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យាដែលបានរៀបចំរួមគ្នាជាមួយភ្នាក់ងារអនុវត្តន៍ដែលមានលេខ 17/GEN/0901-00 គាំទ្រដល់យុទ្ធសាស្រ្តបញ្រ្ជាបយេនឌ័រ ។ ដំណើរការលទ្ធផលដែលបានរកឃើញ និងការសន្និដ្ឋាន ពីការវាយតម្លៃ ត្រូវបានកត់ត្រា នឹងបង្ហាញតាមរយៈរបាយការណ៍ ស្តីពីការវាយតម្លៃនេះ ។

## ១.២. គោលបំណងអនុកិច្ចសន្យា

គោលបំណងបន្ទាន់ ឬទិសដៅនៃអនុកិច្ចសន្យាគឺ នៅចុងឆ្នាំ២០០៩ គ្រួសារស្ត្រីក្រីក្រនិងងាយរងគ្រោះមួយចំនួន មានសមត្ថភាពជំនាញ វិជ្ជាជីវៈ និងមានមុខរបរបន្ថែម ដើម្បីស្វែងរកប្រាក់ចំណូលគ្រួសារ មានភាពប្រសើរឡើងប្រកបដោយសមភាពសមធម៌យេនឌ័រ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

ដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូលបាន ផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ នៃគ.អ.ជ.ខ បានសហការជាមួយមន្ត្រីបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃមន្ទីរសាម៉ីដើម្បីអនុវត្តសកម្មភាពនេះឱ្យស្របតាមលក្ខណៈបច្ចេកទេស ប្រកបដោយតម្លាភាព និង

គណនេយ្យភាព ។ ដូច្នេះ ទំហំនៃការវាយតម្លៃមានដែនកំណត់ តាមទំហំនៃអនុកិច្ចសន្យា និង រាល់បញ្ហាដែលពាក់ព័ន្ធដូចមានចែងក្នុងក្របខណ្ឌការងារនៃការវាយតម្លៃ ។ គោលបំណងនៃការវាយតម្លៃគឺៈ- **ក**)ទាញយកការកត់ត្រា និងវិភាគលក្ខណៈជាប្រព័ន្ធ ទៅលើសមិទ្ធផល នៃអនុកិច្ចសន្យា និងចំនុចខ្សោយ ធៀបទៅនឹងលទ្ធផលគោលបំណងបន្ទាន់ និង ស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំងកត់ត្រានូវចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគតនិង **ខ)** ដើម្បីពង្រឹងរបៀបធ្វើការវាយតម្លៃគម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្តដែលពុំធ្លាប់មានកន្លងមក ។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់ល្អបានកម្រិតណា? និងជួបបញ្ហាអ្វី?

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា?

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង?

៣- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ? សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

**វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើ**

១)ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញនូវៈ របាយការណ៍រីកចម្រើនប្រចាំខែ កំនត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធដែលមាននៅក្នុងផ្នែករដ្ឋបាលនិងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៏។

២)ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៏មានសំខាន់ៗរួមមានៈ-អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផលផ្ទាល់ និងមិនផ្ទាល់ ២ឬ៣នាក់និងអ្នកពាក់ព័ន្ធ២នាក់។ពិគ្រោះជាមួយនឹង

មន្ត្រីបង្គោលទៅលើបញ្ហាយេនឌ័រ និងគ្រប់គ្រងធនធានធម្មជាតិសម្រាប់បញ្ហាពាក់ពន្ធ័វិស័យខាងលើ។

៣)ប្រើប្រាស់វិធីសាស្ត្រចុះពិនិត្យតំបន់អនុវត្តន៍គម្រោង និងសង្កេតមើលសកម្មភាព ពិភាក្សាក្រុម និងករណីសិក្សា។

៤)ចុះពិនិត្យតំបន់អនុវត្តន៍គម្រោង ហើយសង្កេតមើលសកម្មភាពលទ្ធផល និងភស្តុតាងនៃគម្រោងដោយផ្ទាល់។

៥)វិភាគទិន្នន័យនិងបកស្រាយៈ ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់ ។

៦)ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ ដោយភ្នាក់ងារអនុវត្តន៍ និងអ្នកពាក់ព័ន្ធតាមរយៈ ព័ត៏មានត្រឡប់ដែលទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើងក្នុងសិក្ខាសាលាបង្ហាញ លទ្ធផលវាយតម្លៃ របស់ក្រុមការងារនៅមន្ទីរកិច្ចការនារីខេត្ត ថ្ងៃទី ២៩ កញ្ញា ២០១០។ ការវាយតម្លៃ ត្រូវធ្វើតាម "គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ច សន្យា" និងវិធីសាស្ត្រដែលបានណែនាំ ។ ដូច្នេះ ដំណើរការត្រូវបានធ្វើឡើងដោយមាន ទម្រង់ការណែនាំ និងតម្លាភាព រួមទាំងការចូលរួមពីអ្នកពាក់ព័ន្ធ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១)ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយ គ.ប្រ និងអ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា ។ ទោះជាយ៉ាងណាក៏ដោយការប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត ។

២)ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិតៈ- វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោង នៅពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និងបទពិសោធន៍ពីមុនមក។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណងសំខាន់គឺដើម្បី "រៀនធ្វើដោយការអនុវត្តផ្ទាល់"។ អ្នកវាយតម្លៃបានទទួលការគាំទ្រដោយមានគោលការណ៍ការណែនាំ ឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ ។

៣)បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យាៈ ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល

និងសកម្មភាព)សូចនាករ និងមធ្យោបាយផ្ទៀងផ្ទាត់ មិនសូវច្បាស់លាស់ លើការរីកចម្រើន និងជោគជ័យទេ។ មួយទៀតទំនាក់ទំនងសង្ខេបតាមបែបតក្កភាពរវាងសកម្មភាព(ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផលទៅនឹងគោលបំណងបន្ទាន់ មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទៀតផង ។

៤)ដោយយើងមិនមានសូចនាករបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ“គោលដៅអភិវឌ្ឍន៍” ដែលជាកម្រិតអត្ថប្រយោជន៍ទៅលើគោលនយោបាយវិស្សការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត “គោលបំណង” ដែលជាកម្រិត ផលប៉ះពាលទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ ។

៥)ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិតទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ ។ យើងអាចវាយតម្លៃតែទៅលើក្រុមស្ត្រីដែលទទួលការបណ្តុះបណ្តាល ពីការកសាងទំនុកចិត្តដល់ក្រុមស្ត្រី និងគណៈកម្មការធនធានធម្មជាតិដែលជាលទ្ធផលខ.១ និងបណ្តុះបណ្តាលការចិញ្ចឹមជ្រូក ដល់ក្រុមស្ត្រីដែលជាសកម្មភាពទី១ និងបណ្តុះបណ្តាលវិជ្ជាជីវៈកាត់ដេរដល់ស្ត្រី ដែលជាសកម្មភាពទី២ នៃអនុកិច្ចសន្យាលំអិតតាមរយៈការសម្ភាសន៍ស៊ីជម្រៅជាមួយក្រុមពិភាក្សា និង ការចុះពិនិត្យតំបន់អនុវត្តគម្រោង ។

៦)សូមរក្សាទុកចំណុចនេះ ប្រសិនបើវាមានសុពលភាព:- ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាមិនអាចធ្វើទៅបានទេព្រោះចំណុច**គ** នៃផ្នែកទី៣ ក្នុងឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ ឬមិនពេញលេញ ។ ការងារនេះនឹងកាន់តែមានសុពលភាពនិងពោរពេញទៅដោយព័ត៌មាន បើសិនជាចំនុចដែលបានរៀបរាប់ខាងលើនេះត្រូវបានដោះស្រាយ។

**<u>ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និងបដិសេធ :</u>**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ17/GEN/0901-00 គាំទ្រដល់យុទ្ធសាស្រ្តបញ្ញាបយេនឌ័រ និងដែនកំណត់ ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ។

២)ការវាយតម្លៃនេះ លម្អិតតែទៅលើក្រុមស្ត្រីដែលទទួលការបណ្តុះបណ្តាល ពីការកសាងទំនុកចិត្តដល់ក្រុមស្ត្រីនិងគណៈកម្មការធនធានធម្មជាតិដែលជាលទ្ធផល គឺការផ្តល់ការចិញ្ចឹមជ្រូកមេពូជដល់ក្រុមស្ត្រី និងបណ្តុះបណ្តាលវិជ្ជាជីវៈកាត់ដេរដល់ស្ត្រី ដែលជាសកម្មភាព

នៃអនុកិច្ចសន្យា ។

៣)ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃទៅលើភ្នាក់ងារអនុវត្តន៍ ភ្នាក់ងារដែលពាក់ព័ន្ធគម្រោងហើយនឹងការវាយតម្លៃទៅលើគ.ប្រ នៃគ.អ.ជ.ខ និងគ.ជ.អ.បទេ។ មានន័យថា ការវាយតម្លៃនេះសំដៅទៅលើសកម្មភាពនៃលទ្ធផលខ្លះៗ ក្នុងអនុកិច្ចសន្យារបស់មន្ទីរកិច្ចការនារីខេត្តលេខ 17/GEN/0901-00 ប្រចាំឆ្នាំ២០០៩ ។

៤)ការជ្រើសរើស និងផ្តល់គម្រោងខាងលើ(ក្រុមចិញ្ចឹមជ្រូកមេពូជនិងផ្តល់វគ្គបណ្ដុះបណ្ដាលជំនាញកាត់ដេរ និងឆ្នៃម៉ូត) គប្បីពិចារណាផងដែរចំពោះបញ្ហាប្រឈម ដែលមិនមែនជាហានីយភ័យ ឬក៏ជាការចៃដន្យផងនោះដូចជា :-

**ក)កត្តាហានិភ័យ ឬការចៃដន្យ:-** ជ្រូកមេពូជដែលបានផ្តល់ឱ្យចិញ្ចឹមជួបប្រទះជម្ងឺ និងស្លាប់ ។ ជ្រូកកើតកូន យឺតយ៉ាវ កើតកូនតិច ស្លាប់កូន ....។ល។

**ខ)កត្តាមិនមែនហានិភ័យ ឬការចៃដន្យ:-**ភ្នាក់ងារផ្តល់គម្រោង មិនបានពិចារណាបានជិតដល់ចំពោះក្រុមអ្នកទទួលផល ។ បានជ្រើសរើសគ្រួសារជាស្រីក្រីក្រ និងងាយរងគ្រោះដែលផ្នែកមួយគឺពួកគាត់ពុំមានស្បៀងសម្រាប់ហូបគ្រប់គ្រាន់ ។ តែយើងពុំបានគិតថាជ្រូកមេពូជទាំងនោះទាមទារតម្រូវការអាហារដូចមនុស្ស និងការចំណាយថវិកា សម្រាប់ព្យាបាលពេលជ្រូកមានជំងឺផងដែរ។ **នេះជាបញ្ហា** ។

**គ)ភាពសមហេតុផលមួយដែរគឺ:-**ការផ្តល់វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈកាត់ដេរ និងឆ្នៃម៉ូតដល់ក្រុមស្ត្រីក្រីក្រ និង ងាយរងគ្រោះ គឺជាសិល្បៈនៃការចែករំលែកមួយផ្នែកដែលមិនទាមទារស្ត្រីក្រីក្រទាំងនោះត្រូវចំណាយថវិកាគ្រួសារ ដែលពួកគាត់កំពុងតែជួបប្រទះ។ មានន័យថា យើងទាមទារចង់ឱ្យពួកគាត់បានប្រើប្រាស់ចំណេះដឹងដែលបានពីការរៀនសូត្រ និងព្យាយាមក្នុងការក្រេបយកចំណេះដឹងពីគ្រូបណ្តុះបណ្តាលឱ្យអស់លទ្ធភាព និងព្រមទទួលយកម៉ាស៊ីនដេរនិងសម្ភារៈអមជាមួយ សម្រាប់វិលមកលំនៅដ្ឋានវិញពេលចប់វគ្គបណ្តុះបណ្តាលនេះគឺជាចំណុចវិជ្ជមានមួយ ក្នុងការផ្តល់ធនធានយ៉ាងសំខាន់ដល់ពួកគាត់ (ផ្តល់សន្ទូច និងវិធីស្ទូចត្រី ) ។

ហេតុដូច្នេះរបាយការណ៍នៃការវាយតម្លៃលទ្ធផលដែលបានរកឃើញ និងអនុសាសន៍ដែលបានលើកឡើង ត្រូវពិនិត្យដោយយោលទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ ។

# ២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល

**លទ្ធផលទី១ :បណ្តាញទំនាក់ទំនងយេនឌ័រ**

### ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនិងផែនការ

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣ ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | -ប្រជុំបណ្តាញការងារយេនឌ័រនៅថ្នាក់ខេត្ត ដែលមានអង្គការមិនមែនរដ្ឋាភិបាលនិង ជនបង្គោលមន្ទីរនិងស្រុកចូលរួមប្រចាំឆមាស ២លើក មានចំនួន ២ថ្ងៃ ។ | -ប្រជុំបណ្តាញការងារយេនឌ័រនៅថ្នាក់ខេត្ត ដែលមានអង្គការមិនមែនរដ្ឋាភិបាល និង ជនបង្គោលមន្ទីរនិង ស្រុកចូលរួមប្រចាំឆមាស២លើក មានចំនួន ២ថ្ងៃ។<br>-អ្នកចូលរួមមានចំនួន៩៧នាក់ស្រី៨៤នាក់ |
| ១.២ | -ពង្រឹងសមត្ថភាពមន្ត្រីមន្ទីរកិច្ចការនារីខេត្ត-ស្រុកប្រចាំត្រីមាសចំនួន៣លើក | -វគ្គប្រជុំពង្រឹងសមត្ថភាពមន្ត្រី មន្ទីរកិច្ចការនារីខេត្ត-ស្រុកប្រចាំត្រីមាស ៣លើក មានចំនួន៣ថ្ងៃ អ្នកចូលរួមមានចំនួន ៨០នាក់ស្រី៧៧នាក់ ។ |
| ១.៣ | -មន្ត្រីកិច្ចការនារីខេត្តចូលរួមប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និង ទស្សនកិច្ចសិក្សាក្រៅខេត្ត១ប្រជុំ ។ | -មន្ត្រីកិច្ចការនារីខេត្តចូលរួមប្រជុំស្តីពីការបូកសរុប ការងារបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ១ប្រជុំរយៈពេល៣ថ្ងៃ នៅខេត្តកំពង់ចាម ។<br>-មានចំនួន ៤នាក់ស្រី ៤នាក់ ។ |

### ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

| |
|---|
| អនុកិច្ចសន្យានេះសំរេចបាននូវលទ្ធផល និង សកម្មភាពនានារបស់អនុកិច្ចសន្យាដែលបានគ្រោងទុក។ ការពិនិត្យឯកសារអនុកិច្ចសន្យា មិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះបានលំអិតទេ។ |

## លទ្ធផលទី២: មន្ទីរកិច្ចការនារីគាំទ្រដល់ការបញ្ជ្រាបយេនឌ័រ

## ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនិងផែនការ

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣ ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ២.១ | -ប្រជុំរៀបចំកសាងផែនការ ៣ឆ្នាំរំកិល របស់មន្ទីរ ឆ្នាំ២០០៩-២០១៣នៅថ្នាក់ខេត្តចំនួន ០១លើក ។ | -ប្រជុំរៀបចំកសាងផែនការ ៣ឆ្នាំរំកិល របស់មន្ទីរ២០០៩-២០១៣ ថ្នាក់ខេត្តនៅមន្ទីរកិច្ចការនារីចំនួន ០១លើករយៈពេល ២ថ្ងៃ អ្នកចូលរួមសរុប ២៣នាក់ស្រី២២។ |
| ២.២ | -ចុះជួយគាំទ្រជនបង្គោល ទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សមាជិកក្រុមប្រឹក្សាឃុំ ស៊ីអាយភី ជំហាន១ ដល់ជំហាន៤ នៅ១២ឃុំ ស្រុក១២ ។ | -ចុះជួយគាំទ្រជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សមាជិកក្រុមប្រឹក្សាឃុំស៊ីអាយភី ២លើក ក្នុង៣ឃុំរយៈពេល ១០ថ្ងៃ សរុបមានចំនួន ៥នាក់ ស្រី៥ ។ |
| ២.៣ | -មន្ត្រីកិច្ចការនារីចុះគាំទ្រជនបង្គោល ទទួលបន្ទុកកិច្ចការនារីនិងកុមារក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកទាំង១២ ។ | -មន្ត្រីកិច្ចការនារីចំនួន ៣នាក់ ចុះគាំទ្រជនបង្គោល ទទួលបន្ទុកកិច្ចការនារី និងកុមារក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកស្រុកទាំង ១២ រយៈពេល ១២ថ្ងៃ ។ |
| ២.៤ | -សិក្ខាសាលាស្តីពីគោលគំនិតយេនឌ័រដល់ស្ត្រីថ្នាក់ ដឹកនាំជាអភិបាលរងស្រុក និង កិច្ចការនារីស្រុក ទាំង១២ | -សិក្ខាសាលាស្តីពីគោលគំនិតយេនឌ័រដល់ស្ត្រីថ្នាក់ ដឹកនាំជាអភិបាលរងស្រុក និងកិច្ចការ នារីស្រុកទាំង ១២ ចំនួន១លើក រយៈពេល២ថ្ងៃ អ្នកចូលរួមសរុប ៥៦នាក់ ស្រី៥៥នាក់ ។ |

## ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

អនុកិច្ចសន្យានេះសំរេចបាននូវលទ្ធផល និងសកម្មភាពនានារបស់អនុកិច្ចសន្យាដែលបានគ្រោងទុកតាមការពិនិត្យឯកសារបិទអនុកិច្ចសន្យាប្រចាំឆ្នាំ តែមិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះបានលំអិតទេ ។

## លទ្ធផលទី៣: កម្មវិធីប្រឆាំងនឹងអំពើហឹង្សាក្នុងគ្រួសារ/ការជួញដូរស្រ្តីភេទនិងកុមារ

### ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនិងផែនការ

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣ ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ៣.១ | -ផ្សព្វផ្សាយច្បាប់ស្តីពីការបង្រ្កាបអំពើចាប់ពង្រត់និងការលក់ដូរមនុស្សធ្វើអជីវកម្មលើមនុស្ស ១លើក ។ | -ផ្សព្វផ្សាយច្បាប់ស្តីពីការបង្រ្កាបអំពើចាប់ពង្រត់ និង ការលក់ដូរមនុស្សធ្វើអជីវកម្មលើមនុស្សចំនួន ១លើករយៈពេល ៩ថ្ងៃ មានការចូលរួមសរុប៣៩៦នាក់ស្រី២៩៩នាក់ |
| ៣.២ | -អប់រំផ្សព្វផ្សាយពីសិទ្ធកុមារ ២លើក | -អប់រំផ្សព្វផ្សាយពីសិទ្ធកុមារ១លើករយៈពេល១៥ថ្ងៃ អ្នកចូលរួមសរុប ៤៥៧នាក់ ស្រី ២៨៦នាក់ ។ |
| ៣.៣ | -ផ្សព្វផ្សាយច្បាប់ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ១លើក | -ផ្សព្វផ្សាយពីច្បាប់ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ១លើករយៈពេល១៨ថ្ងៃ អ្នកចូលរួមសរុប៦២២នាក់ស្រី៤០០ន |

### ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

អនុកិច្ចសន្យានេះសំរេចបាននូវលទ្ធផលនិងសកម្មភាពនានារបស់អនុកិច្ចសន្យាដែលបានគ្រោងទុក តាមការពិនិត្យឯកសារបិទអនុកិច្ចសន្យាប្រចាំឆ្នាំ តែមិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះបានលំអិតទេ ។

## លទ្ធផល ទី៤ :បណ្តុះបណ្តាលស្តីពីការកសាងទំនុកចិត្តដល់ក្រុមស្ត្រី និងគណះកម្មាធិការ ធន ធានធម្មជាតិ

### ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនិងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី៣ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ៤.១ | ផ្តល់ការបណ្តុះបណ្តាលនិង ចិញ្ចឹមជ្រូកមេពូជដល់ក្រុមស្ត្រី០១វគ្គ | ផ្តល់ការបណ្តុះបណ្តាលនិងចិញ្ចឹមកូនជ្រូកដល់ក្រុមស្ត្រី ០១វគ្គរយះពេល២ថ្ងៃ(ផ្តល់កូនជ្រូកមេពូជចំនួន៥ក្បាល ដល់ស្ត្រីងាយរងគ្រោះចំនួន ៥នាក់) |
| ៤.២ | ផ្តល់ការបណ្តុះបណ្តាល វិជ្ជាជីវះកាត់ដេរដល់ស្ត្រី១វគ្គ | ផ្តល់ការបណ្តុះបណ្តាល វិជ្ជាជីវះកាត់ដេរដល់ស្ត្រី ០១វគ្គ រយះពេល០៦ខែ សរុបសិស្សចំនួន១២នាក់(ទទួលបានម៉ាស៊ីនដេរ១គ្រឿងនឹងសម្ភារះបំរើការកាត់ដេរ១កំប្លេក្នុង១នាក់) |

### ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

| |
|---|
| អនុកិច្ចសន្យានេះសំរេចបាននូវលទ្ធផល និងសកម្មភាពនានារបស់អនុកិច្ចសន្យាដែលបានគ្រោងទុក។ អ្នកចូលរួមទាំងអស់ក្នុងក្រុមពិភាក្សាដែលជាអ្នកទទួលផលពីគម្រោង ផ្តល់ការចិញ្ចឹមពូជជ្រូកចំនួន៥គ្រួសារ បានបង្ហាញថាៈ-ពួគគាត់រីករាយណាស់ ដែលមានមុខរបរបន្ថែមក្រៅពីធ្វើស្រែចំការ ដើម្បីជួយបង្កើនជីវភាពគ្រួសារ របស់ពួកគាត់ឱ្យកាន់តែប្រសើឡើង។ ក្នុងនោះដែរ អ្នកទទួលផលចំនួន ០៤គ្រួសារ ចិញ្ចឹមបានល្អដោយជ្រូកមានការធំធាត់និងជ្រូកចំនួន១ក្បាលបានកើតកូនចំនួន៩ក្បាល។ផ្ទុយទៅវិញមាន ១គ្រួសារទទួលបរាជ័យដោយជ្រូកងាប់ក្រោយពីចិញ្ចឹមបានរយះពេល ២ថ្ងៃ ។ សកម្មភាពនេះបានផ្តល់ឱកាសឱ្យពួកគាត់ចេះសន្សំសំចៃកាកសំណល់ផ្ទះបាយ និងទាញយកធនធានទាំងឡាយដែលមានក្នុងសហមន៍របស់ខ្លួនដូចជាៈ-ត្រកួន ព្រលឹត ស្មៅ ផ្តី និងរុក្ខជាតិទាំងឡាយដែលអាចផ្តល់ឱ្យជ្រូកមានការធំធាត់បាន ។ |

ចំពោះការផ្តល់វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈកាត់ដេរនិងឆ្នៃម៉ូត ដែលមានអ្នកទទួលផលចំនួន ១២នាក់ ក្នុងនោះ (ឃុំសំរោងយា ស្រុកពួកចំនួន៤នាក់ ជាឃុំគោលដៅដែលចុះវាយតម្លៃ) និងឃុំតាយែក ស្រុកសូទ្រនិគមចំនួន ៨នាក់) បានទទួលចំណេះដឹង ជំនាញទាក់ទងនិងបច្ចេកទេសកាត់ដេរដែលជាតម្រូវការរបស់ពួកគាត់ ។

លទ្ធផលគួឱ្យចាប់អារម្មណ៍គឺ ក្រោយពេលបញ្ចប់វគ្គបណ្តុះបណ្តាល និងវិលត្រឡប់មកសហគមន៍វិញ ពួកគាត់ភាគច្រើនបានយកចំណេះដឹងទាំងនេះ ទៅប្រកបមុខរបរក្នុងហាងកាត់ដេរនៅទីផ្សារ ដើម្បីស្វែងរកប្រាក់ចំណូលគ្រួសារ(ធ្វើជាកូនកន្ត្រៃ)។ ផលប្រយោជដែលពួកគាត់ទទួលបានមិនត្រឹមតែទទួលបានប្រាក់កម្រៃប៉ុណ្ណោះទេ គឺពួកគាត់ថែមទាំងទទួលបានចំណេះដឹងពីការអនុវត្តជាក់ស្តែងបន្ថែមទៀតផងដែរ ។ ជាមោទនភាពទៀតនោះគឺ :-យុវតីម្នាក់ដែលជាអតីតសិស្សចូលរួមក្នុងវគ្គបណ្តុះបណ្តាលពីគម្រោងក្នុងឆ្នាំ២០០៨ បានក្លាយខ្លួនជាគ្រូបង្វឹកនៅវគ្គក្រោយទៀតផងដែរ ។

សរុបសេចក្តីមកសកម្មភាពទាំងពីរខាងលើនេះ គឺជាតម្រូវការរបស់ពួកគាត់ និងសហគមន៍ ។ ជាពិសេសអ្នកដែលបានចូលរួមក្នុងការពិភាក្សាទាំងពីរក្រុម បានបញ្ជាក់ថាចំណេះដឹងជំនាញ និងបច្ចេកទេសដែលពួកគាត់បានទទួល គឺធ្វើឱ្យជីវភាពរបស់ពួកគាត់កាន់តែមានភាពល្អប្រសើរឡើង ។ យើងសង្កេតឃើញថាអ្នកដែលមិនបានទទួលផលពីគម្រោងខាងលើក៏មានការចាប់អារម្មណ៍យ៉ាងខ្លាំងនឹងចង់ចូលរួមក្នុងគម្រោងខាងលើ ជាពិសេសវគ្គបណ្តុះ-បណ្តាលជំនាញវិជ្ជាជីវៈកាត់ដេរដើម្បីធ្វើឱ្យចំណូលក្នុងគ្រួសារគាត់កើនឡើង និងជួយបំពេញតាមតម្រូវការក្នុងគ្រួសាររបស់គាត់បន្ថែមទៀត ។ ការផ្តល់គម្រោងទាំងពីរខាងលើនេះគឺពិតជាបានរួមចំណែកកាត់បន្ថយការធ្វើចំណាកស្រុកនិងការប្រកបមុខរបរដែលសង្គមខ្មែរកំពុងរិះគន់យ៉ាងខ្លាំងដល់ពួកគាត់ ។

## ២.២. ការវាយតម្លៃលើការសម្រេចបាននទូវកំរិតអត្ថប្រយោជន៏ភ្លាម១ និងលទ្ធផលអនុកិច្ចសន្យា

### ផ្នែក-ក: ការវាយតម្លៃការសម្រេចបាននូវស្ថានភាពរំពឹងទុកនៃចុងបញ្ចប់ក្នុងកិច្ចសន្យា

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា | ស្ថានភាពជាក់ស្តែងនៅពេលបញ្ចប់ |
|---|---|
| -ស្រ្តី ០៥ គ្រួសារបានទទួលការបណ្តុះបណ្តាល និងចិញ្ចឹមកូនជ្រូកមេពូជ ១វគ្គ ។ | -ស្ត្រីងាយរងគ្រោះចំនួន ០៥គ្រួសារ បានទទួលការ បណ្តុះបណ្តាល ពីការចិញ្ចឹម ជ្រូកមេ ពូជ ១វគ្គ ចំនួន ២ថ្ងៃ ទទួលបានកូនជ្រូកមេពូជចំនួន ០៥ក្បាល ។<br>-អ្នកចូលរួមភាគច្រើននៅក្នុងការពិភាក្សាក្រុម បាន រាយការណ៏ថាពួកគាត់ពេញចិត្តយ៉ាងខ្លាំងនឹង គម្រោងការ វគ្គបណ្តុះបណ្តាល ពីការចិញ្ចឹមជ្រូកនិងផ្តល់ជ្រូកមេពូជនេះ ព្រោះវាឆ្លើយតបយ៉ាងខ្លាំងទៅនិង តម្រូវការរបស់ពួកគាត់ និងសហាគមន៍ ។ ពួកគាត់បានបន្តទៀតថាអាចយកកាកសំណល់ផ្ទះបាយ និងបន្លែក្បែរផ្ទះក្នុងភូមិរបស់ គាត់ ឱ្យវាបាន ។<br>-ក្រោយពីបានទទួលកូនជ្រូកមេពូជយើងសង្កេតឃើញថាស្ត្រីទាំងអស់យកចិត្តទុកដាក់ក្នុងការថែទាំ និងផ្តល់ចំណីដល់មេជ្រូក ។ បច្ចុប្បន្ននេះមានមេជ្រូក១ក្បាលបានកើតកូន និង ៣ក្បាលជិតកើតកូន ។ |
| -ស្ត្រីចំនួន ១២ នាក់ ទទួលបានការបណ្តុះ-បណ្តាលពីវិជ្ជាជីវៈកាត់ដេរ ចំនួន១វគ្គ ។ | -ស្ត្រីក្រីក្រចំនួន ១២នាក់ ទទួលបានការបណ្តុះបណ្តាលពីវិជ្ជាជីវៈកាត់ដេរចំនួន ១លើកមានរយៈពេល៦ខែដោយម្នាក់ៗ ទទួលបានម៉ាស៊ីនដេរចំនួន០១គ្រឿង នឹងសំភារៈ បំរើការកាត់ដេរ ០១កំប្លេ ។<br>-នៅក្នុងការពិភាក្សាក្រុម ពួកនាងបានបង្ហាញពីក្តីរំភើបរីករាយដែលបានចូលរួមក្នុងវគ្គនេះថែមទាំងបានបំពេញបំណងរបស់ពួកនាងដែលចង់ |

| | |
|---|---|
| | បានជំនាញ ក្នុងការរកប្រាក់ចំណូលសំរាប់គ្រួសារ និងសហគមន៍ ។ ពួកនាង បានបន្តថាការខិតខំប្រឹងប្រែង និង យកចិត្តទុកដាក់ក្នុងការសិក្សានេះអស់រយះពេល ០៦ខែ ។<br>-ក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាល ជំនាញវិជ្ជាជីវះកាត់ដេរពួកនាងមានសមត្ថភាពក្នុងការកាត់ដេរសំលៀកបំពាក់ ។ ក្នុងនោះដែរក៏មាន សិស្សឆ្នើមម្នាក់ ដែលបច្ចុប្បន្ន បានក្លាយជាគ្រូបង្រៀននៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ខេត្តសៀមរាប និងមួយចំនួន បានក្លាយជាកូនកន្រ្តៃតាមហាងកាត់ដេរសំលៀកបំពាក់ ។<br>-សមត្ថភាព ជំនាញដែលបានទទួលពីវគ្គបណ្តុះ-បណ្តាលនេះ អាចធ្វើឱ្យពួកនាងរកបានប្រាក់ចំណូលបន្ថែមសំរាប់ផ្គត់ផ្គង់ការចំណាយក្នុងគ្រួសារនិងជីវភាពប្រចាំថ្ងៃរបស់ពួកនាង ប្រសើរជាងមុនដោយមិនបាច់ធ្វើចំណាកស្រុកទៅឆ្ងាយ |

## ផ្នែក-ខ: ការការវាយតម្លៃការសម្រេចបាននូវគោលបំណងបន្ទាន់

| ល.រ | ធាតុនៃគោលបំណងបន្ទាន់ | ការសម្រេចបានជាក់ស្តែង នៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ |
|---|---|---|
| ១ | នៅចុងឆ្នាំ២០០៩ស្ត្រីក្រីក្រងាយរងគ្រោះមានសមត្ថភាពក្នុងការចិញ្ចឹមជ្រូកមេពូជ និងកាត់ដេរ ដើម្បីទទួលបានប្រាក់ចំណូលបន្ថែមក្នុងគ្រួសារ តាមរយះការលក់ជ្រូក ការបំបែកកូនជ្រូកទៅក្រុមផ្សេងទៀត និង ការកាត់ដេរសំលៀកបំពាក់ដែលធ្វើអោយ ជីវភាពក្នុងគ្រួសារមានភាពប្រសើរឡើង ។ | -ដោយគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា មិនបានកំណត់ពីកំរិតក្នុងការទទួលផល ទើបធ្វើអោយក្រុមការងារមានការលំបាកវាស់វែង ក្នុងការអនុវត្តអនុកិច្ចសន្យា ។ ឆ្លងតាមការពិនិត្យលើឯកសារ ការសង្កេត និងការចុះវាយតម្លៃតាមបែបគុណភាពរបស់ក្រុមការងារបានបង្ហាញថាសកម្មភាព នឹងលទ្ធផលក្នុងអនុកិច្ចសន្យាពិតជាឆ្លើយតប និងគោលបំណងបន្ទាន់ ប៉ុន្តែមិនអាចកំណត់ថាសម្រេចបានក្នុងកំរិតណាមួយនោះទេ ។ |

## ផ្នែក-គៈ សង្ខេបការវាយតម្លៃផលប្រយោជន៍ជារួមដែលទទួលបាន

ឆ្លងតាមការពិភាក្សាក្រុមរបស់អ្នកចូលរួមបានបង្ហាញថា ពួកគាត់ពេញចិត្តជាខ្លាំង ចំពោះផលដែលបានទទួលពីគម្រោងនេះ ជាពិសេសការផ្តល់ចំណេះក្នុងការចិញ្ចឹមជ្រូកមេពូជ និងចំណេះដឹង ជំនាញសមត្ថភាពក្នុងការកាត់ដេរសំលៀកបំពាក់ ។ ពួកគាត់ថែមទាំងបញ្ជាក់ថាវាមានសារសំខាន់ណាស់សំរាប់គ្រួសារ និងសហគមន៍របស់គាត់ ដោយមានមុខរបបបន្ថែមក្រៅពីប្រកបមុខរបបរផ្សេងៗ និងធ្វើស្រែចំការ ដោយធ្វើឱ្យគ្រួសាររបស់ ពួកគាត់មានភាពប្រសើរជាងមុន ។

# ករណីសិក្សា

## ករណីសិក្សាទី១ : អ្នកបានទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងវគ្គបណ្តុះបណ្តាលជំនាញកាត់ដេរដល់ក្រុមស្ត្រី



កញ្ញា ឈាង-ស្រស់

កញ្ញា **ឈាង ស្រស់** អាយុ ១៩ ឆ្នាំ ម្តាយឈ្មោះ **ឈឹម សារី** ឪពុក (ចុង) ឈ្មោះ **គង់ មុំ** រស់នៅក្នុងភូមិ ដូនស្វា ស្រុកពួក ខេត្តសៀម រាប ។ នាងជាកូនច្បងក្នុងចំណោមបងប្អូន ០៤ នាក់ ក្នុងគ្រួសារក្រីក្រ មានជាអ្នកលក់ដូរចាប់ហួយ បន្តិចបន្តួចនៅផ្ទះ ។ គ្រួសារនេះស្ថិតក្នុងលំដាប់ គ្រួសារក្រីក្រប្រភេទ ១ ដែលបានទទួលស្គាល់ក្នុងបញ្ជី នៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។ ដោយសារតែជីវភាពគ្រួសារមានភាពខ្វះខាតខ្លាំងពេក នាងត្រូវបញ្ឈប់ការសិក្សាត្រឹមថ្នាក់ទី៨ ។

គ្រួសារនាងពុំមានដីកសិកម្មបន្តិចណាសោះក្រៅពីដីលំនៅស្ថាន ។ ដំណោះស្រាយសម្រាប់ជីវភាព គ្រួសារបចាំថ្ងៃ គឺចំណូលពីការ លក់ចាប់ហួយនេះតែម្តង ។

សំណាងណាស់ដែលរូបនាងត្រូវបានគម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈកាត់ដេរ និងឆ្នៃម៉ូត ដែលរៀបចំ ដោយមន្ទីរកិច្ចការនារីខេត្តសៀមរាប ក្រោមការឧបត្ថម្ភ គាំទ្រ ដោយមូលនិធិរបស់ គ-ជ-អ-ប ក្រោមការចង្អុលបង្ហាញ និងចុះជ្រើសរើសផ្ទាល់ដោយភ្នាក់ងារអនុវត្តអនុកិច្ចសន្យា សហការជាមួយអាជ្ញាធរមូលដ្ឋាន បានកំណត់យករូបនាងម្នាក់ ក្នុងចំណោមយុវតីបីនាក់ទៀតក្នុង ឃុំសំរោងយា ស្រុកពួក ដើម្បីចូលរៀន វគ្គបណ្តុះបណ្តាល។

រយៈពេល ០៦ខែ ដែលរូប និងសិក្ខាកាមដទៃទៀតបានទទួលការបណ្តុះបណ្តាល នាងមានការខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ក្នុងការសិក្សានេះ ។ ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាល នាងបានក្លាយជាមនុស្សម្នាក់ដែលមានសមត្ថភាពរកប្រាក់ចំណូលបន្ថែម សម្រាប់ជួយផ្គត់ផ្គង់ក្នុងគ្រួសារ និងអាចទិញសំភារៈប្រើប្រាស់ផ្ទាល់ខ្លួន ។ នាងបាន បន្ថែមថា ក្នុងមួយថ្ងៃនាងអាចរកប្រាក់បានពី ៣០០០រៀល ទៅ៧០០០រៀល ដើម្បីជួយរំលែកបន្ទុកក្នុងគ្រួសារបាន មួយចំណែក ដែលខុសពីពេលមុន រងចាំតែសំប្រាក់ពីម្តាយ ។

នៅទីបញ្ចប់នាងសូមអរគុណដល់ប្រធានគម្រោង ដែលបានផ្តល់ឱកាសឱ្យនាងបានចូលរួម និងសូមឱ្យមានវគ្គនេះបន្តទៀតដើម្បីជួយអ្នកក្រីក្រដូចជារូបនាង ហើយក៏សុំឱ្យមានវគ្គកែច្នៃម៉ូតបន្ថែមទៀត ព្រោះនាងមិនទាន់មាន ជំនាញកាត់សំលៀកបំពាក់ពី ហូលផាមួង និងក្រណាត់ប៉ាក់ច្បាស់នៅឡើយ ។

**ករណីសិក្សាទី២: អ្នកមិនបានទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈកាត់ដេរដល់ស្ត្រី**

កញ្ញា **នួន សារឿន** អាយុ ១៥ ឆ្នាំ ឪពុកឈ្មោះ **ភី ហួន** និង ម្តាយឈ្មោះ **ពៅ ចន្ទី** មានបងប្អូនចំនួន៩នាក់(ប្រុស២ និងស្រី៧) នាងជាកូនទី៣ ។ នាងរស់នៅក្នុងភូមិដូនស្វា ឃុំសំរោងយា ស្រុកពួក ខេត្តសៀមរាប។ នាង និង គ្រួសារមានចំណូលមកពី លក់ចាប់ហួយបន្តិចបន្តួចនៅផ្ទះ និង ធ្វើជាកម្មករសំណង់ ហើយគ្មានដីស្រែធ្វើកសិកម្មនិងគេទេ។

**នួន សារឿន** មិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈកាត់ដេរ ដែលជាគម្រោងរបស់មន្ទីរកិច្ចការនារីខេត្តសៀមរាប ។ នាងក៏ជាគ្រួសារមួយស្ថិតនៅក្នុងអត្តសញ្ញាណកម្មគ្រួសារក្រីក្រដែរ តែគ្រួសារនាង មិនត្រូវបានគេជ្រើសរើសអោយចូលក្នុងគម្រោងទេ ដោយសារមេភូមិគាត់ជ្រើសរើសយកតែ២នាក់ទេក្នុងភូមិនេះប៉ុណ្ណោះ ។ នាងនិយាយថា វគ្គបណ្តុះបណ្តាលនេះគឺវាមានសារៈសំខាន់ណាស់សំរាប់ខ្លួននាងផ្ទាល់ និង ក្រុមគ្រួសារព្រោះអាចជួយឱ្យ នាងទទួលបាននូវចំណេះដឹង និងជំនាញកាត់ដេរ ហើយអាចប្រកបមុខរបរ រកប្រាក់ចំណូលសំរាប់ជួយគ្រួសារបន្ថែមទៀត ។



កញ្ញា **នួន សារឿន**
និង ក្រុមគ្រួសារ

នាងបានបន្ថែមទៀតថា ឈ្មោះ **សាំង គឹមស៊ន់** និង **ឈាង ស្រស់** ជាអ្នកនៅជិតខាងនាង ដែលទទួលបានការបណ្តុះបណ្តាលពីជំនាញវិជ្ជាជីវៈកាត់ដេរ ឃើញថាពួកគេអាចរកបានប្រាក់កំរៃពីការកាត់ដេរក្នុងមួយថ្ងៃជាមធ្យមចំនួនពី ៦០០០ រៀល ទៅ ១០០០០រៀល ។ បច្ចុប្បន្នពួកគេអាចយកលុយទាំងនោះទៅទិញសម្ភារៈផ្សេងៗដែលត្រូវការ ព្រមទាំងជួយគ្រួសារពួកគេបានមួយកំរិតទៀត ។

កញ្ញា**នួន-សារឿន**មានសង្ឃឹមថា បើមានវគ្គបណ្តុះបណ្តាលលើកក្រោយទៀតគឺនាង ចង់ចូលរួមវគ្គកាត់ដេរនឹងគេដែរ ដើម្បីមានលទ្ធភាពអាចរកប្រាក់មកចិញ្ចឹមគ្រួសាររបស់នាង ព្រោះនាងមានបងប្អូនច្រើនហើយអាចបង្រៀនប្អូនៗរបស់នាងអោយចេះកាត់ដេរដែរ ។

ជាចុងបញ្ចប់នេះ នាងមានសំណូមពរថាបើមានវគ្គបណ្តុះបណ្តាលលើកក្រោយសូមឱ្យម្ចាស់គម្រោងជ្រើសរើសយកនាង ។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

(ពិន្ទុ:១=ខ្សោយណាស់ ២=ខ្សោយ ៣=មិនខ្លាំងមិនខ្សោយ ៤=ខ្លាំង ៥=ខ្លាំងណាស់)

| ល.រ (១) | ធាតុ (២) | ទំនាក់ទំនងតក្កភាព (៣) | បរិយាយច្បាស់លាស់ (៤) | សង្ខេបការវាយតម្លៃ (៥) |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៤ | ៥ | -សកម្មភាពដែលបានលើកឡើងពិតជាមានទំនាក់ទំនងតក្កភាពជាមួយលទ្ធផលដែលបានបរិយាយក្នុងឯកសារនៃអនុកិច្ចសន្យា។ ឧទាហរណ៍លទ្ធផលទី២-១ ទាក់ទិនទៅនឹងការផ្តល់ការវគ្គបណ្តុះបណ្តាល និងចិញ្ចឹមជ្រូកមេពូជនិងវគ្គបណ្តុះបណ្តាលជំនាញកាត់ដេរ និងផ្អែម្ជូតដល់ក្រុមស្ត្រីក្រក្រនិងងាយរងគ្រោះ ។ សកម្មភាពនេះពិតជាបាន អនុវត្តទៅតាមលទ្ធផលនៃអនុកិច្ចសន្យាដែលបានបរិយាយច្បាស់លាស់ដោយបានកណត់ទំហំ និងបរិមាណច្បាស់លាស់នៃអ្នកទទួលផល ។ |
| ២ | លទ្ធផល | ៤ | ៥ | លទ្ធផលដែលបានសរសេរ និងបរិយាយនេះ បានកំណត់សូចនាករជាក់លាក់និងអាចវាស់វែងបាន។លទ្ធផលនេះបានឆ្លើយតប និងបំពេញទៅនឹងគោលបំណងបន្ទាន់ក្នុងលទ្ធផលទី២-១ ។ តែលទ្ធផលនេះក៏នៅមិន |

| | | | | |
|---|---|---|---|---|
| | | | | ទាន់សម្រេចបាននូវគោលបំណង បន្ទាន់ ។ បានទាំងស្រុងឡើយ វាគ្រាន់តែបានឆ្លើយតបតាមអ្វីដែលបានគ្រោងទុកតែប៉ុណ្ណោះ។ ជាក់ស្តែងលទ្ធផលទទួលបានគឺៈ-ការបណ្តុះបណ្តាល និងផ្តល់ការចិញ្ចឹមជ្រូកមេពូជ ០១វគ្គ ០៥ គ្រួសារ។ និងសកម្មភាពមួយទៀតដែរគឺ ផ្តល់វគ្គបណ្តុះបណ្តាលជំនាញកាត់ដេរនិងឆ្នៃម៉ូតចំនួន ០១វគ្គ ស្មើនឹង១២នាក់រយៈពេល០៦ខែ ចូលរួមរៀនដល់ក្រុមស្ត្រីក្រីក្រ និងងាយរងគ្រោះ ។ |
| ៣ | គោលបំណងបន្ទាន់ស្ថិតក្នុងចំណុច(ខ) នៃផ្នែកទី៣ | ៤ | ៤ | ក្នុងអនុកិច្ចសន្យា មិនបានសរសេរលំលេចចេញឱ្យឃើញនិងបរិយាយច្បាស់លាស់ក្នុងអនុកិច្ចសន្យាទេ តែបានបញ្ជាក់ក្នុងលទ្ធផលទី១-១។ក៏ជាហេតុផលដែលបញ្ជាក់ថា អនុកិច្ចសន្យាបានអនុវត្តសម្រេចបាន និងឆ្លើយតបនឹងគោលបំណងបន្ទាន់ដែរ ។ |
| ៤ | ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា(ចំណុច(គ)នៃផ្នែកទី៣ | ៤ | ៥ | ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាត្រូវបានបរិយាយច្បាស់ ហើយមានទំនាក់ទំនងផ្ទាល់ទៅនឹង លទ្ធផលនិងសកម្មភាពនៃអនុកិច្ចសន្យា ។ ស្ថានភាពចុងបញ្ចប់នេះបានឆ្លុះបញ្ចាំងនូវសមិទ្ធផលដែលសម្រេចបានក្នុងកម្រិត |

| | | | | |
|---|---|---|---|---|
| | | | | លទ្ធផល ។ ការឆ្លុះបញ្ចាំងនូវស្ថានភាពចុងបញ្ចប់ឬផលប៉ះពាល់ដែលកើតឡើងក្នុងកម្រិតប្រជាពលរដ្ឋឬសហគមន៍ មិនអាចវាស់វែបានទេ។ លក្ខីករណ៍ខ្លះៗដែលបានបង្ហាញគឺៈ-ក្រុមអ្នកទទួលផលគោលដៅភាគច្រើនបានយកចំណេះដឹងជំនាញទៅប្រើប្រាស់ប្រកបមុខរបររកប្រាក់ចំណូលគ្រួសារទទួលបានផលល្អប្រសើរតែកម្រិតនៃផលទទួលបានទាំងនោះពុំទាន់សម្គត់ថាវាបានជួយរំលែក និងបន្ថយភាពក្រីក្របានកម្រិតណាទេ ។ |
| ៥ | លទ្ធផលអភិវឌ្ឍ/ផលប៉ះពាល់រយៈពេលវែងគោលដៅ និងគោលបំណងអភិវឌ្ឍន៍ (ចំណុចខនៃផ្នែកទី៣) | | | (មិនអាចធ្វើការវាយតម្លៃបានទេ ) |

**ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខ័ណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារៈ-**

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.អ.ជ.ខ** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | នៅមានកម្រិត។ គួរតែពង្រឹងបន្ថែម និងមានការបន្តគាំទ្របច្ចេកទេសពីសំណាក់ទីប្រឹក្សា និងផ្នែកជំនាញដទៃទៀតដែលមានការពាក់ព័ន្ធ ជាពិសេស |

| | | |
|---|---|---|
| | | ថ្នាក់ជាតិ ។ |
| ២ | ការគាំទ្រទាន់ពេលវេលានិងការត្រួតពិនិត្យការអនុវត្តន៍របស់ភ្នាក់ងារអនុវត្តន៍ | អនុវត្តបានសមរម្យ។ គ្មានការប្រឈមនិងឧបសគ្គ ឬការរំខាននានាដែលគួរឱ្យកត់សម្គាល់ឡើយ ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារអនុកិច្ចសន្យា | ដោយសារការអនុវត្តត្រូវបានប្រតិបត្តិតាមគោលការណ៍ និងនិតិវិធីនៃមគ្គុទេសន៍ណែនាំការអនុវត្ត ការកត់ត្រាទុកដាក់និងរក្សាឯកសារគួរត្រូវកែលម្អខ្លះដើម្បីធ្វើឱ្យប្រសើរឡើង ។ |
| **ពីខាងភាគីអនុវត្តន៍កិច្ចសន្យា:** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោងនិងបច្ចេកទេស | បានរៀបចំ និងបង្កើតឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រង និងអនុវត្តត្រឹមត្រូវ។ បុគ្គលិកគម្រោងនិងធនធានមនុស្សតាមរយៈការពង្រឹងសមត្ថភាពត្រូវបានការគាំទ្រគ្រប់គ្រាន់ ។ |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | ការអនុវត្តសកម្មភាពលទ្ធផលនានាបានទាន់ពេលវេលា និងមានភាពរលូនតាមការគ្រោងទុកថ្វីត្បិតការអនុម័ត និងផ្តល់សច្ចាប័នអនុកិច្ចសន្យាមានការយឺតយ៉ាវជាអន្លើរ ពិតមែន ។ |
| ៦ | ការរាយការណ៍ការរីកចំរើននិងការកត់ត្រាឯកសារ | អនុវត្តតាមការណែនាំដូចទំលាប់និងនិតិវិធីណែនាំ តែមានការយឺតយ៉ាវ និងភាពមិនប្រក្រតីខ្លះ ។ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | លក្ខខ័ណ្ឌក្នុងកិច្ចសន្យាត្រូវបានបំពេញ និងគោរព |
| **ទាំងខាង គ.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យា:** | | |
| ៨ | ការគ្រប់គ្រង“ហានិភ័យនិងកត្តាសន្មត” (ចំណុច-ងផ្នែកទី៣)និងបញ្ហាប្រឈម | ដោយសារការអនុម័តកិច្ចសន្យាពីថ្នាក់លើយឺតយ៉ាវ និងការអនុម័តអនុកិច្ចសន្យាថ្នាក់ខេត្តក៏យឺតយ៉ាវផងនោះការអនុវត្តសកម្មភាពទាំងឡាយពុំបានសមស្របតាមតារាងផែនការការងារ បានល្អទេសកម្មភាពត្រូវមមាញឹកនៅខ្ទាំងពាក់កណ្តាលឆ្នាំ។ សកម្មភាពខ្លះជួបបញ្ហាប្រឈមជាអន្លើរៗដែលយើងគ្រប់គ្រងមិន |

| | | |
|---|---|---|
| | | បានដូចជាករណីជ្រូកមិនកើតកូនជ្រូកកូនតិចនិងកើតមកហើយកូនជ្រូកងាប់ ។ |
| ៩ | ការបញ្ជ្រាបយេនឌ័រ (ចំណុច-ចផ្នែកទី៣) | នេះជាគម្រោងដែលអនុវត្តដោយមន្ទីរកិច្ចការនារីផ្ទាល់ដែលផ្នែកសំខាន់គឺការលើកកម្ពស់ស្ត្រី និងយេនឌ័រ។ ភ្នាក់ងារអនុវត្តគឺជាស្ត្រី រីឯក្រុមអ្នកទទួលផលទៀតសោតក៏ជាស្ត្រីក្រីក្រ និងងាយរងគ្រោះ។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ ( ចំណុច-ឆ ផ្នែកទី៣) | អនុកិច្ចសន្យាឆ្នាំ២០០៩របស់មន្ទីរកិច្ចការនារីខេត្តដែលមានលទ្ធផល និងសកម្មភាពទាំងអស់ជាគម្រោងសេវាកម្ម និងផ្តោតលើការគាំទ្រផ្នែកយេនឌ័រ និងលើកកំពស់ស្ត្រី និងកុមារ។ ប៉ុន្តែសកម្មភាពខ្លះគឺការគាំទ្រនិងបញ្ជ្រាបសកម្មភាពស្ត្រីទៅក្នុងការបង្កើត និងគាំទ្រកម្មវិធីវិយោគឃុំ-សង្កាត់ ដែលផ្នែកខ្លះបានបង្កើតឱ្យមានការគាំទ្រការយល់ ដឹងពីការអភិរក្សធនធានធម្មជាតិ និងបរិស្ថានផងដែរ ។ |
| ១១ | ការថែរក្សា(និរន្តភាព)(ចំណុច-ជផ្នែកទី៣) | សកម្មភាព និងលទ្ធផលដែលបានគ្រោង និងអនុវត្តដែលមានចែងក្នុងអនុកិច្ចសន្យាបានពិនិត្យមើលឃើញថា ត្រូវបានយកទៅអនុវត្តដោយក្រុមគោលដៅដែលជាអ្នកទទួលផលហើយបានបន្តអនុវត្តរហូតដល់ពេលក្រុមការងារចុះវាយតម្លៃ ។ ដូចនេះ និរន្តភាពរបស់ផ្នែកខ្លះនៃគម្រោងវាពិតជាសម្រេច ។ |

## ២.៤. សេចក្តីសន្និដ្ឋាន

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យានេះបានអនុវត្តឡើងស្របតាមការគ្រោងទុក។ ភាគីអនុវត្តមានសមត្ថភាព និងធនធានគ្រប់គ្រាន់ក្នុងការអនុវត្ត។ សកម្មភាព និងលទ្ធផលទាំងឡាយដែលបានគ្រោងបានអនុវត្តបញ្ចប់ស្របតាមផែនការ មិនមានការធ្វើវិសោធនកម្ម ដើម្បីកែប្រែសកម្មភាព លទ្ធផលណាមួយទេ ។ |
| ២ | សកម្មភាពដែលអនុវត្តក្នុងអនុកិច្ចសន្យា និងអត្ថប្រយោជន៍ដែលទទួលបានពីសំណាក់អ្នកទទួលផលផ្ទាល់ និងប្រយោលក្នុងសហគមន៍គោលដៅមានការសាទរជាខ្លាំងពេលដែលក្រុមការងារបានចុះប្រមូលពត៌មាន និងសង្កេតផ្ទាល់ពេលវាយតម្លៃ។ ទស្សីករណ៍ទាំងឡាយអំពីលទ្ធផលនិងអត្ថប្រយោជន៍ដែលទទួលបានខាងក្រោមនេះគឺជាការសង្កេតឃើញជាក់ស្តែងបន្ទាប់ពីការបញ្ចប់អនុកិច្ចសន្យារយៈពេលយូរហើយដែរដូចជាៈ-<br>ក)យកការណែនាំ និងបង្ហាត់បង្ហាញពីបច្ចេកទេសចិញ្ចឹមជ្រូកមេពូជសម្រាប់ជួយក្រុមស្ត្រីក្នុងសហគមន៍ ពិតជាបានអនុវត្តតាមពិតប្រាកដមែន ។ ការចិញ្ចឹមជ្រូកមេពូជពិតជាមានការកើនឡើងនូវចំនួនគ្រួសារក្នុងសហគមន៍។ ពួកគេយល់ថាអាចផ្តល់ប្រយោជក្នុងការបង្កើនប្រាក់ចំណូលគ្រួសារពិតប្រាកដមែន ។<br>ខ)មានតម្រូវការជាច្រើនពីសំណាក់ស្ត្រីភាគច្រើនជាយុវតី ដែលស្ថិតក្នុងស្ថានភាព ស្រដៀងគ្នានេះ ប៉ុន្តែមិនបានចូលរួមក្នុងក្នុងការបណ្តុះបណ្តាលជំនាញនេះពីមុនមក ។ សំណូមពរយ៉ាងទទូចឱ្យបន្តការគាំទ្រនូវវគ្គបណ្តុះបណ្តាលជំនាញវិជ្ជីវៈកាត់ដេរនិងផ្អែម៉ូតដល់ពួកគេនៅពេលក្រុមការងារចុះដល់មូលដ្ឋាននេះ។ ពួកគេបានឃើញ បានដឹងយ៉ាងច្បាស់ថាមិត្តភក្តិរបស់គេពិតជារកប្រាក់ចំណូលបានច្រើនគួរសមតាមរយៈការចូលបម្រើក្នុងហាងកាត់ដេរដែលទទួលប្រាក់ខែ ឬប្រាក់កម្រៃឈ្នួល ។ ពុំនោះសោតពួកគេយល់ច្បាស់ថា បានបង្កើនសមត្ថភាព ចំណេះដឹងមួយផ្នែកទៀតដោយអនុវត្តបានតាមរយៈបទពិសោធន៍ទាំងនេះ ។ |
| ៣ | ការជ្រើសរើសក្រុមអ្នកទទួលផលក្នុងសហគមន៍ ពិតជាអនុវត្តតាមនិតិវិធី និងគោលការណ៍ណែនាំ ដោយអនុវត្តដោយភាគីអនុវត្តអនុកិច្ចសន្យា សហការជាមួយអាជ្ញាធរ |

| | |
|---|---|
| | មូលដ្ឋាន ។ មោទនភាពយ៉ាងខ្លាំងបំផុតនោះគឺការធានាថាអ្នកដែលមានតម្រូវការចាំបាច់បំផុតនឹងទទួលបានផលប្រយោជន៍ពិតពីអនុកិច្ចសន្យា ។ |
| ៤ | អនុកិច្ចសន្យានេះមិនមានជួបប្រទះនូវឧបសគ្គ និងបញ្ហាប្រឈមគួរឱ្យកត់សម្គាល់ទេ ។ |

## ចំណុចរៀនសូត្រ

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ការសង្កេតឃើញជាក់ស្តែងក្នុងការវាយតម្លៃនេះ ផលប៉ះពាល់របស់អនុកិច្ចសន្យា និងការធានានិរន្តភាពរបស់អនុកិច្ចសន្យាអាចត្រូវបានសម្រេចក្នុងកម្រិតសមរម្យប្រសិនបើអនុកិច្ចសន្យានេះត្រូវបានរៀបរៀងឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ក្រុមគោលដៅដែលជាអ្នកទទួលផលនិងពិនិត្យដោយយកចិត្តទុកដាក់ដោយផ្តោតលើតារាងតម្រូវការក្នុងកម្មវិធីវិនិយោគឃុំ-សង្កាត់ និងទិន្នន័យតម្រូវការជាចាំបាច់ ។ |
| ២ | ការបរិយាយច្បាស់លាស់នូវគោលបំណងបន្ទាន់ក្នុងកំរិតដែលអាចវាស់វែងបានជាសារប្រយោជន៍សម្រាប់ការកត់ត្រាទុក នូវលទ្ធផលរបស់អនុកិច្ចសន្យានិងផលប្រយោជន៍ដែលមាន ដើម្បីការវាយតម្លៃលទ្ធផល ។ |

## អនុសាសន៍ :

| ល.រ | អនុសាសន៍ |
|---|---|
| ១ | ក្នុងអនុកិច្ចសន្យាគួរត្រូវសរសេរ និងរៀបរៀងអំពីគោលបំណងបន្ទាន់ដែលមានទំនាក់ទំនងជាមួយលទ្ធផល និង អត្ថប្រយោជន៍ ដលរំពឹងទុកដោយរៀបឱ្យមានលំដាប់លំដោយតាមឋានានុក្រមគោលដៅនៃតារាងតក្កភាព ។ |
| ២ | អ្នកអនុវត្តគម្រោងមន្ទីរកិច្ចការនារីខេត្ត-ស្រុក ក្រុមប្រឹក្សាឃុំ និងភូមិគោលដៅ គប្បីពិចារណាអោយបានដិតដល់ ចំពោះគ្រួសារក្រីក្រមុនការផ្តល់គម្រោង ។ ជាការប្រសើរណាស់ដែលចាំបាច់ត្រូវពិចារណាបន្ថែមទៀត ប្រសិនបើពិនិត្យឃើញថាសមាជិកក្រុមគោលដៅដែលជ្រើសរើសបាន ពុំមានលទ្ធភាពអនុវត្តទៅបាន ក្នុងករណីមានការកែប្រែ ចាំបាច់ណាមួយ ដោយត្រូវជ្រើសរើសសមាជិក ក្រុមគោលដៅទទួលផលផ្សេងទៀត ។ |

| | |
|---|---|
| ២ | ភាគីអនុវត្តអនុកិច្ចសន្យា គប្បីជ្រើសរើសគម្រោងទាំងឡាយណាក្នុងគោលបំណងជួយគាំទ្រដល់ស្ត្រីក្រីក្រ និងងាយរងគ្រោះបានទទួលផលប្រយោជន៍ដោយមិនចាំបាច់ និងទាមទារ ឱ្យពួកគាត់ត្រូវចំណាយថវិកាដ៏ចាំបាច់ សម្រាប់ដំណើរការឱ្យគម្រោងនោះទទួលជោគជ័យ ។ ជាក់ស្តែងគម្រោងក្នុងឆ្នាំ ២០០៩នេះ មន្ទីរកិច្ចការនារីបានផ្តល់សកម្មភាពវគ្គបណ្តុះបណ្តាលកាត់ដេរ និងឆ្នៃម្ជុំតដល់ក្រុមស្រីក្រីក្រនិងងាយរងគ្រោះដែលចប់វគ្គបណ្តុះបណ្តាលគម្រោងបានផ្តល់ម៉ាស៊ីនដេរ និងសម្ភារៈមួយចំនួនឱ្យពួកគាត់មកប្រកបអាជីពនៅសហគមន៍វិញ ។ នេះសរបញ្ជាក់ថាគម្រោងបានផ្តល់ឱ្យពួកគាត់បានចំណេះដឹងវិលមកសហគមន៍វិញ ដោយឡែកគម្រោងផ្តល់ការចិញ្ចឹមជ្រូកពូជដល់ពួកគាត់ជាការប្រសើរតែត្រូវពិចារណាផងដែរថាៈ-ក្រុមអ្នកទទួលផលទាំងនោះជាស្ត្រីក្រក្របំផុតក្នុងភូមិ មានន័យថាពួកគាត់ពុំមានស្បៀងហូបគ្រប់គ្រាន់ទេ ហើយថែមទាំងត្រូវការចាំបាច់នូវថវិកាមួយផ្នែកសម្រាប់ទិញចំណី ដើម្បីផ្គត់ផ្គង់ឱ្យបានធំធាតិដូចជាៈ-កន្ទក់ ចុងអង្ករ និងចំណីបំប៉នផ្សេងទៀត......។ល។ បន្ថែមលើរុក្ខជាតិដែលគាត់រកបានក្នុងសហគមន៍ដូចជា :-ត្រកួន ច្រាច់ និងស្មៅថ្មី ដទៃទៀត ។ |

## ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

**ឯកសារដែលត្រូវភ្ជាប់ទី១ : បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗដែលបានពិនិត្យ ។**

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) | មាន (៣) |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា(ផ្នែកទី១ទី២និងទី៣)និងឯកសារវិសោធនកម្ម(បើមាន) | √ |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ | √ |
| ៣ | របាយការណ៍ត្រួតពិនិត្យគម្រោង | √ |
| ៤ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | √ |
| ៥ | បញ្ជីវត្ថុបណ្ដុះបណ្ដាលដែលមានក្នុងអនុកិច្ចសន្យា | √ |
| ៦ | ឯកសារដទៃទៀតរួមមាន រូបថតនៃគម្រោង (អនុកិច្ចសន្យា) ដែលទុកនៅគណៈកម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ និងនៅភ្នាក់ងារអនុវត្តន៍ ដែលមិនបានរៀបរាប់ខាងលើ | √ |

## ឯកសារដែលត្រូវភ្ជាប់ទី២ : បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាស/ជួបពិភាក្សា

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៍ប្រើសម្រាប់ប្រមូលទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | .២១ កញ្ញា | លោកស្រី **អ៊ុំ-រិន** មន្ត្រីគ្រប់គ្រងគម្រោង ស្តីទីទទួលការងាររួម | មន្ទីរកិច្ចការនារី ខេត្តសៀមរាប | សម្ភាសន៍ស៊ីជម្រៅ |
| ២ | ២១ កញ្ញា | លោកស្រី**ឡា-អួន** មន្ត្រីអនុវត្តគម្រោងទទួលការងារក្រុមចិញ្ចឹមជ្រូកមេពូជ | មន្ទីរកិច្ចការនារី ខេត្តសៀមរាប | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | ២១ កញ្ញា | កញ្ញាលុយ-រតនា មន្ត្រីអនុវត្តគម្រោងទទួលការងារកាត់ដេរ និងឆ្នៃម៉ូត | មន្ទីរកិច្ចការនារី ខេត្តសៀមរាប | សម្ភាសន៍ស៊ីជម្រៅ |
| ៤ | ២២ កញ្ញា | លោក **ឡាច-សឿន** មេឃុំសំរោងយា ជាឃុំគោលដៅ និងជាអ្នកពាក់ព័ន្ធ | សាលាឃុំសំរោងយា | សម្ភាសស៊ីជម្រៅ |
| ៥ | ២២ កញ្ញា | លោកស្រី **និល-ខាត់ណា** ប្រធានការិកិច្ចការនារីស្រុកពួក ជាអ្នកពាក់ព័ន្ធ | សាលាស្រុកពួក | សម្ភាសស៊ីជម្រៅ |
| ៦ | ២២ កញ្ញា | លោកស្រី**ប៉ាត-សុភា** ជំទប់ទី២ ទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ | សាលាឃុំសំរោងយា | សម្ភាសស៊ីជម្រៅ |
| ៧ | ២៣ កញ្ញា | ក្រុមអ្នកទទួលផល | ភូមិសំរោងយា | សម្ភាសជាក្រុម |
| ៨ | ២៣ កញ្ញា | កញ្ញា **ឈាង-ស្រស់** អ្នកទទួលផលផ្ទាល់ពីគម្រោងកាត់ដេរ | ភូមិដូនស្វា | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៩ | ២៣ កញ្ញា | កញ្ញា **ឈួន- សារឿន** អ្នកមិនបានទទួលផលពីគម្រោងកាត់ដេរ | ភូមិដូនស្វា | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| **លេខអនុកិច្ចសន្យា :** | **18/AGR/0901-00 (NRML)** |
| **ចំណងជើង :** | **ការបង្កើតផលិតភាព និង ផលិតផលកសិកម្ម** |
| **ភ្នាក់ងារអនុវត្តន៍ :** | មន្ទីរកសិកម្មខេត្តព្រះសីហនុ |
| **រយះពេល ( ចាប់ផ្តើម និង បញ្ចប់)** | ០១ មករា ឆ្នាំ ២០០៩ ដល់ ៣១ ធ្នូ ២០០៩ |
| **រាជធានី ខេត្ត** | ព្រះសីហនុ |
| **ផ្នែក ,មន្ទីរជំនាញ** | មន្ទីរកសិកម្មខេត្តព្រះសីហនុ |
| **ចំនួនថវិកាទទួលបានពីគ.អ.ជ.ប/គ.ប្រនៃ គ.អ.ជ.ខ** | ៧.២៥០ ដុល្លារ |
| **ការរួមចំណែករបស់ដៃគូរអភិវឌ្ឍន៍ដទៃទៀត** | 0.00 ដុល្លារ |
| **ការរួមចំណែករបស់សហគមន៍** | 0.00 ដុល្លារ |
| **ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៍** | 0.00 ដុល្លារ |
| **តម្លៃសរុប ( ដុល្លារសហរដ្ឋអាមេរិក)** | **៧.២៥០ ដុល្លារ** |

## ក្រុមវាយតម្លៃ និង រៀបចំរបាយការណ៍

| ឈ្មោះ | មុខតំណែង |
|---|---|
| **លោក ស៊ី ហេង** | គ្រូបង្គោលប្រចាំខេត្ត និងមន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ គ.ប្រ |
| **កញ្ញា ម៉ិញ ចិន្តា** | គ្រូបង្គោលប្រចាំខេត្ត និង សវនករផ្ទៃក្នុងនៃ គ.ប្រ |
| **លោក ផុក ទូច** | មន្ត្រីត្រួតពិនិត្យ និង វាយតម្លៃ នៃ គ.ប្រ |

**ខេត្តព្រះសីហនុ**

**១២ តុលា ២០១០**

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៣ |
| | របាយការណ៍សង្ខេប | ៤ |
| **១-** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៧** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និង មន្ទីរវិស័យ | ៧ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៧ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៧ |
| ១.៤ | សំណួរវាយតម្លៃ | ៨ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និង ដំណើរការវាយតម្លៃ | ៨ |
| ១.៦ | ដែនកំណត់ និង បញ្ហាប្រឈមនៃការវាយតម្លៃ | ៩ |
| **២-** | **លទ្ធផលសំខាន់ៗ និង ការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១០** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល | ១០ |
| | - លទ្ធផលទី១ | ១០ |
| | - លទ្ធផលទី២ | ១៥ |
| | - លទ្ធផលទី៣ | ១៦ |
| | - លទ្ធផលទី៤ | ២០ |
| ២.២ | ការវាយតម្លៃការសម្រេចបាននូវអត្ថប្រយោជន៍ភ្លាមៗ និង លទ្ធផលនៃអនុកិច្ចសន្យា | ២១ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និង ការគ្រប់គ្រង | |
| ២.៤ | សេចក្តីសន្និដ្ឋាន | |


**ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍**


ទី១- បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និង ឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ

ទី២- ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍/ពិភាក្សា


**ករណីសិក្សា**


ទី១- អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគំរោងបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និង ទទួលពូជដំណាំ

ទី២- អ្នកមិនទទួលផល

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត |
| **គ.អ.ជ.ខ** | គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **AGR** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និង មន្ទីរកសិកម្ម |
| **NRML** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និង មន្ទីរវិស័យដែលប្រើប្រាស់ប្រភពថវិកា **DANIDA** |

# របាយការណ៍សង្ខេប

**គោលបំណង និងវិធីសាស្រ្ត នៃការវាយតម្លៃដែលបានប្រើ :**

មន្រ្តីត្រួតពិនិត្យ និង វាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យា នៃគ.ប្រខេត្ត និង គ្រូបង្គោលថ្នាក់ក្រោមជាតិឆ្នើមប្រចាំខេត្ត បានធ្វើការ វាយតម្លៃអនុកិច្ចសន្យា ដែលមានចំណងជើងថា "ការបង្កើនផលិតភាព និង ផលិតផលកសិកម្ម" លេខ 18/AGR/0901-00 ដែលជា អនុកិច្ចសន្យា រវាង គ.ប្រនៃគ.អ.ជ.ខ ខេត្តព្រះសីហនុ និង មន្ទីរកសិកម្មខេត្ត ។ នេះជាផ្នែកមួយនៃគម្រោងពង្រឹងសមត្ថភាព គ្រូបង្គោលថ្នាក់ក្រោមជាតិ របស់ផ្នែកត្រួតពិនិត្យ វាយតម្លៃ និង ផ្សព្វផ្សាយ គោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែលគាំទ្រដោយ កម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ ។

គោលបំណងជាក់លាក់នៃការវាយតម្លៃនេះគឺ :

១- ទាញយក កត់ត្រា និង វិភាគជាប្រព័ន្ធទៅលើសមិទ្ធផល នៃអនុកិច្ចសន្យា និង ចំនុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និង ស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំង កត់ត្រានូវចំណុចរៀនសូត្រ និង ផ្នែកដែលត្រូវ ធ្វើឱ្យប្រសើរឡើងនៅពេលអនាគត ។

២- ពង្រឹងរបៀបធ្វើការវាយតម្លៃគម្រោង របស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវតន៏គម្រោង ។ ការវាយតម្លៃ អនុវត្តតាមការណែនាំ និង ឧបករណ៏ ស្តីពីការវាយតម្លៃអនុកិច្ចសន្យា របស់គណៈកម្មាធិការប្រតិបត្តិ នៃ គ.អ.ជ.ខ ដែលរៀបចំ ដោយផ្នែកត្រួតពិនិត្យ និង វាយតម្លៃ នៃលេខាធិការដ្ឋាន គ.ជ.អ.ប ។ ក្រុមការងារវាយតម្លៃ បានប្រើ ការពិភាក្សាក្រុម ការសម្ភាសស៊ីជម្រៅ ការចុះមូលដ្ឋាន គន្លឹះក្នុងការសង្កេតផ្ទាល់ និង រំលឹកឯកសារអនុកិច្ចសន្យា របាយការណ៏រីកចម្រើន និង ឯកសារផ្សេងៗទៀត ។

ការវាយតម្លៃ ត្រូវឆ្លើយនឹងសំណួរវាយតម្លៃ ។ ដោយសារធនធានមានកំណត់ យើងធ្វើការវាយតម្លៃ ស៊ីជម្រៅលើលទ្ធផលតែពីរប៉ុណ្ណោះ ចំណែកលទ្ធផលផ្សេងៗទៀត ត្រូវបានវាយតម្លៃ ដោយផ្អែកលើពតិមានដែលមានស្រាប់ ។ ដូច្នេះការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃស៊ីជម្រៅទៅលើអនុកិច្ចសន្យាទេ ហើយការសន្និដ្ឋានត្រូវធ្វើឡើង ទៅតាមអ្វីដែលរក ឃើញ ។

**ឆ្លើយទៅនឹងសំណួរទាំង៥ នៃការវាយតម្លៃ :**

សកម្មភាពទាំងអស់ត្រូវបានអនុវត្ត និង លទ្ធផលសំរេចបានតាមផែនការ :

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣ : ការបរិយាយអំពី អនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|

| | | |
|---|---|---|
| **លទ្ធផលទី១ : ការគាំទ្រប្រពន្ធ័កសិកម្មចំរុះ** | | |
| ១ | ផ្តល់ពូជបន្លែចំនួន ២៥ គីឡូក្រាម | កសិករទទួលបានពូជបន្លែចំនួន ៤០ គីឡូក្រាម |
| ២ | ផ្តល់ពូជស្រូវទិន្នផលខ្ពស់ ១៥០០ គីឡូក្រាម | កសិករទទួលបានពូជស្រូវចំនួន ១២០០គីឡូក្រាម |
| ៣ | ផ្តល់កូនឈើហូបផ្លែចំនួន ១៥០០ ដើម | កសិករទទួលបានកូនឈើហូបផ្លែចំនួន ៨៦០ ដើម |
| ៤ | ផ្តល់មេផ្សិតអំបោះចំនួន ១៨០០ កញ្ចប់ | កសិករទទួលបានមេផ្សិតអំបោះចំនួន ១៨០០ កញ្ចប់ |
| ៥ | ការរៀបចំប្រពន្ធ័កសិកម្មលើស្រែកសិករចំនួន ៥ កន្លែង | បានរៀបចំប្រពន្ធ័កសិកម្មលើស្រែកសិករចំនួន ៤ កន្លែង |
| **លទ្ធផលទី២ : ការចាក់ថ្នាំបង្ការសត្វ និង កម្មវិធីការពារប៉ារ៉ាស៊ីត** | | |
| ១ | ការចាក់ថ្នាំបង្ការ និង ព្យាបាលជម្ងឺគោក្របី ២២០០ ក្បាល | គោក្របីចំនួន៥២៣០ក្បាលត្រូវបានទទួលការចាក់ថ្នាំបង្ការ |
| **លទ្ធផលទី៣ : ការបណ្តុះបណ្តាលដល់កសិករស្តីពីបច្ចេកទេសកសិកម្ម** | | |
| ១ | វគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្មចំនួន ៨វគ្គ=១២០ន | បានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្មចំនួន៦ វគ្គ=៩០នាក់ |
| **លទ្ធផលទី៤ : ជ្រើសរើសកសិករបណ្តុះបណ្តាលអោយក្លាយជាភ្នាក់ងារចិញ្ចឹមសត្វភូមិ** | | |
| ១ | វគ្គបំប៉នដល់អ្នកស្ម័គ្រចិត្តសុខភាពសត្វភូមិចំនួន ២ វគ្គ | អ្នកចូលរួម/សិក្ខាកាមមានចំនួន ៣០ នាក់ |

១- វគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសកសិកម្ម ( ដូចជា ការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ .វិធានការកំចាត់សត្វល្អិត . វដ្តនៃដំណាំ ស្រូវ ការប្រើប្រាស់ជី ប្រពន្ធ័កសិកម្មចំរុះ និង ការកែច្នៃផលិតផលកសិកម្ម ) ការផ្តល់ពូជ ( ដូចជា ពូជបន្លែ ពូជស្រូវ មេផ្សិត និង កូនឈើ ) ការបង្ហាញបច្ចេកទេសស្តីពីប្រពន្ធ័កសិកម្មចំរុះ នៅលើស្រែកសិករ និង ការបើកវគ្គបំប៉នដល់អ្នក ស្ម័គ្រចិត្តសុខភាពភូមិ ពិតជាមានសារ:សំខាន់ មានសារ:ប្រយោជន៍ និង មានតម្លៃ ដែលមិនអាចកាត់ថ្លៃបាន ក្នុងការ រួមចំណែកដើម្បីបង្កើន និង លើកស្ទួយកំរិតជីវភាពរបស់ប្រជាកសិករ។ ជារួម អនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់ នៃអនុកិច្ចសន្យាបានក្នុងកម្រិតខ្ពស់ ។

២- អនុកិច្ចសន្យាពិតជាបានចូលរួមចំណែកក្នុងការសម្រេចនូវគោលបំណងបន្ទាន់ ដោយសារកសិករបានអនុវត្ត បច្ចេកទេសថ្មី ដែលទទួលបានពីវគ្គបណ្តុះបណ្តាល បានសាកល្បងប្រើប្រាស់/ដាំដុះប្រភេទពូជថ្មី បានបង្ហាញ ផលិតផលកសិកម្មតាម លក្ខណ:បច្ចេកទេសថ្មី និង បានបង្ហាញពីកំរិតជីវភាពក្នុងគ្រួសាររបស់ពួកគាត់ មានការកើនឡើង ទោះជាស្ថិតក្នុងកម្រិត និង ដែនកំណត់ក៏ដោយ ។

៣- អនុកិច្ចសន្យានេះ ពិតជាមានភាពពាក់ព័ន្ធ ប្រសិទ្ធភាព និង ប្រសិទ្ធផល ទាក់ទងនឹងធនធានដែលមាន ការប្រតិបត្តិ និង ការគ្រប់គ្រងទូទៅ ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ក៏គុណភាពនៃការរៀបរៀងអនុកិច្ចសន្យា គួរតែត្រូវកែលំអ ដូចខាងក្រោមៈ

ក- បរិយាយអោយបានច្បាស់លាស់ និង អាចវាស់វែងបាន នូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា និង គោលបំណងបន្ទាន់

ខ- ការប្រើប្រាស់សូចនាករជោគជ័យធៀបនឹងទិន្នន័យមូលដ្ឋាន

គ- ភ្ជាប់ទំនាក់ទំនងអោយបានច្បាស់រវាងលទ្ធផល ទៅនឹង គោលបំណងបន្ទាន់ និង គោលបំណងកម្រិតខ្ពស់ ។

៤- សេចក្តីសន្និដ្ឋាន និង ចំនុចរៀនសូត្រ ៈ

១) លទ្ធផល និង អត្ថប្រយោជន៏ ដែលបានពីការអនុវត្តន៏អនុកិច្ចសន្យា ជាប្រយោជន៏ដល់សហគមន៏ គឺមានភស្តុតាង បង្ហាញ ច្បាស់លាស់ ហើយត្រូវបានទទួលការសារទរ ពីអ្នកទទួលផល និង មិនទទួលផល នៅក្នុងឃុំដែលបានអនុវត្តគម្រោង។ ឧទាហរណ៏ ការបង្កើននូវផលិតកម្មបន្លែ ការចិញ្ចឹមសត្វ លទ្ធផលដែលបាន មកពីការប្រើប្រាស់បន្លែនៅក្នុងគ្រួសារ ការសន្សំសំចៃក្នុងគ្រួសារ និង ការកើនឡើងនូវប្រាក់ចំណូល ជាលទ្ធផលសម្រេចបាន ពីវគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និង ការផ្តល់ពូជ នៅក្នុងអនុកិច្ចសន្យា។ លើសពីនេះទៀតពយកគាត់បានបន្តសកម្មភាពទាំងនេះ ទោះបីជា គម្រោងបញ្ចប់ ទៅយូរទៅហើយក្តី។ ជាពិសេសទៀតនោះតំរូវការវគ្គបណ្តុះបណ្តាលស្រដៀងគ្នានេះ បានកើតឡើង បន្ទាប់ពីការអនុវត្ត សកម្មភាពគម្រោង។

២) គួរមានការបន្តការគាំទ្រគំរោងបែបនេះ ក៏ដូចជាការពង្រីកសកម្មភាពគំរោងបៀបនេះបន្តទៀត ទៅលើក្រុមគោលដៅ និង តំបន់គោលដៅដទៃទៀត ។

៣) ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីធ្វើអោយសម្រេចបាននូវអត្ថប្រយោជន៏ក្នុងកំរិតខ្ពស់ ភ្នាក់ងារអនុវត្តគម្រោង គួរមានការ ជ្រើសរើស អ្នកទទួលផលអោយបានសមស្រប (ត្រូវមានគោលការណ៏ និង លក្ខណៈវិនិច្ឆ័យច្បាស់លាស់)។

៤) ដើម្បីពង្រឹងនូវគុណភាព និងភាពទាក់ទងរបស់គម្រោង គយរមានការបរិយាយអោយបានច្បាស់លាស់នូវស្ថានភាពចុង បញ្ចប់នៃកិច្ចសន្យា និង គោលបំណងបន្ទាន់របស់គម្រោង ក៏ដូចជាពង្រឹងនូវទំនាក់ទំនងតក្កវាងធាតុខាងលើទៅនឹង លទ្ធផល។

៥) ផ្នែករដ្ឋបាល និង គ្រប់គ្រងអនុកិច្ចសន្យា គួរធ្វើការវាយតម្លៃគម្រោង ស្រដៀងគ្នានេះអោយបាន ១ ឬ២ អនុកិច្ចសន្យា ជាប្រចាំ។

# ១.  ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១ សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និង មន្ទីរវិស័យ

រៀងរាល់ឆ្នាំ **គ.ជ.អ.ប** ផ្តល់ថវិកាតាមរយៈគ.ប្រ នៃ **គ.អ.ជ.ខ** ទៅមន្ទីរវិស័យ ដើម្បីឲ្យអនុវត្តសកម្មភាព និង គម្រោង ដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈជាប្រព័ន្ធមិនបានអនុវត្តទេ កាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើន។ នៅក្នុងឆ្នាំ **២០១០** ជាមួយនឹងការគាំទ្រ ផ្នែកថវិកា និង បច្ចេកទេស ពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និង ផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន **គ.ជ.អ.ប** ។ ផ្នែករដ្ឋបាល និង គ្រប់គ្រងកិច្ចសន្យា គ.ប្រ នៃ **គ.អ.ជ.ខ** ខេត្តព្រះសីហនុ បានចុះអនុវត្ត ធ្វើការវាយតម្លៃអនុកិច្ចសន្យា ដែលបានរៀបចំរួមគ្នា ជាមួយភ្នាក់ងារអនុវត្តន៍ដែលមានលេខ : **18/AGR/0901-00(NRML)** ក្នុងការបង្កើតផលិតភាព និង ផលិតផលកសិកម្ម ។ ចំពោះដំណើរការ និង លទ្ធផល ដែលបានរកឃើញ និង ការសន្និដ្ឋាន នៃការវាយតម្លៃត្រូវបាន កត់ត្រា ហើយនឹងបង្ហាញ តាមរយៈរបាយការណ៍ស្តីពី ការវាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

ថ្វីត្បិតតែ នៅក្នុងកិច្ចសន្យា ពុំមានសរសេរគោលបំណងបន្ទាន់ក៏ដោយ ។ ប៉ុន្តែតាមរយៈ ការពិនិត្យ អនុកិច្ចសន្យា របាយការណ៍ និង តាមការចុះពិនិត្យជាក់ស្តែងនៅតំបន់អនុវត្តគំរោង បានរំលេចចេញ និង សំដែងអោយឃើញនូវ គោលបំណងបន្ទាន់ នៃអនុកិច្ចសន្យាគឺ នៅចុងឆ្នាំ ២០០៩ កសិករដែលជាក្រុមគោលដៅរបស់គំរោង បានផ្លាស់ប្តូរឥរិយាបថ ដោយយកចំណេះ ដឹងស្តីពីបច្ចេកទេសកសិកម្ម គួបផ្សំទៅនឹងពូជដែលពួកគេទទួលបាននោះ យកទៅអនុវត្តនៅក្នុងអាជីព ជាប្រចាំរបស់ពួកគេ ជាហេតុធ្វើអោយ ទិន្នផលស្រូវ ដំណាំរួមផ្សំ និង ផលិតផលសត្វ ក្នុងគ្រួសារ និង សហគមន៍ ត្រូវបានកើនឡើង តាមរយៈការបណ្តុះបណ្តាល ការបំពាក់បំប៉ន និង ការធ្វើបង្ហាញ នូវបច្ចេកទេសកសិកម្មសមស្រប ។

## ១.៣. គោលបំណង និង ទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូល ដោយផ្នែករដ្ឋបាល និង គ្រប់គ្រងកិច្ចសន្យារបស់ **គ.ប្រ** នៃ **គ.អ.ជ.ខ** នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និង តម្លាភាព ។ ដូច្នេះទំហំនៃការវាយតម្លៃ មានដែន កំណត់តាម ទំហំនៃអនុកិច្ចសន្យា និង រាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែង ក្នុងក្របខណ្ឌការងារនៃការវាយតម្លៃ ។ គោលបំណងនៃ ការវាយតម្លៃគឺៈ **ក)** ទាញយក កត់ត្រា និង វិភាគជាប្រព័ន្ធ ទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និង ចំនុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និង ស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំងកត់ត្រា នូវចំណុច

រៀនសូត្រ និង ផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើង នៅពេលអនាគត និង **ខ)** ដើម្បីពង្រឹងរបៀបធ្វើការវាយតម្លៃ គម្រោងរបស់ **គ.ប្រ** នៃ **គ.អ.ជ.ខ** នៅក្នុងដំណើរការនៃការអនុវត្តន៍ការងារ ។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និង ប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និង ការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និង ចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និង ដំណើរការវាយតម្លៃ

**វិធីសាស្ត្រ និង ឧបករណ៍ដែលត្រូវប្រើ :**

១) ការពិនិត្យឯកសារ អនុកិច្ចសន្យា របាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆ្នាំ កំនត់ហេតុប្រជុំ និង របាយការណ៍បញ្ចប់អនុកិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍វគ្គបណ្តុះបណ្តាល និង រាល់ឯកសារដែលពាក់ព័ន្ធដែលមាននៅក្នុងផ្នែករដ្ឋបាល និង គ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និង ភ្នាក់ងារអនុវត្តន៍ (ឯកសាររបស់មន្ទីរ ) ។

២) ពិគ្រោះ (សំភាសន៍)ជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗ រួមមាន : ក្រុមការងារមន្ទីរ (មន្ត្រីអនុម័ត មន្ត្រីអនុវត្តគំរោង មន្ត្រីត្រួតពិនិត្យនិងវាយតម្លៃ ) អ្នកទទួលផលផ្ទាល់ អ្នកមិនទទួលផលផ្ទាល់ (ចំនួន២ឬ៣នាក់) និង អ្នកពាក់ព័ន្ធ ( PMESA SPPA PM មេភូមិ មេឃុំ ក្រុមប្រឹក្សា និង ស្មៀន ) ។

៣) ប្រើប្រាស់វិធីសាស្ត្រចុះពិនិត្យតំបន់អនុវត្តន៍គម្រោង និង សង្កេតមើលសកម្មភាព ពិភាក្សាក្រុម និង ករណីសិក្សា

៤)ចុះពិនិត្យតំបន់អនុវត្តន៍គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និង ភស្តុតាងគម្រោងដោយផ្ទាល់ ។

៥) វិភាគទិន្នន័យ និង បកស្រាយ : ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងត្រូវធ្វើការវិភាគ និង ផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់ ។

៦) ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និង អនុសាសន៍ដោយភ្នាក់ងារអនុវត្តន៍ និង អ្នកពាក់ព័ន្ធតាមរយៈ ព័ត៌មានត្រឡប់ដែលទទួលបាន ពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើង (កាលពីថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១០ ) ។

ការវាយតម្លៃត្រូវធ្វើតាម "គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា" និង វិធីសាស្ត្រដែលបានណែនាំ ។ ដូច្នេះ

ដំណើរការត្រូវបានធ្វើឡើង ដោយមានទម្រង់ការណែនាំ និង តម្លាភាព រួមទាំងការចូលរួមពីអ្នកពាក់ព័ន្ធ។

## ១.៦. ដែនកំណត់ និង បញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើង ដោយ គ.ប្រ និង អ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និង មិនផ្ទាល់ក្នុងអនុកិច្ចសន្យា ។ ទោះជាយ៉ាងណាក៏ដោយ ការប្រឹងប្រែង ត្រូវធ្វើឡើងដើម្បីធានា ឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត។

២)ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត : វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោង នៅពេល ដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និង បទពិសោធន៍ពីមុនមក ។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណងសំខាន់ គឺដើម្បី "រៀនធ្វើដោយការអនុវត្តផ្ទាល់"។ អ្នកវាយតម្លៃ បានទទួលការគាំទ្រដោយមានគោលការណ៍ការ ណែនាំឧបករណ៍ និង វគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។

៣) បញ្ហាប្រឈមក្នុងផ្នែកទី៣នៃអនុកិច្ចសន្យា : ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និង សកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និង ជោគជ័យទេ ។ មួយទៀត ទំនាក់ទំនង សង្ខេបតាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និង លទ្ធផល និង រវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់ មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់នៅឡើយ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ។

៤) ដោយយើងមិនមានសូចនាករបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៏" ដែលជាកម្រិត អត្ថប្រយោជន៍ទៅលើគោលនយោបាយវិម្បការ និង វិសហមជ្ឈការ និង ការកាត់បន្ថយភាពក្រីក្រ និង កម្រិត "គោល បំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និង រចនាសម្ព័ន្ធនោះទេ។

៥)ដោយយើងមានពេលវេលា ធនធាន និង ថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិតទៅលើលទ្ធផល និង សកម្មភាពទាំងអស់បានទេ។ យើងអាចវាយតម្លៃលម្អិត តែទៅលើការគាំទ្រប្រពន្ធ័កសិកម្មចំរុះ ដែលជា *លទ្ធផលទី១* និង ការបណ្តុះបណ្តាលដល់កសិករ ស្តីពីបច្ចេកទេសកសិកម្ម ដែលជា *លទ្ធផលទី២* នៃអនុកិច្ចសន្យា ។ យើងអាចវាយតម្លៃ លំអិតនេះបាន ធ្វើឡើងតាមរយៈការសម្ភាសន៍ស៊ីជម្រៅ ក្រុមពិភាក្សា និង ការចុះពិនិត្យតំបន់អនុវត្តគម្រោង ។

៦)ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា មិនអាចធ្វើទៅបានទេ ព្រោះ ចំណុច *៣* នៃផ្នែកទី៣ក្នុង ឯកសារអនុកិច្ចសន្យាមិនមានលក្ខណៈច្បាស់លាស់ ឬមិនពេញលេញ។

ការងារនេះ នឹងកាន់តែមានសុពលភាព និង ពោរពេញទៅដោយព័ត៌មាន បើសិនជាចំនុចដែលបានរៀបរាប់ខាងលើនេះ ត្រូវបានដោះស្រាយ។

☞ **ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធន៍ :**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ 18/AGR/0901-00(NRML) ការបង្កើនផលិតភាព និង ផលិតផលកសិកម្ម និង ដែនកំណត់ ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ។
២) ការវាយតម្លៃនេះលម្អិតតែទៅលើ **ការគាំទ្រប្រពន្ធ័កសិកម្មចំរុះ** តាមរយៈនៃការផ្តល់ពូជ ការបង្ហាញ និង **ការបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្ម** ដែលជាសកម្មភាព នៃអនុកិច្ចសន្យា ។
៣) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃទៅលើ ភ្នាក់ងារអនុវត្តន៏ ភ្នាក់ងារដែលពាក់ព័ន្ធគម្រោង និង ការវាយតម្លៃទៅលើ គ.ប្រ នៃ គ.អ.ជ.ខ និង គ.ជ.អ.ប ទេ ។
ហេតុដូច្នេះ របាយការណ៍នៃការវាយតម្លៃ លទ្ធផលដែលបានរកឃើញ និង អនុសាសន៏ដែលបានលើកឡើង ត្រូវពិនិត្យដោយយោលទៅលើបរិបទខាងលើ និង អនុវត្តតាមលំដាប់លំដោយ។

# ២.   លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល

### លទ្ធផលទី១ : ការគាំទ្រប្រពន្ធ័កសិកម្មចំរុះ

### ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | ▪ ផ្តល់ពូជបន្លែចំនួន ២៥ គីឡូក្រាម<br>▪ គ្រោងផ្តល់ជូនប្រជាកសិករចាប់ពីខែ ឧសភា ដល់ ខែ កញ្ញា ឆ្នាំ ២០០៩ | ▪ បានផ្តល់ពូជបន្លែចំនួន ៤០ គីឡូក្រាម ( ត្រកួន៧ គ.ក .សណ្តែកកួរ ៥គ.ក និង ពោត ២៨ គ.ក ) និង ៥៣ កំប៉ុង ( ស្ពៃខៀវ ១៨កំប៉ុង និង ត្រសក់ចំណារ ៣៥ កំប៉ុង ) ។<br>▪ ចែកជូនដល់ឃុំចំនួន ៧ ក្នុងស្រុកព្រៃនប់គឺ ជើងគោ.បិតត្រាំង.រាម.បឹងតាព្រហ្ម.វាលរេញ .ទឹកថ្លា និង ទឹកល្អក់ ។<br>▪ អ្នកទទួលពូជបន្លែមានចំនួន ៧ នាក់ ក្នុងនោះ សុទ្ធតែមេឃុំ ជំទប់ និង ស្មៀន<br>▪ ពូជបន្លែត្រូវបានប្រគល់ទទួលនៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ |
| ១.២ | ▪ ផ្តល់ពូជស្រូវទិន្នផលខ្ពស់ ចំនួន ១៥០០ គីឡូក្រាម<br>▪ គ្រោងផ្តល់ជូនប្រជាកសិករចាប់ពីខែ ឧសភា ដល់ ខែ កញ្ញា ឆ្នាំ ២០០៩ | ▪ បានផ្តល់ពូជស្រូវចំនួន ១២០០ គីឡូក្រាម ( ពូជផ្ការំដួល ៨០០ គ.ក និង សែនពិដោរ ៤០០ គ.ក ) ។<br>▪ ចែកជូនដល់ឃុំទាំង ១៤ ក្នុងស្រុកព្រៃនប់ |

| | | |
|---|---|---|
| | | ▪ អ្នកទទួលពូជស្រូវមានចំនួន ៤០នាក់ (ដោយក្នុង ១នាក់ៗ ទទួលបានទម្ងន់ពី ២០.៣០ .៥០.១០០ ដល់ ១៤០ គ.ក) ។<br>▪ ពូជបន្លែត្រូវបានប្រគល់ទទួលនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩ |
| ១.៣ | ▪ ផ្តល់កូនឈើហូបផ្លែ ចំនួន ១៥០០ ដើម<br>▪ គ្រោងផ្តល់ជូនប្រជាកសិករចាប់ពីខែ ឧសភា ដល់ ខែ កញ្ញា ឆ្នាំ ២០០៩ | ▪ បានផ្តល់កូនឈើហូបផ្លែ ចំនួន ៨៦០ ដើម (ដូង ១៥០ដ.កំពីងរាជ ២០០ដ.ស្វាយកែវចិន១០០ដ .ខ្នុរ ២០០ដ និង ស្វាយកែវរមៀត ២១០ ដ ) ។<br>▪ កូនឈើហូបផ្លែនីមួយៗមានកំពស់ចាប់ពី ០,៤ ម៉ែត្រឡើងទៅ<br>▪ ចែកជូនដល់ឃុំចំនួន៧ ក្នុងស្រុកព្រៃនប់គឺ សាមគ្គី បិតត្រាំង រាម បឹងតាព្រហ្ម ព្រៃនប់ សំរុង និង ទឹកល្អក់ ។<br>▪ អ្នកទទួលកូនឈើមានចំនួន ៧ នាក់ ក្នុងនោះ សុទ្ធតែមេឃុំ ជំទប់ និង ក្រុមប្រឹក្សាឃុំ<br>▪ ពូជកូនឈើហូបផ្លែត្រូវបានប្រគល់ទទួលនៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ |
| ១.៤ | ▪ ផ្តល់ពូជមេផ្សិតអំបោះចំនួន ១៨០០ កញ្ចប់<br>▪ គ្រោងផ្តល់ជូនប្រជាកសិករចាប់ពីខែ ឧសភា ដល់ ខែ កញ្ញា ឆ្នាំ ២០០៩ | ▪ បានផ្តល់ពូជមេផ្សិតអំបោះចំនួន ១៨០០ កញ្ចប់<br>▪ កញ្ចប់ផ្សិតមានទំងន់ពី ១,៣ ទៅ ១,៥ គីឡូក្រាម ផលិតពីអាចម៍រណារ<br>▪ ចែកជូនដល់ឃុំចំនួន១១ក្នុងស្រុកព្រៃនប់គឺ បិតត្រាំង.រាម.បឹងតាព្រហ្ម អូរជ្រៅ . អូរឧកញ៉ាហេង ព្រៃនប់ អណ្តូងថ្ម វាលរេញ ជើងគោ ទឹកថ្លា និង ទឹកល្អក់ ។<br>▪ អ្នកទទួលពូជមេផ្សិតមានចំនួន ១៦ នាក់ ក្នុងនោះ ភាគច្រើន មេភូមិ .មេឃុំ ជំទប់ និង ក្រុមប្រឹក្សាឃុំ ។ |

| | | |
|---|---|---|
| | | ▪ ពូជមេផ្សិតអំបោះត្រូវបានប្រគល់ទទួលនៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ |
| ១.៥ | ▪ ការរៀបចំប្រពន្ធ័កសិកម្មលើស្រែកសិករមានចំនួន ៥ កន្លែង<br>▪ គ្រោងរៀបចំចាប់ពីខែ ឧសភា ដល់ ខែ កញ្ញា ឆ្នាំ ២០០៩ | ▪ បានរៀបចំប្រពន្ធ័កសិកម្មលើស្រែកសិករមានចំនួន ៤ កន្លែង<br>▪ បានរៀបចំនៅក្នុងឃុំចំនួន ៤ គឺ រាម . ព្រៃនប់ . អណ្តូងថ្ម និង សំរុង |

## ផ្នែក-ខ : ការវិភាគ និង វាយតម្លៃជារួមអំពីលទ្ធផល

ឆ្លងតាមតាមរយៈនៃការត្រួតពិនិត្យទៅលើឯកសារ របាយការណ៍ ការសំភាសន៍ស៊ីជម្រៅ ការពិភាក្សាក្រុម និង ការចុះត្រួតពិនិត្យដល់ទីតាំងអនុវត្តគម្រោង យើងសង្កេតឃើញថា អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និង សកម្មភាពនានារបស់អនុកិច្ចសន្យាដែលបានគ្រោងទុក។ ចំពោះដំណើរការនៃការអនុវត្តន៍គម្រោង ក៏នៅមានភាពខ្វះខាតមួយចំនួនតូចផងដែរ ពីព្រោះថា អនុកិច្ចសន្យាពុំទាន់ បានអនុវត្ត ឬសម្រេចបាន អោយបានគ្រប់ចំនួននៃលទ្ធផល និង សកម្មភាពដែលបានគ្រោងទុក ( ការផ្តល់ពូជស្រូវ .ការពូជកូនឈើហូបផ្លែ និង ការរៀបចំប្រពន្ធ័កសិកម្មចំរុះលើស្រែកសិករ ) ។ ទន្ទឹមនឹងនេះ ក៏មានលទ្ធផល និង សកម្មភាពខ្លះ សម្រេចបានលើសចំនួននៃការការគ្រោងទុក ផងដែរ ( ការផ្តល់ពូជបន្លែ ) ។

អ្នកទទួលផលទាំងអស់នៅក្នុងក្រុមពិភាក្សាដែលបានអញ្ជើញមក សុទ្ធតែជាកសិករគំរូ នៅក្នុងសហគមន៏ ឬប្រចាំឃុំនីមួយ១។ អ្វីដែលគួរអោយចាប់អារម្មណ៏នោះគឺថា ពួកគាត់សុទ្ធតែបានទទួលបាន នូវពូជ ពីគម្រោងកសិកម្ម ស្ទើរគ្រប់វគ្គ និង គ្រប់ឆ្នាំទាំងអស់ ( រៀងរាល់ឆ្នាំ ) ហើយ ចំណូលពីអាជីពប្រចាំថ្ងៃ គឺ ពឹងផ្អែកទៅលើវិស័យកសិកម្មតែម្តង ។

អ្នកទទួលផលភាគច្រើនចូលចិត្ត និង ពេញចិត្ត ទៅនឹងគម្រោង ដែលបានផ្តល់ជាពូជ ដល់ពួកគាត់ ពីព្រោះ ពួកគាត់យល់ឃើញថា ជីវភាពរបស់ពួកគាត់ មានភាពធូរធារមកទល់សព្វថ្ងៃនេះ ដោយសារតែគម្រោងកម្មវិធីរបស់មន្ទីរកសិកម្ម ដែលបានជួយជ្រោមជ្រែង និង គាំទ្រដល់ពួកគាត់ ។

ទោះជាយ៉ាងណាក៏ដោយ ក៏មានអ្នកទទួលផលខ្លះ បានគូសបញ្ជាក់ថា ធាតុពិត ពួកគាត់បានរៀន បានចេះ មានចំណេះដឹងទាំងនេះរួចមកហើយ ថែមទាំងបានប្រកបមុខរបរនេះ ជាយូរមកហើយផងដែរ លុះដល់ពេលក្រោយ ទើបគម្រោងរបស់មន្ទីរកសិកម្មខេត្ត បានជ្រើសរើសពួកគាត់ ធ្វើជាកសិករគំរូប្រចាំសហគមន៏/ឃុំរបស់ពួកគាត់ ដោយបញ្ជូនពួក

គាត់អោយទៅរៀនពីបច្ចេកទេសទាំងនេះឡើងវិញ ។ អ្នកទទួលផលខ្លះ បានត្អូញត្អែរថា ការផ្តល់ពូជរបស់គម្រោងមានលក្ខណៈតិចតួច និង ស្តួចស្តើងពេក ដែលមិនអាចយកមកធ្វើអ្វីកើត និង មិនអាចប្រកបធ្វើជាមុខរបរ មានលក្ខណៈអាជីពបានឡើយ គឺពួកគេទាមទារធនធានថវិកា ឬ ប្រភពដើមទុន អោយមានលក្ខណៈសមស្រប /សមរម្យ ទើបអាចប្រកបជាមុខរបរ ឬ អាជីពបែបនេះបាន ។ អ្នកទទួលផលខ្លះ បានបញ្ចេញទស្សនះថា ការផ្តល់ពូជរបស់គម្រោង មានលក្ខណៈយឺតយ៉ាវ ចង់ហួសរដូវកាលនៃការដាំដុះ ជាហេតុធ្វើអោយការដាំដុះ មិនទទួលបាននូវទិន្នផលខ្ពស់ និង សមស្របទៅតាមលក្ខណៈបច្ចេកទេស ដែលបានបណ្តុះបណ្តាល ។

សរុបសេចក្តីមក ទោះបីជាអ្នកទទួលផល បានបញ្ចេញ ឬបង្ហាញនូវទស្សនះផ្សេងៗគ្នាយ៉ាងណាក្តី តែការផ្តល់ពូជទាំងនេះ គឺពិតជាបានឆ្លើយតបទៅនឹង តំរូវការជាក់ស្តែងរបស់ប្រជាកសិករ នៅក្នុងសហគមន៍របស់ពួកគេ ។ អ្វីដែលសំខាន់ទៀតនោះ អ្នកចូលរួម (អ្នកទទួលផល) នៅក្នុងការពិភាក្សាក្រុម បានគូសបញ្ជាក់ថា ពួកគាត់មាន ភាពរីករាយយ៉ាងក្រៃលែង ដោយពួកគាត់ទទួលបានទាំងចំនេះដឹង ជំនាញ និង ពូជថែមទៀត ។ សកម្មភាពនៃគម្រោងនេះ ពិតជាបានរួមចំណែកធ្វើអោយជីវភាពរបស់ពួកគាត់កាន់តែមានភាពប្រសើរឡើងជាលំដាប់ ។ យើងបានសង្កេតឃើញថា ប្រជាកសិករ ដែលមានស្ថិតនៅក្បែរលំនៅដ្ឋាន កសិករគំរូ/អ្នកទទួលផល ខ្លះបានចាប់ផ្តើមដាំបន្លែនៅក្នុងសួនបន្លែ និង ចិញ្ចឹមសត្វនៅតាម គេហដ្ឋានរបស់ពួកគាត់ យ៉ាងសស្រាក់សស្រាំ ធ្វើអោយចំណូលគ្រួសាររបស់ពួកគាត់កើនឡើង ហើយកាត់បន្ថយការចំណាយនៅក្នុងគ្រួសារក៏ដូចជាធ្វើអោយសុខភាពគ្រួសារពួក គាត់មានភាពកាន់តែប្រសើរឡើង។

## លទ្ធផលទី២ : ការចាក់ថ្នាំបង្ការសត្វ និង កម្មវិធីការពារប៉ារ៉ាស៊ីត

### ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ២.១ | ▪ការចាក់ថ្នាំបង្ការ និង ព្យាបាលជម្ងឺគោក្របី ចំនួន ២២០០ ក្បាល<br>▪ការចាក់ថ្នាំបង្ការ និង ព្យាបាលជម្ងឺគោក្របី ចំនួន ២២ ឃុំ/សង្កាត់<br>▪គ្រោងអនុវត្តនៅក្នុងខែ មេសា និង ខែ សីហា ឆ្នាំ ២០០៩ | ▪ការចាក់ថ្នាំបង្ការ និង ព្យាបាលជម្ងឺគោក្របី ចំនួន ៥២៣០ ក្បាល ( គោចំនួន ២៧៥២ ក្បាល និង ក្របីចំនួន ២៤៨០ ក្បាល ) ។<br>▪ការចាក់ថ្នាំបង្ការ និង ព្យាបាលជម្ងឺគោក្របី ចំនួន ២២ ឃុំ/សង្កាត់<br>▪ ចាប់អនុវត្តនៅក្នុងខែ មេសា និង ខែ សីហា ឆ្នាំ ២០០៩ |

### ផ្នែក-ខ : ការវិភាគ និង វាយតម្លៃជារួមអំពីលទ្ធផល

ឆ្លងតាមតាមរយៈនៃការត្រួតពិនិត្យទៅលើឯកសារ អនុកិច្ចសន្យា និង របាយការណ៍ យើងសង្កេតឃើញថា អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និង សកម្មភាពនានារបស់អនុកិច្ច សន្យាដូចដែលបានគ្រោងទុក។ ចំពោះដំណើរការនៃការអនុវត្តន៍គម្រោង បានសម្រេចលទ្ធផលលើសចំនួននៃលទ្ធផល និង សកម្មភាពដែលបានគ្រោងទុក (ការចាក់ថ្នាំង្ការ និង ព្យាបាលគោក្របី )។ លទ្ធផលដែលទទួលបានលើសពីគ្រោងបែបនេះ ដោយសារតែក្រុមការងារចុះអនុវត្តគំរោង បានខិតខំពន្យល់ដល់កសិករ អំពីផលលំបាក និង ការខាតបង់ទ្រព្យ សម្បត្តិ ដែលកើតមានឡើងដល់ពួកគាត់ តាមរយៈនៃការមិនយកគោក្របី ទៅចាក់ថ្នាំបង្ការជាមុន ។ ជាក់ស្តែងពីមួយរដូវទៅមួយរដូវ ពីមួយឆ្នាំទៅមួយឆ្នាំ ការនាំយកគោក្របី របស់ប្រជាកសិករ មានការផុលផុស និង ចូលរួមយ៉ាងសស្រាក់សស្រាំ នៅក្នុងយុទ្ធនាការចាក់ថ្នាំការពារជម្ងឺគោក្របី ។
សរុបសេចក្តីមក សម្មភាពនៃគម្រោងនេះ ពិតជាបានរួមចំណែកធ្វើអោយ និង លើកស្ទួយជីវភាពរបស់ពួកគាត់ កាន់តែមានភាពប្រសើរឡើង ពីព្រោះថា កាលណាគោក្របីរបស់ពួកគាត់មិនមានជម្ងឺនោះ ពួកគាត់ក៏គ្មានខាតបង់ថវិកា ដែលត្រូវចំណាយបញ្ហានេះដែរ ។

## លទ្ធផលទី៣ : វគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម  :

### ផ្នែក-ក : ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ៣.១ | ▪ វគ្គបណ្តុះបណ្តាលស្តីពីការចញ្ចឹមមាន់ជាលក្ខណ:គ្រួសារ ១ វគ្គ<br>▪ វគ្គនីមួយៗមានចំនួន២ថ្ងៃ<br>▪ អ្នកចូលរួមចំនួន១៥នាក់ (សិក្ខាកាម ១៥នាក់ )<br>▪ វគ្គបណ្តុះបណ្តាលចាប់ដំណើរការពីខែ មិនា ដល់ ខែ តុលា ឆ្នាំ ២០០៩ | ▪ វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹម ១ វគ្គ<br>▪ វគ្គនីមួយៗមានចំនួន២ថ្ងៃ<br>▪ អ្នកចូលរួម ១៨នាក់ (សិក្ខាកាម ១៥នាក់/ស=0ន និង អ្នកសំរបសំរួល៣នាក់ )<br>▪ សិក្ខាកាមមកពីឃុំចំនួន ៧ ក្នុងស្រុកព្រៃនប់ គឺ បឹងតាព្រហ្ម អូរជ្រៅ អណ្តូងថ្ម ទួលទទឹង ព្រៃនប់ សំរុង និង អូរឧកញ៉ាហេង ។<br>▪ វគ្គបណ្តុះបណ្តាលចាប់ដំណើរការពីថ្ងៃទី ២៣-២៤ ខែ មិនា ឆ្នាំ ២០០៩ |
| ៣.២ | ▪ វគ្គបណ្តុះបណ្តាលស្តីពីវិធានការកំចាត់សត្វល្អិត ១ វគ្គ<br>▪ វគ្គនីមួយៗមានចំនួន២ថ្ងៃ<br>▪ អ្នកចូលរួមចំនួន១៨នាក់ (សិក្ខាកាម ១៥នាក់ )<br>▪ វគ្គបណ្តុះបណ្តាលចាប់ដំណើរការពីខែ មិនា ដល់ ខែ តុលា ឆ្នាំ ២០០៩ | ▪ វគ្គបណ្តុះបណ្តាលស្តីពីវិធានការកំចាត់សត្វល្អិត ១ វគ្គ<br>▪ វគ្គនីមួយៗមានចំនួន២ថ្ងៃ<br>▪ អ្នកចូលរួមចំនួន១៨នាក់ (សិក្ខាកាម១៥នាក់ /ស=0ននិង អ្នកសំរបសំរួល៣នាក់ )<br>▪ សិក្ខាកាមមកពីឃុំចំនួន១០ ក្នុងស្រុកព្រៃនប់ គឺ បឹងតាព្រហ្ម អណ្តូងថ្ម ព្រៃនប់. សំរុង .រាម.សាមគ្គី ជើងគោ បិតត្រាំង វាលរេញ និង អូរឧកញ៉ាហេង ។<br>▪ វគ្គបណ្តុះបណ្តាលចាប់ដំណើរការពីថ្ងៃទី ៣-៤ ខែ កញ្ញា ឆ្នាំ ២០០៩ |

| | | |
|---|---|---|
| ៣.៣ | ▪ វគ្គបណ្តុះបណ្តាលស្តីពីវដ្តនៃដំណាំស្រូវ ១ វគ្គ<br>▪ វគ្គនីមួយៗមានចំនួន២ថ្ងៃ<br>▪ អ្នកចូលរួមចំនួន១៥នាក់ (សិក្ខាកាម ១៥នាក់ )<br>▪ វគ្គបណ្តុះបណ្តាលចាប់ដំណើរការពីខែ មិនា ដល់ ខែ តុលា ឆ្នាំ ២០០៩ | ▪ វគ្គបណ្តុះបណ្តាលស្តីពីវដ្តនៃដំណាំស្រូវ ១ វគ្គ<br>▪ វគ្គនីមួយៗមានចំនួន២ថ្ងៃ<br>▪ អ្នកចូលរួម ១៨នាក់ ( សិក្ខាកាម ១៥នាក់/ស=០ន និង អ្នកសំរបសំរួល៣នាក់ )<br>▪ សិក្ខាកាមមកពីឃុំចំនួន ១១ ក្នុងស្រុកព្រៃនប់គឺ ទឹកល្អក. សាមគ្គី រាម. បឹងតាព្រហ្ម អូរជ្រៅ អណ្តូងថ្ម ទួលទទឹង ជើងគោ វាលរេញ ទឹកថ្លា និង អូរឧកញ៉ាហេង ។<br>▪ វគ្គបណ្តុះបណ្តាលចាប់ដំណើរការពីថ្ងៃទី ២៩-៣០ ខែ មេសា ឆ្នាំ ២០០៩ |
| ៣.៤ | ▪ វគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ជី ១ វគ្គ<br>▪ វគ្គនីមួយៗមានចំនួន២ថ្ងៃ<br>▪ អ្នកចូលរួមចំនួន១៥នាក់ (សិក្ខាកាម ១៥នាក់ )<br>▪ វគ្គបណ្តុះបណ្តាលចាប់ដំណើរការពីខែ មិនា ដល់ ខែ តុលា ឆ្នាំ ២០០៩ | ▪ វគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ជី ១ វគ្គ<br>▪ វគ្គនីមួយៗមានចំនួន២ថ្ងៃ<br>▪ អ្នកចូលរួម ១៨នាក់ ( សិក្ខាកាម ១៥នាក់/ស=០ន និង អ្នកសំរបសំរួល៣នាក់ )<br>▪ សិក្ខាកាមមកពីឃុំចំនួន ១០ ក្នុងស្រុកព្រៃនប់គឺ រាម បឹងតាព្រហ្ម វាលរេញ . អូរជ្រៅ ទួលទទឹង ព្រៃនប់ ទឹកល្អក់ ទឹកថ្លា សំរុង និង អូរឧកញ៉ាហេង ។<br>▪ វគ្គបណ្តុះបណ្តាលចាប់ដំណើរការពីថ្ងៃទី ២៨-២៩ ខែ ឧសភា ឆ្នាំ ២០០៩ |
| ៣.៥ | ▪ វគ្គបណ្តុះបណ្តាលស្តីពីប្រពន្ធ័កសិកម្មចំរុះ ១ វគ្គ<br>▪ វគ្គនីមួយៗមានចំនួន២ថ្ងៃ<br>▪ អ្នកចូលរួមចំនួន១៥នាក់ (សិក្ខាកាម ១៥នាក់ )<br>▪ វគ្គបណ្តុះបណ្តាលចាប់ដំណើរការពីខែ មិនា ដល់ ខែ តុលា ឆ្នាំ ២០០៩ | ▪ វគ្គបណ្តុះបណ្តាលស្តីពីប្រពន្ធ័កសិកម្មចំរុះ ១ វគ្គ<br>▪ វគ្គនីមួយៗមានចំនួន២ថ្ងៃ<br>▪ អ្នកចូលរួម ១៨នាក់ ( សិក្ខាកាម ១៥នាក់/ស=០ន និង អ្នកសំរបសំរួល៣នាក់ )<br>▪ សិក្ខាកាមមកពីឃុំចំនួន ៩ ក្នុងស្រុកព្រៃនប់គឺ ជើងគោ ទួលទទឹង សាមគ្គី . |

| | | |
|---|---|---|
| | | បឹងតាព្រហ្ម អូរជ្រៅ អណ្តូងថ្ម ព្រៃនប់ សំរុង និង អូរឧកញ៉ាហេង ។<br>▪ វគ្គបណ្តុះបណ្តាលចាប់ដំណើរការពីថ្ងៃទី ២-៣ ខែ កក្កដា ឆ្នាំ ២០០៩ |
| ៣.៦ | ▪ វគ្គបណ្តុះបណ្តាលស្តីពីការកែច្នៃផលិតផលកសិកម្ម ១ វគ្គ<br>▪ វគ្គនីមួយៗមានចំនួន២ថ្ងៃ<br>▪ អ្នកចូលរួមចំនួន១៥នាក់ (សិក្ខាកាម ១៥នាក់ )<br>▪ វគ្គបណ្តុះបណ្តាលចាប់ដំណើរការពីខែ មិនា ដល់ ខែ តុលា ឆ្នាំ ២០០៩ | ▪ វគ្គបណ្តុះបណ្តាលស្តីពីការកែច្នៃផលិតផលកសិកម្ម ១ វគ្គ<br>▪ វគ្គនីមួយៗមានចំនួន២ថ្ងៃ<br>▪ អ្នកចូលរួម ១៨នាក់ (សិក្ខាកាម ១៥នាក់/ស=២៨ និង អ្នកសំរបសំរួល៣នាក់ )<br>▪ សិក្ខាកាមមកពីឃុំចំនួន៨ ក្នុងស្រុកព្រៃនប់ គឺ បិតត្រាំង រាម វាលរេញ អណ្តូងថ្ម ទួលទទឹង ព្រៃនប់ ទឹកល្អក់ និង អូរឧកញ៉ាហេង ។<br>▪ វគ្គបណ្តុះបណ្តាលចាប់ដំណើរការពីថ្ងៃទី ២៣-២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៩ |

## ផ្នែក-ខ : ការវិភាគ និង វាយតម្លៃជារួមអំពីលទ្ធផល

| |
|---|
| សិក្ខាកាមទាំងអស់នៅក្នុងក្រុមពិភាក្សាដែលបានអញ្ជើញមក សុទ្ធតែជាកសិករគំរូ នៅក្នុងសហគមន៍ ឬប្រចាំឃុំនីមួយៗ។ អ្វីដែលគួរអោយចាប់អារម្មណ៍នោះគឺថា ពួកគាត់សុទ្ធតែបានទទួលវគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ស្ទើរគ្រប់វគ្គ និង គ្រប់ឆ្នាំ ទាំងអស់ (រៀងរាល់ឆ្នាំ ) ហើយ អាជីពប្រចាំថ្ងៃ គឺពឹងផ្អែកទៅលើវិស័យកសិកម្មតែម្តង ។<br>សិក្ខាកាមភាគច្រើនចូលចិត្ត និង ពេញចិត្ត ទៅនឹងគម្រោង ដែលបានផ្តល់វគ្គបណ្តុះបណ្តាល ដល់ពួកគាត់ ពីព្រោះ ពួកគាត់យល់ឃើញថា ជីវភាពរបស់ពួកគាត់ មានភាពធូរធារមកទល់សព្វថ្ងៃនេះ ដោយសារតែគម្រោងកម្មវិធីរបស់មន្ទីរកសិកម្ម ដែលបានជួយជ្រោមជ្រែង និង គាំទ្រដល់ពួកគាត់ ។ ម៉្យាងទៀតពួកគាត់ចូលចិត្តនឹងទេពកោសល្យ វិធីសាស្ត្របណ្តុះបណ្តាល (ការបំផុសគំនិត រូបភាព ក្រុមពិភាក្សា ឧទាហរណ៍ជាក់ស្តែង...។ល។ ) និង អាកប្បកិរិយារបស់អ្នកបណ្តុះបណ្តាល /គ្រូឧទ្ទេសន៍ ( អាចបន្សាំខ្លួនទៅនឹងបរិបទនៅសហគមន៍បានល្អ ដើម្បីអោយមានការចូលរួមកាន់តែច្រើនពីសិក្ខាកាម) ។<br>ទោះជាយ៉ាងណាក៏ដោយ ក៏មានសិក្ខាកាមខ្លះ បានគូសបញ្ជាក់ថា ធាតុពិត ពួកគាត់បានរៀន បានចេះ មានចំណេះដឹងទាំងនេះរួចស្រេចមកហើយ ថែមទាំងបានប្រកបមុខរបរនេះ |

ជាយូរមកហើយដែរ  តែក្រោយមកទើបគម្រោងរបស់មន្ទីរកសិកម្មខេត្ត បានជ្រើសរើសពួកគាត់ ធ្វើជាកសិករគំរូប្រចាំសហគមន៍/ឃុំ របស់ពួកគាត់ ដោយបញ្ជូនពួកគាត់អោយទៅបច្ចេកទេសទាំងនេះឡើងវិញ ។ សិក្ខាកាមខ្លះ បានត្អូញត្អែរថា ការបណ្តុះបណ្តាលរបស់គម្រោងនេះ ហាក់បីដូចជាមានលក្ខណៈដដែល១ (ខ្លឹមសារប្រធានបទ)  ពុំសូវមានអ្វីប្លែកសោះ ពី១ឆ្នាំ ទៅ ១ឆ្នាំ ។ សិក្ខាកាមខ្លះ បានបញ្ចេញទស្សនៈថា ការអនុវត្តន៍ជាក់ស្តែង វាមិនបានទិន្នផល ដូចទៅនឹងទ្រឹស្តី នៃខ្លឹមសារមេរៀនទាល់តែសោះ ។

សរុបសេចក្តីមក ការផ្តល់វគ្គបណ្តុះបណ្តាលនេះ ពិតជាបានឆ្លើយតបទៅនឹង តំរូវការជាក់ស្តែងរបស់ប្រជាកសិករ នៅក្នុងសហគមន៍របស់ពួកគេ ។
ឆ្លងតាមតាមរយៈ នៃការត្រួតពិនិត្យទៅលើឯកសារ អនុកិច្ចសន្យា  របាយការណ៍ ការសំភាសន៍ស៊ីជម្រៅ ការពិភាក្សាក្រុម និង ការចុះត្រួតពិនិត្យដល់ទីតាំងអនុវត្តគំម្រោង យើងសង្កេតឃើញថា អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និង សកម្មភាពនានារបស់អនុកិច្ចសន្យាដែលបានគ្រោងទុក ។ ទន្ទឹមនឹងដំណើរការនៃការអនុវត្តន៍គម្រោង ក៏នៅមានភាពខ្វះខាតមួយចំនួន ពីព្រោះថា អនុកិច្ចសន្យាពុំទាន់ បានអនុវត្ត ឬសម្រេចបាន អោយបានគ្រប់ចំនួននៃលទ្ធផល និង សកម្មភាពដែលបានគ្រោងទុកនៅឡើយ (បណ្តុះបណ្តាលបាន ៦វគ្គ/៨វគ្គ)។ រីឯលទ្ធផល និង សកម្មភាពដែលបានគ្រោងក្នុងអនុកិច្ចសន្យានោះទៀតសោត ពុំបានបញ្ជាក់អោយច្បាស់ពីចំនួនប្រធានបទ. ចំនួនវគ្គក្នុងប្រធានបទនីមួយ១ ដែលត្រូវធ្វើការបណ្តុះបណ្តាល។ ចំនួនសិក្ខាកាមក្នុងវគ្គនីមួយ១ . ចំនួនឃុំគោលដៅដែលជ្រើសរើសមកធ្វើការបណ្តុះបណ្តាលជាដើម។ កត្តានេះ ជាហេតុធ្វើអោយ ការវិភាគ និង វាយតម្លៃជារួមអំពីលទ្ធផល ពុំមានសុក្រិតភាពឡើយ ។

អ្វីដែលសំខាន់ទៀតនោះ អ្នកចូល រួម (សិក្ខាកាម) នៅក្នុងការពិភាក្សាក្រុម បានគូសបញ្ជាក់ថា ពួកគាត់មានភាពរីករាយយ៉ាងក្រៃលែង ដោយពួកគាត់ទទួលបានទាំងចំនេះដឹងជំនាញ និង ពូជថែមទៀត ។ សកម្មភាពនៃគម្រោងនេះ ពិតជាបានរួមចំណែកធ្វើអោយជីវភាពរបស់គាត់មានភាពកាន់តែប្រសើរ ។ យើងសង្កេតឃើញថា អ្នកភូមិក្នុង សហគមន៍ភាគច្រើន មានអាជីពជាអ្នក ដាំបន្លែ និង ចិញ្ចឹមសត្វ ធ្វើអោយចំណូលគ្រួសាររបស់ពួកគាត់កើនឡើង ហើយកាត់បន្ថយការចំណាយនៅក្នុងគ្រួសារ ក៏ដូចជាធ្វើអោយសុខភាពគ្រួសារពួកគាត់ប្រសើរឡើងដែរ។

## លទ្ធផលទី៤ :  ជ្រើសរើសកសិករបណ្តុះបណ្តាលអោយក្លាយជាភ្នាក់ងារចិញ្ចឹមសត្វភូមិ :

### ផ្នែក-កៈ ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ៤.១ | ▪ វគ្គបំប៉នដល់អ្នកស្ម័គ្រចិត្តសុខភាពសត្វភូមិចំនួន ២ វគ្គ<br>▪ វគ្គនីមួយៗមានចំនួន៣ថ្ងៃ<br>▪ អ្នកចូលរួមចំនួន ៣០នាក់<br>▪ គ្រោងបើកវគ្គនៅក្នុងខែ មេសា និង ឧសភា ឆ្នាំ ២០០៩ | ▪ បានបើកវគ្គបំប៉នដល់អ្នកស្ម័គ្រចិត្តសុខភាពសត្វភូមិចំនួន ២ វគ្គ<br>▪ វគ្គនីមួយៗមានចំនួន៣ថ្ងៃ<br>▪ អ្នកចូលរួមចំនួន ៣០នាក់ ក្នុងនោះស្រី មានចំនួន ២ នាក់<br>▪ វគ្គត្រូវបានបើកវគ្គនៅក្នុងខែ កញ្ញា តុលា និង ធ្នូ ឆ្នាំ  ២០០៩<br>▪ មុខវិជ្ជាដែលបានបណ្តុះបណ្តាលមាន : ជម្ងឺសត្វ វិធានការទប់ស្កាត់ការឆ្លងរាលដាលជម្ងឺផ្តាសាយបក្សី  ការប្រើប្រាស់ឱសថ និង វិធីសាស្ត្រផ្ទេរ និង ផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្មដល់កសិករ ។ |

### ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

ឆ្លងតាមតាមរយៈនៃការត្រួតពិនិត្យទៅលើឯកសារ អនុកិច្ចសន្យា និង  របាយការណ៍ យើងសង្កេតឃើញថា អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និង សកម្មភាពនានារបស់អនុកិច្ចសន្យាដែលបានគ្រោងទុក។  ការពិនិត្យទៅលើ ឯកសារ អនុកិច្ចសន្យា និង របាយការណ៍ឡើងវិញ មិនអាចវាយតម្លៃគុណភាពនៃលទ្ធផលនេះ បានលម្អិតទេ ពីព្រោះថា យើងមិន បានចុះធ្វើការសំភាសន៍ស៊ីជម្រៅ .មិនបានពិភាក្សាក្រុម និង ចុះពិនិត្យទៅផ្ទាល់តំបន់អនុវត្តគំម្រោងឡើយ ។

## ២.២. ការវាយតម្លៃការសម្រេចបាននូវអត្ថប្រយោជន៍ភ្លាមៗ និង លទ្ធផលនៃអនុកិច្ចសន្យា

### ផ្នែកក: ការវាយតម្លៃការសម្រេចបានរបស់ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា | ស្ថានភាពជាក់ស្តែង |
|---|---|
| **លទ្ធផលទី១ : ការគាំទ្រប្រពន្ធ័កសិកម្មចំរុះ** | |
| ▪ គ្រាប់ពូជបន្លែចំនួន២៥គីឡូក្រាម នឹងត្រូវផ្តល់ ជូនដល់ប្រជាកសិករ ក្នុងស្រុកគោលដៅ ។ | ▪ គ្រាប់ពូជបន្លែចំនួន ៤០គីឡូក្រាម ក្នុងនោះ ( ត្រកួន៧ គ.ក .សណ្តែកកួរ ៥គ.ក និង ពោត ២៨ គ.ក ) និង ៥៣ កំប៉ុង ( ស្ពៃខ្សៀវ ១៨កំប៉ុង និង ត្រសក់ចំណារ ៣៥កំប៉ុង )ត្រូវបានចែកជូនដល់ប្រជាកសិករ ក្នុងឃុំ ចំនួន ៧ នៃស្រុកព្រៃនប់គឺ ជើងគោ.បិតត្រាំង.រាម. បឹងតាព្រហ្ម.វាល រេញ .ទឹកថ្លា និង ទឹកល្អក់ ។ |
| ▪ ពូជស្រូវទិន្នផលខ្ពស់ ចំនួន ១៥០០ គីឡូក្រាម នឹងត្រូវផ្តល់ជូន ដល់ប្រជាកសិករ ក្នុងស្រុកគោលដៅ ។ | ▪ ពូជស្រូវទិន្នផលខ្ពស់ចំនួន ១២០០ គីឡូក្រាម ក្នុងនោះមាន ( ពូជផ្ការំដួល ៨០០ គ.ក និង សែនពិដោរ ៤០០ គ.ក ) ត្រូវបានចែកជូន ដល់ប្រជាកសិករ ក្នុងឃុំទាំង ១៤ នៃ ស្រុកព្រៃនប់ ដែលជាស្រុកគោលដៅ។ |
| ▪ ពូជកូនឈើហូបផ្លែចំនួន ១៥០០ដើម នឹងត្រូវផ្តល់ជូនដល់ប្រជាកសិករក្នុងស្រុកគោលដៅ ។ | ▪ ពូជកូនឈើហូបផ្លែ ចំនួន ៨៦០ដើម ក្នុងនោះមាន (ដូង ១៥០ដ. កំពីងរាជ ២០០ដ. ស្វាយកែវចិន ១០០ដ .ខ្នុរ ២០០ដ និង ស្វាយកែវរមៀត ២១០ដ ) ត្រូវបាន ចែកជូន ដល់ប្រជាកសិករ ក្នុងឃុំចំនួន ៧ នៃស្រុក ព្រៃនប់ គឺ សាមគ្គី បិតត្រាំង រាម បឹងតាព្រហ្ម ព្រៃនប់ សំរុង និង ទឹកល្អក់ ។ |
| ▪ពូជមេផ្សិតអំបោះចំនួន ១៨០០ កញ្ចប់ នឹងត្រូវ ផ្តល់ជូនដល់ប្រជាកសិករក្នុងស្រុកគោលដៅ ។ | ▪ ពូជមេផ្សិតអំបោះចំនួន ១៨០០ កញ្ចប់ ត្រូវបាន ចែកជូន ដល់ប្រជាកសិករ ក្នុងឃុំចំនួន ១១ នៃស្រុក ព្រៃនប់ គឺ បិតត្រាំង រាម បឹងតាព្រហ្ម អូរជ្រៅ អូរឧកញ៉ាហេង ព្រៃនប់ អណ្តូងថ្ម វាលរេញ ជើងគោ ទឹកថ្លា និង ទឹកល្អក់ ។ |

| | |
|---|---|
| ▪ ការរៀបចំប្រពន្ធ័កសិកម្មលើស្រែកសិករមានចំនួន ៥ កន្លែង នឹងត្រូវរៀបចំឡើង ដើម្បីធ្វើបង្ហាញ ដល់ប្រជាកសិករក្នុងស្រុកគោលដៅ ។ | ▪ ដំណើរការនៃរៀបចំប្រពន្ធ័កសិកម្មលើស្រែកសិករមាន ចំនួន ៤ កន្លែង ត្រូវបានរៀបចំឡើង ដើម្បីធ្វើបង្ហាញ ដល់ប្រជាកសិករក្នុងឃុំចំនួន ៤ នៃស្រុកព្រៃនប់គឺមាន រាម . ព្រៃនប់ . អណ្តូងថ្ម និង សំរុង ។ |
| **លទ្ធផលទី២ : ការចាក់ថ្នាំបង្ការសត្វ និង កម្មវិធីការពារប៉ារាស៊ីត** | |
| ▪ការចាក់ថ្នាំបង្ការ និង ព្យាបាលជម្ងឺគោក្របី ចំនួន ២២០០ ក្បាល នឹងត្រូវធ្វើឡើង នៅក្នុងឃុំ/ សង្កាត់ ចំនួន ២២ ទូទាំងខេត្ត ។ | ▪គោក្របី ចំនួន ៥២៣០ ក្បាល ( គោចំនួន ២៧៥២ ក្បាល និង ក្របីចំនួន ២៤៨០ ក្បាល ) នៅក្នុងឃុំ/សង្កាត់ចំនួន ២២ ទូទាំងខេត្ត ត្រូវទទួលនូវការចាក់ថ្នាំបង្ការ និង ព្យាបាល ជម្ងឺ ។ |
| **លទ្ធផលទី៣ : វគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម :** | |
| ▪ ប្រជាកសិករ ១៥នាក់ ក្នុងស្រុកគោលដៅ នឹងត្រូវបាននូវទទួលវគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់ជាលក្ខណ:គ្រួសារចំនួន១វគ្គ មានរយ:ពេល២ថ្ងៃ | ▪ ប្រជាកសិករចំនួន ១៥ នាក់ សុទ្ធតែប្រុសៗ មកពីឃុំ ចំនួន ៧ នៃស្រុកព្រៃនប់គឺ បឹងតាព្រហ្ម អូរជ្រៅ អណ្តូងថ្ម ទួលទទឹង ព្រៃនប់ សំរុង និង អូរឧកញ៉ាហេង បានទទួល វគ្គបណ្តុះបណ្តាល ស្តីពីបច្ចេកទេសចិញ្ចឹមមាន់ ជាលក្ខណ: គ្រួសារ ចំនួន ១វគ្គ មានរយ: ២ថ្ងៃ ។ |
| ▪ ប្រជាកសិករ ១៥នាក់ ក្នុងស្រុកគោលដៅ នឹងត្រូវបាននូវទទួលវគ្គបណ្តុះបណ្តាលស្តីពីវិធានការកំចាត់ សត្វល្អិត ចំនួន១វគ្គ មានរយ:ពេល២ ថ្ងៃ | ▪ ប្រជាកសិករចំនួន ១៥ នាក់ សុទ្ធតែប្រុសៗ មកពីឃុំ ចំនួន១០ ក្នុងស្រុកព្រៃនប់ គឺ បឹងតាព្រហ្ម អណ្តូងថ្ម ព្រៃនប់ សំរុង រាម សាមគ្គី ជើងគោ បិតត្រាំង វាលរេញ និង អូរឧកញ៉ាហេង បានទទួល វគ្គបណ្តុះបណ្តាល ស្តីពីវិធានការកំចាត់សត្វល្អិត ចំនួន ១វគ្គ មានរយ: ២ថ្ងៃ |
| ▪ ប្រជាកសិករ ១៥នាក់ ក្នុងស្រុកគោលដៅ នឹងត្រូវបាននូវទទួលវគ្គបណ្តុះបណ្តាលស្តីពីវដ្តនៃដំណាំស្រូវ ចំនួន១វគ្គ មានរយ:ពេល២ ថ្ងៃ ។ | ▪ ប្រជាកសិករចំនួន ១៥ នាក់ សុទ្ធតែប្រុសៗ មកពីឃុំ ចំនួន ១១ ក្នុងស្រុកព្រៃនប់គឺ ទឹកល្អក់ សាមគ្គី រាម បឹងតាព្រហ្ម អូរជ្រៅ អណ្តូងថ្ម ទួលទទឹង ជើងគោ វាលរេញ ទឹកថ្លា និង អូរឧកញ៉ាហេង បានទទួល វគ្គបណ្តុះបណ្តាល ស្តីពីវដ្តនៃដំណាំស្រូវចំនួន១វគ្គ មានរយ: ២ថ្ងៃ ។ |
| ▪ ប្រជាកសិករ ១៥នាក់ ក្នុងស្រុកគោលដៅ នឹងត្រូវ | ▪ ប្រជាកសិករចំនួន ១៥ នាក់ សុទ្ធតែប្រុសៗ មកពីឃុំ |

| | |
|---|---|
| បាននូវទទួលវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ជី ចំនួន១វគ្គ មានរយៈពេល២ ថ្ងៃ ។ | ចំនួន ១០ ក្នុងស្រុកព្រៃនប់គឺ រាម បឹងតាព្រហ្ម វាលរេញ អូរជ្រៅ ទួលទទឹង ព្រៃនប់ ទឹកល្អក់ ទឹកថ្លា សំរុង និង អូរឧកញ៉ាហេង បានទទួលវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ជី ចំនួន១វគ្គ មានរយៈ ២ថ្ងៃ ។ |
| ▪ ប្រជាកសិករ ១៥នាក់ ក្នុងស្រុកគោលដៅ នឹងត្រូវបាននូវទទួលវគ្គបណ្តុះបណ្តាលស្តីពីប្រពន្ធ័កសិកម្មចំរុះ ចំនួន១វគ្គ មានរយៈពេល២ ថ្ងៃ ។ | ▪ ប្រជាកសិករចំនួន ១៥ នាក់ សុទ្ធតែប្រុសៗ មកពីឃុំចំនួន ៩ ក្នុងស្រុកព្រៃនប់គឺ ជើងគោ ទួលទទឹង សាមគ្គី បឹងតាព្រហ្ម អូរជ្រៅ អណ្តូងថ្ម ព្រៃនប់ សំរុង និង អូរឧកញ៉ាហេង បានទទួលវគ្គបណ្តុះបណ្តាល ស្តីពីប្រពន្ធ័កសិ កម្មចំរុះ ចំនួន១វគ្គ មានរយៈ ២ថ្ងៃ ។ |
| ▪ ប្រជាកសិករ ១៥នាក់ ក្នុងស្រុកគោលដៅ នឹងត្រូវបាននូវទទួលវគ្គបណ្តុះបណ្តាលស្តីពីការកែច្នៃផលិតផលកសិកម្ម ចំនួន១វគ្គ មានរយៈពេល២ ថ្ងៃ ។ | ▪ ប្រជាកសិករចំនួន១៥នាក់ ក្នុងនោះស្រីមាន ចំនួន ២ នាក់ មកពីឃុំចំនួន៨ ក្នុងស្រុកព្រៃនប់ គឺ បិតត្រាំង រាម វាលរេញ អណ្តូងថ្ម ទួលទទឹង ព្រៃនប់ ទឹកល្អក់ និង អូរឧកញ៉ាហេង បានទទួល វគ្គបណ្តុះបណ្តាល ស្តីពីការកែច្នៃផលិតផលកសិកម្ម ចំនួន១វគ្គ មានរយៈ ២ថ្ងៃ ។ |
| **លទ្ធផលទី៤ : ជ្រើសរើសកសិករបណ្តុះបណ្តាលអោយក្លាយជាភ្នាក់ងារចិញ្ចឹមសត្វភូមិ :** | |
| ▪ ប្រជាកសិករដែលជាអ្នកស្ម័គ្រចិត្តសុខភាពសត្វភូមិ ចំនួន ៣០នាក់ ក្នុងស្រុក គោលដៅ នឹងត្រូវបាននូវទទួលវគ្គបណ្តុះបណ្តាលបំប៉ន អោយក្លាយជាភ្នាក់ងារចិញ្ចឹមសត្វភូមិចំនួន២វគ្គ ដោយក្នុងមួយវគ្គៗ មានរយៈពេល ៣ថ្ងៃ ។ | ▪ ប្រជាកសិករដែលជាអ្នកស្ម័គ្រចិត្តសុខភាពសត្វភូមិ ចំនួន ៣០នាក់ ក្នុងនោះស្ត្រីមានចំនួន ២ នាក់មកពីឃុំ ទាំង ១៤ ក្នុងស្រុកព្រៃនប់ គឺ ទឹកល្អក់ សាមគ្គី រាម បឹងតាព្រហ្ម អូរជ្រៅ អណ្តូងថ្ម ទួលទទឹង ជើងគោ វាលរេញ ទឹកថ្លា សំរុង អូរឧកញ៉ាហេង បិតត្រាំង និង ព្រៃនប់ បានទទួល វគ្គបណ្តុះបណ្តាលបំពាក់បំប៉ន ដើម្បីក្លាយខ្លួន ជាភ្នាក់ងារចិញ្ចឹមសត្វភូមិ ចំនួន ០២ វគ្គ ដោយមួយវគ្គមានរយៈពេល ៣ ថ្ងៃ។ |

**ផ្នែកខ: ការវាយតម្លៃការសម្រេចបានរបស់គោលបំណងបន្ទាន់**

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | 19/AGR/0901-00 |
| ចំណងជើង : | គាំទ្រដល់មន្ទីរកសិកម្មដើម្បីកាត់បន្ថយភាពក្រីក្រ |
| ភ្នាក់ងារអនុវត្តន៍ : | មន្ទីរកសិកម្មខេត្ត |
| រយៈពេល (ចាប់ផ្តើម និងបញ្ចប់) | 01/02/2009 ដល់ 31/12/2009 |
| រាជធានី ខេត្ត | ស្ទឹងត្រែង |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរកសិកម្មខេត្ត |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ/គ.អ.ជ.ខ | 23,000 ដុល្លារ |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | 23,000 ដុល្លារ |

## ក្រុមវាយតម្លៃ

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ |
|---|---|
| លោក ថោង ស្រាន់ | គ្រូបង្គោល M&E គ.ប្រ |
| លោក ឡាច ប៊ុនឡុង | គ្រូបង្គោល M&E គ.ប្រ |
| លោក ខឹម សុខខន | មន្ត្រី M&E គ.ប្រ |
| លោក ហ៊ត ពីន | មន្ត្រីមន្ទីរកិច្ចការនារី |
| ស្វាយ ពុទ្ធារ៉ា | មន្ត្រី M&E មន្ទីរកសិកម្ម |

## របាយការណ៍ស្តីពីវាយតម្លៃ រៀបចំដោយ :

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ និងតួនាទីក្នុងការវាយតម្លៃ |
|---|---|
| ១) លោក វ៉ាន់ ម៉ូនីកា | ទីប្រឹក្សា M&E និងវិស័យ |
| ២) លោក ថោង ស្រាន់ | គ្រូបង្គោល M&E គ.ប្រ |
| ៣) លោក ឡាច ប៊ុនឡុង | គ្រូបង្គោល M&E គ.ប្រ |
| ៤) លោក ខឹម សុខខន | មន្ត្រី M&E គ.ប្រ |

## ស្ទឹងត្រែង

**កញ្ញា ២០១០**

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៣ |
| | របាយការណ៍សង្ខេប | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៧** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៧ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៧ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៧ |
| ១.៤ | សំណួរវាយតម្លៃ | ៨ |
| ១.៥ | វិធីសាស្ត្រ សម្ភារ និងដំណើរការវាយតម្លៃ | ៨ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ៩ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១១** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១) | ១១ |
| | - លទ្ធផលទី១ | ១១ |
| ២.២ | ការវាយតម្លៃសម្រេចលើអត្ថប្រយោជន៏ភ្លាមៗ ការសម្រេចបាននូវលទ្ធផល អនុកិច្ចសន្យា (សំណួរវាយតម្លៃទី៣) | ១៣ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤) | ១៧ |
| **២.៤** | **សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី៥)** | **១៩** |
| **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍** | | **២១** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ២១ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៏ /ពិភាក្សា | ២២ |
| **ករណីសិក្សា** | | **១៥** |
| ទី១- | លោក លួន ប៊ុនប៉ែង ភេទប្រុស អាយុ៣១ឆ្នាំ អ្នកទទួលផលគម្រោងបំប៉ន ភ្នាក់ងារសុខភាពសត្វ | ១៥ |
| ទី២- | អ្នកមីង ស៊ូ បាន់ អាយុ៤៨ឆ្នាំ មិនបានទទួលផលផ្ទាល់ពីគម្រោង | ១៦ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

**គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ :**

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យា នៃគ.ប្រខេត្តស្ទឹងត្រែង រួមទាំងក្រុមការងារដែលជាមន្ត្រីបង្គោលM&Eមន្ទីរវិស័យបានធ្វើការវាយតម្លៃអនុកិច្ចសន្យាឆ្នាំ២០០៩ ដែលមានចំណងជើង (គាំទ្រដល់មន្ទីរកសិកម្ម ដើម្បីកាត់បន្ថយភាពក្រីក្រ) និងលេខអនុកិច្ចសន្យា 19/AGR/0901-00 ដែលជាអនុកិច្ចសន្យារវាងគ.ប្រនៃគ.អ.ជ.ខ និងមន្ទីរកសិកម្មខេត្ត។ នេះជាផ្នែកមួយនៃគម្រោងពង្រឹងសមត្ថភាពគ្រូបង្គោលថ្នាក់ក្រោមជាតិ របស់ផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោល នយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍន៍តាម បែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និង វិសហមជ្ឈការ នៅថ្នាក់ក្រោមជាតិ ។

គោលបំណងជាក់លាក់នៃការវាយតម្លៃនេះគឺ :

១- ទាញយក កត់ត្រា និងវិភាគតាមលក្ខណៈជាប្រព័ន្ធ ទៅលើលទ្ធផល និងសមិទ្ធផលនៃអនុកិច្ចសន្យា ចំណុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពបញ្ចប់នៃអនុកិច្ចសន្យា ព្រមទាំងកត់ត្រានូវចំណុច រៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត ។

២- ពង្រឹងរបៀបធ្វើការវាយតម្លៃគម្រោង របស់គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត ការវាយតម្លៃ អនុវត្តតាមការណែនាំ និងឧបករណ៍ ស្តីពីការវាយតម្លៃអនុកិច្ចសន្យារបស់គ.ប្រ នៃ គ.អ.ជ.ខ ដែលរៀបចំដោយផ្នែក ត្រួតពិនិត្យ វាយតម្លៃនៃលេខាធិការដ្ឋាន គ.ជ.អ.ប ។ ក្រុមការងារវាយតម្លៃ បានពិនិត្យអនុកិច្ចសន្យា របាយការណ៍ វិកចម្រើន និងឯកសារផ្សេងទៀត រួមទាំងការចុះមូលដ្ឋាន ដោយប្រើវិធីសាស្ត្រដូចជា : ការសម្ភាសន៍ស៊ីជម្រៅ ការពិភាក្សាក្រុម ការសង្កេតផ្ទាល់ ។ ដោយសារធនធាន និងពេលវេលាមានកំណត់ យើងធ្វើការ វាយតម្លៃស៊ីជម្រៅ ទៅលើតែលទ្ធផល ជ្រើសរើសកសិករ បណ្តុះបណ្តាលឱ្យក្លាយជា ភ្នាក់ងារចិញ្ចឹមសត្វភូមិ និងបំប៉នភ្នាក់ងារសុខភាព សត្វភូមិប៉ុណ្ណោះ តែមិនមែនបានធ្វើជាការវាយតម្លៃស៊ីជម្រៅលើអនុកិច្ចសន្យា ទាំងស្រុងទេ ហើយការសន្និដ្ឋាននេះ ត្រូវធ្វើឡើងតាមអ្វីដែលបានរកឃើញជាក់ស្តែង ។

**ឆ្លើយទៅនឹងសំណួរទាំង៥ នៃការវាយតម្លៃ :**

**១- សកម្មភាព និងលទ្ធផលដែលបានអនុវត្ត ធៀបនឹងផែនការ :**

| ល.រ | **សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី: ការបរិយាយអំពីអនុកិច្ចសន្យា** | **អ្វីដែលសម្រេចបានជាក់ស្តែង** |
|---|---|---|
| ១.១ | វគ្គបណ្តុះបណ្តាលស្តីពីការបំប៉នភ្នាក់ងារសុខភាពសត្វភូមិ<br>- ១វគ្គ | អនុវត្ត០១វគ្គ ១០០% |

| | | |
|---|---|---|
| | - ៣ថ្ងៃ<br>- អ្នកចូលរួម ២៨ នាក់ | |

២-វគ្គបំប៉នភ្នាក់ងារសុខភាពសត្វភូមិ បានធ្វើឱ្យស្ថានភាពក្នុងមូលដ្ឋានទាំងមូល មានការផ្លាស់ប្តូរដោយកាត់បន្ថយ បានអត្រាឈឺងាប់ របស់សត្វមកសត្វគ្មានជំងឺ និងស្លាប់មានចំនួនតិចតួច មានការកើនឡើងនៃចំនួនសត្វ និង បង្កើន មុខរបរ នាំឱ្យជីវភាពក្នុងសហគមន៍ប្រសើរឡើង ។

៣- គោលបំណងបន្ទាន់បានបរិយាយច្បាស់លាស់ ហើយមានទំនាក់ទំនងជាមួយលទ្ធផល និង សកម្មភាពក៏ប៉ុន្តែ វា មានកម្រិតខ្ពស់ពេក ដែលយើងនឹងពិបាកធ្វើការវាស់វែងបាន ។

៤- ស្ថានភាពនៅចុងបញ្ចប់នៃអនុកិច្ចសន្យាមានទំនាក់ទំនងទៅនឹងលទ្ធផល និងសកម្មភាព ។ ហើយវាបានឆ្លុះបញ្ចាំងនូវសមិទ្ធផលដូចជាការផ្តល់នូវចំណេះដឹង សេវា និងការអនុវត្តជាក់ស្តែងនៅមូលដ្ឋាន ប៉ុន្តែវាមិនបានឆ្លុះបញ្ចាំង នូវស្ថានភាពចុងបញ្ចប់ ឬផលប៉ះពាល់ដែល អាចកើតមានឡើងក្នុងកម្រិតប្រជាជន និងសហគមន៍ទេ ព្រោះវាគ្មាន ភស្តុតាងច្បាស់លាស់ណាមួយដើម្បី បង្ហាញថាតើក្រុមគោលដៅបានយកចំណេះដឹង និង ជំនាញដែលពួកគេ ទទួលបាន ទៅធ្វើជាប្រយោជន៍ ក្នុងការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ពួកគាត់ បន្តទៀត ឬយ៉ាងណា ។

៥- ជាក់ស្តែងក្រុមគោលដៅ និងសហគមន៍ នៅតែអនុវត្តសកម្មភាពបន្តរហូតដល់ក្រុមការងារចុះធ្វើការវាយតម្លៃ ដែលអាចធ្វើឱ្យស្ថានភាព ចុងបញ្ចប់ នៃអនុកិច្ចសន្យាទទួលបានជោគជ័យមួយកម្រិតដែរ ។

**អនុសាសន៍ដែលទាញចេញពីការវាយតម្លៃអនុកិច្ចសន្យាៈ**

១- **លទ្ធផល និងអត្ថប្រយោជន៍ដែលបានមកពីការអនុវត្តអនុកិច្ចសន្យា** ជាប្រយោជន៍ដល់សហគមន៍ វាបានឆ្លុះបញ្ចាំងនូវសមិទ្ធផល ដូចជាការផ្តល់នូវចំណេះដឹងផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែង នៅមូលដ្ឋានដែលនាំមកនូវកំណើន ផលិតកម្មសត្វ កំណើនកម្លាំងអូសទាញ ប្រយោជន៍ក្នុងការធ្វើឱ្យប្រសើរឡើង នូវជីវភាពរស់នៅរបស់ប្រជាជន តាម រយៈវគ្គបំប៉នភ្នាក់ងារសុខភាពសត្វភូមិនេះ ។

២- **ការរៀបចំអនុកិច្ចសន្យា** ត្រូវធ្វើយ៉ាងណាឱ្យមានទំនាក់ទំនង និងបានឆ្លុះបញ្ចាំង នូវស្ថានភាពចុងបញ្ចប់ ឬផលប៉ះពាល់ដែលអាចកើតមានឡើងក្នុងកម្រិតប្រជាជន និងសហគមន៍ ដែលមានភស្តុតាងច្បាស់លាស់ដើម្បីបង្ហាញថាតើក្រុមគោលដៅបានយកចំណេះដឹង និង ជំនាញដែលពួកគេទទួលបានទៅធ្វើជាប្រយោជន៍ ក្នុងការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ពួកគាត់ ក្នុងន័យរួមចំណែកកាត់ បន្ថយភាពក្រីក្របានមួយកម្រិត ។

៣- ទោះបីជាយ៉ាងណាក៏ដោយ ដើម្បី**ធ្វើឱ្យសម្រេចនូវអត្ថប្រយោជន៍កម្រិតខ្ពស់** ភ្នាក់ងារអនុវត្តគម្រោងគួរតែមានការជ្រើសរើសអ្នកទទួលផល ឬក្រុមគោលដៅឱ្យបានសមស្រប មានចំណេះដឹងជាមូលដ្ឋាន មានឆន្ទៈទទួល

ខុសត្រូវ និងសកម្មការងារ ។

៤- គួរមាន**ការបន្តគាំទ្រគម្រោង**បែបនេះឱ្យបានទូលំទូលាយ និងគ្រប់តំបន់គោលដៅដែលដាច់ស្រយាលដោយប្រើប្រាស់វិធីសាស្ត្រដូចជា : ក្រុមគោលដៅធ្វើការចុះផ្សព្វផ្សាយបន្តដល់តំបន់គោលដៅដាច់ស្រយាល តាមរយៈការលើកទឹកចិត្តជា សោហ៊ុយ ឬសម្ភារផ្សេងៗដែលជាតម្រូវការចាំបាច់ជាក់ស្តែង

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្តល់ថវិកាតាមរយៈគ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និងគម្រោងដែលគាំទ្រ ដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈជាប្រព័ន្ធ មិនបានអនុវត្តទេកាលពីពេលកន្លងមកដោយមកពីហេតុផលជាច្រើន។ នៅក្នុងឆ្នាំ២០១០ ជាមួយនឹងការគាំទ្រ ផ្នែកថវិកានិងបច្ចេកទេស ពីផ្នែកត្រួតពិនិត្យវាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែករដ្ឋបាលនិងគ្រប់គ្រងកិច្ចសន្យា គ.ប្រនៃគ.អ.ជ.ខ ក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យាដែលបានរៀបចំ រួមគ្នាជាមួយភ្នាក់ងារអនុវត្តន៍ដែលមានលេខអនុកិច្ចសន្យា 19/AGR/0901-00 និងឈ្មោះអនុកិច្ចសន្យា គាំទ្រដល់ មន្ទីរកសិកម្មដើម្បីកាត់បន្ថយភាពក្រីក្រ ដំណើរការលទ្ធផលដែលបានរកឃើញ និងការសន្និដ្ឋាននៃការវាយតម្លៃត្រូវ បានកត់ត្រា ហើយនឹងបង្ហាញតាមរយៈរបាយការណ៍ស្តីពី ការវាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

គោលបំណងនៃកិច្ចសន្យានេះនឹងរួមជាវិភាគទានដល់កម្មវិធីសិលាដែលមានគោលបំណងកាត់បន្ថយភាពក្រីក្រ តាមរយៈអភិបាលកិច្ចល្អ ។ ភារកិច្ចដើម្បីលើកតម្កើងបច្ចេកវិជ្ជាដល់កសិករតាមរយៈការផ្សព្វផ្សាយ បច្ចេកទេសចិញ្ចឹម សត្វ ធ្វើឱ្យកសិករក្លាយជា ភ្នាក់ងារសុខភាពសត្វភូមិ ធ្វើឱ្យមានកំណើន ផលិតកម្មសត្វ។ តួនាទីរបស់មន្ទីរកសិកម្មខេត្ត ជាពិសេស ការិយាល័យផលិតកម្ម និងបសុព្យាបាល គឺត្រូវផ្តល់ជាសេវាកម្មប្រកបដោយប្រសិទ្ធភាព តាមរយៈការ វិនិយោគ សម្រាប់ការ អភិវឌ្ឍន៍មូលដ្ឋាន ដែលក្រោមការរំពឹងទុកថាចំនួន និង គុណភាពផលិតផលសត្វ មានភាព ទទួលយក បាន និង សមស្រប។

កម្មវិធីនឹងចូលរួមចំណែកក្នុងការរក្សាស្ថេរភាពស្បៀងដែលជាបញ្ហាមួយយ៉ាងសំខាន់នឹងជាចម្បងក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនតាមភូមិ ឃុំនានា តាមជនបទ ម្យ៉ាងទៀតការអភិវឌ្ឍន៍ធនធានមនុស្ស ក៏មានសារៈសំខាន់ណាស់ដែរ ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូល ដោយផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និងតម្លាភាព។ ដូច្នេះទំហំនៃការវាយតម្លៃមានដែនកំណត់តាមទំហំនៃអនុកិច្ចសន្យា និង រាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខណ្ឌការងារនៃការវាយតម្លៃ។

គោលបំណង នៃការវាយតម្លៃគឺៈ ក) ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និងចំណុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំងកត់ត្រានូវ ចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត និង ខ) ដើម្បីពង្រឹងរបៀបធ្វើការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត ។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារ និងដំណើរការវាយតម្លៃ

**វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើៈ**

១) ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំណត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់ កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធដែលមាន នៅក្នុងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៍ ។

២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗ រួមមានៈ អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផលផ្ទាល់ និងមិនផ្ទាល់ ២ នាក់ និងអ្នកពាក់ព័ន្ធ ២នាក់ ។

៣) វិធីសាស្ត្រចុះពិនិត្យតំបន់អនុវត្តន៍គម្រោង និងសង្កេតមើលសកម្មភាព ពិភាក្សាក្រុម និង ករណីសិក្សា ។

៤) ចុះពិនិត្យតំបន់អនុវត្តន៍គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់ ។

៥) <u>វិភាគទិន្នន័យ និងបកស្រាយៈ</u> ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់ ។

៦) <u>ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៍</u> ដោយភ្នាក់ងារអនុវត្តន៍និងអ្នកពាក់ព័ន្ធតាមរយៈព័ត៌មានត្រឡប់ដែលទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើងនៅថ្ងៃទី១៣ខែកញ្ញាឆ្នាំ ២០១០ ការវាយតម្លៃត្រូវធ្វើតាម "គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា" និងវិធីសាស្ត្រដែលបានណែនាំ ។ដូច្នេះដំណើរការត្រូវបានធ្វើឡើងដោយមានទម្រង់ការណែនាំ និងតម្លាភាព រួមទាំងការចូលរួមពីអ្នកពាក់ព័ន្ធ ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ ។ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយ គ.ប្រ និង អ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា ។ ទោះជាយ៉ាងណាក៏ដោយ ការប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត ។

២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត : វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោងនៅពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និងបទពិសោធន៍ពីមុនមក ។ ទោះបីជាយ៉ាងណាក៏ដោយគោលបំណងសំខាន់ គឺដើម្បី "រៀនធ្វើដោយការអនុវត្តផ្ទាល់" ។ អ្នកវាយតម្លៃ បានទទួលការគាំទ្រដោយមានគោលការណ៍ការណែនាំឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ ។

៣) បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យា: ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និងជោគជ័យទេ ។មួយទៀតទំនាក់ទំនងសង្ខេបតាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់ មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ ។

៤) ដោយយើងមិនមានសូចនាកបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍"ដែលជាកម្រិតអត្ថប្រយោជន៍ទៅលើគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ ។

៥) ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិតទៅលើលទ្ធផល និង សកម្មភាពទាំងអស់បានទេ ។យើងអាចវាយតម្លៃតែទៅលើ *(ជ្រើសរើសកសិករបណ្តុះបណ្តាលឱ្យក្លាយទៅជាភ្នាក់ងារចិញ្ចឹមសត្វភូមិ )* ដែលជាលទ្ធផល និង *(វគ្គបណ្តុះបណ្តាលស្តីពីការបំប៉នភ្នាក់ងារសុខភាពសត្វភូមិ )* ដែលជាសកម្ម ភាពនៃអនុកិច្ចសន្យាលម្អិតតាមរយៈការសម្ភាសន៍ស៊ីជម្រៅ ក្រុមពិភាក្សា និងការចុះពិនិត្យតំបន់ អនុវត្តគម្រោង ។

៦) ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាមិនអាចធ្វើទៅបានទេព្រោះចំណុច គ នៃផ្នែកទី៣ក្នុងឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ ឬមិនពេញលេញ ។ ការងារនេះនឹងកាន់តែមានសុពលភាព និងពោរពេញទៅ

ដោយព័ត៌មាន បើសិនជាចំណុចដែលបានរៀបរាប់ខាងលើ នេះត្រូវបានដោះស្រាយ ។

**ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធនឹះ**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ (19/AGR/0901-00) និងដែនកំណត់ ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ ។

២) ការវាយតម្លៃនេះលម្អិតតែទៅលើលទ្ធផល *ជ្រើសរើសកសិករបណ្តុះបណ្តាលឱ្យក្លាយទៅជាភ្នាក់ងារចិញ្ចឹមសត្វភូមិ* និងសកម្មភាព *វគ្គបណ្តុះបណ្តាលស្តីពីការបំប៉នភ្នាក់ងារសុខភាពសត្វភូមិ* ដែលជាសកម្មភាពនៃអនុកិច្ចសន្យា

៣) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃទៅលើ ភ្នាក់ងារអនុវត្តន៍ ភ្នាក់ងារដែលពាក់ព័ន្ធគម្រោង ហើយនឹងការវាយតម្លៃទៅលើគ.ប្រ នៃគ.អ.ជ.ខ និង គ.ជ.អ.ប ទេ។

ហេតុដូច្នេះរបាយការណ៍នៃការវាយតម្លៃ លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ដែលបានលើកឡើងត្រូវពិនិត្យដោយយោងទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ ។

# ២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល

លទ្ធផលទី១ :ជ្រើសរើសកសិករបណ្តុះបណ្តាលឱ្យក្លាយទៅជា ភ្នាក់ងារចិញ្ចឹមសត្វភូមិ

**ផ្នែក-ក :ការសម្រេចជាក់ស្តែងធៀបនឹងផែនការ**

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | វគ្គបណ្តុះបណ្តាលស្តីពីការបំប៉នភ្នាក់ងារសុខភាពសត្វភូមិ<br>- ១វគ្គ<br>- ៣ថ្ងៃ<br>- អ្នកចូលរួម២៨ នាក់ | អនុវត្ត០១វគ្គ ១០០% |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និងសកម្មភាពរបស់អនុកិច្ចសន្យាដែលបានគ្រោងទុក អ្នកចូលរួមទាំងអស់នៅក្នុងក្រុមពិភាក្សាដែលជាសិក្ខាកាមនៃវគ្គបំប៉នពេទ្យសត្វភូមិ បានបញ្ជាក់ថាគេបានទទួលនូវចំណេះដឹង និងជំនាញដែលទាក់ទងទៅនឹងបច្ចេកទេសក្នុងការថែទាំ និងព្យាបាល ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺថាពួកគាត់នៅមានការចងចាំផ្នែកទ្រឹស្តីពីវគ្គបំប៉នបច្ចេកទេសភ្នាក់ងារពេទ្យសត្វភូមិ ទោះបីជាវគ្គបានបញ្ចប់យូរទៅហើយក្តី (ឆ្នាំ២០០៩) វិធីសាស្ត្រដែលមន្ទីរជំនាញបានយកទៅបណ្តុះបណ្តាល ធ្វើឱ្យសិក្ខាកាមភាគច្រើន ចូលចិត្ត និងមានការចាប់អារម្មណ៍ខ្ពស់ហើយវិធីសាស្ត្រដែលយកមកប្រើរួមមានការបំផុសគំនិតតាមរយៈរូបភាព និងពិភាក្សាក្រុមជាដើម ។ ល។ ក្រុមគោលដៅទទួលបានជំនាញ និង សមត្ថភាពក្នុងការថែរក្សាការពារ និងព្យាបាលជំងឺសត្វ ធ្វើឱ្យស្ថានភាពក្នុងមូលដ្ឋានទាំងមូលមានការផ្លាស់ប្តូរដោយកាត់បន្ថយ បានអត្រា ឈឺងាប់របស់សត្វ

មកសត្វគ្មានជំងឺ និងស្លាប់ មានចំនួនតិចតួច ដូច្នេះចំនួនសត្វមានការកើនឡើង ប្រជាជនមានចំណូលគ្រួសារ សហគមន៍ទាំងមូលជីវភាពធូរធាជាងមុន ដោយសារការលក់ដូរសត្វ ។ ទន្ទឹមនឹងលទ្ធផលខាងលើនេះក៏នៅមានបញ្ហាមួយចំនួនដោយក្រុមគោលដៅមិនយកចំណេះដឹងទៅផ្សព្វផ្សាយបន្ត និងអនុវត្តបានទូលំទូលាយ ដល់ សហគមន៍ ។ម្យ៉ាងទៀត ជំងឺសត្វមាន ការវិវត្តន៍លឿននាំឱ្យពួកគាត់មានការលំបាកក្នុងការតាមដាន និងព្យាបាល រួមទាំងការប្រើប្រាស់ថ្នាំឱ្យ ត្រូវនឹងប្រភេទ ជំងឺថ្មីប្លែកៗនេះពួក គាត់មិនអាចស្គាល់ ។

## ២.២. ការវាយតម្លៃសម្រេចលើអត្ថប្រយោជន៍ភ្លាមៗ ការសម្រេចបាននូវលទ្ធផល អនុកិច្ចសន្យា

### ផ្នែក -ក: ការសម្រេចបាននូវស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា

| ស្ថានភាពនៅពេលបញ្ចប់កិច្ចសន្យា (១) | លទ្ធផលប្រសើរឡើងជាក់ស្តែងនៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| វគ្គបណ្តុះបណ្តាលបំប៉នដល់ភ្នាក់ងារសុខភាពសត្វភូមិនេះ មានក្រុមគោលដៅចូលរួមចំនួន ២៨នាក់ ស្រី០១នាក់មកពីឃុំចំនួន៥និង២៨ភូមិ(១ភូមិ១នាក់)ក្នុងស្រុកសៀមប៉ាង ទាំងមូល ។ | ក្រុមគោលដៅចូលរួមមានចំនួន២៨នាក់ ស្រី០១នាក់ បានទទួលវគ្គបណ្តុះបណ្តាលស្តីពីការបំប៉ន ភ្នាក់ងារសុខភាពសត្វភូមិ ជាក្រុមគោលដៅ ចាស់ជា ភ្នាក់ងារមានស្រាប់ដែលមន្ទីរបានជ្រើសរើសតាមរយៈ ការស្ម័គ្រចិត្ត និងផ្អែកលើចំណេះដឹងជាមូលដ្ឋានរបស់ពួកគាត់ ។ វគ្គបានឆ្លើយតបនៅ នឹងតម្រូវការស្រប ពេលដែលស្ថានភាព ក្នុងសហគមន៍ កំពុងជួបប្រទះបញ្ហាសត្វមានជំងឺហើយ ភ្នាក់ងារសុខភាពសត្វ កំពុងមានតម្រូវការ នូវសមត្ថភាព បន្ថែមទៀតសម្រាប់ការពារ និងព្យាបាលជំងឺសត្វ ។ ដោយសារឆន្ទៈនិងភាពសកម្មចូលរួមថែមទាំងមាន សំណួរផុលផុស និងមានការផ្លាស់ប្តូរបទពិសោធន៍ ពីគ្នាទៅវិញទៅមករបស់សិក្ខាកាម រួមទាំងការបង្រៀនល្អរបស់គ្រូ មិនតែ ប៉ុណ្ណោះក្រោយពីវគ្គត្រូវ បានបញ្ចប់មួយរយៈ គ្រូបាន ចុះតាមដានសកម្មភាព ក្រុមគោលដៅផងនោះ វារឹតតែ សំខាន់ណាស់សម្រាប់ ពួកគាត់មាន ឱកាស សាកសួរ បន្ថែម នូវចម្ងល់ នានា ធ្វើឱ្យ ពួកគាត់មានចំណេះដឹង និង សមត្ថភាពកាន់ តែប្រសើរឡើងក្នុងការថែរក្សា ការពារ និងព្យាបាលប្រកដោយប្រសិទ្ធភាពធ្វើឱ្យស្ថាន ភាពក្នុងមូលដ្ឋាន ទាំងមូលមានការផ្លាស់ប្តូរដោយ កាត់បន្ថយបានអត្រាឈឺងាប់របស់សត្វមកសត្វ គ្មាន ជំងឺ និងស្លាប់មានចំនួនតិចតួច ដូច្នេះចំនួនសត្វមានការ កើនឡើងប្រជាជន |

| | |
|---|---|
| | មានចំណូល គ្រួសារសហគមន៍ទាំងមូលជីវភាពធូរធា ដោយសារ ការលក់ដូរសត្វ ។ |

## ផ្នែក-ខ: ការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា

| ធាតុនៃទិសដៅបន្ទាន់ (១) | ការសម្រេចបាន/លទ្ធផលជាក់ស្តែង នៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| ដោយផ្អែកទៅសភាពការណ៍នៃបញ្ហារបស់ប្រជាកសិករ ដែលកំពុងកើតមាន ហើយត្រូវការជាចាំបាច់នូវការដោះស្រាយផ្នែកផលិតកម្ម និងបសុព្យាបាលដោយផ្តោត សំខាន់ ទៅលើការថែរក្សា ការពារ និងព្យាបាលប្រកដោយ ប្រសិទ្ធភាព ធ្វើឱ្យស្ថានភាពក្នុងមូលដ្ឋាន ទាំងមូលមានការផ្លាស់ប្តូរ ដូចជាមានកំណើនកម្លាំងអូសទាញ ការកាត់បន្ថយបានអត្រា ឈឺ ងាប់របស់សត្វ មកសត្វគ្មានជំងឺ និងងាប់មានចំនួនតិចតួច និងធ្វើឱ្យមានចំណូលគ្រួសារ សហគមន៍ទាំងមូលមាន ជីវភាព ប្រសើរឡើងតាមរយៈ វគ្គបំប៉នភ្នាក់ងារសុខភាព សត្វភូមិ | គោលបំណងបន្ទាន់បានចែងនេះមានកម្រិតខ្ពស់ ដែលធ្វើឱ្យ ពិបាកវាស់វែងនៅចុង បញ្ចប់នៃអនុកិច្ចសន្យា។ ទោះបីគេរំពឹងទុកថាលទ្ធផល និងសកម្មភាព និងចូលរួមទៅក្នុងគោលបំណងបន្ទាន់ ប៉ុន្តែដោយការពិនិត្យលើឯកសារ និង វិធីសាស្ត្រ វាយតម្លៃតាមបែបគុណភាព គេមិនអាច ធ្វើការវាយតម្លៃ ថាតើគោលបំណងបន្ទាន់នេះសម្រេចបានកម្រិតណានោះឡើយ ។ |

## ផ្នែក-គ: ការវាយតម្លៃអត្ថប្រយោជន៍ជារួមដែលទទួលបាន

| |
|---|
| តាមរយៈការពិភាក្សាក្រុមពេទ្យសត្វបានបង្ហាញថា ពួកគាត់មានការពេញចិត្តចំពោះផលប្រយោជន៍ដែល អនុកិច្ចសន្យានេះសម្រេចបានជាពិសេសចំណេះដឹង និងបច្ចេកទេស នៃការចិញ្ចឹម ថែរក្សាការពារ និងព្យាបាលសត្វពាហនៈ។ ពួកគាត់បានទទួលស្គាល់ថាវាមាន សារៈប្រយោជន៍ សម្រាប់គ្រួសារ និងសហគមន៍ទាំងមូល ព្រោះជាទូទៅនៅពេល ដែលគាត់ទំនេរពីការធ្វើស្រែ ចំការពួកគាត់យកចិត្តទុកដាក់ ក្នុងការថែបំប៉នគោក្របីរបស់ពួកគាត់ដែលធ្វើឱ្យពួកគាត់ មាន លទ្ធភាពទាញយកប្រាក់ចំណូលបន្ថែមក្នុងគ្រួសារ និងសហគមន៍ ។ ទោះជាលទ្ធផល ខាងលើនេះមានលក្ខណៈល្អ ប្រសើរក៏ដោយ ក៏ប្រជាពលរដ្ឋ ក្នុងសហគមន៍ប្រមាណតែ៧0%ប៉ុណ្ណោះ ដែលបានទទួលផលពីគម្រោងនេះ ។ ទន្ទឹមនេះដែរប្រជាពលរដ្ឋ មួយចំនួនទៀត មិនបានទទួលផល ពីគម្រោងនេះ ដោយសារពួកគាត់ រស់នៅតំបន់ឆ្ងាយដាច់ ប្រយាល ភូមិសាស្ត្រមានការលំបាកក្នុងការធ្វើដំណើរ និងការទំនាក់ទំនង ។ |

# ករណីសិក្សា

## ករណីសិក្សាទី១ (អ្នកទទួលផលផ្ទាល់)

| | |
|---|---|
| លោកលួន ប៊ុនប៉ែង  | លោក **លួន ប៊ុនប៉ែង** ភេទប្រុស អាយុ៣១ឆ្នាំ ដែលជាអ្នកទទួលផលពីគម្រោងបំប៉នភ្នាក់ងារសុខភាពសត្វភូមិរបស់ គ.ជ.អ.ប នៅភូមិ សៀមប៉ាង ឃុំសេកុង ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង មានប្រពន្ធ និងកូន៣នាក់ ស្រី១នាក់ ពីមុនគាត់មានជីវភាពលំបាក រស់នៅពឹងតែមុខរបរបិទស្រាចិញ្ចឹមជ្រូក និងលក់បង្អែមបន្តិចបន្តួចតែប៉ុណ្ណោះ ប៉ុន្តែមុខរបរនេះមិន សូវរីកចម្រើន ដោយសារជ្រូកមានជំងឺ និងងាប់ជារៀងរាល់ឆ្នាំ ។ ក្រោយពីបានចូលរួមជា ភ្នាក់ងារសុខភាពសត្វភូមិមក ធ្វើឱ្យគាត់មានចំណេះដឹងជំនាញក្នុងការការពារ និងព្យាបាល ជំងឺសត្វ សម្រាប់សត្វចិញ្ចឹមរបស់គាត់គ្មានជំងឺលក់បានប្រាក់ចំណូលច្រើនក្នុងគ្រួសារ។ ម្យ៉ាងទៀតគាត់បានព្យាបាលសត្វក្នុងសហគមន៍ធ្វើឱ្យគាត់រកប្រាក់ចំណូលបានបន្ថែមទៀត សម្រាប់ផ្គត់ផ្គង់ជីវភាពក្នុង គ្រួសាររបស់គាត់ បានធូរធាជាងមុន |

**ករណីសិក្សាទី២ :( អ្នកទទួលផលមិនផ្ទាល់)**

អ្នកមីង ស៊ូ បាន់



អ្នកមីង **ស៊ូ បាន់** អាយុ៤៨ឆ្នាំ មានគ្រួសារ កូន៦នាក់ ស្រី៤ នាក់នៅភូមិសៀមប៉ាង ឃុំសេកុង ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង គាត់មិនបានទទួលផលផ្ទាល់ពីគម្រោង បំប៉នភ្នាក់ងារសុខភាពសត្វនេះទេ ហើយចំពោះគម្រោងនេះ គាត់អត់ដឹងដែរ តែគាត់ស្គាល់ឈ្មោះ លោក លួន ប៊ុនប៉ែង ជាភ្នាក់ងារសុខភាពសត្វភូមិ ដែលធ្លាប់បានចូលរួមវគ្គបំប៉នភ្នាក់ងារសុខភាពសត្វនេះ ហើយធ្លាប់បានព្យាបាលសត្វ ក្នុងគ្រួសាររបស់ គាត់ទៀតផង។ គាត់ចង់ចូលរួមយ៉ាងខ្លាំងក្នុងសកម្មភាព គម្រោងនេះ ព្រោះវាល្អ ចេះព្យាបាលសត្វសម្រាប់គ្រួសារដោយខ្លួនឯង ហើយ ព្យាបាលសត្វអ្នកដ៏ទៃនៅក្នុង សហគមន៍ អាចរកប្រាក់ចំណូលបានទៀតផង ។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

**ផ្នែក-ក: ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅតាមតម្រូវការៈ មន្ទីរវិស័យ មូលដ្ឋាន គ.ជ.អ.ប និងការកាត់បន្ថយភាពក្រីក្រៈ**

*សំគាល់:ពិន្ទុ ១= ខ្សោយណាស់២= ខ្សោយ ៣=មធ្យម ៤=ខ្លាំង ៥=ខ្លាំងណាស់)*

| ល.រ (១) | ធាតុ (២) | ទំនាក់ទំនងតក្កភាព (៣) | បរិយាយច្បាស់លាស់ (៤) | សង្ខេបការវាយតម្លៃ (៥) |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៤ | ៤ | ការសរសេរអនុក្កិសន្យា និងការអនុវត្តសកម្មភាពនេះវាយមានភាពស៊ី ជម្រៅ និងមានទំនាក់ទំនងទៅនឹងតក្កភាព ថែមទាំងបាន ឆ្លើយតបជាមួយក្រុមគោលដៅ ។ ឧទាហរណ៏: វគ្គបំប៉នភ្នាក់ងារសុខភាពសត្វភូមិចំនួន១វគ្គមានអ្នកចូល រូម ២៨នាក់ ស្រី១នាក់ |
| ២ | លទ្ធផល | ៤ | ៤ | ដោយសារលទ្ធផលនៃការជ្រើសរើសកសិករសម្រាប់បណ្តុះបណ្តាលឱ្យក្លាយជាភ្នាក់ងារចិញ្ចឹម សត្វភូមិ ហើយសកម្មភាពបណ្តុះបណ្តាលបំប៉ន ភ្នាក់ងារសុខភាពសត្វភូមិនេះ វាបានឆ្លើយតបទៅ នឹងតម្រូវការ ដោយគាត់ ទទួលបានចំណេះដឹង និង ជំនាញដើម្បីយកទៅប្រើប្រាស់ទាន់ពេលវេលា |
| ៣ | - គោលបំណងបន្ទាន់ *(គោលបំណងស្ថិតក្នុងចំណុច "ខ" នៃផ្នែកទី ៣)* | ៤ | ៤ | គោលបំណងបន្ទាន់បានបរិយាយច្បាស់លាស់ ហើយមានទំនាក់ទំនងជាមួយលទ្ធផល និង សកម្មភាព ក៏ប៉ុន្តែ វាមានកម្រិតខ្ពស់ពេក ដែលយើងនឹងពិបាកធ្វើការវាស់វែងបាន ។ |
| ៤ | ស្ថានភាពចុងបញ្ចប់នៃអនុកិច្ច សន្យា | ៤ | ៤ | ស្ថានភាពនៅចុងបញ្ចប់នៃអនុកិច្ចសន្យាមានទំនាក់ទំនង ទៅនឹងលទ្ធផល និងសកម្មភាព។ |

| | | | | |
|---|---|---|---|---|
| | (ចំណុច គ នៃផ្នែកទី៣) | | | ហើយវាបានឆ្លុះបញ្ចាំង នូវសមិទ្ធផលដូចជាការផ្តល់នូវចំណេះដឹងសេវា និងការអនុវត្តជាក់ស្តែង នៅមូលដ្ឋានដែលនេះនឹងនាំមកនូវកំណើន ផលិត កម្មសត្វកំណើនកម្លាំងអូសទាញ ប៉ុន្តែវាមិនបាន ឆ្លុះបញ្ចាំងនូវស្ថានភាពចុងបញ្ចប់ ឬផលប៉ះពាល់ ដែលអាចកើតមានឡើងក្នុងកម្រិតប្រជាជន និងសហគមន៍ទេព្រោះ វាគ្មានភស្តុតាងច្បាស់លាស់ណាមួយដើម្បីបង្ហាញ ថាតើក្រុមគោលដៅបានយកចំណេះដឹង និងជំនាញ ដែលពួកគេទទួលបាន ទៅធ្វើជាប្រយោជន៍ ក្នុងការធ្វើឱ្យប្រសើរឡើង នូវជីវភាពរស់នៅរបស់ពួកគាត់ បន្តទៀត ឬយ៉ាង ណា ។ |

## ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារ:

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.ជ.អ.ខ :** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | ជំនាញការរៀបចំនៅមានកម្រិតនៅឡើយ ដែលត្រូវការជួយពង្រឹងសមត្ថភាពបន្ថែម ។ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យ ការអនុវត្តន៏ របស់ភ្នាក់ងារអនុវត្តន៏ | ការគាំទ្រមានភាពរលូនគ្មានការប្រឈម និងឧបសគ្គដែលនាំឱ្យរាំងស្ទះដល់កិច្ចដំណើរការរបស់គម្រោងនោះឡើយ ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារអនុកិច្ចសន្យា | មានការរៀបចំទុកដាក់ឯកសារ និងការកត់ត្រាឯកសារដែលទាក់ទង និងអនុកិច្ចសន្យាបានល្អ ។ |
| **ពីខាងភាគីអនុវត្តន៏កិច្ចសន្យា :** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | មន្ត្រីមានជំនាញ និងបទពិសោធន៏គ្រប់គ្រាន់ |

| | | |
|---|---|---|
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | ការអនុវត្តសកម្មភាព និង លទ្ធផលមិនទាន់ពេលវេលាតាមការគ្រោងទុក ។ |
| ៦ | ការរាយការណ៍ការរីកចម្រើន និង ការកត់ត្រាឯកសារ | មានរបាយការណ៍ការរីកចម្រើនប៉ុន្តែមិនឃើញមានការកត់ត្រាឯកសារផ្សេងៗដូចជាកំណត់ហេតុប្រជុំនិងឯកសារចុះតាមដានការអនុវត្តគម្រោង ។ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | ត្រូវបានបំពេញ តាមលក្ខខណ្ឌកិច្ចសន្យា |
| **ទាំងខាង គ.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យា :** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត់" (ចំណុច-ង ផ្នែកទី៣) និងបញ្ហាប្រឈម | មានការរៀបចំផែនការគ្រប់គ្រងនិងបានកំណត់ "ហានិភ័យនិងកត្តាសន្មត" និងបញ្ហាប្រឈម ។ |
| ៩ | ការបញ្ជ្រាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | មានការបញ្ជ្រាបយេនឌ័រទៅក្នុងគម្រោង |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ ( ចំណុច-ឆ ផ្នែកទី៣) | គម្រោងមានបញ្ចូលការគ្រប់គ្រងធនធានធម្មជាតិ |
| ១១ | ការថែរក្សា (និរន្តភាព) ( ចំណុច-ជ ផ្នែកទី៣) | សកម្មភាព និងបច្ចេកទេសខ្លះៗដែលបានកើតឡើងដោយគម្រោងបានមើលឃើញថាបានយកទៅ អនុវត្ត ដោយកសិករ ឬសិក្ខាកាម ហើយបានបន្តរហូតដល់ ពេលក្រុមការងារចុះទៅវាយតម្លៃ ។<br>ដូច្នេះនិរន្តរភាពគម្រោង ត្រូវបានសម្រេច ។ |

## ២.៤. សេចក្តីសន្និដ្ឋាន

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យាត្រូវបានអនុវត្តដូចការគ្រោងទុក ។ ភាគីអនុវត្តអនុកិច្ចសន្យាមានមន្ត្រីមានសមត្ថភាព បទពិសោ ធន៏ និងធនធាន គ្រប់គ្រាន់ក្នុងការអនុវត្តគម្រោងដែលបានចុះកិច្ចសន្យាជាមួយគ.ប្រនៃគ អ ជ ខ ។ សកម្មភាព និងលទ្ធផលដែលបាន គ្រោងទុកបានអនុវត្តរួចរាល់ទោះបីមានការយឺតយ៉ាវបន្តិចបន្តួចក្តី ។ |
| ២ | លទ្ធផល និងអត្ថប្រយោជន៏ដែល បានមកពីការអនុវត្តអនុកិច្ចសន្យា ជាប្រយោជន៏ដល់សហគមន៏ វាបានឆ្លុះបញ្ចាំងនូវសមិទ្ធផល ដូចជាការផ្តល់នូវចំណេះដឹងផ្សាភ្ជាប់នឹងការអនុវត្តជាក់ស្តែងនៅមូលដ្ឋាន ដែលនាំ មកនូវកំណើនផលិតកម្មសត្វ កំណើនកម្លាំងអូសទាញ ប្រយោជន៏ ក្នុងការធ្វើឱ្យ ប្រសើរឡើងនូវជីវភាព រស់នៅ របស់ប្រជាជន តាមរយៈវគ្គបំប៉នភ្នាក់ងារសុខភាពសត្វភូមិនេះ ។<br>សកម្មភាពអនុកិច្ចសន្យាបានអនុវត្តដោយជោគជ័យ មានការពេញចិត្ត និងចូលយ៉ាងសកម្ម ពីភ្នាក់ងារ និង |

| | |
|---|---|
| | សហគមន៍តំបន់គោលដៅ នូវសមិទ្ធផលដែលបានផ្តល់ឱ្យពួកគាត់ ។ ជាក់ស្តែងក្រុមគោលដៅ និង សហគមន៍ នៅតែអនុវត្តបន្តរហូតដល់ក្រុមការងារចុះធ្វើការវាយតម្លៃ ដែលធ្វើឱ្យស្ថានភាព ចុងបញ្ចប់ នៃ អនុកិច្ចសន្យាទទួលបានជោគជ័យ ។ |
| ៣ | ក្នុងអំឡុងពេលអនុវត្តអនុកិច្ចសន្យា មានជួប ឧបសគ្គ និងការប្រឈមខ្លះៗ ដូចជា : កត្តាធនធានមនុស្ស ធម្មជាតិ (ព្យុះកេត សាណា) ភូមិសាស្ត្រតំបន់ដាច់ស្រយាល ទោះបីបានជួបនូវបញ្ហាប្រឈម ដូចបានរៀបរាប់ ខាងលើក៏គម្រោងនៅតែអនុវត្តបានជោគជ័យ តាមការគ្រោងទុក ។ |

ចំណុចរៀនសូត្រ:

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ផលប៉ះពាល់នៃអនុវត្តអនុកិច្ចសន្យា និងលទ្ធផលដែលសម្រេចបាន នៅតែមាននិរន្តភាព ក្នុងកម្រិតខ្ពស់ ពីព្រោះអនុកិច្ចសន្យាបានឆ្លើយតប នឹងតម្រូវការជាក់ស្តែង ជាអាទិភាពរបស់ក្រុមគោលដៅ និងសហគមន៍ ។ |
| ២ | ក្នុងគោលបំណងបន្ទាន់នៃអនុក្ចិសន្យាបានបរិយាយច្បាស់លាស់ឆ្លើយតប នឹងតម្រូវការជាក់ស្តែងជាអាទិភាព របស់ក្រុមគោលដៅ និងសហគមន៍ ដែលអាចវាយតម្លៃបានសម្រាប់ទុកជាបទពិសោធន៍ ។ |

អនុសាសន៍ :

| ល.រ | អនុសាសន៍ |
|---|---|
| ១ | ការរៀបរៀងអនុកិច្ចសន្យាមានលក្ខណៈទូលំទូលាយពេកដោយក្តោបតែទៅលើការកាត់បន្ថយភាពក្រីក្រមិន បានលំអិតច្បាស់លាស់លើចំណុចតម្រូវការបន្ទាន់សកម្មភាពរបស់លទ្ធផលនិងអត្ថប្រយោជន៍ដែលបានគ្រោងទុក ។ |
| ២ | ត្រូវតែពង្រឹងការទំនាក់ទំនងល្អជាប្រចាំ រវាងភ្នាក់ងារអនុវត្ត និង គ.ប្រ/គ អ ជ ខដើម្បីធ្វើឱ្យការអនុវត្តគម្រោង បានទទួល ជោគជ័យប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ |
| ៣ | សកម្មភាពត្រូវអនុវត្តតាមផែនការដែលបានគ្រោងទុកដើម្បីឱ្យអនុកិច្ចសន្យាទទួលបានជោគជ័យ |
| ៤ | ភ្នាក់ងារអនុវត្តអនុកិច្ចសន្យាត្រូវធានាលើការរៀបចំ និងទុកដាក់ឯកសារឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ ។ |
| ៥ | ភ្នាក់ងារអនុវត្តគម្រោងត្រូវលើកទឹកចិត្ត និងពង្រឹងការអនុវត្ត និងការចុះតាមដានដល់ក្រុមគោលដៅ ដើម្បីធ្វើឱ្យគម្រោងមាននិរន្តភាព ។ |

## ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

### ឯកសារត្រូវភ្ជាប់ទី១ : បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យារបាយការណ៍និងឯកសារទាក់ទងផ្សេងៗដែលបានពិនិត្យ

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) | មាន (៣) |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និងឯកសារវិសោធនកម្ម (ប្រសិនមាន) | ✓ |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ | ✓ |
| ៣ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | ✓ |
| ៤ | លិខិតឆ្លើយឆ្លងរវាងភ្នាក់ងារអនុវត្តន៏ និងគណៈកម្មាធិការប្រត្តិបត្តិគ.អ.ជ.ខ | ✓ |
| ៥ | បញ្ជីវត្ថុបណ្តុះបណ្តាលដែលមានក្នុងអនុកិច្ចសន្យា | ✓ |
| ៦ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា | ✓ |
| ៧ | ឯកសារដទៃទៀតរួមមាន រូបថតនៃគម្រោង (អនុកិច្ចសន្យា) ដែលទុកនៅ គណៈកម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ និងនៅភ្នាក់ងារអនុវត្តន៏ ដែលមិនបានរៀបរាប់ខាងលើ | ✓ |
| ៨ | ផ្សេងទៀត | |

## ឯកសារត្រូវភ្ជាប់ទី២: បញ្ជីឈ្មោះអ្នកផ្ដល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាសន៍/ជួបពិភាក្សា

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៍ប្រើសម្រាប់ប្រមូលទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | ៣០ សីហា | លោកទូច ធា ប្រធានមន្ទីរកសិកម្មខេត្ត | មន្ទីរកសិកម្មខេត្ត | សម្ភាសន៍ស៊ីជម្រៅ |
| ២ | ៣០ សីហា | លោក នួន គីមឡេង ប្រធានទីប្រឹក្សា PSDD | គ.ប្រ | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | ៣១ សីហា | <u>**ក្រុមអ្នកទទួលផល**</u><br>១) លោក លួន ប៊ុនប៉ែង<br>២) ប៊ុត ស៊ីបួលី<br>៣) ផេង ស៊ីសុវ៉ាត់<br>៤) ស៊ឹង ឡាំង<br>៥) ខាំ ម៉ៃ<br>៦) ស៊ុនថ សន | ភូមិ សៀមប៉ាង | សម្ភាសន៍ជាក្រុម |
| ៤ | ៣១ សីហា | លោក លួន ប៊ុនប៉ែង អ្នកទទួលផលផ្ទាល់ | ភូមិសៀមប៉ាង | សម្ភាសន៍ស៊ីជម្រៅ/ករណីសិក្សា |
| ៥ | ៣១ សីហា | លោកស្រីស៊ូ បាន់ អ្នកមិនទទួលផល | ភូមិ សៀមបាង | សម្ភាសន៍ស៊ីជម្រៅ/ករណីសិក្សា |
| ៦ | | មន្ត្រីបង្គោលយេនឌ័រ | | |
| ៧ | | មន្ត្រីបង្គោល គ្រប់គ្រងធនធានធម្មជាតិ | | |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | **20/GEN/0901-00 (GOV)** |
| ចំណងជើង : | ការគាំទ្រការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ |
| ភ្នាក់ងារអនុវត្តន៍ : | មន្ទីរកិច្ចការនារីខេត្តស្វាយរៀង |
| រយះពេល (ចាប់ផ្តើម និងបញ្ចប់) | ០១មករាឆ្នាំ២០០៩ដល់ ៣១ធ្នូឆ្នាំ២០០៩ |
| រាជធានី ខេត្ត | ស្វាយរៀង |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរកិច្ចការនារីខេត្តស្វាយរៀង |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ/គ.អ.ជ.ខ | ៧,000.00 ដុល្លា |
| ការរួមចំណែករបស់រាជធានី ខេត្ត | 0 |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៍ | 0 |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | ៧,000.00 ដុល្លា |

## ក្រុមវាយតម្លៃនិងរៀបចំរបាយការណ៍

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ |
|---|---|
| លោក គីម សាពណ៌ | ទីប្រឹក្សាត្រួតពិនិត្យ និងវាយតម្លៃ |
| លោក ទេព ស៊ីនួន | ប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យានិងរដ្ឋបាល |
| លោក គង់ ចាន់ថន | អនុប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យានិងរដ្ឋបាល |
| លោក ពុត កាអុល | មន្ត្រីត្រួតពិនិត្យនិងវាយតម្លៃ គ.ប្រ |
| លោក សុខា រ៉ាម | មន្ត្រីត្រួតពិនិត្យនិងវាយតម្លៃ គ.ប្រ |

## ខេត្ត ស្វាយរៀង

ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១០

# **មាតិកា**


| | | |
|---|---|---|
| | អក្សរកាត់ | ១ |
| | របាយការណ៏សង្ខេប | ២ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៤** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៤ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៤ |
| ១.៣ | គោលបំនង និង ទំហំនៃការវាយតម្លៃ | ៤ |
| ១.៤ | សំណួរវាយតម្លៃ | ៥ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ៥ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ៦ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **៨** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១) | ៨ |
| | - លទ្ធផលទី១ | ៨ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៏បឋម (សំណួរវាយតម្លៃទី៣) | ១០ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤) | ១៣ |
| **២.៤** | **សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី៥)** | **១៦** |
| | | |
| **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៏** | | **១៨** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៏ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ១៨ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៏ /ពិភាក្សា | ១៩ |
| | | |
| **ករណីសិក្សា** | | **១១** |
| ទី១- | " ជីវភាពរស់នៅមានភាពប្រសើរ " **អ្នកស្រី ភោគ សន** អ្នកទទួលផល | ១១ |
| ទី២- | អ្នកមិនទទួលផលពីអនុកិច្ចសន្យា | ១២ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

| |
|---|
| **គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ :** មន្ត្រីត្រួតពិនិត្យនិងវាយតម្លៃ ផ្នែកគ្រប់គ្រងកិច្ចសន្យានិងរដ្ឋបាលនៃគ.ប្រខេត្តស្វាយរៀងបានធ្វើការវាយតម្លៃ អនុកិច្ច-សន្យា របស់មន្ទីរកិច្ចការនារី ដែលមានចំណងជើង **ការគាំទ្រដល់ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ 20/GEN/0901-00** ជាអនុកិច្ចសន្យា រវាងគ.ប្រ នៃ គ.អ.ជ.ខ ខេត្តស្វាយរៀង និង មន្ទីរកិច្ចការនារី ។ នេះជាផ្នែក មួយនៃការពង្រឹងសមត្ថភាព ដល់គ្រូបង្គោល និង មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃគ.ប្រ និងមន្ទីរវិស័យ តាមរយៈ លេខាធិការដ្ឋាន គ.ជ.អ.ប ដែលគាំទ្រដោយកម្មវិធី អភិវឌ្ឍន៏តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ ។ គោលបំណងជាក់លាក់ នៃការវាយតម្លៃនេះគឺ មន្ទីរវិស័យ ត្រូវយកចិត ទុកដាក់ក្នុងការបញ្ជ្រាប យុទ្ធសាស្ត្រ និងគោលនយោបាយរបស់ខ្លួន អោយបានទូលំទូលាយ ក្នុងរង្វង់ឃុំសង្កាត់ ។ ពិនិត្យលិឯកសារពាក់ពន្ធ័ ដែលមានស្រាប និង ចុះមូលដ្ឋានធ្វើការពិភាក្សាក្រុម សំភាសន៏កត់ត្រាថតរូបភាព ដើម្បី ប្រមូលទិន្នន្យ័ ។ បើពិនិត្យទៅលើ កសិករដែលបានចូលរួមក្នុង វគ្គបណ្តុះបណ្តាល ពួកគេទទួលបានចំណេះដឹងប្រសើ ។ ចំពោះការរៀបចំ អនុកិច្ចសន្យា យើងពិនិត្យទៅលើផ្នែកទី៣ ឃើញថា មានភាពស៊ីសង្វាក់គ្នាបានប្រសើរវាងលទ្ធផល និងសកម្មភាព របស់មន្ទីរកិច្ចការនារី ។ |
| គោលបំណងជាក់លាក់ នៃការវាយតម្លៃនេះគឺ មន្ទីរវិស័យត្រូវយកចិត្តទុកដាក់ក្នុងការបញ្ជ្រាបយុទ្ធសាស្ត្រ និង គោលនយោបាយរបស់ខ្លួន អោយបានទូលំទូលាយដល់មូលដ្ឋាន ។ អនុកិច្ចសន្យានេះបានអនុវត្តបញ្ចប់ទៅតាមផែនការ ដែលបានគ្រោងទុក ១០០% ចំណែកធនធានសមល្មម និង សមត្ថភាពរបស់ភ្នាក់ងារអនុវត្តគម្រោង ។ ដូចនេះប្រៀបធៀប លទ្ធផលដែល សំរេចបាន ត្រូវគ្នាទៅនិង ផែនការដែលបានគ្រោង នៅក្នុងអនុកិច្ចសន្យា របស់មន្ទីរ ។ សកម្មភាព របស់ អនុកិច្ចសន្យា និងអត្ថប្រយោជ ដែលបានអនុវត្តត្រូវបានប្រជាពលរដ្ឋ ដែលជាអ្នកទទួលផលផ្ទាល់ និង អ្នកទទួលផល ដោយប្រយោល រីករាយនិងទទួលយក នៅក្នុងឃុំដែលគម្រោងបានអនុវត្ត ។ ចំពោះការបណ្តុះបណ្តាល ទប់ស្កាត់ អំពើហិង្សាក្នុងគ្រួសារថ្វីត្បិតតែមិនអាច វាយតម្លៃបែបបរិមាណ តែវាបានស្តែងចេញតាមបែបគុណភាព សកម្មភាព នេះត្រូវនិង គោលការណ៏របស់ រាជរដ្ឋាភិបាល ដែលផ្តោតទៅលើការបញ្ជ្រាបយេនឌ័រ ហើយក៏រួមចំណែកគាំទ្រ ក្នុងកំរិតខ្ពស់ ដល់ការកាត់បន្ថយភាពក្រីក្រ ។ ការជ្រើសរើសសិក្ខាកាម ដែលជាអ្នកទទួលផលនៅក្នុង អនុកិច្ចសន្យានេះ ដោយភាគីអនុវត្ត អនុកិច្ចសន្យាផ្ទាល់ ធ្វើអោយមានការធារនាថា អ្នកដែលមានតម្រូវការ ខ្លាំងបំផុត និងទទួល បានពីអនុកិច្ចសន្យាពិតប្រាកដ ។<br><br>ចំណុចសំខាន់ៗដែលបានសង្កេតឃើញក្នុងការវាយតម្លៃនេះ ផលប៉ះពាល់របស់អនុកិច្ចសន្យា និង ប្រសិទ្ធភាព នៃលទ្ធផល សម្រេចបានក្នុងកំរិតខ្ពស់ ត្រូវនិងតម្រូវការអាទិភាពរបស់អ្នកទទួលផលក្នុងឃុំគោលដៅ ។ គោលបំណង បន្ទាន់នៃ អនុកិច្ចសន្យា ដែលបានរៀបចំ និងសរសេរក្នុងនយ័ដែលមានទំនាក់ទំនងទៅនឹង លទ្ធផល ហើយបរិយាយ ច្បាស់លាស់ |

អំពីអ្វីដែលជាលទ្ធផលបន្ទាន់ និងអត្ថប្រយោជន៍ដែលរំពឹងទុក។

រួមសេចក្តីមកការវាយតម្លៃជាក់ស្តែង លើអនុកិច្ចសន្យាដោយផ្ទាល់ កសិករពេញចិត្ត និងវគ្គបណ្តុះបណ្តាលនេះ និងមានចំណេះដឹង៨០%។ បច្ចុប្បន្នកសិករ មានការផ្លាស់ប្តូរ ឥរិយាបទច្រើនក្នុងភូមិគ្មានការប្រើប្រាស់អំពើហិង្សា មិនស្រវឹង ឈ្លោះប្រកែកគ្នា ពួកគេខិតខំរកស៊ី ជួយកិច្ចការក្នុងគ្រួសារ ហើយជីវភាពកាន់តែប្រសើ។

១- គួរផ្តល់ការបណ្តុះបណ្តាលបន្ថែមដល់ភ្នាក់ងារអនុវត្ត អនុកិច្ចសន្យារបស់មន្ទីរវិស័យ។

២- លើកទឹកចិត្តអោយមានការដោះស្រាយបញ្ហាភ្លាមៗដែលបានរកឃើញក្នុងអំឡុងពេលនៃការអនុវត្តអនុកិច្ចសន្យាភ្លាមៗ។សកម្មភាពដែលបានលើកឡើងត្រូវមានការកំណត់សូចនាករអោយបានច្បាស់លាស់ដើម្បីងាយស្រួលក្នុងការ វាស់វែង (ទិន្នន័យមូលដ្ឋាន-Baline)

៣- ត្រូវបញ្ជ្រាបការងារយេនឌ័រអោយបានគ្រប់អនុកិច្ចសន្យារបស់មន្ទីរវិស័យ ដែលទទួលបានថវិកាពីគ.ប្រ។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្តល់ថវិកាតាមរយៈ គ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និងគម្រោង ដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈជាប្រព័ន្ធ មិនបានអនុវត្តទេកាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើន។ នៅក្នុងឆ្នាំ ២០១០ ជាមួយនឹងការគាំទ្រផ្នែក ថវិកា និងបច្ចេកទេស ពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល គ.ប្រ នៃ គ.អ.ជ.ខ ក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យា ដែលបាន រៀបចំរួមគ្នាជាមួយភ្នាក់ងារអនុវត្តដែលមានលេខ **20/GEN/0901-00** បណ្តុះបណ្តាលស្តីពីការបញ្ច្រាបយេនឌ័រ ដំណើរការលទ្ធផល ដែលបានរកឃើញ និងការសន្និដ្ឋាននៃការវាយតម្លៃត្រូវបានកត់ត្រាហើយនឹង បង្ហាញតាម រយៈរបាយការណ៍ស្តីពី ការវាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

គោលបំណងបន្ទាន់នៃអនុកិច្ចសន្យាគឺនៅចុងឆ្នាំ២០០៩បានបង្កើនសមត្ថភាពមន្ត្រីរាជការស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ ឱ្យបានទូលំទូលាយដល់ឃុំ ទាំង១១ និង៨៦ ភូមិ ក្នុងស្រុកស្វាយទាប នៃខេត្តស្វាយរៀង ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូល ដោយផ្នែក គ្រប់គ្រងកិច្ចសន្យា និង រដ្ឋបាលរបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និងតម្លាភាព។ ដូច្នេះ ទំហំនៃការវាយតម្លៃមានដែន កំណត់តាមទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខណ្ឌការងារនៃការវាយតម្លៃ។ គោលបំណងនៃការវាយតម្លៃគឺៈ **ក)** ទាញយកកត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និងចំនុចខ្សោយធៀបទៅនឹងលទ្ធផល គោលបំណង បន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំង កត់ត្រានូវ ចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើង នៅពេលអនាគត និង **ខ)** ដើម្បីពង្រឹងរបៀប ធ្វើការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការ នៃការអនុវត្ត។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើ:

១) ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំនត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់ កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធដែលមាន នៅក្នុងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៍ ។

២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័តិមានសំខាន់ៗ រួមមានៈ អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផល ផ្ទាល់១០ និងមិនផ្ទាល់១ និងអ្នកពាក់ព័ន្ធ២នាក់ ។ សូមពិគ្រោះជាមួយនឹងមន្ត្រីបង្គោលទៅលើបញ្ហាយេនឌ័រ និង គ្រប់គ្រងធនធានធម្មជាតិ សម្រាប់បញ្ហាពាក់ពន្ធ័វិស័យខាងលើ ។

៣) សូមប្រើប្រាស់វិធីសាស្ត្រចុះពិនិត្យតំបន់អនុវត្តន៍គម្រោង និងសង្កេតមើលសកម្មភាព ពិភាក្សាក្រុម និង ករណីសិក្សា។

៤) ចុះពិនិត្យតំបន់អនុវត្តន៍គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់ ។

៥) វិភាគទិន្នន័យ និងបកស្រាយៈ ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់

៦) ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ ដោយភ្នាក់ងារអនុវត្តន៍ និងអ្នកពាក់ព័ន្ធតាមរយៈ ព័តិមានត្រឡប់ដែលទទួលបានពីការបង្ហាញដោយសង្ខេប ។

ការវាយតម្លៃត្រូវធ្វើតាម "គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា" និងវិធីសាស្ត្រដែលបានណែនាំ។ ដូច្នេះ ដំណើរការត្រូវបានធ្វើឡើងដោយមានទម្រង់ការណែនាំ និងតម្លាភាព រួមទាំងការចូលរួមពីអ្នកពាក់ព័ន្ធ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយ គ.ប្រ និងអ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយការប្រឹងប្រែង ត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត។

២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត : វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោង នៅ ពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និងបទពិសោធន៍ពីមុនមក។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណង សំខាន់ គឺដើម្បី "រៀនធ្វើដោយការអនុវត្តផ្ទាល់"។ អ្នកវាយតម្លៃ បានទទួលការគាំទ្រដោយមានគោលការណ៍ ណែនាំឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។

៣) បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យា: ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និងជោគជ័យទេ។ មួយទៀតទំនាក់ទំនង សង្ខេបតាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ។

៤) ដោយយើងមិនមានសូចនាករបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍" ដែលជាកម្រិតអត្ថប្រយោជន៍ទៅលើគោលនយោបាយវិម្ឋការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។

៥)ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់យើងមិនអាចធ្វើការវាយតម្លៃលម្អិត ទៅលើទ្ធផល និងសកម្មភាពទាំងអស់បានទេ។ យើងអាចវាយតម្លៃតែទៅលើ លទ្ធផលបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រ "សកម្មភាពការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ នៅថ្នាក់ភូមិ ដល់ថ្នាក់ដឹកនាំភូមិ និងប្រជាពលរដ្ឋនៅក្នុងស្រុកស្វាយទាប ៨៦វគ្គ/១ថ្ងៃ ដែលជាសកម្មភាពនៃអនុកិច្ចសន្យា លម្អិតតាមរយៈការសម្ភាសន៍ ស៊ីជម្រៅក្រុមពិភាក្សា និងការចុះ ពិនិត្យ តំបន់

អនុវត្តគម្រោង។

**<u>ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធនឹះ</u>**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះអនុកិច្ចសន្យាលេខ**20/GEN/0901-00** និងដែនកំណត់ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ។

២) ការវាយតម្លៃនេះលម្អិតតែទៅលើ លទ្ធផលបណ្តុះបណ្តាលស្តីពីការបញ្ច្រាបយេនឌ័រ និង សកម្មភាពទប់ស្កាត់ អំពើហឹង្សាក្នុងគ្រួសារ នៅថ្នាក់ភូមិ ដល់ថ្នាក់ដឹកនាំភូមិ និងប្រជាពលរដ្ឋ

៣) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃទៅលើ ភ្នាក់ងារអនុវត្តន៏ ភ្នាក់ងារដែលពាក់ព័ន្ធគម្រោង ហើយនឹងការវាយតម្លៃទៅលើគ.ប្រ នៃគ.អ.ជ.ខ និង គ.ជ.អ.ប ទេ។

ហេតុដូច្នេះ របាយការណ៍នៃការវាយតម្លៃ លទ្ធផលដែលបានរកឃើញ និងអនុសាសន៏ដែលបានលើកឡើង ត្រូវពិនិត្យដោយយោលទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ។

# ២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១)

**លទ្ធផលទី១ :.បណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រ**

**ផ្នែក-ក :** ការសម្រេចបានជាក់ស្តែងធៀបនឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | បណ្តុះបណ្តាលស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ នៅថ្នាក់ភូមិ ដល់ថ្នាក់ដឹកនាំភូមិ និងប្រជាពលរដ្ឋនៅក្នុងស្រុកស្វាយទាប ៨៦វគ្គ /១ថ្ងៃ | បានបើកវគ្គបណ្តុះបណ្តាលចំនួន៨៦វគ្គ /១ថ្ងៃមានអ្នកចូលរួមចំនួន ៣,៧១៤ នាក់ ក្នុងនោះមានស្រី ២,៤00នាក់ |
| ១.២ | ប្រជុំបូកសរុប ការចុះផ្សព្វផ្សាយតាមភូមិនៅថ្នាក់ខេត្ត | ប្រជុំបូកសរុបមានអ្នចូលរួមចំនួន ២៦ នាក់ ជាស្រី |
| ១.៣ | វគ្គបណ្តុះបណ្តាលគោលការណែនាំស្តីពីដំណើការរៀបចំសហគ្រាសខ្នាតតូចសំរាប់ក្រុមស្រ្តីដល់មន្ត្រីយេនឌ័រខេត្ត៥ នាក់ ស្រុក ៥នាក់ និងអ្នកផ្សព្វផ្សាយឃុំ៣៤នាក់សរុប ៤៩នាក់រយៈពេល២ថ្ងៃនៅថ្នាក់ខេត្ត | បានបើកវគ្គបណ្តុះបណ្តាលចំនួន១វគ្គ សរុប : ចំនួន ៤៧ នាក់ក្នុងនោះ ស្រី ២៥ នាក់ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល ធៀបនឹងគោលបំណងបន្ទាន់ (ផលប៉ះពាល់ /លទ្ធផលបឋម រយៈពេលខ្លី/មធ្យមនៃលទ្ធផល) នៃអនុកិច្ចសន្យា

| |
|---|
| -អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផលនិងសកម្មភាពនានាដូចដែលបានគ្រោងទុក។ អ្នកចូលរួមទាំងអស់នៅក្នុងក្រុមពិភាក្សាដែលជាសិក្ខាកាមបានទទួលការផ្សព្វផ្សាយ |

ស្តីពីការ ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ ពួកគេមានការយល់ដឹងបានប្រសើ លើការបញ្ជ្រាបយេនឌ័រ ដូចជាការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ សមភាពយេឌ័ររវាងបុរស និងស្ត្រី លើកំពស់ស្ត្រី បុរស់ជួយកិច្ចការផ្ទះ ការជួយធុរៈគ្នានៅក្នុងភូមិរបស់ពួគេ និង ចាំបានមេរៀនដែលបានផ្សព្វផ្សាយនៅក្នុងឆ្នាំ២០០៩។

-ក្រុមពិភាក្សាបានសម្តែងពីទឹកចិត្តរីករាយដែលពួកគេទទួលបានពីគ្រូសម្របសម្រួល មានអាកប្បកិរិយាសមរម្យ សម្របខ្លួនតាមបែបសមញ្ញចេះ មានវិធីសាស្ត្របំផុសគំនិត ធ្វើអោយអ្នកចូលរួមមានភាពក្លាហាន មិនធុញទ្រាន់ ចេះឆ្នៃប្រឌិតផ្ទាំងរូបភាពសំរាប់ បង្ហាញដល់សិក្ខាកាមដែលមិនចេះអក្សរ ធ្វើអោយពួគេងាយយល់ និងសំណូមពរអោយមានបើកវគ្គបន្តទៀត។

-រួមសេចក្តីមកវគ្គផ្សព្វផ្សាយនេះមានភាពទាក់ទងទៅនិង តម្រូវការរបស់អ្នកភូមិ និង សហគមន៏។ ក្រុមពិភាក្សាបានបញ្ជាក់ថាមុនពេលបណ្តុះបណ្តាលមានអំពើហិង្សាច្រើន ប៉ុន្តែក្រោយពីបានធ្វើការផ្សព្វផ្សាយ ពួកគេមានចំណេះដឹងជាមូលដ្ឋាន បច្ចុប្បន្នបានកាត់បន្ថយជាខ្លាំងចំពោះការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ ឯបុរស់វិញមានការយល់ដឹងច្រើន មិនប្រកាន់ការងារចេះជួយធ្វើកិច្ចការផ្ទះ ។តាមការសង្កេតពេលទំនេរពួកគេប្រកបការងារកសិកម្ម ក្រៅពីធ្វើស្រែ ចិញ្ចឹមសត្វ ដាំបន្លែ និងប្រកបអាជីវកម្មផ្សេងៗមិននាំគ្នាផឹកស្រា ដូចពេល មុនៗទេ ។សព្វថ្ងៃស្ថានភាពជីវភាពរស់នៅរបស់ពួកគេកាន់តែប្រសើឡើង។

## ២.២. ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម (សំណួរវាយតម្លៃទី ៣)

### ផ្នែក-ក: ការសម្រេចបាននូវស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា (សំណួរវាយតម្លៃទី២)

| ស្ថានភាពនៅពេលបញ្ចប់កិច្ចសន្យា (១) | លទ្ធផលប្រសើរឡើងជាក់ស្តែងនៅពេលបញ្ចប់អនុកិច្ចសន្យា |
|---|---|
| បើកវគ្គបណ្តុះបណ្តាលស្តីពី ការទប់ស្កាត់អំពើហឹង្សា ក្នុងគ្រួសារ ជូនដល់ ប្រជាពលរដ្ឋនៅក្នុងភូមិ ដែលមានចំនួន ៨៦កន្លែង /ថ្ងៃ១កន្លែង | សរុបអ្នកចូលរួមទាំង៨៦កន្លែងមានចំនួន ៣,៧១៤នាក់ ក្នុងនោះមានស្រី ២,៤០០ នាក់<br>• ក្រុមពិភាក្សាបានបង្ហាញថា វគ្គបណ្តុះបណ្តាលស្តីពីនេះមានភាពទាក់ទងទៅនិងសហគមន៍។ ក្រុមពិភាក្សាបានគូសបញ្ជាក់ថា ចំណេះដឹងដែលពួកគេ ទទួលបានពីការផ្សព្វផ្សាយ មានសារៈប្រយោជន៍ណាស់។ |

### ផ្នែក-ខ: ការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា (សំណួរវាយតម្លៃទី៣)

| ធាតុនៃទិសដៅបន្ទាន់ (១) | ការសម្រេចបាន/លទ្ធផលជាក់ស្តែង នៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| គោលបំណងបន្ទាន់នៃអនុកិច្ចសន្យាគឺនៅចុងឆ្នាំ២០០៩ បានបង្កើនសមត្ថភាពមន្ត្រីរាជការស្តីពីការទប់ស្កាត់អំពើហឹង្សា ក្នុងគ្រួសារ ឱ្យបានទូលំទូលាយដល់ឃុំ ទាំង១១ និង៨៦ ភូមិ ក្នុងស្រុកស្វាយទាប នៃខេត្តស្វាយរៀង ។ | គោលបំណងបន្ទាន់ដែលបានចែងនៅក្នុងផ្នែកទី៣មានភាពស៊ីសង្វាក់គ្នាគ្រាន់បើ តាមការពិនិត្យ ឯកសារពាក់ពន្ធ័ និងអនុកិច្ចសន្យា។ |

### ផ្នែក-គ: ការវាយតម្លៃ ផលប្រយោជន៍ជារួមដែលទទួលបាន

| |
|---|
| បើតាមការចុះទៅដល់មូលដ្ឋានធ្វើសម្ភាសន៍ និងការពិភាក្សាក្រុម បានបង្ហាញថាពួកគាត់មានចិត្តសប្បាយចំពោះសកម្មភាពបណ្តុះបណ្តាលរបស់មន្ទីរកិច្ចការនារី។ មានអត្ថប្រយោជន៍ សំខាន់ណាស់សំរាប់ពួកគាត់ ករណីក្នុងភូមិគ្មាន អំពើហិង្សាធ្វើអោយកសិករមានសេចក្តីសុខ កូនចៅរបស់ពួកគាត់ បានរៀនសូត្រពេញលេញ និងការប្រកបមុខរបរផ្សេងៗមានភាពរីកចំរើន រកប្រាក់ចំណូលបាន និង ធ្វើអោយជីវភាពធូរធារ។ |

# ករណីសិក្សា

## ករណីសិក្សាទី១:អ្នកទទួលផលពីអនុកិច្ចសន្យាបណ្តុះបណ្តាល ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ

| |
|---|
| បន្ទាប់ពីចូលរួមជាមួយអនុកិច្ចសន្យារបស់មន្ទីរកិច្ចការនារី ដែលគាំទ្រដោយ គ.អ.ជ.ខ ខេត្ត ស្វាយរៀង អ្នកស្រី ភោគ សន បាននិយាយថា: "ជីវភាពរស់នៅរបស់ខ្ញុំ មានការប្រសើរឡើងតាំងពីខ្ញុំបានចូលរួមវគ្គបណ្តុះបណ្តាលទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ" |
| អ្នកស្រី ភោគ សន អាយុ ៥៥ ឆ្នាំជាកសិករនៅភូមិបន្ទាយ ឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង។ គាត់និយាយថា គម្រោងបណ្តុះបណ្តាល មានសារៈសំខាន់ណាស់ ព្រោះអ្នកទទួលផលទទួលបានចំណេះដឹង និងមានការពិចារណា ពីសមភាពយេនឌ័រ ឈានទៅលុបបំបាត់ការប្រើប្រាស់អំពើហិង្សា។ នាងខ្ញុំទទួលបានវគ្គបណ្តុះ-បណ្តាល និងវគ្គផ្សព្វផ្សាយជាបន្តបន្ទាប់ ដោយឡែក អនុកិច្ចសន្យាឆ្នាំ២០០៩របស់មន្ទីរកិច្ចការនារី បានបើកវគ្គបណ្តុះបណ្តាលស្តីពីការទប់ស្កាត់អំពើហិង្សា ក្នុងគ្រួសារបច្ចុប្បន្ន នៅក្នុងភូមិគ្មានអំពើហិង្សាធំដុំកើតឡើងទេជាពិសេសអ្នកទទួលផលពីគម្រោង" ចំពោះគ្រួសារនាងខ្ញុំវិញ ក្រៅពីធ្វើស្រែបានដាំដំណាំ ចិញ្ចឹមសត្វ បានផលល្អប្រសើរ" មុខរបរបន្ថែម ទាំងនេះធ្វើអោយជីវភាពនាងខ្ញុំធូរធារ។ ម្យ៉ាងវិញទៀត ភូមិ ឃុំ របស់នាងខ្ញុំ មានការអភិវឌ្ឍន៍ ហើយត្រូវ និងតម្រូវការអាទិភាព របស់អ្នកទទួលផលដូចជា ផ្លូវថ្នល់ល្អ សាលារៀននៅក្នុងភូមិ ធ្វើអោយនាងខ្ញុំ ក៏ដូចអ្នក ផ្សេងទៀត មានលទ្ធភាពបញ្ជូនកូនទៅសាលារៀន។ ទាំងនេះធ្វើអោយនាងខ្ញុំ និង អ្នកទទួលផលទាំងអស់ សប្បាយរីករាយ និងទទួលយកគម្រោង ទាំងសេវាកម្ម និង ហេដ្ឋារចនាសម្ព័ន្ធ និងចូលរួមចំណែកថែទាំ គម្រោងទាំងអស់ និងសូមអោយមានការ គាំទ្របន្តទៀត។  |

**ករណីសិក្សាទី២:អ្នកមិនទទួលផលពីអនុកិច្ចសន្យា**



លោក ស្រី ប៊ូរី អាយុ ៣៩ឆ្នាំ មានគ្រួសារ មានកូនស្រី ២នាក់។ គាត់ជាកសិកររស់នៅភូមិបន្ទាយ ឃុំកណ្ដៀងរាយ ស្រុកស្វាយទាខេត្តស្វាយរៀង បានមានប្រសាន៍ថា គាត់មិនបានទទួលការបណ្តុះបណ្តាល ពីគម្រោងនេះទេ។ ព្រោះគាត់ទៅរកស៊ីនៅភ្នំពេញ ការបណ្តុះបណ្តាលនេះ មានសារ:សំខាន់ណាស់ ព្រោះអ្នកចូលរួមមានចំណេះដឹង ធ្វើអោយពួកគេមានការពិចារណាពាក់ពន្ធ័ទៅនិងការ រស់នៅ ជាពិសេសការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ។ ថ្វីត្បិតតែខ្ញុំមិនបានចូលរួមវគ្គបណ្តុះបណ្តាលនៅឆ្នាំ២០០៩នេះ ។ បើមើលទៅលើស្ថានភាពក្នុងភូមិបច្ចុប្បន្ន ការឈ្លោះប្រកែកគ្នា ឬការប្រើអំពើហិង្សាក្នុងគ្រួសារ មិនសូវកើតមានទេ ហើយជីវភាពរបស់ពួកគេ ល្អប្រសើរមែនទែន។ គាត់បាននិយាយថា : "ចំពោះគ្រួសារខ្ញុំវិញ គឺលក់ដូរតិចតួច ដើម្បីដោះស្រាយជីវភាព។ ដោយសារភូមិ របស់ខ្ញុំ មានផ្លូវថ្នល់ល្អ មានសាលារៀន ទើបខ្ញុំមានឱកាស បញ្ជូនកូនទៅសាលាទាំងនេះ ធ្វើអោយខ្ញុំមាន ក្តីសង្ឃឹមសំរាប់ ពេលអនាគត ខ្ញុំសប្បាយរីករាយ និងចូលរួមចំណែកជួយថែទាំ សមិទ្ធផល គម្រោងទាំងនោះ ខ្ញុំសង្ឃឹមថា លើកក្រោយៗ គម្រោង និង ជួយគាំទ្របន្ថែមទៀត ហើយខ្ញុំនិងបានចូលរួមដែរ"។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

| ពិន្ទុ : ១=ខ្សោយណាស់ ២=ខ្សោយ ៣=មិនខ្លាំងមិនខ្សោយ ៤=ខ្លាំង ៥=ខ្លាំងណាស់ |
|---|

**ផ្នែក-ក: ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅនឹងតំរូវការៈ មន្ទីរវិស័យមូលដ្ឋាន គ.ជ.អ.ប និងការកាត់បន្ថយភាពក្រីក្រ**

| ល.រ (១) | ធាតុ (២) | ទំនាក់ទំនងតក្កភាព (៣) | បរិយាយ ច្បាស់លាស់ (៤) | សង្ខេបការវាយតម្លៃ (៥) |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៣ | ៤ | សកម្មភាពដែលបានលើកឡើង មានការទំនាក់ទំនង និងលទ្ធផលមធ្យម។ ឧទាហរណ៍ លទ្ធផលទី១ កសិករទទួល បានការបណ្តុះបណ្តាលស្តីពីការទប់ស្កាត់ អំពើហឹង្សា ក្នុងគ្រួសារ ៨៦កន្លែង/១ថ្ងៃ / កន្លែងចំនួន នៅតាមភូមិ ។ |
| ២ | លទ្ធផល | ៤ | ៤ | លទ្ធផលនេះបានសរសេរបរិយាយដោយមានសូចនាករមួយចំនួន តែមិនបានលំអិត |
| ៣ | - គោលបំនងបន្ទាន់ *(គោលបំនងស្ថិតក្នុងចំណុច "ខ" នៃផ្នែកទី ៣)* | ៣ | ៣ | ការពិណិនាអំពី គោលបំណងបន្ទាន់នេះ ពិបាក វាយតម្លៃ ឧទាហរណ៍ (បង្កើនសមត្ថភាព មន្ត្រី រាជការ និងផ្សព្វផ្សាយស្តីពីការទប់ស្កាត់អំពើ ហឹង្សា ក្នុងគ្រួសារ ឱ្យបានទូលំទូលាយដល់ ឃុំទាំង១១ និង ៨៦ភូមិក្នុង ស្រុកស្វាយទាប នៃខេត្តស្វាយរៀង។ មិនអាចវាស់វែងតាម ជាបរិមាណ តែយើងធ្វើការ វាយតម្លៃតាមបែបគុណភាព។ |

| | | | | |
|---|---|---|---|---|
| ៤ | -ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា (*ចំណុច "គ" នៃផ្នែកទី ៣*) | | | ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា ត្រូវបានបរិយាយហើយមានទំនាក់ទំនង ផ្ទាល់ទៅនិងលទ្ធផល សកម្មភាពនៃ អនុកិច្ចសន្យា ។ ស្ថានភាព ចុងបញ្ចប់ សំរេចបាន លទ្ធផលល្អ ប៉ុន្តែពិបាកវាយ តម្លៃផល ប៉ះពាល់ ។ |

**ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារ:**

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.ជ.អ.ខ:** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | នៅមានក៏រឹតត្រូវពង្រឹងបន្ថែម |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យការអនុវត្តន៏របស់ភ្នាក់ងារអនុវត្តន៏ | គ្មានការប្រឈម គួអោយកត់សំគាល់ទេ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា គួរធ្វើការកែលំអ ។ |
| **ពីខាងភាគីអនុវត្តន៏កិច្ចសន្យា:** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | គួរបំពាក់បំប៉នបន្ថែម |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | អនុវត្តបានតាមផែនការដែលបានគ្រោងទុក ។ |
| ៦ | ការរាយការណ៏ការរីកចំរើន និង ការកត់ត្រាឯកសារ | ការផ្តល់របាយការណ៏មានការយឺតយ៉ាវ ត្រូវកែលំអ ។ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | បានបំពេញតាមលក្ខខ័ណ្ឌកិច្ចសន្យា |
| **ទាំងខាង គ.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យា:** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" (ចំណុច-ឃ ផ្នែកទី៣) និងបញ្ហាប្រឈម | ការសរសេរហានិភយ័មិនបានសង្កត់ទៅលើឧបសគ្គ ធ្ងន់ធ្ងរ ឧទារណ៏ (គ្រោះធម្មជាតិ និងសន្តិសុខ អាចមានផលប៉ះពាល់ជាអវិជ្ជមានដល់ការអនុវត្តន៏ កិច្ចសន្យានេះ) |
| ៩ | ការបញ្ជ្រាបយេនឌ័រ (ចំណុច-ង ផ្នែកទី៣) | ជួយធ្វើអោយស្ថានភាពស្ត្រីក្នុងកិច្ចអភិវឌ្ឍន៏រួមទាំងការធ្វើផែនការ ការគ្រប់គ្រង ការសំរេចចិត្ត និងការដឹកនាំ មាន |

| | | |
|---|---|---|
| | | ភាពប្រសើរ ។ គោលការណ៍សមភាព និងសមធមិរវាង បុរសនិងស្ត្រី និងភាពស៊ីចង្វាក់គ្នា នៅក្នុងវគ្គនេះមាន ស្ត្រីចំនួន ៦៥%។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ ( ចំណុច-ច ផ្នែកទី៣) | ការអនុវត្តន៍កិច្ចសន្យានេះ មិនមានផលប៉ះពាល់ ឬឥទ្ធិពលអ្វីជាវិជ្ជមានដល់បរិស្ថានទេ ផ្ទុយទៅវិញមន្ទីរកិច្ចការនារីខេត្ត នឹងដើរតួយ៉ាងសំខាន់ក្នុងការផ្តល់ចំណេះដឹង ដល់មន្ត្រី ជនបង្គោលតាមបណ្តាមន្ទីរជំនាញ និងនៅតាម ស្រុក-ឃុំ អោយមានការ យល់ដឹងច្រើនពីផ្នែកយេនឌ័រ ជាពិសេសតួនាទីយេនឌ័រ តំរូវការយេនឌ័រ ដើម្បីដោះ ស្រាយបញ្ហាវិសមភាពយេនឌ័រនៅក្នុងសង្គម ហើយអាចយល់ដឹង ចូលរួមដាំដើមឈើថែទាំ និងគ្រប់គ្រងធនធាន ធម្មជាតិ ដែល មានស្រាប់ឱ្យបានប្រសើរឡើង ។ |
| ១១ | ការថែរក្សា (និរន្តភាព) ( ចំណុច-ឆ ផ្នែកទី៣) | វគ្គបណ្តុះបណ្តាលអំពើហិង្សានេះមិនអាចមើលឃើញទេ ។ ប៉ុន្តែវារួមចំណែកទាំងអស់គ្នា មានក្រុមប្រឹក្សាឃុំ និងអ្នកភូមិមានគំនិតថា ខ្លួនគេជាម្ចាស់សមិទ្ធផល នៃគំរោងទាំងអស់ពិតប្រាកដ ដែលអាចនាំទៅរកនិរន្តរភាព និងយន្តការយូរអង្វែង ។ |

## ២.៤. សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី ៥)

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យានេះបានអនុវត្តបញ្ចប់ទៅតាមផែនការដែលបានគ្រោងទុក ១០០% ចំណែក ធនធានសមល្មម និង សមត្ថភាព របស់ភ្នាក់ងារអនុវត្តគម្រោង។ ដូចនេះបើប្រៀបធៀបលទ្ធផលដែល សំរេចបាន ត្រូវគ្នាទៅនិង ផែនការ ដែល បានគ្រោង នៅក្នុងអនុកិច្ចសន្យា និងសមល្មមទៅសមត្ថភាពរបស់មន្ទីរ។ |
| ២ | សកម្មភាពរបស់អនុកិច្ចសន្យា និងអត្ថប្រយោជ ដែលបានអនុវត្តត្រូវបានអ្នកទទួលផលផ្ទាល់ និង មិនផ្ទាល់ រីករាយនឹងទទួលយក។ ក្រុមការងារដែល ចុះជួបផ្ទាល់ ជាមួយកសិករនៅក្នុងពេលធ្វើការវាយតម្លៃ ស្ថានភាព ចុងបញ្ចប់នៃការអនុវត្ត អនុកិច្ចសន្យា បានសម្រេច ទាំងស្រុងតាមផែនការគ្រោងទុក។ ជាក់ស្តែងតាមការសង្កេត និងចម្លើយរបស់ប្រជាពលរដ្ឋបានបង្ហាញថា ។<br>ក) ការបណ្តុះបណ្តាលទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ មានសារៈសំខាន់សំរាប់ការកែលំអ អាកប្បកិរិយារបស់ បុគ្គលខិលខូច។<br>គ) ការបណ្តុះបណ្តាលទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារថ្វីត្បិតតែមិនអាចវាយតម្លៃបែបបរិមាណ តែវាបានស្តែង ចេញតាមបែបគុណភាព សកម្មភាពនេះត្រូវនិងគោលការណ៏របស់រាជរដ្ឋាភិបាល ដែលផ្តោតទៅលើការបញ្ជ្រាប យេនឌ័រ ហើយសកម្មភាពនេះក៏រួមចំណែកគាំទ្រក្នុងគោលដៅក៏រិតខ្ពស់ ក្នុងការរួមចំណែក ដើម្បីកាត់ បន្ថយភាព ក្រីក្រ។ |
| ៣ | ការជ្រើសរើសសិក្ខាកាម ជាអ្នកទទួលផលនៅក្នុងអនុកិច្ចសន្យា ដោយភាគីអនុវត្តអនុកិច្ចសន្យាផ្ទាល់ ធ្វើអោយមាន ការធានាថា អ្នកដែលមានតម្រូវការខ្លាំងបំផុត និងទទួលបានពីអនុកិច្ចសន្យា។ |

<u>ចំណុចរៀនសូត្រ:</u>

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ចំណុចសំខាន់ៗដែលបានសង្កេតឃើញក្នុងការវាយតម្លៃនេះ ផលប៉ះពាល់របស់អនុកិច្ចសន្យា និង ប្រសិទ្ធភាព របស់លទ្ធផល សម្រេចបានក្នុងក៏រិតខ្ពស់ ត្រូវនិងតម្រូវការអាទិភាពរបស់អ្នកទទួលផលក្នុងឃុំគោលដៅ។ |
| ២ | ការបរិយាយនូវ "គោលបំណងបន្ទាន់ " ក្នុងក៏រិតដែលអាចវាស់វែងបានជាការសំខាន់សម្រាប់ការកត់ត្រាទុក នូវលទ្ធផលរបស់អនុកិច្ចសន្យា និង ផលប្រយោជន៍ ដើម្បីធ្វើការវាយតម្លៃ។ |

អនុសាសន៍ :

| ល.រ | អនុសាសន៍ |
|---|---|
| ១ | គោលបំណងបន្ទាន់នៃអនុកិច្ចសន្យា ដែលបានរៀបចំ និងសរសេរក្នុងនយ័ដែលមានទំនាក់ទំនងទៅនឹង លទ្ធផល ហើយបរិយាយច្បាស់លាស់អំពីអ្វីដែលជាលទ្ធផលបន្ទាន់ និងអត្ថប្រយោជន៍ដែលរំពឹងទុក ។ |
| ២ | នៅពេលដែលជ្រើសរើសក្រុមគោលដៅដោយភ្នាក់ងារអនុវត្តអនុកិច្ចសន្យា វាជាការប្រសើ ហើយបើសិនភាគីអនុវត្ត កិច្ចសន្យា ពិនិត្យឡើងវិញ នូវក្រុមគោលដៅ ថាពិតជាត្រឹមត្រូវ នោះលទ្ធផលនៃវគ្គបណ្តុះ បណ្តាល ពិតជាមានអត្ថប្រយោជន៍ខ្ពស់ ។ |
| ៣ | ការតាមដានសកម្មភាពក្រោយវគ្គបណ្តុះបណ្តាល ភ្នាក់ងារអនុវត្តគម្រោងគួរតែចុះពិនិត្យ ដើម្បីក្តាប់បាន នូវបញ្ហាផ្សេងៗដែល អ្នកទទួលផល និងសហគមន៍ត្រូវការ ។ |

## ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

**ឯកសារដែលត្រូវភ្ជាប់ទី១ : បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបានពិនិត្យ**

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) |
|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និង ឯកសារវិសោធនកម្ម (ប្រសិនមាន) |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ |
| ៣ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា |
| ៤ | បញ្ជីវត្ថុបណ្ដុះបណ្ដាលដែលមានក្នុងអនុកិច្ចសន្យា |
| ៥ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា |

**ឯកសារដែលត្រូវភ្ជាប់ទី២ : ឯកសារអនុកិច្ចសន្យា លេខ (20/GEN/0901-00 (GOV) ) ខេត្តស្វាយរៀង**

**បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាស/ជួបពិភាក្សា**

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៍ប្រើសម្រាប់ប្រមូល ទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | ២៧ កញ្ញា | លោក គឹម សុពណ៌ ទីប្រឹក្សាត្រួតពិនិត្យ និងវាយតម្លៃ | សាលាខេត្ត | សម្ភាសន៍ស៊ីជម្រៅ |
| ២ | ២៨ កញ្ញា | លោកស្រី ទុំ សារ៉ានី អនុប្រធានមន្ទីកិច្ចការ នារី ជាអ្នកទទួលខុសត្រូវ | មន្ទីរកិច្ចការនារី | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | ២៩កញ្ញា | ក្រុមអ្នកទទួលផល (សូមសរសរឈ្មោះខាងក្រោម) | ភូមិបន្ទាយ | សម្ភាសជាក្រុម |
| ៤ | ២៩ កញ្ញា | អ្នកស្រី ភោគ សន អ្នកទទួលផលផ្ទាល់ | ភូមិបន្ទាយ | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៥ | ២៩ កញ្ញា | លោក ស្រី បូរី អ្នកមិនទទួលផល | ភូមិបន្ទាយ | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | 21/AGR/0901-00 |
| ចំណងជើង : | គាំទ្រដល់ការអភិវឌ្ឍន៍វិស័យកសិកម្មចំរុះ |
| ភ្នាក់ងារអនុវត្តន៍ : | មន្ទីរកសិកម្មខេត្តតាកែវ |
| រយះពេល (ចាប់ផ្តើម និងបញ្ចប់) | ០១ មិនា ឆ្នាំ ២០០៩ ដល់ ៣១ ធ្នូ ឆ្នាំ ២០០៩ |
| រាជធានី ខេត្ត | តាកែវ |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរកសិកម្មខេត្តតាកែវ |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ/ គ.អ.ជ.ខ | ១៥.៧២០ ដុល្លារ |
| ការរួមចំណែករបស់ដៃគូរអភិវឌ្ឍន៍ដទៃទៀត | ៤.៣២០ ដុល្លារ |
| ការរួមចំណែករបស់សហគមន៍ | ៤.៩៦០ ដុល្លារ |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៍ | ៥.៤០០ ដុល្លារ |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | ៣០.៤០០ ដុល្លារ |

## ក្រុមវាយតម្លៃ

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ |
|---|---|
| ១) លោក ទូច ផេង | អនុប្រធានផ្នែក CAU និង ជាគ្រូបង្គោលថ្នាក់ខេត្ត |
| ២) លោក ជា ថាច | មន្ត្រីត្រួតពិនិត្យវាយតំលៃ គ.ប្រ |
| ៣) លោក នួន សំអាត | មន្ត្រីមន្ទីរអប់រំ និង ជាគ្រូបង្គោលថ្នាក់ខេត្ត |
| ៣) លោក ពី ស៊ា | មន្ត្រីត្រួតពិនិត្យវាយតំលៃ គ.ប្រ |

ខេត្តតាកែវ

កាលបរិច្ឆេទ : ខែ កញ្ញា ឆ្នាំ ២០១០

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៣ |
| | របាយការណ៍សង្ខេប | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៧** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៧ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៧ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៧ |
| ១.៤ | សំណួរវាយតម្លៃ | ៨ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ៨ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ៩ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១១** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១) | ១១ |
| | - លទ្ធផលទី១ | ១១ |
| | - លទ្ធផលទី២ | ១៤ |
| | - លទ្ធផលទី៣ | ១៥ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម (សំណួរវាយតម្លៃទី៣) | ១៦ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤) | ២២ |
| **២.៤** | **សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី៥)** | **២៥** |
| **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍** | | **២៩** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ២៩ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍/ពិភាក្សា | ៣០ |
| | | |
| **ករណីសិក្សា** | | **២០** |
| ទី១- | អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគំរោងបណ្តុះបណ្តាលបច្ចេកទេសផលិតជីធម្មជាតិ | ២០ |
| ទី ២- | អ្នកមិនទទួលផល | ២១ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប


គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ :

មន្ត្រីត្រួតពិនិត្យ និងវាយតំលៃផ្នែកគ្រប់គ្រងកិច្ចសន្យា នៃ គ.ប្រ បានធ្វើការវាយតំលៃអនុកិច្ចសន្យា ដែលមានចំណងជើងថា " **ការគាំទ្រដល់ការអភិវឌ្ឍន៏វិស័យកសិកម្មចំរុះ** " លេខ 21/AGR/0901-00 ជាអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរកសិកម្មខេត្ត ។ នេះជាផ្នែកមួយនៃគំរោងពង្រឹងសមត្ថភាពគ្រូបង្គោល ថ្នាក់ក្រោមជាតិរបស់ផ្នែកត្រួតពិនិត្យ វាយតំលៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែល គាំទ្រដោយកម្មវិធីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ ។

**គោលបំណងនៃអនុកិច្ចសន្យា**

គោលបំណងបន្ទាន់នៃអនុកិច្ចសន្យាគឺ នៅចុងឆ្នាំ ២០០៩ ទិន្នផលស្រូវ ដំណាំរួមផ្សំ និងផលិតផលសត្វក្នុង គ្រួសារ និង សហគមន៏ ត្រូវបានកើនឡើងតាមរយៈការបណ្តុះបណ្តាល ផ្សព្វផ្សាយ និងការធ្វើបង្ហាញ នូវបច្ចេកទេស កសិកម្មសមស្រប ។

**គោលបំណងជាក់លាក់នៃការវាយតំលៃ**

- ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមទ្ធិផលនៃអនុកិច្ចសន្យា និងចំណុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តអនុកិច្ចសន្យា រួមទាំងកត់ត្រាចំណុចរៀនសូត្រ និង ផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត ។

- ពង្រឹងរបៀបធ្វើការវាយតំលៃគំរោងរបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត ។

ការវាយតំលៃ អនុវត្តតាមការណែនាំ និងឧបករណ៏ស្តីពីការវាយតំលៃអនុកិច្ចសន្យារបស់ គ.ប្រនៃ គ.អ.ជ.ខ ដែលរៀបចំដោយផ្នែកត្រួតពិនិត្យ និងវាយតំលៃនៃលេខធិការដ្ឋាន គ.ជ.អ.ប ។ ក្រុមការងារវាយតំលៃបានប្រើការ ពិភាក្សាក្រុម ការសំភាសន៍ស៊ីជំរៅ ការចុះមូលដាន គន្លឹះក្នុងការសង្កេតផ្ទាល់ និងរំលឹកឯកសារអនុកិច្ចសន្យា របាយការណ៏រីកចំរើន និងឯកសារផ្សេងៗទៀត ។

ការវាយតំលៃត្រូវឆ្លើយតបនឹងសំនួរវាយតំលៃ ។ ដោយសារធនធានមានកំណត់យើងធ្វើការវាយតំលៃស៊ីជំរៅលើលទ្ធផលតែមួយប៉ុណ្ណោះ ចំណែកលទ្ធផលផ្សេងៗទៀត ត្រូវបានវាយតំលៃដោយផ្អែកលើព័តិមានដែលមានស្រាប់ ។ ដូច្នេះការវាយតំលៃនេះ មិនមែនជាការវាយតំលៃស៊ីជំរៅទៅលើអនុកិច្ចសន្យាទាំងមូលនោះទេ ហើយការសន្និដ្ឋានត្រូវធ្វើឡើងទៅតាមអ្វីដែលរកឃើញ ។

ឆ្លើយទៅនឹងសំណួរទាំង៥ នៃការវាយតម្លៃ :

១. សកម្មភាពទាំងអស់ត្រូវបានអនុវត្ត និងលទ្ធផលសំរេចបានតាមផែនការ មានដូចខាងក្រោម:

| ល.រ | សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយ អំពីអនុកិច្ចសន្យា | អ្វីដែលសំរេចបាន |
|---|---|---|
| ១ | វគ្គបណ្តុះបណ្តាលផលិតកម្មដំណាំស្រូវ ១០ វគ្គ (១វគ្គ /៣០នាក់ /៥ថ្ងៃ ) អនុវត្តក្នុង ៧ ឃុំគោលដៅ | វគ្គបណ្តុះបណ្តាលចំនួន ១០ ត្រូវបានបើក មានអ្នកចូលរួម ៣០២ នាក់ ក្នុងនោះស្រី ១៤១ នាក់បានទទួល ចំណេះដឹង ។ ដែលអនុវត្ត (១វគ្គ /៣០នាក់ /៥ថ្ងៃ ) ក្នុង ៧ ឃុំគោលដៅ ។ |
| ២ | វគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ ៦ វគ្គ (១វគ្គ .២០នាក់ . ៥ថ្ងៃ ) អនុវត្តក្នុង ៥ ឃុំគោលដៅ | វគ្គបណ្តុះបណ្តាលចំនួន ៦ ត្រូវបានបើក អ្នកចូលរួម ១២១ នាក់ ក្នុងនោះស្រី ៣៥ នាក់ បានទទួលចំណេះដឹង ដែលអនុវត្ត (១វគ្គ /៣០នាក់ /៥ថ្ងៃ ) ក្នុង ៥ ឃុំគោលដៅ |
| ៣ | ការធ្វើបង្ហាញផលិតកម្មដំណាំបន្លែ ៣០ សួន | សួនបន្លែចំនួន ៣០ ត្រូវបានអនុវត្ត លើ ៣០ គ្រួសារ |
| ៤ | វគ្គបណ្តុះបណ្តាលការផលិតជីធម្មជាតិ ១០ វគ្គ (១វគ្គ ៣០នាក់/១ថ្ងៃ ) អនុវត្តក្នុង ៥ ឃុំគោលដៅ | វគ្គបណ្តុះបណ្តាលចំនួន ១០ ត្រូវបានបើក អ្នកចូលរួមចំនួន ៣០៦ នាក់ ក្នុងនោះស្រី ១២៦ នាក់ បានទទួលចំណេះដឹង។ ដែលអនុវត្ត(១វគ្គ ៣០នាក់/១ថ្ងៃ ) ក្នុង ៥ ឃុំគោលដៅ |
| ៥ | ធ្វើបង្ហាញការផលិតជីធម្មជាតិ ៧១ រោង | រោងជីធម្មជាតិចំនួន ៧១ រោង ត្រូវបានធនុវត្តលើ ៧១ គ្រួសារ |
| ៦ | វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក ៧ វគ្គ (១វគ្គ ២០នាក់/៣ថ្ងៃ ) អនុវត្តក្នុង ៧ ឃុំគោលដៅ | វគ្គបណ្តុះបណ្តាលចំនួន ៧ ត្រូវបានបើក អ្នកចូលរួមចំនួន ១៤៤ នាក់ ក្នុងនោះស្រី ៦៥ នាក់ ទទួលបានចំណេះដឹង ដែលអនុវត (១វគ្គ ២០នាក់/៣ថ្ងៃ ) ក្នុង ៧ ឃុំគោលដៅ |
| ៧ | វគ្គបណ្តុះបណ្តាលពេទ្យសត្វភូមិ ១ វគ្គ ០១ (វគ្គ/៣០ នាក់/៣០ ថ្ងៃ ) | វគ្គបណ្តុះបណ្តាលចំនួន ១ ត្រូវបានបើក អ្នកចូលរួមចំនួន ៣០ នាក់ ក្នុងនោះស្រី ២ នាក់ បានក្លាយជាភ្នាក់ងារពេទ្យសត្វភូមិ ។ |

២. វគ្គបណ្តុះបណ្តាលអំពីការផលិតជីធម្មជាតិ ផលិតកម្មដំណាំស្រូវ បច្ចេកទេសដំណាំបន្លែ រួមទាំងការបង្ហាញ និងការប្រើប្រាស់ជីធម្មជាតិមានប្រសិទ្ធិភាពខ្ពស់ណាស់ ដោយសារវាបានចូលរួមចំណែកក្នុងការបង្កើនទិន្នផល និងបរិមាណផលិតផលស្រូវ និង បន្លែ កសិករមានចំណូលក្នុងគ្រួសារ និងបន្ថយការប្រើប្រាស់ជីគីមីទៅលើដំណាំបានមួយកំរិតធំ ។

៣. លទ្ធផលបន្ទាន់ និងផលប្រយោជន៍ពីវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក និងពេទ្យសត្វភូមិ ពិបាកវាយតំលៃណាស់ ព្រោះគ្មានព័ត៌មានមូលដ្ឋាន ។

៤. ជារួមអនុកិច្ចសន្យាសំរេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យានៅមានកំរិត ។

៥. អនុកិច្ចសន្យាពិតជាបានចូលរួមចំណែកក្នុងការសំរេចនូវគោលបំណងបន្ទាន់ ដោយសារកសិករបានអនុវត្តបច្ចេកទេសថ្មី ដែល ទទួលបានពីវគ្គបណ្តុះបណ្តាល និងបង្ហាញ ការប្រើប្រាស់ជីគីមី ផលិតផលកសិកម្ម និងចំនូលគ្រួសាររបស់ពួកគាត់មាន ការកើនឡើង ទោះជាក្នុងកំរិត និងដែនកំណត់ក៏ដោយ ។

៦. អនុកិច្ចសន្យានេះពិតជាមានភាពពាក់ព័ន្ធ ប្រសិទ្ធភាព និងប្រសិទ្ធិផល ទាក់ទងនឹងធនធានដែលមាន ការប្រតិបត្តិ និងការគ្រប់គ្រងទូទៅ ។ ប៉ុន្តែទោះជាយ៉ាងណា គុណភាពនៃការរៀបចំអនុកិច្ចសន្យា គួរតែត្រូវកែលំអដូចខាងក្រោម:

ក. បរិយាយឱ្យបានច្បាស់លាស់ ដោយរំលេចនូវសូចនាករដែលអាចអាចវាស់វែងបាន នូវស្ថានភាពចុងបញ្ចប់ នៃអនុកិច្ចសន្យា និងគោលបំណងបន្ទាន់

ខ. ការប្រើប្រាស់សូចនាករជោគជ័យធៀបទៅនឹងទិន្នន័យមូលដ្ឋាន

គ. ភ្ជាប់ទំនាក់ទំនងឱ្យបានច្បាស់រវាងលទ្ធផល និងគោលបំណងបន្ទាន់ និងគោលបំណងកំរិតខ្ពស់ ។

សេចក្តីការសន្និដ្ឋាន :

១.លទ្ធផលនិងអត្ថប្រយោជន៍ដែលបានពីការអនុវត្តអនុកិច្ចសន្យា ជាប្រយោជន៍ដល់សហគមន៍ ជាក់ស្តែង អ្នកទទួលផល និងមិនទទួលផល នៅក្នុងតំបន់គោលដៅនៃការអនុវត្តគំរោងបានទទួលការអបអរសាទរដោយពេញចិត្ត។

ឧទាហរណ៍ ការបង្កើតនូវបរិមាណផលិតផលជីធម្មជាតិ និងលទ្ធផលផ្សេងៗដែលបានមកពីការប្រើប្រាស់ជីធម្មជាតិក្នុងការបង្កបង្កើនផលក្នុងគ្រួសារ ជាលទ្ធផលសំរេចបានពីវគ្គបណ្តុះបណ្តាលបច្ចេកទេសការផលិតជីធម្មជាតិនៅក្នុងអនុកិច្ចសន្យា ។ លើស ពីនេះទៀតពួកគាត់បានបន្តសកម្មភាពទាំងនេះរហូតមកដល់សព្វថ្ងៃ ទោះបីជាគម្រោងបានបញ្ចប់ទៅយូរហើយក្តី ។ ជាពិសេស ទៀតនោះ តំរូវការវគ្គបណ្តុះបណ្តាលស្រដៀងគ្នានេះបានកើតឡើងបន្ទាប់ពីការអនុវត្តសកម្មភាពគម្រោង ដូចជាវគ្គបណ្តុះបណ្តាល ចិញ្ចឹមត្រី និងចិញ្ចឹមមាន់។

២. គួរមានថវិកាបន្តពង្រីកសកម្មភាពគម្រោងដែលទើបបញ្ចប់ក្នុរយ:ពេលមួយសមស្រប និងបន្តការគាំទ្រគម្រោងបែបនេះបន្តទៀត ក្នុងតំបន់គោលដៅដែលទោះបីក្នុងកំរិតតិចតួចក្តី ។

៣. ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីធ្វើអោយសំរេចបាននូវអត្ថប្រយោជន៍ក្នុងកំរិតខ្ពស់ ភ្នាក់ងារអនុវត្តគម្រោងគួរជ្រើសរើសអ្នកទទួលផលអោយបានសមស្រប សាក់សមជាអ្នកទទួលគំរោង។

៤. ដើម្បីពង្រឹងនូវគុណភាពនិងភាពទាក់ទងរបស់គម្រោង គួរមានការបរិយាយអោយបានច្បាស់លាស់នូវស្ថានភាពចុងបញ្ចប់ នៃអនុកិច្ចសន្យា និងគោលបំណងបន្ទាន់របស់គម្រោង ដោយរំលេចនូវសូចនាករដែលអាចវាស់វែងបាន ក៏ដូចជាការពង្រឹងទំនាក់ ទំនងតក្កភាពរវាងធាតុខាងលើទៅនឹងលទ្ធផល ។

៥. មន្ទីរវិស័យ និងផ្នែករដ្ឋបាលនិងគ្រប់គ្រងកិច្ចសន្យាគួរធ្វើការវាយតំលៃគម្រោងស្រដៀងគ្នានេះអោយបាន ១ ឬ ២ អនុកិច្ចសន្យាជាប្រចាំ ។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្តល់ថវិកាតាមរយៈ គ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និងគម្រោង ដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈជាប្រព័ន្ធ មិន បានអនុវត្តទេកាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើន។ នៅក្នុងឆ្នាំ ២០១០ ជាមួយនឹងការគាំទ្រផ្នែក ថវិកា និងបច្ចេកទេស ពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យា គ.ប្រ នៃគ.អ.ជ.ខ ក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យា ដែលបាន រៀបចំរួមគ្នាជាមួយភ្នាក់ងារអនុវត្តន៏ដែលមានលេខៈ 21/AGR/0901-00 គាំទ្រដល់ការអភិវឌ្ឍន៏វិស័យ កសិកម្មចំរុះ ដំណើរការលទ្ធផលដែលបានរកឃើញ និងការសន្និដ្ឋាន នៃការវាយតម្លៃត្រូវបានកត់ត្រា ហើយនឹង បង្ហាញតាមរយៈរបាយការណ៏ស្តីពី ការវាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

គោលបំណងបន្ទាន់នៃអនុកិច្ចសន្យាគឺ នៅចុងឆ្នាំ ២០០៩ ទិន្នផលស្រូវ ដំណាំរួមផ្សំ និង ផលិតផលសត្វក្នុងគ្រួសារ និងសហគមន៍ ត្រូវបានកើនឡើងតាមរយៈការបណ្តុះបណ្តាល ផ្សព្វផ្សាយ និងការធ្វើបង្ហាញ នូវបច្ចេកទេសកសិកម្មសមស្រប។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូល ដោយផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និងតម្លាភាព។ ដូច្នេះ ទំហំនៃការវាយតម្លៃមានដែនកំណត់តាមទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខណ្ឌការងារនៃការវាយតម្លៃ។ គោលបំណង នៃការវាយតម្លៃគឺ: **ក**) ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និងចំនុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំង កត់ត្រានូវ ចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត និង **ខ**) ដើម្បីពង្រឹងរបៀបធ្វើការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើៈ

១) ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំនត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធដែលមាននៅក្នុង ផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៍។

២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗ រួមមានៈ អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផលផ្ទាល់ និងមិនផ្ទាល់ ២ ឬ៣ នាក់ និងអ្នកពាក់ព័ន្ធ ២នាក់។ សូមពិគ្រោះជាមួយនឹងមន្រ្តីបង្គោលទៅលើបញ្ហាយេនឌ័រ និងគ្រប់គ្រងធនធានធម្មជាតិ សម្រាប់បញ្ហាពាក់ពន្ធ័វិស័យខាងលើ ។

៤) ចុះពិនិត្យតំបន់អនុវត្តន៏គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់។

៥) **<u>វិភាគទិន្នន័យ និងបកស្រាយៈ</u>** ទិន្នន័យដែលបានប្រមូលតាមវិធីសាស្រ្តខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់

៦) **<u>ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៏</u>** ដោយភ្នាក់ងារអនុវត្តន៏ និងអ្នកពាក់ព័ន្ធតាមរយៈព័ត៌មានត្រឡប់ដែលទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើងកាលពីថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១០។ ការវាយតម្លៃត្រូវធ្វើតាម "គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា" និងវិធីសាស្រ្តដែលបានណែនាំ។ ដូច្នេះដំណើរការត្រូវបានធ្វើឡើងដោយមានទម្រង់ការណែនាំ និងតម្លាភាព រួមទាំងការចូលរួមពីអ្នកពាក់ព័ន្ធ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយ គ.ប្រ និងអ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយការប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត។

២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត : វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោង នៅពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និងបទពិសោធន៍ពីមុនមក។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណងសំខាន់ គឺដើម្បី"រៀនធ្វើដោយការអនុវត្តផ្ទាល់"។ អ្នកវាយតម្លៃ បានទទួលការគាំទ្រដោយមានគោលការណ៍ការណែនាំឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។

៣) បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យា: ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និងជោគជ័យទេ ។ មួយទៀត ទំនាក់ទំនងសង្ខេបតាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ។

៤) ដោយយើងមិនមានសូចនាករបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍" ដែលជាកម្រិតអត្ថប្រយោជន៍ទៅលើគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។

៥) ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិតទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ។ យើងអាចវាយតម្លៃតែទៅលើ **កសិករបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសផ្សព្វផ្សាយគ្សេត្រសាស្ត្រ និងបង្ហាញ** ដែលជាលទ្ធផលទី ១ និង ***វគ្គបណ្តុះបណ្តាលការផលិតជីធម្មជាតិ*** ដែលជាសកម្មភាពទី ៤ នៃអនុកិច្ចសន្យាលំអិតតាមរយៈការសម្ភាសន៍ស៊ីជម្រៅ ក្រុមពិភាក្សា និង ការចុះពិនិត្យតំបន់អនុវត្តគម្រោង។

៦) ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា មិនអាចធ្វើទៅបានទេ ព្រោះចំណុច គ នៃផ្នែកទី ៣ ក្នុងឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ ឬមិនពេញលេញ ។

ការងារនេះ នឹងកាន់តែមានសុពលភាព និងពោរពេញទៅដោយព័ត៌មាន បើសិនជាចំនុចដែលបានរៀបរាប់ខាងលើនេះត្រូវបានដោះស្រាយ។

**<u>ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធនី:</u>**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ 21/AGR/0901-00 គាំទ្រការអភិវឌ្ឍន៍វិស័យកសិកម្មចំរុះ និងដែនកំណត់ ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ។

២) ការវាយតម្លៃនេះលម្អិតតែទៅលើ **កសិករបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសផ្សព្វផ្សាយក្សេត្រសាស្ត្រ និងបង្ហាញ** ដែលជាលទ្ធផល និង **វគ្គបណ្តុះបណ្តាលការផលិតជីធម្មជាតិ** ដែលជាសកម្មភាពទី ៤ នៃអនុកិច្ចសន្យា ។

៣) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃទៅលើ ភ្នាក់ងារអនុវត្តន៍ ភ្នាក់ងារដែលពាក់ព័ន្ធគម្រោង ហើយនឹងការវាយតម្លៃទៅលើគ.ប្រ នៃគ.អ.ជ.ខ និង គ.ជ.អ.ប ទេ។

ហេតុដូច្នេះ របាយការណ៍នៃការវាយតម្លៃ លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ដែលបានលើកឡើង ត្រូវពិនិត្យដោយយោលទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ។

# ២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១)

**លទ្ធផលទី១ : កសិករបានទទួលការបណ្តុះបណ្តាលពី បច្ចេកទេសផ្សព្វផ្សាយក្សេត្រសាស្ត្រ និងការបង្ហាញ**

**ផ្នែក-ក : ការសំរេចបានជាក់ស្តែងធៀបនឹងផែនការ**

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ១.១ | **វគ្គបណ្តុះបណ្តាលផលិតកម្មដំណាំស្រូវ ១០វគ្គ (១វគ្គ /៣០នាក់ /៥ថ្ងៃ** ) អ្នកចូលរួមសរុប ៣០០នាក់ ក្នុងនោះស្រីចំនួន ៩០ នាក់ អនុវត្តនៅក្នុង ៧ ឃុំគោលដៅ រួមមានឃុំដូងខ្ពស់ ២ វគ្គ, អង្គរបុរី ៣ វគ្គ, និងឃុំគោកធ្លក, ឃុំបឹងត្រាញ់ខាងជើង, ឃុំបឹងត្រាញ់ខាងត្បូង, ឃុំអង្គខ្នុរ ឃុំធ្លក ក្នុងមួយឃុំៗ ចំនួន ១ វគ្គ ។ | សំរេចបាន ១០ វគ្គ (១វគ្គ /៣០នាក់ /៥ថ្ងៃ ) មានអ្នកចូលរួមសរុបចំនួន ៣០២ នាក់ ក្នុងនោះស្រី ១៤១ នាក់ នៅក្នុង ០៧ ឃុំគោលដៅ ។ |
| ១.២ | **បណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ ៦វគ្គ (១វគ្គ .២០នាក់ . ៥ថ្ងៃ** ) អ្នកចូលរួមសរុបចំនួន ១២០ នាក់ ក្នុងនោះស្រីចំនួន ៣៦ នាក់ អនុវត្តនៅក្នុង ៥ ឃុំគោលដៅ រួមមានឃុំឃុំបឹងត្រាញ់ខាងជើង ១វគ្គ ឃុំរវៀង ១វគ្គ, ឃុំអង្គកែវ ១ វគ្គ, ឃុំរនាម ១វគ្គ និងឃុំសន្លុង ០២ វគ្គ។ | សំរេចបាន ០៦ វគ្គ (១វគ្គ .២០នាក់ . ៥ថ្ងៃ ) មានអ្នកចូលរួមសរុបចំនួន ១២១ នាក់ ក្នុងនោះស្រី ៣៥ នាក់ នៅក្នុង ០៥ ឃុំគោលដៅ ។ |
| ១.៣ | **ធ្វើបង្ហាញផលិតកម្មដំណាំបន្លែ ៣០ សួនបន្លែ** មានអ្នកចូលរួមសរុប ៣០ គ្រួសារ ដែលអនុវត្តក្នុង ៥ ឃុំគោលដៅ រួមមានៈ ឃុំបឹងត្រាញ់ខាងជើង ០៥ បង្ហាញ, ឃុំរវៀង ០៥ បង្ហាញ, ឃុំអង្គកែវ ០៥ បង្ហាញ, ឃុំរនាម ០៥ បង្ហាញ, ១វគ្គ និងឃុំ សន្លុង ១០ បង្ហាញ ។ | សំរេចបាន ៣០ បង្ហាញ មានអ្នកចូលរួមចំនួន ៣០ គ្រួសារ ដែលស្ថិតនៅក្នុង ០៥ ឃុំគោលដៅ |

| | | |
|---|---|---|
| ១.៤ | **វគ្គបណ្តុះបណ្តាលការផលិតជីធម្មជាតិ ១០ វគ្គ (១វគ្គ ៣០នាក់/១ថ្ងៃ)** មានអ្នកចូលរួម សរុប ចំនួន ៣០០ នាក់ ក្នុងនោះស្រី ៩០ នាក់ ដែលអនុវត្តក្នុង ០៩ ឃុំគោលដៅ រួមមានៈ ឃុំចំបក់, ឃុំកុមារាជា, ឃុំបឹងត្រាញ់ខាងត្បូង, លំចង់, ប្រាំបីមុំ, អង្គកែវ, ត្រពាំងក្រញូង, ពពេល ក្នុងមួយឃុំៗចំនួន០១ វគ្គ និង ឃុំរមេញ ២ វគ្គ ។ | លទ្ធផលសំរេចបាន ១០ វគ្គ មានអ្នកចូលរួមសរុបចំនួន ៣០៦ នាក់ ក្នុងនោះស្រី ១២៦ នាក់ នៅក្នុង ៩ ឃុំគោលដៅ ។ |
| | **ធ្វើបង្ហាញការផលិតជីធម្មជាតិ ៧១ រោង** អ្នកចូលរួមសរុប ចំនួន ៧១ គ្រួសារ អនុវត្តនៅក្នុង ៩ ឃុំគោលដៅ រួមមាន ឃុំរមេញ ១០ រោង ឃុំចំបក់ ៥ រោង, ឃុំកុមារាជា ៥ រោង, ឃុំបឹងត្រាញ់ខាងត្បូង ៥ រោង, ឃុំលំចង់ ៥ រោង, ប្រាំបីមុំ ៥ រោង, អង្គកែវ ៥ រោង, ត្រពាំងក្រញូង ២០ រោង និង ពពេល ១១ រោង ។ | លទ្ធផលសំរេចបាន ៧១ បង្ហាញ មានអ្នកចូលរួមសរុបចំនួន ៧១ គ្រួសារ នៅក្នុង ៩ ឃុំគោលដៅ ។ |

## ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

អនុកិច្ចសន្យានេះសំរេចបានលទ្ធផល និងសកម្មភាពទាំងអស់របស់អនុកិច្ចសន្យាដែលបានគ្រោងទុក ។

ផ្អែកតាមការវិភាគព័តមាន ដែលបានពីមូលដ្ឋានតាមរយៈការពិភាក្សាក្រុមជាមួយអ្នកចូលរួមទាំងអស់ ដែលជាសិក្ខាកាមពីវគ្គបណ្តុះបណ្តាលការផលិតជីធម្មជាតិឃើញថាៈ ការជ្រើរើសតំបន់គោលដៅភ្នាក់ងារអនុវត្តបានកំណត់តាមរយៈសមាហរណកម្មផែនការថ្នាក់ស្រុក ដោយឡែកចំពោះការជ្រើសរើសក្រុមគោលដៅ ឬអ្នកទទួលផលវិញ ត្រូវបាន ភ្នាក់ងារអនុវត្តជ្រើសរើសតាមរយៈមេភូមិដោយផ្តោតទៅលើលក្ខខ័ណ្ឌមួយចំនួនដូចជា គ្រួសារមានចិញ្ចឹមសត្វ ជាអ្នកឧស្សាហ៍ព្យាយាម មានទឹកចិត្តចង់ចូលរួម និងមានដីសំរាប់ បង្កបង្កើនផល ជាពិសេសដីសំរាប់ដាំដំណាំរួមផ្សំផ្សេងៗ ។ល។ ប៉ុន្តែទោះជាយ៉ាងនេះក្តីក្រុមពិភាក្សាបានផ្តល់យោបល់បន្ថែមថា បន្ទាប់ពីមេភូមិជ្រើសរើសហើយ ភ្នាក់ងារអនុវត្តក៏ពុំ បានចុះមកសិក្សាអំពីស្ថានភាព និងតំរូវការជាក់ស្តែងរបស់ក្រុមគោលដៅបន្ថែមទៀតឡើយ ។

ឆ្លងតាមការបណ្តុះបណ្តាលសិក្ខាកាមទាំងអស់ ជាដំបូងទទួលបាននូវចំណេះដឹង និងជំនាញយ៉ាងច្បាស់លាស់ ដែលទាក់ទងទៅបច្ចេកទេសផលិតជីធម្មជាតិ ។ ពេល

បណ្តុះបណ្តាល សិក្ខាកាមមានការចូលរួមយោបល់យ៉ាងសកម្ម ផុលផុស ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍ទៅវិញទៅមក បណ្តាលឱ្យមកដល់សព្វថ្ងៃពួកពួកគាត់នៅចងចាំទ្រឹស្តីស្ទើរតែ ទាំងអស់ពីវគ្គបណ្តុះបណ្តាល ទោះបីវគ្គនេះបានបញ្ចប់យូរទៅហើយក្តី (កាលពីឆ្នាំ ២០០៩ ) ។ ហើយអ្នកទទួលផលទាំងអស់សុទ្ធតែបានយកចំណេះដឹងពីវគ្គបណ្តុះបណ្តាលទៅ ប្រើប្រាស់ក្នុងគ្រួសារ ដើម្បីអនុវត្តផលិតជីធម្មជាតិទៅតាមសមត្ថភាព និងលទ្ធភាពរបស់គ្រួសារម្នាក់ៗដែលអាចធ្វើបានដែលស្តែងចេញជាលទ្ធផលក្នុង១ឆ្នាំបានប្រមាណពី ២ តោន ទៅ ៤ តោនជីធម្មជាតិ ។

វិធីសាស្រ្តបណ្តុះបណ្តាលរបស់គ្រូ បានធ្វើអោយសិក្ខាកាមចាប់អារម្មណ៍ និងទាក់ទាញទឹកចិត្តចង់ចូលរួមមិនមានការធុញទ្រាន់ រួមមានការពន្យល់ ការបំផុសគំនិត ការប្រើប្រាស់ រូបភាពបង្ហាញ ការពិភាក្សាក្រុម ។ល។ ចំពោះអាកប្បកិរិយាគ្រូវិញ ក្រុមពិភាក្សាបានអោយដឹងថា គាត់ស្លូតសុភាពរាបសារ មានទំនាក់ទំនងល្អ និងស្និទ្ធស្នាលជាមួយអ្នកភូមិ ដែលធ្វើអោយមានការចូលរួមកាន់តែច្រើនពីសំណាក់សិក្ខាកាម ក៏ដូចជាអ្នកភូមិដ៏ទៃទៀត ក្នុងសហគមន៍ ។

ជារួមផ្អែកតាមយោបល់ក្រុមពិភាក្សា វគ្គនេះពិតជាបានឆ្លើតបទៅនឹងសេចក្តីត្រូវការចាំបាច់ចំពោះមុខរបស់សិក្ខាកាម ដោយពួកគាត់ជាកសិករដែលប្រកបរបរកសិកម្ម ជីជាបញ្ហាចំបងក្នុងការបង្ករបង្កើនផល ហើយការប្រើប្រាស់ជីធម្មជាតិ វានឹងធ្វើអោយដីធូរ ដីមានគុណភាពកាន់តែល្អ និងម្យ៉ាងទៀតស្រូវ និង ដំណាំផ្សេងៗ មានទិន្នផលកើនឡើង ផលិតផលហូបមានឱជារសឆ្ងាញ់ និងមិនប៉ះពាល់ដល់សុខភាព ។ អ្វីដែលសំខាន់ទៀតនោះ គឺបទពិសោធន៍ ចំណេះដឹង និងជំនាញដែលពួកគាត់ទទួលបាន នៃការរួមចំណែកធ្វើឱ្យបរិមាណ ផលិតផលស្រូវ និងដំណាំរួមផ្សំផ្សេងៗរបស់ពួកគាត់មានការកើនឡើង និងមានគុណភាពកាន់តែប្រសើរជាងមុន ។ ម្យ៉ាងទៀតមកដល់សព្វថ្ងៃពួកគាត់បន្ថយការប្រើប្រាស់ជីគីមីបាន មួយកំរិតធំ ។

**លទ្ធផលទី២ : ជ្រើសរើសកសិករ បណ្តុះបណ្តាលឱ្យក្លាយជា ភ្នាក់ងារចិញ្ចឹមសត្វភូមិ**

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | **បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក ៧វគ្គ (១វគ្គ ២០នាក់/៣ថ្ងៃ)** មានអ្នកចូលរួមសរុប ចំនួន ១៤០ នាក់ ក្នុងនោះស្រី ៤២ នាក់ ដែលអនុវត្តក្នុង ០៧ ឃុំគោលដៅ រួមមាន: ឃុំបាស្រែ, ឃុំព្រៃស្លឹក, ឃុំរនាម, លាយបូរ, ញ៉ែងញ៉ង, ត្រពាំងក្រញូង និងឃុំស្រែរនោង។ | បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូកសំរេចបាន ៧វគ្គ (១វគ្គ ២០នាក់/៣ថ្ងៃ) មានអ្នកចូលរួមសរុប ចំនួន ១៤៤ នាក់ ក្នុងនោះស្រី ៦៥ នាក់ ដែលអនុវត្តក្នុង ០៧ ឃុំគោលដៅ ។ |

**ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល**

| |
|---|
| លទ្ធផល ជ្រើសរើសកសិករ បណ្តុះបណ្តាលឱ្យក្លាយជាភ្នាក់ងារចិញ្ចឹមសត្វភូមិ អនុវត្តសំរេចបាន ១00% តាមការគ្រោទុកក្នុងអនុកិច្ចសន្យា ។ ប៉ុន្តែទោះជាយ៉ាងនេះក្តីតាមរបាយការណ៍បញ្ចប់គំរោង បានបង្ហាញឱ្យឃើញថា អ្នកចូលរួមសរុបមានការកើនលើសពីការគ្រោងប្រមាណ ៣% រីឯស្ត្រីក៏មានការកើនលើសពីការគ្រោងទុកចំនួនប្រមាណ ៥៥% ផងដែរ ។ ជារួមតាមការពិនិត្យឯកសារអនុកិច្ចសន្យា និងរបាយការណ៍បញ្ចប់កិច្ចសន្យា លទ្ធផលនេះពុំមានទិន្នន័យ និងព័ត៌មានគ្រប់គ្រាន់ ដើម្បីធ្វើការវាយតំលៃគុណភាពនៃលទ្ធផលនេះបានលំអិតទេ ។ |

## លទ្ធផលទី៣:. ការបង្កើត/គាំទ្រភ្នាក់ងារចិញ្ចឹមសត្វភូមិ

### ផ្នែក-ក : ការសំរេចបានជាក់ស្តែងធៀបនឹងផែនការ

| ល.រ | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា | អ្វីដែលសម្រេចបានជាក់ស្តែង |
|---|---|---|
| ១.១ | **បង្កើត និង បណ្តុះបណ្តាលពេទ្យសត្វភូមិ ៣០នាក់ ក្នុងនោះស្រី ០៥ នាក់ :**<br>- វគ្គនិមួយៗមាន ៣០ ថ្ងៃ<br>- ដែលអ្នកចូលរួមទាំងនោះមកពី :<br>✓ ស្រុកទ្រាំង ៧ នាក់ : ឃុំធ្លក ២ នាក់ និងឃុំត្រឡាច ៥ នាក់<br>✓ ស្រុកសំរោង ១៨ នាក់: បឹងត្រាញ់ខាងត្បូង ១០ នាក់, លំចង់ ៥ នាក់ និងខ្វាវ ៣ នាក់<br>✓ ក្រុងដូនកែវ ៣ នាក់ : សង្កាត់បារាយណ៍ ១ នាក់ រកាក្រៅ ១ នាក់ និង រកាក្នុង ១ នាក់<br>✓ ស្រុកបូរីជលសារ ២ នាក់: មកពីឃុំដូងខ្ពស់ | - វគ្គបណ្តុះបណ្តាលបច្ចេកទេសពេទ្យសត្វភូមិសំរេចបាន ១ វគ្គ ស្មើរ ១០០% ធៀបនឹង ផែនការ មានអ្នកចូលរួមសរុបចំនួន ៣០ នាក់ ក្នុងនោះស្រី ២ នាក់ ។<br>- វគ្គនិមួយៗមាន ៣០ ថ្ងៃ |

### ផ្នែក-ខ : ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

| |
|---|
| លទ្ធផល ការបង្កើត/គាំទ្រភ្នាក់ងារចិញ្ចឹមសត្វភូមិ : អនុវត្តសំរេចបាន ១០០% តាមការគ្រោងទុកក្នុងអនុកិច្ចសន្យា ។ ប៉ុន្តែទោះជាយ៉ាងនេះក្តីតាមរបាយការណ៍បញ្ចប់គំរោង បានបង្ហាញឱ្យឃើញថា អ្នកចូលរួមជាស្ត្រីបានប្រមាណ ៤០% ធៀបនឹងផែនការគ្រោងទុក។ ជារួមតាមការពិនិត្យឯកសារអនុកិច្ចសន្យា និងរបាយការណ៍បញ្ចប់កិច្ចសន្យា លទ្ធផលនេះពុំមានទិន្នន័យ និងព័ត៌មានគ្រប់គ្រាន់ដើម្បីធ្វើការវាយតំលៃគុណភាពនៃលទ្ធផលនេះបានលំអិតទេ ។ |

## ២.២. ការវាយតម្លៃលើការសម្រេចបាននូវ អត្ថប្រយោជន៍បឋម និង លទ្ធផល នៃអនុកិច្ចសន្យា

### ផ្នែក-ក: ការវាយតំលៃការសម្រេចបានរបស់ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា (សំនួរវាយតម្លៃទី២)

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា (១) | ស្ថានភាពជាក់ស្តែងនៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| - កសិករចំនួន ៣០០ នាក់ ក្នុងនោះស្រី ៩០ នាក់ ៧ ឃុំ ក្នុង ៤ ស្រុកគោលដៅ បានទទួលចំណេះដឹងអំពី បច្ចេកទេសផលិតកម្មដំណាំស្រូវ ។ | កសិករសរុបចំនួន ៣០២ នាក់ ក្នុងនោះស្រី ១៤១ នាក់ បានទទួលការបណ្តុះបណ្តាលអំពីបច្ចេកទេសផលិតកម្ម ដំណាំស្រូវនៅក្នុង ១០ ឃុំគោលដៅ (របាយការណ៍បញ្ចប់ ) ។<br>- តាមការផ្ទៀងផ្ទាត់ឯកសារអនុកិច្ចសន្យា និង របាយការណ៍បញ្ចប់គំរោងឃើញថា លទ្ធផលសំរេចបាន អ្នកចូលរួមជាស្ត្រីមានការកើនឡើង ៥៧%ធៀបនឹងផែនការគ្រោងអ្នកចូលរួមជាស្ត្រី ។<br>- ម្យ៉ាងទៀត ផ្អែកតាមព័ត៌មានដែលប្រមូលបានពីថ្នាក់មន្ទីរបញ្ជាក់ថា វគ្គបណ្តុះបណ្តាលទាំងនេះអនុវត្តតែក្នុង ៧ ឃុំគោលដៅទេ មិនមែន ១០ ឃុំគោលដៅដូចក្នុងរបាយការណ៍បញ្ចប់គំរោងឡើយ ។ បញ្ហានេះ ជាចំណុចខ្វះខាតរបស់អ្នកសរសេររបាយការណ៍តែប៉ុណ្ណោះ ។ |
| - កសិករចំនួន ១២០នាក់ ក្នុងនោះស្រី ៣៦នាក់ ៥ឃុំ ក្នុង ២ ស្រុកគោលដៅ បានទទួលចំណេះដឹង អំពីបច្ចេកទេសដំណាំបន្លែតាមរយៈការបណ្តុះ បណ្តាលចំនួន ៦វគ្គ និងការធ្វើបង្ហាញចំនួន ៣០ បង្ហាញ។ | កសិករសរុបចំនួន ១២១ នាក់ ក្នុងនោះស្រី ៣៥ នាក់ នៅក្នុង ០៦ ឃុំគោលដៅ បាទទួលការបណ្តុះបណ្តាល និងធ្វើបង្ហាញដំណាំបន្លែ ចំនួន ៣០ សួន។<br>ផ្អែកតាមព័តិមានដែលប្រមូលបាន ពីថ្នាក់មន្ទីរបញ្ជាក់ថា វគ្គបណ្តុះបណ្តាលទាំងនេះអនុវត្តតែក្នុង ៥ ឃុំគោលដៅទេ មិនមែន ០៦ ឃុំ គោលដៅដូចក្នុងរបាយការណ៍ បញ្ចប់គំរោងឡើយ។ បញ្ហានេះ ជាចំណុចខ្វះខាតរបស់អ្នកសរសេររបាយការណ៍ ប៉ុណ្ណោះ ។ |
| - កសិករចំនួន ៣០០នាក់ ក្នុងនោះស្រី ៩០ នាក់ មកពី ៩ ឃុំ ក្នុងស្រុកគោលដៅទាំង ៥ បានទទួលចំណេះដឹង បច្ចេកទេសការផលិតជីធម្មជាតិ តាមរយ:ការបណ្តុះបណ្តាល ចំនួន ១០ | - កសិករសរុបចំនួន ៣០៦ នាក់ក្នុងនោះ ស្រី ១២៦ នាក់ បានទទួលការបណ្តុះបណ្តាលអំពីបច្ចេកទេសការផលិតជីធម្មជាតិ នៅក្នុង ១០ ឃុំគោលដៅ និងធ្វើបង្ហាញការផលិតជីធម្មជាតិ |

| | |
|---|---|
| វគ្គ និង ការធ្វើបង្ហាញចំនួន ៧១ បង្ហាញ។ | ៧១ រោង។<br>- តាមការពិភាក្សាក្រុម ពួកគាត់ស្ទើរតែទាំងអស់បញ្ជាក់ថា ពួកគាត់ ពេញចិត្តនឹងវគ្គបណ្តុះបណ្តាកនេះណាស់ ហើយវគ្គបណ្តុះបណ្តាល ការផលិតជីធម្មជាតិនេះ ពិតជាបានឆ្លើយតបទៅ នឹងតំរូវការជាក់ស្តែងរបស់ពួកគាត់ និងសហគមន៍ ពីព្រោះពួក គាត់ជាកសិករ ជីវិតរស់នៅអាស្រ័យដោយធ្វើស្រែចំការ ហើយ ជីធម្មជាតិ ជាអាហារបំប៉នមិនអាចខ្វះបាន លើដំណាំដែលពួក គាត់បង្ករបង្កើនផល។ លើសពីនេះទៀត លោកអ៊ីម្នាក់ក្នុង ចំណោមអ្នកចូលរួមក្នុងក្រុមពិភាក្សាបានបញ្ជាក់ថា គាត់ប្រើ ជីធម្មជាតិលើដំណាំស្រូវរបស់គាត់ឆ្នាំកន្លងមក ឃើញថាទិន្នផល ស្រូវកើនលើសពីធម្មតា គ្រាប់ស្រូវមានគុណភាពល្អ មានទម្ងន់ ភ្លឺរលោងបាយហូបមានឱជារសឆ្ងាញ់ជាងស្រូវប្រើជីគីមី។<br>- មកដល់ពេលនេះ វគ្គបណ្តុះបណ្តាលបានបញ្ចប់ជាងមួយឆ្នាំមក ហើយ តាមការសង្កេតនៅតំបន់គោលដៅឃើញថា ជាទូទៅកសិករក្នុងភូមិ បានសន្សំជីធម្មជាតិស្ទើរតែគ្រប់គ្រួសារ ហើយកសិករភាគច្រើនមានរោងទុកដាក់ត្រឹមត្រូវ និងមួយចំនួនទៀត បានសន្សំជី ដោយគរពំនូកលាមកសត្វ លាយឡំនឹងសំរាមដាក់ ក្រោមម្លប់ឈើ និងដាក់កណ្តាលវាលក្បៀនរបងលំនៅដ្ឋាន ដោយគ្រាន់តែយកធាងត្នោតព័ទ្ធជុំវិញតែប៉ុណ្ណោះ។ *អ្វីដែលគួរ ឱ្យចាប់អារម្មណ៍ ក្នុងមួយរដូវពួកគាត់ផលិតជីបានពី ២ តោន ទៅ ៤ តោន ក្នុង ១ គ្រួសារ ។ ពួកគាត់មានទឹកចិត្តរីករាយ ដោយឆ្នាំនេះពួកគាត់ពុំមានជួបការលំបាកអំពីបញ្ហាខ្វះថវិកា សំរាប់ចំណាយទៅលើការទិញជីគីមីដូចបណ្តាឆ្នាំកន្លងមក ។*<br>- ការសាងសង់រោងជី ហាក់បីដូចជាធូរលុងបន្តិច ភ្នាក់ងារអនុវត្ត មិនបានតំរូវឱ្យសាងសង់ទៅតាមបទដ្ឋានបច្ចេកទេស |

| | |
|---|---|
| | ពេកទេ ធ្វើយ៉ាងណាឱ្យកើតជារោង តែប៉ុណ្ណោះ ។<br>- កំរិតនៃការយល់ដឹងរបស់អ្នកទទួលផលលើបច្ចេកទេសផលិតជីធម្មជាតិ មានភាពកាន់តែប្រសើរ បន្ទាប់ពីពួកគាត់បានឆ្លងកាត់ វគ្គបណ្តុះបណ្តាល និងធ្វើបង្ហាញអំពីបច្ចេកទេសផលិជីធម្មជាតិ ជាក់ស្តែងកន្លងមក ។ *ប្រការដែលគួរចាប់អារម្មណ៍ពួកគាត់ដែល បានចូលរួមក្នុងក្រុមពិភាក្សានៅចងចាំទ្រឹស្តី និងរបៀបសន្សំជី ធម្មជាតិ អាចរៀបរាប់ឡើងវិញបានទាំងអស់ ។* |
| - កសិករចំនួន ៣០ នាក់ ក្នុងនោះស្រី ៥ នាក់ ៩ ឃុំ ក្នុង ៤ ស្រុកគោលដៅបានទទួលការបណ្តុះបណ្តាលអំពីវគ្គបច្ចេកទេសភ្នាក់ងារពេទ្យសត្វភូមិ និង មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការផ្តល់សេវាកម្មផ្នែកការពារ និង ព្យាបាលជំងឺសត្វ និងការចិញ្ចឹមសត្វ។ ពេទ្យសត្វភូមិ ដែលបានបណ្តុះបណ្តាលរួច ចំនួន ៦០ នាក់ បានទទួលការពង្រឹងសមត្ថភាពតាមរយៈប្រជុំពង្រឹង ដើម្បីផ្លាស់ប្តូរបទពិសោធន៍ក្នុងការការពារ ព្យាបាលជំងឺ និងការចិញ្ចឹម សត្វ។ | - កសិករចំនួន ៣០ នាក់ ក្នុងនោះស្រី ៣ នាក់ បានទទួលការបណ្តុះបណ្តាលបច្ចេកទេស ធ្វើជាភ្នាក់ងារពេទ្យសត្វភូមិ ។<br>- ពេទ្យសត្វដែលបានទទួលការបណ្តុះបណ្តាលចំនួន ៦០ នាក់ បាន ចូលរួមការប្រជុំពង្រឹងសមត្ថភាព និងផ្លាស់ប្តូរបទពិសោធន៍ របាយការណ៍ត្រួតពិនិត្យអនុកិច្ចសន្យា បានបង្ហាញថា មាន កសិករស្ម័គ្រចិត្តចូលរួម នៅក្នុងវគ្គបណ្តុះបណ្តាលនេះទោះបីជា គ្មានសំភារៈបណ្តុះបណ្តាល សំរាប់ពួកគាត់ក៏ដោយ ។ |
| - កសិករចំនួន ១៤០ នាក់ ក្នុងនោះស្រី ៤២ នាក់ ៧ ឃុំ ក្នុង ៣ ស្រុកគោលដៅ បានទទួលចំណេះដឹងមូលដ្ឋាន ស្តីអំពីបច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ។ | - វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូកចំនួន ០៧ វគ្គត្រូវបានអនុវត្តប្រកបដោយជោគជ័យ ។<br>- កសិករចំនួន ១៤៤ នាក់បានទទួលការបណ្តុះបណ្តាល និងមានចំណេះដឹង អំពីបច្ចេកទេសចិញ្ចឹមជ្រូក ។ |

**ផ្នែក-ខ: ការវាយតំលៃការសម្រេចបានរបស់គោលបំណងបន្ទាន់របស់អនុកិច្ចសន្យា**

| ធាតុនៃគោលបំណងបន្ទាន់ (១) | ការសម្រេចបានជាក់ស្តែង នៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| នៅចុងឆ្នាំ ២០០៩ ទិន្នផលស្រូវ ដំណាំរួមផ្សំ និង ផលិតផលសត្វ ក្នុងគ្រួសារ និងសហគមន៍ ត្រូវបានកើនឡើង តាមរយៈ ការបណ្តុះបណ្តាល | គោលបំណងបន្ទាន់នៃអនុកិច្ចសន្យារបស់មន្ទីរកសិកម្មកំណត់ឡើងក្នុងអត្ថន័យទូលំទូលាយពេក ហើយពុំបានសំដែងចេញនូវសូចនាករ ជាក់លាក់ណាមួយ សំរាប់ធ្វើការវាស់វែងនៅចុងបញ្ចប់ |

| | |
|---|---|
| ផ្សព្វផ្សាយ និងការធ្វើបង្ហាញ នូវបច្ចេកទេសកសិកម្ម សមស្រប ។ | នៃអនុកិច្ចសន្យា ។ ប៉ុន្តែទោះជាមានការរំពឹងទុកថា លទ្ធផល និងសកម្មភាពទាំងអស់នៃអនុកិច្ចសន្យា នឹងបានរួមចំណែកឆ្លើយតបណាមួយទៅនឹងគោលបំណងបន្ទាន់ក៏ដោយ ក៏ពុំអាចធ្វើអោយការវាយតំលៃគោលបំណងនេះថាបានសំរេចក្នុងកំរិតណាទេ ។ |

**ផ្នែក-គៈ សង្ខេបការវាយតម្លៃផលប្រយោជន៍ ជារួមដែលទទួលបាន**

| |
|---|
| ផ្អែកតាមព័តិមានដែលបានពីក្រុមពិភាក្សានៅមូលដ្ឋានបានបង្ហាញថា ពួកគាត់មានការពេញចិត្ត ចំពោះផលប្រយោជន៍ ដែលអនុកិច្ចសន្យាសំរេចបាន ដូចជា ចំណេះដឹង បទពិសោធន៍ និងបច្ចេកទេសថ្មីៗទៅលើការផលិតជីធម្មជាតិ ។ ពួក គាត់ទទួលស្គាល់ និងអះអាងថាអ្វីៗដែលពួកគាត់ទទួលបានពីវគ្គបណ្តុះបណ្តាល និង ការធ្វើបង្ហាញអំពីជីធម្មជាតិ វា ពិតជាមានសារៈប្រយោជន៍សំរាប់គ្រួសាររបស់ពួកគាត់ ។ ជាទូទៅការសន្សំជីធម្មជាតិ ពួកគាត់អនុវត្តជារៀងរាល់ថ្ងៃ ហាក់ដូចជាកាតព្វកិច្ចប្រចាំថ្ងៃក្នុងគ្រួសារ ជាក់ស្តែងពួកគាត់បានសន្សំជីធម្មជាតិបានចំនួនពី ២ តោន ទៅ ៤ តោនក្នុង ១ គ្រួសារក្នុង ១ ឆ្នាំ សំរាប់ប្រើប្រាស់ក្នុងការបង្កបង្កើនផលធ្វើឱ្យពួកគាត់កាត់បន្ថយការប្រើប្រាស់ជីគីមីបានមួយកំរិតធំ ។ ជាងនេះទៅទៀតពួកគាត់បានប្តេជ្ញាចិត្តថា នឹងផលិតជីធម្មជាតិនេះឱ្យបានកាន់តែច្រើន អាចប្រើប្រាស់គ្រប់គ្រាន់ ដើម្បីឈានទៅកាត់ផ្តាច់ការប្រើប្រាស់ជីគីមី ទាំងស្រុងនៅពេលអនាគត ។ |

## ករណីសិក្សាទី ១ : អ្នកទទួលផលពីអនុកិច្ចសន្យា



លោកអ៊ុំ នាក់ ហ៊ុម មានអាយុ ៥៧ឆ្នាំ ប្រពន្ធឈ្មោះ ជួប យឺន អាយុ ៥៩ ឆ្នាំ មានកូន ៦នាក់ ក្នុងនោះ ៥ នាក់ បានរៀបការហើយ និងកូនស្រី ១នាក់ រស់នៅក្នុងបន្ទុក ព្រមទាំងម្តាយម្នាក់ងងឹតភ្នែកអាយុ ៧៩ ឆ្នាំ រស់នៅភូមិ ចមពល ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ។ គាត់ជាកសិករឧស្សាហ៍ព្យាយាមម្នាក់ក្នុងចំណោមកសិករក្នុងភូមិទាំងមូល។ គាត់រកប្រាក់ ចំណូលបានពីការធ្វើស្រែចំការ ដាំដំណាំរួមផ្សំ ចិញ្ចឹមមាន់ និងចិញ្ចឹមត្រី ដែលក្នុង ១ ឆ្នាំ បានប្រហែលជា ១,៥-២ លានរៀល។ គាត់មាន ប្រសាសន៏ទាំងទឹកមុខញញឹមញញែមថាៈ "វគ្គបណ្តុះ បណ្តាលអំពីជីធម្មជាតិ នេះមានសារៈសំខាន់ខ្លាំងណាស់សំរាប់គាត់ ដោយបានទទួល នូវចំណេះដឹង និងវិធីសាស្រ្តជាច្រើនអំពីការផលិតជី និងរបៀបប្រើប្រាស់ជី"។ លោកអ៊ុំបានបញ្ជាក់ថា *"ខ្ញុំរោងជីនេះធ្វើ អស់ទឹក ប្រាក់ហែលជា ៦ ម៉ឺនរៀល ប៉ុន្តែក្នុងពេលបណ្តុះបណ្តាលខ្ញុំចាប់ឆ្នោតបាន ការធ្វើរោងជីបង្ហាញ ទើបមន្ទីរកសិកម្ម ខេត្តបានផ្តល់ថវិកា ចំនួន ១៥ដុល្លារ និង ស្លាក១ ក្នុងពេលធ្វើរោងរួច"។ ហើយក្នុង ១ ឆ្នាំ ខ្ញុំអាចសន្សំជីបាន ពី ៣ តោនទៅ ៤ តោន និងចេះធ្វើមេជី IXM ដោយមិនប្រើជីគីមី។* ជាពិសេសទៀតដីស្រែរបស់គាត់ប្រហែល ៨៥អា គាត់ទទួលបានផលស្រូវប្រហែល ៨០-៩០ ថាំងក្នុង ១រដូវ ហើយសល់ពីហូបគាត់លក់បាន ៣០០-៤០០ គ.ក្រ ។ ចាប់ តាំងពីពេលគាត់ចេះធ្វើជីធម្មជាតិមក គាត់ពុំបានចំណាយថវិកាទិញជីគីមីពីទីផ្សារទេ ។ ពីមុនគាត់បានទិញជីគីមី ៣បាវ ក្នុង ១ រដូវ តែមកដល់ពេលនេះ



គាត់អត់ទិញជីគីមីទៀតទេ ធ្វើឱ្យគាត់សល់ថវិកាពី ៣០-៣៥ម៉ឺនរៀល សំរាប់ប្រើ ប្រាស់លើការចំណាយផ្សេងៗ ។ រីឯកសិករជិតខាងពួកគេពុំទាន់ធ្វើរោង សំរាប់សន្សំជីនៅឡើយទេ គឺពួកគេភាគច្រើនយកធាងត្នោតធ្វើជាបង្គោល បាំងពុំមានដំបូល ហើយពុំបានស្រោចទឹកនៅពេលរាំងស្ងួតទៀត ។ ពួកគេ សន្សំជីពុំបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ជាហេតុបណ្តាលឱ្យជីបាត់បង់នូវគុណភាព។

ការផ្លាស់ប្តូរជាវិជ្ជមានមួយទៀតសំរាប់គាត់ បន្ទាប់ពីចូលរួមសកម្មភាពក្នុងគំរោង គឺគាត់កាន់តែមានការងារច្រើន ដោយសារគាត់បានសន្សំជីធម្មជាតិពីប្រភពផ្សេងៗក្រៅលំនៅដ្ឋាន ។ ហេតុនេះហើយទើបគាត់មាន ជីគ្រប់គ្រាន់សំរាប់ប្រើប្រាស់ពេញមួយឆ្នាំ។

ចុងបញ្ចប់គាត់បានប្តេជ្ញាចិត្តដោយទឹកចិត្តរីករាយក្នុងការបន្តសកម្មភាពធ្វើជីធម្មជាតិ និងការប្រើប្រាស់វាតទៅ ទៀតទោះបីជាគាត់មិនបានទទួលអ្វីផ្សេងៗទៀតពីគំរោងក៏ដោយ។ គាត់បន្ថែមទៀតថា ការសន្សំជីធម្មជាតិមាន លក្ខណៈងាយស្រួលណាស់សំរាប់គាត់ គឺគ្រាន់តែយកលាមកសត្វ សំរាម ស្លឹកឈើមកគរ ហើយស្រោចទឹកតែប៉ុណ្ណោះវាជាការស្រេច ។ គាត់បានសំណូមពរអោយអង្គការ ឬកម្មវិធីនានាជួយអភិវឌ្ឍន៏បន្តទៀតនៅមូលដ្ឋានរបស់គាត់ ។

## ករណីសិក្សាទី ២ : អ្នកមិនបានទទួលផល



អ្នកមីង សុខ ម៉ាលី មានអាយុ ៤៦ ឆ្នាំ ជាស្ត្រីមេម៉ាយ មានកូនក្នុងបន្ទុក ២ នាក់ ស្ថិតក្នុងភូមិប្រាំបីមុំ ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ ។ គាត់ជាគ្រូបង្រៀននៅអនុវិទ្យាល័យប្រាំបីមុំ ។ បន្ទាប់ពីគាត់ចុះពីបង្រៀននៅសាលា គាត់បានប្រកបរបរធ្វើស្រែ ដាំបន្លែ និងចិញ្ចឹមសត្វ ដើម្បីរកចំណូលបន្ថែម។

អ្នកមីង សុខ ម៉ាលី គាត់មិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល និង ការធ្វើបង្ហាញអំពីជីធម្មជាតិដែលជាគំរោងរបស់ គ.អ.ជ.ខ ខេត្តតាកែវទេ តែគាត់បានស្គាល់ និងនៅជិតអ្នកទទួលផលពីគំរោង ដូចជាឈ្មោះ ដុំ ដេន, ង៉ែត សុខខេន, ចែម រដ្ឋា ។ល។ គាត់មិនត្រូវបានគេជ្រើសរើសអោយចូលរួមក្នុងវគ្គនេះទេ ដោយសារគាត់ជាគ្រូបង្រៀននៅអនុវិទ្យាល័យ ។ គាត់បានបង្ហើបអោយដឹងថា វគ្គបណ្តុះបណ្តាលអំពីការផលិតជីធម្មជាតិ និងធ្វើបង្ហាញជីធម្មជាតិនេះ មានសារៈសំខាន់ណាស់សំរាប់អ្នកជិតខាង ដែលបានចូល រួមក្នុងវគ្គនេះ ព្រោះពួកគេទទួលបានចំណេះដឹង នឹងជំនាញបច្ចេកទេសផលិតជី ការថែរក្សាទុកដាក់ ព្រមទាំងដឹង អំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ជីធម្មជាតិ ។ គាត់បានបញ្ជាក់បន្ថែមទៀតថា : មកដល់ពេលនេះ អ្នកដែលទទួល ការបណ្តុះបណ្តាលអំពីការផលិតជីធម្មជាតិ ពួកគេបានធ្វើរោងជីគ្រប់ៗគ្នា ហើយផលិតជីធម្មជាតិបានច្រើនជាងមុន ប្រកបដោយគុណភាពខ្ពស់ ហើយការប្រើប្រាស់ជីនេះ ធ្វើអោយដំណាំស្រូវ បន្លែ របស់ពួកគេបានល្អទាំងបរិមាណ និង គុណភាព ព្រមទាំងបានរួមចំណែកកាត់ បន្ថយ នូវការប្រើប្រាស់ជីគីមីបានមួយចំនួន ធ្វើឱ្យសល់ថវិកាពីការទិញជីគីមី សំរាប់ប្រើ ប្រាស់លើការចំណាយផ្សេងៗ បានមួយចំនួន។ គាត់បានលើកឡើងទៀតថា: ឥឡូវនេះពួកគេប្រើប្រាស់ជីគីមីបន្ទាប់ បន្សំតែប៉ុណ្ណោះ ពួកគេពុំមាន ជួបការលំបាកក្នុងការរកថវិកា សំរាប ទិញជីគីមី ដូចមុនទៀតទេ។ ម្យ៉ាងវិញទៀត ទិន្នផលស្រូវ បន្លែ និងបរិមាណផលិតផលរបស់ពួកគេ បានកើន និងមានគុណភាពល្អ ជាងមុន ធ្វើឱ្យសុខភាពក្នុងក្រុមគ្រួសារ របស់ពួកគេកាន់តែប្រសើរ ។

*ដោយឃើញអ្នកជិតខាងធ្វើបានល្អ អ្នកមីង សុខ ម៉ាលីមានប្រសាន៍ថា: ខ្ញុំក៏ចាប់ផ្តើមធ្វើរោងសន្សំជីនេះដែរ ដោយខ្ញុំបានទៅសួរនាំអំពីរបៀប និងបច្ចេកទេសធ្វើពីអ្នកដែលបានទទួលការបង្ហាញ ខ្ញុំបានប្រើប្រាស់សំភារៈដែលមាន ស្រាប់ និងថវិកាតិចតួចសំរាប់ធ្វើរោងជីនេះ ។ ខ្ញុំអាចសន្សំជីបានច្រើនជាងមុនប្រកបដោយគុណភាព សំរាប់យកទៅ ដាក់ស្រូវ បន្លែ ធ្វើឱ្យផលិតផលមានគុណភាពល្អ និងកើនជាងមុន ។* ព្រមជាមួយនោះផងដែរ គាត់បានសំដែងអាការៈ សប្បាយរីករាយ និងពេញចិត្តភោគផលដែលទទួលបានពីការប្រើប្រាស់ជីធម្មជាតិនេះណាស់ ដោយទាំងបានអញ្ជើញ ក្រុមការងារយើងទៅមើលសួនបន្លែរបស់គាត់ដែលស្ថិតនៅក្បែរនោះ ទាំងបញ្ចេញនូវស្នាមញញឹមមិនដាច់។ និង បានប្តេជ្ញាចិត្តបន្តការសន្សំជីធម្មជាតិនេះតទៅទៀត ទោះបីពុំមានគំរោងជួយ ដល់គាត់ក៏ដោយ ។ គាត់បានសំណូមពរ អោយកម្មវិធី អង្គការនានា មកជួយអភិវឌ្ឍន៍នៅមូលដ្ឋានរបស់គាត់ ។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤)

### ផ្នែក-កៈ ភាពជាប់ពាក់ពន្ធ័នៃការរៀបចំអនុកិច្ចសន្យាផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់

| ល.រ (១) | ធាតុ (២) | ទំនាក់ទំនងតក្កភាព (៣) | បរិយាយច្បាស់លាស់ (៤) | សង្ខេបការវាយតម្លៃ (៥) |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៤ | ៥ | បណ្តាសកម្មភាពដែលបានលើកឡើង ពិតជាមានទំនាក់ទំនងតក្ក ជាមួយនឹងលទ្ធផល ដែលបានសរសេរ នៅក្នុងឯកសារអនុកិច្ចសន្យា ។ ជាក់ស្តែងលទ្ធផល ទី ១ ទាក់ទិននឹងកសិករទទួលបានការបណ្តុះបណ្តាល ពីបច្ចេកទេសកសិកម្ម និងការបង្ហាញ រួមមាន សកម្មភាពជាក់លាក់ដូចជា វគ្គបណ្តុះបណ្តាលបច្ចេក ទេសដំណាំស្រូវចំនួន ១០ វគ្គ វគ្គបណ្តុះបណ្តាល បច្ចេកទេសដំណាំបន្លែចំនួន ៦ វគ្គ ការធ្វើបង្ហាញសួន បន្លែចំនួន ៣០ បង្ហាញ វគ្គបណ្តុះបណ្តាលបច្ចេកទេស ផលិតជីធម្មជាតិចំនួន ១០ វគ្គ និងធ្វើបង្ហាញជី ធម្មជាតិចំនួន ៧១ រោង។ ទាំងនេះឆ្លុះបញ្ចាំងថា សកម្មភាពទាំងនេះ មានទំនាក់ទំនងតក្កជាមួយនឹង លទ្ធផលខាងលើ ហើយបានសរសេរយ៉ាងច្បាស់ ។<br>សកម្មភាពនិមួយៗបានសរសេរបង្ហាញច្បាស់លាស់ដោយមានចំនួន វគ្គបណ្តុះបណ្តាល និងចំនួនសិក្ខាកាមដែលត្រូវចូលរួម និងតំបន់គោលដៅដែលត្រូវគ្របដណ្តប់ (ដូចជាស្រុក ឃុំ ) ។<br>សកម្មភាពដ៏ទៃទៀតនៅក្រោមលទ្ធផលបន្ត |

| | | | | |
|---|---|---|---|---|
| | | | | បន្ទាប់ទៀត (លទ្ធផលទី ២ និងទី ៣ ) ត្រូវបានសរសេរក្នុងបែបបទដូចគ្នានឹងលទ្ធផលទី ១ ដែរ ។ សកម្មភាពនិមួយៗមានទំនាក់ទំនងតក្ក ហើយនឹងត្រូវបានបរិយាយច្បាស់លាស់ ដូចដែលមានសរសេរនៅក្នុងអនុកិច្ចសន្យា ។ |
| ២ | លទ្ធផល | ៤ | ៥ | លទ្ធផលនិមួយៗត្រូវបានសរសេរបរិយាយច្បាស់លាស់ ដោយមានសូចនាករ ជាក់លាក់ និងអាចវាស់វែងបាន ។ ជាងនេះទៅទៀត លទ្ធផលនិមួយៗផ្សារភ្ជាប់ គ្នាល្អ ហើយបំពេញឱ្យគ្នាទៅវិញទៅមក និងរួមគ្នាបំពេញឱ្យគោលបំណងបន្ទាន់ ។ ទោះបីជាយ៉ាងនេះក៏ដោយលទ្ធផលទាំងនេះ នៅមិនអាចធ្វើឱ្យគោលបំណងបន្ទាន់សំរេចបាននៅឡើយ ។ |
| ៣ | - គោលបំណងបន្ទាន់ *(គោលបំណងស្ថិតក្នុងចំណុច "ខ" នៃផ្នែកទី ៣)* | ៤ | ៣ | គោលបំណងបន្ទាន់ ត្រូវបានផ្តល់អត្ថន័យយ៉ាងច្បាស់ ប៉ុន្តែគោលបំណងបន្ទាន់នេះ មានកំរិតទូលាយពេក ជាហេតុធ្វើឱ្យអនុកិច្ចសន្យានេះពិបាកនឹងសំរេចគោល បំណងបន្ទាន់នេះ ក្នុងកាលៈទេសៈបែបនេះ ។ |
| ៤ | - ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា *(ចំណុច "គ" នៃផ្នែកទី ៣)* | ៤ | ៤ | ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យាត្រូវបានបរិយាយច្បាស់ ហើយមានទំនាក់ទំនងទៅនឹងលទ្ធផល និងសកម្មភាពនៃអនុកិច្ចសន្យា ។ ស្ថានភាពចុងបញ្ចប់នេះបានឆ្លុះបញ្ចាំងនូវសមិទ្ធិផលដែលសំរេចបាន នៅក្នុងកំរិតលទ្ធផល ។ ប៉ុន្តែវាមិនបានឆ្លុះបញ្ចាំងនូវស្ថានភាពចុងបញ្ចប់ ឬផលប៉ះពាល់ដែលអាចកើតមានឡើងនៅក្នុងកំរិតអ្នកភូមិ និងសហគមន៍ទេ ។ គ្មានសូចនាករជាក់លាក់ និងច្បាស់លាស់ណាមួយបង្ហាញថា សិក្ខាកាមបានយកចំណេះដឹង និងជំនាញ |

| | | | | |
|---|---|---|---|---|
| | | | | ដែលពួកគេទទួលបាន ទៅធ្វើជាប្រយោជន៍ក្នុងការធ្វើ ឱ្យប្រសើរឡើងនូវជីវភាពរបស់ពួកគាត់ទេ |
| ៥ | *លទ្ធផលអភិវឌ្ឍន៍/ផលប៉ះពាល់ រយៈពេលវែង: គោលដៅ និងគោល បំណងអភិវឌ្ឍន៍* | | | មិនអាចធ្វើការវាយតំលៃបាន ។ |

**ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខ័ណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារ:**

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.ជ.អ.ខ:** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | នៅមានកំរិត ទាមទារឱ្យមានការពង្រឹងបន្ថែម និងមានការគាំទ្រទាំងខាងបច្ចេកទេស ។ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យការអនុវត្តន៏របស់ភ្នាក់ងារអនុវត្តន៍ | សមស្រប។ គ្មានការប្រឈម និងឧបសគ្គដែលគួរឱ្យកត់សំគាល់ទេ ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ អនុកិច្ចសន្យា | ធ្វើតាមទំលាប់ និងនិតិវិធីដែលបានធ្វើ ។ ការកត់ត្រា និងទុកដាក់ ឯកសារ គួរតំរូវឱ្យមានការកែលំអ។ |
| **ពីខាងភាគីអនុវត្តន៏កិច្ចសន្យា:** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | មានធនធានមនុស្ស មានជំនាញ និងបទពិសោធន៏ គ្រប់គ្រាន់ច្បាស់លាស់ ។<br>ប៉ុន្តែការផ្សព្វផ្សាយ/បណ្តុះបណ្តាលខ្លះនៅមូលដ្ឋាន មិនទាន់មានគុណភាពខ្ពស់នៅឡើយ ។ |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | ការអនុវត្តសកម្មភាព និងលទ្ធផលទាន់ពេលវេលា ដូចកាលវិភាគដែលបានគ្រោងទុក ទោះបីមានការកែប្រែ ពេលវេលាខ្លះៗក្នុងផែនការការងារប្រចាំខែក៏ដោយ ។ |
| ៦ | ការរាយការណ៏ការីកចំរើន និង ការកត់ត្រាឯកសារ | អនុវត្តតាមគោលការណ៏ណែនាំ |
| ៧ | ការគោរពតាមលក្ខ័ខណ្ឌកិច្ចសន្យា | គោរពបានល្អ ។ លក្ខ័ខណ្ឌកិច្ចសន្យាត្រូវបានបំពេញ |
| **ទាំងខាង គ.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យា:** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" (ចំណុច-ង ផ្នែកទី៣ ) និងបញ្ហាប្រឈម | ហានិភ័យនេះត្រូវបាន បញ្ជាក់យ៉ាងច្បាស់នៅ ក្នុងអនុកិច្ចសន្យា ប៉ុន្តែវានៅក្រៅការគ្រប់ គ្រងរបស់ភ្នាក់ងារអនុវត្តគំរោង ។ |
| ៩ | ការបញ្ជ្រាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | កិច្ចសន្យានេះបានយកចិត្តទុកដាក់លើកកំពស់យេនឌ័រ។ ការចូល |

| | | |
|---|---|---|
| | | រួមរបស់កសិករជាស្ត្រី នៅក្នុងវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក ដំណាំស្រូវ និងការផលិតជីធម្មជាតិ មានការកើនលើសពីផែនការគ្រោលទុក ។ ការចូលរួមនេះបូករួមទាំងស្ត្រីជាមេគ្រួសារទៀតផង។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ ( ចំណុច-ឆ ផ្នែកទី៣) | បញ្ហាការគ្រប់គ្រងធនធានធម្មជាតិក៏មានការលើកកំពស់ តំរូវឱ្យមានការដាំដុះដោយប្រើជីធម្មជាតិ និងមិនប្រើជីគីមី ។ នៅក្នុងបណ្តាវគ្គបណ្តុះបណ្តាល និងបង្ហាញ ក៏បានចូលរួមជាវិជ្ជមានទៅដល់ការយល់ដឹងពីការអភិរក្សបរិស្ថានផងដែរ ។ |
| ១១ | ការថែរក្សា (និរន្តភាព) ( ចំណុច-ជ ផ្នែកទី៣) | សកម្មភាព និងបច្ចេកទេសខ្លះៗដែលបានលើកឡើងដោយគំរោងត្រូវបានមើលឃើញថាត្រូវបានយកទៅអនុវត្តដោយកសិករ ហើយបានបន្តរហូតដល់ពេលក្រុមការងារចុះទៅធ្វើការវាយតំលៃដូចជារោងជី ។ ដូច្នេះនិរន្តរភាពរបស់ផ្នែកខ្លះៗនៃគំរោងត្រូវបានសំរេច ។ |

## ២.៤. សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី ៥)

<u>សេចក្តីសន្និដ្ឋានជារួម</u> :

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យានេះត្រូវបានអនុវត្តឡើងដូចការគ្រោងទុក ។ ភាគីអនុវត្តអនុកិច្ចសន្យាមានធនធានមនុស្សគ្រប់គ្រាន់ ទាំងសមត្ថភាពជំនាញ ទាំងស្មារតីទទួលខុសត្រូវ ដើម្បីអនុវត្តអនុកិច្ចសន្យាយ៉ាងមានប្រសិទ្ធភាព ។ សកម្មភាព និងលទ្ធផលដែលបានគ្រោងទុកត្រូវបានបញ្ចប់ស្របតាមផែនការការងារ ។ |
| ២ | សកម្មភាពរបស់អនុកិច្ចសន្យា និងអត្ថប្រយោជន៍ដែលសហគមន៍ទទួលបាន ត្រូវបានអ្នកទទួលផល និងអ្នកមិនទទួលផលអបអរសាទរ នៅក្នុងឃុំដែលគំរោងបានអនុវត្ត។ ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាត្រូវបាន សម្រេចទាំងស្រុងដូចការរំពឹងទុក ។ ជាក់ស្តែងលទ្ធផល និង ផលប្រយោជន៍ដែល ទទួលបានបន្ទាប់ពីការបញ្ចប់ អនុកិច្ចសន្យាជាយូរមកហើយនោះ ក៏នៅតែត្រូវបានក្រុមការងារសង្កេតឃើញក្នុងកំឡុងពេលធ្វើការវាយតម្លៃ មានដូចខាងក្រោមដូចជា :<br>ក) កសិករគោលដៅបន្តធ្វើរោង និងការសន្សំជីធម្មជាតិ ដោយប្រើប្រាស់ចំណេះដឹង ជំនាញ និងបច្ចេកទេសថ្មីដែលពួកគាត់បានទទួលពីវគ្គបណ្តុះបណ្តាល និងធ្វើបង្ហាញជីធម្មជាតិ។ |

| | |
|---|---|
| | ខ) ការសន្សំជីធម្មជាតិរបស់អ្នកទទួលផលពីគំរោង មានសន្ទុះកើនឡើងជាលំដាប់ ដែលក្នុងឆ្នាំកន្លងមក ពួកគាត់អាចផលិតបានពី ២ តោនទៅ ៤តោន ធ្វើអោយដំណាំដែលពួកគាត់បង្ករបង្កើនផលដូចជា ដំណាំស្រូវទទួលបានទិន្នផលខ្ពស់ ដីស្រែធូរមានគុណភាព បាយមានគុណភាពល្អ ហូបមានឱជារស់ឆ្ងាញ់ ជាពិសេសបរិស្ថានលំដ្ឋានស្អាត ។<br><br>គ) ម្យ៉ាងទៀតការប្រើប្រាស់ជីគីមី ត្រូវបានកាត់បន្ថយជាអតិបរិមាលើអ្នកទទួលផលពីគំរោង ដែលពីមុនមានគំរោងនេះ ពួកគាត់ប្រើជីគីមីពី ២ បាវ ៣ បាវ ទៅ ៤ បាវ ហើសព្វថ្ងៃនេះប្រើត្រឹមក៏រិត ១ បាវ ១,៥ បាវ ទៅ ២ បាវ តាមលំដាប់លំដោយលើផ្ទៃដីដដែល ។<br><br>ឃ) រោងជីធម្មជាតិសាងសង់មិនតាមបទដ្ឋានដែលបានកំណត់ ដែលជាហេតុធ្វើឱ្យបាត់នូវគុណភាព ប៉ុន្តែជាភាពជោគជ័យមួយដែរក្នុងការផ្តល់លទ្ធភាពដល់ពួកគាត់ធ្វើរោងបានគ្រប់គ្នា។<br><br>ង) មានតម្រូវការវគ្គបណ្តុះបណ្តាលអំពីការចិញ្ចឹមមាន់ ត្រី ដែលសំណូមពរដោយភាគច្រើនពីអ្នកចូលរួមពិភាក្សា ជាងនេះទៅទៀតក្នុងករណីមានបង្ហាញរោងជីធម្មជាតិជាបន្ត គំរោងគួរមានបំពង់ទីបទំហំ0,១០ម មួយកង់ប្រវែង ២ មសំរាប់កប់កណ្តាលពំនូកជីដើម្បីចាក់ទឹក ។<br><br>ដូច្នេះអនុកិច្ចសន្យានេះ បានទទួលនូវនិរន្តរភាពក្នុងសកម្មភាពរបស់ខ្លួនក្នុងក៏រិតខ្ពស់។ ប៉ុន្តែគំរាងបានចូល រួមចំណែកក្នុងក៏រិតតិចតួចទៅគោលដៅអភិវឌ្ឍន៏នៅក្នុងអនុកិច្ចសន្យា ហើយនិងគោលដៅក្នុងការកាត់បន្ថយ ភាពក្រីក្រ ។ |
| ៣ | ការជ្រើសរើសសិក្ខាកាម និងអ្នកទទួលផលនៅក្នុងអនុកិច្ចសន្យា អនុវត្តដោយភាគីអនុវត្តកិច្ចសន្យា តាមរយៈមេភូមិ ។ ទោះបីយ៉ាងនេះក្តី ក៏ភ្នាក់ងារអនុវត្តពុំបានចុះសិក្សាអំពីស្ថានភាពគ្រួសាររបស់អ្នកទទួលផលទាំងនោះដើម្បីធ្វើអោយមានការធានាថា អ្នកដែលមានតម្រូវការខ្លាំងបំផុតនឹងទទួលបានផលប្រយោជន៍ពីអនុកិច្ចសន្យា |
| ៤ | ក្នុងកំឡុងពេលអនុវត្តគំរោង ភ្នាក់ងារអនុវត្តបានចុះម្តងម្កាល ដើម្បីពិនិត្យមើលការសាងសង់រោងជី និងជំរុញឱ្យមានដំណើរការផលិតជីធម្មជាតិ ។ ប៉ុន្តែបន្ទាប់ពីគំរោងត្រូវបានបញ្ចប់ ការចុះត្រួតពិនិត្យក្រុមគោលដៅមិនត្រូវបានអនុវត្តទេ ដោយគ្មានថវិកាគាំទ្រ ។ |
| ៥ | ទីតាំងដែលគំរោងធ្វើសកម្មភាពមានភាពមិនស៊ីគ្នា រវាងទីតាំងដែលបានអនុវត្តជាក់ស្តែង និងទីតាំងដែលបានរាយការណ៍ក្នុងរបាយការណ៏បញ្ចប់គំរោង (ឧទាហរណ៏ :វគ្គដំណាំស្រូវអនុវត្ត 0៧ ឃុំគោលដៅ រាយការណ៏ ១0ឃុំ , វគ្គបន្លែ ៦ វគ្គអនុវត្ត ៥ឃុំគោលដៅ រាយការណ៏ ៦ឃុំគោលដៅ .....។ល។ |
| ៦ | អនុកិច្ចសន្យានេះមិនបានជួបប្រទះនូវ ឧបសគ្គ និងបញ្ហាប្រឈមគួរអោយកត់សំគាល់ទេ ។ |

**ចំណុចរៀនសូត្រ:**

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ដូចដែលបានសង្កេតឃើញក្នុងការវាយតម្លៃនេះ ផលប៉ះពាល់របស់អនុកិច្ចសន្យា និងនិរន្តរភាពរបស់លទ្ធផលនៅក្នុងអនុកិច្ចសន្យា អាចត្រូវបានសម្រេចបានក្នុងកំរិតខ្ពស់ ប្រសិនបើអនុកិច្ចសន្យាត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាព របស់ក្រុមគោលដៅដែលជាអ្នកទទួលផល ។ |
| ២ | ការបរិយាយច្បាស់លាស់នូវ "គោលបំណងបន្ទាន់ " ក្នុងកំរិតដែលអាចវាស់វែងបាន ជាការសំខាន់សម្រាប់ការកត់ត្រាទុក នូវលទ្ធផលរបស់អនុកិច្ចសន្យា និងផលប្រយោជន៍ដែលមាន ដើម្បីការវាយតម្លៃលទ្ធផល ។ |
| ៣ | ទោះបីជាអ្នកទទួលផល ត្រូវបានជ្រើសរើសតាមរយៈអាជ្ញាធរភូមិ (មេភូមិ) ហើយភ្នាក់ងារអនុវត្តបានចុះសិក្សាអំពីស្ថានភាពគ្រួសារជាក់ស្តែងរបស់អ្នកទទួលផលផងនោះ ជាការសំខាន់សំរាប់ការផ្តល់គំរោងនៅមូដ្ឋាន ដើម្បីធ្វើអោយមានការធានាថា អ្នកដែលមានតម្រូវការខ្លាំងបំផុតនឹងទទួលបានផលប្រយោជន៍ពីអនុកិច្ចសន្យា។ |

**អនុសាសន៍ :**

| ល.រ | អនុសាសន៍ |
|---|---|
| ១ | មន្ត្រីក្នុងសេចក្តីសំរេចតែងតាំងជាជនបង្គោលមន្ទីរវិស័យ សំរាប់អនុវត្តអនុកិច្ចសន្យា ត្រូវមានសកម្មភាព និងអនុវត្តទៅតាមតួនាទីភារៈកិច្ចរៀងៗខ្លួន ព្រមទាំងមានការប្តេជ្ញាចិត្ត និងអនុវត្តខ្ពស់ ។ |
| ២ | មន្ត្រីជាអ្នករៀបចំអនុកិច្ចសន្យាត្រូវយល់ឱ្យច្បាស់អំពីរចនាសម្ព័ន្ធ និងធាតុសំខាន់ៗរបស់អនុកិច្ចសន្យា ព្រមទាំងអធិប្បាយឱ្យបានគ្រប់ជ្រុងជ្រោយ ។ |
| ៣ | មន្ត្រីកិច្ចសន្យា គ.ប្រ បន្តពង្រឹង និងគាំទ្រដល់មន្ទីរវិស័យ ជាពិសេសលើទិដ្ឋភាពបច្ចេកទេស រួមទាំងជំនាញសេរសេរ និង ប្រព័ន្ធ NCD ។ ម្យ៉ាងទៀតគួរយកចិត្តទុកដាក់សំរបសំរួល ពិនិត្យរបាយការណ៍បញ្ចប់គំរោង និងផ្ទៀងផ្ទាត់ឱ្យបានច្បាស់នូវតំបន់គោលដៅ ដែលបានអនុវត្តជាក់ស្តែង។ |
| ៤ | ការរៀបចំអនុកិច្ចសន្យា (លទ្ធផល សកម្មភាព និងថវិកា) គួរត្រូវរៀបចំតាមបែបចូលរួម (មន្ទីរអ្នកតំណាង តំបន់ទទួលផល និង គ.ប្រ ) ។ |
| ៥ | គោលបំណងបន្ទាន់ នៃអនុកិច្ចសន្យា គួរត្រូវបានរៀបរៀង និង សរសេរក្នុងន័យដែលវាមានទំនាក់ទំនងទៅនឹង លទ្ធផល ហើយបរិយាយអោយបានច្បាស់អំពីអ្វីដែលជាលទ្ធផលបន្ទាន់ និងអត្ថប្រយោជន៍ ដែលរំពឹងទុក និងអាចធ្វើការវាស់វែងបាន។ |
| ៦ | នៅពេលដែលការជ្រើសរើសក្រុមគោលដៅ ដោយភាគីអនុវត្តមិនអាចធ្វើទៅបាន វាជាការប្រសើរ បើសិនភាគីអនុវត្តកិច្ចសន្យា ពិនិត្យមើលឡើងវិញនូវបេក្ខជនមានសក្តានុពល ដែលអាចជ្រើសរើសឱ្យចូលរួមក្នុង |

| | |
|---|---|
| | គំរោង ដើម្បីជ្រើសរើសពួកគេចូលរួម ។ ការពិនិត្យឡើងវិញនេះនឹងធានាថា ក្រុមគោលដៅសមស្របនឹងត្រូវបានជ្រើសរើសអោយចូលរួម ដើម្បីធានានូវប្រសិទ្ធភាពរបស់គំរោងក្នុងកំរិតខ្ពស់ ។ |
| ៧ | សកម្មភាពតាមដាននិងគាំទ្របន្ត គួរត្រូវបានធ្វើឡើងទោះបីជាជីវិតរបស់គម្រោងត្រូវបានបញ្ចប់ ដើម្បីធានានិរន្តរភាពសកម្មភាពគម្រោង និង ផលប្រយោជន៍ទៅដល់សហគមន៍ ។ |

## ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

**ឯកសារដែលត្រូវភ្ជាប់ទី១ : បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបានពិនិត្យ**

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) | មាន (៣) |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និង ឯកសារវិសោធនកម្ម (ប្រសិនមាន) | √ |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ | √ |
| ៣ | របាយការណ៍ត្រួតពិនិត្យគម្រោង | √ |
| ៤ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | √ |
| ៥ | បញ្ជីវគ្គបណ្ដុះបណ្ដាលដែលមានក្នុងអនុកិច្ចសន្យា | √ |
| ៦ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា | √ |
| ៧ | ឯកសារដ៏ទៃទៀតរួមមាន រូបថតនៃគម្រោង (អនុកិច្ចសន្យា) ដែលទុកនៅ គ.ប្រ នៃ គ.អ.ជ.ខ និងនៅភ្នាក់ងារអនុវត្តន៍ ដែលមិនបានរៀបរាប់ខាងលើ | |
| ៨ | ផ្សេងទៀត | |

## ឯកសារដែលត្រូវភ្ជាប់ទី២ : ឯកសារអនុកិច្ចសន្យា លេខ (21/AGR/0901) ខេត្ត/រាជធានី តាកែវ

## បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាស/ជួបពិភាក្សា

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៍ប្រើសម្រាប់ប្រមូល ទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | ១៥/០៩/១០ | លោក អ៊ំ ភិណន់ ទីប្រឹក្សាត្រួតពិនិត្យ និង វាយតម្លៃ<br>ផ្នែកគ្រប់គ្រងកិច្ចសន្យា | គ.ប្រ | សម្ភាសន៍ស៊ីជម្រៅ |
| ២ | ១៥/០៩/១០ | លោក ញឹបស្រ៊ន<br>លោក យក់ លន់<br>លោក ចាន់ សុវណ្ណ<br>លោក សុក សូភី | ប្រធានមន្ទីរ<br>មន្ត្រីគ្រប់គ្រង គ.រ<br>ភ្នាក់អនុវត្ត<br>ភ្នាក់ងារអនុវត្ត | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | ១៦/០៩/១០ | ក្រុមអ្នកទទួលផល :<br>លោក ណុប ចន្ទន<br>លោក សៃស សារី<br>លោក មាឃ ទូច<br>លោក សុខ ចាន់ធួន<br>លោក ស្រី គំ ស្រីម៉ៅ<br>លោក ស្រី ទូច ភិន<br>លោក លោក អ៊ឹង ណាម<br>លោក ស្រី អ៊ឹង សុខុម<br>លោកស្រី សុខ ម៉ាលី | ភូមិ ប្រាំបីមុំ<br>មេភូមិ<br>កសិករ<br>កសិករ<br>កសិករ<br>កសិករ<br>កសិករ<br>កសិករ<br>កសិករ<br>កសិករ | សម្ភាសន៍ជាក្រុម |
| ៤ | ១៦/០៩/១០ | អ្នកស្រី សុខ ម៉ាលី | ភូមិប្រាំបីមុំ | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៥ | ១៧/០៩/១០ | អ្នកទទួលផលផ្ទាល់<br>លោក អ៊ឹ ធី<br>លោក ស្រី គុជ សំអុន<br>លោក នាក់ ហ៊ុម | ភូមិ ចមពល<br>កសិករ<br>កសិករ<br>កសិករ | សម្ភាសជាក្រុម |

| | | | | |
|---|---|---|---|---|
| | | លោក គីម យ៉ុន<br>លោក ង៉ែត ចណ្ណេ<br>លោក ស្រី ចាន់ កិ<br>លោក នាង វង់<br>លោក ឃិន សែម | កសិករ<br>កសិករ<br>កសិករ<br>កសិករ<br>កសិករ | |
| ៥ | ១៧/០៩/១០ | លោក នាក់ ហ៊ីម អ្នកទទួលផល | ភូមិ ចមពល | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |

គជអប NCDD

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | **22/AGR/0901-00** |
| ចំណងជើង : | បង្កើនសន្តិសុខស្បៀង |
| ភ្នាក់ងារអនុវត្តន៏ : | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត |
| រយៈពេល (ចាប់ផ្តើម និងបញ្ចប់) | 01/01/2009 -31/12/2009 |
| រាជធានី ខេត្ត | ឧត្តរមានជ័យ |
| ផ្នែក /មន្ទីរជំនាញ | មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទខេត្ត |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬគ.ប្រ/ គ.អ.ជ.ខ | **6,926.05 $** |
| ការរួមចំណែករបស់រាជធានី ខេត្ត | គ្មាន |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៏ | **692.60 $** |
| តម្លៃសរុប (ដុល្លារសហរដ្ឋអាមេរិក) | **7,618.65 $** |

## ក្រុមវាយតម្លៃ និងរៀបចំរបាយការណ៏

| ឈ្មោះ | មុខតំណែង និងភ្នាក់ងារ |
|---|---|
| ១.លោកស្រី ឯក សុភារុំ | ប្រធានមន្ទីរកិច្ចការនារី |
| ២.លោក ផុន ចាន់និល | អនុប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា |
| ៣.លោក ឈូក អឿត | អនុប្រធានផ្នែករដ្ឋបាលមូលដ្ឋាន |
| ៤.លោក សន់ សេដ្ឋា | មន្ត្រីជនបង្គោលត្រួតពិនិត្យ និងវាយតំលៃ |

# ខេត្តឧត្តរមានជ័យ

កាលបរិច្ឆេទ: ២៨ តុលា ឆ្នាំ២០១០

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៣ |
| | របាយការណ៍សង្ខេប | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៦** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៦ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៦ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៦ |
| ១.៤ | សំណួរវាយតម្លៃ | ៧ |
| ១.៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ៧ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ៨ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១០** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១) | ១០ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម (សំណួរវាយតម្លៃទី៣) | ២១ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤) | ២៤ |
| ២.៤ | សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី៥) | ២៧ |
| **ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍** | | **៣០** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានពិនិត្យ | ៣០ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានជួបសម្ភាសន៍/ពិភាក្សា | ៣១ |
| **ករណីសិក្សា** | | **២៣** |
| ទី១- | " ជីវភាពរស់នៅមានភាពប្រសើរ " **— លោក នាម សំអាល** អ្នកទទួលផល | ២៣ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

| គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ :<br>មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តអនុកិច្ចសន្យា ដែលផ្តោតលើការបណ្តុះបណ្តាលកសិករ អំពីបច្ចេកទេស ប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ស្ទូនបន្លែលក្ខណៈគ្រួសារ ការសន្សំជីកំប៉ុស្ត និងពង្រឹងភ្នាក់ងារសុខភាព សត្វភូមិ។ កសិករគំរូនៅក្នុងតំបន់គោលដៅ នៃស្រុកទាំង៥ ប្រមាណជាង ៤00 នាក់ទទួលការបណ្តុះបណ្តាលលើបច្ចេកទេស "ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ដាំបន្លែ ធ្វើជីកំប៉ុស្ត" ។ ក្រោយពីការបណ្តុះបណ្តាល បានបញ្ចប់ មន្ទីរបានផ្តល់សំភារៈគាំទ្រមួយចំនួន ដល់កសិករ ១៩៩ នាក់ សំរាប់ការអនុវត្តន៏ក្រោយពេលបណ្តុះបណ្តាលចប់ សំភារៈទាំនោះ ដូចជា ពូជស្រូវស្រាល ផ្ការរំដួល ស្បៃប្រក់រោង ពូជត្រសក់ ពូជសណ្តែកកួរ ពូជត្រកួន ពូជស្ពៃក្រញាញ់។ ជាងនេះទៅទៀត សំរាប់ភ្នាក់ងារសុខភាពសត្វភូមិចំនួន ៥៥នាក់ បានគាំទ្រក្រោយពេលបណ្តុះបណ្តាលចប់ មានដូចជា ស៊ីរ៉ាង ម្ជុល ថ្នាំព្យាបាលមួយចំនួន ប្រអប់ដាក់ស៊ីរ៉ាង បាំុង ដើម្បីយកទៅអនុវត្តក្នុងការព្យាបាល គោ-ក្របី ។ល។ នៅក្នុងសហគមន៏ របស់គាត់រៀង១ខ្លួន ក្រោយពីបាលទទួលចំណេះដឹង ក្នុងការសិក្សាផ្អែកលើការចុះតាមដានរបស់មន្ត្រីជំនាញ មានកសិករប្រហែល ៥0% បានអនុវត្ត បានតាមបច្ចេកទេសសល់ពីនោះគឺមានកសិករខ្លះពុំបានអនុវត្តល្អត្រឹមត្រូវនៅឡើយទេ ។ ទោះជាយ៉ាងណាក្តីមន្ត្រីជំនាញបានវាយ តំលៃថា កសិករទាំងនោះនៅតែមានចំណាប់អារម្មណ៏ នឹងយកចំណេះទាំងនេះ ទៅអនុវត្តជាបន្តទៀត ដោយសារ នេះជា តម្រូវការ ប្រចាំថ្ងៃ របស់ពួកគាត់ ។ |
|---|
| ឆ្លើយទៅនឹងសំណួរទាំង៥ នៃការវាយតម្លៃ :<br>មន្ត្រីរបស់មន្ទីរកសិកម្មមានជំនាញគ្រប់គ្រាន់ក្នុងការបណ្តុះបណ្តាល ការរៀបចំ ឯកសារមេរៀននិងសម្ភារធ្វើបង្ហាញសំខាន់ៗ និងមានថវិការគាំទ្រពីគ.ប្រ។ ចំណុចចខ្លាំងមួយទៀតមន្ទីរបានអនុវត្តរាល់សកម្មភាពក្នុង អនុកិច្ចសន្យាគ្រប់តាមផែនការ និងបានសហការល្អជាមួយមន្ត្រីគ.ប្រ មន្ត្រីការិយាល័យជំនាញស្រុក-ក្រុង និងការិយាល័យទីប្រឹក្សា ភីអេសឌីឌី ។ ចំពោះចំណុចខ្វះខាតវិញ គឺមន្ត្រីខ្វះមធ្យោបាយធ្វើដំណើរ ដោយសារយានយន្ត មានសភាពចាស់ ទ្រុឌទ្រោមពិបាកធ្វើដំណើរឱ្យបានទាន់ពេល ម្យ៉ាងទៀតផ្ទាំងរូបភាពសម្រាប់បង្ហាញដល់ អ្នកមិនចេះអក្សរខ្វះភាព ពេញលេញ ។ ចំណុចខ្សោយសំខាន់មួយទៀតគឺ មានការយឺតយ៉ាវក្នុងការរង់ចាំថវិកា និងសម្ភារ តាមរយៈការ ធ្វើលទ្ធកម្មមួយចំនួន ។ ប្រជាពលរដ្ឋជាក្រុមគោលដៅមួយចំនួន មានការយល់ដឹងទាប ដោយសារ ពួកគាត់មានទម្លាប់ ប្រកបមុខរបរកសិកម្មតាមបែបប្រពៃណីភាគច្រើននៅឡើយ ។ |

**សេចក្តីសន្និដ្ឋានសំខាន់ៗ:**

ក្រុមវាយតម្លៃសុំជូនយោបល់មួយចំនួន ទាក់ទងទៅនឹងកាកែលម្អ ធើយ៉ាងណាឱ្យការអនុវត្តអនុកិច្ចសន្យា បានកាន់តែ ប្រសើ ឡើងមានដូចជា គួមានការបណ្តុះបណ្តាលពង្រឹងសមត្ថភាពកសិករពីបច្ចេកទេសដាំស្រូវ ដាំបន្លែ ធ្វើជីកំប៉ុស្ត គួបង្កើនថវិកាគាំទ្រ គំរោង ឆ្លើយតប ទៅនឹងតំរូវការឃុំ-សង្កាត់ដែលបានលើកឡើង ក្នុងកម្មវិធីវិយោគឃុំ-សង្កាត់។

ជាងនេះទៀតគួមានកម្មវិធីដែលគាំទ្រទៅដល់ ការបង្ហាញផ្នែកកសិ្យត្រសាស្ត្រ (ឈើហូបផ្លែ ស្រូវ បន្លែ ដំណាំ)និង បង្កើនការយកចិត្តទុកដាក់លើយុទ្ធសាស្ត្របញ្ជ្រាប ការបង្កើនទិន្នផលស្រូវ និង សួនបន្លែជាលក្ខណៈគ្រួសារ ទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំឃុំ-សង្កាត់ឱ្យបានទូលាយជាងមុន ដោយប្រមូលផ្តុំកសិករចូលរួមឱ្យបានគ្រប់ៗគ្នា។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្តល់ថវិកាតាមរយៈ គ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យ ដើម្បអនុវត្តសកម្មភាព និងគម្រោងដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការវាយតម្លៃអនុកិច្ចសន្យាដែលមានលក្ខណៈជាប្រព័ន្ធ មិនបានអនុវត្តទេកាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើន។ នៅក្នុងឆ្នាំ ២០១០ ជាមួយនឹងការគាំទ្រផ្នែកថវិកា និងបច្ចេកទេស ពីផ្នែកត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យា គ.ប្រ នៃគ.អ.ជ.ខ ក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យា ដែលបានរៀបចំរួមគ្នាជាមួយភ្នាក់ងារអនុវត្តន៍ដែលមានលេខ : (**22/AGR/0901-00** និងចំណងជើង បង្កើន សន្តិសុខស្បៀង ) ដំណើរការលទ្ធផល ដែលបានរកឃើញ និងការសន្និដ្ឋាន នៃការវាយតម្លៃត្រូវបានកត់ត្រា ហើយនឹងបង្ហាញតាម រយៈរបាយការណ៍ស្តីពី ការវាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

អនុកិច្ចសន្យានេះបានរៀបចំឡើងនិងបានអនុម័តដោយ គ.ប្រ នៃ គ.អ.ជ.ខ ដើម្បីអនុវត្តការ ផ្សព្វផ្សាយពីបច្ចេកទេសបង្កើន ទិន្នផលស្រូវ ដល់កសិករគំរូចំនួន ៦៥ នាក់ បណ្តុះបណ្តាលបច្ចេកទេសដាំបន្លែដល់កសិករជ្រើសរើស ២០ នាក់ និងបណ្តុះបណ្តាល ជំនាញពេទ្យសត្វដល់ ភ្នាក់ងារពេទ្យសត្វភូមិចំនួន ៥៥ នាក់ ក្នុងឃុំគោលដៅនៃស្រុកទាំង០៥ ។ គោលបំណងនៃអនុកិច្ចសន្យា នេះគឺដើម្បីចូលរួមចំណែក ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋតាមរយៈការបង្កើនសន្តិសុខស្បៀងរបស់ ប្រជាពលរដ្ឋដែលជាក្រុមគោលដៅ ។ មន្ទីរកសិកម្ម បានទទួលថវិកាគាំទ្រពី គ.អ.ជ.ខ គ.ប្រ ចំនួន ៦៩២៦.០៥ដុល្លារ សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០៨ នេះ ដើម្បីគាំទ្រសកម្មភាពដូចបានរៀបរាប់នៅខាងលើ ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូល ដោយផ្តែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និងតម្លាភាព។ ដូច្នេះទំហំនៃការវាយតម្លៃមានដែនកំណត់តាមទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាដែលពាក់ព័ន្ធ ដូចមានចែងក្នុងក្របខណ្ឌការងារនៃការវាយតម្លៃ។ គោលបំណង នៃការវាយតម្លៃគឺៈ **ក)** ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា

និងចំនុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យា រួមទាំងកត់ត្រានូវ ចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត និង ខ) ដើម្បីពង្រឹងរបៀបធ្វើការវាយតម្លៃ គម្រោងរបស់ គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត ។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្រ្ត សម្ភារៈ និងដំណើរការវាយតម្លៃ

វិធីសាស្រ្ត និងឧបករណ៍ដែលត្រូវប្រើៈ

១) ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំនត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ព័ន្ធដែលមាននៅក្នុងផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៏ ។

២) ពិគ្រោះជាមួយអ្នកដែលផ្តល់ព័ត៌មានសំខាន់ៗរួមមានៈ អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នក ទទួលផលផ្ទាល់ និងមិនផ្ទាល់ ២ ឬ៣នាក់ និងអ្នកពាក់ព័ន្ធ ២នាក់ ។ សូមពិគ្រោះជាមួយនឹង មន្រ្តីបង្គោលទៅលើបញ្ហាយេនឌ័រ និងគ្រប់គ្រងធនធានធម្មជាតិ សម្រាប់បញ្ហាពាក់ពន្ធ័វិស័យខាងលើ ។

៣) សូមប្រើប្រាស់វិធីសាស្រ្តចុះពិនិត្យតំបន់អនុវត្តន៏គម្រោង និងសង្កេតមើលសកម្មភាព ពិភាក្សាក្រុម និងករណីសិក្សា។

៤) ចុះពិនិត្យតំបន់អនុវត្តន៏គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់ ។

៥) <u>វិភាគទិន្នន័យ និងបកស្រាយៈ</u> ទិន្នន័យដែលបានប្រមូលតាមវិធីសាស្រ្តខាងលើ នឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់

៦) <u>ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៏</u> ដោយភ្នាក់ងារអនុវត្តន៏ និងអ្នកពាក់ព័ន្ធតាមរយៈ

| |
|---|
| ព័ត៌មានត្រឡប់ដែលទទួលបានពីការបង្ហាញដោយសង្ខេបដែលបានធ្វើឡើង (ដាក់កាលបរិច្ឆេទនៃការធ្វើបទបង្ហាញនៅទីនេះ)<br>ការវាយតម្លៃត្រូវធ្វើតាម "គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា" និងវិធីសាស្ត្រដែលបានណែនាំ។ ដូច្នេះដំណើរការត្រូវបានធ្វើឡើងដោយមានទម្រង់ការណែនាំ និងតម្លាភាព រួមទាំងការចូលរួមពីអ្នកពាក់ព័ន្ធ។ |

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

| |
|---|
| ១) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយ គ.ប្រ និងអ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់ក្នុងអនុកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយការប្រឹងប្រែងត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត។<br><br>២) ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត ៖ វាជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោង នៅពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និងបទពិសោធន៍ពីមុនមក។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណងសំខាន់ គឺដើម្បី"រៀនធ្វើដោយការអនុវត្តផ្ទាល់"។ អ្នកវាយតម្លៃ បានទទួលការគាំទ្រដោយមានគោលការណ៍ការណែនាំឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។<br><br>៣) បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យាៈ ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ " លើការរីកចម្រើន និងជោគជ័យទេ ។ មួយទៀត ទំនាក់ទំនងសង្ខេបតាមបែបតក្កភាពរវាងសកម្មភាព (ធាតុចូល) និងលទ្ធផល និងរវាងលទ្ធផល ទៅនឹងគោលបំណងបន្ទាន់មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ។<br><br>៤) ដោយយើងមិនមានសូចនាករឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍" ដែលជាកម្រិតអត្ថប្រយោជន៍ទៅលើគោលនយោបាយវិម្ឋការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។<br><br>៥)ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិតទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ។ យើងអាចវាយតម្លៃតែទៅលើដែលជាលទ្ធផល **លទ ក.២ (១០១០២០០១)** |

**ការបង្ហាញ ផ្នែកក្សេត្រសាស្រ្ត (ឈើហូបផ្លែ ស្រូវ បន្លែ ដំណាំ** និងដែលជាសកម្មភាព **សក ខ.១.២ ផ្ដល់ការ បណ្ដុះបណ្ដាល អំពី បច្ចេកទេសដាំបន្លែ ដល់កសិករ ២០នាក់ក្នុងឃុំបេង** នៃអនុកិច្ចសន្យាលំអិតតាមរយៈការសម្ភាសន៍ស៊ីជម្រៅ ក្រុមពិភាក្សា និងការចុះពិនិត្យតំបន់អនុវត្តគម្រោង។

៦) សូមរក្សាទុកចំណុចនេះប្រសិនបើវាមានសុពលភាពៈ ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាមិនអាចធ្វើទៅបានទេ ព្រោះចំណុច គ នៃផ្នែកទី៣ក្នុងឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ ឬមិនពេញលេញ។ ការងារនេះ នឹងកាន់តែមានសុពលភាព និងពោរពេញទៅដោយព័ត៌មាន បើសិនជាចំនុចដែលបានរៀបរាប់ខាងលើនេះត្រូវបានដោះស្រាយ។

**<u>ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធនីះ</u>**

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះលេខអនុកិច្ចសន្យានៅទីនេះ **22/AGR/0901-00** និងដែនកំណត់ ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌ នៃការវាយតម្លៃនេះ។

២) ការវាយតម្លៃនេះលម្អិតតែទៅលើដែលជាលទ្ធផល **លទ ក.២ (១០១០២០០១) ការបង្ហាញផ្នែកក្សេត្រសាស្រ្ត (ឈើហូបផ្លែ ស្រូវ បន្លែ ដំណាំ)** និងដែលជាសកម្មភាព **សក ខ.១.២ ផ្ដល់ការ បណ្ដុះបណ្ដាលអំពី បច្ចេកទេសដាំបន្លែ ដល់កសិករ ២០នាក់ក្នុងឃុំបេង** នៃអនុកិច្ចសន្យា

៣) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃទៅលើ ភ្នាក់ងារអនុវត្តន៍ ភ្នាក់ងារដែលពាក់ព័ន្ធគម្រោង ហើយនឹងការវាយតម្លៃទៅលើគ.ប្រ នៃគ.អ.ជ.ខ និង គ.ជ.អ.ប ទេ។

ហេតុដូច្នេះ របាយការណ៍នៃការវាយតម្លៃ លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ដែលបានលើកឡើង ត្រូវពិនិត្យដោយយោលទៅលើបរិបទខាងលើ និងអនុវត្តតាមលំដាប់លំដោយ។

បញ្ហាប្រឈមផ្សេងៗ :

-មន្ត្រីវាយតំលៃគ.ប្រ និងមន្ត្រីអនុវត្តន៏គម្រោងមានការរង្វល់ច្រើនក្នុងខែតុលា និងខែវិច្ឆិកា

-ប្រជាពលរដ្ឋបានមានការរវល់ការងារស្រែចំការ

# ២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១)

**លទ្ធផលទី១ :លទ ក.១ (១០១០២០០១) ការបង្ហាញផ្នែកក្សេត្រសាស្ត្រ (ឈើហូបផ្លែ ស្រូវ បន្លែ ដំណាំ)**

**ផ្នែក-កៈ**

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ១.១ | សក ក.១.១ ជ្រើសរើសកសិករសម្រាប់បណ្តុះបណ្តាល ប.រ.ស ចំនួន ៦៥ នាក់ក្នុង ឃុំ បេង ឃុំផ្លាត ឃុំត្រពាំងប្រាសាទ | ថ្ងៃទី ០២-០៦ ខែមីនា ឆ្នាំ ២០០៩ មន្ត្រីមន្ទីរអនុវត្ត គម្រោងបានចុះជ្រើសរើសកសិករ សម្រាប់ឱ្យចូលរៀន បច្ចេកទេស បរស នៅ ឃុំបេង ឃុំផ្លាត ឃុំត្រពាំង ប្រាសាទ អ្នកចូលរួម ៧២ នាក់ ស្រី ៣០ នាក់ សម្រេចជាលទ្ធផល រើសបានតាមការកំណត់៧៥នាក់ ស្រី៣៣ នាក់ (ចែកចេញជា ពីរក្រុម) |
| ១.២ | សក ក.១.២ ជ្រើសរើសកសិករសម្រាប់បណ្តុះបណ្តាលពីការដាំបន្លែ ចំនួន ២០ នាក់ក្នុងឃុំបេង | ថ្ងៃទី០២-០៣ ខែមីនា ឆ្នាំ ២០០៩ មន្ត្រីមន្ទីរអនុវត្ត គម្រោងបានចុះជ្រើសរើសកសិករ សម្រាប់ឱ្យចូលរៀន បច្ចេកទេសដាំ បន្លែ នៅភូមិទទឹងថ្ងៃ ឃុំបេង ស្រុកបន្ទាយអំពិល អ្នកចូលរួម ៣៨ នាក់ ស្រី ២០ នាក់ សម្រេចជាលទ្ធផល រើសបានតាមការកំណត់ ២៥នាក់ ស្រី ១២នាក់ ។ |
| ១.៣ | សក ក.១.៣ ជ្រើសរើសកសិករសម្រាប់បណ្តុះបណ្តាលការធ្វើជីកំប៉ុស្ត ចំនួន | ថ្ងៃទី ២៣-២៧ ខែ កុម្ភៈ និង ថ្ងៃទី ០៩មិនា ឆ្នាំ ២០០៩ មន្ត្រីមន្ទីរ អនុវត្តគម្រោង |

| | | |
|---|---|---|
| | ១២៥ នាក់ក្នុងឃុំបេង ឃុំអំពិល ឃុំសំរាង ឃុំបន្ទាយរាក់ ឃុំបុស្សូវ | បានចុះ ជ្រើសរើសកសិករ សម្រាប់ ឱ្យចូលរៀន បច្ចេកទេស ធ្វើជី កំប៉ុស្ត នៅឃុំបេង ឃុំអំពិល ឃុំសំរាង ឃុំបន្ទាយរាក់ ឃុំបុស្សូវ អ្នកចូលរួម ១១៦ នាក់ ស្រី ៩២ នាក់ សម្រេច ជាលទ្ធផលរើសបានតាមការកំណត់១២៥នាក់ ស្រី៦៣នាក់។ |
| ១.៤ | សក ក.១.៤ ផ្តល់ការបណ្តុះបណ្តាលការធ្វើជីកំប៉ុស្ត ដល់កសិករចំនួន ១២៥ នាក់ក្នុងឃុំបេង ឃុំអំពិល ឃុំសំរាង ឃុំបន្ទាយរាក់ ឃុំបុស្សូវ | ថ្ងៃទី ២៨-៣១ ខែ មីនា ឆ្នាំ២០០៩មន្ត្រីមន្ទីរអនុវត្ត គម្រោងបានចុះបើកវគ្គ បណ្តុះបណ្តាល ដល់កសិករ ស្តីពីបច្ចេកទេស ធ្វើជីកំប៉ុស្ត នៅឃុំបេង ឃុំអំពិល ឃុំសំរាង ឃុំបន្ទាយរាក់ ឃុំបុស្សូវអ្នកចូលរួម ១២៥ នាក់ ស្រី៥៣ នាក់ ។ |
| ១.៥ | សក ក.១.៥ ផ្តល់សម្ភារបច្ចេកទេសដល់កសិករដែលបានទទួលការបណ្តុះបណ្តាល តាមជំនាញ ២១០នាក់ ( ការដាំបន្លែ កសិករបរស និងកសិករ ជីកំប៉ុស្ត៍) | នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០០៩ បានរៀបចំពិធី ចែក សម្ភារបច្ចេកទេស កសិកម្ម ដល់ អ្នកទទួលផល ១១៩ នាក់ មាន ស្បូវកណ្តប ប៉ោតស្រោចទឹក ស្ពៃ ខ្សៀវ ពូជស្រូវ សែន ពិដោរ គ្រាប់ត្រកួន គ្រាប់ សណ្តែក គ្រាប់ត្រសក់ និងគ្រាប់ស្ពៃខ្សៀវ។ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផលធៀបនឹងគោលបំណងបន្ទាន់

| |
|---|
| លទ្ធផលសម្រេចបានក្នុងអនុកិច្ចសន្យា: <br> ១) កសិករ ៧២ នាក់ត្រូវបានជ្រើសរើស តាមលក្ខលណៈវិនិច្ឆ័យ ដើម្បីត្រៀមចូលក្នុងវគ្គបណ្តុះបណ្តាល បរស ក្នុងឃុំគោលដៅ ៣ ឃុំ ។ ២) កសិករគោលដៅចំនួន ២០ នាក់ត្រូវបាន ជ្រើសរើស និងទទួលបានការបណ្តុះបណ្តាលរយៈពេល ៥ថ្ងៃ ក្នុងឃុំបេងស្រុកបន្ទាយអំពិល ។ ៣) កសិករចំនួន ១២៥នាក់ត្រូវបានជ្រើសរើសបណ្តុះបណ្តាល ការធ្វើជីកំប៉ុស្ត នៅក្នុង ឃុំគោលដៅ ៥ឃុំ ។ ៤) ក្រោយពីបានជ្រើសរើស កសិករចំនួន ១២៥ នាក់ ស្រី ៥៣ នាក់ទទួលបានការបណ្តុះបណ្តាលពីបច្ចេកទេសធ្វើជីកំប៉ុស្តន៍ តាមគោលបំណង ក្នុងឃុំ គោលដៅ ចំនួន ៥ ឃុំ ។ ៥) ក្រោយពីការបណ្តុះបណ្តាល កសិករទទួលផលចំនួន ១១៩ នាក់បានទទួលសម្ភារបច្ចេកទេសកសិកម្ម តទៅតាមជំនាញ។ តាមការវាយ តម្លៃជារួមលើការ ជ្រើសរើស និងកាទទួលបានការបណ្តុះបណ្តាលគឺសម្រេចបានលទ្ធផល ១០០% ស្របតាមគោលបំណងបន្ទាន់ក្នុងអនុកិច្ចសន្យាក្នុងការកាត់បន្ថយភាព ក្រីក្ររបស់ ប្រជាពលរដ្ឋ |

| |
|---|
| តាមរយៈ ការបង្កើន សន្តិសុខស្បៀងរបស់ ប្រជាពលរដ្ឋដែលជាក្រុមគោលដៅ តាមរយៈការកែប្រែទម្លាប់ដែលកសិករធ្លាប់តែអនុវត្តការដាំដុះទៅតាមការយល់ឃើញ ហើយទទួលបានទិន្នផលទាប ឱ្យប្រែក្លាយ ទៅជាការ ដាំដុះតាមបច្ចេកទេសសមស្រប នាំឱ្យពួកគាត់ទទួលបានទិន្នផលខ្ពស់ជាងមុន ចំណែកប្រាក់ចំណូលក៏មានការកើនឡើងផងដែរ ដោយបានពីការលក់បន្លែបង្កា ដែលកសិករផលិតបាន និងបានសន្សំ ប្រាក់កាសសម្រាប់កូនៗបានទៅសាលារៀន និង សម្រាប់បរិភោគជាអាហារប្រចាំថ្ងៃមិនដាច់ចំណាយប្រាក់ទិញ។ |

## លទ្ធផលទី២: ការចុះតាមដាន

### ផ្នែក-ក :

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ២.១ | សក ក.២.១ មន្ត្រីតាមដាន និងមន្ត្រីជំនាញពេទ្យសត្វចុះតាមដាននៅពេលអនុវត្តន៍ និង ក្រោយពេលអនុវត្តន៍សកម្មភាពបណ្តុះបណ្តាលពេទ្យសត្វភូមិ | មន្ត្រីតាមដានមន្ទីរកសិកម្ម០២នាក់ចុះត្រួតពិនិត្យការអនុវត្តន៍សកម្មភាពក្រោយពេលបណ្តុះបណ្តាល ។ |
| ២.២ | សក ក.២.២មន្ត្រីតាមដានមន្ទីរកសិកម្មចុះ ត្រួតពិនិត្យការអនុវត្តន៍សកម្មភាពបណ្តុះបណ្តាល និងក្រោយពេលបណ្តុះបណ្តាលអំពី បវស ។ | មន្ត្រីតាមដានមន្ទីរកសិកម្មមួយនាក់ចុះត្រួតពិនិត្យការអនុវត្តន៍សកម្មភាពបណ្តុះបណ្តាលនិងក្រោយពេលបណ្តុះ បណ្តាលអំពី បវស ។ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផលធៀបនឹងគោលបំណងបន្ទាន់

| |
|---|
| |

## លទ្ធផលទី៣: ការវាយតម្លៃ

**ផ្នែក-ក :**

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ៣.១ | សក ក.៣.១ប្រជុំរៀបចំវាយតំលៃបញ្ចប់ អនុកិច្ចសន្យាដែលមានមន្ត្រីគ.ប្រ ចូលរួម | មន្ត្រីតាមដានមន្ទីរកសិកម្មបានរៀបចំវាយតំលៃបញ្ចប់អនុកិច្ចសន្យាដែលមានមន្ត្រីគ.ប្រចូលរួម |
| ៣.២ | សក ក.៣.២ ប្រមូលពតិមាន វិភាគពតមានលើការអនុវត្តអនុកច្ចសន្យាដើម្បី វាយតំលៃបញ្ចប់ អនុកិច្ចសន្យា។ | មន្ត្រីនៃមន្ទីរកសិកម្មខេត្តចំនួន ២ នាក់បានចុះ វាយតំលៃ បញ្ចប់គម្រោងរយ:ពេល ៣ថ្ងៃ និង រៀបចំរបាយការណ៍ វាយតំលៃបញ្ចប់ អនុកិច្ច សន្យា។ មន្ទីរបានសហការណ៍ជាមន្ត្រីត្រួតពិនិត្យ វាយតម្លៃ គ.ប្រ ដើម្បីអនុវត្តការងារវាយតំលៃ ។ |
| ៣.៣ | សក ក.៣.៣ ប្រជុំវិភាគនិងរៀបចំរបាយការណ៍ បញ្ចប់អនុកិច្ចសន្យា | មន្ត្រីនៃមន្ទីរកសិកម្មខេត្តចំនួន ២ នាក់ ប្រជុំ វិភាគនិងរៀបចំរបាយការណ៍បញ្ចប់អនុកិច្ចសន្យា |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផលធៀបនឹងគោលបំណងបន្ទាន់

| |
|---|
| |

## លទ្ធផលទី៤:ការគាំទ្រប្រតិបត្តិការ

### ផ្នែក-ក :

| ល.រ<br>(១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា<br>(២) | អ្វីដែលសម្រេចបានជាក់ស្តែង<br>(៣) |
|---|---|---|
| ៤.១ | សក ក.៤.១ ទិញកាមេរ៉ាឌីជីថល | មន្ត្រីតាមដានមន្ទីរកសិកម្មទិញកាមេរ៉ាឌីជីថល ១គ្រឿង |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផលធៀបនឹងគោលបំណងបន្ទាន់

| |
|---|
| |

## លទ្ធផលទី៥: កសិករបានទទួលការបណ្ដុះបណ្ដាលពី បច្ចេកទេសផ្សព្វផ្សាយ ក្សេត្រសាស្ត្រ និងការបង្ហាញ

**ផ្នែក-ក:**

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ៥.១ | សក ខ.១.១ ផ្តល់ការបណ្ដុះបណ្ដាលបច្ចេកទេស ប.វ.ស ដល់កសិករចំនួន ៦៥នាក់ ក្នុងឃុំបេង ឃុំផ្លូត ឃុំត្រពាំងប្រាសាទ | មន្ត្រីនៃមន្ទីរកសិកម្មខេត្តបានរៀបចំបើកវគ្គបណ្ដុះ បណ្ដាលដល់កសិករ ស្តីពីបច្ចេកទេសធ្វើ ប.វ.ស ចំនួន ៦៥ នាក់ ស្រី៣៦នាក់ នៅក្នុងឃុំបេង ឃុំផ្លូត ឃុំត្រពាំងប្រាសាទ |
| ៥.២ | សក ខ.១.២ ផ្តល់ការបណ្ដុះបណ្ដាលអំពីបច្ចេកទេស ដាំបន្លែ ដល់កសិករ ២0នាក់ក្នុងឃុំបេង | ថ្ងៃទី ០៤-០៨ ខែ ឧសភា ឆ្នាំ២០០៩មន្ត្រីមន្ទីរអនុវត្ត គម្រោងបានចុះបើកវគ្គបណ្ដុះបណ្ដាល ដល់កសិករ ស្តីពី បច្ចេកទេស ដាំបន្លែជាលក្ខណៈគ្រួសារ នៅភូមិទទឹង ថ្ងៃ ឃុំបេង ស្រុកបន្ទាយអំពិល អ្នកចូលរួម ២៥ នាក់ ស្រី ១២ នាក់ ។ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផលធៀបនឹងគោលបំណងបន្ទាន់

១) លទ្ធផលដែលសម្រេចបានគឺ កសិករ ចំនួន ៦៥ នាក់ ស្រី ៣៦ នាក់ ទទួលបានការបណ្ដុះបណ្ដាលបច្ចេកទេសដំណាំស្រូវ តាមគោលការណ៍ធម្មជាតិ នៅក្នុងឃុំគោលដៅ ចំនួន ៣ ឃុំ សម្រេចតាមផែនការគ្រោង ១០០% ។២) កសិករចំនួន ២៥ នាក់ ស្រី ១២ នាក់ ទទួលបាន ការបណ្ដុះបណ្ដាល បច្ចេកទេស ដាំបន្លែជាលក្ខណៈគ្រួសារ ក្នុងភូមិគោលដៅ ១ ភូមិ ក្នុង ១ ឃុំ សម្រេចបាន ១០០ % តាមផែនការដែលបានគ្រោងទុក ។ យោងតាមការវិភាគពតិមានដែលប្រមូលបានពីគ្រប់ប្រភព ក្នុងចំណោមកសិករ ដែលទទួលបានការបណ្ដុះបណ្ដាល មានកសិករចំនួន ជាង ៥០ % បានអនុវត្តន៍បច្ចេកទេសដំណាំស្រូវ និង ដំណាំបន្លែ បានត្រឹមត្រូវទៅតាមបច្ចេកទេសដែលមន្ត្រីជំនាញបានបង្ហាត់បង្ហាញ ។ កសិករបានកែប្រែទម្លាប់ ដោយបានធ្វើស្រែ តាមការណែនាំ ដូចជាការបន្សុតពូជ ការស្ទូងស្រូវ តែមួយដើម និងការប្រើប្រាស់ជី អ៊ុីអឹម នាំឱ្យពួកគាត់ទទួលបាន ទិន្នផលស្រូវខ្ពស់ជាងមុន ។ ចំពោះការដាំបន្លែ លក្ខណៈគ្រួសារវិញ គឺកសិករទាំងអស់ដែលទទួលបានការបណ្ដុះបណ្ដាល បានអនុវត្តតាមបច្ចេកទេស បានត្រឹមត្រូវ និងទទួលបានផល ពីដំណាំបន្លែសម្រាប់បរិភោគ និងសម្រាប់លក់ នាំឱ្យជីវភាពពួកគាត់បានប្រសើរឡើងមួយកម្រិត ។

## លទ្ធផលទី៦: ជ្រើសរើសកសិករ បណ្តុះបណ្តាលឱ្យក្លាយជា ភ្នាក់ងារចិញ្ចឹមសត្វភូមិ

**ផ្នែក-កៈ**

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ៦.១ | សក ខ.២.១ ចុះជួបប្រឹក្សាឃុំជ្រើសរើសភ្នាក់ងារ ពេទ្យសត្វភូមិចំនួន ៩៥ នាក់ក្នុងឃុំគោលដៅ | ថ្ងៃទី ២២-២៦ ខែកុម្ភៈ ឆ្នាំ២០០៩ មន្ត្រីមន្ទីរអនុវត្តគម្រោងបានចុះជ្រើសរើសភ្នាក់ងារសុខភាពសត្វភូមិសម្រាប់បណ្តុះបណ្តាលបន្ថែមនូវជំនាញពេទ្យសត្វនៅសង្កាត់សំរោង សង្កាត់បុស្សូរ ឃុំជើងទៀន ឃុំក្រសាំង អ្នកចូលរួម ៥២ នាក់ ស្រី 0 នាក់ សម្រេចជា លទ្ធផល រើសបាន តាមការកំណត់ ២៥នាក់ ស្រី គ្មាន ។ |
| ៦.២ | សក ខ.២.២ ផ្តល់សម្ភារពេទ្យសត្វដល់ភ្នាក់ងារ ពេទ្យសត្វភូមិដែលទទួលបានការបំពាក់បំប៉ន ៩៥នាក់ ។ | នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០០៩ បានរៀបចំពិធី ចែកសម្ភារបច្ចេកទេស ផ្នែកពេទ្យសត្វដល់ ភ្នាក់ ងារសុខ ភាពត្វភូមិ ៥៥នាក់ មាន (ម្ជុល ស៊ីរ៉ាំង បាំង ប្រអប់ ដាក់ស៊ីរ៉ាំង ថ្នាំព្យាបាល ៤មុខ) ក្នុងមួយ នាក់៧។ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផលធៀបនឹងគោលបំណងបន្ទាន់

| |
|---|
| កសិករចំនួន ៥២ នាក់ ស្រី 0 នាក់ សស្មីនឹង ៩៥ % ត្រូវបានជ្រើសរើស ដើម្បីទទួលវគ្គបណ្តុះបណ្តាល ឱ្យក្លាយទៅជាភ្នាក់ងារសុខភាពសត្វភូមិ ក្នុងឃុំគោដៅចំនួន ៤ ឃុំ ឆ្លើយតបទៅ នឹងតម្រូវការរបស់ប្រជាពលរដ្ឋដែលបានលើកឡើងនៅក្នុងកម្មវិធីវិនិយោគឃុំ។ ក្រុមគោលដៅ ដែលជាសិក្ខាកាមនៅបានទទួលសម្ភារពេទ្យសត្វ គ្រប់៧គ្នា តាមផែនការផ្តល់ និងបាន ប្រើប្រាស់ជំនាញ របស់ពួកគេ សម្រាប់រកប្រាក់ចំណូលប្រចាំគ្រួសារ ក៏ដូចជាជួយជាវិភាគទានដ៏សំខាន់ លើការថែទាំសុខភាពសត្វនៅក្នុងសហគមន៏ របស់ |

ពួកគាត់ដើម្បីរកកម្រៃទ្រទ្រង់ ជីវភាពប្រចាំថ្ងៃ ។ ដោយមានសម្ភារៈការអនុវត្តជំនាញជាប្រចាំ នាំឱ្យពួកគាត់កាន់តែមានបទពិសោធន៍ល្អៗថែមទៀត លើការបំពេញតួនាទីជាអ្នកព្យាបាលសត្វចិញ្ចឹមដែលមានជម្ងឺ ក៏ដូចជាការផ្តល់ វ៉ាក់សាំងការពារជម្ងឺសត្វនៅក្នុងសហគមន៍ បានកាន់តែប្រសើឡើង ។ ដោយឡែកទំនាក់ទំនងពតិមានរវាងមន្ទីរកសិកម្ម និងសហគមន៍ នៅពេលដែលមាន បញ្ហាកើតឡើង ទៅលើសត្វចិញ្ចិម របស់កសិករតែងត្រូវបានផ្តល់ត្រឡប់មកថ្នាក់មន្ទីរ ដើម្បីសុំយោបល់ឬសុំជំនួយផ្នែកព្យាបាលទាន់ពេលជាងមុន ។ ជាងនេះទៀត ដោយសារ សត្វចិញ្ចឹម មាន សុខភាពល្អ នាំកសិករមានជីភាពប្រសើរជាងមុន ទទួលបានប្រាក់ចំណូលពីការលក់សត្វចិញ្ចឹម ដូចជាជ្រូក គោ មាន់ទា ទទួលបានកម្រៃសម្រាប់ ឱ្យកូនទៅ សាលារៀន និងសម្រាប់ជាអាហារ បរិភោគប្រចាំថ្ងៃ ដោយមិនចាំបាច់ចំណាយប្រាក់ទិញ ។

## លទ្ធផលទី៧: ការបណ្តុះបណ្តាលកសិករពីបច្ចេកទេស ផ្សព្វផ្សាយសុខភាពសត្វ ផលិតកម្ម និងការបង្ហាញ

**ផ្នែក-ក :**

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ៧.១ | សក ខ.៣.១ ផ្តល់ការបណ្តុះបណ្តាលបំប៉នដល់ភ្នាក់ ងារពេទ្យសត្វភូមិចំនួន ១៥ នាក់ក្នុងឃុំគោលដៅ នៅស្រុកសំរោង(បន្សាយរាក់ សំរោង បុស្សបូវ) | ផ្តល់ការបណ្តុះបណ្តាលបំប៉នដល់ភ្នាក់ងារ ពេទ្យ សត្វភូមិចំនួន ១៥ នាក់ ចំនួន ១វគ្គ ក្នុងឃុំគោល ដៅនៅស្រុកសំរោង (បន្សាយរាក់ សំរោង បុស្សបូវ) ។ |
| ៧.២ | សក ខ.៣.២ ផ្តល់ការបំពាក់បំប៉នដល់ភ្នាក់ងារ ពេទ្យសត្វភូមិចំនួន ១០ នាក់ក្នុងឃុំគោលដៅ នៅ ស្រុកចុងកាល់ នៅ(ឃុំជើងទៀន និងឃុំក្រសាំង) | ផ្តល់ការបំពាក់បំប៉នដល់ភ្នាក់ងារពេទ្យសត្វភូមិចំនួន ១0នាក់ ចំនួន ១វគ្គ ឃុំគោលដៅ នៅស្រុកចុងកាល់ នៅ(ឃុំជើងទៀន និងឃុំក្រសាំង) ។ |
| ៧.៣ | សក ខ.៣.៣ផ្តល់ការបណ្តុះបណ្តាលបំប៉នជំនាញដល់ ភ្នាក់ងារពេទ្យសត្វភូមិចំនួន ១៥ នាក់ក្នុងឃុំគោលដៅ នៅស្រុកអន្លង់វែង ។ | ផ្តល់ការបណ្តុះបណ្តាលបំប៉នជំនាញដល់ភ្នាក់ងារពេទ្យសត្វភូមិចំនួន ១២ នាក់ ចំនួន ១វគ្គ ក្នុងឃុំគោលដៅ នៅស្រុកអន្លង់វែង (ឃុំ អន្លង់វែង ឃុំ ត្រពាំងប្រីយ៍) |
| ៧.៤ | សក ខ.៣.៤ ផ្តល់ការបណ្តុះបណ្តាលបំប៉ន ជំនាញ ដល់ភ្នាក់ងារ ពេទ្យសត្វភូមិចំនួន ១៥ នាក់ក្នុងឃុំគោល ដៅ នៅឃុំត្រពាំងប្រាសាទផ្អាវ និងអូរស្វាយ | ផ្តល់ការបណ្តុះបណ្តាលបំប៉នជំនាញដល់ភ្នាក់ងារពេទ្យសត្វភូមិចំនួន ១៨ នាក់ ចំនួន ១វគ្គ ក្នុងឃុំគោល ដៅ នៅឃុំត្រពាំងប្រាសាទ ផ្អាវ និង អូរស្វាយ ។ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីការសម្រេចបាននូវលទ្ធផល ធៀបនឹងគោលបំណងបន្ទាន់

| |
|---|
| កសិករចំនួន ៥២ នាក់ ស្រី 0 នាក់ សស្មើនឹង ៩៥ % ទទួលបានជំនាញពីវគ្គបណ្តុះបណ្តាល ឱ្យក្លាយទៅជាភ្នាក់ងារសុខភាពសត្វភូមិ ក្នុងឃុំគោលដៅចំនួន ៤ ឃុំ ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋដែលបានលើកឡើងនៅក្នុងកម្មវិធីវិនិយោគឃុំ ។ ក្រុមគោលដៅបានចូលរួមក្នុងវគ្គបានគ្រប់ៗគ្នាតាមផែនការគ្រោងទុក និងបានប្រើប្រាស់ចំណេះដឹងជាទុនសម្រាប់រកប្រាក់ចំណូលប្រចាំគ្រួសារ ដោយបានជួយជាវិភាគទានដ៏សំខាន់ លើការថែទាំសុខភាពសត្វនៅក្នុងសហគមន៍ដើម្បីរកកម្រៃទ្រទ្រង់ ជីវភាពប្រចាំថ្ងៃ ។ ដោយសារមានចំណេះដឹងជាមូលដ្ឋាន ក្រុមគោលដៅ បានអនុវត្តជំនាញនេះជាប្រចាំ នាំឱ្យពួកគាត់កាន់តែមានបទពិសោធន៍ល្អៗថែមទៀត លើការបំពេញតួនាទីជា អ្នកព្យាបាលសត្វចិញ្ចឹមដែលមានជម្ងឺ ក៏ដូចជាការផ្តល់ វ៉ាក់សាំងការពារជម្ងឺសត្វនៅក្នុងសហគមន៍ បានកាន់តែប្រសើឡើង ។ ដោយខ្សែទំនាក់ទំនងពតិមាន រវាងមន្ទីរកសិកម្ម និងសហគមន៍នៅពេលដែលមាន បញ្ហាកើតឡើង ទៅលើ សត្វចិញ្ចឹម របស់កសិករតែងត្រូវបានផ្តល់ត្រឡប់មកថ្នាក់មន្ទីរ ដើម្បីសុំយោបល់ឬសុំជំនួយផ្នែកព្យាបាលទាន់ពេលជាងមុន ។ ជាងនេះទៀតដោយសារសត្វចិញ្ចឹមមានសុខភាពល្អ នាំឱ្យជីវភាពកសិករប្រសើរជាងមុន ទទួលបានប្រាក់ចំណូលពីការលក់សត្វចិញ្ចឹម ដូចជាជ្រូក គោ មាន់ទា ទទួលបានកម្រៃសម្រាប់ ឱ្យកូនទៅសាលារៀន និងសម្រាប់ជាអាហារ បរិភោគប្រចាំថ្ងៃ ដោយមិនចាំបាច់ចំណាយប្រាក់ទិញ។ |

## ២.២. ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៏បឋម

### ផ្នែក-កៈ ការសម្រេចបាននូវស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា (សំណួរវាយតម្លៃទី២)

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា (១) | ស្ថានភាពជាក់ស្តែងនៅពេលបញ្ចប់ អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| នៅចុងបញ្ចប់នៃកិច្ចសន្យានេះយើង និងទទួលបានពីមូលដ្ឋាននូវលទ្ធផលគួជាទីគាប់ចិត្ត គឺប្រជាកសិករចំនួន ៤00នាក់ បានជ្រួតជ្រាបយ៉ាងប្រសើរលើបច្ចេកទេសដំណាំស្រូវប្រពលវប្បកម្ម ដោយប្រើប្រាស់ពូជស្រូវដែលមានទិន្នផលខ្ពស់និងដែល ផ្តល់ដោយមន្ទីរសម្រាប់ធ្វើបង្ហាញដល់កសិករ ហើយទិន្នផល ស្រូវរបស់កសិករគោលដៅត្រូវបានកើនឡើង។ ជាងនេះទៀត កសិករគោលដៅ ដែលទទួលបានការ បណ្តុះបណ្តាលពេទ្យសត្វភូមិ និងទទួល បាននូវបទ ពិសោធន៏ដោយកែប្រែ ទំលាប់ ចាស់បែរមកអនុវត្តតាម របៀបថ្មី និងបានទទួលប្រាក់ ចំណូលគ្រួសារប្រសើជាង មុន ។ | ស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា ជាក់ស្តែង អ្នកទទួលផល ៨0% បានអនុវត្តការការបង្កបង្កើនផលតាមបច្ចេកទេស និងទទួលបានទិន្នផលប្រសើជាងមុន ដោយពួកគាត់បាន ប្រើប្រាស់ពូជស្រូវ និងបន្លែដែលជម្រុញឱ្យកសិករមាន ជីវភាពគ្រាន់បើជាងមុន ពីការលក់ បន្លែ តាមរដូវ និង ធ្វើជាអាហារប្រចាំថ្ងៃ និងអាចសន្សំលុយកាក់ ខ្លះ សម្រាប់កូនចៅបានរៀនសូត្រ ។ |

### ផ្នែក-ខៈ ការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា (សំណួរវាយតម្លៃទី៣)

| ធាតុនៃគោលបំណងបន្ទាន់ (១) | ការសម្រេចបានជាក់ស្តែង នៅពេលបញ្ចប់ អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| ទុនដែលបានគាំទ្រ ដើម្បីបង្កើត អនុកិច្ចសន្យានេះឡើង គឺបានមក ពីកម្លាំងធនធានដែលមាននៅក្នុង គ.ប្រ និង មន្ទីរកសិកម្ម ដូចជាមន្ត្រីជំនាញដែលមានជំនាញនិង បទពិសោធន៏ស្រាប់។ មន្ត្រីគ.ប្រមានធនធានមនុស្សសម្រាប់រួមចំណែករៀបចំ និងអនុវត្តគម្រោង នេះទៅ | អនុកិច្ចសន្យាត្រូវបានបញ្ចប់តាមការគ្រោងទុក និទទួលបានលទ្ធផលជាផ្លែផ្កាគួជាទីគាប់ចិត្ត ដោយសារគម្រោងនេះអនុវត្តបានចប់ ១00% បានជួយជាវិភាគទាន ដ៏សំខាន់ ដល់ការកែលម្អសន្តិសុខស្បៀង របស់កសិករទទួលផលភាគច្រើន ។ ដោយសារក្រុមគោលដៅ ទទួល |

| | |
|---|---|
| បានរលូន ។ អនុកិច្ចសន្យាអនុវត្តន៍ទៅបានដោយសារមានកិច្ចសហការល្អពីអាជ្ញាធរ ឃុំ-ភូមិ និង ស្រុក-ក្រុងក្នុងតំបន់គោលដៅ ។ | ផលពីគម្រោង ទទួលបានចំណេះដឹង និងបានប្រើប្រាស់ចំណេះដឹងនេះទៅអនុវត្ត និងបានទទួលជោគជ័យ យ៉ាងហោចណាស់ ៥០% នៃក្រុមទទួលផលបានទទួលផលប្រយោជន៍ ពីអនុកិច្ចសន្យានេះ ។ |

**ផ្នែក-គៈ សង្ខេបការវាយតម្លៃ "លទ្ធផល" និង "ផលប្រយោជន៍" ដែលអាចបំលែងជាបរិមាណ អាចវាស់វែងបាន និងអាចមើលឃើញៈ**

| |
|---|
| តាមរយៈការសង្កេត នៅក្នុងសហគមន៍ ភូមិ គោលដៅដែលកសិករជាក្រុមទទួលផល កំពុងរស់នៅ មានក្រុមកសិករ ដែលពុំបានចូលរួម ការបណ្តុះបណ្តាល បានយកគំរូតាមអ្នកទទួលផល តាមរយៈការពិនិត្យមើល និងធ្វើតាមតៗគ្នា នាំឱ្យពួកគាត់មាន ចំណេះដឹង លើរបៀបដាំដុះដំណាំបន្លែ របៀបធ្វើជីកំប៉ុស្ត និងការធ្វើស្រែតាមគោលការណ៍ធម្មជាតិ ។ល។ តាមរយៈការអនុវត្តតាមបច្ចេកទេសកសិកម្មសមស្របទាំងឡាយ ទទួលបានទិន្នផលខ្ពស់ជាងមុន រក្សាបាននូវ លំនឹងសន្តិសុខស្បៀង ក៏ដូចជាជីវភាពប្រចាំថ្ងៃរបស់ពួកគាត់បានប្រសើឡើង ។ |

## ករណីសិក្សា

លោក នាម សំអាល ដែលជាអ្នកទទួលផលពីដំណាំបន្លែ នៅភូមិទទឹងថ្ងៃ ឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យៈ "ជីវភាពរស់នៅរបស់ខ្ញុំ មានការប្រសើរឡើង តាំងពីខ្ញុំបានទទួលចំណេះដឹងពីដំណាំបន្លែសម្រាប់យកទៅអនុវត្តន៍"

បន្ទាប់ពីចូលរួមវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសដំណាំបន្លែរបស់មន្ត្រីមន្ទីរកសិកម្មខេត្ត ឧត្តរមានជ័យលោកបាននិយាយថាបច្ចុប្បន្ននេះ បន្លែជាអាហារប្រចាំថ្ងៃរបស់យើងមានគ្រប់គ្រាន់។ សមាជិក គ្រួសារដែលបានទទួលការបណ្តុះបណ្តាល និងបានទទួលបច្ចេកទេសពូជបន្លែរបស់មន្ទីរកសិកម្មខេត្ត ឃើញថាជីវភាពរបស់ខ្ញុំមានភាពប្រសើរជាងមុន។ លោក នាម សំអាល និយាយបន្តទៀតថា គ្រួសារក្រណាស់ទើបខ្ញុំមិនអាចបញ្ជូនកូនទៅរៀនបានជាប់លាប់ឡើយ។ ពេលនេះខ្ញុំរីករាយណាស់នៅពេលប្រៀបធៀបទៅនឹងស្ថានភាពពីមុនរបស់ខ្ញុំ។ប្រជាពលរដ្ឋភាគច្រើនក៏ចាប់អារម្មណ៍ដូចគាត់ដែរព្រោះគ្រួសារគាត់មានជីវភាពប្រសើរជាងមុន។

**២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង (សំណួរវាយតម្លៃទី ៤)**

**ផ្នែក-ក: ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅនឹងតំរូវការ: មន្ទីរវិស័យ មូលដ្ឋាន គ.ជ.អ.ប និងការកាត់បន្ថយភាព ក្រីក្រ:**

| ល.រ (១) | ធាតុ (២) | ទំនាក់ទំនងតក្កភាព (៣) | បរិយាយច្បាស់លាស់ (៤) | សង្ខេបការវាយតម្លៃ (៥) |
|---|---|---|---|---|
| ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់ | | | | |
| ១ | សកម្មភាព | ៤ | ៤ | |
| ២ | លទ្ធផល | ៤ | ៤ | |
| ៣ | អត្ថប្រយោជន៍រយៈពេលខ្លី:<br>(លទ្ធផល/ផលប្រយោជន៍)<br>- គោលបំណងបន្ទាន់ *(គោលបំណងស្ថិតក្នុងចំណុច "ខ" នៃផ្នែកទី ៣)*<br>- ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា *(ចំណុច "គ" នៃផ្នែកទី ៣)* | ៣<br>៣<br>៤<br>៤ | ៣<br>៣<br>៤<br>៤ | |
| ៤ | លទ្ធផលអភិវឌ្ឍន៍/ផលប៉ះពាល់រយៈ ពេលវែង:<br>គោលដៅ និងគោលបំណងអភិវឌ្ឍន៍ *( ចំណុច "ខ" នៃផ្នែកទី ៣)* | ៣<br>៣ | ៣<br>៣ | |

**ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខ័ណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារ:**

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.ជ.អ.ខ:** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | ជួយគាំទ្រក្នុងការរៀបចំកិច្ចសន្យា |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យ ការអនុវត្តន៍ របស់ភ្នាក់ងារអនុវត្តន៍ | ជួយគាំទ្រការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យ ការអនុវត្តន៍របស់ភ្នាក់ងារអនុវត្តន៍ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារ | ជួយពិនិត្យតាមដាន ការត្រួតពិនិត្យ និងកត់ត្រា ឯកសារ អនុកិច្ចសន្យា |

| | | |
|---|---|---|
| | អនុកិច្ចសន្យា | |
| **ពីខាងភាគីអនុវត្តន៏កិច្ចសន្យាៈ** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | មានចំណេះដឹងជំនាញក្នុងការគ្រប់គ្រងគម្រោង និងបច្ចេកទេស |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | មានពេល ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផលបានល្អ |
| ៦ | ការរាយការណ៍ការរីកចម្រើន និង ការកត់ត្រាឯកសារ | រៀបចំរបាយការណ៏រីកចម្រើន និង ការកត់ត្រាឯកសារ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | មន្រ្តីអនុវត្តន៏កិច្ចសន្យាគោរពតាមលក្ខខណ្ឌកិច្ចសន្យា |
| **ទាំងខាង គ.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យាៈ** | | |
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្មត" (ចំណុច-ង ផ្នែកទី៣ ) និងបញ្ហាប្រឈម | ថ្វីត្បិតនេះជាកម្មវិធីដែលមន្ទីរធ្លាប់បានអនុវត្តមានរយៈយូរបង្គួរមកហើយក្តី ការអនុវត្តអនុកិច្ចសន្យាត្រឹមពេលមួយឆ្នាំ ឱ្យបានចប់ សព្វគ្រប់ ទាមទារ ឱ្យមានការរៀបចំផែនការ និង សហប្រត្តិបត្តិការសំរបសំរួល ដើម្បីធានា លើពេលវេលា និង គុណភាព នៃបទ ពិសោធន៏ដែលបាន មកពីការ បណ្តុះបណ្តាល និងអនុវត្តការងារសម្រាប់ទាំងអស់គ្នា។ គ្រោះថ្នាក់ សំខាន់ ដែលនឹងកើតមានឡើង ក្នុងកំឡុងពេលអនុវត្តន៏ កិច្ចសន្យានេះគឺ បទពិសោធន៏ និង ពេលវេលារបស់មន្ត្រីនៅមានកំរិត តាមរយៈការបណ្តុះបណ្តុល និង ការផ្សព្វផ្សាយ មិនអាចត្រូវបាន យកទៅអនុវត្ត ដោយ សហ គមន៏ ព្រោះហេតុថា ពួកគេនៅមាន ការខ្វះខាត ធនធាន និង បច្ចេកទេស ក្នុងការផ្តល់ការប្រឹក្សាយោបល់ នៅថ្នាក់មូលដ្ឋានផ្ទាល់នោះ គឺជាឧបសគ្គដ៏សំខាន់មួយទៀត ។ ម្យ៉ាងទៀត ការប្រមូលកសិករ ចូលរួមក្នុងការ បណ្តុះបណ្តាលដែលពុំមានកំរៃគឺជាឧបសគ្គមួយដែរ។ គម្រោងអាចអនុវត្តទៅបានតាមផែនការ លុះត្រាណា តែមានការចូលរួម ខ្លាំងក្លាពីសហគមន៏ និង អាជ្ញាធរមូលដ្ឋានផងដែរ ។ |
| ៩ | ការបញ្រ្ជាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | កិច្ចសន្យាត្រូវមានការយកចិត្តទុកដាក់ចំពោះការចូលរួមរបស់ស្ត្រី លើក ស្ទួយស្ថានភាព ស្ត្រីក្នុងសង្គមគឺជាផ្នែកមួយ នៃការប្តេជ្ញា ចិត្តដែលមាន ចែងក្នុងអនុកិច្ចសន្យានេះ ។ ការផ្តល់ចំណេះដឹងពីយេនឌ័រក្នុងកិច្ច អភិវឌ្ឍន៏ធ្វើ ឱ្យមន្ត្រីមន្ទីរ កសិកម្មខេត្ត អាចជួយ ជំរុញឱ្យ មានការ ចូលរួមយ៉ាង ពេញលេញ |

| | | |
|---|---|---|
| | | ពីស្ត្រី និងបុរស នៅពេលដំណើរការធ្វើ សកម្ម ភាពអភិវឌ្ឍន៍ លើវិស័យកសិកម្ម។ ស្ត្រីជាកសិករ និងចូលរួមយ៉ាង សកម្ម ក្នុងការ បណ្តុះបណ្តាលពីបច្ចេកទេស សមស្របលើផ្នែកកសិកម្មដែល នឹង ធ្វើឡើងនៅក្នុង មូលដ្ឋានដែលគេរស់នៅ។ បន្ថែមលើនេះទៀត ភ្នាក់ងារ អនុវត្តគម្រោងនៃកិច្ចសន្យា និងផ្តល់អាទិភាព ដល់ស្ត្រីជាកសិករ ក្នុងការចូលរួម បំរើការងារនិងជ្រើសរើសកសិករ ក្នុងការដាំ ដុះដំណាំស្រូវ និងបច្ចេកទេសចិញ្ចឹមត្រីតាមរយៈ ការធ្វើ បង្ហាញដោយផ្ទាល់។ កិច្ចសន្យា នេះនិងដាក់ បញ្ចូលផងដែរ ដោយលើកទឹកចិត្ត ទាំងស្ត្រីទាំងបុរស ចូលរួម ក្នុងកម្មវិធីបណ្តុះ បណ្តាល និង មានបញ្ចូល ឈុតខ្លី១ ពីទស្សនៈ យេនឌ័រ ដើម្បីឱ្យសិក្ខាកាម បានយល់ដឹងពីតួនាទី យេនឌ័រក្នុង សហគមន៍ និងដែល តែងតែមានការ ជាប់ទាក់ទងជាមួយនឹងបញ្ហាស្ត្រីនិង កុមារក៏ដូចជា បញ្ហា ដ៏ទៃទៀតជា ច្រើន ដែលស្ត្រី និងបុរស ក្នុងសហគមន៍កំពុង ជួបប្រទះ ។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ ( ចំណុច-ឆ ផ្នែកទី៣) | កិច្ចសន្យានេះជាផ្នែកមួយនៃការចូលរួមយ៉ាងសំខាន់បំផុត ក្នុងការអភិវឌ្ឍន៍ការ កែលំអបរិស្ថាន និង ការការពារធនធានធម្មជាតិដែល មន្ទីរកំពុងយកចិត្តទុក្ខដាក់នឹងធានាឱ្យបានប្រសើរឡើងលើការការពារថែរក្សាបរិស្ថាន។<br>ការអភិវឌ្ឍន៍ លើវិស័យកសិកម្មជាឆន្ទៈ ដែលផ្តោត ទៅលើការគ្រប់គ្រងធនធាន ឱ្យបានយូរអង្វែង ទន្ទឹមគ្នានេះដែរគម្រោង និង ផ្តោតលើការប្រើប្រាស់ និងគ្រប់ គ្រងឱ្យបាន ត្រឹមត្រូវនូវធនធានធម្មជាតិទាំងនោះ ។ ជាងនេះទៀតមន្ទីរ បានផ្តល់ចំណេះដឹងពីបច្ចេកទេស ប្រើប្រាស់ជីសរីរាង្គជំនួសឱ្យជីគីមីនិងការ ប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត គឺជាការរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តន៍ នូវយុទ្ធសាស្ត្របញ្ច្រាប ការគ្រប់គ្រង ធនធាន ធម្មជាតិ និងបរិស្ថាន ។ ដោយសារកម្មវិធីបានផ្តល់អន្តរាគមន៍លើវិស័យនេះ នឹងនាំឱ្យប្រជាកសិករ តាមសហគមន៍ មានការយល់ដឹងកាន់តែប្រសើ ឡើង កាត់បន្ថយបាននូវការ កាប់ព្រៃ ឈើលក់ ដោយបែរមកធ្វើមុខរបរកសិកម្មតាមបែបធម្មជាតិ វិញដើម្បីបង្កើន ប្រាក់ចំណូលក្នុងគ្រួសារ ។ |
| ១១ | ការថែរក្សា (និរន្តភាព) ( ចំណុច-ជ ផ្នែកទី៣) | អនុកិច្ចសន្យាគឺជាគំនិតផ្តើមក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកដែលជា អាទិភាពក្នុងផែនការអភិវឌ្ឍន៍ឃុំ ដោយទទូចចង់បានឱ្យមានការ |

| | | |
|---|---|---|
| | | បណ្តុះបណ្តាល ពីបច្ចេកទេសកសិកម្មដើម្បីបង្កើនទិន្នផលស្រូវ។ តាមរយៈការផ្តល់ការបណ្តុះបណ្តាលនិងផ្សព្វផ្សាយដោយផ្ទាល់ ជាមួយនឹងកិច្ចសហការ សំរបសំរួល គោលបំណងនេះគឺដើម្បីពង្រឹង សិទ្ធិអំណាច សហគមន៍មូលដ្ឋាន បង្កើន ជំនឿ ទុកចិត្ត និងធានាដល់និរន្តរភាពនៃ ការគ្រប់គ្រងការអនុវត្តតាមបច្ចេកទេសក សិកម្ម ថ្មីនិងឈាន ទៅកាត់បន្ថយតំរូវការ ជំនួយ វិភាគ ទានពីខាងក្រៅ ។ គណៈកម្មការទិញសម្ភារត្រូវបានបង្កើត ឡើងហើយយ៉ាងហោចណាស់ក៏មានសមាជិក៤នាក់ដែរ(បុគ្គលិកមន្ទីរកសិកម្មមួយនាក់, គ.ប្រពីរនាក់, និងអ្នកសង្កេតការណ៍ ភីអេសឌីភី មួយនាក់) ការបញ្ជាទិញសម្ភារគ្រប់ប្រភេទត្រូវអនុវត្តន៏តាមគម្រោងការស្នើសុំ សម្ភារ និងត្រូវបានយកពីហាងដែលបានជ្រើសរើសរួច។ |

## ២.៤. សេចក្តីសន្និដ្ឋាន (សំណួរវាយតម្លៃទី ៥)

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | យោងតាមបទពិសោធន៏កន្លងមកការផ្តល់វគ្គបណ្តុះបណ្តាល ស្តីពីបច្ចេកទេសបង្កើន ទិន្នផលស្រូវ ប.រ.ស ដល់កសិករ គោលដៅតែងតែមានការយឺតយ៉ាវខ្លះ ដោយសារការខ្វះខាតទាំងពេលវេលា និងសម្ភារបរិក្ខាបច្ចេកទេស ចាំបាច់មួយ ចំនួនការ រីឯការអនុវត្តន៏គម្រោងការ ចំពេលប្រជាកសិករ ជាប់មមាញឹកក្នុងការងារបង្កបង្កើនផល។ ទោះជាយ៉ាងណាក្តី មន្ត្រីជំនាញបានធ្វើការប្រមូលផ្តុំ ពន្យល់ណែនាំដល់ប្រជាពលរដ្ឋ ក្រុមគោលដៅអំពីគោលគំនិត និង បច្ចេកទេសបង្កើន ទិន្នផលស្រូវបានយ៉ាងល្អិតល្អន់ នាំឱ្យពួកគាត់មាន ចំណាប់អារម្មណ៍ និងមានឆន្ទះចូលរួម។ បទពិសោធន៏ល្អៗដែល បានពីការអនុវត្តន៏កន្លងមកនេះ គឺការចូលរួមពេញលេញក្នុងវគ្គបណ្តុះបណ្តាល និងបន្តការយកចិត្ត ទុកដាក អនុវត្តតាមការរៀនសូត្រនាពេលបន្ទាប់ភ្លាមៗ។ យោងតាមការវាយតំលៃបញ្ចប់គម្រោង កសិករដែលបាន អនុវត្តតាមបច្ចេកទេស ត្រឹមត្រូវ តែងតែទទួលបានទិន្នផលស្រូវខ្ពស់គួជាទីពេញចិត្ត ក៏ប៉ុន្តែ ដោយដីស្រែ របស់ពួកគាត់មានទំហំតូច និងជួនកាល បានជួបប្រទះពីភាពរាំងស្ងួតទៀត ធ្វើឱ្យការអនុវត្តមិនអាចទទួលបានជោគជ័យ ១០០% នោះទេ។ ដើម្បីអនុវត្ត អនុកិច្ចសន្យាថ្មីនេះមន្ទីរនឹងបង្កើនការយកចិត្តទុកដាក់ ក្នុងការរៀបចំកាលវិភាគ និងរៀបចំឯកសារ ឱ្យសមស្រប សម្រាប់មូលដ្ឋានតាមស្ថានភាពជាក់ស្តែង និង បង្កើនការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ ធានាបានឯកសារ ស្របតាមកំរិតយល់ដឹងរបស់ប្រជាកសិករមូលដ្ឋាន |

| | |
|---|---|
| | ដើម្បីធ្វើការបង្ហាញ ពីការធ្វើស្រែតាមបច្ចេកទេស បវស និងចិញ្ចឹមសត្វ តាមបច្ចេកទេសថ្មីឱ្យទទួលបាននូវលទ្ធផលល្អនិងមានគុណភាពខ្ពស់ ។ ម្យ៉ាងទៀតកសិករភាគច្រើន បានទទួលយកការ ចេះដឹងរបស់ពួកគេ ទៅអនុវត្តតាមការធ្វើស្រែតាមបែបប្រពលវប្បកម្ម ដោយសំចេបានជោគជ័យល្អបង្គួនិងមានជំនឿជឿជាក់លើការងារនេះ ដោយបានបង្កើនការប្តេជ្ញាចិត្តកាន់តែខ្ពស់ដើម្បីអនុវត្តតាមការបង្ហាត់បង្ហាញ ។ |
| ២ | មន្ទីរកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ ខេត្តឧត្តរមានជ័យ បានចុះកិច្ចសន្យាជាមួយគ.ប្រ នៃ គ.អ.ជ.ខ នាដើមឆ្នាំ ២០០៩ និងបានទទួលថវិកាវិភាជពី ប្រ.ក នៃ គ.អ.ជ.ខ ចំនួន 6,926.05 ដុល្លា សហរដ្ឋអាមេរិក។ ថវិកានេះគឺដើម្បីគាំទ្រ ដល់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ សម្រាប់អនុវត្តអនុកិច្ចសន្យាដែលផ្តោតលើការបណ្តុះបណ្តាលកសិករ អំពីបច្ចេកទេស ប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ស្ទួនបន្លែលក្ខណៈគ្រួសារ ការសន្សំជីកំប៉ុស្ត និងពង្រឹង ភ្នាក់ងារសុខភាពសត្វភូមិ។ គោលបំណងបន្ទាន់នៃអនុកិច្ចសន្យាគឺដើម្បី រួមចំណែកក្នុង ការកែលំអសន្តិសុខស្បៀង ដោយ ឡែក ក្នុងឆ្នាំ២០០៩ នេះ មន្ត្រីអនុវត្តគម្រោងនៃមន្ទីរកសិកម្ម បានចុះធ្វើការជ្រើសកសិករគំរូនៅក្នុងតំបន់គោលដៅ នៃស្រុកទាំង៥ ដោយមានកសិករប្រមាណជាង ២០០នាក់ ត្រូវបានជ្រើសរើស សម្រាប់ទទួលការបណ្តុះបណ្តាល លើបច្ចេកទេស "ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ដាំបន្លែ ធ្វើជីកំប៉ុស្ត" ។ ក្នុងឆ្នាំនេះផងដែរ មន្ត្រី អនុវត្តគម្រោងនៃមន្ទីរកសិកម្ម បានចុះធ្វើការជ្រើស ភ្នាក់ងារសុខភាពសត្វភូមិ ចំនួន ៥៥នាក់ទៀត សម្រាប់ទទួល ការបណ្តុះ បណ្តាលបន្ថែមលើបច្ចេកទេស "ការព្យាបាលសត្វ លក្ខណៈជំងឺ និងការចិបញ្ចឹមសត្វ"។ ជោគជ័យដ៏ចំបង មួយទៀតមន្ទីរបានរៀបចំផ្តល់ការបណ្តុះបណ្តាល ពីបច្ចេកទេសដំណាំស្រូវ តាមបែប បវស ដាំបន្លែ ធ្វើជីកំបុស្ត៍ ដល់កសិករ គំរូបានគ្រប់ផែនការកំណត់។ ក្រោយពីការបណ្តុះបណ្តាលបានបញ្ចប់មន្ទីរបានផ្តល់សម្ភារគាំទ្រមួយចំនួន ដល់កសិករ ១៩៩នាក់ សម្រាប់ការអនុវត្តន៍ក្រោយពេលបណ្តុះបណ្តាលចប់ សម្ភារទាំនោះដូចជា ពូជស្រូវស្រាល ផ្ការរំដួល ស្បូវប្រក់រោង ពូជត្រសក់ ពូជសណ្តែកកួរ ពូជត្រកួន ពូជស្ពៃក្រញាញ់។ ជាងនេះទៅទៀត សម្រាប់ភ្នាក់ងារ សុខភាពសត្វភូមិចំនួន ៥៥នាក់ បានគាំទ្រក្រោយពេលបណ្តុះបណ្តាលចប់ មានដូចជា ស៊ីរ៉ាំង , ម្ជុល , ថ្នាំព្យាបាលមួយចំនួន , ប្រអប់ដាក់ស៊ីរ៉ាំង , ប៉ាំង ដើម្បីយកទៅអនុវត្តក្នុងការព្យាបាល គោ-ក្របី ។ល។ នៅក្នុងសហគមន៍ របស់គាត់ រៀង១ខ្លួន ក្រោយពីបាលទទួល ចំណេះដឹងក្នុងការសិក្សា។ ផ្អែកលើការចុះតាមដានរបស់មន្ត្រីជំនាញ មានកសិករប្រហែល ៥០% បានអនុវត្តបាន តាមបច្ចេក ទេស សល់ពីនោះគឺមានកសិករខ្លះពុំបានអនុវត្តល្អ ត្រឹមត្រូវ នៅឡើយទេ។ ទោះជាយ៉ាងណាក្តីមន្ត្រី ជំនាញបានវាយតំលៃថា កសិករទាំងនោះ នៅតែមានចំណាប់អារម្មណ៍នឹងយក ចំណេះទាំងនេះ ទៅអនុវត្តនៅឆ្នាំក្រោយ១ទៀត ។ |
| ៣ | (ផ្តោតលើឧបសគ្គ និងការប្រឈមចំបង១ ដែលអាចចៀសវាងបាន) |

| | |
|---|---|
| | បញ្ហាប្រឈមដែលបានជួបប្រទះ គឺកសិករដែលបានជ្រើសរើសឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលមួយចំនួនមិនចេះអក្សរ ទាមទាការពន្យល់បកស្រាយដោយប្រើប្រាស់ រូបភាព និងការធ្វើបង្ហាញឱ្យបានហ្មត់ចត់ ក្នុងរយៈពេលនៃការបណ្តុះបណ្តាល ។បញ្ហាប្រឈមនៅទីនេះគឺ តំបន់គោលដៅភាគច្រើន ក្នុងខេត្តសម្បូរ ទៅដោយដីខ្សោះជីជាតិ ទាមទារឱ្យកសិករត្រូវប្រើជីធម្មជាតិ ដោយប្តូរទម្លាប់ប្រើជីគីមី និងថ្នាំសម្លាប់ល្អិតខុសបច្ចេកទេស ម្យ៉ាងទៀតតំបន់នេះតែងជួបប្រទះភាពរាងស្ងួត ជាញឹកញាប់ កសិករចាំបាច់ត្រូវមានប្រភពទឹកនៅជិត១ សម្រាប់បូមដាក់ស្រែ និងស្រោចដំណាំផងដែរ ។ |

<u>ចំណុចរៀនសូត្រ</u>:

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | មេរៀនដែលបានពីការវាយតំលៃ គឺជាបទពិសោធន៍សំខាន់បំផុត សំរាប់ការនុវត្តន៍អនុកិច្ចសន្យាលើកក្រោយ តាមរយៈការប្រើប្រាស់វិធីសាស្ត្រ និងឧបករណ៍ សម្រាប់វាយតម្លៃលើភាពជោគជ័យ និងផលប៉ះពាល់នៃអនុកិច្ចសន្យា ។ |
| ២ | អនុកិច្ចសន្យាដែលមានរយៈពេលត្រឹមមួយឆ្នាំ នំាឱ្យលំបាកក្នុងការវាស់វែង ឬពិចារណាទៅលើ ភាពជោគជ័យ ពីគម្រោង ។ |
| ៣ | កសិកររីករាយក្នុងការចូលរួម ដោយសារគម្រោងការនេះជាតម្រូវការពិតប្រាកដរបស់ពួកគាត់ (សន្តិសុខស្បៀង) |
| ៤ | ការរក្សាទុកមន្ត្រីមានបទពិសោធន៍សម្រាប់អនុវត្តន៍ឆ្នាំបន្តទៀតតាមរយៈការរៀបចំផែនការ ការងារទាន់ពេលវេលា ក៏ដូចជាការ រៀបចំបញ្ចប់គម្រោងមុនដំណាច់ឆ្នាំ ។ |

<u>អនុសាសន៍</u> :

| ល.រ | អនុសាសន៍ |
|---|---|
| ១ | គួមានការបណ្តុះបណ្តាលពង្រឹងសមត្ថភាពកសិករពីបច្ចេកទេសដាំស្រូវ ដាំបន្លែ ធ្វើជីកំប៉ុស្ត គួបង្កើនថវិកាគាំទ្រ គម្រោង ដែលឆ្លើយតប ទៅនឹងតំរូវការឃុំក្នុងកម្មវិធីវិនិយោគឃុំ ។ |
| ២ | គួមានកម្មវិធីដែលគាំទ្រទៅដល់ ការបង្ហាញផ្នែកក្សេត្រសាស្ត្រ (ឈើហូបផ្លែ ស្រូវ បន្លែ ដំណាំ)ឱ្យបានទូលំទូលាយជាងមុន |
| ៣ | គួបង្កើនការយកចិត្តទុកដាក់លើយុទ្ធសាស្ត្របញ្ជ្រាប បង្កើនទិន្នផលស្រូវ និង សួនបន្លែជាលក្ខណ:គ្រួសារទៅក្នុង កម្មវិធីវិនិយោគឃុំ ។ |

## ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍

**ឯកសារដែលត្រូវភ្ជាប់ទី១ : បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារទាក់ទងផ្សេងៗ ដែលបានពិនិត្យ**

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) | មាន (៣) |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) និង ឯកសារវិសោធនកម្ម (ប្រសិនមាន) | √ |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្តអនុកិច្ចសន្យា /មន្ទីរវិស័យ | ដកចេញ |
| ៣ | របាយការណ៍ត្រួតពិនិត្យគម្រោង | √ |
| ៤ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | √ |
| ៥ | លិខិតឆ្លើយឆ្លងរវាងភ្នាក់ងារអនុវត្តន៍ និងគណៈកម្មាធិការប្រត្តិបត្តិគ.អ.ជ.ខ | ដកចេញ |
| ៦ | បញ្ជីវត្ថុបណ្តុះបណ្តាលដែលមានក្នុងអនុកិច្ចសន្យា | ដកចេញ |
| ៧ | របាយការណ៍ហិរញ្ញវត្ថុរបស់អនុកិច្ចសន្យា | ដកចេញ |
| ៨ | ឯកសារដ៏ទៃទៀតរួមមាន រូបថតនៃគម្រោង (អនុកិច្ចសន្យា) ដែលទុកនៅគណៈកម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ និងនៅភ្នាក់ងារអនុវត្តន៍ ដែលមិនបានរៀបរាប់ខាងលើ | ដកចេញ |
| ៩ | ផ្សេងទៀត | |

## ឯកសារដែលត្រូវភ្ជាប់ទី២: បញ្ជីឈ្មោះអ្នកផ្តល់ព័តិមានសំខាន់ៗ ដែលបានជួបសម្ភាសន៍/ជួបពិភាក្សា

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៍ប្រើសម្រាប់ប្រមូលទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | ២៥ តុលា | -លោក ផុន ចាន់និលមន្ត្រីត្រួតពិនិត្យនិងវាយតម្លៃ ផ្នែកគ្រប់គ្រងកិច្ចសន្យា<br>-លោក យ៉ត វង្សមុន្នីរត្ន័ន៍ មន្ត្រីគ្រប់គ្រងកិច្ចសន្យានិងរដ្ឋបាល គ.ប្រ | គ.ប្រ ខេត្ត | សម្ភាសន៍ស៊ីជម្រៅ |
| ២ | ២៦ តុលា | លោក សន សេដ្ឋា មន្ត្រីបង្គោលត្រួតពិនិត្យ និងវាយតម្លៃ និងមន្ត្រីទទួលខុសត្រូវ | មន្ទីរកសិកម្មខេត្ត | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | ២៧ តុលា | ក្រុមអ្នកទទួលផល | ភូមិទទឹងថ្ងៃ ឃុំបេង ស្រុកបន្ទាយអំពិល | សម្ភាសជាក្រុម |
| ៤ | ២៨ តុលា | លោក នាម សំអាល ប្រជាពលរដ្ឋ អ្នកទទួលផលផ្ទាល់ | ភូមិទទឹងថ្ងៃ ឃុំបេង ស្រុកបន្ទាយអំពិល | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៥ | ២៨ តុលា | លោកស្រី ភីយ សារ៉ាយ ប្រជាពលរដ្ឋជាអ្នកមិនទទួលផល | ភូមិទទឹងថ្ងៃ ឃុំបេង ស្រុកបន្ទាយអំពិល | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៦ | | មន្ត្រីបង្គោលយេនឌ័រ | | |
| ៧ | | មន្ត្រីបង្គោល គ្រប់គ្រងធនធានធម្មជាតិ | | |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា : | 23/GEN/0901-00 |
| ចំណងជើង : | គាំទ្រដល់ការចូលរួមរបស់ស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍ |
| ភ្នាក់ងារអនុវត្តន៍ : | មន្ទីរកិច្ចការនារី |
| រយះពេល（ចាប់ផ្តើម និង បញ្ចប់）: | ០១ មករា ២០០៩ ដល់ ៣១ ធ្នូ ២០០៩ |
| ខេត្ត : | ខេត្តកែប |
| ផ្នែក / មន្ទីរជំនាញ : | មន្ទីរកិច្ចការនារី |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ប ឬ គ.ប្រនៃ គ.អ.ជ.ខ | 4,825.00 USD |
| ការរួមចំណែកដោយសហគមន៍ : | 120.00 USD |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្តន៍ : | 400.00 USD |
| តម្លៃសរុប（ដុល្លារសហរដ្ឋអាមេរិក）: | 5,345.00 USD |

## ក្រុមវាយតម្លៃ និងរៀបចំរបាយការណ៍

| ឈ្មោះ | មុខតំណែង និង ភ្នាក់ងារ |
|---|---|
| ១-លោក ម៉ែន វណ្ណៈ | គ្រូបង្គោលប្រចាំខេត្ត |
| ២- កញ្ញា ជិន សុភ័ក្រ្តា | គ្រូបង្គោលប្រចាំខេត្ត |
| ៣-លោក សៀប អឿន | មន្ត្រីតាមដានត្រួតពិនិត្យ និងវាយតម្លៃ គ.ប្រ |

## ខេត្ត ៖ កែប

កាលបរិច្ឆេទ :០៤/១០/២០១០

ខែ កញ្ញា –តុលា ឆ្នាំ ២០១០

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៣ |
| | របាយការណ៏សង្ខេប | ៤ |
| **១** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៨** |
| ១.១ | សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខ និងមន្ទីរវិស័យ | ៨ |
| ១.២ | គោលបំណងអនុកិច្ចសន្យា | ៨ |
| ១.៣ | គោលបំណង និង ទំហំនៃការវាយតម្លៃ | ៨ |
| ១.៤ | សំណួរវាយតម្លៃ | ៩ |
| ១.៥ | វិធីសាស្រ្ត សម្ភារៈ និងដំណើរការវាយតម្លៃ | ៩ |
| ១.៦ | ដែនកំណត់ និងបញ្ហាប្រឈមនៃការវាយតម្លៃ | ១០ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរ នៃការវាយតម្លៃ** | **១២** |
| ២.១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល (សំណួរវាយតម្លៃទី ១) | ១២ |
| ២.២ | ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផលភ្លាមៗ និងលទ្ធផលនៃអនុកិច្ចសន្យា | ១៧ |
| ២.៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង | ២៣ |
| **២.៤** | **សេចក្តីសន្និដ្ឋាន** | **២៧** |
| **ឯកសារដែលត្រូវភ្ជាប់ ជាមួយនឹងរបាយការណ៍** | | **២៩** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យារបាយការណ៏ និង ឯកសារពាក់ព័ន្ធផ្សេងៗដែលបានពិនិត្យ | ២៩ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្តល់ពត៌មានសំខាន់ដែលបានជួបសម្ភាសន៏/ពិភាក្សា | ៣០ |
| **ករណីសិក្សា** | | **១៩** |
| ទី១- | អ្នកទទួលផលពីការបណ្តុះបណ្តាលជំនាញធ្វើក្រចក | ១៩ |
| ទី២- | អ្នកមិនទទួលផលពីការបណ្តុះបណ្តាលជំនាញធ្វើក្រចក | ២០ |
| ទី៣- | អ្នកទទួលផលពីវគ្គបណ្តុះបណ្តាលការបញ្ច្រាបយេនឌ័រក្នុងស៊ីអាយភី | ២១ |
| ទី៤- | អ្នកមិនទទួលផលពីវគ្គបណ្តុះបណ្តាលការបញ្ច្រាបយេនឌ័រក្នុងស៊ីអាយភី | ២២ |

# អក្សរកាត់

| | |
|---|---|
| **គ.ប្រ នៃ គ.អ.ជ.ខ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត |
| **កិច្ចសន្យា GOV** | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃគ.អ.ជ.ខ និង មន្ទីរវិស័យ |
| **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **CIP** | កម្មវិធីវិនិយោគឃុំ-សង្កាត់ |
| **GEN** | យេនឌ័រ |
| **23/GEN/0901-00** | អនុកិច្ចសន្យា របស់មន្ទីរកិច្ចការនារីខេត្តកែប |

ខែ កញ្ញា – តុលា ឆ្នាំ ២០១០

# របាយការណ៍សង្ខេប

**គោលបំណង និងវិធីសាស្ត្រ នៃការវាយតម្លៃដែលបានប្រើ :**

មន្ត្រីត្រួតពិនិត្យ និង វាយតម្លៃផ្នែកគ្រប់គ្រងកិច្ចសន្យានៃគ.ប្រ និង គ្រូបង្គោលប្រចាំខេត្តកែប បានធ្វើការវាយតម្លៃអនុកិច្ចសន្យាដែលមានចំណងជើងថា ***"ការគាំទ្រដល់ការចូលរួមរបស់ស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍"*** លេខកិច្ចសន្យា 23/GEN/0901-00 ដែលជា អនុកិច្ចសន្យារវាងគ.ប្រនៃគ.អ.ជ.ខ ខេត្តកែប និង មន្ទីរកិច្ចការនារី ។ នេះជាផ្នែកមួយនៃគម្រោងពង្រឹង សមត្ថភាពគ្រូបង្គោលថ្នាក់ក្រោមជាតិរបស់ផ្នែកត្រួតពិនិត្យវាយតម្លៃ និង ផ្សព្វផ្សាយ គោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែលគាំទ្រដោយ កម្មវិធីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ តាមរយៈវិមជ្ឈការ និង វិសហមជ្ឈការ ។

***គោលបំណងជាក់លាក់នៃការវាយតម្លៃនេះគឺ :***

១- ទាញយក កត់ត្រា និង វិភាគជាប្រព័ន្ធទៅលើសមិទ្ធិផលនៃអនុកិច្ចសន្យា និង ចំនុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និង ស្ថានភាពចុងបញ្ចប់នៃការអនុវត្តអនុកិច្ចសន្យា រួមទាំងការកត់ត្រានូវចំណុចរៀនសូត្រ និង ផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៅពេលអនាគត ។

២- ពង្រឹងរបៀបធ្វើការវាយតម្លៃគម្រោងរបស់គ.ប្រ នៃគ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត។

ការវាយតម្លៃដោយអនុវត្តតាមការណែនាំ និងឧបករណ៍ស្តីពីការវាយតម្លៃអនុកិច្ចសន្យា របស់គណៈកម្មាធិការប្រតិបត្តិ គ.អ.ជ.ខ ដែលរៀបចំដោយផ្នែកត្រួតពិនិត្យ និងវាយតម្លៃនៃលេខាធិការដ្ឋាន គ.ជ.អ.ប ។ ក្រុមការងារវាយតម្លៃបានប្រើការ ពិភាក្សាក្រុម ការសម្ភាសន៍ស៊ីជម្រៅ ការចុះមូលដ្ឋាន គន្លឹះក្នុងការសង្កេតផ្ទាល់ និង រំលឹកឯកសារអនុកិច្ចសន្យា របាយការណ៍រីកចម្រើន និង ឯកសារផ្សេងៗទៀត។ ការវាយតម្លៃត្រូវឆ្លើយនឹងសំណួរវាយតម្លៃ ដោយសារធនធានមាន កំណត់ យើងធ្វើការវាយតម្លៃស៊ីជម្រៅលើលទ្ធផលតែមួយប៉ុណ្ណោះ ចំណែកលទ្ធផលផ្សេងៗទៀត ត្រូវបានវាយតម្លៃ ដោយផ្អែកលើពត៌មានដែលមានស្រាប់ ។ ដូច្នេះការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃស៊ីជម្រៅទៅលើអនុកិច្ចសន្យា ទេ ហើយការសន្និដ្ឋានត្រូវធ្វើឡើងទៅតាមអ្វី ដែលរកឃើញតាមស្ថានភាពជាក់ស្តែង។

**ឆ្លើយសំណួរទាំង ៥ នៃការវាយតំលៃ:**

១-សកម្មភាពទាំងអស់ត្រូវបានអនុវត្ត និង លទ្ធផលសំរេចបានតាមផែនការ

| *ល.រ* | *សកម្មភាពដែលបានគ្រោងក្នុងផ្នែកទី៣: ការបរិយាយអំពីអនុកិច្ចសន្យា* | *អ្វីដែលសម្រេចបានជាក់ស្តែង* |
|---|---|---|
| ១ | រៀបចំវេទិកាលើកទី២ជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ០១វគ្គ | ១-រៀបចំវេទិការលើកទី២ជាមួយ គណៈកម្មាធិការ ទទួលបន្ទុកកិច្ចការនារី និងកុមារ<br>•រយៈពេល ០២ថ្ងៃ<br>•អ្នកចូលរួម ២៥ នាក់ ស្រី ១៤នាក់ |
| ២ | ប្រជុំប្រចាំឆមាសជាមួយមន្ត្រីបង្គោលយេនឌ័រនៅតាមមន្ទីរវិស័យ ខណ្ឌ និង ការិយាល័យកិច្ច ការនារីខណ្ឌ ២លើក | ២-ប្រជុំប្រចាំឆមាសជាមួយមន្ត្រីបង្គោលយេនឌ័រ នៅតាមមន្ទីរវិស័យ ខណ្ឌ និង ការិយាល័យ កិច្ចការនារី ខណ្ឌ ០២វគ្គ<br>•វគ្គនីមួយៗមានរយៈពេល ០១ថ្ងៃ<br>•អ្នកចូលរួមមានចំនួន៥៤នាក់ ស្រី ៣៩ នាក់ |
| ៣ | ប្រជុំប្រចាំឆមាសជាមួយគណៈកម្មាធិការទទួលបន្ទុក កិច្ចការនារីនិងកុមារ ២លើក | ៣-ប្រជុំប្រចាំឆមាសជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីងកុមារសង្កាត់០២វគ្គ<br>•វគ្គនីមួយៗមានរយៈពេល ០១ថ្ងៃ<br>•អ្នកចូលរួមមានចំនួន៤៨ នាក់ ស្រី ២៩នាក់ |
| ៤ | សិក្ខាសាលាស្តីពីការចូលរួមរបស់ស្ត្រីក្នុងមុខរបរប្រចាំ ថ្ងៃ ១វគ្គ | •អ្នកចូលរួមចំនួន ៣៤នាក់ (ស ៣៣នាក់) |
| ៥ | ទិវានារីអន្តរជាតិ ៨ មីនា ១លើក | •អ្នកចូលរួមចំនួន ៥០០នាក់ (ស ៣១៥នាក់) |
| ៦ | វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើក្រចក ១វគ្គ | •រយៈពេល ០២ខែ អ្នកចូលរួមជាស្ត្រី ចំនួន ១០នាក់ |
| ៧ | វគ្គបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុង CIP ១វគ្គ | •រយៈពេល០៣ថ្ងៃ<br>•អ្នកចូលរួមចំនួន ៣០នាក់ (ស ២៤នាក់) |

២-ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យានេះ សំរេចបានលទ្ធផលល្អប្រសើរ ដោយហេតុថាមន្ទីរបានខិតខំអនុវត្តន៍អនុកិច្ចសន្យានេះទៅតាមអ្វីដែលមន្ទីរបានគ្រោងហើយការចូលរួមបានផុសផុល តាមការអញ្ជើញរបស់មន្ទីរដែរ។ ទោះជាយ៉ាងនេះក្តី យើងសង្កេតឃើញថាសកម្មភាពទាំងអស់ របស់មន្ទីរត្រូវការពេលវេលាយូរបន្តិច ដើម្បីបញ្ជ្រាបការយល់ដឹងរបស់ប្រជាពលរដ្ឋ និង សហគមន៍អោយបានទូលំទូលាយ ។

៣-អនុកិច្ចសន្យានេះពិតជាបានរួមចំណែកក្នុងការសំរេចគោលបំណងបានមួយកំរិត ដោយហេតុថាកសិករបានទទួលចំនេះដឹងពីវគ្គបណ្តុះបណ្តាលពី យេនឌ័រ ទិវាសិទ្ធនារី កិច្ចប្រជុំជាមួយគណៈកម្មាធិការទទួលបន្ទុកស្ត្រី និងកុមារតាមមន្ទីរវិស័យ ក្រុង-ស្រុក ហើយក្នុងចំណោមអ្នកទាំងនេះពួកគាត់មានសមត្ថភាពគ្រប់គ្រាន់ អាចក្លាយជាភ្នាក់ងារផ្សព្វផ្សាយការងារយេនឌ័រ និងការលើកឡើងទាក់ទងទៅនឹងបញ្ហាស្ត្រី និងកុមារបញ្ចូលទៅក្នុងកម្មវិធីវិនិយោគរបស់ឃុំ-សង្កាត់ហើយសកម្មភាពទាំងនេះ កំពុងតែអនុវត្តន៍ជាប្រចាំ ហើយទន្ទឹមនេះដែរយើងសង្កេតឃើញថា ជីវភាពរបស់ពួកគាត់មានភាពប្រសើរឡើងជាងមុន មួយកំរិតផងដែរ ។

៤-អនុកិច្ចសន្យានេះមានភាពជាប់ទាក់ទងរវាងប្រសិទ្ធភាព និង ប្រសិទ្ធផលបានកំរិតខ្ពស់ ។ ហេតុផលមួយចំនួនមាន ដូចខាងក្រោម :

- ប្រសិទ្ធភាព: មន្ទីរប្រើប្រាស់ថវិកាបានត្រឹមត្រូវតាមផែនការ និងថវិកាប្រចាំឆ្នាំ និងស្របតាមគោលការណ៍ណែនាំរបស់គ.ជ.អ.ប។ ជាពិសេសការកំណត់ក្រុមគោលដៅបានត្រឹមត្រូ និង ឆ្លើយតបទៅនឹងតំរូវការជាក់ស្តែងរបស់ប្រជាជន ។

- ប្រសិទ្ធផល : មន្ត្រីមន្ទីរមានសមត្ថភាព និង ចំណេះដឹងគ្រប់គ្រាន់ ប៉ុន្តែសមត្ថភាពក្នុងការរៀបចំអនុកិច្ចសន្យានៅ មានកំរិតនៅឡើយទោះជាយ៉ាងនេះក្តីក៏សិក្ខាកាម ដែលបានចូលរួមមានភាពពេញចិត្ត និងសប្បាយរីករាយដោយសារវាមានសារៈសំខាន់ណាស់សំរាប់បង្កើនចំណេះដឹង និង ជំនាញមួយពិតប្រាកដអោយពួកគាត់យកទៅអនុវត្តន៍ដើម្បី កាត់បន្ថយភាពក្រីក្រ ។

**សេចក្តីសន្និដ្ឋានៈ**

ឆ្លងតាមរយៈនៃការវាយតម្លៃនេះ យើងសង្កេតឃើញថាលទ្ធផល និង សកម្មភាពដែលបានសម្រេច ក្នុងអនុកិច្ចសន្យាបានបំរើសេចក្តីត្រូវការ របស់ប្រជាជននៅក្នុងភូមិ និងនៅក្នុងសហគមន៍ទាំងអ្នកទទួលផលផ្ទាល់ពីគំរោង និងអ្នកមិនទទួលផលពីគំរោងនេះ ព្រោះថាពួកគាត់មានភាពពេញចិត្តសកម្មភាពទាំងអស់ ហើយបានយកចំណេះដឹងដែលទទួលបាន មកអនុវត្តន៍ និងបានផ្សព្វផ្សាយបន្តទៅដល់ប្រជាជន និងសហគមន៍។ ជាងនេះទៅទៀតអំពើហឹង្សា ក្នុងភូមិរបស់គាត់ហើយ ការងារយេនឌ័រត្រូវបានលើកកំពស់។

ការទុកដាក់ឯកសារពុំទាន់រៀបរយតាមលំដាប់លំដោយដូចជាៈរបាយការណ៍ អនុកិច្ចសន្យា ឯកសារទាក់ទងនៃការទូទាត់ រូបថតសកម្មភាពឯកសារផ្សេងៗទៀតដែលទាក់ទង ។ ទន្ទឹមនឹងនេះមន្ត្រីមន្ទីរគួរបង្កើនចំណេះដឹង ទាក់ទងទៅនឹងការរៀបចំនិងការអនុវត្តអនុកិច្ចសន្យាអោយកាន់តែមានប្រសិទ្ធិភាពថែមទៀតហើយមន្ទីរគួរតែធ្វើការ តាមដានត្រួតពិនិត្យ និងវាយតំលៃ ជាប្រចាំនូវរាល់សកម្មភាពដែលបានអនុវត្តន៏រួច។

# ១. ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១.១. សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាង គ.ប្រ នៃ គ.អ.ជ.ខ និងមន្ទីរវិស័យ

រៀងរាល់ឆ្នាំ គ.ជ.អ.ប ផ្តល់ថវិកាតាមរយៈគ.ប្រ នៃគ.អ.ជ.ខ ទៅមន្ទីរវិស័យដើម្បីអនុវត្តសកម្មភាព និងគម្រោងដែលគាំទ្រដល់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ ។ ការវាយតម្លៃអនុកិច្ចសន្យា ដែលមានលក្ខណៈជាប្រព័ន្ធមិនបានអនុវត្តទេកាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើន។ នៅក្នុងឆ្នាំ ២០១០ជាមួយនឹងការគាំទ្រផ្នែកថវិកា និង បច្ចេកទេសពីផ្នែកត្រួតពិនិត្យវាយតម្លៃនិងផ្សព្វផ្សាយគោលនយោបាយនៃលេខាធិការដ្ឋានគ.ជ.អ.ប និងផ្នែករដ្ឋបាល និង គ្រប់គ្រងកិច្ចសន្យាគ.ប្រនៃគ.អ.ជ.ខក្នុងការអនុវត្តការវាយតម្លៃ អនុកិច្ចសន្យាដែលបានរៀបចំរួមគ្នាជាមួយ ភ្នាក់ងារ អនុវត្តន៍ដែលមានលេខៈ 23/GEN/0901-00 គាំទ្រដល់ការចូលរួមរបស់ស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍ ដំណើរការលទ្ធផល ដែលបានរកឃើញនិងការសន្និដ្ឋាននៃការវាយតម្លៃត្រូវបានកត់ត្រាហើយ នឹង បង្ហាញ តាមរយៈរបាយការណ៍ស្តីពីការ វាយតម្លៃនេះ។

## ១.២. គោលបំណងអនុកិច្ចសន្យា

ពង្រឹងសមត្ថភាពស្ត្រីក្នុងជួរថ្នាក់ដឹកនាំ មន្ត្រីរាជការតាមមន្ទីរ មន្ត្រីគាំទ្រការងារពាក់ព័ន្ធ និង រចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទជាពិសេស ពង្រឹងសមត្ថភាពស្ត្រីក្នុងជួរក្រុមប្រឹក្សាឃុំ-សង្កាត់ ទូទាំងខេត្ត អោយក្លាយជាដៃគូការងារ យ៉ាងសំខាន់ ជាមួយ និងបុរស ក្នុងការចូលរួមលើកិច្ចអភិវឌ្ឍន៍គ្រប់ក៏រិត/វិសយ័ក្នុងការកសាងសង្គមជាតិ។

## ១.៣. គោលបំណង និងទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូល ដោយផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុង លក្ខណៈមួយប្រកបដោយបច្ចេកទេស និង តម្លាភាព។ ដូច្នេះទំហំនៃការវាយតម្លៃមានដែនកំណត់តាមទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាដែលពាក់ព័ន្ធដូចមានចែងក្នុងក្របខណ្ឌការងារ នៃការវាយតម្លៃ។ គោលបំណងនៃការវាយតម្លៃគឺ: **ក**) ទាញយកកត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃអនុកិច្ចសន្យា និងចំនុចខ្សោយធៀបទៅនឹងលទ្ធផលគោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃការអនុវត្តកិច្ចសន្យារួមទាំងកត់ត្រានូវចំណុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើង នៅពេលអនាគត និង **ខ**) ដើម្បីពង្រឹងរបៀបធ្វើការវាយតម្លៃគម្រោងរបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត។

## ១.៤. សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា? (ចំណុច គ ផ្នែកទី ៣)

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនបានកម្រិតណា ? (ចំណុច ខ ផ្នែកទី ៣)

៤- តើអនុកិច្ចសន្យាមានភាពពាក់ព័ន្ធ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទងនឹងការរៀបចំអនុវត្ត និងការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំណុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១.៥. វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ

វិធីសាស្ត្រ និង ឧបករណ៍ដែលត្រូវប្រើ:

*១-* ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំនត់ហេតុប្រជុំ និង របាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍វគ្គបណ្តុះបណ្តាល និង រាល់ឯកសារដែលពាក់ព័ន្ធដែលមាននៅក្នុងផ្នែករដ្ឋបាល និង គ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និង ភ្នាក់ងារអនុវត្តន៏ ។

*២-* ពិគ្រោះជាមួយអ្នកដែលផ្តល់ព័តិមានសំខាន់ៗ រួមមាន: អ្នករៀបចំ និងអនុវត្តអនុកិច្ចសន្យា និងអ្នកទទួលផលផ្ទាល់ និងមិនផ្ទាល់ ២ និងអ្នកពាក់ព័ន្ធ ០១នាក់ ។

*៣-* ចុះពិនិត្យតំបន់អនុវត្តន៏គម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់ ។

*៤-* <u>វិភាគទិន្នន័យ និងបកស្រាយ:</u> ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើនឹងត្រូវធ្វើការវិភាគ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់ ។

*៥-* <u>ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៏</u> ដោយភ្នាក់ងារអនុវត្តន៏ និងអ្នកពាក់ព័ន្ធតាមរយៈព័តិមានត្រឡប់ ់ដែលទទួលបានពីការបង្ហាញដោយសង្ខេប ដែលបានធ្វើឡើងនៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១០ កំណត់ការវាយតម្លៃ ត្រូវធ្វើតាម "គោលការណ៏ណែនាំការវាយតម្លៃអនុកិច្ចសន្យា" និងវិធីសាស្ត្រដែលបានណែនាំ ។ ដូច្នេះដំណើរការត្រូវបាន ធ្វើឡើង ដោយមានទម្រង់ការណែនាំ និងតម្លាភាព រួមទាំងការចូលរួមពីអ្នកពាក់ព័ន្ធ ។

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១- ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើង ដោយ គ.ប្រ និង អ្នកវាយតម្លៃដែលពាក់ព័ន្ធផ្ទាល់ និង មិនផ្ទាល់ក្នុងអនុកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយការប្រឹងប្រែង ត្រូវធ្វើឡើងដើម្បីធានាឱ្យដំណើរការវាយតម្លៃមានភាពល្អប្រសើរបំផុត។

២- ចំណេះដឹងលើបច្ចេកទេសនៃការវាយតម្លៃនៅមានកម្រិត : ជាបញ្ហាប្រឈមក្នុងការវាយតម្លៃគម្រោងនៅពេលដែលអ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និងបទពិសោធន៍ពីមុនមក ។ ទោះបីជាយ៉ាងណាក៏ដោយគោលបំណងសំខាន់គឺដើម្បី "រៀនធ្វើដោយការអនុវត្តផ្ទាល់"។ ការវាយតម្លៃបានទទួលការគាំទ្រដោយមានគោលការណ៍ការណែនាំឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដើម្បី ដោះស្រាយបញ្ហាទាំងអស់នេះ។

៣- បញ្ហាប្រឈមក្នុងផ្នែកទី៣ នៃអនុកិច្ចសន្យា: ការវិភាគតារាងតក្កភាព (សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន "សូចនាករ" និង "មធ្យោបាយផ្ទៀងផ្ទាត់ "លើការរីកចម្រើននិងជោគជ័យទេ។ មួយទៀតទំនាក់ទំនងសង្ខេបតាមបែបតក្កក រវាងសកម្មភាព (ធាតុចូល)និងលទ្ធផល និងរវាងលទ្ធផលទៅនឹងគោលបំណងបន្ទាន់ មិនត្រូវបានបង្ហាញឱ្យបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ។

៤- ដោយយើងមិនមានសូចនាករបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ "គោលដៅអភិវឌ្ឍន៍" ដែលជាកម្រិតអត្ថប្រយោជន៍ ទៅលើគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត "គោលបំណង" ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ។

៥- ដោយយើងមានពេលវេលា ធនធាន និង ថវិកាមានកំណត់យើងមិនអាចធ្វើការវាយតម្លៃលម្អិត ទៅលើលទ្ធផល និងសកម្មភាពទាំងអស់បានទេ។ យើងអាចវាយតម្លៃតែទៅលើលទ្ធផលទី១ បណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រ និងជ្រើសរើស តែជាសកម្មភាពវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើក្រចក និង វគ្គបណ្តុះបណ្តាលការបញ្ជ្រាបយេនឌ័រទៅក្នុង CIP តាមរយៈការ សម្ភាសន៍ស៊ីជម្រៅ ក្រុមពិភាក្សា និងការចុះពិនិត្យតំបន់អនុវតគម្រោង។

៦- សូមរក្សាទុកចំណុចនេះប្រសិនបើវាមានសុពលភាព: ការវាយតម្លៃទៅលើស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យា មិនអាចធ្វើទៅបានទេ ព្រោះចំណុច គ នៃផ្នែកទី៣ក្នុងឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ ឬមិនពេញលេញ។ ការងានេះនឹងកាន់តែ មានសុពលភាព និងពោរពេញទៅដោយព័ត៌មាន បើសិនជាចំនុចដែលបានរៀបរាប់ខាងលើ នេះត្រូវបានដោះស្រាយ។

**<u>ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ និង បដិសេធនឹះ:</u>**

១- ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះអនុកិច្ចសន្យា 23/GEN/0901-00 និង ដែនកំណត់ដូចដែលបានកំណត់ នៅក្នុង ក្របខ័ណ្ឌនៃការវាយតម្លៃនេះ។

២- ការវាយតម្លៃនេះលម្អិតតែទៅលើបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រ និង ជ្រើសរើសតែជាសកម្មភាពវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើក្រចកនិង វគ្គបណ្តុះបណ្តាលការបញ្ជ្រាបយេនឌ័រទៅ ក្នុង CIP

៣- ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃទៅលើ ភ្នាក់ងារអនុវត្តន៍ ភ្នាក់ងារដែលពាក់ព័ន្ធ គម្រោងហើយ នឹងការវាយតម្លៃទៅលើគ.ប្រ នៃគ.អ.ជ.ខ និង គ.ជ.អ.ប ទេ។

ហេតុដូច្នេះ របាយការណ៍នៃការ វាយតម្លៃលទ្ធផលដែលបានរកឃើញ និង អនុសាសន៍ដែលបានលើកឡើងត្រូវពិនិត្យដោយយោងទៅលើបរិបទខាងលើ និង អនុវត្តតាមលំដាប់លំដោយ។

# ២. លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២.១. វាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល

***លទ្ធផលទី១ : មន្ទីរកិច្ចការនារីគាំទ្រដល់ការបញ្ជ្រាបយេនឌ័រ***

**ផ្នែក-ក :** *ការសម្រេចបានជាក់ស្តែងធៀប និង ផែនការ*

| ល.រ<br>(១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា<br>(២) | អ្វីដែលសម្រេចបានជាក់ស្តែង<br>(៣) |
|---|---|---|
| ១.១ | • រៀបចំវេទិការលើកទី២ជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ<br>• រយៈពេល ០២ថ្ងៃ<br>• អ្នកចូលរួម ៣០នាក់ | • រៀបចំវេទិការលើកទី២ជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ<br>• រយៈពេល ០២ថ្ងៃ<br>• អ្នកចូលរួម ២៥ នាក់ ស្រី ១៤នាក់ |
| ១.២ | ប្រជុំប្រចាំឆមាសជាមួយមន្ត្រីបង្គោលយេនឌ័រនៅតាមមន្ទីរវិស័យ ខណ្ឌ និង ការិយាល័យកិច្ចការនារីខណ្ឌ ០២វគ្គ<br>• វគ្គនីមួយៗមានរយៈពេល ០១ថ្ងៃ<br>• អ្នកចូលរួមមានចំនួន ៣០ នាក់ | ប្រជុំប្រចាំឆមាសជាមួយមន្ត្រីបង្គោលយេនឌ័រនៅតាមមន្ទីរវិស័យ ខណ្ឌ និង ការិយាល័យ កិច្ចការនារីខណ្ឌ ០២វគ្គ<br>• វគ្គនីមួយៗមានរយៈពេល ០១ថ្ងៃ<br>• អ្នកចូលរួមមានចំនួន៥៤នាក់ ស្រី ៣៩ នាក់ |

| | | |
|---|---|---|
| ១.៣ | ប្រជុំប្រចាំឆមាសជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារសង្កាត់ ០២វគ្គ ។<br>•វគ្គនីមួយៗមានរយៈពេល ០១ថ្ងៃ<br>•អ្នកចូលរួម ៣០នាក់ | ប្រជុំប្រចាំឆមាសជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារសង្កាត់ ០២វគ្គ<br>•វគ្គនីមួយៗមានរយៈពេល ០១ថ្ងៃ<br>•អ្នកចូលរួមមានចំនួន៤៨ នាក់ ស្រី ២៩នាក់ |
| ១.៤ | សិក្ខាសាលាស្តីពីការចូលរួមរបស់ស្ត្រីក្នុងមុខរបរប្រចាំថ្ងៃ ០១វគ្គ<br>•រយៈពេល ០២ថ្ងៃ<br>•អ្នកចូលរួម ៣០នាក់ | •សិក្ខាសាលាស្តីពីការចូលរួមរបស់ស្ត្រីក្នុងមុខរបរប្រចាំថ្ងៃចំនួន ០១វគ្គ<br>•វគ្គនេះមានរយៈពេល ០២ថ្ងៃ<br>•អ្នកចូលរួមមានចំនួន ៣៤នាក់ (ស្រី:៣៣នាក់) |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

| |
|---|
| អនុកិច្ចសន្យានេះសំរេចនូវលទ្ធផល និង សកម្មភាពនានានៅក្នុងអនុកិច្ចសន្យាដែលបានគ្រោងទុក ។ |

***លទ្ធផលទី២ : យុទ្ធនាការយេនឌ័រ***

**ផ្នែក-ក :** *ការសម្រេចបានជាក់ស្តែងធៀប និង ផែនការ*

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ២.១ | • ប្រារព្ធពិធីទិវានារីអន្តរជាតិ ៨ មីនា<br>• រយៈពេល ០១ថ្ងៃ<br>• អ្នកចូលរួម ៤០០នាក់ | • ប្រារព្ធពិធីទិវានារីអន្តរជាតិ ៨ មីនា<br>• មានរយៈពេល ០១ថ្ងៃ<br>• អ្នកចូលរួមចំនួន ៥០០នាក់ ( ស្រី:៣១៥នាក់) |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

| |
|---|
| អនុកិច្ចសន្យានេះសំរេចនូវលទ្ធផល និង សកម្មភាពនានានៅក្នុងអនុកិច្ចសន្យាដែលបានគ្រោងទុក ។ |

***លទ្ធផលទី៣ :ការបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រ***

**ផ្នែក-ក :** *ការសម្រេចបានជាក់ស្តែងធៀប និង ផែនការ*

| ល.រ (១) | សកម្មភាព ដែលបានគ្រោងក្នុងផ្នែកទី ៣ : ការបរិយាយអំពីអនុកិច្ចសន្យា (២) | អ្វីដែលសម្រេចបានជាក់ស្តែង (៣) |
|---|---|---|
| ៣.១ | •វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើក្រចក<br>•រយៈពេល ០២ខែ<br>•អ្នកចូលរួម ១០នាក់ | •វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើក្រចកចំនួន ០១ វគ្គ<br>•វគ្គនេះមានរយៈពេល០២ខែ (៦០ថ្ងៃ)<br>•អ្នកចូលរួមមានចំនួន ១០ នាក់ ស្រី ១០ នាក់ |
| ៣.២ | •វគ្គបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុង CIP<br>•មានរយៈពេល ០៣ថ្ងៃ<br>•អ្នកចូលរួមមានចំនួន ៣០ នាក់ | •វគ្គបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុង CIP ចំនួន ០១វគ្គ<br>•វគ្គនេះមានរយៈពេល ០៣ថ្ងៃ<br>•អ្នកចូលរួមមានចំនួន ៣០ នាក់ ស្រី ២៦ នាក់ |

**ផ្នែក-ខ :** ការវិភាគ និងវាយតម្លៃជារួមអំពីលទ្ធផល

អនុកិច្ចសន្យានេះសំរេចនូវលទ្ធផល និងសកម្មភាពនានានៅក្នុងអនុកិច្ចសន្យាដែលបានគ្រោងទុក :

- អ្នកចូលរួមទាំងអស់ជាសិក្ខាកាមពីវគ្គបណ្តុះបណ្តាលបច្ចេកទេសធ្វើក្រចក បានទទួលនូវចំណេះដឹង និងជំនាញដែលទាក់ទងទៅនិងវិជ្ជាជីវៈ កែសម្ផស្សដូចជា ការធ្វើក្រចក ផាត់មុខ ធ្វើសក់ ។ អ្វីដែលយើងគួរចាប់អារម្មណ៏នោះ ពួកគាត់បានចងចាំនៅបច្ចេកទេស អាចយកទៅប្រកបរបររកស៊ីបានខ្លះ ប៉ុន្តែមួយចំនួនមិនអាចយករបរនេះទៅប្រកប

របរទេ ដោយ គ្រាន់តែពួកគាត់បានត្រឹមតែធ្វើអោយបងប្អូនមិត្តភក្ត្រ័និងញាតិមិត្តជិតខាងគាត់នៅពេលមានពិធីបុណ្យទាន ឬ ពិធីផ្សេងៗទៀត ពេលពួកគេត្រូវការ ។ សិក្ខាកាមភាគច្រើនចូល ចិត្តនូវបទពិសោធន៍ដែលបានផ្តល់និងអាកប្បកិរិយាល្អរួមផ្សំនិងភាពប៉ិនប្រសប់របស់គ្រូដោយ ជ្រើសរើសយក វិធីសាស្រ្តៈ ការបំផុសគំនិត បង្ហាញរូបភាព ជាក់ស្តែង ក្រុមពិភាក្សា ការចាប់ដៃគូធ្វើសាកល្បង ដែលជាហេតុធ្វើអោយ សិក្ខាកាមមាន ទំនុកចិត្តខ្ពស់ ក្នុងការចូលរួមអនុវត្តន៍ ជាក់ស្តែងកំឡុងពេល សិក្សាទោះជាយ៉ាងនេះក្តីក៏នៅមានសិក្ខាកាមផ្សេង ទៀតបានលើកឡើង ថាគួរបន្ថែមគ្រូជំនួយការម្នាក់ទៀតដើម្បីអោយ ពួកគាត់មានលទ្ធភាព បង្ហាញបានគ្រប់ជ្រុង ជ្រោយជាពិសេសសុំអោយមានឧបត្ថម្ភជាថ្លៃធ្វើដំណើរ និង ប្រាក់ជាដើមទុនសំរាប់ប្រកបមុខរបរពេលពួកគាត់បញ្ចប់វគ្គនេះរួច ។

- ការចូលរួមវគ្គបណ្តុះបណ្តាលពីការបញ្ជ្រាបយេនឌ័រទៅក្នុង CIP ធ្វើអោយពួកគេទទួលបាននូវចំណេះដឹង ទាក់ទងទៅនឹងការបញ្ជ្រាបយេនឌ័រក្នុងសហគមន៍ ដូចជាទស្សនៈទាន នៃយេនឌ័រ ភាពខុសគ្នា សមភាព និង សមធមិយេនឌ័រ ជាពិសេសស្វែងយល់អោយបានច្បាស់ ដើម្បីក្លាយជាភ្នាក់ងារផ្សព្វផ្សាយនាមជាតំណាងប្រជាជន និងសហគមន៍ នឹងមានលទ្ធភាព កំណត់បញ្ហាតម្រូវការ ដំណោះស្រាយផ្នែកស្រ្តី-កុមារ និង ក្រុមងាររងគ្រោះដែលអាចជ្រើសរើសគម្រោងបានច្រើន និង សមស្របដើម្បីបំពេញតម្រូវការ របស់សហគមន៏អាទិភាពក្នុងការដាក់បញ្ចូលក្នុងស៊ីអាយភី ។

- ចំពោះការបណ្តុះបណ្តាលគ្រូមកពីមន្ទីរកិច្ចការនារីមានចរិតស្លូតបូត តែម៉ឺងម៉ាត់ដែលធ្វើអោយ សិក្ខាកាម យល់ដឹងច្រើនជាពិសេសគាត់បានប្រើវិធីសាស្រ្តបំផុសគំនិតពិភាក្សាក្រុម បង្ហាញខ្លឹមសារ លេងល្បែងកំសាន្ត រូបភាពទាក់ទងនឹងបញ្ហាយេនឌ័រ តេស្តសាក ល្បង មុន-ក្រោយវគ្គ ។ល។ ទោះជាយ៉ាងនេះ ក៏ដោយក៏នៅមានចំនុចខ្វះខាតដោយសិក្ខាកាមដែលមករៀនជាស្រ្តីភាគច្រើនដូច្នេះពេលបើកវគ្គគួរតែមានបុរសយ៉ាងតិច ៤០ភារយ ដែរជាពិសេសពេលបើកវគ្គនេះ អោយបានច្រើន២-៣ដងនៅតាមសហគមន៍ ដែលទីតាំងជិត ងាយធ្វើដំណើរ ប្រសិនបើមានការឧបត្ថម្ភថ្លៃធ្វើដំណើរ ឬ អាហារថ្ងៃត្រង់ កាន់តែប្រសើរព្រោះអ្នកមាន ជីវភាពក្រីក្រ ។

## ២.២. ការវាយតម្លៃលើការសម្រេចបាននូវលទ្ធផល និងអត្ថប្រយោជន៍បឋម

### ផ្នែក-ក: ការសម្រេចបាននូវស្ថានភាពចុងបញ្ចប់នៃកិច្ចសន្យា

| ស្ថានភាពនៅពេលបញ្ចប់អនុកិច្ចសន្យា (១) | លទ្ធផលប្រសើរឡើងជាក់ស្តែងនៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ (២) |
|---|---|
| ១- សិក្ខាកាមដែលជាស្ត្រី និង ក្មេងកំព្រាចំនួន១០នាក់នឹងទទួលបាននូវជំនាញវិជ្ជាជីវៈ ដែលប្រកបដោយគុណភាពយកទៅ ប្រកបមុខរបរចិញ្ចឹមជីវិតបន្ថែមដើម្បីបង្កើនប្រាក់ចំណូលគ្រួសារ ក្រោយពេលបញ្ចប់វគ្គ ។ | ១- សិក្ខាកាម១០នាក់បានទទួលការបណ្តុះបណ្តាល ជំនាញធ្វើក្រចក ផាត់មុខ និង ធ្វើសក់មានចំណេះដឹង និងចំណេះធ្វើអាចកាត់បន្ថយការចំណាយបានមួយ ក៏វិតប៉ុន្តែមិនបានយកសកម្មភាពទៅអនុវត្ត សំរាប់ប្រកបមុខរបរប្រចាំថ្ងៃ ។ |
| ២- សិក្ខាកាមចំនួន៣០នាក់មានក្រុមប្រឹក្សា-គ.ផ.ថ គណៈកម្មាធិការទទួលបន្ទុកស្ត្រី និង កុមារឃុំសង្កាត់ទាំង០៥ បានចូលរួមវគ្គការបញ្ជ្រាបយេនឌ័រទៅក្នុង CIP និង មានចំណេះដឹងក្លាយជាភ្នាក់ងារ ផ្សព្វផ្សាយ និង ជាតំណាង របស់ប្រជាពលរដ្ឋ សមត្ថភាពអាចជ្រើសរើស បញ្ហាស្ត្រីបានច្រើននៅ ក្នុងCIP និងស្ត្រីមានភាពជាម្ចាស់ការ ក្នុងការ ទទួលខុសត្រូវដើម្បីចូលរួមចំណែក កាត់បន្ថយ ភាពក្រីក្រ ។ | ២- អ្នកចូលរួមទាំងអស់មានចំនួន ៣៦នាក់ ក្នុងនោះស្រីចំនួន២៦នាក់ បានចូលរួមវគ្គការបញ្ជ្រាបយេនឌ័រ ទៅក្នុង CIP។ អ្នកចូលរួមភាគច្រើនក្នុង ការពិភាក្សាជាក្រុម បានរាយការណ៍ថា ពួកគាត់បានពេញចិត្តចំពោះវគ្គនេះណាស់ ព្រោះវគ្គនេះបានច្រើន តបទៅនឹងតំរូវការរបស់ពួកគាត់ និង សហគមន៍ជាពិសេសអាចអោយពួកគាត់មានចំនេះដឹង ពី យេនឌ័រអាចកំនត់នូវបញ្ហា និងតំរូវការនានារបស់ស្ត្រី និង កុមារក្រុមងាយរងគ្រោះ និងអាចកាត់បន្ថយពីអំពើហឹង្សាក្នុងគ្រួសារយល់ច្បាស់ពីសមភាពយេនឌ័រ...។ល។ បន្ទាប់ពីការរៀបចំវគ្គនេះរួចយើងសង្កេតឃើញថា សិក្ខាកាមដែលចូលរួមអាចបំផុសគំនិត លើកឡើងពីបញ្ហាស្ត្រីនៅក្នុងភូមិដាក់ចូលទៅក្នុង CIP និងបានយកចំណេះដឹងទាំងនេះទៅ ផ្សព្វផ្សាយទៅដល់ ប្រជាពលរដ្ឋអោយ ពួកគាត់បានជ្រាបពីបញ្ហានេះ ផងដែរ ។ |

## ផ្នែក-ខ: ការវាយតម្លៃការសម្រេចបាននូវ គោលបំណងបន្ទាន់

| ធាតុនៃគោលបំណងបន្ទាន់ | ការសម្រេចបាន/លទ្ធផលជាក់ស្តែង នៅពេលបញ្ចប់អនុកិច្ចសន្យា/ក្នុងពេលវាយតម្លៃ |
|---|---|
| នៅចុងបញ្ចប់អនុកិច្ចសន្យា មន្ទីរ នឹងធ្វើការ ពង្រឹងសមត្ថភាពស្រ្តីមេម៉ាយ និង ក្មេងកំព្រា អោយមានជំនាញពិត ប្រាកដក្នុងរបរចិញ្ចឹមជីវិត និងពង្រឹងសមត្ថភាព របស់ស្រ្តីក្នុង ជួរថ្នាក់ដឹកនាំ មន្ត្រីរាជការតាមមន្ទីរ និង មន្ត្រីគាំទ្រការងារពាក់ពន្ធ័ និង រចនាសម្ពន្ធ័អភិវឌ្ឍន៏ជនបទ ហើយជាពិសេស ពង្រឹងសមត្ថភាព ស្រ្តីក្នុងជួរ ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងទូទាំងខេត្ត អោយក្លាយទៅជាដៃគូការងារ យ៉ាងសំខាន់ ជាមួយ នឹងបុរស ក្នុងការចូលរួមលើកិច្ចអភិឌ្ឍន៏ គ្រប់ក៏រិត/វិស័យក្នុង ការកសាងសង្គមជាតិ ។ | គោលបំណងបន្ទាន់គឺវាមានគម្លាឆ្ងាយក្នុងការអនុវត្តន៏សកម្មភាពជាក់ស្តែង ដែលមានការពីបាកវាស់វែងនៅពេលបញ្ចប់ អនុកិច្ចសន្យា ។ ការរំពឹងទុកថាលទ្ធផលនិងសកម្មភាពទាំងឡាយដែលបានគ្រោង នៅក្នុងអនុកិច្ចសន្យា របស់មន្ទីរនឹងចូលរួមនៅក្នុង គោលបំណងបន្ទាន់ ប៉ុន្តែផ្អែកទៅលើការពិនិត្យ ឯកសារ និង វិធីសាស្រ្តវាយតំលៃ តាមបែបគុណភាពគឺមិនអាច វាយតម្លៃថា គោលបំណង នេះអាច សំរេចបានក្នុងក៏រិត ណាមួយនោះទេ។ គ្រាន់តែអនុកិច្ចសន្យា នេះរួមចំណែកក្នុង ការបញ្រ្ជាបយេនឌ័រ លើកកំពស់ ជីវភាពស្រ្តី និងបង្កើនចំណេះដឹង របស់ស្រ្តីបានមួយក៏រិត ។ |

## ផ្នែក-គ: សង្ខេបការវាយតម្លៃជារួមដែលទទួលបាន

តាមរយៈការចុះអង្កេត ការពិភាក្សាជាក្រុម និង ការសំភាសន៏ស៊ីជំរៅទៅលើក្រុមអ្នកទទួលផល អ្នកមិនទទួលផលនៅក្នុងសកម្មភាព វគ្គបណ្តុះបណ្តាលជំនាញធ្វើក្រចក និង ការបញ្រ្ជាបយេនឌ័រក្នុងស៊ីអាយភី យើងសង្កេតឃើញថាពួកគាត់មានសេចក្តីសប្បាយរីករាយ ដែលបានទទួលចំណេះដឹង ឬមិនបានទទួលចំណេះដឹងដោយផ្ទាល់ ដែលទាក់ទងទៅនឹងបញ្ហាស្រ្តីនិងកុមារនៅក្នុង ឃុំ-សង្កាត់ ហើយពួកគាត់ប្តេជ្ញាចិត្តខ្ពស់ ក្នុងការយកចំណេះដឹងថ្មីនេះទៅអនុវត្តន៏ និងធ្វើការផ្សព្វផ្សាយដើម្បីអោយប្រជាពលរដ្ឋនៅក្នុងភូមិ និង នៅក្នុងសហគមន៏ អោយបានយល់ច្បាស់ពីយេនឌ័រ អប់រំស្រ្តីអោយមានភាពក្លាហានហ៊ានលើកឡើង អំពីបញ្ហារបស់ខ្លួនហើយធ្វើយ៉ាងណាទប់ស្កាត់អោយអស់ពីបញ្ហាអំពើហឹង្សាក្នុងគ្រួសារ។ ហើយឆ្លងតាមរយៈ ការអនុវត្តគំរោងនេះបានធ្វើអោយពួកគាត់មាន ជីវភាពធូរធាបានមួយក៏រិតផងដែរ ដោយសារពេលនេះមិនមាន អំពើហឹង្សាក្នុងគ្រួសារ ហើយពួកគាត់ចេះជួយទុក្ខធុរៈគ្នា ចេះស្រលាញ់យល់ចិត្តគ្នាទៅវិញទៅមក ហើយជាពិសេសពួកគាត់ ខិតខំធ្វើការងារប្រកបរបរដើម្បីអោយជីវភាពរីកចំរើនផងដែរ ។

## ករណីសិក្សា ទី១ : អ្នកទទួលផលពីអនុកិច្ចសន្យា ក្នុងសកម្មភាពវគ្គបណ្តុះបណ្តាលជំនាញធ្វើក្រចក

ក្រោយពីបានចូលរួមក្នុងគម្រោងរបស់មន្ទីរកិច្ចការនារីខេត្តកែបក្នុងឆ្នាំ២០០៩កញ្ញា **អ៊ុង សោភី** បាននិយាយថាៈ "ខ្ញុំអាចកាត់បន្ថយការចំណាយបានមួយកំរិតបន្ទាប់ពីខ្ញុំបាន ចូល រួមរៀនជំនាញវិជ្ជាជីវៈធ្វើក្រចក" ។

កញ្ញា **អ៊ុង សោភី** អាយុ២១ឆ្នាំ រស់នៅភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ។ គាត់បាន និយាយថា គម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈនេះ មានសារៈសំខាន់ខ្លាំងណាស់ ព្រោះគាត់បានទទួលចំណេះដឹង និងជំនាញពីការធ្វើក្រចក។ ដោយពីមុនគាត់បានចំណាយលុយ ទៅលើការធ្វើក្រចកនេះ ប៉ុន្តែឥឡូវគាត់អាចធ្វើ ខ្លួនឯងបាន និង អាចធ្វើអោយគ្រួសារឬមិត្តភក្តិបានទៀតផង ។ គាត់បញ្ជាក់ថា : "ជំនាញធ្វើក្រចកនេះជាការងារស្រួល ដែលយើងអាចធ្វើនៅផ្ទះ និងប្រកប មុខរបរ ផ្សេងទៀតបាន" ។ លើសពីនេះ ទៅទៀតគាត់បានប្តេជ្ញាចិត្តបន្ត អនុវត្តន៏គម្រោងនេះដោយសារ ការធ្វើក្រចកជាតម្រូវការរបស់មនុស្សច្រើន ហើយគាត់អាចរកចំណូលបន្ថែមដើម្បី បង្កើនជីវភាពបានមួយកំរិត និង អាចបង្រៀនអ្នកជិតខាងបានទៀតផង ទោះបីជាឥឡូវនេះគាត់មិនទាន់មានលទ្ធភាពអាចបើកមុខរបរនេះបាន។

## ករណីសិក្សាទី២ : អ្នកមិនបានទទួលផលពីអនុកិច្ចសន្យាក្នុងសកម្មភាពវគ្គបណ្តុះបណ្តាលជំនាញធ្វើក្រចក

កញ្ញា **ឈឿន ស្រីនាង** អាយុ២២ឆ្នាំ ។ គាត់ជាក្មេងកំព្រា រស់នៅក្នុងបុរីកុមារកំព្រាខេត្តកែប ស្ថិតនៅភូមិថ្មី សង្កាត់ ព្រៃធំ ក្រុងកែប ខេត្តកែប ។ កញ្ញា **ឈឿន ស្រីនាង** មិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើក្រចក របស់ មន្ទីរកិច្ចការនារីទេ ព្រោះគាត់មិនបានដាក់ពាក្យសុំចូលរៀន នៅពេលដែលមន្ទីរកិច្ចការនារីធ្វើការផ្សព្វផ្សាយ និង ជ្រើសរើស អ្នកចូលរួមទេ ដោយសារគាត់ជាប់រៀននៅវិទ្យាល័យ។ គាត់និយាយថាៈ"វគ្គបណ្តុះបណ្តាលនេះល្អណាស់ព្រោះជួយ អោយស្ត្រីមានការរីកចំរើន លើចំណេះដឹងការធ្វើក្រចក បន្ថែមលើការងារ បច្ចុប្បន្ន"។ ជាពិសេសយកជំនាញនេះទៅអនុវត្ត និងអាចរកចំណូល ផ្គត់ផ្គង់គ្រួសារបានមួយក៏រិត។ គាត់បញ្ជាក់ ទៀតថា : គាត់ចង់ចូលរួមក្នុងគម្រោងនេះណាស់ព្រោះគាត់ ចង់ចេះជំនាញពិតប្រាកដមួយដើម្បីចិញ្ចឹមជីវិត ។

ខ្ញុំគិតថាៈ ទោះបីជាវគ្គនេះ មានរយៈពេលខ្លីតែ០២ខែ មិនអាចយកទៅបើកមុខរបរបានក៏ដោយតែគាត់ឃើញ មិត្តភក្តិដែលរស់នៅក្នុងបុរីជាមួយគាត់បានចូលរួមក្នុងគម្រោងនេះ ពួកគេអាចធ្វើក្រចក និងផាត់មុខដោយ ខ្លួនឯងបានម៉្យាងទៀត ពួកគេបានធ្វើអោយមិត្តភក្តិដទៃ ដែលត្រូវសម្តែងរបាំទៀតផង និង អាចកាត់បន្ថយ ការចំណាយ ដែលពីមុនមកយើងត្រូវជួលជាងមកធ្វើ ឬក៏ទៅធ្វើនៅឆ្ងាយពីផ្ទះ ។

ជាទីបញ្ចប់ សុំអោយមន្ទីរ ធ្វើការបណ្តុះបណ្តាលជនក្រីក្រជា ស្ត្រី និង ក្មេងកំព្រា ចូលរួមអោយបានច្រើន និង ផ្តល់ឧបករណ៍ សម្ភារៈផ្សេងៗបន្ទាប់ពីបញ្ចប់វគ្គ ។ កញ្ញា **ឈឿន ស្រីនាង** សង្ឃឹមថា នឹង បានចូលរួមវគ្គបណ្តុះ បណ្តាលវិជ្ជាជីវៈជំនាញធ្វើក្រចករបស់មន្ទីរកិច្ចការនារី នេះនៅវគ្គលើកក្រោយ ។

## ករណីសិក្សាទី៣ : អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងសកម្មភាពវគ្គបណ្តុះបណ្តាលការបញ្ជ្រាបយេនឌ័រក្នុងស៊ីអាយភី

ក្រោយពីទទួលបានចំណេះដឹងទាក់ទងទៅនឹងការបញ្ជ្រាបយេនឌ័រទៅក្នុង CIP ក្នុងឆ្នាំ ២០០៩ រួចមកអ្នកស្រី **សួន ង៉ែត** បានលើកឡើងដូច្នេះថា: "នៅក្នុងភូមិនិងសហគមន៍របស់ខ្ញុំ បានមានការយល់ដឹងពីយេនឌ័រ ក្នុងភូមិហាក់ដូចជាប្រសើរ ជាងមុនដែរ" ។

អ្នកស្រី **សួន ង៉ែត** ជាជំនួយការភូមិ គាត់មានអាយុ ៤៥ ឆ្នាំ មានកូន ០៤ នាក់ ស្រី ០១ នាក់ និងប្រុស០៣ នាក់ រស់នៅក្នុង ភូមិព្រៃតាកុយ ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប ។ គាត់បាននិយាយថា សកម្មភាពនេះ មានសារៈសំខាន់ខ្លាំងណាស់ ព្រោះ គាត់បានទទួលចំណេះដឹង និងជំនាញច្រើនអំពីសមភាពយេនឌ័រ និង ទំរង់ផ្សេងៗ នៃអំពើហឹង្សាក្នុងគ្រួសារ ក៏ដូចជារបៀបបំផុស និងការលើកឡើងពីអំពីតំរូវការ បញ្ហាប្រឈមរបស់ស្ត្រី និងកុមារ ដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគរបស់ឃុំ/សង្កាត់ ។

គាត់បានបន្តទៀតថា: " គ្មានអំពើហឹង្សាកើតមានទៀតទេនៅក្នុងភូមិខ្ញុំ" ជាងនេះទៅទៀតជីវភាពរបស់ពួក យើងក៏បានធូរធាជាងមុនដែរ ដោយសារពួកគាត់ចេះស្រលាញ់គ្នា យល់ចិត្តគ្នា លែងឈ្លោះប្រកែកគ្នា ហើយនាំគ្នា ខិតខំប្រកបមុខរបរនានាបានរីកចំរើន។ នៅចុងបញ្ចប់គាត់បានបង្ហាញពីការប្តេជ្ញាចិត្តថា នឹងបន្តការខិតខំយកចំនេះដឹងដ៏មានសារៈសំខាន់ នេះ ដើម្បីធ្វើការផ្សព្វផ្សាយទៅដល់ ប្រជាជននៅក្នុងភូមិ និងសហគមន៍របស់គាត់ធ្វើយ៉ាងណា អោយពួកគេបានយល់ដឹងច្បាស់លាស់ពីបញ្ហាស្ត្រី និងកុមារថែមទៀត និងការលើកឡើងពីការងារយេនឌ័រ អោយបានស៊ីជំរៅថែមទៀត។

## ករណីសិក្សាទី៤ : អ្នកមិនទទួលផលពីអនុកិច្ចសន្យា ក្នុងសកម្មភាពវគ្គបណ្តុះបណ្តាលការបញ្ជ្រាបយេនឌ័រក្នុងស៊ីអាយភី

អ្នកស្រី **សែម សុខុម** អាយុ ៤១ ឆ្នាំ។ គាត់មានគ្រួសារ និងកូន ០៦ នាក់ ( ស្រី ០៤ និង ប្រុស ០២ នាក់) ។ គាត់រស់នៅក្នុងភូមិ កំពង់ត្រឡាច សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ។ គាត់ជាកសិករ ដែលមានចំណូលពីការធ្វើកសិកម្ម ដូចជាៈ ធ្វើស្រែ ចិញ្ចឹមជ្រូក មាន់ ទា ចិញ្ចឹមត្រី និង សួនបន្លែ ។

អ្នកស្រី **សែម សុខុម**មិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុង CIP របស់ គ.អ.ជ.ខ ខេត្តទេ។ គាត់មិនបានត្រូវគេជ្រើសរើសអោយចូលរួមវគ្គនេះទេ ដោយ សារគាត់ពុំមែនជាស្ត្រី ជំនួយការតាមភូមិ ហើយ លទ្ធភាពរបស់មន្ទីរមានកំរិត។ គាត់បានបន្តទៀតថាវគ្គបណ្តុះបណ្តាលការបញ្ជ្រាប យេនឌ័រក្នុងស៊ីអាយភីនេះ មានសារៈសំខាន់ណាស់ ព្រោះគាត់ឃើញអ្នកដែល បានចូលរួមវគ្គនេះ ធ្វើអោយពួកគេបានយល់ដឹងអំពីសម ភាពយេនឌ័រ អំពីអំពើហឹង្សាក្នុងគ្រួសារហើយធ្វើអោយពួកគេមាន ជីវភាពប្រសើរជាងមុន ។

អ្នកស្រី **សែម សុខុម** មានសេចក្តីសង្ឃឹមថាអាចចូលរួមវគ្គបណ្តុះបណ្តាល អំពីការបញ្ជ្រាបយេនឌ័រទៅក្នុង CIP ក្នុងឆ្នាំក្រោយៗទៀត និង ទទួលបានផលប្រយោជន៍ ដូចអ្នកជិតខាងរបស់គាត់ដែរ ។ ចុងបញ្ចប់គាត់ទទូចអោយអង្គការ និង ភ្នាក់ងារនានា ជួយអភិវឌ្ឍភូមិរបស់គាត់ ។

## ២.៣. ការវាយតម្លៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

| |
|---|
| ការរៀបចំ គឺសំដៅលើផ្នែកទី ៣: ការបរិយាយអំពីអនុកិច្ចសន្យាពិន្ទុ: ១=ខ្សោយណាស់ ២=ខ្សោយ ៣=មិនខ្លាំងមិនខ្សោយ ៤=ខ្លាំង ៥=ខ្លាំងណាស់ |

### ផ្នែក-ក: ភាពជាប់ពាក់ពន្ធ័នៃអនុកិច្ចសន្យាទៅនឹងតំរូវការៈ មន្ទីវិស័យ មូលដ្ឋាន គ.ជ.អ.ប និងការកាត់បន្ថយភាពក្រីក្រ

| ល.រ (១) | ធាតុ (២) | ទំនាក់ទំនង តក្កភាព (៣) | បរិយាយ ច្បាស់លាស់ (៤) | សង្ខេបការ វាយតម្លៃ (៥) |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនឹងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៤ | ៥ | - សកម្មភាពដែលបានលើកឡើងពិតជាមានទំនាក់ទំនងតក្កក ជាមួយនឹង លទ្ធផលទី១ដែលបានសរសេរក្នុង អនុកិច្ចសន្យា ។<br>- ជាក់ស្តែងលទ្ធផលទី១: បណ្តុះបណ្តាលពី ការបញ្ជ្រាប យេនឌ័រមានសកម្មភាព ជាក់លាក់ ដូចជាវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើក្រចក១វគ្គ វគ្គបណ្តុះបណ្តាលពីការបញ្ជ្រាបយេនឌ័រទៅក្នុង CIP ចំនួន០១វគ្គ។<br>- រាល់សកម្មភាពនីមួយៗបានសរសេរច្បាស់លាស់ ដោយបានបង្ហាញពី បរិមាណ អ្នកទទួលផល និង រយៈពេលច្បាស់លាស់ ហើយអ្នកចូលរួមចំគោលដៅរបស់គំរោង។ |
| ២ | លទ្ធផល | ៤ | ៤ | លទ្ធផលនីមួយៗ បរិយាយបានច្បាស់លាស់ជាក់លាក់អាចវាស់វែងបាន ។ ហើយលទ្ធផលទាំងអស់បានបំពេញបន្ថែមទៅអោយ គ្នាទៅវិញទៅមក ដើម្បីសំរេច បាននូវគោលបំណងបន្ទាន់។ ទោះជាយ៉ាងនេះក្តី លទ្ធផលទាំងនេះ មិនអាចសំរេចគោលបំនងបន្ទាន់មួយរយភាគរយទេ ដោយសារការចូល |

| | | | | |
|---|---|---|---|---|
| | | | | រួមរបស់ស្ត្រីជាថ្នាក់ ដឹកនាំនៅមានកំរិត ហើយការ អនុវត្តតួនាទី របស់ពួកគាត់នៅមិនទាន់ បានពេញលេញនៅឡើយហើយការលើកឡើង របស់ស្ត្រី នៅមិនទាន់ឆ្លើយតបទៅនឹងតំរូវការជាក់ស្តែងរបស់ស្ត្រីបានគ្រប់ជ្រុងជ្រោយនៅឡើយ ។ |
| ៣ | - គោលបំនងបន្ទាន់ *(គោលបំនងស្ថិតក្នុងចំណុច "ខ" នៃផ្នែកទី ៣)* | ៤ | ៤ | គោលបំណងបន្ទាន់បង្ហាញខ្លឹមសារច្បាស់លាស់ ប៉ុន្តែវាមានកំរិតខ្ពស់ ធ្វើអោយយើងពិបាកវាស់វែង នៅពេលចុងបញ្ចប់អនុកិច្ចសន្យានេះវាទាមទារពេលវេលាច្រើនដើម្បីជំរុញ អោយមានការយល់ដឹងពីសមភាពយេនឌ័រ បញ្ហាស្ត្រី និងកុមារដល់ភាគីពាក់ពន្ធ័ដើម្បីក្លាយខ្លួនជាដៃគូយ៉ាងសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍ ។ |
| ៤ | ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា *(ចំណុច "គ" នៃផ្នែកទី ៣)* | ៤ | ៤ | ស្ថានភាពចុងបញ្ចប់ នៃអនុកិច្ចសន្យានេះវាបានបញ្ជាក់ច្បាស់ អំពីការគ្របដណ្តប់លើ តំបន់គោលដៅ ការរំពឹងពីការសំរេចបានលើ សកម្មភាពលទ្ធផលទាំងអស់ ដែលបានគ្រោងទុកនិងត្រូវបានទាញចេញជាបទពិសោធន៍ លើភាពខ្លាំង ភាពខ្សោយ សំរាប់ប្រើប្រាស់ ក្នុងអនុវត្ត។ ប៉ុន្តែទោះជាយ៉ាងណាវាមិនបានឆ្លុះ បញ្ចាំងទៅលើប្រសិទ្ធភាពកំរិតយល់ដឹងរបស់អ្នក ចូលរួម និងទិន្នន័យចុងក្រោយលើ បញ្ហាយេនឌ័រ ក៏ដូចជាកំរិតជីវភាពរបស់ពួកគាត់ទេ ។ |
| ៥ | លទ្ធផលអភិវឌ្ឍន៍/ផលប៉ះពាល់រយៈពេលវែង : គោលដៅ និងគោលបំណងអភិវឌ្ឍន៍ | | | មិនអាចធ្វើការវាយតម្លៃបាន |

**ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារ:**

| ល.រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| **ពីខាង គ.ជ.អ.ខ :** | | |
| ១ | ជំនាញរៀបចំកិច្ចសន្យា | មានជំនាញប្រហែល ៧០-៨០ ភាគរយ គួរតែពង្រឹងសមត្ថភាពបន្ថែម ហើយមានការគាំទ្របច្ចេកទេសបន្តទៀត ។ |
| ២ | ការគាំទ្រទាន់ពេលវេលា និងការត្រួតពិនិត្យការអនុវត្តន៍ របស់ភ្នាក់ងារ អនុវត្តន៍ | សកម្មភាពអនុវត្តន៍បានទាន់ពេលវេលា និង មានប្រសិទ្ធភាពខ្ពស់គ្មានបញ្ហាប្រឈមធ្វើអោយរាំងស្ទះគួរអោយកត់សំគាល់ទេ ។ |
| ៣ | ការត្រួតពិនិត្យ និង កត់ត្រាឯកសារ អនុកិច្ចសន្យា | ធ្វើតាមទម្លាប់ និង នីតិវិធីរបស់កម្មវិធី ។ ការកត់ត្រា និងទុកដាក់ឯកសារគួរតែ រៀបចំអោយមានសណ្តាប់ ធ្នាប់ល្អ ងាយស្រួលរក (តាមបច្ចេកទេសក្នុងការគ្រប់គ្រង និងទុកដាក់ឯកសារ) ។ |
| **ពីខាងភាគីអនុវត្តន៍កិច្ចសន្យា:** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោង និងបច្ចេកទេស | មានបុគ្គលិកជំនាញ និងបទពិសោធន៍គ្រប់គ្រាន់អាចធ្វើការបាន តែនៅមានកំរិត ។ |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និង លទ្ធផល | ការអនុវត្តន៍បានល្អទោះបីជាមានការយឺតយ៉ាវ ក្នុងការរៀបចំអនុកិច្ចសន្យា និង ការទម្លាក់ថវិកាក៏ដោយ ។ នៅពេលមានចំណុចខ្វះខាតមន្ទីរ នឹងធ្វើការសាកសួរ និង រៀនសូត្របន្ថែមពីការរៀបចំឯកសារលទ្ធកម្ម និងឯកសារដទៃផ្សេងទៀតដោយធ្វើយ៉ាងណាអោយស្របតាមគោលការណ៍នៃ នីតិវិធីក្នុងការទូទាត់ថវិកា ។ |
| ៦ | របាយការណ៍រីកចំរើន និង ការកត់ត្រាឯកសារ | ធ្វើបានទៀងទាត់និងទាន់ពេលវេលាប៉ុន្តែការសរសេររបាយការណ៍នៅមិនទាន់ បានគ្រប់ជ្រុងជ្រោយតាមគោលបំណងរបស់កម្មវិធី ។ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | គោរពតាមលក្ខខណ្ឌនៃកិច្ចសន្យា |
| **ទាំងខាង គ.ជ.អ.ខ និងភាគីអនុវត្តកិច្ចសន្យា:** | | |

| | | |
|---|---|---|
| ៨ | ការគ្រប់គ្រង "ហានិភ័យ និងកត្តាសន្ទុត" (ចំណុច-ង ផ្នែកទី៣) និង បញ្ហាប្រឈម | ដោយសារមានការយឺតយ៉ាវក្នុងការរៀបចំ អនុមត័ អនុកិច្ចសន្យា ការទម្លាក់ថវិកាធ្វើអោយសកម្មភាព មួយចំនួន អនុវត្តមិនត្រូវតាមផែនការប៉ុន្តែទោះបីយ៉ាងនេះ ក៏ដោយវាក៏មិនមែនជាឧបសគ្គដែលបណ្តាលអោយរាំងស្ទះដល់ការអនុវត្តអនុកិច្ចសន្យានេះដែរ ។ |
| ៩ | ការបញ្រ្ជាបយេនឌ័រ ( ចំណុច-ច ផ្នែកទី៣) | ការអនុវត្តសកម្មភាពទាំងអស់របស់អនុកិច្ចសន្យានេះសុទ្ធតែផ្តោតលើការ បញ្រ្ជាបយេនឌ័រទាំងអស់ ។ |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ (ចំណុច-ឆ ផ្នែកទី៣) | ការអនុវត្តន៏គម្រោងនេះធ្វើអោយស្រ្តីមានចំណេះដឹងកាន់តែច្រើន និង មានឱកាសដើម្បីចូលរួមគ្រប់សកម្មភាពរបស់សហគមន៍ដូចជា ការចូលរួម ការផ្តល់យោបល់ ការសម្រេចចិត្ត និងអាចកំណត់ពីបញ្ហា និង តម្រូវការដែលទាក់ទងនឹងការគ្រប់គ្រងនិងថែរក្សាធនធានធម្មជាតិ ដើម្បីកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ និង ការនេសាទខុសច្បាប់ ។ |
| ១១ | ការថែរក្សា (និរន្តភាព) (ចំណុច-ជ ផ្នែកទី៣) | ចំណេះដឹងដែលបានទទួលពីការបណ្តុះបណ្តាលសិក្ខាកាមភាគច្រើនបានយកទៅអនុវត្តបន្តជារៀងរហូត ជាពិសេសនៅពេលធ្វើ ផែនការវិនិយោគឃុំ-សង្កាត់ និងសកម្មភាពយេនឌ័រផ្សេងៗ ។ |

## ២.៤. សេចក្តីសន្និដ្ឋាន

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យារបស់មន្ទីរកិច្ចការនារីបានអនុវត្តដូចការគ្រោងទុក រាល់សកម្មភាពទាំងអស់បានបញ្ចប់១០០ភាគរយ ។ អ្នកអនុវត្តអនុកិច្ចសន្យា មានសមត្ថភាពគ្រប់គ្រាន់ មានទំនាក់ទំនងល្អជាមួយភាគីពាក់ពន្ធ័ក្នុងការអនុវត្តន៏រាល់របាយការណ៏ និង ផែនការសកម្មភាពបានផ្ញើមក គ.ប្រស្រេបតាមផែនការដែលបានគ្រោងទុក ។ |
| ២ | រាល់សកម្មភាពរបស់មន្ទីរកិច្ចការនារីទទួលបានលទ្ធផល និង អត្ថប្រយោជន៏គួរជាទីមោទនៈមានការគាំទ្រពេញចិត្ត ពីអ្នកទទួលផលក្តី និង អ្នកមិនទទួលផលក្តី （លទ្ធផលនៃការសម្ភាសន៏）ជាពិសេសវគ្គបណ្តុះបណ្តាលជំនាញធ្វើក្រចក និង ការបញ្រ្ជាបយេនឌ័រទៅក្នុងស៊ីអាយភីនៅក្នុង ឃុំ-សង្កាត់ទាំង០៥។ ភស្តុតាងមួយចំនួន ដែលទាក់ទងទៅនឹងអត្ថប្រយោជន៏ យើងសង្កេត ឃើញបន្ទាប់ពីការ អនុវត្តន៏ អនុកិច្ចសន្យាចប់ សព្វគ្រប់មានដូចជា :<br>ក/.វគ្គបណ្តុះបណ្តាលជំនាញធ្វើក្រចក សិក្ខាកាមមានចំណេះដឹង និង ជំនាញយកទៅអនុវត្តបាន ប៉ុន្តែអ្នកទាំងអស់នោះមិនបានយកទៅប្រកបរបរចិញ្ចឹមជីវិតនៅឡើយទេ ។ ដោយសារខ្វះធនធានជាសម្ភារៈ និង ថវិកា ជាពិសេសរយៈពេលនៃការបណ្តុះបណ្តាលខ្លីពេក （កញ្ញា **អ៊ុង សោភី**）។ មានតម្រូវការវគ្គដូចគ្នានេះដែលជាសំណូមពររបស់ប្រជាជន ជាច្រើនទៀតដែលមាន ជីវភាពខ្វះខាតដូចគ្នា ប៉ុន្តែមិនទទួលបានការបណ្តុះបណ្តាល ដោយសារចំនួនសិក្ខា កាមមានកំណត់ដូច្នេះ សុំបន្ថែមចំនួនសិក្ខាកាមអោយបានច្រើនជាងនេះពី ១៥ - ២០នាក់ ក្នុងមួយវគ្គ ហើយមាន រយៈពេល០៦ខែ -០១ឆ្នាំ ។<br>ខ/.វគ្គបណ្តុះបណ្តាលការបញ្រ្ជាបយេនឌ័រទៅក្នុង CIP សិក្ខាកាមមានការយល់ដឹងច្រើនពីតម្រូវការ របស់ស្រ្តីនៅក្នុង ឃុំ-សង្កាត់ របស់ខ្លួនដោយយកបញ្ហាតាមរយៈ ការចូលរួមបញ្ចេញមតិ និង សម្រេចចិត្តក្នុងដំណើរការធ្វើ CIP ប្រចាំឆ្នាំ និង សកម្មភាពបញ្រ្ជាបយេនឌ័រ ដែលផ្តោតទៅលើផលប្រយោជន៏របស់ស្រ្តី និងកុមារ នៅក្នុងសហគមន៏ ដូចជា គាត់ក្លាយជាអ្នកផ្សព្វផ្សាយបន្ត ប៉ុន្តែចំណេះដឹងទាំងអស់របស់គាត នៅមានកំរិតដូច្នេះ ការបន្តផ្សព្វផ្សាយក៏មាន កំរិតដែរម៉្យាងទៀតគាត់មានជីវភាពក្រីក្រ ការចូលរួមមិនបានទៀងទាត់ ផ្ទះឆ្ងាយ និង គ្មានប្រាក់ឧបត្ថម្ភ ។ |
| ៣ | សិក្ខាកាមដែលបានចូលរួមក្នុង វគ្គការជ្រើសរើសដោយផ្អែកលើនីតិវិធី និង លក្ខខណ្ឌ័នានា ជាអាទិភាពសម្រាប់ផ្តល់នូវការលើកកម្ពស់ជីវភាពរបស់ស្រ្តី មេម៉ាយ ក្មេងកំព្រា ។ សិក្ខាកាមដែលជាស្រ្តីថ្នាក់ដឹកនាំ ក្រុង-ស្រុក ឃុំ-សង្កាត់ ភ្នាក់ងារផ្សព្វផ្សាយភូមិ ត្រូវមានចំណេះដឹង ភាពក្លាហាន ពេលវេលាគ្រប់គ្រាន់ ការបញ្ចេញមតិ និង តស៊ូមតិដោយយកបញ្ហា ស្រ្តី ដាក់បញ្ចូលជាអាទិភាពនៅក្នុង CIP ។ |

| | |
|---|---|
| ៤ | ជារួមអនុកិច្ចសន្យានេះ បានជួបប្រទះបញ្ហាមួយចំនួន តែយើងអាចដោះស្រាយបានដូចជា :<br>- ការជ្រើសរើសអ្នកចូលរួមមួយចំនួន មានការផ្លាស់ប្តូរញឹកញាប់ធ្វើអោយការអនុវត្តបន្តពេលបញ្ចប់គំរោង ពុំសូវមានប្រសិទ្ធភាពទៀងទាត់ និង អាចយកទៅអនុវត្តបន្តពេលបញ្ចប់គំរោង ។<br>- ការរៀបចំអនុកិច្ចសន្យា ការអនុមត័ និង បុរេប្រទានថវិកាមានការយឺតយ៉ាវ ។ |

## ចំណុចរៀនសូត្រ:

| ល.រ | ចំណុចសំខាន់ៗ |
|---|---|
| ១ | ការកំណត់គោលបំណងវគ្គ ច្បាស់លាស់ស្របជាមួយ ពេលវេលាអំណោយផលដែល អ្នកចូលរួមអាចទទួលយកចំណេះដឹងបាន (រយៈពេលនៃការបណ្តុះ បណ្តាល) ។ |
| ២ | គោលបំណងបន្ទាន់ ត្រូវសរសេរអោយច្បាស់អាចវាស់វែងបាន ងាយស្រួលកត់ត្រា លទ្ធផល និង អត្ថប្រយោជន៍ដើម្បីយើងអាចវាយតម្លៃលទ្ធផលបានល្អប្រសើរ ។ |
| ៣ | ការអនុវត្តន៍សកម្មភាព ត្រូវធ្វើអោយចំគោលដៅដែលជាអាទិភាព របស់ ឃុំ-សង្កាត់ ដើម្បីធានានិរន្តភាពរបស់អនុកិច្ច សន្យាបានកំរិតខ្ពស់ ។ |

## អនុសាសន៍ :

| ល.រ | អនុសាសន៍ |
|---|---|
| ១ | ពេលគ្រោងថវិការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈគួរតែពិចារណា ពី រយៈពេល សម្ភារៈ និង ថវិកា ដល់អ្នកចូលរួមសម្រាប់យកទៅប្រកបមុខរបរ នៅពេលដែលបញ្ចប់វគ្គ គួរមាន ប្រាក់ឧបត្ថម្ភ ដល់ សិក្ខាកាម ដែលមកពីឆ្ងាយ ។ |
| ២ | ពេលបើកវគ្គ គួតែបើកនៅទីតាំងសហគមន៍ ដើម្បីងាយស្រួលធ្វើដំណើរ និង មានការចូលរួមច្រើន។ |
| ៣ | គួរតែមានបើក វគ្គបណ្តុះបណ្តាល ពីការរៀបចំអនុកិច្ចសន្យា ការត្រួតពិនិត្យ តាមដាន និង វាយតំលៃ អោយបាន ២ ដងក្នុង១ ឆ្នាំ ។ |
| ៤ | គោលបំណងបន្ទាន់ត្រូវមានលក្ខណៈតូច អាចវាស់វែង និង សសេរអោយមានទំនាក់ទំនងទៅនឹងលទ្ធផល ។ |
| ៥ | ការទុកដាក់ឯកសារត្រូវដាក់តាមបច្ចេកទេស (ការគ្រប់គ្រង និង ទុកដាក់ឯកសារ) ។ |
| ៦ | ត្រូវមានសកម្មភាពតាមដាន និង គាំទ្រ ទោះបីគំរោងបញ្ចប់ក៏ដោយ ដើម្បីធានា និរន្តភាព នៃគំរោង ដើម្បីជួយ ដល់សហគមន ៍។ |

## ឯកសារដែលត្រូវភ្ជាប់ និង របាយការណ៍

## ឯកសារទី១: បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ ឯកសារទាក់ទងនិងការពិនិត្យ

| ល.រ (១) | ឈ្មោះឯកសារ/របាយការណ៍ (២) | មាន (៣) |
|---|---|---|
| ១ | ឯកសារអនុកិច្ចសន្យា (ផ្នែកទី១ ទី២ និងទី៣) | √ |
| ២ | របាយការណ៍ប្រចាំខែ ពីភ្នាក់ងារអនុវត្ត អនុកិច្ចសន្យា /មន្ទីរវិស័យ | √ |
| ៣ | របាយការណ៍ត្រួតពិនិត្យគម្រោង | |
| ៤ | របាយការណ៍បញ្ចប់អនុកិច្ចសន្យា | √ |
| ៥ | លិខិតឆ្លើយឆ្លងរវាងភ្នាក់ងារអនុវត្តន៍ និង គណៈកម្មាធិការប្រត្តិបត្តិគ.អ.ជ.ខ | |
| ៦ | បញ្ជីវត្ថុបណ្តុះបណ្តាល ដែលមានក្នុងអនុកិច្ចសន្យា | √ |
| ៧ | របាយការណ៍ហិរញ្ញវត្ថុ របស់អនុកិច្ចសន្យា | √ |
| ៨ | ឯកសារដ៏ទៃទៀតរួមមាន រូបថតនៃគម្រោង (អនុកិច្ចសន្យា) ដែលទុកនៅ គណៈកម្មាធិការប្រត្តិបត្តិ គ.អ.ជ.ខ និង នៅភ្នាក់ងារអនុវត្តន៍ ដែលមិនបានរៀបរាប់ខាងលើ | √ |
| ៩ | ផ្សេងទៀត | |

## ឯកសារដែលត្រូវភ្ជាប់ទី២ : បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានជួបសម្ភាសន៍/ជួបពិភាក្សា

**❋វគ្គបណ្តុះបណ្តាល ស្តីពីការបញ្ជ្រាបយេនឌ័រក្នុង CIP**

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៍ប្រើសម្រាប់ ប្រមូលទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១០ (ព្រឹក) | ១-លោកស្រី កៅ នី អនុប្រធានមន្ទី<br>២-លោក សៅ បុត្រធី មន្រ្តីពិនិត្យបញ្ជាក់ | មន្ទីរកិច្ចការនារី | ពិភាក្សាជាមួយអ្នករៀបចំ និងអនុវត្ត អនុកិច្ច សន្យា |
| ២ | ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១០ (រសៀល) | ៣-លោក ជិន សុមួស្ស ទីប្រឹក្សា តាមដានត្រួតពិនិត្យ និង វាយតំលៃ គំរោង ភីអេសឌីឌី | គ.ប្រ ខេត្ត | ពិភាក្សាជាមួយ អ្នក អ្នកពាក់ពន្ធ័ |
| ៣ | ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១០ (ព្រឹក) | ក្រុមអ្នកទទួលផល | មជ្ឈមណ្ឌល ស្ត្រី និង អភិវឌ្ឍន៍ ខេត្តកែប | សម្ភាសន៍ ជាមួយ ក្រុមអ្នកទទួល ផល ពីគំរោង |
| ៤ | ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១០ (ព្រឹក) | លោកស្រី **សួន ង៉ែត** អ្នកទទួលផលផ្ទាល់ | ភូមិព្រៃតាកុយ | សម្ភាសស៊ីជម្រៅ /ករណីសិក្សា |
| ៥ | ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១០ (រសៀល) | លោកស្រី **សែម សុខុម** អ្នកមិនទទួលផល | ភូមិកំពង់ត្រឡាច | សម្ភាសស៊ីជម្រៅ /ករណីសិក្សា |

❋វគ្គបណ្តុះបណ្តាលស្តីពីការធ្វើក្រចក

| ល.រ (១) | ថ្ងៃខែ (២) | ឈ្មោះ និង តួនាទី នៅក្នុងបរិបទអនុកិច្ចសន្យា (៣) | ទីកន្លែង (៤) | ឧបករណ៍ប្រើសម្រាប់ប្រមូលទិន្នន័យដែលបានប្រើ (៥) |
|---|---|---|---|---|
| ១ | ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១០ (ព្រឹក) | ក្រុមអ្នកទទួលផល : | ភូមិកំពង់ត្រឡាច (ជិតសាលាសង្កាត់ព្រៃធំ) | សម្ភាសន៍ជាមួយក្រុមអ្នកទទួលផលពីគំរោង |
| ៤ | ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១០ (ព្រឹក) | កញ្ញា **អ៊ុន សោភី** អ្នកទទួលផលផ្ទាល់ | ភូមិដំណាក់ចង្អើរ | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |
| ៥ | ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១០ (រសៀល) | កញ្ញា **ឈឿន ស្រីនាង** អ្នកមិនទទួលផល | បុរីកុមារខេត្តកែប | សម្ភាសស៊ីជម្រៅ/ករណីសិក្សា |

# របាយការណ៍ស្តីពីការវាយតម្លៃ

| | |
|---|---|
| លេខអនុកិច្ចសន្យា: | **24/GEN/0901-00** |
| ចំណងជើង: | ពង្រឹងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ពីខេត្តដល់មូលដ្ឋាន |
| ភ្នាក់ងារអនុវត្តន៍: | មន្ទីរ កិច្ចការនារី ខេត្ត ប៉ៃលិន |
| រយៈពេល( ចាប់ផ្តើម និងបញ្ចប់ ) | 01/01/2009 ដល់ 31/12/2009 |
| ខេត្ត | ប៉ៃលិន |
| ផ្នែក\មន្ទីរជំនាញ | ខេត្ត ប៉ៃលិន |
| ចំនួនថវិកាទទួលបានពី គ.អ.ជ.ខ | **US$ 5,326.00** |
| ការចូលរួមចំណែករបស់ដៃគូរអភិវឌ្ឍន៍ដទៃទៀត | US$ 0.00 |
| ការរួមចំណែករបស់សហគមន៍ | US$ 0.00 |
| ការរួមចំណែករបស់ភ្នាក់ងារអនុវត្ត | **US$ 532.60** |
| តម្លៃសរុប(ដុល្លាសហរដ្ឋអាមេរិច) | **US$ 5,853.60** |

## ក្រុមវាយតម្លៃ និង រៀបចំរបាយការណ៍

| ឈ្មោះ | មុខតំណែង |
|---|---|
| លោក លឹម ហ្វាស៊ី | មន្ត្រី ត្រួតពិនិត្យវាយតម្លៃ គ.ប្រ |
| លោក ប៉ុល ហោលី | មន្ត្រី ត្រួតពិនិត្យវាយតម្លៃ គ.ប្រ |
| លោក ព្រៅ គឹមហួន | គ្រូបង្គោលឆ្មើម |
| កញ្ញា ហុង សុឃឿន | គ្រូបង្គោលឆ្មើម |

ប៉ៃលិន

កញ្ញា ២០១០

# មាតិកា


| | | |
|---|---|---|
| | អក្សរកាត់ | ៣ |
| | របាយការណ៍សង្ខេប | ៤ |
| **១-** | **ទិដ្ឋភាពរួមនៃការវាយតម្លៃ** | **៦** |
| ១-១ | សេចក្ដីផ្ដើមនៃការវាយតម្លៃអនុកិច្ចសន្យារវាងគ.ប្រ នៃគ.អ.ជ.ខ និង មន្ទីរវិស័យ | ៦ |
| ១-២ | គោលបំណងអនុកិច្ចសន្យា | ៦ |
| ១-៣ | គោលបំណងនិងទំហំនៃការវាយតម្លៃ | ៦ |
| ១-៤ | សំណួរវាយតម្លៃ | ៦ |
| ១-៥ | វិធីសាស្ត្រ សម្ភារៈ និងដំណើរការវាយតម្លៃ | ៧ |
| ១-៦ | ដែនកំណត់និងបញ្ហាប្រឈមនៃការវាយតម្លៃ | ៧ |
| **២** | **លទ្ធផលសំខាន់ៗ និងការវិភាគតាមសំណួរវាយតម្លៃ** | **៩** |
| ២-១ | ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល | ៩ |
| | - លទ្ធផលទី១ | ៩ |
| | - លទ្ធផលទី២ | ១១ |
| | - លទ្ធផលទី៣ | ១២ |
| | - លទ្ធផលទី៤ | ១៣ |
| | - លទ្ធផលទី៥ | ១៤ |
| ២-២ | ការវាយតម្លៃការសម្រេចបាននូវអត្ថប្រយោជន៍ភ្លាមៗនិងលទ្ធផលនៃអនុកិច្ចសន្យា | ១៥ |
| ២-៣ | ការវាយតម្លៃលើការរៀបចំ ភាពពាក់ពន្ធ័ និងការគ្រប់គ្រង | ១៩ |
| ២-៤ | សេចក្ដីសន្និដ្ឋាន | ២១ |
| **ឯកសារដែលភ្ជាប់ជាមួយនឹងរបាយការណ៍** | | **២៣** |
| ទី១- | បញ្ជីឈ្មោះឯកសារអនុកិច្ចសន្យា របាយការណ៍ និងឯកសារពាក់ពន្ធ័ផ្សេងៗដែលបានពិនិត្យ | ២៣ |
| ទី២- | ឯកសារអនុកិច្ចសន្យា បញ្ជីឈ្មោះអ្នកផ្ដល់ព័ត៌មានសំខាន់ ដែលបានជួបសំភាសន៍ \ពិភាក្សា | ២៤ |
| **ករណីសិក្សា** | | **១៧** |
| ទី១- | អ្នកទទួលផលពីអនុកិច្ចសន្យាក្នុងគម្រោងបណ្ដុះបណ្ដាលស្ដីពីគោលគំនិតយេនឌ័រ | ១៧ |
| ទី២- | អ្នកមិនទទួលផល | ១៨ |

# អក្សរកាត់

| | |
|---|---|
| គ.ប្រ នៃ គ.អ.ជ.ខ | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ខេត្ត |
| កិច្ចសន្យា GOV | កិច្ចសន្យាគម្រោងរវាង គ.ប្រ នៃ គ.ជ.អ.ខ និង មន្ទីរវិស័យ |
| គ.អ.ជ.ប | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# របាយការណ៍សង្ខេប

ជារៀងរាល់ឆ្នាំគ.ជ.អ.ប ផ្តល់ថវិកាតាមរយៈ គ.ប្រនៃគ.អ.ជ.ខទៅមន្ទីរវិស័យដើម្បីអនុវត្តសកម្មភាព និងគំរោង ដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ក្នុងនោះមន្ទីរកិច្ចការនារីក៏បានលើកសំណើ គំរោងអាទិភាពខ្ពស់របស់ខ្លួន មកគ.ប្រ ដើម្បីស្នើសុំថវិកាវិភាជន៍ យកទៅអនុវត្ត គោលនយោបាយនិង យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ កិច្ចសន្យារបស់មន្ទីរផ្តោតទៅលើការពង្រឹងសមត្ថភាពបណ្តាញការងារ យេនឌ័រ ជាពិសេសអ្នកទទួលបន្ទុកកិច្ចការនារីឃុំ.សង្កាត់។

មន្ត្រីត្រួតពិនិត្យ និងវាយតំលៃផ្នែកគ្រប់គ្រងកិច្ចសន្យា និង គ្រូបង្គោលឆ្នើមបានវាយតំលៃអនុកិច្ច សន្យាដែលមានចំណងជើងថា ការបញ្ជ្រាបយេនឌ័រ ដែលជាអនុកិច្ចសន្យារវាង គ.ប្រ នៃគ.អ.ជ.ខនិង មន្ទីរកិច្ចការនារីនោះជា ផ្នែកមួយនៃគំរោងពង្រឹងសមត្ថភាពយេនឌ័រ ការបញ្ជ្រាបយេនឌ័រ ពិសេស គឺចង់បណ្តុះបណ្តាល ធនធានមនុស្ស ឬ អ្នកចូលរួមគម្រោងនេះ អោយមានឥទ្ធិពលខ្លាំងក្នុងការគោរព សិទ្ធិ និង អធ្យាស្រ័យគ្នា ក្នុងសហគមន៍ រួមគ្នារកចំណូលប្រចាំថ្ងៃ នឹង កាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ បានមួយចំនួនក្នុងន័យកាត់បន្ថយភាពក្រីក្រ ក្នុងគ្រួសារ។

ម្យ៉ាងវិញទៀតគឺចង់អោយប្រជាពលរដ្ឋបានយល់ដឹងច្បាស់ពី សុខមាលភាពរបស់មាតា និង ទារកក្នុងន័យជំរុញអោយពួកគេទៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យបង្អែក ដើម្បីពិគ្រោះ និងព្យាបាលជំងឺ អោយបានទាន់ពេលវេលាដើម្បីកាត់បន្ថយនៅគ្រោះថ្នាក់ជាយថាហេតុ ។ កត្តាដែលចាំបាច់ជាងនេះទៅទៀតគឺចង់ផ្សព្វផ្សាយ បន្ថែមដល់ប្រជាពលរដ្ឋដែលចាកចេញពីស្រុកភូមិ ទៅរកការងារនៅទីក្រុង ឬ ក៏ទៅរក ការងារនៅប្រទេសដ៏ទៃ ដែលគ្មានច្បាប់ទម្លាប់ត្រឹមត្រូវ ហើយវាអាចធ្វើអោយគ្រោះថ្នាក់ទាំងផ្លូវកាយ និង ផ្លូវភេទ ។

មន្ត្រីត្រួតពិនិត្យ និងវាយតំលៃផ្នែកគ្រប់គ្រងកិច្ចសន្យា និង គ្រូបង្គោលឆ្នើមបានវាយតំលៃផ្អែកទៅលើរបាយការណ៍ ប្រចាំខែ កំណត់ហេតុប្រជុំ របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍វគ្គបណ្តុះបណ្តាល ឯកសារពាក់ព័ន្ធ និងរបាយការណ៍បញ្ចប់កិច្ចសន្យាចុះពិនិត្យដល់កន្លែងដែលភ្នាក់ងារអនុវត្តគំរោង សង្កេតមើលសកម្មភាព ក្រុមគោលដៅ និងលទ្ធផលដែលបានទទួលជាក់ស្តែងនៅមូលដ្ឋាន ឃើញថាមានការប្រែប្រួលច្រើន ( មានភាពវិជ្ជមានច្រើនជាងមុន) ។

# សេចក្តីសន្និដ្ឋាន

អត្ថប្រយោជន៍ដែលបានពីការអនុវត្តអនុកិច្ចសន្យាជូនដល់មូលដ្ឋាននិងសហគមន៍ គឺជាការ បង្ហាញយ៉ាងច្បាស់ នឹងទទួលស្គាល់ពីអ្នកទទួលផល និងអ្នកមិនបានទទួលផលនៅក្នុងគំរោងឃុំ.សង្កាត់ គោលដៅ ឃើញថាប្រជាពលរដ្ឋដែលបានទទួលការផ្សព្វផ្សាយ ពីការបញ្ជ្រាបយេនឌ័រ ពួកគាត់ បានទទួលនូវចំណេះដឹង និងជំនាញជាច្រើន ឆ្លងតាមបទពិសោធន៍របស់ភូមិនីមួយៗដែល បានលើក ឡើង វាអាចឆ្លុះបញ្ចាំង ទៅវិញទៅមក ធ្វើអោយពួកគាត់ងាយដោះស្រាយ នៅពេលមាន បញ្ហា ហិង្សា ក្នុងគ្រួសារ និងការជួញដូរ កើតឡើង។ អ្វីដែលសំខាន់បំផុតនោះ សហគមន៍របស់ពួកគាត់ អាចយល់ដឹង ពីអំពើ ហឹង្សាក្នុងគ្រួសារបានមួយកំរិតធំប្រជាពលរដ្ឋក៏យល់បានច្រើន ពីភាពលំបាក និងការខាត បង់ទ្រព្យសម្បត្តិក្នុងគ្រួសារបើសិនពួកគាត់នៅមាន

អំពើហិង្សាក្នុងគ្រួសារ។ រីឯអំពើ ហិង្សាក្នុងគ្រួសារ ដែលបានកើតក្នុងគ្រួសារមួយចំនួនតូច ក្នុងសហគមន៍ ដោយសារ គ្រួសារមួយចំនួនតូចនេះ មិនបានចូលរួម ក្នុងការផ្សព្វផ្សាយ ពី អ្នកទទួលបន្ទុកស្ត្រី និង កុមារ។ ជាពិសេសជាងនេះទៅទៀត យើងសង្កេត ឃើញថានៅក្នុងមូលដ្ឋានពួកគាត់បច្ចុប្បន្ន មានការរីកចំរើន ច្រើនផ្នែកជីវភាព ដោយសារគាត់ យកពេលវេលាដែលឥតប្រយោជន៍ពីពេលមុន មកធ្វើស្រែចំការនិងប្រកប មុខរបរផ្សេងៗវិញ ដើម្បី ចិញ្ចឹមជីវិតនិងបានផ្គត់ផ្គង់កូនៗអោយបានចូលរៀនគ្រប់ៗគ្នា។

ជាមួយគ្នានេះដែរដើម្បីអោយបញ្ហាដែលបានលើកឡើងទាំងអស់អាចដោះស្រាយ បានជាបន្តបន្ទាប់ទៀត នោះ មន្ទីរកិច្ចការនារី គួរពង្រឹងសមត្ថភាពអ្នកទទួលបន្ទុកការងារ ស្ត្រី និងកុមារបន្តទៀត ពិសេសនៅភូមិ និងក្រុម ។

# ១- ទិដ្ឋភាពរួមនៃការវាយតម្លៃ

## ១-១ សេចក្តីផ្តើមអំពីការវាយតម្លៃអនុកិច្ចសន្យារវាងគ.ប្រ នៃគ.អ.ជ.ខ និង មន្ទីរវិស័យ

រៀងរាល់ឆ្នាំថវិកាតាមរយៈ គ.ប្រ នៃ គ.អ.ជ.ខ ទៅមន្ទីរវិស័យ ដើម្បីអនុវត្តសកម្មភាព និង គម្រោងដែលគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។ ការវាយតម្លៃដែលមានលក្ខណៈជាប្រព័ន្ធ មិនបាន អនុវត្តទេកាលពីពេលកន្លងមក ដោយមកពីហេតុផលជាច្រើន ។ នៅក្នុងឆ្នាំ២០១០ ជាមួយនឹងការគាំទ្រ ផ្នែកថវិកា និងផ្នែកបច្ចេកទេស ពីផ្នែកត្រួតពិនិត្យវាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃលេខាធិការ ដ្ឋានគ.ជ.អ.ប ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល គ.ប្ក នៃ គ.អ.ជ.ខ ក្នុងការអនុវត្តការវាយតម្លៃអនុកិច្ចសន្យា ដែលបានរៀបចំរួមគ្នា ជាមួយភ្នាក់ងារអនុវត្តដែលមានលេខ 24/GEN/0901-00 ដំណើរការលទ្ធផលដែលបានរក ឃើញ និងការសន្និដ្ឋាន នៃការវាយតម្លៃត្រូវបានកត់ត្រា ហើយនឹងបង្ហាញតាមរយៈរបាយការណ៍ស្តីពីការវាយ តម្លៃនេះ ។

## ១-២ គោលបំណងអនុកិច្ចសន្យា

ការបញ្ជ្រាបយេនឌ័រ ការពង្រឹងបណ្តាញការងារគឺជាផ្នែកមួយនៃការបណ្តុះបណ្តាលធនធានមនុស្ស ។ អ្នកចូលរួមគម្រោងនេះ នឹងមានឥទ្ធិពលខ្លាំងក្នុងការរកចំណូលប្រចាំថ្ងៃ រួមទាំងការកាត់បន្ថយនូវការ ចំណាយ មិនចាំបាច់នានា តាមរយៈការវិភាគសេដ្ឋកិច្ចគ្រួសារ ។ ការបញ្ជ្រាបយេនឌ័រនេះ ជាចំណែកមួយ នៃការ។ ប់រំសង្គមដែលនាំអោយអ្នកចូលរួមចេះមានសេចក្តីមេត្តា និងសាមគ្គីគ្នាក្នុងការរស់នៅ ជាមួយ សហគមន៍ ។

ការរៀបរាប់ខាងលើនឹងបម្រើដល់គោលបំណង នៃការកាត់បន្ថយភាពក្រីក្រ តាមរយៈគោលនយោបាយរាជរដ្ឋាភិបាល និងគម្រោង គាំទ្រកិច្ចអភិវឌ្ឍន៍បែបប្រជាធិបតេយ្យតាមរយៈ វិមជ្ឈការ និង វិសហមជ្ឈការ ចង់បានជាពិសេសស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋក្នុងការកែលំអជីវភាពរស់នៅ ។

## ១-៣ គោលបំណង និង ទំហំនៃការវាយតម្លៃ

គោលបំណង គឺដើម្បីវាយតម្លៃអនុកិច្ចសន្យាទាំងមូល ដោយផ្នែករដ្ឋបាល និងគ្រប់គ្រងកិច្ចសន្យារបស់គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងលក្ខណៈមួយប្រកបដោយបច្ចេកទេស និង តម្លាភាព ។ដូច្នេះទំហំនៃការវាយតម្លៃមាន ដែនកំណត់តាមទំហំនៃអនុកិច្ចសន្យា និងរាល់បញ្ហាដែលពាក់ពន្ធ័ ដូចមានចែងក្នុងក្របខណ្ឌការងារនៃការ វាយតម្លៃ។ គោលបំណងនៃការវាយតម្លៃគឺៈ ក)- ទាញយក កត់ត្រា និងវិភាគជាប្រព័ន្ធទៅលើសមិទ្ធផលនៃ អនុកិច្ចសន្យា និងចំនុចខ្សោយ ធៀបទៅនឹងលទ្ធផល គោលបំណងបន្ទាន់ និងស្ថានភាពចុងបញ្ចប់នៃអនុកិច្ច សន្យា រួមទាំងកត់ត្រានូវចំនុចរៀនសូត្រ និងផ្នែកដែលត្រូវធ្វើអោយប្រសើរឡើងនាពេលអនាគត និងខ)- ដើម្បីពង្រឹងរបៀបធ្វើការវាយតម្លៃគម្រោងរបស់ គ.ប្រ នៃ គ.អ.ជ.ខ នៅក្នុងដំណើរការនៃការអនុវត្ត។

## ១-៤ សំណួរវាយតម្លៃ

១- តើលទ្ធផលនៃអនុកិច្ចសន្យាសម្រេចបានកម្រិតណាធៀបនឹងផែនការ ?

២- តើអនុកិច្ចសន្យាសម្រេចនូវស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាល្អបានកម្រិតណា ? (ចំនុច គ ផ្នែកទី៣ )

៣- តើអនុកិច្ចសន្យាសម្រេចទិសដៅបន្ទាន់របស់ខ្លួនកម្រិតណា ?

៤- តើអនុកិច្ចសន្យាមានភាពពាក់ពន្ធ័ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ទាក់ទង នឹងការរៀបចំអនុវត្ត និង ការគ្រប់គ្រង ?

៥- តើមានការសន្និដ្ឋាន និងចំនុចរៀនសូត្រអ្វីខ្លះ សម្រាប់កែលម្អអនុកិច្ចសន្យាក្នុងពេលអនាគត ?

## ១-៥ វិធីសាស្ត្រសម្ភារ: និងដំណើរការវាយតម្លៃ

*វិធីសាស្ត្រ និងឧបករណ៍ដែលត្រូវប្រើ:*

១)- ការពិនិត្យអនុកិច្ចសន្យាឡើងវិញ របាយការណ៍ប្រចាំខែ កំណត់ហេតុប្រជុំ និងរបាយការណ៍បញ្ចប់ កិច្ចសន្យា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វគ្គបណ្តុះបណ្តាល និងរាល់ឯកសារដែលពាក់ពន្ធ័ ដែលមាន នៅក្នុងផ្នែក គ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល នៃ គ.ប្រ និងភ្នាក់ងារអនុវត្តន៍។

២)- ពិគ្រោះយោបល់ជាមួយអ្នកដែលផ្តលព័ត៌មានសំខាន់ៗរួមមាន: អ្នករៀបចំ និងអនុវត្តកិច្ចសន្យា អ្នកទទួល ផលផ្ទាល់ និង មិនផ្ទាល់ ព្រមទាំងភាគីពាក់ពន្ធ័។

៣)- ប្រើប្រាស់វិធីសាស្ត្រចុះពិនិត្យ តំបន់អនុវត្តគម្រោង និងសង្កេតមើលសកម្មភាព ពិភាក្សាក្រុម និង ករណីសិក្សា។

៤)- ចុះពិនិត្យតំបន់អនុវត្តគម្រោង ហើយសង្កេតមើលសកម្មភាព លទ្ធផល និងភស្តុតាងគម្រោងដោយផ្ទាល់ ។

៥)- វិភាគទិន្នន័យ និងបកស្រាយ: ទិន្នន័យដែលបានប្រមូលតាមវិធីសាស្ត្រខាងលើ នឹងត្រូវធ្វើការវិភាគ និង ផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឆ្លើយទៅនឹងសំណួរវាយតម្លៃជាក់លាក់ ។

៦)- ផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ ដោយភ្នាក់ងារអនុវត្ត និងអ្នកពាក់ពន្ធ័ តាមរយ: ព័ត៌មានត្រឡប់ ដែលទទួលបានពីការបង្ហាញ ដោយសង្ខេបដែលបានធ្វើឡើង ការវាយតម្លៃត្រូវធ្វើតាម « គោលការណ៍ណែនាំការវាយតម្លៃអនុកិច្ចសន្យា » និងវិធីសាស្ត្រដែលបានណែនាំ។ ដូច្នេះដំណើរការត្រូវបាន ធ្វើឡើងដោយមានទម្រង់ការណែនាំ និងតម្លាភាព

## ១.៦. ដែនកំណត់ និងបញ្ហាប្រឈម នៃការវាយតម្លៃ

១) ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃឯករាជ្យមកពីខាងក្រៅទេ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើង ដោយ គ.ប្រ និងអ្នកវាយតម្លៃដែលពាក់ពន្ធ័ផ្ទាល់ និងមិនផ្ទាល់ក្នុងការអនុវត្តអនុកិច្ចសន្យា ។ ទោះជាយ៉ាងណាក៏ដោយ ការប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីធានាអោយការវាយតម្លៃមានភាពល្អប្រសើរបំផុត ។

២) ចំណេះដឹងលើបច្ចេកទេសវាយតម្លៃនៅមានកម្រិត: វាជាបញ្ហាប្រឈមក្នុការវាយតម្លៃគម្រោង នៅពេលដែល អ្នកវាយតម្លៃមិនធ្លាប់មានជំនាញ និងបទពិសោធន៍ពីមុនមក ។ ទោះបីយ៉ាងណាក៏ដោយគោល បំណងសំខាន់ គឺ ដើម្បីរៀនធ្វើដោយការអនុវត្តផ្ទាល់ ។ អ្នកវាយតម្លៃបានទទួលការគាំទ្រដោយ មានគោលការណ៍ ណែនាំឧបករណ៍ និងវគ្គបណ្តុះបណ្តាលដែលពាក់ពន្ធ័ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ ។

៣) បញ្ហាប្រឈមនៅក្នុងផ្នែកទី៣នៃអនុកិច្ចសន្យា: ការវិភាគតារាងតក្កភាព(សង្ខេបលទ្ធផល និងសកម្មភាព) មិនមាន«សូចនាករ» និង « មធ្យោបាយផ្ទៀងផ្ទាត់»លើការរីកចម្រើន និងជោគជ័យទេ។ មួយទៀតទំនាក់ទំនង

សង្ខេបតាមបែបតក្កភាពរវាងសកម្មភាពធាតុចូល និងលទ្ធផល និងរវាងលទ្ធផលទៅនឹងគោលបំណងបន្ទាន់ មិនត្រូវបានបង្ហាញអោយបានច្បាស់លាស់ ហើយទំនាក់ទំនងទាំងនោះវាមិនសូវស៊ីគ្នាទេ ។

៤) ដោយយើងមិនមានសូចនាករបឋម យើងមិនអាចធ្វើការវាយតម្លៃទៅលើ « គោលដៅអភិវឌ្ឍន៍ » ដែលជាកម្រិតអត្ថប្រយោជន៍ទៅលើគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ និងកម្រិត«គោលបំណង» ដែលជាកម្រិតផលប៉ះពាល់ទៅលើការពង្រឹងស្ថាប័ន និងរចនាសម្ព័ន្ធនោះទេ ។

៥) ដោយយើងមានពេលវេលា ធនធាន និងថវិកាមានកំណត់ យើងមិនអាចធ្វើការវាយតម្លៃលម្អិតទៅលើ លទ្ធផល និងសកម្មភាពទាំងអស់បានទេ។ យោងអាចវាយតម្លៃទៅលើ **លទ្ធផល** (យុទ្ធនាការយេនឌ័រ) **សកម្មភាព** (វេទិការសម្រាប់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារដល់ថ្នាក់ដឹកស្ត្រី )ដែលជាសកម្មភាព នៃអនុកិច្ចសន្យា លម្អិតតាមរយៈការសំភាសន៍ស៊ីជម្រៅ ក្រុមពិភាក្សា និងការចុះ ពិនិត្យ តំបន់អនុវត្តគម្រោង ។

៦) *សូមរក្សាទុកចំនុចនេះប្រសិបើវាមានសុពលភាព:* ការវាយតម្លៃទៅលើស្ថានភាពចងបញ្ចប់នៃអនុកិច្ចសន្យាមិនអាចធ្វើទៅបានទេ ព្រោះចំនុច <u>គ</u> នៃផ្នែកទី៣ ក្នុងឯកសារអនុកិច្ចសន្យាមិនច្បាស់លាស់ឬ ពេញលេញ ។ ការងារនេះ នឹងកាន់តែមានសុពលភាព នឹង កាន់តែមានសុពលភាព និងពោពេញទៅដោយព័ត៌មាន បើសិនជាចំនុចដែលបានរៀបរាប់ខាងលើនេះត្រូវបានដោះស្រាយ ។

*ចំណុចដែលត្រូវរាប់បញ្ចូល ដកចេញ បដិសេធ:*

១) ការវាយតម្លៃនេះត្រូវបានកម្រិតយ៉ាងជាក់លាក់ចំពោះ ( 24/GEN/0901-00) និងដែនកំណត់ដូចដែលបានកំណត់នៅក្នុងក្របខណ្ឌនៃការវាយតម្លៃនេះ ។

២) ការវាយតម្លៃលម្អិតតែទៅលើ **លទ្ធផល** (យុទ្ធនាការយេនឌ័រ) និង **សកម្មភាព** (វេទិ ការសម្រាប់អ្នកទទួល បន្ទុកកិច្ចការនារី និងកុមារដល់ថ្នាក់ដឹកស្ត្រី )ដែលជាសកម្មភាពនៃអនុកិច្ចសន្យា ។

៣) ការវាយតម្លៃនេះមិនមែនជាការវាយតម្លៃទៅលើ ភ្នាក់ងារដែលពាក់ពន្ធ័គម្រោង ហើយនឹងការវាយតម្លៃទៅលើ គ.ប្រ នៃ គ.ជ.អ.ប ទេ ។

ហេតុដូច្នេះរបាយការណ៍ នៃការវាយតម្លៃ លទ្ធផលដែលបានរកឃើញ និងអនុសាសន៍ដែលបានលើកឡើងត្រូវពិនិត្យ ដោយយោលទៅបរិបទខាងលើ និង អនុវត្តតាមលំដាប់លំដោយ ។

# ២- លទ្ធផលសំខាន់ៗនៃការវិភាគតាមសំណួរវាយតម្លៃ

## ២-១ វាយតម្លៃការសម្រេចបានអនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល

*លទ្ធផលទី១ យុទ្ធនាការយេនឌ័រ*

*ផ្នែក-ក: ការសម្រេចបានជាក់ស្តែងធៀប និង ផែនការ*

| ល.រ | ការបរិយាយអំពីអនុកិច្ចសន្យា | លទ្ធផលសម្រេចបានជាក់ស្តែង |
|---|---|---|
| 1-1 | -ទិវានារីអន្តរជាតិ០៨មីនាឆ្នាំ២០០៩<br>-អ្នកចូលរួម ២៥០នាក់<br>-រយៈពេល ០១ថ្ងៃ | -បានរៀបចំប្រារព្ធទិវា០៨មីនា នាថ្ងៃទី០៩ខែមីនា<br>-អ្នកចូលរួមលើសផែនការដែលមានការចូលរួមពីលោកជំទាវ បាន ស្រីមុំ អ៊ី ឈាន សរុបចំនួន ៣៤៩ នាក់ស្រី ២៨២នាក់ |
| 1-2 | -វេទិកាសម្រាប់ពិភាក្សាដល់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ដល់ថ្នាក់ដឹកនាំស្ត្រី<br>-ពីរវគ្គ ០២ ថ្ងៃ<br>- អ្នកចូលរួម ៤០នាក់ ក្នុង ១វគ្គ សរុប ៨០នាក់ | - បានប្រារព្ធវេទិកាសម្រាប់ពិភាក្សាដល់អ្នកទទួលបន្ទុកកិច្ចការ នារីនិងកុមារ ដល់ថ្នាក់ដឹកនាំស្ត្រី នាថ្ងៃទី១៦ ខែ ឧសភានៅស្រុកសាលាក្រៅ និង នៅថ្ងៃទី ១៩ ខែ ឧសភា នៅក្រុងប៉ៃលិន<br>-អ្នកចូលរួម ស្រុកសាលាក្រៅចំនួន ៤៧ នាក់ ស្រី៣៩នាក់ ក្រុងប៉ៃលិន ចំនួន ៤៣នាក់ ស្រី ៣៩ នាក់ លើសផែនការ |
| 1-3 | ចុះធ្វើអន្តរាគមន៍អំពើហិង្សាក្នុងគ្រួសារ និងបទល្មើសដែលទាក់ទិននារីនិងកុមារ នៅសង្កាត់ទាំង ៨ | -បានចុះធ្វើអន្តរាគមន៍ចំនួន ០៥ ករណី ផ្លូវចិត្ត នៅភូមិក្រចាប់ ទួលខ្សៀវ ប៉ាហ៊ីត្បូង និងអូរតាពុកលើ<br>- បានចុះធ្វើអន្តរាគមន៍ចំនួន ១១ ករណីផ្លូវកាយ នៅភូមិផ្សារព្រំ អូរតាពុកលើ ទួលល្វា ប៉ាហ៊ីត្បូង ភ្នំដំបង ចំការកាហ្វេ ក្រចាប់ អូរឈើក្រំ ទួលខ្សៀវ ផ្សារព្រំ ក្រោក<br>- បានចុះធ្វើអន្តរាគមន៍ចំនួន ០៣ ករណី ជួញដូរបានកើតឡើង នៅភូមិប៉ាហ៊ីជើង ទឹកចេញ បរតាំងស៊ូ |

*ផ្នែក-ខ: ការវិភាគនិងវាយតម្លៃជារួមអំពីលទ្ធផល*

អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និង សកម្មភាពនានាលើសផែនការ ដែលបានគ្រោងទុកក្នុងកិច្ចសន្យាដោយមានអ្នកចូលរួមលើសពីការប៉ាន់ស្មាន ។

តាមប្រសាសន៍របស់សិក្ខាកាមដែលបានចូលរួមក្នុងក្រុមពិភាក្សាស្តីពីវេទិកាពិភាក្សា ដល់អ្នកទទួលបន្ទុក

កិច្ចការនារី និងកុមារដល់ថ្នាក់ដឹកនាំជាស្ត្រីថាពួកគាត់បានទទួលនូវចំណេះដឹង និងជំនាញ ជាច្រើន ពាក់ពន្ធ័នឹងបញ្ហានេះព្រោះតាមកិច្ចប្រជុំពិភាក្សាពួកគាត់បានបញ្ជាក់ថាឆ្លងតាមរយៈបទពិសោធន៍របស់ភូមិនីមួយៗដែលបានលើកឡើង វាបានឆ្លុះបញ្ចាំងទៅវិញទៅមកធ្វើអោយពួកគាត់ងាយដោះស្រាយនៅពេលមានបញ្ហាហិង្សាជួញដូរ កើតឡើង ។

ភាគច្រើននៃសិក្ខាកាមចូលចិត្ត អោយអ្នកសម្របសម្រួលប្រើប្រាស់ក្រុមពិភាក្សា ។ ព្រោះក្រុមពិភាក្សានេះអាច ឆ្លុះបញ្ចាំងអោយឃើញនូវបញ្ហាជាក់ស្តែងដែលពួកគាត់អាចប្រជុំគ្នា ដើម្បីស្វែងរកដំណោះស្រាយដូចជាករណីប្រើអំពើហិង្សា ករណីជួញដូរផ្លូវភេទ-ល-។ ទន្ទឹមនឹងនេះពួកគាត់ក៏បានលើកឡើងដែរថាអ្នកសម្របសម្រួលក្នុងកម្មវិធីនេះមានបទពិសោធន៍ច្រើនក្នុងការងារយេនឌ័រនេះ ។

សរុបសេចក្តីមក វេទិកាសម្រាប់ពិភាក្សាដល់អ្នកទទួលបន្ទុកកិច្ចការ នារីនិងកុមារ ដល់ថ្នាក់ដឹកនាំស្ត្រី មានលក្ខណៈប្រសើរណាស់សំរាប់ពួកគាត់ យកទៅផ្សព្វផ្សាយក្នុងសហគមន៍ដែលគាត់រស់នៅ ។

អ្វីដែលចាំបាច់និងសំខាន់បំផុតនោះ សហគមន៍របស់ពួកគាត់អាចកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារបានមួយកម្រិតធំ ហើយប្រជាជនក៏យល់បានច្រើន ពីភាពលំបាក និងការខាតបង់នៅក្នុងគ្រួសារប្រសិនបើពួកគាត់នៅតែប្រើអំពើហិង្សាតទៅទៀត ។ ជាពិសេសជាង នេះទៅទៀតយើងសង្កេតឃើញថា នៅក្នុងមូលដ្ឋាន របស់ពួកគាត់បច្ចុប្បន្ន សឹងតែពុំមានអំពើហិង្សាកើតឡើងទេ ពួកគាត់បែរទិសដៅយកពេលវេលាទាំងនោះទៅប្រកបការងារឬមុខរបរចិញ្ចឹមជីវិតវិញ ។ អ្វីដែលពិសេសជាងនេះទៅទៀតការបោះការសិក្សារបស់សិស្សត្រូវថយចុះ ការចំណាកស្រុក ត្រូវកាត់បន្ថយ គ្រោះថ្នាក់ក្នុងការសម្រាលកូនក៏បានកាត់បន្ថយផងដែរ ។

**លទ្ធផលទី២ បណ្តាញទំនាក់ទំនងយេនឌ័រ**

**ផ្នែក-ក: ការសម្រេចបានជាក់ស្តែងធៀប និង ផែនការ**

| ល.រ | ការបរិយាយអំពីអនុកិច្ចសន្យា | លទ្ធផលសម្រេចបានជាក់ស្តែង |
|---|---|---|
| 2-1 | -ប្រជុំប្រចាំត្រីមាសជាមួយយេនឌ័រ និងអ្នកពាក់ពន្ធ័ថ្នាក់ក្រុង\ស្រុក ៤ត្រីមាស | បានរៀបចំប្រជុំប្រចាំត្រីមាសចំនួន០៣លើក ដែលមានអ្នកចូលរួមសរុបចំនួន ១០២នាក់ស្រី ៦៨នាក់ (ត្រីមាសទី១មិនទាន់បានរៀបចំបណ្តាញយេនឌ័រ) |

**ផ្នែក-ខ: ការវិភាគនិងវាយតម្លៃជារួមអំពីលទ្ធផល**

| |
|---|
| អនុកិច្ចសន្យានេះអនុវត្តបានត្រឹមតែ ៧៥ ភាគរយ ប៉ុណ្ណោះមូលហេតុត្រីមាសទី១ មន្ទីរមិនទាន់បានរៀបចំបណ្តាញយេនឌ័រ ដោយការងារដើមឆ្នាំមមាញឹកច្រើន ។ ការពិនិត្យឯកសារអនុកិច្ចសន្យាឡើងវិញ មិនអាចវាយតម្លៃគុណភាពនៃលទ្ធលនេះ ។ |

**លទ្ធផលទី៣ (ក្នុងកិច្ចសន្យាលទ្ធផលទី៥) មន្ទីរកិច្ចការនារី គាំទ្រដល់ការបញ្ជ្រាបយេនឌ័រ**

***ផ្នែក-ក: ការសម្រេចបានជាក់ស្តែងធៀប និង ផែនការ***

| ល.រ | ការបរិយាយអំពីអនុកិច្ចសន្យា | លទ្ធផលសម្រេចបានជាក់ស្តែង |
|---|---|---|
| 3-1 | -ចុះបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល ពីជំហាន១-៥ | -ចាប់ពីថ្ងៃទី០៣-២៦ខែមិថុនា មន្ត្រីមន្ទីរកិច្ចការនារីចំនួន ១៣នាក់ ស្រី០៩ នាក់ បានសហការគ្នាជាមួយអង្គភាពរដ្ឋបាលមូលដ្ឋាន និង គ.ផ.ថ បានចុះបញ្ជ្រាបយេនឌ័រក្នុងការកសាងកម្មវិធីវិនិយោគឆ្នាំ ២០១០ ទាំង៨ឃុំ\សង្កាត់ ចាប់ពីជំហាន១-៥ |
| 3-2 | ចូលរួមសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក\ក្រុង | -ថ្ងៃទី១៩ ខែវិច្ឆិកា មន្ត្រីមន្ទីរកិច្ចការនារីបានចូលរួមសិក្ខាសាលាសមាហរណកម្ម ស្រុកសាលាក្រៅ<br>- ថ្ងៃទី២០ ខែវិច្ឆិកា មន្ត្រីមន្ទីរកិច្ចការនារីបានចូលរួមសិក្ខាសាលាសមាហរណកម្ម ក្រុងប៉ៃលិន |

***ផ្នែក-ខ: ការវិភាគនិងវាយតម្លៃជារួមអំពីលទ្ធផល***

អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និងសកម្មភាពដែលបានគ្រោងទុក ។ ការពិនិត្យអនុកិច្ចសន្យាឡើងវិញមិនអាចវាយតម្លៃនៃលទ្ធផលបានលម្អិតទេ

## លទ្ធផលទី៤ (ក្នុងអនុកិច្ចសន្យាលទ្ធផលទី៥) បណ្តុះបណ្តាលស្តីពីការបញ្ច្រាបយេនឌ័រ

### *ផ្នែក-ក: ការសម្រេចបានជាក់ស្តែងធៀប និង ផែនការ*

| ល.រ | ការបរិយាយអំពីអនុកិច្ចសន្យា | លទ្ធផលសម្រេចបានជាក់ស្តែង |
|---|---|---|
| 4-1 | -វគ្គផ្សព្វផ្សាយអប់រំកុមារតូច និងសិទ្ធិស្ត្រីដល់ប្រជាពលរដ្ឋទាំង៨ឃុំ\សង្កាត់<br>- ចំនួន០២ វគ្គ | -ថ្ងៃទី២៨ ខែកក្កដា បានបើកវគ្គផ្សព្វផ្សាយអប់រំកុមារតូចនៅ សង្កាត់បយ៉ាខា មានអ្នកចូលរួម ៤៦នាក់ ស្រី ៤២នាក់។<br>-ថ្ងៃទី២៩ ខែ កក្កដា បានបើកវគ្គផ្សព្វផ្សាយអប់រំកុមារតូចនៅ ឃុំស្ទឹងត្រង់ មានអ្នកចូលរួម ៥២នាក់ ស្រី ៤៥នាក់។ |
| 4-2 | បើកវគ្គផ្សព្វផ្សាយអោយយល់ដឹងពីច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារដល់ប្រជាពលរដ្ឋទាំង ៨ឃុំ\សង្កាត់<br>-ចំនួន២វគ្គ | -ថ្ងៃទី០៩ ខែ កក្កដា បានបើកវគ្គបណ្តុះបណ្តាលនៅ ស្រុកសាលាក្រៅ មានអ្នកចូលរួម ៥០នាក់ស្រី២៣ នាក់<br>-ថ្ងៃទី ១០ ខែ កក្កដា បានបើកវគ្គបណ្តុះបណ្តាលនៅ ក្រុងប៉ៃលិន មានអ្នកចូលរួម៥០នាក់ស្រី ៣៤នាក់ |

### *ផ្នែក-ខ: ការវិភាគនិងវាយតម្លៃជារួមអំពីលទ្ធផល*

| |
|---|
| អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និងសកម្មភាពដែលបានគ្រោងទុក ។ ការពិនិត្យអនុកិច្ចសន្យាឡើងវិញមិនអាចវាយតម្លៃនៃលទ្ធផលបានលម្អិតទេ |

### លទ្ធផលទី៥ ពង្រឹងសមត្ថភាពដល់មន្ត្រីមន្ទីរកិច្ចការនារី

### ផ្នែក-ក: ការសម្រេចបានជាក់ស្តែងធៀប និង ផែនការ

| ល.រ | ការបរិយាយអំពីអនុកិច្ចសន្យា | លទ្ធផលសម្រេចបានជាក់ស្តែង |
|---|---|---|
| 5-1 | -បណ្តុះបណ្តាលស្តីពីជំនាញរដ្ឋបាលនិងការគ្រប់គ្រង ផ្អែកលើលទ្ធផលជាមូលដ្ឋានដល់មន្ត្រីមន្ទីរ | -ថ្ងៃទី២០-៣០ខែកញ្ញា បានបើកវគ្គបណ្តុះបណ្តាល មានសិក្ខាកាមចូលរួមចំនួន ៣០នាក់ ស្រី១៩ នាក់ នៅសាលប្រជុំមន្ទីរ |

### ផ្នែក-ខ: ការវិភាគនិងវាយតម្លៃជារួមអំពីលទ្ធផល

| |
|---|
| អនុកិច្ចសន្យានេះសម្រេចបាននូវលទ្ធផល និងសកម្មភាពដែលបានគ្រោងទុក ។ ការពិនិត្យអនុកិច្ចសន្យាឡើងវិញ មិនអាចវាយតម្លៃនៃលទ្ធផលបានលម្អិតទេ |

## ២-២ ការវាយតម្លៃការសម្រេចបាននូវអត្ថប្រយោជន៍ភ្លាមៗ និងលទ្ធផលនៃអនុកិច្ចសន្យា

### *ផ្នែកក: ការវាយតម្លៃការសម្រេចបានរបស់ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា*

| ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា | ស្ថានភាពជាក់ស្តែង |
|---|---|
| - មន្ត្រីរាជការ និងប្រជាពលរដ្ឋ ចំនួន ២៥០នាក់មកពីជុំវិញខេត្តបានចូលរួមទិវា ០៨មីនាឆ្នាំ២០០៩។ | -មន្ត្រីរាជការនិងប្រជាពលរដ្ឋចំនួន៣៤៩នាក់ក្នុងនោះស្រី២៨២នាក់បានចូលរួមទិវា ០៨មីនា |
| អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារចំនួន៨០នាក់មកពី៨ឃុំ\សង្កាត់ ក្នុង ស្រុកសាលាក្រៅនិងក្រុងប៉ៃលិនបានចូលរួមក្នុងវេទិកាពិភាក្សាស្តីពីតួនាទីរបស់អ្នកទទួលបន្ទុកស្ត្រីនិងកុមារ ។ | - អ្នកទទួលបន្ទុកស្ត្រី និង កុមារចំនួន៩០នាក់ ស្ត្រីចំនួន៧៨ នាក់បានចូលរួមពិភាក្សាក្នុងវេទិកាស្តីពីតួនាទីអ្នកទទួលបន្ទុកស្ត្រីនិងកុមារ ។<br>- អ្នកចូលរួមពិភាក្សាភាគច្រើននៅក្នុងអំឡុងពេលពិភាក្សាក្នុងក្រុម បានមានប្រសាសន៍រាយការណ៍ ដោយសេចក្តីរីករាយថាគាត់មានការពេញចិត្តយ៉ាងខ្លាំងចំពោះវេទិកានេះ ។ ព្រោះថាវេទិកានេះបានបង្ហាញពីបញ្ហាជួបប្រទះជាច្រើន នៅក្នុងសហគមន៍របស់ពួកគាត់ ដែលជា តម្រូវការចាំបាច់ក្នុងការពិភាក្សាដើម្បីស្វែងរក ដំណោះស្រាយជូនប្រជាពលរដ្ឋនៅក្នុងសហគមន៍ពួកគាត់ ។ ជាពិសេសពួកគាត់បានបន្ថែមថាក្រោយពីបានចូលរួមក្នុងវេទិកានេះ រួចយកទៅផ្សព្វផ្សាយនៅមូលដ្ឋាន របស់ពួកគាត់ឃើញថាអំពើហិង្សាក្នុងគ្រួសារត្រូវកាត់បន្ថយ ការជួញដូរផ្លូវភេទ និង ទៅស៊ីឈ្នួលនៅប្រទេសជិតខាងមានការថយ ចុះ ។ ជាមួយគ្នានេះក៏បានកាត់បន្ថយការបោះបង់ការសិក្សារបស់សិស្ស តាមការជំរុញពីឪពុក ម្តាយដែលបានចូលរួមទទួលការផ្សព្វផ្សាយបន្តពីពួកគាត់ ។ ចំណែកស្ត្រីមានផ្ទៃពោះភាគច្រើនបានទៅពិនិត្យសុខភាព និង សម្រាលកូននៅមន្ទីរពេទ្យ ។<br>- តាមការចុះសំភាសន៍និងសាកសួរនៅមូលដ្ឋានឃើញថាប្រជាពលរដ្ឋភាគច្រើនបានទទួលនូវសេវាផ្សព្វផ្សាយបន្តពីអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារប្រចាំភូមិ ឃុំនីមួយៗ ។ |
| ប្រជាពលរដ្ឋ ០៤ឃុំ ៤សង្កាត់ដែលទទួលរងនូវអំពើ ហិង្សាក្នុងគ្រួសារ និងបទល្មើសនានាដែលទាក់ទិន លើស្ត្រីនិងកុមារ ត្រូវបានទទួលអន្តរាគមន៍ពីមន្ត្រីមន្ទីរកិច្ចការនារី | -បានចុះធ្វើអន្តរាគមន៍ចំនួន ០៥ ករណី ផ្លូវចិត្ត នៅភូមិក្រចាប់ ទួលខ្សេវ ប៉ាហ៊ីត្បូង និងអូរតា ពុកលើ<br>- បានចុះធ្វើអន្តរាគមន៍ចំនួន ១១ ករណីផ្លូវកាយ នៅភូមិផ្សារព្រំ អូរតាពុកលើ ទួលល្វា ប៉ាហ៊ីត្បូង ភ្នំ ដំបង ចំការកាហ្វេ ក្រចាប់ អូរឈើក្រំ ទួលខ្សេវ ផ្សារព្រំ ក្បោក |

| | |
|---|---|
| | - បានចុះធ្វើអន្តរាគមន៍ចំនួន ០៣ ករណី ជួញដូរ បានកើតឡើង នៅភូមិ ប៉ាហ៊ីដើង ទឹកចេញ បរតាំងស៊ូ |

## ផ្នែកខ ការវាយតំលៃការសំរេចបានរបស់គោលបំណងបន្ទាន់

| ធាតុនៃគោលបំណងបន្ទាន់ | ការសំរេចបានជាក់ស្តែងនៅពេលបញ្ចប់ អនុកិច្ចសន្យា |
|---|---|
| ការកាត់បន្ថយការយល់\ទស្សនៈខុសឆ្គង អំពីការបញ្ជ្រាបយេនឌ័រដើម្បីចូលរួមការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងគោលបំណង ពង្រឹងយុទ្ធសាស្ត្រយេនឌ័រពីខេត្តដល់មូលដ្ឋាននិងកាត់បន្ថយបាននៅអំពើហិង្សាក្នុងគ្រួសារព្រមទាំងបង្កើនការយល់ដឹងពីសិទ្ធិនារី ។ | ក្រោយពីបានអនុវត្តនៅកិច្ចសន្យា របស់មន្ទីរកិច្ចការនារីពិសេស អនុកិច្ចសន្យា ស្តីពី យុទ្ធនាការយេនឌ័រ ។ នឹងក្រោយពីបានចុះសំភាសន៍ជាមួយមន្ត្រីពាក់ពន្ធ័ ព្រមទាំងពិភាក្សាក្នុងក្រុមរួចមកជាលទ្ធផលដូចខាងក្រោម:<br>- បានប្រារព្ធវេទិកាសម្រាប់ពិភាក្សាដល់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ដល់ថ្នាក់ដឹកនាំស្ត្រីនាថ្ងៃទី១៦ ខែ ឧសភានៅស្រុកសាលាក្រៅ និង នៅថ្ងៃទី ១៩ ខែ ឧសភា នៅក្រុងប៉ៃលិន<br>-អ្នកចូលរួម ស្រុកសាលាក្រៅចំនួន ៤៧ នាក់ ស្រី៣៩នាក់ ក្រុងប៉ៃលិន ចំនួន ៤៣នាក់ ស្រី ៣៩ នាក់ លើសផែនការ។<br>-បានចុះធ្វើអន្តរាគមន៍ចំនួន ០៥ ករណី ផ្លូវចិត្ត នៅភូមិក្រចាប់ ទួលខ្សេវ ប៉ាហ៊ីត្បូង និងអូរតា ពុកលើ។<br>- បានចុះធ្វើអន្តរាគមន៍ចំនួន ១១ ករណីផ្លូវកាយ នៅភូមិផ្សារព្រំ អូរតាពុកលើ ទួលល្វា ប៉ាហ៊ីត្បូង ភ្នំ ដំបង ចំការកាហ្វេ ក្រចាប់ អូរឈើក្រំ ទួលខ្សេវ ផ្សារព្រំ ក្រោក ។<br>-បានចុះធ្វើអន្តរាគមន៍ចំនួន ០៣ ករណី ជួញដូរ បានកើតឡើងនៅភូមិ ប៉ាហ៊ីដើង ទឹកចេញ បរតាំងស៊ូ ។<br>- បានប្រារព្ធវេទិកាសម្រាប់ពិភាក្សាដល់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ដល់ថ្នាក់ដឹកនាំស្ត្រីនាថ្ងៃទី១៦ ខែ ឧសភានៅស្រុកសាលាក្រៅ និង នៅថ្ងៃទី ១៩ ខែ ឧសភា នៅក្រុងប៉ៃលិន<br>-អ្នកចូលរួម ស្រុកសាលាក្រៅចំនួន ៤៧ នាក់ ស្រី៣៩នាក់ ក្រុងប៉ៃលិន ចំនួន ៤៣នាក់ ស្រី ៣៩ នាក់ លើសផែនការ |

## ផ្នែកគ: ការវាយតម្លៃផលប្រយោជន៍ជារួមដែលទទួលបាន

តាមរយៈការពិភាក្សាក្រុម អ្នកចូលរួមបានបង្ហាញថាពួកគាត់មានការពេញចិត្តចំពោះផលប្រយោជន៍ដែលអនុកិច្ចសន្យា នេះសម្រេចបានជាពិសេសអាចពង្រឹងបាននូវចំណេះដឹងនិងបទពិសោធន៍ក្នុងការដោះស្រាយបញ្ហាដែលពាក់ពន្ធ័ និងការងារយេនឌ័រ ។ ពួកគាត់មានប្រសាសន៍ថាការងារនេះមានសារៈប្រយោជន៍ដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ ក្នុងការកាត់បន្ថយភាពក្រីក្រ ។ ពិសេស ការកាត់បន្ថយអំពើហិង្សា កាត់បន្ថយគ្រោះថ្នាក់នៅពេលសម្រាល កូនដោយឆ្មបបុរាណ កាត់បន្ថយការចំណាក ស្រុក និងការជួញដូរផ្លូវភេទ ។

# ករណីសិក្សា

### *ករណីសិក្សាទី១ ៖ អ្នកទទួលផលផ្ទាល់ពីអនុកិច្ចសន្យាក្នុងគម្រោងវេទិកាពិភាក្សាអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ*

បន្ទាប់ពីបានចូលរួមក្នុងគម្រោងយ៉េនឌ័រ របស់មន្ទីរកិច្ចការនារី ដែល ទទួលថវិកាវិភាជន៍ពី គ.អ.ជ.ខ ខេត្តប៉ៃលិន ស្តីពីវេទិកាពិភាក្សាអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ក្នុងឆ្នាំ ២០០៥រួចមក លោកស្រី ទន់ ស៊ីមែន បាននិយាយថា: សព្វថ្ងៃនៅក្នុងសហគមន៍របស់គាត់ពុំសូវកើតមានបញ្ហាហិង្សាក្នុងគ្រួសារ ចំណាកស្រុក ស្ត្រីមានផ្ទៃពោះមានគ្រោះថ្នាក់ច្រើនដូចមុននោះទេ ។

លោកស្រី ទន់ ស៊ីមែន ជាចៅសង្កាត់រងទី១ សង្កាត់ទួលល្វា ក្រុងប៉ៃលិន នឹងជាជនបង្គោលទទួលបន្ទុកកិច្ចការនារីបាននិយាយថាបន្ទាប់ពីលោកស្រីបានចូលរួមក្នុងវេទិកាពិភាក្សា ជាមួយអ្នកទទួលបន្ទុកកិច្ចការនារីរួចមក លោកស្រី បានយកចំណេះដឹង ដែលលោកស្រីទទួលបានក្នុងវេទិកាពិភាក្សានោះមកផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍លោកស្រី ក៏ដូចជាក្នុងសង្កាត់លោកស្រីផងដែរ ។ លោកស្រីបានបញ្ជាក់ថាពីមុននៅក្នុងសហគមន៍ លោកស្រីមានបញ្ហាជាច្រើន ដែលពិបាកដោះស្រាយណាស់ ពិសេសអំពើហិង្សា ចំណាកស្រុក អ្នកមានផ្ទៃពោះភាគច្រើនមិនបានគិតគូរពីសុខភាពរបស់ខ្លួន ។ ហើយការជួញដូរផ្លូវភេទកើតឡើងជាបន្តបន្ទាប់ ។ ក្រោយពីលោកស្រីបានយកចំណេះដឹង និងបទពិសោធន៍ដែលទទួលបានពីកិច្ចពិភាក្សាយកមក ផ្សព្វផ្សាយដោយផ្ទាល់ជាមួយប្រជាពលរដ្ឋរួចមក ឃើញថាបញ្ហា ដែលធ្លាប់កើតមានពីពេលមុនត្រូវបានកាត់បន្ថយមួយកម្រិតធំ ។ នៅពេលដែលបញ្ហាទាំងនេះត្រូវបានកាត់បន្ថយលោកស្រីបានបន្ថែមថា ភាពក្រីក្ររបស់ប្រជាពលរដ្ឋក៏ថយចុះមួយកម្រិត ដោយប្រជាពលរដ្ឋចេះប្រើប្រាស់ពេលវេលារបស់ខ្លួនប្រកបការងារចិញ្ចឹមជីវិត នៅក្នុងស្រុកមិនចំណាកស្រុកទៅរកការងារនៅក្រៅប្រទេស ។ ទន្ទឹមនឹងនេះលោកស្រីក៏បានសង្កេតឃើញថាឪពុក ម្តាយចេះយកចិត្តទុកដាក់ក្នុងការ ជំរុញកូនអោយទៅសាលារៀន និងចេះផ្តល់ភាពកក់ក្តៅដល់ក្រុមគ្រួសារ ។

ចុងបញ្ចប់ក្នុងនាមលោកស្រីជាជនបង្គោលទទួលបន្ទុកកិច្ចការនារី និង កុមារ ហើយលោកស្រីជាអាជ្ញាធរដែនដីទៀតលោកស្រីប្តេជ្ញាថា និងខិតខំប្រឹងប្រែងយកចិត្តដាក់ផ្សព្វផ្សាយ ពីបញ្ហាទាំងអស់នេះជាប្រចាំពិសេសពេលប្រជុំ ពេលចុះទៅតាមមូលដ្ឋាននានា ដើម្បីអោយស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ។

## ករណីសិក្សាទី២ ៖ អ្នកមិនទទួលផលផ្ទាល់

អ្នកស្រី សុខ វណ្ណី អាយុ ៤២ ឆ្នាំ ។ គាត់មានគ្រួសារ និងកូន ០៣នាក់ ។ គាត់រស់នៅភូមិ ទួលនិមិត្ត សង្កាត់ ទួលល្វា ក្រុង ប៉ៃលិន ខេត្ត ប៉ៃលិន ។ គាត់គឺជាមនុស្សម្នាក់ដែលធ្លាប់តែទទួលរងនៅការធ្វើបាបពីប្តី របស់គាត់ ជារៀងរាល់ថ្ងៃ (ប្តីគាត់គឺជាអ្នកចូលចិត្តផឹកស្រា) ។ អ្នកស្រី សុខ វណ្ណី មិនបានចូលរួមក្នុងវេទិកា ពិភាក្សាស្តីពី កិច្ចការនារី នឹងកុមារនោះទេ ព្រោះគាត់ពុំមានតួនាទីអ្វីក្នុងភូមិនេះទេ គាត់ជាប្រជាជនសាមញ្ញ។

អ្នកស្រីបានបញ្ជាក់ថាគាត់ចង់ចូលក្នុងវេទិកានេះណាស់ តែគាត់គ្មានលទ្ធភាព ។ មូលហេតុដែលគាត់ ចង់ចូលរួមវេទិកានេះព្រោះគាត់យល់ថាវានឹងអាចជួយគាត់ក្នុងការដោះស្រាយបញ្ហាក្នុងគ្រួសារគាត់បាន ។ ថ្ងៃមួយ គាត់មានសេចក្តីសង្ឃឹមឡើងវិញ នៅពេលដែលប្តីរបស់គាត់បានចូលរួមស្តាប់ ការផ្សព្វផ្សាយពីអ្នកទទួល បន្ទុក កិច្ចការនារី និងកុមារ នៅក្នុងភូមិ ។ ក្រោយពីប្តីខ្ញុំបានចូលរួមស្តាប់រួចមកឃើញថាឥរិយាបថរបស់គាត់ មានការ ប្រែប្រួល គួរអោយកត់សម្គាល់ ។ ទន្ទឹមនឹងឥរិយាបទបែបនេះខ្ញុំក៏បានលួចសួរអ្នកជិតខាងដែលបាន ចូលរួមស្តាប់ ការផ្សព្វផ្សាយនោះទើបគេប្រាប់ខ្ញុំថា ក្រុមការងារដែលបានចុះមកផ្សព្វផ្សាយនោះគឺគេផ្សព្វផ្សាយពីច្បាប់ទប់ស្កាត់ អំពើហិង្សា ពីទោសទណ្ឌ នឹងពីផលវិបាកក្រោយពីមានអំពើហិង្សាកើតឡើងផង ។ មិនត្រឹមតែប៉ុណ្ណោះពួកគេ ក៏បានផ្សព្វផ្សាយពីការថែទាំសុខភាពរបស់មាតា និង ទារកការជំរុញកូនអោយចូលរៀន និងផលវិបាក នៃការចាកឆ្ងាយ ពីផ្ទះទៅស្វែងរកការងារធ្វើនៅទីក្រុង ឬ ប្រទេសដ៏ទៃ ។

ជាចុងក្រោយ អ្នកស្រី សុខ វណ្ណីបានបញ្ជាក់ថាបើសិនជាមានឱកាស ពេលដែលមានក្រុមការងារចុះមក ផ្សព្វផ្សាយដល់មូលដ្ឋានយើងខ្ញុំទៀតខ្ញុំសង្ឃឹមថានឹងបានចូលរូមក្នុងការផ្សព្វផ្សាយនេះព្រោះវាអាចជួយសម្រួលដល់ អនាគតក្រុមគ្រួសារ និងកូនចៅរបស់ខ្ញុំ ។

## ២-៣ ការវាយតំលៃលើការរៀបចំ ភាពពាក់ព័ន្ធ និងការគ្រប់គ្រង

(ពិន្ទុ: ១=ខ្សោយណាស់ ២=ខ្សោយ ៣=មិនខ្លាំងមិនខ្សោយ ៤=ខ្លាំង ៥=ខ្លាំងណាស់)

| លរ | ធាតុ | ទំនាក់ទំនងតក្កភាព | បរិយាយច្បាស់លាស់ | សង្ខេបការវាយតម្លៃ |
|---|---|---|---|---|
| **ភាពពាក់ព័ន្ធនៃការរៀបចំផ្នែកទី ៣ និងភាពសក្តិសមទៅនិងតំរូវការដែលបានកំណត់** | | | | |
| ១ | សកម្មភាព | ៤ | ៥ | សកម្មភាពដែលបានលើកឡើងពិតជាមានទំនាក់ទំនងតក្ក ជាមួយនិងលទ្ធផល ដែលបាន សំរេចក្នុងកិច្ចសន្យា ។<br>ឧទាហរណ៍:លទ្ធផលទី ១ ទាក់ទងទៅនិងប្រជាពលរដ្ឋដែលបានទទួល ការយល់ដឹង<br>ច្រើន និងការង្ហាញ ស្តីពី ការទប់ស្កាត់ អំពើហិង្សានៅក្នុងគ្រួសារ មានសកម្មភាពជាក់ លាក់ដូចជាផ្សព្វផ្សាយពីរទិវានារីអន្តរជាតិ០៨ មីនា មានអ្នកចូលរួមចំនួន២៥០នាក់មានរយៈ ពេល១ថ្ងៃ។<br>បណ្តុះបណ្តាលដល់អ្នកទទួលបន្ទុក កិច្ចការ នារី និង កុមារ ដល់ថ្នាក់ដឹកនាំ ស្ត្រីមាន ពីរវគ្គ ០២ថ្ងៃ អ្នកចូល៤០ នាក់ក្នុង ១វគ្គ សរុប ៨០ នាក់។<br>បានចុះធ្វើអន្តរាគមន៍ អំពើហិង្សាក្នុង គ្រួសារ និងបទល្មើសដែលទាក់ទិននារី និងកុមារ នៅ សង្កាត់ទាំង ៨។<br>សកម្មភាពនិមួយៗបានសរសេរបង្ហាញច្បាស់លាស់ ដោយមានចំនួនវគ្គបណ្តុះបណ្តាល និង ចំនួនសិក្ខាកាម ដែលត្រូវចូលរួមក៏ដូចជាឃុំ និងស្រុកគោលដៅ ដែលគ្រប ដណ្តប់។ សកម្មភាពដៃទៀតនៅក្រោមលទ្ធផល បន្តបន្ទាប់ទៀត (លទ្ធផលទី ២ និងទី ៣) ត្រូវបានសរសេរ ក្នុងបែបបទដូចគ្នា នឹង លទ្ធផលទី ១ដែល ។ សកម្មភាព និមួយៗមានទំនាក់ទំនងតក្កភាព ហើយនិង ត្រូវបានបរិយាយ ច្បាស់លាស់ដូច ដែលមាន សរសេរនៅ ក្នុងអនុកិច្ចសន្យា ។ |
| ២ | លទ្ធផល | ៤ | ៥ | លទ្ធផលនីមួយៗ ត្រូវបានសរសេរ បរិយាយច្បាស់លាស់ ដោយមាន សូចនាករ ជាក់សាក់ និងអាចវាស់វែងបាន។ ជាងនេះទៅ ទៀត លទ្ធផល នីមួយៗ |

| | | | | |
|---|---|---|---|---|
| | | | | ផ្សារភ្ជាប់គ្នាល្អ ។លទ្ធផល នីមួយៗជាការបំពេញបន្ថែមអោយគ្នាទៅវិញ ទៅមក ហើយរួមគ្នាបំពេញ គោលបំណង បន្ទាន់។ ទោះបីជាយ៉ាងណាក៏ដោយលទ្ធផល ទាំងនេះនៅមិនអាចធ្វើឲ្យគោលបំណងបន្ទាន់ សម្រេចបាន នៅឡើយ ។ |
| ៣ | គោលបំណងបន្ទាន់ គោល បំណងស្ថិតក្នុងចំនុច (ខ) នៃផ្នែកទី៣ | ៤ | ៤ | គោលបំណងបន្ទាន់នេះត្រូវបានផ្តល់អត្ថន័យយ៉ាងច្បាស់។ ហើយដំណើរការនៃការកាត់ បន្ថយបញ្ហាថយចុះបន្តិចម្តងៗ ។ |
| ៤ | ស្ថានភាពចុងបញ្ចប់អនុកិច្ចសន្យា(ចំណុច -គ - នៃផ្នែកទី៣ ) | ៤ | ៤ | ស្ថានភាពចុងបញ្ចប់នៃអនុកិច្ចសន្យាត្រូវបាន បរិយាយយ៉ាងច្បាស់ ហើយមានទំនាក់ទំនង ផ្ទាល់ទៅនិងលទ្ធផល សកម្មភាពអនុកិច្ច សន្យា ។ ស្ថានភាព ចុងបញ្ចប់នេះបានឆ្លុះបញ្ចាំងក្នុងលទ្ធផល ដែលសម្រេចបានត្រឹមកម្រិតលទ្ធផល ។ ប៉ុន្តែទាំងអ្នកបានចូលរួម ក្នុងវេទិកាទាំងប្រជាពលរដ្ឋ ដែលទទួលបាន ការផ្សព្វផ្សាយគេអាចដោះស្រាយ បញ្ហារបស់ ពួកគេបានមួយកម្រិតធំ ។ |
| ៥ | លទ្ធផលអភិវឌ្ឍន៍\ផលប៉ះពាល់រយៈពេលវែងៈគោលដៅ និងគោលបំណងអភិវឌ្ឍន៍ (ចំនុច-ខ-នៃផ្នែកទី ៣) | | | មិនអាចធ្វើការវាយតំលៃបាន |

**ផ្នែក-ខ: សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោលរពតាមលក្ខខ័ណ្ឌកិច្ចសន្យាការត្រួត ពិនិត្យការធ្វើរបាយការណ៍ និងការកត់ត្រាឯកសារ:**

| លរ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| ១ | ជំនាញរៀបចំកិច្ចសន្យា | នៅមានកម្រិតគួរតែពង្រឹងបន្ថែម |
| ២ | ការគាំទ្រទាល់ពេលវេលា និងការត្រួតពិនិត្យការអនុវត្តន៍របស់ភ្នាក់ងារអនុវត្តន៍ | សមរម្យ -គ្មានការប្រឈម និងឧបសគ្គដែលគួឲ្យកត់ សំគាល់ទេ។ |
| ៣ | ការត្រួតពិនិត្យ និងកត់ត្រាឯកសារអនុកិច្ចសន្យា | ដូចតាមទំលាប់ និងនិតិវិធីដែលបានធ្វើ ។ការកត់ត្រា និងទុកដាក់ឯកសារគួរត្រូវបានកែលម្អ ។ |

| ល-រ | ធាតុ | សង្ខេបការវាយតម្លៃ |
|---|---|---|
| ១ | ជំនាញរៀបចំកិច្ចសន្យា | នៅមានកម្រិតគួរតែពង្រឹងបន្ថែម |
| **ពីខាងភាគីអនុវត្តអនុកិច្ចសន្យា** | | |
| ៤ | ជំនាញគ្រប់គ្រងគម្រោងនិងបច្ចេកទេស | មានបុគ្គលិក ជំនាញ តែមិនទាន់មានធនធានគ្រប់គ្រាន់ |
| ៥ | ការអនុវត្តសកម្មភាពទាន់ពេលវេលា និងលទ្ធផល | ទាន់ពេលដូចដែលបានគ្រោងទុក |
| ៦ | របាយការណ៍រីកចម្រើន និងការកត់ត្រាឯកសារ | ដូចតាមទំលាប់ និងនិតិវិធីដែលបានធ្វើ |
| ៧ | ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា | បានបំពេញត្រឹមត្រូវ |
| **ទាំងខាង គ.អ.ជ.ខ និង ភាគីអនុវត្តអនុកិច្ចសន្យា** | | |
| ៨ | ការគ្រប់គ្រង ហានិភ័យ និង កត្តាសន្មត់ ចំនុចង ផ្នែកទី៣ និងបញ្ហាប្រឈម | - មិនមានបញ្ហាអ្វីកើតឡើងទេ |
| ៩ | ការបញ្ជ្រាបយេនឌ័រ ចំនុច ច ផ្នែកទី៣ | - មិនមានបញ្ហាព្រោះការងារទាំងអស់នេះពាក់ពន្ធ័ស្ត្រី និងបុរស |
| ១០ | ការគ្រប់គ្រងធនធានធម្មជាតិ | -គ្មានបញ្ហាព្រោះមិនទាក់ទង |
| ១១ | ការថែរក្សា(និរន្តភាព) | មន្ទីរកិច្ចការនារីនិងសហការជាមួយអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ សង្កាត់ដើម្បីជំរុញស្ត្រីចូលរួមជាអតិបរិមាជាពិសេសពេលប្រជុំជំហាន២ ក្នុងការរៀបចំកម្មវិធីវិនិយោគ |

## ២-៤ សេចក្តីសន្និដ្ឋាន

| ល.រ | ការសន្និដ្ឋានជារួម |
|---|---|
| ១ | អនុកិច្ចសន្យានេះត្រូវបានអនុវត្តឡើងដូចការគ្រោងទុក។ ភាគីអនុវត្តអនុកិច្ចសន្យាសមត្ថភាព ធនធាន នៅមានកម្រិត ក្នុងការអនុវត្តអនុកិច្ចសន្យា ។ លទ្ធផល និងសកម្មភាព ដែលបានគ្រោងទុកត្រូវបានបញ្ចប់ស្របតាមផែនការ ការងារ ។ |
| ២ | សកម្មភាពរបស់អនុកិច្ចសន្យា និង អត្ថប្រយោជន៍ដែលសហគមន៍ទទួលបាន គឺពួកគាត់ទាំងអស់គ្នាមានសេចក្តីសប្បាយរីករាយ ដែលគម្រោងដ៏មានតម្លៃនេះបានអនុវត្តនិង ផ្សព្វផ្សាយដល់ភូមិ ឃុំរបស់ពួកគាត់ ។ ស្ថានភាពអនុកិច្ចសន្យា ត្រូវអនុវត្តបានជោគជ័យដូចការគ្រោងទុក ។<br>ភស្តុតាង អំពីលទ្ធផល និងផលប្រយោជន៍ទទួលបានដូចខាងក្រោម:<br>- អំពើហិង្សាក្នុងគ្រួសារត្រូវបានកាត់បន្ថយច្រើន<br>- ការជួញដូរផ្លូវភេទពុំសូវមានកើតឡើង |

| | |
|---|---|
| | - សុខមាលភាពមាតា និងទារកត្រូវបានពង្រឹង<br>- ការចំណាកស្រុកមានសល់តិចតួច<br>- មានការកើនឡើងក្នុងការជំរុញកូនអោយទៅរៀន<br>- មានសំណូមពរពីក្រុមគោលដៅភាគច្រើនស្នើអោយមានការផ្សព្វផ្សាយ ពីបញ្ហាយេនឌ័រនេះ អោយបាន ញឹកញាប់តាមភូមិរបស់គាត់តាមដែលអាចធ្វើទៅបាន ។<br>សរុបមកអនុកិច្ចសន្យានេះ បានផ្តល់ប្រយោជន៍ច្រើនដល់ ក្រុមគោលដៅក្នុងសហគមន៍ ព្រោះវាចជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនិងអភិវឌ្ឍន៍សង្គមជាតិរបស់ខ្លួនអោយរីកចម្រើនទៅថ្ងៃអនាគ។ |
| ៣ | ការជ្រើសរើសសិក្ខកាម និងអ្នកទទួលផល នៅក្នុងអនុកិច្ចសន្យា ដោយភាគីអនុវត្តអនុកិច្ចសន្យាផ្ទាល់ នឹងធ្វើអោយមានការធានាថា អ្នកដែលមានតម្រូវការខ្លាំងបំផុតនឹងទទួលបានផលប្រយោជន៍ពីអនុកិច្ចសន្យា។ |
| ៤ | អនុកិច្ចសន្យានេះមិនបាជួបប្រទះនូវឧបសគ្គ និងបញ្ហាប្រឈមគួរអោយកត់សម្គាល់ទេ។ |

## ចំណុចរៀនសូត្រ

| ល.រ | ចំនុចសំខាន់ៗ |
|---|---|
| ១ | ក្រោយពីបានធ្វើការវាយតម្លៃរួចមកសង្កេតឃើញថា ផលប៉ះពាល់របស់អនុកិច្ចសន្យា និងនិរន្តភាពរបស់លទ្ធផលនៅក្នុងអនុកិច្ចសន្យា អាចត្រូវសម្រេចបានកម្រិតខ្ពស់ ប្រសិនបើអនុកិច្ចសន្យា ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹង តម្រូវការជាអាទិភាពរបស់ក្រុមគោលដៅដែលជាអ្នកទទួលផល ។ |
| ២ | ការបរិយាយច្បាស់លាស់នូវ គោលបំណងបន្ទាន់ ក្នុងកម្រិតអាចវាស់វែងបាន ជាកត្តាសំខាន់សម្រាប់ការកត់ត្រាទុក នូវលទ្ធផលរបស់អនុកិច្ចសន្យា និងផលប្រយោជន៍ដែលមាន ដើម្បីងាយស្រួលក្នុងការវាយ តម្លៃ។ |

## អនុសាសន៍

| ល.រ | អនុសាសន៍ |
|---|---|
| ១ | -មន្ទីរកិច្ចការនារីគួរពង្រឹងធនធាន និង ជំរុញបន្ថែមព្រមទាំងមានការលើកទឹកចិត្ត ដល់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារនៅថ្នាក់ឃុំ\សង្កាត់ពិសេសថ្នាក់មូលដ្ឋាន ។ |
| ២ | -មន្ទីរកិច្ចការនារីគួរបណ្តុះបណ្តាលមន្ត្រីជំនាញបន្ថែមក្នុងការរៀបចំសរសេរអនុកិច្ចសន្យាដោយផ្អែកលើលទ្ធផល |
| ៣ | -គ.ជ.អ.ប គួរតែបង្កើនកញ្ចប់ថវិកាលើការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ |

## ឯកសារទី១ ដែលត្រូវភ្ជាប់ជាមួយរបាយការណ៍

| ល.រ | ឈ្មោះឯកសារ | មាន |
|---|---|---|
| ១ | សៀវភៅកិច្ចសន្យា ឆ្នាំ២០០៩ | ✓ |
| ២ | របាយការណ៍បញ្ចប់អនុកិច្ចសន្យាឆ្នាំ ២០០៩ | ✓ |
| ៣ | របាយការណ៍ប្រចាំឆមាស | ✓ |
| ៤ | ផ្សេងៗ | |

## ឯកសារទី២ ៖ ឯកសារអនុកិច្ចសន្យា លេខ 24/GEN/0901-00ខេត្តប៉ៃលិន

| ល.រ | ថ្ងៃ ខែ | ឈ្មោះ និងតួនាទីនៅក្នុងបរិបទអនុកិច្ចសន្យា | ទីកន្លែង | ឧបករណ៍ប្រើប្រាស់សម្រាប់ប្រមូលទិន្នន័យដែលបានប្រើ |
|---|---|---|---|---|
| ១ | ១៤\០៩ | លោក គង់បុន្នី អនុប្រធានមន្ទីរកិច្ចការនារី | មន្ទីរកិច្ចការនារី | សម្ភាសន៍ស៊ីជម្រៅ |
| ២ | ១៤\០៩ | លោកស្រី តុំ ចាន់ថូ ប្រធានការិយាល័យកិច្ចការនារីក្រុង(មន្ត្រីអនុវត្តកិច្ចសន្យា) | មន្ទីរកិច្ចការនារី | សម្ភាសន៍ស៊ីជម្រៅ |
| ៣ | ១៤\០៩ | លោកស្រី ប៊ុត ទូក ប្រធានការិយាល័យកិច្ចការនារីស្រុក(មន្ត្រីអនុវត្តកិច្ចសន្យា) | មន្ទីរកិច្ចការនារី | សម្ភាសន៍ស៊ីជម្រៅ |
| ៤ | ១៥\០៩ | ក្រុមអ្នកទទួលផល | ភូមិទួលនិម្មិត | សម្ភាសន៍ជាក្រុម |
| ៥ | ១៥\០៩ | លោកស្រី ទន់ ស៊ីមែន | ភូមិទួលនិម្មិត | សម្ភាសន៍ស៊ីជម្រៅ\ករណីសិក្សា |
| ៦ | ១៥\០៩ | លោកស្រី  សុខ វណ្ណី | ភូមិទួលនិម្មិត | សម្ភាសន៍ស៊ីជម្រៅ\ករណីសិក្សា |

# ផ្នែកទី៣

# ការឆ្លុះបញ្ចាំងលើ
# របាយការណ៍វាយតម្លៃ
# អនុកិច្ចសន្យា

# ការអនុលោមតាមគោលការណ៍ណែនាំ

- មួយភាគធំនៃរបាយការណ៍មានលក្ខណៈពេញលេញ និងបានអនុលោមតាមគោលការណ៍។

- មួយភាគតូចនៃរបាយការណ៍មានលក្ខណៈច្របូកច្របល់ (សេចក្ដីណែនាំមួយចំនួនមិនបានលុបចេញ)។

# វិធីសាស្ត្រ និងឧបករណ៍វាយតម្លៃ

- លទ្ធផលវាយតម្លៃបានឆ្លុះបញ្ចាំងនូវការប្រើប្រាស់ វិធីសាស្ត្រ និងឧបករណ៍វាយតម្លៃជាប្រព័ន្ធបានមួយកំរិត។

- ការបំប្លែងទិន្នន័យពីសន្លឹកកិច្ចការមកជាព័តមាននិងសេចក្តីសន្និដ្ឋានៅក្នុងរបាយការណ៍ទាមទារឱ្យមានពេលវេលាអនុវត្តបន្ថែមទៀត។

# គុណភាព
# របាយការណ៍

# របាយការណ៍សង្ខេប

- ជារួមរបាយការណ៍សង្ខេបបានគ្របដណ្តប់សមាសភាពទាំង៥នៃរបៀបសរសេររបាយការណ៍សង្ខេប៖
  - *ប្រវត្តិគម្រោង*
  - *គោលបំណងនៃការវាយតម្លៃ*
  - *វិធីសាស្ត្រនៃការវាយតម្លៃ*
  - *លទ្ធផល*
  - *សេចក្តីសន្និដ្ឋាន*

# របាយការណ៍សង្ខេប

- ប៉ុន្តែសមាសភាពទាំងនេះមិនគួរដាក់នៅក្នុងរបាយការណ៍សង្ខេបទេ។
- ខ្លឹមសារនៃការសរសេរមិនទាន់ស៊ីចង្វាក់គ្នាបានល្អនៅឡើយទេ។
- របាយការណ៍សង្ខេបគួរ៖ *ប្រាប់អ្នកអានថាតើយើងវាយតម្លៃអ្វី ដើម្បីអ្វី វាយតម្លៃយ៉ាងដូចម្តេច និងអ្វីដែលបានរកឃើញ។ ការរកឃើញជាចម្បងៗត្រូវតែសង្ខេបយ៉ាងខ្លីនិងមានខ្លឹមសារគ្រប់គ្រាន់។*

# ការវាយតម្លៃការសម្រេចបានរបស់អនុកិច្ចសន្យាក្នុងកម្រិតលទ្ធផល

- តារាងការសម្រេចបានជាក់ស្តែងធៀបនិងផែនការបានបង្ហាញនូវតួលេខស៊ីគ្នា។
- ប៉ុន្តែពាក្យពេចន៍នៅក្នុងជួរឈរអំពីអ្វីដែលសម្រេចបានជាក់ស្តែងគួរធ្វើការកែសម្រួល។
- ការវិភាគ និងការវាយតម្លៃជារួមអំពីលទ្ធផល៖ មានការសន្និដ្ឋានជាក់ស្តែង និងមានហេតុផល ព្រមទាំងអំនះអំនាងដែលបានមកពីការប្រើប្រាស់ឧបករណ៍ត្រឹមត្រូវ។

# ការវាយតម្លៃការសម្រេចបានរបស់ស្ថានភាពរំពឹងទុកនៅពេលបញ្ចប់អនុកិច្ចសន្យា

- គុណភាពនៃព័ត៌មាននៅក្នុងឯកសារអនុកិច្ចសន្យាទំនងជាកម្រិតនូវលទ្ធភាពនៃការវាយតម្លៃ។ ភាគច្រើននៃការរំពឹងទុកនៅចុងបញ្ចប់អនុកិច្ចសន្យាគឺជាតួលេខនៅក្នុងកម្រិតលទ្ធផល។

- ការវិភាគ និងការសន្និដ្ឋានមួយចំនួនគឺបានប្រើប្រាស់ទិន្នន័យដែលមានលក្ខណៈជាប្រព័ន្ធ។

# ការវាយតម្លៃការសម្រេចបាននូវគោលបំណងបន្ទាន់របស់អនុកិច្ចសន្យា

- ភាគច្រើននៃគោលបំណងបន្ទាន់មានលក្ខណៈស្មុគស្មាញ មិនច្បាស់លាស់ និងពិបាកវាស់វែង។
- របាយការណ៍វាយតម្លៃបានបង្ហាញនូវចំនុចខ្វះខាតទាំងនេះដោយយោងលើការសន្និដ្ឋានដែលបានមកពីការវិភាគជាលក្ខណៈប្រព័ន្ធ៖*ការពិនិត្យឯកសារ ការសង្កេត និងទិន្នន័យដែលបានមកពីការសម្ភាសន៍ជាមួយអ្នកដែលពាក់ព័ន្ធ។*

# ការវាយតម្លៃផលប្រយោជន៍ជារួមដែលទទួលបាន

- ភាគច្រើននៃព័ត៌មាននៅក្នុងផ្នែកនេះគឺជាការពិពណ៌នាមិនសូវមានលក្ខណៈជាការវិភាគ និងសន្និដ្ឋានទេ។
- ឃ្លាដំបូងនៃកថាខ័ណ្ឌនិមួយៗគួរតែជាគំនិតវិភាគ និងសន្និដ្ឋាន។ ចំនែកឯកឃ្លារបន្តបន្ទាប់អាចជាការពិពណ៌នា រៀបរាប់ ដោយយោងលើប្រភពទិន្នន័យ ឧទាហរណ៍ដូចជា៖ *ភាគច្រើននៃប្រជាពលរដ្ឋដែលបានចូលរួមការពិភាក្សាក្រុមបានបញ្ជាក់ថា...*

# ករណីសិក្សា

- ការសរសេរភាគច្រើនមានលំដាប់លំដោយ។
- ខ្លឹមសារបានឆ្លុះបញ្ចាំងនូវអត្ថប្រយោជន៍របស់គម្រោង។
- ប៉ុន្តែការសរសេរនៅខ្វះការដកស្រង់សម្តីរបស់អ្នកផ្តល់ចម្លើយ។
- រូបថតភាគច្រើនមិនសូវស៊ីគ្នាទៅនឹងករណីសិក្សា។

# *ភាពជាប់ពាក់ព័ន្ធនៃអនុកិច្ចសន្យាទៅនឹងគម្រោងការ*

- ទោះបីជាមានភាពស្មុកស្មាញនៅក្នុងគោលការណែនាំក៏ដោយ ការវាយតម្លៃនៅតាមផ្នែកនិមួយៗមានអំនះអំនាងនិងការពន្យល់ច្បាស់លាស់។
- ដើម្បីងាយស្រួល ផ្នែកនេះអាចសម្រួលទៅជា៖
  - *សកម្មភាព*
  - *លទ្ធផល*
  - *គោលបំនងបន្ទាន់*
  - *ស្ថានភាពនៅចុងបញ្ចប់អនុកិច្ចសន្យា*

# សមត្ថភាពក្នុងការគ្រប់គ្រងអនុកិច្ចសន្យា ការគោរពតាមលក្ខខណ្ឌកិច្ចសន្យា ការត្រួតពិនិត្យ និងការធ្វើរបាយការណ៍

- ការវាយតម្លៃតាមផ្នែកនិមួយៗ បានបង្ហាញនូវគុណសម្បត្តិ និងចំនុចខ្វះខាត ពោលគឺជាការពិភាក្សាដែលមានមតិស្រប និងមតិផ្ទុយដែលមានអំនះអំនាង។
- ផ្នែកនេះអាចកែសម្រួលដើម្បីឲ្យមានលក្ខណៈងាយស្រួល។

# សេចក្តីសន្និដ្ឋាន

- ជាទូទៅ សេចក្តីសន្និដ្ឋាន មិនមែនជាការសង្ខេបការរកឃើញនៅក្នុងរបាយការណ៍ទេ។
- សេចក្តីសន្និដ្ឋានគួរតែឆ្លើយតបទៅនឹងសំនួរវាយតម្លៃ។
- ភាគច្រើននៃសេចក្តីសន្និដ្ឋានបានឆ្លុះបញ្ចាំងពីការឆ្លើយតបទៅនឹងសំនួរវាយតម្លៃ។
- មានសេចក្តីសន្និដ្ឋានមួយចំនួនមានលក្ខណៈសង្ខេបខ្លីពេក ហើយមិនបានឆ្លើយតបទៅនឹងសំនួរវាយតម្លៃទេ។

# អនុសាសន៍ និងចំនុចរៀនសូត្រ

មួយភាគធំនៃអនុសាសន៍ និងចំនុចរៀនសូត្រនក្នុងរបាយការណ៍បានឆ្លុះបញ្ចាំងនូវគម្លាតដែលបានរកឃើញ និងសំណើដើម្បីកែលម្អ។

# សន្និដ្ឋានជារួមអំពីសមត្ថភាពរបស់ក្រុមអ្នកវាយតម្លៃ

- មានការយល់ដឹងច្រើនអំពីទ្រឹស្តី និងដំណើរការវាយតម្លៃ។
- គួរផ្តល់ការបណ្តុះបណ្តាលជាប្រព័ន្ធអំពីវិធីសាស្ត្រស្រាវជ្រាវសង្គមដើម្បីឱ្យក្រុមអ្នកវាយតម្លៃនៅថ្នាក់ក្រោមជាតិចេះវិភាគ និងសរសេររបាយការណ៍ទៅតាមបច្ចេកទេសនៃវិធីសាស្ត្រនិមួយៗ។
- ដោយសារការវាយតម្លៃគឺជាការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវសង្គម។